# បណ្ដាំព្រះមេមហានគរក្មែរ

ភាគ១



## រូបព្រះនាងនាគ ឬព្រះម៉ែគង់លើនាគ

ឯកសារសាវតាព្រះម៉ែមហានគរ ស្រាវជ្រាវ និងរៀបរៀង

ដោយខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ថុន** អតីតសិស្សសាលាវិចិត្រសិល្បៈ

# <u>អារម្ភបទ</u>

*ហេតុអ្វីបានជាធ្វើឲ្យកើតនៅស្នាដៃ* **អាថ៌កំបាំងបណ្តាំព្រះម៉ែមហានគរខ្មែរ** *នេះ? ខ្ញុំនឹងឆ្លើយរៀបរាប់ដោយត្រួសៗ ដើម្បីឲ្យមិត្តអ្នកអានដែលជាពូជពង្សនាគរួមត្រកូលតែមួយ គឺអ្នកទទួលនូវមរតកព្រះម៉ែដូចគ្នា (ខ្មែរ) ដែលកំពុងតែឆ្ងល់ថាតើខ្ញុំរៀនពីអ្នកណា? ទើបបានជាឯកសារសាវតានេះ ខុសប្លែកពីឯកសារអ្នកជំនាន់មុន ហើយឯកសារនេះកើតឡើងបានពីការឆ្ងល់មិនចេះចប់។*

*ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ ប្រជាជនខ្មែរបានរួចផុតពីការកាប់សម្លាប់ និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ពីបក្សពួកមេដឹកនាំផ្តាច់ការដែលបានគ្រប់គ្រងមាតុភូមិនេះអស់រយៈកាលជាងបីឆ្នាំ។ កូនខ្មែរប្រុសស្រីទាំងឡាយ ចាប់ផ្តើមកសាងជីវិតថ្មីក្នុងទឹកដីមាតុភូមិដ៏សែនកម្សត់នេះឡើងវិញ ក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ពេលនោះពុទ្ធចក្រ និងអាណាចក្រក៏កើតមានឡើងវិញ រួមទាំងខ្ញុំបាទផងក៏បានចូលសាលាបន្តការសិក្សាតចំណេះ ដែលមានតិចតួចមុនសម័យកម្ពុជាប្រជាធិបតេយ្យ (សម័យសាធារណរដ្ឋខ្មែរ) ដើម្បីឲ្យការចេះដឹងមានការកើនឡើង។ ក្នុងឆ្នាំ១៩៨២ ខ្ញុំបានទៅប្រឡងជាប់នៅសាលាវិចិត្រសិល្បៈ ហើយបានសិក្សាផ្នែកប្រវត្តិសិល្បៈ និងមុខវិជ្ជាដទៃទៀត រួមទាំងជំនាញសិល្បៈផ្សេងៗ ពេលនោះការឆ្ងល់សង្ស័យក៏ចាប់ផ្តើមកើតមានក្នុងសន្តានចិត្តខ្ញុំ ថាតើប្រជាជនខ្មែរទាំងក្មេងចាស់ ប្រុសស្រីរួមទាំងខ្ញុំ និងញាតិទាំងអស់របស់ខ្ញុំ តើពួកគាត់មានកំហុសអ្វី? ទើបត្រូវបានគេយកទៅសម្លាប់ និងធ្វើទារុណកម្ម ក្នុងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ហើយខ្ញុំឆ្ងល់ទៀតថា ដូនតាអ្នកនគរនេះ ធ្លាប់ជាពូជពង្សរុងរឿងថ្កុំថ្កើង ហេតុអ្វីក៏ក្រោយពេលដែលខ្មែរបានបោះបង់ចោលក្រុងអង្គរ ប្រទេសចាប់ផ្តើមបែកបាក់ និងធ្លាក់ដុនដាបយ៉ាងនេះ? អ្នកនគរនេះជាអ្នកកាន់ និងគោរពព្រះពុទ្ធសាសនា ហេតុអ្វីក៏ពួកគេមិនដឹងបុណ្យបាប គុណទោស.... ជាពិសេសគឺសម័យផ្តាច់ការ កម្ពុជាប្រជាធិបតេយ្យដែលអ្នកដឹកនាំក្នុងសម័យនោះ ភាគច្រើនសុទ្ធតែជាអ្នកធ្លាប់បានបួសរៀន ហេតុអ្វីក៏ពួកគេប្រព្រឹត្តនូវកម្មអកុសលយ៉ាងនេះ? ការឆ្ងល់និងសង្ស័យនេះ ចេះតែកើតមានក្នុងចិត្តរបស់ខ្ញុំ ហើយចំងល់ទាំងនេះខ្ញុំពុំហ៊ានសួរគ្រូឡើយ ព្រោះខ្លាចគាត់យល់ថាយើងឆ្ងល់ពុំសមហេតុផល។ មានពេលមួយខ្ញុំសាកសួរគាត់ ពីប្រស្នាសិល្បៈរូបចម្លាក់នាគខ្មែរ ហេតុអ្វីក៏នាគខ្មែរមានតែក្បាលឯខ្លួនត្រូវសត្វម្ករលេប គាត់ឆ្លើយថា នេះគឺជាសិល្បៈដែលដូនតាបានរចនាឡើង ចម្លើយដែលគាត់បានឆ្លើយនេះខ្ញុំពុំអស់ចិត្តឡើយ ព្រោះសត្វនាគដែលត្រូវ*

គេលេបដល់**ក** ទៅហើយនោះ ពេលដែលត្រូវលាងខ្លួនឬងូតទឹក និងអេះនូវរមាស់ដែលកើតនៅលើកាយ តើត្រូវអេះទៅលើអ្វីបើជាខ្លួនរបស់គេយ៉ាងនោះ? ចំងល់នេះ១៦ឆ្នាំក្រោយ ទើបចាប់ផ្ដើមមានពន្លឺព្រាលៗម្ដងបន្តិចៗ ព្រោះក្នុង**ឆ្នាំ១៩៩៨** ក្នុងរាត្រីមួយនោះខ្ញុំបានជួបនឹងស្ត្រីម្នាក់ក្នុងសុបិន្ត ដែលក្នុងសុបិន្តនោះស្ត្រីដែលខ្ញុំបានជួប **គាត់មានអាយុរហូតដល់១៩៩៨ឆ្នាំ**តែគាត់មិនទាន់ស្លាប់នៅឡើយ ហើយជាអ្នកមានទោសជាប់ខ្លួនទៀតផង (អ្នកងារខ្ញុំឆ្ងល់ថាតើស្ត្រីនោះជាអ្នកណា? ហេតុអ្វីបានជាគាត់ត្រូវជាប់ទោស? ដូច្នេះតាំងពីឆ្នាំនោះ មកទល់នឹងពេលនេះ (**២០០៩**) ខ្ញុំត្រូវស្វែងរកប្រវត្តិសាវតាររបស់ស្ត្រីនេះ អស់រយៈពេលជាង១១ឆ្នាំ ទើបដឹងថាគាត់ជាអ្នកណា ដែលខ្ញុំនឹងបកស្រាយពន្យល់នៅក្នុងឯកសារសាវតាបណ្ដាំព្រះម៉ែមហានគរក្មែរ ភាគ១ ភាគ២ និងភាគ៣នេះ **ដែលស្នាដៃនេះកេតឡើងពីការឆ្ងល់ហើយឆ្ងល់ទៀត** ពុំចេះចប់។ ហើយស្នាដៃនេះនឹងបានបើកបង្ហាញនៅបឋមក្សត្រ គឺអ្នក **ក+កើត** កំណើតនគរ និងជា អ្នកបង្កើតនូវប្រែកពមោទនភាព និងអច្ឆរិយជាតិ ដែលមិនចេះរីងស្ងួតពីសម័យអតីតកាល ហើយ**កេរ** នេះបានបន្សល់ទុករហូតមកដល់បច្ចុប្បន្ន ដែលយើងជាកូនក្មែរកំពុងទទួលនៅកេរមរតករបស់គាត់គ្រប់ៗគ្នា។

ដូច្នេះសូមកូនក្មែរប្រុសស្រីតាមដាននិងពិចារណាឈ្វេងយល់ ពីរអាទិទេពដើមរបស់យើងតាមរយៈស្នាដៃនេះថា តើគាត់ជា នរណាហ្ន៎? តើគាត់បំពេញពលិកម្មគ្រប់បែបយ៉ាងនេះដើម្បីអ្នកណា? ហើយតើគាត់នៅរង់ចាំអ្វី? ចម្លើយទាំងអស់នេះនឹងមានបកស្រាយតាមលំដាប់លំដោយដែលមានរៀបរាប់ក្នុង**អាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរក្មែរ** ឬ **សាសនអច្ឆរាមហាតាមហានគរ** ។

គេហទំព័រ: http://www.kietchanthon.blogspot.com / http://www.kietchanthon.info

អ៊ីម៉ែល: kietchanthon@gmail.com / info@kietchanthon.info

ឯកសារសាវតាព្រះម៉ែនេះ ស្រាវជ្រាវ និងចងក្រងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្ប:

# អាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរក្មែរ

*អាណាចក្រខ្មែរ(ក្មែរ) មហានគរក្មែរជាមហានគរដែលមានភាពរីកចម្រើនខ្លាំង ខាងការគ្រប់គ្រង ការកសាង និងមានកិត្តិស័ព្ទល្បីល្បាញរន្ទឺសុះសាយពាសពេញជ្រោយសុវណ្ណភូមិ ព្រមទាំងធ្វើការគ្រប ដណ្ដប់លើបណ្ដាប្រទេសជាច្រើននៅក្នុងទ្វីបអាស៊ីពីអតីត។ តើហេតុដូចម្ដេចបានជានៅសម័យក្រោយ មហានគរ ក្មែរយើងបែរជាធ្លាក់ចុះនិងអន់ថយទៅវិញ ក្នុងការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងប្រវត្តិ* ***ជនជាតិក្មែរ*** *ពួកគាត់ (អ្នកស្រាវជ្រាវប្រវត្តិជនជាតិក្មែរ) តែងតែមានការស្រពិចស្រពិលពីដើមកំណើត នៃជនជាតិក្មែរនេះ។ ទាំងអស់នេះ ចោទជាបញ្ហាដែលនាំឲ្យអ្នកស្រាវជ្រាវទាំងឡាយ ទាំងជនជាតិក្មែរ ជនជាតិបរទេសដែលពុំបានដឹង មានការងឿងឆ្ងល់ ហើយចង់ដឹងពីការពិត អំពីប្រវត្តិជនជាតិក្មែរ ក៏ដូច ជាវប្បធម៌ អរិយធម៌ជាតិ។ យ៉ាងណាមិញ អ្នកស្រាវជ្រាវសម័យមុនៗ (សូមមិនលើកយកពីអ្នក ស្រាវជ្រាវបរទេស) មានដូចជាលោក* ***ឈឹមក្រសេម*** *លោក* ***រស់សារ៉េត*** *លោក****ពៅឈិន*** *លោក****មាសហាំ*** *លោក****ហ៊ឹមខាន់*** *លោក****ឆត្រាប្រេមឬឌី*** *លោក****កេងវ៉ាន់សាក់****......។ ទស្សនៈរបស់លោកទាំងនោះ សុទ្ធតែ មានទំនោរទាញទៅរកបរទេស គឺភាគច្រើនៗទាញប្រភពដើមកំណើតជនជាតិក្មែរនេះទៅរកឥណ្ឌា។ ប៉ុន្តែក្នុងនោះមានទស្សនៈរបស់លោក* ***កេងវ៉ាន់សាក់*** *ដែលបានបង្ហាញពីដើមកំណើតមេខ្លះៗ ប៉ុន្តែមិន សូវជាច្បាស់លាស់ ព្រោះខ្វះឯកសារសម្រាប់ពន្យល់បញ្ជាក់។ ដូច្នេះក្នុងនាមខ្ញុំបាទ ជាកូនក្មែរម្នាក់ដែល កើត និងកប់ទងសុក នៅទីបំផុតនឹងត្រូវកប់សាកសពនៅលើទឹកដីក្មែរនេះ ខ្ញុំបាទនឹងខិតខំស្រាវជ្រាវរាវ រកការពិត ពីដើមកំណើតរបស់ជនជាតិនេះ ដើម្បីយកមកបើកបង្ហាញពីបុគ្គលមានឧបការគុណ ដែល បានបង្កើតនូវភាពអច្ឆរិយៈជាតិ ហើយគាត់បានលិចកប់បាត់ក្នុងអតីតកាល តាមរយៈស្នាដៃខ្លី* ***អាថ៌ កំបាំងបណ្ដាំព្រះម៉ែមហានគរ****ដែលនឹងត្រូវបានបើកបង្ហាញជូននេះ។ ខ្ញុំបាទសង្ឃឹមថា កូនក្មែរទាំងឡាយ ដែលមានពូជពង្សឈាមជ័រជាក្មែរ ជាពូជនាគ ហើយមានចិត្តស្រឡាញ់ជាតិចង់ដឹងរឿងពិត ពីមហា នគររបស់ខ្លួនក្នុងអតីតនោះ នឹងធ្វើការតាមដានត្រិះរិះពិចារណា និងឈ្វេងយល់នូវអ្វីដែលខ្ញុំបានស្រាវ ជ្រាវ ហើយខ្ញុំព្រះករុណាខ្ញុំបាទក៏រង់ចាំទទួលនូវការរិះគន់ ពីមិត្តអ្នកអានគ្រប់ពេលវេលា ក្នុងន័យជួយ ស្ថាបនាឯកសារសាវតានេះ ឲ្យបានកាន់តែប្រសើរឡើង ដើម្បីទុកជាមរតកគំនិតថ្មី ដល់កូនក្មែរជំនាន់ ក្រោយហើយខ្ញុំក៏សង្ឃឹមថា ឯកសារសាវតានេះ នឹងបានបើកបង្ហាញពីប្រវត្តិជាតិក្មែរមួយ* ***ដែលឈរលើ***

**ដែនដីព្រះម៉ែនាគដ៏ពិតប្រាកដ** ដោយមិនឈរលើក្បួនបរទេសទៀតឡើយ ។ ហើយនៅក្នុងទំព័រនៃអាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរនេះ ខ្ញុំសូមសរសេរពាក្យ ( ក្មែរ = ខ្មែរ ) តាមពាក្យដែលដូនតាយើងធ្លាប់បានចារឹកទុកនៅលើ ផ្ទាំងសិលានៅតាមប្រាសាទនានា សម្រាប់ជាទុនក្នុងការសិក្សាស្រាវជ្រាវ នឹងទុកជាកេរតំណែលឲ្យកូនក្មែរ ជំនាន់ក្រោយធ្វើជាឯកសារ អត្ថបទនេះគឺជា **ភាគទីមួយ** ហើយខ្ញុំនឹងខិតខំស្រាវជ្រាវនូវ**ភាគទីពីរ និងភាគទីបី**មកពន្យល់បកស្រាយជាបន្តបន្ទាប់។

# I. ការបង្កើតពូជមេ ឬក្មេរ

ក្មេរ = កេរ + មេ = កេរមរតករបស់មេ ឬកេរតំណែលមេ

**ក/.ប្រវត្តិ**អតីតកាលនៃនគរនេះគឺជា នគរស្ត្រី (នគរមេ ឬក្មេរ = កេរ + មេ) ដែលមានស្ត្រីជាអ្នកដឹកនាំ។ នៅក្នុងសាវតារឿងព្រេងចិន គឺរឿង "ថាងចេងចម្លងធម៌" ពួកគេបានដើរឆ្លងកាត់នគរមួយឈ្មោះថា "នគរស្ត្រី" ឬ "នគរស្រីល្វោ" សព្វថ្ងៃទីតាំងនេះស្ថិតនៅក្នុងប្រទេសសៀម(ថៃ) ហៅថាខេត្ត ល្វោ ឬលពបុរី" ដែលពីដើមខេត្តនេះ គឺជាទឹកដីដើមដំបូងរបស់មេ (ក្មេរ ⇨ ក្មែរ)។

## ពន្យល់ពាក្យ

ល្វោ ➔ ល្វតល្វន់ ➔ ដំណើរទន់ភ្លន់របស់ស្ត្រី

នគរហ៊្វូណាន = មកពីពាក្យក្បាច់គុនចិនម្យ៉ាង ឈ្មោះថា(កុងហ៊្វូ ឬ ក្បាច់គុនកុងហ៊្វូ) ព្រោះក្បាច់គុននេះ វាមានកាយវិការទន់ដូចកាយវិការស្ត្រី ដូច្នេះហើយបានជាចិនហៅឈ្មោះអ្នកនគរ ដែលមានមេដឹកនាំជាស្ត្រីនេះថា "ហ៊្វូណាន" ទៅតាមកាយវិការទន់របស់ស្ត្រី (នៅក្នុងឯកសារប្រវិត្តិសាស្ត្រខ្មែរ)។

ជនជាតិនេះជាអ្នកទទួលមរតករបស់បុព្វជនខ្លួនគឺ **មេ** ទើបនៅសម័យនោះគេហៅអ្នករស់នៅក្នុងនគរនេះថាជា **ជនជាតិក្មេរ** ដែលនៅសិលាចារឹកបុរាណមានសសេរពាក្យនេះ ក្មេរ = កេរ + មេ មានន័យ ថាអ្នកទទួលមរតកមេ ឬកេរតំណែលមេ (ក្មេរ)។

**ខ/.**ដោយផ្អែកទៅលើការបកស្រាយខាងលើ យើងអាចទាញយកនូវហេតុផលពីអតីតកាល ដែលមានទាក់ទងក្នុងរឿងព្រេងរបស់ក្មែរ ក្នុងការ**ក**កើតទឹកដី គឺ**រឿងព្រះថោងនាងនាគ** មកធ្វើការបកស្រាយ

បន្ថែម តែពេលនេះ ខ្ញុំពុំលើកពី**ព្រះថោង**ឡើយ ព្រោះគាត់គឺជាអ្នកចំណូលថ្មី ទើបមកនៅខាងក្រោយ ដូច្នេះខ្ញុំលើកតែព្រះនាងនាគ មកបកពន្យល់តែប៉ុណ្ណោះ។ ព្រោះ**ព្រះនាងនាគ**ជាបុព្វហេតុដែលនាំឲ្យកើតពាក្យថា **មេ ឬ ខ្មែរ** នេះ ពាក្យ**ព្រះនាងនាគ** ប្រសិនបើយើងមិនមើលការពន្យល់បកស្រាយឲ្យបានក្បោះក្បាយ និងត្រឹមត្រូវនោះទេ ប្រាកដជានឹងមានការយល់ច្រឡំទៅលើ**សត្វនាគ**ជាមិនខាន ព្រោះមកទល់នឹងសព្វថ្ងៃនេះ យើងនៅតែច្រឡំថាពូជខ្មែរនេះ កើតចេញពីសត្វនាគដោយសារតែការមិនបានបំបែកភាសាគំនិតក្នុងរូបចម្លាក់ថ្ម ដែលបុព្វបណ្ឌិតយើងបានឆ្លាក់ចារឹកទុកលើប្រាសាទថ្មរាប់រយពាន់ និងកប់ទុកនៅក្នុងប្រពៃណីទំនៀមទម្លាប់ សាសនា ទំនាយ.... សម្រាប់ឲ្យមនុស្សជំនាន់ក្រោយសិក្សាឈ្វេងយល់។ ប្រសិនបើយើងត្រិះរិះពិចារណាតាមហេតុផល ដែលមាននៅក្នុងទ្រឹស្ដី**ព្រះសម្មាសម្ពុទ្ធបរមគ្រូ**នៃយើងព្រះអង្គពន្យល់ថា មនុស្សកើតមកពីមនុស្ស តិរច្ឆានកើតមកពីតិរច្ឆាន វាពុំអាចមានមនុស្សណាកើតកូនមកជាតិរច្ឆាន ឬ តិរច្ឆានកើតកូនមកជាមនុស្សនោះឡើយ (នាគជាសត្វតិរច្ឆាន)។

***ចុះហេតុអ្វីបានជាម្ចាស់នគរខ្មែរ មានឈ្មោះថា ព្រះនាងនាគ ទៅវិញ? តើព្រះនាងនាគហេតុអ្វីបានជាបង្កើតពូជពង្ស មកដល់សព្វថ្ងៃនេះទៅជាមនុស្ស ឈ្មោះ (ខ្មែរ )ព្រះនាងនាគ ព្រះនាងសក់ក្រអូបក្រពុំឈូក វិមានច័ន្ទ រំសាយសក់ ទិព្វសេតាច័ន្ទ...(ចិន) លីវយី... (ឥណ្ឌា) សោមា មេរា ខេមា ឧមាវតី...។***

ហេតុដូច្នេះ សូមកុលបុត្រកុលធីតាខ្មែរ ប្រុសស្រីទាំងអស់ តាមដាន និងពិចារណានូវការបកស្រាយ ពន្យល់ពីពាក្យថា**នាគ**នេះ ដែលមានពន្យល់នៅក្នុងវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** (ភាគ ១+២)។

***គ/.*<u>*ពន្យល់ពាក្យ*</u>** (ពាក្យ**នាគ**)

១/. នាគ (ន) ប្រសើរចម្បងបរិសុទ្ធ...

២/. នាគ (ន) ព្រះសម្មាសម្ពុទ្ធឬព្រះពុទ្ធនាគ(ក៏ហៅថានាគ)

៣/. នាគ (ន) ព្រះបច្ចេកពុទ្ធ (ក៏ហៅថានាគ)

៤ /.នាគ (ន) ព្រះអរហន្តទាំងអស់ (ក៏ហៅថានាគ)

៥/. នាគ (ន) ព្រះអនាគាមិបុគ្គល អរិយផ្នាក់ទីបី (ក៏ហៅថានាគ)

៦/. នាគ (ន) ព្រះសោតា ព្រះសកទាគាមី អរិយៈថ្នាក់ទីមួយ ទីពីរ (ក៏ហៅថានាគ)

៧/. នាគ (ន) បុគ្គលជាបុថុជ្ជនណាមួយដែលមានសេចក្តីអៀនខ្មាស ខ្លាចបាបប្រឹងប្រែងវៀរចាកនូវបាបសមាទានសីល( សីល៥ សីល ៨ សីល ១០...) (ក៏ហៅថានាគ)

៨/. នាគ(ន)កុលបុត្រដែលមានការចុញទ្រាន់ក្នុងការគ្រប់គ្រងផ្ទះសម្បែង ហើយមានចិត្តជ្រះថ្លាចូលសាងផ្នួសបួសជាភិក្ខុសាមណេរ ក្នុងព្រះពុទ្ធសាសនាប្រព្រឹត្តនូវព្រហ្មចរិយធម៌ (ធ្វើកូននាគ ក៏ហៅថានាគ)

៩/. នាគ (ន) ពស់ដែលមានអនុភាពចម្បង ដែលធំ(ក៏ហៅថានាគ)

១០/. នាគ (ន) ដំរីដែលមានរូបរាងសាកសមប្រសើរ(ក៏ហៅថានាគ)

១១/. នាគ (ន) ដើមខ្លឹងសំណ (ក៏ហៅថានាគ)

បើតាមការពន្យល់នូវពាក្យខាងលើគឺអត្ថន័យពាក្យ**នាគ** មានរហូតដល់ទៅដប់មួយពាក្យ ដូច្នេះពាក្យថា**ព្រះនាងនាគ** នៅក្នុងរឿង ឬព្រះម៉ែនាគ **តើស្ថិតនៅក្នុងនាគមួយណា?** សូមប្រិយមិត្តអ្នកអានជាពិសេសគឺកូនក្មេរប្រុសស្រី ចូរពិចារណាហេតុផល តាមការយល់ឃើញរបស់ខ្លួនចុះ កុំចេះតែជឿទៅលើការបកស្រាយរបស់អ្នកខាងក្រៅ (**បរទេស**) ក្រៅពីជាតិខ្លួន។

**ឃ**/.ខ្ញុំបានពន្យល់ណែនាំពីខាងដើមរួចហើយថា នគរនេះគឺជានគរស្ត្រី ឬនគរ **មេ** ដូច្នេះពាក្យថា មេ មានន័យថា មុខគេ មុនគេ ឬ ធំជាងគេ ប្រសើរជាងគេ រុងរឿងជាងគេ ជាពិសេសគឺគ្រប់គ្រងលើគេ ។ល។ រហូតក្នុងប្រវត្តិសាស្ត្របានរៀបរាប់បញ្ជាក់ប្រាប់ថា នគរ**មេ**ពីអតីតមានស្តេចជាចំណុះឲ្យរាប់រយប្រទេស ដែលប្រទេសទាំងនោះតែងតែយកសួយសារអាករ មកឲ្យប្រទេស **មេ** ឬនគរ**មេ** ព្រះនាងនាគ ដែលជាស្ត្រីចម្បង ដូចបានពន្យល់ន័យរបស់ពាក្យក្នុងវចនានុក្រមស្រាប់ហើយ។ ទាំងអស់នេះហើយ ដែលមកដល់សព្វថ្ងៃ ទម្លាប់នៃជនជាតិនេះ តែងតែប្រើពាក្យ **មេ**ជាប្រមុខ ជាធំ (**គេរ + មេ = ក្មេរ**) សូមទាញយកឧទាហរណ៍មកពន្យល់បញ្ជាក់ជូនខាងក្រោម ៖

១. ផ្នែកខាងអវយវៈ ប៉ែកខាងធំយើងតែងតែហៅថា មេ ឧ. មេដៃ មេជើង...។ល។

២. ផ្នែកខាងការដឹកនាំ**ល្អ** ឧ.មេគ្រួសារ មេភូមិ មេឃុំ មេស្រុក មេទ័ព មេដឹកនាំ មេបុណ្យ មេពួក មេក្រុម មេគយ មេកន្ទ្រាញ...។ល។

៣. ផ្នែកខាងការដឹកនាំ**អាក្រក់** ឧ.មេចោរ មេពុករលួយ មេខូច មេបន មេធ្មប់ មេប្លាប ...។ល។

៤. ផ្នែកខាងគ្រឿង**ស្រវឹង** ឧ.មេស្រា មេត្រប៉ែ មេទឹកត្នោតជូរ ...។ល។

៥. ផ្នែកខាង**ទំនៀមទំលាប់ប្រពៃណី** ឧ.មេបា មេអណ្តើក មេខ្មែរ ...

៦. ផ្នែកខាង**សំណង់** ឧ.មេការ មេជាង មេដំបូល មេគ្រែ មេជណ្តើរ មេសោ មេរត...។ល។

៧. ផ្នែកខាង**គណិតវិទ្យា** ឧ.មេលេខ មេនព្វន្ត មេគុណ មេចែក...។ល។

៨. ផ្នែកខាង**អក្សរសាស្ត្រ** ឧ.មេសូត្រ មេកាព្យ មេពាក្យ...។ល។

៩. ផ្នែកខាង**ធម៌អាថ៌** ឧ.មេវត្ត មេកុដិ ធម៌មួយមេ ឬ ពីរមេ មេគណ...។ល។

១០. ផ្នែកខាង**យុត្តិធម៌** ឧ.មេធាវី ...។ល។

១១. ផ្នែកខាង**ដី** និង**ភ្នំ** ឧ.ព្រះមេ (ទឹក ដី) (ស្តេចភ្នំ) គឺភ្នំព្រះសុមេរុ ឬភ្នំព្រះសុមែរុ...។ល។

១២. ផ្នែកខាង**ទឹក** ឧ.មេទឹក មេកុង ឬមេគង្គ មេណាម ភ្លៀងមួយមេ ប្រឡាយមេ...។ល។

១៣. ផ្នែកខាង**រោគ** ឧ.មេរោគ មេក្រមី មេក្រុប...។ល។ (និងមានពាក្យថាមេ ច្រើនទៀត)

សរុបសេចក្តីមកពាក្យថា**មេ** បើបុព្វជននគរនេះពុំមែនជាស្ត្រី ឬជាអ្នកដឹកនាំស្ត្រីធ្វើដូចម្តេច ទើបពាក្យនេះ អាចបន្សល់ទុករាប់ពាន់ឆ្នាំ រហូតដល់បច្ចុប្បន្នបាន។ ដូចពាក្យមួយទៀត ដែលចាស់ៗតែងតែតំណាលប្រាប់កូនៗ ពេលដែលកំពុងហូបបាយគាត់ប្រាប់និងពន្យល់ថា ៖ **កូនហូបបាយ កុំឲ្យ កំពុប** ព្រោះត្រូវដឹងគុណ**ព្រះមេ** (ព្រះម៉ែ) ព្រោះព្រះមេចិញ្ចឹមមនុស្សមួយនគរ។ ពាក្យនេះ ប្រសិនបើយើងមិនដឹងពីអាថ៌កំបាំងនៃពាក្យឲ្យបានច្បាស់លាស់ទេ មុខជាយល់ច្រឡំថា ឲ្យដឹងគុណ**បាយ ឬអង្ករ**... តាមពិតពុំមែនដូច្នោះឡើយ គឺគាត់ (ព្រះម៉ែ) ពន្យល់ឲ្យយើងដឹងគុណម្ចាស់ដី ម្ចាស់នគរ **ប្រទេស** ព្រោះម្ចាស់

នគរនេះបានទុកកេរដំណែលរបស់គាត់ឲ្យយើងទទួលមកទល់នឹងសព្វថ្ងៃ ហើយដែលនគរមេនេះ (**ក្មេរ**) ក្រោយមកបាន ក្លាយជានគរម៉ែ (ក្មែរ) នេះឯង ។

បាយកើតពីអង្ករៗកើតពីស្រូវៗកើតពីសំណាបឬសន្ទូង ដែលគេយកទៅស្ទូង តើអ្នកស្រែទាំងអស់នោះ បានយកសន្ទូងរបស់ពួកគាត់**ទៅស្ទូងឯណា?** គឺពួកគាត់យកវាទៅស្ទូងនៅលើទឹកដីដែលជាដីកេរមរតករបស់**ព្រះមេ**នេះឯង។ បកស្រាយមកដល់ត្រង់នេះ ទើបយើងយល់ថា ពីមុនយើងតែងច្រឡំថាបាយមានគុណ ប៉ុន្តែតាមពិតគឺម្ចាស់នគរដែលយើងបានកើត និងកំពុងរស់នៅលើទឹកដីរបស់គាត់សព្វថ្ងៃនេះទេ ដែលជាអ្នកមានឧបការគុណ ព្រោះបុព្វជនមេនេះបានទុកទឹកដីវប្បធម៌អរិយធម៌ សាសនា..... ឲ្យកុលបុត្រកុលធីតាប្រុសស្រី ទាំងអស់ បានទទួលមរតករបស់គាត់គ្រប់ៗគ្នា។

សរុបសេចក្ដីមក ដោយអនុភាពជាធំរបស់ **មេ**ពីអតីតនោះហើយ ទើបធ្វើឲ្យកូនក្មែរសម័យក្រោយស្គាល់ពាក្យនេះច្បាស់ ព្រោះថាវាជាពាក្យក្មែរសុទ្ធសាធ សូម្បីតែអ្នកពុំបានសិក្សារៀនសូត្រឲ្យបានត្រឹមត្រូវ ក៏គង់ចេះនិយាយ បានដឹងបានឮនូវពាក្យនេះរត់មាត់ សុំាត្រចៀកអស់ទៅហើយដែរ។ ដូច្នេះសូមកូនក្មែរទាំងអស់ ដែលកំពុងរស់នៅទទួលមរតកមេ អ្នកត្រូវចេះត្រិះរិះពិចារណាវែកញែកស្វែងរកការពិត នៃប្រវត្តិខាងដើមជនជាតិរបស់ខ្លួន មិនត្រូវពឹងផ្អែកទៅលើការស្រាវជ្រាវរបស់បរទេសទាំងស្រុងនោះទេ **បើយើងពឹងលើបញ្ញាគេ ឬខួរក្បាលគេ គេច្បាស់ជាកុហកយើង ឬក៏បំភាន់យើងជាមិនខានឡើយ ព្រោះពុំមានជនបរទេសណា ម្នាក់ស្រឡាញ់ក្មែរ ជាជាងក្មែរស្រឡាញ់ប្រទេសខ្លួនឯងនោះឡើយ ហើយក៏គ្មានជនបរទេសណាដែលស្មោះត្រង់នឹងយើងនោះដែរ។**

ដូច្នេះហើយ ទើបពួកបរទេសមានសុភាសិតមួយឃ្លាថា: **បើចង់គ្រប់គ្រងជនជាតមួយ ឬប្រទេសមួយត្រូវតែធ្វើឲ្យ ជនជាតទាំងនោះល្ងង់ ឬដេកលក់សិន ទើបងាយស្រួលគ្រប់គ្រង** ហើយបើពួកគេចង់គ្រប់គ្រងពូជនាគ ត្រូវតែធ្វើឲ្យពូជនាគនេះ ក្លាយទៅជាពស់ដែល**អត់ពិស**សិន ទើបងាយគ្រប់គ្រងងាយដឹកនាំ។ ការពន្យល់ដោយសង្ខេបនេះ យើងអាចយល់បានកាន់តែច្បាស់ពីកា**រក**កើតនៃពូជមេ ឬការ**ក**កើតនៃពូជនាគ ឬនគរនាគ(មាតុភូមិ) ការបកស្រាយពន្យល់ដោយត្រួសៗខាងលើ គ្រាន់តែជាគោលគំនិតសម្រាប់មិត្តអ្នកអានប្រុសស្រី ទុកជាទុនពិចារណាស្វែងរកសារវតាពិតរបស់ជាតិ (យើងមិនអាចឈរនៅលើក្បួនបរទេសទៀតឡើយ យើងត្រូវតែឈរនៅលើ**ដនដីមេ**ដោយពិតប្រាកដ)។

*យើងនឹងធ្វើការស្វែងយល់ពីវិវឌ្ឍនាការនៃពាក្យ* ***មេ ឬក្មេរ = កេរ + មេ → ទៅជាពាក្យក្មែរ =កេរ + ម៉ែ*** *តាមដំណើរវិវឌ្ឍន៍នៃធម្មជាតិ ដែលខ្ញុំនឹងបកស្រាយពន្យល់ជាបន្ត។*

## <u>II. វិវឌ្ឍនាការពីក្មេរទៅក្មែរ</u>

*ក្មែរ = កេរ + ម៉ែ = អ្នកទទួលកេរមរតករបស់ព្រះម៉ែ ឬកេរតំណែលព្រះម៉ែ*

***ក***/.*ដោយការរីកចម្រើននៃអនុភាពមេ ដែលល្បីខាងសោភ័ណភាព (អប្សរា ឬអច្ឆរា អ្នកមានលោមពណ៌ល្អ) និងភាពថ្កុំថ្កើងរុងរឿងដ៏ចម្បងនោះហើយ ធ្វើឲ្យបច្ចាមិត្រចូលមកលុកលុយហើយ ដណ្ដើមយក រហូតទាល់តែបានសម្រេច។ ក្នុងសាច់រឿង**ព្រះថោងនាងនាគ** យើងដឹងហើយថា មានបុរសម្នាក់ឈ្មោះ **ព្រះថោង** ដែលមាននៅក្នុងប្រវត្តិសាស្ត្រក្មែរ ហើយចិនហៅថា **ហ៊ុនទៀន** ឥណ្ឌាហៅថា **កៅណ្ឌិន ឬឥសីកម្ពុ**.... ដែលបានចូលមកឈ្លានពាន ប្រយុទ្ធប្រឆាំង តតាំងជាមួយព្រះនាងនាគ ដែលជាប្រមុខនគរក្មេរ ទីបំផុតព្រះនាងនាគត្រូវចាញ់នូវមន្តស្នេហ៍ សណ្ដំរបស់ព្រះថោង ព្រោះអ្នកនៅឯនាយសមុទ្រ ពូកែខាងប្រើមន្តស្នេហ៍ ហើយព្រះនាងនាគក៏បានដាក់ចិត្តដាក់កាយ ក្លាយទៅជាមហេសីរបស់ព្រះថោង ដែលជាអ្នករស់នៅស្រុកឆ្ងាយនោះទៅ។*

***ខ***/.*ការប្រែប្រួលវិវឌ្ឍន៍របស់ប្រទេស ត្រូវផ្លាស់ពីក្មេរទៅក្មែរវិញ ព្រោះជាតិជាស្ត្រីរាល់រូប ពេលណាដែលមានស្វាមីឬប្ដី រមែងតែងមានបុត្រជាដាច់ខាត ទាំងនេះគឺជាច្បាប់របស់ធម្មជាតិ។ ពាក្យថា* ***ក្មេរ = កេរ + មេ*** *(េ◌) ត្រូវផ្លាស់ជា* ***ក្មែរ = កេរ + ម៉ែ (ែ◌)****ព្រោះស្ត្រីនោះ ត្រូវបន្ថែមនូវទម្ងន់ទុក្ខមួយទៀត គឺស្រៈ* ***(ែ◌)*** *មានន័យថា**កូន**។ ពីមុន មានខ្លួនតែម្នាក់ឯង ពុំសូវមានទុក្ខច្រើន ប៉ុន្តែពេលដែលមានស្វាមីឬប្ដី តែងតែមានទុក្ខរហូតដល់មានបុត្រ គឺថែមទម្ងន់ទុក្ខមួយទៀតដល់គាត់ ព្រោះខ្លួនត្រូវតែពរផ្ទៃ ប្រសូត្រ បំបៅដោះ និងចិញ្ចឹម បីបាច់ថែរក្សា នេះជាបុព្វហេតុដែលនាំឲ្យនគរ ត្រូវមានឈ្មោះថ្មីមួយទៀតគឺ* ***មាតុភូមិ*** *ឬភូមិម៉ែ (ភូមិព្រះម៉ែនាគ)។*

### <u>ពន្យល់ពាក្យ</u>

*មាតុ = មាតា ម្ដាយ ម៉ែ ម៉ាក់...*

*ភូមិ = ផ្ទៃ លំនៅ ទីកើត ទីប្រសូត្រ...*

*មាតុភូមិ = ផ្ទៃដែលជាទីកើតនូវកូនប្រុសស្រី (ផ្ទៃម៉ែ ឬប្រទេសម៉ែ)*

*ហេតុនេះហើយ កុលបុត្រកុលធីតា ដែលប្រសូត្រចេញពីប្រទេស ឬនគរនេះ តែងបានមរតកពីព្រះម៉ែគ្រប់ៗគ្នា ទើបគេហៅថាជាជនជាតិ**ក្មែរ** ពាក្យ**ក្មែរ** ដែលយើងធ្លាប់ដឹងស្គាល់ពីមុន ត្រូវប្រែប្រួលទៅតាមពេលវេលានៃវិវឌ្ឍនាការរបស់ធម្មជាតិ។ ចុះហេតុដូចម្តេច បានជាសព្វថ្ងៃអ្នកប្រវត្តិសាស្ត្រ និយមសរសេរពាក្យ **ក្មែរ** ទៅជា **ខ្មែរ**ទៅវិញ? ដើម្បីឲ្យអស់ចំងល់ សូមមិត្តអ្នកអានមើលការបកស្រាយពន្យល់ពាក្យខាងក្រោម ដែលបើកបង្ហាញបែបគតិបណ្ឌិតព្រះម៉ែ និងទស្សនៈបរទេស ដែលជាអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរ។*

*១/.ខ្មែរ ➔ ខេមរៈ ➔ អ្នកក្សេម ➔ អ្នកមានសេចក្តីសុខ (**ភាសាបាលី** មើលពាក្យខេមរៈនេះក្នុងវចនានុក្រមខ្មែរ ១ + ២)*

*២/.ក្មែរ ➔ កេរ + ម៉ែ ➔ អ្នកទទួលកេរមរតកម៉ែ គឺអ្នកដែលកើតចេញពីផ្ទៃម៉ែមាតុភូមិ ឬភូមិម៉ែ ជាភាសាក្មែរសុទ្ធៗព្រោះព្យញ្ជនៈ "**ក**" ជាព្យញ្ជនៈដើម ដែល **ក**កើតគ្រប់អ្វីៗទាំងអស់ក្នុងទឹកដីព្រះម៉ែនេះ។*

*ពេលនេះយើងអាចគូសបញ្ជាក់បាន ទៅតាមហេតុផលនៃពាក្យ**ក្មែរ**គឺត្រឹមត្រូវជាង ព្រោះវាជាពាក្យក្មែរសុទ្ធសាធ ហើយជនជាតិនេះកើតចេញពីផ្ទៃប្រទេសម៉ែគ្រប់ៗគ្នា(មាតុភូមិ) យើងដឹងហើយថាដូនតាយើង គឺជាពូជនាគ ឬពូជមេ ពុំមែនជាពូជទាប ឬទន់ខ្សោយឡើយ ធម្មតាពូជពង្សខ្ពង់ខ្ពស់ពុំមែនយកពាក្យ ឬភាសាគេ មកដាក់សម្គាល់ឈ្មោះឲ្យជនជាតិខ្លួនឯងនោះឡើយ។ ព្រោះជនជាតិនេះ ជាអ្នកទទួលមរតកព្រះម៉ែបន្តគ្នា បើពាក្យប្រើ**សម្គាល់ជនជាតិ**ពុំបានត្រឹមត្រូវនោះទេ អ្នកទទួលបន្តកេរខាងក្រោយ ច្បាស់ជាវង្វេងរួចភាន់ច្រឡំជាពុំខានឡើយ។ ចុះហេតុអ្វីបានជាសព្វថ្ងៃនេះ យើងសរសេរពាក្យក្មែរ ទៅជាពាក្យខ្មែរនេះទៅវិញ? ខ្ញុំបានពន្យល់សុភាសិតពីខាងដើមរួចមកហើយ **ចង់គ្រប់គ្រងពូជនាគត្រូវធ្វើមហិទ្ធិឫទ្ធិពួកគេឲ្យក្លាយទៅជាពស់គ្មានពិសសិន**។ ភាគច្រើននៃប្រវត្តិសាស្ត្រក្មែរ គឺទស្សនវិទូបរទេសជាអ្នកស្រាវជ្រាវ និងរៀបរៀងចងក្រងឲ្យកូនក្មែររៀន និងថាតាមរហូតមកដល់សព្វថ្ងៃនេះ គឺរាប់រយឆ្នាំហើយនិងគ្រប់ៗជនបរទេស ដែលធ្លាប់មកធ្វើអាណានិគមលើក្មែរ។ ហេតុនេះយើងមិន*

អាចដឹងពីសាវតាពិតរបស់ខ្លួនឡើយ គឺយើងដឹងតែតាមការចងក្រង និងស្រាវជ្រាវដោយបញ្ញារបស់ពួកគេតែប៉ុណ្ណោះ ទីបំផុតពូជមេ ឬពូជនាគ ត្រឡប់ជាអ្នកថាតាម ជាអ្នកចំឡងតាម ឬជាអ្នកត្រូវគេដឹកនាំ សូម្បីតែបុព្វជនបានកសាងទុកនូវប្រាសាទថ្មរាប់រយពាន់ក៏ដោយ ទីបំផុតស្នាដៃទាំងនោះ ក្លាយជារបស់បរទេសទាំងអស់ ព្រោះគេពន្យល់ថា រឿងរ៉ាវ ដែលដូនតាក្មេរឆ្លាក់នៅលើប្រាសាទថ្មសុទ្ធតែជារឿងរ៉ាវក្នុង**ព្រហ្មញ្ញសាសនា** និង**ពុទ្ធសាសនាទាំងពីរនិកាយ** (ហិនយាន មហាយាន) ទៅវិញ តែតាមរឿងពិតគឺគាត់យកព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ទាំងពីរនិកាយមករម្លាយចូលរឿងពិតរបស់គាត់តែ**មួយ** ប៉ុណ្ណោះ គឺ**សាសនបីរួមមួយ** (សាសនព្រះម៉ែ សាសនព្រហ្មញ្ញ សាសនព្រះពុទ្ធ)។ តាមសុភាសិតបរទេស ពិតជាត្រឹមត្រូវមែន **ពូជមេឬពូជនាគ** ពិតជាដេកលក់ក្នុងអំណាចមនោគមវិជ្ជារបស់ពួកគេមែន ព្រោះពួកគេបានសណ្ដំ និងបំភាន់ជនជាតិនេះឲ្យដេកលង់លក់រហូតមក។

**<u>ពន្យល់ពាក្យ</u>** (មនោគមវិជ្ជា)

មនោ = ចិត្ត ➔ ទឹកចិត្ត

គម = អាគម ឬ អាគមន = ការមកឬដំណើរមក (ការទៅមក)

វិជ្ជា = ចំណេះដឹង ការចេះដឹង

ដូចនេះ ពាក្យមនោគមវិជ្ជា = ដំណើរមកនៃអំណាចចិត្ត របស់បរទេស (វិជ្ជាសណ្ដំ ឬបំភាន់ផ្លូវចិត្ត)

**គ**/.មកទល់នឹងពេលនេះ មិត្តអ្នកអានច្បាស់ជាមានការភ្ញាក់ និងគួរឲ្យសង្វេគ ដែលជនជាតិបរទេស គេបានធ្វើឲ្យយើងរាល់គ្នា ដេកលក់រាប់រយជំនាន់ ដោយអំណាច**មនោគមវិជ្ជា** ហើយពុំបានឲ្យកូនក្មេរដឹងនូវរឿងហេតុ ដែលនិយាយពីសាវតាពិតរបស់ខ្លួនសោះ។

ខ្ញុំសូមលើកយកឧទាហរណ៍មួយ មកពន្យល់ពីការពិតដែលកើតឡើងក្នុងសង្គមក្មេរ យើងបច្ចុប្បន្ន សមាជិកសភាក្មេរដែលអង្គុយប្រជុំ ហើយពួកគាត់តែងតែពាក់អាវគ្រីរស៊េ (អាវធំ) ពាក់ក្រវ៉ាត់ក ហើយស្លៀក ខោបារាំង **តើមិត្តអ្នកអានមើលសម្បកខាងក្រៅសមាជិកសភាក្មេរនោះជាជនជាតិបារាំង ឬក៏ក្មេរ?** យើងពិតជាឆ្លើយថា ពួកគាត់ទាំងអស់នោះជាជនជាតិក្មេរ ព្រោះពួកគាត់គ្រាន់តែខ្ចីសម្លៀកបំពាក់បែបបរទេស មកស្លៀកពាក់ដើម្បីបិទបាំងកេរ្តិ៍ខ្មាស់ ការពារកម្ដៅថ្ងៃ របោម មូស ខ្យល់...

*តែប៉ុណ្ណោះ។ យ៉ាងណាមិញដូនតាក្មេរក៏យ៉ាងដូច្នោះដែរ គាត់ខ្ចីរឿងរ៉ាវពីព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា(មហាយាន និងហិនយាន) មកបិទបាំងរឿងពិតរបស់ពួកគាត់តែប៉ុណ្ណោះ ព្រោះពួកគាត់ចង់លាក់នូវអាថ៌កំបាំង ប្រៀបបីដូចជា **ផ្លែដាវក្មេរតែនៅក្នុងស្រោមសាសនា។** ដោយហេតុនេះហើយបរទេសដែលជាអ្នកស្រាវជ្រាវ គេមានប្រាជ្ញាមើលយល់នូវអាថ៌កំបាំងគំនិត ក្នុងរូបចម្លាក់ថ្មទាំងនោះគេក៏បាន**បង្វែរសំបកខាងក្រៅឲ្យលាយជាមួយសាច់ខាងក្នុង**តែម្តងទៅ ដើម្បីបំភាន់រឿងពិត កុំឲ្យកូនក្មេរជំនាន់ខាងក្រោយ បានដឹងពីសាវតាពិតរបស់ខ្លួន។ តែគួរអោយហួសចិត្ត ដែលដូនតាលោកចង់លាក់បំបាំងភ្នែកអ្នកដទៃ កុំឲ្យមើលយល់និងដឹង តែបែរជាកូនក្មេរមើលពុំយល់ពីគំនិតរបស់គាត់ ហើយបែរជាអ្នកខាងក្រៅមើលយល់ទៅវិញ **នេះគឺពិតជាបាបកម្មរបស់ដូនតាដែលតាមឲ្យផល ដោយពួកគាត់បានសាងអកុសលកម្មនេះទុករួចមកហើយ៕***

*ខ្ញុំសូមទាញយករឿងក្នុងចម្លាក់ថ្មមួយ មកពន្យល់និងបើកបង្ហាញ លាតត្រដាងគឺរឿង **កូរសមុទ្រទឹកដោះ** រឿងនេះកូនក្មេរភាគច្រើន បានស្គាល់ពីចំណងជើងរឿង ហើយជាពិសេសទៅទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានយករូបភាពនៃរឿងនេះ មកធ្វើជាតំណាងអោយនិមិត្តសញ្ញារបស់ខ្លួននៅក្នុងឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ។ រឿងនេះទៀតសោត បើយើងមិនបានស្រាវជ្រាវ ពិចារណាឈ្វេងយល់ឲ្យបានល្អិតល្អន់នោះទេ យើងច្បាស់ជាយល់ដូចការបកស្រាយរបស់បរទេសថា ជារឿងរបស់ព្រហ្មញ្ញសាសនា នៅប្រទេសឥណ្ឌាជាមិនខាន។ ផ្ទុយទៅវិញ បើមិត្តអ្នកអានបានពិចារណា តាមការបកស្រាយពន្យល់ជាហូរហែពីខាងលើមកនោះ ច្បាស់ជាយល់ខ្លះៗជាពុំខានឡើយ ព្រោះយើងដឹងហើយថានគរនេះកូនក្មេរគ្រប់ៗរូបតែងតែបានស្គាល់ និងនាំគ្នាហៅថា **មាតុភូមិ** (ភូមិម៉ែ) ហើយពាក្យនេះខ្ញុំបានពន្យល់ពីខាងដើមរួចមកហើយ ប៉ុន្តែពេលនេះសូមមិត្តអ្នកអានតាមដាន និងពិចារណាជាមួយខ្ញុំ ក្នុងការបកស្រាយនៃសាច់រឿងនេះ ដោយឈរលើ**សាសនរបស់ព្រះម៉ែ ឬការផ្តាំទុករបស់ព្រះម៉ែមហានគរ៕***

***ឧទាហរណ៍ ៖** នៅក្នុងពេលបច្ចុប្បន្ននេះ ជាមធ្យមម្តាយទូទៅ រមែងមានបុត្រយ៉ាងតិចក៏ពីរនាក់ដែរ (ខ្ញុំពុំគិតពីសម័យដើម ដូចម្តាយរបស់ខ្ញុំគាត់មានកូនជាង១០នាក់ឯណោះ) ហើយក្នុងចំណោមទារកទាំងពីរនេះទារកម្នាក់ៗក្នុងមួយថ្ងៃគេបៅទឹកដោះម្តាយអស់ប្រហែលមួយលីត្រកន្លះ រួចគេបៅអស់រយៈពេល ៩ ទៅ ១០ ខែទើបម្តាយ ផ្តាច់ដោះ ចំពោះម្តាយដែលមានកូនញឹក។ ដូច្នេះចូរយើងយកចំនួន*

*លិត្រទឹកដោះទាំងអស់ ដែលកូនម្នាក់បានបៅក្នុងមួយថ្ងៃទៅគុណនឹងចំនួនខែ (៩ខែ ឬ១០ខែ) នោះយើងនឹងឃើញចំនួនលីត្រទឹកដោះរបស់ទារកម្នាក់ដែលបានបៅ រួចយកចំនួនលិត្រទឹកដោះទារកម្នាក់ទៅគុណនឹងពីរ យើងនឹងឃើញចំនួនលិត្រទឹកដោះរបស់ម្ដាយម្នាក់ ដែលបានបង្ហូរបំបៅបុត្រជាពុំខាន។ រួចហើយយើងយកចំនួនលិត្រទឹកដោះម្ដាយម្នាក់ទៅ គុណនឹងចំនួនមាតាទូទាំងប្រទេសយើងនឹងឃើញទឹកដោះ ដែលម្ដាយខ្មែរបង្ហូរមក ជិតស្មើនឹងសមុទ្រទឹកដោះហើយឬនៅ? ប្រសិនបើនៅមិនទាន់ស្មើទេ យើងគុណថយក្រោយកាលពីពេលកកើតនគរព្រះម៉ែ ដែលមានចំនួនរាប់ពាន់តំណ យើងនឹងឃើញទឹកដោះម្ដាយខ្មែរ ដែលបានបង្ហូរគ្រប់ៗជំនាន់ស្មើនឹងសមុទ្រទឹកដោះជាពុំខាន។ ព្រោះនគរនេះ ជានគរម៉ែ (មាតុភូមិ) បើម៉ែបង្កើតបុត្រហើយ ម៉ែត្រូវតែបំបៅបុត្រនេះជាក្រិតក្រមរបស់ធម្មជាតិ ប៉ុន្តែសព្វថ្ងៃរឿងនេះយើងយល់ច្រឡំថា ជារឿងនៅឯឥណ្ឌាតាមរយៈរឿងក្នុងព្រហ្មញ្ញសាសនាទៅវិញ។ យើងឥតបានយល់ថា ព្រះម៉ែគាត់ខ្ចីសាច់រឿងពីក្នុង***សាសនា*** *មកលាក់រឿងពិតរបស់ខ្លួនគាត់ឡើយ ព្រោះសាច់រឿងរបស់សាសនា វាស្រដៀងនឹងរឿងពិតរបស់គាត់(**បុព្វជនម៉ែ**) តើប្រទេសឥណ្ឌា គេមានហៅប្រទេសគេថាភូមិម៉ែ ឬមាតុភូមិ ដូចយើងដែរឬទេ? យើងច្បាស់ជាឆ្លើយថាទេ ព្រោះថា ក្រៅពីខ្មែរគ្មានប្រទេសណាមួយដែលលើកតម្លៃម៉ែថា ជាម្ចាស់ប្រទេសឡើយ (**មាតុភូមិ**) គឺមានតែប្រទេសខ្មែរនេះ តែមួយគត់ដែលលើកតម្លៃរបស់**មេ ឬ ម៉ែ ហើយសព្វថ្ងៃ គឺមាននូវសល់តែពាក្យដែលទុកជាកេរតំណែលតែប៉ុណ្ណោះ**។ ចុះហេតុអ្វីបានជាអ្នកប្រាជ្ញបរទេស ដែលបកស្រាយរឿង **កូរសមុទ្រទឹកដោះ** នៅលើជញ្ជាំងគ្រប់ប្រាសាទរបស់ខ្មែរ ថាជារឿងក្នុងសាសនានៅឥណ្ឌាទៅវិញ? ព្រោះហេតុតែយើងបាន ប្រគល់ឲ្យបរទេសជាអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ និងប្រវត្តិរបស់ភាសាចម្លាក់រូប ព្រោះពួកបរទេសគេចេះមើលភាសារូបនេះ តាំងពីស.វទី១៨មកម្ល៉េះ (ភាសារូបនៅពីរ៉ាមីត) **ពួកគេបានមើលយល់គំនិតប្រស្នាក្នុងភាសារូប របស់យើង ហើយគេក៏បានបង្វែរចុងស្លាបប៉ាកា សរសេរទៅតាមការគិត លាក់បំបិទបំភាន់របស់គេទៅ នេះម្យ៉ាងៗទៀតពួកគេពុំមែនជាជាតិខ្មែរឡើយ គេពុំអាចដឹងពីសារជាតិពូជនាគទេ។***

***ង**/.តាមការសិក្សាស្រាវជ្រាវមកទល់នឹងពេលនេះ យើងសង្ស័យរួចឆ្ងល់ហើយសួរខ្លួនឯងថា ហេតុអ្វីក៏ដូនតាខ្មែរ កសាងប្រាសាទថ្មរាប់ពាន់ ឥតមានបន្សល់ទុកនូវឯកសាររឿងរ៉ាវខ្លួនឯង ហើយ**បែរជាឆ្លាក់សុទ្ធតែរឿងរ៉ាវក្នុងសាសនាព្រហ្មញ្ញ និងពុទ្ធសាសនាទាំងពីរនិកាយភាគច្រើនទៅវិញ***

តែតាមការពិតសិលាចារឹក (សិលា = ថ្ម ចារឹក = ការដាប់ឆ្លាក់លើផ្ទាំងថ្ម) មិនថា**អក្សរ ឬរូបភាព** ក្បូរក្បាច់ចម្លាក់ឡើយ សុទ្ធតែជាសិលាចារឹកទាំងអស់ ហើយរឿងរ៉ាវទាំងអស់នោះ សុទ្ធតែជាប្រវត្តិពិតរបស់បុព្វជនជាតិនេះទាំងស្រុង ដែលពួកគាត់បាននិយាយរៀបរាប់ប្រាប់ពីអតីតកាល ពីបច្ចុប្បន្នកាល នឹងតទៅអនាគតកាលសម្រាប់ឲ្យកូនម៉ែទាំងអស់គ្នាមើល ហើយពិចារណាឈ្វេងយល់។ ទីបំផុតកូនដែលរស់ក្នុងភូមិម៉ែ **បានត្រឹមតែមើលនឹងភ្នែក ពុំបានមើលនឹងថ្វាស គឺត្រិះរិះគិតពិចារណា**ទេ បានត្រឹមតែទទួលកេរមរតកពីប្រទេសព្រះម៉ែ ហើយបែរជាពុំដឹងគុណព្រះម៉ែ មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងនាំគ្នាជេរប្រមាថគាត់ថែមទៀត។ យើងឥតបានយល់ពីសាសនព្រះម៉ែ ដែលបង្កប់ទុកក្នុងថ្ម ពួកគាត់មិនហ៊ានសរសេរលើក្រដាស ឬស្បែកទេ ខ្លាចនាំឲ្យឆាប់ខូច សុខចិត្តឲ្យកូនព្យាយាមដាប់ឆ្លាក់ថ្ម ដែលគាត់មានគតិបណ្ឌិតដ៏ធំទូលាយ ដូចជាសមុទ្ទទឹកដោះ រហូតដល់ពួកបរទេស ដែលជាអ្នកស្រាវជ្រាវគេឆ្ងល់ថា **តើដូនតាជាតិនេះ លាក់សាវតានគររបស់ខ្លួន នៅឯណា?** ពួកគេនាំគ្នាជីកគាស់ដីស្វែងរកនូវឯកសារទាំងអស់នោះ ទីបំផុតទើបគេដឹងថាបុព្វជននៃអ្នកនគរនេះមានបញ្ញាណាស់ ទុកសាវតាមរតកឲ្យកូនចៅទៅជំនាន់ក្រោយរបស់ពួកគាត់នៅលើគោក ក្នុងទឹក.... ដើរឃើញរាល់ថ្ងៃ កណ្តាលវាល ហាលថ្ងៃ ហាលភ្លៀង ហាលខ្យល់....។ល។ ហើយឈរបង្អួតបង្ហាញ និងនិយាយប្រាប់ ដូចជាទស្សនាខ្សែភាពយន្ត ដោយភាគច្រើនពុំបានឆ្លាក់ជាអក្សរឡើយ **គឺឆ្លាក់ជាដំណើររឿង** ឈរនៅរាប់រយពាន់ឆ្នាំយ៉ាងស្ងៀមស្ងាត់ តែពោរពេញទៅដោយអត្ថន័យ និងអាថ៌កំបាំង បង្ហាញពីប្រស្នាគំនិតក្នុងភាពរុងរឿង ភាពចុះទន់ខ្សោយ និងភាពរីកចម្រើនឡើងវិញ សម្រាប់ទុកឲ្យមនុស្សជំនាន់ក្រោយ(**ក្មេរ**) សិក្សាស្រាវជ្រាវ និងពិចារណារាវរកការពិត។ មានប្រាសាទមួយនៅខេត្តកំពង់ចាមឬ(ចាម់) មានឈ្មោះថា **ប្រាសាទហាន់ជ័យ** ហេតុអ្វីបានជាគាត់ដាក់ឈ្មោះប្រាសាទភ្នំនេះថា **ហាន់ជ័យ**?

<u>ពន្យល់ពាក្យ</u>

ហាន់ = កាត់ជាចំណិតៗ ឧ.ហាន់សាច់ ហាន់បន្លែ...

ជ័យ = ភាពឈ្នះ ជ័យជំនះ

ដូចនេះ ពាក្យ**ហាន់ជ័យ**មានន័យថា ហាន់ជ័យជំនះរបស់ដូនតាក្មេរពីសម័យមុនឲ្យទៅជាចំណិតៗគឺ ហាន់ជ័យជំនះស្តេចតាំងពីជ័យស្រី ឬស្រីជ័យ(ព្រះម៉ែនាគ) រហូតដល់កូនគាត់ដែលជាអ្នក

ទទួលមរតកពីគាត់ គឺស្ដេចគ្រប់ៗជំនាន់ខាងក្រោយសម័យគោកធ្លក រហូតមកដល់ស្ដេចជ័យវរ្ម័នទី៧ ដែលជាស្ដេចចក្រពត្តិចុងក្រោយ រួចហើយយករឿងដែលហាន់ជាចំណិតៗនោះ ទៅពង្រាយពេញផ្ទៃប្រទេស **បើកូនណាចង់ដឹងរឿងព្រះម៉ែ** ទាល់តែកូននោះ ដើរប្រមូលផ្គុំនូវ**ធនធានជ័យ**ពីអតីតកាល ទើបដឹងសាវតាពិតរបស់ខ្លួន។ ដូច្នេះទើបគាត់និទានរឿងមួយសម្រាប់ដើរប្រមូលធនធានជ័យជំនះរបស់គាត់ គឺ (**រឿងធនជ័យ ឬជ័យធន**) ព្រោះបុរសនេះជាអ្នកដើរប្រមូលផ្គុំផ្គុំ រើសនូវជ័យជំនះពីអតីតកាល ដែល**ហាន់ជាចំណិតៗ**មកបូកបញ្ចូលឲ្យកើតជារូបរឿងពិតរបស់ព្រះម៉ែឡើង។ កូនខ្មែរមានពេលឯណា ដើម្បីពិចារណាឲ្យដឹងរឿងរ៉ាវពិតរបស់ខ្លួន បើបរទេសអ្នកស្រាវជ្រាវ គេបំភាន់ថាជាសាច់រឿងនៅក្នុងព្រហ្មញ្ញសាសនា និងពុទ្ធសាសនាអស់ទៅហើយនោះ។ យើងពុំបានដឹងសោះថាដូនតាខ្មែរ បានចារឹកប្រវត្តិសាវតាពិតរបស់ពួកខ្លួនជាសាច់រឿង ទុកនៅលើជញ្ជាំងថ្ម ដែលជារឿងនិយាយរៀបរាប់ពីទុក្ខវេទនារបស់អច្ឆរាមាតា **មហានគរ** ដែលគាត់កំពុងជាប់ឃុំឃាំង នៅក្នុងសមុទ្រទឹកដោះ ហើយកូនប្រុសស្រី និងយក្សព្រមទាំងបក្សពួកចាប់គាត់ទាញសត្វ**នាគ** (**នាគនិមិត្តរូបនគរព្រះម៉ែ**) ដណ្ដើមមរតកគ្នាគ្រប់ជំនាន់ដូចមាននៅក្នុងរូបរឿងកូរសមុទ្រទឹកដោះស្រាប់។

**ច**/.យើងក្រឡេកមើលអ្នកវិទ្យាសាស្ត្រសព្វថ្ងៃ ដែលយើងនាំគ្នាសរសើរថា ពូកែស្រាវជ្រាវនូវបច្ចេកវិជ្ជាទំនើបៗ ពិសេសនោះគឺ កុំព្យូទ័រ យើងសួរថា ***តើកុំព្យូទ័រនោះអាចទុកឯកសារបានរាប់ពាន់ឆ្នាំដូចកុំព្យូទ័ររបស់ដូនតាខ្មែរដែរឬទេ? ហើយអាចទុកនៅកណ្ដាលវាលហាលថ្ងៃ ហាលភ្លៀង ហាលខ្យល់ និងនៅក្នុងទឹកបានដែរឬអត់?*** ហើយវិទ្យាសាស្ត្រដែលកំពុងតែរីកចម្រើនដូចសព្វថ្ងៃនេះ ***តើអាច កសាងនូវមហាសំណង់ប្រាសាទថ្មរាប់ពាន់បានដូចដូនតាខ្មែរដែរឬទេ*** យើងនិយាយនេះ ហាក់បីដូចជាមានអំនួត ឬ មោទនភាពជាតិខ្លាំងពេកហើយ ក៏ប៉ុន្តែនេះជារឿងពិត ដែលកូនខ្មែរពុំអាចប្រកែកបាន ទោះបីជាសព្វថ្ងៃនេះ ខ្លួនយើងជាកូនខ្មែរគ្មានជំនឿថា នឹងអាចកសាងបាននូវមហាសំណង់ដែលគ្មានគូប្រៀបក្នុងលោក ក៏យើងនៅតែជឿជាក់ថា ដូនតារបស់យើងពិតជាមានបញ្ញា ជាអាទិទេពពិតប្រាកដ មែនទើបពួកគាត់អាចមានមហិទ្ធិឫទ្ធិពង្រីកទឹកដី និងកសាងសម្បិទ្ធិផលនានាជាពិសេសគឺប្រាង្គប្រាសាទថ្មរាប់ពាន់ ដែលលាតត្រដាងបង្ហាញពីកំពូលបញ្ញាញាណរបស់**ពូជនាគ** (ពូជអច្ឆរា ឬពូជអច្ឆរិយៈ)។

**ឆ/.តើអាទិទេពខ្មែរជានរណា? ហេតុអ្វីបានជាខ្មែរមិនស្គាល់ ពីអាទិទេពរបស់ខ្លួន?**

នេះជារឿងលំបាកគិត លំបាកយល់ និងលំបាកស្រាវជ្រាវណាស់ ទោះបីជាស្រាវជ្រាវបានមក ហើយក៏លំបាកនឹងធ្វើឲ្យកូនខ្មែរងាយយល់ ហើយព្រមជឿ និងទទួលយកថែមទៀតផង ព្រោះវាជារឿងដែលពុំគួរឲ្យជឿសម្រាប់មនុស្សសម័យបច្ចុប្បន្ននេះ(សម្ភារៈនិយម និងបច្ចេកវិជ្ជាថ្មី...)។ខ្ញុំបានពន្យល់រួចហើយថាពូជ នាគ ឬពូជមេ (ពូជម៉ែ) គឺជាអ្នកកសាងទុកនូវមរតក ដែលមានទឹកដី វប្បធម៌ អរិយធម៌ ប្រពៃណីទំនៀមទម្លាប់ សាសនា.... ដោយមិនចេះស្លាប់។ ទោះបីនគរនេះធ្លាក់កប់ជ្រៅជិតផុតដង្ហើម ក៏ពុំព្រមដាច់ដង្ហើមដែរនៅតែជាមាតុភូមិ ទោះបីជាស្គមស្គាំងត្រដាបត្រដួស យ៉ាងណាក៏ព្រះម៉ែនៅតែឈរបង្ហាញមុខឲ្យពិភពលោកគេឃើញ គេស្គាល់ នូវអនុភាពរបស់ខ្លួនពីអតីតកាលដែលបានសាយភាយ នូវភាពក្រអូប(រឿង**ព្រះនាងសក់ក្រអូប ឬបាយ៉ង់កោរ**) ពីអតីតកាលដែលពោរពេញដោយកិត្តិយស កិត្តិនាម ធ្វើឲ្យអ្នកទទួលមរតកព្រះម៉ែ(ខ្មែរ) ជំនាន់ក្រោយៗនេះ រីកមុខរីកមាត់ ហើយកើបយកនូវលាភសក្ការៈ ដែលបន្សល់ពីកេរមរតកគតិបណ្ឌិតព្រះម៉ែ ដោយមិនចេះរីងស្ងួត គឺវិស័យទេសចរណ៍ វប្បធម៌ ធម្មជាតិ សាសនា...។ល។

**ហេតុអ្វីបានជាខ្ញុំហ៊ានថាស្នាដៃ និងមរតកទាំងនេះជារបស់ព្រះម៉ែ** ? ខ្ញុំបានបកស្រាយ និងពន្យល់ត្រួសៗពីខាងដើមជាហូរហែរួចមកហើយ ក្រែងមិត្តអ្នកអានមិនសូវយល់ នឹងពុំជឿជាក់ ខ្ញុំសូមលើកយករឿងរ៉ាវរបស់ អ្នកនគរចេនឡាតាមរយៈកំណត់ហេតុអ្នកការទូតចិនជីវតាក្វាន់ មកវែកញែកពន្យល់។ នៅក្នុងកំណត់ហេតុនេះ លោកជីវតាក្វាន់បាននិយាយថា អ្នកស្រុកចេនឡានេះមានរឿងអាថ៌កំបាំងមួយដែលមានដំណើរថា មានបិសាចពស់មួយ ដែលជា**ព្រះភូមិ ឬទេវតារក្សាព្រះនគរ** ហើយបិសាចពស់នេះ តែងតែប្រែកាឡា(និម្មិត)ខ្លួនជាស្ត្រី មករួមរ័កផ្ដេកផ្ដិតជាមួយស្ដេចនាពេលរាត្រី ហើយរឿងនេះមានតែស្ដេចទេដែលដឹង សូម្បីតែមហេសីឬស្រីស្នំដទៃទៀត ពុំដែលបានទៅជិតទីនោះឡើយ (ប្រាសាទវិមានអាកាស) លុះដល់កណ្ដាលរាត្រីទើបស្ដេចយាងចុះមកផ្ទំ ជាមួយមហេសីឬស្រីស្នំខ្លួនវិញ។ ប៉ុន្តែក្នុងឯកសារកំណត់ហេតុនេះបានបញ្ជាក់ប្រាប់ថា កាលបើស្ដេចបានជួបបិសាចពស់ពេលណា ពេលនោះស្ដេចមានអាយុនគររុងរឿង ពុំមានកើតកលយុគ គឺ**សង្គ្រាម**ឡើយ។ តែបើស្ដេចពុំបានឡើងទៅជួប ឬ ឡើងទៅហើយពុំបានជួប នោះនគរនឹងកើតមានកលយុគ អពមង្គលនឹងកើតមានចំពោះស្ដេចៗនឹងត្រូវអស់អាយុ។ ខ្ញុំត្រូវស្វែងរកការពិត ក្នុងកំណត់ហេតុរបស់អ្នកការទូត

ចិននោះ ដើម្បីឲ្យដឹងថា តើបិសាចពស់នោះជាអ្នកណា? ហើយគាត់មកជួបជាមួយស្ដេច ដើម្បីប្រយោជន៍អ្វី?

**បិសាចពស់**ចិនហៅ ព្រោះចិន(ចិន្ត) ពុំបានស្គាល់នាគក្មេរទេ ដោយសារតែនាគចិនមានជើងបួន នាគក្មេរ គ្មានជើងហើយមានក្បាលច្រើនទៀត។ ធម្មតាបរទេសគេ ពុំដែលសរសេររបស់អ្វីមួយ ឲ្យអ្នកក្រៅបានល្អឡើយ **ឧទាហរណ៍:** ស្ត្រីជាអាប យើងតែងតែគិតថាស្ត្រីនោះអាក្រក់ ប៉ុន្តែយើងសួរថាដែលឃើញស្ត្រីនោះសម្លាប់កូនខ្លួនឯងដែរឬទេ? គឺពិតជាពុំមានឡើយ ព្រោះស្ត្រីនោះតែងតែមានព្រហ្មវិហារធម៌ចំពោះ កូនប្រុសស្រីរបស់គាត់ ប៉ុន្តែអ្នកដទៃទេតើ ដែលនាំគ្នាចោទគាត់ថា អាក្រក់នោះហើយក៏មិនដែលឮល្បីថាអ្នកចេះមន្តអាគមនេះ ទៅសម្លាប់អ្នកណាផង ប៉ុន្តែបើមនុស្សមិនមែនជា**អាប** ហើយមានចិត្តអាក្រក់ មនុស្សនោះអាក្រក់ជាងអាបរាប់រយពាន់ដង ព្រោះមនុស្សដែលគ្មាន**គុណធម៌** (សីល សមាធិ បញ្ញា) អាចសម្លាប់មនុស្សបានរាប់រយពាន់លាននាក់(**មេដឹកនាំ ដែលផ្ដាច់ការ**)។

ក្នុងឯកសារដដែល**ចិន**នោះ គាត់បានប្រាប់ថាបិសាចពស់នេះ ជា**ព្រះភូមិ ឬទេវតា** ដែលថែរក្សា ព្រះនគរជាទេវតាដែលមានឫទ្ធិបារមី យើងពិតជាមិនច្រឡំឡើយគឺជាព្រះម៉ែមហានគរនោះឯង (**ព្រះមាតានាគ**) ប៉ុន្តែនាគនេះ(បិសាចពស់ ឬបិសាចនាគ ) គ្រាន់តែជានិមិត្តរូបព្រះម៉ែតែប៉ុណ្ណោះ ដែលខ្ញុំបានពន្យល់ពីពាក្យ **នាគ** នៅទំព័រខាងដើមរួចមកហើយ។

## ចុះព្រះម៉ែនាគគាត់មកធ្វើអ្វី?

គាត់មកចង្អុលផ្លូវប្រាប់កូននាគគឺស្ដេចពីរបៀបដឹកនាំប្រទេសឲ្យបានរុងរឿង ហើយឲ្យកូននាគរួមគ្នាកសាងប្រាសាទថ្មឆ្លាក់រឿងរ៉ាវរបស់គាត់ទុក ព្រោះព្រះម៉ែគាត់ដឹងថាតទៅថ្ងៃក្រោយ គាត់ពុំអាចចេញពីទីឃុំឃាំងមកជួបនឹងកូនបានទៀតឡើយ។ តទៅថ្ងៃខាងមុខកូនក្មេរប្រុសស្រីច្បាស់ជាលែងដឹងលែងស្គាល់គាត់ដែលជាអ្នកកកើតនគរ ហើយអ្នកដែលអាចស្គាល់គាត់បានទៅថ្ងៃក្រោយ លុះត្រាតែយល់ពីអាថិកំបាំងសាច់រឿងនៅក្នុងចម្លាក់**ប្រាសាទថ្ម** ឈ្មោះនៅក្នុងធម្មជាតិ ក្នុងរឿងព្រេងទំនៀមទម្លាប់ ប្រពៃណី និងឈ្មោះភូមិស្រុក ឬទំនាយផ្សេងៗ...។ល។ បើកូនរបស់គាត់ណាអាចមើលយល់បានពីអត្ថន័យ សាសន គំនិតរបស់ព្រះម៉ែ ដែលបានចារឹកបន្សល់ទុក គេនឹងព្យាយាមជួយគាត់ឯកសារកំណត់ហេតុបាននិយាយថា បិសាចពស់នោះមករួមរ័កនេះជាពាក្យមិនពិត មិត្តអ្នកអាន

ពិចារណាទៅមើល ក្នុងន័យពាក្យនោះថា ពេលណាកូនបានជួបព្រះម៉ែ**នាគ** នគររុងរឿងស្ដេចមានអាយុ ពេលណាដែលមិនបានជួបព្រះម៉ែទេ នគរកើតកលយុគស្ដេចអស់អាយុ(ចូលទីវង្គតឬស្លាប់)។ ដូច្នេះយើងអាចដឹងថាគាត់ជាព្រះម៉ែនាគ ជាអាទិទេពរបស់កូននាគប្រុសស្រី(ស្ដេច) ជាអ្នកប្រសើរខ្ពង់ខ្ពស់ ពេលណាកូនបានជួបអ្នកប្រាជ្ញ ឬបណ្ឌិតនគររុងរឿង ពេលណាដែលកូនមិនបានជួប បណ្ឌិត ឬអ្នកប្រាជ្ញដែលជាអាទិទេពនោះ នគរនឹងងងឹត ហើយកើតមានកលយុគ បែកបាក់ទ្រុឌទ្រោម រួចចុះទន់ខ្សោយ។ ហេតុនេះបានជាក្រោយពេលបោះបង់ចោលក្រុងអង្គរក្មេរចាប់ផ្ដើមចុះទ្រុឌទ្រោមទន់ខ្សោយរហូត ព្រោះយើងលែងមានអាទិទេពមកបំភ្លឺចង្អុលបង្ហាញផ្លូវគំនិត និងរបៀបដឹកនាំប្រទេសដូចកាលពីមុនទៀតហើយ។ ព្រះម៉ែគាត់ពុំអាចចេញពីទីឃុំឃាំងក្នុងសមុទ្រទឹកដោះបាន ព្រោះហេតុនេះហើយទើបនគរយើង ចាប់ផ្ដើមចុះអន់ថយរហូតមក មិនត្រឹមតែប៉ុណ្ណោះទេ កូនៗរបស់គាត់ជំនាន់ក្រោយបែកបាក់សាមគ្គី ឈ្លោះដណ្ដើមកេរគ្នា និងនាំគ្នាជេរប្រមាថគាត់ជាព្រះម៉ែ ដែលជាអាទិទេពមហានគរដោយពុំដឹងខ្លួន ហេតុតែពុំយល់ពុំដឹងទើបនាំគ្នាឆ្លោយមាត់ស្ទើរតែគ្រប់ៗកូនក្មេរ ទាំងប្រុសស្រី ទាំងក្មេង ទាំងចាស់នាំគ្នា**ជេរម៉ែ** តួយ៉ាងដូចពាក្យ **ចុយម្រាយ ឬចុយម៉ាយ = ចុយម្ដាយ** (**រំលោភ ម្ដាយដោយវាចា**) ព្រោះខ្ញុំបានឮអ្នកនគរនេះ ភាគច្រើនកំពុងប្រព្រឹត្តិ។

ពួកគេពិតជាមានបាបកម្មខ្លាំងណាស់ ព្រោះពុំបានដឹងនូវពាក្យដែលប្រើសព្វថ្ងៃជាពាក្យប្រមាថចំពោះព្រះម៉ែខាងដើម និងម៉ែបង្កើតរបស់ខ្លួនបច្ចុប្បន្ន។ ហេតុតែមាក់ងាយអ្នកមានឧបការគុណរបស់ខ្លួន ដូច្នេះហើយ បានជាអ្នកនគរនេះ ពេលដែលស្លាប់ទៅ គេតែងតែលើក **ទង់ក្រពើពណ៌ស**ឲ្យម្នាក់មួយៗ ពីខាងមុខផ្ទះគ្រប់ៗគ្នាទាំង **គ្រហស្ថ បព្វជិត អ្នកមាន អ្នកក្រ អ្នកតូច អ្នកធំ បុរសស្ត្រី ពាលបណ្ឌិត**....។ល។

## ព្រោះហេតុអ្វី?

ដោយសារតែពួកគេរស់ក្នុងភូមិប្រទេសព្រះម៉ែ បានកេរពីព្រះម៉ែ ប៉ុន្តែទីបំផុតពុំដឹងគុណព្រះម៉ែឡើយ ថែមទាំងនាំគ្នាជេរគាត់ទៀត នេះសមនឹងគេលើកទង់ក្រពើឲ្យហើយ ដោយពាក្យក្រពើមានពាក្យពីរម៉ាត់**ក្រ+ពើ ក្រ** = អត់ ក្សត់ គ្មាន . **ពើ** = ធ្វើពើមិនដឹង។ កាលនៅរស់នាំគ្នាលើកទង់ក្រពើធំៗ(ដងទង់) នៅមុខព្រះវិហារ(**វត្ត**) ពណ៌ក្រហម ខៀវ លឿង.... ដល់ពេលស្លាប់ទៅ ត្រូវគេលើកទង់ក្រពើពណ៌សឲ្យ

ម្នាក់មួយៗនៅមុខផ្ទះ។ ព្រោះអ្នកនោះស្លាប់ទៅដោយទទេស្អាត គឺមួយជីវិតក្នុងចន្លោះការកើត និងស្លាប់ ពុំបានដឹងរឿងព្រះម៉ែ ហើយឧទ្ទិសបុណ្យជូនទៅគាត់ គឺបានត្រឹមតែនាំគ្នាជេរប្រមាថគាត់ នេះហើយជាកំហុសដ៏ធំរបស់កូនក្មេរប្រុសស្រី។ កូនប្រុសស្រីម៉ែធ្វើពើពុំដឹងហើយ ថែមទាំងបរទេសអ្នកសិក្សាស្រាវជ្រាវបំភាន់ រួចបង្វែរការពិតទៅទៀត រឹតតែធ្វើឲ្យងងឹត និងថែមទាំងមិនយល់ដឹងទៀតផង។ នេះជាហេតុដែលយើងនាំគ្នាប្រមាថអាទិទេពខ្លួនឯង ព្រះម៉ែខ្លួនឯងរហូតដល់សព្វថ្ងៃនេះ កូនខ្លះហ៊ានដល់ទៅសម្លាប់ម៉ែឪបង្កើតខ្លួនទៀតផង (ចេញផ្សាយតាមសារព័ត៌មាន)។

ដោយការបកស្រាយពន្យល់របស់ខ្ញុំ ទៅលើកំណត់ហេតុរបស់ចិន យើងឃើញថាសម័យមុននគរអាចរុងរឿង ដោយបានជួប**ព្រះម៉ែ** ជាអ្នកមានឫទ្ធិអ្នកដែលប្រសើរ ដល់សម័យខាងក្រោយគាត់មិនអាចចេញពីទីឃុំឃាំងបាន ទើបយើងបាត់បង់អ្នកចង្អុលបង្ហាញផ្លូវ ក្នុងការដឹកនាំនគរ ឲ្យបានរុងរឿង(សាច់រឿងនេះ មាននៅក្នុងចម្លាក់លើផ្តែរប្រាសាទប៉ែនជុន សព្វថ្ងៃដាក់តាំងនៅសារមន្ទីរជាតិភ្នំពេញ)។

មិត្តអ្នកអានទាំងឡាយ ពេលដែលបានតាមដានសាច់រឿងមកដល់ត្រឹមនេះ ទើបយើងដឹងថាគួរឲ្យភ្ញាក់និងសង្វេគខ្លួនណាស់ ដែលយើងពុំបានដឹងនូវសាវតាពិតរបស់ខ្លួន ប្រៀបបីដូចជាមនុស្សងងឹតដើរកណ្តាលថ្ងៃត្រង់ ហើយនៅក្នុងដៃមានកាន់ប្រទីបមួយថែមទៀត ប៉ុន្តែទីបំផុតតើមានប្រយោជន៍អ្វីដល់មនុស្សដែលងងឹត ចំពោះពន្លឺ ថ្ងៃនិងប្រទីបដែលខំបំភ្លឺនោះ។ យើងជាកូនក្មេរប្រុសស្រីភាគច្រើនក៏មិនសូវខុសគ្នាដែរ គឺបានត្រឹមតែរស់នៅក្នុងភូមិព្រះម៉ែ ទទួលកេរពីព្រះម៉ែ ហើយនាំគ្នាជេរប្រមាថព្រះម៉ែដែលជាអាទិទេពដើមរបស់ខ្លួន ព្រោះអ្នកស្រុកនេះគេមិនដែលជេរ**ឪ**ឡើយ។ រឿងរ៉ាវដែលឲ្យកូនក្មេរជេរម៉ែនោះ គាត់បានឆ្លាក់ទុកនៅក្នុង**ប្រាសាទនាគព័ន្ធ** រូបព្រះម៉ែពាក់ម្កុដរាជកប់ត្រឹម**ក**(មើលរូប) រួចហាមាត់ស្រែកដង្ហោយឲ្យកូនប្រុសស្រីជួយ ប៉ុន្តែនៅលើមកុដរបស់គាត់ គេឲ្យទូលយោនីខ្លួនឯង(***ភេទរបស់ស្ត្រី***) និងមួយទៀត នៅក្នុងល្បែងចាក់ទឹកដូង។ នេះជាហេតុដែលនាំឲ្យ


មុខព្រះម៉ែ នៅប្រាសាទនាគព័ន្ធ

កូនក្មេរដេរម៉ែ ព្រោះគេពុំអាចមើលឃើញ**សិរ** ឬក្បាលអ្នកមានគុណឡើយ គឺឃើញតែភេទរបស់គាត់ **តើពេលណាទើបព្រះម៉ែអាចអង្គុយលើភេទគឺមាតុភូមិរបស់ខ្លួនបានវិញទៅហ្ន៎?**

និយាយមកដល់ត្រឹមនេះ ហាក់បីដូចជាខ្ញុំអ្នកស្រាវជ្រាវរាវរករឿងពិតនេះ រិះគន់អ្នកអានដែលជាកូនក្មេរ ហើយបានវាងឃ្លាតឆ្ងាយពីក្នុងសាច់រឿងកូរសមុទ្រទឹកដោះ។ ប៉ុន្តែបើខ្ញុំមិននិយាយបកស្រាយបំភ្លឺទេ ខ្លាចក្រែងខ្ញុំពុំមានឱកាសបានសរសេរពន្យល់និងចងក្រងទុក ព្រោះសង្ខារធម៌មិនទៀងឡើយ កើតហើយតែងស្លាប់ទៅវិញជាធម្មតា ហើយមរណៈនេះទៀត មិនដឹងជាមកដល់ពេលណា។ ដោយកុំឲ្យការខិតខំស្រាវជ្រាវអស់កាលដ៏យូរ ទីបំផុតជាការឥតប្រយោជន៍ ដែលពុំអាចជួយពន្យល់ប្រាប់ប្រវត្តិសាវតាពិតរបស់ដូនតា ហើយនិងជួយស្រោចស្រង់កូនក្មេរប្រុសស្រីឲ្យរួចផុតពីអន្លង់អកុសលកម្ម ដែលយើងកំពុងនាំគ្នាធ្វើពើ(**ក្រ+ពើ**) ហើយជាពិសេសទៅទៀតគឺចង់ឲ្យកូនក្មេរប្រុសស្រី រួមសាមគ្គីគ្នាឧទ្ទិសកុសលជូនទៅលោកអ្នកដ៏មានគុណទាំងនោះ។ ឥឡូវយើងបែរមកមើល រឿងកូរសមុទ្រទឹកដោះជាបន្តទៅទៀត នៅក្នុងសាច់រឿងបានប្រាប់ថា ក្បាលនាគត្រូវយក្សដែលមានក្បាលដប់ចាប់កាន់ជាប់ រើខ្លួនពុំរួចឡើយ រួមជាមួយនឹងបក្សពួករបស់គេ នៅកណ្ដាលនាគមានរូបព្រះវិស្ណុដែលមានដៃបួន ដៃពីរទប់នាគ និងដៃពីរទៀត ម្ខាងកាន់ដុំមូល (**ដុំហ្វិល** ដែលនិយាយពីរឿងពិតរបស់ព្រះម៉ែ) ហើយដៃម្ខាងទៀត កាន់ដាវឈរលើអណ្ដើក ខាងកន្ទុយមានទេវតាកំពុងចាប់ទាញក្បាលនាគពីយក្ស ដែលខាងចុងកន្ទុយមានហនុមានជាមេ នៅខាងលើមានទេវតាដែលថែរក្សាទ្វារសមុទ្រទឹកដោះ ចាំបិទបើកគម្រប ហើយខាងក្រោមបន្ទាប់មានអច្ឆរា(អប្សរា)រាប់រយពាន់ហោះហើរអណ្ដែត នៅខាងក្រោមក្នុងទឹកមានសត្វទឹកគ្រប់ប្រភេទកំពុងវិល ដាច់ខ្លួនជាកំណាត់ៗ ដោយអំណាចការកូររបស់យក្សនិងទេវតាដើម្បីស្វែងរកទឹក **អម្រឹត** ។

ដោយខ្លាចក្រែង ការបកស្រាយទៅលើរឿងកូរសមុទ្រទឹកដោះមានភាពស្រពិចស្រពិល ពុំសូវច្បាស់លាស់ ខ្ញុំនឹងយកប្រវត្តិសាស្ត្រក្មេរ ដែលបានរៀបរាប់ពីរជ្ជកាលស្ដេចជ័យវរ័ន្មទីពីរមកបកស្រាយពន្យល់បញ្ជាក់បន្ថែម។

**ក**/.ក្រោយពេលស្ដេចជ្វា បានកាត់ព្រះសិរ(ក្បាល)ស្ដេចក្មេរនៅទីក្រុងបាភ្នំ(ព្រៃវែង) មកមានស្ដេចក្មេរមួយអង្គ បានយាងត្រឡប់មកពីប្រទេសជ្វា ហើយបានកសាងទីក្រុងនៅភ្នំគូលែន ដើម្បីតឡើង

វិញនូវក្បាលដែលស្ដេចថ្វាបានកាត់ រួចបង្កើតបានរាជធានីថ្មីមួយដើម្បីតពូជពង្សស្ដេចនៅបាភ្នំ។ ហើយក្បាលដែលតក្រោយ តើគាត់យកក្បាលអ្វីទៅត? គឺគាត់យកក្បាលដំរី ទៅតក្បាលដែលគេកាត់ដាច់ពីអតីត ក្រោយមកស្ដេចអង្គនោះ ក៏បង្កើតទីក្រុងថ្មីមួយឈ្មោះហៅថា **ទីក្រុងយសោធបុរៈ** (ទីក្រុងដំរី ឬក្រុងអ្នកទាក់ដំរី)។ ដូច្នេះហើយបានជាចម្លាក់ក្មែរ មានរូបមនុស្សក្បាលដំរី (ក្បាលធំ ឬភគណេស) តើស្ដេចជ័យវរ័ន្មទី២ បានបង្កើតទីក្រុងបណ្ដោះអាសន្ន នៅភ្នំគូលែននោះ **គាត់បានធ្វើពិធីអ្វីខ្លះ?** គឺគាត់បានតាំងលទ្ធិទេវរាជដោយប្រកាសខ្លួនឯងថា ជាព្រះឥសូរ គឺស្ដេចភ្នំឬស្ដេចចក្រវាល បើស្ដេចក្មែរជាព្រះឥសូរទៅហើយ តើសាច់រឿងដែលបានឆ្លាក់លើជញ្ជាំងប្រាសាទថ្ម ជារឿងរ៉ាវព្រះឥសូរនៅក្នុងព្រហ្មញ្ញសាសនា ឬក៏រឿងរបស់គាត់? សូមមិត្តអ្នកអានត្រិះរិះពិចារណាឈ្វេងយល់រកចម្លើយពិតដោយខ្លួនឯងចុះ។

**ខ**/.ស្ដេចជ័យវរ័ន្មទី៧ ក្រោយការបង្ក្រាបពួកបរទេសឈ្លានពានឲ្យរាបទាបហើយ គាត់ក៏រៀបចំកសាងព្រះនគរ រួចឡើងសោយរាជ្យដោយប្រកាសបរមងារថា ជាពោធិសត្វលោកេស្វរៈ បើគាត់ជាពោធិសត្វលោកេស្វរៈទៅហើយ តើគាត់ឆ្លាក់រឿងរ៉ាវព្រះពោធិសត្វលោកេស្វរៈនៅក្នុង ពុទ្ធសាសនាមហាយាន ឬមួយក៏ **គាត់ត្រូវឆ្លាក់ពីរឿងរបស់គាត់?**

អស់លោក និងមិត្តអ្នកអានជាទីមេត្រី ការបកស្រាយបំភ្លឺនេះ ធ្វើឲ្យយើងយល់ថា ការពិតរឿងរ៉ាវនៅលើជញ្ជាំងគ្រប់ប្រាសាទថ្ម គឺជារឿងពិតៗរបស់ក្មែរ ប៉ុន្តែយើងបែរជាយល់ច្រឡំតាម គំនិតបំភាន់របស់បរទេសទៅវិញ ដោយពួកគេបានសរសេរលាក់អាថ៌កំបាំងសាវតាពិត មិនឲ្យកូនម៉ែប្រុសស្រីបានដឹង យល់ពីបណ្ដាំព្រះម៉ែដែលបានចារឹកទុកនៅលើថ្មទាំងនោះឡើយ។ ហេតុអ្វីក៏ខ្ញុំជាអ្នកស្រាវជ្រាវអាថ៌កំបាំងព្រះម៉ែមហានគរ ចេះតែទាញយកហេតុផលមកបញ្ជាក់ពន្យល់ពុំចេះចប់យ៉ាងដូច្នេះ? ដោយខ្ញុំយល់ថា ក្មែរយើងបានសិក្សាតាមក្បួនច្បាប់របស់បរទេសដែលពួកគេបានស្រាវជ្រាវឲ្យកូនក្មែររៀន និងសិក្សារាប់ជំនាន់មកហើយ ប៉ុន្តែយើងពុំបានយល់ពីការបំភ័ន្តរឿងពិតរបស់បរទេសឡើយ ហេតុនេះបានជាអ្នកប្រាជ្ញក្មែរខាងដើមរបស់យើង គាត់បានតាក់តែង ប្រស្នាជាទំនុកឲ្យកូនក្មែរច្រៀងគឺបទ **សារិកាកែវ** ដែលមានសេចក្ដីថា៖

-សារិកាកែវអើយស៊ីអីកងៗ ស៊ីផ្លែដំបងប្រចឹកគ្នាលេង
-ស្លាបវាចាក់ក្បាច់មាត់វាធ្វើភ្លេង ប្រចឹកគ្នាលេងក្នុងព្រៃព្រឹក្សា

តើមិត្តអ្នកអានធ្លាប់បានឮ និងច្រៀងបទចម្រៀងនេះទេ ? ហើយដឹងពីអាថ៌កំបាំងនៃបទចម្រៀងដែរឬទេ? មិត្តអ្នកអានដឹងទេថា សត្វសារិកាកែវមុននឹងចេះនិយាយ គេត្រូវតែធ្វើទណ្ឌកម្មវា គឺកោសអណ្ដាតវា ទើបបង្រៀនវាឲ្យវាថាតាមឬនិយាយតាម អ្នកបង្រៀនឲ្យវាចេះនិយាយប៉ុណ្ណា វាចេះតែប៉ុណ្ណឹង ពុំអាចចេះឲ្យហួសពីម្ចាស់បង្រៀនបានឡើយ នេះជាសារជាតិរបស់សត្វសារិកាកែវ។ ចំណែកផ្លែដំបង មិត្តអ្នកអានស្គាល់ផ្លែនេះទេ? ផ្លែដំបងនេះ គឺអ្នកប្រាជ្ញខ្មែរគាត់ចង់ប្រាប់ថា គ្រប់ជនបរទេសដែលធ្លាប់ធ្វើអាណានិគមមកលើប្រទេសខ្មែរនោះ ពួកគេតែងវាយដំឲ្យជនជាតិខ្មែរយើង ធ្វើតាមនិងនិយាយតាមគេ ហើយស្នាមរបួសដែលត្រូវវាយដោយដំបងនោះ ពេលជាសះស្បើយឡើងវិញ តែងតែមានផ្លែនៅលើសាច់ដែលបែករយះនោះ យើងតែងហៅថាផ្លែសាច់ ប៉ុន្តែផ្លែសាច់នេះគឺកើតពីការវាយដោយដំបង(**ផ្លែដោយសារដំបង អាថ៌កំបាំងដំបងនេះខ្ញុំនឹងពន្យល់ក្នុងភាគ៣**)។ ដូចកាលអាណានិគមបារាំងបានបង្ខំឲ្យប្រជារាស្ត្រខ្មែរ សរសេរអក្សរឡាតាំង ប៉ុន្តែដោយចលនាតស៊ូរបស់អាចារ្យ **ហែមចៀវ** គាត់បានក្រោកឡើងតស៊ូប្រឆាំងនឹងពួកបរទេសទើបយើងអាចរក្សា ភាសាជាតិបានមកដល់សព្វថ្ងៃនេះ កុំអីកូនខ្មែរពុំអាចមានអក្សរសាស្ត្រជាតិរបស់ខ្លួនឡើយ។ ដូចនេះមិត្ត អ្នកអានស្គាល់ផ្លែដំបងហើយ គឺគេបង្ខំអោយកូនខ្មែរជំនាន់អាណានិគម ថាតាមគេនិយាយតាមគេ ដូចសារិកាកែវយ៉ាងដូច្នោះ បរទេសវាយដូនតាខ្មែរ ដូនតាវាយឪពុកម្ដាយ ឪពុកម្ដាយវាយកូនបន្តគ្នា កើតជាផ្លែសាច់បន្តមកដល់សព្វថ្ងៃដោយសារដំបង (**ផ្លែដំបងមានពីរ មួយលើស្បែក មួយទៀតនៅក្នុងចិត្ត**។

ហេតុនេះហើយ ទើបធ្វើឲ្យកូនខ្មែរជំនាន់ក្រោយ ពុំអាចដឹងពីសារតាពិតរបស់ខ្លួនឡើយ ដូច្នេះអ្នកប្រាជ្ញដែលគាត់បានយល់ពីអាថ៌កំបាំងនេះ គាត់បានតែងបទ ចម្រៀងជាប្រស្នានេះទុក ព្រោះចង់ឲ្យកូនខ្មែរជំនាន់ក្រោយត្រិះរិះពិចារណា នៅចម្រៀងបង្កប់ទៅដោយប្រស្នានេះ។ ដោយការទាញយកនូវហេតុផលមកពន្យល់ និងប្រៀបធៀបនេះខ្ញុំនឹងខិតខំស្រាវជ្រាវរាវរករឿងហេតុពិតហើយសាមញ្ញដែលលាក់កប់ទុកក្នុងស្រទាប់អ្នកស្រែ ដើម្បីយកមកវែកញែកឲ្យអស់លោក មិត្តអ្នកអានតាមដានជាបន្តទៅទៀតនៅទំព័រខាងក្រោយ។

**គ**/.ឥឡូវយើងត្រឡប់ថយក្រោយ មកពិចារណាសិក្សារឿង **កូរសមុទ្រទឹកដោះ**ឡើងវិញ ហេតុអ្វីបានជាខ្ញុំយករឿងកូរសមុទ្រទឹកដោះ**មកជាគោល** ដើម្បីលាតត្រដាងបង្ហាញ ព្រោះរូបចម្លាក់រឿងទាក់ទងនឹងពាក្យមាតុភូមិ និងពាក្យក្មេរដែលខ្ញុំបានពន្យល់ខាងលើរួចហើយ ហើយដែលខ្ញុំលើកយកមកបកស្រាយក្នុងពេលនេះ គឺចង់ពន្យល់ពីតួអង្គរូបក្នុងរឿងដើម្បីឲ្យមិត្តអ្នកអាន យល់ពីខ្លឹមសារពិតដោយឈរលើបណ្ដាំព្រះម៉ែ។ ជៀសវាងការយល់តាមគំនិតបរទេស ដែលយើងធ្លាប់អាន ស្ដាប់ ធ្លាប់សូត្រតាមគម្ពីរគេពីមុនមកនោះ ឲ្យមកជារបស់ជាតិក្មេរសុទ្ធសាធវិញ ព្រោះម៉ែឪខំរកស៊ីមួយជីវិត គឺដើម្បីទុកទ្រព្យសម្បត្តិកេរមរតកឲ្យកូន ពុំមែនទុកឲ្យអ្នកដទៃនោះឡើយ។ ម្ដាយឪពុកទោះបីជាក្រក្សត់ក៏គង់មានរបស់របរបន្តិចបន្តួចទុកជាកេរ ឲ្យកូនប្រុសស្រីគាត់ដែរ ចុះទម្រាំដូនតាយើងជាអ្នកដ៏ប្រសើរជាព្រះម៉ែ ជាពូជពង្សអ្នកកសាងប្រាសាទថ្ម ហេតុអ្វីបានជាទុករឿងរ៉ាវទាំងអស់នៅលើថ្មឲ្យទៅជារឿងរបស់សាសនាភាគច្រើនទៅវិញ? ហេតុអ្វីក៏កូនក្មេរមិនខិតខំស្រាវជ្រាវរកបណ្ដាំព្រះម៉ែ? ចំណុចនេះហើយ ដែលយើងជាកូនក្មេរត្រូវតែចេះឆ្ងល់ចេះត្រិះរិះពិចារណាឈ្វេងយល់ ទើបអាចស្វែងរកនូវការពិតឃើញ បើពុំនោះទេយើងនៅតែមានការយល់ច្រឡំដដែល។ ដូចពាក្យសុភាសិតក្មេរបានពោលថា **វប្បធម៌រលត់ ជាតិរលាយ អរិយធម៌ពណ្ណរាយ មាតុភូមិរុងរឿងថ្កើងថ្កាន** ដូច្នេះក្នុងនាមជាកូន អ្នកទទួលមរតកព្រះម៉ែ (កេរ+ម៉ែ) ត្រូវតែសាមគ្គីគ្នា ស្រាវជ្រាវរាវរកការពិត ក្នុង**អាថ៌កំបាំងបណ្ដាំប្រស្នារបស់ព្រះម៉ែមហានគរយើង។**

តួអង្គទាំងឡាយនៅក្នុងសាច់រឿង **កូរសមុទ្រទឹកដោះ** រឿងនេះ ក្នុងសង្គមក្មេរទើបកើតមានឡើងក្នុងឆ្នាំ១៩៩៣ ក្នុងពេលដែលប្រទេសក្មេរកើតមាននូវពហុបក្ស ពេលនោះគណៈកម្មាការជាតិរៀបចំការបោះឆ្នោតកកើតឡើង រាជរដ្ឋាភិបាលបានយកនិម្មិតរូប គឺ**រូបកូរសមុទ្រទឹកដោះ** ដែលមានក្រុមទេវតានិងយក្សចាប់ទាញនាគ ហើយមានព្រះវិស្ណុចុះមករារាំងឲ្យឈប់ទាញនាគ កូរសមុទ្រទឹកដោះស្វែងរកនូវទឹកអម្រឹតទៀត។ ព្រោះពីអតីតកាល ក្នុងមាតុភូមិនេះពុំដែលយកនិមិត្តសញ្ញារូបនេះឡើយ ដូច្នេះចូរមើលនូវការពន្យល់តាមន័យពិតក្នុងសង្គមរបស់ក្មេរ អំពីរូបរឿងកូរសមុទ្រទឹកដោះដែលកើតក្នុងសម័យនោះ។

១/.**យក្សក្បាលដប់** តំណាងឲ្យសភាវអាក្រក់ ដែលចាប់ក្បាលនាគ(ចាប់ក្បាលព្រះម៉ែ) កុំឲ្យរើរួចរួមជាមួយនិងបក្សពួកនិយាយឲ្យងាយយល់ គឺឆ្នាំចាំគុក(ចង់ដឹងពីរឿងនេះ ចូរមិត្តអ្នកអានទៅស្រាវជ្រាវរូបរឿងនៅលានព្រះគម្លង់ ដែលជាកន្លែងទុកឯកសារសាវតានៅពេលព្រះម៉ែជាប់ឃុំឃាំង)។

២/.**ទេវតា** តំណាងឲ្យបក្សខាងទេវតា គឺសភាវៈល្អ សភាវៈល្អនេះនាំព្រះម៉ែនាគចេញពីទីឃុំឃាំង ប៉ុន្តែទាញពុំរួច ព្រោះពុំទាន់មានកម្លាំងគ្រប់គ្រាន់ ដោយក្រុមទេវតានៅកាន់ខាងកន្ទុយចំណែកពួកយក្ស គេមានកម្លាំងជាង ព្រោះគេបានចាប់ក្បាលនាគមុនរាប់រយពាន់ឆ្នាំទៅហើយ ដោយអំណាចបាបកម្ម របស់ព្រះម៉ែនាគ គឺបរទេសគេចុះមកស្រាវជ្រាវរាងរករឿងនេះ តាំងពីដើមសតវត្សមកម្លេះ។

៣/.**ហនុមាន** តំណាងឲ្យសភាវល្អដែលនៅខាងបក្សទេវតា ប៉ុន្តែគាត់នៅខាងកន្ទុយជាមេរបស់

ក្រុមទេវតាព្រោះរូបធំជាងគេ ហើយបើមើលមកសព្វថ្ងៃគឺតំណាងឲ្យយោធាក្មេរនេះតែម្តង ព្រោះយោធា ក្មេរពាក់បន្តោងហនុមាន ហនុមានតំណាងឲ្យអ្នកដែលធំជាងគេ មេគ្រប់គ្រងយោធា ព្រោះបើតាម មើលរូបចម្លាក់គេ ឆ្លាក់ហនុមានមាឌធំជាងក្រុមទេវតាទៅទៀត ហនុមាននៅក្នុងបក្សទេវតា។

៤/.**ព្រះវិស្ណុ** តំណាងឲ្យអ្នកថែរក្សាលោក និងជួយស្រោចស្រង់លោក គឺជាអ្នកមានគុណធមិ (កតញ្ញូកតវេទិតា) អ្នកបញ្ឈប់នូវពៀរវេរារវាងសភាវៈល្អ និងអាក្រក់ដែលកំពុងទាញនាគទាំងសងខាង។

៥/.**នាគ** តំណាងឲ្យព្រះនាងនាគ ប៉ុន្តែក្រោយមកគាត់ក្លាយជាព្រះម៉ែនាគ(មើលក្នុងពាក្យ ក្មេរ និង ក្មែរ) ខ្ញុំនឹងបកស្រាយនៅទំព័រខាងក្រោយថា ហេតុអ្វីបានជាគាត់ត្រូវជាប់ឃុំក្នុងសមុទ្រទឹកដោះ? ហើយ យក្សចាប់ក្បាលគាត់ជាប់?

៦/.**សត្វអណ្តើក** តំណាងឲ្យឧបាទានក្ខន្ធប្រាំក្នុងជាតក(រឿងដំបូកហុយផ្សែង)ក្នុងគម្ពីរព្រះពុទ្ធ សាសនា**ព្រះត្រៃបិដក**។

៧/.**អប្សរាឬអច្ឆរា** តំណាងឲ្យអ្នកបង្កើតនគរក្មែរ(ក្មេរ ➔ ក្មែរ) អប្សរាឬអច្ឆរា = **ស្ត្រីដែលមានរូប ឆោមលោមពណ៌សម្បុរស្បែកស្អាតល្អ** ហើយអាថ៌កំបាំងអច្ឆរានេះទាល់តែបុគ្គលចុះក្នុងសមុទ្រទឹកដោះ ទើបអាចដឹងសាវតារឿងពូជពង្សដែលជាអតីតកាលរបស់ព្រះមេ(នគរស្រីល្វោ)។

៨/.**ទេវតាដែលកាន់គម្របបិទបើកសមុទ្រទឹកដោះ** តំណាងឲ្យបុគ្គលដែលពុំចង់ឲ្យបុរសជាព្រះវិស្ណុ នាំយករឿងសាវតាពិតរបស់ព្រះម៉ែនាគនៅក្នុងសមុទ្រទឹកដោះមកផ្សព្វផ្សាយនៅខាងលើឡើយ គឺបិទ សន្ធប់ព្រះវិស្ណុទុកមិនឲ្យយករឿងចេញមកក្រៅរួច។

៩/.**សត្វទឹកគ្រប់ប្រភេទ** តំណាងឲ្យប្រជារាស្ត្រក្មេរ (កូននាគប្រុសស្រី)។

១០/.**សមុទ្រទឹកដោះ** តំណាងឲ្យទឹកដោះម្តាយដែលបានបង្ហូរពីដំបូង តាំងពីបង្កើតនគរព្រះម៉ែ រហូតមកដល់សព្វថ្ងៃ(បានពន្យល់រួចមកហើយនៅទំព័រខាងដើម)។

១១/.**ការទាញនាគ** តំណាងឲ្យការដណ្តើមគ្នាទៅវិញទៅមករាប់ពាន់ឆ្នាំ រវាងសភាវល្អ និងសភាវអាក្រក់ប៉ុន្តែពុំមានចាញ់ឈ្នះ ត្រូវរងចាំអ្នកទៅបញ្ឈប់នៅពៀរវេរានេះ។

១២/.**ទឹកអម្រឹត** តំណាងឲ្យដំណក់ទឹកដោះដំបូងរបស់ព្រះម៉ែ ដែលជាអ្នកបង្ហូរទឹកដោះមុនគេ ហើយមិនចេះស្លាប់(**មាតុភូមិដែលជាដែនដីអមតៈ**) គឺ**ទឹកដោះអាទិទេពក្មេរ ឬព្រះម៉ែមហានគរ**។

១៣/.**ការធ្វើជាអាជ្ញាកណ្តាល** តំណាងឲ្យអ្នកបញ្ឈប់ការទាញ ការកកូររបស់គូបដិបក្ខទាំងសងខាងដែលកើតមានរាប់ពាន់ឆ្នាំមកហើយ ឲ្យឈប់នាំគ្នាទាញ ពេលដែលព្រះវិស្ណុចុះទៅដល់ ( ហើយរឿងអាថ៌កំបាំងព្រះម៉ែនេះអាចដឹងបានលុះត្រាតែមាននិមិត្តសញ្ញាកូរសមុទ្រទឹកដោះ និងនិមិត្តសញ្ញាទេវតាកើតឡើងព្រមគ្នាក្នុងនគរ ទើបអាចដឹងរឿងនេះបាន)។

១៤/.**ព្រះវិស្ណុបែរមុខ ទៅខាងទេវតា** តំណាងព្រះវិស្ណុជួយខាងសភាវល្អ ពុំជួយខាងអាក្រក់ឡើយ មានតែបក្សដែលមាននិមិត្តសញ្ញាទេវតាទេ ទើបអាចជួយជ្រោងជ្រែងព្រះម៉ែនាគបាន។

១៥/.**ដៃទាំងបួនរបស់ព្រះវិស្ណុ** តំណាងឲ្យដៃពីរខាងក្រោមទប់នូវពៀរវេរា របស់ក្រុមទាំងសងខាង ដៃមួយខាងលើកាន់ដាវ តំណាងឲ្យប្រាជ្ញាជាអាវុធ និងជាប្រទីបសម្រាប់បំភ្លឺ ភាពងងឹតដែលពុំធ្លាប់ឃើញ ពុំធ្លាប់ដឹងពីមុនឲ្យមើលឃើញនូវការពិតរបស់ខ្លួន។ ដៃម្ខាងទៀតកាន់ដុំមូល តំណាងឲ្យគម្ពីរ ឬហ្វិល សម្រាប់ប្រមូលនូវសាច់រឿងពិតរបស់ព្រះម៉ែនាគ ដែលគេបានហាន់រឿងពិតរបស់គាត់ជាចំណិតៗ (ប្រាសាទ **ហាន់ ជ័យ**) នៅក្នុងសមុទ្រទឹកដោះ ដោយបានលាក់កប់ទុកជាយូរយារណាស់មកហើយ ពុំមានកូនក្មេរណាម្នាក់បានដឹងរឿងពិតនេះឡើយ។

១៦/.**ព្រះវិស្ណុឈរលើអណ្តើក** តំណាងឲ្យព្រះវិស្ណុឈប់ប្រកាន់បញ្ចក្ខន្ធថាជារបស់ខ្លួន រួចបាន**អធិដ្ឋាននូវបញ្ចក្ខន្ធនេះ** ឲ្យទៅយក្សទសមុខ (យក្សមុខដប់) ដើម្បីឲ្យគេព្រមដោះលែងព្រះម៉ែ (ព្រះអច្ឆរាមាតានាគ)។

១៧/.**ពពុះទឹកដែលពុះព្រួចៗ** តំណាងឲ្យពពុះទឹកចិត្តរបស់ព្រះវិស្ណុ អាចផ្សព្វផ្សាយអាថ៌កំបាំងនេះបានតែត្រឹមក្រុមញាតិ ដែលនៅជិតៗខ្លួនតែប៉ុណ្ណោះ ចំណែកឯកូនក្មេរទូទាំងនគរ ពុំអាចដឹងរឿងរ៉ាវរបស់ព្រះម៉ែបានឡើយ ព្រោះទេវតាកាន់គម្របសមុទ្រទឹកដោះ ពុំឲ្យព្រះវិស្ណុយករឿងពិតនេះចេញមកខាងក្រៅបានទេ។

១៨/.**ត្រីតូចត្រីធំ និងសត្វទឹកគ្រប់ប្រភេទ ដែលរំលងដាច់ខ្លួនជាកំណាត់ៗដោយសារការកូរសមុទ្រទឹកដោះនោះ** តំណាងឲ្យរាស្ត្រក្មេរ ដែលរងគ្រោះដោយសារសង្គ្រាម ខ្លះស្លាប់ ពិការ ព្រាត់ប្រាស់ អ្នកស្លាប់គឺប្រជារាស្ត្រ ប្រៀបដូចសត្វនៅក្នុងទឹកទាំងនោះ។

១៩/.មានតែព្រះវិស្ណុប៉ុណ្ណោះ ដែលអាចដឹងនូវអាថ៌កំបាំងក្នុងសមុទ្រទឹកដោះ ដែលបានលាក់ទុករឿងព្រះម៉ែជាប់ទោសរាប់ពាន់ឆ្នាំ ហើយបានដឹងពីរឿងពួកទេវតានិងពួកយក្ស ទាញ ព្រះម៉ែទៅវិញទៅមកពុំឈប់ឈរ ដើម្បីស្វែងរកទឹកអម្រិតគឺ **ទឹកដោះ** អាទិទេពដំបូង ម្យ៉ាងទៀតគាត់ដឹងរឿងព្រះម៉ែទន្ទឹងចាំមើល កូននាគណាមួយហ៊ានធ្វើពលិកម្មដើម្បីជ្រាវរកសាវតាពិតរបស់គាត់ហើយជួយគាត់។




បើយើងចង់ដឹងច្បាស់ យើងទៅមើលរូបភាពកូរសមុទ្រទឹកដោះ នៅខាងមុខខ្លោងទ្វារចូលក្រុងអង្គរធំ យើងឃើញខាងយក្ស ហាក់បីដូចជាចាប់ទាញនាគឲ្យចូលក្នុងគុហារឬគុកវិញ ចំណែកខាងទេវតាហាក់បីដូចជាទាញនាគចេញពីគុហារឬគុក ដូច្នេះមានតែរង់ចាំអាជ្ញាកណ្ដាលតែប៉ុណ្ណោះ និយាយម្យ៉ាងទៀតគឺរង់ចាំកូនក្មេរណាម្នាក់ ដែលហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង (កត្តញ្ញូកតវេទី) ដើម្បីចុះជួយព្រះម៉ែ។ និយាយដោយខ្លី មានតែកូនកត្តញ្ញូ គឺតួអង្គ **ព្រះវិស្ណុ ព្រះឥសូរ ព្រះពោធិសត្វលោក**

*កេស្វរៈ ព្រះព្រហ្ម... ទើបអាចជួយព្រះម៉ែមហានគរបាន ព្រោះតួរអង្គទាំងនេះ អ្នកប្រាជ្ញបានតាងនាមឲ្យគាត់ទៅតាមកាលវេលា ប្រែប្រួលរបស់សង្គមសម្រាប់កូនក្មេរម្នាក់នោះ។*

*ឃ.ប៉ុន្តែគួរឲ្យអាណិតគាត់ណាស់ នៅពេលចុងក្រោយរូបគាត់លែងក្រោកឈរដើរ ឬអង្គុយបានទៀតហើយ គឺត្រូវដេកនៅមួយកន្លែង ហើយវារលូនដឹកនាំព្រះម៉ែចេញពីគុក(ព្រះវិស្ណុដេកគងជើងព្រះម៉ែ)។ ពាក្យថាដេក គឺនៅក្នុងផ្ទះ ក្នុងបន្ទប់ លើគ្រែងាយអ្វីនឹងអាចឲ្យកូនក្មេរទាំងឡាយ ដឹងពីរឿងពិតនៅក្នុងសមុទ្រទឹកដោះបាន បើគាត់នៅក្នុងទីកំបាំងយ៉ាងនេះ។* ***តើហេតុអ្វីបានជាគេចេះតែឆ្លាក់រូបព្រះវិស្ណុដដែលៗ នៅលើប្រាសាទផងនៅក្នុងទឹកផងដូច្នេះ*** *ព្រោះដូនតាក្មេរ ខ្លាចក្រែងកូនក្មេរមួយចំនួនដែលពុំដឹងរឿងពិត ហើយស្រឡាញ់នូវមាសប្រាក់ ត្រូវពួកបរទេសជួលឲ្យដាប់គាស់បំផ្លាញរូបចម្លាក់ទាំងនោះ ប្រសិនបើគេបំផ្លាញនៅលើប្រាសាទអស់ ច្បាស់ជានៅសល់ស្នាដៃគាត់ក្នុងទឹក គ្រាន់ទុកឲ្យកូនរបស់គាត់ គឺ* ***ព្រះវិស្ណុ****អាចមើលហើយយល់នូវរឿងរ៉ាវរបស់ខ្លួន ហើយកូននាគនោះនឹងព្យាយាមជួយគាត់។ ហើយចុងក្រោយ គាត់ឆ្លាក់ព្រះវិស្ណុដេកលើនាគ ហើយនៅលើសត្វគុជសីទៀត* ***នៅប្រាសាទបន្ទាយសំរែ*** *នៅកណ្ដាលផ្ចិតព្រះវិស្ណុ មានទងផ្កាឈូកមួយដើមដុះ រួចផ្កាឈូកនោះ ក៏បំបែកជាខ្នែងបីម្ខាងរែកឪពុក ម្ខាងរែកម្ដាយ កណ្ដាលព្រះព្រហ្ម ដៃព្រះវិស្ណុជាអ្នកទប់ទងផ្កា ហើយសាច់រឿង នេះក្រៅពីព្រះវិស្ណុ* ***តើមានអ្នកណាអាចមើលយល់ មកជារឿងក្មេរបាន?*** *រូបនេះដូនតាក្មេរ គាត់ឆ្លាក់នៅលើក្បាំងក្លែង (ប្រាំងក្លែង = ប្រាំងក្លែងបន្លំ) ប្រាសាទបន្ទាយសំរែ និងប្រាសាទដទៃទៀតជាច្រើន។ មិត្តអ្នកអានមានឆ្ងល់ដែរឬទេ ហេតុអ្វីក៏ប្រាសាទនេះមានឈ្មោះថាបន្ទាយសំរែ?*

## ***<u>ពន្យល់ន័យពាក្យ</u>***

*១/.****ប្រាសាទបន្ទាយសំរែ*** *(បន្ទាយអ្នកស្រែ) គួរតែបុព្វជនក្មេរចារឹករឿងរ៉ាវអ្នកស្រែធ្វើស្រូវ ឬចំការដំណាំ តើហេតុអ្វីបានជាគាត់ឆ្លាក់សាវតារឿង ព្រះវិស្ណុដឹកនាំព្រះម៉ែចេញពីទីឃុំឃាំងទៅវិញ ? ព្រោះព្រះម៉ែដឹងថានៅពេលអនាគតនឹងមានកូន ដែលអាចមកជួយគាត់បាន តែអ្នកនោះជាពូជអ្នកស្រែ ហើយកូនអ្នកស្រែនោះ រស់នៅជ្រៅជាងអ្នកស្រែធម្មតា* ***គឺគេហៅថាសំរែ*** *មនុស្សសំរែនេះហើយ ដែលគេតាមចាប់ តាមសម្លាប់ឲ្យផុតពូជ ព្រោះមានតែអ្នកសំរែម្នាក់នេះទេ ដែលអាចដឹងរឿងអាថ៌កំបាំង ហើយ ជួយស្រោចស្រង់ព្រះម៉ែ ពីទីឃុំក្នុងសមុទ្រទឹកដោះបាន។*

២/. ក្នុងរឿង **បក្សីចាំក្រុង**

បក្សី = សត្វគ្រុឌ និមិត្តសញ្ញាប្រទេសសៀម

ក្រុង = គ្របពីលើ បាំងពីលើ **ឧ.** ក្រុងមាន់ ទា ឬគ្រុឌក្រុងនាគ (រូបគ្រុឌនៅប្រាសាទព្រះខ័ន...)

ក្រុង = រាជធានី (ទីប្រជុំជន ឬទីក្រុង)

ដូចនេះបក្សីចាំក្រុងមានន័យថា គ្រុឌចាំក្រុងនាគមិនឲ្យនាគចេញរួចពីគុក (ឆ្នាំចាំគុក) ប៉ុន្តែក្រោយមកមានកូនខ្មែរម្នាក់ មកជួយព្រះម៉ែនាគឲ្យរួចផុតពីអំណាចគ្រុឌ ព្រោះមានរូបចម្លាក់ព្រះវិស្ណុជាន់ពីលើសត្វគ្រុឌឲ្យលើកដៃឡើង ដើម្បីដោះលែងព្រះម៉ែនាគ ហេតុនេះហើយទើបគាត់ឲ្យយើងជាកូនខ្មែរចេះយករឿងព្រេង ឈ្មោះភូមិស្រុក រុក្ខជាតិ ទំនាយ.... ទៅផ្គុំនឹងរូបចម្លាក់លើថ្ម រួចបំបែកប្រស្នានឹងត្រូវដឹងពីការពិតរបស់ខ្លួនហើយ។

ដូច្នេះរឿងរ៉ាវ ដែលដូនតាខ្មែរបានបន្សល់ទុកឲ្យកូនខ្មែរ ដោះស្រាយនូវប្រស្នារបស់គាត់ គឺមានច្រើនណាស់ ទោះបីជាបរទេសខំជួលខ្មែរឲ្យដាប់បំផ្លាញឯកសារសាវតាជាតិទាំងនោះ ក៏ដាប់បំផ្លាញពុំអស់ដែរ ព្រោះសាសន គតិបណ្ឌិតរបស់ព្រះម៉ែទុកនៅលើគោកផង ក្នុងទឹកផង រឿងព្រេងផង ឈ្មោះភ្នំ ភូមិស្រុក ទំនៀមទម្លាប់ប្រពៃណី ក្នុងទំនាយ.... ហើយជាពិសេសនោះ នៅក្នុងប្រស្នាល្បែង ដែលក្មេងៗ ស្រុកស្រែតែងលេងពីសម័យដើម គឺ**ល្បែងចាក់ទឹកដូង**។

មិត្តអ្នកអានតាមដានមកទល់នឹងពេលនេះ ទើបបានដឹងថា ហេតុអ្វីក៏គេជួលឲ្យកូនខ្មែរ ដាប់រូបចម្លាក់ក្នុងប្រាសាទ រួចគេទិញក្បាលរូបបដិមាទាំងនោះ (**ក្បាលអ្នកតាឬទេវតា**...) ព្រោះគេដឹងថា ប្រវត្តិសាវតាពិតរបស់ជនជាតិខ្មែរ គឺនៅលើថ្ម(សិលាចារឹក)។ សព្វថ្ងៃបរទេស រាប់ម៉ឺនសែននាក់ នាំគ្នាចំណាយលុយរាប់ពាន់ម៉ឺនដុល្លាក្នុងម្នាក់ៗ ដើម្បីមកសិក្សាស្រាវជ្រាវពីភាសាគំនិតក្នុងចម្លាក់ ដែលបានលាក់រឿងរ៉ាវ អាថ៌កំបាំងនៅក្នុងប្រាសាទរាប់ពាន់ ដែលមាននៅក្នុងទឹកដីនេះ ព្រោះពួកគេដឹងថាដូនតាជាតិនេះ ជាកំពូលមនុស្ស**ជាព្រះមេជាព្រះម៉ែក្នុងសម័យមហានគរ**។ហេតុនេះបាននាំឲ្យក្រុមអ្នកស្រាវជ្រាវ **អាថ៌កំបាំង ប្រវត្តិសាស្ត្រគេនាំគ្នា លាត់ជើងខោ មូរដៃអាវចុះរាវរកយ៉ាងសស្រាក់សស្រាំដើម្បីស្វែងយល់ការពិតពីអតីតកាលរបស់បុព្វជនជាតិនេះ។**

៣/.ខ្ញុំចេះតែលើកយកហេតុផល មកពន្យល់មិត្តអ្នកអានដោយលើកឧទាហរណ៍ខ្លីៗ គឺចង់ពញ្ញាក់ស្មារតីកូនក្មេរ ដែលកំពុងដេកលក់ឲ្យភ្ញាក់ឡើង ព្រោះការស្រាវជ្រាវមានការលំបាកណាស់ ទម្រាំអាចប្រមូលឯកសារទាំងអស់មកផ្គុំផ្គំរួចបំបែក (**ព្រហ្មញ្ញ + ពុទ្ធសាសនា + បណ្តាំព្រះម៉ែ**) គំនិតព្រះម៉ែ ដែលគាត់រម្លាយបីឲ្យក្លាយមកតែមួយ ថ្វីបើការស្រាវជ្រាវលំបាក តែការយករឿងពិតទៅផ្សព្វផ្សាយ រឹងរិតតែលំបាកថែមទៀត ព្រោះបញ្ញាកូនក្មេរគេបានកាច់ជាផ្នត់ៗ ឲ្យយើងសិក្សាតាមរបត់គំនិតរបស់បរទេសរាប់រយឆ្នាំទៅហើយ ដូច្នេះហើយបានជាដូនតា គាត់ឆ្លាក់រូបព្រះវិស្ណុដេករួចវារគើមៗដឹកនាំរឿងពិតព្រះម៉ែចេញពីទីឃុំឃាំងនោះ។ និយាយមកដល់ចំណុចនេះខ្ញុំអ្នកស្រាវជ្រាវមានតែការតឹងក្នុងចិត្ត ក្តុកក្តួលរមួលក្នុងឱរាតែប៉ុណ្ណោះ ព្រោះលំបាកនឹងឲ្យកូនក្មេរប្រុសស្រីទទួលយក នឹងយល់ពីអាថ៌កំបាំងបណ្តាំព្រះម៉ែមហានគរនេះណាស់ ព្រោះរឿងនេះបានលាក់បាំងកប់ទុករាប់ពាន់ឆ្នាំទៅហើយ។

ហេតុអ្វីបានជាបុព្វជនកសាងប្រាសាទអង្គរវត្ត ហើយធ្វើ**ប្រាសាទគក់ទ្រូង** ដែលប្រាសាទនេះសម្រាប់ឧទ្ទិសដល់ព្រះវិស្ណុ? ប្រាសាទគក់ទ្រូងមានន័យថា គក់ទ្រូងអ្នកដែលមានទុក្ខធំនិយាយមិនចេញ និយាយចេញហើយគេពុំជឿ មិនមែនធ្វើសម្រាប់ឲ្យអ្នកសប្បាយចិត្តឬមានមោទនភាពនោះទេ ? ឧទាហរណ៍ខ្លីៗ ដែលខ្ញុំបានលើកមកពន្យល់គឺគ្រាន់តែចង់រំកញ្ឆែកបញ្ជាក់ជូនប្រាប់មិត្តអ្នកអានឲ្យជួយត្រិះរិះពិចារណាឈ្វេងយល់នូវប្រស្នាព្រះម៉ែតែប៉ុណ្ណោះ។

ដូចពាក្យដូនតាក្មេរធ្លាប់និយាយថា ៖

**សូមកូនកុំមើលនឹងភ្នែកត្រូវកូនចេះមើលនឹងថ្ងាស**(គឺត្រិះរិះគិតពិចារណាឈ្វេងយល់)

តើការបកស្រាយពន្យល់ មកជាបណ្តាំពិតរបស់ព្រះម៉ែ នេះ ត្រឹមត្រូវដែរឬទេ? បើពុំត្រឹមត្រូវទេ សូមមិត្តអ្នកអាន បោះបង់ចោលដោយកុំស្តាយ ប៉ុន្តែបើសិនជាសមហេតុផលតាមការពិតមែន សូមមិត្តអ្នកអាន ក្នុងនាមយើងជាកូនក្មេរជាពូជនាគចូររួមសាមគ្គីគ្នាឡើង ដើម្បីជួយជ្រោងស្រង់ព្រះម៉ែនាគ កុំឲ្យគាត់អស់សង្ឃឹម ដែលគាត់សុខចិត្តរងទុក្ខរាប់ពាន់ឆ្នាំ **ព្រោះហេតុតែកូននាគប្រុសស្រី។**

ឯកសារសាវតាខ្លីៗដែលខ្ញុំបានពន្យល់ជាលំដាប់លំដោយហូរហែមកនេះ គឺខ្ញុំគ្រាន់តែច្បិចយកពីក្នុងឯកសារសាវតារបស់បុព្វជនក្មេរ ដែលបានបន្សល់ទុករាប់ម៉ឺនសែន ហើយពេលខ្លះសូម្បីខ្ញុំបាទជាអ្នក

ស្រាវជ្រាវក៏ពុំទាន់មានបញ្ញាអាចបំបែកឈ្វេងយល់នូវអាថ៌កំបាំងដទៃទៀតឲ្យអស់បានឡើយ ព្រោះបណ្តាំរបស់គាត់មានជម្រៅពន់ពេក។ ហេតុនេះមិត្តអ្នកអាន ច្បាស់ជាយល់ថាការស្រាវជ្រាវរបស់ខ្ញុំ និងការស្រាវជ្រាវរបស់អ្នកជំនាន់មុន (**ខ្មែរ + បរទេស**) គឺខុសគ្នាពីព្រោះការស្រាវជ្រាវរបស់ខ្ញុំៗបានទាញចេញពីបណ្តាំគំនិតបណ្ឌិតពិតរបស់បុព្វជនក្មេរ (**ព្រះម៉ែ**) មកបំបែករាវរករឿងពិតក្នុងទឹកចិត្តរបស់គាត់ ដោយខ្ញុំ **មិនចង់ឲ្យកូនក្មេរនាំគ្នាយល់ច្រឡំជាបន្តទៅទៀតឡើយ។**

ឥឡូវចូរយើងនាំគ្នា មកពិចារណា ពីរអាថ៌កំបាំងផ្លែឈើមួយប្រភេទ ដែលមានឈ្មោះតាំងពីអតីតកាលមក ហើយមានបង្កប់នូវន័យប្រស្នាយ៉ាងជ្រៅ ផ្លែឈើធម្មជាតិនោះ យើងហៅថា **ផ្លែដូង។ ហេតុអ្វីបានជាបុព្វជនក្មេរ ដាក់ឈ្មោះផ្លែឈើនេះ ថាជាដូង** យើងដឹងហើយថា ពេលចង់ហូបផ្លែនេះ ត្រូវតែបេះវាយកមកកាប់ហូបគឺ **បេះដូង** ហើយពាក្យនេះវាដូចនឹងដុំសាច់មួយដុំនៅក្នុងទ្រូងរបស់យើងគ្រប់ៗគ្នា គឺ **បេះដូងៗ** ជាទីសំណាក់របស់ចិត្ត ព្រោះអ្នកប្រាជ្ញគាត់ពុំចេះដាក់ឈ្មោះអ្វីមួយ ដោយមិនមានន័យបង្កប់ក្នុងពាក្យនោះឡើយ។ **តើផ្លែដូងមានលាក់អ្វីខាងក្នុង?** គឺលាក់**ទឹក** ចំណែកបេះដូងមនុស្សក៏មានលាក់ទឹកក្នុងដុំសាច់នោះ មួយទុកដៃដែរគឺ**ទឹកចិត្ត** ហើយក្នុងទ្រឹស្តីព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានសម្តែងថា ទឹកនេះតែងប្រែប្រួលទៅតាមចិត្ត ចិត្តជាកុសលទឹកថ្លា ចិត្តជាអកុសលទឹកល្អក់ ចំណែកផ្លែដូងក៏មានលាក់ទុកនូវទឹកដូចបេះដូងដែរ។

**តើផ្លែដូងមានប៉ុន្មានស្រទាប់ ដែលលាក់ទុកនូវទឹកនោះ** គឺ ១.សំបក ២.ស្រកី ៣.លលាដ៍ ៤.សាច់

**តើបួននេះគាត់ប្រៀបធៀបទៅអ្វី?**

១.សំបក ដូច **មេត្តា**    ២.ស្រកី ដូច **ករុណា**

៣.លលាដ៍ ដូច **មុទិតា**    ៤.សាច់ ដូច **ឧបេក្ខា**

ចំណែកឯបេះដូងមនុស្សវិញ ក៏លាក់ទុកក្នុងស្រទាប់ **បួន** ដែរ គឺ ៖

-ស្រទាប់ទី១ គឺស្បែក

-ស្រទាប់ទី២ គឺសាច់

-ស្រទាប់ទី៣ គឺសរសៃ

-ស្រទាប់ទី៤ គឺឆ្អឹង

បកស្រទាប់បួនចេញ ទើបយើងឃើញទឹកមួយទុកដៃនៅក្នុងបេះដូង គឺទឹកចិត្ត ទឹកចិត្តនេះហើយ ដែលបង្កប់នូវធម៌បួនហៅថា **ព្រហ្មវិហារធម៌** ( ធម៌ជាដំបូលសម្រាប់ឲ្យកូនប្រុសស្រីជ្រក)។ **ព្រហ្មវិហារធម៌** តែងមាននៅគ្រប់មាតាបិតារាល់រូប ជាពិសេសគឺព្រះម៉ែអ្នកបង្កើតនគរ ព្រោះឈ្មោះនគរ និងជនជាតិនេះ កើតឡើងពីព្រះម៉ែអ្នកដាក់ឈ្មោះឲ្យ សព្វថ្ងៃយើងស្គាល់ថាក្មេរ (ខ្មែរ)។ ហើយផ្លែដូងដដែលនេះ គាត់បន្សល់ទុកក្នុងល្បែងមួយប្រភេទ សម្រាប់កូនក្មេរដែលនៅស្រុកស្រែចំការលេង គឺល្បែង **ចាក់ទឹកដូង** តើល្បែងចាក់ទឹកដូងនេះ មានអត្ថន័យយ៉ាងណា ? ខ្ញុំនឹងបកស្រាយពន្យល់ក្នុងន័យពិតរបស់ល្បែងនេះ ដើម្បីឲ្យកូនក្មេរដឹងថា ដូនតាយើងពិតជា **អ្នកប្រាជ្ញាបណ្ឌិតមែន** ព្រោះគាត់បានទុកប្រស្នាសម្រាប់ឲ្យកូនក្មេរ ស្រាយបំបែកនូវគំនិតរបស់គាត់ រួចទើបអាចជួយស្រង់គាត់បាន។ ហើយប្រស្នានេះជាពិសេស គឺគាត់ទុកឲ្យកូនអ្នកស្រែ(**អ្នកសំរែ**) អ្នកចំការជាអ្នកស្រាយតែប៉ុណ្ណោះ ព្រោះកូនក្មេរអ្នករស់នៅទីក្រុង ពុំសូវចេះលេងល្បែងនេះឡើយ។

៤/.ពាក្យពិតពីដើម របស់ល្បែងចាក់ទឹកដូងបែបទីមួយ ៖

## ក/.(បែបទីមួយ)

**-ចាក់ទឹកដូងពីទ្រូងម៉ែ កន្ទុយខ្លែងក្មេរពាក់ក្បាលក្រពើ**

**-ក្រពើជិះសេះខ្ញុំជិះដំរី ក្រពើចង់ឆី**

**-ខ្ញុំឡើងផ្ទះក្រពើត្របាក់ ខ្ញុំប្រឹងរុលក្រពើ**

**-ភ្នែកទុល ខ្ញុំញីម្ទេស។**

ពាក្យនិយាយក្លាយ ដែលក្មេងថា ពុំសូវច្បាស់ក្មេងនិយាយតគ្នាថា ៖

**-ចាក់ទឹកដូងមីឡូងមីឡៃ កន្ទុយមាន់ចៃពាក់ក្បាលក្រពើ**

-ក្រពើជិះសេះ ខ្ញុំជិះដំរី

-ក្រពើកងកី ខ្ញុំកងកាក់ ក្រពើចាក់រ៉ាក់ ខ្ញុំចាក់ម្ជុល

-ក្រពើភ្នែកទុល ខ្ញុំញីម្ទេស។

ព្រោះល្បែងប្រស្នានេះ អ្នកប្រាជ្ញជំនាន់មុនដែលជាអ្នកបង្កើត គាត់បង្រៀនតែកូនក្មេងតូចៗ ដែលនិយាយមិនទាន់ច្បាស់ ឲ្យលេងជុំគ្នាដើម្បីកែជម្ងឺអផ្សុក ដូច្នេះទើបក្លាយទៅតាមភាសាដែលក្មេង ទើបរៀននិយាយនោះ។ ហើយល្បែងដដែលនេះ គឺអ្នកប្រាជ្ញ **ធនជ័យ (ជ័យវរ្ម័នទី៧)** ជាអ្នកតាក់តែង រៀបរៀងឡើង **(ព្រោះធនជ័យគាត់កើតឡើងពីម្ដាយ ដែលបានយល់សុបិនឃើញថា យល់សប្ដិយល់សូង យល់សប្ដិបេះដូង បេះបានទាំងផ្លែ យល់សប្ដិឃើញខែ ខែពេញបូណ៌មី)** ហើយអ្នកតែងរឿងនេះ គឺស្ដេច ជ័យវរ្ម័នទី៧ លោកតែងប្រាវព្ធទៅលើមនុស្សម្នាក់ ដែលហ៊ានប្រឆាំងនឹងអ្នកជិះជាន់កេងប្រវ័ញ្ចគ្រប់ លំដាប់ថ្នាក់ រហូតដល់បរទេស មានគំនិតចង់លេបយកទឹកដីនេះ (ធនជ័យ ➔ ជ័យធន ឬជ័យវិធន=ជ័យ វរ្ម័នទី៧)។

តើល្បែងនេះមានបង្កប់នូវអាថ៌កំបាំង ឬអត្ថន័យអ្វីខ្លះ ? ហើយប្រស្នាក្នុងល្បែងនេះ គាត់ចង់ឲ្យ យើងមើលឃើញពីរឿងអ្វី? ហេតុអ្វីបានជាល្បែងនេះចេះលេងភាគច្រើនតែកូនអ្នកស្រែ?

បានជាគាត់(បុព្វជន) បង្រៀនតែកូនក្មេងអ្នកស្រែ ពុំបង្រៀនចាស់លេង ព្រោះមានតែកូនអ្នក ស្រែទេ ដែលអាចថែរក្សាទុកនូវមរតកនេះ ឲ្យបានគង់វង្សរហូតមកទល់សព្វថ្ងៃ។ ព្រោះកូនអ្នកស្រែ ពុំ មានល្បែងទំនើបៗដូចកូនអ្នកទីក្រុងឡើយ ម៉្យាងទៀតអាថ៌កំបាំងភាសាថ្ម នៅប្រាសាទបន្ទាយសំរែ បានគូសបញ្ជាក់ហេតុផលប្រាប់រួចទៅហើយ (ពន្យល់ដោយសង្ខេបខាងលើ)។ ក្នុងល្បែងប្រស្នានេះគាត់ ចង់ឲ្យយើងមើលឃើញនូវរឿងពិតពីអតីត បច្ចុប្បន្ននិងតទៅអនាគត របស់វាសនាក្នុងនគរព្រះម៉ែ ល្បែងនេះ បានបង្កប់នូវរឿងរ៉ាវក្នុងបេះដូងម្ចាស់នគរ ខ្ញុំនឹងពន្យល់អត្ថន័យម្ដងមួយឃ្លាៗ ឲ្យមិត្តអ្នក អានបានយល់អត្ថន័យក្នុងប្រស្នានេះ។

១/.**ចាក់ទឹកដូងពីទ្រូងម៉ែ** ចង់ដឹងរឿងម៉ែ ទាល់តែកូនប្រុសស្រីចាក់ទឹកចិត្តគាត់ចេញពីក្នុងបេះដូង មកទើបអាចដឹងរឿងពិតរបស់គាត់ (ខ្ញុំបានពន្យល់ពីអាថ៌កំបាំងព្រះម៉ែខាងដើមរួចខ្លះហើយ)។

២/.***កន្ទុយខ្លែងក្មេរពាក់ក្បាលក្រពើ***ខ្លែងក្មេរ គឺខ្លែងឯកៗ គឺមានតែមួយ ខ្លែងឯកនេះ បានបង្ក្រាបស្ដេចចិនក្នុងរឿងធនជ័យ (ខ្លែងក្មេរ) ដែលជាកេរដំណែលរបស់ព្រះម៉ែពីអតីត គឺនៅសល់តែកន្ទុយប៉ុណ្ណោះ ចំណែកឯឯកដែលនៅខាងក្បាលនោះ ត្រូវក្រពើលេបត្របាក់បាត់ឈប់ស្រែកបញ្ចេញនូវសម្លេងមោទនភាពថ្កុំថ្កើងរុងរឿង របស់ព្រះម៉ែពីអតីតទៀតហើយ ព្រោះកូនក្មេរសព្វថ្ងៃ នាំគ្នាយកក្បាលក្រពើមកពាក់ (ខ្ញុំបានពន្យល់រួចហើយ ពីអត្ថន័យនៃពាក្យក្រពើ) ហើយយើងនាំគ្នាធ្វើពើ លុបដានស្នាមដែលបង្ហាញពីភាពរុងរឿងរបស់ព្រះម៉ែមហានគរ អស់ទៅហើយ។

៣/.***ក្រពើជិះសេះខ្ញុំជិះដំរី*** (***ក្រ+ពើ***) ការក្រដឹងគុណនេះ បានដេញត្របាក់ខាំមនុស្សម្នាក់ ដែលជាកូនឡើងពីទីទុក្ខ (គុក) ដើម្បីព្យាយាមជួយស្រង់ម៉ែ ***ឲ្យគាត់ធ្វើពើមិនដឹងគុណព្រះម៉ែដែរ តែគាត់ពុំព្រម។***

៤/.***ក្រពើចង់ឆីខ្ញុំឡើងផ្ទះ***មានន័យថា គាត់ឡើងកាន់តែខ្ពស់ កុំឲ្យការមិនដឹងគុណ (ក្រ+ពើ) តាមខាំត្របាក់គាត់បាន បើក្រពើខាំបានគាត់នឹងធ្វើពើ មិនដឹងគុណព្រះម៉ែមហានគរ ដូចគេដែរ។

៥/.***ក្រពើត្របាក់ខ្ញុំប្រឹងរុល*** ព្រោះក្រពើប្រឹងឡើង តាមដេញត្របាក់គាត់ៗប្រឹងរុលទៅខាងលើទៀត។

៦/.***ក្រពើភ្នែកទុលខ្ញុំញីម្ទេស*** ពេលក្រពើចាប់ផ្ដើមអស់កម្លាំងហើយ ទើបបុរសដែលងើបរួចពីអន្លង់ក្រពើ ឬទីទុក្ខ គាត់យកម្ទេសមកញីភ្នែកក្រពើឲ្យភ្លឺ។ ព្រោះចាស់ៗគាត់តែងតំណាលតៗគ្នាថា បើងងឹតភ្នែក ឲ្យយកម្ទេសទៅញីគឺភ្លឺហើយ យ៉ាងណាមិញកូនក្មេរប្រុសស្រីដែលធ្វើពើមិនដឹងគុណយូរមកហើយ ប៉ុន្តែពេលនេះបុរសដែលងើបរួចពីអន្លង់ក្រពើ បានយកម្ទេសគឺរឿងពិតរបស់ព្រះម៉ែមកញីភ្នែកកូនក្មេរយើងឲ្យភ្លឺឡើងវិញ។ (កូនម៉ែកុំភ្លេចពេលភ្នែកត្រូវញីម្ទេស គឺក្រហាយផ្សា ប៉ុន្តែក្រោយមកនឹងភ្លឺ)

***៥.*** ចំណែកល្បែងចាក់ទឹកដូង***បែបទីពីរ*** កាលចាក់លើកទីមួយ ពុំអាចដឹងរឿងរ៉ាវរបស់ព្រះម៉ែបានអស់ឡើយ ព្រោះរវល់តែរត់គេច ពីក្រពើដែលដេញខាំ ដូចនេះគាត់ត្រូវតែព្យាយាម ចាក់ទឹកចិត្តម៉ែចេញពីបេះដូងជាលើកទីពីរទៀត ទើបអាចដឹងរឿងកាន់តែច្បាស់ពាក្យពិតពីដើមនោះគឺ ៖

## ខ/. (បែបទីពីរ)

-ចាក់ទឹកដូងពីទ្រូងមាតា កន្ទុយត្រីប្រាក្បាលនាងកុក
-អកកំប្រោរចាំកូនស្រង់ បំពង់ស្រីចាំកូនរៃក
-ក្បាលម៉ែពេក ក្អែកជុះអាចម៍ដាក់ប៉ក់។

ពាក្យដែលក្មេងលេងហើយថា បន្តគ្នានឹងនិយាយពុំច្បាស់ថា ៖

-ចាក់ទឹកដូងមីឡូងមីឡា កន្ទុយត្រីប្រាមីនាងអុក

-អកកំប្រោរប្រចាំថង់ បំពង់ឫស្សីប្រចាំរៃក

-ក្បាលទំពែក ក្អែកជុះអាចម៍ដាក់ប៉ក់។

តើចាក់ទឹកដូងក្នុងរបៀបទីពីរនេះ មានអត្ថន័យដូចម្តេច? ខ្ញុំនឹងពន្យល់មួយឃ្លាម្តងៗ ដូចតទៅ៖

១/. **ចាក់ទឹកដូងពីទ្រូងមាតា** (មាតា=ម៉ែ) ចង់ដឹងរឿងម៉ែទាល់តែចាក់ទឹកចិត្តចេញពីបេះដូងគាត់ ទើបដឹងរឿងពិតរបស់គាត់ (បណ្តាំក្នុងចិត្តព្រះម៉ែមហានគរ)។

២/. **កន្ទុយត្រីប្រាក្បាលនាងកុក** (ក្នុងឃ្លានេះ សូមប្រិយមិត្តអ្នកអានទៅតាមដានក្នុងរឿង ធន ជ័យ អ្នកប្រាជ្ញនេះពេលគាត់រៀបស្លាប់គាត់បានផ្តែផ្តាំស្តេចថា ៖

-បើព្រះអង្គសោយត្រីព្រួលកុំចោលស្រកា សោយត្រីប្រាកុំចោលស្រកី

-ស្ងោរក្បាលត្រីប្រា កុំចោលម្ទូរសណ្តាន់ ។

ពេលនេះខ្ញុំទាញយកមួយវគ្គត្រង់ (**សោយត្រីប្រាកុំចោលស្រកី** វគ្គដទៃខ្ញុំពុំពន្យល់ឡើយ ព្រោះឥត ទាក់ទងនឹងប្រស្នាចាក់ទឹកដូង ព្រោះធនជ័យគាត់យល់ថា ស្រកីរបស់ត្រីប្រា គឺដង្ហើមរស់ ដង្ហើមគិត របស់ ត្រី ស្រកីតំណាងឲ្យ នយោបាយសេដ្ឋកិច្ចរបស់ជាតិ យ៉ាងណាមិញអ្នកដឹកនាំត្រូវតែមានប្រាជ្ញាក្នុងការ ដឹកនាំ ដោយមិនពឹងផ្អែកទៅលើគំនិតបរទេស ដើម្បីឲ្យប្រទេសរុងរឿងដូចសម័យមហានគរ ហើយ ស្រកីគឺនូវត្រង់ក្បាលតែម្តង ចុះហេតុអ្វីបានជាក្នុងវគ្គនេះ គាត់បែរជាថាកន្ទុយត្រីប្រា តែក្បាលនាងកុក

*ទៅវិញ ចម្លើយមិត្តអ្នកអានឈ្វេងយល់ដោយខ្លួនឯងចុះ។ អ្នកប្រាជ្ញាធនជ័យបានផ្តាំទុកឲ្យអ្នកដឹកនាំគ្រប់ជំនាន់ថា* **បើកូនចង់ដឹកនាំប្រទេសឲ្យបានរឹងមាំ និងរុងរឿងត្រូវចេះប្រាស្រ័យទាក់ទង ពីតូចទៅធំ ពីទាបទៅខ្ពស់ ពីនគរមួយទៅនគរមួយ***ទើបនគរអាចរុងរឿងបាន នេះជាប្រស្នាធនជ័យទាក់ទងនឹងពាក្យត្រីប្រា គឺ*ប្រាស្រ័យទាក់ទង **(ប្រស្នាធនជ័យនេះមានពន្យល់ក្បោះក្បាយក្នុងភាគបី)។**

*៣/.* ***អកកំបោរចាំកូនស្រង់*** *អកកំបោរជានិមិត្តរូបរបស់ស្ត្រីជាម្តាយ ម៉ែ ឬយាយ....។ ព្រោះកេរមរតករបស់ម៉ែគឺ(ម្លូស្លា កំបោរ) តែពេលនេះ អកកំបោរដែលជាកេរព្រះម៉ែបានលិចចុះទៅក្នុង សមុទ្រទឹកដោះនៃអតីតកាលអស់ទៅហើយ គាត់មានតែស៊ូទ្រាំដេករងចាំមើលក្នុងទីទុក្ខ តើកូនកត្តញ្ញូក្មេកណាមួយ ដែលស្រង់កេរតំណែលព្រះម៉ែឡើងមកវិញ (ជួយព្រះម៉ែឲ្យ រួចផុតពីទីឃុំឃាំងទៅតាមបណ្តាំគាត់)។*



**រូបទឹកអង្គបំពង់ស្រី**

*៤/.***បំពង់ស្រីចាំកូនរើក** *អាចារ្យពេលាការ ភាគច្រើនតែងឲ្យពរដល់កូនប្រុសស្រី ដែលរៀបមង្គលការថា សូមឲ្យរស់នៅ ហើយស្រឡាញ់គ្នាឲ្យ***ត្រជាក់ត្រជុំដូចទឹកអប់បំពង់ខ្ចី** *ប៉ុន្តែតាមពិតពាក្យនេះ គឺខុសន័យដើមទាំងស្រុង ព្រោះបំពង់ខ្ចីគឺសំដៅលើបំពង់ឬស្សីដែលខ្ចីៗ ហើយគេកាត់យកមកអប់ទឹក។ ចំណែកពាក្យពិតរបស់ពាក្យនេះ ពុំមែនដូច្នោះឡើយ គឺ* **ទឹកអង្គបំពង់ស្រី** *(វចនានុក្រមសម្តេចព្រះសង្ឃរាជ***ជួនណាតជោតញ្ញាណោ***) គឺគេយកទឹកទៅស្រោចនៅលើអង្គជាតិ(លិង្គ) រួចទឹកនេះ ហូរធ្លាក់មកក្នុងទរយោនីនាងឧមាវតី (បំពង់យោនី) រួចទើបគេនាំគ្នាត្រងយកទឹកនោះមកធ្វើជាទឹកមង្គល (អាចារ្យពីដើម)។ នេះគឺជាអាថ៌កំបាំងមួយ ក្នុងការស្រាវជ្រាវទឹកនោះ ហើយដែលចាស់ៗពីដើមហៅថា ទឹកអង្គបំពង់ស្រី ទឹកដែលហូរចេញពីទ្វារយោនី (មាតុភូមិ) នេះហើយដែលបង្កើតបានជាពូជក្មេរប្រុសស្រី មកដល់សព្វថ្ងៃ។ ឥឡូវរឿងរ៉ាវរបស់បំពង់ស្ត្រីនេះ ត្រូវលិចកប់បាត់ស្រមោលទៅហើយ ថែមទាំងមានថ្មកមកចុកបិទបាំងពីខាងលើថែមទៀត មិនអាចឲ្យដឹងពីប្រវត្តិសាវតាពិត របស់ព្រះម៉ែនៅខាងក្រោមបានឡើយ (មនោគមវិជ្ជាបរទេស)។ ហេតុនេះហើយ ទើបគាត់រង់ចាំកូនមករើកថ្មកចេញ គឺរើកញែករឿងរ៉ាវពិតរបស់គាត់ ប្រៀបដូចជាគេរើកចកចេញ ដើម្បីមើលបាត*

ខាងក្រោម ដោយដកគំនិតនិងទស្សនៈឬមនោគមវិជ្ជាបរទេសចេញ ពីផ្នត់គំនិតកូនខ្មែរ ហើយស្រង់បណ្ដាំគំនិតព្រះម៉ែឲ្យអណ្ដែតឡើងវិញ។

៥/. ***ក្បាលម៉ែព្រៃក្អែកជុះអាចម៍ដាក់ប៉ក់*** ក្បាលព្រះម៉ែព្រៃ គឺក្បាលរហែកបែកជាបី (មើលរូបភាពចម្លាក់ថ្ម រឿងនៅប្រាសាទបន្ទាយស្រី ) គេឆ្លាក់រូបស្ត្រីម្នាក់ត្រូវហែកក្បាលជាបី ក្បាលខាងឆ្វេងដៃ ពុំមានពាក់ក្រវិលត្រចៀកទេ ក្បាលខាងស្ដាំក៏គ្មានពាក់ក្រវិលដែរ មានតែក្បាលកណ្ដាល ទើបមានពាក់ក្រវិលត្រចៀក គឺកណ្ដាលនេះហើយ តំណាងឲ្យជនជាតិខ្មែរ អ្នកស្នងមរតកព្រះម៉ែ (មាតុភូមិ) ចំណែកក្បាលស្ត្រីសងខាង ដែលឥតពាក់ក្រវិលនេះ គឺតំណាងឲ្យបរទេស ដណ្ដើមហែកទឹកដីពីប្រទេសព្រះម៉ែទៅ(អាចកំបាំងរូបដំរីក្បាលបី)។ ដូច្នេះទើបពួកគេ ពុំមែនជាអ្នកទទួលកេរពីព្រះម៉ែ (ឥតមានពាក់ក្រវិល) ចំណែកឯដំរីក្បាលបី ក៏តំណាងឲ្យអតីតនគរ ***យសោធរបុរ*** (ទីក្រុងដំរី ឬទីក្រុងអ្នកទាក់ដំរី) តែទីក្រុងនេះពីអតីត គឺតំណាងឲ្យដំរីមានក្បាលតែមួយទេ




ក្រោយមកដំរី ត្រូវគេដណ្ដើមហែកក្បាលជាបីតែខ្លួនមួយ គ្រាន់តែរូបចម្លាក់ប្រភេទទីមួយ គាត់ប្រៀបធៀបជាមនុស្ស និងមួយទៀតគាត់ប្រៀបធៀបជាសត្វ។ មិត្តអ្នកអានតាមដានមកដល់ត្រឹមនេះ ទើបដឹងថារឿងក្នុងប្រស្នារូបទាំងនោះ សុទ្ធតែបង្កប់នូវរឿងពិតពីអតីតកាលនៃនគរនេះទាំងអស់។ ក្អែកជុះអាចម៍ដាក់ក្បាលព្រះម៉ែ តើកើតមានពីត្រឹមណាមក? ក្អែកជាឈ្មោះនៅក្នុងទំនាយ ថ្ងៃសុក្រ ថ្ងៃសៅរ៍ ដែលតំណាងមនុស្សមួយក្រុមស្លៀកពាក់ខ្មៅលើខ្មៅក្រោម ហើយពួកនេះ នាំយកលទ្ធិជេរម៉ែមកជាមួយ ថា (**ឌុំម៉ែ**) ក្រុមនេះហើយ ដែលមកបង្រៀនកូនខ្មែរឲ្យជេរថា **ចុយម្រាយ ឬចុយម៉ាយ** (ម្រាយ ឬម៉ាយ = ម្ដាយ) ខ្ញុំបានពន្យល់ពីខាងដើមរួចហើយ។ ដូច្នេះអ្នកទទួលមរតកព្រះម៉ែ ស្រីប្រុសភាគច្រើនបានជុះអាចម៍ដាក់ក្បាលម៉ែ គឺមើលងាយគាត់ដែលជាអាទិទេពរបស់ពួកខ្លួន ហើយចាត់ទុកព្រះម៉ែដូចជាបង្គន់។

ហើយល្បែងចាក់ទឹកដូងទាំងពីរបែបនេះ ពេលចាក់ទៅត្រូវដៃណាដៃអ្នកនោះដកចេញ ពេលចប់ដៃដៃលចាក់ត្រូវនោះ ត្រូវច្បិចខ្នងដៃបន្តគ្នា (សាមគ្គីគ្នា ឬតនាគ) ពេលច្បិចរួចហើយមានដៃមួយទៀត មកកាត់ផ្តាច់នូវ**សាមគ្គីច្បិចៗ**នេះ ឲ្យដាច់ពីគ្នាវិញ គឺកូននាគប្រុសស្រីពុំអាចផ្គុំនាគ ឬសាមគ្គីឲ្យបានរឹងមាំឡើយ ដោយយើងពុំបានយល់សារតាពិតរបស់ល្បែងនេះ បើចង់ផ្គុំនាគឲ្យបានរឹងមាំ ទាល់តែដឹងពីអាថ៌កំបាំង **ប្រាសាទនាគព័ន្ធ**។

សរុបសេចក្តីមក គ្រាន់តែល្បែងកូនអ្នកស្រែលេងធម្មតាសោះ ក៏ដូនតាជាបណ្ឌិតក្មេរពីអតីតកាលគាត់បានចងក្រងអត្ថន័យប្រស្នាដ៏មានជម្រៅ ទុកឲ្យកូនម៉ែសម័យក្រោយបំបែក ប៉ុន្តែទីបំផុតមកដល់សម័យបច្ចុប្បន្ន កូនក្មេងក្មេរប្រុសស្រីភាគច្រើននាំគ្នាបោះបង់ចោលល្បែងនេះទៅហើយ រួចឈោងចាប់ល្បែងទំនើបថ្មី គឺហ្គេម (Game) តើធ្វើដូចម្តេច ទើបអាចបំបែកប្រស្នានេះបាន? គ្រាន់តែលេង ក៏យើងស្ទើរតែលែងចេះលេងទៅហើយសព្វថ្ងៃនេះ ព្រោះវប្បធម៌វិទ្យា សាស្ត្របរទេស ហ្គេមនិងល្បែងទំនើបៗ បានចូលមកលុកលុយក្នុងវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់.... ដែលជាមរតព្រះម៉ែអស់ទៅហើយ។ ដូចអាថ៌កំបាំងក្នុងរឿងព្រេង **ព្រះនាងសក់ក្រអូប** នៅភ្នំបាយ៉ង់កោរ ប្រសិនបើយើងមិនបានពិចារណាទេ យើងច្បាស់ជាយល់ថា រឿងព្រះនាងសក់ក្រអូប ឬបាយ៉ង់កោរ ជារឿងព្រេងពីសម័យមុនពុំខានឡើយ ដែលឥតមានទាក់ទងឬមានសារប្រយោជន៍អ្វីដល់យើងសម័យបច្ចុប្បន្ននេះទេ ប៉ុន្តែតាមការពិត គឺជារឿងដែលនិយាយពីបច្ចុប្បន្ននេះសុទ្ធសាធ។ ខ្ញុំនឹងបកស្រាយពន្យល់ត្រួសៗ ហើយបើមិត្តអ្នកអានចង់សិក្សាឲ្យបានពិស្តារ ត្រូវដាវសៀវភៅ **ប្រជុំរឿងព្រេងខ្មែរ**យកមកអានខ្លួនឯងបន្ថែមទៀតចុះដើម្បីជាឲ្យយល់កាន់តែច្បាស់បញ្ជាក់ថាជារឿងដែលទាក់ទងនឹងបច្ចុប្បន្នភាពនេះ។

***<u>ពន្យល់ពាក្យ</u>*** (បាយ៉ង់កោរ)

- បាយ៉ង់ បយ័ង្ក = បាយ័នឬបាយន = ការផឹក ឬ ពៅ
- (សំ.)បយង្ក , (បា.)បល្ល័ង្ក) ក្លាយមកជា បញ្ជង្ក (ប័ញ្ជយង់)
- កោរ = ជំរះដោយកាំបិត ឬឡាម (កោរសក់ ពុកមាត់ ពុកចង្កា)
- កោរ = ជ្រុះស្លឹកអស់ នៅសល់តែឬស ឬមើម (ខ្ចី ព្រៃ ប្រទាល..... កោរ)
- បយង្កកោរ ឬបាយ៉ង់កោរ = បល្ល័ង្កទទេ (បល្ល័ង្កដែលគ្មានអ្នកអង្គុយ)

*ព្រោះពាក្យកោរពេលយើងដាំប្រទាលផ្សេងៗ ពេលដល់ខែធ្លាក់ខ្យល់ គឺវាកោរស្លឹកអស់ហើយនៅសល់តែមើមប៉ុណ្ណោះដែលនៅក្នុងដី លុះត្រាតែខែធ្លាក់ភ្លៀងដើមឆ្នាំ ទើបដុះសន្លឹកចេញសារជាថ្មីមក មើមនោះមានតែអ្នកដាំទើបអាចចំណាំ ហើយអាចរកឃើញនៅទីដាំដុះពេលដែលវាកោរ។*

*យ៉ាងណាមិញប្រាសាទបាយ័ង់កោរក៏ដូច្នោះដែរ គឺសព្វថ្ងៃនៅសល់តែបល្ល័ង្កទទេឯអ្នកអង្គុយ លើបល្ល័ង្កពីអតីតនោះ ចុះទៅជាប់ឃុំក្នុងសមុទ្រទឹកដោះបាត់ទៅហើយ ដូច្នេះបានជាបុព្វជន គាត់កសាងប្រាសាទនៅលើភ្នំនោះ មានប្រាសាទបាយ័ង់កោរ ប្រាសាទដុបវិញ្ញាណ (គឺដុបវិញ្ញាណព្រះម៉ែនៅក្នុងដី) ប្រាសាទ**នាងសក់ក្រអូប** ប្រាសាទ**ព្រះកែវ**....។ល។*

*ខ្ញុំសូមលើកយករឿងព្រះនាងសក់ក្រអូប មកបកស្រាយវែកញែកបង្ហាញឲ្យត្រូវនឹងបច្ចុប្បន្ន សាច់រឿងបានប្រាប់ថា ព្រះនាងសក់ក្រអូបត្រូវបរទេសចាប់គាត់បាន ដោយសារគាត់ទៅមើលមហោស្រព នៅលើសំពៅអ្នកស្រុកឆ្ងាយ ដែលគេតាមចាប់គាត់តាំងពីមុនមកនោះ ប៉ុន្តែពេលនេះពួកគេបន្លំខ្លួនជាអ្នកសម្ដែងសិល្បដើម្បីបំភាន់ភ្នែក។*

***សក់ក្រអូប** មានន័យថា បញ្ញារបស់ព្រះនាងនោះ(ព្រះម៉ែ) ក្រអូបចេញពីក្បាលសាយភាយតាមសរសៃសក់រួចក្រអូបនូវកេរ្តិ៍ឈ្មោះរបស់គាត់ សាយភាយពេញពិភពលោក ដែលសព្វថ្ងៃពិភពលោកនេះ គេនាំគ្នាស្ងើចសរសើរនូវអានុភាព បញ្ញាញាណរបស់ព្រះម៉ែ ដែលបានបន្សល់ទុកមករកគំនិតនៅលើប្រាសាទនានា។ ចុះហេតុអ្វីបានជាគេចាប់គាត់បានតាមរយៈមហោស្រព? មិត្តអ្នកអានសម្លឹងមកមើលក្មេរបច្ចុប្បន្ន សព្វថ្ងៃគេចង់ផ្សព្វផ្សាយលក់របស់របរ ដែលនាំចូលពីក្រៅប្រទេសឬនៅក្នុងស្រុក គេតែងតែមានលេងមហោស្រព (Concert) **តើខនសឺតហ្នឹងជាអ្វី មិនមហោស្រពទេឬ?** ព្រោះតែមហោស្រពនេះហើយ ដែលកូនក្មេរប្រុសស្រីនាំគ្នាបោះបង់ចោលអស់ សិល្បៈ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អៗ ដែលជាកេរតំណែលរបស់ព្រះម៉ែ ប្រៀបបីដូចជាព្រះម៉ែសក់ក្រអូបដែលត្រូវបរទេសគេចាប់យកទៅបាត់នោះដែរ។ យ៉ាងណាមិញស្មារតីរបស់កូនក្មេរបច្ចុប្បន្ន ក៏ត្រូវសិល្បវប្បធម៌ មនោគមវិជ្ជាបរទេស បានពង្វក់ឲ្យវក់រួចចាប់យកមនសិកាជាតិដែលជាបេះដូងរបស់ព្រះនាងសក់ក្រអូប យកទៅអស់ហើយ តើមែនឬមិនមែនសព្វថ្ងៃនេះ? ចម្លើយគឺពិតមែនហើយ។ ក្នុងរឿងដដែលនេះគាត់បានបញ្ជាក់ប្រាប់ថា ពេលដែលបរទេសចាប់ព្រះ**នាងសក់ក្រអូប**បានហើយ **ព្រះបាទដៃខ្លី**ដែលជាកូនលុះធំដឹងក្តីឡើង បានស្វះ*

ស្វែងទៅតាមរកម្ដាយនៅឯស្រុកអាយ ដែលពួកគេបានចាប់ម្ដាយទៅ ទីបំផុតគាត់មិនបានស្គាល់ម្ដាយខ្លួន ហើយទាក់ទងស្នេហារហូតដល់បានរួមរ័កជាមួយម្ដាយក្រោយមកទើបដឹង ប៉ុន្តែហួសពេលទៅហើយ។ ដោយការប្រព្រឹត្តខុសនឹងម្ដាយខ្លួនឯង បណ្ឌិតសម័យនោះ បានឲ្យកូនគឺព្រះបាទដៃខ្លីជីកអង្គមួយពាន់(១០០០) ហើយអធិដ្ឋានថា ពីរពាន់ឆ្នាំក្រោយពេលដែលអង្គនោះរលុប ដីពេញស្មើដូចជាវាលស្រែ ទើបកម្មរបស់កូននេះរួច។ **ព្រះបាទដៃខ្លី** កាលពីពីរពាន់ឆ្នាំ(២០០០ឆ្នាំ)មុន គាត់តែម្នាក់ឯងទេ ដែលបានប្រព្រឹត្តខុសលើម្ដាយបង្កើតខ្លួន (សេពសន្ថវៈ) ប៉ុន្តែសម័យបច្ចុប្បន្ននេះ កូនក្មេរស្ទើរតែទូទាំងនគរ កូនព្រះម៉ែបានប្រើពាក្យរួម **សេពសន្ថវៈដោយវាចារ**ជាមួយម្ដាយខ្លួនឯងស្ទើរតែគ្រប់ៗគ្នា (អ្នកដែលពុំមានសីល) គឺប្រើពាក្យ (ចុយម្រាយ ឬម៉ាយ) ។

តើយើងជាកូនក្មេរនឹងទទួលបាបកម្មយ៉ាងណាទៅនៅថ្ងៃអនាគតនោះ? ពេលដែលយើងបានអានតាមការបកស្រាយពន្យល់ទើបយើងដឹងថា **ដូនតាក្មេរ**បានដឹងជាមុនរួចទៅហើយ ពីការវិវឌ្ឍន៍នូវសីលធម៌ គុណធម៌ និងការប្រើពាក្យនិយាយរបស់កូនក្មេរ អ្នករស់នៅក្នុងនគរព្រះម៉ែតទៅអនាគត។ មិត្តអ្នកអានច្បាស់ជាឆ្ងល់ថា តើឪពុកឬបិតាទៅណា បានជាខ្ញុំបាទអ្នកស្រាវជ្រាវ ពុំលើកយកមកនិយាយផង? ព្រោះខ្ញុំបានពន្យល់ពីខាងដើមហើយថា នគរនេះមានឈ្មោះថាកម្ពុជា (ខ្ញុំមិនបកស្រាយទេ) និងពាក្យនិយមមួយទៀត គឺមាតុភូមិ ដូច្នេះពុំមែនបិតាភូមិទេ ហេតុនេះហើយ ទើបសិលាចារឹក**រូប**រឿងទាំងអស់ នៅលើថ្មភាគច្រើននិយាយទាក់ទងតែពីរឿងព្រះម៉ែឬព្រះមេ ព្រោះគាត់សុខចិត្តយកទម្ងន់ទុក្ខទោសរបស់បិតានិងកូនមកទទួលតែឯង នេះជាគុណធម៌របស់ម៉ែគ្រប់ៗរូប ព្រោះគាត់សុខចិត្តពរផ្ទៃប្រសូត និងធ្វើបង្គន់ឲ្យកូនប្រុសស្រី ហើយបង្ហូរនូវឈាមស្រស់ៗ គឺទឹកដោះ ដើម្បីបំប៉ៅបុត្រនោះឯង (នឹងមានពន្យល់ក្នុងភាគ៣ ពីឪពុកនិងកូនក្នុងភាសារូប)។

ហេតុនេះហើយ បានជាគាត់ទុកនូវឈ្មោះស្ករម៉្សាង ដែលមិត្តអ្នកអានធ្លាប់ហូបគ្រប់ៗគ្នាគឺ **ស្ករតាំងម៉ែ** ព្រោះតាំងខ្លួនជាម៉ែគេ គឺលំបាកណាស់ ដូចខ្ញុំបានពន្យល់ពីខាងលើជាហូរហែមកហើយ ផ្អែមផង ល្វីងផង ស្ងិតផង ហើយមានពណ៌សម្បុរខ្មៅថែមទៀតផង ព្រះកូររាងខ្លោច។

អត្ថន័យសារជាតិ **ស្ករតាំងម៉ែ** គឺៈ

-**ផ្អែម** គឺព្រហ្មវិហារធម៌ផ្សាយទៅលើកូនប្រុសស្រី

-**ល្វីង** គឺការស្ដីវាយថាប្រៀនប្រដៅ អប់រំកូន

-**ស្វិត** គឺ បេះមិនដាច់ (ទោះបីកូនប្រព្រឹត្តិអាក្រក់យ៉ាងណា ក៏កាត់ចិត្តមិនដាច់កាត់សាច់មិនបាន)

-**ពណ៌ខ្មៅ** គឺសំដៅទៅលើព្រះម៉ែសុខចិត្តដាច់សីល គឺសន្សំធម៌ខ្មៅ (អកុសល) ហេតុតែដើម្បីចិញ្ចឹម កូន ប្រុសស្រីគាត់សុខចិត្តធ្លាក់ក្នុងអបាយភូមិព្រោះតាំងខ្លួនជាព្រះម៉ែ (ឯកសារព្រះធម៌ ទាក់ទងនឹងគុណម៉ែឪមានសម្បូណ៌បែបសព្វថ្ងៃនេះ) សូមមិត្តអ្នកអានឈ្វេងយល់ដោយខ្លួនឯង។

**ហេតុអ្វីក៏ក្មេរ មិនដឹងរឿងពិតរបស់ខ្លួន** ក៏ព្រោះតែយើងប្រគល់បញ្ញាស្មារតីរបស់យើង ឲ្យទៅជនបរទេសជាអ្នកសិក្សាស្រាវជ្រាវសាវតាជាតិរួចយើងរៀនតាម ទើបកូនក្មេរមើលពុំឃើញរឿងពិតរបស់ខ្លួន ដែលដូនតាគាត់មានបណ្ដាំគំនិតសម្បូណ៌បែប តែសព្វថ្ងៃបណ្ដាំនេះ ពុំអាចជ្រាបចូលទៅក្នុងសន្ដានចិត្តកូននាគប្រុសស្រីបានឡើយ គឺយើងជាកូនក្មេរបានត្រឹមតែរស់ក្នុងភូមិម៉ែ បានកេរពីម៉ែ តែពុំដឹងគុណម៉ែឡើយ ហើយនាំគ្នាធ្វើពើ (**ពាក់ក្បាលក្រពើ**)។

## ៦/.តើហេតុអ្វីក៏ក្មេរសម័យក្រោយមហានគរចុះទន់ខ្សោយ?

**ក/.**ខ្ញុំបាទបានរៀបរាប់ពីខាងដើម រួចមកហើយតាមរយកំណាត់ហេតុជីវតាក្ខាន់ គឺខ្ញុំបានពន្យល់វែកញែក ពីព្រះម៉ែមហារនគរ ដែលលោកអាចចេញមករួចខ្លះ និងមិនរួចខ្លះ នៅក្នុងសម័យនោះ។ តែក្រោយមក គេបានថែមសោមួយជាន់ទៀត គឺគម្របដែលបានបិទពីលើសមុទ្រទឹកដោះនោះតែម្ដងដូច្នេះហើយបានជា ចំហាយឫទ្ធិរបស់ព្រះម៉ែនាគ ក្នុងសោជាន់ទីបីនេះ បានបិទយ៉ាងជិត ធ្វើឲ្យគាត់ពុំអាចផ្សព្វផ្សាយនូវអនុភាពនៃឫទ្ធិ ឲ្យអ្នកដឹកនាំនគរសម័យខាងក្រោយបានដឹងឡើយ។ ទើបនគរក្មេរសម័យក្រោយអង្គរបាត់បង់នូវប្រទីប គឺពន្លឺកែវមនោរាដែលសម្រាប់បំភ្លឺផ្លូវ នេះជាហេតុធ្វើឲ្យនគរ ចុះអន់ថយរហូតមក ព្រោះអីគាត់ពុំអាចចេញពីទីឃុំក្នុងសមុទ្រទឹកដោះបានទៀតឡើយ។ហេតុនេះរស្មីពន្លឺនៃភាពរុងរឿងរបស់គាត់ជំនាន់ក្រោយអង្គរ គឺលែងមានទៀតហើយ ចំពោះកូនក្មេរសម័យខាងក្រោយ។ ពេលនោះអរិយធម៌ដែលធ្លាប់តែឈានឡើងដល់កំពូល ត្រូវស្រុតចុះបន្តិចម្ដងៗរឹតតែនឹងបាត់បង់មាតុភូមិនេះ ចេញពីផែនទីពិភពលោកនោះទៀតផង ដោយអំណាចបរទេសឈ្លានពាន។ បើគ្មានអ្នកប្រាជ្ញ ដូចអត់ប្រទីប ហើយបើគ្មានប្រទីបសម្រាប់បំភ្លឺផ្លូវនោះទេ (ចក្ខុវិស័យ) អ្នកដើរក្នុងទីងងឹតត្រូវធ្លាក់ទៅក្នុង

ជ្រោះនៃគ្រោះមហន្តរាយ ដូច្នេះនគរអាចរុងរឿងបានដោយសារអ្នកប្រាជ្ញ ដូចមានសុភាសិតបានចារឹកទុកលើភ្នំជីសូរ បានសរសេរថា៖

- ស្ដេចខ្លៅនាម៉ឺនខ្លៅ ដូចពស់ឆាងត្រាវពេនមាត់ជណ្ដើរ
- ស្ដេចប្រាជ្ញនាម៉ឺនមហិទ្ធិយក្ស ដូចពស់ពញ្ញាក់ពេនមាត់ជណ្ដើរ
- ស្ដេចប្រាជ្ញនាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាំកែវមនោរា។

ខ/.ព្រះបាទជ័យវរ្ម័នទី៧ លោកបានចារឹកសុភាសិតទុកលើថ្មថា គាត់នឹងធ្វើប្រជារាស្ត្រគាត់ឲ្យទៅជា**ទេវតា** និងធ្វើឲ្យទឹកដីនេះក្លាយទៅជា**ស្ថានសួគ៌** **តើយើងអាចយល់ពីអត្ថន័យពាក្យសុភាសិតនេះដែរឬទេ?**

សម័យនោះតាមឯកសារអ្នកការទូត បានរៀបរាប់ពីអាថ៌កំបាំងនៃនគរនេះហើយ ដូចនេះយើងអាចយល់បានថា ស្ដេចក៏ដោយរាស្ត្រក៏ដោយ សុទ្ធតែដឹងរឿងទុក្ខសោករបស់ព្រះម៉ែមហានគរទាំងអស់ ដើម្បីតបនូវឧបការគុណ ពួកគេសុទ្ធតែមាន**បេះដូងទេវតា** គឺមាន**កតញ្ញូកតវេទី**គ្រប់ៗគ្នា។ ដោយអំណាចនៃកតញ្ញូនេះ ទើបធ្វើឲ្យប្រាសាទថ្មបានកើតឡើង ព្រោងព្រាតពីជំនាន់មួយទៅជំនាន់មួយ (**សម័យអង្គរ**) ដើម្បីឧទ្ទិសដល់គុណ គឺសេចក្ដីល្អរបស់ពួកគាត់ ហើយបានឆ្លាក់រៀបរាប់បណ្ដាំព្រះម៉ែ ទុកឲ្យកូនក្មេងសម័យក្រោយដែលមានបញ្ញាអាចមើលយល់ រួចពួកគេអាចជួយស្រង់នឹងដោះទុក្ខគាត់បាន។ បើកូនក្មេងសម័យនោះ សុទ្ធតែមានបេះដូងទេវតាទាំងអស់យ៉ាងនេះ **តើដែនដីនោះជាអ្វី? គឺពុំមែនជាស្ថានសួគ៌ទេឬ?** គឺពិតជាស្ថានសួគ៌នៅក្នុងស្ថានមនុស្សនេះពិតៗ ព្រោះកូនក្មេងសម័យនោះ ក្នុងចិត្តរបស់ពួកគេពោរពេញទៅដោយគុណធម៌(កតញ្ញូកតវេទី)។**ឧទាហរណ៍៖** បើក្រឡេកមើលមកបច្ចុប្បន្ននេះវិញ នៅរដូវបុណ្យភ្ជុំបិណ្ឌ សូម្បីគ្រាន់តែឮតៗគ្នា តាមចាស់ៗតំណាលពីប្រេតជាញាតិ ក្នុងរដូវកាន់បិណ្ឌ ញាតិជាប្រេតតែងមករកកូនចៅ ហើយបើរកពេវត្តពុំឃើញ ពួកគាត់នឹងដាក់បណ្ដាសារ ឲ្យកូនចៅវិនាសហិនហោច។ ដូច្នេះគ្មានកូនប្រុសស្រីណា ហ៊ានធ្វេសប្រហែសឡើយក្នុងរដូវនេះ គឺពួកគេរូតរះយកទាន (បច្ច័យបួន) ទៅប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់ប្រេតជាញាតិ។ នេះយើងធ្វើដោយបានឮតៗគ្នាផង ដោយពុំបានដឹងច្បាស់លាស់ពីបុព្វហេតុខាងដើម គ្រាន់តែចង្អាន់ម្នាក់

មួយស្រាក់ៗ សាលាឆាន់ដែលមានទំហំធំៗ រកកន្លែងដាក់នូវចង្ក្រាន់នោះពុំបានឡើយ នេះជា **កតញ្ញូតាៗគ្នា។** ចុះទម្រាំសម័យខាងដើម ដែលពួកគេបានជួបព្រះម៉ែមហានគរពិតៗនោះ តើនគររុងរឿងដូចម្ដេចទៅ? គ្រាន់តែថ្មម្នាក់មួយដុំៗ ក៏អាចកសាងប្រាសាទថ្មបានរាប់រយពាន់ដែរ នេះហើយគឺជាកម្លាំងសាមគ្គី ដែលកើតឡើងពីកម្លាំងកតញ្ញូកតវេទី នៅសិលាចារឹកនគររាជបានសរសេរថា **ប្រសិនណាជាមានជាតិក្រោយ សូមឲ្យខ្ញុំបានកើតជាក្មែរទៀត** តើពួកគាត់ចង់កើតជាក្មែរដើម្បីប្រយោជន៍អ្វី? ចម្លើយសូមលោកអ្នកអាន ពិចារណាឈ្វេងយល់ដោយខ្លួនឯង។

លោកអ្នកអានជាទីមេត្រី ក្រោយពីបានតាមដានជាហូរហែមក ទើបយើងដឹងពីការចុះទន់ខ្សោយក្រោយសម័យមហានគររបស់មាតុភូមិយើង គឺមកពីការមិនដឹងរឿងហេតុពិតរបស់ព្រះមេ ឬព្រះម៉ែនោះឯង ដោយយើងទាំងអស់គ្នារវល់តែភ្លេចស្មារតីជឿអ្នកដទៃបំភាន់ (បរទេស) ដូច្នេះទើបយើងពុំអាចរកឃើញនូវអាថ៌កំបាំងបណ្ដាំព្រះម៉ែក្នុងសម័យមហានគរបាន។

## គ/. ហេតុអ្វីបានជាព្រះម៉ែត្រូវជាប់ទោស?

សេចក្ដីលោភលន់របស់បុគ្គលម្នាក់ៗ គ្រួសារមួយ អ្នកដឹកនាំប្រទេសមួយ គឺមិនចេះឆ្អែតឬស្កប់ស្កល់ឡើយ (**ការឆ្អែតដោយស្ទឹងតណ្ហា គឺពុំមានឡើយ**) ហើយពេលណាដែលសេចក្ដីលោភកើនកម្លាំងខ្លាំងច្បាស់ជាត្រូវប៉ះពាល់ដល់អ្នកដទៃឬ ប្រទេសដទៃជាពុំខាន។ **ឧ.** សព្វថ្ងៃនេះម្ដាយដែលគាត់រកស៊ីលក់ដូរនៅឯផ្សារ ដូចជាពួកគាត់លក់សាច់ បន្លែឬរបស់របរផ្សេងៗ... ក្នុងមួយគីឡូ គាត់ថ្លឹងមិនឲ្យគ្រប់ដប់ខាំទេ គឺគាត់ត្រូវលួចភ្នែកជញ្ជីងខ្លះ កុហកខ្លះ..... ដើម្បីយកប្រាក់មកចិញ្ចឹមកូនប្រុសស្រី ដោយសុខចិត្តដាច់សីល ផលនៃបាបដែលម្ដាយឪពុកដាច់សីលនេះ ធ្វើឲ្យពួកគាត់ធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិ យើងសួរថា**តើកូនគេមានប្រើឲ្យម៉ែឪទៅប្រព្រឹត្តអំពើអាក្រក់នេះទេ** នេះគ្រាន់តែជាចំណែកតូចមួយនៃបាបរបស់ម៉ែឪនៃគ្រួសារមួយដែលខ្ញុំលើកយកមកជា**ឧ.** ពួកគាត់ពេញចិត្តធ្វើនូវអំពើអកុសលទាំងនេះដោយខ្លួនឯងដើម្បីកូន ដូច្នេះអំពើបាបនេះនឹងធ្វើឲ្យពួកគាត់ ធ្លាក់ទៅទទួលរងទុក្ខក្នុងអបាយភូមិ។ យ៉ាងណាមិញដូនតាមហានគរក្មែរក៏យ៉ាងដូច្នោះដែរ ដោយចង់ឲ្យកូនក្មែរសម័យខាងក្រោយចុំចើ្ងងរុងរឿងរស់នៅដោយមោទនភាព គាត់បានធ្វើសង្គ្រាមពង្រាតទឹកដីរហូតមានស្ដេចជាចំណុះរាប់រយប្រទេស។ យើងមើលមកសព្វថ្ងៃ មហាអំណាចបច្ចុប្បន្នគ្រាន់តែចង់គ្រប់គ្រងប្រទេសមួយ ខ្លួនអ្នក

*ដឹកនាំសុខចិត្តធ្វើសង្គ្រាមសម្លាប់ជីវិតមនុស្សរាប់ម៉ឺនសែននាក់ ចុះទម្រាំបុព្វជនក្មេងគ្រប់គ្រងគេរាប់រយប្រទេសនោះ* ***តើពួកគាត់ត្រូវសម្លាប់មនុស្សប៉ុន្មាននាក់ទៅ ហើយបាបកម្មទាំងអស់នេះអ្នកណាជាអ្នកទទួល?*** *យ៉ាងណាមិញ បរទេសដែលគាត់ធ្លាប់ធ្វើអាណានិគមពីលើគេក្នុងអតីតកាលនោះ គេតាមចងកម្មពៀរនឹងពួកគាត់រហូតមកដល់សព្វថ្ងៃ។ ដោយខ្ញុំលើកយកហេតុផលនេះមកពន្យល់ ព្រោះមិនចង់ឲ្យម៉ែឪជំនាន់ក្រោយនាំគ្នាធ្វើបាបដើម្បីគេ (**កូន ចៅ ញាតិ**...) ហើយភ្លេចធ្វើទីពឹងឲ្យខ្លួនឯង ទីបំផុតត្រូវរងទុក្ខតែម្នាក់ឯងក្នុងអបាយភូមិ រួចទើបទូញយំស្ដាយជាខាងក្រោយ (**ទំនួញប្រេត**) នោះគឺវាហួសពេលទៅហើយព្រោះយើងរវល់តែភ្លេចធ្វើទីពឹងឲ្យខ្លួនឯង* ***(ខ្លួនជាទីពឹងខ្លួន តើអ្នកដទៃឯណាហ្នំហ្នឹងជាទីពឹងបាន បុគ្គលដែលបានអប់រំខ្លួនបានល្អ ហើយនឹងបាននូវទីពឹងដែលគេបានដោយកម្រ*** *នេះជាព្រះគាថាដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែង។ ព្រះម៉ែមហានគរក៏យ៉ាងដូច្នោះដែរ ខំពង្រីកទឹកដីទុកឲ្យកូនក្មេងរស់នៅឲ្យបានថ្កុំថ្កើងក្នុងមោទនភាព ប៉ុន្តែទីបំផុតខ្លួនត្រូវជាប់ឃុំឃាំងក្នុងសមុទ្រទឹកដោះហើយដេកស្រែកយំរងចាំកូនក្មេងជំនាន់ក្រោយឲ្យជួយស្រង់ជួយរែកគឺធ្វើបុណ្យឧទ្ទិសកុសលទៅពួកគាត់ តើកូនក្មេងសម័យនេះមានអ្នកណាគេនឹងជួយគាត់បើពួកគេពុំដឹងរឿង ម្យ៉ាងទៀតកូនគាត់កំពុងវង្វេងនឹង**កេរតំណែលម៉ែ**...។ មូលហេតុដែលនាំឲ្យកូនក្មេងភ្លេចពុំបានដឹងរឿងពិតរបស់គាត់ ព្រោះដោយអំណាចបាបកម្ម ដែលគាត់បានសាងទុកមកហើយដោយបាបនោះមិនទាន់ឲ្យផលអស់ ទើបធ្វើឲ្យកូនក្មេងភាគច្រើននាំគ្នាជេរប្រមាថ មាក់ងាយដល់គាត់ថែមទៀត។ សរុបសេចក្ដីមក នេះជាហេតុនិងផលរបស់កម្មដែលនាំឲ្យព្រះម៉ែជាប់ឃុំឃាំងរាប់ពាន់ឆ្នាំនេះ ព្រោះការមិនមានសីល (**៥ ; ៨ និង១០**)។*

*ហេតុនៃការខិតខំស្រាវជ្រាវរាវរកសាវតាពិតរបស់ព្រះម៉ែមហានគរ ដោយបានទាញយករឿងពិត ពីក្នុងថ្មនិងឯកសារផ្សេងៗនៅក្នុងភាសារឿងក្នុងរូបចម្លាក់ រឿងព្រេង ឈ្មោះធម្មជាតិ...។ល។ មកពន្យល់នេះ គឺចង់ពញ្ញាក់ស្មារតីកូនក្មេងប្រុសស្រីគ្រប់រូបឲ្យភ្ញាក់ឡើង ហើយនាំគ្នាត្រិះរិះពិចារណា ឈ្វេងយល់ដើម្បីទ្រោលបំភ្លឺ ប្រវត្តិពិតរបស់អ្នកបង្កើតជាតិនេះ យើងគួរនាំគ្នាជួយស្រង់ព្រះម៉ែមហានគរដែលបានលិចកប់បាត់អស់រយៈកាលរាប់រយពាន់ឆ្នាំនោះឲ្យលោកបានរួចពីទុក្ខ ហើយងើបត្រដែតឡើងវិញដោយរួបរួមសាមគ្គីគ្នាឧទ្ទិសនូវបុណ្យជូនទៅឲ្យពួកគាត់។ ការស្រាវជ្រាវទាំងអស់នេះទោះបីខុសឬត្រូវក្តី ចូរមិត្តអ្នកអានធ្វើការត្រិះរិះពិចារណាឈ្វេងយល់ ក្នុងនាមយើងជាកូនក្មេងកំពុងរស់នៅលើទឹកដីព្រះម៉ែ ហើយប្រសិនជាឯកសារសាវតារបស់គាត់នេះ ពុំត្រឹមត្រូវទេសូមបោះបង់ចោលចុះ ប៉ុន្តែបើត្រឹមត្រូវតាម*

ហេតុផលដូចក្នុងការបកស្រាយពន្យល់ សូមលោកអ្នកអានជួយរិះរក ជួយស្រង់ម៉ែ ជួយឧទ្ទិសបុណ្យជូនឲ្យព្រះម៉ែ ដើម្បីជួយលោកអ្នកដ៏មានគុណទាំងទ្វេរជាទីគោរពនិងស្នេហានៃយើង ឲ្យលោកបានរួចផុតពីទុក្ខរួចអណ្តែតទៅកាន់ទីខ្ពស់ ហើយសូមឲ្យដួងកែវរបស់ព្រះម៉ែរស់ឡើងវិញក្នុងសន្តានចិត្តកូននាគប្រុសស្រីក្មេរដូចអត្ថន័យដែលមាននៅក្នុងប្រាសាទនាគព័ន្ធ ឬព័ន្ធនាគស្រាប់ **(សាសនគំនិតនេះពួកគាត់បានពន្យល់ទុកក្នុងប្រាសាទនោះ)។**

ខ្ញុំខ្លាចក្រែងមិត្តអ្នកអាន មើលភាគទី១នេះពុំសូវយល់ ខ្ញុំនឹងខិតខំប្រឹងប្រែងស្រាវជ្រាវនូវ**ភាគទី២** មកបើកបង្ហាញនូវប្រវត្តិសាវតាពិតរបស់ជនជាតិនេះ ដែលដូនតាបានបន្សល់ទុកនៅក្នុងកេរតំណែលរបស់គាត់ឲ្យរឹងរឹតតែពិស្តារឡើងថែមទៀត ដើម្បីទុកជាប្រទីបសម្រាប់ឲ្យកូនក្មេរជំនាន់ក្រោយចេះឈ្វេងយល់ខ្លួនឯងដោយពុំពឹងផ្អែកលើបញ្ញារបស់បរទេសទៀតឡើយ។

ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមអភ័យទោសពីសំណាក់មិត្តអ្នកអានគ្រប់ភេទទាំងគ្រហស្ថ និងបព្វជិតនូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា ព្រោះស្នាដៃនេះជាការស្រាវជ្រាវ និងចងក្រងលើកទីមួយ សូមឲ្យព្រះពុទ្ធសាសនារុងរឿងឡើងវិញ ដោយកូនក្មេរប្រុសស្រីបានដឹងពីហេតុផលបាបកម្មក្នុងអតីតកាលរបស់ព្រះមាតាបិតាមហានគរដែលបានប្រព្រឹត្ត នឹងបានទទួលនូវបាបកម្មនេះ អ្នកដែលជួយវាយនិងរៀបចំអត្ថបទភាគទី១នេះ គឺក្មួយប្រុស**សេនរ៉ន** សព្វថ្ងៃរៀននៅសាលាបច្ចេកទេសដុនបុស្កូខេត្តព្រះសីហនុ ឯកទេសផ្នែកទំនាក់ទំនងសង្គម។

ខ្ញុំព្រះករុណាខ្ញុំបាទក៏សូមឧទ្ទិសនូវសេចក្តីព្យាយាម ដែលខិតខំស្រាវជ្រាវអាថ៌កំបាំងសាវតាបណ្តាំព្រះម៉ែមហានគរនេះ ក្នុងនាមខ្ញុំព្រះករុណាខ្ញុំបាទ ជាកូនក្មេរម្នាក់បានកើត និងចេះដឹងហើយរីកធំធាត់ដោយកេរមរតកព្រះម៉ែ **(ពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងសាសនព្រះម៉ែ)** សូមឲ្យផលនៃបុណ្យនេះ កើតមានចំពោះលោកអ្នកដ៏មានគុណ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ និងញាតិធម៌ដែលសុទ្ធតែជាអ្នកមានឧបការគុណ គ្រប់ៗកាលទាំងបី (អតីត បច្ចុប្បន្ន អនាគត) សូមឲ្យជួបប្រសព្វតែនូវសម្បត្តិទាំងបី គឺ សម្បត្តិមនុស្ស ទេវតា និងព្រះនិព្វាន និងជួបតែពរទាំងឡាយប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

*ស្នាដៃសង្ខេបភាគទីមួយនេះ ចងក្រងរួចជាស្ថាពរនៅថ្ងៃសុក្រ* **៨***កើត ខែពិសាខ ឆ្នាំឆ្លូវ ឯកស័ក*

*ព.ស២៥៥៣ ត្រូវនឹងថ្ងៃ ទី* **០១** *ខែ ឧសភា ឆ្នាំ* **២០០៩** *នៅខេត្តព្រះសីហនុ*

*ការខិតខំស្រាវជ្រាវនេះខ្ញុំសូមរក្សាសិទ្ធិទាំងស្រុង!...*

*ពីខ្ញុំព្រះករុណាខ្ញុំបាទអ្នកទទួលមរតកព្រះម៉ែ*

*ឯកសារសាវតាព្រះម៉ែនេះ ស្រាវជ្រាវនិងចងក្រងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ* **គៀត ចាន់ថុន**

*អតីតសិស្សសាលាវិចិត្រសិល្ប*

# សាសនអច្ឆរាមហាគាមហានគរខ្មែរ

## ភាគ២



**ព្រះមាតាសម្ដេចឫទ្ធិ**

ឯកសារសាវតាព្រះម៉ែមហានគរ ស្រាវជ្រាវនិងរៀបរៀងដោយខ្ញុំព្រះករុណា

ខ្ញុំបាទ គៀត ចាន់ថុន អតីតសិស្សសាលាវិចិត្រសិល្បៈ

# អារម្ភកថា

ពេលដែលខ្ញុំព្រះករុណាខ្ញុំបាទ សរសេរចងក្រងភាគទីមួយរួចហើយ ខ្ញុំបានប្រគេនជូនលោកម្ចាស់ ដែលបាននិមន្តមកបិណ្ឌបាតនៅមុខផ្ទះខ្ញុំព្រះករុណាខ្ញុំបាទ នូវឯកសារសាវតាបណ្ដាំមាតាមហានគរថតចម្លងមួយច្បាប់ ដើម្បីឲ្យព្រះអង្គយកទៅអាន ឈ្វេងយល់។ រំលងជាច្រើនថ្ងៃក្រោយមក លោកម្ចាស់អង្គនោះ លោកបាននិមន្តមកបិណ្ឌបាតម្ដងទៀត ព្រះអង្គបានសួរខ្ញុំថា ញោមស្រាវជ្រាវអស់រយៈពេលជាង១០ឆ្នាំសរសេរចងក្រងបានតែប៉ុណ្ណឹងទេឬ?

សំណួរដែលលោកម្ចាស់សួរខ្ញុំ ធ្វើឲ្យខ្ញុំភ្ញាក់រួចគិតពិចារណាក្នុងចិត្តតែម្នាក់ឯងថា ៖ លោកម្ចាស់អង្គនេះច្បាស់ជាមើលការស្រាវជ្រាវ **អាថ៌កំបាំងបណ្ដាំព្រះម៉ែ** នេះពុំយល់ឡើយ ដូច្នេះខ្ញុំត្រូវតែស្រាវជ្រាវ ភាគទីពីរជាបន្ត ដើម្បីយកមកពន្យល់បកស្រាយជាបន្ថែមទៀត បើពុំដូច្នោះទេអ្នកអានដែលមានបញ្ហាក្នុងការសិក្សាស្រាវជ្រាវបានតិចតួច ពិតជាពុំអាចមើលយល់បានឡើយនៅឯកសារសាវតាចងក្រងដោយសង្ខេបក្នុងភាគ១នេះ។ ហេតុនេះទើបខ្ញុំព្រះករុណាខ្ញុំបាទ ខិតខំស្រាវជ្រាវប្រមូលផ្ដុំនូវការសិក្សានិងការចងចាំទាំងឡាយជិតមួយជីវិតនេះ មកសរសេរពន្យល់បកស្រាយក្នុងភាគទីពីរ ដើម្បីទុកជាមរតកបណ្ដាំគំនិតព្រះម៉ែ សម្រាប់បំភ្លឺមើលការពិតពីអតីតកាល បច្ចុប្បន្ន និងតទៅអនាគត ទុកជាប្រយោជន៍ឲ្យកូននាគប្រុសស្រីដែលជាអ្នកកាន់និងគោរពព្រះពុទ្ធសាសនា ឲ្យបានយល់ច្បាស់ពី**សាសនបណ្ដាំព្រះម៉ែ** ដែលលោកបានផ្ដាំទុកនៅក្នុងប្រាសាទថ្ម ទំនៀមទម្លាប់ ប្រពៃណីសាសនា ឈ្មោះភូមិស្រុក ឈ្មោះប្រាសាទ ធម្មជាតិ ទំនាយផ្សេងៗ.... **សម្រាប់ឲ្យកូននាគទាំងឡាយជួយគាស់កកាយសើរើរឿងពិត** រួចនាំគ្នារួមសាមគ្គីជួយឧទ្ទិសបុណ្យស្រង់គាត់ពីទីទុក្ខដែលបានបន្សល់ទុកជាយូរយារណាស់មកហើយនោះ ឲ្យគាត់បានទៅកាន់សុគតិភព។

គេហទំព័រ: http://kietchanthon.blogspot.com

http://kietchanthon.info

អ៊ីម៉ែល: kietchanthon@gmail.com

info@kietchanthon.info

ឯកសារសាវតាព្រះម៉ែនេះ ស្រាវជ្រាវ និងចងក្រងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្ប:

# សាសនអច្ឆរាមាតាមហានគរខ្មែរ

I. នៅក្នុងស្នាដៃរបស់ខ្ញុំ ភាគទីមួយខ្ញុំបាននិយាយជាហូរហែ នូវរឿងរ៉ាវទុក្ខវេទនារបស់មាតាមហានគរ ដែលគាត់សុខចិត្តរងទុក្ខនៅក្នុងមហាសមុទ្រទឹកដោះ ក្នុងការតាំងខ្លួនជាប្រមុខគេ ជាម៉ែគេ (ស្ករតាំងម៉ែ) ទើបស្ត្រីជា **មាតុ** លោកភ្លេចធ្វើទីពឹងឲ្យខ្លួនឯង គួរ ឲ្យអាណិតនិងសង្វេគគាត់ណាស់។ បើគាត់មាននូវមហាគុណដ៏ធំធេងដូចនេះ តើកូនខ្មែរប្រុសស្រីគួរបំពេញកិច្ចតបស្នងយ៉ាងណា ដើម្បីឲ្យសមជាកូនដែលជាអ្នកទទួលនូវមរតកម៉ែ(ខ្មែរ) ជាអ្នកបានកើត ថែមទាំងបានកប់ទងសុក និងចុងក្រោយ គឺត្រូវកប់សាកសពនៅលើទឹកដីរបស់គាត់នេះ ។

***ក***/.តើកូនម៉ែដឹងទេ? ដំណក់ទឹកដោះ ដែលអ្នកបៅ បឺត ជញ្ជាក់ដំបូងឡើយ គឺមានរសជាតិផ្អែមពណ៌សថ្លា ប្រៀបដូចជាទឹកចិត្តម៉ែបង្ហូរមកដើម្បីចិញ្ចឹមកុលបុត្រប្រុសស្រី ហើយបានហូរចេញពីក្នុងទ្រូងម្ដាយ។ ទឹកដោះហូរចេញដំបូងមានរសផ្អែម ទុករំលងច្រើនម៉ោង ក្លាយទៅជាមានក្លិនឆ្អាបដូចឈាម ទុករំលងច្រើនថ្ងៃប្រែក្លាយទៅជាទឹកគំរង់ដែលមានក្លិនស្អុយ។ ពេលណាអ្នកពិចារណាតាមការបកស្រាយរបស់ខ្ញុំនេះ តើអ្នកនឹងមានសេចក្ដីអាណិតដល់**មាតាមហានគរខ្មែរ** ដែលលោកខិតខំកកើត**មាតុភូមិ**នេះទេ? **ព្រះម៉ែ**លោកសុខចិត្តស៊ូទ្រាំដេកត្រាំក្នុងមហាសមុទ្រទឹកដោះខ្លួនឯងរាប់ពាន់ឆ្នាំ ដែលទឹកដោះនេះសព្វថ្ងៃ បានក្លាយទៅជាមហាសមុទ្រគំរង់ដ៏ស្អុយគួរឲ្យខ្ពើម ប៉ុន្តែដើម្បីកូនប្រុសស្រី ក្នុងនាមជាម៉ែគេ(តាំងម៉ែ) គាត់សុខចិត្តដេកត្រាំក្នុងមហាសមុទ្រគំរង់នេះ (សមុទ្រទឹកដោះ = អបាយភូមិ = ទីទុក្ខ)។ តើមានកូនប្រុសស្រីណាដឹងពីទុក្ខវេទនានេះទេ? ម៉ែបានដេកត្រាំក្នុងទុក្ខយ៉ាងនេះ ដើម្បីតែកូនខ្មែរប្រុសស្រី តើកូនខ្មែរប្រុសស្រី ដែលប្រមាថគាត់ជេរគាត់ តើកម្មនេះកូនម៉ែប្រុសស្រី ទទួលទោសដូចគាត់ ឬមួយក៏លើសពីគាត់? ***សូមមិត្តអ្នកអានពិចារណាបាបកម្មដែលខ្លួនបានជេរប្រមាថនេះដោយខ្លួនឯងចុះ!***។

***ខ***/.ក្នុងភាគមុន ខ្ញុំពុំបានបកស្រាយពីសមុទ្រទឹកដោះនេះឲ្យបានក្បោះក្បាយទេ ឥឡូវខ្ញុំសូមលើកយកមកពន្យល់បន្ថែម ដើម្បីឲ្យកូនខ្មែរយល់កាន់តែច្បាស់ថា ហេតុអ្វីបានជាគាត់ត្រូវយកសាសនា

*ព្រហ្មញ្ញចូលមកក្នុងនគរខ្លួន? ព្រោះរឿងរ៉ាវក្នុងសាសនានេះវាមានចំណុចជាច្រើន ដែលដូចរឿងរបស់គាត់ (ឧទាហរណ៍: ដូចជារឿងកូរសមុទ្រទឹកដោះនេះជាដើម)។ តើអ្នកធ្លាប់បរិភោគផ្លែទឹកដោះឬទេ?*

*ផ្លែទឹកដោះមានពីរបែប មួយទុំពណ៌ស និងមួយទៀតទុំពណ៌ក្រហមក្រម៉ៅ ហេតុអ្វីបានជាគាត់ហៅផ្លែនេះថាផ្លែទឹកដោះ? ព្រោះផ្លែនេះមានសណ្ឋានរាងដូចដោះស្ត្រី ហើយជាពិសេសពេលដែលយើងចិតវាហូបនោះ វាបានហូរចេញនូវជ័រពណ៌សដូចជាទឹកដោះម៉ែដែរ ហើយជ័រនេះមានរសជាតិផ្អែមថែមទៀតគួរឲ្យចង់ទទួលទាន ដូចជាទារកដែលបានទទួលបំបៅ ជញ្ជក់បឺតបៅទឹកដោះម្ដាយដែរ។ ហើយពណ៌ក្រហមក្រម៉ៅនិងសនេះ គឺតំណាងឲ្យម៉ែដែលមានស្បែកសំបុរថ្ងៃជ្រះ ឬម៉ែដែលមានស្បែកសំបុរថ្ងៃស្រអែមនិងខ្មៅ (នេះជាអាថ៌កំបាំងរបស់ឈ្មោះផ្លែទឹកដោះ ដែលទាក់ទងនឹងរឿងអាថ៌កំបាំងព្រះម៉ែយើង)។*

*ហេតុអ្វីបានជា យើងមានរឿងព្រះថោងនាងនាគ? តើរឿងព្រះថោងនាងនាគ បានលាក់ទុកនូវអាថ៌កំបាំងអ្វីខ្លះ? តើរឿងនេះហេតុអ្វីមានតែនៅក្នុងស្រុកខ្មែរ?*

***គ/.*** *យើងដឹងហើយថារឿងនេះ វាទាក់ទងទៅនឹងប្រវត្តិដំបូងរបស់នគរនេះ បឋមក្សត្ររបស់នគរនេះ គឺព្រះនាងនាគ ដែលខ្ញុំបានពន្យល់ពីខាងដើមរួចមកហើយ (គឺបុព្វពាក្យ* ***មេ*** *ក្នុងភាគ១) ដើម្បីចង់ដឹងពីរឿងពិតរបស់នគរនេះ យើងត្រូវយករឿងព្រេងនេះមករើកញែក ដើម្បីស្វែងរកការពិតរបស់ជនជាតិខ្មែរ ព្រោះនេះជារឿងតែមួយគត់ដែលយើងជាកូនខ្មែរ បានចេះចាំតៗគ្នាមកដល់សព្វថ្ងៃនេះ។ ពាក្យថានាគ គឺខ្ញុំបានពន្យល់រួចហើយ នៅក្នុងភាគ១នៃឯកសារអាថ៌កំបាំងនេះ ឥឡូវខ្ញុំពន្យល់ពីកាតព្វកិច្ចរបស់កូននាគប្រុសស្រីដែលជាអ្នកស្នងមរតកព្រះម៉ែវិញ តើកូននាគប្រុសត្រូវធ្វើអ្វី? កូននាគស្រីត្រូវធ្វើអ្វី? កាលពីសម័យដើម មាតាបិតាខ្មែរតែងធ្វើការជាមង្គលឲ្យកូនចំនួនបីលើកគ្រប់កូនប្រុសនិងកូនស្រី រាល់ពិធីមង្គលនីមួយៗ គាត់តែងតែអញ្ជើញអាចារ្យពេលា ដើម្បីស្វែងរកពេលវេលាល្អធ្វើមង្គល ហើយបានអញ្ជើញញាតិមិត្តជិតឆ្ងាយ មកចូលរួមក្នុងពិធីនីមួយៗនេះ។ នៅក្នុងពិធីមង្គលទាំងបីនេះ តែងបញ្ចប់កិច្ចចុងក្រោយដោយការ បង្វិលពពិលព័ទ្ធសីមាឲ្យកូនប្រុសស្រីគ្រប់ៗពិធីមង្គល។*

## *ពន្យល់ពាក្យ:*

*__ពពិល__ => ពពារ => បើកពពារ => គឺព្រះម៉ែមហានគរគង់នៅលើនាគបើកពពារ (រូបពពិលពីសម័យដើម) ហើយព្រះម៉ែតែងតែទៅព័ទ្ធសីមាការពារឲ្យកូនខ្មែរគ្រប់ៗជំនាន់ ទោះបីជាខ្លួនត្រូវជាប់ទោសក្នុងសមុទ្រទឹកដោះទៅហើយ ក៏គាត់នៅតែតាំងខ្លួនជាម៉ែគេដដែល (__ស្គរតាំងម៉ែ__) ហើយពិធីមង្គលទាំងបីនេះ មានន័យស្រដៀងនឹងរឿងកបិលមហាព្រហ្មក្នុងសិរីបីប្រការ ដែលគេធ្វើពិធីមហាសង្រ្កាន្តផ្លាស់ប្តូរគ្រប់រាល់ៗឆ្នាំថ្មី។ ហើយរឿងកបិលមហាព្រហ្មនេះ ខ្ញុំនឹងព្យាយាមស្រាវជ្រាវរាវរកនូវអត្ថន័យពិត ដើម្បីយកមកបកស្រាយពន្យល់ក្នុងទំព័រខាងក្រោយ តើហេតុអ្វីរឿងសិរីបីប្រការនេះមានតែនៅក្នុងស្រុកខ្មែរ?*

## *ការបកស្រាយអាថ៌កំបាំងក្នុងមង្គលបី៖*

### ១/.មង្គលទីមួយ

*ពន្យល់ពាក្យ មង្គល = សេចក្តីចម្រើន សេចក្តីសុខ សិរីសួស្តី*

*មាតាបិតាពីសម័យដើម តែងធ្វើមង្គលទីមួយឲ្យកូនប្រុសស្រី ពេលកូនធំដឹងក្តី គឺពិធីកោរទុកជុកឬទុកកំប៉ោយ) ពិធីកោរជុកទុកកំប៉ោយសក់សម្រាប់លាក់បិទបាំងនូវបង្កើយ ព្រោះបង្កើយនេះមានន័យថា __ចប់__ ដូច្នេះបើអ្នកដទៃគេរកឃើញបង្កើយរស់របស់យើង បានន័យថាចប់ វាពុំមែនដូចរឿងអាជ័យ ប្តីនាងគ្រតនោះឡើយ ដែលល្ងង់ហើយទៅចាក់បង្កើយដែល ជាដង្កើមរស់របស់កូន ហើយនិយាយថាមិនដឹង ដោយស្មានច្រឡំថាជាបូសនោះទេ។ តើអាថ៌កំបាំងក្នុងមង្គលទី១ គាត់ចង់និយាយពីអ្វី? គឺម៉ែនាគគាត់ចង់ប្រាប់កូននាគប្រុសស្រីថា ពាក្យថា កោរទុកជុក ត្រឡប់ ពាក្យមកវិញ គឺគុកទុកចោរ។ តើអ្នកណាជាចោរ? ចោរគឺមាតាបិតានោះឯង ព្រោះហេតុតែចិញ្ចឹមកូនប្រុសស្រី ម៉ែឪសុខចិត្តដាច់សីលគឺសិក្ខាបទប្រាំ មានឈ្មោះថាជាអ្នកធ្វើនូវបាបកម្មដើម្បីកូន ទីបំផុតត្រូវរងទុក្ខជាប់ឃុំឃាំង (ក្នុងសមុទ្រទឹកដោះ)។ អត្ថន័យនេះ ខ្ញុំបានពន្យល់រួចហើយពីក្នុងភាគទី១ (តាំងខ្លួនជាម៉ែ) ដូច្នេះហើយ ទើបគាត់លួចចេញពីគុកឡើងមកប្រាប់កូនសម័យនោះឲ្យកសាងប្រាសាទថ្មរាប់រយពាន់*

ហើយមានប្រាសាទមួយដាក់ឈ្មោះថា **ប្រាសាទវត្តភូ** ដែលសព្វថ្ងៃប្រាសាទនេះ ស្ថិតនៅក្នុងប្រទេសឡាវ។



រូបនៅប្រាសាទ វត្តភូ

## <u>ពន្យល់ពាក្យ</u> **វត្តភូ**

វត្ត = បដិបត្តិ ប្រតិបត្តិ ធ្វើតាមវី អនុវត្តតាម ឧះ វត្តិប្រតិបត្តិ

ភូ = សំណុំសក់រោម សរសៃអ្វីៗសំរាប់ចងជារំយោលកំប៉ោយ

ភូ = ផែនដី លោក ពិភពលោក ចិញ្ចើម (វចនានុក្រមសម្តេចសង្ឃរាជ ជួនណាត១+២)

វត្តភូ = មានន័យថាការធ្វើតាម រឺអនុវត្តតាមពិធីទុកសំណុំសក់ (កោរទុកជុកវី កំប៉ោយ) ដែលគាត់បានឆ្លាក់រឿងរ៉ាវរបស់គាត់ ទុកលើផ្តែរប្រាសាទនោះ ដែលរៀបរាប់ពីកូននាគម្នាក់ដកឆ្នុកកំប៉ោយចេញ រួចហែកចូលទៅមើលរឿងក្នុងបេះដូងម៉ែ(**អាថ៌កំបាំងក្នុងល្បែងចាក់ទឹកដូង**) (ភាគទី១)។

ដោយការតាមរកនូវបង្ហើយ(ដង្ហើមរស់) របស់ព្រះម៉ែនេះ ពួកបរទេសគេតាមស្រាវជ្រាវអស់កាលដ៏យូរ ទីបំផុតពួកគេបានរកឃើញបង្ហើយរស់របស់គាត់នៅក្នុងភ្នំអង្គរស ឬរាជទ្រព្យ ទើបពួកគេសាងរូបពុទ្ធបដិមាមួយអង្គ កំពស់១៨ហត្ថព្រះសុគតសន្ធប់មាត់រូង ដែលជាបង្ហើយរបស់ព្រះមាតាមហានាគ ដើម្បីកុំឲ្យគាត់ចេញមកក្រៅរួច។ ព្រោះគេដឹងថាចំណុចខ្សោយរបស់ព្រះម៉ែនាគ គឺព្រះរូប ព្រះធាតុ...... របស់ព្រះសម្មាសម្ពុទ្ធ ដែលជាព្រះបិតាវិវដ្ត ហើយព្រះបិតានេះ គឺព្រះម៉ែនាគគាត់បាននាំមកប្រតិស្ឋានទុកក្នុងនគរនេះតាំងពីអតីតកាលមកម្ល៉េះ គឺដើម្បីទុកជាកេររបស់ម៉ែ (ខ្មែរ)។ នៅពេលណាដែលមានព្រះចេតិយ ព្រះពុទ្ធ ព្រះធាតុ និងរបស់របរផ្សេងៗដែលជាតំណាងព្រះសម្មាសម្ពុទ្ធ នៅពីខាងលើក្បាលព្រះម៉ែ (បង្ហើយ) គឺគាត់ពុំអាចចេញមកខាងលើរួចឡើយ ព្រោះពេលដែលគាត់ចេញមក នឹងធ្វើឲ្យព្រះចេតិយជាទីសក្ការៈទាំងនោះ ប្រេះរលំវិនាសបាក់បែកជាពុំខាន ហេតុនេះគាត់មានតែ ស៊ូទ្រាំនៅទ្រភ្នំ ឬទ្រទុក្ខ



ព្រះម៉ែទ្រភ្ជុំ

បន្តទៅទៀត (រូបចម្លាក់ស្ត្រីទេវភ្នំសព្វថ្ងៃតាំងនៅក្នុងសារមន្ទីរជាតិភ្នំពេញ)។

ចំណុចខ្សោយទាំងអស់នេះហើយ ដែលធ្វើឲ្យពួកបរទេសជិតឆ្ងាយគេមើលយល់ គេបានមកស្រាវជ្រាវរាវរកដង្ហើមរស់ទាំងនេះ តាំងពីដើមសតវត្សមកម្ល៉េះ ដូច្នេះហើយទើបសម័យក្រោយៗពួកគេតែងតែសាងរូបព្រះពុទ្ធបដិមា ឬព្រះចេតិយដំកល់ព្រះធាតុ ... មកបិទសន្ធប់តាមមាត់រូងភ្នំណាដែលគេសង្ស័យថា ព្រះ ម៉ែនាគនឹងចេញតាមបង្ហើយនោះខ្ញុំសូមលើកយកឧទាហរណ៍មួយមកពន្យល់។ សម័យពីដើម ដូនតាយើងគាត់ចង់ជីកអណ្តូងយកទឹកមកប្រើប្រាស់ក្នុងរដូវប្រាំង ដែលខ្សត់ទឹក តើគាត់ត្រូវធ្វើដូចម្តេច? គឺគាត់ត្រូវប្រើវិធីសាស្ត្រស្ទង់ រកមើលដង្ហើមរបស់ទឹកបីយ៉ាង។

## វិធីទាំងបីសំរាប់ជីកអណ្តូង ៖

១.គាត់ត្រូវដើរមើលស្មៅដែលដុះតាមវាលស្រែ បើស្មៅត្រង់ទីណា នៅមានពណ៌បៃតងស្រស់ខ្ចី បានន័យថាទីកន្លែងនោះ ពិតជាមានប្រភពទឹកនៅខាងក្រោមជាពុំខានឡើយ។

២.គាត់ត្រូវយកក្អម ឆ្នាំង ឬភាជន៍ផ្សេងៗ យកទៅគ្របតាមទីកន្លែងដែលពួកគាត់ចង់ជីកអណ្តូងនៅពេលព្រលប់ ប្រសិនបើព្រឹកឡើងមានចំហាយដំណក់ទឹកជាប់នៅខាងក្នុងភាជន៍ទាំងនោះ គឺទីត្រង់នោះ នឹងមានប្រភពទឹកនៅខាងក្រោមជាពុំខាន។

៣.ពួកគាត់អញ្ជើញលោកគ្រូអាចារ្យ ដែលសិក្សាផ្នែក**កម្មដ្ឋានសមាធិ** មកអង្គុយមើលដោយប្រើឫទ្ធិក្នុងអភិញ្ញាគឺ **ចក្ខុទិព្វ** ដើម្បីរកមើលនូវប្រភពទឹកខាងក្រោម។

ក្នុងវិធីទាំងបីយ៉ាងនេះ វិធីទីបីគឺមានភាពវិសេសជាងគេ វិធីនេះលុះត្រាតែអ្នកមាននូវឈានសមាបត្តិបួន ឬប្រាំបីទើបអាចយកមកប្រើបាន យ៉ាងណាមិញពួកបរទេសក៏ដូច្នេះដែរ ដើម្បីស្វែងរកបង្ហើយរស់របស់ព្រះម៉ែ (បិសាចពស់នៅក្នុងឯកសារ ចិនជីវតាក្វាន់ ) ពួកគេបានបញ្ជូនអ្នកមានឫទ្ធិអភិញ្ញា **(អ្នកមើលហុងស៊ុយ)** មកក្នុងស្រុកខ្មែរដើម្បីដើរស្រាវជ្រាវរាវរក រួចបិទសន្ធប់បង្ហើយរស់របស់ម៉ែនោះ ដើម្បីកុំឲ្យស្ត្រីជាព្រះម៉ែមហានគរចេញពីក្នុងគុករួច ព្រោះពួកគេមិនចង់ឲ្យនគរនេះរុងរឿងឡើងវិញឡើយ ហេតុនេះគេត្រូវប្រើប្រាស់មនោគមវិជ្ជាគ្រប់បែបយ៉ាង ដើម្បីសន្ធប់បិទបញ្ញាកូនខ្មែរកុំឲ្យដឹង

រឿងពិតរបស់ខ្លួនឡើយ (ខ្ញុំបានពន្យល់នៅក្នុងភាគ១រួចហើយ)។ ម្យ៉ាងទៀតគ្រប់រូបសំណាករអង្គជាតិ (លិង្គព្រះឥសូរ) ដែលនៅចុកបិទរន្ធយោនីរបស់មាតានោះ គេតែងតែឆ្លាក់រូបព្រះពុទ្ធនៅ ពីខាងលើក្បាលលិង្គ ពីមួយអង្គទៅដល់បួនអង្គ រួចបែរមុខទៅរកទិសទាំងបួន ដើម្បីកុំឲ្យ ព្រះម៉ែចេញពីក្នុងរន្ធយោនី (មាតុភូមិ) នេះរួច (រូបចម្លាក់នៅប្រាសាទនាគព័ន្ធគេឆ្លាក់រូបក្បាលម៉ែពាក់មកុដរាជកប់ត្រឹមកមាត់ហាស្រែកហៅកូនឲ្យជួយ ដែលនៅលើក្បាលទូលយោនីខ្លួនឯង)។ តើមិត្តអ្នកអានមានឆ្ងល់ឬទេ? បើតួលិង្គជារបស់ព្រះឥសូរហេតុអ្វីក៏ត្រូវឆ្លាក់រូបព្រះពុទ្ធ? នេះជារអាថ៌កំបាំងប្រស្នារូបដែលយើងត្រូវស្រាវជ្រាវរាវរកនូវអត្ថន័យពិត។

ធម្មតារឿងពិតរបស់ធម្មជាតិ ប្រសិនបើចង់បង្កើតកូនប្រុសស្រី ក្បាលលិង្គត្រូវបែរចុះទៅខាងក្រោម ចុះហេតុអ្វីបានជាក្បាលលិង្គបែរទៅខាងលើ ហើយមានរូបពុទ្ធបដិមាទៀត? នេះហើយគឺជាប្រស្នាដែលបរទេសដើរបិទសន្ធប់រន្ធបង្ហើយវាត្រូវនឹង ពាក្យ**កុងម៉ាឬកុងសង្កត់ម៉ា** ដែលផ្ទុយពីពាក្យខ្មែរថា **ដូនតា ឬមេបា**។ ដូច្នេះបើរន្ធយោនី ឬភេទដែលមានឆ្នុកចុក ហើយមានរូបព្រះពុទ្ធបដិមាទៀតនោះ ធ្វើដូចម្ដេចទើបឲ្យគាត់ចេញពីសមុទ្ទទុក្ខរួច? នេះជាប្រស្នាទាក់ទងនឹងមង្គលទីមួយ ដែលគាត់បានលាក់ទុករអាថ៌កំបាំងក្នុងឈ្មោះប្រាសាទ និងរូបចម្លាក់។ ពេលដែលធ្វើពិធីកោរជុកចប់កូនស្រីនៅជួយកិច្ចការម៉ែឪ ចំណែកឯកូនប្រុសវិញ ម៉ែឪបានយកទៅផ្ញើរនឹងភិក្ខុសង្ឃនៅឯវត្ត ដើម្បីបានសិក្សារៀនសូត្រធម៌អាថ៌ និងជួយបម្រើព្រះសង្ឃ (កូនសិស្សលោក)។

## ២.មង្គលទីពីរ

ក/. ក្រោយពីចប់មង្គលទីមួយហើយ វ័យរបស់កូនប្រុសស្រីត្រូវចំរើនឡើង ដូច្នេះមាតាបិតាត្រូវរៀបចំមង្គលទីពីរឲ្យកូនទៀត គឺធ្វើទៅតាមកម្លាំងធនធានគ្រួសារនីមួយៗ គ្រួសារក្រីក្រធ្វើតិចតួចគ្រួសារដែលមានស្ដុកស្ដម្ភគេធ្វើអធិករអធម។ មង្គលទីពីរនេះ កូនប្រុសត្រូវធ្វើពិធី **បំបួសនាគខ្ញាន់** ចំណែកឯកូនស្រីវិញ ត្រូវធ្វើពិធី **ចូលម្លប់** នេះជាកិច្ចរបស់កូននាគប្រុសស្រី។ ហេតុអ្វីកូនប្រុសចាំបាច់ធ្វើកូននាគ កូនស្រីចូលម្លប់? ខ្ញុំនឹងបកស្រាយពន្យល់ទៅតាមការស្រាវជ្រាវ ក្នុងបណ្ដាំគំនិតរបស់ **ព្រះម៉ែ** ដែលបានបន្សល់ទុក នៅក្នុងពិធីមង្គលនេះ។ យើងដឹងហើយថា មង្គលទីមួយនៅខាងលើ

ក្បាល (កោរជុកលាក់ទុកបង្កើយ) មង្គលទីពីរ គឺចុះមកដល់ដើមទ្រូងជាទីកន្លែងលាក់ទុកនូវបេះដូង ដែលបេះដូងនេះ គឺជាទីលាក់ទុករឿងល្អនិងអាក្រក់របស់ចិត្ត **(ទ្រូង = ទ + រូង)** ។

ទ ➜ ទីបង្ហូរនូវទឹក ➜ ទឹកចិត្ត

រូង ➜ ផ្លូវលាក់កំបាំង កម្រមានមនុស្សដឹង **ឧ.** (រូងភ្នំ រូងដី)

បេះដូង = ទីលាក់ទុករឿងរ៉ាវល្អអាក្រក់របស់ចិត្ត **ឧ.** (រឿងអាក្រក់ល្អលាក់ទុកក្នុងចិត្ត) ហេតុនេះហើយ ទើបពួកបរទេសគេតាមបិទសន្ធប់គ្រប់រូង ធម្មជាតិ និងរូងសិប្បនិម្មិតនោះ ព្រោះវាទាក់ទិននឹងរឿងរ៉ាវខាងក្នុងទ្រូងម៉ែ អ្នកចង់ដឹងរឿងម៉ែទាល់តែចាក់ទឹកបេះដូងពីក្នុងទ្រូងម៉ែ (នៅក្នុងភាគ១) ទើបដឹងរឿងបណ្ដាំរបស់ម៉ែ ។

ក្នុងសម័យពុទ្ធកាល កុលបុត្រអ្នកបួសដំបូង ព្រះអង្គបំបួសដោយឫទ្ធិ គឺ**ឯហិភិក្ខុ** បន្តមកព្រះអង្គបំបួសដោយឲ្យឱវាទគឺ **ព្រះមហាកស្សបះ** ហើយការបំបួសជាចុងក្រោយ គឺព្រះអង្គឲ្យសង្ឃបំបួសដោយ **សូត្រញត្តិចតុត្ថកម្មវាចាឧបសម្បទា**(សូត្រញត្តិនាគ) ចុះហេតុអ្វីនៅក្នុង នគរព្រះម៉ែនេះ មុននឹងបួសត្រូវបំបួសនាគសិន (ធ្វើកូននាគ)? ហេតុអ្វីក៏ខុសពីព្រះវិន័យព្រះសម្មាសម្ពុទ្ធពីអតីតកាល? នេះជាហេតុដែលព្រះម៉ែមហានាគម្ចាស់នគរដែលបានទទួលយកនូវព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាមកប្រតិស្ថានក្នុងនគរនេះទុកជាកេរមរតក វាត្រូវតែមានហេតុផល ព្រោះការបំបួសនាគ និងធ្វើជាកូននាគ គឺគាត់ឲ្យកូននាគស្វែងរកមេនាគ ដើម្បីឲ្យបានដឹងរឿងគាត់ នឹងព្យាយាមជួយគាត់នេះជា **បញ្ហា**។ បើមិនបន្សល់ទំនៀមទម្លាប់បំបួសនាគនេះទុកទេ កូននាគសម័យក្រោយៗច្បាស់ជាពុំមានចម្ងល់ឡើយ ហើយបើពុំឆ្ងល់ គឺពុំអាចរកបណ្ដាំពិតរបស់ម៉ែឃើញឡើយ។

**កូននាគ**ត្រូវកោរសក់ស្លៀកសំពត់ហូល...ដូចស្ត្រីដែរ ហើយមានពាក់ឆៀងស្នាម្ខាង **សំពត់ហូល** តំណាងឲ្យស្បែកសត្វនាគ ព្រោះ**ក្រឡាគោមសំពត់ ដូចក្រឡាសត្វនាគ**ដែរ។ សូមស្ត្រីទាំងឡាយដែលនាំគ្នាស្លៀកពាក់ហូល... ប្រយ័ត្នមិនដឹងពីអាថ៌កំបាំងក្រឡាគោមសំពត់នេះ យើងជាពូជនាគឈប់នាំគ្នាធ្វើពើមិនដឹងទៀតទៅ។ កូននាគនៅក្នុងចន្លោះកណ្ដាល គឺចន្លោះគ្រហស្ថ និងបព្វជិត តើកូននាគគ្រប់ជំនាន់ អ្នកដែលស្គាល់មេនាគរបស់អ្នកទេ? តើមេអ្នកនៅឯណា? ចុះហេតុអ្វីក៏កូននាគពុំស្គាល់មេ

នាគ? នេះជាប្រស្នាដែលព្រះម៉ែនាគ ទុកឲ្យកូននាគគ្រប់ជំនាន់ត្រិះរិះពិចារណា ដើម្បីស្វែងរកម៉ែនាគ រួចជួយគាត់ ព្រោះគាត់បានឆ្លាក់បណ្ដាំរឿងនៅលើប្រាសាទរាប់ពាន់ ទៅអនាគតគាត់ដឹងថានឹងមាន កូននាគណាម្នាក់ដែលជាកំពូលលើកូននាគទាំងឡាយ ( ឈ្មោះ**ជីសូរ**) នឹងដឹងរឿងគាត់ហើយព្យាយាម ជួយគាត់ឲ្យរួចផុតពីបាបកម្ម ដែលគាត់បានទទួលកន្លងមក ហើយដែលរឿងរបស់គាត់ត្រូវគេ (បរទេស)តាមបិទសន្ធប់ជិតគ្រប់ទីកន្លែងដែលគេសង្ស័យ ។

កូននាគខុសពីមនុស្សធម្មតា (កូននាគពិត) ព្រោះកូននាគស្គាល់កាលបី **អតីត** + **បច្ចុប្បន្ន** + **អនាគត** និងស្គាល់ផ្លូវទៅកាន់ **អបាយភូមិ សុគតិ ព្រះនិព្វាន្ត**។

## តើមេនាគជាអ្នកណា?

– មេនាគទីមួយ គឺមាតាបិតាបង្កើតបច្ចុប្បន្ន

– មេនាគទីពីរ គឺមាតាបិតាមហានគរ ព្រោះគាត់ជាព្រះម៉ែនាគដែលបានបន្សល់ទុកនូវ កេរមរតកសព្វបែបយ៉ាង ពីមុនយើងហៅថា**ព្រះនាងនាគ**។

– មេនាគទីបី គឺព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូនៃយើង (ព្រះពុទ្ធនាគ) ព្រះអង្គជាធំលើស សាវ័កទាំងឡាយគឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា សាមណេរ ហើយនិងទេវតាគ្រប់ជាន់ថ្នាក់ ។ តើព្រះម៉ែនាគគាត់នៅឯណា? ខ្ញុំបានពន្យល់ហើយ នៅក្នុងអាថិកំបាំងភាគទីមួយ។

ចុះហេតុអ្វីបានជាកូននាគមិនស្គាល់មេនាគ ឬព្រះមាតានាគ? ព្រោះហេតុតែអកុសលកម្មបាន តាក់តែងនូវបាបរបស់ព្រះម៉ែដែលបានធ្វើហើយ ទើបធ្វើឲ្យកូននាគប្រុសស្រីគ្រប់ជំនាន់ខាងក្រោយ ភ្លេចឆ្ងល់ ម្យ៉ាងទៀតព្រោះតែកូននាគពុំព្រមចុះទៅក្នុងទ្រូងរូងយកបេះដូងម៉ែឪមកបើកមើលរឿងក្នុង ចិត្តប្រកបដោយ ព្រហ្មវិហារធម៌របស់គាត់ចេះតែនាំគ្នានៅមាត់រូងខាងក្រៅ ព្រោះរវល់មើលតែនឹង ភ្នែកមិនបានមើលហើយគិតនឹងថ្វាស (ត្រិះរិះគិតឆ្ងល់) ហេតុនេះទើបមិនស្គាល់មេនាគ។ ទោះបីជា គាត់ខំសាងប្រាសាទទុករាប់ពាន់ ហើយប្រាសាទខ្លះគាត់ឆ្លាក់មុខព្រហ្មត្រឹម**ក** ទុកឲ្យកូនខ្មែរមើលយ៉ាង ណា ក៏យើងមិនបានអើពើឆ្ងល់ថា ហេតុអ្វីព្រហ្មខ្មែរមានតែក្បាល តើខ្លួនបាត់ទៅណាហ្ន៎? ឥណ្ឌាជា

ប្រភពនៃទីកើតរបស់ព្រហ្មញ្ញសាសនា ចុះហេតុអ្វីបានជាគ្មានប្រាសាទមុខព្រហ្មដ៏ច្រើន និងស្កឹមស្កៃ ដូចយើងជាខ្មែរ? ហេតុអ្វីដូនតាខ្មែរគ្រាន់តែជាអ្នកទទួលឥទ្ធិពល បែរជាមានប្រាសាទចម្លាក់មុខព្រហ្មដ៏ច្រើន និងស្កឹមស្កៃទៅវិញ? តើគំនិតបណ្ឌិតព្រះម៉ែមហានគរខ្ពស់ឬបរទេសខ្ពស់? ចម្លើយកូនម៉ែប្រុសស្រីពិចារណាត្រិះរិះរួចឆ្លើយដោយខ្លួនឯងចុះ ជាពិសេសគឺកូននាគ។ កូននាគទាំងឡាយតែងប្រែភេទ ពី **ហីនភេទ** (ភេទទាប) ទៅរក**ឧត្តមភេទ** (ភេទប្រសើរ) ហើយគុណធម៌នេះចំរើនឡើងថែមទៀតតាមថ្នាក់ **សីល សមាធិ បញ្ញា** ដែលជាមាគ៌ាត្រៃសិក្ខារបស់ព្រះសម្មាសម្ពុទ្ធ រួចធ្វើដំណើរឆ្ពោះទៅរកទីបញ្ចប់នៃទុក្ខ **វិមុត្តិសុខគឺព្រះនិព្វាន្ត**។ កូននាគបានប្រែភេទទៅជាបព្វជិត គឺអ្នកបួសក្នុងព្រះពុទ្ធសាសនាទទ្រង់នូវសំពត់កាសាវៈ ហើយបព្វជិតដែលក្លាយខ្លួនពីកូននាគនោះសូម្បីតែញាតិសន្ដាន និងគ្រហស្ថរួមទាំងមាតាបិតាបង្កើតផង តែងតែលំឱនកាយថ្វាយបង្គំសមណៈនោះ ព្រោះលោកជារតនៈត្រៃទីបីគឺ **សង្ឃរតនៈ**។ពេលនោះកូននាគក្លាយទៅជាកូនរបស់មេនាគទីបីគឺ **ព្រះពុទ្ធនាគ** ដែលជាមេនាគធំលើសនាគទាំងឡាយក្នុងភពបីគឺ **កាមភព រូបភព អរូបភព**។

ពេលដែលកូននាគនោះអស់និស្ស័យក្នុងផ្នួសតែងតែសុំឧបជ្ឈាយ៍លាចាកសិក្ខាបទ (សឹក) មកវិញជាគ្រហស្ថ គេតែងឲ្យនាមថ្មីមួយទៀតថា **បណ្ឌិត ឬជី** (សម័យដើម) សព្វថ្ងៃនេះហៅថាអន្ទិត ឬអន្ទិតគោលោត ព្រោះអីសឹកមកមិនទាន់ទាំងដុះសក់ស្រួលផង កូននាគភាគច្រើនបានដាច់សិក្ខាបទប្រាំអស់ទៅហើយ (ដាច់សីលប្រាំ)។ ចំពោះកូននាគបែបនេះ ពុំមែនជាពូជនាគតំណពីអតីតកាលទេ ព្រោះពួកខ្លួនបានធ្វើឲ្យខូចពូជពង្សដ៏ប្រសើរឧត្ដម ហើយត្រូវអាប់ឱនអន់ថយនូវកេរ្ដិ៍ឈ្មោះនេះដោយសារតែខ្លួន។ សម័យពីដើមបើកូនប្រុសមិនបានបួសរៀនទេ ហើយទៅស្ដីដណ្ដឹងកូនគេៗពុំឲ្យឡើយ តែបច្ចុប្បន្ននេះវាខុសស្រឡះ ព្រោះកូននាគភាគច្រើន បានធ្វើឲ្យអាប់ឱនពូជពង្សត្រកូលនាគអស់ហើយ មិនត្រឹមតែប៉ុណ្ណឹងទេ កូននាគមួយចំនួននាំគ្នាជេរប្រមាថមេនាគ ដែលជាព្រះម៉ែនាគទៀតផង។

នេះជាការបកស្រាយដោយសង្ខេប នៅក្នុងមង្គលទីពីរចំពោះកូនប្រុស ដែលបានធ្វើជាកូននាគ ហើយមាតាបិតាតែងធ្វើបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ រហូតបានក្លាយជាទំនៀមទំលាប់ប្រពៃណីត្រូវបានបន្សល់ទុកជាកេរតំណែលរបស់ព្រះម៉ែម្ចាស់ប្រទេស ដូច្នេះទើបមានពាក្យទំនៀមមួយឃ្លាថា

បួសនេនសងគុណម្ដាយ បំពេញភិក្ខុសងគុណឪពុក (នេះជាពាក្យទំនៀមដែលបន្សល់ទុកពីដូនតាសម័យខាងដើម) ព្រោះហេតុអ្វី? ចម្លើយមិត្តអ្នកអានត្រិះរិះគិតរួចឆ្លើយ។

ខ/. ចុះចំណែកកូនស្រី តើមាតាបិតាគាត់ធ្វើមង្គលអ្វីឲ្យក្នុងមង្គលលើកទីពីរនេះ? គឺពួកគាត់ធ្វើពិធីចូលម្លប់ ដែលពិធីនេះទាក់ទងនឹងរឿងព្រេងពីបូរាណមួយ គឺរឿង មេចោរចិញ្ចឹមកូនស្រី (ប្រជុំរឿងព្រេងខ្មែរ) លាក់ទុកក្នុងរូងភ្នំ ដែលជាហេតុឲ្យកើតរឿងទំនៀមទំលាប់ប្រពៃណីរហូតមកដល់សម័យខាងក្រោយ គឺរឿងពិធីបញ្ចូលម្លប់កូនស្រី។

## ពន្យល់ពាក្យ ( ចូលម្លប់)

ចូល = ទៅខាងក្នុង (សាច់រឿងគឺក្នុងរូងភ្នំ)

ម្លប់ = ទីដែលមានស្រមោលបាំង

ម្លប់ = ម + លុប (មឲ្យគេលប់កុំឲ្យដឹងរឿង) ព្រោះសាច់រឿង គឺពុំឲ្យអ្នកទីបី ដឹងរឿង។

ចំណែកឯកូនស្រីដែលត្រូវចូលម្លប់ក៏ដូច្នោះដែរ គឺពុំបានឲ្យអ្នកខាងក្រៅដឹងឡើយ ជាពិសេស **បុរស** រហូតពេលខ្លះគេពុំដឹងថា ក្នុងផ្ទះនោះមានកូនក្រមុំផង។ ក្នុងមង្គលទីពីរនេះ ទាក់ទិននឹងរឿងរបស់ស្ត្រីវាដូចជារឿងអាថ៌កំបាំងរបស់ **ព្រះម៉ែ** មហានគរយ៉ាងដូច្នោះដែរ គេបានបិទសន្ធប់លុបដានគាត់បាត់អស់ទៅហើយ ព្រោះក្នុងសាច់រឿងបុរសជាមេចោរដែលជាឪពុកចិញ្ចឹម បានសន្ធប់បិទមាត់រូងឲ្យជិតពុំឲ្យអ្នកទីបីដឹងរឿងឡើយ តែក្រោយមកដោយកូនចិញ្ចឹមនោះ មានជម្ងឺស្លេកស្លាំង ទើបឪពុកចិញ្ចឹមទៅរកពេទ្យឆ្មបស្រី ដើម្បីមកមើលជម្ងឺទើបកើតជារឿងដឹងបន្តគ្នា រហូតក្លាយទៅជាទំនៀមកូនស្រីត្រូវចូលម្លប់នេះ (បង្ខាំងទុក)។

គ/. សរុបសេចក្តីមក ក្នុងមង្គលទីពីរដែលខ្ញុំបានបកស្រាយត្រួសៗនេះ មិនថាកូនម៉ែប្រុស ឬស្រីឡើយសុទ្ធតែត្រូវចូលទៅក្នុងទ្រូង (ទ + រូង) ទើបដឹងរឿងក្នុងបេះដូងម៉ែ (នៅក្នុងប្រស្នាចាក់ទឹកដូង) ពេលដឹងបណ្ដាំរឿងក្នុងបេះដូងព្រះម៉ែហើយ គេនឹងព្យាយាមជួយស្រង់គាត់ឲ្យរួចផុតពីទីទុក្ខនេះ

ទៅតាមកម្លាំងឧបនិស្ស័យកតញ្ញូកតវេទីរបស់កូននាគម្នាក់ៗ ដោយមានសទ្ធាជឿលើកម្មផល និងរួម ទាំងមានសេចក្ដីព្យាយាមរបស់កូននាគប្រុសស្រី ( សព្វថ្ងៃបណ្ដាំប្រស្នាចូលម្លប់នេះ មាននៅក្នុងរូងភ្នំ ឈ្យោកខេត្តកំពត) (គុហារ ក្នុងគុហារ) និងក្នុងរូងគុហារដទៃទៀត។

## ៣.មង្គលទីបី

នៅពេលដែលវ័យរបស់កូននាគប្រុសស្រី ចំរើនដល់វ័យគ្រប់អាយុ (គ្រប់ការ) ម្ដាយឪពុករាល់រូប តែងតែធ្វើ មង្គលទីបីជាចុងក្រោយឲ្យកូនប្រុសស្រី គឺមង្គលការ (អាពាហ៍ពិពាហ៍) មង្គលនេះ បានរំកិល ធ្លាក់ទៅដល់ចុងជើងហើយ ព្រោះកូនប្រុសស្រីត្រូវចាកចេញពីម៉ែឪដើម្បីបង្កើតគ្រួសារថ្មី គឺចាប់ផ្ដើម ករែក កឆ្នាំង រៀបចំខ្លួនធ្វើជាម៉ែឪគេនៅពេលមង្គលទីបីនេះត្រូវបានបញ្ចប់។ តើក្នុងមង្គលទីបីនេះ កូននាគប្រុសត្រូវធ្វើអ្វី? កូននាគស្រីត្រូវធ្វើអ្វី?

ក/. ខាងកូនប្រុសត្រូវដើរតួជាព្រះថោង នាំយកនូវគ្រឿងបណ្ណាការចូលមកស្ដីដណ្ដឹងកូនស្រី តាមទំនៀមទំលាប់ ដែលបានធ្វើតៗគ្នាមកនៅក្នុងរឿងព្រេង **ព្រះថោងនាងនាគ**។ (សូមមិត្តអ្នកអាន ស្រាវជ្រាវក្នុងពិធីមង្គលការនេះ ដោយខ្លួនឯងចុះ)

ខ/. ចំណែកខាងកូនស្រីត្រូវដើរតួជាព្រះនាងនាគ ព្រោះខ្លួនបានចេញពីម្លប់ហើយ ដូច្នេះដល់ ពេលដែលមាតាបិតារៀបចំទុកដាក់ឲ្យមានស្វាមី ទៅតាមគន្លងប្រពៃណី។ នៅក្នុងមង្គលទីបីនេះ ខ្ញុំចង់ លើកយកនៅប្រស្នាអាថ៌កំបាំងខ្លះៗមកពន្យល់ថា ហេតុអ្វីបានជាព្រះនាងនាគបច្ចុប្បន្ននេះពុំបានដឹង រឿងរ៉ាវពិតរបស់ព្រះនាងនាគពីអតីតកាល? ហេតុអ្វីព្រះនាងនាគបច្ចុប្បន្ននេះ ពុំរុងរឿងថ្កុំថ្កើង ដូច ព្រះនាងនាគពីអតីតកាល? ខ្ញុំនឹងឆ្លើយសំណួរនេះនៅទំព័រខាងក្រោយ។

គ/. នៅក្នុងមង្គលទីបីនេះ ខ្ញុំនឹងលើកយកគោលធំៗ ដែលមាននៅក្នុងពិធីនេះ គឺមាតាបិតាទាំង ខាងកូនប្រុសកូនស្រី អ្នកផ្លូវចៅមហា មេបាប្រុសស្រី ដែលត្រូវបំពេញនូវកិច្ចការនេះ ។ខ្ញុំសូមដកស្រង់ ទាំងស្រុងចេញពីសៀវភៅ **លំអានទំនៀមទម្លាប់ខ្មែរបុរាណ** (រៀបរៀងចងក្រងដោយលោក ញាណ ភឿន និងលោក ម៉ម ផៃ ក្នុងការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ព.ស ២៥៤៦ គ.ស ២០០២)។

<u>គោលធំៗ មាន ៖</u>

១.ពិធីសែនក្រុងពលី

២.ពិធីស្ដីដណ្ដឹង

៣.ពិធីហែរកំណាត់

៤.ពិធីកាត់ផ្កាស្លា

៥.ពិធីកាត់សក់

៦.ពិធីសូត្រមន្ត

៧.ពិធីសែនគួចដៃ

៨.ពិធីធ្វើច្រុញ ចែកជា ៖

ក.ក្រាលអង្កររាប

ខ.ធ្វើច្រុញ

គ.ប្រតប់ច្រុញ

ឃ.បរសេះ

ង.កាត់ខាន់ស្លា

ច.កប់ដី

៩.ពិធីយកពេលា (វេលា)

១០.ពិធីផ្ទឹមសំពះ

១១.ពិធីផ្សំដំណេក

ក្នុងពិធីទាំងដប់មួយធំៗនេះ ខ្ញុំសូមដកយកតែពិធីទី១០ មកបកស្រាយពន្យល់រៀកញែក ដើម្បីកុំឲ្យអត្ថបទនេះកើនទំព័រច្រើនពេក ម្យ៉ាងទៀតខ្ញុំទុកឲ្យមិត្តអ្នកអានស្រាវជ្រាវពិធីនេះដោយខ្លួនឯងដើម្បីជាកូនសោសំរាប់ពិចារណា បើកនូវអាថ៌កំបាំងក្នុងមង្គលទីបីនេះ ដែលទាក់ទងជាមួយនឹងរឿងព្រះម៉ែមហានគរ។

១.ក្នុងពិធីសំពះផ្ទឹម **អ្នកមហា** បានសុំឲ្យកូនស្រីមកលាងជើងកូនប្រុស ខាងកូនស្រីត្រូវមានផ្លែដូងឡៅទុកជាស្រេច រួចរកសំឡី ឬកូនកន្សែងថ្មីមកទុកជិតផ្លែដូងនោះ។ **មេខ្មែរ** អ្នកដឹកដៃកូនស្រីឲ្យនាងមកឈរមុខកូនប្រុស រួចឲ្យលុតជង្គង់សំពះកូនប្រុស ហើយកូនស្រីយកសំឡីឬកូនកន្សែងថ្មីមកជ្រលក់ទឹកដូងដែលឡៅទុកនោះ មកជូតជើងឲ្យកូនប្រុស ចំណែកឯកូនប្រុសយកវត្ថុដែលមានតម្លៃមកបំពាក់ជូនឲ្យកូនស្រី ដែលជានិមិត្តរូបតំណាងឲ្យ***សុភមង្គល***។ តើមិត្តអ្នកអានដឹងទេ ហេតុអ្វីបានជាត្រូវយកទឹកដូង មកលាងជើងឲ្យកូនប្រុស? អាថ៌កំបាំងទឹកដូងនេះ ខ្ញុំបានពន្យល់នៅភាគ១រួចហើយ កូននាគប្រុសស្រី ពុំអាចស្គាល់ទឹកក្នុងបេះដូងរបស់ព្រះ**ម៉ែនាគ**ឡើយគឺបានត្រឹមតែយកមកលាងជើងឲ្យគ្នាតែប៉ុណ្ណោះនេះជាអាថ៌កំបាំងក្នុងពិធីយកទឹកដូងមកលាងជើង។

២. ហើយកិច្ចមួយទៀត គឺពិធីហែកូនប្រុសស្រីចូលបន្ទប់ ពេលនោះកូនស្រីដើរតួជាព្រះ**នាងនាគ** រីឯកូនប្រុសដើរតួជាព្រះថោង (រឿងព្រះថោងតោងស្បៃនាងនាគ) តើក្នុងចំណោមទាំងពីរនាក់នេះអ្នកណាជា **មេ**? មេ គឺពិតជា**ព្រះនាងនាគ** ព្រោះគាត់បាន**ដើរមុខ នាំមុខ ដឹកមុខ** បុរសជាព្រះថោង។ តែគួឲ្យអាណិតព្រះនាងនាគណាស់ គ្រាន់តែដឹកគេចូលក្នុងបន្ទប់ផុតភ្លាម គេក៏បិទទ្វារបន្ទប់អាចារ្យនៅខាងក្រៅ បានឲ្យអ្នកភ្លេងច្រៀងបទលុបជើងពីរ(លុបដាន) ដោយឲ្យអ្នកច្រៀងអង្គុយចោងហោងច្រៀងបទលុបដាន ហើយធ្វើកាយវិការរំកិលថយក្រោយ ដូចជាលុបដានស្នាមជើងមនុស្សមែនៗ(**ស្នាលុបបំបាត់ដានព្រះម៉ែ**។ ចប់ពិធីលុបដានគេធ្វើពិធីសាកន្ទេល អ្នកភ្លេងលេងបទសាកន្ទេល អ្នកច្រៀងធ្វើកាយវិកាដូចជាអ្នកមូរសាកន្ទេល ចប់ពិធីសាកន្ទេលគេធ្វើពិធីលក់កន្ទេល ។ តើមិត្តអ្នកអានយល់ពីប្រស្នាក្នុងពិធីទាំងបីនេះទេ? លុបដាន សាកន្ទេល លក់កន្ទេល។

នេះជាចម្លើយ ដែលព្រះនាងនាគបច្ចុប្បន្នពុំអាចដឹងនូវបណ្ដាំនៃភាពរុងរឿងធុំធ្ងើងរបស់ព្រះម៉ែនាគ គឺរឿងរ៉ាវពិតពីអតីតកាលរបស់គាត់ ព្រោះគ្រាន់តែគាត់ដឹកព្រះថោងចូលក្នុងបន្ទប់ភ្លាម គេបិទទ្វារជិត ដោយពុំបានដឹងរឿងអ្នកនៅខាងក្រៅគេធ្វើអ្វីឡើយ ។ គាត់មិនដឹងថាពួកគេនៅខាងក្រៅលុបដានស្នាមនៃភាពរុងរឿងរបស់ខ្លួនឡើយ ហើយស្នាមដែលនៅសេសសល់លុបមិនអស់ គេ**សាដានស្នាម**នោះឡើង (សាកន្ទេល) រួចប្រមូលយកទៅដើរលក់នៅខាងក្រៅ ហើយអ្នកដែលទិញដានស្នាមនៃភាពរុងរឿងរបស់គាត់គឺអ្នកខាងក្រៅ(បរទេស)នេះជាប្រស្នា **លុបដាន សាដាន លក់ដាន។**

៣/. ដូច្នេះកូននាគដែលកើតអំពីព្រះម៉ែនាគ ដែលគេបានលុបដាននៃភាពរុងរឿងរបស់ គាត់អស់ហើយ ដែលគាត់នៅក្នុងបន្ទប់ពុំបានដឹងថាអ្នកខាងក្រៅលុបដានស្នាមដែលតំណាងឲ្យភាពរុងរឿងរបស់គាត់ឡើយ។ តើកូននាគដែលកើតចេញពីម៉ែនាគនៅក្នុងបន្ទប់ ដែលត្រូវគេលុបដានអស់នោះ ធ្វើដូចម្ដេចអាចដឹងពីបណ្ដាំរុងរឿងរបស់ព្រះម៉ែនាគពីអតីតបាន? បើពុំដឹងបណ្ដាំព្រះម៉ែនាគយ៉ាងហ្នឹង តើធ្វើដូចម្ដេចអាចក្លាយខ្លួនទៅជា **ព្រះនាងនាគ** ពិតប្រាកដបាន? (ស្គាល់ដានស្នាមប្រវត្តិសាវតាពិតរបស់ព្រះម៉ែពីអតីតកាល)។ ឧ: ដូចជារឿងមាតាទាំង **១២** សព្វថ្ងៃត្រូវគេខ្វេះកៃវភ្នែកទាំងដប់មួយកន្លះចោលអស់ទៅហើយតើកូនដែលកើតចេញពីមាតាទាំង**១២**នោះ ភ្លឺ ឬមួយងងឹត?

ភ្នែកមាតាមួយគូ = **៣០**ឬ**៣១**ថ្ងៃ x **១២**ខែ = **៣៦៥**ថ្ងៃ តែសព្វថ្ងៃនៅសល់តែភ្នែកមួយចំហៀងស្មើ **១៥**ថ្ងៃ តើធ្វើដូចម្ដេចឲ្យកូនខ្មែរដឹងរឿងពីអតីតបាន ? បើ**៣៦៥**ថ្ងៃដក នឹង**១៥**ថ្ងៃ = **៣៥០**ថ្ងៃ នេះ គឺជាថ្ងៃដែលកូន និងម៉ែសម័យក្រោយងងឹតព្រោះនគរនេះ គឺជាមាតុភូមិ = ទីកើតរបស់កូនប្រុសស្រី ហើយរឿងមាតាទាំង**១២**នេះទៀតសោត គឺជារឿងពិតប្រចាំនគរនេះទៀតផង។ ដោយពួកគាត់បានសាងប្រាសាទព្រះនាង**១២** ឬស៊ូព្រាត់ទុកជាកេរបណ្ដាំព្រះម៉ែឲ្យយើងមើលរហូតមកដល់សព្វថ្ងៃ ។

ឃ/. នេះជាចម្លើយដែលខ្ញុំបានបកស្រាយពន្យល់ដោយសង្ខេបនៅក្នុងអាថ៌កំបាំងដែល ទាក់ទងនឹងមង្គលទីបីនេះ។ សរុបសេចក្ដីមក កាតព្វកិច្ចរបស់មាតាបិតាពីអតីត តែងធ្វើការជាមង្គលឲ្យកូនបីលើក ដូច្នេះហើយទើបកូនខ្មែរពីសម័យដើម ពុំសូវមានកូនដែលទៅប្រព្រឹត្តអំពើខុសឆ្គងឡើយ ព្រោះម្ដាយឪពុកតាមគ្រប់គ្រងកូនគ្រប់កាលនិងគ្រប់វ័យ បើនិយាយពីបច្ចុប្បន្ននេះវិញ មានមាតាបិតាខ្លះសូម្បីតែមង្គលមួយក៏ពុំបានធ្វើឲ្យកូនផង នេះហើយអ្នកស្នងមរតកព្រះម៉ែ(ខ្មែរ) បើមាតាបិតារាល់រូប

បោះបង់នូវមង្គលគឺសេចក្តីល្អចោលអស់យ៉ាងហ្នឹង តើអនាគតមាតុភូមិនេះនឹងទៅជាយ៉ាងណា? តើព្រះម៉ែមហានគរលោកអាចសង្ឃឹមទៅលើកូននាគប្រុសស្រីសម័យក្រោយបានដែរឬទេ? ដែលគាត់រង់ចាំឲ្យកូននាគជួយគាត់នោះជាពិសេសគឺកូននាគសព្វថ្ងៃដែលជាអ្នកទទួលនូវមរតកបណ្តាំព្រះម៉ែ ។

សូមឲ្យកូននាគប្រុសស្រី(ម៉ែឪកូនចៅ) នាំគ្នាសាមគ្គីពួតដៃជាធ្លុងមួយ (សាមគ្គីនាគព័ន្ធ ឬព័ន្ធនាគ) ដើម្បីជួយស្រង់ព្រះមាតាបិតាឡើងវិញ មានតែកូនកតញ្ញូទេដែលអាចជួយស្រោចស្រង់ពួកគាត់បាន។ ព្រះម៉ែនាគមានគុណធំជាងភ្នំ**ព្រះសុមេរុ** ហេតុអ្វីបានជាយើង មើលពុំឃើញនូវគុណដ៏ធំរបស់លោក? ហេតុអ្វីបានជាយើងយកភាពអាក្រក់នៃភេទរបស់គាត់(យោនី) ដែលសំរាប់បង្ហូរនូវទឹកមូត្រ និងកាកសំណល់ ឈាមខ្ទុះ យកមកដាក់នៅក្នុងមាត់ទៅវិញ? (ពេលជេរម៉ែគ្នាម្តងៗកូនតែងយកភេទម៉ែមកដាក់ក្នុងមាត់)។ សូមកូននាគប្រុសស្រីភ្ញាក់ឡើង ពេលវេលារបស់យើងដល់ហើយ សូមកូនខ្មែរនាំគ្នាក្រោកចាកចេញពីអន្លង់ក្រពើ(ក្រធ្វើដឹង)នេះទៅ។ ព្រោះយើងជាអ្នកកាន់ និងគោរពព្រះពុទ្ធសាសនា ដូច្នេះយើងត្រូវតែដឹងហេតុផលរបស់ **កុសល** និង**អកុសល** ដែលពួកគាត់បានសាងសន្សំទុកដើម្បីជាប្រយោជន៍សម្រាប់កូនខ្មែរគ្រប់ៗគ្នាហេតុនេះអ្នកទទួលមរតកព្រះម៉ែ ត្រូវតែតបនូវគុណគឺសេចក្តីល្អទៅពួកគាត់វិញ(កតញ្ញូកតវេទី)។

**II.** ហើយជាបន្តខ្ញុំនឹងបកស្រាយ ពន្យល់អំពីអាថិកំបាំងមហាសង្ក្រាន្តខ្មែរក្នុងរឿង **កបិលមហាព្រហ្ម** ដែលទាក់ទងនឹងរឿងសិរីបីប្រការ ដែលកូនខ្មែរប្រុសស្រីប្រារព្ធធ្វើនៅខែចេត្រក្នុងរដូវចូលឆ្នាំថ្មី។ ដើម្បីប្រៀបធៀបថា តើរឿងមង្គលបី និងរឿងសិរីបី វាមានបង្កប់អត្ថន័យដូចគ្នា ឬមួយក៏ខុសគ្នា? (រឿងព្រេងនេះជារឿងទាក់ទងក្នុងនគរខ្មែរ)។

ពន្យល់ពាក្យសិរី = ស្រី → សិរីបីប្រការ = រឿងរ៉ាវស្ត្រីបីយ៉ាង

រឿងសិរីបីប្រការ គឺជាបណ្តាំរឿងរបស់ស្ត្រីបីយ៉ាង ដែលបានលាក់ទុកក្នុងទំនៀមទំលាប់នៃពិធីមហាសង្ក្រាន្តចូលឆ្នាំថ្មី ហើយជារឿងប្រចាំនគរនេះសំរាប់ផ្លាស់ប្តូរឆ្នាំថ្មី សិរីទាំងបីប្រការនោះមាន៖

១.ពេលព្រឹកសិរី (ស្រី) នៅលើមុខឬក្បាល (បុរសស្ត្រីត្រូវយកទឹកលាងមុខឬលុបមុខ)

២.ពេលថ្ងៃ សិរី (ស្រី) ធ្លាក់ចុះមកដល់ដើមទ្រូង (បុរសស្ត្រីត្រូវយកទឹកមកលុបលាងទ្រូង)

៣.ពេលល្ងាចសិរី (ស្រី) ធ្លាក់ចុះមកដល់ចុងជើង (បុរសស្ត្រីត្រូវយកទឹកមកលុបលាងជើង)

រឿងសិរីទាំងបីនេះ យើងបានតែត្រឹមធ្វើតគ្នាពីមួយជំនាន់ទៅមួយជំនាន់តែប៉ុណ្ណោះ គឺពុំបានដឹងរឿងពិតរបស់ស្ត្រី ដែលជាម្ចាស់រឿងនោះឡើយ។ ហើយសិរីបីនេះ កើតមានក្នុងរឿងព្រេងខ្មែរ គឺរឿងកបិលមហាព្រហ្ម ដែលបានយកប្រស្នាបីខទៅសាកសួរថៅមាណពឈ្មោះធម្មបាល ដែលល្បីថាគាត់ចេះដឹងធម៌អាថ៌ច្រើន ហើយបានដាក់ខសន្យាគ្នាថា៖ ប្រសិនបើថៅមាណពឯងដោះប្រស្នាសិរីទាំងបីនេះមិនចេញទេត្រូវតែកាត់ក្បាល តែបើដោះប្រស្នាចេញយើងសុខចិត្តកាត់ក្បាលឲ្យ។ ទីបំផុតថៅធម្មបាលមាណព បានដោះប្រស្នានោះចេញ ដោយសារបានស្តាប់ពាក្យ កូនឥន្ទ្រីសាកសួរមេឥន្ទ្រីពីអាថ៌កំបាំងនៃប្រស្នាទាំងបី។ ពេលដែលមហាព្រហ្មបានចាញ់ក្តីនេះ ដោយធម្មបាលមាណពដោះប្រស្នាសិរីបីនេះរួច គាត់ក៏ព្រមកាត់ព្រះសិរសា (ក្បាល) ប៉ុន្តែមុននឹងកាត់ គាត់ក៏បានហៅកូនស្រីតំណាងឲ្យថ្ងៃទាំង**៧** មកប្រាប់រួចផ្តាំថា ក្បាលរបស់ឪពុកនេះ ប្រសិនបើយកទៅដាក់នៅក្នុងសមុទ្រនឹងរីងទឹកសមុទ្រ ប្រសិនបើដាក់នៅអាកាសនឹងរាំងភ្លៀង ប្រសិនបើដាក់នៅលើផែនដី នឹងធ្វើឲ្យឆេះដីប្រេះបែកក្រហែង មានតែយកទៅដំកល់ទុកក្នុងរូងគុហារភ្នំព្រះសុមេរុ។ ពេលផ្តាំបុត្រីទាំង**៧** រួចហើយ កបិលមហាព្រហ្មក៏ចាប់កាន់ព្រះខ័ន កាត់សិរសាហុចទៅឲ្យកូនស្រី កូនស្រីក៏នាំគ្នាដង្ហែរព្រះសិរសាព្រះបិតាទៅដំកល់ទុកនៅភ្នំព្រះសុមេរុ (សុមែរុ)។ បុត្រីទាំង**៧**បានប្រជុំដាក់វេនគ្នាថា ប្រសិនបើចក្រវិល (ផែនដីវិល) ទៅដល់ខួបចំលើថ្ងៃអ្នកណាដែលជាថ្ងៃសង្ក្រាន្ត កូនស្រីនោះត្រូវមកហែព្រះសិរសាបិតាប្រទក្សិណប្រាំពីរជុំជុំវិញភ្នំព្រះសុមេរុជារៀងរាល់ឆ្នាំ។

តាមពិត កូនស្រីរបស់គាត់មានដល់**១២**នាក់ឯណោះ ប៉ុន្តែអ្នកមកដង្ហែមានតែប្រាំពីរនាក់ទេ




នេះម្យ៉ាង ម្យ៉ាងទៀត កូនស្រីៗរបស់គាត់តែងប្រចាំគ្នា ព្រោះតែមានការប្រចាំគ្នាដល់វេនអ្នកណាអ្នកហ្នឹងដង្ហែទៅ ឯអ្នកមិនត្រូវវេនគឺមិនរវីរវល់ឡើយ។ ព្រោះហេតុអ្វី? ព្រោះហេតុតែកូនស្រីទាំង**១២**ត្រូវយក្សខ្វេះយកភ្នែក (បញ្ញា) អស់ទៅហើយ នៅសល់មួយចំហៀង ហើយកូនស្រីទាំង**១២**នេះទៀតសោតមានតែ**៧**

ទេវដែលមកដង្ហែសិរសាមាតាបិតាខ្លួនជារៀងរាល់ៗឆ្នាំនោះ (រូបចម្លាក់នៅជុំវិញកព្រហ្មនៅប្រាសាទតាព្រហ្ម និងបន្ទាយក្ដី)។

ក. **សិរីទីមួយ** សូមមិត្តអ្នកអានពិចារណា និងប្រៀបធៀបទៅមើល សិរីទីមួយស្ថិតនៅលើមុខ **មុខ**មានន័យថា ប៉ែកខាងក្បាលឬខាងលើ ដូច្នេះវាដូចនឹងមង្គលទីមួយដែលនៅពីខាងលើដែរគឺ**ការជុកលាក់បង្កើយ** បាននន័យថាប្រស្នាយកទឹកមក លុបមុខឬក្បាលនេះ គឺគាត់ចង់ឲ្យយល់ពីប្រស្នាអាថ៌កំបាំងនៃមង្គលទីមួយ និងសិរីទីមួយ គឺវាទាក់ទងនឹងអវយវៈប៉ែកខាងលើ គឺសិរសានេះឯង។ តើទឹកដែលយកមកលុបគ្រប់កាលទាំងបីនោះតំណាងឲ្យអ្វី? ទឹកតំណាងឲ្យ ទឹកចិត្តកូននាគប្រុសស្រី តើកូននាគប្រុសស្រីណាដែលមានឧបនិស្ស័យសន្សំនូវទឹកចិត្តកតញ្ញូ ដែលអាចចាក់ទឹកទៅក្នុងបេះដូងរបស់ ព្រះម៉ែ ហើយដឹងរឿងព្រះម៉ែ រួចជួយស្រោចស្រង់គាត់ចេញពីអបាយភូមិបាន? ព្រោះដូនតាយើងមានពាក្យទំនៀមមួយឃ្លាថា **ម៉ែឪគិតកូនដូចផ្កាច្រវាប្រដេញ ចំណែកកូនគិតម៉ែឪវិញដូចព្រះបែរក្រោយ**តើព្រះឯណាងាយនឹងបែរព្រះភក្ត្រទៅខាងក្រោយនោះ? តើកូននាគណាមួយ ដែលបានយកទឹកចិត្តទៅលាងអកុសលកម្មឲ្យព្រះម៉ែបាន? តើកូននាគណាដែលបានយកទឹកចិត្តព្រះម៉ែទៅលុបមុខ ដើម្បីឲ្យស្វាងងងុយ ហើយមើលឃើញពីបណ្ដាំពិតរបស់ព្រះម៉ែ?

ខ. **សិរីទីពីរ** គឺស្ថិតនៅលើដើមទ្រូង មានន័យថាថ្ងៃត្រង់ត្រូវយកទឹកទៅលាងទ្រូង ពាក្យ **ទ្រូង** ខ្ញុំបានពន្យល់រួចហើយ **ទ្រូង** គឺជាទីលាក់ទុកនូវបេះដូង បេះដូងជាទីលាក់ទុកនូវចិត្ត ប្រសិនបើយើងប្រៀបធៀបសិរីទីពីរនេះទៅនឹងមង្គលទីពីរ គឺកូនប្រុសបំបួសនាគកូនស្រីចូលម្លប់ មានន័យថា៖ ចូលទៅក្នុងទ្រូង រួងយកបេះដូងម៉ែឪមកមើល។ តែអត្ថន័យនៅក្នុងសិរីទីពីរ គឺមានន័យស្រាលជាងមង្គលទីពីរ ព្រោះគ្រាន់តែយកទឹកមកលុបលាងទ្រូងខាងក្រៅ ធ្វើដូចម្ដេចអាចដឹងរឿងខាងក្នុងចិត្តបាន ? ព្រោះរឿងខាងក្នុងចិត្តទាល់តែយកបញ្ហាទៅស្រាយ ព្រោះព្រះម៉ែជាប់ចំណងអកុសលចិត្ត ប្រសិនបើកូនប្រុសស្រីចង់ស្រាយចំណងចិត្តម៉ែឪ ទាល់តែកូនប្រុសស្រីបំពេញនូវ**កតញ្ញូ**និង**កតវេទី** គឺជាទឹកចិត្តដែលមាននូវគុណធម៌ ទើបអាចយកទៅលាងទឹកចិត្តនៅក្នុងបេះដូងម៉ែឪបាន ធ្វើឲ្យពួកគាត់អាចរួចផុតពីអបាយភូមិបាន ដូចព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានបំពេញកិច្ចជាកូនបានល្អហើយ ដោយព្រះអង្គបានសំដែងព្រះធម៌ប្រោសពុទ្ធបិតា អោយបានទទួលនូវអមតធម៌ គឺព្រះនិព្វាន្ត ហើយ

ចំណែកឯពុទ្ធមាតាវិញ គឺលោកបានសំរេចនូវអរិយផលថ្នាក់ **លោកានាមិស្សរសោតា** ទៀងតែនឹងបាន ត្រាស់ដឹង និងត្រូវបរិនិព្វានត្តនៅឋានព្រហ្មលោក។ ចុះចំណែកកូននាគប្រុសស្រីវិញ ដែលបានទទួល មរតកពីព្រះម៉ែ គឺព្រះពុទ្ធសាសនានេះ តើអ្នកមា នបំពេញសេចក្ដីល្អ គឺការតបគុណដល់មាតាបិតា បង្កើត ឬក៏ដល់ព្រះមាតាបិតាម្ចាស់នគរ នេះទេ? តើអ្នកបានដើរតាមគន្លងព្រះយុគលបាទ ព្រះពុទ្ធជា បរមគ្រូអ្នកទេ? ចម្លើយនេះ គឺកូននាគប្រុសស្រីពិចារណារួចឆ្លើយដោយខ្លួនឯង!...

គ.**សិរីទីបី** គឺថ្ងៃល្ងាចយកទឹកទៅលាងជើង គឺប៉ែកខាងក្រោមបើប្រៀបធៀបនឹងមង្គលទីបី គឺ កូនប្រុសធ្វើជាព្រះថោងចំណែកឯកូនស្រីធ្វើជាព្រះនាងនាគ គឺអ្នកទាំងពីរចាប់ផ្ដើមចាកចេញពី មាតាបិតាដើម្បីបង្កើតគ្រួសារថ្មី។ ចុះហេតុអ្វីក៏ក្នុងសិរីទីបីត្រូវយកទឹកទៅ លុបលាងជើង? ព្រោះមង្គល ទាំងបីជាកិច្ចរបស់មាតាបិតារាល់រូបដែលត្រូវបំពេញ(ពីសម័យដើម) ពេលដែលបំពេញរួចហើយចុង ក្រោយ គឺមាតាបិតាត្រូវតែលាងជើង បានន័យថា ដើម្បីលាងជម្រះនូវរឿងជំពាក់ទាំងឡាយ ហើយ មកធ្វើទីពឹងឲ្យខ្លួនឯងសម្រាប់លោកខាងមុខ(ស្វែងរកសីលសមាធិបញ្ញា) ទប់ទល់នូវបាបអកុសលដែល ពួកគាត់ក្នុងមួយជីវិត ដើរគ្រប់ច្រកល្ហកស្វែងរកនូវបច្ច័យបួន(ទ្រព្យ)ដើម្បីយកមកចិញ្ចឹមបុត្រ។ ដូច្នេះ កិច្ចចុងក្រោយរបស់មាតាបិតាគឺរកស្វាមី ភរិយាឲ្យកូនរួចចែករំលែកនូវទ្រព្យទៅតាមខ្លួនមាន ពួកគាត់ បានបំពេញកិច្ចទៅដល់ទីបញ្ចប់ហើយ រីឯកូនប្រុសស្រីត្រូវបំពេញនូវសេចក្ដីល្អរបស់ខ្លួនតបទៅពួក គាត់វិញ ដែលពួកគាត់បានខំពុះពារមួយជីវិត ដើម្បីបំពេញកិច្ចជា **ព្រះព្រហ្ម**។ ការបកស្រាយពន្យល់ មួយបែបទៀតពីសិរីបីប្រការនេះ គឺតំណាងឲ្យពួកគាត់រួចចេញពីទីឃុំឃាំង ក្នុងទ្វារគុកទាំងបី (ខ្ញុំពុំបក ស្រាយឡើយ)។

ហេតុនេះរឿង **សិរីបីប្រការ** និងរឿង**មង្គលទាំងបី** មានអត្ថន័យប្រហាក់ប្រហែលគ្នា ហើយរឿង ទាំងនេះ សុទ្ធតែបានបង្កប់នូវអាថ៌កំបាំងបណ្ដាំព្រះមាតាបិតាមហានគរ វាខុសពីមង្គលសូត្រដែលព្រះ សម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងក្នុងមង្គល **៣៨ប្រការ** នោះ។ មង្គលរបស់ខ្មែរទាក់ទិនទៅក្នុងរឿង អាថ៌កំបាំងប្រស្នារបស់ព្រះម៉ែម្ចាស់នគរ (មាតាមហានគរ) ចំណែកឯមង្គលសូត្រដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងទាក់ទងនឹងមង្គលរបស់មនុស្ស និង ទេវតា ដែលក្នុងកាលសម័យនោះ ទេវតាបានចុះ មកសាកសួរមង្គលពីព្រះអង្គនៅវត្ត **ជេតពនមហាវិហារ**។

ចំណែកឯរឿងកបិលមហាព្រហ្ម ដែលទាក់ទងនឹងប្រស្នាសិរីបីប្រការ មកទល់សព្វថ្ងៃនេះ ពួកគាត់នៅតែមិនស្លាប់ នៅតែស្ថិតក្នុងសន្ដានកូនខ្មែរប្រុសស្រីគ្រប់ៗរដូវចូលឆ្នាំថ្មី ហើយសិរិសារបស់មហាព្រហ្មនេះទៀតសោត បានរីកសាយដុះដាលគ្រប់ប្រាសាទថ្ម ដែលជាស្នាព្រះហស្ដរបស់ស្ដេចជ័យវរ្ម័នទី៧ (ប្រាសាទមានមុខ **ព្រហ្ម**) ហើយបានបន្សល់ទុកជាកេរតំណែលរហូតមកដល់សព្វថ្ងៃជាមរតកបណ្ដាំរបស់ព្រះម៉ែ (រឿងរ៉ាវនេះខ្ញុំបានពន្យល់ក្នុងភាគមួយខ្លះហើយ)។

សរុបសេចក្ដីមករឿងមង្គលបីប្រការក្ដី រឿងសិរិបីប្រការក្ដីគឺមានតែក្នុងនគរខ្មែរនេះទេ ព្រោះពួកគាត់ បានតែងសាច់រឿងបញ្ចូលលាយឡំទៅក្នុងព្រះត្រៃបិដក(ពុទ្ធសាសនា) ក្នុងគម្ពីរវេទ (ព្រហ្មញ្ញសាសនា) ព្រោះវាជារឿងទាក់ទងនឹងមាតុភូមិនេះ មិនត្រឹមតែប៉ុណ្ណឹងទេ ដូនតាអ្នកនគរនេះ បានតាក់តែងលាយឡំទៅក្នុងជាតក បញ្ញាសជាតក និងជាតកនានា ដែលមាននៅក្នុងព្រះពុទ្ធសាសនា ដើម្បីបំភាន់លាក់រឿងពិតរបស់ព្រះម៉ែមហានគរ។ ដូចជារឿងឥសីមាត់ទិព្វ សព្វសិទ្ធ ព្រះសុធន (ក្រុងសុភមិត្ត) ពុទ្ធសែន...។ល។ ឧ. ដូចរឿងពុទ្ធសែននាងកង្រី ឬនាងដប់ពីរ ក្នុងសាច់រឿងគាត់ចង់និយាយពីម្ដាយទាំងដប់ពីរ ដែលបានទទួលមរតកពីព្រះម៉ែមហានគរ ប៉ុន្ដែទីបំផុតពួកគាត់ពុំអាចថែរក្សានូវពូជបញ្ញា និងភាពថ្កុំថ្កើងរបស់ ព្រះម៉ែមហានគរបានឡើយ ព្រោះត្រូវគេខ្វេះ កែវភ្នែក (យក្សខ្វេះ) គឺខ្វេះបញ្ញានៅសល់តែកែវភ្នែកមួយចំហៀងតែប៉ុណ្ណោះ តើធ្វើដូចម្ដេចឲ្យកូនខ្មែរបានដឹងរឿងរបស់បុព្វជនព្រះម៉ែនាគខាងដើមបាន? បើអ្នកទទួល **បណ្ដាំមរតក**ងងឹតទៅហើយនោះ (ចូរមើលការពន្យល់នូវទំព័រលើ)។ បើកូនកើតចេញពីម្ដាយដែលឥតបញ្ញាដូច្នេះ តើពួកគេអាចដឹងពីសាវតាពិតរបស់ខ្លួនបានដែរឬទេ? គឺពិតជាពុំអាចដឹងបានឡើយ។ ចុះយក្សដែលជាអ្នកខ្វេះ កែវភ្នែកជានរណា? ខ្ញុំបានពន្យល់រួចមកហើយពីអាថ៌កំបាំងកូរសមុទ្រទឹកដោះ គឺយក្សគេកាន់ក្បាលនាគ (និមិត្តរូបក្បាលព្រះម៉ែ) បើក្បាលគេជាអ្នកគ្រប់គ្រងទៅហើយ តើអ្នកនៅកាន់កន្ទុយមានប្រយោជន៍អ្វី? ដូចជាមាតាខ្វាក់ទាំងដប់ពីរក៏យ៉ាងដូច្នោះដែរ មានកែវភ្នែកឯណាដើម្បីមើលដឹងរឿងពិតរបស់ខ្លួន បើកែវភ្នែកពួកគាត់នៅសល់តែមួយចំហៀងយ៉ាងនេះ ហើយមួយចំហៀងនេះ ត្រូវកើតមានរោគភ្នែកខ្លះទៀត (មានរូបមានរោគព្រោះរូបជាសំបុកនៃរោគ) ដែលធ្វើឲ្យភាពភ្លឺ នៅសល់ដប់ប្រាំថ្ងៃនោះ រឹតតែនៅខើចខ្លីទៅទៀត។ នេះជាអាថ៌កំបាំងដែលដូនតាបានលាក់ទុកក្នុងរឿងព្រេង ឈ្មោះប្រាសាទ ឈ្មោះភ្នំ និង

ធម្មជាតិ រួមទាំងប្រពៃណីទំនៀមទំលាប់សាសនា និងទំនាយផ្សេងៗ...។ល។ បើចង់ដឹងរឿងពួកគាត់ត្រូវតែបូកបញ្ចូលកេរទាំងអស់ ទើបអាចដឹងរឿងរ៉ាវកេរតំណែលរបស់ពួកគាត់បាន ព្រោះរឿងពួកគាត់បានពូនគរដូចជាភ្នំ ហើយពួកគាត់ធ្វើប្រាសាទនៅលើភ្នំមួយក្នុងខេត្តសៀមរាបឈ្មោះថា **ប្រាសាទភ្នំបូក** បើយើងត្រ ឡប់ពាក្យនេះមកវិញ គឺបូកភ្នំមានន័យថា បើចង់ដឹងរឿងដ៏ធំដូចជា **ភ្នំ** របស់ពួកគាត់ ទាល់តែនាំគ្នាបូកភ្នំទូទាំងមាតុភូមិនេះ ទើបអាចរកអាថ៌កំបាំងរបស់ព្រះម៉ែឃើញ ព្រោះនៅលើភ្នំនោះ គាត់បានសាងរូបស្ដេចលិង្គ និងយោនីដ៏ធំដែលសព្វថ្ងៃត្រូវបានបំផ្លាញ គាត់បានប្រាប់ឈ្មោះផ្លូវទៅកាន់ភ្នំបូក គឺភូមិប្រដាក់ ឬបណ្ដាក់ប្រៀបបីដូចជា សត្វខ្យងបណ្ដាក់គ្នាដើម្បីផ្ទាញ់ទន្សាយយ៉ាងដូច្នោះ។ ពាក្យថា **បណ្ដាក់** គឺមានន័យថា **តៗគ្នា** នៅក្នុងភាគមួយខ្ញុំបានពន្យល់ពីភ្នំហាន់ជ័យ ឬប្រាសាទហាន់ជ័យ ចង់ផ្ដុំផ្គុំនូវរឿងរ៉ាវដែលគេហាន់ជាចំណិតៗនោះ ទាល់តែផ្គុំតៗគ្នា ព្រោះហេតុអ្វី? ព្រោះទីដែលកើតនូវភាពរុងរឿងពីអតីតរបស់ព្រះម៉ែ ត្រូវបាត់ដាន (បាត់ទី)អស់ទៅហើយ ព្រោះពួកគេបានលុបដានស្នាមរបស់គាត់ (អាថ៌កំបាំងក្នុងមង្គលទីបី ព្រះថោងតោងស្បៃ ព្រះនាងនាគ)។ ដូចនេះទើបគាត់កសាងប្រាសាទមួយឡើងក្នុងខេត្តតាកែវ ក្នុងទីតាំងទន្លេបាត់ទី **ប្រាសាទតាព្រហ្ម** ចុះហេតុអ្វីបានជាបាត់ទី? ព្រោះទីដែលហូរនាំមកនូវប្រភពទឹកចូលទន្លេនោះ បានបាត់ប្រភពដើមវាអស់ហើយ។ សព្វថ្ងៃគេហៅប្រាសាទនោះថា ទន្លេបាទី ពាក្យថា **បាទី** និង **បាត់ទី** តើពាក្យទាំងពីរនេះ ពាក្យមួយណាត្រឹមត្រូវជាង? សូមមិត្តអ្នកអានពិចារណា ទៅតាមការបកស្រាយខាងក្រោមចុះ។ ឧ . ដូចទន្លេមេកុង (មេគង្គ) ប្រភពដើមហូរចេញមកពីភ្នំទីបេ ចុះទន្លេបាទីវិញ ប្រភពហូរមកពីណា? ហើយទន្លេមេកុងនេះ មិត្តអ្នកអានពិចារណាទៅមើល ហូរមកពីដំបូង **មេ** មុន **កុង** (មេនៅពីមុខកុង) ប៉ុន្តែពេលដែលហូរមកដល់ខេត្តកំពង់ចាមទន្លេត្រូវបិទ(ទន្លេបិទ) ប៉ុន្តែការបិទមេពុំជាប់ឡើយ មេត្រូវហូមកដល់ទន្លេបួនមុខទើបត្រូវបាត់ពាក្យមេ ( បាត់ដាន) អស់ទៅហើយ។ បែកទីមួយឈ្មោះ **ទន្លេសាប** បែកទីពីរឈ្មោះ**ទន្លេបាសាក់** បែកទីបីឈ្មោះ **ទន្លេធំឬអ្នកលឿង** ហេតុអ្វីបានជាបាត់ឈ្មោះមេកុង? ព្រោះស្នាមដានរបស់មេ ត្រូវគេលុបបាត់ ដានទៅហើយ សព្វថ្ងៃបុរសដណ្ដើមធ្វើមេតែតាមពិតគឺជា **បា** សោះ (វប្បធម៌សង្កត់មេ ឬលុបដានមេ គឺ **កុង សង្កត់ ម៉ា**)។

ចំណែកនៅប្រាសាទទន្លេបាត់ទី(ប្ញាទី)វិញ គាត់បានឆ្លាក់រៀបរាប់រឿងមាតា នៅក្នុងចម្លាក់ផ្ដែរមួយផ្ទាំង ដែលសព្វថ្ងៃបានបាក់ធ្លាក់ជ្រុះទៅលើដីខាងមុខ ផ្លូវចូលប្រាសាទនោះ។ គាត់បានឆ្លាក់



**ផ្ដែរប្រាសាទតាព្រហ្ម នៅទន្លេប្ញាទី**

រៀបរាប់ពីបុរសម្នាក់ ក្បាលពាក់មកុដ ដៃកាន់ព្រះខ័ន លែងខ្លួនទទេល្វែងខាងលើ កំពុងបររទេះសេះ ដែល មានដឹកស្ត្រីបីនាក់នៅលើរទេះនោះ ។ ស្ត្រីទាំងបីអ្នកនោះក្បាលពាក់មកុដ លែងខ្លួនទទេល្វែងខាងលើ ដូចអ្នកបររទេះដែរ ប៉ុន្តែគេ ឆ្លាក់ស្ត្រីទាំងបីនោះ ស្ត្រីទីមួយមានរូបរាងតូច ទីពីររាងធំបន្តិចឯរូបស្ត្រីទីបីធំជិតស្មើនឹងបុរសបររទេះ ហើយនៅពីខាងមុខនិងខាងក្រោយរទេះ មានកងទ័ពកំពុងឈរជាជួរ ខ្លះកាន់ក្លស់ ខ្លះកាន់លំពែង ឬដាវខ្លះកាន់ផ្ទិត និងខ្លះទៀតកាន់ទង់ជ័យនៅឈរហែហាមរទេះ ដែលកំពុងដឹកស្ត្រីទាំងបីនោះចេញ។ តើស្ត្រីទាំងបីនាក់នៅលើរទេះនោះតំណាងឲ្យអ្វី? ហើយនាក់បររទេះតំណាងអ្វី? ពួកគាត់ទាំងបីនាក់នោះតំណាងឲ្យរឿងរ៉ាវ ក្នុងមង្គលទាំងបីនិងក្នុងរឿងសិរីបីប្រការ (ស្រីបី) ចំណែកឯបុរសជាអ្នកបររទេះវិញ គឺជាអ្នកដឹកបណ្ដាំរឿងរបស់ពួកគាត់ទាំងបីនាក់ចេញ (ស្រីបី) ដើម្បីយកមកបើកបង្ហាញឲ្យកូនខាគប្រុសស្រីបានឃើញ និងដឹងពីរអាថ៌កំបាំងពិតរបស់ស្ត្រីនោះ គឺ **ព្រះម៉ែមហានគរ**។

**III.** ដោយខ្លាចក្រែងមិត្តអ្នកអានពុំទាន់យល់ ខ្ញុំនឹងលើករឿងដែលទាក់ទងនឹងឈ្មោះភ្នំ ប្រាសាទ និងភូមិ ស្រុក.... ដែលមានអាថ៌កំបាំងបង្កប់នូវរឿងរ៉ាវរបស់មាតាមហានគរ មកពន្យល់បកស្រាយជាបន្ថែមដើម្បីឲ្យកាន់តែច្បាស់។

ភ្នំជាទីដីខ្ពស់ ដែលធម្មជាតិបានតាក់តែង ឬមនុស្សពូនចាក់គរឲ្យទៅជាភ្នំ ភ្នំមានជើងភ្នំ ចង្កេះភ្នំ ច្រមុះភ្នំ ខ្នងភ្នំ កំពូលភ្នំ មាត់រូងភ្នំ...។ ភ្នំពិតមែនតែជាដីធម្មជាតិ ប៉ុន្តែមានឈ្មោះស្រដៀងអវយវៈមនុស្សដែរ(ជើង ចង្កេះ ច្រមុះ មាត់ ខ្នង...) គឺខ្វះតែបន្តិចបន្តួចតែប៉ុណ្ណោះ។ ហេតុនេះហើយ បានជាព្រះម៉ែនាគយកគំនិតបណ្ដាំរបស់គាត់មួយចំនួន បញ្ចូលទៅក្នុងឈ្មោះរបស់ភ្នំ ព្រោះរឿងរបស់គាត់គឺពូនទៅជាភ្នំ ហើយភ្នំខ្លះទៀតគាត់បានឲ្យកូននាគសម័យអង្គរ កសាងប្រាសាទបន្ថែមពីលើភ្នំនោះដើម្បីឲ្យកាន់តែច្បាស់នូវរឿងហេតុបណ្ដាំរបស់គាត់។ ខ្ញុំនឹងរៀបរាប់ពន្យល់ពីឈ្មោះភ្នំ ប្រាសាទរួមទាំងអ្វីៗដែលទាក់ទងអាថ៌កំបាំង**ព្រះម៉ែ**នេះ ដើម្បីជាប្រយោជន៍ដល់កូននាគទាំងឡាយគ្រាន់បានជាទុនសំរាប់ត្រិះរិះ និងពិចារណាឈ្វេងយល់ក្នុងបណ្ដាំ **ព្រះម៉ែ**។

**១.ភ្នំប្រាសាទភ្នំបូក**(ខេត្តសៀមរាប)

ពាក្យនេះបើត្រឡប់មកវិញ គឺបូកភ្នំ ព្រះម៉ែគាត់ចង់ប្រាប់យើងថា បើកូនចង់ដឹងរឿងព្រះម៉ែ ហើយជួយ ស្រង់ព្រះម៉ែ កូនត្រូវយកភ្នំទាំងអស់ដែលមានក្នុងភូមិព្រះម៉ែ មកបូកបញ្ចូលគ្នា កូននឹងអាចរកឃើញចម្លើយមួយដោយសន្ទត់។ ព្រោះរយៈពេលនៃការកកើតទឹកដីព្រះម៉ែ (ប្រទេសព្រះម៉ែ) ជាងរាប់ពាន់ឆ្នាំនេះ រឿងរ៉ាវរបស់ព្រះម៉ែពូនគរដូចជាភ្នំ ដែលកូននាគប្រុសស្រីមិនអាច គណនានូវមហាគុណដ៏ធំធេងនេះបានឡើយ គឺមានតែព្រះអរហន្តសម្មាសម្ពុទ្ធទេ ទើបព្រះអង្គមាននូវព្រះបញ្ញាញាណអាចជ្រាបនូវគុណនេះបាន ដូច្នេះហើយទើបខ្មែរមានសុភាសិតមួយឃ្លាថា **គុណមាតាបិតាធំជាងភ្នំព្រះសុមេរុ** ហេតុអ្វីបានជាគាត់យកស្ដេចភ្នំព្រះសុមេរុ មកប្រៀបធៀបយ៉ាងនេះ? ព្រោះគាត់ចង់ពន្យល់ប្រាប់កូននាគទាំងអស់ថា៖ ពាក្យ **សុមេរុ** ឬ**សុម៉ែ** គឺម៉ែល្អ ជាពាក្យសំរាប់កូនខ្មែររស់ក្នុងនគរនេះហៅស្ត្រីដែលជាអ្នកបង្កើតនូវបុត្រថា**ម៉ែ** ដែលខ្ញុំបានពន្យល់នៅក្នុងភាគ១រួចហើយ។ ហេតុអ្វីបានជាក្នុងទ្រឹស្ដីអាចារ្យខ្លះថា គុណម៉ែមាន**១២**គុណឪពុកមាន**២១**?ក្នុងទ្រឹស្ដីនេះបើយើងមិនបានយកគំនិតនេះមកត្រិះរិះពិចារណាទេ យើងច្បាស់ជារកប្រភពនៃគំនិតពុំឃើញឡើយ។ តាមការពិតលេខទាំងពីរនេះ គឺវាតែមួយទេ គ្រាន់តែបញ្ច្រាសគ្នាទៅវិញទៅមកតែប៉ុណ្ណោះ ពេលណាយើងដាក់លេខ **១**ពីខាងមុខ២ ទៅជា**១២** ពេលណា ដាក់លេខ **២** នៅខាងមុខ **១** ទៅជា **២១** លេខនេះគឺដូចគ្នា **១២=១+២=៣** → **២១=២+១=៣** (ព្យញ្ជនៈ៣៣តួ)។ ចំ ណែកឯចំនួន**១២**និង**២១**នេះ គឺតំណាងឲ្យធាតុទឹក **១២**

និងធាតុដី**២១** គឺជាធាតុសុទ្ធ ពុំមែនពណ៌នារៀបរាប់ពីគុណឡើយ ម៉ែមានធាតុទឹក **១២**ឪពុកមានធាតុដី**២១** ព្រោះម៉ែបានបង្ហូរនៅធាតុទឹកច្រើនជាងឪពុក ទើបម៉ែមានមនោសញ្ចេតនាទន់ជាងឪពុក។ បើវែកញែកឲ្យកាន់តែវែងឆ្ងាយទៅទៀត(គំនិតនេះបរទេសគេបំភាន់ ត្រឡប់ដើម្បីបំបែកកូននាគ) គំនិតនេះជាប្រស្នារបស់ព្រះម៉ែនាគដែលគាត់ទុកឲ្យយើងស្រាយ ពុំមែនសម្រាប់ចែកចំនួនគុណម៉ែឪឡើយ ព្រោះ**១២**=**១**+**២**=**៣** → **២១**=**២**+**១**=**៣** (ប្រស្នាព្យញ្ជនៈ **៣៣**ត្ង)។ ពេលណាកូននាគប្រុសស្រីព័ន្ធគ្នា នគរនឹងរុងរឿងឡើងវិញដូចសម័យគោកធ្លក ដូច្នេះហើយទើបដូនតាយើង គាត់បានកសាងប្រាសាទនាគព័ន្ធ ផុសនៅកណ្ដាលទឹកនោះ (សូមមើលប្លង់រូប) ប្រៀបដូចនគរគោកធ្លកដែលអណ្ដែតក្នុងមហាសាគរដ៏ធំធេងដោយអំណាចកម្លាំងសាមគ្គីព័ន្ធគ្នារបស់ កូននាគប្រុសស្រីជ្រោងប្រាសាទនោះឲ្យផុសឡើងផុតពីទឹក ដូចរូបប្រាសាទនាគព័ន្ធនេះ។

ទឹក = អំណាចទឹកចិត្តបរទេសដែលគ្របពីលើខ្មែរ(មនោគមវិជ្ជា ពន្យល់រួចហើយក្នុងភាគមួយ) នាគពីរ=កូននាគប្រុសស្រីខ្ញុំពន្យល់នៅមង្គលបីនិងសិរីបីរួចហើយ)

ប្រាសាទ=ភាពស្ដុកស្ដម្ភរុងរឿងពីអតីតកាល

នាគព័ន្ធ = កូននាគប្រុសស្រីសាមគ្គីវេញចូលគ្នាជាផ្លុងមួយ (រួមចិត្តតែមួយ)។

ដោយការវែកញែកនេះ ទើបយើងដឹងថាគេបានបំបែកម្ដាយឪពុក បុរសស្ត្រីអោយបែកគ្នាដោយភាពមិនយុត្តិធម៌នេះ ដែលវាខុសពីទ្រឹស្ដីក្នុងព្រះពុទ្ធសាសនារបស់ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា គុណមាតាបិតាគឺ **អនន្តគុណ** គុណដែលមិនអាចយកទំហំឬចំនួនណាមួយមកប្រៀបផ្ទឹមបានឡើយ។ ប៉ុន្តែចំពោះដូនតាខ្មែរ បានយកភ្នំព្រះសុមេរុមកប្រៀបផ្ទឹមនោះ ព្រោះតែគុណរបស់មាតាបិតាធំជាងភ្នំនោះទៅទៀត។ រីឯគុណរបស់មាតាបិតាព្រះអង្គទ្រង់ត្រាស់សម្ដែងថា ប្រសិនបើមាតាអត់សីល បិតាអត់សីល គុណគឺសេចក្ដីល្អមាតាមានច្រើនជាងបិតាព្រោះហេតុអ្វី? ព្រះអង្គត្រាស់សម្ដែងថា ទីមួយ ការមកនូវឈាមរដូវ បិតាធ្វើបានដោយកម្រ ទីពីរការពារ



ប្រាសាទនាគព័ន្ធ រដូវមានទឹក

ផ្ទៃបុត្រ បិតាធ្វើបានដោយកម្រ ទីបីការប្រសូត្រនូវបុត្រ បិតាធ្វើបានដោយកម្រ ទីបួនការបំបៅដោះលាងមូត្រលាមក ធ្វើបង្គន់ឲ្យកូនប្រុសស្រីនោះ គឺបិតាធ្វើបានដោយកម្រ តែបើបិតាមានសីលឬក៏មាននូវគុណធម៌ផ្សេងៗទៀត បិតាមានគុណធំជាង ឬធ្ងន់ជាងទៅតាមគុណធម៌របស់ឪពុកនោះ។ រួមសេចក្តីមក គុណ មាតាក្តី បិតាក្តី គឺអនន្តគុណ គឺគុណដែលមិនអាចរាប់ចំនួនបាន ឬយកទំហំអ្វីទៅវាស់វែងសេចក្តីល្អរបស់ពួកគាត់បានឡើយ នេះចំពោះតែមាតាបិតាដែលធ្វើព្រះព្រហ្មពិតប្រាកដឲ្យកូន តែប្រសិនបើពួកគាត់ពុំបានបំពេញកាតព្វកិច្ចឲ្យគ្រប់ក្នុង ព្រហ្មវិហារធម៌ទាំងបួននោះទេ គុណនោះក៏ចុះខ្សោយទៅតាមលំដាប់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ម៉ែឪគ្រប់រូបសុទ្ធតែជាព្រះអរហន្តរបស់កូនប្រុសស្រីជា **ទក្ខេណេយបុគ្គល**( បុគ្គលគួរគោរពថ្វាយបង្គំ) គឺជាបុគ្គលដែលត្រូវទទួលនូវការតបស្នងពីកូននាគប្រុសស្រី។ ដូច្នេះចង់ឲ្យនគរមានមហិទ្ធិឫទ្ធិរុងរឿងឡើងវិញ កូនខ្មែរប្រុសស្រីត្រូវតែ បូកភ្ជុំគឺពូនផ្តុំកម្លាំងសាមគ្គីឲ្យក្លាយទៅជាភ្នំ ទើបអាចរុញច្រាននូវបាបអកុសលកម្មពីអតីតកាល ឲ្យរបើកឃ្លាតចេញពីអាទិទេពខ្មែរ(ព្រះម៉ែមហានាគ) រួមនិងកូននាគទាំងអស់គ្នាផង។

មិត្តអ្នកអានជាទីគោរពរាប់អានពេលនេះទើបយើងយល់ថា គេយកទ្រឹស្តី បំភាន់មកបំបែកកូននាគប្រុសស្រី ឲ្យបែកគ្នាងាយស្រួលពួកគេគ្រប់គ្រង **បែកសាមគ្គីស្លាប់មានសាមគ្គីរស់**តើពេលណាហ្ន៎ទើបកូននាគប្រុសស្រីអាចព័ន្ធគ្នាឡើងវិញបាន?

## ២.ប្រាសាទភ្នំហាន់ជ័យ ឬភ្នំហាន់ជ័យ (ខេត្តកំពង់ចាម)

អត្ថន័យនៃពាក្យភ្នំ ឬប្រាសាទនេះ ខ្ញុំបានបកស្រាយពន្យល់ត្រួសៗរួចហើយ នៅក្នុងស្នាដៃភាគមួយ ប៉ុន្តែពេលនេះខ្ញុំគ្រាន់តែចង់បញ្ជាក់បន្ថែមថា ហេតុអ្វីបានជាពួកគាត់ ត្រូវហាន់រឿងរ៉ាវភ្នំឲ្យទៅជាចំណិតៗ? រហូតដល់ទៅបាត់ដាន បាត់ទី សូម្បីតែខ្ញុំអ្នកស្រាវជ្រាវក៏លំបាកផ្គុំ ដើររកទីដើម ឬប្រភពដើមរបស់ពួកគាត់មកផ្គុំ ឲ្យចេញជាសាច់រឿងហូរហែ ដើម្បីយកមកពន្យល់កូនខ្មែរ ដែលចង់ដឹងសាវតាពិតរបស់ខ្លួននោះ។ ព្រោះខ្ញុំបានពន្យល់ហើយនៅក្នុងភាគមួយ រឿងបិសាចពស់នៅក្នុងឯកសារជីវតាក្វាន់ និងរឿងគាត់ជាប់ឃុំឃាំងក្នុងគុក សមុទ្រទឹកដោះ តើអ្នកទោសមានសិទ្ធិអំណាចអ្វី ឬមួយមានសេរីភាពដូចជាអ្នកជានោះ គឺមិនដូចគ្នាទេ ដូច្នេះហើយទើបនគរខ្មែរចេះតែផ្លាស់ប្តូរទីក្រុង ពី

*តំបន់មួយទៅតំបន់មួយពុំចេះឈប់ឈរ។ កាលព្រះម៉ែនៅអាចបែងភាគលួចចេញពីគុកបានដោយឫទ្ធិ ព្រះម៉ែចេះតែមកពន្យល់ប្រាប់ពីគំនិត របស់គាត់ឲ្យកូននាគធំជាងគេគឺ**ស្តេច** ដែលជាអ្នកដឹកនាំប្រទេសទៅតាមគំនិតនិងឱវាទរបស់គាត់( ពន្យល់រួចហើយក្នុងភាគមួយ) ហេតុអ្វីបានជាខ្ញុំថា ស្តេចអ្នកដឹកនាំប្រទេសជាកូននាគធំជាងគេ? ព្រោះស្តេចមួយភិក្ខុសង្ឃមួយ សុទ្ធតែជាអ្នកអាចជ្រកក្រោមដំបូលក្បឿងស្រកានាគ (ព្រះរាំង និងវត្តគេប្រក់ក្បឿងស្រកានាគ) បានទាំងយប់ទាំងថ្ងៃ ក្រៅពីភេទទាំងពីរនេះចេញ គឺពុំសូវមានឱកាសចូលជ្រកក្រោមម្លប់ស្រកាព្រះម៉ែបានទាំងយប់ថ្ងៃឡើយ លុះត្រាតែពេលមានបុណ្យទាន ទើបអាចចូលទៅជ្រកក្រោមម្លប់ដំបូលស្រកានាគ (ព្រះម៉ែ) បានម្តងម្កាល។ ម្យ៉ាងទៀតថ្នាក់ដឹកនាំប្រទេស(ស្តេច) គឺជាអ្នកថែរក្សា និងស្នងមរតកផ្ទាល់ពីព្រះម៉ែ (ដើរតួជាមេនាគ) ដើម្បីរក្សានៅមាតុភូមិនេះ។ សព្វថ្ងៃទីវត្តអារាម ដែលជាទីកន្លែងផ្ទុក និងថែរក្សានូវបណ្តាំមរតកសិល្បៈវប្បធម៌ព្រះម៉ែមួយចំនួនបាន ប្រែប្រួលអស់ទៅហើយ ព្រោះឈប់រក្សាមកុដម៉ែ ហើយនាំគ្នាផ្លាស់មកុដបរទេស យកមកជំនួសវិញ។ **តើមកុដជាអ្វី?** មកុដគឺជាក្បឿង ដែលគេប្រក់បិទបាំងនៅលើដំបូល(ក្បាល) ព្រោះពាក្យក្បឿងនេះ មានបង្កប់នូវអត្ថន័យប្រស្នាពេលយើងប្រក់ក្បឿង គឺយើងយកក្បឿងទៅពាក់ក្រាលលើដែរណែង។ ដូចនេះពាក្យ**ក្បឿងពាក់ក្រាល ត្រលប់ពាក្យមកវិញ គឺក្បាលពាក់គ្រឿង** តើត្រូវពាក់គ្រឿងអ្វី? គឺពាក់គ្រឿងរបស់ព្រះម៉ែ មកុដព្រះម៉ែ គឺក្បឿង**ស្រកានាគ** ឬក្បឿងក្បាច់ ប៉ុន្តែសព្វថ្ងៃវត្តនិងទីលំនៅភាគច្រើនៗប្រក់ក្បឿង ដែលនាំចូលពី**បរទេស**។ កូននាគប្រុសស្រីត្រូវពិចារណាមើល សព្វថ្ងៃនេះ **ព្រំប្រទល់ប្រទេសដើរនៅលើដីតទៅអនាគតព្រំប្រទល់ត្រូវដើរនៅលើក្បាល។** ព្រោះហេតុអ្វី? ព្រោះក្បឿងដែលជាគ្រឿងប្រក់លំនៅឋានសព្វថ្ងៃ សុទ្ធតែមានផ្លាកសំគាល់ឈ្មោះបរទេសជិត ខាងចំណែកឯក្បឿងខ្មែរ ឈប់មានប្រក់បិទបាំងទៀតហើយៗក្បឿងខ្មែរចាស់ៗ ដែលមានត្រាខ្មែរសល់ពីសម័យដើម គេរុះរើយកមកវាយកំទេចចាក់សាបអស់ហើយ។ ដូច្នេះក្បាលខ្មែរ (ដំបូល) លែងមានពាក់មកុដខ្មែរទៀតហើយ នេះគ្រាន់តែជាចំណុចតូចមួយ នៅក្នុងបណ្តាំគំនិតដ៏ធំដូចជាភ្នំរបស់ព្រះម៉ែដែលខ្ញុំបានមើលឃើញ គួរយកមកត្រិះរិះគិតពិចារណា ព្រោះរំលងតែពីរបីជំនាន់ទៀតក្បឿងទាំងនោះនឹងអាចក្លាយទៅជាភស្តុតាងព្រំមួយរបស់បរទេស ដែលយើងលំបាកនឹងប្រកែក។ ខ្មែរឈប់ប្រក់ក្បឿងដែលមានផ្លាកសញ្ញាសំគាល់ **អត្តសញ្ញាណជាតិ** ទៀតហើយ បើកូន*

នាគសម័យនេះមិនចាប់អារម្មណ៍ទេ គ្រោះថ្នាក់នឹងកើតមានចំពោះមនុស្សជំនាន់ក្រោយ (**ធូកនៅកំពង់នៅ**) ដែលយើងសព្វថ្ងៃបានយកអត្ថសញ្ញាណបរទេសមកពាក់ខាងលើក្បាល ហើយគ្រឿងប្រក់ពីលើទាំងនេះ មិនងាយពុកផុយឡើយ វាមានអាយុកាលវែងជាងមនុស្ស។

## ៣.ប្រាសាទភ្នំជីសូរ ឬភ្នំជីសូរ (ខេត្តតាកែវ)

អត្ថន័យដែលខ្ញុំបានលើកមកពន្យល់ គឺខ្ញុំពុំបានយកពីរឿងព្រេងដែលទាក់ទងនឹងភ្នំ មកបកស្រាយឡើយ គឺខ្ញុំយកតែឈ្មោះពិតរបស់ភ្នំនិងប្រាសាទមកធ្វើអត្ថាធិប្បាយតែម្ដង ដើម្បីឲ្យមិត្តអ្នកអានជួយពិចារណា នូវហេតុនិងផល ដែលកើតមានរឿងរ៉ាវជាគំនិតអច្ឆរិយៈ ដែលសព្វថ្ងៃនេះ គេបានប្រសិទ្ធិនាមថា (កម្ពុជារាជាណាចក្រអច្ឆរិយៈ)។ តើនគរនេះ មានអច្ឆរិយៈនៅត្រង់ណា? មិត្តអ្នកអានច្បាស់ជាជ្រាប រួចចាប់ផ្ដើមយល់នូវគំនិតអច្ឆរិយៈរបស់មាតុភូមិ តាមរយៈស្នាដៃបណ្ដាំព្រះម៉ែមហានគរ (ភាគ១) ដែលអ្នកបង្កើតភាពអច្ឆរិយៈទាំងអស់នេះ គឺសុទ្ធតែជាបណ្ដាំគំនិតបណ្ឌិតរបស់ព្រះម៉ែមហានគរ ដែលពីមុនយើងជាកូននាគប្រុសស្រី ពុំបានដឹងនិងយល់ឡើយ រួមទាំងខ្ញុំអ្នកស្រាវជ្រាវផង។ តែពេលនេះទើបយើងរកឃើញ អ្នកបង្កើតភាពអច្ឆរិយៈនេះគឺជាម៉ែដែលកូនខ្មែរភាគច្រើននាំគ្នាជេរគាត់រាល់ៗថ្ងៃ។ ហេតុអ្វីបានជាគេ ធ្វើប្រាសាទភ្នំជីសូរនៅលើកំពូលភ្នំដ៏ខ្ពស់ ហើយបែរជាអ្នកកសាង **ជីកភ្នំ** ក្លាយជារណ្ដៅដូចជាគុក ទើបគាត់ចាប់កសាងប្រាសាទ?

## ពន្យល់ពាក្យ (ភ្នំជីសូរ) (តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជជួន ណាត)

ភ្នំ = ខ្ញុំបានពន្យល់ហើយ

ជី = អ្នកដែលបានបួសជាសាមណេរ ហើយសឹកមកវិញគេហៅថា **ជី** បុរសស្ត្រីដែលទៅសមាទានសីលក៏ហៅថា**ជី** (តាជី ដូនជីឬយាយជី)

សូរ = សូរ សំព្វ សំឡេង

សូរ = (បា.សំ) សូរៈ អង់អាច ក្លាហាន អាចហ៊ាន ដែលមានចិត្តមោះមុត ក្លៀវក្លា....

ភ្នំជីសូរ = គឺជីដែលមានសំព្វសំឡេង អង់អាចក្លាហានមោះមុត លើជីទាំងឡាយព្រោះជីសូរ គឺជាទីខ្ពស់លើសទីទាបទាំងពួង គឺកំពូលលើជីទាំងអស់។ ដូចស្ពានបុរាណមួយ ដែលស្ថិតនៅខេត្តសៀម

រាប មានឈ្មោះថាស្ពានកំពុងក្តី ហើយស្ពាននោះគាត់សាងពីលើដងស្ទឹងមួយ គឺស្ទឹង **ជីក្រែង**។ តើជីក្រែងមានន័យដូចម្តេច? ហើយស្ពានកំពុងក្តីមានន័យដូចម្តេច?

ជីក្រែង = ជីគាត់ខ្លាចញញើត ធ្វើមិនបានឬជួយព្រះម៉ែមិនបាន ព្រោះនាគក្បាល១៤ នៅខាងលើស្ពានកំពុងកើតក្តីក្តាំគ្នា (កំពុងក្តី) ចំណែកឯជីឡើងមកស្រាយ និងទប់ក្តីគាត់ៗខ្លាចក្រែង ដោះក្តីព្រះម៉ែនៅខាងលើមិនរួច ទើបដូនតាយើងសាងស្ពានកំពុងក្តីនេះនៅលើស្ទឹងជីក្រែង ទុកឲ្យជីជាអ្នកស្រាយក្តីនោះពិចារណា។ ខ្លួនឯងជាពូជទាប នៅក្នុងទឹកខាងក្រោមស្ពាន រឿងអ្វីហ៊ានមកតតាំងក្តីនៅខាងលើ ដោយមិនខ្លាចក្រែងនោះ? នាគនៅស្ពានកំពុងក្តី និងនាគនៅលានព្រះគំលង់ គឺដូចគ្នាប៉ុន្តែខុសគ្នាត្រង់ នាគនៅកំពុងក្តី ក្បាលប្រាំបួននៅពីលើប្រាំ ហើយមានស្ត្រីម្នាក់ឈរទ្រពីខាងក្រោមនាគ សព្វថ្ងៃត្រូវគេដាប់រូបស្ត្រីខាងក្រោមនាគបាត់ហើយ យើងមើលស្ទើរតែពុំយល់ ព្រោះពួកគេចង់លុបបំបាត់ដាន ហើយស្ត្រីនោះគឺតំណាងឲ្យព្រះម៉ែនាគ។ ចំណែកឯនាគនៅលានព្រះគំលង់វិញ គឺក្បាល៥នៅពីលើក្បាល៩និង៧ បញ្ច្រាស់គ្នាជាមួយនឹងនាគនៅកំពុងក្តី (អាថ៌កំបាំងប្រស្នាបញ្ច្រាស់គ្នានេះ ខ្ញុំនឹងពន្យល់នៅភាគ៣)។ យើងត្រឡប់មកតាមដានអាថ៌កំបាំងភ្នំជីសូរវិញ បានជាដូនតាយើងគាត់ជីកភ្នំរួចសាងប្រាសាទ ព្រោះគាត់ចង់ប្រាប់ថាជីសូរ ដែលកំពូលលើ **ជី** ទាំងឡាយ ត្រូវទៅជួយព្រះម៉ែកំពុងជាប់គុកនោះ ខ្លួនគាត់ក៏ជាប់គុកដូចព្រះម៉ែដែរគ្រាន់តែតិចជាង គឺ**យកថ្លុកទៅលុបត្រពាំង** ពេលណាទើបលុបជិតហ្ន៎។ ចំណែកឯរឿងដែលគេឆ្លាក់នៅលើផ្តែរ និងប្រាសាទដែលគេធ្វើបិទឃុំឃាំងព្រះម៉ែ ខ្ញុំពុំបានពន្យល់ឡើយទុកឲ្យមិត្តអ្នកអានទៅទស្សនាប្រាសាទ និងពិចារណាតាមសាច់រឿងរបស់ព្រះម៉ែ ដែលខ្ញុំបានពន្យល់ជាហូរហែនោះចុះ នឹងបានដឹងដោយពិស្តារខ្លួនឯង។



**នាគក្បាល៩លើក្បាល៥**
**(ស្ពានកំពង់ក្តី)**

## ៤.ប្រាសាទភ្នំបាយ៉ង់កោរ (ខេត្តតាកែវ)

ពាក្យ (បយ័ង្គ ឬបល្ល័ង្ក) ខ្ញុំបានពន្យល់ក្នុងភាគ១រួចខ្លះហើយ ដែលខ្ញុំលើកយកមកសរសេរនេះ ដើម្បីបញ្ចូលទៅក្នុងរឿងភ្នំ ដែលទាក់ទងនឹងកេរតំណែលព្រះម៉ែ ចង់ដឹងរឿងព្រះម៉ែ រួចជួយគាត់បាន ទាល់តែបូកភ្នំឬផ្គុំភ្នំ។ រឿងរ៉ាវទាក់ទងនឹងភ្នំនេះ ស្តេចជ័យវរ្មន័ទី៧គាត់បានឆ្លាក់ រូបរឿងទុកនៅក្នុង




ប្រាសាទ **តាព្រហ្ម** ដែលប្រាសាទនោះគាត់ ធ្វើឧទ្ទិសឲ្យព្រះម៉ែ។ គាត់បានឆ្លាក់សាច់រឿង**របស់ស្ត្រីម្នាក់ ឈរលើផ្កាឈូក កំពុងតែដុះឡើងទ្រស្ត្រី**នោះ យកទៅដាក់លើបល្ល័ង្កទទេខាងលើ វិញ ដែលបល្ល័ង្កនេះ គាត់ធ្លាប់អង្គុយពីអតីត ដោយកម្មអកុសលធ្វើឲ្យគាត់ធ្លាក់ចុះទៅក្រោម។ ហើយនៅក្នុងរូបនេះដដែល គាត់ឆ្លាក់សកម្មភាពសត្រូវ មកពីគ្រប់ទិសទី ដែលក្នុងដៃមានកាន់ដាវ លំពែង បុកចាក់ទៅលើគាត់ ព្រោះពួកគេមិនចង់ឲ្យស្ត្រីនេះ មកអង្គុយលើបល្ល័ង្ករបស់ខ្លួនវិញឡើយ។ ធម្មតាពៀររមែងរម្ងាប់ដោយការមិនចងពៀរ ហើយពៀរនេះបើអ្នកមិនស្រាយទេ ទោះបីជារលាយអស់ទៅនៃផែនដីក៏ពៀរវេរារបស់ពួកអ្នកមិនរម្ងាប់ដែរ (នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ សម្តែងប្រោសយក្ខិនី និងនាងកុលធីតា) អត្ថន័យរូបចម្លាក់រឿងខាងលើនេះ ទាក់ទងនឹងរឿងភ្នំបាយ៉ង់កោរ។ ហើយនៅលើភ្នំនេះមាន ប្រាសាទ បាយ៉ង់កោរ ដុបវិញ្ញាណ ព្រះបាទដៃខ្លី (ជាកូន) ព្រះនាងសក់ក្រអូប ព្រះគោ ព្រះកែវ ហើយមានឈ្មោះភ្នំ បាយ៉ង់កោរ សក់ក្រអូប ដុកស្វាគយ ព្រះបក សំពៅលូន វិហារចិន ភ្នំតូចនិងមាន ទំនប់បុរាណមួយហៅថា**ទំនប់អរូបន្ទាយ**ហើយឈ្មោះទាំងនេះខ្ញុំបានដកស្រង់ចេញពីទស្សនាវដ្តីមួយ។

## ៥.ប្រាសាទភ្នំតាម៉ៅ(ខេត្តតាកែវ)

ប្រាសាទភ្នំនេះមានភាពបាក់បែកទ្រុឌទ្រោមយ៉ាងខ្លាំង ហើយប្រាសាទនេះមានទ្វារចូលតែមួយទេ នៅខាងលើទ្វារមានចម្លាក់ផ្តែរមួយផ្ទាំង សព្វថ្ងៃបានជ្រុះធ្លាក់មកលើដីនៅមុខប្រាសាទ។ រូបក្នុង

ចម្លាក់ផ្ដែរនោះ ត្រូវពួកទុច្ចរិតដាប់បំផ្លាញអស់ហើយ តែបើមើលតាមដានស្នាមរូប គឺរឿងកូរសមុទ្រទឹកដោះ។ នៅក្នុងប្រាសាទនោះមានថ្មធម្មជាតិមួយដុំធំ ថ្មនេះបើមើលពីខាងមុខទ្វារ មិនអាចស្គាល់រូបរាងបានឡើយ ទាល់តែដើរទៅឈរមើលពីខាងក្រោយប្រាសាទ ដែលបាក់បែកមួយចំហៀងខាងក្រោយ ទើបអាចមើលយល់ពីថ្មធម្មជាតិនោះ។ ដូនតាខ្មែរគាត់បានយកបណ្ដាំគំនិត ទៅបង្កប់ទុកក្នុងថ្ម ព្រោះថ្មនោះជារាងក្បាលនាគបើកពារពារកប់ត្រឹមក ហើយត្រូវគេធ្វើប្រាសាទគ្រប ឬក្រុងពីលើ (បក្សីចាំក្រុង)។ បើនិមិត្តរូបក្បាលគាត់ធំម្លឹងៗ តើឲ្យគាត់ចេញមកម្ដេចរួច? ព្រោះមាត់ទ្វារប្រាសាទតូចជាងក្បាលនាគ ដែលជាថ្មធម្មជាតិនោះ នេះជាប្រស្នាអាថ៌កំបាំងទាក់ទងនឹងព្រះម៉ែនាគ ដែលបានប្រតិស្ឋានទុកក្នុងប្រាសាទភ្នំតាម៉ៅនេះ មាននៅសល់ដានស្នាមទុកដល់សព្វថ្ងៃ ដែលយើងជាកូនខ្មែរត្រូវពិចារណាបំបែកបណ្ដាំគំនិតរបស់ពួកគាត់ ហើយគាត់អាចចេញមកក្រៅរួច ទាល់តែមានអភូតហេតុធម្មជាតិ រយៈដី ឬរញ្ជួយដី..... ទើបអាចចេញពីទីឃុំរួច។

៦. **ភ្នំរទង់** (សព្វថ្ងៃហៅថាភ្នំទទង់) (ន័យពិតពីដើម គឺដើររកទង់) (ខេត្តកំពត)

ហេតុអ្វីបានជាគាត់ដាក់ឈ្មោះភ្នំថា**រកទង់** ព្រោះនៅតំបន់នោះ មានឈ្មោះថា**ដងទង់** (សព្វថ្ងៃឈ្មោះថាស្រុកដងទង់) បើយើងពិចារណាស្វែងរកពាក្យពិតនៅទីនោះ គឺទង់ព្រះម៉ែបានបាត់ទៅហើយ នៅសល់តែដងទង់ប៉ុណ្ណោះ។ ព្រោះភាពរុងរឿងរបស់ព្រះម៉ែពីអតីត បានធ្លាក់ចុះនិងលិចកប់បាត់ទៅក្នុងសមុទ្រទឹកដោះទៅហើយ សព្វថ្ងៃនេះមិនទាន់រកឃើញទង់ព្រះម៉ែនៅឡើយ ដើម្បីយកមកចងបង្កូតឡើងវិញ ព្រោះហេតុតែយើងមិនដឹង ទើបនាំគ្នាបង្កូតទង់ក្រពើ (នៅក្នុងភាគ១) តើកេរតំណែលទង់ក្រពើ និងទំនួញប្រេតខែភ្នំបិណ្ឌ កើតឡើងពីសម័យណាមក? តាមការស្រាវជ្រាវប្រវត្តិទង់ក្រពើ និងទំនួញប្រេតខែភ្នំបិណ្ឌ ដែលទាក់ទងនឹងរឿងប្រេតជាញាតិ យើងអាចយល់បានថា គឺកើតឡើងក្នុងរជ្ជកាលសម្ដេចព្រះបាទអង្គឌួង។ ព្រោះស្ដេចអង្គនេះ គាត់បានសិក្សាវិជ្ជាផ្នែកសមាធិ និងវិបស្សនាកម្មដ្ឋានបានជ្រៅជ្រះ ទៅតាមក្បួនច្បាប់ព្រះពុទ្ធសាសនា។ ធម្មតាអ្នកសិក្សាសមាធិកម្មដ្ឋាន រមែងបាននូវឈានសមាបត្តិ ឬអភិញ្ញាដែលជាគុណធម៌របស់សមាធិ អាចធ្វើឲ្យបុគ្គលនោះដឹងរឿងរ៉ាវពីអតីត បច្ចុប្បន្ន និងតអនាគតរបស់ព្រះម៉ែនាគបាន(រឭកជាតិ)។ គាត់បានមកកសាងទីក្រុងនៅជិតភ្នំ ដែល

សន្ធប់ព្រះម៉ែ (ភ្នំអង្គារស) ហើយគាត់បានជួបព្រះម៉ែតាមរយៈឈានសមាបត្តិ ហេតុនេះហើយ បានជាគាត់ទុកនៅបណ្ដាំប្រស្នាព្រះម៉ែជាច្រើនដូចជា ទង់ក្រពើ ពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ បណ្ដែតប្រទីប បុណ្យភ្ជុំបិណ្ឌ ...។ល។ ទុកឲ្យកូននាគសម័យក្រោយឆ្ងល់ និងធ្វើការស្រាវជ្រាវពីអាថិកំបាំងក្នុងបេះដូងព្រះម៉ែ ពេលដែលបាបកម្ម ព្រះម៉ែអស់ តើកូននាគមានឆ្ងល់ឬទេ ? ហេតុអ្វីបានជាយើងជាអ្នកគោរពព្រះពុទ្ធសាសនា ហើយបែរជាឧទ្ទិសបុណ្យឲ្យប្រេតជាញាតិបានតែ ១៥ថ្ងៃ ពីថ្ងៃ ១រោជខែភទ្របទ ដល់ថ្ងៃ១៥រោជខែភទ្របទ ? កាលពីសម័យពុទ្ធកាល ពុទ្ធបរិស័ទ គេឧទ្ទិសបុណ្យឲ្យញាតិជាប្រេត១២ខែ គឺស្មើនឹង៣៦៥ថ្ងៃឯណោះ ហើយដែលរឿងប្រេតនេះ ទាក់ទង និងញាតិរបស់ព្រះបាទពិម្ពាសារាជ មាននៅក្នុងគម្ពីរព្រះពុទ្ធសាសនា(តិរោកុឌ្ឌសូត្រ)។ នេះហើយដែលជាប្រស្នាដែលស្ដេចអង្គឌួង លោកទុកឲ្យកូនខ្មែរសម័យក្រោយ ស្រាយបំបែកចំណាងប្រស្នាកំបាំងនេះ។ ខ្ញុំបានពន្យល់នៅក្នុងទំព័រមុន ពីអាថិកំបាំងមាតាទាំង១២រួចហើយកែវភ្នែកម្ដាយទាំង១២ ត្រូវគេខ្វេះយកអស់ដប់មួយគូកន្លះ នៅសល់តែភ្នែកមួយចំហៀងប៉ុណ្ណោះ។ នៅក្នុងសាច់រឿង បានបញ្ជាក់ប្រាប់ថាមិនត្រឹមតែត្រូវគេឆ្កៀលយកកែវភ្នែកទេ(បញ្ញា) គឺពួកគាត់ថែមទាំងបាននាំគ្នាហែកកូន ដែលកើតចេញពីផ្ទៃ ចែកគ្នាបរិភោគដោយគ្មានក្ដីមេត្តាករុណាថែមទៀតផងនៅក្នុងគុក។ មានតែមាតាពៅម្នាក់តែប៉ុណ្ណោះ ដែលនៅសល់កែវភ្នែកមួយចំហៀង ហើយភ្នែកម្ខាងនេះបានមើលឃើញនៅបុត្រដែលកើតចេញពីផ្ទៃរបស់ខ្លួន ទើបគាត់ពុំបានសម្លាប់កូនបរិភោគ។ តើកែវភ្នែកមួយចំហៀងនេះតំណាងឲ្យអ្វី? គឺតំណាងឲ្យភ្នែកកូនខ្មែរដែលភ្លឺបានតែ១៥ថ្ងៃ នៅរដូវភ្ជុំបិណ្ឌនោះឯង ហើយ១៥ថ្ងៃនេះទៀតសោត គឺពុំបានភ្លឺគ្រប់ទាំងអស់ឡើយ វាត្រូវមានកើតរោគក្នុងកែវភ្នែក ដែលធ្វើឲ្យការភ្លឺកាន់តែថយចុះ។ ម្យ៉ាងទៀតការធ្វើបុណ្យនេះកូនខ្មែរមួយចំនួនធ្វើពុំត្រឹមត្រូវតាមខ្នាតក្នុងព្រះវិន័យព្រះពុទ្ធសាសនាឡើយ ដោយកូននាគភាគច្រើននាំគ្នាយកបាយបិណ្ឌ ទៅគប់ទៅបោះឲ្យប្រឡាក់ស្មោកគ្រោកពេញទីសេនាសនសង្ឃ រួចហើយភិក្ខុសង្ឃជាអ្នកបោសច្រាស។ តើពួកគេនាំគ្នាទៅបោះបាយបិណ្ឌឲ្យប្រេត ឬក៏សន្សំពូជប្រេតខ្លួនឯង? ម្យ៉ាងទៀតសព្វថ្ងៃយើងពុំសូវមាន ព្រះអរិយបុគ្គលដែលមានគុណធម៌ថ្នាក់ខ្ពស់ៗ ឬអ្នកមាននូវសីលបរិសុទ្ធដែលជាពូជនាគទៀតផង ដូច្នេះការឧទ្ទិសបុណ្យជូនទៅពួកប្រេតជាញាតិ គឺលំបាកនឹងទៅដល់ណាស់។ តើក្រពើដែលគេចាប់យកមកធ្វើទង់សល់កេរមក

ដល់សព្វថ្ងៃនេះគេចាប់នៅទីណា? ក្រពើនេះ បានលេបព្រះនាងក្រពុំឈូក ឬឈូកក្រពុំ គេទៅចាប់បាននៅខេត្តក្រចេះរួចទើបគេភ្លះយកស្បែក មកធ្វើទង់រហូតទល់នឹងសព្វថ្ងៃនេះ(ក្នុងរឿងព្រេង) គេហៅក្លាយថាទង់ព្រលឹង ទង់រលក ឬទង់ឆ្លាមករ។ ព្រះចេតិយរបស់ព្រះម៉ែក្រពុំឈូក ឬឈូកក្រពុំដែលក្រពើលេបនោះ សព្វថ្ងៃនៅក្នុងទីតាំងព្រះវិហារសសរមួយរយ ក្នុងភូមិ***សំបុក*** ស្រុក***សំបូរ*** ខេត្ត***ក្រចេះ*** ហើយពេលណា ទើបផ្កាឈូករអាចរីក រួចបើគាត់នៅក្នុងទី***សំបុកសំបូរ មិនខាយចេះ***យ៉ាងនេះ (**ក្រ + ចេះ**) តើពេលណាកូននាគ អាចធ្វើដឹងឡើងវិញ? តើពេលណាទើបអាចរកទង់ព្រះម៉ែឃើញ? បើទន្លេ**មេ** បាត់ទីបាត់ដានអស់ទៅហើយៗត្រូវគេបិទទន្លេមេថែមទៀត(ទន្លេបិទ)។

**៧.ភ្នំក្រពើ** (ខេត្តបាត់ដំបង)

ភ្នំក្រពើនេះនៅក្នុងខេត្តបាត់ដំបង មិត្តអ្នកអានដឹងទេដែលយើងនាំគ្នាធ្វើពើមិនដឹងពីម្នាក់ទៅម្នាក់ ពីមួយជំនាន់ទៅមួយជំនាន់ការមិនដឹងគុណនេះបានពូនទៅជាភ្នំ ដែលមានសល់កេរតំណែលមកដល់សព្វថ្ងៃ ស្ទើរតែគ្រប់ទីកន្លែងនៅពាក្យក្រពើនេះ ពុំមែនមានតែក្នុងខេត្តបាត់ដំបងមួយឡើយ។ មិនត្រឹមតែប៉ុណ្ណឹងទេ ដូនតាគាត់បានប្រាប់ទៀតថា ត្បូងកែវឬដួងកែវរបស់វានៅទល់មេឃឯណោះ (ផ្កាយក្រពើ) សព្វថ្ងៃនៅក្នុងខេត្តកំពង់ធំ មានភូមិមួយឈ្មោះថា (ភូមិកាល់មេឃ ឃុំត្បូងក្រពើ ស្រុកសន្ទុក)។ ហើយផ្កាយក្រពើនេះរះនៅតែទិសខាងជើង ព្រោះទិសនេះប្រែមកថាខាងក្រោម (ជើងផ្ទុយពីក្បាល ក្បាល = ត្បូង) នេះជាប្រស្នាគំនិតបង្កប់នៅក្នុងទិស នៅក្នុងពាក្យដែលគាត់ប្រើសម្គាល់ដើម្បីទុកឲ្យយើងរើកញែក រកឲ្យឃើញនូវចម្លើយពិតរបស់ឈ្មោះភ្នំ ក្រពើ ផ្កាយក្រពើ និងទង់ក្រពើ.... ប្រសិនបើយើងពុំឆ្ងល់ ហើយពិចារណាត្រិះរិះទេយើងនៅតែមិនដឹងរឿងពិតក្នុងបណ្ដាំរបស់ព្រះម៉ែដដែល។ សូមឲ្យការមិនដឹងគុណដែលបានក្លាយជាទង់ ផ្កាយ ភ្នំនេះ រលាយបន្តិចម្ដងៗចេញពីក្នុងសន្ដានចិត្តកូននាគ ដោយបុណ្យរបស់កូនខ្មែរបានយល់ដឹងពីបណ្ដាំពិតរបស់ព្រះម៉ែមហានគរ។

**៨.ប្រាសាទភ្នំបាណន់**(ភ្នំបាទៅបន់)(ខេត្តបាត់ដំបង)

ឈ្មោះប្រាសាទបាណន់ ឬបាទៅបន់ តើគេទៅបន់ស្រន់ឲ្យអ្នកណា? បាណន់ → បន់ណា គឺកូនប្រុសដែលជាជីសូរនោះ គាត់ទៅបន់ស្រន់បួងសួង ឧទ្ទិសដ្ឋាននូវបុណ្យជូន**ព្រះម៉ែនាគ** ដែលគំនរ

នៃពាក្យ បន់ បួងសួង ទាំងអស់នេះបានគរពូនទៅជាភ្នំ ហេតុតែចង់ឲ្យព្រះម៉ែបានត្រេកអរអនុមោទនានូវបុណ្យ ឆាប់បានរួចចាកពីទីទុក្ខ។ ដូច្នេះអត្ថន័យពិតនៃឈ្មោះប្រាសាទភ្នំនេះ គឺដូចការដែលខ្ញុំបាទបានរៀបរាប់ពន្យល់ត្រួសៗនៅខាងលើ ហើយប្រាសាទនេះខ្ញុំពុំទាន់បានទៅទស្សនានិងសិក្សាស្វែងយល់ពីរូបចម្លាក់នៅលើប្រាសាទនោះឡើយ។

*៩.ភ្នំសំពៅ* (ខេត្តបាត់ដំបង)

សំពៅ គឺជាជលយាន្ត ដែល**ព្រះម៉ែនាគ**បានយកមកធ្វើជាមធ្យោបាយ ដើម្បីពង្រីកទឹកដីកាលសម័យគាត់នៅជាព្រះនាងនាគ (មេ ឬក្មេរ) ហើយឈ្មោះជលយាន្ត(សំពៅ) ទាំងអស់នេះបានគរបន្តៗគ្នាមកសម័យខាងក្រោយ រហូតគរបានក្លាយទៅជាភ្នំ។ ម្យ៉ាងទៀតក្នុងរឿងព្រះនាងសក់ក្រអូប ពេលដែលសត្រូវចាប់គាត់បាន ក៏ទាក់ទងនឹងសំពៅនេះដែរដែលសព្វថ្ងៃមាននៅសល់បទភ្លេងប្រពៃណីក្នុងពិធីមង្គលការ គឺបទ(ស្រាវយុថ្កា សំពៅថយ បើកក្ដោង...)។ល។ រឿងព្រេងព្រះនាងរំសាយសក់ ក៏មានទាក់ទងនឹងភ្នំសំពៅដែរ ដែលរូបគាត់សព្វថ្ងៃគេឆ្លាក់ឈរនៅលើក្រពើ ហើយច្បូតសក់មានឈ្មោះថា (នាងគង្ហីងព្រះធរណី) គឺតំណាងឲ្យព្រះមេឬព្រះម៉ែនោះឯង (ពន្យល់រួចហើយនៅក្នុងអាថិកំបាំងបាយ)។ ហេតុនេះហើយ ទើបរឿងព្រះម៉ែ ដែលពូនគរជាភ្នំទាក់ទងគ្នាពីមួយទៅមួយពីឈ្មោះរបស់ភ្នំទៅរឿងព្រេងប្រចាំភ្នំ និងរឿងប្រាសាទដែលកសាងនៅលើភ្នំ..... ដែលតភ្ជាប់គ្នារហូតទៅដល់លើមេឃឯណោះ (ផ្កាយ ក្រពើ សេះ កូនមាន់ យាម...) នេះជាការបកស្រាយដោយសង្ខេប។

*១០.ភ្នំស្រង់* (ខេត្តកំពង់ស្ពឺ)

*ពន្យល់ពាក្យ* (ភ្នំស្រង់ និងកំពង់ស្ពឺ)

ស្ពឺ = ផ្លែស្ពឺ

ស្ពឺ = ស្ពឺចក្រ កាំរបស់ចក្រ មីញ៉ុង ឬលីប

កំពង់ស្ពឺ = កំពង់មានដើមស្ពឺ

កំពុងស្ពឺ = កំពុងវិល

ភ្នំ = (ពន្យល់រួចហើយ)

ស្រង់ = លើកឡើង ជ្រោងឡើង សណ្តូនឡើង

ភ្នំស្រង់ ➜ ស្រង់ភ្នំ តើន័យពិតរបស់ពាក្យពិតកំពង់ស្ពឺនិងកំពុងស្ពឺ ន័យពិតនៅក្នុងពាក្យមួយណា? សូមមិត្តអ្នកអានស្វែងយល់ដោយខ្លួនឯងទៅតាមបញ្ញាត្រិះរិះ ឈ្វេងយល់នូវការពិត។

បើភ្នំធំម្លឹងៗតើត្រូវយកអ្វីទៅស្រង់? គុណធម៌របស់មាតានិងបិតា បានសន្សំពូនគររហូតមានទំហំធំជាងស្តេចភ្នំព្រះសុមេរុទៅទៀត បើគុណរបស់គាត់ធំហើយធ្ងន់ម្លឹងៗ តើកូននាគប្រុសស្រីទៅរែកទៅស្រង់ម្តេចរួច? ហើយរែកភ្នំនេះ តើត្រូវយកដងរែកអ្វីទៅរែក? គឺមានតែដងរែកភ្នំទើបរែកឬស្រង់ភ្នំរួច (ភ្នំដងរែក)។ នៅក្នុងខេត្តកំពង់ស្ពឺនេះដដែលមានស្រុកមួយមានឈ្មោះថា ស្រុកគងពិសី (គងពិសី =




គងលើស្ត្រី) ពេលយើងពិចារណា អត្ថន័យក្នុងពាក្យនេះយើងនឹងនឹកឃើញដល់រូប ព្រះវិស្ណុដេក ឬផ្ទំលើសត្វនាគលើសត្វគុជសី (ប្រាសាទខ្លះ) គងលើស្ត្រីដែលជាព្រះម៉ែ(គងពិសី) កំពុងដឹក(កំពុងវិល) គាត់ចេញពីក្នុង សមុទ្រទឹកដោះ។ ក៏ប៉ុន្តែ អ្នកដឹកម៉ែចេញដេក វារលូនយ៉ាងនេះ ពេលណាទើបអាចនាំព្រះម៉ែឡើងមកខាងលើរួច? កំពុងវិល(ស្ពឺ)ទៅមុខដឹករឿងសាវតាព្រះម៉ែចេញ។

**១១.ភ្នំស្រួច** (ខេត្តកំពង់ស្ពឺ)

ភ្នំស្រួច គឺភ្នំដែលខ្ពស់ហើយស្រួច អត្ថន័យពាក្យភ្នំនេះសំដៅទៅលើកូននាគណាដែលមានបញ្ញាស្រួចស្រាវដូចជាភ្នំ គឺមោះមុត អង់អាច ហានក្លា ដែលជាកំពូលលើដីទាំងឡាយ ហ៊ានរែកហ៊ានស្រង់ភ្នំម៉ែភ្នំឪ យកទៅដាក់លើកំពូលព្រះវិហាររបស់គាត់វិញ គឺកំពូលភ្នំស្រួច(កំពូលនៃអរិយធម៌អង្គរ) ន័យម្យ៉ាងទៀត ព្រះម៉ែមហានគរពីអតីតលោកគង់នៅទីស្រួច គឺលើគេ ដូចនេះមិនងាយស្រង់គាត់ទៅ

ដាក់លើបល្ល័ង្កដ៏ខ្ពស់នោះបានដោយងាយស្រួលឡើយ ត្រូវតែប្រើពេលវេលាព្យាយាមដ៏យូរ ទើបអាចសំរេចកិច្ចការដ៏ធំនេះបាន។

**១២.ភ្នំដងរែក** (ខេត្តព្រះវិហារ)

ហេតុអ្វីបានជាដូនតាយើងដាក់ឈ្មោះភ្នំនេះថា**ភ្នំដងរែក**? ខ្ញុំបានពន្យល់បកស្រាយរៀបរាប់អាថ៌កំបាំងភ្នំតាំងពីទំព័រដើមរហូតមកទល់នឹងពេលនេះ គឺមានចំនួនច្រើនហើយ។ គុណរបស់ព្រះមាតាបិតាទោះបីស្ដេចភ្នំព្រះសុមេរុដែលទេវឋានតាវតឹង្ស ក៏ពុំស្មើនឹងគុណរបស់ពួកគាត់ដែរ ប៉ុន្ដែហេតុអ្វីបានជាគុណដ៏ធំនេះ បែរជាលិចចុះទៅវិញ? ហេតុតែសេចក្ដីលោភលន់និងប្រកាន់មាំក្នុងឧបាទានក្ខន្ធថា ជាសត្វជាបុគ្គល ជាស្ដេច ជានាម៉ឺនមន្ត្រី ជាឧបាសកឧបាសិកា ជាគ្រហស្ថ ជាបព្វជិត.... ការលោភលន់និងប្រកាន់មាំនេះហើយ តែងធ្វើឲ្យសត្វទាំងនោះជាប់ឃុំក្នុងវដ្ដសង្សារ រកទីបំផុតនៃការបញ្ចប់ទុក្ខពុំឃើញគឺនៅវិលវល់ ម្ដងកើត ម្ដងស្លាប់ ម្ដងខ្ពស់ ម្ដងទាប ម្ដងសុគតិ ម្ដងអបាយភូមិ...។ល។ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ស្ដាប់ទៅគួរឲ្យសង្វេគណាស់ តើងាយអ្វីនឹងធ្វើឲ្យសត្វដែលក្រាស់ទៅដោយអវិជ្ជានិងតណ្ហាអាចឆ្លងនូវសមុទ្រទុក្ខនេះបាន? យ៉ាងណាមិញ ព្រះមាតាបិតាមហានគរ ពីអតីតកាលក៏ដូច្នោះដែរ ដោយមានការលោភលន់និងប្រកាន់មាំ ព្រោះចង់ឲ្យកូនខ្មែរសម័យខាងក្រោយ សោយសុខក្នុងកេរមរតករបស់ខ្លួន ទើបធ្វើឲ្យពួកគាត់ជាប់ឃុំក្នុងទីទុក្ខ។ គុណរបស់គាត់ធំដូចជាភ្នំ ទុក្ខវេទនារបស់ពួកគាត់ក៏ធំដូចជាភ្នំដែរ ដូច្នេះចង់រែកចង់ស្រង់ភ្នំព្រះមាតាបិតានេះត្រូវយកដងរែកភ្នំទៅរែកទើបរែករួច។ តើអ្នករែកជានរណា? អ្នករែកក៏មានគុណធម៌ស្មើនឹងភ្នំដែរ ទើបអាចលើកដងរែកភ្នំទៅរែកពួកគាត់រួច គឺកូននាគនោះគាត់ឲ្យនាមជាភ្នំជីសូរ ភ្នំបាណន់ បាភ្នំ ភ្នំបាយ៉ង់កោរ ភ្នំបាខែង បាពួន បាគង...។ល។ កូននាគនេះបានបំពេញនូវគុណធម៌ គឺកតញ្ញូកតវេទីដូចជាពោធិសត្វ សុវណ្ណសាមដែរ ហើយគាត់ត្រូវស្រង់រែកព្រះមាតាបិតាដើម្បីយកពួកគាត់ទៅដាក់ក្នុងកំពូលព្រះវិហារវិញ (ប្រាសាទព្រះវិហារ) នេះជាអត្ថន័យនៃពាក្យភ្នំដងរែក។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងព្រះអង្គសន្សំនូវបារមីអស់កាល បួនអសង្ខៃយ្យមួយសែនផែនដី ទើបអាចរែកព្រះមាតាបិតាទៅកាន់ទីរំលត់ទុក្ខបាន(ព្រះនិព្វាន្ត) ចុះកូននាគប្រុសស្រី ដែលជាអ្នកទទួលបណ្ដាំនិងមរតកព្រះមាតាបិតាវិញ អ្នកមានសន្សំបុណ្យកុសល ដើម្បីឧទ្ទិសមហាកុសលនេះជូនចំពោះពួកគាត់ដែលជាម្ចាស់នគរដែរឬទេ?

## ១៣.ប្រាសាទព្រះវិហារ(ខេត្តព្រះវិហារ)

ដូនតាយើងគាត់បានកសាងប្រាសាទព្រះវិហារក្នុងជួរភ្នំដងរែកព្រោះកូននាគត្រូវរែកព្រះម៉ែ និងព្រះឪយកទៅដាក់លើកំពូលភ្នំព្រះវិហារ ដែលជាវិហារធម៌របស់ពួកគាត់ពីអតីតកាលវិញ។ សព្វថ្ងៃបរទេសឈ្លានពានកំពុងចង់បានប្រាសាទនេះ ព្រមទាំងទឹកដីជាប់ព្រំប្រទល់តំបន់នោះផង ព្រោះគេដឹងថាទីនោះជាដែនដីអាទិទេពខ្មែរ។ ពេលណាគេដណ្ដើមបានទីនោះដូចជាគេបាន អាទិទេពរបស់អ្នកនគរនេះ ដូច្នេះហើយទើបគេខិតខំពន្យល់ប្រជាជនគេគ្រប់ស្រទាប់វណ្ណៈថា ប្រាសាទនេះជារបស់ពួកគេទោះបីជាដឹងថា ពុំមែនជារបស់ខ្លួនក៏ដោយ។ ដូចជាវាលឥន្ទ្រីពួកគេចេះតែដណ្ដើមចង់បាន ព្រោះឥន្ទ្រីតំណាងឲ្យសត្វគ្រុឌ ហើយគ្រុឌនេះកំពុងចាប់នាគ តែឥឡូវវាលឥន្ទ្រី(និមិត្តរូប)នេះគឺជារបស់ខ្មែរ គេមិនអាចមានកម្លាំងឫទ្ធិខាងក្នុងចាប់ព្រះម៉ែបានទៀតឡើយ ព្រោះវាលឥន្ទ្រីជារបស់ខ្មែរ។

ប្រាសាទព្រះវិហារតំណាងឲ្យអ្វី? ប្រាសាទព្រះវិហារតំណាងឲ្យព្រហ្មវិហារធម៌ទាំងបួន ដែលគាត់បានធ្វើដំបូលឲ្យកូននាគប្រុសស្រីជ្រក (**ក្បឿងស្រកានាគ**) ជាម្លប់រាប់ពាន់ឆ្នាំមកហើយ។ ម្លប់នៃព្រហ្មវិហារធម៌នេះបានគរពូនក្លាយទៅជាភ្នំ ហើយកូនខ្មែរប្រុសស្រីដែលជ្រកក្រោមម្លប់នេះ ពុំបានស្គាល់ម្ចាស់ដំបូលឬជម្រករបស់ខ្លួនឡើយ មិនត្រឹមតែប៉ុណ្ណោះយើងនាំគ្នាជេរប្រមាថ មាក់ងាយដល់ម្ចាស់ជម្រកនោះទៀតផង(ជេរអាទិទេពខ្លួនឯង)។

សព្វថ្ងៃនេះរាជរដ្ឋាភិបាលដែលមានសម្ដេចនាយកជាប្រមុខ លោកបានខិតខំប្រឹងប្រែងដាក់បញ្ចូលប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក គឺលោកជួយរែកស្រង់វិហារធម៌ព្រះមាតាបិតាទៅដាក់លើកំពូលឡើងវិញហើយ។ ដូច្នេះអនាគតដ៏ខ្លីខាងមុខព្រះមាតាបិតាមហានគរនឹងរួចពីទុក្ខហើយនឹងធ្វើឲ្យនគរនេះរុងរឿងដូចសម័យដើម ពេលនោះកូននាគប្រុសស្រីនឹងស្គាល់អាទិទេពខ្លួនឯងជាមិនខាន។

## ១៤.ប្រាសាទភ្នំបាខែង(ខេត្តសៀមរាប)

ប្រាសាទភ្នំបាខែងនេះ ជាភ្នំធម្មជាតិដែលដូនតាខ្មែរបានកសាងប្រាសាទមួយទុកនៅលើកំពូលភ្នំនេះដាក់ឈ្មោះថា ប្រាសាទបាខែងឬភ្នំបាខែង។

### ពន្យល់ពាក្យ (បាខែង)

បា = កូនប្រុស

ខែង = ដែលក្លៀវក្លា អង់អាច ហ៊ឺហា ឬកពាខែងរ៉ែង

បាខែង = បាដែលក្លៀវក្លា អង់អាច ហ៊ឺហា បាដែលមានឬកពាខែងរ៉ែង

មុននឹងខ្ញុំពន្យល់ពីអត្ថន័យ,ប្រាសាទបាខែង ខ្ញុំសូមទាញយកឈ្មោះប្រាសាទបាពួន និងប្រាសាទបាគងមកបកស្រាយសិន ព្រោះប្រាសាទទាំងពីរនេះពុំមែនជាប្រាសាទភ្នំឬភ្នំប្រាសាទឡើយ ប៉ុន្តែទាក់ទងនឹងឈ្មោះ**បា**។ នេះគឺជាគុណធម៌ដំបូង ដែលកូនប្រុសរបស់គាត់បានដឹងរឿងគាត់រួចបានោះ ពួនលាក់ខ្លួនដើម្បីជួយស្រោចស្រង់ព្រះម៉ែ នៅក្នុងព្រៃមនុស្សដោយស្ងៀមស្ងាត់ នេះជាអត្ថន័យ**ពាក្យ** ប្រាសាទ**បាពួន** ➔ (**បាលាក់ខ្លួន**ជួយស្រង់ព្រះម៉ែ) ចំណែកប្រាសាទបាគង់សព្វថ្ងៃគេហៅថា បាគង ឈ្មោះរបស់ប្រាសាទនេះ មានពីរ។

**ពន្យល់ពាក្យ**(បាគង់ និង បាគង)

បាគង់ ➔ កូនប្រុសគង់ចាំ ឬអង្គុយចាំព្រះម៉ែឡើងមកពីទីទាប (សមុទ្រទឹកដោះ)

បាគង ➔ បាគងព្រះមេឬព្រះម៉ែឲ្យគាត់ឱបជើង (រូបចម្លាក់ព្រះវិស្ណុដេក នៅក្បាលស្ពាន ប្រាសាទព្រះខ័ន្ធ បន្ទាយសំរ៉ែ ភ្នំដារ បាតស្ទឹងភ្នំ គូលែន) ....។ល។ គឺព្រះវិស្ណុផ្ទុំលើគុជសី ផ្ទុំលើនាគ រួចគងព្រះម៉ែ (ដែលសព្វ ថ្ងៃមានស្រុកមួយនៅក្នុងខេត្តកំពង់ស្ពឺ **គងពិសី** ខ្ញុំបានពន្យល់ខាងលើ រួចហើយ) គាត់វារផង លូនផង ដឹកអូសព្រះម៉ែចេញពីទីឃុំឃាំង។ នៅក្នុងរឿងព្រេងបក្សីចាំក្រុង មានឈ្មោះភូមិស្រុក ដែលទាក់ទងនឹងរឿងនេះ បានសល់កេរដំណែលមកដល់សព្វថ្ងៃ គឺវិហារសួគ៌(សួរ) **ល្វាទេ** និង **រកាកោង** ដែលជាបិស្នាទាក់ទងក្នុងទំនាយ រឿងព្រេង.....។ល។



វិស្ណុផ្ទុំនៅប្រាសាទព្រះខ័នសៀមរាប

**ពន្យល់ពាក្យ** (ក្នុងរឿងបក្សីចាំក្រុង)

បក្សី = គ្រុឌ

ក្រុង = យកអង្រុត ឬសំណាញ់ទៅគ្របក្រុងពីលើ

ក្រុង = រាជធានី (ទីក្រុង)

**ល្វាទេ** = ល + វា + ទេ ➜លវារចុះ (សាកវារចុះ)

**រកាកោង** = (រកា= មាន់) កោង= ពាក់កណ្តាល



រូបតំណាងពាក្យរកាកោង

មានន័យថា ឆ្នាំរកាទៅនៅសល់ពាក់កណ្តាលទៀត ព្រោះបុរសដែលបក្សីចាំក្រុង គាត់ត្រូវវារពាក់កណ្តាលនៃឆ្នាំដែលនៅសល់ដើម្បីនាំព្រះម៉ែចេញ (មើលរូបខាងលើ)។ បើប្រៀបធៀបនឹងមង្គលបីឬសិរីបីបានន័យថា ពីក្បាលដល់ផ្ចិតគឺពាក់កណ្តាលៗទៀតគឺពីផ្ចិតដល់ចុងជើងព្រោះក្នុងសិរីបីប្រការក្តីមង្គលបីក្តី គឺព្រឹកនៅមុខ ថ្ងៃត្រង់នៅទ្រូង ល្ងាចនៅចុងជើង ប្រស្នាពីរខាងដើម គឺស្មើនឹងខាងចុងមួយ។ តាមពិតរឿងព្រះម៉ែរួចពីទុក្ខនោះ ត្រូវចប់ក្នុងឆ្នាំរកាឯណោះ ព្រោះចាស់ៗតែងដំណាលតៗគ្នាទុកក្នុងទំនាយថា **រកាសាដាន** ពាក្យថាសាដាននេះ គឺសាដានព្រះម៉ែ ដែលត្រូវគេលុបមិនឲ្យកូនខ្មែរដឹងនោះឲ្យដឹងឡើងវិញ ក៏ប៉ុន្តែពុំអាចសារួចឡើយ ព្រោះដល់ឆ្នាំរកាត្រូវសាដានព្រះម៉ែបែរជារកាកោងទៅវិញ គឺត្រូវស្មើនឹងពាក់កណ្តាលពីរដងខាងលើឯណោះ។ នេះខ្ញុំបាទអ្នកស្រាវជ្រាវចង់ពន្យល់រូបចម្លាក់រឿងឲ្យទាក់ទងនឹងឈ្មោះភូមិ ស្រុក ប្រាសាទ ភ្នំ រឿងព្រេងប្រចាំនគរ ឬទំនាយប្រចាំនគរជាដើម (**ប្រមូលផ្តុំជ័យ**)។ ប្រស្នាព្រះម៉ែនេះមិនដែលមានអ្នកណា ចាប់អារម្មណ៍បំបែកបណ្តាំគំនិតរបស់គាត់ឡើយ បើយើងអត់បំបែកបណ្តាំប្រស្នានេះទេ គឺពុំអាចរកគន្លឹះបើកទ្វារអាថ៌កំបាំងបណ្តាំព្រះម៉ែនេះរួចឡើយ **ទាល់តែយើងផ្គុំផ្គុំរឿងដែលគេហាន់ជាចំណិតៗ** នោះទើបអាចមើលឃើញនូវសាច់រឿងពិតរបស់គាត់បាន។

ឥឡូវយើងត្រឡប់មកសាច់រឿង**ភ្នំបាខែង**វិញ **តើមានអត្ថន័យយ៉ាងណាដែរ?** ខ្ញុំបានពន្យល់ក្នុងទំព័រខាងដើមខ្លះៗហើយ ដោយគុណធម៌របស់បា(កូនប្រុស) គាត់សន្សំតាំងពីតូចរហូតដល់ធំប៉ុនភ្នំ

ទីបំផុតគុណធម៌ដែលសន្សំបាននេះធ្វើឲ្យគាត់អាចលើកដងរែកភ្នំរួច(និមិត្តរូប) ហើយស្រង់រែកភ្នំម៉ែឪដែលលិចកប់ចុះរាប់ពាន់ឆ្នាំឲ្យងើបអណ្តែតឡើងវិញ រួចរែកពួកគាត់ទៅដាក់លើកំពូលភ្នំព្រះវិហារវិញ។ កាលបើអាទិទេពខ្មែររួចពីទុក្ខទោសហើយនោះ តើកូនខ្មែរអាចរួចពីទោសបានទេ? គឺ **ពិតជាបាន** ពេលដែលដូនតាយើងលែងជាប់ទុក្ខទោសនោះហើយដែលហៅថា **ខែងរ៉ែង**(បាខែង)។ សព្វថ្ងៃកូនខ្មែរបានត្រឹមតែឡើងលើភ្នំបាខែង មើលថ្ងៃលិចជាមួយបរទេសតែប៉ុណ្ណោះ គឺពុំបានដឹងពីអត្ថន័យបណ្តាំពាក្យពិតរបស់ព្រះម៉ែឲ្យមើលឈ្មោះប្រាសាទភ្នំនេះឡើយ។ សូមឲ្យក្លិនក្រអូបនៃបញ្ញារបស់ព្រះម៉ែសក់ក្រអូប ជ្រាបចូលក្នុងបេះដូងកូនខ្មែរប្រុសស្រីឡើងវិញ សូមឲ្យកោះកេរ**ព្រះ**ម៉ែ (ប្រាសាទកោះកែរ**កោះកេរ**ឬកោះគោកធ្លក) អណ្តែតឡើងដោយកម្លាំងសាមគ្គីរបស់កូននាគប្រុសស្រី។

**១៥. ភ្នំត្បែងមានជ័យ**(ខេត្តព្រះវិហារ)

ត្បែង = ត្របែង ចងដោយប្រើកូនកំព្រាស័ករឹត មូលឲ្យតឹង (ចងរួចត្បែងឬត្របែង)

ត្បែង = ឈ្មោះឈើសន្តានខ្លុង ត្រាច

មានជ័យ = ជម្នះការឈ្នះ ជោគជ័យ

ភ្នំត្បែងមានជ័យ = ចងរឹតត្បែងភ្នំដោយបានជោគជ័យ

តើឈ្មោះភ្នំត្បែងមានជ័យនេះ មានទាក់ទងអ្វីនឹងរឿងព្រះម៉ែមហានគរដែរ? ឯកសាររូបរឿងរបស់ភ្នំត្បែងមានជ័យនេះ ស្តេចជ័យវរ្ម័នទី៧ ព្រះអង្គបានកសាងទុករូបរឿងនៅប្រាសាទបាយ័ន និងប្រាសាទបន្ទាយឆ្មារ ព្រោះសព្វថ្ងៃមាននៅសល់រូបភាពដែលអាចនៅមើលយល់បាន។

មិត្តអ្នកអានជាទីមេត្រី បើអ្នកទៅទស្សនាប្រាសាទបាយ័ន ពេលអ្នកដើរចូលទៅក្នុងបរិវេណខាងមុខ អ្នកនឹងបានឃើញខ្លោងទ្វារដែលមានមុខព្រហ្មដំបូងគេ ដែលយើងត្រូវដើរឆ្លងកាត់ពីក្រោម។ ពេលនោះអ្នកសម្លឹងមើលទៅខាងលើមុខព្រហ្ម អ្នកនឹងកើតក្តីសង្ស័យជាមិនខាន ព្រោះនៅខាងលើក្បាលព្រហ្មមានសុទ្ធតែរូបសត្វគ្រុឌឈរស្រាក់ដៃគ្នាជ្រែងត្បែង មិនឲ្យព្រហ្មរើក្បាលរួចឡើយ។ តើមិត្តអ្នកអានមានឆ្ងល់ទេ? បើព្រហ្មមានឋានៈខ្ពស់ទៅហើយ **ហេតុដូចម្តេចបានជាមានសត្វគ្រុឌជាសត្វ**

***តិរិច្ឆាននៅពីលើ?*** *កូននាគទាំងឡាយ ចូរអ្នកជួយពិចារណាព្រហ្មម៉ែព្រហ្មឪឡើងវិញដោយពឹងផ្អែកនឹង* ***ឈរលើគំនិតនិង មនសិការជាតិសុទ្ធៗ*** *រីឯប្រាសាទបន្ទាយឆ្មារក៏ដូច្នោះដែរ មានសុទ្ធតែមនុស្សអង្គុយស្រាក់គ្នាជុំវិញពីខាងលើក្បាលព្រហ្ម។ តាមឯកសារពន្យល់ពីប្រាសាទយើងដឹងហើយថា ប្រាសាទបន្ទាយឆ្មារ គឺធ្វើឡើងដើម្បីឧទ្ទិសឲ្យកូន រីឯប្រាសាទបាយ័នវិញ គឺធ្វើដើម្បីឧទ្ទិសឲ្យមាតាបិតា។ បើព្រហ្មម៉ែនិងព្រហ្មឪ ត្រូវគេចងត្បែងជាប់ទៅហើយ ថែមទាំងព្រហ្មកូនក៏គេត្បែងជាប់ដូចគ្នា ពេលណាទើបយើងអាចស្រាយចំណងត្បែងទាំងនេះរួច គឺបានន័យថា (យកថ្លុកទៅលុបត្រពាំង)។ សព្វថ្ងៃក្រុមតាបស ឥសី គ្រូមន្តអាគម...តែងតែនាំគ្នាទៅរកអ្នកមានបុណ្យ នៅភ្នំត្បែងនោះដោយពួកគាត់ឮតៗគ្នាក្នុងពុទ្ធទំនាយថា មានអ្នកមានបុណ្យ កំពុងតាំងសិល្បិ៍សមាធិនៅក្នុងភ្នំត្បែង។ ប៉ុន្តែតាមន័យពិត ពួកគាត់ត្រូវគេចងត្បែងជាប់ មកទល់នឹងពេលនេះ ពួកគាត់មិនទាន់រួចពីចំណងបាបកម្មចាស់ផង នេះជាអាថ៌កំបាំងបណ្ដាំរបស់ព្រះម៉ែក្នុង* ***ពាក្យភ្នំត្បែងមានជ័យ។*** *ចង់ស្រាយចំណងត្បែងនេះរួច លុះត្រាតែកូននាគប្រុសស្រីរួមសាមគ្គី ព័ន្ធគ្នាជាធ្លុងមួយហើយឧទ្ទិសនូវមហាកុសលដែលកើតចេញពីការដឹងឧបការគុណ(កតញ្ញូកតវេទី)ទើបអាចស្រាយនូវចំណងត្បែងដែលជាបាបកម្មដ៏ធំនេះរួច។*



**រូបព្រហ្មបាយ័នមានគ្រុឌស្រាក់ត្បែងពីលើ**

## **១៦.ប្រាសាទភ្នំត្រប់** *( ភ្នំទ្រព្យខេត្តព្រះវិហារ)*

*ប្រាសាទនេះ ខ្ញុំបាទអ្នកស្រាវជ្រាវទើបតែស្គាល់ឈ្មោះ នៅពេលដែលវិវាទជំលោះប្រាសាទព្រះវិហារកើតឡើង តើវាទាក់ទងអ្វីដែរនៅក្នុងរឿងបណ្ដាំព្រះម៉ែមហានគរ? កូននាគប្រុសស្រីទាំងឡាយអ្នកពិតជាធ្លាប់អាន ធ្លាប់ស្ដាប់នូវរឿងមរណៈមាតា(ម៉ែស្លាប់) ឬដើមកំណើតត្រីដំរីហើយ រឿងនេះជារឿងរបស់ព្រះម៉ែមហានគរ ដែលសាច់រឿងស្រដៀងនឹងរឿងមាតាទាំង១២ដែរ គ្រាន់តែក្នុងរឿងនេះ គឺមានម្ដាយតែមួយប៉ុណ្ណោះ។ ម្ដាយក្នុងរឿងនេះត្រូវស្ត្រីរួមប្ដីជាមួយញុះញង់ប្ដីឲ្យយកគាត់*

ទៅសម្លាប់នៅពេលដែលគាត់ទៅបង់សំណាញ់ជាមួយប្តី ហើយប្រពន្ធដើមនោះ គាត់មានកូនស្រីម្នាក់ ជាកូនកតញ្ញូកតវេទី(ដឹងគុណ)។ កូនស្រីនៅពេលដែលបាត់ម្តាយ នាងបានទៅយំរៀបរាប់នៅឯមាត់កំពង់ទឹកដែលម្តាយស្លាប់ ដោយសារឪពុកនាងសម្លាប់នោះ ហើយគាត់បានកើតជាត្រីដំរី ពេលឮកូនស្រីខ្លួនយំរៀបរាប់ គាត់ក៏បានហែលមកជិតរួចប្រាប់រឿងរ៉ាវដល់កូន។ កូនស្រីតែងតែយកចំណីទៅឲ្យម្តាយជាត្រីដំរីបរិភោគរាល់ៗថ្ងៃ ធ្វើឲ្យដំណឹងនេះឮទៅដល់ម្តាយចុង ដែលជាមនុស្សមានចិត្តអាក្រក់ រួចម៉ែចុងនោះបានប្រើកូនស្រីទាំងពីររបស់ខ្លួន ឲ្យទៅល្បួងចាប់ត្រីដំរីនោះមកសម្លាប់ធ្វើម្ហូប។ ពេលដែលសម្លាប់ធ្វើម្ហូបនោះ ឆ្អឹងរបស់ត្រីជ្រុះទៅក្រោម សត្វឆ្មាបានពាំយកឆ្អឹងនោះ ទៅឲ្យកុមារិកាជាកូនៗ បានយកឆ្អឹងទៅកប់(បញ្ចុះធាតុ)ក្នុងទីមួយ នៅទីដែលកប់ឆ្អឹងនោះក្រោយមកបានដុះចេញជាដើមត្រប់មួយដើម។ នាងកុមារិកាជាកូន តែងតែទៅស្រោចទឹកដើមត្រប់នោះរាល់ៗថ្ងៃ ធ្វើឲ្យរឿងនេះបានលេចឮទៅដល់ម្តាយចុងដែលជាមនុស្សព្យាបាទឈ្នានីស ស្ត្រីនេះបានប្រើកូនឲ្យទៅបោចដើមត្រប់នោះចោលទៀត។ ក្រោយពេលដែលកុមារិកាបានដឹង នាងក៏បានទៅមើលក្នុងទីនោះ ឃើញមាននៅសល់ឫសត្រប់ខ្លះក្នុងដី នាងក៏ប្រមូលនូវឫសទាំងនោះទៅបញ្ចុះក្នុងទីមួយថ្មីផ្សេងទៀត ដែលក្រោយមកទីបញ្ចុះនោះបានដុះចេញឡើងជាដើម **រលួសមាស** (រលស់)។ និយាយពីស្តេចនគរនោះ ថ្ងៃមួយមានសេចក្តីអផ្សុកបានចេញទៅប្រពាតព្រៃ រួចបានឃើញនូវដើមរលួសមាសនោះ ស្តេចបានឲ្យគេរកម្ចាស់ដើមរលួសមាសនេះ ដើម្បីសុំយកទៅដាំក្នុងរាជវាំង ព្រោះឃើញពណ៌សម្បុររបស់វាល្អ។ ពេលដែលស៊ើបដឹងពីម្ចាស់ដើមរលួស ស្តេចបានពេញចិត្តនឹងកុមារិកានោះ ហើយបានតែងតាំងនាងជាមហេសី នាងកុមារិកាក៏បានឧទ្ទិសដ្ឋាននូវដើមរលួសមាសជាម្តាយ ឲ្យគាត់ទៅប្រតិស្ឋានក្នុងផើងមាសឯព្រះបរមរាជវាំង ដែលនាងអាចក្លាយជាមហេសីស្តេចបាន ក៏ដោយសារអំណាចបុណ្យដែលនាងបានបំពេញនូវកតញ្ញូកតវេទី (ការដឹងឧបការគុណ និងតបនូវឧបការគុណនេះ) ។ កូននាគទាំងឡាយ តើអ្នកដឹងទេថា រឿងនេះមានបង្កប់នូវប្រស្នាអ្វីខ្លះ?

១. ទាក់ទងនឹងត្រីដំរី (ទីក្រុងយសោធបុរៈឬទីក្រុងដំរី)

២. ទាក់ទងនឹងដើមត្រប់ (ដែលសព្វថ្ងៃតំណាងឲ្យប្រាសាទភ្នំត្រប់ ឬភ្នំទ្រព្យ)

៣. ទាក់ទងនឹងដើមរលួសមាស (ដែលប្រស្នាតំណាងឲ្យប្រាសាទរលស់)

*យើងដឹងហើយថាទីក្រុងសម័យអង្គរគេហៅថា រាជធានីយសោធបុរៈ ដែលប្រែមកថា ក្រុងអ្នកទាក់ដំរីឬក្រុងដំរី ហើយនគរនេះរុងរឿងបានដោយសារមហិទ្ធិឫទ្ធិបិសាចពស់ (ឯកសារចិន* ***ជីវតាក្វាន់*** *បានពន្យល់រួចហើយក្នុងភាគ១)។ ម្តាយក្លាយទៅជាត្រីដំរីមកពីពាក្យ* ***ស្ត្រី = សត្វ + ត្រី + ដំរី ស្ត្រីដំរីនេះ*** *បានធ្លាក់លិចកប់ចុះទៅក្នុងសមុទ្រទឹកដោះ (ព្រះម៉ែនាគ) រីឯ* ***ដើមត្រប់*** *ឬទ្រព្យវិញតំណាងឲ្យធនធានទ្រព្យធនរបស់ខ្មែរ ដែលសព្វថ្ងៃបានពូនគរទៅជាភ្នំ ចំណែក* ***ដើមរលួស(រលស់)*** *តំណាងឲ្យបាបកម្មរបស់ព្រះម៉ែរលស់អស់បន្តិចម្តងៗ ព្រោះពាក្យថា* ***រលស់ ឬរម្លស់*** *គឺបាត់ចំនួនដើមអស់បន្តិចម្តងៗ (ឧ. ពាក្យថាសងរម្លស់)។ មិត្តអ្នកអានតើមានឆ្ងល់ដែរឬទេ? ក្នុងសាច់រឿងបានប្រាប់ថា ម្តាយស្លាប់ពីមនុស្សទៅកើតជាត្រីដំរី ស្លាប់ពីត្រីដំរីទៅកើតជាដើមត្រប់ ស្លាប់ពីដើមត្រប់ទៅកើតជាដើមរលួសមាស(រលស់)។ បើតាមកាសិក្សាពីព្រះធម៌ក្នុងព្រះពុទ្ធសាសនា ព្រះអង្គទ្រង់ត្រាស់សំដែងថា អកុសលកម្មដែលសត្វបានធ្វើ កម្មនោះតែងនាំសត្វឲ្យធ្លាក់ទៅកាន់អបាយភូមិ៤ (នរក ប្រេត តិរិច្ឆាន អសុរកាយ) ចុះហេតុអ្វីបានជាក្នុងសាច់រឿងដូនតាយើងសរសេរថា* ***ត្រីដំរីជាសត្វតិរិច្ឆាន*** *បែរទៅកើតជារុក្ខជាតិទៅវិញ? ព្រោះរុក្ខជាតិពុំមានចិត្ត វិញ្ញាណឡើយ។ គាត់ចង់ឲ្យកូននាគប្រុសស្រីជាអ្នកស្តាប់រឿងអានរឿង នឹងជាអ្នកកាន់ព្រះពុទ្ធសាសនានោះ កើតមានការងឿងឆ្ងល់ រួចធ្វើការស្រាវជ្រាវត្រិះរិះពិចារណា នូវបណ្តាំគំនិតព្រះម៉ែទាំងនេះ។ ការបកស្រាយពន្យល់ជាហូរហែដែលទាក់ទងប្រាសាទភ្នំត្រប់ និងរឿងកំណើតត្រីដំរី ទោះបីជារឿងព្រេងនិទាន ប៉ុន្តែវាបានភ្ជាប់សាច់រឿងទៅនឹងប្រាសាទ ភ្នំធម្មជាតិ... ដែលធ្វើឲ្យយើងអាចស្រាយនូវបណ្តាំប្រស្នាព្រះម៉ែបាន ព្រោះឈ្មោះកើតចេញពីមនុស្សអ្នកសន្មត់រួចដាក់សម្គាល់ ហើយបង្កប់អត្ថន័យទៅតាមបញ្ញារបស់បុគ្គលម្នាក់ៗ ដូចជាសព្វថ្ងៃ ម្តាយឪពុកដែលចេះដឹងតែងដាក់ឈ្មោះបុត្រទៅតាមកម្លាំងថ្ងៃដែលកើត ហើយការដាក់ឈ្មោះនោះតែងមានបង្កប់អត្ថន័យដែលខ្លួនជាមាតាបិតាចង់បាន។*

**១៧.ភ្នំសន្ទុក** (ខេត្តកំពង់ធំ)

*តាមឯកសារទាំងឡាយដែលមានសេសសល់ពីបុរាណនៅលើភ្នំនោះ ពីដើមភ្នំនេះមានឈ្មោះថាភ្នំសន្សំទុក (ភាសានិយាយច្រើនក្លាយ) ព្រោះនៅលើភ្នំបានបន្សល់ទុកនូវឯកសារសាវតាចម្លាក់រូបជាច្រើន ដែលមាននៅសល់ទុកជាកេរមកដល់សព្វថ្ងៃ។ នៅក្នុងព្រះវិហារមានបល្ល័ង្កព្រះពីបុរាណមួយដែលនៅខាងលើបល្ល័ង្កនោះ ពុំមានពុទ្ធបដិមាគង់នៅពីខាងលើឡើយ គឺមានតែផ្កាឈូកក្រពុំមួយទងនៅខាងលើបល្ល័ង្កតែប៉ុណ្ណោះ ចំណែកឯរូបពុទ្ធបដិមាបែរជាចុះមកគង់នៅខាងក្រោម បល្ល័ង្កទៅវិញ*

(គំនិតអ្នកឆ្លាក់)។ នៅខាងក្រោយព្រះវិហារនោះ មានរូបដោះស្រ្តីឆ្លាក់ថ្មពីបុរាណពីរ ទីមួយដោះតូច តំណាងឲ្យស្រ្តីនៅក្រមុំ (ខ្មែរ = មេ) ទីពីរដោះធំតំណាងឲ្យស្រ្តីដែលមានប្ដី ហើយមានកូន (ខ្មែរ =ម៉ែ) ហើយនៅក្នុងចន្លោះនៃដោះទាំងគូនេះ មានអណ្ដូងថ្មជីកយ៉ាងជ្រៅ ដែលនៅក្នុងអណ្ដូងនោះ មានសសរថ្មបួនជ្រុងចំនួនបីដើម។ នៅចំហៀងភ្នំឯណោះវិញ មានរូបពុទ្ធបដិមាគ្រប់ឥរិយាបទដែលដូនតាយើងឆ្លាក់ទុកមានទំហំធំៗ ហើយរូបចម្លាក់ទាំងអស់ ជាបណ្ដាំប្រស្នាដែលទាក់ទងនឹងឈ្មោះភ្នំនេះ។ តើរូបចម្លាក់ថ្មទាំងអស់នោះមានអត្ថន័យយ៉ាងណាហ្ន៎? បើយើងមិនបានសិក្សាពិចារណាស្រាវជ្រាវទេ យើងច្បាស់ជាយល់ថា ដូនតាយើងមានពេលទំនេរមកឆ្លាក់រូបលេងទុកនៅទីនោះហើយ (រៀនឆ្លាក់)។

ក .ពេលដែលយើងមើលឃើញផ្កាឈូកក្រពុំដែលស្ថិតនៅលើបល្ល័ង្កនេះ យើងនឹកឃើញដល់ព្រះចេតិយព្រះនាងក្រពុំឈូក នៅឯព្រះវិហារសសរមួយរយក្នុងភូមិសំបុក ស្រុកសំបូរ ខេត្តក្រចេះឯណោះ។ ព្រោះផ្កាឈូកនៅលើ បល្ល័ង្កព្រះវិហារភ្នំសន្ទុកនេះ អត្ថន័យរបស់វាគឺជាប់ជាមួយនឹងរឿងព្រះចេតិយព្រះនាងក្រពុំឈូកនៅឯខេត្តក្រចេះនោះ(ពន្យល់នៅក្នុងភ្នំរទង់រួចហើយ)។ ហេតុអ្វីបានជាពុទ្ធបដិមាចុះមកគង់ខាងក្រោមទៅវិញ?

ផ្កាឈូកតំណាងឲ្យបរិស័ទទាំង ៤ ពួក និងតំណាងបញ្ញាបារមីរបស់ព្រះពុទ្ធ និង ព្រះបច្ចេកពុទ្ធដែលត្រូវត្រាស់ដឹងដោយខ្លួនឯង។ យ៉ាងណាមិញ ផ្កាឈូកដែលនៅលើបល្ល័ង្កក៏តំណាងឲ្យបញ្ញាព្រះមាតានាគបិតានាគរួមទាំងកូននាគទាំងទ្វេដែលបញ្ញាទាំងនេះ មិនទាន់អាចរីករួច(ឈូកក្រពុំ)។ ព្រោះយើងទាំងអស់គ្នា កំពុងនៅក្នុងភូមិសំបុក ស្រុកសំបូរ ខេត្តក្រចេះ ម្យ៉ាងទៀតបញ្ញារបស់ពួកគាត់ ត្រូវគេតៀ្បងជាប់អស់ហើយ (អាថ៌កំបាំងភ្នំត្បែង)។ ចំណែកឯពុទ្ធបដិមា ដែលចុះមកគង់ខាងក្រោមវិញ គឺតំណាងឲ្យពោធិសត្វដែលកំពុងបំពេញបារមីនៅឡើយ (ពោធិសត្វលោកេស្វរៈ) ។

ខ.រូបដែលទាក់ទងនឹងដោះវិញ តើមានអត្ថន័យខ្លឹមសារយ៉ាងណាដែរ? ខ្ញុំបានពន្យល់រួចហើយ ក្នុងភាគទីមួយពីពាក្យ មេ និងម៉ែ ដូច្នេះរូបចម្លាក់ដោះទាំងពីរនេះ ដោះដែលតូច(ដោះក្រមុំ) គឺកាលគាត់នៅជាព្រះមេ គឺព្រះនាងនាគ ចំណែកឯដោះដែលធំគឺពេលដែលគាត់ក្លាយទៅជាព្រះម៉ែ ឬមាតានាគ (មាតុភូមិ)។ចំណែកឯអណ្ដូងវិញមានអត្ថន័យយ៉ាងណា?

គ. អណ្ដូងគឺជាទីជ្រៅដែលលាក់ទុកនូវបេះដូង គឺក្នុងទ្រូង (ខ្ញុំពន្យល់រួចហើយ) នឹងលាក់ទុកនូវប្រភពទឹកដោះ ដែលបានហូរផ្សព្វផ្សាយចេញមកពេញទូទាំងមាតុភូមិនេះ កូនណាចង់ដឹងពីប្រភពដើមរបស់ទឹកដោះ ទាល់តែចុះទៅក្នុងអណ្ដូងនោះទើបដឹង។ ចុះសសរថ្មបីដើមនោះតំណាងឲ្យអ្វី? ខ្ញុំបានពន្យល់ក្នុងមង្គលបីនិងសិរីបីប្រការរួចហើយ គឺព្រះម៉ែគាត់ជាប់នៅក្នុងគុកទាំងបីជាន់ បើកូនខ្មែរ

ណាចង់ជួយស្រង់គាត់ទាល់តែរកប្រស្នានៅក្នុងមង្គលទាំងបី និងសិរីបីឬក៏ចុះទៅក្នុងអណ្តូង ទើបអាច លើកសសរថ្មដែលសោចាក់បិទក្នុងអណ្តូងនោះចេញរួច ព្រោះវាជានិមិត្តរូបសោបីជាន់ (មេសោបើក បានដោយសារកូន)។ ប៉ុន្តែគួរឲ្យសោកស្តាយណាស់ ដែលសព្វថ្ងៃនេះអ្នកទេសចរណ៍ដែលទៅលេង លើភ្នំនោះ គេតែងនាំគ្នាបោះលុយចូលទៅក្នុងអណ្តូង ដើម្បីផ្សងមើលនូវមុខរបរ ការងាររកស៊ី ចិញ្ចឹមជីវិតទៅវិញ ដោយពុំបានយល់ពីប្រស្នាគំនិតបណ្តាំរបស់ព្រះម៉ែនេះឡើយ ព្រោះរវល់តែចង់បាន លាភសក្ការៈពីមុខរបរខ្លួន ម្យ៉ាងទៀតហេតុតែមិនដឹងនិងមិនបានពិចារណាឈ្វេងយល់ ធ្វើឲ្យ យើង បាត់នូវបញ្ញាដើម្បីគិតត្រិះរិះដោះប្រស្នាមរតកបណ្តាំព្រះម៉ែនេះ។

**១៨.ភ្នំជីលា** (ខេត្តកំពង់ចាម)

ខ្ញុំបានពន្យល់ពីភ្នំជីសូរ និងស្ទឹងជីក្រែងនៅទំព័រខាងដើមរួយហើយ ឥឡូវនេះ ចូលមកដល់ ឈ្មោះភ្នំជីលា

តើភ្នំជីលាមានន័យដូចម្តេច? មុនពេលដែលជីចេញទៅប្រមូលរឿង ដែលគេហាន់ជាចំណិតៗ (ហាន់ ជ័យ) គាត់បានទៅលាផ្តែផ្តាំញាតិមិត្តម៉ែឪថា គាត់នឹងចេញទៅស្វែងរកនូវអាថ៌កំបាំងព្រះម៉ែនេះ ទើប នៅក្នុងតំបន់នោះ មានឈ្មោះទីកន្លែងមួយទៀត ហៅថាចរចា(ជីលាចរចា)។ ដូចស្ទឹងជីនិតពាក្យនេះ មានន័យដូចស្ទឹងជីក្រែងដែរ គឺជីនោះគាត់ស្ថិតនៅក្នុងវណ្ណៈទាប ឬត្រកូលទាប (ពូជសំរែ) ដូច្នេះហើយ ទើបគាត់ក្រែងជួយព្រះម៉ែពុំបាន (ជីក្រែង) ព្រោះខ្លាច ដោះក្តីក្នុងទីខ្ពស់ដូចជាភ្នំពុំរួច ព្រោះរឿងក្តីក្តាំ របស់ព្រះម៉ែ ជារឿងដែលស្ថិតក្នុងទីខ្ពស់ (យក្សចាប់ នាងសេតា)។

**១៩.ភ្នំបាធាយ** (ខេត្តកំពង់ចាម)

ពាក្យនេះពីមុនឈ្មោះថាភ្នំបាស្តាយ ព្រោះពាក្យនិយាយច្រើនក្លាយ ឧ. ស្រីសន្ធរពីមុនស្រីសឈរ កំពង់ចាមពីមុន**កំពុងចាម់** ទួលគកពីមុន**ទួលគោក** ទន្លេបាទីពីមុន**ទន្លេបាត់ទី**....។ល។ តើបានោះគាត់ ស្តាយអ្វី? គឺគាត់ស្តាយនូវបណ្តាំរឿងរ៉ាវទាំងឡាយ ដែលដូនតាបានហាន់ជាចំណិតៗ ដើម្បីយកមកផ្គុំ នៅបណ្តាំរឿងពីអតីត ឲ្យមានជារូបរាងពិតរបស់ដូនតាឡើងវិញ មានន័យថាបាគាត់ស្តាយបណ្តាំរឿង

ទាំងអស់ ដែលទាក់ទងនឹងរឿងព្រះម៉ែមកផ្គុំ ឲ្យកើតជាដានស្នាមចេញជារូបរាង ព្រោះយើងបាត់ដឹងរឿងយូរមកហើយ (ពាក្យបាត់ដឹងនេះ ខ្ញុំនឹងពន្យល់ពីឈ្មោះភ្នំវាពណ៍នៅទំព័រខាងក្រោយ) ដូច្នេះ**ចាំ**ត្រូវដើរប្រមូលស្ដាយនូវរឿងឯណេះបន្តិចឯណោះបន្តិច មកផ្គុំឲ្យកើតមានជារូបរាងឡើងវិញ។

## ២០.ភ្នំប្រសិទ្ធិ / សិទ្ធី

***ពន្យល់ពាក្យ***(ប្រសិទ្ធិ /សិទ្ធី)

*ប្រសិទ្ធី = ការតាក់តែង ការប្រដាប់ ដំណើរធ្វើឲ្យសម្រេច* **ឧ.** *ប្រសិទ្ធីឲ្យមានស្រីសួស្ដី ភ្នំប្រសិទ្ធី គឺប្រសិទ្ធីភ្នំឲ្យគ្រប់លក្ខណៈ ប៉ុន្តែបើតាមសាច់រឿងពុទ្ធសែនកង្រីក្ដី បក្សីចាំក្រុងក្ដី ទីភ្នំនេះសុទ្ធតែបានជួយប្រសិទ្ធីអ្នកទាំងពីរក្នុងសាច់រឿង ឲ្យបានរួចពីសេចក្ដីស្លាប់របស់សត្រូវ។ ដូចក្នុងរឿងពុទ្ធសែន ឬរថសែន អាចរួចពីសេចក្ដីស្លាប់របស់ម្ដាយចុងជាយក្សនោះបាន ដោយអំណាចឫទ្ធិលោកតាឥសីជួយបំប្លែងសារ ទីបំផុតពុទ្ធសែនបានរៀបការជាមួយកង្រី ហើយថែមទាំងបានយកគ្រាប់កែវភ្នែក (បញ្ញា) ម្ដាយទាំង១២មកបញ្ចូលឲ្យពួកគាត់វិញ ព្រោះដល់ពេលវេលាបាបកម្មរបស់មាតាទាំង១២ ត្រូវរលស់អស់ (ប្រសិទ្ធីទីមួយ)។ ឯក្នុងរឿងបក្សីចាំក្រុងក៏ដូច្នេះដែរ តួអង្គបក្សីចាំក្រុង និងតាគហេហ៍ បានរត់រួចពីការដេញតាមសម្លាប់ របស់ពួកកងទ័ពព្រហ្មកិល ក៏នៅក្នុងភ្នំប្រសិទ្ធិនេះដែរ (ប្រសិទ្ធីទីពីរ)។ ព្រោះរឿងការចងពៀរវេរានឹងគ្នា រវាងតួអង្គទាំងពីរនោះ គឺនៅក្នុងភ្នំប្រសិទ្ធីនេះ (ពុទ្ធសែន និងបក្សីចាំក្រុង) ហើយអ្នកទាំងពីរនេះ ទីបំផុតបានក្លាយជាស្ដេច បានឡើងសោយរាជ្យដូចគ្នា ដោយអំណាចប្រសិទ្ធីភ្នំ ឬភ្នំប្រសិទ្ធីនេះ។ ហេតុនេះហើយភ្នំនោះ មិនថាតួអង្គបក្សីចាំក្រុង ឬពុទ្ធសែនឡើយ គឺគ្រាន់តែជាមនុស្សម្នាក់ ប៉ុន្តែដូនតាខ្មែរគាត់ឲ្យមនុស្សទាំងពីរនេះ មានឈ្មោះផ្សេងគ្នាទទួលបាបកម្មក៏ផ្សេងគ្នាទៀត បើចង់ដឹងរឿងព្រះម៉ែ ទាល់តែផ្គុំភ្នំ នេះជាអត្ថន័យពិតរបស់ឈ្មោះភ្នំប្រសិទ្ធិ ដែលយើងជាកូនខ្មែរត្រូវតែពិចារណាវារកហេតុផលពិតរបស់ឈ្មោះភ្នំនេះ។*

**២១.ភ្នំរាពណ៍** (ទីតាំងជិតភ្នំប្រសិទ្ធិ)

**ពន្យល់ពាក្យ** (រាពណ៍)

រាពណ៍ = នាមរបស់ព្រះបាទទសក័ណ្ឋ ឬទសមុខ (ក្នុងរឿងរាមាយណៈ ឬរាមកេរ្តិ៍)

រាប = ដែលមិនរដិបរដុប ដែលឥតប៉ោង ឥតផត ឥតខ្ពស់ទាប ឧ. ដីរាប ផ្លូវរាប




ហេតុអ្វីបានជាភ្នំរាពណ៍មកប្រតិស្ឋាននៅក្នុងទីនេះទៅវិញ? ព្រោះភ្នំនេះ ទាក់ទងនឹងឈ្មោះយក្សនៅក្នុងរឿងរាមកេរ្តិ៍ ដែលសព្វថ្ងៃមានសប្បុរសជនមកកសាងប្រាសាទមួយនៅទីនោះ ឈ្មោះថាប្រាសាទភ្នំរាពណ៍។ នៅក្នុងប្រាសាទ មានតាំងរូបក្រុងរាពណ៍ឈរជាន់ព្រះមាតាមហានគរ (ដែលសព្វថ្ងៃរូបនោះគេពន្យល់ថា ព្រះសិវៈរាំជាន់កូនក្មេង. មើលរូប) យក្សទសមុខនេះហើយ ដែលបានចាប់ព្រះម៉ែឃុំឃាំងក្នុងសមុទ្រទឹកដោះ (យក្សក្បាលដប់កាន់ក្បាលនាគ ពន្យល់រួចហើយក្នុងភាគទីមួយ)។ ពាក្យថាព្រហ្មមារ គឺយក្សដែលមានមុខបួនជាន់គ្នាពីរដងស្មើនឹងប្រាំបី ហើយជាន់ខាងលើប្រាំបីនោះ មានមុខពីរទៀតត្រូវជាដប់ ទើបយក្សនេះ មានឈ្មោះថា ទសក័ណ្ឋ ឬទសមុខ។ ក្រុងរាពណ៍នេះ និងសេនារបស់គេតាមឡោមព័ទ្ធចាប់ព្រះម៉ែតាំងពីបឹង**យក្សឡោម** រហូតដល់**ភ្នំដំរីរមៀល** ព្រោះទីនោះ មានកន្លែងមួយនៅពីខាងមុខភ្នំហៅថា **ព្រលានយក្ស** ទើបចាប់បានព្រះម៉ែយកទៅឃុំឃាំងទុកក្នុងសមុទ្រទឹកដោះ (ព្រោះព្រលានយក្សសំរាប់យក្សចុះ ពុំមែនយន្តហោះចុះឡើយ)។

បើយើងធ្វើដំណើរចាកចេញពីភ្នំរាពណ៍បន្តិចមក មានភូមិមួយឈ្មោះថា **ភូមិតាប្រាប់** តើតាគាត់ប្រាប់យើងពីរឿងអ្វី? គឺគាត់ប្រាប់ពីរឿងក្រុងរាពណ៍ ចាប់ព្រះម៉ែយកទៅឃុំឃាំងក្នុងសមុទ្រទឹកដោះ ក៏ប៉ុន្តែគ្រាន់តែយើងចេញមកដល់ផ្លូវជាតិភ្លាម មានភូមិមួយទៀតឈ្មោះថា**បាត់ដឹង**។ តើពាក្យ

បាត់ដឹងមានន័យថាដូចម្ដេច? បានន័យថារឿងព្រះម៉ែធំដូចជាភ្នំ ដែលក្រុងរាពណ៍បានចាប់ម៉ែយកទៅឃុំឃាំង តាគាត់ខំរ៉ាយរ៉ាប់ប្រាប់ដំណើររឿងរបស់ជីដូន ទីបំផុតបណ្ដាំនេះ កូននាគដែលជាកូនសម័យក្រោយៗ បានធ្វើឲ្យបាត់ដឹងដំណឹងរបស់ព្រះម៉ែអស់រលីង (លុបដាន បាត់ទី បាត់ដឹង ពុំមែនបាត់ផ្ទៃដីងនោះឡើយ)។ ខ្ញុំបាទជាអ្នកស្រាវជ្រាវ គ្រាន់តែចង់បន្ថែមរឿងរ៉ាវខ្លះៗ ដែលទាក់ទងនឹងឈ្មោះភូមិស្រុក ធម្មជាតិ រុក្ខជាតិ ទំនៀមទម្លាប់....... មកផ្គុំ ផ្គុំរឿងដែលហាន់ជាចំណិតៗនោះ កកើតបានជារូបរាង អាចឲ្យមិត្តអ្នកអាន មើលឆាប់យល់នូវសារតាបណ្ដាំព្រះម៉ែនេះ។

**២២.ភ្នំអដ្ឋារស ឬរាជ្យទ្រព្យ** (ខេត្តកណ្ដាល)

អាថ៌កំបាំងភ្នំនេះ ខ្ញុំបានពន្យល់ពីទំព័រខាងដើមរួចខ្លះហើយ ដើម្បីឲ្យកាន់តែច្បាស់ ខ្ញុំគ្រាន់តែលើកយកនូវហេតុភេទ ដែលកើតមានរួចយកមកពន្យល់បន្ថែម នៅក្នុងអាថ៌កំបាំងភ្នំនេះ តាមឯកសារសាវតាស្រុកបរិបូណ៌ ក្នុងសាវតាទាក់ទងនឹងភូមិសាស្ត្រខ្មែរ ដែលរៀបរៀងដោយលោក **ឌ គាម** គាត់បានសរសេរថា ព្រះចន្ទរាជាបានឲ្យគេបោះបន្ទាយទ័ព នៅភ្នំព្រះរាជ្យទ្រព្យ(អដ្ឋារស) ពេលដែលព្រះអង្គគង់នៅភ្នំនោះ ទ្រង់បានទតឃើញ**ពន្លឺកែវមនោ** ដ៏អស្ចារ្យដែលជាបុព្វនិមិត្តរបស់ព្រះម៉ែ។ ប៉ុន្តែស្ដេចអង្គនោះ ពុំយល់ពីអត្ថន័យពន្លឺកែវមនោ ដែលផ្សាយចេញពីភ្នំនោះ គាត់ក៏សន្និដ្ឋានថា ជាពន្លឺនៃជ័យជម្នះរបស់ខ្លួនទៅវិញ ប៉ុន្តែតាមពិត ព្រះម៉ែគាត់ខំសម្ដែងឫទ្ធិ ដើម្បីឲ្យកូនជាស្ដេចដឹងថា គាត់នៅជាប់ឃុំឃាំងក្នុងភ្នំនេះ។ អភូតហេតុដែលកើតឡើងនេះហើយ បានធ្វើឲ្យកូនខ្មែរនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ទីបំផុត បានឮដល់ពួកបរទេស ដែលគេខំស្រាវជ្រាវរកបង្កើយនេះ ដើម្បីបិទសន្ដប់ជាយូរយារមកហើយ។ ទើបកាលជាខាងក្រោយ ពួកគេមកសុំសាងពុទ្ធបដិមាមួយអង្គ មានកំពស់១៨ហត្ថព្រះសុគត សន្ធប់បិទរូងភ្នំនោះ ទើបមានឈ្មោះថ្មីថាភ្នំអដ្ឋារស (ហៅតាមកំពស់ពុទ្ធបដិមា)។ ហេតុអ្វីបានជាព្រះម៉ែខំបញ្ចេញពន្លឺឲ្យកូនឃើញ? ហេតុតែចង់ឲ្យកូនជួយគាត់ ព្រោះស្ដេចជាអ្នកទទួលមរតកគាត់ បានមកបោះទីតាំងនៅភ្នំនេះ ដោយគាត់សង្ឃឹមថាកូនគាត់នឹងដឹងហើយជួយ ព្រោះគាត់ចេញពុំរួច ប៉ុន្តែមិនដូច្នោះទេ ស្ដេចបែរជាយល់ថា ជាពន្លឺនៃជោគជ័យរបស់ខ្លួនទៅវិញ។ រឿងរ៉ាវអភូតហេតុនិមិត្តនេះ បានកើតមានម្ដងទៀត នៅពេលដែលស្ដេចអង្គនោះ ប្រទានរង្វាន់យសសក្តិដល់ខ្ញុំ

រាជការ ដែលបានជួយធ្វើសង្គ្រាមឲ្យព្រះអង្គ។ ពេលនោះ បានបង្កើតឲ្យមានហេតុចម្លែកអស្ចារ្យ គឺថ្ងៃរះ ចែងចាំងពុំមានភ្លៀង ប៉ុន្តែមានឥន្ទធនូចុះនៅក្នុងទីនោះ មានរស្មីភ្លឺរន្ទាលច្រាលដាលច្រវ៉ាត់ លុះតែង តាំងមន្ត្រីរាជការហើយ ពន្លឺឥន្ទធនូនោះ ក៏រលាយបាត់ទៅវិញ។ រឿងហេតុភេទនេះ កើតមានក្នុងខេត្ត



ភ្នំអដ្ឋរស មើល ពីលើរាង ដូចពស់

អម្រាក់តិរិន្ទបូណ៌ ពេលនោះ ព្រះរាជាក៏បានកែឈ្មោះខេត្តនោះ ដាក់ថា ខេត្តបរិបូណ៌វិញ ទៅតាមហេតុភេទនិមិត្តនោះ សព្វថ្ងៃខេត្តនោះហៅថា ស្រុកបរិបូណ៌ ក្នុងខេត្តកំពង់ឆ្នាំង។

ឯរូបរាងភ្នំអដ្ឋារស មើលពីខាងលើ ដូចជាសត្វពស់ ឬនាគបើក ពពារ ដែលបែរក្បាលទៅរកពុទ្ធមណ្ឌលវិបស្សនា ឯកន្ទុយនាគនៅម្ដុំព្រះ វិហារអដ្ឋារស ដែលគេបិទសន្ធប់ពីសម័យមុននោះ។ រូបភាពភ្នំអដ្ឋារស មើលពីខាងលើនេះ មាននៅក្នុងឯកសារ (ខ្ញុំចង់ដឹងពីជនជាតិខ្មែរភាគពីរ និពន្ធដោយលោក Paul Brunon និងស៊ុនហេង ម៉េងឈាង) ហើយរឿង ព្រេងដែលទាក់ទងនឹងភ្នំនេះ កូននាគទាំងឡាយសូមអ្នកស្រាវជ្រាវរក មើលក្នុងប្រជុំរឿងព្រេងខ្មែរ រួចត្រិះរិះពិចារណាជាបន្ថែមទៀតចុះ។

## ២៣.ភ្នំនាងកង្រី (ខេត្តកំពង់ឆ្នាំង)

ភ្នំនេះខ្ញុំបាទជាអ្នកស្រាវជ្រាវពុំបានទៅដល់ទីនោះឡើយ គ្រាន់តែឈរសម្លឹងមើលពីចំងាយតែ ប៉ុណ្ណោះ យើងដឹងហើយថា ភ្នំនេះឈ្មោះកង្រី ហើយនាងកង្រីនេះ គឺជាកូនយក្សឈ្មោះនាងសន្ធមារ។ យក្សសន្ធមារនេះហើយ ដែលបានខ្វេះយកគ្រាប់កែវភ្នែកមាតាទាំង១២ រួចផ្ញើរកែវភ្នែកមាតាទាំង១២ នេះ ទៅឲ្យកង្រីជាកូនអ្នកថែរក្សាទុក។ រឿងរ៉ាវទាំងអស់នេះ ដែលកើតឡើងតៗគ្នា ពីមួយជំនាន់ទៅ មួយជំនាន់ ធ្វើឲ្យកកើតផ្ដុំពូនបានទៅជាភ្នំ(ភ្នំនាងកង្រី) ហើយយើងអាចដឹងរឿងព្រះម៉ែមហានគរ និង រឿងមាតាទាំង១២ លុះត្រាតែបានកែវភ្នែក គឺបញ្ញា ដែលនាងកង្រីបានលាក់ទុកនោះ មកបញ្ចូលឲ្យ ពួកគាត់វិញទើបភ្លឺ នេះជាបណ្ដាំប្រស្នារបស់គាត់។ ហើយអាថ៌កំបាំងរបស់រឿងនេះ មាននៅក្នុងល្បែង ក្មេងលេងមួយ គឺល្បែង **បាយខុំ ឬបាយខុន** ព្រោះល្បែងបាយខុំមុននឹងលេង គេត្រូវជីកគ្រលុកដូចជា

គ្រលុកគ្រាប់ភ្នែក ដែលត្រូវគេខ្វេះ រួចយកគ្រាប់មូល តំណាងឲ្យគ្រាប់ភ្នែកមាតាទាំង១២ ទៅដាក់ក្នុងរន្ធនោះ ទើបគេនាំគ្នាខ្វេះយកគ្រាប់នោះ ចេញមកវិញ(នេះជាប្រស្នា ទាក់ទងនឹងរឿងគ្រាប់ភ្នែកមាតាទាំង១២ ដែលយក្សខ្វេះយក)។ ចំណែកឯមរតកជាចំណងដៃវិញ ក្នុងពិធីមង្គលការ ជូនតា និងមាតាបិតាខ្មែរ រួមទាំងសាច់សាលោហិត បានទុកប្រស្នានេះ ក្នុង **បទបាយខុន** ឬខុំក្នុងពិធីចងដៃកូនប្រុសស្រី ដោយពួកគាត់ចង់ប្រាប់ថា យើងជាពូជនាគចងដៃបន្តគ្នា ឬកាន់ដៃតគ្នា ក្នុងភាពងងឹត (ដែលយក្សខ្វេះកែវភ្នែក គឺបញ្ញា ) ហើយបញ្ចប់ចុងក្រោយ គឺលុបដាន សាដាន លក់ដាន (បទលុបដាន មូរកន្ទេល លក់កន្ទេល ក្នុងពិធីព្រះថោងតោងស្បៃនាងនាគ)។

## ២៨.ភ្នំដូនពេញ (ភ្នំពេញ)

ប្រវត្តិទាក់ទងនឹងទីក្រុងភ្នំពេញ កើតចេញពីរឿងរ៉ាវរបស់ម្ចាស់ភ្នំដំបូង គឺដូនពេញ ចំណែកពាក្យថាពេញ គឺវាផ្ទុយគ្នាពីកន្លះ ពីមុនទីក្រុងភ្នំពេញ មិនមានមនុស្សរស់នៅច្រើនដូចសព្វថ្ងៃនេះទេ។ ប៉ុន្តែក្នុងបច្ចុប្បន្នពាក្យភ្នំពេញនេះ ពិតជាត្រឹមត្រូវតាមឈ្មោះ ហើយមិនត្រឹមតែពេញទេ គឺហៀរហូររហូតមកខាងក្រៅក្រុង ខុសពីជំនាន់អតីតកាល សូម្បីតែបឹងដែលពុំធ្លាប់មានមនុស្សរស់នៅ ឥឡូវក្លាយជាគេហដ្ឋានស្កឹមស្កៃ ហើយច្រើនស្អេកស្កះ។ បើយើងក្រឡេកមើលអតីតប្រវត្តិរបស់ភ្នំនេះ គឺជាស្ត្រីម្នាក់ឈ្មោះពេញជាអ្នកផ្ដើមដំបូង ដែលសព្វថ្ងៃគាត់បានក្លាយទៅជាជីដូន ឬដូនពេញ ហើយជីដូននេះ គាត់ជាអ្នកបានទទួលមរតក ពីព្រះម៉ែមហានគរ ពេលណាភ្នំនេះពេញតាមឈ្មោះ ពេលនោះព្រះម៉ែ នឹងរួចផុតពីទុក្ខទោសពីអតីត។

ការរៀបរាប់អំពីឈ្មោះភ្នំ ទោះបីជាខ្ញុំបាទពុំបានលើកយកមកពន្យល់ឲ្យបានគ្រប់ភ្នំ ក៏ឯកសារសៅវតានេះ ជាប្រទីបមួយសម្រាប់ឲ្យកូននាគប្រុសស្រី ដែលបានតាមដានអាន ទុកធ្វើជាទុនសំរាប់ត្រិះរិះគិតពិចារណាស្វែងយល់ ទៅលើអ្វីដែលទាក់ទងក្នុងបណ្ដាំរឿងអាថ៌កំបាំងរបស់ព្រះម៉ែ។ គាត់ខំបំពេញពលិកម្មគ្រប់បែបយ៉ាង ដើម្បីកូននាគប្រុសស្រី ដែលរស់ក្នុងមាតុភូមិរបស់គាត់នេះ ដូច្នេះសូមឲ្យគុណព្រះមាតាបិតា ដែលធំដូចស្ដេចភ្នំ ចូលទៅស្ថិតក្នុងសន្ដានចិត្តកូននាគប្រុសស្រីគ្រប់ស្រទាប់វណ្ណៈ ជាពិសេស គឺអាថ៌កំបាំងបណ្ដាំរបស់ព្រះម៉ែមហានគរនេះ។ កូននាគទាំងឡាយ ពេលនេះអ្នកដឹង

ពី**សារជាតិ**ខ្មែរជាពូជនាគហើយ ពីមុនយើងពុំបានចាប់អារម្មណ៍ឡើយ ព្រោះយើងគិតថាពូជនាគស្ថិតនៅប្រទេសផ្សេងឯណោះ តាមពិត គឺកូនខ្មែរប្រុសស្រីនេះឯង ដែលជាពូជព្រះនាងនាគពូជអ្នកប្រសើរ ពូជអ្នកកសាងប្រាសាទថ្ម ពូជចក្រភព ហើយចុងក្រោយ គឺជា**ពូជអច្ឆរិយៈ សូមកូនជាគ្រប់រួមគ្នាជួយអាធិទេពអ្នកបង្កើតភាពអច្ឆរិយៈគអច្ឆរាមាតាមហានគរ។**

**IV.** ខ្ញុំនឹងលើកយកឈ្មោះរបស់បឹង ធម្មជាតិ ភូមិស្រុក.... ដែលមានទាក់ទង នឹងរឿងរបស់ព្រះម៉ែ មកបកស្រាយបំភ្លឺ ដើម្បីទុកជាទុនសំរាប់ត្រិះរិះពិចារណា រាវរករឿងពិតរបស់ខ្លួនជាបន្តទៅទៀត។

ក.**បឹងប្រស្នា** (ខេត្តព្រៃវែង)

បឹងប្រស្នានេះ បានប្រតិស្ឋានទុកក្នុងភូមិប្រស្នាធំ (ទីកើតនូវប្រស្នាធំ) ឃុំសេនារាជឧត្តម ស្រុកព្រះស្តេច ខេត្តព្រៃវែងដែលទឹកដីនេះ ពីអតីតកាលជារាជធានីចាស់របស់ចក្រភពខ្មែរបាភ្នំ។ ចុះហេតុអ្វីបានជាដូនតាយើង ដាក់ឈ្មោះថាបឹងប្រស្នា? ខ្ញុំបានពន្យល់ត្រួសៗតាំងពីភាគទី១ រហូតមកទល់នឹងពេលនេះ គឺទាក់ទងនឹងរឿងបណ្តាំប្រស្នារបស់ព្រះម៉ែ ហើយរឿងប្រស្នានេះ យើងពុំបានដឹងទីតាំងរបស់ឈ្មោះនោះត្រង់ណាឡើយ។ ទើបតែថ្ងៃ៨កើត ខែពិសាខ ឆ្នាំរកា ព.ស ២៥៤៩ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា គ.ស២០០៥ នៅក្នុង**ភូមិប្រស្នាធំ**នេះប្រជាជននាំគ្នាស្តារបឹងដែលរាក់ឲ្យជ្រៅឡើងវិញ ដើម្បីតម្កល់ទឹកទុកប្រើប្រាស់នៅរដូវប្រាំង ដោយប្រើប្រាស់អង្គរពលកម្ម។ ពេលនោះពួកគាត់ ជីកបានរូបចម្លាក់ថ្មព្រះវិស្ណុផ្ទំលើនាគ ហើយគងលើស្ត្រីជាព្រះម៉ែ ដែលនៅកណ្តាលផ្ចិតរូប មានផ្កាឈូកមួយទងរីកទ្រព្រះព្រហ្មកំពុងអង្គុយសមាធិ (រឿងព្រះវិស្ណុដេកនេះខ្ញុំបានពន្យល់ក្នុងទំព័រខាងដើមខ្លះហើយ) តើបឹងប្រស្នានៅទីនោះមានប៉ុន្មាន? បឹងប្រស្នានៅទីនោះ មានបី គឺបឹងប្រស្នាតូចពីរ និងបឹងប្រស្នាធំមួយ។


**ចម្លាក់វិស្ណុផ្ទំនៅបឹងប្រស្នា**

១.បឹងប្រស្នាទីមួយ គឺជាបឹងតូចល្មម ដែលសព្វថ្ងៃមានដុះប្រលិតតូចធំ និងវារីជាតិផ្សេងៗទៀតជាច្រើន បឹងនេះទាក់ទងទៅនឹងរឿងមង្គលបី សិរីបីប្រការក្នុងបឹងទី១ ទាក់ទងមង្គលទី១ ឬសិរីទី១

២.បឹងប្រស្នាទីពីរមានទំហំប្រហាក់ប្រហែលនឹងបឹងប្រស្នាទីមួយដែរ តែបឹងនេះ មានទីតាំងនៅរៀងបន្ទាប់គ្នា អត្ថន័យរបស់បឹង គឺទាក់ទងនឹងមង្គលទី២ ឬសិរីទី២។

៣.បឹងប្រស្នាទីបី គឺជាបឹងធំជាងបឹងតូចទាំងពីរ ដែលប្រជាជនក្នុងភូមិនោះ បានទៅជីកស្តារហើយគាស់បានរូបព្រះវិស្ណុដេកនោះ ដែលរូបនោះកប់នៅចំកណ្តាលផ្ចិតបឹង នៅទីនោះមានគល់គ្រាក់មួយដើម ដែលបានកប់ជ្រៅទៅក្នុងដីមិនដឹងមានជម្រៅប៉ុន្មានដែលសព្វថ្ងៃនេះ មិនទាន់មានអ្នកណាហ៊ានទៅគាស់គល់គ្រាក់នោះឡើយ (គ្រាក់លុប ➜ គ្រប់លាក់)។ បឹងនេះ ទាក់ទងនឹងមង្គលទី៣ ឬសិរីទី៣ ហើយរឿងទាំងអស់នេះ បានលាក់កំបាំងយ៉ាងស្ងាត់ស្ងៀម សូម្បីតែប្រជាជនដែលរស់នៅក្នុងភូមិនោះ ក៏ពុំដឹងរឿងដែលទាក់ទងនឹងឈ្មោះបឹងប្រស្នានេះឡើយ។ ពាក្យបឹងប្រស្នានេះ ជាពាក្យមានជំរៅបើគ្រាន់តែឮ គឺពុំអាចចាប់អារម្មណ៍នឹងពាក្យនេះឡើយ ព្រោះយើងពុំនឹកស្មានថា ពួកគាត់បានបង្កប់នៅក្នុងឈ្មោះ ហើយឈ្មោះដដែលនេះ ដែលយើងអាចយល់ និងស្គាល់ក៏ដោយសារគាត់បានរូបព្រះវិស្ណុផ្ទុំនៅទីនោះ បើមិនដូច្នោះ គឺខ្ញុំបាទពុំអាចស្គាល់ភូមិ.បឹងប្រស្នា ដែលជាឫសគល់ដើមនៃអាថ៌កំបាំងខ្មែរនេះបានឡើយ ព្រោះពួកគាត់បន្សល់ទុកឈ្មោះនេះ សម្រាប់ឲ្យយើងជាកូននាគឆ្ងល់ រួចធ្វើការស្រាវជ្រាវរករឿងពិត ដើម្បីដោះប្រស្នារបស់គាត់។

រូបព្រះវិស្ណុនោះ គេឆ្លាក់រាងជាផ្ទាំងសំប៉ែត ហើយគេធ្វើដុំថ្មបីជាន់ ដែលមានជន្លួញត្រណាប់ស៊កបន្តគ្នា ដែលជាន់ទីបីខាងលើ គឺជាផ្ទាំងរូបចម្លាក់បានន័យថា ថ្មពីរផ្ទាំងខាងក្រោមប៉ុនគ្នា ឯផ្ទាំងទីបីដែលមានរូបចម្លាក់ស្តើងជាង ព្រោះត្រូវយកទៅស៊ក នៅលើជើងទម្រទាំងពីរ។ ក្នុងដុំថ្មទាំងពីរដែលជាទម្រនោះ នៅបាតបន្ទាប់មានដាក់កថាមាសចំនួនច្រើនសន្លឹក(មាសផ្កាកប្បាស) ហើយក្នុងកថានីមួយៗមានឆ្លាក់រូបផ្សេងៗគ្នា កថាទីមួយមានរូបនាគកំពុងហែលឡើងទៅលើ រូបនាគនេះមានឆ្លាក់នៅលើបាំងក្លែងប្រាសាទបន្ទាយស្រី កថាសន្លឹកទីពីរមានរូបអណ្តើក ដែលទាក់ទងនៅក្នុងរឿង កូរសមុទ្ទទឹកដោះស្វែងរកទឹកអម្រឹត សន្លឹកកថាទីបីមានរូបផ្កាឈូករីក រូបនេះឃើញមាននៅក្នុងដៃស្ត្រីគ្រប់

លក្ខណៈ និងរូបឆ្នាំនៅលើជញ្ជាំងប្រាសាទបន្ទាយស្រី សន្លឹកកថាទីបួនមានរូបត្រី រូបត្រីនេះ មាននៅក្នុងរឿងកូរសមុទ្រទឹកដោះ និងសង្គ្រាមជាមួយចម្ប៉ានៅបាយ័ន ចំណែកឯសន្លឹកកថាដទៃទៀត ខ្ញុំពុំបានឃើញឡើយ ដោយពួកគាត់បានយកទៅរំលាយ ស្មានថាជាមាសទឹកដប់ ព្រោះ ដូនតាខ្មែរពីសម័យដើមគាត់ពូកែឲ្យទឹកមាសណាស់។ រឿងរូបក្នុងកថាមាស ដែលបង្កប់នៅក្នុងត្រណាប់ថ្មទម្រ គឺជារឿង ប្រស្នាអាថ៌កំបាំង ដែលខ្ញុំបានរៀបរាប់ជាហូរហែក្នុងឯកសារសាវតានេះ ដែលទាក់ទងរូបព្រះវិស្ណុជិះព្រះម៉ែចេញ ហើយរូបនេះ តែងតែមានឆ្លាក់នៅគ្រប់ទីកន្លែងនៃប្រាសាទ និងមានច្រើនបំផុតនៅបាតស្ទឹងភ្នំគូលែន ត្រង់លិង្គ១០០០។

ផ្លូវចូលទៅកាន់បឹងប្រស្នានោះមានផ្លូវពីរ មួយចូលតាមវត្តគោកសំពៅ ឬសំពៅគោក ឯផ្លូវទីពីរចូលតាមផ្លូវប្រមូលព្រហ្ម តើប្រមូលព្រហ្មមានន័យយ៉ាងដូចម្ដេច? អាចដោះប្រស្នាភូមិបឹងទាំងនោះបាន ត្រូវប្រមូលព្រហ្ម ដែលបែកខ្ញែកឲ្យមូលគ្រប់ទាំងបួនវិញ ទើបអាចបំបែកប្រស្នានេះបាន។ តើភូមិតំណាងឲ្យអ្វី? ភូមិតំណាងឲ្យទីកើត ទីប្រសូតនៃពាក្យប្រស្នានេះ តើបឹងតំណាងអ្វី? បឹងតំណាងឲ្យសមុទ្រទឹកដោះ ឬទីឃុំឃាំង ដែលគេបានចាប់ព្រះម៉ែយកទៅឃុំទុករាប់ពាន់ឆ្នាំនោះ គាត់ពុំមែនត្រឹមតែនៅក្នុងទឹកប៉ុណ្ណោះទេ គឺថែមទាំងកប់ក្នុងភក់ថែមទៀត (ថ្មភក់ ឬភក់ថ្ម) ដែលរូបនេះ មានក្នុងក្បាំងក្លែងប្រាសាទបន្ទាយស្រី។ នៅភ្នំគូលែនមានព្រៃមួយឈ្មោះថា ព្រៃទេវតានៅក្នុងព្រៃនោះ ដូនតាគាត់បានឆ្លាក់រូបព្រះវិស្ណុផ្ទុំជិះព្រះម៉ែចេញ តើអ្នកដឹងពីអត្ថន័យ ពាក្យព្រៃទេវតា និងរូបព្រះវិស្ណុផ្ទុំនេះទេ?

ខ.ព្រៃទេវតាមានន័យថា សមាជិកសមាជិកាគណបក្សដែលមាននិមិត្តរូបទេវតាតំណាងឲ្យគណបក្សប្រជាជន ដែលមានចំនួនសមាជិកច្រើននោះគឺព្រៃមនុស្ស ពាក្យនេះគេច្រើនប្រើក្នុងសម័យប៉ុលពតឬសម័យតស៊ូប្រឆាំងនឹងបរទេស ព្រោះលាក់ខ្លួនក្នុងព្រៃធម្មជាតិ ពុំជិតដូចលាក់ក្នុងព្រៃមនុស្សឡើយព្រៃមនុស្ស គឺព្រៃប្រជាជននោះឯង។ ដូចនៅក្នុងក្បួនពុទ្ធទំនាយបានសរសេរថា ដល់ពេលដែលស្ដេចមានឫទ្ធិអាចប្រើភ្លើង ប្រើទឹក ប្រើខ្យល់ ប្រើខ្មោចបាន ពេលនោះនឹងមានចោរឃ្មួញចេញពីព្រៃ។ ក្នុងន័យនេះគាត់ចង់ប្រាប់ថា ចោរលួចចោរប្លន់ គឺចេញពីព្រៃមនុស្សនេះឯងគឺប្រជារាស្ត្រ ពុំមែនចេញពីព្រៃភ្នំធម្មជាតិនោះទេ ព្រោះពាក្យនេះជាពាក្យប្រស្នាបំប្លែងរបស់ដូនតា។ ហេតុអ្វីបានជាមានរូបព្រះវិស្ណុផ្ទុំ នៅក្នុងព្រៃទេវតា? ន័យបំប្លែងពាក្យរបស់ដូនតាគាត់ចង់ពន្យល់ថា ព្រះវិស្ណុដេក

នៅក្នុងព្រៃទេវតា គឺនៅក្នុងព្រៃមនុស្សរបស់គណបក្សប្រជាជន ដែលមានរូបទេវតាជានិមិត្ត។ គាត់លាក់ខ្លួនក្នុងព្រៃទេវតាដើម្បីជួយព្រះម៉ែ ដែលជាប់ឃុំឃាំងក្នុងសមុទ្រទឹកដោះ(ពន្យល់រួចហើយ) ហើយរូបចម្លាក់នេះ ខ្ញុំបានមើលប៉ះដោយចៃដន្យ នៅក្នុងទស្សនាវដ្តីបរទេសមួយ ខ្ញុំបាទពុំនឹកស្មានថា ដូនតាខ្មែរគាត់មាននូវ**បុព្វេនិវាសានុស្សតិ** (រលឹកជាតិបាន) ទៅអនាគតដ៏វែងឆ្ងាយដល់ម្លឹង ទើបគាត់ឆ្លាក់រូបក្នុងព្រៃទេវតា(ឈ្មោះជានិមិត្តរូប) ទុកឲ្យយើងឆ្ងល់រួចគិតត្រិះរិះពិចារណា ស្រាយប្រស្នារបស់ពួកគាត់។

### គ.**កំចាយមារ**

ពាក្យកំចាយមារនេះ ជាឈ្មោះរបស់ស្រុកមួយក្នុងខេត្តព្រៃវែង (**ស្រុកកំចាយមារ**) និងជាឈ្មោះរបស់ភ្នំមួយ នៅក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុគឺ**ភ្នំកំចាយមារ**។ តើពាក្យកំចាយមារមានអត្តន័យដូចម្តេច?

**ពន្យល់ពាក្យ** (កំចាយមារ)

កំចាយ =កម្ចាយ = ធ្វើឲ្យខ្ចាត់ខ្ចាយ

កំចាយមារ ឬកម្ចាយមារ= គឺធ្វើឲ្យមារឬយក្សក្រុងរាពណ៍នោះបែកខ្ចាត់ខ្ចាយអស់

ហើយមារនេះឯងដែលជាម្ចាស់នៃពៀរបានចាប់ព្រះម៉ែមហានគរ យកទៅឃុំឃាំងទុករាប់ពាន់ឆ្នាំក្នុងសមុទ្រទឹកដោះរហូតរឿងរបស់គាត់ពូនបានទៅជាភ្នំហើយអ្នកព្យាយាមកំចាយមារដើម្បីជួយព្រះម៉ែសេចក្តីព្យាយាមរបស់គាត់ក៏ពូនទៅជាភ្នំដែរ សព្វថ្ងៃភ្នំនេះនៅជាប់ក្នុងជួរភ្នំបូកគោ។ ហេតុអ្វីបានជាស្រុកកំចាយមារ នៅក្នុងខេត្តព្រៃវែង? ព្រោះអំណាចរបស់ក្រុងមារបានពូនទៅជាភ្នំ ចង់កំចាយនូវមារនោះដើម្បីជួយព្រះម៉ែ កូននាគនោះត្រូវសម្ងំលាក់ខ្លួនក្នុងព្រៃមនុស្សដ៏វែងដើម្បីប្រយុទ្ធតតាំងនឹងមារ(ព្រៃវែង)ព្រោះមារបានចាប់ម្តាយឃុំទុករាប់ពាន់ឆ្នាំហើយនេះខ្ញុំគ្រាន់តែបកស្រាយពាក្យបំភ័ន្តរបស់ដូនតា ដើម្បីរាវរករឿងពិតរបស់ព្រះម៉ែតែប៉ុណ្ណោះ សូមមិត្តអ្នកអានជួយពិចារណានូវឈ្មោះទាំងអស់ ដែលដូនតាបានបន្សល់ទុកឲ្យយើងជាកូននាគកំពុងរស់នៅសព្វថ្ងៃ ឲ្យជួយស្រាយប្រស្នាពួកគាត់។

ឃ. ក្របៅ

ក្របៅនេះ ក៏ជាឈ្មោះសំគាល់ភូមិស្រុកមួយ នៅក្នុងខេត្តព្រៃវែង តើពាក្យក្របៅនេះ មានន័យពិតយ៉ាងដូចម្ដេច?

***ពន្យល់ពាក្យ*** (ក្របៅ)

ក្របៅ = ឈ្មោះផ្លែឈើមួយប្រភេទដែលអាចបរិភោគបាន

ក្របៅ = ដុំម្សៅដែលសម្រាប់ធ្វើនំបញ្ចុកដែលគេលញ់ផ្ដុំជាដុំៗ បម្រុងនឹងស្ងោរ(ក្របៅនំបញ្ចុក)

ក្របៅ = មិនងាយបៅ(កូនកើតមក វាក្របៅដោះម៉ែ)

បើកូននាគប្រុសស្រី ដែលជាអ្នកទទួលមរតកព្រះម៉ែពុំព្រមនាំគ្នាបៅដោះព្រះម៉ែទេ(ហូបបាយដឹងគុណព្រះមេ) តើពេលណាទើបស្គាល់ព្រះម៉ែជាម្ចាស់ដោះ? ដូច្នេះយើងជាកូនខ្មែរប្រុសស្រី បានត្រឹមតែរស់ក្នុងភូមិព្រះម៉ែ បានទទួលកេរពីព្រះម៉ែ តែពុំស្គាល់គាត់ដែលជាម្ចាស់ដោះនោះឡើយ ហើយមិនត្រឹមតែប៉ុណ្ណឹងទេ កូនខ្លះហ៊ានជេរប្រមាថមាក់ងាយដល់ម្ចាស់ដោះនេះថែមទៀតផង។ ឈ្មោះភូមិស្រុក ភ្នំ ធម្មជាតិ ប្រពៃណី ទំនៀមទម្លាប់... តែងរស់នៅជាមួយនឹងយើងរាល់ថ្ងៃ យើងក៏មិននឹកស្មានថាមរតកទាំងនេះបានបង្កប់នូវបណ្ដាំប្រស្នាព្រះម៉ែដ៏មានជម្រៅយ៉ាងនេះឡើយ។

## V. ១. បុណ្យអុំទូក លយប្រទីប សំពះព្រះខែ អកអំបុក (អំបុក)

មានពិធីបុណ្យមួយទៀត ដែលទាក់ទងនឹងរឿងក្នុងប្រស្នាព្រះម៉ែនេះដែរ គឺបុណ្យអុំទូក លយប្រទីប សំពះព្រះខែ អកអំបុក តើកូននាគទាំងឡាយអ្នកមានឆ្ងល់ដែរឬទេ? ហេតុអ្វីបានជាគាត់សន្មត់យកថ្ងៃពេញបូណ៌មីខែកត្តិកធ្វើពិធីបុណ្យនេះ? ហេតុអ្វីបានជាដូនតាយើង ធ្វើខុសពីថ្ងៃសែនលោកខែចិន? នេះហើយជាប្រស្នា ដែលដូនតាយើងបន្សល់ទុកមក ហើយខ្ញុំបាទអ្នកស្រាវជ្រាវចេះតែមានចម្ងល់ដើម្បីជួយរាវរកអាថ៌កំបាំងក្នុងបុណ្យនេះ តើគាត់មានបង្កប់ន័យប្រស្នាអ្វីខ្លះ? ដូនតាយើង

គាត់បានខ្ចីសម្លៀកបំពាក់ គឺសំពត់ព្រហ្មញ្ញសាសនា និងអាវព្រះពុទ្ធសាសនា (ទាំងពីរនិកាយ) មកលាក់បិទបាំងរូបរឿងពិតរបស់ខ្លួន (ព្រះម៉ែមហានគរ)។

**ពន្យល់ពាក្យ** (កត្តិក)

កត្តិក= ឈ្មោះខែទី១២ តាមចន្ទគតិ

ឬក្បូកត្តិកា = មាន៣០ (ផ្ទៃផ្កាយកូនមាន់)

តើខែកត្តិកមានបង្កប់ន័យអ្វីទុកនៅក្នុងពិធីបុណ្យទាំងនេះ?

**ក.អកអំបុក**

ក្នុងរាត្រីនៃថ្ងៃពេញបូណ៌មី ខែកត្តិក សម័យពីដើមទាំងស្រីទាំងប្រុស ទាំងចាស់ទាំងក្មេង បាននាំយកនំនែក ស្ករ អំពៅ ដូង.... រួមទាំងអំបែង ត្បាល់ អង្រៃ និងឧបករណ៍ផ្សេងៗទៀត ទៅជួបជុំគ្នានៅក្នុងទីវត្តអារាម។ ពេលជួបជុំគ្នាហើយពួកគេចាប់ផ្ដើមលីងស្រូវ រួចបុករែងទៅតាមជំនាញរបស់ពួកគេ ចាស់ៗរៀបចំគ្រឿងសក្ការៈផ្សេងៗ ដើម្បីបូជាគុណព្រះរតនៈត្រៃ និងសម្រាប់ថ្វាយដល់ព្រះពោធិសត្វសសបណ្ឌិត(ទន្សាយ) កាលព្រះបរមគ្រូនៃយើងព្រះអង្គនៅបំពេញបារមីនៅឡើយ។ ដល់វេលាខែពេញពន្លឺ គេចាប់ផ្ដើមនាំគ្នានមស្ការព្រះរតនត្រៃ និងសមាទានសីលទៅតាមឧបនិស្ស័យរួចនាំគ្នាដុតទៀនធូប ដើម្បីផ្សងមើលទឹកភ្លៀងនិងបួងសួងដល់ម្ចាស់ទឹកម្ចាស់ដី និងវត្ថុសក្តិសិទ្ធិ សុំសេចក្ដីសុខរៀងៗខ្លួន។ ពិធីអកអំបុកក៏មកដល់ ពួកកំលោះក្រមុំ ដែលមានសេចក្ដីក្លាហាន ឡើងទៅឈរងើយដើម្បីឲ្យគេអក អ្នកណាដែលឈ្នះនឹងបានទទួលនូវរង្វាន់ដែលមានចេក ដូង ស្ករ អំពៅ.... សម្រាប់អ្នកឈ្នះក្នុងការអកនោះ។ ប៉ុន្តែខ្ញុំបាទសុំសួរថា ពេលដែលអ្នកអកងើយមុខទៅលើដើម្បីឲ្យគេយកអំបុកទៅអកនោះ តើពួកគេមានឆ្ងល់ថា ហេតុអ្វីបានជាគេអកអំបុកក្នុងថ្ងៃពេញបូណ៌មី ខែកត្តិកនេះ? ហើយគេមិនធ្វើក្នុងខែដទៃ? អ្នកអកច្បាស់ជាពុំបានគិតពិចារណានូវអាថ៌កំបាំងនៃបណ្ដាំប្រស្នាព្រះម៉ែនេះឡើយ ព្រោះចិត្តអ្នកអកកំពុងចង់បានរង្វាន់ នៅពេលដែលឈ្នះនេះជា**លោភមូលចិត្ត** របស់បុថុជ្ជន។ ដូនតាយើងគាត់ចង់ប្រាប់ថា បានជាពួកគាត់ទុកនៅទំនៀមទម្លាប់បុណ្យនេះក្នុងខែកត្តិក

ព្រោះគាត់ចង់ឲ្យកូននាគទាំងឡាយដែលកំពុងងើយមើលទៅលើក្នុងពេលអកអំបុកនោះ កូននាគមានឆ្ងល់ទេ ផ្កាយកូនមាន់ដែលតំណាងឲ្យខែកត្តិក តើមេរបស់ពួកវា(មេមាន់) បាត់ទៅណាបានជាទុកកូនឲ្យនៅវញ្ញង់ដូច្នេះ តើគេចាប់មេមាន់យកទៅក្រុងឃុំនៅឯណា? មេនេះគេចាប់ឃុំនៅឯប្រាសាទគុករកា (**គុកដាក់មាន់**) នៅក្នុងខេត្តកំពង់ធំឯណោះ ចំណែកឯខែពេញបូណ៌មីវិញ គាត់ចង់ប្រាប់យើងថាពន្លឺខែលើមេឃភ្លឺចែងចាំងដូចថ្ងៃ រួមទាំងពន្លឺប្រទីប ដែលដុតនៅលើដីថែមទៀត ក៏មិនអាចឲ្យកូននាគមើលឃើញនូវរឿងពិតរបស់ព្រះម៉ែឡើយ ដោយយើងកើតចេញពីម៉ែទាំង**១២** ដែលយក្សបានខ្វេះកែវភ្នែក គឺបញ្ញាចេញអស់ហើយ តើមានប្រយោជន៍អ្វីចំពោះពន្លឺព្រះច័ន្ទ ក្នុងដួងខែពេញបូណ៌មី និងពន្លឺប្រទីបដែលដុតនៅលើដី និងបណ្តែតនៅលើទឹកនោះ។

## ខ.អុំទូក ឬទូកអុំ

ហេតុអ្វីពិធីបុណ្យអុំទូកនេះ គេធ្វើតែនៅក្នុងខែកត្តិកនេះដែរ? ខ្ញុំបានពន្យល់ពីទឹកចិត្តម៉ែឪដែលបានគ្របដណ្តប់ទៅលើកូនប្រុសស្រីរួចហើយ តែពេលនេះខ្ញុំចង់ឲ្យកូននាគបានស្គាល់ពីប្រស្នាក្នុងបុណ្យអុំទូកដែលគេធ្វើក្នុងខែកត្តិកនោះ គឺមានទាក់ទងនឹងទឹកចិត្តម៉ែឪ។ សុភាសិតដែលជាពាក្យបណ្តាំរបស់ដូនតាយើង គាត់បានពោលទុកថា ម៉ែឪគិតកូនដូចច្រវាប្រដេញ កូនគិតម៉ែឪវិញ ដូចព្រះបែរក្រោយ ពេលដែលអ្នកទៅមើលបុណ្យអុំទូករាល់ឆ្នាំ តើអ្នកមានបានគិតពិចារណាទេ? ពេលយើងមើលពីច្រាំងទន្លេទៅ យើងឃើញអ្នកអុំទូក លើកច្រវាឡើងស្រុះគ្នាណាស់ ទើបអាចរុញទូកឲ្យទៅដល់ទីដៅបាន។ យ៉ាងណាមិញ ទឹកចិត្តរបស់ម៉ែឪក៏ដូចជាច្រវាទូកទាំងនោះដែរ គឺពួកគាត់ស្រុះគ្នាណាស់អបស្អបកូនរុញច្រានកូន គិតគូរកូនសព្វបែបយ៉ាង ទាំងខាងផ្លូវកាយវាចាចិត្ត រុញកូនឲ្យបានទៅដល់ទីដៅ គឺអនាគតរុងរឿងនិងមានសុភមង្គល។ ពួកគាត់ជាច្រវាសុខចិត្តចុះទៅក្នុងទឹក (អបាយភូមិ) ដើម្បីរុញច្រានទូកកូន ព្រោះភ័យខ្លាចទូកកូន លិចចុះក្នុងអបាយភូមិ ដូច្នេះហើយពួកគាត់សុខចិត្តធ្វើពលិកម្មគ្រប់បែបយ៉ាងក្នុងមួយជីវិតរបស់ពួកគាត់ដើម្បីតែកូនប្រុសស្រី។ នេះគឺជា**ព្រហ្មវិហារធម៌** ដែលបានបង្កប់ជ្រៅទៅក្នុងពិធីបុណ្យអុំទូកនេះ ព្រោះពួកគាត់ពុំធ្វើអ្វីដោយគ្មានបង្កប់ន័យ **បិរួមមួយ** ឡើយ នេះជាចម្លើយស្រាយប្រស្នាក្នុងពិធីបុណ្យនេះ។ កូននាគប្រុសស្រីគិតម៉ែឪវិញ ដូចព្រះបែរក្រោយ

តើមានន័យដូចម្ដេច? ពាក្យនេះ សូមកូននាគទាំងឡាយ មើលនៅក្នុង**មហាបរិនិព្វានសូត្រ** អ្នកនឹងយល់ពីប្រស្នាដូនតាជាពុំខាន ហើយខ្ញុំសូមលើកយកវគ្គនេះមកពន្យល់។ គ្រានោះ ព្រះដ៏មានព្រះភាគស្ដេចយាងទៅកាន់ក្រុងវេសាលី ក្នុងបុព្វណ្ហសម័យដើម្បីបិណ្ឌបាត លុះស្ដេចយាងត្រឡប់មកវិញ **ទ្រង់ងាកព្រះភ័ក្ត្រមើលក្រុងវេសាលី ប្រៀបបីដូចដំរីហត្ថីនាគ ងាកមើលក្រោយ** ហើយទ្រង់ត្រាស់និងព្រះអានន្ទថា **(ឥទំបច្ឆិមកំទស្សនំអានន្ទ** ម្នាលអានន្ទ! តថាគតឃើញក្រុងវេសាលីម្ដងនេះជាបច្ឆិមទស្សន៍គឺឃើញជាចុងក្រោយនិងជាទីបំផុត តើកូននាគណាដែលងាយនឹងបែរងាកទៅក្រោយមើលឃើញរឿងទុក្ខវេទនារបស់ព្រះមាតាបិតាម្ចាស់នគរឃ្មុំ ហេតុអ្វីក៏ពួកគាត់ឲ្យកូនសម័យអង្គរកសាងប្រាសាទថ្មរាប់ពាន់ ឆ្លាក់រឿងរ៉ាវបណ្ដាំរបស់ពួកគាត់? ព្រោះពួកគាត់មានសង្ឃឹមថា អនាគតនឹងមានកូននាគណាមួយ ងាកបែរទៅក្រោយមើលឃើញរឿងពិតរបស់គាត់ជាពុំខាន រួចគេនឹងព្យាយាមជួយគាត់ឲ្យបានរួចផុត ពីទុក្ខទោសនិងបាបអកុសលទាំងនោះ។

អត្ថន័យដែលខ្ញុំបានលើកយកមកពន្យល់នេះ គឺជាសាវតារឿងពិតរបស់ពួកគាត់ដែលបានលាក់ទុកក្នុងពិធីបុណ្យនេះ សូមកូននាគទាំងប្រុសស្រីអានហើយគិតពិចារណា តើហេតុផលនៃពិធីបុណ្យខាងលើ ដែលខ្ញុំលើកយកមកពន្យល់នេះ សមតាមហេតុផលដែលឬទេ? ហើយបើត្រឹមត្រូវតាមការពន្យល់បកស្រាយ សូមជួយស្រាវជ្រាវបន្ថបន្ថែមរកឲ្យឃើញនូវសេចក្ដីពិតដើម្បីជួយស្រង់ព្រះម៉ែព្រះឪមហានគររបស់យើងដែលពួកគាត់រងចាំឲ្យកូននាគសម័យនេះជួយគាត់(គាត់មានសង្ឃឹមតិចតួចណាស់ចំពោះយើង ព្រោះសម័យនេះជាសម័យបច្ចេកវិជ្ជាទំនើប និងសម្ភារះទំនើប ហើយក៏ជាសម័យដែលកូននាគលែងសូវមានជំនឿលើកម្មនិងផល) ។

មិត្តអ្នកអានបានដឹងហើយ ពីអត្ថន័យបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែ ដែលដូនតាគាត់ធ្វើក្នុងខែកត្តិកនេះ (**ផ្កាយកូនមាន់**) រួចខ្ញុំក៏បានប្រាប់ហើយថាមេមាន់ គេបានចាប់យកទៅក្រុងឃុំនៅគុករកា (គុកដាក់មាន់) ហេតុអ្វីបានជាគាត់យកសត្វមាន់មកប្រៀបធៀបនឹងរឿងព្រះម៉ែមហានគរ? យើងដឹងហើយថា សភាវៈរបស់សត្វមាន់ សត្វជាបាពុំដែលបណ្ដើរកូន ក្រុងកូន ឬការពារ និងរកចំណីឲ្យកូនឡើយ តែបើមេវិញ ទោះបីជាគេក្រុងក្នុងអង្រុត ក៏នៅតែកកាយក្រុកៗហៅកូនមកជុំដើម្បីចញ្ចឹមនិងថែរក្សា។ យ៉ាងណាមិញប្រស្មានេះ ផ្កាយកូនមាននៅខាងលើ ចំណែក

ឯមេមាន់នៅជាប់គុកខាងក្រោម ក៏នៅតែគិតកូននៅខាងលើ ដូចជា ព្រះម៉ែមហានគរសព្វថ្ងៃ ជាប់ឃុំនៅក្នុងសមុទ្រទឹកដោះទៅហើយ ប៉ុន្តែ និមិត្តរូបរបស់គាត់នៅតែមកការពារព័ទ្ធសីមាការពារក្រុងកូនដដែល (ពិធីបង្វិលពពិល) ហើយឈ្មោះផ្កាយកូនមាន់នោះទៀតសោត គឺមានតែស្រុកខ្មែរទេដែលហៅ។ នៅក្នុងខេត្តកំពង់ធំ (កំពង់ទូលាយ) មានលាក់នូវរឿងជាច្រើនរបស់ដូនតាមហានគរយើង ហើយមិនត្រឹមតែប៉ុណ្ណោះទេ ពួកគាត់បានកសាងប្រាសាទគុកច្រើនណាស់ គឺ**គុករកា គុករមាស គុកនគរ សំបូរព្រៃគុក** នេះខ្ញុំអ្នកស្រាវជ្រាវបានដឹង មិនដឹងថាមានប្រាសាទគុកប៉ុន្មានទៀត ដែលខ្ញុំពុំដឹង? ចំណែកនៅក្នុងខេត្តកំពង់ចាម មានប្រាសាទគុកមួយឈ្មោះថា គុកព្រះធាតុ ហេតុអ្វីបានជាគាត់ធ្វើប្រាសាទ ហើយដាក់ឈ្មោះថាគុកច្រើនម្លេះ? តើប្រាសាទគុកទាំងអស់ហ្នឹង សម្រាប់ដាក់អ្នកណា?

ក្នុងឯកសារសាវតាភាគទីមួយក្ដី ភាគទីពីរនេះក្ដី ខ្ញុំបាទខិតខំប្រមូលនូវបណ្ដាំរឿងរ៉ាវទាក់ទងផ្សេងៗ ដែលខ្ញុំបានឆ្លងរួចសិក្សាស្រាវជ្រាវអស់ពេលដ៏យូរ ដើម្បីរកចម្លើយពិតមួយយកមកវែកញែកបកស្រាយបម្រាពន្យល់ដល់កូននាគទាំងឡាយឲ្យឆាប់ងាយយល់។ តែទោះបីជាយ៉ាងនេះក៏ដោយក៏ខ្ញុំជឿជាក់ថា លំបាកនឹងឲ្យកូនខ្មែរទទួលយកបានណាស់ ព្រោះសព្វថ្ងៃជាសម័យ ដែលកូននាគចូលក្នុងរបត់មនោគមវិជ្ជាបែបថ្មី គឺមនោគមបច្ចេកវិជ្ជាទំនើប និងសំភារៈទំនើប។ មនោគមវិជ្ជាថ្មីនេះហើយ ដែលពុំអាចឲ្យបណ្ដាំរឿងអច្ឆរិយៈរបស់ព្រះម៉ែមហានគរ ជ្រៀបចូលទៅក្នុងសន្តានចិត្ត កូននាគប្រុសស្រីបានឡើយ កុំថាតែកូននាគប្រយោល សូម្បីកូននាគផ្ទាល់ គឺកូននាគដែលបានបួសរៀននោះក៏លំបាកនឹងទទួលយកដែរ ព្រោះ ការមិនដឹងនេះ បរទេសបាន បកប្រែបំភ័ន្តជាយូរយារណាស់មកហើយ(អត្ថន័យបទសារិកាកែវអើយក្នុងភាគ១)។ ម្យ៉ាងទៀតគ្រឿងស្រវឹង និងគ្រឿងញៀនគ្រប់ប្រភេទ កំពុងតែសណ្ដំកូននាគប្រុសស្រី ឲ្យលង់លក់លែងស្គាល់គុណធម៌ ដែលជាធម៌ខ្ពង់ខ្ពស់របស់ពូជនាគ ជាពិសេសគឺព្រហ្មវិហារធម៌ ព្រះម៉ែឪដែលជាដំបូល ហើយកូននាគប្រុសស្រីបានជ្រកក្រោមដំបូលនោះគ្រប់ៗជំនាន់ ទីបំផុតយើងពុំបានមើលឃើញ និងដឹងនូវរឿងអច្ឆរិយៈពីអតីតកាលរបស់ម្ចាស់ដំបូលជម្រកនេះ ដែលកើតឡើងដោយសារតែហេតុអ្វីពីដំបូង?

២.គុករកា (ខេត្តកំពង់ធំ)

គុកនេះគេធ្វើសម្រាប់ដាក់មាន់ ដែលខ្ញុំបានពន្យល់ត្រួសៗពីរឿងបក្សីចាំក្រុង ឬពិធីបុណ្យអុំទូក អកអំបុក លយប្រទីប និងសំពះព្រះខែ រួចមកហើយ តែពេលនេះ ខ្ញុំចង់លើកយកពាក្យថាព្រះខែ ឬព្រាំច័ន្ទមកពន្យល់បន្ថែម។ ហេតុអ្វីក៏គាត់មិននិយាយថា សំពះព្រះច័ន្ទ បែរជានិយាយថាសំពះព្រះខែទៅវិញ?

ពាក្យខែនេះវាទាក់ទងទៅនឹងជម្ងឺមួយបែបរបស់ផ្លែដូង គឺ **ដូងខែស៊ី** ផ្លែដូងពេលណាវាខូច គ្មានទឹក គ្មានសាច់យើងហៅតៗគ្នាថាដូងខែស៊ី តើខែបានមាត់ឯណាមកស៊ីដូង? នេះជាបណ្ដាំប្រស្នាដែលគាត់ទុកឲ្យកូននាគទាំងឡាយឆ្លល់ជាពិសេស គឺកូននាគដែលពុំព្រមចុះទៅក្នុងទ្រូងព្រះម៉ែ ដើម្បីឲ្យយល់ពីទុក្ខវេទនាក្នុងបេះដូងព្រះម៉ែ។ បើកូននាគទាំងនោះ ពុំយល់ពីទឹកចិត្តព្រះម៉ែបានន័យថា បេះដូងកូននាគនេះត្រូវខែស៊ីអស់ហើយព្រោះហេតុអ្វី? គឺក្នុងបេះដូងរបស់កូននាគនោះ គ្មាននូវទឹកចិត្តកតញ្ញូកតវេទីឡើយគឺមានតែរាងផ្លែដូង ហើយគ្មានសាច់និងទឹកគ្រប់គ្រាន់(អាថ៌កំបាំងផ្លែដូងនេះខ្ញុំបានពន្យល់រួចហើយ នៅក្នុងល្បែងចាក់ទឹកដូងភាគ១)។ ពេលនេះខ្ញុំយកតែពាក្យ **ខែ** មកពន្យល់តែប៉ុណ្ណោះដែលគាត់ប្រាប់ថាដូងខែស៊ី គឺមានអត្ថន័យថា ទឹកចិត្តក្នុងបេះដូងកូននាគប្រុសស្រីត្រូវ ខែថ្ងៃពេលវេលាស៊ីអស់ហើយ ព្រោះកូនខ្មែរប្រុសស្រីរវល់គិតត្រឹមតែខ្លួន និងក្រុមគ្រួសារខ្លួនក្នុងពេលបច្ចុប្បន្នតែប៉ុណ្ណោះ ពុំបានគិតគុណព្រះម៉ែពីអតីតនិងតទៅអនាគតខាងមុខឡើយ បានន័យថាពុំបានតបស្នងដល់អ្នក **បង្កបង្កើតមាតុប្រទេស** (ព្រះមាតាបិតាមហានគរ)។ ក្នុងពាក្យទំនៀមដដែលមានពាក្យមួយឃ្លាទៀតពោលទុកថា **កូនរាហ៍កន្លង ឬគ្រាសកន្លង** តើពាក្យរាហ៍កន្លងមានអត្ថន័យដូចម្ដេច? យើងដឹងហើយថាពាក្យថ្ងៃរាហ៍ និងខែរាហ៍(សូរ្យគ្រាសនិងច័ន្ទគ្រាស) គឺ ***រាហូអសុរិន្ទ*** បានបិទបាំងពន្លឺព្រះអាទិត្យ និងព្រះច័ន្ទមិនអាចឲ្យបញ្ចេញពន្លឺរស្មីបានឡើយ ចំណែកឯកូនដែលត្រូវរាហ៍កន្លងវិញត្រូវបាត់បង់សតិបញ្ញាស្មារតីដែលតំណាងឲ្យពន្លឺរស្មីនោះ។ ព្រោះដូនតាបានទុកសម្រាប់ឲ្យយើងពិចារណាដែលមាននៅក្នុងប្រាសាទ រឿងព្រេង ទំនៀមទំលាប់ ប្រពៃណី ឈ្មោះភូមិស្រុក ភ្នំធម្មជាតិ និងទំនាយផ្សេងៗដ៏ច្រើនស្អេកស្កះ ដើម្បីឲ្យកូនខ្មែរទាំងអស់យល់ពីប្រស្នាអាថ៌កំបាំង ថាតើ

នរណាជាអ្នកចាប់ព្រះម៉ែយកទៅឃុំ នេះជាការបកស្រាយពន្យល់ពីពាក្យពិត របស់កូនរាហ៍កន្លង។ សរុបសេចក្ដីមកការពន្យល់ពីគុករកាក្ដី ពីដូងខៃស៊ីក្ដី និងរាហ៍កន្លងក្ដី គ្រាន់តែជាពន្លឺប្រទីបដ៏តូចមួយ សំរាប់ជ្រោងបំភ្លឺក្នុងទីងងឹត ឲ្យមានពន្លឺអាចមើលឃើញនូវបណ្ដាំប្រស្នាគំនិតរបស់ព្រះម៉ែ ដែលបាន បង្កប់ទុកក្នុងពាក្យនិយាយ ក្នុងជីវភាពរស់នៅរាល់ថ្ងៃរបស់កូននាគពីសម័យមុន ចំណែកសព្វថ្ងៃនេះ វិញ យើងពុំបានយកពាក្យទាំងនេះមកប្រៀបធៀបដូចពីសម័យមុនទេ ឧ. ដូចពាក្យគាត់ជេរ ស្ដីកូនពីមុនថា មិនដឹងខ្យល់ ដំបូកខ្នងទូល ក្នុងចុងស្រុក ដំណើបលាយខ្យាយ ក្រពើរមិលគុណ រាហ៍ ឬគ្រាសកន្លង.... វាខុសពីសម័យសព្វថ្ងៃ ដែលសីលធម៌សង្គមបានធ្លាក់ចុះ យើងបានយកពាក្យអសុរោះ គឺយកភេទម្ដាយ(យោនី)មកជេរ ហាក់បីដូចជាពួកគាត់គ្មានស្លៀកពាក់សំពត់បិទបាំង ហើយម្ដាយ ខ្លះទៀតពួកគាត់បានស្លាប់ពុកឆ្អឹងអស់ទៅហើយ ក៏កូនៗនៅតែនាំគ្នាគាស់គាត់យកមកជេរប្រមាថ ដដែល។


រូបរាហូលេបព្រះគោព្រះកែវ និងក្បួនគម្ពីរ
(ប្រាសាទបន្ទាយឆ្មារ)

## ៣.គុករមាស (ខេត្តកំពង់ធំ)

ក.ប្រាសាទគុករមាសនេះ ក៏នៅក្នុងខេត្តកំពង់ធំដែរ តើមិត្តអ្នកអានមានឆ្ងល់ទេ ហេតុអ្វីបានជារមាសជាប់គុក? ក្នុងរឿងទីមួយ សត្វរមាសនេះជាយានជំនិះដែលមាននិយាយនៅក្នុងរឿងព្រៃងបឹងទំលៃង ក្នុងសាច់រឿងបានប្រាប់ថាស្ដេចអង្គនោះ ទៅស្នេហានាងមុខរាហ៍ (រាហូ) ពេលនោះនាងមុខរាហ៍សួរព្រះអង្គថា ស្ដេចយាងមកដោយយានអ្វី? ព្រះរាជាទ្រង់តបថា បងមកដោយសត្វរមាស ឥឡូវចងនៅក្រោមដើមក្រសាំង។ ឯរមាសស្ដាប់មិនច្បាស់ឮតែថាក្រសាំង ក៏នឹកតូចចិត្តថាម្ចាស់ខ្លួនហៅថា សត្វក្រសាំងទៅវិញ រួចហើយរមាសខឹងក៏បោលផ្ដាច់ខ្សែចំណងនោះទៅ ពេលដែលដាច់ចំណងនោះ ត្រូវបានហ្លួឈ្មោះទំ ទាញទប់រមាសរួចជើងគាត់ជ្រែងដី ទើបស្ដេចឲ្យទំជាហ្លួលែងខ្សែរមាសនោះទៅ។ ទីកន្លែងដែលទំបានឈរជ្រែងដីនោះ កើតបានជាបឹងមួយឈ្មោះ **បឹងទំលៃង** ចំណែកឯសត្វរមាសវិញ ស្ដេចបានដាក់បណ្ដាសាដល់សត្វរមាសនោះថា ពូជអាឯងចាប់ពីថ្ងៃនេះទៅ

ត្រូវស៊ីតែបន្លា និងផឹកនូវទឹកល្អក់ជាដរាប។ ហេតុនេះហើយ បានជានៅលើខ្នងសត្វរមាសទាំងឡាយ សព្វថ្ងៃនេះមានស្រទាប់លើខ្នង សណ្ឋានដូចជាគេចងអាន (កែប) ស្បែកក៏ក្រហេងក្រហូងជាច្រើនស្រទាប់ ជាទីជ្រកនៅនៃពួកសត្វក្អែបនិងខ្ទួយ ហើយស៊ីតែឈើ ឬវល្លិ៍ណាដែលមានបន្លាជាអាហារ ផឹកតែទឹកល្អក់ ទោះបីទឹកថ្លាក៏វាយកជើងកូរឲ្យល្អក់សិនទើបវាផឹក ព្រោះវាបានត្រូវទោសបណ្ដាសាព្រះមហាក្សត្រតាំងពីពេលនោះឯង (រមាសជាប់ទោសទីមួយ)។

## -រឿងឥសីមាត់ទិព្វ

ចំណែកឯរឿងទីពីរដែលទាក់ទងនឹងសត្វរមាសគឺរឿង **ឥសីមាត់ទិព្វឬព្រះថោងទិព្វវង្ស** រឿងនេះមាននៅក្នុង**ជាតក**នានា ពុំមែននៅក្នុងជាតកដែលមានក្នុងព្រះត្រៃបិដកឡើយ ព្រោះខ្ញុំបានពន្យល់ហើយ ដូនតាខ្មែរបានរំលាយបិឡូរមតែមួយ។ បើចង់ដឹងរឿងរ៉ាវរបស់លោក ទាល់តែរែកពីរចេញដែលជាសំបក (ពុទ្ធសាសនា ព្រហ្មញ្ញសាសនា) ទើបឃើញខ្លឹមខាងក្នុងដែលជារឿងរបស់គាត់ (ផ្លែដាវលាក់ក្នុងស្រោមដាវ) នេះជាបណ្ដាំប្រស្នាដែលពួកគាត់ខ្ចីសំបករបស់គេមកបិទបាំងសាច់រឿងរបស់ខ្លួន។

ក្នុងសាច់រឿងនេះគាត់បានប្រាប់ថា អ្នកនគរនោះបានក្លាយទៅជាថ្ម ដោយត្រូវបណ្ដាសាឥសីមាត់ទិព្វ ព្រោះស្ដេចនគរនេះ បានប្រើឲ្យគេយកដុំថ្មទៅគរពីខាងលើឥសីមាត់ទិព្វ នៅពេលដែលលោកកំពុងចូលក្នុងឈានសមាបត្តិ ក្នុងដែនទីឧទ្យានរបស់ស្ដេចនោះ ស្ដេចអង្គនេះ ប្រើគេឲ្យយកថ្មទៅគរសង្កត់ ក៏ព្រោះតែហៅតាឥសីពុំឆ្លើយ (អ្នកចូលឈានពុំអាចឮសម្លេងអ្នកហៅឡើយ) ទើបកើតជាកំហឹងនេះឡើង។ ពេលលោកតាឥសី មាត់ទិព្វចេញពីឈានសមាបត្តិវិញ ទុក្ខវេទនាក៏កើតមានឡើងជាទម្ងន់ដោយអំណាចថ្មសង្កត់គាត់ លោកក៏បានអធិដ្ឋានថា សូមឲ្យថ្មនេះ(កម្មនេះ) កើតមានចំពោះអ្នកដែលប្រព្រឹត្តចុះ ទីបំផុតអ្នកក្នុងនគរនេះ ដែលចូលរួមប្រព្រឹត្តនូវបាបកម្មនោះ ក៏បានរឹងក្លាយទៅជាថ្មដោយអំណាចឫទ្ធិរបស់ឥសីមាត់ទិព្វ។ លោកតាឥសី លោកមានកូនសិស្សម្នាក់ឈ្មោះ **ព្រះថោងទិព្វវង្ស** សិស្សនេះហើយដែលលោកបានហៅមកផ្ដែផ្ដាំថា **២០០០** ឆ្នាំក្រោយអ្នកនគរនេះនឹងបានរួចពីបាបកម្ម ហើយអ្នកដែលអាចជួយពួកគេបានគឺមានតែថៅម្នាក់ប៉ុណ្ណោះ។ ថៅអាចមាន

ជីវិតរស់ទៅដល់សម័យនោះបាន លុះតែចៅបានបរិភោគផ្លែឈើទិព្វនៅឯព្រៃហេមពាន្ត ទើបអាចរស់បានទៅដល់ **២000**ឆ្នាំក្រោយ ហើយម្ចាស់ក្សត្រីរបស់ស្តេចអង្គនេះ នឹងបានជាមហេសីរបស់ចៅក្នុងអនាគត នៅពេលរួចពីកម្មពៀរ។ លោកតាផ្តែផ្តាំរួច ក៏ឲ្យផ្ចាំទិព្វមួយកញ្ចប់ទៅចៅទិព្វវង្ស ហើយប្រាប់ថា ផ្ចាំទិព្វនេះពេលដល់គម្រប់ឆ្នាំដែលរួចកម្ម ចៅយកវាទៅលាយនឹងទឹក រួចយកទៅប្រោះរូបចម្លាក់ថ្មទាំងអស់នោះ ថ្មនឹងក្លាយជាព្រះនគរមនុស្សប្រុសស្រីហើយរស់រានមានជីវិតឡើងវិញ។ លោកតាឥសីក៏ចាប់ផ្តើម បង្រៀនមន្តវិជ្ជាសព្វបែបយ៉ាងដល់សិស្សដើម្បីទុកការពារខ្លួន ព្រោះនៅតាមផ្លូវទៅកាន់ព្រៃហេមពាន្តមានអមនុស្សកាចៗនៅរារាំងតំណើរ ជាពិសេសគឺនៅនឹងដើមឈើទិព្វនោះ ដែលមានយក្សពីរនាក់នៅថែរក្សា គាត់បង្រៀននិងផ្តែផ្តាំកូនសិស្សរួចហើយ ឥសីមាត់ទិព្វជាគ្រូក៏បានសុគតទៅ ដោយអំណាចទុក្ខវេទនា ដែលកើតចេញពីភាពគ្រាំគ្រានៃថ្មសង្កត់។ ព្រះចៅទិព្វវង្ស ដែលជាសិស្សបានរៀបចំបូជាព្រះសពលោកគ្រូ ហើយក៏បានយកធាតុទៅបញ្ចុះក្នុងទីដ៏សមគួរ ទើបដើរចូលទៅក្នុងព្រះនគរ មើលរូបព្រះនាងច័ន្ទរស្មីអនាគតមហេសីដែលបានក្លាយជាថ្ម រួចនិយាយ ម្នាក់ឯងថា **២000**ឆ្នាំក្រោយចាំយើងជួបគ្នា។

ព្រះចៅទិព្វវង្សក៏បានចាកចេញពីនគរនោះ ធ្វើដំណើរទៅកាន់ព្រៃភ្នំហេមពាន្ត ដើម្បីស្វែងរកនូវដើមឈើទិព្វតាមបណ្តាំរបស់លោកគ្រូ នៅតាមផ្លូវព្រះចៅទិព្វវង្សបានជួបតាបសឥសីជាច្រើន ហើយពួកគាត់ទាំងនោះ បានជួយចង្អុលផ្លូវទៅរកដើមឈើទិព្វនោះ។ ពេលដែលបានឃើញដើមឈើទិព្វហើយ ពួកយក្សដែលថែរក្សាដើមឈើនោះ មិនព្រមឲ្យព្រះចៅទិព្វវង្សចូលទៅជិតបេះឡើយ តែដោយអំណាចមន្តរបស់ឥសីមាត់ទិព្វជាគ្រូបាន ធ្វើឲ្យយក្សទាំងពីរដែលនៅរក្សាដើមឈើទិព្វនោះ បាក់បបខ្លបខ្លាចចេស្តាព្រះ អង្គទីបំផុតព្រះអង្គបានបេះផ្លែឈើទិព្វនោះ មកបរិភោគតាមបណ្តាំលោកគ្រូគឺ១00ឆ្នាំហូបមួយផ្លែ រហូតដល់គម្រប់២000ឆ្នាំ។ ២000ឆ្នាំក្រោយ ព្រះចៅទិព្វវង្សបានដឹងថា ដល់ពេលអ្នកនគរទាំងនោះត្រូវអស់បាបកម្មហើយ គាត់ក៏ធ្វើដំណើរទៅនគរនោះដើម្បីប្រោះថ្ម ពេលដែលទៅដល់ពាក់កណ្តាលផ្លូវ គាត់ស្ទាបរាវរកផ្ចាំទិព្វតែមិនឃើញ ទើបដឹងថាផ្ចាំទិព្វបាត់ គាត់ក៏ធ្វើដំណើរត្រឡប់មកក្រោយវិញ ដើម្បីរកពួកយក្សសួរនាំ។ ពេលដែលជួបពួកយក្សហើយ ព្រះចៅទិព្វវង្សក៏សាកសួរពីដំណឹងផ្ចាំទិព្វរបស់ខ្លួន ពួកគេប្រាប់ថាដោយខឹង នឹងព្រះចៅដណ្តើមផ្លែឈើទិព្វគេ ទើប

ពួកគេនាំគ្នាលួចយកថ្នាំទិព្វនោះទៅបោះចោល នៅក្នុងមហាសមុទ្របាត់ទៅហើយ ពេលចៅដេកលក់។ ហេតុតែសេចក្តីក្រោធខឹង ពេលនោះចម្បាំងក៏កើតឡើងជាថ្មីទៀត ពួកយក្សបានចាញ់ឫទ្ធិព្រះចៅទិព្វវង្ស ក៏ចេះតែនាំគ្នារត់ រហូតមកដល់មុខអាស្រមឥសីអគ្គីនេត្រ ដោយព្យួរសន្ធឹកជើងយក្សរត់ក្រើកដី ពេលនោះឥសីអគ្គីនេត្របានបើកភ្នែកទីបី ធ្វើឲ្យពួកយក្សឆេះរលាយអស់ នៅសល់តែព្រះចៅទិព្វវង្សម្នាក់។ ឥសីឆ្ងល់ក៏សួរថា អ្នកឯងជាសិស្សរបស់គ្រូណា ទើបមិនឆេះដោយអំណាចភ្នែកទីបីរបស់យើង ព្រះចៅបានឆ្លើយប្រាប់ថា ខ្ញុំជាកូនសិស្សលោកតាឥសីមាត់ទិព្វ ហើយចៅទិព្វវង្សក៏បានរ៉ាយរ៉ាប់ នូវដំណើររឿងជាហូរហែពីដើមរហូតដល់ចប់ ឲ្យលោកតាឥសីអគ្គីនេត្រស្តាប់។ ពេលបានស្តាប់រឿងរបស់ចៅរួច លោកតាបានប្រាប់ទៅចៅទិព្វវង្សថា ថ្នាំទិព្វរបស់ចៅយក្សបានលួចហើយយកទៅបោះចោលក្នុងមហាសមុទ្រ ពេលនោះមានស្តេចក្រពើមួយមកស៊ីថ្នាំទិព្វនេះ ដោយអំណាចនៃឫទ្ធិរបស់ថ្នាំទិព្វ ធ្វើឲ្យស្តេចក្រពើនោះក្តៅក្រហល់ក្រហាយនៅក្នុងទឹកពុំបានទើបឡើងមកដេកក្រាំងនៅលើគោក រហូតក្រោយមកប្រែក្លាយជាសត្វរមាស ឥឡូវតាបានឃាំងសត្វរមាសនោះទុកហើយ។ ដូច្នេះចូរចៅយកសត្វរមាសនេះ ធ្វើជាយានជំនិះជិះទៅប្រោះអ្នកនគរនោះចុះ! ពេលទៅដល់នគរហើយ ចៅត្រូវយកទឹកមាត់របស់រមាសទៅលាយនឹងទឹក ហើយយកទៅប្រោះលើថ្មទាំងនោះព្រោះជាតិថ្នាំទិព្វបានរលាយពេញសព្វសាច់ក្នុងខ្លួនរមាសអស់ហើយ។

ពេលដែលព្រះចៅទិព្វវង្សទៅដល់ព្រះនគរនោះ គាត់រកទីតាំងព្រះនគរពុំឃើញឡើយ ដោយរយៈកាលកន្លងអស់២០០០ឆ្នាំ ធ្វើឲ្យព្រះនគរមានព្រៃដុះក្រាស់ឃ្មឹករកមើលទីតាំងពុំយល់ឡើយ ទើបចៅទិព្វវង្សលើកដៃអធិដ្ឋាននឹកដល់គុណបុណ្យបារមីរបស់លោកតាឥសីមាត់ទិព្វជាគ្រូឲ្យជួយ ទីបំផុតព្រៃនោះ ក៏ក្លាយទៅជាព្រះនគរដូចពីដើមវិញ។ រួចហើយ ចៅទិព្វវង្សក៏ផ្តិតយកទឹកមាត់រមាសមកលាយជាមួយទឹកដើរប្រោះរូបចម្លាក់ថ្ម ហើយរូបទាំងអស់នោះក៏បានប្រែក្លាយជាមនុស្សប្រុសស្រី ស្តេច នាម៉ឺន មន្ត្រី រាស្ត្រ ទៅតាមឋានានុក្រមឡើងវិញ។ ក្រោយពីបានរួចផុតពីបាបកម្មហើយ ស្តេចជាមាតាបិតានគរនេះ បានរៀបចំអភិសេកព្រះនាងច័ន្ទរស្មី ឲ្យទៅព្រះចៅទិព្វវង្សធ្វើជាមហេសី និងបានប្រគល់រាជសម្បត្តិឲ្យព្រះចៅទិព្វវង្សឡើងគ្រងរាជ្យ ចំណែកខ្លួនឯង និងព្រះមហេសីក៏លាចេញទៅបួសជាតាបស។

នៅក្នុងរឿងនេះ បើយើងពុំបានយកមករំកែញែក យើងច្បាស់ជាពុំបានដឹងរឿងពិតរបស់ព្រះម៉ែឡើយ យើងដឹងហើយថា បណ្ដាំ ព្រះម៉ែព្រះឪ ខ្មែរបានរឹងក្លាយទៅជារឿក្នុងថ្មនៅគ្រប់ប្រាសាទទូទាំងប្រទេស ម្យ៉ាងទៀតស្ដេចក្រពើក្នុងសាច់រឿងបានក្លាយទៅជារមាស (ដោយអំណាចកម្ម) ស្ដេចក្រពើនេះ គឺតំណាងឲ្យភ្នំក្រពើ ទង់ក្រពើ ផ្កាយក្រពើ និងពាក្យក្រពើដែលមាននៅគ្រប់កន្លែង ក្នុងស្រុកនេះ ហើយដែលប្រែក្លាយជារមាសនោះ តើមានន័យយ៉ាងដូចម្ដេចដែរ?

ពាក្យរមាស ➔ រាស្ត្រម ឬរាស្ត្រមក តើរាស្ត្រមកធ្វើអ្វី គឺមកស្ដាប់រឿងរបស់ថ្ម ដែលដូនតាខ្មែរបានផ្ដែផ្ដាំរៀបរាប់ពីបាបកម្មចាស់រាប់ពាន់ឆ្នាំមុនរបស់ពួកគាត់ សព្វថ្ងៃភក់ដែលកប់គាត់នោះ បានរឹងក្លាយទៅជាថ្មហើយ (ថ្មភក់ ឬភក់ថ្ម) ដែលដូនតាខ្មែរបានយកទៅកសាងប្រាសាទថ្មរាប់ពាន់នោះ។ សរុបសេចក្ដីមក រឿងទាំងពីរនេះទាក់ទងនឹងប្រាសាទដែលដាក់ឈ្មោះថាគុករមាស ហើយរឿងប្រាសាទគុករមាស ដែលខ្ញុំបាទបានដកស្រង់យកមកពន្យល់នេះ ដើម្បីទុកជាប្រទីបមួយសម្រាប់ពិចារណាកុំឲ្យយល់ច្រឡំ ថាដូនតាយើងគាត់ធ្វើអ្វីមួយទុកទោះតូចក្ដី ឬធំក្ដី ពុំដែលឥតបង្កប់នូវន័យខ្លឹមសារនោះទេ គឺសុទ្ធតែមានបង្កប់ប្រស្នា **គំនិតបីរួមមួយ** សម្រាប់ឲ្យកូនខ្មែរសម័យក្រោយ បំបែកនូវភាសារូបក្នុងបណ្ដាំគំនិតរបស់ពួកគាត់។

## ៤.គុកនគរ (គុហ៍នគរ)

ប្រាសាទគុកនគរនេះ ព្រះម៉ែគាត់ចង់ពន្យល់ប្រាប់យើង ថាគាត់ជាបឋមក្សត្រ ដែលបានបង្កើតនគរនេះ ដោយហេតុនៃសេចក្ដីលោភលន់ ធ្វើឲ្យពួកគាត់ត្រូវជាប់ទោស ព្រោះក្នុងចម្លាក់រឿងគ្រប់ប្រាសាទទាំងអស់ អត្ថន័យរឿងភាគច្រើន សុទ្ធតែនិយាយពីរឿងព្រះម៉ែត្រូវយក្សចាប់ ហើយរឿងរបស់គាត់ពេលខ្លះមាននិមិត្តរូបជាសត្វនាគ ត្រូវយក្សចាប់ផង គ្រុឌចាប់ផង ហើយថែមទាំងមានថ្មសង្កត់ពីខាងលើថែមទៀត ដូច្នេះហើយពេលដែលសោទ្វារទីមួយចាប់បើកក្នុងថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០០ មកក្នុងនគរនេះចេះតែមានអភូតហេតុរឿងរបស់នាគដើរផុសគ្រប់ទីកន្លែង ព្រោះគាត់ចង់ឲ្យកូននាគប្រុសស្រីជួយគាត់។ រួចពេលខ្លះទៀត រូបរបស់គាត់គេឆ្លាក់ជាស្ត្រីត្រូវយក្សក្បាលដប់ (ទសក័ណ្ឋ) ជាន់ពីលើគាត់ត្រង់ដើមទ្រូង (មើលរូបដែលនិយាយ ពីឈ្មោះភ្នំរាពណ៍) **ឬក៏គេឆ្លាក់រូបគាត់ឃុំក្នុងរង្វង់សីមា**

រូបខ្លះទៀតគេឆ្លាក់ជារូបស្ដ្រីទ្រទ្រូង (ទុក្ខ)....។ល។ ប៉ុន្តែគ្រប់រូបចម្លាក់រឿងរបស់គាត់ ក៏បានបើកបង្ហាញពីការជាប់ឃុំ ហើយនឹងពីការរួចពីទីឃុំឃាំងបន្តិចម្ដងៗ (ប្រាសាទរលស់) នេះជាអត្ថន័យពិតរបស់ឈ្មោះប្រាសាទគុកនគរ បើអ្នកដឹកនាំដំបូងជាអ្នកជាប់ទោសទៅហើយ នគរជាកេរមរតករបស់គាត់ក៏ត្រូវជាប់គុកដែរ។ នៅក្នុងខេត្តកំពង់ធំ ខ្ញុំបានឃើញប្រាសាទមួយ ដូនតាគាត់សាងសង់កប់ទៅក្នុងដី មើលទៅហាក់បីដូចជា ប្រាសាទនោះ ស្រុតចុះទៅក្រោម ប៉ុន្តែតាមការពិត គាត់ចង់ប្រាប់កូននាគសម័យខាងក្រោយ ឲ្យបានដឹងថា ព្រះម៉ែបានកប់ទៅក្នុងភក់ទៅហើយៗដែលភក់នោះបានរឹងខះទៅជាថ្ម (ថ្មភក់ ឬភក់ថ្ម)។ ដូច្នេះហើយស្ទើរតែគ្រប់ប្រាសាទថ្មទាំងអស់ គាត់តែងតែឲ្យកូនគាត់សម័យកសាងប្រាសាទថ្មនោះ យកថ្មភក់នេះ


**រូបព្រះមាតាបិតាជាប់ក្នុងសីមា** (បន្ទាយសំរ៉ែ)

មកសាងប្រាសាទហើយឆ្លាក់រឿងរបស់ពួកគាត់ទុកដើម្បីឲ្យកូននាគសម័យក្រោយ ពិចារណាពីប្រស្នាក្នុងថ្មភក់ទាំងនេះ។ ក្នុងសម័យទុំទាវអ្នកស្រុកត្បូងឃ្មុំ បានក្លាយជាអ្នកទោសយូរអង្វែងគឺ **អ្នកងារ** ឯអ្នកស្រុករលៀវផ្អៀរក៏ជាប់ឈ្មោះថាជាអ្នកងារដែរ (ភូមិតិរិច្ឆានសម័យអាណានិគមបារាំង) យ៉ាងណាមិញព្រះមាតាបិតាមហានគរក៏ជាអ្នកងារដែរ តែអ្នកងារពួកគាត់ គឺជាប់ទោសរបស់យក្សរាប់ពាន់ឆ្នាំហើយ។ ដូច្នេះទើបកើតមានប្រាសាទគុកនគរនេះឡើង ដើម្បីទុកឲ្យកូនខ្មែរសម័យក្រោយ យកឈ្មោះនេះមកគិតពិចារណាថា ហេតុអ្វីបានជានគរជាប់គុក (គុកនគរ) ខ្ញុំគ្មានសង្ឃឹមថាកូននាគទាំងឡាយជឿទៅលើ ការបកស្រាយនេះឡើយ ព្រោះហាក់បីដូចជារឿងនិទាន ប៉ុន្តែពុទ្ធសាសនិកទាំងអស់ត្រូវតែយល់ថា (**នត្ថិកម្មំសមំពលំ = កម្លាំងអ្វី ស្មើដោយកម្លាំងកម្ម គឺមិនមានឡើយ**) ហើយកម្លាំងកម្មនេះ ទោះបីកុសលកម្មក្ដី អកុសលកម្មក្ដី តែងតែតាមឲ្យផលគ្រប់ៗជាតិ លុះត្រាតែអស់ជាតិជរាព្យាធិ និងមរណៈ (អនុបាទិសេសនិព្វាន) ទើបកម្មនេះក្លាយទៅជាអហោសិកម្ម។

## ៥.ប្រាសាទសំបូរព្រៃគុក

អត្ថន័យរបស់ឈ្មោះប្រាសាទនេះក៏មិនខុសពីប្រាសាទគុកដទៃៗទៀតដែរគ្រាន់តែដូនតាយើងគាត់ចង់ពន្យល់បញ្ជាក់ឲ្យបានច្រើនដើម្បីឲ្យយើងកាន់តែឆ្ងល់ថា ទីព្រៃដ៏ស្ងាត់ស្ងៀមដែលលាក់ទុកក្នុងអតីតកាលនេះ ពោរពេញទៅដោយប្រាសាទគុក ហើយប្រាសាទគុកទាំងអស់នេះពុំមែនសម្រាប់ដាក់មនុស្សនៅខាងក្រៅនគរឡើយ គឺជាគុកសម្រាប់ដាក់មនុស្សនៅក្នុងនគរ ក៏ប៉ុន្តែយើងជាកូនខាគសម័យក្រោយ ពុំបានចាប់ភ្លឹកឆ្ងល់ពីឈ្មោះប្រាសាទទាំងនោះឡើយ ដោយយកពាក្យទាំងនេះ មកសិក្សាស្រាវជ្រាវ និងរែកញែកពិចារណារាវរកហេតុផល ដើម្បីស្វែងរកចម្លើយពិត។ បើយើងត្រិះរិះពិចារណាតាមទិដ្ឋិព្រះសម្មាសម្ពុទ្ធសត្វលោកដែលនៅជាបុថុជ្ជន ក្រាស់ទៅដោយកិលេស រមែងជាប់គុក គឺសមុទ្ទវដ្ដសង្សារ រកទីត្រើយពុំឃើញឡើយ ប៉ុន្តែបើមានបញ្ញាបារមីគ្រប់គ្រាន់ ហើយបានស្ដាប់ធម៌របស់សប្បុរសទៀតនោះ អរិយមគ្គនិងអរិយផលក៏នឹងកើតឡើង អាចបើកទ្វារព្រះនិព្វាន បានពេលនោះទ្វារគុក គឺវដ្ដសង្សារត្រូវបានបើក។ ដូច្នេះពាក្យពេចន៍ទាំងឡាយ ដែលដូនតាយើងបានយកទៅដាក់សម្គាល់ជាឈ្មោះ នៅលើវត្ថុអ្វីមួយ សុទ្ធតែមានបង្កប់នូវន័យ ពុំមែនគ្រាន់តែដាក់ឲ្យតែបាននោះទេ ហើយពាក្យគុកនេះទៀតសោត ពុំមែនជាគុករម្ទាស់ស្គរ (ចង្ក្រាន) ឬព្រៃគប់នោះឡើយ។

## ៦.ប្រាសាទគុកព្រះធាតុ

ពាក្យថាព្រះធាតុ គឺជាឆ្អឹងរបស់អ្នកមានគុណណាមួយ ដែលទុកដូចជាព្រះហើយយើងមិនដឹងថាតើម្ចាស់នៃព្រះធាតុនោះជាអ្នកណាឡើយ នៅពេលដែលយើងមិនបានឆ្ងល់នូវពាក្យនេះ ហើយស្រាវជ្រាវ យើងពិតជាមិនអាចរកឃើញនូវអាថ៌កំបាំងនៃពាក្យនេះឡើយ។ ដូចសព្វថ្ងៃនៅខេត្តបាត់ដំបង មានស្រុកមួយឈ្មោះ **ព្រះនេត្រព្រះ** តើព្រះនេត្រព្រះនេះ ជាភ្នែករបស់ព្រះណា? យើងដឹងហើយថាមាតាទាំង១២ ត្រូវបានយក្សឈ្មោះនាងសន្ធមារ ខ្វេះយកគ្រាប់ព្រះនេត្រ (កែវភ្នែក) ដូច្នេះ ឈ្មោះរបស់ស្រុកនេះ វាមានទាក់ទងនឹងឈ្មោះព្រះនេត្ររបស់ម្ដាយទាំង១២ ព្រោះពាក្យព្រះនេត្រព្រះពុំទាន់បញ្ជាក់ប្រាប់ន័យរបស់ព្រះអង្គណាមួយឡើយ។ ចំណែកឯព្រះធាតុវិញ ក៏មិនខុសពីពាក្យព្រះនេត្រព្រះខាងលើឡើយ ប៉ុន្តែយើងឆ្ងល់ថា ហេតុអ្វីបានជាព្រះធាតុនេះ ត្រូវជាប់គុក (គុកព្រះធាតុ)? ខ្ញុំបាន

ពន្យល់រ៉ាយរ៉ាប់ពីឈ្មោះរបស់ប្រាសាទ ដែលទាក់ទងនឹងគុកនៅទំព័រខាងលើ បានសន្និកសន្ទាប់ហើយៗឈ្មោះប្រាសាទគុកព្រះធាតុនេះ បើយើងពុំបានពិចារណាទេ យើងច្បាស់ជាពុំមានក្ដីសង្ស័យតក់ស្លុតឡើយ។ កូននាគទាំងឡាយ មនុស្សរស់សត្វរស់ ពេលដែលមានទោសត្រូវជាប់គុក ចុះហេតុអ្វីដូនតាខ្មែរនៅសល់តែព្រះធាតុ(ឆ្អឹង)ទៅហើយ ពួកគាត់នៅតែជាប់គុកទៀត? ព្រោះបាបកម្មរបស់ពួកគាត់មកទល់នឹងសព្វថ្ងៃនេះ មិនទាន់មានកូនខ្មែរប្រុសស្រីណាដឹង រួចជួយឧទ្ទិសនៅមហាកុសលជូនទៅពួកគាត់នៅឡើយ ដើម្បីឲ្យបានរួចពីគុកនៃបាបអកុសលនោះ។ ដូច្នេះហើយ ទើបដូនតាយើងគាត់កសាងប្រាសាទបន្ទាយក្ដី ស្ពានកំពុងក្ដី និងឈ្មោះភូមិស្រុកមួយចំនួនក្នុងមាតុភូមិ ដែលទាក់ទងនឹងឈ្មោះពាក្យថាក្ដី ព្រោះក្ដីរបស់ព្រះម៉ែនេះមិនទាន់មានកូននាគណាឡើយមកស្រាយឡើយ។ សូមកូនខ្មែរទាំងប្រុសទាំងស្រីទូទាំងនគរ រួមសាមគ្គីគ្នាឧទ្ទិសនូវមហាកុសល ដែលកើតចេញពីកតញ្ញូ និងកតវេទី ជូនទៅព្រះមាតាបិតា ដែលលោកមាននូវឧបការគុណ ឲ្យលោកបានរួចផុតពីទុក្ខទោសកម្មពៀរនិងអកុសលទាំងឡាយដែលនៅមាន។

## ៧.ប្រាសាទបន្ទាយក្ដី

តើប្រាសាទនេះមានអត្ថន័យលាក់បាំងយ៉ាងដូចម្ដេច?

**ពន្យល់ពាក្យ** (បន្ទាយក្ដី)

បន្ទាយ = ទីតាំងជម្រក ដីលើកខ្ពស់មានកំពែងមាំមួនព័ទ្ធជុំវិញ

ក្ដី = រឿងរ៉ាវ ក្ដីក្ដាំ ទំនាស់ដែលពុំទាន់បានស្រាយ (ទាញទៅទាញមក)

បន្ទាយក្ដី = ទីតាំងទុកដាក់នៅរឿងក្ដីក្ដាំ តើប្រាសាទនេះទុកដាក់រឿងក្ដីរបស់អ្នកណា?

ខ្ញុំបានសរសេររៀបរាប់តាំងពីភាគទី១ រហូតមកដល់ពេលនេះ រឿងរ៉ាវភាគច្រើនសុទ្ធតែទាក់ទងនឹងក្ដីពីអតីតកាល របស់ព្រះមាតាបិតាមហានគរ ហើយជាពិសេសគឺព្រះម៉ែ ព្រោះគាត់បានតាំងខ្លួនជាម៉ែ (មេ) ដោយព្រមទទួលនូវអមែ្រកក្ដីដ៏ធ្ងន់ ដែលជាហេតុនាំឲ្យកើតនូវមហាស្ពាបត្យកម្មដ៏ច្រើនព្រោងព្រាតចេញពីកម្លាំងសាមគ្គីរបស់កូនខ្មែរប្រុសស្រី ដែលមានកតញ្ញូពីសម័យមុន បានកសាងបន្ត

គ្នា ហើយឆ្លាក់ទុកនូវរូបរឿងរបស់ម៉ែឪក្នុងថ្ម ដែលសព្វថ្ងៃហៅថាសិលាចារឹក (ដាប់ឆ្លាក់លើថ្ម)។ ហើយប្រាសាទបន្ទាយក្តីនេះ នៅពីខាងមុខក្លោងទ្វារប្រាសាទ គាត់បានឲ្យកូនជីកស្រះមួយ ដែលមានឈ្មោះថាស្រះស្រង់ ហើយនៅកណ្តាលស្រះ មានប្រាសាទមួយផ្សេងទៀត ប៉ុន្តែសព្វថ្ងៃរលំបាក់បែកអស់ហើយ ដោយការរុករកកាលពីសម័យអាណានិគម ខឿនប្រាសាទនេះ យើងអាចមើលឃើញបាននៅរដូវប្រាំងដែលទឹកត្រូវស្រក។ ពាក្យថាស្រះស្រង់នេះ គឺពុំមែនស្រង់ទឹក (ងូតទឹក) តែម្យ៉ាងនោះឡើយ គឺមានន័យបង្កប់ផ្សេងមួយទៀត ព្រះម៉ែគាត់ចង់ប្រាប់កូនថា បើកូនចង់ដឹងរឿងក្តីម៉ែ កូនត្រូវស្រង់បណ្តាំរឿង (ស្រង់ឲ្យងើបឡើង) យកចេញពីក្នុងស្រះ ដែលនៅមាត់កំពង់ស្រះ គាត់បានឆ្លាក់រូបតោនៅពីខាងលើនិងរូបនាគ(និមិត្តរូបព្រះម៉ែ) ដែលមានសត្វម្ករលេប និងរូបសត្វគ្រុឌចាប់ក្បាលនាគមុខក្រោយ នៅខាងក្រោមជាប់មាត់ទឹក។ ហើយស្រះស្រង់ដដែលនេះ ក៏ជានិមិត្តរូបតំណាងឲ្យសមុទ្រទឹកដោះ ដែលជាទីឃុំឃាំងព្រះម៉ែមហានគរ ចំណែកឯប្រាសាទដែលនៅក្នុងស្រះខ្ញុំពុំដឹងឈ្មោះអ្វីឡើយ ប៉ុន្តែគ្រាន់តែដឹងថា ដូនតាយើងគាត់កសាងប្រាសាទក្នុងស្រះនេះ សម្រាប់លាក់ទុកនូវសាវតាបណ្តាំរឿងក្តីរបស់គាត់ ហេតុនេះហើយទើបបរទេសដឹងរឿងពួកគេបានគាស់កកាយបាក់បែករលំអស់។

សរុបសេចក្តីមក ការបកស្រាយដោយសង្ខេបពីអត្ថន័យប្រាសាទបន្ទាយក្តី គឺជាបន្ទាយលាក់នៅរឿងក្តី របស់ព្រះមាតាបិតាមហានគរ រីឯស្រះស្រង់ ដែលស្ថិតនៅក្នុងប្លង់ទល់មុខ គឺសម្រាប់ស្រង់រឿងក្តីដែលលាក់ទុកក្នុងស្រះនោះ ចំណែកឯរូបចម្លាក់ក្នុងប្រាសាទវិញខ្ញុំពុំបានបកស្រាយឡើយ ព្រោះភាគច្រើនត្រូវដាប់បំផ្លាញបាក់បែកអស់។

## ៨.ប្រាសាទប្រែរូប

### ពន្យល់ពាក្យ(ប្រែរូប)

ប្រែ = គឺត្រឡប់ពីម្ខាងទៅម្ខាង ពីមិនដឹងទៅដឹង ប្រែពីចាស់ទៅថ្មី....ពីខ្ពង់ទៅបាត

រូប = អ្វីដែលភ្នែកមើលឃើញ ឧ. រូបរាងកាយមនុស្ស សត្វ ធម្មជាតិផ្សេងៗ (រូបបរមត្ថ២៨)

ប្រែរូប = ប្រែរូបពីមិនដឹងទៅដឹង ប្រែរូបពីមើលមិនឃើញឲ្យមើលឃើញ....(ប្រែត្រឡប់រូប)

សព្វថ្ងៃតាមការពន្យល់របស់បរទេស ថាប្រាសាទនេះពីសម័យដើមសម្រាប់បូជាសពរបស់ស្ដេច ក៏ប៉ុន្តែពេលដែលខ្ញុំឡើងទៅមើល បណ្ដាំរឿងតាមជញ្ជាំង និងផ្ដែរប្រាសាទពុំបាននិយាយយ៉ាងនេះឡើយ គឺសាច់រឿងគាត់បានប្រាប់ឲ្យយើងជាកូននាគទាំងអស់ជួយប្រែរូបគាត់ ដែលដេកស្លាប់យូរណាស់មកហើយនោះឲ្យរស់ឡើងវិញ ក្នុងសន្ដានចិត្តកូនខ្មែរប្រុសស្រី។ ដូច្នេះពាក្យថាប្រែរូប ឬរូបប្រែតាមអត្ថន័យដែលខ្ញុំបាទស្រាវជ្រាវ គឺប្រែពីស្លាប់មករស់ ប្រែពីក្រដឹង ទៅឆាប់ដឹង (ក្រ + ពើ).... នេះជាអត្ថន័យបណ្ដាំប្រស្នាកំបាំងរបស់ព្រះម៉ែចំពោះឈ្មោះប្រាសាទនេះ ដែលខ្ញុំបានពន្យល់បកស្រាយដោយសង្ខេប។

## ៩.ប្រាសាទក្រវ៉ាន់

ឈ្មោះរបស់ប្រាសាទនេះ បើតាមខ្ញុំបាទអ្នកស្រាវជ្រាវយល់ពីមុន ឈ្មោះថា **ប្រាសាទក្រវាត់** ព្រោះរូបដែលគេឆ្លាក់ក្នុងប្រាសាទនេះគឺរូបព្រះម៉ែមានក្បាំងគ្រប់ក្រវាត់ពីលើដែលចុងក្បាំងមានក្បាលនាគសងខាងត្រូវយក្សលេបខ្លួនទៅដល់ក ហើយក្បាំងនេះគ្របក្រវាត់វាត់បន្តគ្នា។ម្យ៉ាងទៀតប្រាសាទនេះ



ប្រាសាទធំកណ្ដាលត្រូវប្រាសាទតូចពីរក្រវាត់អមសងខាងជាប់ ប្រៀបបីដូចម្រាមចង្អុលដៃកណ្ដាលត្រូវម្រាមពីរក្រវាត់អមសងខាងយ៉ាងដូច្នោះ។អត្ថន័យរបស់រូបនេះ គឺព្រះម៉ែនាគដែលបានតាំងខ្លួនជាមេជាម៉ែ ទីបំផុតសេចក្ដីលោភលន់ ក្នុងភាពរុងរឿងថ្កុំថ្កើងបានចងក្រុងក្រវាត់គាត់ ដោយអំណាចនៃនាគ (នាគ = ប្រសើររុងរឿង....)។ ហើយក្នុងប្រាសាទនោះដដែល គាត់បានឆ្លាក់រូបព្រះវិស្ណុជិះគ្រុឌ សព្វថ្ងៃតាមការពន្យល់របស់បរទេស គេនិយាយថា គ្រុឌជាយានជំនិះរបស់ព្រះវិស្ណុ តែខ្ញុំពុំយល់ឃើញស្របដូចពួកគេថាឡើយ ព្រោះសត្វគ្រុឌនោះហើយដែលចាប់ព្រះម៉ែនាគ ប៉ុន្តែត្រូវព្រះវិស្ណុជាន់ពីលើឲ្យលើកដៃឡើងដើម្បីឲ្យគ្រុឌព្រមលែងព្រះម៉ែនាគ។ ភាគច្រើននៃរូបចម្លាក់ គឺព្រះវិស្ណុជិះលើគ្រុឌៗតែងតែលើកដៃទៅលើបង្ហាញពីការចុះចាញ់ឫទ្ធិរបស់ព្រះវិស្ណុ ពេលនោះហើយដែលព្រះវិស្ណុអាចជួយព្រះម៉ែបាន (នេះជានិមិត្តរូប)។ ឈ្មោះរបស់

ប្រាសាទក្រវ៉ាន់ ឬក្រវាត់នេះ មានន័យស្រដៀង នឹងឈ្មោះត្បែងមានជ័យដែរ គឺចងក្រវាត់ត្បែងបាន ដោយជោគជ័យ។ ដូចពាក្យចាស់ចំណាំនិយាយតគ្នាថា សត្វត្រកួតគេចងកវានឹងកន្ទុយខ្លួនឯង ចំណែកព្រះមាតាបិតាភាគច្រើន ចងកព្រះកូនចៅប្រុសស្រី(ចំណងប្រាំប្រការ) ដោយហេតុពួកគាត់ មានសេចក្ដីលោភលន់ សុខចិត្តដាច់សីលរួចធ្វើបាបកម្មគ្រប់បែបយ៉ាង ព្រោះចង់ទុកកេរមរតកឲ្យកូន ចៅជំនាន់ក្រោយ រស់ក្នុងភាពចុំថ្កើង។ ចំណែកខ្លួនឯងសុខចិត្តធ្លាក់ក្នុងអបាយភូមិ ទើបស្ដាយក្រោយ ហើយស្រែកហៅឲ្យកូនជួយជាខាងក្រោយ (ទំនួញប្រេត) តើមានសារៈប្រយោជន៍អ្វីដែលពួកគេមិន ជឿព្រោះមើលមិនឃើញ ដូចមានរឿងព្រះម៉ែមហានគរជាភស្តុតាងស្រាប់ ដែលពួកគាត់នៅជាប់ ទោសរហូតមកដល់សព្វថ្ងៃ។

**១០.ប្រាសាទបន្ទាយសំរែ**(ខេត្តសៀមរាប)

**ពន្យល់ពាក្យ**(ស្រែ)

ស្រែ = អ្នកស្រែដែលរស់នៅជិតផ្លូវជាតិ មានវប្បធម៌ស្រដៀងនឹងអ្នករស់នៅទីក្រុងដែរ

សំរែ = អ្នកស្រែរស់នៅជ្រៅដែលពុំមានវប្បធម៌ជឿនលឿន

កាលសម័យពីដើមពួកនេះ បើឃើញរថយន្តបើកចូលទៅ គេនាំគ្នាយកអំពៅ ឬស្មៅទៅឲ្យ រថយន្តស៊ី ព្រោះពួកគាត់សម្គាល់ថាជាគោ ដំរី សេះ... ឬបើធៀបមកក្នុងន័យបច្ចុប្បន្ន គឺមនុស្សដែលពុំ ចេះប្រើប្រាស់ បច្ចេកវិជ្ជាទាន់សម័យ នោះហើយគឺអ្នកសំរែ ដែលខ្លួនដើរមិនទាន់សម័យសម្ភារៈ និង បច្ចេកវិជ្ជាទំនើបនិយមនឹងគេ។




អាថ៌កំបាំងនៃពាក្យប្រាសាទបន្ទាយសំរែនេះ ព្រះ ម៉ែគាត់ចង់ប្រាប់ពីបុគ្គលិកលក្ខណៈពូជពង្ស កូននាគ ដែលត្រូវមកនាំគាត់ចេញពីក្នុងគុកទាំងបីជាន់នោះ ព្រោះ ប្រាសាទនេះគេធ្វើបីជាន់ មានរូបព្រះវិស្ណុដេកដឹកម្ដាយ ចេញជាពូជអ្នកសំរែបានន័យថា ពូជពង្សនេះមានឋានៈ

ទាបជាងអ្នកស្រែចម្ការទៅទៀត។ តើងាយអ្វីនិងគេស្គាល់គាត់? (ខ្ញុំបានពន្យល់ក្នុងភាគ១រួចហើយ) ហើយនៅក្នុងប្រាង្គកណ្ដាល មានកូនមឈូសថ្មតូចមួយនៅពីខាងមុខដែលសព្វថ្ងៃគេពន្យល់ប្រាប់ថា ដាក់សាកសពស្ដេច ហើយនៅកណ្ដាលប្រាង្គ មានអណ្ដូងមួយសព្វថ្ងៃត្រូវថ្មលុបជិតអស់ហើយ តែយើងឆ្ងល់ថាកូនមឈូសដ៏តូចនេះ ធ្វើដូចម្ដេចអាចដាក់សាកសពមនុស្សចាស់ (ស្ដេច) បាន? ហើយបើសិនជាបូជាហើយយកធាតុទៅដាក់ ក៏ពុំត្រឹមត្រូវទៀត ព្រោះខ្មែរយើងមានទំនៀមយកធាតុទៅដាក់ក្នុងកោដិ នេះជាប្រស្នាមួយដែលដូនតាយើង ទុកឲ្យកូនចៅនាគសម័យក្រោយស្វែងរកការពិតនេះដោយខ្លួនឯង។ រីឯអណ្ដូងក្នុងប្រាង្គកណ្ដាលនៃប្រាសាទវិញ គឺមានអត្ថន័យដូចអណ្ដូងនៅចន្លោះដោះទាំងគូ នៅឯលើភ្នំសន្ទុក និងអណ្ដូងក្នុងប្រាសាទបាយ័ន ព្រោះបើចង់ដឹងបណ្ដាំរឿងព្រះម៉ែពីព្រេងនាយ ត្រូវកូនចុះក្នុងអណ្ដូងព្រះម៉ែ ឬទ្រូងម៉ែ ទើបដឹងរឿងក្នុងបេះដូងគាត់។

## ១១.ប្រាសាទបន្ទាយស្រី

ប្រាសាទបន្ទាយស្រីនេះ មានន័យថា ជាទីតាំងលាក់នូវបណ្ដាំរឿងរាវរបស់ស្ត្រី ហើយស្ត្រីនោះមិនជាអ្នកដទៃណាឡើយ គឺស្ត្រីដែលជាព្រះម៉ែម្ចាស់មាតុភូមិនេះ ព្រោះរូបរឿងដែលឆ្លាក់ភាគច្រើននិយាយប្រាប់ពីរឿងកូនចៅជួយព្រះម៉ែដែលជាប់ឃុំ។

នៅក្នុងចំណោមរូបរឿងថ្មទាំងអស់ មានរឿងក្នុងក្បាំងក្លែងមួយបាននិយាយរៀបរាប់ពីព្រះវិស្ណុអង្គុយលើបល្ល័ង្ក មានមហេសីអង្គុយលើភ្លៅ ដៃកាន់ឈើ ស្ទួនរលាស់ទឹកឲ្យព្រះមាតាបិតានៅជាន់


ផ្ទាំងក្លែងប្រាសាទបន្ទាយស្រី

ខាងក្រោម រួមទាំងញាតិវង្សានុវង្ស ឲ្យបានរួចពីអំណាចរបស់ យក្សទសមុខ(យក្សមានមុខដប់)។ យក្សទសមុខនេះ បានដាក់ទោសព្រះម៉ែព្រះឪ ដែលជាប្រមុខអ្នកដឹកនាំពី អតីតដែលយើងបានឃើញនៅក្នុងរឿងកូរសមុទ្រទឹកដោះ តែរូបយក្សទសមុខនោះ ត្រូវរលំដួលបន្តិច ម្ដងៗដោយអំណាចទឹកមន្តគឺ កតញ្ញូកតវេទីរបស់ ព្រះវិស្ណុរលាស់ពីខាង

លើ។ នេះគ្រាន់តែជាការបកស្រាយអាចខុសខ្លះខុសត្រូវសៗ ក្នុងរូបចម្លាក់រឿងមួយក្នុងចំណោមរូបរាប់ពាន់ម៉ឺនសែន ឲ្យមកជារឿងរបស់ព្រះម៉ែព្រះឪខ្មែរសុទ្ធសាធ ព្រោះខ្ញុំពុំយល់ថារឿងចម្លាក់នៅក្នុងថ្មទាំងអស់នោះ វាពុំមែនជារឿងក្នុងសាសនានោះឡើយ ព្រោះប្រាសាទទាំងអស់នេះ ជាបណ្ដាំកេរមរតកគំនិតព្រះម៉ែ នេះជាការបកស្រាយដោយសង្ខេបពីឈ្មោះ **ប្រាសាទបន្ទាយស្រី** និងរូប។

### ១២.ប្រាសាទតាសោម

**ពន្យល់ពាក្យ** (សោម)

សោម = ព្រះចន្ទ ព្រះបាទកុវេរៈ ព្រះសិវៈ អាកាស ខ្យល់ ឈ្មោះទឹកអម្រឹតរបស់ពួកទេវតា ឈ្មោះវល្លិមួយប្រភេទ សំរាប់ស្ងោរយកទឹកមកធ្វើថ្នាំ (មើមសោម ទឹកសោម) ចុះពាក្យថាប្រាសាទតាសោមតើមាននៅក្នុងន័យមួយណា? ចម្លើយ សូមកូននាគប្រុសស្រីគិតឈ្វេងយល់ដោយខ្លួនឯងចុះ តាមការពន្យល់ពាក្យខាងលើ។

នៅក្នុងខេត្តតាកែវ មានទីប្រជុំជនមួយស្ថិតនៅក្នុងស្រុកត្រាំកក់ ឈ្មោះថាអង្គតាសោម។ អង្គនេះ កើតមានមុនប្រាសាទតាសោម ព្រោះឈ្មោះទីអង្គនេះ កើតមានក្នុងសម័យ **ព្រះម៉ែសក់ក្រអូប** (ប្រាយ៉ង់កោរ ពន្យល់រួចហើយ) ដូច្នេះពាក្យដែលដូនតា បានយកមកសម្គាល់ជាឈ្មោះ តែងតែវិវឌ្ឍន៍ទៅតាមកាលវេលានៃការផ្លាស់ប្ដូរទីកន្លែង ហើយថែមទាំងមានបង្កប់នៅអត្ថន័យ ក្នុងឈ្មោះនោះទៀតផង សម្រាប់ទុកជាត្រីវិស័យចង្អុលផ្លូវ ទៅរកសាវតាពិតពីអតីតកាល។

### ១៣.ប្រាសាទនាគព័ន្ធ (មើលរូបភាពប្រាសាទក្នុងទំព័រ **២៣** )

**ពន្យល់ពាក្យ** (នាគព័ន្ធ)

នាគ = (ពន្យល់រួចហើយក្នុងភាគ១)

នាគព័ន្ធ = នាគវេញចូលគ្នា នាគព័ន្ធគ្នា នាគសាមគ្គីគ្នា (កូនខ្មែរប្រុសស្រីសាមគ្គីបែបនាគព័ន្ធ)

នាគពាន់ = ពូជនាគកើតមានរាប់ពាន់ជំនាន់មកហើយ (រាប់ពាន់ឆ្នាំ)

អត្ថន័យរបស់ឈ្មោះប្រាសាទនេះ ខ្ញុំបានពន្យល់ខ្លះៗហើយនៅទំព័រមុន ពេលនេះខ្ញុំគ្រាន់តែលើកយកមកបញ្ជាក់ នៅចំណុចណាដែលខ្ញុំមិនទាន់បានពន្យល់។ ប្លង់របស់ប្រាសាទនេះ បើមើលពីខាងលើ គឺដូចសញ្ញា**កាកបាទ** (សញ្ញាលេខបូក) ព្រោះដូនតាយើងគាត់បានបញ្ជាក់ពីន័យសាមគ្គីជាកម្លាំងធ្វើឲ្យរឹងមាំ គឺត្រូវតែបូកពុំមែនដក ឬក៏ចែកឡើយ។ ដូច្នេះកូននាគទាំងពីរភេទ ចង់ឲ្យនគរមានឫទ្ធានុភាពឡើងវិញ ទាល់តែកូននាគបូកគ្នា ព័ន្ធគ្នា ហើយដឹងរឿងរបស់ព្រះមេនាគ កាលពីរាប់ពាន់ឆ្នាំមុន ទើបអាចក្លាយជាកម្លាំងមហាសាមគ្គី ដែលអាចនាំនគរឈានទៅរកអានុភាពរុងរឿងឡើងវិញ ប្រសិនបើកូននាគ




នៅក្រោមមនោគមវិជ្ជា បំបែកនាគរបស់បរទេសនោះ គឺមិនអាចរឹងមាំ និងមានមហិទ្ធិឫទ្ធិរុងរឿងថ្កុំថ្កើងបានឡើយ។ បើយើងក្រឡេកមើលទៅខាងក្នុងទឹក ឃើញមានរូបចម្លាក់សេះមួយកំពុងជញ្ជូនមនុស្ស យកទៅដាក់នៅលើប្រាសាទមួយ ដែលអណ្ដែតចេញពីផ្ទៃទឹក ហើយនៅជាន់ខាងក្រោមប្រាសាទ មាននាគមួយគូកំពុងព័ន្ធកន្ទុយគ្នា វេនព័ទ្ធជ្រោងប្រាសាទនោះឡើង (នេះជារអាថ៌កំបាំងប្រស្នារបស់នាគព័ន្ធ)។ ចំណែកឯទឹកនៅខាងក្រោម និងជុំវិញប្រាសាទ គឺតំណាងឲ្យទឹកចិត្តរបស់ព្រះម៉ែនាគ និងតំណាងឲ្យមនោគមវិជ្ជាបរទេស ដែលធ្លាប់គ្របសង្កត់ និងធ្វើអាណានិគម ប៉ុន្តែពេលដែលនាគចាប់ផ្ដើមព័ន្ធគ្នា កម្លាំងសាមគ្គីអាចធ្វើឲ្យប្រាសាទអណ្ដែត ផុតពីអំណាចបរទេស ហើយមានមហិទ្ធិឫទ្ធិរុងរឿងដូចជាសម័យមហានគរវិញ។ នៅខាងចុងទាំងបួននៃសញ្ញាលេខបូក មានប្រាង្គគ្របទៅលើមុខគ្រប់ទិសទាំងបួន (និមិត្តរូបលាក់បាំងរឿងព្រះម៉ែ)។ មុខទាំងបួននេះ តាមឯកសារបរទេសគេពន្យល់ថា ទឹកដែលហូរចេញពីមាត់នៃរូបទាំងបួន គឺជាថ្នាំសំរាប់ព្យាបាលរោគក្នុងធាតុទាំងបួន ព្រោះគ្រប់មនុស្សសត្វតែងមានធាតុបួន (ទឹក ដី ភ្លើង ខ្យល់) ចំណែកការយល់ពីរូបមុខទាំងបួនរបស់ខ្ញុំវិញ គឺផ្ទុយពីទស្សនៈរបស់បរទេស ខ្ញុំសូមធ្វើការបកស្រាយតាមការស្រាវជ្រាវរបស់ខ្ញុំ ក្នុងបណ្ដាំប្រស្នាគំនិតព្រះម៉ែ។

១.**រូបក្បាលព្រះម៉ែ** ពាក់មកុដរាជកប់ត្រឹម**ក**មាត់ហាស្រែកហៅកូនឲ្យជួយ នៅលើក្បាលដែលមានពាក់មកុដ ត្រូវទូលយោនីខ្លួនឯង (ឋិតនៅទិសខាងកើត)។


មុខព្រះម៉ែ នៅប្រាសាទនាគព័ន្ធ

តើអត្ថន័យរបស់រូបនេះ ដូនតាចង់និយាយពីអ្វី? ព្រះម៉ែគាត់ផ្តែផ្តាំបញ្ជាក់ប្រាប់កូនថា កាលដែលក្បាលម៉ែមានពាក់មកុដ និងទូលយោនីខ្លួនឯង មកុដតំណាងពេលដែលម៉ែកំពុងគ្រប់គ្រងនគរ(សោយរាជ) យោនីតំណាងទ្វារសម្រាប់បង្កើតនូវកូនប្រុសស្រី ព្រោះហេតុតែតាំងខ្លួនជាម៉ែគេទីបំផុតបាបទាំងឡាយ ដែលខ្លួនបានប្រព្រឹត្ត ព្រោះហេតុនៃការតាំងខ្លួននោះ ត្រូវតែទូលភេទខ្លួនឯង។ រីឯមាត់ហាធំមានហូរទឹកចេញ គឺតំណាងឲ្យទឹកចិត្តក្នុងបេះដូងរបស់ព្រះម៉ែ ស្រែកហៅកូនប្រុសស្រីឲ្យជួយ ដែលទឹកចិត្តនេះ ហូរតាំងពីដាប់ទោសដំបូងរហូតមកដល់សព្វថ្ងៃ ទឹកនេះហូរស្ទើរតែជុំវិញផែនដីទៅហើយ។ ក្បាលកប់ត្រឹម **ក** ខ្ញុំមិនពន្យល់ឡើយ ទុកឲ្យកូននាគប្រុសស្រី ស្វែងយល់ដោយខ្លួនឯងចុះ។ ចំណែកឯមុខម៉ែនេះ គេកសាងទុកនៅទិសខាងកើត មានន័យថា មុនគេគឺគាត់នេះហើយ ដែលបាន **កកើត** ទឹកដីមាតុនេះមុនគេ ខ្ញុំបានពន្យល់ក្នុងអាថ៌កំបាំង (ក្មេរ ➜ ខ្មែរ) ក្នុងភាគមួយ។

២.**រូបក្បាលសេះ** នៅទិសខាងលិច គឺទល់នឹងមុខព្រះម៉ែដែលនៅទិសខាងកើត តើអត្ថន័យរបស់រូបនេះ ដូនតាចង់និយាយប្រាប់យើងពីអ្វី? រូបក្បាលសេះនេះ សព្វថ្ងៃបាក់បែកស្ទើរតែមើលពុំយល់ ហើយរូបដដែលនេះ ក៏មានទឹកហូរចេញតាមមាត់ដែរ ពាក្យសេះ


មុខក្បាលសេះនាគព័ន្ធ

តំណាងឲ្យឆ្នាំមមី ខែអស្សុជ ដែលមានផ្កាយរូបសេះ រះជិតផ្កាយកូនមាន់ តំណាងឲ្យខែកត្តិក ដែលខ្ញុំបានពន្យល់ហើយក្នុងពិធីបុណ្យអុំទូក។ ឆ្នាំមមីឬសេះ តំណាងឲ្យឆ្នាំ ដែលគាត់រួចចេញពីទីឃុំឃាំងលើកទីពីរ នៅថ្ងៃពុធ ១២រោច ខែបុស្ស ឆ្នាំមមី ព.ស២៥៤៦ និងតំណាងឲ្យមនុស្ស ដែលកើតឆ្នាំមមី (រូបមនុស្ស ក្បាលសេះ) ដែលចូលរួមជួយព្រះម៉ែ និងរូបនៅក្នុងគុកលានដល់ដំរី ក៏គេឆ្លាក់រូបសេះមានក្បាលប្រាំដែរ។ ពាក្យថាមមីនេះ មាន

ន័យមួយផ្សេងទៀត គឺមិនទាន់ស្វាងល្អនៅងោកងក់ធ្វើភ្នែកមមី បានន័យថាមកទល់នឹងសព្វថ្ងៃនេះ ព្រះម៉ែរួចពីទោសជាងពាក់កណ្ដាលហើយ តែកូននាគនៅងោកងក់ធ្វើភ្នែកមមី មិនដឹងរឿង**ម៉ែ**ដដែល។

៣.***រូបក្បាលដំរី***(ទិសខាងត្បូង) រូបក្បាលដំរីតំណាងឲ្យអ្វី?




រូបក្បាលដំរីនេះ ក៏មានទឹកហូរចេញពីមាត់ដែរ ហើយដូនតាគាត់ចង់ពន្យល់ប្រាប់ថា កាលដែលគាត់ធ្វើរូបនេះនៅទិសខាងត្បូង គឺទិសខាងក្បាល (ត្បូង = ក្បាល) ហើយក្បាលដំរីធំ តំណាងឲ្យក្បាលពោរពេញដោយបញ្ញា នឹងមានមហិទ្ធិឫទ្ធិអាចកសាង បង្កើតនូវចក្រភពអង្គរបាន។ ក្បាលដ៏ធំនេះពីមុនមានក្បាលតែមួយទេ ក្រោយមកក្បាលនេះត្រូវគេហែកជាបី(លានជល់ដំរី) ព្រោះរូបរឿងក្នុងលានជល់ដំរី ហ្មដែលនៅលើក្បាលដំរីទាំងបីនោះឈ្លោះគ្នា រួចហ្មបញ្ជាដំរីឲ្យបោចផ្កាឈូកចោល ដើម្បីឲ្យដោយផ្កាឈូក ដែលធំជាងគេនៅលើខ្នង។ ចំណែកឯក្បាលដំរីក្នុងប្រាសាទនាគព័ន្ធ មាត់ហូរទឹកចេញ គឺព្រះម៉ែគាត់ចង់ប្រាប់ថា ដំរីកំពុងដង្ហោយហៅហ្ម មកជួយស្រង់ដំរីឡើងវិញ គឺបង្រួមក្បាលដំរីដែលហែកជាបីឲ្យរួមមកមួយវិញ **ដូចមានប្រស្នាពោលទុកក្នុងទំនាយពារសុក្រពារសៅរ៍ថា ដំរីរេចរត់រកទ្រមាក ឃើញម្លប់ត្រជាក់សំណាក់ប្រាណ ទំរាំចាំពេលវេលាឲ្យបាន ទើបចរចេញឋានម្លប់នោះឯង**។ ដូច្នេះហើយទើបនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវមានភ្នំមួយឈ្មោះ ភ្នំដំរីរមៀល ដែលដំរីនេះបានពួនរឿងខ្លួនទៅជាភ្នំ កំពុងរមៀលចុះក្រោមតាមរកហ្មរបស់ខ្លួនដែលជាពូជទាប(បន្ទាយសំរែ)។

## ៤.*រូបក្បាលរាជសី ឬគោ*



មុខនេះស្ថិតនៅក្នុងគម្របដំបូលទិសខាងជើង គឺទល់នឹងទិសមុខដំរី (ត្បូង) ហើយមុខចុងក្រោយនេះ ក៏មានទឹកហូរចេញពីមាត់ដូចមុខបី ដែលបានរៀបរាប់ហើយពីខាងលើដែរ។ តាមការស្រាវជ្រាវ និងយល់ឃើញ

*របស់ខ្ញុំ ដូនតាគាត់ចង់ប្រាប់ថា កាលដែលគាត់កសាងរូបនេះនៅទិសខាងជើង ខាងជើងមានន័យថា ផ្ទុយពីត្បូង(ក្បាល) នៅទិសទាប ទិសក្រោម ឬក៏ក្រោយ ព្រោះទិសខាងក្បាលដំរី គឺកើតមុន (ទីក្រុងយសោធបុរៈ ឬទីក្រុងដំរី) ចំណែកឯខាងជើងកើតក្រោយ គឺទីក្រុងក្បាលរាជសី ឬទីក្រុងសីហនុ សព្វថ្ងៃក្លាយទៅជា (ខេត្តព្រះសីហនុ)។ នៅប្រាសាទបន្ទាយស្រី គេមានឆ្លាក់រូបមនុស្សក្បាលគ្រុឌ ក្បាលស្វា ក្បាលហង្ស ឬមាន់ ក្បាលរាជសី ឬគោ និងមនុស្សតឿ(តំណាងឲ្យមនុស្ស ដែលមានឋានៈតូចទាប)។ យើងសាកល្បងប្រៀបធៀបសិល្បៈខ្មែរ និងអេស៊ីប ស្តេចហ្វារ៉ាអុងអេស៊ីប គេឆ្លាក់ខ្លួនគាត់ជាគោ ក្បាលជាមនុស្ស នៅសិង្ហបុរី គេឆ្លាក់ខ្លួនត្រីក្បាលតោ ចំណែកឯដូនតាខ្មែរវិញ គាត់ឆ្លាក់ខ្លួនជាមនុស្សឯក្បាលជាគោ តើកូនចៅប្រុសស្រីអ្នកយល់យ៉ាងណា ចំពោះប្រស្នានេះ? សូមរកចម្លើយដោយខ្លួនឯង។ នៅឯប្រទេសឥណ្ឌាវិញ សរសរស្តម្ភដែលជាស្នាព្រះហស្តព្រះបាទធម្មាសោក (អសោករាជ) គាត់ក៏បានឆ្លាក់រូបរាជសីឬគោ នៅឈរលើសរសរស្តម្ភនោះដែរ តើរូបចម្លាក់គោនោះ អាចមានទាក់ទងអ្វីនឹងរូបគោរបស់ដូនតាខ្មែរ? នេះគ្រាន់តែជា គំនិត ដែលយកមកឆ្លុះបញ្ចាំងប្រៀបធៀបសិល្បៈវប្បធម៌បរទេសក្នុងពិភពលោក ជាមួយនឹងសិល្បៈវប្បធម៌ដូនតាខ្មែរ ពីអតីតកាលតែប៉ុណ្ណោះ ចំណែកចម្លើយកូនចៅស្រាវជ្រាវពិចារណាចុះថាតើអនាគត រាជសីពិតប្រាកដ តើកើតនៅប្រទេសណា? អាថ៌កំបាំងសត្វដំរី និងសត្វរាជសីនេះ ដូនតាបានឆ្លាក់បកស្រាយនៅលើផ្តែររឿងមួយផ្ទាំងនៅប្រាសាទបន្ទាយស្រី ព្រោះចម្លាក់រឿងនេះ បានរៀបរាប់ពីសត្វទាំងពីរ កំពុងរាំហើយរឹលចូលគ្នា រួចរលាយកើតជាសត្វមួយទៀត គឺសត្វគុជសី។ យើងដឹងហើយថាស្តេចរបស់ពពួកសត្វចតុប្បាទ គឺ***រាជសី***




*ស្តេចពពួកសត្វស្លាប(បក្សាបក្សី) គឺរាជហង្ស ស្តេចរបស់សត្វល្មូន គឺនាគរាជ ស្តេចរបស់ពួកមច្ឆា គឺសុវណ្ណមច្ឆា ឬទេពមច្ឆា ... មាននៅក្នុងរឿងព្រេងខ្មែរ។* ***ចុះសត្វគុជសី មានន័យដូចម្តេច?*** *សត្វ* ***គុជសី*** *គឺជាសត្វពីររួមចូលគ្នា ពាក់កណ្តាលដំរី ពាក់កណ្តាលរាជសី នេះជាប្រស្នាបណ្តាំរបស់ដូនតាដែលគាត់ចង់និយាយប្រាប់ថា ទីក្រុងពីររលាយចូលគ្នា ទើបស្វែងរកបណ្តាំពិត របស់ព្រះម៉ែមហានគរឃើញ ប្រសិនបើមានតែជើងអត់ក្បាលក៏ស្រាយពុំរួច មានក្បាលអត់ជើង ក៏ទៅមុខពុំរួចដូចគ្នា។ ដូច្នេះ*

ហើយទើបគាត់សាងរូបប្រស្នាទុកក្នុងប្រាសាទនាគព័ន្ធ ទីមួយគឺសត្វរាជសីជិះលើដំរី(រូបជុំវិញប្រាង្គខាងលើសព្វថ្ងៃបាក់បែកអស់) ទីពីរគឺរូបក្បាលដំរីនៅទិសខាងត្បូង និងក្បាលរាជសី នៅទិសខាងជើង។ ហើយដូនតាគាត់ចង់ប្រាប់យើងទៀតថា ចង់ដឹងបណ្ដាំរឿងពិតរបស់ ព្រះម៉ែទាល់តែបង្វែរទឹក ដែលហូរចេញពីមាត់ក្នុងទិសទាំងបួន (ទឹកចិត្ត) ឲ្យមក រួមបញ្ចូលគ្នាតែមួយវិញ (បូក)ទើបដឹងរឿងបណ្ដាំព្រះម៉ែហើយអាចជួយគាត់បាន។ ហើយក្នុងឈ្មោះសត្វរាជសីនេះ ដូនតាគាត់បានសរសេរនៅក្នុងទំនាយថ្ងៃសុក្រ ថ្ងៃសៅរ៍(សា ស្ត្រា ពារសុក្រ សា ស្ត្រាពារសៅរ៍) បានសម្ដែងថា ៖

**អស់**ឱអាសូររាជសីសត្វ សព្វថ្ងៃជ្រកបាត់ក្នុងហេមពាន្ត
មិនឃើញអ្នកមកចេញទូន្មាន ឬអាក់អន់អៀនដំណើរអ្វី។
ឬមួយឃើញបឹងរីងហែងហួត ពិរុណរាំងស្ងួតវិនាសត្រី
ឬឃើញស្មាពីរលើឃ្លាងបី ទើបបានអ្នកថ្លៃមិនចេញមក។
បាត់សូន្យយ៉ាងហ្នឹងដឹងយ៉ាងណា ឬចាំអាចារ្យទៅតាមរក
ឬមួយគ្មានម្លប់នឹងឈប់ជ្រក ទើបកែវពន្លកមិនមកអាយ។
ម្ដេចអ្នកមិនអាសូរសព្វសត្វ រង់ចាំពេកក្ដាត់លំបាកកាយ
សព្វថ្ងៃគ្មានសោះហៅសប្បាយ ព្រួយណាស់ហើយណាយឥតឧបមា។
ហៃជនទាំងឡាយចូរស្ដែងស្ដាប់ អស់អាថិសារសព្វគ្រប់ប្រការ
ពីលោកអ្នកប្រាជ្ញចែងចរចា ចោទចងប្រស្នាដោយប្រាជ្ញប្រាណ។

បើតាមទំនាយខ្ញុំបាទបានដកស្រង់ក្នុងវគ្គ ដែលទាក់ទងនឹងរាជសីនេះ គឺដូនតាយើងគាត់បាន បំបែកប្រស្នារបស់សត្វនេះ ចេញពីក្នុងថ្លុរចបញ្ចូលក្នុងទំនាយ ប៉ុន្តែបើតាមទំនាយបុគ្គល ដែលជាតួអង្គរាជសីនេះ លំបាកណាស់ វេទនាណាស់ ព្រោះគេអាណិតអាសូរ ហើយគាត់សម្ងំលាក់ខ្លួនក្នុងព្រៃមនុស្សមួយនគរ តើងាយអ្វីនឹងរកគាត់ឃើញ (ព្រៃហេមពាន្ត = ព្រៃមនុស្សមួយនគរ។


ចម្លាក់បន្ទាយស្រី

សព្វថ្ងៃយើងស្គាល់គាត់បាន ទៅតាមប្រស្នារូបចម្លាក់តែប៉ុណ្ណោះ ដូច្នេះហើយ ទើបពួកបរទេសចូលចិត្តឲ្យគេដាប់ក្បាលរូបចម្លាក់ចោល(ក្បាលអ្នកតា) រួចហើយគេឧបកិច្ចឲ្យបុគ្គលនោះដាច់ក្បាល ដូចជាស្តេចជ័យវរ្ម័នទីពីរ ធ្លាប់ឧបកិច្ចកាត់ករូបចម្លាក់ស្តេចថ្វាយ៉ាងដូច្នោះ។ តើគេឧបកិច្ចឲ្យគាត់ស្លាប់ ឬវិនាសប្រយោជន៍អ្វី? បើតាមរូបរឿងចម្លាក់ក្នុងប្រាសាទ គឺមានតែគាត់ម្នាក់គត់ ដែលអាចប្រែរូបព្រះម៉ែដែលដេកស្លាប់ រាប់រយពាន់ឆ្នាំនោះ ឲ្យរស់ឡើងវិញបាន រូបរឿងនេះ ខ្ញុំបានឃើញក្នុងប្រាសាទប្រែរូប ដែលគេឆ្លាក់មនុស្សមានមុខតោ ឬរាជសីបីស្ត្រីជា ព្រះម៉ែដាក់នៅលើភ្លៅ (ពន្យល់រួចហើយអាថ៌កំបាំងប្រាសាទប្រែរូប) និងរូបមួយទៀតនៅប្រាសាទបន្ទាយស្រី គេឆ្លាក់គាត់ឈរជើងតែមួយចំហៀង ផ្តេកស្ត្រីជា ព្រះមាតានៅលើភ្លៅ រួចដៃទាំងពីរកំពុងច្របាច់ស្នាមហែកជាបីឲ្យរួមមកជាមួយវិញ (ដំរីក្បាលបីឬស្ត្រីហែកជាបី) តែគួរឲ្យអនិច្ចាណាស់ក្បាលរបស់បុរសនោះ ត្រូវបានគេដាប់ចោលរួចឧបកិច្ច ឲ្យដាច់ក្បាលបាត់ទៅហើយ (មើលរូបខាងលើ)។

ហើយនៅក្នុងប្រាសាទនាគព័ន្ធនេះដដែល កាលសម័យដែលសៀមចូល មកលុកលុយក្រុងអង្គរ ពួកគេបាននាំយក រូបបដិមាអាទិទេពខ្មែរ ដែលជាបេះដូងប្រាសាទនាគព័ន្ធ ទៅកាន់**ក្រុងស្រីអយុធ្យា**។ ហើយពួកវាថែមទាំងបំផ្លិចបំផ្លាញប្រាសាទនេះ ក្នុងឆ្នាំ១៤៣១ នៃគ.ស (តាមពង្សសាវតាសៀម) ព្រោះពួកគេយល់ថា ការបំផ្លាញប្រាសាទនាគព័ន្ធបាន គឺជាការបំផ្លាញដួងកែវអំណាចចក្រពត្តិរបស់ស្តេចជ័យវរ្ម័នទី៧ (ដួងកែវខ្មែរ) និងស្តេចដែលត្រូវសោយរាជ្យ បន្ត ពីព្រះអង្គក្រោយៗ។ នៅស.វទី១៦ ភូមាបានចូលលុកលុយ ឈ្លានពានដល់ក្រុងស្រីអយុធ្យា រូបបដិមាការពារប្រាសាទនាគព័ន្ធ (ដួងកែវនាគព័ន្ធ) ដែលសៀមបានយកទៅនោះ ត្រូវបានភូមាយកទៅទុកក្នុងប្រទេសរបស់ខ្លួន ហើយឥឡូវបដិមានេះ ប្រហែលជា នៅក្នុងទីក្រុង **ម៉ានដាឡេ** ឯកសារនេះ ខ្ញុំដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រខ្មែរ សរសេរដោយលោក ដេវិឌឆាណ្ឌលែរ (DavidChandler)។ សរុបសេចក្តីមកការបកស្រាយ និងពន្យល់ដោយសង្ខេបពីអាថ៌កំបាំងរបស់ឈ្មោះប្រាសាទនេះ គឺជាហេតុផលដ៏ធំ មួយ និងពិតប្រាកដដែលគាត់

ចង់ឲ្យកូននាគទាំងស្រីប្រុស រួមសាមគ្គីព័ន្ធគ្នាឡើង ដែលមានន័យគ្រប់គ្រាន់នៅក្នុងប្លង់ **លេខបូក** និងរឿងរ៉ាវក្នុងប្រាសាទនោះ ព្រោះជាតិយើងបាន រងទុក្ខវេទនាគ្រាំគ្រាខ្លោចផ្សា និងទុំឌទ្រោមជាច្រើន ស.វ ហើយ ជាពិសេសនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលជាសម័យរំលាយបេះដូងជាតិខ្មែរ (ព្រះម៉ែ) ឲ្យធ្លាក់ចុះក្នុងអន្លង់ដ៏សែនអន្ធការ។

## ១៤. ប្រាសាទតាព្រហ្ម

ប្រាសាទនេះស្តេចជ័យវរ្ម័នទី៧ លោកធ្វើឧទ្ទិសឲ្យព្រះម៉ែ ចុះបើប្រាសាទនេះធ្វើឧទ្ទិសឲ្យម្តាយ ហេតុអ្វីបានជាឈ្មោះប្រាសាទ មាននាមថាតាព្រហ្មទៅវិញ? ប្រាសាទតាព្រហ្មនេះ មានពីរ មួយនៅខេត្តសៀមរាប មួយទៀតនៅខេត្តតាកែវ (ទន្លេ បាត់ទី) កសាងក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៧។

ពន្យល់ពាក្យ (តាព្រហ្ម)

តា = មនុស្សប្រុសដែលមានវ័យចំណាស់ ជាឪពុករបស់ឪពុកយើង (ហៅថាតា)

ព្រហ្ម = សេចក្តីរីកចិត្ត សេចក្តីប្រសើរចំណែកចិត្ត វេទសីល (មេត្តា ករុណា មុទិតា ឧបេក្ខា ព្រហ្មវិហារធម៌)

តាព្រហ្ម = តាដែលជាឪពុករបស់ឪពុកមាននៅព្រហ្មវិហារធម៌៤ ឬមានចិត្តដ៏ប្រសើរ

ប្រាសាទតាព្រហ្មនេះ ដូនតាគាត់ចង់បញ្ជាក់ប្រាប់យើងថា គាត់មានព្រហ្មដល់ទៅពីរជាន់ ជាន់ទីមួយគាត់មានចំពោះកូនប្រុសស្រីបង្កើត ឯព្រហ្មជាន់ទីពីរ គាត់មានព្រហ្មវិហារធម៌ចំពោះកូននាគទូទៅ ហើយជាពិសេសទៅទៀតនោះ គាត់មានព្រហ្មចំពោះព្រះមាតាព្រះបិតាមហានគរ ដែល កូននាគសម័យនេះ នាំគ្នាភ្លេចគាត់អស់ទៅហើយ។ តាព្រហ្មនេះហើយ ជាតួអង្គរាជសីក្នុងទំនាយ និងជាតួអង្គក្នុងរូបចម្លាក់ ដែលសព្វថ្ងៃគាត់កំពុងសម្ងំលាក់ខ្លួន ក្នុងព្រៃមនុស្សព្យាយាមជួយស្រង់ អ្នកមានគុណចេញពីទីឃុំក្នុងសមុទ្រទឹកដោះ នេះជាហេតុដែលដូនតាដាក់ ឈ្មោះប្រាសាទដែលធ្វើឧទ្ទិសឲ្យព្រះម៉ែនេះឈ្មោះថា**តាព្រហ្ម**។

## ១៥.ប្រាសាទព្រះខាន់ ឬខ័ន (ប្រាសាទជ័យស្រី)

**ពន្យល់ពាក្យ** (ព្រះខ័ន និងជ័យស្រី)

ព្រះ = ប្រសើរ ខ្ពង់ខ្ពស់ លើសលន់ ជាចម្បង ដែលគួរប្រាថ្នា គួរចង់បាន

ខ័ន ឬខាន់ = មកពីពាក្យថា ខ័ឌ្គ (ខាត់) គ្រឿងសស្ត្រាវុធមួយប្រភេទ ដែលផ្លែរបស់វាមានមុខមុតទាំងពីរខាង មានសណ្ឋានដូចផ្លែលំពែង ប៉ុន្តែធំហើយវែងជាងផ្លែលំពែង ដងខ្លីជាងដងលំពែង ហើយមានស្រោមស័ករអាចសៀតចង្កេះបាន ដោយមានខ្សែចងស្រាក់ស្រោមនោះ។

ជ័យ = ឈ្នះ ជំនះ ការឈ្នះដែលផ្ទុយនឹងចាញ់

ស្រី = សិ + រី

ព្រះខ័ន = សស្ត្រាវុធដ៏ប្រសើរលើសលន់

ជ័យស្រី = ឈ្នះដោយមានសិរី ឈ្នះដោយអំណាចរបស់បុណ្យតាមឲ្យផល

ហេតុអ្វីបានជាដូនតាយើង ដាក់ឈ្មោះប្រាសាទនេះថា **ព្រះខ័ន ឬជ័យស្រី**ទៅវិញ? បើប្រាសាទនេះព្រះបាទជ័យវរ្ម័ន៧ លោកកសាងឧទ្ទិសឲ្យព្រះបិតានោះ នេះជាហេតុដែលខ្ញុំបាទត្រូវយកឈ្មោះនេះមកវែកញែកពិចារណា រាវរកគំនិតពិតរបស់ដូនតាយើង។ តាមការផ្ទៀងផ្ទាត់នូវអត្ថន័យក្នុងពន្យល់ពាក្យសម្គាល់ប្រាសាទនោះ ន័យទីមួយគឺអាវុធដ៏ប្រសើរលើសលុប ចំណែកឯន័យទីពីរឈ្នះដោយស្រី (សិរី) ជ័យស្រី គឺស្រីមានជ័យ។ បើយើងបូកបញ្ចូលគ្នាក្នុងឈ្មោះទាំងពីរ មានន័យថា **ស្រីមានជ័យ** ដោយអំណាចអាវុធដ៏ប្រសើខ្ពង់ខ្ពស់(បញ្ញា) ព្រោះពាក្យដូនតាយើងបានពោលទុកថា **ចំណេះជាអាហារ បញ្ញាជាអាវុធ** រីឯសុភាសិតរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងព្រះអង្គទ្រង់ត្រាស់សម្តែងក្នុងត្រៃសិក្ខាគឺ **សីល សមាធិ បញ្ញា** ព្រោះបញ្ញាក្នុងវិបស្សនាជាអាវុធសម្រាប់កាប់ឆ្ការនូវអវិជ្ជា (បញ្ញាលោកុត្តរ)។ ព្រោះកិច្ចសិក្សាក្នុងព្រះសាសនាមានបី គឺសីលសិក្ខា ចិត្តសិក្ខា (សមាធិ) និងបញ្ញាសិក្ខា

ហើយសិក្ខាខាងដើមពីរជាកម្លាំងឧបត្ថម្ភសិក្ខាខាងចុងឲ្យកាន់តែខ្លាំងក្លាឡើង ដែលអាចមានកម្លាំងកាប់ឆ្ការនូវអវិជ្ជាដែលជាឫសគល់នៃវដ្តសង្សារបាន។

នៅលើបាំងក្លែងប្រាសាទខាងក្រោយ ដូនតាគាត់បានឆ្លាក់រូបព្រះវិស្ណុដេកលើសត្វគុជសី គងលើព្រះម៉ែរួចនាំគាត់ចេញពីទីឃុំឃាំង ដែលនៅក្នុងដៃដែលច្រត់មានកាន់រាជសារ ដៃមួយទៀតទល់ក្បាល



រូបក្នុងបាំងក្លែងវិស្ណុផ្ទុំ(ព្រះខ័ន)

ចំណែកឯដៃស្តាំវិញ ដៃមួយកាន់ផ្កាឈូកហុចទៅឲ្យព្រះម៉ែ ដៃបែកមួយទៀតកាន់ដុំបណ្តាំរឿង (ហ្វីល) របស់ព្រះម៉ែ នៅខាងក្រោមសងខាង មានរូបឥសីម្ខាងបួនៗ កំពុងអង្គុយបញ្ឈរជង្គង់លើកដៃសំពះ នៅខាងក្រោមពោះគុជសីមានរូបអណ្តើកនិងត្រីជាច្រើន។ បើតាមអត្ថន័យក្នុងរូបចម្លាក់ប្រាសាទព្រះខ័ននេះ គាត់ចង់ប្រាប់ថា ព្រះវិស្ណុកំពុងនាំព្រះម៉ែចេញពីទីឃុំឃាំងក្នុងសមុទ្រទឹកដោះ ដែលមានក្រុមឥសីកំពុងឲ្យពរសព្វសាធុការ។ នៅខាងក្រៅប្រាសាទព្រះខ័ន គាត់មានឆ្លាក់រូបគ្រុឌកំពុងចាប់ជាន់នាគ (បក្សីចាំក្រុង) ដែលអត្ថន័យរបស់រូបនេះ គាត់ចង់ប្រាប់យើងថា ព្រះមាតាព្រះបិតារួមទាំងកូននាគទាំងឡាយ សុទ្ធតែនៅក្រោមអំណាចឃុំក្រុងរបស់គ្រុឌជាឆ្មាំ។ ដូច្នេះនៅក្នុងប្រាសាទមួយៗ សុទ្ធតែមានបង្កប់នូវរឿងរបស់ដូនតាយើង និងរឿងកូនចៅគាត់ជំនាន់ក្រោយ ដែលគាត់បានលាក់កប់ទុកក្នុង



គ្រុឌចាប់នាគ (ព្រះខ័ន)

ស្រោមរបស់សាសនាទាំងពីរ បើយើងពុំរើកញែកដោយឈរលើបណ្តាំប្រស្នាព្រះម៉ែទេ យើងច្បាស់ជាគ្មានអ្វីជាមរតករបស់ខ្លួនឡើយ ហើយច្បាស់ជាយល់ថាជារឿងនៅក្នុងសាសនាដូចបរទេសថាដូច្នោះ។ ហើយរូបចម្លាក់មាននៅក្នុងប្រាសាទនេះគឺមានច្រើនណាស់ ខ្ញុំគ្រាន់តែលើកយករូបខ្លះមកពន្យល់ជាបែបភាសាបណ្តាំព្រះម៉ែ ដើម្បីធ្វើការពិចារណាឈ្វេងយល់តែប៉ុណ្ណោះ។

## ១៦.ប្រាសាទលាក់នាង

***ពន្យល់ពាក្យ*** *(លាក់នាង)*

*លាក់នាង = លាក់ស្ត្រីកុំឲ្យគេរកឃើញ*

*ប្រាសាទលាក់នាងនេះ បើយើងមើលតាមប្លង់ប្រាសាទ ដូនតាយើងគាត់សង់ក្នុងជួរជាមួយប្រាសាទប្រែរូប* ***ប្រាសាទតាព្រហ្ម*** *ហើយនៅជិតស្រះស្រង់ និង****ប្រាសាទបន្ទាយក្ដី****។ តើប្រាសាទលាក់នាងនេះ លាក់នាងមួយណា? ខ្ញុំបានពន្យល់ហើយក្នុងសិរីបី មង្គលបី គឺ* ***អាថ៌កំបាំងលុបដាន*** *តើលុបដានស្នាមអ្នកណា? គឺលុបដានព្រះនាងនាគ ព្រោះពេលដែលគេកំពុងលុបដាន និងលាក់នាងក្នុងបន្ទប់នោះ រូបគាត់(ព្រះនាងនាគ)ពុំទាន់ក្លាយជាព្រះម៉ែនាគឡើយ ព្រោះទើបតែធ្វើមង្គលទីបីចប់។ តើគេលាក់នាងបានជិតដែរឬទេ? គឺលាក់បានជិតល្អណាស់ រហូតមកដល់សព្វថ្ងៃ មិនមានកូននាគណាមួយដឹងពីសាវតាពិតរបស់គាត់ឡើយ មានតែបរទេសដែលនៅជុំវិញគាត់ ធ្លាប់ធ្វើអាណានិគមលើប្រទេសគាត់ ទើបគេដឹងរឿង ព្រោះពួកគេបានទិញស្នាមដាន នៃភាពរុងរឿងរបស់មាតានាគ ដែលជាប់នៅលើកន្ទេល(អាថ៌កំបាំងក្នុង* ***ប្រស្នាលុបដាន សាកន្ទេល និងលក់កន្ទេល****)។ ដូចជារូបចម្លាក់មួយក្នុងប្រាសាទបន្ទាយស្រី សព្វថ្ងៃគេហៅថាស្រីគ្រប់លក្ខណ៍ ឬលក្ស្មី ប៉ុន្តែបើយើងត្រឡប់ពាក្យនេះ (ស្រី****គ្រប់លក្ខណ៍*** *→ ស្រីត្រូវ****គ្រាក់លុប****) គឺលុបលាក់នាងនេះឯង ហើយម្យ៉ាងទៀត បើមើលតាមរូបរឿងចម្លាក់ស្រីនេះ គឺគាត់កំពុងលាក់ក្រុងក្នុងអង្រុតមួយ ហើយអង្រុតនេះ អាចរបើកដឹងរឿងបាន លុះត្រាតែកើតមានទេវតាពីខាងលើ។ ចំណែកក្បាច់ចង្វាយអមចំហៀងខាងក្រោមក្បាច់ មានជើងសត្វតោ ឬរាជសី ប៉ុន្តែអត់មានក្បាលឡើយ ហើយក្បាលរាជសី (តោ) អាចមានរូបរាងពេញលេញ នៅបាំងក្លែងខាងលើ កំពុងចេញពីមាត់យក្ស ឬម្ករ អត្ថន័យនៃរូបនេះ ខ្ញុំបានពន្យល់នៅក្នុងរឿងប្រាសាទនាគព័ន្ធហើយ។ ពាក្យសរសេរ មានសូរសម្លេងដូចស្រីគ្រប់លក្ខណ៍ ម្យ៉ាងទៀតគឺ* ***ស្រីគ្រប់លាក់*** *មានន័យថារឿងរបស់ស្ត្រីនេះត្រូវបានលាក់បំបាំង មិនឲ្យគេដឹងរឿងរបស់ខ្លួន(លាក់នាង) ហើយរូបចម្លាក់ភាគច្រើន ដែលដូនតាយើងឆ្លាក់នៅក្នុង* **បាំងក្លែង** *ព្រោះពាក្យនេះ មានន័យថា* **ក្លែងបំបាំងភ្នែក** *ឬបំភាន់* **ភ្នែក** *(បំប្លែង)។*

## ១៧.ប្រាសាទតាព្រហ្មកិល

**ពន្យល់ពាក្យ** (ព្រហ្មកិល)

ព្រហ្ម = (ពន្យល់រួចហើយ)

កិល = បង្ខិត រំកិលបន្តិចម្តងៗ

តាព្រហ្មកិល = តារំកិលព្រហ្មវិហារធម៌របស់គាត់បន្តិចម្តងៗ តើតារំកិលព្រហ្មទៅណា? ដើម្បីអ្នកណា? ប្រាសាទនេះ មានរឿងព្រេងប្រចាំប្រាសាទ ប៉ុន្តែខ្ញុំពុំលើកយករឿងមកពន្យល់ឡើយ គឺយកតែឈ្មោះរបស់ប្រាសាទ មកបកស្រាយតែប៉ុណ្ណោះ ហើយពាក្យតាព្រហ្មនេះ ខ្ញុំបានពន្យល់នៅក្នុងប្រាសាទតាព្រហ្មរួចហើយ ក៏ប៉ុន្តែឥឡូវពាក្យតាព្រហ្មនេះ ត្រូវថែមពាក្យកិល ឬរំកិលពីខាងចុង។ ដែលគាត់រំកិលព្រហ្មនេះ គឺរំកិលព្រហ្មម៉ែ និងព្រហ្មឪ (រូបព្រះវិស្ណុធំ / បន្ទាយសំរ៉ែ) បន្តិចម្តងៗ យកទៅដាក់លើកំពូលភ្នំព្រះវិហារ **ដើម្បីឲ្យពួកគាត់ក្លាយជាអាទិទេពក្នុងបេះដូងកូននាគ** ឡើងវិញ ក្រោយពីបានលាក់កប់ទុកក្នុងសមុទ្រទឹកដោះអស់រាប់ពាន់ឆ្នាំមកនោះ។ ចុះហេតុអ្វីបានជាតាពុំដើរ បែរជាដេករំកិលទៅវិញ? ព្រោះខ្ញុំបានពន្យល់រួចហើយពីអាថ៌កំបាំងព្រះវិស្ណុដេក ពាក្យថាដេក គឺនៅលើគ្រែក្នុងបន្ទប់ក្នុងផ្ទះ បើតាមមើលសកម្មភាពនៃរូបគីវារ(ល្វា) លូន រំកិលបន្តិចម្តងៗ ដោយសេចក្តីព្យាយាមដើម្បីជ្រោងព្រះមាតាបិតាចេញពីទីទុក្ខ។ ដូច្នេះពាក្យថាប្រាសាទព្រហ្មកិល ឬតាព្រហ្មរំកិល គឺគាត់រំកិលខ្លួនឯងផង រំកិលព្រះមាតាបិតាផង រួមទាំងញាតិសាច់សាលោហិតទាំងពួង ឲ្យបានរួចចាកចេញពីអកុសលកម្មទាំងឡាយដែលបានបន្សល់ទុកពីអតីតកាលមក។

## ១៨.ប្រាសាទតាកែវ

**ពន្យល់ពាក្យ** (តាកែវ)

តា = (ពន្យល់ហើយ)

កែវ = រតនៈវត្ថុមានសាច់រឹង ហើយស្រួយ ធ្វើពីខ្សាច់ និងសំណ

*កែវ = ពាក្យប្រៀបធៀប (គឺអ្វីៗដែលរាប់អានថាជាវត្ថុមានតម្លៃ)*

*តើតាកែវដែលដូនតាយើងដាក់ឈ្មោះសម្គាល់ប្រាសាទនេះ តើជានរណា? ហើយឈ្មោះកែវនេះគាត់ចង់ប្រៀបធៀបនឹងអ្វី? យើងបានដឹងហើយថា ប្រវត្តិរឿងដ៏ជូរចត់មួយ ដែលកូនខ្មែរគ្រប់ស្រទាប់វណ្ណៈបានស្គាល់និងដឹងគឺរឿង**ព្រះគោព្រះកែវ**ដែលសាច់រឿងនេះ បានត្រូវបើកបង្ហាញពីភាពបែកបាក់ទុំឱទ្រោមចុះទន់ខ្សោយ និងឈឺចាប់ខ្លោចផ្សា ធ្វើឲ្យកូននាគប្រុសស្រីចងចាំមិនភ្លេច នូវសារវតាដ៏ជូរចត់ចុងក្រោយនេះ។ តើព្រះកែវក្នុងសាច់រឿង និងតាកែវឈ្មោះប្រាសាទមានអ្វីទាក់ទងគ្នា? រឿងរ៉ាវនៅក្នុងលោកយើងនេះ ពិតជាមានការទាក់ទងគ្នាពីមួយជំនាន់ទៅមួយជំនាន់ ពីមួយជាតិទៅមួយជាតិរហូតវិលមិនចេះចប់ក្លាយទៅជាកងដ៏ធំមួយ គឺវដ្តសង្សារ ដែលរកទីបំផុតខាងដើម និងខាងចុងពុំឃើញឡើយ។ អាចបញ្ចប់នូវវដ្តសង្សារនេះបាន លុះត្រាតែបានត្រាស់ដឹងនូវសច្ចធម៌ ទើបអាចរំលត់នូវជាតិ ដែលជាហេតុនាំឲ្យមានវដ្តសង្សារនេះ (ពុទ្ធភាសិតដែលព្រះអង្គទ្រង់ត្រាស់សម្ដែងក្នុងបដិច្ចសមុប្បាទធម៌)។ ហើយពាក្យកែវនេះ ប្រសិនបើជាន័យប្រៀបធៀបវិញ ព្រះកែវក្ដី ប្រាសាទតាកែវក្ដី ខេត្តតាកែវក្ដី ដូនកែវក្ដី វត្តកែវសិក្ខាគិរីស្វារៈនៅលើភ្នំព្រះវិហារក្ដី......គឺសុទ្ធតែតំណាងឲ្យបញ្ញាបារមីដ៏កំពូលរបស់ **ពូជពង្សនាគ**។ ពីអតីត បញ្ញារបស់ដូនតាយើងបានក្លាយទៅជាឃ្លាំងជាប្រាសាទ ជាខេត្ត ជាភ្នំ ហើយបញ្ញានេះត្រូវរលស់បាត់បង់អស់បន្តិចម្ដងៗ រហូតដល់ចុងក្រោយដែលនៅត្រឹមតែព្រះកែវ ក៏ត្រូវពួកបរទេស ឈ្លានពានដណ្ដើមយកទៅអស់ដែរ។ ដូច្នេះហើយដួងកែវដែលធ្លាប់តែបំភ្លឺនគរ ឲ្យមានមហិទ្ធិឫទ្ធិពីអតីតកាល នោះ ក្រោយមកត្រូវចុះទន់ខ្សោយបាត់ពន្លឺម្ដងបន្តិចៗ ចេញពីក្នុងសន្ដានចិត្តកូននាគប្រុសស្រី ធ្វើឲ្យនគរយើងចាប់ផ្ដើមងងឹត ដោយខ្វះដួងប្រទីបដែលជាភ្លើងហ្វា ឬដួងផ្កាយសម្រាប់ទ្រោលបំភ្លឺមើល ឲ្យដឹងនូវគន្លឹះសម្រាប់បើកមើល នូវសារវតាអច្ឆរិយពិតរបស់ខ្លួន។ ដូចសុភាសិតរបស់អ្នកប្រាជ្ញភ្នំជីសូរបានពោលទុកថា **ស្ដេចខ្លៅនាម៉ឺនខ្លៅ ដូចពស់ឆាងត្រាវពេនមាត់ជណ្ដើរស្ដេចប្រាជ្ញនាម៉ឺនមហិទ្ធិយក្សដូចពស់ពញាក់ពេនមាត់ជណ្ដើរស្ដេចប្រាជ្ញនាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាំកែវមនោរា**(ពន្យល់ហើយក្នុងភាគមួយ) ពាក្យ **កែវមនោរា** នេះហើយដែលជាប្រទីបសម្រាប់បំភ្លឺនគរឲ្យមានឫទ្ធានុភាពបាន។ ចុះចំណែកវត្ត **កែវសិក្ខាគិរីស្វារ**វិញ មានន័យដូចម្ដេចដែរ? មុននឹងខ្ញុំបកស្រាយពន្យល់វត្តនេះ ខ្ញុំពន្យល់អំពីខេត្តស្រះកែវសិន សព្វថ្ងៃនៅក្នុង*

ប្រទេសសៀម ពាក្យថា ***ស្រះកែវ*** គឺជាស្រះទឹកដែលលាក់ទុកនូវមរតកមានតម្លៃពីអតីតកាល ហើយឈ្មោះខេត្តស្រះកែវនេះ វាមានអត្ថន័យស្រដៀងស្រះស្រង់ និងប្រាសាទលាក់នាងក្នុងខេត្តសៀមរាប ដែលបានពន្យល់ហើយ។ ប្រាសាទលាក់នាងនេះជាអាថ៌កំបាំងនៃពន្លឺកែវមនោ ដែលខ្ញុំបានពន្យល់ក្នុងឯកសារតាភ្នំរាជទ្រព្យនោះ កែវមនោនេះទៀតសោតត្រូវបានលាក់ទុកនៅក្រោម ***អំណាចមនោគមវិជ្ជា*** ដែលខ្ញុំបានពន្យល់អស់ហើយ នៅក្នុងអាថ៌កំបាំងសមុទ្រទឹកដោះ។ រីឯតាកែវ គឺជាកូននាគ ដែលមានបញ្ញាដូចកែវ ជាអ្នកចុះទៅក្នុងស្រះកែវដើម្បីស្រង់នូវដូនកែវ (កែវមនោ) ដែលជាព្រះម៉ែមហានគរនោះ ឲ្យលោកមកគង់លើបល្ល័ង្ករបស់លោកវិញ គឺប្រាសាទព្រះវិហារ (មាតុភូមិ) ។

***ពន្យល់ពាក្យ*** (កែវសិក្ខាគិរីស្វរៈ)

កែវ = (ពន្យល់រួចហើយ)

សិក្ខា = រៀន សិក្សា ស្វាធ្យាយ

គិរី = ភ្នំ បព្វតា

ស្វរៈ = លោកកេស្វរៈ ពោធិសត្វទៀងតែនឹងបានត្រាស់ជាព្រះពុទ្ធ ទៅអនាគតជាតិ (មហាយាន)

ដូច្នេះឈ្មោះថាកែវសិក្ខាគិរីស្វរៈ គឺភ្នំដែលតាកែវនោះកំពុងសិក្សា រៀនសូត្រ សន្សំនូវបារមីឲ្យចាស់ក្លាដូចជាភ្នំ ដើម្បីមានកម្លាំងលើកប្រទីបទ្រោលបំភ្លឺនូវភាពងងឹត ពីអតីតកាលឲ្យភ្លឺឡើងវិញដូចជាភ្នំកែវមនោ ទើបអាចដឹងរឿងហើយទៅស្រង់ភ្នំបាន (ភ្នំស្រង់ ឬស្រង់ភ្នំ) ហេតុអ្វីក៏ខេត្តស្រះកែវនៅក្នុងទឹកដីបរទេស ហើយភ្នំកែវសិក្ខាគិរីស្វរៈ នៅក្នុងទឹកដីខ្មែរទៅវិញ? យើងដឹងហើយថា បរទេសសៀមឈ្លានពាន គេបានយកនិមិត្តរូបសត្វគ្រុឌដែលជាសត្វតំណាងឲ្យជាតិគេ ហើយដែលសត្វគ្រុឌនេះ ដែកំពុងចាប់កន្ទុយនាគ និងជើងជាន់ក្បាលនាគ រូបចម្លាក់នៅប្រាសាទតាព្រហ្ម ព្រះខ័ន បន្ទាយក្ដី.... (បក្សីចាំក្រុង) ដែលសត្វនាគនោះ ជានិមិត្តរូបរបស់ជនជាតិខ្មែរ ហើយជនជាតិនេះ គឺជាពូជអំបូរព្រះម៉ែនាគ(ព្រះនាងនាគ) ដែលជាម្ចាស់កេរមរតកគំនិតក្នុងការដឹកនាំនគរពីអតីត (ពន្លឺកែវមនោ ឬដូនកែវ)។ ហេតុនេះហើយព្រះមាតានាគ (និមិត្តរូបសត្វនាគ) ដែលលោកត្រូវបានជាប់ឃុំក្នុងសមុទ្រ

ទឹកដោះពីអតីតកាល ដោយអំណាចអកុសលកម្ម ដែលលោកបានប្រព្រឹត្តិពីអតីតកាលតាមឲ្យផលរហូតមកទល់សព្វថ្ងៃ ហើយកម្មនេះវាមិនទាន់ឲ្យផលអស់ ដូច្នេះហើយទើបខេត្តស្រះកែវនៅក្នុងទឹកដីបរទេស។ ចំណែកឯកូននាគ ដែលជាអ្នកជួយគាត់ កំពុងតែនៅសិក្សារៀនសូត្រពូតផ្ដុំ សន្សំបារមីឲ្យបានគ្រប់ ដើម្បីជាន់គ្រុឌឲ្យព្រមដោះលែងព្រះម៉ែនាគ (រូបចម្លាក់ ព្រះវិស្ណុជិះលើគ្រុឌ) ទើបវត្តកែវសិក្ខាគិរីស្វរៈនិងវាលឥន្ទ្រី (តំណាងឲ្យគ្រុឌ) សព្វថ្ងៃស្ថិតនៅក្នុងទឹកដីខ្មែរ។

## ១៩.ប្រាសាទក្រោលគោ

ពាក្យថា ក្រោលគោ គឺមានន័យថាប្រមូលគោទាំងអស់ ដែលដើរបែកខ្ញែកពេញវាលឲ្យចូលទៅក្នុងប្រាសាទ ឬក្រោលវិញ។ ហើយរឿងគោនេះក៏វាទាក់ទងទៅក្នុងរឿងព្រះគោ ព្រះកែវផងដែរ ដែលបរទេសសៀមឈ្លានពាន បានចាប់យកព្រះកែវផងព្រះគោផង (ព្រះកែវខ្ញុំបានពន្យល់ហើយ)។ ជាបន្តខ្ញុំនឹងបកស្រាយពន្យល់ពីអាថ៌កំបាំង ពាក្យព្រះគោនៅក្នុងន័យពិតរបស់ឈ្មោះនេះដែលដូនតាខ្មែរបានឆ្លាក់រូបព្រះគោតូចធំ ដាក់ក្នុងប្រាសាទស្ទើរគ្រប់ប្រាសាទ ហើយតែងតែមានព្រះឥសូរជិះ និងព្រះនាងឧមាវតីគង់លើភ្លៅ មិនតែប៉ុណ្ណោះគាត់ថែមទាំងបានធ្វើប្រាសាទដាក់ឈ្មោះថា ប្រាសាទក្រោលគោ ហើយដោយខ្លាចកូនខ្មែរពុំដឹង គាត់បានហៅឈ្មោះភ្នំជាប់ភ្នំកំចាយមារ ថាភ្នំបូកគោ។

តើន័យពិតរបស់ឈ្មោះភ្នំបូកគោនេះ មានន័យដូចម្ដេចទៅហ្ន៎? ហេតុអ្វីបានជាគោនេះអាចបូករឿងរ៉ាវរបស់ខ្លួនឲ្យក្លាយជាភ្នំមួយយ៉ាងធំដូចនេះ? ខ្ញុំបានរៀបរាប់ពន្យល់រួចហើយថា ដោយគាត់ចង់លាក់រឿងពិតរបស់គាត់ គាត់បានខ្ចីស្រោមបរទេសមកលាក់ផ្ទៃដាវរបស់ខ្លួន ដើម្បីកុំឲ្យបរទេសគេមើលដឹង ទីបំផុតគាត់ពុំបានលាក់បរទេស បែរជាលាក់កូននាគខ្លួនឯង ដែលជាអ្នកទទួលមរតករបស់គាត់ទៅវិញ(កេរម៉ែ)។ នៅក្នុងសូត្រមួយ នៃគម្ពីរព្រះត្រៃបិដកគឺ(កសិសូត្រ) ពេលនោះព្រះពុទ្ធបរមគ្រូនៃយើង បានប្រមើលមើលនិស្ស័យសត្វនៅពេលទៀបភ្លឺ បានឃើញព្រាហ្មណ៍ពីរនាក់ប្ដីប្រពន្ធ ចូលក្នុងសំណាញ់ញាណរបស់ព្រះអង្គ ទើបព្រឹកឡើងព្រះអង្គនិមន្តទៅបិណ្ឌបាត នៅទីដែលព្រាហ្មណ៍នោះ កំពុងភ្ជួរស្រែ ដែលមានគោរាប់សិបកំពុងភ្ជួររាស់ ហើយព្រះអង្គបានទ្រង់ឈរបិណ្ឌបាតចំពោះមុខព្រាហ្មណ៍នោះ ព្រាហ្មណ៍បានពោលពាក្យដោយចិត្តមិនជ្រះថ្លាថា ព្រះអង្គមិនគិតធ្វើ

ស្រែទេឬ? គិតតែពីដើរសុំគេយ៉ាងនេះ? ព្រះអង្គមានពុទ្ធដិកាទៅកាន់ព្រាហ្មណ៍នោះថា តថាគតធ្វើស្រែអស់បួនអសង្ខេយ្យកំម្រៃមួយសែនមហាកប្ប ពេលនេះកិច្ចធ្វើស្រែរបស់តថាគតគឺចប់ហើយ ព្រាហ្មណ៍នោះឆ្ងល់ក៏សួរទៅកាន់ព្រះសម្មាសម្ពុទ្ធវិញថា តើព្រះអង្គធ្វើស្រែដូចម្ដេច? ហើយឧបករណ៍សម្រាប់ធ្វើស្រែនោះនៅឯណា? ព្រះអង្គទ្រង់ត្រាស់សម្ដែង សុភាសិតប្រៀបធៀបដោះការសង្ស័យរបស់ព្រាហ្មណ៍នោះថា៖

១/ សទ្ធារបស់តថាគត គឺជាពូជ

២/ តបៈ និងការសង្រួមឥន្ទ្រីយរបស់តថាគត គឺជាទឹកភ្លៀង

៣/ បញ្ញារបស់តថាគត គឺជានឹម និងផ្ទៀងនង្គ័ល

៤/ ហិរិ និងឱត្តប្បៈរបស់តថាគត គឺជាដងនង្គ័លនិងចន្ទោល

៥/ ចិត្តរបស់តថាគត គឺជាខ្សែសម្រាប់ទាញគោ

៦/ សតិរបស់តថាគត គឺជាផាល និងជន្លួញ

៧/ សច្ចៈ គឺការគ្រប់គ្រងកាយវាចាចិត្តសង្រួមអាហារក្នុងផ្ទៃ និងធ្វើការដកជំរះស្មៅ

៨/ ការឈប់សម្រាករបស់តថាគត គឺជាព្រះនិព្វាន

៩/ សេចក្ដីព្យាយាមរបស់តថាគត គឺជា**គោ** ដែលអូសទៅនូវនង្គ័ល ដើម្បីបំបែកនូវអាចម៍បំណះ គឺបំបែកនូវរូបធម៌ នាមធម៌ដាក់ចុះនូវធុរៈដ៏ធ្ងន់ ហើយដើរទៅកាន់ទីដ៏ក្សេម គឺព្រះនិព្វាន (ទាំងនេះ គឺជាការធ្វើស្រែរបស់តថាគត)

បើតាមន័យភាសិតរបស់ព្រះសូត្រនេះ ដូនតាខ្មែរដែលគាត់បានយកនិមិត្តរូបគោនេះ (ប្រាសាទព្រះគោ ក្រោលគោ បូកគោ...) គឺតំណាងឲ្យសេចក្ដីព្យាយាមដែលសេចក្ដីព្យាយាមនេះនៅរាយប៉ាយគាត់បានប្រមូលផ្ដុំបញ្ចូលក្នុងក្រោលវិញ ហើយទីបំផុតបានពូនទៅជាភ្នំ (បូកគោ = បូកសេចក្ដីព្យាយាម) បើពុំមានកម្លាំងវិរិយទេ តើធ្វើម្ដេចអាចកសាងប្រាសាទថ្មរាប់ពាន់បាន? បើពុំមានវិរិយ

ពលៈនោះទេ ធ្វើម្ដេចអាចស្រង់ភ្នំព្រះម៉ែព្រះឪដ៏ធំ រើកទៅដាក់លើព្រះវិហារឡើងវិញបាន? នេះជាអត្ថន័យពិតរបស់ប្រាសាទក្រោលគោ និងប្រាសាទតាកែវ (ព្រះគោព្រះកែវ) ដែលពីអតីតរហូតមកដល់


រូបនៅជញ្ជាំងខាងក្រៅប្រាសាទបន្ទាយឆ្មារ

បច្ចុប្បន្ន ត្រូវរាហូអសុរិន្ទលេបបាំងបាត់ពន្លឺរស្មីអស់ទៅហើយ (រូបភាពចម្លាក់រាហូលេបនឹងក្អែព្រះគោព្រះកែវចម្លាក់ននៅប្រាសាទបន្ទាយឆ្មារ ដែលប្រាសាទនេះ ដូនតាធ្វើឧទ្ទិសឲ្យកូនខ្មែរគ្រប់ៗជំនាន់)។ ម្យ៉ាងទៀតព្រះគោព្រះកែវ ដែលនៅសេសសល់ត្រូវបរទេសឈ្លានពាន ដណ្ដើមយកអស់ជាចុងក្រោយ ក្នុងសម័យឧត្តុង្គលង្វែក។ តើធ្វើដូចម្ដេចអាចធ្វើឲ្យពូជនាគនេះ មានឫទ្ធានុភាពឡើងវិញបាន? កូននាគទាំងឡាយពេលអ្នកយល់ហើយ ត្រូវរួមសាមគ្គីគ្នាព័ន្ធគ្នាជាធ្លុងមួយ ជ្រោងទង់វិរិយិន្ទ្រីយ ជ្រោងទង់បញ្ញិន្ទ្រីយឡើង ហើយសូមឲ្យដួងកែវ គឺកម្លាំងជាធំរបស់បញ្ញា និងកម្លាំងជាធំនៃសេចក្ដីព្យាយាម កើតមានឡើងវិញចំពោះកូននាគប្រុសស្រី ការបកស្រាយដោយសង្ខេបនេះជាចម្លើយប្រស្នា ឈ្មោះ ប្រាសាទក្រោលគោ។

## ២០.ប្រាសាទក្រោលរមាស

អត្ថន័យនៃពាក្យ ឬប្រាសាទនេះ ខ្ញុំបានពន្យល់ក្នុងអាថ៌កំបាំងប្រាសាទគុករមាសហើយ ខ្ញុំមានតែបួងសួងសុំឲ្យទឹកថ្នាំទិព្វ ដែលមានក្នុងខ្លួនរមាសនោះ មកជួយប្រោះព្រំអ្នកនគរ ដែលបានក្លាយខ្លួនជាថ្មរាប់ពាន់ឆ្នាំនោះ ឲ្យរស់រានមានជីវិតឡើងវិញ ដូចប្រស្នាក្នុងរឿងឥសីមាត់ទិព្វ ឬព្រះថោទិព្វវង្ស។ សូមឲ្យកូននាគទាំងអស់ឆាប់រួចផុតពីគុក គឺអកុសលកម្មចាស់ពីអតីត ហើយសូមឲ្យរឿងរ៉ាវក្នុងថ្មទាំងឡាយឆាប់មានជីវិតរស់រវើករួចនិយាយពីបណ្ដាំរឿងប្រាប់កូនខ្មែរឲ្យបានដឹងពីសាវតាពិតរបស់ខ្លួន។

## ២១.<u>ប្រាសាទព្រះបាលិលេយ្យ</u>

តើអត្ថន័យពិតរបស់ឈ្មោះប្រាសាទនេះ មានន័យយ៉ាងណាហ្ន៎? ឈ្មោះបាលិលេយ្យនេះ គឺតំណាងឲ្យដំរីមួយនៅក្នុងគម្ពីរព្រះត្រៃបិដក ពេលនោះភិក្ខុក្នុងដែនអាឡវិបានឈ្លោះទាស់ទែងគ្នាព្រោះ

តែរឿងអាបត្តិបន្តិចបន្តួច ក៏កើតរឿងបែកបាក់គ្នា ក្រោយមកព្រះសម្មាសម្ពុទ្ធពន្យល់ឃាត់ឃាំងពុំបាន ព្រះអង្គក៏ស្តេចយាងទៅគង់ចាំព្រះវស្សា នៅព្រៃ**បាលិលេយ្យ**នោះទៅ ដែលនៅក្នុងព្រៃនោះ មានដំរីពោធិសត្វ និងបរិវារនៅគាល់បម្រើអស់កាលត្រីមាស។ ហើយដំរីនេះព្រះអង្គបានព្យាករណ៍ថា តទៅអនាគតនឹងបានត្រាស់ ជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ជាវិរិយាធិកដែលត្រូវសន្សំបារមីរាប់អសង្ខេយ្យ ពេលបានត្រាស់ទ្រង់មានព្រះនាមថា សុមង្គលសម្មាសម្ពុទ្ធ (នៅក្នុងអនាគតទសវង្ស)។ ចុះហេតុអ្វីក៏ដូនតាយកឈ្មោះដំរីព្រះពោធិសត្វ មកដាក់ជាឈ្មោះប្រាសាទ? ខ្ញុំបានពន្យល់ហើយ ពីអាថ៌កំបាំងក្បាលដំរី ក្បាលរាជសីនៅប្រាសាទនាគព័ន្ធ ព្រោះព្រះបាទជ័យវរ័ន្មទី៧ គាត់បានលើកតម្កើងព្រះពុទ្ធសាសនាបែបមហាយាន ប៉ុន្តែគាត់ពុំបានលើកជាធំហបែបហិនយាន ព្រោះហេតុអ្វី? ព្រោះបើគាត់កាន់បែបហិនយាន(យានតូច) គាត់ពុំអាចឆ្លាក់រឿងរ៉ាវរបស់ព្រះម៉ែ និងរឿងរបស់កូននាគដែលត្រូវសរជាតិមកបំពេញបារមីជួយព្រះម៉ែបានឡើយ ព្រោះពុទ្ធសាសនា**ហិនយាន** ព្រះអង្គបានបរិនិព្វានទៅហើយ មានតែពុទ្ធសាសនា**មហាយាន** ទេដែលនៅមានព្រះពោធិសត្វ នូវបំពេញបារមីបន្តទៅទៀត។ ដូច្នេះត្រូវមានកូននាគណាម្នាក់សរជាតិ មកបំពេញនូវបារមី ដើម្បីជួយស្រោចស្រង់ព្រះមាតាបិតាមហានាគ និងអ្នកនគរនេះ ឲ្យបានរួចផុតពីបាបកម្ម ដែលពួកគាត់បានសាងពីអតីតកាល។ នេះជាហេតុដែលនាំឲ្យស្តេចអង្គនេះ កាន់ព្រះពុទ្ធសាសនាបែបមហាយាន(យានធំ) ហើយខ្លួនរបស់ព្រះអង្គក៏បាន តាំងនាមជា ***ព្រះពោធិសត្វលោកេស្វរៈ*** ហើយកសាងប្រាសាទដាក់ឈ្មោះថា **បាលីលេយ្យ** ព្រោះព្រះម៉ែគាត់ចង់ប្រាប់យើងថា ដំរីនេះនៅបំពេញបារមីនៅឡើយ។

## ២២.<u>ប្រាសាទព្រះពិធូរ ឬវិធូរបណ្ឌិត</u>

តើអត្ថន័យឈ្មោះរបស់ប្រាសាទនេះទាក់ទងទៅនឹង ***អាថ៌កំបាំងព្រះម៉ែមហានគរ*** មានន័យយ៉ាងដូចម្តេចដែរ? ពាក្យថា**ពិធូរ ឬវិធូរ**នេះ គឺជាឈ្មោះព្រះពុទ្ធបរមគ្រូនៃយើង កាលព្រះអង្គនៅបំពេញបារមីនៅឡើយ គឺរឿងវិធូរបណ្ឌិត ដែលត្រូវយក្សចាប់បោកព្រះអង្គផ្ទប់ទៅនឹងថ្មឲ្យស្លាប់ ដើម្បីវះយកបេះដូងទៅឲ្យកូនស្រីនាគ ព្រោះកូនស្រីនាគនោះ បានស្រែកច្រៀងថា អ្នកណាយកបេះដូងវិធូរបណ្ឌិតបានខ្ញុំនឹងយកអ្នកនោះធ្វើជាស្វាមី(ប្តី)។ ពេលដែលយក្ស ចាប់គាត់បោកផ្ទប់ទៅនឹងថ្មដើម្បីឲ្យស្លាប់

គាត់បែរជាមិនស្លាប់ ដោយអំណាចបុណ្យបារមីរបស់ពោធិសត្វអង្គនោះ ទើបព្រះពោធិសត្វសួរទៅយក្សនោះ យក្សក៏បានរៀបរាប់ដំណើររឿងជាហូរហែប្រាប់ទៅព្រះអង្គ។ ព្រះអង្គក៏សំដែងធម៌ពន្យល់យក្ស ហើយប្រាប់យក្សថាប្រពន្ធរបស់ស្ដេចនាគរាជ ពុំចង់ស៊ីបេះដូងខ្ញុំឡើយ គឺគ្រាន់តែចង់ស្ដាប់ធម៌ទេសនាក្នុងចិត្តរបស់ខ្ញុំតែប៉ុណ្ណោះ(អធិប្បាយរឿងដោយសង្ខេប)។ ពាក្យថាចង់ស៊ីបេះដូង សូមកូននាគទាំងឡាយបកទៅក្រោយមើលរឿងសិរីបិប្រការ មង្គលបី និងល្បែងចាក់ទឹកដូង នោះនឹងដឹងរឿងពិតនៃឈ្មោះប្រាសាទនេះហើយ ដែលព្រះមាតានាគគាត់ចង់ផ្ដែផ្ដាំប្រដៅដល់យើងថា តើកូននាគណាមួយដែលព្រមខ្វះបេះដូងទៅឲ្យគាត់បរិភោគ(យកបេះដូងឧទ្ទិសឲ្យយក្ស) នេះជាអាថ៌កំបាំងរបស់ឈ្មោះប្រាសាទព្រះវិធូរបណ្ឌិត។

## ២៣. ភិមានអាកាស ឬវិមានអាកាស

តើឈ្មោះរបស់ប្រាសាទនេះ មានបង្កប់នូវអាថ៌កំបាំងអ្វី? យើងបានដឹងរួចហើយ នៅក្នុងឯកសារសាវតារអាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរភាគទីមួយ ដែលខ្ញុំបានរ៉ាយរ៉ាប់ពីការកត់ត្រារបស់អ្នកការទូតចិន ជីវតាក្វាន់ ពីរឿងរបស់ខ្មែរយើងក្នុងសម័យនោះ។ គាត់និយាយថា ស្ដេចតែងតែទៅជួបបិសាចពស់ (នាគក្បាលប្រាំបួន) នៅក្នុងប្រាសាទវិមានអាកាសនេះដើម្បីរួមរ័ក នេះជាភាសារបស់អ្នកការទូតនោះ ប៉ុន្ដែតាមន័យពិត គឺស្ដេចបានទៅជួបព្រះមាតាដើម្បីទទួលនូវ**ឱវាទ** ដែលព្រះម៉ែបានមកចង្អុលបង្ហាញកូននៅនាទីចុងក្រោយ ដែលគាត់អាចចេញពីទីឃុំក្នុងសមុទ្រទឹកដោះបាន។ ពាក្យថា **វិមានអាកាស** គឺជាវិមានអណ្ដែតនៅលើអាកាស ព្រោះព្រះមាតាគាត់តែងតែនិម្មិតជាស្ត្រីមកជួបកូន (ស្ដេច) មានន័យថា រូបរាងពិតរបស់ព្រះមាតា គឺពុំអាចចេញពីទីឃុំឃាំងរួចឡើយ មានតែនិម្មិតចិត្តដោយអំណាចមនោមយិទ្ធិតែប៉ុណ្ណោះ ព្រោះចិត្តដូចជាអាកាសគ្មានរូប គ្មានក្លិន គ្មានពណ៌ សម្បុរ...។ល។ ហើយបុគ្គលដែលអាចនិម្មិតចិត្តចេញមកបាន ត្រូវមានឈានសមាបត្តិ និងអភិញ្ញាដែលជាគុណធម៌របស់សមាធិ ដូច្នេះទើបប្រាសាទនេះមានឈ្មោះថា**វិមានអាកាស ឬភិមានអាកាស** សម័យនោះ គាត់អាចដកចិត្តចេញមកជួបកូនបាន តែសម័យក្រោយគឺអត់ទេបរទេសគេដើរបិទ ដើរសន្ធប់អស់ហើយចំពោះរូងណាដែលគេសង្ស័យនេះជាន័យពិតរបស់ឈ្មោះប្រាសាទវិមានអាកាស។

## ២៤.ប្រាសាទមេបុណ្យខាងកើត

ហេតុអ្វីបានជាគាត់ដាក់ឈ្មោះប្រាសាទនេះថា មេបុណ្យខាងកើត? ពាក្យថា**មេបុណ្យ** វាផ្ទុយគ្នាពីមេបាប ព្រោះសភាវធម៌ទាំងពីរនេះ ពុំអាចរលាយចូលគ្នាបានឡើយ ពាក្យថា បុណ្យ គឺប៉ែកខាង**កុសលាធម្មា** ឯពាក្យថាបាប គឺ **អកុសលាធម្មា**។ ចុះហេតុអ្វីក៏ចាំបាច់មាន មេបុណ្យខាងកើតផង មេបុណ្យខាងលិចផង អត្ថន័យនៃឈ្មោះនេះ ខ្ញុំបាទនឹងខិតខំស្រាវជ្រាវ ប្រមូលផ្ដុំឯកសារយកមកពន្យល់ទាំងខាងព្រហ្មញ្ញសាសនាព្រះពុទ្ធសាសនា និងបណ្ដាំគំនិត ព្រះម៉ែសម្រាប់យកមកបកស្រាយបំភ្លឺចំងល់ ដែលមាននៅក្នុងចិត្តពីឈ្មោះមេបុណ្យទាំងពីរ នេះ។ ប្រាសាទនេះ ដូនតាគាត់ច្រើនធ្វើក្នុងបារាយណ៍ (ក្នុងទឹក) ដោយគាត់បានពូនដីជាកោះ ហើយមានទឹកព័ទ្ធជុំវិញ រួចគាត់ចាប់ផ្ដើមកសាងប្រាសាទ ឆ្លាក់រឿងទុកក្នុងប្រាសាទនោះ ដើម្បីជាប្រយោជន៍ទុកឲ្យកូនចៅនាគសម័យក្រោយសិក្សា និងស្វែងយល់រឿងពិតរបស់ព្រះម៉ែ។ មេបុណ្យខាងកើតមានទឹកដក់តែក្នុងរដូវវស្សា ចំណែករដូវប្រាំងពុំមានទឹកឡើយ ដូច្នេះវាផ្ទុយ នឹងពាក្យដែលថាសមុទ្រទឹកដោះ ព្រោះគ្មានទឹកនេះម្យ៉ាងៗទៀតបើយើងប្រៀបធៀបមក ប្រាសាទអង្គរវត្ត ឬអង្គរតូច ដែលគាត់ធ្វើឧទ្ទិសឲ្យព្រះវិស្ណុនោះគឺប្រាសាទមានផ្លូវពិតប្រាកដ តែក្នុងទិសខាងលិចទេ ចំណែកឯទិសខាងកើតវិញគឺគ្មានផ្លូវចេញចូលត្រឹមត្រូវឡើយ។ ចុះ ហេតុអ្វីបានជាគេធ្វើប្រាសាទអង្គរវត្ត បែរមុខទៅទិសខាងលិច? ព្រោះមេបុណ្យខាងកើត ពុំមានទឹកចិត្តគ្រប់គ្រាន់សម្រាប់ជួយស្រង់ព្រះម៉ែឡើយ មានតែមេបុណ្យទិសខាងលិចតែ ប៉ុណ្ណោះដែលអាចជួយស្រង់ព្រះម៉ែបាន ដូចនេះហើយទើបគេកសាងប្រាសាទអង្គរវត្តបែរមុខ ទៅទិសខាងលិចព្រោះប្រាសាទនេះ គេធ្វើឧទ្ទិសឲ្យព្រះវិស្ណុដែលដេកវារលូននាំព្រះម៉ែចេញ រហូតដល់មានពាក្យទំនាយដែលចាស់ៗនិយាយតៗគ្នាថានឹងមានអ្នកមានបុណ្យ មកពីទិស ខាងលិច(គឺពួកគាត់លិចចុះក្នុងសមុទ្រទឹកដោះ) ជួយលើក**ព្រះសាសនា** ព្រោះអ្នកប្រាជ្ញតាក់

តែងទំនាយនោះ គាត់មើលតាមប្លង់ពិតនៃប្រាសាទ និងរឿងរ៉ាវចម្លាក់ក្នុងប្រាសាទ ដូចខ្ញុំបាន ពន្យល់មកនេះ។

សរុបសេចក្ដីមក អត្ថន័យរបស់ឈ្មោះប្រាសាទមេបុណ្យខាងកើត គឺគាត់ចង់ពន្យល់ប្រាប់យើង ថាមេបុណ្យនោះ មានគុណធម៌ពុំទាន់គ្រប់គ្រាន់អាចជួយស្រង់ជួយរើកព្រះមាតាបិតាមហានគរបាន ឡើយលុះត្រាតែកើតមានមេបុណ្យពីខាង**លិច** ទើបព្រះមាតាបិតាអាចរួចពីទុក្ខទោសបាន ព្រោះ ទំនាយដូនតាគាត់ដកចេញរឿងពីក្នុងថ្ម។

## ២៥.ប្រាសាទមេបុណ្យខាងលិច

ប្រាសាទនេះ មានទីតាំងនៅក្នុងបារាយណ៍ទឹកថ្លា គឺនៅកណ្ដាលបារាយណ៍ឬបារាយណ៍ ខាង លិច។

**ពន្យល់ពាក្យ** (បារាយណ៍)

បា = ដឹក គ្រប់គ្រង អ្នកគ្រប់គ្រង រក្សា ទំនុកបម្រុង...

បា = កូនប្រុស ម្នាលបា...ហៅសត្វផ្ទុយពីមេគឺបា

រាយណ៍ = នរាយណ៍ (ខ្មែរនិយមហៅព្រះនរាយណ៍) វិស្ណុ ហរ:




បា + នរាយណ៍ នេះជាការយល់ឃើញ របស់ខ្ញុំបាទជាអ្នកស្រាវជ្រាវព្រោះហេតុអ្វី? ព្រោះនៅប្រាសាទមេបុណ្យខាងលិចនេះ គេគាស់បាន រូបបដិមាព្រះវិស្ណុធំ (នរាយណ៍)ដែលមានទំហំធំ ហើយ រូបនេះ បានកសាងដោយលោហធាតុចម្រុះ ដែលមានត្រឹមតែពាក់កណ្ដាលពីក្បាលដល់ទ្រូង

ចំណែកឯពាក់កណ្ដាលខាងជើងពុំទាន់រកឃើញឡើយ សព្វថ្ងៃរូបនេះ បានតម្កល់ទុកក្នុងសារមន្ទីរជាតិភ្នំពេញ។ ហើយរូបរាងរបស់កោះប្រាសាទមេបុណ្យនោះ បើមើលពីខាងលើ គឺពួកគាត់ពូនកោះជារូបក្បាលក្រពើ(រូបថតខាងលើនេះ នៅក្នុងសៀវភៅ Book guides of Ancient Angkor) ដូច្នេះវាទាក់ទងនឹងល្បែងចាក់ទឹកដូងបែបទីមួយដែលថា **កន្ទុយខ្លែងខ្មែរពាក់ក្បាលក្រពើ** តាមអត្ថន័យពិតរបស់កោះនេះ មានបង្កប់នៅរូបរាងក្បាលក្រពើដ៏ធំ ហើយនៅក្នុងកោះនោះមានមេបុណ្យម្នាក់ គឺ**ព្រះវិស្ណុ** ឬ **ព្រះនារាយណ៍** ។ តើព្រោះហេតុអ្វី? ដូនតាគាត់បានបង្កប់ភាសាគំនិតក្នុងរូបចម្លាក់និងឈ្មោះមេបុណ្យតំណាងឲ្យមនុស្សម្នាក់ជាព្រះវិស្ណុដែលសន្សំនូវគុណធម៌ គឺបារមីញាណធំជាងគេនៅក្នុងកោះ ដែលមានរាងក្បាលក្រពើនោះ ហើយគ្រប់រូបនៃព្រះវិស្ណុតែងតែឃើញដូនតាឆ្លាក់ស្ទើរតែគ្រប់ប្រាសាទ និងគ្រប់ទីកន្លែងដែលគាត់ត្រូវឆ្លាក់ គឺព្រះវិស្ណុដេកទល់ដៃរួចគងគាបព្រះម៉ែនៅចុងជើង។ ហេតុអ្វីបានជាគេធ្វើប្រាសាទមេបុណ្យនេះនៅទិសខាងលិច? ព្រោះពាក្យថាលិចវាផ្ទុយពីកើតគឺរះឡើងបានន័យថាបុគ្គលជាមេបុណ្យនេះមិនងាយនឹងងើបរួចឡើយ ព្រោះហេតុអ្វី? ព្រោះគាត់បានលិចចុះទៅក្នុងសមុទ្រទឹកដោះ(សមុទ្រទុក្ខ) ជាមួយព្រះម៉ែមហានាគទៅហើយ ដើម្បីប្រមូលផ្ដុំកម្លាំងចុះជួយស្រង់ម្ដាយ ឲ្យឡើងមកខាងលើវិញ តើពេលណាទើបអាចស្រង់គាត់រួច បើរឿងរ៉ាវរបស់គាត់ក្លាយទៅជាភ្នំទៅហើយនោះ ម្យ៉ាងទៀតរឿងនេះ បានលាក់កប់ទុករាប់ពាន់ឆ្នាំ ធ្វើដូចម្ដេចដែលអាចឲ្យមនុស្សសម័យនេះទទួលយក និងជឿនូវបណ្ដាំរឿងរបស់គាត់បាន? លុះត្រាតែកូននាគជឿនូវហេតុផលនៃកម្លាំងកម្មទើបអាចជឿរឿងពិតនេះបាន។ ដូច្នេះប្រាសាទមេបុណ្យនេះបើយើងចង់ទៅទស្សនាយើងត្រូវជិះទូកឆ្លងកាត់វាលបឹងដ៏ធំមួយ ប្រៀបដូចជាសមុទ្រយ៉ាងដូច្នោះ ហើយសព្វថ្ងៃប្រាសាទនេះ បាក់បែកអស់ហើយ ដោយសារការគាស់កកាយពីសំណាក់ពួកបរទេសសម័យអាណានិគម ស្វែងរកនូវបេះដូងមេបុណ្យរបស់ប្រាសាទនេះ។ ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ តែងសន្សំមេបុណ្យទាំង**៣០** គឺបារមី**១០** ឧបបារមី**១០** បរមត្ថបារមី**១០** បារមី ឬមេបុណ្យទាំង៣០ នេះហើយសម្រាប់អភិសេកពោធិសត្វគ្រប់ៗព្រះអង្គ ឲ្យបានគង់លើរតនបល្ល័ង្កត្រាស់ដឹងនូវសច្ចធម៌ជាព្រះសម្មាសម្ពុទ្ធនោះឯង។ យ៉ាងណាមិញរឿងដែលទាក់ទងនឹងប្រាសាទមេបុណ្យទាំងពីរនេះ តួអង្គដែលគេបានឆ្លាក់ទុកក្នុងប្រាសាទនោះ ខាងព្រហ្មញ្ញសាសនាជាព្រះវិស្ណុ.... ចំណែកខាងពុទ្ធសាសនាគេហៅថា **ព្រះពោធិសត្វលោកេស្វរៈ...**

ចំណែកក្នុងបណ្តាំគំនិតព្រះម៉ែមហានគរវិញ គឺកូននាគដែលមាននូវកតញ្ញូនិងកតវេទី។ ហើយភាគច្រើនក្នុងអាថ៌កំបាំងនគរខ្មែរយើង ដូនតាគាត់តែងដាក់បញ្ចូលបុគ្គលនោះ ទៅក្នុងរឿង**ព្រេង ប្រាសាទ ភ្នំ ទំនៀមទម្លាប់ ប្រពៃណី ទំនាយ....** ហើយតួអង្គនេះ បានបញ្ចេញនូវសកម្មភាពផ្សេងៗទៅតាមកាល និងពេលវេលា ទីកន្លែង ដើម្បីសន្សំនូវបារមីដូចតួយ៉ាងសិលាចារឹករបស់ស្តេចជ័យវរ្ម័នទី៧ ដែលមានន័យថា **គុណធម៌ដែលខ្ញុំបានធ្វើ និងកសាងហើយនេះ ខ្ញុំសូមឧទ្ទិសជូនព្រះមាតាបិតាខ្ញុំ ឲ្យឆាប់រួចផុតពីវដ្តទុក្ខ ហើយទីបំផុតនឹងអាចត្រាស់ដឹងនូវអមតធម៌គឺព្រះនិព្វាន** សូមឲ្យពួកគាត់ឆាប់រួចពីទុក្ខវេទនា ដោយអំណាចមហាកុសលរបស់កូននាគប្រុសស្រីសម័យបច្ចុប្បន្ននេះ រួមសាមគ្គីគ្នាឧទ្ទិសបញ្ជូននូវបុញ្ញកម្មទៅឲ្យពួកគាត់ ដែលកើតចេញពីកម្លាំងកតញ្ញូកតវេទី (កតញ្ញូ=ដឹងគុណ / កតវេទី=តបគុណ) របស់កូននាគប្រុសស្រី ។

## ២៦.ប្រាសាទអង្គរវត្ត ឬអង្គរតូច

ហេតុអ្វីបានជាដូនតាយើងដាក់ឈ្មោះប្រាសាទនេះថា អង្គរវត្ត ឬអង្គរតូច ?

**ពន្យល់ពាក្យ** (អង្គ និងអង្គរ)

អង្គ = អវយវៈ រូប តួរូបកាយ រាងកាយ ខ្លួនប្រាណ ភាគ...

អង្គ = អង្គជាតិ (ព្រះឥសូរ) ឬសិវលិង្គ (លិង្គព្រះសិវៈ) ប្រដាប់ភេទរបស់បុរស...

អង្គ = នាក់ រូប ខ្លួន ទ្រង់ លោក សម្រាប់ប្រើចំពោះតែព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះពុទ្ធរូប ព្រះអរហន្ត ក្សត្រិយ ទេវតាសក្តិធំ បព្វជិតថ្នាក់ខ្ពស់...

អង្គរ = (អង់ + គរ) អង្គ គរតគ្នាជាគំនរ បើតាមការយល់របស់ខ្ញុំបាទ ពាក្យថា អង្គរនេះ ន័យទីមួយគឺអង្គជាតិ(លិង្គ) គរគ្នា បូកគ្នា គ្រប់សម័យកាល ទើបបានក្លាយទៅជាស្តេចលិង្គដ៏ធំនៅលើកំពូលភ្នំបូក ដែលសព្វថ្ងៃស្តេចលិង្គនេះ ត្រូវបានគេបំផ្លាញអស់ហើយ។ ន័យទីពីរ គឺបូកតួអង្គព្រះវិស្ណុតូចៗ ដែលគេឆ្លាក់ទុកនៅខាងក្រោមស្ពានថ្មផ្លូវចូលប្រាសាទ គ្រប់ជើងទ្វារប្រាសាទ ហើយអង្គព្រះវិស្ណុដែលតូចៗ ទ្រស្ពានបូកបញ្ចូលគ្នាយូរៗទៅ បានក្លាយទៅជាអង្គព្រះវិស្ណុធំដែលគេឆ្លាក់នៅផ្លូវចេញសព្វថ្ងៃ យើងហៅថា**តារាជ** និងព្រះវិស្ណុដែលនៅកំពូលកណ្តាល ឬប្រាសាទកណ្តាល (បាកាន ឬបាកាន់)

តើ**ប្ងា**គាត់កាន់អ្វី? គឺគាត់កាន់ម្កុដ ឬក្បួនគម្ពីររឿងរ៉ាវរបស់ព្រះម៉ែនៅក្នុងសមុទ្រទឹកដោះ ពេលដែលគាត់ចុះទៅស្រង់ព្រះម៉ែ ហើយទប់ពួកទេវតា និងពួកយក្សឈប់ឲ្យចងកម្មពៀរគ្នា ។

តើអត្ថន័យអង្គជាតិតូចៗបូកបញ្ចូលគ្នា ឬគរគ្នានឹងអត្ថន័យអង្គព្រះវិស្ណុតូចៗ បូកបញ្ចូល ឬគរគ្នា តើន័យទាំងពីរខាងលើនេះ ន័យមួយណាពិតនឹងត្រឹមត្រូវ? យើងដឹងហើយថាប្រាសាទនេះ


រូបព្រះវិស្ណុតូចៗគគ្នាបានជារូបធំជិះលើគ្រុឌ

ដូនតាគាត់ធ្វើទុកឲ្យឬឧទ្ទិសឲ្យព្រះវិស្ណុ (ព្រះនរាយណ៍) បើប្រាសាទនេះ គាត់ធ្វើឧទ្ទិសឲ្យព្រះវិស្ណុ អត្ថន័យទីពីរដែលខ្ញុំបានពន្យល់ខាងលើ ពិតជាត្រឹមត្រូវជាង គឺ**រូបព្រះវិស្ណុតូចៗ** កាន់ដៃគគ្នាទ្រក្រោមស្ពាន ហើយក្នុងមួយវគ្គ ឬមួយសង្កាត់តែងតែមានសត្វគ្រុឌនៅរាររាំងម្ដង ដូច្នេះការផ្គុំ ឬគរនូវអង្គរូបព្រះវិស្ណុតូចៗនេះ ទើបធ្វើឲ្យប្រាសាទមានឈ្មោះថា **អង្គរតូច**។ ចុះចំណែកឈ្មោះមួយទៀត ដែលយើងហៅថាអង្គរវត្តវិញ មានន័យយ៉ាងណា? ***អង្គរវត្ត*** ន័យទីមួយ ព្រោះនៅជាប់ប្រាសាទមានវត្តដែលតំណាងឲ្យព្រះពុទ្ធសាសនា ទើបគេហៅថាអង្គរវត្ត ឯន័យទីពីរ ពាក្យខ្មែរសព្វថ្ងៃច្រើនតែនិយាយតគ្នាថា យកចង្ហាន់ឬទេយ្យវត្ថុផ្សេងៗ និងបច្ច័យបួនជាដើមទៅវត្ត ពាក្យវត្តក្លាយមកពីពាក្យថា វត្តប្រតិបត្តិ ឬវត្តបដិបត្តិ គឺបដិបត្តិឬប្រតិបត្តិឲ្យបានត្រឹមត្រូវទៅតាមត្រៃសិក្ខា (**សិល សមាធិ បញ្ញា**) នេះគឺជាពាក្យដែលយើងគ្រប់គ្នាតែងប្រើសម្រាប់ហៅទីអាវាស ឬអារាមថា ***វត្ត***។ មិនថាភិក្ខុ សាមណេ ឧបាសក ឧបាសិកា តែងតែមានកិច្ចវត្តទៅតាមត្រៃសិក្ខារៀងៗខ្លួន ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់បានត្រាស់សម្ដែងសរសើរនូវបុគ្គលណា ដែលបានបូជាព្រះអង្គដោយបដិបត្តិបូជា គឺជាការបូជាដ៏ឧត្តម (បរិនិព្វានសូត្រ) នេះជាកិច្ចវត្តប្រតិបត្តិរបស់ពុទ្ធសាសនិកទាំងឡាយ។ ចុះចំណែកអង្គរវត្តវិញ មានន័យយ៉ាងណា? គឺមានន័យថា ព្រះវិស្ណុដែលដូនតាប្រសិទ្ធិនាមឲ្យឬធ្វើប្រាសាទឧទ្ទិសឲ្យនោះ គាត់ត្រូវមានវត្តប្រតិបត្តិដើម្បីសន្សំបារមី ឲ្យបានក្រាស់ក្រែលរហូតអាចមានកម្លាំងស្រង់ ឬរែកអ្នកមានគុណ ទៅដាក់លើកំពូលព្រះវិហារវិញបាន ព្រោះប្រាសាទអង្គរវត្ត ដូនតាគាត់កសាងតាមប្លង់ ***លោកុត្តរៈ*** ឬប្លង់អាទិទេព។ ព្រោះន័យរបស់ព្រះវិស្ណុ (នរាយណ៍) គឺទ្រទ្រង់លោក ថែរក្សាលោក និងស្រោចស្រង់លោក ដូច្នេះគាត់មានកិច្ចវត្តស្រោចស្រង់ទ្រទ្រង់ និងថែរក្សានូវអាទិទេពរបស់ខ្លួន គឺព្រះមាតាបិតាមហានាគ

*នេះជាអត្ថន័យរបស់ឈ្មោះអង្គរវត្ត។ ចុះហេតុអ្វីបានជាគាត់ធ្វើប្រាសាទគក់ទ្រូងទុកឲ្យព្រះវិស្ណុ? យើងដឹងហើយថា មនុស្សដែលមានទុក្ខនិយាយមិនចេញ គឺមានតែគក់ទ្រូងខ្លួនឯង ទើបបានធូរស្បើយ ពុំមែនអ្នកមានសេចក្ដីសប្បាយរីករាយជាអ្នកគក់ទ្រូងឡើយ នេះជាអាថ៌កំបាំងប្រាសាទគក់ទ្រូង ដែលគេធ្វើទុកឲ្យព្រះវិស្ណុគក់ ពេលដែលតឹងចិត្តលំបាកចិត្តនិយាយមិនចេញ ឬក៏ស្រាយប្រស្នាកំបាំងព្រះម៉ែមិនរួច ឬមួយស្រាយរួចហើយយកទៅប្រាប់គេៗមិនជឿហើយគេមិនជួយ។ ហេតុអ្វីក៏ក្នុងប្រាសាទអង្គរវត្តនេះ ដូនតាគាត់ឆ្លាក់រូបអប្សរាច្រើនម្លេះ? ហើយក្នុងអប្សរារាប់រយពាន់នោះ មានតែពីរទេ ដែលមួយលានអណ្ដាត មួយទៀតសើចចេញធ្មេញ? បើយើងចម្លងសិល្បៈវប្បធម៌ពីឥណ្ឌាហេតុអ្វីក៏អប្សរាឬអច្ឆរាខ្មែរមិនមានពាក់អាវ?*

***ពន្យល់ពាក្យ*** *(អប្សរា)*

*អប្សរា = អច្ឆរាស្ត្រី ដែលមានពណ៌សម្បុរ ស្បែកថ្លាស្រស់ផូរផង់ ឬស្ត្រីដែលមានមុខស្រស់បំព្រង (ស្រីសួគ៌ ស្រីទេពអប្សរ)*

*ក្នុងឯកសារអាថ៌កំបាំងបណ្ដាំព្រះមាតាមហានគរភាគទី១ ខ្ញុំបានពន្យល់រួចហើយពីពាក្យថា មេ ឬក្មេរ ហើយពាក្យថាមេឬក្មេរ ដែលជាការទាក់ទាញនូវពួកបុរសៗឲ្យជាប់ជំពាក់ក្នុងវត្ថុកាម* ***គឺរូប សម្លេង ក្លិន រស ផោដ្ឋព្វ (កាមគុណប្រាំ)*** *រហូតបង្កើតបានសង្គ្រាមជាបន្តបន្ទាប់ ទីបំផុតប្រមុខនៃមេសុខចិត្តចុះចាញ់ដោយអំណាចមន្តស្នេហ៍របស់ព្រះថោង (កៅណ្ឌិន ហ៊ុនទៀន ឥសីកម្ពុ...) ហើយជាតំណាតមកខាងក្រោយ អច្ឆរាទាំងនេះ ដែលមានពាក្យហៅថាព្រះមេ ឬក្មេរបានក្លាយជាព្រះម៉ែឬខ្មែរ ហើយអាថ៌កំបាំងរបស់ព្រះមេនិងព្រះម៉ែនេះ បានលិចចុះទៅជាមួយខ្លួននៅក្នុងសមុទ្ទទឹកដោះ (សមុទ្ទទុក្ខ)។ រឿងរបស់មេ និងម៉ែនេះទៀតសោត គឺតួអង្គព្រះវិស្ណុបានចុះតាមទ្រូង (ទ+រូង) ទៅក្នុងបេះដូងរបស់ព្រះម៉ែ ទើបបានដឹងនូវសារវតារឿងរាប់ពាន់ឆ្នាំមុន ដែលបានលាក់កប់ទុកក្នុងសមុទ្រនៃអតីតកាលដ៏សែនវែងឆ្ងាយ ពោរពេញទៅដោយក្ដីទុក្ខក្នុងការព្រាត់ប្រាស (ប្រាសាទស៊ូព្រាត់) បាក់បែកគំនុំគុំកួនព្យាបាទ ចងពៀរឈ្នានីស ព្រោះហេតុតែគាត់ធ្លាប់បានរំលោភឈ្លានពានលើបណ្ដាប្រទេសរាប់រយដោយហេតុតែតាំងខ្លួនជាព្រះមេ ឬព្រះម៉ែ។ ហេតុនេះហើយ ទើបអប្សរារាប់*

ពាន់គាត់ឆ្លាក់ពុំមានពាក់អាវ ព្រោះគាត់ចង់បញ្ជាក់ប្រាប់កូននាគសម័យខាងក្រោយថា គាត់ពុំបាន ចម្លងវប្បធម៌គេទាំងស្រុងនោះទេ គឺជាវប្បធម៌ប្រពៃណីរបស់គាត់ជាព្រះមេនិងព្រះម៉ែ ដែលបានបង្ហូរទឹកដោះបំប៉ៅកូនរហូតក្លាយទៅជាសមុទ្រ (ពន្យល់ហើយក្នុងភាគ១)។ រីឯអប្សរាពីរ មួយលានអណ្តាត មួយសើចចេញធ្មេញ អត្ថន័យរបស់រូបទាំងពីរនេះបើតាមការយល់របស់ខ្ញុំ អប្សរាលានអណ្តាត ដោយ**អណ្តាត** គឺជាអវយវៈម្យ៉ាងសម្រាប់បញ្ចេញនូវសូរស័ព្ទសម្លេង ដែលអាចនិយាយចេញដោយការត្រិះរិះគិតក្នុងចិត្ត វាផ្ទុយពីមនុស្សគដែលពុំអាចនិយាយបាន យ៉ាងណាមិញអប្សរាដែលលានអណ្តាតនោះ ពីមុនពុំអាចនិយាយចេញឡើយ បានត្រឹមតែបិទមាត់តែឥឡូវគាត់អាចបញ្ចេញសម្លេងបានខ្លះហើយ (អច្ឆរាមួយក្នុងរាប់ពាន់) ទោះបីជាសម្លេងរបស់គាត់មិនទាន់បានឮផ្សព្វផ្សាយទូទាំងនគរក៏ដោយ ក៏អាចឲ្យឮដល់កូននាគដែលចុះទៅស្រង់គាត់(ព្រះវិស្ណុ) ហើយអប្សរាលានអណ្តាតនេះ គាត់ឆ្លាក់នៅជិតនឹងប្រាសាទគក់ទ្រូងដើម្បីឲ្យយើងជាកូននាគចេះឆ្ងល់ និងចេះពិចារណា។ ចំណែកឯអប្សរាញញឹមចេញធ្មេញវិញ គាត់ឆ្លាក់នៅគៀនជញ្ជាំងផ្លូវចេញសម្រាប់មនុស្សមានវណ្ណៈទាប ព្រោះខ្លោងទ្វារសម្រាប់ចេញចូលនៅអង្គរតូច មានចែកវណ្ណៈ ហើយព្រះវិស្ណុនាំរឿងរបស់អប្សរាចេញមកខាងក្រៅ គាត់ជាពូជទាបគឺពូជសំរែ ន័យរបស់អប្សរាចេញធ្មេញ គឺបង្ហាញពីសម្រស់របស់ធ្មេញមើលក្នុងមង្គលទីបី គឺមង្គលការ(បុកល័ក្ខ ធ្វើធ្មេញ តប់ធ្មេញ បន្សាបពិសនាគ) ដែលមង្គលទីបីនោះបានប្រាប់ថា ចុះទៅដល់ចុងជើងហើយ គឺអប្សរាចាប់ផ្តើមធ្វើដំណើរចេញពីសមុទ្រទឹកដោះដែលជាទីឃុំឃាំង(និយាយរៀបរាប់ពីបណ្តាំរឿងរបស់ខ្លួន)។

សរុបសេចក្តីមក តាមការបកស្រាយពន្យល់ដោយសង្ខេបពីឈ្មោះប្រាសាទ និងរឿងរ៉ាវចម្លាក់ក្នុងប្រាសាទអង្គរវត្ត ឬអង្គរតូចនេះ កូននាគទាំងឡាយច្បាស់ជាមានបញ្ញាអាចឈ្វេងយល់ថា ជាបណ្តាំសាវតារឿងរបស់ព្រះមេ និងព្រះម៉ែសុទ្ធសាធដែលគាត់បានលាក់បង្កប់លទៅក្នុងព្រហ្មញ្ញសាសនាដើម្បីជាការក្លែងបំភាន់។

## ២៧.ប្រាសាទសួព្រ័ត្រ ឬប្រាសាទនាងដប់ពីរ

តើពាក្យថា សួព្រ័ត្រ និងស៊ូព្រាត់ ពាក្យមួយណាត្រឹមត្រូវ?

***ពន្យល់ពាក្យ***(សួព៌ត្រ ឬស៊ូព្រាត់)

សួព៌ត្រ = ដើរលើខ្សែរព៌ត្រ

ស៊ូព្រាត់ = ស៊ូព្រាត់ប្រាសគ្នា ដោយអំណាចបាបកម្មតាមឲ្យផល

បើតាមការសិក្សាស្រាវជ្រាវ ឈ្មោះរបស់ប្រាសាទនេះ មានឈ្មោះមួយទៀតថា ប្រាសាទនាងដប់ពីរ ឬនាងពីរដណ្ដប់ រឿងនេះខ្ញុំបានពន្យល់ខ្លះៗហើយ ដែលទាក់ទងនឹងមាតាទាំងដប់ពីរ ក្នុងរឿងឈ្មោះភ្នំប្រសិទ្ធិ។ ដែលខ្ញុំលើកយកមកវែកញែកពន្យល់នេះ ចង់ឲ្យកូននាគទាំងឡាយនាំគ្នាពិចារណាឈ្វេងយល់ឡើងវិញថា តើពាក្យប្រាសាទសួព៌ត្រ និងស៊ូព្រាត់ តើពាក្យណាមួយត្រឹមត្រូវ? ព្រោះពាក្យនិយាយរបស់ខ្មែរយើងច្រើនមានកម្លាយពាក្យ ដូច្នេះវាធ្វើឲ្យបាត់អត្ថន័យដើមនៃឈ្មោះ ដូចជាប្រាសាទស៊ូព្រាត់នេះជាដើមដែលមាតាទាំងដប់ពីរលោកសុខចិត្តស៊ូព្រាត់ប្រាសស្វាមី បុត្រាបុត្រី ដោយហេតុតែការញុះញង់របស់យក្សធ្វើឲ្យស្វាមីខ្វេះគ្រាប់កែវភ្នែក (បញ្ញា)ហើយយកទៅដាក់ឃុំឃាំងនៅក្នុងប្រាសាទទាំងដប់ពីរ។ ទីបំផុត ពួកគាត់ដោយអំណាចអកុសលកម្មគាត់ត្រូវព្រាត់ប្រាសកែវភ្នែកស្វាមី បុត្រាបុត្រី ពេលសេចក្ដីស្រេកឃ្លានកើតឡើង គាត់បាននាំគ្នាហែកកូនដែលកើតចេញពីផ្ទៃរបស់ខ្លួន ចែកគ្នាបរិភោគដូចជាប្រេត (កម្មរបស់ប្រេតក្នុងជាតក) ដូច្នេះពាក្យថា **ស៊ូព្រាត់ គឺ**ត្រឹមត្រូវជាងពាក្យ**សួព៌ត្រ** ព្រោះអ្នកទាំងនោះសុខចិត្តព្រាត់ប្រាសនូវរបស់ដែលជាទីស្រឡាញ់។ ប្រាសាទស៊ូព្រាត់នេះ គាត់បានកសាងនៅទល់មុខនឹងលានព្រះគម្លង់ និងលានជល់ដំរី ដែលកន្លែងទាំងពីរនេះ សុទ្ធតែជាគុកឃុំឃាំងព្រះមាតាបិតា និងកូនដែលត្រូវឡើងមកជួយស្រង់វែកពួកគាត់។

ការរៀបរាប់ក្នុងមង្គលបី សិរិបីឈ្មោះភ្នំប្រាសាទ ភូមិស្រុក ទំនៀមទម្លាប់ ប្រពៃណី ទំនាយ.... ដែលខ្ញុំបានលើកយកមកបកស្រាយនេះ ទោះបីជាមិនបានគ្រប់ទីកន្លែង និងក្បោះក្បាយ ក៏អាចទុកដូចជាដួងប្រទីបមួយ សម្រាប់ទ្រោលបំភ្លឺមើលឲ្យឃើញនូវបណ្ដាំប្រស្នាគំនិតពិតរបស់ព្រះម៉ែមហានាគ ដែលលោកខិតខំបំពេញពលិកម្មគ្រប់បែបយ៉ាងដើម្បីបន្សល់ទុកនូវគំនិតអច្ឆរិយ ដែលសព្វថ្ងៃពិភពលោកគេបានស្ងើចសរសើរនូវក្លិនក្រអូប ដែលបានសាយភាយចេញពីបញ្ញារបស់លោក ហើយយើងជាកូននាគ បែរជាពុំបានដឹងពីការផ្ដែផ្ដាំរឿងពិតក្នុងបេះដូងព្រះម៉ែទៅវិញ ដូច្នេះសូមឲ្យពន្លឺនេះ

ជួយបំភ្លឺឲ្យកូននាគទាំងឡាយបានដឹង ហើយនឹងខិតខំជួយពួកគាត់ឲ្យបានរួចពីអកុសលកម្មចាស់នេះ តាមការផ្ដែផ្ដាំទុករបស់ពួកគាត់ ។

## VI. ឥទ្ធិពលពុទ្ធសាសនា និងព្រហ្មញ្ញសាសនាក្នុងនគរខ្មែរ

តើព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមានអាថ៌កំបាំងអ្វីជាមួយបណ្ដាំប្រស្នាគំនិតរបស់ព្រះម៉ែ?

### ក.ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនានេះបានចូលមកប្រតិស្ឋានទុកក្នុងនគរ តាំងពីយូរយារណាស់មកហើយ ចុះហេតុអ្វីបានជាពួកគាត់ សុខចិត្តទទួលយកសាសនានេះ មកធ្វើជាកេរមរតកទុកឲ្យកូនគាត់សម័យក្រោយ? យើងបានដឹងហើយថា ប្រវត្តិដើមអ្នកនគរមេនេះ មុននឹងសាសនាទាំងពីរចូលមកប្រតិស្ឋាន អ្នកនគរមានជំនឿសាសនាខ្លួនឯងរួចទៅហើយ តែក្រោយមកពេលដែលព្រះថោងចូលមកលុកលុយ សាសនាទាំងពីរក៏បានចូលមកតាមអ្នកចំណូលថ្មី។ ហើយសាសនាទាំងពីរ បានបូកនឹងសាសនាដើមមួយទៅជាបីរួមមួយ ទើបអាចរុញអរិយធម៌របស់ពួកគាត់ ឲ្យឡើងទៅដល់កំពូលបាន ហើយសាសនាទាំងអស់នេះទៀតសោត បើអ្នកខាងក្នុងមិនទទួលយកមកទុកទេ ក៏មិនអាចឋិតថេរមកដល់សព្វថ្ងៃនេះបានឡើយ។ ដែលគាត់យល់ព្រមឲ្យសាសនានេះមកប្រតិស្ឋាន ព្រោះរឿងរ៉ាវដែលមានក្នុងគម្ពីរវេទ មានសាច់រឿងស្រដៀងនឹងសាច់រឿងរបស់គាត់ ដូចជារឿង **កូរសមុទ្រទឹកដោះ រាមកេរ្តិ៍ ក្រឹស្ណៈ**....ភាគច្រើនក្នុងសាច់រឿងគឺប្រហាក់ប្រហែលនឹងរឿងគាត់ ទើបគាត់ខ្ចីសំបកគេមកលាក់អាថ៌កំបាំងសាវតាពិតរបស់ខ្លួន ព្រោះកាលពីសម័យមុន មិនដូចសម័យកាលខាងក្រោយឡើយ គាត់ខ្ចីសំបកពីគេ មករំលាយចូលប្រស្នាគំនិតរបស់ខ្លួន បង្កើតបានជាអាទិទេពសំខាន់ៗ ដូចជា **ព្រះឥសូរ** តំណាងអ្នកបង្កើតលោក និងបំផ្លាញលោក ឧ. ស្ដេចជ័យវរ្ម័នទី២ តាំងខ្លួនជាព្រះឥសូរលើកំពូលភ្នំគូលែន **ព្រះព្រហ្ម** តំណាងឲ្យអ្នកបង្កើតលោក ឧ. មុខព្រហ្មបាយ័ន បន្ទាយក្ដី តាព្រហ្ម បន្ទាយឆ្មារ.... ហើយ**ព្រះវិស្ណុ** តំណាងឲ្យសភាវៈទ្រទ្រង់លោក ថែរក្សាលោក ស្រោចស្រង់លោក ឧ. ស្ដេចសូរ្យវរ្ម័នទី២ មានឈ្មោះថាបរមវិស្ណុលោក និងអាទិទេពដ៏ទៃទៀតជាច្រើន ពុំដូចសម័យខាងក្រោយ គឺពុំមានបញ្ចូលរឿងខ្មែរទៅក្នុងសាសនា ដូចសម័យពីមុនឡើយ។ ដោយពួកបរទេសធ្វើអាណានិគម គេបានបង្រៀនយើងឲ្យសរសេរ គូរ ឆ្លាក់ពីរឿងសាសនាសុទ្ធសាធ ដើម្បីបំភាន់កូនខ្មែរសម័យក្រោយ ឲ្យយល់ច្រឡំថា រឿងរ៉ាវក្នុងថ្មពីអតីតកាលក្ដីរឿងរ៉ាវក្នុងព្រះវិហារសម័យកាលជាខាង

ក្រោយក្ដី គឺនិយាយតែពីរឿងសាសនា ។ ដូច្នេះ គំនិតខ្ចីសំបកយកមកលាក់សាច់ជាគំនិតប្រកបទៅ ដោយប្រស្នាអាថ៌កំបាំង ទាល់តែយើងជាកូននាគសម័យខាងក្រោយចេះឆ្ងល់ រួចឈ្វេងយល់ដោយឈរ លើប្រស្នាគំនិតព្រះម៉ែ វែកពីរ ទុកមួយ ទើបរកឃើញរឿងពិតរបស់ខ្លួន ឧ. យើងឆ្ងល់ថា ដូនតាគ្រាន់តែ ជាអ្នកទទួលឥទ្ធិពលពីគេ ហេតុអ្វីក៏ពួកគាត់មានមហិទ្ធិឫទ្ធិសម្បើមម្ល៉េះ ដោយពួកគាត់មានបញ្ញា អាចកសាងប្រាសាទថ្មបានរាប់ពាន់ ហើយក្នុងចំណោមប្រាសាទថ្មទាំងនោះ មានប្រាសាទមួយចំនួន គាត់បានឆ្លាក់មុខព្រហ្មធំៗរាប់សិបមុខ ព្រោះគាត់ចង់បញ្ជាក់ប្រាប់កូនខ្មែរសម័យក្រោយឲ្យបានយល់ ថា គាត់ជាប្រមុខនៃព្រហ្មក្នុងនគរនេះ គ្មានព្រហ្មខាងក្រៅណាមកគ្របសង្កត់បញ្ញាគាត់បានឡើយ ដែលគាត់ទទួលយកព្រហ្មពីខាងក្រៅ គឺគ្រាន់តែសាច់រឿងវាប្រហាក់ប្រហែល នឹងរឿងរបស់ខ្លួន ម្យ៉ាង ទៀតគាត់ចង់លាក់បាំងបំភាន់ភ្នែកបរទេស កុំឲ្យពួកគេមើលយល់ រួចដាប់បំផ្លាញប្រស្នាគំនិតនេះ ចោល។ បើពួកគេដាប់បំផ្លាញចោល ពេលដែលអកុសលកម្មរបស់គាត់ត្រូវអស់ តើបានកូននាគ សម័យក្រោយណាជួយគាត់ បើរូបចម្លាក់នៅលើថ្មត្រូវគេដាប់បំផ្លាញអស់ទៅហើយនោះ តើកូននាគ ដែលត្រូវជួយគាត់ទៅស្រាវជ្រាវឯកសារសាវតាពិតរបស់ថ្មនៅឯណា? ដូច្នេះហើយ ទើបសម័យ ខាងក្រោយ ពួកបរទេសគេបានយល់ពីបណ្ដាំគំនិតរបស់ដូនតាខាងលើគេបានប្រើកូនខ្មែរ ដែលគ្មាន មនសិការជាតិឲ្យដាប់បំផ្លាញបេះដូងខ្លួនឯងចោលដើម្បីជាថ្នូរនឹងប្រាក់។ ប្រាសាទថ្មទាំងនោះ បើគ្មាន រូបរឿងចម្លាក់នៅលើជញ្ជាំងទេ តើមានប្រយោជន៍អ្វី ចំពោះកូនខ្មែរអ្នកស្រាវជ្រាវសាវតារបស់គាត់ ព្រោះរូបរឿងទាំងអស់នោះ គឺជាឯកសារសាវតាពិតដែលនិយាយពីភាសាគំនិតរបស់ព្រះម៉ែ។

សរុបសេចក្ដីមក ឥទ្ធិពលព្រហ្មញ្ញសាសនាដែលដូនតាទទួលយកមកធ្វើជាកេរមរតក គឺអត្ថន័យទីមួយ រឿងនៅក្នុងសាសនាដូចរឿងរបស់គាត់ និងអត្ថន័យទីពីរគាត់ចង់ឲ្យកូនខ្មែរជំនាន់ ក្រោយ ចេះបន់ស្រន់បួងសួង.... ក្នុងពិធីបុណ្យផ្សេងៗប្រចាំនគរដើម្បីឲ្យនឹកឃើញដល់ពួកគាត់ដែលជា បុព្វទេពអ្នកកកើតមាតុភូមិនេះ(ព្រះមេព្រះម៉ែ) និងន័យពិតម្យ៉ាងទៀត គាត់ចង់លាក់បណ្ដាំរឿងបំភ័ន ភ្នែកពួកជនបរទេសសម័យខាងក្រោយដែលត្រូវចូលមកលុកលុយឈ្លានពានក្នុងនគរនេះ ក្នុងពេល ដែលនគរចុះទន់ខ្សោយ ពេលដែលព្រះមាតានាគលោកមិនអាចចេញពីទីឃុំឃាំងមកផ្ដល់ឱវាទបាន។

## ខ.ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា ដែលដូនតាគាត់បានយកមកប្រតិស្ឋានទុកជាកេរមរតក មានពីរនិកាយ ទី មួយគឺ និកាយហិនយាន(ថេរវាទ) ទីពីរគឺ និកាយមហាយាន(អាចារ្យវាទ) ហើយនិកាយទាំងពីរនេះ ដែលរីកចម្រើនខ្លាំង គឺនិកាយមហាយាន ក្នុងសម័យព្រះបាទជ័យវរ្ម័នទី៧។ តើនិកាយមហាយាន និង ហិនយានមានអត្ថន័យអ្វីសម្រាប់លាក់បណ្ដាំអាថ៌កំបាំងគំនិតព្រះមាតាមហានគរ?

**១.ពុទ្ធសាសនាមហាយាន** (យានធំ)

ក្នុងគម្ពីរមហាយានបានសម្ដែងប្រាប់ថា នឹងមាននូវពោធិសត្វមួយអង្គទៀត ដែលនឹងត្រូវបានត្រាស់ដឹងជាព្រះពុទ្ធនៅចុងនៃភទ្ទកប្បនេះ គឺព្រះសម្មាសម្ពុទ្ធសិរិអារ្យមេត្រីយ ដូច្នេះមានន័យថា នៅមានពោធិសត្វត្រូវបំពេញបារមីនៅឡើយ។ ហេតុនេះហើយ ទើបស្ដេចជ័យវរន្ម័ទី៧ លោកបានទ្រទ្រង់នូវព្រះពុទ្ធសាសនាបែបមហាយាននេះ ឲ្យបានរុងរឿងឡើងនៅសម័យលោកគ្រប់គ្រងប្រទេស ព្រោះលោកបានប្រកាសខ្លួនឯងថា ជា**ពោធិសត្វលោកេស្វរៈ** ដើម្បីទុកជាប្រស្នាឲ្យកូនខ្មែរជំនាន់ក្រោយធ្វើការសិក្សាពិចារណាឈ្វេងយល់ថា គាត់ខ្ចីពុទ្ធសាសនាពីខាងក្រៅមក ប៉ុន្តែពោធិសត្វពិតប្រាកដគឺជាខ្លួនគាត់ទៅវិញទេ ពុំមែនពោធិសត្វមកពីខាងក្រៅឡើយ ហើយបើគាត់ជាព្រះពោធិសត្វទៅហើយ រឿងរ៉ាវក្នុងថ្មគឺសុទ្ធតែជារឿងរបស់គាត់ទាំងអស់ គាត់ខ្ចីសំបកសាសនាមកលាក់ទុករឿងពិតរបស់ខ្លួន។ ដូច្នេះហើយ សម័យគាត់ពុំបានលើកតម្កើងព្រះពុទ្ធសាសនា បែបហិនយាន(យានតូច) ព្រោះហិនយានពុំមានព្រះពោធិសត្វសរជាតិ ដើម្បីបំពេញនូវបារមីទៀតឡើយ ព្រោះព្រះអង្គបានបរិនិព្វានទៅហើយ។ ទោះបីជាគាត់ពុំបានលើកតម្កើងក៏ព្រះពុទ្ធសាសនាបែបហិនយាន ត្រូវបានគោរព និងបូជាទូទាំងនគរដែរ។ ដូច្នេះហើយ ព្រះពុទ្ធសាសនាមហាយាន គឺជាសំបកមួយយ៉ាងសំខាន់សម្រាប់លាក់ទុកនូវរឿងព្រះមាតាមហានគរ និងរឿងកូននាគដែលត្រូវសរជាតិបំពេញបារមីជួយព្រះមាតាមហានគរ ឲ្យបានរួចផុតពីបាបកម្មនៅពេលដែលកម្មគាត់ត្រូវអស់ ដូចមានភាសិតមួយឃ្លារបស់ស្ដេចជ័យវរ័ន្មទី៧ ដែលបានចារឹកទុកលើថ្មមានន័យថា **ដោយសារគុណធម៌ ដែលខ្ញុំបានសាងក្នុងស្នាដៃទាំងអស់នេះ ខ្ញុំសូមឧទ្ទិសដល់ព្រះមាតាខ្ញុំ ពេលដែលលោករំដោះខ្លួនរួចផុតពីបាបកម្ម សូមឲ្យបានសម្រេចជាពោធិសត្វ(ពុទ្ធមាតា) ទៅអនាគតជាតិ** ដកស្រង់ចេញពីសៀវភៅ ខ្ញុំចង់ដឹងពីជនជាតិខ្មែរ។

ដោយយោងទៅតាមការបកពន្យល់ខាងលើ ទើបយើងដឹងថាដូនតាខ្មែរពីសម័យដើម លោកពុំដែលចម្លងពីគេមកទាំងស្រុងទេ គឺលោកតែងតែបញ្ចូលគំនិតរបស់ខ្លួនទៅលាក់ទុកក្នុងសាសនា ដើម្បីជាប្រយោជន៍លាក់បំបាំងភ្នែកអ្នកដទៃ ហើយនឹងទុកឲ្យកូនខ្មែរសម័យក្រោយឈ្វេងយល់ រួចបំបែកដកយករឿងគាត់ចេញពីសាសនាដើម្បីជួយគាត់ វាខុសពីសម័យខាងក្រោយដែលពួកអាណានិគមគ្រប់គ្រងខ្មែរ ពួកគេបានដឹងពីអាថ៌កំបាំងនេះគេក៏បង្រៀនឲ្យកូនខ្មែរសរសេរ គូរឆ្លាក់.... ពីរឿងសាសនាសុទ្ធៗ គឺពុំមានលាយបណ្ដាំប្រស្នាគំនិតព្រះម៉ែ ដូចពីសម័យដែលគាត់ចេញពីគុករួចឡើយ **ឧ.** សព្វថ្ងៃព្រះវិហាររបស់ព្រះពុទ្ធសាសនា ស្ទើរទូទាំងប្រទេសតែងតែនាំគ្នាគូរឆ្លាក់រឿងរ៉ាវព្រះជាតកក្នុង

សាសនាសុទ្ធៗពុំមានលាយពីបណ្តាំប្រស្នាគំនិតព្រះម៉ែ ដូចពីសម័យមុនឡើយ។ ទាំងនេះជាគំនិតបរទេស ដែលបានបំភាន់កូនខ្មែរសម័យខាងក្រោយ ឲ្យយល់ច្រឡំពីរឿងរ៉ាវនៅលើប្រាសាទថ្មពីរអតីតកាល និងរឿងក្នុងព្រះវិហារបច្ចុប្បន្ន គឺជារឿងដែលរៀបរាប់នូវអត្ថន័យរបស់សាសនាសុទ្ធសាធ។

**២.ព្រះពុទ្ធសាសនាហិនយាន**(យានតូច)

ព្រះពុទ្ធសាសនាហិនយាន (ថេរវាទ) ក៏បានចូលមកដំណាលគ្នានឹងមហាយានដែរ(អាចារ្យវាទ) តែពុទ្ធសាសនាបែបហិនយាន ពុំសូវមានបន្សល់ទុកនូវសំណង់ប្រាសាទធំៗ បញ្ជាក់ពីឥទ្ធិពលនៃព្រះពុទ្ធសាសនា បែបថេរវាទនេះឡើយ ព្រោះខ្ញុំបានពន្យល់ខាងលើហើយថា ពុទ្ធសាសនាបែបថេរវាទព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានបរិនិព្វានទៅហើយ។ ប៉ុន្តែព្រះមាតាមហានគរ លោកត្រូវតែទទួលយកព្រះពុទ្ធសាសនាបែបថេរវាទនេះ មកទុកជាមរតកឲ្យកូនខ្មែរជំនាន់ក្រោយ ព្រោះនិកាយនេះ ជាឫសគល់ពិតប្រាកដរបស់ព្រះពុទ្ធសាសនាពុំដូចជានិកាយមហាយានឡើយ។ ឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់ត្រាស់សម្តែងអស់ **៤៥**ព្រះវស្សា ៖

ទី**១**ព្រះអង្គហាមមិនឲ្យសត្វធ្វើបាបទាំងពួង

ទី**២**ព្រះអង្គឲ្យសត្វបំពេញនូវបុណ្យកុសល

ទី**៣**ព្រះអង្គឲ្យសត្វសម្អាតចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់

ឱវាទទាំងបីនេះ គឺជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ ដើម្បីឲ្យសត្វស្គាល់**គុណទោស បាបបុណ្យ នរកសួគ៌** ហើយនឹងផ្លូវទៅកាន់ទីរំលត់ទុក គឺព្រះនិព្វាន។ ដូច្នេះហើយ ទើបមានរឿងព្រះជាតក បានមកប្រតិស្ថានជាឈ្មោះប្រាសាទ រូបចម្លាក់ **ឧ.** ប្រាសាទ វិធូរបណ្ឌិត ធម្មានន្ទបាលិលយ្យ សេះពលាហកៈ សត្វអណ្តើក (តំណាងឧបាទានក្ខ័ន្ធ៥ ក្នុងរឿងកុមារកស្សបៈ)....។ល។ ព្រះមាតាមហានគរ លោកយល់តាមបុព្វេនិវាសានុស្សតិ ដែលលោកចម្រើនបាន (រលឹកជាតិបានទៅអនាគត) បើព្រះពុទ្ធសាសនា ពុំមាននៅសល់ក្នុងនគរនេះទេ គាត់ពុំអាចរួចពីអកុសលកម្មចាស់បានឡើយ ព្រោះពេលដែលកូនខ្មែរ ពុំគោរពកាន់ព្រះពុទ្ធសាសនាពួកគេពិតជាគ្មានគុណធម៌នៅក្នុងខ្លួន (សីល សមាធិ បញ្ញា) គ្មានដឹងគុណទោសបាបបុណ្យ ហើយបើកូននាគទាំងអស់ ពុំមានគុណធម៌ទាំងនេះ ធ្វើម្តេចអាចឧទ្ទិសបុណ្យជូនទៅគាត់បាន (ទំនួញប្រេត) នេះហើយជាអាថ៌កំបាំងបណ្តាំព្រះម៉ែ ដែលព្រះពុទ្ធសាសនាបានក្លាយទៅជាកេរមរតករបស់គាត់ ដែលយើងសព្វថ្ងៃបានទទួលនូវកេរនេះគ្រប់ៗគ្នា លើកលែងតែកូននាគមួយចំនួនដែលទៅទទួលសាសនាដទៃក្រៅពីមរតកព្រះម៉ែ។ នៅក្នុងរតនបុគ្គលរកបានដោយកម្រនៅក្នុងលោកប្រាំយ៉ាងនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា ៖

១. ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូនៃយើង ជារតនបុគ្គលរកបានដោយកម្រក្នុងលោក

២. បុគ្គលដែលចេះប្រកាសសម្តែងនូវព្រះធម៌ និងព្រះវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសសម្តែងហើយ

៣. បុគ្គលដែលអាចស្តាប់យល់នូវអាថ៌របស់ព្រះធម៌ និងព្រះវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសសម្តែងហើយ

៤. បុគ្គលដែលអាចប្រតិបត្តិឲ្យបានត្រឹមត្រូវទៅតាមព្រះធម៌ និងព្រះវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសសម្តែងហើយ

៥/ បុគ្គលដែលមាននូវកតញ្ញូ និងកតវេទីតា

ហេតុនៃរតនបុគ្គលទាំងប្រាំខាងលើនេះ លោកសង្ឃឹមថានឹងមានកូននាគណាមួយ ដែលរស់ក្នុងទឹកដីរបស់គាត់គេនឹងចុះក្នុងទ្រូង(បេះដូង) របស់គាត់រួចដឹងរឿងក្នុងចិត្ត ហើយកូននាគនោះនឹងព្យាយាមជួយស្រង់គាត់ជាពុំខាន ព្រោះគាត់រលឹកជាតិទៅអនាគតដឹងយ៉ាងដូច្នេះ។ ដូចជារឿងនៅក្នុងជាតកមួយ ព្រះអង្គបានត្រាស់សម្តែងថា កាលព្រះអង្គនៅជាពោធិសត្វបំពេញបារមីនៅឡើយ ពេលនោះព្រះអង្គជាអ្នកជំនួញម្នាក់ បានដើរកណ្តាលថ្ងៃក្តៅដើម្បីចេញទៅជួញ ហើយបានទៅជ្រកនៅក្រោមម្លប់ឈើមួយដើម ដែលនៅក្នុងម្លប់នោះមានបុរសម្នាក់បានចូលជ្រកមុនព្រះអង្គ។ ពេលនោះព្រះអង្គបានសួរទៅបុរសនោះថា តើអ្នកមានម្លូស្លាទេឲ្យខ្ញុំសុំមួយម៉ាត់មកព្រោះខ្ញុំស្រេកទឹក និងជូរមាត់ណាស់ បុរសដែលអង្គុយជ្រកមុននោះ ក៏ហុចម្លូស្លាឲ្យព្រះពោធិសត្វមួយម៉ាត់ ដើម្បីបំបាត់ការស្រេក និងជូរមាត់ លុះបាត់ហត់ហើយអ្នកទាំងពីរក៏បានធ្វើដំណើរទៅកាន់កំពង់ផែ ដើម្បីឡើងជិះសំពៅចេញទៅជួញ។ សំពៅនោះចេញពីច្រាំងបានចំនួនប្រាំពីរថ្ងៃ ក៏ត្រូវខ្យល់ព្យុះបោកបក់ពន្លិច ព្រះអង្គមានក្តារមួយបន្ទះតោងហែលធ្វើជាក្បូន ចំណែកឯបុរសដែលបានឲ្យម្លូស្លាដល់ព្រះអង្គ កាលនៅជ្រកក្រោមម្លប់ឈើនោះ កំពុងប្រឹងហែលនឹងដៃ។ ពេលដែលពោធិសត្វក្រឡេកឃើញបុរសនោះ លោកក៏នឹកឃើញដល់ឧបការៈគុណរបស់បុរសនោះ ពេលអាត្មាអញកំពុងស្រេកទឹក និងជូរមាត់បានបុរសនេះ ឲ្យម្លូស្លាមួយម៉ាត់ដើម្បីបំបាត់សេចក្តីស្រេក ដូច្នេះដើម្បីតបនូវគុណនេះព្រះអង្គបានហុចបន្ទះក្តារកំពុងតោងទៅឲ្យបុរស ដែលមានឧបការៈគុណនោះ រួចខ្លួនព្រះអង្គឯងខំប្រឹងហែលនឹងដៃទៅតាមយថាកម្មទៅ។ ដោយអំណាចនៃកតញ្ញូ និងកតវេទីនេះបានធ្វើឲ្យញាប់ញ័រទៅដល់ទេពធីតាដែលថែរក្សារមហាសមុទ្រ ព្រះនាងបានគិតត្រិះរិះថា បើអាត្មាអញមិនទៅជួយស្រង់បុរសដែលដឹងគុណគេនេះទេ ក្បាលអាត្មាអញនឹងប្រេះបែកជាប្រាំពីរភាគជាពុំខាន ពេលនោះទេវតាក៏ហោះឆ្ពោះទៅទីកន្លែងដែលពោធិសត្វកំពុងហែល រួចចាប់ឱបបីព្រះអង្គយកទៅដាក់នៅលើគោក ហើយក៏និម្មិតជាសម្លៀកបំពាក់និងអាហារជាទិព្វថ្វាយដល់ព្រះពោធិសត្វបានស្លៀកពាក់និងបរិភោគ។ រីឯបុរសដែលបានក្តារតោង

នោះវិញ រយៈពេលយូរទើបបានអណ្ដែតមកដល់ច្រាំងពេលឃើញព្រះពោធិសត្វនៅលើច្រាំងមុនក៏សួរដោយឆ្ងល់ថា ហេតុអ្វីក៏អ្នកមកដល់គោកលឿនម្ល៉េះ? ពោធិសត្វបានពោលរៀបរាប់តាមដំណើររឿងដែលខ្លួនដឹងគុណ និងតបគុណដល់អ្នកមានឧបការៈ ពេលនោះព្រះអង្គចង់ឲ្យបុរសនេះបានអាហារ និងសំពត់ជាទិព្វដូចខ្លួនដែរ តែគេពុំអាចទទួលយកបានឡើយ ព្រោះគាត់គ្មាននូវគុណធម៌អ្វីដែលត្រូវបានរបស់ជាទិព្វទាំងនោះឡើយ ទើបព្រះពោធិសត្វលោកប្រាប់ឲ្យបុរសនោះ ត្រេកអរ និងអនុមោទនានូវបុណ្យរបស់ខ្លួន ដែលបានបំពេញក្នុងការដឹងគុណ និងតបគុណ បុរសនោះក៏ឆ្លើយ ថា **សាធុ សាធុ** ទើបទេវតាថែរក្សាមហាសមុទ្រនិម្មិតសំពត់អាវ និងអាហារជាទិព្វឲ្យដល់បុរសនោះ។ ក្រោយមកទេវតាក៏បានបីពរអ្នកទាំងពីរ យកមកដាក់ដល់លំនៅដ្ឋានរៀងៗខ្លួន ហើយក៏បាននិម្មិតជាកែវកងមាសប្រាក់ឲ្យដល់បុរសទាំងពីរទុកចិញ្ចឹមជីវិតឈប់ឲ្យទៅធ្វើជំនួញតទៅទៀត។

នេះគ្រាន់តែជាស្លាមួយម៉ាត់សោះ ក៏ព្រះអង្គសុខចិត្តលះបង់ជីវិតដើម្បីតបនូវឧបការៈគុណ ព្រោះក្តារដែលព្រះអង្គតោងនៅក្នុងសមុទ្រនោះ ដូចជាក្បូនសំរាប់ជួយជីវិតព្រះអង្គ ឲ្យរួចផុតពីសេចក្តីស្លាប់ តែព្រះអង្គសុខចិត្តលះបង់នូវក្តារនោះដើម្បីតបគុណ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងនូវរតនបុគ្គល ដែលរកបានដោយកំរ ទី៥គឺបុគ្គលដែលមាននូវកតញ្ញូ និងកតវេទី ដែលព្រះអង្គប្រារព្ធលើបុគ្គល ដែលជាពោធិសត្វបានបំពេញនូវបារមីក្នុងរឿងខាងលើ។ ចំណែកព្រះមាតាមហានគរវិញ ដែលលោកបានទុកកេរមរតករាប់ពុំអស់ឲ្យកូនខ្មែរសម័យក្រោយ ទទួលនូវមរតករបស់លោកនេះ ព្រះម៉ែក៏លោកមានសេចក្តីសង្ឃឹមយ៉ាងមុតមាំដូច្នោះដែរ។ ព្រោះលោកដឹងថា នឹងមានកូននាគណាមួយងាកបែរមើលទៅខាងក្រោយហើយដឹងរឿងក្នុងចិត្តរបស់ខ្លួន កូននាគទាំងនោះគេនឹងព្យាយាមជួយគាត់ជាមិនខាន។ ទាំងនេះ គឺជាមូលហេតុដែលព្រះមាតាមហានគរលោកបានទទួលយក ព្រះពុទ្ធសាសនាមកទុកជាកេររបស់ខ្លួន សម្រាប់ទុកឲ្យកូនគាត់ជំនាន់ក្រោយៗ ព្រោះព្រះសាសនានេះ មានសារៈប្រយោជន៍នាំសត្វទៅរកសុគតិភព (កាមភព រូបភព និងអរូបភព) ហើយនឹងនាំសត្វឲ្យចេញចាកពីសង្សារទុក្ខ(ព្រះនិព្វាន) រួមទាំងខ្លួនគាត់ផង ដែលរងទុក្ខទទួលទោសមកដល់សព្វថ្ងៃ ព្រោះមិនបានប្រតិបត្តិតាមឱវាទព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងហើយនិងទុកសម្រាប់ឲ្យកូននាគសម័យក្រោយយល់ដឹងពីគុណទោសបុណ្យបាប....អាចជួយចម្លងគាត់ឲ្យរួចផុតពីទីទុក្ខទោសនោះ **ដោយការឧទ្ទិសបុណ្យ។ ឧ. បើសិនណារឿងរ៉ាវទាំងអស់ដែលខ្ញុំបានរៀបរាប់ក្នុងភាគមួយ និងភាគពីរនេះវាជារឿងរបស់អស់លោកអ្នកអានក្នុងបច្ចុប្បន្នវិញ ហើយអស់លោកអ្នកបានបំពេញពលិកម្មមួយជីវិត ដើម្បីកូនចៅ ញាតិមិត្ត ប្រុសស្រី តែទីបំផុតពួកគេទាំងនោះពុំបានតបនូវ សេចក្តីល្អទៅអស់លោកអ្នកវិញ**

*ហើយថែមទាំងជេរប្រមាថមាក់ងាយដល់លោកអ្នកអានទៀត តើក្នុងចិត្តរបស់លោកអ្នកអានទាំងអស់មានអារម្មណ៍ឈឺចាប់ដូចម្ដេចដែរ*

សរុបសេចក្ដីមក ព្រហ្មញ្ញសាសនាក្ដី ព្រះពុទ្ធសាសនាក្ដី សុទ្ធតែមានសារៈប្រយោជន៍សម្ដែងគាត់ និងកូនគាត់ដែលជាអ្នកទទួលស្នងមរតកសម័យក្រោយៗ ព្រោះក្នុងសាសនាទាំងពីរជាសំបក ដែលអាចលាក់បិទបាំងនូវសាវតារឿងពិតរបស់ខ្លួនផង និងជាពាក្យទូន្មានប្រៀនប្រដៅ ដល់កូនចៅនាគសម័យក្រោយផង។ ហើយម្យ៉ាងទៀត គាត់បានទុកបណ្ដាំប្រស្នាដើម្បីឲ្យកូនប្រុសស្រីសម័យខាងក្រោយឈ្វេងយល់ថា ហេតុអ្វីបានជាមានសាសនាបីរួមមួយ(**ព្រហ្មញ្ញ ព្រះពុទ្ធ បណ្ដាំព្រះម៉ែ**) នេះជាគំនិត ដែលខ្ញុំបាទបានស្រាវជ្រាវឃើញនៅក្នុងសាវតាប្រស្នាអាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរ ។

ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមអភ័យទោសពីសំណាក់ព្រះគុណម្ចាស់ អស់លោក និងមិត្តអ្នកអានគ្រប់ភេទ ទាំងគ្រហស្ថ និងបព្វជិត ... នូវរាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងដោយអចេតនា ដែលខ្ញុំបាទបានលើកយកសាច់រឿងមកជាឧទាហរណ៍ ពីក្នុងព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា។ ព្រោះស្នាដៃនេះជាការស្រាវជ្រាវចងក្រងលើកទីពីរ ហើយក៏សូមឲ្យព្រះពុទ្ធសាសនារុងរឿងឡើងវិញ ដោយបញ្ញាកូនខ្មែរប្រុសស្រីបានដឹង និងមើលឃើញពីបាបកម្មក្នុងអតីតរបស់ព្រះមាតាបិតាមហានគរយើង ហើយអ្នក ជួយវាយអត្ថបទភាគពីរនេះ គឺកូនរបស់ខ្ញុំ បាទឈ្មោះគៀត វង្សច័ន្ទភូមានជាសិស្សរៀននៅអនុវិទ្យាល័យកម្មករក្រុង។

ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមឧទ្ទិសនូវសេចក្ដីព្យាយាម ដែលខិតខំស្រាវជ្រាវ**សាវតាបណ្ដាំព្រះម៉ែមហានគរ**នេះ ក្នុងនាមខ្ញុំព្រះករុណាខ្ញុំបាទជាកូនខ្មែរម្នាក់បានកើត និងចេះដឹងហើយរីកធំធាត់ដោយកេរមរតកព្រះម៉ែ(ព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងសាសនព្រះម៉ែ) សូមឲ្យផលនៃបុណ្យនេះកើតមានចំពោះលោកអ្នកដ៏មានគុណមាន**មាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យញាតិធម៌**ដែលសុទ្ធតែជាអ្នកមានឧបការគុណ គ្រប់ៗកាលទាំងបី (អតីត បច្ចុប្បន្ន អនាគត) សូមឲ្យជួបប្រសព្វតែនៅសេចក្ដីសុខក្នុងសម្បត្តិទាំងបី គឺសុខក្នុង សម្បត្តិមនុស្ស សុខក្នុងសម្បត្តិទេវតា និងសុខរួចចាកទុក្ខទាំងពួងគឺ

*ព្រះនិព្វាន ហើយ សូមជួបតែពរទាំងឡាយប្រាំប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និង **បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ។*

*ស្នាដៃសង្ខេបសាវតាព្រះម៉ែភាគទីពីរនេះបានស្រាវជ្រាវ និងចងក្រងរួចជាស្ថាពរនៅថ្ងៃអង្គារ៍ **១២**កើត ខែភទ្របទ ឆ្នាំឆ្លូវ ឯកស័ក ព.ស **២៥៥៣**ត្រូវនឹងថ្ងៃទី **០១** ខែកញ្ញា ឆ្នាំ**២០០៩***

*ការខិតខំស្រាវជ្រាវនេះខ្ញុំសូមរក្សាសិទ្ធិទាំងស្រុង !.....*

*ពីខ្ញុំព្រះករុណាខ្ញុំបាទអ្នកទទួលមរតកព្រះម៉ែ*

**គៀត ចាន់ថុន**

*អតីតសិស្សសាលាវិចិត្រសិល្ប*

# ឯកសារព្រះម៉ែមហានគរទេវី



ឯកសារសាវតាព្រះម៉ែមហានគរ
សាវជ្រាវ និងរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ
**គៀត ចាន់ថុន**
អតីតសិស្សសាលាវិចិត្រសិល្បៈ

រូបព្រះមាតានាគ
រួចពីទោស

**ភាគ៣**

## មាតិកា

**I រូបចម្លាក់និយាយពីការជាប់ទោសដំបូងរបស់ព្រះមាតាមហានគរ(ព្រះមាតានាគ) ៣**


១/. រូបភាពចម្លាក់ទី១(នៅសារមន្ទីរជាតិភ្នំពេញ)........................................................................................៣
២/. រូបភាពចម្លាក់ទី២រូបក្បាលនាគនៅសម័យបាយ័ន (ប្រាសាទបាយ័ន)........................................................៤
៣/. រូបភាពទី៣ចម្លាក់ផ្តែរ (ប្រាសាទបន្ទាយស្រី)..........................................................................................៦
៤/. រូបភាពទី៤ផ្តែរប្រាសាទរលស់(សៀមរាប)...............................................................................................៨
៥/. រូបភាពទី៥នៅក្នុងក្បាំងក្លែង (ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំ) ..........................................................៩
៦/. រូបភាពទី៦ក្បាលម៉ែពាក់មកុដរាជកប់ត្រឹមករូចទូលយោនី (ប្រាសាទនាគព័ន្ធ)......................................១០
៧/. រូបភាពទី៧នាគក្បាំងក្លែង (ប្រាសាទបន្ទាយស្រី) ....................................................................................១១
៨/. រូបភាពទី៨ គ្រុឌបាំងក្លែង (ប្រាសាទបន្ទាយស្រី) ....................................................................................១២
៩/. រូបភាពទី៩ រូបបាំងក្លែង (មិនស្គាល់ប្រភព) ...........................................................................................១៣
១០/. រូបភាពទី១០រូបនៅលើសសរ (ផ្លូវចូលប្រាសាទបន្ទាយសម្រែ) ...............................................................១៥
១១/. រូបភាពទី១១ (នៅប្រាសាទបន្ទាយស្រី) .................................................................................................១៥
១២/. រូបភាពទី១២រូបផ្តែរ(មិនស្គាល់ប្រភព) ..................................................................................................១៧
១៣/. រូបភាពទី១៣រូបនាគក្បាល៥លើ៧ជាប់ទោសត្រឹមក (លានព្រះគំលង់) ...................................................១៩
១៤/. រូបភាពទី១៤រូបនាគក្បាល៥លើ៩ (លានព្រះគម្លង់) ...............................................................................២០
១៥/. រូបភាពទី១៥រូបនាគក្បាល៩ពីលើក្បាល៥ (ស្ពានកំពុងក្តី) ....................................................................២១
១៦/. រូបភាពទី១៦គ្រុឌចាប់ជាន់នាគ (នៅជញ្ជាំងខាងក្រៅលានជល់ដំរី) .......................................................២៣
១៧/. រូបភាពទី១៧គ្រុឌនៅកែងខ្លោងទ្វារ (នៅជញ្ជាំងខាងក្រៅប្រាសាទបន្ទាយក្តី) .........................................២៤
១៨/. រូបភាពទី១៨រូបខ្លោងទ្វារប្រាសាទ (តាព្រហ្មមើលពីចំហៀង) ...............................................................២៤
១៩/. រូបភាពទី១៩រូបយក្សជាន់ព្រះម៉ែ (មិនស្គាល់ប្រភព) ............................................................................២៦
២០/. រូបភាពទី២០យក្សឈរជាន់ព្រះម៉ែមហានគរ (សារមន្ទីរជាតិភ្នំពេញ) ......................................................២៨
២១/. រូបភាពទី២១រូបក្មេងស្រី (ជនជាតិមន) .................................................................................................៣១
២២/.រូបភាពទី២២រូបព្រហ្មត្រូវគ្រុឌចងត្បៀង(នៅប្រាសាទបាយ័ន)..............................................................៣៣
២៣/.រូបភាពទី២៣រូបព្រហ្ម(នៅបាយ័ន) ......................................................................................................៣៤
២៤/.រូបភាពទី២៤រូបមុខព្រហ្ម (ប្រាសាទបន្ទាយឆ្មារ).....................................................................................៣៥
២៥/.រូបភាពទី២៥រូបយក្សបែងភាគមើលពីចំហៀងនិងចំពីមុខ(នៅប្រាសាទបន្ទាយឆ្មារ)...............................៣៦
២៦/.រូបភាពទី២៦រូបយក្សដួលរលំជញ្ជាំងកំពែងខាងក្រៅ (ប្រាសាទបន្ទាយឆ្មារ)........................................៣៨
២៧/.រូបភាពទី២៧រូបក្នុងក្បាំងក្លែង(ប្រាសាទបន្ទាយសំរែ) ........................................................................៣៩

២៨/. រូបភាពទី២៨ រូបនៅក្នុងក្បាំងក្លែង (ប្រាសាទបន្ទាយស្រី) ..................................... ៤២
២៩/. រូបភាពទី២៩ រូបនៅជញ្ជាំង(ប្រាសាទបាយ័ន្ត) ..................................... ៤៤
៣០/. រូបភាពទី ៣០ ស្ត្រីគ្រប់លក្ខណ៍ ឬលាក់(ជញ្ជាំងប្រាសាទបន្ទាយស្រី)..................................... ៤៥
៣១/.រូបភាពទី៣១រូបគោនៅចុងក្បាំងក្លែង(ប្រាសាទបន្ទាយស្រី) ..................................... ៤៩
៣២/.រូបភាពទី៣២រូបក្បាំងក្លែងបន្ទាយស្រី(សព្វថ្ងៃនៅសារមន្ទីជាតិភ្នំពេញ) ..................................... ៥០
៣៣/.រូបភាពទី៣៣រូបផ្តែរទ្វារ និងក្បាំងក្លែងខាងលើ(ប្រាសាទបន្ទាយស្រី) ..................................... ៥២

## II.រូបភាពបង្ហាញពីសកម្មភាពកូននាគ បានទៅជួយមាតាឲ្យរួចពីអំណាចយក្ស ៥៥

៣៤/.រូបភាពទី៣៤រូបកូនចាប់មាតាផ្ដុំខ្លួនដែលហែក(ប្រាសាទបន្ទាយស្រី) ..................................... ៥៥
៣៥/.រូបភាពទី៣៥រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី) ..................................... ៥៧
៣៦/.រូបភាពទី៣៧រូបយក្សនិងក្មេងតូច(ប្រាសាទបាគង ឬបាគង់) ..................................... ៥៩
៣៧/.រូបភាពទី៣៧រូបផ្តែរប្រាសាទបន្ទាយស្រី(សារមន្ទីរជាតិភ្នំពេញ) ..................................... ៦២
៣៨/.រូបភាពទី៣៨រូបផ្តែរ(ប្រាសាទព្រះគោ)..................................... ៦៤
៣៩/.រូបភាពទី៣៩រូបផ្តែរ(ពុំដឹងប្រភព) ..................................... ៦៥
៤០/.រូបភាពទី៤០រូបទ្វារបញ្ឆោត ផ្តែរ ក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)..................................... ៦៧
៤១/.រូបភាពទី៤១រូបភាពបាតដៃផ្កាចន្ទន៍(នៅសារមន្ទីជាតិភ្នំពេញ) ..................................... ៦៨
៤២/.រូបភាពទី៤២រូបចម្លាក់លោត(សារមន្ទីជាតិភ្នំពេញ..................................... ៧១
៤៣/.រូបភាពទី៤៣រូបអង្គវិស្ណុតូចៗ(ព្រះខ័នកំពង់ស្វាយ) ..................................... ៧៣
៤៤/.រូបភាពទី៤៤រូបក្នុងក្បាំងក្លែង(មិនដឹងប្រភព នៅសារមន្ទីរជាតិ)..................................... ៧៤
៤៥/. រូបភាពទី៤៥រូបផ្តែរ(នៅប្រាសាទភ្នំជីសូរ) ..................................... ៧៧
៤៦/.រូបភាពទី៤៦រូបក្បាំងក្លែង(ប្រាសាទភ្នំជីសូរ) ..................................... ៧៨
៤៧/.រូបភាពទី៤៧រូបផ្តែរនិងក្បាំងក្លែង(ប្រាសាទភ្នំជីសូរ) ..................................... ៧៩
៤៨/.រូបភាពទី៤៨រូបផ្តែរ(ប្រាសាទនាងខ្មៅ ខេត្តតាកែវ)..................................... ៨០
៤៩/.រូបភាពទី៤៩រូបអប្សរាឬអច្ឆរា(ជញ្ជាំងប្រាសាទបាណន់) ..................................... ៨២
៥០/.រូបភាពទី៥០រូបអប្សរា ឬអច្ឆរា(ប្រាសាទបាណន់) ..................................... ៨៣
៥១/.រូបភាពទី៥១រូបផ្តែរ(ប្រាសាទបាណន់) ..................................... ៨៤
៥២/.រូបភាពទី៥២រូបអប្សរាឬអច្ឆរានៅជញ្ជាំង(ប្រាសាទអង្គរវត្ត) ..................................... ៨៥
៥៣/.រូបភាពទី៥៣រូបព្រះវិស្ណុអង្គធំ(ប្រាសាទអង្គរវត្ត)..................................... ៨៧
៥៤/.រូបភាពទី៥៤រូបមាតាមហានគរ(អង្គរវត្ត)..................................... ៨៨
៥៥/.រូបភាពទី៥៥នាគ៣រួមខ្លួនតែមួយ(ប្រាសាទអង្គរវត្ត)..................................... ៨៩

៥៦/.រូបភាពទី៥៦រូបផ្តែរខាងក្នុងប្រាសាទ(មិនស្គាល់ប្រភព).................................................................៩០
៥៧/.រូបភាពទី៥៧រូបអច្ឆរាញញឹមចេញធ្មេញ(ប្រាសាទអង្គរវត្ត)..............................................................៩១
៥៨/.រូបភាពទី៥៨រូបផ្តែរ(ប្រាសាទប្រែរូប)..........................................................................................៩៣
៥៩/.រូបភាពទី៥៩រូបនៅជញ្ជាំង(ប្រាសាទអង្គរវត្ត).............................................................................៩៤
៦០/.រូបភាពទី៦០រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)..........................................................................៩៦
៦១/.រូបភាពទី៦១រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)..........................................................................៩៩
៦២/.រូបភាពទី៦២រូបនៅ(ប្រាសាទបន្ទាយស្រី)....................................................................................១០១
៦៣/.រូបភាពទី៦៣រូបនៅជញ្ជាំង(ប្រាសាទតាព្រហ្ម)..........................................................................១០២
៦៤/.រូបភាពទី៦៤រូបអង្គរវត្ត(ប្លង់មើលពីខាងលើ)..........................................................................១០៥
៦៥/.រូបភាពទី៦៥រូបយោនីនៅខាងក្រោមទឹក(ក្បាលស្ពាន)................................................................១០៧
៦៦/.រូបភាពទី៦៦រូបព្រះវិស្ណុផ្ទុំ(នៅក្បាលស្ពាន)..............................................................................១០៩
៦៧/.រូបភាពទី៦៧រូបព្រះវិស្ណុផ្ទុំនៅលើក្បាំងក្លែង(ប្រាសាទព្រះខាន់ឬជ័យស្រី)........................................១១២
៦៨/.រូបភាពទី៦៨រូបព្រះវិស្ណុដេកនៅក្បាំងក្លែង(ប្រាសាទបន្ទាយសំរែ)..................................................១១៤
៦៩/.រូបភាពទី៦៩រូបក្រពើសាមពាន់(នៅក្បាលស្ពាន)........................................................................១១៦
៧០/.រូបភាពទី៧០រូបបុរសជ្រោងក្រពើឡើង(មិនដឹងប្រភព)..................................................................១១៧
៧១/.រូបភាពទី៧១រូបផ្តែរនៅប្រាសាទវត្តភូ(ប្រទេសលាវ)......................................................................១១៨
៧២/.រូបភាពទី៧២រូបក្បាច់ចង្វាយក្នុងសសរ(ប្រាសាទទន្លេបាត់ទី)........................................................១១៩
៧៣/.រូបភាពទី៧៣រូបវិស្ណុនៅក្បាំងក្លែងខាងលើ(ប្រាសាទទន្លេបាត់ទី)...................................................១២២
៧៤/.រូបភាពទី៧៤រូបផ្តែរកូរសមុទ្រទឹកដោះនៅផ្តែរ(ប្រាសាទទន្លេបាត់ទី).................................................១២៦
៧៥/.រូបភាពទី៧៦រូបក្នុងរង្វង់បេះដូង(មិនដឹងប្រភព)...........................................................................១៣១
៧៦/.រូបភាពទី៧៦រូបយោនីមានស្នឹងចុកបិទ(នៅប្រាសាទបាណន់)........................................................១៣៣
៧៧/.រូបភាពទី៧៧រូបលើជញ្ជាំង(ពុំដឹងប្រភព)...................................................................................១៣៤
៧៨/.រូបភាពទី៧៨រូបយក្សនិងទេវតានៅលើជើងទំរ(សព្វថ្ងៃនៅសារមន្ទីរ)...............................................១៣៧
៧៩/.រូបភាពទី៧៩ រូបពពិលពីសម័យដើម(នៅសារមន្ទីរ).....................................................................១៣៩
៨០/.រូបភាពទី៨០រូបអច្ឆរមាតាឬបិសាចពស់(មិនដឹងប្រភព)...............................................................១៤៣
៨១/.រូបភាពទី៨១រូបចម្លាក់នៅលើបល្ល័ង្កតែមួយ(មិនដឹងប្រភព)...........................................................១៤៥
៨២/.រូបភាពទី៨២រូបនៅជញ្ជាំគ្រលុកនៅខាងឆ្វេង(លានជល់ដំរី)...........................................................១៤៨
៨៣/.រូបភាពទី៨៣រូបនៅជញ្ជាំគ្រលុកនៅខាងឆ្វេង(លានជល់ដំរី)..........................................................១៤៨
៨៤/.រូបភាពទី៨៤រូបនៅជញ្ជាំងគ្រលុកខាងស្តាំផ្លូវចុះ(លានជល់ដំរី)........................................................១៥០
៨៥/.រូបភាពទី៨៥រូបជញ្ជាំងខាងលើ(លានជល់ដំរី)............................................................................១៥១

៨៦/.រូបភាពទី៨៦រូបក្នុងជញ្ជាំងកណ្តាលទ្រូងដំរី(លានជល់ដំរី)..........១៥២
៨៧/.រូបភាពទី៨៧ រូបព្រះមាតាមហានគរ(នៅប្រាសាទរលស់)..........១៥៥
៨៨/.រូបភាពទី៨៨រូបផ្តេរ(មិនដឹងប្រភព)..........១៥៩

**III.អត្ថន័យសាសនមាតាបង្កប់ក្នុងថ្ម(ពាក្យប្រៀនប្រដៅរបស់អច្ឆរមាតាឲ្យមើលថ្ម)១៦៤**

# បណ្ដាំព្រះម៉ែមហានគរ[illegible]



ឯកសារសាវតាព្រះម៉ែមហានគរ

សាវជ្រាវ និងរៀបរៀងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ

**គៀត ទាន់ឌុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ

រូបព្រះមាតានាគ

រួចពីទោស

ភាគ៣

# អារម្ភបទ

ក្រោយពីខ្ញុំព្រះករុណាខ្ញុំបាទបានចងក្រង អត្ថបទស្រាវជ្រាវអាថ៌កំបាំងបណ្ដាំមាតាមហានគរខ្មែរ ភាគមួយ និងភាគពីររួចហើយ ញាតិទាំងឡាយដែលគាត់បានមកជួបជាមួយខ្ញុំ គាត់សំណូមពរឲ្យខ្ញុំសរសេរពន្យល់ពីអត្ថន័យនៅក្នុងរូបចម្លាក់នៅតាមប្រាសាទនានា ដែលខ្ញុំព្រះករុណាខ្ញុំបាទមានជាបន្ថែមទៀត។ ដោយពួកគាត់ភ័យខ្លាចអត់ពីខ្ញុំទៅពុំមានអ្នកណាចេះមើល បកស្រាយអត្ថន័យនៃភាសារូបចម្លាក់ទាំងនោះឲ្យមកជារឿងរបស់ខ្មែរបាន ព្រោះបរទេសអ្នកបកប្រែភាសាចម្លាក់នៅលើថ្មប្រាសាទពីសម័យមុន គេបានពន្យល់ថាជាសាច់រឿងនៅក្នុងសាសនាព្រហ្មញ្ញ និងពុទ្ធសាសនាទាំងពីរនិកាយទៅហើយ។

ដោយការសំណូមពររបស់ញាតិរួមទាំងខ្ញុំព្រះករុណាខ្ញុំបាទ ពិចារណាទៅលើស្នាដៃសង្ខេប ភាគមួយ និងភាគពីរ ដែលបានចងក្រងហើយ ខ្ញុំគិតថាស្នាដៃទាំងពីរភាគនេះ ពុំអាចធ្វើឲ្យកូននាគប្រុសស្រីងាយនឹងយល់ដឹងបានឡើយ ព្រោះរឿងនេះបានលាក់បំបាំងរាប់ពាន់ឆ្នាំហើយ ដូច្នេះខ្ញុំព្រះករុណាខ្ញុំបាទត្រូវចងក្រងភាគ៣នេះជាបន្តទៀត ដោយយករូបភាពទាំងអស់ដែលប្រមូលបាន យកមកបកស្រាយពន្យល់ពីអាថ៌កំបាំងគំនិតក្នុងភាសារូបឲ្យមកជារឿងរបស់ខ្មែរ ដែលមាតាមហានគរលោកបានពន្យល់រួចចារឹករឿងក្នុងចិត្ត ទុកក្នុងថ្មពីហេតុភេទក្នុងនគរកាលពីអតីត បច្ចុប្បន្ន និងតទៅអនាគត តើនគរខ្មែរនេះនឹងវិវឌ្ឍន៍ប្រែប្រួលទៅជាយ៉ាងណា?

ខ្ញុំព្រះករុណាខ្ញុំបាទមានក្ដីសង្ឃឹមទុកជាមុនថា ឯកសារសាវតាស្រាវជ្រាវក្នុងភាគទី៣នេះ ទុកដូចជាដួងកែវប្រទីបមួយសម្រាប់កូននាគទ្រោលបំភ្លឺមើលឲ្យកាន់តែច្បាស់ ពីបណ្ដាំព្រះម៉ែមហានគរ ឬសាសនព្រះមាតានាគ។

គេហទំព័រ: http://kietchanthon.blogspot.com
http://kietchanthon.info
អ៊ីម៉ែល: kietchanthon@gmail.com
info@kietchanthon.info

ឯកសារនេះស្រាវជ្រាវ និងចងក្រងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ថុន**
អតីតសិស្សសាលាវិចិត្រសិល្បៈ

# I.រូបភាពចម្លាក់និយាយពីការជាប់ទោសដំបូង របស់ព្រះមាតាមហានគរ (ព្រះមាតានាគ)

## ១/.រូបភាពចម្លាក់ទី១(នៅសារមន្ទីរជាតិភ្នំពេញ)



រូបភាពចម្លាក់នេះ ជាផ្តែរនៅលើទ្វារប្រាសាទប៉ៃនជុន តើពាក្យផ្តែរមានន័យដូចម្តេច? ផ្តែរក្លាយមកពីពាក្យគន្លាស់កាត់ថា ផ្តែរមើលកេម៉ុាំ⇔ផ្តាំមើលកេរម៉ែ ព្រោះពាក្យផ្តែរមាន «រ» ដែលម៉ែគាត់ផ្តាំឲ្យមើលរឿងរបស់គាត់នៅលើមាត់ទ្វារ (ផ្តែរ) គ្រប់ៗទ្វារប្រាសាទ និងក្បាំងក្លែង។ តើរូបភាពនេះ ព្រះម៉ែចង់និយាយប្រាប់ពីរឿងអ្វី? បើយើងមើលដោយពិនិត្យគិតពិចារណា នោះនឹងឃើញសាច់រឿងមួយដែលគួរឲ្យសង្វេគពន់ពេក ព្រោះរូបរឿងបានរៀបរាប់នូវទុក្ខវេទនាក្នុងទីឃុំឃាំងរបស់ស្ត្រីម្នាក់ អស់រយកាលរាប់ពាន់ឆ្នាំ ដោយហេតុតាំងខ្លួនជា**មេ** និង**ម៉ែ (ស្ករតាំងម៉ែ)**។

រូបនេះបានបង្ហាញនូវរូបកណ្តាលមានក្បាលនាគមួយដែលមានក្បាលប្រាំមួយ ឯក្បាលទីប្រាំពីរគឺក្បាលរបស់ស្ត្រីនោះ គាត់នោះហើយជាព្រះនាងនាគនោះឯង។ ព្រោះគ្រប់ក្បាលនាគខ្មែរ ដូនតារបស់យើង តែងឆ្លាក់សេសពុំមែនគូឡើយ **ឧ.** នាគមានក្បាល មួយ បី ប្រាំ ប្រាំពីរ ប្រាំបួន...។ល។

ចំណែកព្រះម៉ែដែលនៅក្នុងក្បាលនាគនោះ បានបង្ហាញពីភាពរស់រវើករបស់គាត់ ហាក់បីដូចជាមនុស្សមានជីវិត ហើយគាត់ចង់ប្រាប់យើងថានាគគឺតំណាងគាត់។ គឺនាគដែលខ្ញុំបានពន្យល់ក្នុងអាថ៌កំបាំងបណ្តាំព្រះម៉ែមហានគរខ្មែរក្នុងភាគទីមួយ រួចហើយអំពីពាក្យថា "នាងនាគ"។ តែគួរឲ្យអនិច្ចាគាត់ណាស់ នាគគាត់គឺមានត្រឹមតែក្បាលប៉ុណ្ណោះ ពីត្រឹម "ក" ទៅក្រោយគឺត្រូវសត្វម្ករលេប

តែតាមពិតនាគនៅមុខផ្លូវចូលអង្គរតូចគឺយក្សចាប់ឬលេប ដូច្នេះរូបដែលយើងឃើញពីមុនហៅថា សត្វម្ករនោះ ដល់ពេលខ្ញុំស្រាវជ្រាវទៅទើបដឹងថាជាយក្ស ដែលជាអ្នកដាក់ទណ្ឌកម្មដល់គាត់។ ហេតុដូចនេះហើយការ**ឆ្លល់របស់ខ្ញុំកាលពីជាងម្ភៃឆ្នាំមុន** ខ្ញុំបានរកឃើញចម្លើយមួយដ៏សមស្របថា គ្រប់រូបចម្លាក់រឿងតាមប្រាសាទនានា ភាគច្រើនគាត់បានឆ្លាក់ពីយក្សចាប់នាគ ហើយនាគនោះគឺតំណាងឲ្យព្រះម៉ែមហានគរ ដូចមានក្នុងរឿងកូរសមុទ្រទឹកដោះជាភស្តុតាងស្រាប់។ គាត់ត្រូវយក្សចាប់ឃុំឃាំងប៉ុណ្ណឹងហើយ តែគាត់នៅតែអាចបែងភាគលួចចេញពីក្នុងគុក មកជួបជាមួយកូន ដែលជាអ្នកទទួលមរតកផ្ទាល់ពីគាត់ គឺអ្នកដឹកនាំនគរសម័យមុន (ស្ដេច) ដែលខ្ញុំបានរៀបរាប់ក្នុងភាគមួយពីឯកសារអ្នកការទូតចិន ជីវតាក្វាន់ ដោយគាត់បានមកស្រុកខ្មែរសម័យនោះ។ គាត់បានឮអ្នកស្រុកនិយាយតៗគ្នាពីបិសាចពស់ដែលតែងតែលួចចេញមកជួបជាមួយស្ដេចនោះ "ពេលបានជួបបិសាចពស់នោះនគររុងរឿង ស្ដេចមានអាយុ ពេលដែលមិនបានជួបបិសាចពស់ នគរកើតកលយុគ ស្ដេចអស់អាយុ" អាថ៌កំបាំងនេះខ្ញុំបានពន្យល់ក្នុងឯកសារភាគមួយរួចហើយ ។ ដោយគាត់ពូកែលួចចេញពីគុកមកជួបកូននោះ ទើបយក្សថែមសោមួយជាន់ទៀតគឺ **"គ្រុឌ"** (សព្វថ្ងៃនិមិត្តសញ្ញាទង់ស្ដេចសៀម) នៅក្នុងរូបភាពចម្លាក់បានបង្ហាញពី គ្រុឌពីរនៅពីខាងលើគ្រៀក ក្បាលនាគជាប់មិនឲ្យចេញរួច ក៏ប៉ុន្តែគាត់នៅតែអាចបែងភាគចេញមកបានទៀត មើលរូបភាពនាគនៅខ្លោងទ្វារចូល ប្រាសាទអង្គរធំ បន្ទាយក្ដី បន្ទាយឆ្មារ បាណន់ ...។ល។

## ២/.រូបភាពចម្លាក់ទី២រូបក្បាលនាគនៅសម័យបាយ័ន(ប្រាសាទបាយ័ន)



បើយើងមើលរូបភាពក្បាលនាគ សម័យបាយ័ន យើងនឹងឃើញការវិវឌ្ឍន៍នៃទោស របស់មាតាមហានគរកាន់តែកើនច្រើនឡើង និមិត្តរូបខ្លួនគាត់ត្រូវយក្សលេបត្រឹមក ចំណែកឯក្បាលខាងមុខ និងខាងក្រោយ ត្រូវគ្រុឌចាប់ក្រុងក្បាលខាងលើជាប់។ ប៉ុន្តែគាត់នូវតែអាចលួចចេញពីគុកបានទៀត ព្រោះនៅចន្លោះជើងគ្រុឌខាងក្រោមពីក្រោយ មានឆ្លាក់ក្បាលនាគបីលួចចេញពីក្រោមជើងគ្រុឌ ដើម្បីចេញមកជួបកូន (មើលឯកសារភាគ១)។ ដោយមិនអាចឃាត់ឃាំងឫទ្ធិ

របស់មាតាមហានគរបាន យក្សបានប្រើសោទីបីទៀត (មើលរូបទី១) គឺសន្ទប់បិទពីខាងលើក្បាលនាគ ដោយប្រើឆ្នុកមកចុកបង្កើយរបស់គាត់ ទើបសម័យខាងក្រោយ លោកពុំអាចលួចចេញមកចង្អុលបង្ហាញផ្លូវ ដល់អ្នកដឹកនាំប្រទេសសម័យក្រោយៗបានទៀតឡើយ។ នេះជាហេតុដែលធ្វើឲ្យអរិយធម៌ថ្មបានចាប់ផ្ដើមរលំស្រុតបន្តិចម្ដងៗ រិះរិតតែនឹងផុតពូជអ្នកស្នងនូវកេរមរតកម៉ែ។ ឆ្នុកបិទចុងក្រោយនេះ ខ្ញុំបានពន្យល់ប្រាប់នៅក្នុងមង្គលទីបីរួចទៅហើយ ពីរឿងបរទេសតាមបិទសន្ទប់រូងនាគហើយមាត់រូងក្រោយគេគឺនៅភ្នំអង្គរស្បូរនោះឯង។ ទទួលទោសប៉ុណ្ណឹងហើយ យក្សនៅតែមិនអស់ចិត្តទៀត ពួកគេថែមទាំងប្រើមនោគមវិជ្ជា មកសណ្ដំជនជាតិនេះឲ្យដេកលក់ លែងនឹកគិតស្រាវជ្រាវរាវរកអាថ៌កំបាំងរបស់ខ្លួន ព្រោះនៅខាងលើថ្មឆ្នុកចុកបង្កើយនាគ (រូបទី១) នោះគាត់បានឆ្លាក់រូបសត្វករវិក មួយជួរជាសោចាក់ជាន់ទីបួន សម្រាប់ច្រៀងបំភ័ន្តស្មារតីកូននាគឲ្យវង្វេងភ្លេច សត្វករវិកមួយតំណាងប្រទេសមួយ ចុះសត្វករវិកមួយជួរតំណាងឲ្យប៉ុន្មានប្រទេស? តើអាថ៌កំបាំងសម្លេងសត្វករវិកនេះមានឫទ្ធិយ៉ាងណាទៅ?

មហិទ្ធិឫទ្ធិសត្វករវិកនេះ មាននិយាយពន្យល់នៅក្នុងគម្ពីរមហាវង្សព្រង្សាវតារលង្កាទ្វីប គឺរឿងព្រះបាទធម្មាសោក ឬអសោករាជ្យ ដែលជាស្ដេចមានអំណាចផ្សាយទៅលើអាកាស មួយយោជន៍ និងទៅក្រោមមួយយោជន៍ អានិសង្សនេះកើតឡើងដោយគាត់បានបំពេញនូវទានទឹកឃ្មុំ កាលពីជាតិមុនជាមួយនឹងព្រះបច្ចេកពុទ្ធមួយអង្គ ដែលគាត់ក្នុងជាតិនោះជាឈ្មួញលក់ទឹកឃ្មុំ។ អ្នកដែលបានជួយចង្អុលបង្ហាញផ្ទះអ្នកលក់ទឹកឃ្មុំ គឺនាងកុម្ភៈទាសី ជាស្រីកណ្ដៀតក្អមដងទឹក ដោយនាងបានធ្វើទានសំពត់រុំដំបៅជាមួយនឹងព្រះបច្ចេកពុទ្ធអង្គនោះ ដែលមកបិណ្ឌបាតទឹកឃ្មុំដោយនាងបានជួយចង្អុលផ្លូវប្រាប់ ទីបំផុតនាងកុម្ភៈទាសីបានមកជាមហេសីព្រះបាទធម្មាសោកនេះ មានឈ្មោះថា "នាងអសន្ធិមិត្តា"។ ព្រះនាងអសន្ធិមិត្តានេះហើយបានសួរទៅព្រះភិក្ខុសង្ឃ ដែលជាព្រះអរហន្តថា តើសម្លេងព្រះសម្មាសម្ពុទ្ធ ពីរោះយ៉ាងណាទៅ? ហើយសម័យនេះមានអ្វី មកប្រៀបធៀបឲ្យប្រហាក់ប្រហែលនឹងសម្លេងព្រះអង្គបាន ព្រះភិក្ខុសង្ឃបានមានថេរៈដីកាថា មានសត្វករវិក មានសម្លេងប្រហាក់ប្រហែល និងសម្លេងព្រះសម្មាសម្ពុទ្ធ។ ដោយហេតុចង់ស្ដាប់សម្លេងសត្វនោះ ព្រះនាងអសន្ធិមិត្តា បានអង្វរស្វាមីជួយរកសត្វនោះមកឲ្យខ្លួន ព្រះបាទធម្មាសោកបានប្រើសេនាយក្ស ដែលនៅក្រោមអំណាចរបស់ព្រះអង្គ ឲ្យទៅចាប់សត្វនោះមកថ្វាយ។ ពេលបានសត្វនោះមកហើយវាពុំព្រមរងាវសោះព្រោះគ្មានគូ ទើបគេយកកញ្ចក់ទៅដាក់ឲ្យឃើញរូបវាម្ខាងទៀត ទើបវារងាវ។ ពេល

ដែលសត្វករវិករងាវ ព្រះឃោសាចារ្យបានពន្យល់ថា សត្វកំពុងហើរលើមេឃត្រូវឈប់សំកាំងខ្លួន ដើម្បីស្ដាប់នូវសូរសព្ទដ៏ពីរោះរបស់សត្វនេះ សត្វត្រីនៅក្នុងទឹកដែលងើបមកដកដង្ហើម ត្រូវសំកាំងនៅលើទឹក ចាំស្ដាប់សម្លេងសត្វនោះសិន រីឯសត្វម្រឹគដែលខ្លាកំពុងដេញក៏ឈប់ស្ងៀម ចាំស្ដាប់សម្លេងសត្វនោះដោយពុំគិតពីមរណៈភ័យ រីឯសត្វខ្លាវិញដែលកំពុងដេញម្រឹគនោះ ក៏ឈប់ស្ងៀមចោលចំណីចាំស្ដាប់សត្វនោះរងាវឲ្យចប់សិន។ អនុភាពនៃសម្លេងពីរោះរបស់សត្វករវិកក្នុងពេលនោះ បានធ្វើឲ្យព្រះនាងអសន្ធិមិត្តាបាននូវអមតធម៌ (សោតាបត្តិផល) ដោយព្រះនាងបានពិចារណាតាមហេតុបច្ច័យនៃធម៌ថា សភាវធម៌ទាំងឡាយកើតមាន ព្រោះមានហេតុ និងបច្ច័យ ពុំមានបុគ្គលណាមួយអាចធ្វើឲ្យកើតឡើងដោយខ្វះហេតុនោះឡើយ ដូចជាសម្លេងពីរោះ របស់សត្វករវិកនេះជាដើម។

ដោយខ្ញុំបានដកយករឿងសម្លេងសត្វករវិក មកអត្ថាធិប្បាយពន្យល់ដោយសង្ខេបនេះ ព្រោះចង់យកមកឆ្លុះបញ្ចាំង រូបភាពក្នុងចម្លាក់របស់យើងក្នុងរូបទីមួយ ដែលមាតាមហានគរលោកបានឲ្យកូននាគសម័យនោះ ឆ្លាក់រឿងនេះទុកសម្រាប់កូននាគសម័យក្រោយមើល ដោយត្រិះរិះគិតពិចារណាថា បើសត្វករវិកច្រើនម្លឹងៗ តើធ្វើដូចម្ដេចយើងអាចស្គាល់សាវតាពិតរបស់ខ្លួនបាន? ដូចនេះលោកមានសង្ឃឹមតិចណាស់ ចំពោះកូនកែ្មរសម័យខាងក្រោយ ដែលព្រមទទួលស្គាល់រឿងពិតនៅលើថ្មថាជារឿងរបស់ព្រះម៉ែមហានគរ។ ព្រោះសត្វករវិកចាស់ហើរចេញទៅ សត្វករវិកថ្មីហើរចូលមក (មើលរូបទី១) សត្វករវិកនេះ តំណាងឲ្យការផ្សព្វផ្សាយមនោគមវិជ្ជាបរទេស ដែលធ្លាប់ធ្វើអាណានិគមសាបព្រោះបំភ័ន្តបញ្ញាស្មារតីកូនកែ្មរ ឲ្យលង់លិចរាប់ជំនាន់មកហើយ ដោយខ្ញុំបានពន្យល់ពីអត្ថន័យបទសារិកាកែវអើយក្នុងភាគ១រួចហើយ ។

## ៣/.រូបភាពទី៣ចម្លាក់ផ្ដែរ(ប្រាសាទបន្ទាយស្រី

ផ្ដែរនេះបានបង្ហាញពីយក្ស ចាប់ព្រះម៉ែមហានគរយកមកដាក់ទោស គឺក្រុងរាពណ៍ចាប់នាងសេតា ហើយក្នុងរូបនេះមានក្បាលគ្រុឌកំពុងចាប់ខាំក្បាច់ តំណាងឲ្យខ្លួននាគទាំងសងខាងកុំឲ្យសត្វនាគនេះរើខ្លួនរួច នៅក្នុងទីឃុំដ៏កំបាំងនេះ អ្នកដឹងរឿងគឺមានតួរអង្គតែបីប៉ុណ្ណោះ ទីមួយយក្ស ទីពីរគ្រុឌ ហើយទីបីគឺព្រះម៉ែនាគ ដែលជាមាតាមហានគរនោះឯង គឺពុំមានអ្នកដទៃណាដឹងរឿងកំបាំងទាំងនេះឡើយ។



ចំណែកឈ្មោះរបស់ព្រះម៉ែមហានគរនោះ គាត់មានឈ្មោះជាច្រើនដូចជា លីវយី(ចិន) សោមា(ឥណ្ឌា) ព្រះនាងនាគ(រឿងព្រេងប្រចាំនគរ) ព្រះនាងសេតា(ក្នុងរឿងរាមកេរ្តិ៍) ព្រះនាងក្រពុំឈូក(រឿងទាក់ទងនឹងទង់ក្រពើ) ព្រះម៉ែសក់ក្រអូប(រឿងព្រេងទាក់ទងបទភ្លេងការ) ព្រះនាងរំសាយសក់(រឿងទាក់ទងភ្នំក្រពើ ទុងមាន់ សំពៅ...) ព្រះនាងវិមានច័ន្ទ(រឿងទាក់ទងរូបមាតានៅតែក្បាល) ទិព្វសេតាច័ន្ទ(រឿងទាក់ទងពៀររវេរា ហើយនឹងដើមកំណើតអង្គរតូច) ព្រះនាងហ៊ីងព្រះធរណី ឬគង្ហីង(ទាក់ទងនឹងអ្នកបង្កើតទឹកដី) ព្រះនាងអាក់អរ(ទាក់ទងប្រាសាទភ្នំដា និងអង្គរបុរី ព្រោះ **អរត្រូវអាក់**) បិសាចពស់(ឯកសារអ្នកកត់ត្រាជីវតាក្វាន់)។ល។ ប៉ុន្តែឈ្មោះទាំងអស់ដែលអាចយកជាត្រីវិស័យក្នុងការស្រាវជ្រាវបាន គឺមានតែរឿងព្រះថោងព្រះនាងនាគតែប៉ុណ្ណោះព្រោះរឿងនេះបានបើកបង្ហាញពីការបង្កើតពូជខ្មែរ(**កេរ+មេ**) និងខ្មែរ(**កេរ+ម៉ែ**) ដែលខ្ញុំបានពន្យល់ក្នុងភាគមួយរួចមកហើយ ឯរឿងដទៃទៀត គ្រាន់តែជាគ្រឿងផ្សំឲ្យរូបរាងរឿងរបស់គាត់កាន់តែច្បាស់ ក្នុងការស្វែងរកអាថ៌កំបាំងរបស់គាត់តែប៉ុណ្ណោះ។ ហេតុនេះបានជាសម័យខាងក្រោយអង្គរ កូននាគប្រុសស្រីពុំអាចយល់ពីសាវតាពិតរបស់ខ្លួនបាន ព្រោះអនុភាពសត្វករវិកដែលពន្យល់រួចហើយក្នុងរូបភាពទីមួយនោះ បានច្រៀងបំភ្លៃការពិតទៅជាមិនពិត នេះម្យ៉ាងៗទៀតព្រះម៉ែមហានគរលោកលែងលួចចេញពីទីឃុំឃាំងមកខាងក្រៅបានទៀត ព្រោះសោឃុំខ្លួនគាត់កាន់តែច្រើនជាន់ ហើយជាពិសេសសត្វ

ករវិកនោះ បានស្រែកច្រៀងបំភ័ន្តការពិតរបស់គាត់ ព្រោះតួរអង្គតំណាងសត្វទាំងនោះភាគច្រើន សុទ្ធតែជាប្រទេសដែលធ្លាប់ចំណុះឲ្យគាត់ពីអតីតកាល។

## ៤/.រូបភាពទី៤ផ្ដែរប្រាសាទរលស់ (ស្យេមរាប)




ក្នុងរូបរឿងរបស់ផ្ដែរនេះ ព្រឹទ្ធដូនតាបានឆ្លាក់ក្បាលយក្សដ៏ធំមួយ កំពុងឱបក្បាលនាគពីរសង្ខាង និងមួយទៀតនៅក្នុងរង្វង់អណ្ដាតខាងក្រោមមុខយក្ស ហើយនៅក្រោមខ្លួននាគដែលយក្សចាប់ទាំងសង្ខាង មានរូបស្ត្រីអង្គុយពែនភ្នែន ស្លៀកពាក់ជាស្ដេច។ រូបនេះគាត់ចង់ប្រាប់យើងថា រូបគាត់នៅខាងក្រោមខ្លួននាគដែលត្រូវយក្សចាប់នោះ គឺតំណាងឲ្យ ព្រះនាងនាគ ឬ ព្រះម៉ែនាគ (មើលការពន្យល់ក្នុងភាគ១ ភាគ២) ត្រូវលាក់បំបាំងដោយអំណាចបិទបាំងរបស់យក្ស។

សរុបសេចក្ដីមក រូបនេះបានបើកបង្ហាញពីរូបពិតរបស់យក្សក្នុងរូបទីមួយ ដែលជារូបពីរចំហៀង ឲ្យមើលឃើញចំពីមុខនូវសកម្មភាពរបស់យក្ស ក្នុងការចាប់ក្បាលនាគទាំងបីយកទៅឃុំ ដែលនាគនោះជានិមិត្តរូបតំណាងមាតាមហានគរ ដែលនៅខាងក្រោមដៃយក្ស គឺរូបស្ត្រីតូចៗទាំងពីរនោះ។

# ៥/.រូបភាពទី៥នៅក្នុងក្បាំងភ្លែង (ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំ)



ប្រាសាទនេះទោះបីកសាងឡើងពីឥដ្ឋ ដែលមានចំណាស់ទ្រុឌទ្រោមណាស់ទៅហើយ ក៏នៅបន្សល់ទុករូបភាពចម្លាក់ក្បាលស្ត្រីម្នាក់ត្រឹម**ក** នៅក្នុងរង្វង់គ្របពីខាងលើ ដែលស្ថិតក្នុងទីខ្ពស់ហាក់បីដូចជាប្រាប់យើងទាំងអស់គ្នាជាកូនខ្មែរថា ទោះបីព្រះម៉ែជាអ្នកទោសគេលេបដល់កក៏ដោយ ម៉ែនៅតែតាមជួយមើលថែរក្សាកូនម៉ែទាំងអស់គ្នាដដែល។ ព្រោះព្រះម៉ែមិនអាចឲ្យកេរតំណែល ដែលខំប្រឹង**ក**កើតទឹកដីនេះ ឲ្យរលាយសាបសូន្យចេញពីក្នុងលោកនេះបានឡើយ ម្យ៉ាងទៀតដែលម៉ែខំបំពេញពលិកម្មសុខចិត្តរងទុក្ខទទួលទោសរាប់ពាន់ឆ្នាំ ក៏ព្រោះតែមាតុភូមិ ដែលជាមរកតទុកសំរាប់កូនម៉ែ។

# ៦/.រូបភាពទី៦ក្បាលព្រះម៉ែពាក់មកុដរាជកប់ត្រឹម**ក**រួចទូលយោនី(ប្រាសាទនាគព័ន្ធ)



រូបភាពចម្លាក់នេះ ខ្ញុំបានពន្យល់រួចម្តងមក ហើយ នៅក្នុងភាគមួយនិងភាគទីពីរ ដែលខ្ញុំត្រូវយក បកស្រាយនេះ ចង់ពន្យល់ថាព្រះម៉ែបានពង្រាយ រឿងទុក្ខវេទនារបស់គាត់ គ្រប់ជញ្ជាំងថ្ម ដែលអាច រក្សារទុកនៅរឿងបានយូរ។ រូបនេះបង្ហាញពីស្ត្រីម្នាក់ ពាក់មកុដជាស្តេចគ្រងរាជ រួចទូលយោនីខ្លួនឯង មាត់ស្រែកហៅកូននាគប្រុសស្រី ឲ្យជួយគាត់ផង។ ឯកសារថ្មនេះ បរទេសគេពន្យល់ថាទឹកដែលហូរ ចេញពីមាត់រូបស្ត្រីនេះ និងរូបក្បាលសត្វទាំងបីទៀត ដំរី សេះ និងរាជសី គឺជាឱសថសម្រាប់ព្យាបាលរោគ ទាំងបួន ដែលមាននៅក្នុងខ្លួនមនុស្ស។ ចំណែកការ ឈ្វេងយល់របស់ខ្ញុំវិញ ខ្ញុំបានពន្យល់រួចហើយតាំងពី រូបទី១ រហូតដល់រូបទី៦នេះ គឺមានន័យដូចគ្នា ប៉ុន្តែរូបនេះប្លែកត្រង់ទូលយោនីខ្លួនឯង និងមាត់ហា បញ្ចេញទឹក តើទូលយោនីខ្លួនឯងមានន័យដូចម្តេច? ហើយមាត់ហាស្រែកចេញទឹកមានន័យដូច ម្តេច? ភាសាគំនិតរូបនេះ ត្រូវបានពន្យល់ប្រាប់យើងថា ម្តាយគ្រប់រូបគាត់តែងតែប្រសូត្របុត្រប្រុស ស្រីតាមទ្វារយោនីនេះ ហេតុតែប្រសូត្របុត្រ គាត់ត្រូវហួងហែងថែរក្សាបុត្រ ហេតុតែប្រកាន់មាំថា ជា បុត្ររបស់គាត់ៗសុខចិត្តដាច់**សីល៥** (សិក្ខាបទ៥) ដើម្បីចិញ្ចឹមបុត្រ អំពើដែលពុំមានសីលបានធ្វើឲ្យ គាត់ត្រូវទូលយោនីខ្លួនឯង ព្រោះបើគាត់ពុំមានទ្វារយោនីនេះ តើគាត់ត្រូវបង្កើតបុត្រតាមណា? ហេតុ នេះគាត់ចង់បង្ហាញប្រាប់កូននាគប្រុសស្រី ដែលកំពុងទទួលកេរមរតកគាត់ឲ្យបានយល់ថា ហេតុតែ ដើម្បីប្រទេស នគរ មាតុភូមិនេះ គាត់បានធ្វើបាបកម្មយ៉ាងច្រើនដើម្បីកូនខ្មែរ ទីបំផុតអំណាចជា ស្តេចពីអតីតកាល បានត្រឹមតែទូលយោនីខ្លួនឯង រួចកប់ខ្លួនដល់ត្រឹម**ក**តែប៉ុណ្ណោះ។ ចុះទឹកដែលហូរ ចេញពីមាត់ដែលហាស្រែកនោះ មានន័យដូចម្តេច? គឺមានន័យថា ពេលដែលគាត់ធ្លាក់ទៅរងទុក្ខក្នុង អបាយភូមិហើយ ទើបស្តាយក្រោយ ដូច្នេះមានតែស្រែកហៅកូននាគប្រុសស្រីឲ្យជួយគាត់តែ ប៉ុណ្ណោះ ដែលសម្លេងស្រែក កើតចេញពីទឹកចិត្តឈឺចាប់ក្នុងអបាយភូមិ ព្រោះហេតុតែកូន (ទំនួញ

ប្រែតខែភ្នំ) ដូច្នេះទឹកគឺតំណាងឲ្យទឹកចិត្តម្តាយរាល់រូប។ រូបនេះមិនត្រឹមតែកប់ត្រឹម**ក**ហើយទូលយោនី ខ្លួនឯងប៉ុណ្ណោះទេ គឺជាប់ឃុំក្នុងគុហារមួយ គ្របពីលើថែមទៀត ដូចអត្ថន័យរូបទី៥ ដែលនៅប្រាសាទសំបូរព្រៃគុកដែរ។

## ៧/.រូបភាពទីពនាគក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)



រូបចម្លាក់នេះក៏បានបង្ហាញពីយក្សមួយ កំពុងលេបនាគទៅដល់ក ទោះបីជានាគនេះឡើងទៅដល់កំពូលលើហើយ (ប្រាំងក្លែង ឬក្បាំងក្លែង) ក៏នៅតែជាប់ទោសដដែល។ ហេតុអ្វីបានជាដូច្នោះ? ប្រាសាទភាគច្រើនគឺ កើតក្រោយពេលដែលពួកគាត់ជាប់ទោសរួចទៅហើយ (ម្តាយឪពុក) ដូច្នោះទោះបីជាអរិយធម៌ថ្មក្នុងសម័យអង្គរ ឡើងទៅដល់កំពូលយ៉ាងណាក៏ដោយ គឺគ្រាន់តែជាគំនិតរបស់ព្រះម៉ែមហានគរតែប៉ុណ្ណោះ (បិសាចពស់) ដែលលោកបានលួចចេញពីទីឃុំឃាំង មកជួយរុញគំនិតកូននាគសម័យនោះ ឲ្យទៅដល់កំពូលអរិយធម៌។ ព្រោះរូបមន្តដឹកនាំនគរសម័យនោះ គឺរូបមន្តនាគចេញពីរូង ហេតុនេះទើបធ្វើឲ្យកូននាគសម័យនេះ អាចឡើងទៅដល់កំពូលអច្ឆរិយៈបាន ក៏ព្រោះតែ អច្ឆរា = អប្សរា ដែលជាមេគំនិត បង្កើតភាពអច្ឆរិយៈ (ខ្មែរ) ។

អប្សរាឬអច្ឆរា (បា.សំ) ស្ត្រីមានសម្បុរថ្លាស្រស់ផូរផង់ ឬស្ត្រីមានមុខស្រស់បំព្រង ស្ត្រីសួគ៌ ស្រីអប្សរ ស្រីទេពអប្សរ នាងអប្សរ....អច្ឆរា (វចនានុក្រមសម្តេចជួនណាត)។

ភាសាចារឹកនៅនគររាជបានសរសេរថា បើសិនណាជាមានជាតិក្រោយទៀត សូមឲ្យខ្ញុំបានកើតជាខ្មែរ តើដើម្បីប្រយោជន៍អ្វី? ដែលពួកគេចង់មកកើតជាខ្មែរ គឺដើម្បីបំពេញកិច្ចជាកូនកតញ្ញូ និងកតវេទីជូនចំពោះមាតាបិតាមហានគរនោះឯង ដោយពួកគាត់បានលះបង់មួយជីវិត ហើយសុខចិត្តធ្លាក់ទៅសោយទុក្ខនៅក្នុងអបាយភូមិ ព្រោះហេតុតែដើម្បីកូនខ្មែរប្រុសស្រី ហើយពួកគាត់តែង

នឹកសង្ឃឹមថា នឹងមានកូននាគណាម្នាក់មកជួយគាត់ជាមិនខាន នូវពេលកំណត់ទោសរបស់គាត់ត្រូវបញ្ចប់។ ហើយរូបរឿងទាំងនេះគាត់បានឲ្យកូនខ្មែរសម័យអង្គរឆ្លាក់ទុកនៅគ្រប់ប្រាសាទ និងនៅលើថ្មបាតស្ទឹងភ្នំគូលែន ក្បាលស្ពាន ព្រៃទេវតា និងនៅទីស្ថានដទៃៗផ្សេងៗទៀត ដែលរូបខ្ញុំបាទមិនទាន់បានដឹងនឹងទៅដល់។

## ៨/.រូបភាពទីប្រាំ៨គ្រុឌបាំងក្លែង(ប្រាសាទបន្ទាយស្រី)



រូបភាពនេះ ក៏មិនខុសពីរូបភាពមុនៗដែរ គឺបានបង្ហាញពីយក្ស ខាំលេបនាគ បន្ទាប់មកគឺគ្រុឌ(សៀម) ដែលនៅក្នុងមាត់គ្រុឌ គឺខ្លួននាគ ហើយនៅខាងក្រោមជើងគ្រុឌ គឺមានក្បាលនាគមួយគូ។ ហើយត្រចៀករបស់សត្វគ្រុឌ មានពាក់ក្រវិលមូលមួយគូ ដែលក្រវិលនេះ មាននៅត្រចៀកយក្សរូបទីបី គឺគាត់ចង់បង្ហាញប្រាប់យើងថា ក្រវិលមូលនេះ គឺតំណាងឲ្យបក្សពួកយក្ស ហើយដៃរបស់គ្រុឌបានបែងភាគជាបួន ដើម្បីចាប់មាតាបិតាកុំឲ្យរើខ្លួនរួច ទោះបីជាត្រូវឡើងទៅដល់ខាងលើហើយ ក៏នៅជាប់ទោសដដែល ហើយក្បាលគ្រុឌពាក់មកុដរាជ គឺតំណាងឲ្យស្ដេចនគរមួយ។ រូបភាពទាំងនេះ នៅក្នុងគម្ពីរព្រហ្មញ្ញ ពុំបាននិយាយរៀបរាប់ពីរឿងនាគជាប់ទោសឡើយ ហេតុតែយើងប្រគល់សិទ្ធឲ្យបរទេសស្រាវជ្រាវនឹងយកគំនិតគេមកសិក្សា ទីបំផុតយើងមើលរឿងរបស់ខ្លួន ទៅជារឿងរបស់សាសនាទៅវិញ។

## ៩/.រូបភាពទី៩ រូបបាំងក្លែង(មិនស្គាល់ប្រភព)



បើយើងពិនិត្យរូបចម្លាក់នេះ គាត់បានបង្ហាញប្រាប់យើងថាបាំងក្លែងគឺមានន័យថា ″បាំង″ កុំឲ្យមើលឃើញ ″ក្លែង″ ឲ្យខុសពីសភាពដើម មួយទៀតគាត់បានប្រាប់យើងថា រឿងក្នុងបាំងក្លែង គឺជារឿងរបស់នាគ ព្រោះតួបាំងក្លែង គឺជានាគមួយគូកំពុងជាប់ទោស ត្រូវយក្សលេប។ ហើយរឿងដែលមានក្នុងបាំងក្លែងគឺជារឿងរបស់គាត់ ព្រោះហេតុអ្វី? ព្រោះរូបនៅក្នុងខ្លួននាគមួយគូត្រូវឃុំក្រុងនោះ បានឆ្លាក់រៀបរាប់នូវគ្រប់សកម្មភាពផ្សេងៗទៅតាមពេលវេលា វិវឌ្ឍន៍របស់នគរនាគនេះ (មាតុភូមិ) ហើយបាំងក្លែងគឺមាននៅលើទ្វារ គ្រប់ប្រាសាទបុរាណទាំងអស់ ដែលមានក្នុងនគរបច្ចុប្បន្ន ហើយនឹងនៅក្នុងប្រាសាទ ដែលបរទេសដណ្តើមយកទៅ កាលពីអតីតជារបស់ព្រះម៉ែ។

ដូច្នេះបរទេសអ្នកសិក្សាស្រាវជ្រាវភាសារូប (ភាសាគំនិត) គេយល់ថា ព្រះម៉ែមហានគរលោកមានប្រាជ្ញាណាស់ បានលាក់រឿងក្នុងបេះដូងខ្លួនទុកនៅក្នុងថ្មទាំងអស់ ទើបគេប្រើប្រាស់ប្រាក់ដើម្បីជួលកូននាគ ដែលល្ងង់ឲ្យដាប់បំផ្លាញ ឯកសារថ្មទាំងនេះ។ ឯកសារទាំងនេះបើកុំតែត្រូវដាប់បំផ្លាញ រាប់រយឆ្នាំទៅមុខទៀត គឺពុំទាន់ខូចទៅណាឡើយ ឲ្យតែយើងចេះថែទាំរក្សា យើងមើលសក្យមុនីចេតិយ នៅពុទ្ធគយាដែលជាស្នាព្រះហស្ថ របស់ព្រះបាទធម្មាសោកមកទល់នឹងសព្វថ្ងៃ មានអាយុ ជាង២ពាន់ឆ្នាំទៅហើយ តែត្រូវបានឈរត្រដែតបង្ហាញពិភពមនុស្ស ទេវតាឲ្យមកធ្វើនមស្ការគោរពបូជាគ្រប់ៗគ្នា ព្រោះហេតុអ្វី? ចម្លើយមិត្តអ្នកអានឆ្លើយដោយខ្លួនឯងចុះ។

នៅក្នុងរូបបាំងក្លែងទី៩នេះ គាត់បានបង្ហាញពីស្ត្រីពនាក់ ដែលស្ត្រីម្នាក់មានក្បាលនាគបែកជាបី អង្គុយបត់ជើង លើកដៃសំពះនៅជាន់ខាងក្រោម។ ហើយជាន់ខាងលើបន្ទាប់ ក៏មានស្ត្រីមាន

ក្បាលនាគបែកជាបីម្នាក់ នៅម្ខាងទៀតមានរូបបុរស និងរូបមនុស្សដូចនៅពីខាងក្រោយខ្នង ចំណែកកណ្តាលមានបល្ល័ង្កទទេមួយដែលប្រកនាគ។ តើរូបនេះគាត់ចង់និយាយពីអ្វី? ស្ត្រីទាំង៧នាក់មានក្បាលជានាគក្បាលបី នោះគឺតំណាងឲ្យទេពធីតា ដែលមកហែក្បាលកបិលមហាព្រហ្ម រាល់ៗឆ្នាំនេះឯង ព្រោះប្រាំពីរស្មើមួយសប្តាហ៍ ហេតុអ្វីបានជាគាត់ឆ្លាក់នាងទាំង៧ ជានាគក្បាល៣រួចលើកដៃសំពះ? បានជាគាត់ឆ្លាក់នាងនាគទាំងនោះ មានក្បាល៣ ព្រោះបុរសស្ត្រីជាកូនម៉ែទាំងអស់កើតក្នុងនគរនាគ ដំបូងឡើយកូននាគមានក្បាលតែមួយទេ ចាប់ផ្តើមមានភរិយាស្វាមី នាគបំបែកក្បាលជាពីរ មានកូនបំបែកក្បាលបី រហូតដល់មានចៅប្រុសស្រី មុខរបរ ទ្រព្យសម្បត្តិ នាគត្រូវបំបែកក្បាលកាន់តែច្រើន ទីបំផុតនាគម៉ែនាគឪត្រូវជាប់នូវក្នុងក្បាលដ៏ច្រើន ដែលពុំអាចរើខ្លួនរួចឡើយ ហើយនាគពិតប្រាកដ គឺមានក្បាលតែមួយទេ។ ចំណែកឯដៃលើកសំពះគឺ បួងសួងសុំឲ្យម៉ែឆាប់រួចផុតពីបាបកម្ម តែកម្មនេះពុំមែនរួចបានដោយការបួងសួងឡើយ លុះត្រាតែមានកូននាគណាម្នាក់ ស្ម័គ្រចូលទៅក្នុងទ្រូងព្រះម៉ែដើម្បីបើកគាត់ឲ្យរួច។ អាថ៌កំបាំងនេះមាននៅក្នុងពាក្យកូនសោ និងមេសោ មេសោអាចរបើកបាន លុះត្រាតែកូនចូលទៅបើកនៅក្នុងទ្រូងម៉ែ ដូច្នេះទើបអ្នកនគរហៅថា មេសោ និងកូនសោ ពុំមែនហៅបាសោឡើយ នេះជាប្រស្នាបណ្តាំព្រះម៉ែមហានគរ។ ផ្ទាក់ទី២ក៏មិនខុសពីអត្ថន័យផ្ទាក់ទី១ឡើយ គ្រាន់តែអ្នកនៅជាន់ទី២ខាងលើ នៅក្បែកនឹងបល្ល័ង្កទទេតែប៉ុណ្ណោះ ហើយប្រស្នាកំបាំងបល្ល័ង្កទទេនេះខ្ញុំបានពន្យល់ក្នុងភាគមួយ និងភាគពីររួចហើយ (បាយ៉ង់កោរ)។

## ១០/.រូបភាពទី១០រូបនៅលើសសរ (ផ្លូវចូលប្រាសាទបន្ទាយសម្រែ)



នៅក្នុងរូបភាពនេះ បង្ហាញពីអច្ឆរាដែលមានពាក់ក្បាំងមកុដកំពូលបី ត្រូវឃុំខ្លួនដោយនាគបួន ហើយមានរាងដូចជាបេះដូងផ្កាប់ អត្ថន័យគឺដូចជាសត្វត្រកួត ត្រូវយកកន្ទុយមកចងកខ្លួនឯង យ៉ាងដូច្នោះ តើដោយសារហេតុអ្វី? ព្រះម៉ែនាគ ហេតុតែចង់ឲ្យកូននាគសម័យក្រោយៗ រស់នៅដោយមោទនភាព ក្នុងកេរមរតករបស់ខ្លួន គាត់បានតាំងខ្លួនជាមេជាម៉ែ ទីបំផុតបានត្រឹមតែជាប់ ក្នុងចំណងប្រាំប្រការ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយការប្រកាន់មាំថា ជាភរិយា ស្វាមី កូនក្មេរប្រុសស្រីទូទាំងនគរ ដែលជាពូជពង្សរបស់គាត់។ ទីបំផុតបានត្រឹមតែជាប់ផុង ក្នុងអបាយភូមិដែលជាទីទុក្ខ ព្រោះហេតុតែសេចក្ដីប្រកាន់ថា ជាសត្វ ជាបុគ្គល ជាតួខ្លួន តាមពិតគឺជាបុគ្គលប្បញ្ញត្តិសោះ។

## ១១/.រូបភាពទី១១ (នៅប្រាសាទបន្ទាយស្រី)

ក្នុងរូបភាពនេះ បានបង្ហាញពីស្ត្រីម្នាក់ពាក់មកុដរាជ្យ បាំងខ្លួននៅក្នុងព្រៃក្បាច់ ដែលបង្ហាញចេញនៅដោះល្បៀនចេញមកក្រៅតាមចន្លោះក្បាច់ ដើម្បីឲ្យយើងស្គាល់ថាជាស្ត្រី។ ចំណែកឯដៃទាំងពីរលើកលាបង្ហាញពីបាតដៃ គឺគាត់ចង់ពន្យល់ប្រាប់យើងថា ឈប់នាំគ្នាមើលរឿងខ្នងដៃដូចពីមុនទៀត បើមើលខ្នងដៃគឺពុំស្គាល់គាត់ឡើយ ព្រោះមរតកម៉ែទាំងអស់ កើតចេញពីបាតដៃទាំងគូរបស់ម៉ែនេះ។



ដូចជាក្នុងទំនាយដែលចាស់ៗនិយាយតៗគ្នាថា **រកា**សាដាន **ចផ្កា**ប់ចាន **ក្រុរ**ឆ្កែលូ ពាក្យទំនាយនេះពីមុនខ្ញុំពុំបានយល់ន័យឡើយ ពេលដែលខ្ញុំស្រាវជ្រាវអាថ៌កំបាំងព្រះម៉ែមហានគរ ទើបខ្ញុំយល់ប្រស្នាទំនាយនេះ ដែលមានជម្រៅពុំនឹកស្មានដល់។ ពាក្យរកាសាដានគឺមានន័យថា សាដានស្នាមចាស់របស់គាត់ តែមកដល់ឆ្នាំរកាត្រូវសាដាន បែរជាសាពុំរួច ព្រោះរកាត្រូវកោង (រកាកោង មើលការពន្យល់ភាគមុន)។ ពាក្យ**ច**ផ្កាប់ចានមានន័យថា ចានយើងអាចដឹងប្រភពនាំចូលរបស់វាបាន លុះត្រាតែផ្កាប់ ព្រោះហេតុអ្វី? គ្រប់ចានតូចធំ តែងតែមានសញ្ញាសម្គាល់ប្រទេសដែលផលិតនៅបាតចាន យើងអាចស្គាល់ប្រភពរបស់វា លុះត្រាតែមើលបាត ដូចជាក្នុងប្រស្នារូបនេះ មិនខុសពីមើលបាតចានឡើយ គឺមើលបាតដៃ។ នៅក្នុងសម័យពុទ្ធកាល ព្រះអង្គតែងសម្តែងធម៌ប្រោសបរិស័ទ ហើយបរិស័ទទាំងនោះ ពេលស្តាប់ធម៌រួចយល់ពីអត្ថន័យធម៌តែងតែភ្លាតមាត់ឧទានថា អស្ចារ្យណាស់ព្រះអង្គ ធម៌ព្រះអង្គសម្តែងដូចជាគេត្រឡប់ររបស់ផ្កាប់ឲ្យផ្ងារឡើង ដូចជាគេដុតប្រទីបបំភ្លឺក្នុងទីងងឹត...។ល។ យ៉ាងណាមិញ រូបភាពនេះ គាត់ក៏ចង់បង្ហាញកូននាគប្រុសស្រី ឲ្យយល់ពីរឿងពិតរបស់គាត់ ដែលបានបិទបាំងក្នុងព្រៃគី អតីតកាលដ៏យូរលង់ណាស់មកហើយ ឲ្យមកឃើញរឿងពិតរបស់គាត់ដូចជាគេផ្ងារបាតដៃដែលធ្លាប់តែផ្កាប់ឲ្យផ្ងារឡើងយ៉ាងដូច្នោះ។

សរុបសេចក្ដីមក ប្រស្នាក្នុងរូបនេះ គាត់ចង់ឲ្យយើងមើលរឿងរ៉ាវរបស់គាត់ នៅលើបាតដៃទាំងគូ ដែលខំប្រឹងលាចេញពីព្រៃក្សាច់ ឲ្យបានឃើញក្រយៅពិតនៅក្នុងបាតដៃទាំងពីររបស់គាត់ ហើយឈប់នាំគ្នាមើលខ្នងដៃតទៅទៀត។

## ១២/.រូបភាពទី១២រូបផ្តែរ (មិនស្គាល់ប្រភព)



ក្នុងរូបភាពផ្តែរនេះ អត្ថន័យរបស់រូបក៏មិនសូវខុសពីរូបផ្តែរមុនឡើយ គ្រាន់តែក្នុងផ្តែរនេះមានបន្ថែមរូបឥសី អង្គុយក្នុងទ្រនុងខ្នងនាគ ដែលយើងពុំធ្លាប់បានឃើញពីមុន។ ក្នុងរូបនេះមានគ្រុឌកំពុងចាប់នាគពីរ ដែលនាគទាំងពីរពុំមានខ្លួនពិតឡើយ គឺជាខ្លួនរបស់យក្ស (ម្ករ) ព្រោះតួខ្លួនពិតរបស់គាត់បានបាត់រូបរាងទៅហើយ សូម្បីតែទ្រនុងនាគខាងលើក៏ជាខ្លួនរបស់យក្សដែរ។ នៅខាងក្រោមក្បាលនាគទាំងសងខាង មានទំផ្កាឈូក និងមានសត្វតោម្ខាងមួយ កំពុងជ្រោងលើកក្បាលនាគឡើង តើទំផ្កាឈូកមានន័យដូចម្ដេច? ទំផ្កាឈូកដែលទ្រនាគ គឺតំណាងឲ្យនាគទាំងពីរជាអ្នកគោរពព្រះពុទ្ធសាសនា ព្រោះផ្កាឈូក តំណាងឲ្យព្រះពុទ្ធសាសនា។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងថា សត្វដែលកំពុងស្ថិតក្នុងភពបី គឺកាមភព រូបភព និងអរូបភព ប្រៀបប្រដូចនឹងផ្កាឈូកដែលដុះក្នុងជលស្ថានទាំងបួនពួក។ ផ្កាឈូកទីមួយ ប្រៀបដូចបុគ្គលដែលទើបដុះចេញពីភក់ ផ្កាឈូកទីពីរ ប្រៀបដូចបុគ្គលដែលដុះចេញពីភក់ ហើយដែលនៅក្នុងទឹក ផ្កាឈូកទីបីប្រៀបដូចបុគ្គលដែលដុះផុតពីទឹក ផ្កាឈូកទីបួន ប្រៀបដូចបុគ្គលដែលដុះផុតពីទឹកហើយរង់ចាំងព្រះសែងសូរិយា ចាំងមកប្រុងនឹងរីក។ ដូច្នេះទើបព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គដែលបានត្រាស់ដឹង ដូចជាអម្បាលខ្សាច់ក្នុងមហាសាគរ តែងមានពុទ្ធកិច្ចប្រាំយ៉ាង ព្រឹកព្រះអង្គនិមន្តបិណ្ឌបាត ថ្ងៃរសៀលទ្រង់សម្ដែងធម៌ប្រោសពុទ្ធបរិស័ទ ព្រលប់ទ្រង់ផ្ដល់ឱវាទចំពោះពួកភិក្ខុសង្ឃ អាធ្រាតទ្រង់ដោះស្រាយប្រស្នាពួកទេវតា ជិតភ្លឺទ្រង់

ពិចារណាមើលនិស្ស័យសត្វ ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង។ ហេតុនេះហើយទើបព្រះម៉ែមហានគរលោកបានយករចនាប័ទ្ម = ត្របកផ្កាឈូកនេះ មកប្រតិស្ឋានទុកគ្រប់ប្រាសាទ ដើម្បីទុកជាប្រស្នាឲ្យកូននាគសម័យក្រោយមើលរួចត្រិះរិះគិតពិចារណា នេះជាអាថ៌កំបាំងរបស់ព្រះម៉ែមហានគររចនាប័ទ្ម = (សំ) ក្បាច់ត្របកឈូក (វចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត**)។ ចំណែកឯសត្វតោពីរ តំណាងឲ្យទីក្រុងមួយដែលនឹងកើតឡើងទៅអនាគត គឺទីក្រុងដែលមានរូបសំណាកតោពីនោះឯង ប៉ុន្តែក្នុងរូបភាពនេះ ពុំទាន់មានកូនខ្មែរណាមួយអាចមកជាន់លើក្បាលយក្ស និងជាន់លើគ្រុឌបាន ទើបតោទាំងពីរ ពុំអាចមានកម្លាំងលើករឿងព្រះម៉ែនាគរួចឡើយ ព្រោះនាគទាំងពីរជាប់ឃុំនៅក្នុងអំណាចយក្ស គ្រុឌ គម្រមបថ្ម និងសត្វករវិក ដែលខ្ញុំបានពន្យល់ក្នុងរូបភាពទីមួយរួចហើយ។ នៅខាងលើទ្រនុងនាគមានរូបឥសីមួយគូ កំពុងអង្គុយពែនភ្នែនលើផ្កាឈូក ដៃលើកសំពះ ចំណែកឯនៅកឥសី មានពាក់ខ្សែអង្កាំសម្រាប់ធ្វើសមាធិ តើឥសីទាំងពីរតំណាងឲ្យអ្វី? ឥសីទីមួយគឺតំណាងឲ្យឥសីកម្ពុ ព្រះថោង កៅណ្ឌិន ហ៊ុនទៀន....។ល។ ដែលគាត់ជាស្វាមីរបស់ព្រះនាងនាគពីអតីត ហើយគាត់ជាប់ទោសដូចព្រះម៉ែមហានគរដែរ គ្រាន់តែគាត់នៅក្រៅឃុំតែប៉ុណ្ណោះ ដូច្នេះហើយទើបគេឆ្លាក់រូបគាត់អង្គុយនៅលើទ្រនុងនាគ បានន័យថា គាត់នៅក្រៅឃុំ (ព្យួរទោស)។ ចំណែកឥសីទីពីរ គឺតំណាងឲ្យពូជឥសីខាងក្រោយគឺ "កូន" ព្រោះសម័យក្រោយ គឺកូនខ្មែរគ្រប់ជំនាន់ដែលបានទទួលមរតកឥសីពីអតីតកាល គឺតំណាងឲ្យឥសីកម្ពុ ព្រោះអ្នកដឹកនាំគរសម័យក្រោយៗ គឺជាបុរសបន្តគ្នា គេពុំបានដឹងពីរឿងព្រះមេ និងព្រះម៉ែពីអតីតកាលទៀតឡើយ។ រូបនាគដែលជាប់ទោសមានក្បាលបីនោះ មួយតំណាងម្ដាយ ពីរតំណាងឪពុក បីតំណាងឲ្យកូន ហេតុអ្វីបានជាឥសីទាំងពីរអាចនៅក្រៅឃុំបាន? ព្រោះស្ត្រីដែលជាភរិយាឬម៉ែ ហេតុតែនគរខ្លួន កូនខ្លួន ក្នុងនាមជាម៉ែ (ស្គរតាំងម៉ែ) គាត់សុខចិត្តយកអម្រែកទោសពីរថែមទៀត របស់ស្វាមី និងកូន មកទទួលរែកតែម្នាក់ឯង។ ដោយគាត់យល់ថា បើជាប់ទោសទាំងអស់គ្នា គឺគ្មានអ្នកណាទៅខាងក្រៅឃុំសរជាតិ ដើម្បីជួយគ្នាឡើយ ដូច្នេះហើយទើបគាត់ ទទួលអម្រែកទាំងពីរថែមទៀត រួមទាំងទោសរបស់គាត់មួយផង ទើបរួមជាបី (មើលសោបីជាន់រូបទីមួយ)។ នៅលានព្រះគម្លង់ស្ដេចគម្លង់ (ព្រះថោង) គេឆ្លាក់រូបគាត់នៅខាងលើ ប៉ុន្តែនៅទិសទាំងបួន មានអ្នកឈរយាមគាត់គ្រប់ទិស តែសព្វថ្ងៃរូបទាំងបួនទិសនោះ នូវសល់តែជើងទំរតែប៉ុណ្ណោះ ឯរូបខាងលើមិនដឹងទៅដល់ទីណាឡើយ នេះបានបង្ហាញឲ្យយើងដឹងថា គាត់នូវព្យួរទោសនៅឡើយ។ បញ្ញាសជាតករបស់ខ្មែរ ក៏បានពន្យល់ពីការសរជាតិរបស់ពោធិសត្វ ដើម្បីបំពេញបារមី ហេតុអ្វីបានជារឿងនៅក្នុងបញ្ញាសជាតកខុសពីរឿងក្នុងជាតកគម្ពីរព្រះត្រៃបិតក ព្រោះរឿង

ក្នុងបញ្ញាសជាតក និងជាតកនានា ជារឿងសរជាតិរបស់អ្នកទាំងពីរ ដែលខ្ញុំបានពន្យល់ហើយខាងលើ ហើយអ្នកប្រាជ្ញជំនាន់នោះ គាត់បានលាក់រឿងគាត់ក្នុងស្រោមព្រះពុទ្ធសាសនា។ ឥសីទាំងពីរនេះទៀតសោត វិលងអត្តភាពពីមួយកំណើតទៅមួយកំណើត គឺស្ត្រីជាព្រះម៉ែនេះហើយ (បិសាចពស់) ដែលបានមកភ្ជាប់រឿងឲ្យដឹងតជាប់គ្នាឡើង ទម្រាំដល់ពេលដែលត្រូវកំណាត់រួចពីទោស។ ក្នុងភាគមួយ និងភាគពីរមុន ខ្ញុំពុំបានបង្ហាញ ពីស្វាមី ឬឪពុករួមទាំងកូននេះឡើយ ព្រោះពួកគាត់កំពុងនៅព្យួរទោសខាងលើស្រាប់ ដូចនេះខ្ញុំបានពន្យល់បកស្រាយតែរឿងរបស់មាតាមហានគរតែប៉ុណ្ណោះ ដែលសុខចិត្តយកទម្ងន់ទោសអ្នកទាំងពីរ មកទទួលតែឯង **នេះជាហេតុដែលខ្ញុំពុំបានពន្យល់ក្នុងភាគមុនៗ។**

សរុបសេចក្ដីមក ភាសារូបក្នុងផ្ទៃរនេះក៏មិនខុសពីន័យផ្ទៃរមុនៗឡើយ គ្រាន់តែគាត់បានបន្ថែមឥសីពីររូប ដែលខ្ញុំត្រូវបកស្រាយពន្យល់ដោយសង្ខេបនៅក្នុងរូបភាពនេះ គ្រាន់ទុកជាទុនសម្រាប់កូននាគប្រុសស្រីពិចារណាឈ្វេងយល់ មកជារឿងរបស់ព្រះម៉ែ ឈប់យល់ច្រឡំថាជារឿងនៅក្នុងសាសនាទៀត។

## ១៣/.រូបភាពទី១៣រូបនាគក្បាល៥លើ៧ជាប់ទោសត្រឹមក (លានព្រះគំលង់)



រូបភាពក្បាលនាគពីរជាន់នេះ តំណាងឲ្យនាគជាប់ទោស ក្នុងទីឃុំលានព្រះគម្លង់ ព្រោះនាគដែលស្ថិតក្នុងទីនេះ មានតែក្បាលខ្លួនត្រូវកប់ទៅក្នុងដី ឬភក់ ដែលដីនិងភក់នេះ សព្វថ្ងៃបានរឹងក្លាយទៅជាថ្ម (ថ្មភក់ ឬភក់ថ្ម)។ ក្នុងសកម្មភាពរូបភាពនេះ មានក្បាលនាគពីរជាន់ ក្បាលខាងក្រោមមាន៧ ក្បាលខាងលើមាន៥។ កន្លែងខ្លះក្បាលខាងក្រោម៩ និងក្បាលខាងលើ៥ ហើយនាគទាំងនោះ គឺបិទមាត់សង្រួមរួចងើយទៅលើស្រែកហៅកូនឲ្យជួយ ព្រោះទីលាននេះគឺជា

គុក វាខុសពីនាគនៅកំពុងក្ដី ដែលនាគក្បាល៩ នៅពីលើនាគក្បាល៥វិញ តើអត្ថន័យនាគក្បាល៥លើ៧នេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? ខ្ញុំបានបកស្រាយពន្យល់ដោយត្រួសៗរួចមកហើយក្នុងអាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរភាគ១ ភាគ២ រហូតមកដល់ភាគ៣នេះ គឺនិយាយតែពីអាថ៌កំបាំងរបស់សត្វនាគ ជានិមិត្តរូបតំណាងឲ្យមាតានាគ ដែលគាត់ត្រូវជាប់ទោសព្រោះហេតុតែសេចក្ដីប្រកាន់មាំក្នុងបញ្ចខន្ធ (ខន្ធ៥) **គឺរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ។** ដោយសន្មត់ថាជាខ្លួន ថាជាស្វាមី បុត្រា បុត្រី កូនខ្មែរប្រុសស្រី ថាជាញាតិ ហេតុនេះទើបក្បាលទាំង៥ (តំណាងបញ្ចខន្ធ) មានកម្លាំងអាចត្រួតសង្កត់នៅលើក្បាល៧បាន ដោយក្បាល៧នេះតំណាងឲ្យមួយសប្ដាហ៍។ ដូច្នេះពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ ត្រូវបញ្ចខន្ធសង្កត់ជាប់ ពុំអាចរើខ្លួនរួចឡើយ ហើយខន្ធនោះ ត្រូវជាប់ក្នុងឃុំ (អបាយភូមិ) នោះដែរ ព្រោះបុថុជ្ជនគ្រប់រូបដែលគ្មានសីលកម្រនឹងរួចពីអបាយភូមិបានណាស់។ នៅពីខាងលើក្បាលនាគ សង្ខាងក្បាលនាគ មានពលសេនាយក្សជាច្រើននៅយាមការពារទាំងខាងក្រោមពីចំហៀងទាំងសង្ខាង ទាំងខាងលើ មិនឲ្យព្រះម៉ែនាគ (បិសាចពស់) រើខ្លួនចេញពីភក់ថ្មនេះរួចឡើយ (នេះជាអាថ៌កំបាំងភាសារូបក្នុងលានព្រះគម្លង់ទី១)។

១៤/.រូបភាពទី១៤រូបនាគក្បាល៥លើ៩(លានព្រះគម្លង់)



ក្នុងរូបភាពនេះ នាគមានក្បាល៥ នៅពីលើនាគក្បាល៩ ហើយក្បាលនាគទាំង១៤សុទ្ធតែសង្រួមងើយក្បាលទៅលើដូចគ្នា ព្រោះដូនតាខ្មែរគាត់កម្រឆ្លាក់នាគសង្រួមណាស់ នាគសង្រួមមានតែនាគពីរបែបប៉ុណ្ណោះ ទីមួយគឺនាគមានសីល ទីពីរគឺនាគដែលជាប់ឃុំឃាំង។ ក្បាលនាគដែលស្ថិតក្នុងទីលាននេះទាំងអស់ ងើយក្បាលទៅលើ ហើយរំពឹងគិតថា ពេលណាហ្ន៎ ទើបកូននាគគេមើលឃើញរួចដឹងរឿងខ្លួន បើជញ្ជាំងក្នុងទីឃុំនេះខ្ពស់ម្ល៉ឹងៗ តើអាត្មាអញស្រែកហៅកូនធ្វើម្ដេចឮ ទោះបីជាជញ្ជាំងឃុំនៅជាប់នឹងផ្លូវថ្នល់ក៏ដោយ ពួកគេក៏ពុំអាចមើលឃើញដែរ មានតែនៅស្ងៀមទ្រាំបង្ហូរទឹកភ្នែករងចាំ លុះដល់បាបកម្មឲ្យផលអស់ (ទំនួញប្រេត)។ ចំណែកឆ្មាំដែលយាមគាត់គឺមានបួនជាន់ ខាងក្រោម កណ្ដាល និងលើ បើយើងមើលសកម្មភាពអ្នកយាមទាំងនោះព្រះម៉ែមហានគរលោកពុំអាចលួចចេញមកខាងក្រៅបានទៀតឡើយ ព្រោះភាសារូបក្នុងទីនេះ បានប្រាប់យើងជាកូននាគសម័យខាងក្រោយថា បិសាចពស់ដែលចិនជីវតាក្វាន់និយាយនោះ មិនអាចចេញមកជួយចង្អុលផ្លូវប្រាប់ក្នុងការដឹកនាំនគរបានទៀតទេ តើគាត់ចេញមកម្ដេចរួច បើគាត់នៅសល់តែក្បាល ហើយអ្នកចាំយាមគាត់ច្រើនម្ល៉ឹងៗនោះ? ចម្លើយសូមកូននាគប្រុសស្រីមើលរឿងក្នុងរូបទីលាននេះ និងរូបទាំង១៣ដែលខ្ញុំបានពន្យល់រួចហើយនោះផង យើងនឹងយល់ច្បាស់ពីអាថ៌កំបាំងទោសរបស់គាត់ជាពុំខាន។

## ១៥/.រូបភាពទី១៥រូបនាគក្បាល៩ពីលើក្បាល៥ (ស្ពានកំពុងក្ដី)

អត្ថន័យរូបនេះ ខ្ញុំបានពន្យល់ក្នុងភាគមុន ខ្លះៗហើយ ខ្លាចក្រែងពុំសូវច្បាស់ ដូច្នេះខ្ញុំត្រូវបកស្រាយពន្យល់ បន្ថែមទៀត ដើម្បីឲ្យកាន់តែងាយយល់ ចំពោះភាសាគំនិត ដែលបានបង្កប់នៅក្នុងរូបនេះ។ ហេតុអ្វីបានជានាគ កំពុងក្ដីនេះ នាគក្បាល៩នៅពីលើ៥ទៅវិញ ខុសពីនាគក្នុងលានព្រះគម្លង់ អាថ៌កំបាំងប្រស្នារូបនេះ គាត់ចង់ប្រាប់យើងថា ស្ពានកំពុងក្ដីនេះ ស្ថិតនៅលើស្ទឹងជីក្រែង ខ្ញុំបានពន្យល់រួចហើយ ក្នុងភាគមុន ចំណែករូបនាគ លើស្ពាននេះ គ្មានកន្ទុយទេ គឺក្បាលនាគរួមខ្លួនតែមួយ (នាគព័ន្ធ)



សងខាង ហើយនៅក្រោម ក្បាលនាគពីរជាន់ ទាំងក្បាល១៤នេះ មាននៅសល់ស្នាមរូបស្ត្រីម្នាក់ ឈរទ្រពីខាងក្រោម តំណាងឲ្យនាគខាងលើ គឺព្រះម៉ែនាគ (មាតាមហានគរ)។ នាគក្បាល៩នេះ នៅលើទម្រផ្កាឈូក ដែលខ្ញុំបានពន្យល់រួចហើយ ពីន័យផ្កាឈូក តើក្បាល៩តំណាងអ្វី? ក្បាល៩ គឺតំណាងឲ្យលោកុត្តរធម៌ គឺមគ្គបួន ផលបួន និងនិព្វានមួយ ដែលធ្វើឲ្យផ្កាឈូក គឺបញ្ញានេះ អាចរីករួច ព្រោះអំណាចនៃគុណធម៌របស់ពួកគាត់ ទីបំផុតផ្កាឈូក ដែលជាទម្រដ៏ធំនេះ និងអាចរីករួចនៅចុងបញ្ចប់ ក្នុងរឿងអាថ៌កំបាំងនេះ។ ចំណែកឯក្បាល៥ តំណាងឲ្យបញ្ចក្ខន្ធ ដែលខន្ធនេះពុំអាចឡើងទៅសង្កត់លើ៩ បានទៀតឡើយ នៅពេលណាដែលវិបស្សនាកម្មដ្ឋាន កើតផុលផុសឡើង។ នេះជាប្រស្នាដែលក្បាលនាគកំពុងក្ដី និងក្បាលនាគលានព្រះគម្លង់ ស្ថិតក្នុងទិសបញ្ច្រាសគ្នានោះ បញ្ញាក្នុងទីទុក្ខពុំអាចមាន វិបស្សនាកើតឡើងឡើយ នេះជាក្រិតក្រមធម្មជាតិ។ នាគកំពុងក្ដី គឺចេញផុតពីទីឃុំហើយ លូនវាបន្តិចម្ដងៗ ចេញពីក្ដី ដែលមានដីក្រៃងនៅខាងក្រោមនោះ (ស្ទឹងដីក្រៃង) ជួយជ្រោងព្រះម៉ែនាគឲ្យឡើងមកខាងលើ រហូតបានរួចផុតពីអំណាចឃុំរបស់យក្ស (ពន្យល់រួចហើយក្នុងភាគមុន)។

## ១៦/.រូបភាពទី១៦រូបគ្រុឌចាប់ជាន់នាគ(នៅជញ្ជាំងខាងក្រោលានផល់ដំរី)



ក្នុងសកម្មភាពរូបនេះ បានបង្ហាញពីគ្រុឌមួយ ដែលមានមាឌធំ កំពុងតែឈរជ្រែងដៃចាប់កន្ទុយនាគសង្ខាង រីឯជើងខាងក្រោម ជាន់ត្រង់កខ្លួននាគបី ក្បាលមួយនៅកណ្ដាលក្បាលពីសង្ខាង ហាក់បីដូចជាខ្លាចនាគទាំងបីរើបម្រះរួចពីអំណាចខ្លួន។ ចំណែកនៅលើក្បាលនាគសង្ខាង ពីខាងក្រោយ មានក្បាលយក្សកំពុងខាំក្បាច់និមិត្តរូបខ្លួននាគ បើយើងមិនដឹង មើលទៅដូចជាក្បាច់សម្រាប់លម្អ តាមពិតនិមិត្តរូបយក្សដែលជាម្ចាស់ពៀរ ដែលកំពុងញ្ញេញធ្មេញខាំក្បាច់ដែលគ្របក្បាលនាគ។ សរុបសេចក្ដីមកអត្ថន័យក្នុងរូបទី១៦ ក៏មិនខុសពីរូបមុនៗដែលខ្ញុំបានពន្យល់រួចហើយ ព្រោះពួកគាត់ឆ្លាក់រូបភាពដដែលៗនេះ គាត់ភ័យខ្លាចកូននាគសម័យខាងក្រោយពុំចាប់អារម្មណ៍មើល រួចឆ្ងល់ហើយពិចារណាស្វែងយល់លើសិលាចារឹករូបរឿងសាវតាទាំងនោះ។

## ១៧/.រូបភាពទី១៧គ្រុឌនៅកែងខ្លោងទ្វារ (នៅជញ្ជាំងខាងក្រៅប្រាសាទបន្ទាយក្ដី



រូបគ្រុឌខ្លោងទ្វារនេះ អត្ថន័យរបស់វាក៏មិនខុសពីរូបមុនដែរ គ្រាន់តែរូបភាពក្បាលនាគនៅក្រោមជើងគ្រុឌយើងអាចមើលឃើញច្បាស់ជាង ហើយរូបខ្លោងទ្វារនេះបានបង្ហាញពីអ្នកកាន់កន្ទុយនាគ គឺស្ត្រីម្នាក់នៅចន្លោះក្បាលព្រហ្មខាងលើ តែខ្លោងទ្វារនេះ រូបនៅខាងលើមើលពុំសូវឃើញឡើយ ខ្ញុំនឹងយករូបភាព ខ្លោងទ្វារប្រាសាទតាព្រហ្មមកពន្យល់វិញ ព្រោះនៅមានរូបភាពច្បាស់ជាងគ្រាន់នឹងមើលឃើញអាចពន្យល់បកស្រាយបាន។

## ១៨/.រូបភាពទី១៨រូបខ្លោងទ្វារប្រាសាទ (តាព្រហ្មមើលពីចំហៀង)



រូបខ្លោងទ្វារប្រាសាទតាព្រហ្មនេះ គ្រុឌនៅខាងជ្រុងទ្វារ កំពុងជាន់ខ្លួននាគទាំងបី នៅខាងក្រោមជើងនោះ គឺនៅសល់តែដៃគ្រុឌតែប៉ុណ្ណោះ រីឯខ្លួនគ្រុឌបានបំផ្លាញស្លាកស្នាម អស់ហើយ តែក៏យើងអាចនៅមើលយល់បានដែរ ដោយយើងយករូបនេះ ទៅប្រៀបធៀប និងខ្លោងទ្វារបន្ទាយក្ដី ឬបន្ទាយឆ្មារ និងប្រាសាទដ៏ទៃៗទៀត ដែលនៅសល់អាចមើលយល់បាន។

តើក្បាលនាគ ដែលគ្រុឌកំពុងជាន់នោះកន្ទុយទីណានៅឯណា? បើយើងក្រឡេកមើលទៅលើ ចន្លោះត្រចៀកព្រហ្មទាំងសង្ខាងនៃរូបនេះ យើងនឹង

ឃើញរូបស្ត្រីម្នាក់ឈរ ដែលក្បាលមានពាក់ក្បាំងដូចអប្សរា ដៃទាំងពីរកាន់កន្ទុយនាគ យើងមើលឃើញតែទ្រនុងខ្នងនាគ ទម្លាក់ខ្លួនចុះមកក្រោម រីឯក្បាលនាគ គឺនៅក្រោមជើងត្រុឌខាងក្រោម។ អត្ថន័យទាំងនេះ ខ្ញុំបានពន្យល់តាំងពីរូបភាពទីមួយមកម្ល៉េះ គឺព្រះម៉ែមហានគរលោកទៅដល់កំពូលព្រហ្មទៅហើយ ទីបំផុតគាត់ទម្លាក់ក្បាលចុះមកក្រោម ព្រោះហេតុតែធ្វើជាព្រហ្មឲ្យកូនប្រុសស្រី (វិហារធម៌) សុខចិត្តឲ្យត្រុឌជាន់ខ្លួនកប់ក្នុងភក់ តាំងពីភក់នៅទន់ រហូតដល់ភក់រឹងក្លាយជាថ្ម (ថ្មភក់)។

ហេតុនេះហើយបានជាសម័យក្រោយស្ថាបត្យកម្ម សំណង់ប្រាសាទ ព្រះវិហារ រាជវាំង....តែងតែធ្វើបន្តគ្នានូវក្បាលនាគរមក្បាំងក្លែង ហោជាង ដំបូល ធ្វើនាគសំយ៉ុងក្បាលចុះមកក្រោម ដោយពុំបានដឹងថា ហេតុអ្វីនាគទៅដល់កំពូលលើទៅហើយ បែរជាលូនវាចុះមកក្រោមវិញ នេះជាប្រស្នាព្រះម៉ែមហានគរ ដែលបានទុកកេរឲ្យយើងជាអ្នកស្រាយនៅប្រស្នារាប់ពាន់ឆ្នាំនេះ។

ចំណែកនៅ**ក**ព្រហ្មខាងក្រោម ខ្ញុំបានពន្យល់ន័យខ្លះហើយ ក្នុងភាគមុន ពេលនេះខ្ញុំគ្រាន់លើកយកចំណុចខ្វះខាតខ្លះ មកពន្យល់បន្ថែមតែប៉ុណ្ណោះ នៅកព្រហ្មមានស្ត្រីអង្គុយ១២នាក់ តំណាងឲ្យមាតាទាំង១២ បន្ទាប់មកមានដំបូលរាងចង្អូរដូចប្រ៊ីប្រូ តែតាមពិតពុំមែនប្រ៊ីប្រូដូចសព្វថ្ងៃឡើយ គឺជាតួខ្លួននាគដែលបានពាក់ជាន់ៗគ្នាក្លាយជាដំបូលបញ្ឆោតមួយ តែសម័យក្រោយដំបូលនេះ បានក្លាយជាគ្រឿងស្រកានាគ (ពន្យល់រួចហើយក្នុងភាគមុន)។ ស្ត្រីទាំង១២ មានភារកិច្ច ថែរក្សាព្រហ្ម គឺមាតុភូមិនេះ ប៉ុន្តែមាតាទាំង១២មានតែ៧នាក់ទេ ដែលថែព្រហ្មម៉ែឪរាល់ឆ្នាំ ហើយ៧នាក់នេះប្រចាំគ្នាទៀត ដល់វេនអ្នកណា អ្នកហ្នឹងទៅហែទៅ ចំណែកអ្នកឯទៀតរវល់ចិញ្ចឹមក្រុមគ្រួសាររបស់ខ្លួន ព្រោះបេះដូងពួកគាត់ខែថ្ងៃស៊ីអស់ហើយ (អាថិកំបាំងដូងខែស៊ី) តើមាតាបិតាមហានគរសង្ឃឹមអ្វី បើបេះដូងកូនគាត់ ខែស៊ីអស់ទៅហើយនោះ? នេះជាប្រស្នាថ្មបានរៀបរាប់ប្រាប់ពីទុក្ខសោកវេទនា នឹងភាពអស់សង្ឃឹមរបស់គាត់ មកលើកូននាគប្រុសស្រីជំនាន់ខាងក្រោយ ដែលគាត់ពុំអាចចេញពីទីឃុំឃាំងរួច មានតែដេករងចាំបាបកម្មចាស់ឲ្យផលអស់តែប៉ុណ្ណោះ។

សរុបសេចក្ដីមក អត្ថន័យរបស់រូបខ្លោងទ្វារប្រាសាទទាំងពីរនេះ គឺគំនិតរបស់ពួកគាត់ បានយកមកបង្កប់ទុកក្នុងថ្ម ដូចខ្ញុំបានពន្យល់ដោយសង្ខេបនេះ ពុំមែននិយាយពីរឿងព្រហ្មញ្ញសាសនានៅឥណ្ឌាឡើយ ព្រោះឥណ្ឌាពុំមានប្រាសាទមុខព្រហ្មទេ មុខព្រហ្មទាំងអស់ ដែលមាននៅលើទឹកដីខ្មែរពីអតីតកាល និងសល់គង់វង្សមកដល់បច្ចុប្បន្ន គឺតំណាងឲ្យព្រហ្មម៉ែព្រហ្មឪ និងព្រហ្មកូនដែលត្រូវមកជួយម៉ែឪ ឲ្យរួចផុតពីបាបកម្មចាស់តែប៉ុណ្ណោះ។

## ១៩/.រូបភាពទី១៩រូបយក្សជាន់ព្រះម៉ែ (មិនស្គាល់ប្រភព)



រូបភាពនេះ គាត់ឆ្លាក់រង្វង់ក្បាច់មួយវង់ ព័ទ្ធជុំវិញយក្សឈរលើកជើងឆ្វេង ដែលមានទំរ ជាផ្កាឈូក ដែលនៅខាងក្រោមជើងយក្សម្ខាងនោះ មានស្ត្រីបួននាក់ កំពុងលើកដៃសំពះដាក់បន្ទូលលើក្បាល ហាក់ដូចជាបួងសួងឲ្យអ្នកណាមួយមកជួយខ្លួន។ តើស្ត្រីទាំងបួននៅក្រោមជើងយក្សតំណាងអ្វី? ស្ត្រីទាំងបួននាក់ តំណាងឲ្យព្រះម៉ែមហានគរ ដែលគាត់ជាប់ក្នុងឃុំ សោទាំងបួនជាន់ (មើលការពន្យល់ ក្នុងរូបភាពទីមួយ) ឯគាត់លើកដៃបន្ទូលទៅលើ គឺគាត់អង្វរកូននាគប្រុសស្រី ឲ្យជួយគាត់ផង ព្រោះគាត់ទ្រនូវទម្ងន់ទុក្ខធ្ងន់ណាស់ (យក្សជាន់) ចំណែកផ្កាឈូក ដែលគាត់ដេកពីលើ តំណាងឲ្យការបំពេញបារមី របស់គាត់ ប្រាថ្នាឲ្យបានជាពុទ្ធមាតា ទៅអនាគតជាតិ។ ឯក្បាលស្ត្រីព្យួរក្រោមជើងយក្ស ដែលលើកបត់នោះ គឺតំណាងឲ្យមាតាទាំងប្រាំពីរ (ទេពធីតាទាំងប្រាំពីរ) ដែលមកហែក្បាលកបិលមហាព្រហ្មរាល់ៗឆ្នាំ តាមពិតមាតាទាំងអស់មានដល់ដប់ពីរនាក់ឯនុះ ហើយក្បាលទាំងនោះមានច្រវាក់ទាក់បន្តគ្នា មើលទៅហាក់បីដូចជាខ្សែលម្អ តាមពិតពួកគាត់ជាប់ទោសយក្ស ដូចព្រះម៉ែមហានគរដែរ។ ដៃយក្សទាំងអស់មានដប់ប្រាំមួយ គឺម្ខាងមានប្រាំបីៗ តែប្រាំបីនេះមាននៅសល់ម្ខាងប្រាំពីរទេ ឯដៃពីរទៀតកំពុងតែឱបកូនស្រីកជ្រី ដូច្នេះដៃដែលបែងសងខាងមានប្រាំពីរដៃ។ តើដៃប្រាំពីរតំណាងអ្វី? ដៃប្រាំបីតំណាងអ្វី? ដៃប្រាំពីរគឺតំណាងឲ្យមួយសប្តាហ៍រាល់ខែ និងឆ្នាំ ចំណែកដៃប្រាំបីតំណាងឲ្យទិសតូចបួន ទិសធំបួន គឺទិសទាំងប្រាំបី មានន័យថាគ្រប់ៗទិសតូចធំទាំងប្រាំបី រាល់សប្តាហ៍ (ប្រាំពីរថ្ងៃ) ថ្ងៃ

ណាក៏ព្រះម៉ែមហានគររួមទាំងម៉ែទាំងដប់ពីររបស់គាត់និងកូន ត្រូវនៅក្នុងការឃុំគ្រងរបស់យក្ស។ នៅលើដៃស្តាំទាំងប្រាំពីរមានក្មេងម្នាក់ទើបតែងើបរួចពីក្នុងពួច ឬក្រឡកំពុងដេកពោបចង់ងើបក្រោកអង្គុយដែរ តែពុំអាចងើបរួច ដូច្នេះបានត្រឹមតែដេកពោបនៅលើមាត់ពួចតែប៉ុណ្ណោះ។ ចំណែកឯដៃឆ្វេងទាំងប្រាំពីរវិញ ទើបក្មេងតូចនោះ អាចងើបអង្គុយលើមាត់ពួច ឬក្រឡបាន ដល់ដៃទីប្រាំពីរ គឺមានដៃរបស់កង្រីជាស្ត្រីកូនយក្សបានចាប់ក្មេងនោះ ក្នុងដៃលើកយកទៅដាក់លើក្បាល នាងសន្ធមារដែលជាមាតា។ ដូច្នេះហើយទើបសាច់រឿងព្រេងនាងទាំងដប់ពីរ ឬពុទ្ធិសែននាងកង្រីបានបញ្ជាក់ប្រាប់ថា ពុទ្ធិសែនបានរៀបការជាមួយនឹងនាងកង្រីហើយបានយកកែវភ្នែកម្តាយទាំងដប់មួយៗចំហៀង រួមទាំងថ្នាំទិព្វផងទៅដាក់បញ្ចូលឲ្យម្តាយវិញ ទើបម្តាយធំទាំងដប់មួយ រួមទាំងម្តាយបង្កើតខ្លួនផងមានកែវភ្នែកភ្លឺឡើងវិញ។ ដែលអាចមានកែវភ្នែកមើលឃើញ គឺបញ្ហានេះក៏ព្រោះតែមានការជួយឧបត្ថម្ភជ្រោមជ្រែង ពីសំណាក់នាងកង្រីជាកូនយក្សតែប៉ុណ្ណោះ ដូចក្នុងរូបភាពនេះបានបង្ហាញប្រាប់យើងស្រាប់ បើពុំដូច្នោះទេកូននាគនេះ ពុំអាចដឹងរឿងហើយឡើងទៅជាន់លើក្បាលយក្ស ឲ្យព្រមលែងម្តាយនៅខាងក្រោមបានឡើយ កង្រីជាកូនសោមួយ អាចបើកបំភ្លឺអាថ៌កំបាំងរបស់មាតាទាំងដប់ពីរបាន ពេលកែវភ្នែកមាតាទាំងដប់ពីរភ្លឺ នឹងដឹងរឿងរបស់ព្រះម៉ែមហានគរជាមិនខាន ព្រោះពួកគាត់ទាំងដប់ពីរជាកូនរបស់ព្រះម៉ែមហានគរ។ កូនណាបានរៀបការជាមួយកង្រី ទើបអាចមានដំណឹងយល់ដឹងពីកន្លែងលាក់កែវភ្នែករបស់ម៉ែទាំងដប់ពីរបាន ពេលណាដឹងរឿងម៉ែទាំងដប់ពីរ គេនឹងដឹងរឿងម្តាយឪពុកនាងទាំងដប់ពីរ ដែលបានយកកូនទៅបំបរបង់ចោលក្នុងព្រៃជាពុំខាន ព្រោះវាជាប្រាស្នាអាថ៌កំបាំងដែលបានលាក់កប់ទុករាប់ពាន់ឆ្នាំហើយ។ ឯគ្រុឌនៅលើក្បាលយក្សនោះ គឺតំណាងឲ្យសោជាន់ទីពីរដែលខ្ញុំបានពន្យល់ពីរូបភាពមុនៗរួចមកហើយ ឯរង្វង់ព័ទ្ធពីលើគឺជាផ្តុកឬអង្រុត (បក្សីចាំក្រុង) ដែលបិទបាំងលាក់រឿងរបស់គាត់មិនឲ្យកូននាគសម័យក្រោយយល់ដឹងបាន។

សរុបសេចក្តីមកការបកស្រាយពន្យល់ដោយសង្ខេបនេះ គឺបង្ហាញពីអត្ថន័យខ្លឹមសារពិត ដែលបានបង្កប់លាក់ទុកក្នុងរូបភាពចម្លាក់នេះ ពុំមែនជាព្រះសិវៈ ឬឥសូររាំជាន់កូនក្មេងដូចឯកសារបរទេសដែលបានបកពីអតីតកាលនោះទេ ព្រោះបរទេសពុំមែនជាខ្មែរ បេះដូងរបស់ពួកគេពុំមែនជាបេះដូងនាគឡើយ គឺមានតែយើងជាកូនខ្មែរនេះទេដែលមានបេះដូងនាគ ព្រោះយើងជាពូជពង្សព្រះនាងនាគ។

## ២០/.រូបភាពទី២០យក្សឈរជាន់ព្រះម៉ែមហានគរ(នៅសារមន្ទីរជាតិភ្នំពេញ)



រូបភាពចម្លាក់នេះ បង្ហាញពីយក្សក្បាល១០រួចដៃបែងភាគម្ខាង៨ ហើយនៅលើដៃទាំង១៦មានក្មេងតូចអង្គុយគ្រប់ រូបនេះនិងរូបនៅប្រាសាទបន្ទាយឆ្មារ ជញ្ជាំងខាងក្រោយ គឺមានន័យដូចគ្នា។ នៅខាងក្រោមជើងយក្ស មានស្ត្រីម្នាក់ពាក់ក្បាំងមកុដ ត្រូវយក្សជាន់ដល់**ក** ឯខាងក្រោមស្ត្រីគឺទំរង់ផ្កាឈូកដ៏ធំមួយ ហើយស្ត្រីពាក់ក្បាំងត្រូវក្រុងរាពណ៍ជាន់នោះ បានបែងភាគជាបួនជាន់ ដូចមុនដែរ គ្រាន់តែរូបនេះជាន់ៗជាប់គ្នា តើយក្សតំណាងអ្វី? ស្ត្រីនៅក្រោមជើងយក្សតំណាងអ្វី? ផ្កាឈូកតំណាងអ្វី?

**ក**/.យក្សតំណាងឲ្យម្ចាស់ពៀរ គឺឆ្នាំគុក អ្នកចាប់ព្រះម៉ែមហានគរ យកទៅឃុំ

**ខ**/.ដៃបែងភាគ៨ តំណាងឲ្យទិសតូច៤ធំ៤ ដែលនៅក្នុងទិសណាមួយ ក៏ស្ថិតនៅក្រោមអំណាចយក្សគ្រប់គ្រង។

**គ**/.ក្មេងដែលនៅលើដៃយក្ស តំណាងឲ្យកូនខ្មែរ (កូននាគ) ដែលសុខចិត្ត បំពេញគុណធម៌ គឺកតញ្ញូ កតវេទី ដើម្បីឡើងតតាំងជាមួយយក្សឲ្យព្រមចុះចាញ់ ដើម្បីដោះលែងព្រះម៉ែដែល ត្រូវយក្សជាន់រាប់ពាន់ឆ្នាំនោះ។

**ឃ**/.ស្ត្រីដែលនៅខាងក្រោមជើងយក្ស តំណាងឲ្យព្រះម៉ែមហានគរ ដែលបានប្រព្រឹត្តខុស ក្នុងឋានក្រុងរាពណ៍ (ព្រះបាទទសកណ្ឋ ឬទសមុខ)នេះ ត្រូវបានយក្សចាប់ជាន់ ពីត្រឹមកទៅដល់ខាងក្រោម (និមិត្តរូបនាគខ្មែរមានតែក្បាល) ហើយគាត់បានបែងភាគ៤ជាន់ ដើម្បីលួចឡើងមកជួបកូននាគ សម័យមុនជួយចង្អុលផ្លូវដឹកនាំនគរ ឲ្យបានរុងរឿង (បិសាចពស់) អាចទៅដល់កំពូលនៃអារ្យ

ធមិ។ តែក្រោយមក គាត់ពុំអាចចេញ ពីឃុំរួចទៀតឡើយ ព្រោះយក្សបាន ថែមសោចាក់គាត់កាន់តែច្រើន ធ្វើឲ្យកូននាគសម័យក្រោយ លែងដឹងពីអាថ៌កំបាំងមេនាគ ព្រមទាំងសត្វករវិកដ៏ច្រើន បំពេបំភ័ន្តស្មារតី ថែមពីលើទៀត ធ្វើឲ្យកូនខ្មែរ ឬកូននាគបានដើរបញ្ច្រាសសាសនព្រះម៉ែមហានគរ ដែល ជាមេនាគទីពីរ និងបញ្ច្រាសឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ដែលជាមេនាគទីបី (ពន្យល់ក្នុងមង្គលទី៣ ភាគមុន) នៅក្នុងទំនាយថ្ងៃសុក្រ ថ្ងៃសៅរ៍ ដូនតាយើងបានទុកប្រស្នាកំបាំងក្នុងវគ្គមួយថា៖

ឱះឱអាសូររាជសីហ៍សត្វ　　សព្វថ្ងៃជ្រកបាត់ក្នុងហេមពាន្ត
មិនឃើញអ្នកចេញមកទូន្មាន　　ឬរអាក់រអន់អៀនដំណើរអ្វី?
ឬមួយឃើញបឹងរីងហែងហួត　　ពិរុណរាំងស្ងួតវិនាសត្រី
ឬឃើញស្មាពីរលើឃ្នាងបី　　ទើបបានអ្នកថ្លៃមិនចេញមក
បាត់សូន្យយ៉ាងហ្នឹងដឹងយ៉ាងណា　　ឬចាំអាចារ្យទៅតាមរក
ឬមួយគ្មានម្លប់នឹងឈប់ជ្រក　　ទើបកែវពន្លកមិនមករអាយ។
ម្ដេចអ្នកមិនអាសូរសព្វសត្វ　　រង់ចាំពេកក្ដាត់លំបាកកាយ
សព្វថ្ងៃគ្មានសោះហៅសប្បាយ　　ព្រួយណាស់ហើយណាយឥតឧបមា។
ហៃជនទាំងឡាយចូរស្ដែងស្ដាប់　　អស់អាថ៌សារសព្វគ្រប់ប្រការ
ពីលោកអ្នកប្រាជ្ញចែងចរចា　　ចោទចងប្រស្នាដោយប្រាជ្ញប្រាណ។
ព្រោះដោយបានដឹងដំណឹងច្បាស់　　ប្រាកដជាក់ណាស់ទើបនិទាន
ឲ្យអស់អ្នកផងទើបបានហ៊ាន　　អ្នកអើយគ្រប់ប្រាណស្ដាប់ប្រស្នា។
នេះឯងឲ្យដឹងបានច្បាស់ជាក់　　បើដឹងហើយអ្នកកុំចរចា
រង់ចាំមើលទៅតាមសាសនា　　ធម្មតាសាសនាខ្មែរមិនសូន្យ។
វិស័យស្រមោលមិនចោលប្រាណ　　ស្រីង្គារក្នុងឋានមិនបង់ខ្លួន

រីឯដង្កៅមិនចោលក្បួន មាតានិងកូនមិនដែលបង់។
អ្នកអើយពុំហើយគួររំពឹង ទប់ចិត្តឲ្យនឹងទាត់ទៀងត្រង់
ណាៗអ្នកកុំចោលព្រះសង្ឃ ខ្ចីឃ្មាតតម្រង់កុំតាមគេ។
ត្បិតរាជ្យឥឡូវខុសសណ្ដាប់ ក្រពើលង់ស្លាប់ក្នុងទន្លេ
មច្ឆាខ្លាចបឹងអ្នកដឹងទេ កូនខ្លាខ្លាចមេភេខ្លាចត្រី។
អន្លង់ខ្លាចភក់កុកព្រីបឹង ស្វាក្រេះក្រញឹងចេះស្រដី
ឈើធំមួយដើមបង្អោងបី ទិវាប្រុសស្រី**ស្រឡាញ់ប្រេត**។
សំបកឃ្លោកលិចក្នុងទឹកស្រែ អំបែងបែកប្រែជាអណ្ដែត
នេះហើយហៅកើតកោលាភេទ ផ្គរលាន់ខែចេត្រភ្លៀងលិចស្រុក។
លិចស្រែចំការច្បារដំណាំ លិចព្រៃកទាំងប្រាំត្រពាំងថ្លុក
ទើបត្រីទាំងឡាយសប្បាយសុខ ស្បើយទុក្ខរីកមុខដោយសារភ្លៀង។
ភ្លើងភ្លឺបំផ្លុងកណ្ដាលព្រៃ រោលរាលដល់ន័យស្រីមានរាង
សំពត់ពេញដីស្រីមិនលាង ព្រោះឃើញទឹកភ្លៀងពីលើភ្នំ។
សេចក្ដីចំណោទអស់នេះណា ថែងតាមប្រាជ្ញាគិតផ្សំផ្សំ
លើកតាមហេតុភេទបុរីរម្យ កើតខុសក្រិតក្រមទំនៀមខ្មែរ។
ជំពូកមួយទៀតខ្ញុំគិតថា ចង់ដឹងប្រាជ្ញាអ្នកស្រុកស្រែ
ក្រែងមានលោកណាប្រាជ្ញពូកែ អាចកត់បកប្រែស្រាយដឹងទៅ។

អាថ៌កំបាំងកំណាព្យប្រស្នានេះ មកទល់នឹងសព្វថ្ងៃ មិនទាន់ឃើញអ្នកប្រាជ្ញណាមួយ អាចស្រាយបំភ្លឺពន្យល់បាននៅឡើយ ត្បិតយើងមើលឃើញរាក់ ក៏ប៉ុន្តែមានន័យជ្រៅ ព្រោះវាសុទ្ធតែ

កើតចេញពីគតិបណ្ឌិតកូននាគសម័យមុន ដែលលោកមានចក្ខុវិស័យ អាចយល់ដល់សន្ដានចិត្ត មនុស្សសម័យក្រោយ នៅការវិវឌ្ឍន៍ផ្ទត់គំនិតចរិយាមារយាទ គុណធម៌ និងផ្លូវចិត្តខាងក្នុង។

**ង**/.ផ្កាឈូកតំណាងឲ្យបញ្ញាក្នុងព្រះពុទ្ធសាសនា តទៅអនាគតខាងមុខរបស់គាត់ (ពន្យល់រួចហើយ)។ សរុបសេចក្ដីមកអត្ថន័យភាសាគំនិតក្នុងរូបនេះ ក៏មិនខុសពីអត្ថន័យក្នុងរូបមុនដែរ គ្រាន់តែពួកគាត់បានឆ្លាក់រូបមុនព្រះម៉ែមហានគរ ត្រួតៗគ្នាបួននាក់ ឯក្នុងរូបនេះ គាត់បែងភាគក្នុងរូបមួយទៅជាបួន ព្រោះគាត់ខ្លាចយើងមើលរូបនេះពុំយល់ គាត់ឲ្យទៅមើលក្នុងរូបមុនដោយវាងាយស្រួលមើលជាង។

## ២១/.រូបភាពទី២១រូបក្មេងស្រី(ជនជាតិមន)



រូបភាពនេះ បង្ហាញពីក្មេងស្រីជនជាតិភាគតិចមន ដែលមានពាក់កងដក "ក" ឲ្យវែង ហេតុអ្វីក៏ខ្ញុំត្រូវយករូបនេះមកពន្យល់? តើវាមានទាក់ទងអ្វី ទៅ នឹងអាថ៌កំបាំងមាតាមហានគរ? ពាក្យថាជនជាតិមន ឬខ្មែរមន គឺជាអំបូរជនជាតិមួយរួមគ្នាពីអតីតកាល តើពាក្យមនមានន័យដូចម្ដេច? មន = មនៈ ឬមនសិការ ⇨ ការធ្វើទុកក្នុងចិត្ត ការកំណត់ទុកក្នុងចិត្ត ដំណើរយកចិត្តទុកដាក់ (វចនានុក្រមសម្ដេចព្រះសង្ឃរាជ**ជួន ណាត**)។

ក្នុងរូបភាពទី៥ និងទី៦ ដែលខ្ញុំបានពន្យល់រួចហើយ ពីមាតាបានត្រូវយក្សដាក់ទណ្ឌកម្ម កប់ត្រឹមក ឬយក្សលេបទៅដល់ "ក" ដូច្នេះស្ត្រីមន ដែលជាកូនគាត់ពីអតីតដែរនោះ ត្រូវទទួលរងនូវបាបនេះ ដូចរូបគាត់ដែរ ដើម្បីបំពេញកិច្ច ជាកូនកត្តញ្ញូកតវេទី ស្ត្រីមនត្រូវពាក់កងដកកឲ្យវែង ដើម្បីតំណាងឲ្យមាតាអាច

ដក៏ក៏បានវែង មើលមកមាតុភូមិខ្លួនឃើញ។ ជាតិជាស្ត្រីរាល់រូប មិនថាជាតិណាៗឡើយ តែង ស្រឡាញ់រូបសម្រស់របស់ខ្លួន តែអនិច្ចាអ្វី តែជនជាតិនេះ ត្រូវពំនៀរកម្មពីអតីត ត្រូវពាក់កងដកកឲ្យ វែងដូចជាកកុកយ៉ាងនេះ? នេះជាហេតុប្រស្នាអាថ៌កំបាំងមួយរបស់ស្ត្រីជនជាតិភាគតិចនេះ ដែល បានបំពេញពលិកម្មបន្តគ្នា រាប់ជំនាន់មកហើយ ទោះបីមកទល់សព្វថ្ងៃ ក៏ត្រូវតែពាក់កងដកក ដើម្បី បំពេញកិច្ចជាកូនកតញ្ញូកតវេទី ហើយអត្ថន័យជាតិមននេះ មកពីពាក្យមនសិការនេះឯង។ ចំណែក ឯយើងវិញ ក៏មានពាក្យមននេះដែរ គឺអ្វី? ឈ្មោះតំណាងឲ្យរុក្ខជាតិមួយបែបគឺ ដើមមន តើដើមមន សម្រាប់ធ្វើអ្វី? ស្លឹកមនគេសម្រាប់យកមកឲ្យដង្កូវនាងស៊ី ដង្កូវនាងបង្កើតសំបុកៗគេស្រាវយកមកធ្វើ សសៃសរសូត្រ សូត្រគេត្បាញគោមហូល តំណាងឲ្យស្រកានាគ (ពស់) ហូលស្ត្រីខ្មែរស្លៀកដណ្ដប់ទូទាំង ប្រទេស ដូចនេះមាតានាគនៅព័ទ្ធថែរក្សា មាតុភូមិរបស់គាត់រាល់ថ្ងៃ តើស្ត្រីស្លៀកពាក់ហូល មានដឹង អាថ៌កំបាំងនេះទេ? រីឯដង្កូវនាងខំធ្វើសំបុក ដើម្បីឲ្យគេហូតយកសសៃសូត្រនោះ បានត្រឹមតែធ្វើ ពលិកម្ម គឺត្រូវដេកស្ងោរក្នុងទឹកក្ដៅតែប៉ុណ្ណោះ នេះគឺជាបាបកម្មរបស់គាត់ (និមិត្តរូបមាតានាគ)។ នេះជាប្រស្នាពាក្យ ដង្កូវនាង (នាងនាគ) ពាក្យថាមន (ដើមមន) និងពាក្យសម្គាល់ជនជាតិមន (មន សិការ) ដែលជាអំបូររួមជាតិគ្នាពីអតីត ព្រោះពាក្យមននៅក្នុងប្រវត្តិសាស្ត្រខ្មែរ អ្នកប្រាជ្ញជំនាន់មុន បានពន្យល់ផ្សេង តែខ្ញុំពុំយល់ដូចពួកគាត់ឡើយ ព្រោះទំនៀមទម្លាប់របស់ជនជាតិនេះ ពាក់កងដកក វាទាក់ទង និងអាថ៌កំបាំងព្រះមាតាមហានគរ ដែលខ្ញុំបានបកស្រាយពន្យល់ដោយសង្ខេបខាងលើ ព្រោះពួកគេសុខចិត្ត លះបង់សោភ័ណភាពរបស់ខ្លួនមួយជីវិត ដើម្បីកេរដំណែលដូនតា គឺបំពេញ កតញ្ញូកតវេទី។

# ២២/.រូបភាពទី២២រូបព្រហ្មត្រូវគ្រុឌចងតៀង(នៅប្រាសាទបាយ័ន)



មុខព្រហ្មនេះ ខ្ញុំបានពន្យល់ក្នុងភាគមុនរួចហើយ ដែលខ្ញុំយកមកពន្យល់ក្នុងភាគទីបី គ្រាន់តែចង់ឲ្យមិត្តអ្នកអាន ដែលជាកូននាគប្រៀបធៀបរូប ដោយខ្ញុំបានពន្យល់រួចហើយ។ យើងដឹងហើយថា ព្រហ្មជាសត្វបដិសន្ធិនៅក្នុងរូបព្រហ្ម ដោយអំណាចរូបាវចរឈាន (បឋមឈាន.... ចតុត្ថជ្ឈាន) ហើយព្រហ្មនេះទៀតសោត គឺគ្មានភេទទេ (មិនមែនប្រុសមិនមែនស្រី) សោយអាហារគឺបីតិ (ក្នុងគម្ពីរពុទ្ធសាសនា) តែយើងឆ្ងល់ហើយសួរខ្លួនឯងថា ហេតុអ្វីព្រហ្មខ្មែរមានតែក្បាល ហើយនៅលើក្បាលព្រហ្មនោះ មានសត្វគ្រុឌ ដែលជាសត្វតិរិច្ឆាន ឈរជើងត្របែង (តៀង) ស្រាក់ដៃគ្នានៅជុំវិញសង្កត់ពីលើព្រហ្មទៅវិញ? នេះជាប្រស្នាកំបាំងបង្កប់ក្នុងរូប ដែលខ្ញុំបានពន្យល់រួចហើយ នៅរូបភាពទី១៧ ១៨ និយាយពីខ្លោងទ្វារប្រាសាទបន្ទាយក្ដី និងប្រាសាទតាព្រហ្ម។ ដូចនេះ មាតាមហានគរ លោកចង់ពន្យល់បង្ហាញប្រាប់យើង ជាកូននាគប្រុសស្រី ឲ្យបានយល់ថា ទោះបីជាមាតាបិតាមហានគរ លោកចម្រើនសមាធិភាវនាបាននូវផលសមាបត្តិ ជាលោកិយយ៉ាងណាក្ដី ក៏ចិត្តរបស់ពួកគាត់នៅជាបុថុជ្ជន (មិនមែនព្រះអរិយ)។ ព្រោះលោភមូលចិត្ត៨ដួង គឺនៅពេញដដែល ធ្វើឲ្យពួកគាត់ត្រូវសំយ៉ុងចិត្តចុះទៅរកអកុសល ជាដាច់ខាត នេះជាហេតុធ្វើឲ្យពួកគាត់ជាប់ក្នុងទោស ព្រោះការប្រកាន់មាំ ថាខ្លួនជាព្រះមេ ជាព្រះម៉ែ ជាប្រមុខ ជាម្ចាស់នគរ (ប្រកាន់មាំក្នុងឧបាទានក្ខន្ធ៥)។

## ២៣/.រូបភាពទី២៣រូបព្រហ្ម(នៅបាយ័ន)



មុខព្រហ្មនេះ ក៏ស្ថិតក្នុងប្រាសាទបាយ័នដែរ នៅជ្រុងប្រសព្វត្រចៀកព្រហ្ម មានរូបឥសីពាក់កណ្តាលខ្លួនមួយ គឺតំណាងឲ្យបិតាមហានគរ ដែលខ្ញុំបានពន្យល់ក្នុងរូបទី១២ រួចហើយ។ ចំណែក នៅជាប់ត្រចៀកព្រហ្ម មានរាង ជាក្បាច់កន្ទុយហង្ស គឺតំណាងឲ្យ ទ្រនុងខ្នងនាគ ដែលខ្ញុំបាន បកស្រាយពន្យល់រួចហើយ ក្នុងរូបទី១២ រីឯនៅកព្រហ្មមានក្រយៅវង្វង់ បន្តគ្នាគ្រប់ៗកព្រហ្មនោះ គឺតំណាងឲ្យទោសរបស់ពួកគាត់ត្រូវយក្សលេបមកដល់ត្រឹមក (ពន្យល់ហើយក្នុងរូបទីមួយ)។ ហេតុដូចនេះ មាតាបិតា និងកូនគាត់ គ្រប់ជំនាន់មកខាងក្រោយ ត្រូវទទួលទោសពីយក្សមិនឲ្យងូតទឹក ជាងពីពាន់ឆ្នាំហើយ គាត់ខ្លាចក្រែងយើងមើលអាថ៌កំបាំងនេះពុំយល់ ទើបគាត់បានឲ្យកូននាគទី៧ (ជ័យវរ្ម័នទី៧) កសាងលានព្រះគម្លង់ទុក ព្រោះរឿងរ៉ាវចុងក្រោយក្នុងទីលាននេះ គេបានឆ្លាក់មនុស្សប្រុសស្រី អេះរមាស់ ដែលមិនបានងូតទឹករាប់ពាន់ឆ្នាំកន្លងមកនោះ ស្នាមអេះបានមុតចូលជ្រៅៗ ទៅក្នុងដងខ្លួនមនុស្សក្នុងចម្លាក់ថ្ម ដូចជាស្នាមក្រចកអេះយ៉ាងដូច្នោះ។ នៅគ្រប់ថ្ពាសព្រហ្ម គឺមានភ្នែកមួយចំកណ្តាល គាត់ចង់ប្រាប់កូននាគជំនាន់ក្រោយថា ត្រូវមើលរឿងគាត់ក្នុងថ្ពាស មានន័យថាចេះត្រិះរិះគិតពិចារណា (កុំមើលតែនឹងភ្នែក គឺត្រូវមើលនឹងថ្ពាស) ទើបដឹងរឿងរបស់ពួកគាត់។

សរុបសេចក្តីមកហេតុផលភាសារូប ដែលខ្ញុំបានបកស្រាយពន្យល់ដោយសង្ខេបនេះ ដូចជាការពន្យល់រៀបរាប់ខាងលើ ព្រោះជារឿងរបស់ព្រហ្មម៉ែព្រហ្មឪ គាត់ពុំបាននិយាយរឿងព្រហ្មញ្ញសាសនាឡើយ គឺពួកគាត់និយាយតែពីរឿងក្នុងចិត្តព្រហ្ម។

# ២៤/.រូបភាពទី២៤រូបមុខព្រហ្ម (ប្រាសាទបន្ទាយឆ្មារ)



ប្រាសាទនេះ ស្តេចជ័យវរ្ម័នទី៧ លោកកសាងឡើង ដើម្បីឧទ្ទិសឲ្យកូនរបស់គាត់ ពាក្យថាកសាងឡើង ដើម្បីឧទ្ទិសឲ្យកូនរបស់ គឺមានន័យថា កូនខ្មែរគ្រប់ជំនាន់គ្រប់កាល គ្រប់សម័យខាងក្រោយ បើចង់ដឹងរឿងពិតរបស់ខ្លួន ត្រូវទៅមើលភាសារូប ក្នុងប្រាសាទនេះ នោះនឹងអាចដឹងអាថ៌កំបាំងខ្លួន ជាកូនពុំខានឡើយ។ រូបភាពមុខព្រហ្មនេះ គឺជាសំណល់ ដែលសល់ពីការបំផ្លាញ របស់ពួកជនទុច្ចរិត ព្រោះតែប្រាក់ គាត់សុខចិត្តខ្វេះបេះដូង យកទៅលក់ឲ្យជនបរទេស ទីបំផុតប្រាសាទដ៏ធំស្កឹមស្កៃមួយ ត្រូវបានបំផ្លាញស្ទើររាបដល់ដី បើកុំតែប្រាសាទនេះ រលំបាក់បែក ម្លេះសមទេសចរណ៍ ត្រូវយកប្រាក់ទៅចាយក្នុងទីនោះដ៏ច្រើន ដើម្បីទស្សនា និងធ្វើការសិក្សាស្វែងយល់។ មុខព្រហ្មនេះ ក៏មានមនុស្សអង្គុយនៅពីលើក្បាល វាខុសពីព្រហ្មនៅបាយ័ន ព្រោះព្រហ្មបាយ័នសត្វតិរច្ឆានឈរត្បៀងពីលើ (គ្រុឌនិមិត្តសញ្ញាសៀម) ចំណែកឯមុខព្រហ្មបន្ទាយឆ្មារវិញ (បន្ទាយតូច) គឺជាមនុស្សស្រីអង្គុយលើកដៃសំពះ ជុំវិញក្បាលព្រហ្ម មិនដឹងមានចំនួនប៉ុន្មាន ព្រោះបាក់បែកអស់។ នៅចន្លោះត្រចៀកព្រហ្ម ក៏មានរូបមនុស្សអង្គុយគ្រប់ជ្រុងទាំងបួនដែរ ប៉ុន្តែបានបាក់បែកអស់ ដោយរូបភាពនេះ បានបាត់បង់ភាពដើមអស់ទៅហើយ ខ្ញុំអ្នកស្រាវជ្រាវភាសាគំនិតបង្កប់ក្នុងរូប ពុំអាចបកស្រាយពន្យល់ពីអាថ៌កំបាំង របស់ពួកគាត់ក្នុងរូបថ្មទាំងនេះបានឡើយ ព្រោះភាសារូបស្ថិតក្នុងសកម្មភាពក្នុងថ្ម ពុំមែនយើងចេះតែបកស្រាយឲ្យខុសពីរឿងរ៉ាវក្នុងថ្មបានឡើយ។ ហេតុ

នេះ ទើបគាត់កសាងប្រាសាទថ្មទុករាប់ពាន់ ដើម្បីឲ្យកូននាគសម័យខាងក្រោយ មើលរួចត្រិះរិះពិចារណា ពីរឿងក្នុងប្រាសាទមួយ ទៅឆ្លុះបញ្ចាំងរឿងក្នុងប្រាសាទមួយទៀត ពីជំនាន់មួយ នឹងទៅជំនាន់មួយ។ ហើយពួកគាត់បានដឹងជាមុនថា នៅសម័យខាងក្រោយ ពួកបរទេសខាងក្រៅ រួមទាំងកូននាគដែលពុំយល់ ច្បាស់ជាបំផ្លាញរឿងខាងក្នុងប្រាសាទ ជាពុំខាន ពេលដែលគាត់នៅអាចលួចចេញពីគុកមកខាងក្រៅបាន គាត់បានប្រាប់កូននាគសម័យនោះ ឲ្យកសាងប្រាសាទ ឆ្លាក់រឿងរ៉ាវរបស់គាត់ទុកឲ្យបានច្រើនពាន់ប្រាសាទ ព្រោះបើគេបំផ្លាញមួយក៏នៅសល់មួយដែរ យ៉ាងហោចណាស់ ក៏អាចសល់រូបភាពខ្លះ ពេលដែលគាត់ដល់កាលវេលាបញ្ចប់នូវបាបកម្ម (ដល់កំណត់នៃទោស) ក៏គង់មានកូននាគណាមួយ គេមើលយល់អាថ៌កំបាំងក្នុងថ្មទាំងនេះ ហើយគេអាចជួយពួកគាត់ឲ្យរួចពីទោសបាន។

## ២៥/.រូបភាពទី២៥រូបយក្សបែងភាគមើលពីចំហៀងនិងចំពីមុខ(នៅប្រាសាទបន្ទាយឆ្មារ)



រូបភាពនៅលើជញ្ជាំងប្រាសាទនេះ គឺមានក្មេងតូចម្នាក់ កំពុងអង្គុយលើបាតដៃយក្ស ក្មេងតូចនេះហើយ ដែលតំណាងឲ្យឈ្មោះប្រាសាទបន្ទាយឆ្មារ ព្រោះពាក្យឆ្មារ = តូច ហេតុអ្វីបានជាក្មេងតូចនេះ អាចអង្គុយលើដៃយក្សបាន? ព្រោះក្មេងតូចនេះហើយ ដែលជាកូននាគ ត្រូវមកបំពេញនៅគុណធម៌រួចឡើងតាមដៃយក្សទាំង**១៦** ដែលចង្អុលទៅខាងលើ គាត់ត្រូវព្យាយាមឡើងទៅដាន់លើក្បាលយក្ស ដើម្បីឲ្យយក្សព្រមចុះចាញ់ រួចដោះលែងមាតាបិតាមហានគរ (ប្រស្នាកំបាំងក្នុងរូបនេះ ខ្ញុំបាន

*ពន្យល់រួចហើយក្នុងរូបទី១៩ និងទី២០) ចេញពីអំណាចឃុំរបស់ខ្លួន។ ហើយនៅជុំវិញសង្វាងយក្ស មានមនុស្សប្រុសស្រីលើកដៃហាក់បីដូចជាសំពះ* ***៦****នាក់ និងម្នាក់ទៀតលើកដៃទ្រវត្ថុម្យ៉ាង តើតំណាងឲ្យអ្វី? ដែលមនុស្សទាំង៦នាក់ លើកបាតដៃទាំងពីរផ្ទារឡើង គឺគាត់ចង់ឲ្យយើងមើលរឿងក្នុងបាតដៃ (មើលការពន្យល់ក្នុងរូបភាពទី១១) ហើយចំណែកឯមនុស្សម្នាក់ទៀតលើកដៃទ្រវត្ថុនោះ គឺតំណាងឲ្យការអង្វរចំពោះក្មេងតូចខាងលើ ជួយយកកែវភ្នែកមកឲ្យពួកខ្លួនវិញ ព្រោះពួកគាត់ទាំង៧នាក់នេះ តំណាងឲ្យទេពធីតា ដែលមកហែក្បាលម៉ែឪ (ព្រហ្ម) រាល់ៗឆ្នាំនោះ។ ចំណែកដៃម្ខាងទៀតរបស់យក្ស កាន់ផ្ទូ ឬពួច (មើលរូបចំពីមុខ) អត្ថន័យក៏ខ្ញុំបានពន្យល់រួចហើយក្នុងរូបទី១៩ និង២០ ឯរូបទាំង៧ នៅខាងឆ្វេងដៃយក្សនេះ អត្ថន័យរូបក៏មិខុសពីរូបនៅខាងស្ដាំដៃយក្សដែរ គ្រាន់តែរូបខាងឆ្វេងអ្នកលើកដៃសំពះដាន់ខាងក្រោម ខុសពីខាងស្ដាំ គឺរូបខាងស្ដាំលើកដៃទ្ររបស់ម្យ៉ាង។ នៅពីក្រោមជើងយក្ស មានប្រអប់ក្បាក់មួយ ដែលប្រអប់នេះ ជានិមិត្តរូបទុកនូវកែវភ្នែក មាតាទាំង****១២**** ហើយប្រអប់នេះអាចយកបាន ទាល់តែយក្សនោះរលំ ឬព្រមចុះចាញ់។ នៅម្ខាងទៀតខ្លោងទ្វារ ក៏មានរូបយក្ស*



*ឈរបែងភាគដៃដូចគ្នា ប៉ុន្តែខុសត្រង់នៅសង្វាងយក្ស មានរូបម៉ែ និងឪ កំពុងជាប់ក្នុងរង្វង់សីមារបស់យក្ស ហើយរង្វង់សីមាដែលឃុំម៉ែ ឪនោះ កំពុងអណ្ដែតឡើងទៅលើម្ដងបន្តិចៗ ដោយអំណាចបារមី*

របស់ក្មេងតូច ដែលនៅលើបាតដៃយក្សនោះ គាត់បានបំពេញនូវគុណធម៌រែកម៉ែឪ ទៅដាក់លើកំពូលព្រះវិហារវិញ (មើលការពន្យល់ក្នុងភាគ២ភ្នំដងរែកក្នុងប្រាសាទព្រះវិហារ) ព្រោះក្មេងតូចនោះទីបំផុតនៃរឿងគាត់អាចតតាំងច្បាំងនឹងយក្ស រហូតដល់ឈ្នះ រួចជាន់យក្សឲ្យក្អែនៅរឿងទាំងអស់ដែលយក្សបានលេប (អាថ៌កំបាំងពាក្យកូនរាហ៍កន្លង) នោះ ឲ្យចេញមកខាងក្រៅវិញ។

សរុបសេចក្ដីមក រូបភាពនៅកំពែងប្រាសាទបន្ទាយឆ្មារ គឺបានបង្ហាញពីឈ្មោះរបស់ប្រាសាទនេះតែម្ដង រឿងក្នុងបន្ទាយដែលនៅសេសសល់នេះ បានរៀបរាប់ពីសកម្មភាព របស់ក្មេងតូចម្នាក់ដែលហ៊ានតតាំងនឹងយក្សជាម្ចាស់ពៀរ ដែលចាប់ព្រះមាតាបិតាយកឃុំពីអតីតកាលនោះ ឲ្យលោកមានសេរីភាពឡើងវិញ ដោយអំណាចគុណធម៌ គឺកតញ្ញូកតវេទី។

## ២៦/.រូបភាពទី២៦រូបយក្សដួលរលំជញ្ជាំងកំពែងខាងក្រៅ(ប្រាសាទបន្ទាយឆ្មារ)



រូបភាពនៅលើជញ្ជាំងកំពែង ខាងក្រៅប្រាសាទបន្ទាយឆ្មារ ជាបន្តនេះបានបង្ហាញពីសកម្មភាពមនុស្សប្រុសម្នាក់ជិះរទេះ ដៃម្ខាងកាន់ប្រអប់គ្រាប់ភ្នែកម្ដាយទាំង១២ ហើយបន្តមកទៀត គឺគាត់ទៅ

តតាំងច្បាំងនឹងយក្សធាក់យក្សឲ្យដួល ផ្ងារទៅក្រោយ នៅទីបំផុតយក្សនោះ ត្រូវរលំដេកដួលនៅលើដី។ នៅពេលដែលយក្សដេកពោបនៅលើដី យក្សបានក្អែចេញនូវព្រះគោព្រះកែវព្រមទាំងក្បួនគម្ពីរទាំងឡាយនៅលើរទេះ ដែលខ្លួនបានលេបពីអតីតកាលនោះឲ្យចេញមកក្រៅម្ដងមួយៗ ទីបំផុតកូននាគប្រុសស្រីតទៅថ្ងៃអនាគត លែងត្រូវរាហ៍កន្លងឬបិទបាំងពន្លឺរស្មីបញ្ញាទៀតហើយ គឺបានន័យថាឈប់នៅក្នុងអំណាចឃុំខាងក្នុងពោះយក្ស (កូនរាហ៍កន្លង)។

សរុបសេចក្ដីមក រូបភាពនៅកំពែងជញ្ជាំងប្រាសាទបន្ទាយឆ្មារ ដែលនៅសេសសល់នេះ បានបើកបង្ហាញ ពីអនាគតកាលរបស់កូននាគប្រុសស្រី កំពុងរស់នៅក្នុងមាតុភូមិនេះ ឲ្យបានដឹងពីសាវតាពិតរបស់ខ្លួន ដែលដួងកែវមាតាបានប្រតិស្ឋានទុកក្នុងថ្ម (សិលាចារឹក) ដែលពីមុនយើងតែងនាំគ្នាយល់ថា វាជារឿងរបស់សាសនា "**កុំជឿអ្វីដែលថាតគ្នា កុំជឿអ្វីដែលពុំទាន់បានពិចារណា មុននឹងជឿនៅលើអ្វីមួយ ត្រូវត្រះរិះពិចារណារាវរកហេតុផលសិនសឹមជឿ ព្រោះយើងជាបុត្រដែលកេតចេញពីមាត់របស់ព្រះសម្មាសម្ពុទ្ធជាមេនាគទីបី (ពន្យល់ហើយក្នុងភាគពីរ)**" ។

## ២៧/.រូបភាពទី២៧រូបក្នុងក្បាំងក្លែង(ប្រាសាទបន្ទាយសំរែ)



នៅក្នុងរូបភាពនេះបានបង្ហាញពីមនុស្សចំនួនបួនថ្នាក់ ហើយនៅក្នុងជាន់ថ្នាក់និមួយៗ មានសកម្មភាពរូបផ្សេងៗគ្នា ជាន់ក្រោមមានមនុស្សមួយជួរកំពុងតែលើកដៃសំពះ ជាន់ទីពីរមានក្រុមឥសី ជាន់ទីបីមានមនុស្សជាប់ក្នុងរង្វង់សីមា ជាន់ទីបួនមានរូបស្ត្រីលើកដៃសំពះមានរូបពាក់កណ្ដាលខ្លួន និងស្ត្រីទេពអប្សរកំពុងហោះ តើរូបក្នុងជាន់និមួយៗគាត់ចង់និយាយប្រាប់យើងពីរឿងហេតុអ្វី?

ក/.ជាន់ទីមួយ រូបស្ត្រីពាក់មកុដ នឹងលម្អដោយគ្រឿងអលង្ការផ្សេងៗ អង្គុយដង្ហែគ្នាកំពុងលើកដៃសំពះនោះ គឺតំណាងឲ្យមាតាទាំងដប់ពីរ ហើយដៃលកន្លងមកត្រូវម្ដាយនាងកង្រីឈ្មោះ សន្ធមារ (យក្ស) ខ្វេះយកកែវភ្នែកអស់ចំនួនដប់មួយកន្លះ (មើលរឿងព្រេង)។ ដូច្នេះធ្វើឲ្យពួកគាត់ ងងឹតមើលអ្វីមិនយល់រហូតទល់នឹងសព្វថ្ងៃនេះ ហើយក្នុងចំណោមកែវភ្នែកទាំងដប់មួយកន្លះ ដែលត្រូវយក្សសន្ធមារខ្វេះយកទៅនោះ សព្វថ្ងៃនៅសល់តែកែវភ្នែកមួយចំហៀងតែប៉ុណ្ណោះ ទើបក្នុងសកម្មភាពរូបនេះបានបង្ហាញថា ពួកគាត់កំពុងសំពះអង្វរឲ្យអ្នកណាមួយមកជួយយកកែវភ្នែកឲ្យពួកគាត់វិញព្រោះហេតុតែគ្មានកែវភ្នែក សូម្បីតែកូនខ្លួនឯងក៏ហែកចែកគ្នាបរិភោគដែរ (មើលការពន្យល់ក្នុងភាគពីរ ពីប្រាសាទនាងដប់ពីរ)។

ខ/. ជាន់ទីពីរ មានរូបឥសីប្រាំនាក់ កំពុងអង្គុយបត់ជើង ហើយនៅខាងក្រោយឥសីខាងស្ដាំមានមនុស្សឱនលើកដៃសំពះ និងមានសត្វរមាំង ឬក្ដាន់មួយកំពុងតែដេកពោបងាកក្បាលទៅក្រោយឯខាងឆ្វេងដៃឥសីខាងក្រោយក៏មានមនុស្សអង្គុយសំពះដែរ ហើយរូបដែលនៅក្រោយមនុស្សសំពះនោះយើងមើលពុំយល់ថាជារូបអ្វីឡើយ តើរូបទាំងអស់នេះ ព្រឹទ្ធដូនតាគាត់ចង់និយាយពីអ្វី?

ឥសីទាំងប្រាំនោះ គឺតំណាងឲ្យពូជឥសីកម្ពុ (ព្រះថោង ហ៊ុនទៀន កៅណ្ឌិន...) ដែលជាអ្នកបួសខាងក្រៅព្រះពុទ្ធសាសនា ដែលបានសម្រេចឈានសមាបត្តិតែជាមច្ឆាទិដ្ឋិ ព្រោះពុំមានមគ្គដែលប្រកបដោយអង្គប្រាំបីជាគោលគឺ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ។ ហើយពួកអ្នកបួសជាឥសីក្រៅពុទ្ធសាសនានេះមានស្ទើរគ្រប់ប្រទេស ខ្មែរ ចិន វៀតណាម សៀម...។ល។ និយាយរួមឲ្យតែពួកគ្រូចេះទស្សន៍ទាយជឿលើឫក្ស មង្គលភ្ជាក់ផ្អើល ដោយអាងលើក្បួនតម្រានោះ ព្រមទាំងមានទុកពុកមាត់ពុកចង្កាវែងៗ ពួកគេនោះគឺជាឥសីហើយពួកឥសីទាំងនោះ មានឫទ្ធិអភិញ្ញាទៅតាមកម្លាំងផលសមាបត្តិដែលខ្លួនចម្រើនបាន។ ចំណែកឯឥសីក្នុងរូបនេះបានបង្ហាញពីលក្ខណសម្បត្តិខុសៗគ្នាទៅតាមកំរិតនៃគុណធម៌របស់ពួកគាត់ដែលជាកូននាគ កំពុងអង្គុយរង់ចាំមាតាបិតាមហានគរ លោករួចពីបាបកម្មចាស់ ឯមនុស្ស

ដៃលអង្គុយលើកដៃសំពះ នៅខាងក្រោយឥសីទាំងសងខាងនោះ គឺពួកគាត់អង្វរលន់តួចំពោះឥសីទាំងនេះ ឲ្យជួយព្រះមាតាបិតាមហានគរ បានចេញរួចពីទុក្ខទោស ដៃលសល់ពីអតីតកាល។

**គ/.** រូបដាន់ទីបីនេះ អត្ថន័យរូបក៏មិនខុសពីរូបទី២៥ដៃលមាននៅលើជញ្ជាំងកំពែងប្រាសាទបន្ទាយឆ្មារ (ពន្យល់រួចហើយ) ព្រោះរូបនេះគេឆ្លាក់ពួកគាត់កំពុងជាប់ឃុំក្នុងរង្វង់សីមា ដៃលមានដៃកាន់ផ្កាឈូក ផ្កាឈូកតំណាងឲ្យនិមិត្តរូបបញ្ញាក្នុងពុទ្ធសាសនា (ពន្យល់ហើយ)។ ទោះបីជាពួកគាត់ឡើងដល់កំពូលក្បាំងខាងលើក៏ដោយ ក៏ពួកគាត់នៅតែជាប់ទោសដដៃល ព្រោះក្បាំងនាគដៃលនៅគ្របពួកគាត់ពីលើនាគទាំងពីរនោះគឺយក្សនៅលេបត្រឹមកដដៃល។

**ឃ/.** រូបដាន់ទីបួននេះ ស្ត្រីពីរនាក់ដៃលមានតែពាក់កណ្ដាលខ្លួនកំពុងលើកដៃប្រណម បួងសួងសូមឲ្យមាតាបិតាបានរួចពីទុក្ខទោស (ឲ្យយក្សព្រមដោះលែង) រីឯស្ត្រីកំពុងហោះហើរនោះវិញគឺជាទេវតាឬអច្ឆរាដៃលសកម្មភាពរូបហាក់ដូចជាលើកយកដុំអ្វីមួយដៃលកំពុង សង្កត់ពីលើសីមានោះចេញ ខ្ញុំពុំអាចមើលយល់បានឡើយ ព្រោះដុំទាំងនោះត្រូវបានបំផ្លាញ បាត់រូបភាពដើមអស់ហើយ។

សរុបសេចក្ដីមក រូបភាពដៃលខ្ញុំបានបកស្រាយក្នុងក្បាំងខ្លែងនេះអត្ថន័យក្នុងរូបក៏មិនខុសពីរូបមុនៗដៃលបានបកស្រាយរួចហើយនោះទេ ដៃលខ្ញុំលើកយកមកពន្យល់ ព្រោះចង់ឲ្យកូននាគចេះមើលប្រវត្តិរឿងនៅក្នុងថ្ម ទោះបីជាស្ថិតក្នុងសម័យកាលកសាងខុសគ្នា ក៏ប៉ុន្តែអត្ថន័យគំនិតបង្កប់ក្នុងរូប (ថ្ម) គឺនៅតែដដៃលៗទាំងរូបក្នុងប្រាសាទ ដៃលមាននៅក្នុងដៃនដីខ្មែរសព្វថ្ងៃ និងដៃនដីពីអតីតកាលដៃលគេបានដណ្ដើមយកទៅ សាច់រឿងគឺនិយាយពីពួកគាត់ជាប់ក្នុងទោស ពួកគាត់កំពុងរួចពីទោសនឹងនិយាយពីពួកគាត់មានសេរីភាពក្លាយជា ***អ្នកជា*** ដូចដើម (នេះគឺជារឿងបេះដូងរបស់មេនាគចារឹកបង្កប់ទុកក្នុងភាសាថ្ម)។

## ២៨/. រូបភាពទី២៨ រូបនៅក្នុងក្បាំងភ្លែង(ប្រាសាទបន្ទាយស្រី



នៅក្នុងសកម្មភាពដ៏រស់រវើកនៃផ្ទាំងចម្លាក់នេះ បានបើកបង្ហាញពីរឿងរបស់មាតាមហានគរ និងពួក ស្ត្រីដែលជាអ្នកទទួលមរតកព្រះមេជំនាន់ក្រោយ ដោយរូបភាពបានចែកចេញជាពីរជាន់ ហើយបែងជាបន្ទប់ៗ តើរូបទាំងនេះមានបង្កប់អត្ថន័យអ្វីខ្លះ?

១/. ជាន់ទីមួយខាងក្រោម បង្ហាញពីស្ត្រីទាំងឡាយបានទទួលរងនូវអំពើហឹង្សាដែលបុរសវាយធ្វើបាប ពេលដែលមនោគមវិជ្ជាថ្មីបានលុកលុយចូលទឹកដីព្រះមេ (កុងសង្កត់ម៉ា ឬកុងម៉ា) ក្រៅពីនគរនេះពុំសល់ទំនៀមទម្លាប់លើកស្ត្រីជាធំឡើយ (មេ)។ មានតែនគរនេះមួយគត់ដែលយើងហៅថា **មាតុភូមិ** គឺជាភូមិ ឬប្រទេសរបស់ព្រះមាតា ឬព្រះម៉ែ (មើលការពន្យល់ក្នុងភាគមួយនិងពីរ) ហើយសព្វថ្ងៃនេះប្រទេសមេ ឬ ម៉ែ (ក្មេរ, ខ្មែរ) នៅសល់តែឈ្មោះប៉ុណ្ណោះ។

សកម្មភាពស្ត្រីទាំងអស់ដែលមានក្នុងរូបត្រូវគេរុញបញ្ចូលទៅក្នុងបន្ទប់ គឺមានន័យថាស្ត្រីត្រូវនៅក្នុងផ្ទះគ្រប់គ្រងផ្ទះសម្បែងមិនអាចចេញទៅខាងក្រៅធ្វើជា **មេ** ទៀតបានឡើយ ដូច្នេះពាក្យ **មេ** ពីមុននៅសល់ត្រឹមតែឈ្មោះប៉ុណ្ណោះ ដោយហេតុព្រះមេដែលជាប្រមុខពីអតីតនោះត្រូវជាប់ឃុំ និងលុបដានស្នាមអស់ទៅហើយ (មើលក្នុងមង្គលបីភាគពីរ ឬមើលការពន្យល់រូបទីមួយនេះ)។

២/.ជាន់ទីពីរត្រង់រូបខ្លោងទ្វារកណ្ដាល បានបង្ហាញពីបុរសម្នាក់ពាក់ក្រវិលដូចរូបស្ត្រីគ្រប់លក្ខណ៍ដែលគាត់ជាអ្នកទទួលមរតកម៉ែ ព្រោះក្រវិលដែលគាត់បានពាក់គឺក្រវិលម៉ែ ដៃគាត់ម្ខាងកាន់ដំបងលើកឡើងបំរុងនឹងវាយ ដៃម្ខាងទៀតបួងសក់ស្ត្រីដែលដួលនោះ ឯជើងម្ខាងបុរសនោះជាន់ធាក់បានបង្ហាញឲ្យដឹងថាកូននាគសម័យខាងក្រោយអរិយធម៌ថ្មី លែងគោរពនិងទទួលស្គាល់មហិទ្ធិឫទ្ធិមាតាមហានគរទៀតហើយ (បិសាចពស់)។ ដោយសកម្មភាពរូបនេះបានបង្ហាញពីការធ្វើទារុណកម្មផង ជេរប្រមាថផង ដោយខ្លួនជាអ្នករស់ក្នុងភូមិម៉ែទទួលកេរពីម៉ែ ពុំបានតបស្នងនូវសេចក្ដីល្អដែលអ្នកមុនបានធ្វើចំពោះខ្លួន (ក្រធ្វើដឹង ក្រ+ពើ ពន្យល់រួចហើយក្នុងភាគមួយ)។ រូបខ្លោងទ្វារបន្ទប់នេះគឺធំជាងខ្លោងងសងខាង ដូចនេះរូបស្ត្រីកណ្ដាលគឺតំណាងឲ្យស្ត្រីដែលជាប្រមុខនៃពូជកេរមេ និងពូជកេរម៉ែ ហើយនៅខាងក្រោយរូបគាត់មានរូបស្ត្រីតូចៗ នោះតំណាងឲ្យភាពបាត់បង់សិទ្ធិរបស់ព្រះមេជំនាន់ក្រោយៗ ព្រោះមានបន្ទះរាងដូចជាខ្សែ បានបិទឃាំងស្ត្រីនៅខាងក្រោយ។ ចំណែកស្ត្រីដែលនៅក្នុងបន្ទប់សងខាង ជាន់ទីពីរក៏ត្រូវបានគេញាត់ទៅខាងក្នុងបន្ទប់ដូចរូបបន្ទប់កណ្ដាលដែរ គឺឈប់មានសិទ្ធិ ឬអំណាចដូចពីមុនព្រោះស្នាមជានរបស់ព្រះមាតា ត្រូវគេលុបជានសាជាននិងលក់ជានអស់ហើយ (មើលការពន្យល់ក្នុងមង្គលទាំងបី ភាគពីរ)។

សរុបសេចក្ដីមក សកម្មភាពរូបទាំងអស់ដែលមាននៅក្នុងក្បាំងក្លែង (បំប្លែង) នេះបានបង្ហាញពីការបាត់បង់ឥទ្ធិពលព្រះនាងនាគ ឬព្រះមាតានាគនៅលើមាតុភូមិរបស់ខ្លួន ដែលពីមុនខ្លួនជាប្រមុខឥឡូវត្រូវមនោគមវិជ្ជាថ្មីខាងក្រោយចូលមកលុកលុយបំផ្លាញពេលដែលមាតាលោកសុខចិត្តទៅទទួលទោសព្រោះហេតុតែកូននាគប្រុសស្រី។

## ២៩/. រូបភាពទី២៩ រូបនៅជញ្ជាំង(ប្រាសាទបាយ័ន្ត)



រូបភាពក្នុងចម្លាក់នេះ បានបង្ហាញពីបុរសម្នាក់ពាក់មកុដជាស្ដេចទ្រង់គ្រឿងអលង្ការកំពុងចាប់ពស់ ឬនាគ ដៃស្ដាំចាប់កាន់កន្ទុយនាគ ដៃឆ្វេងចាប់កាន់ខ្លួននាគ ជើងឆ្វេងជាន់កនាគ ដែលនាគនោះកំពុងលូននាំមុខចូលទៅក្នុងបន្ទប់ប្រាសាទដ៏ស្កឹមស្កៃមួយ តើអត្ថន័យរូបចម្លាក់នេះគាត់ចង់និយាយប្រាប់យើងពីអ្វី? ហើយបុរសនោះជានរណា? នាគឬពស់នោះជានរណា? ហើយទេវតានៅលើស្វេតច្ឆត្រតំណាងឲ្យអ្វី?

**ក**/.បុរសតំណាងឲ្យអ្នកទទួលមរតកព្រះម៉ែតំណាខាងក្រោយ គឺអ្នកដឹកនាំនគរព្រោះត្រចៀករបស់គាត់មានពាក់ក្រវិលដូចជាម៉ែដែរដែលគាត់បានទទួលខ្មែរ (កេរម៉ែ)។

**ខ**/.នាគ ឬពស់តំណាងឲ្យប្រមុខរបស់ស្ត្រីក្នុងនគរនេះពីអតីតកាល គឺព្រះនាងនាគ ក្នុងពិធីមង្គលការស្ត្រីធ្វើជាមេគេដឹកនាំគេ នាំមុខគេបានតែមួយភ្លែតតែប៉ុណ្ណោះ គ្រាន់តែចូលផុតមាត់ទ្វារបន្ទប់ភ្លាមត្រូវបុរសជាន់កបាត់ទៅហើយ ដូចមានអត្ថន័យក្នុងរូបភាពចម្លាក់នេះជាភស្តុតាងបង្ហាញស្រាប់។ ដោយនាគនាំគេចូលទៅក្នុងពិភពនាគ (ព្រះថោងតោងស្បៃព្រះនាងនាគ) គ្រាន់តែក្បាលលូនចូលក្នុងមាត់ទ្វារប្រាសាទភ្លាម ត្រូវព្រះថោងជាន់កជាប់ទៅហើយ មើលការពន្យល់ក្នុងអត្ថន័យរូបទី២៨។ បន្ទប់ដែលមានកំពូលប្រាសាទពីខាងលើទ្វារ គឺបង្ហាញពីភាពរុងរឿងរបស់ពូជព្រះនាង

នាគពីអតីតកាល តែភាពរុងរឿងទាំងនេះ ពុំបានស្ថិតក្នុងសន្តានកូននាគ សម័យខាងក្រោយឡើយ ដោយសារហេតុត្រូវគេលុបដាន សាដាន និងលក់ដាន មើលបទភ្លេងការពេលព្រះនាងនាគ ដឹកព្រះថោងចូលក្នុងបន្ទប់ អាចារ្យឲ្យអ្នកភ្លេងលេងបទទាំងនេះ (មានក្នុងមង្គលបឹ)។

**គ**/.ទេវតាដែលនៅលើស្វេតច្ឆត្រគឺតំណាងឲ្យនិមិត្តរូបសម្គាល់ឲ្យគណបក្សនយោបាយមួយ (គណបក្សប្រជាជន) ព្រោះគាត់បានដឹងថាក្នុងសម័យកាលខាងក្រោយនឹងមានរូបនិមិត្តសញ្ញានេះ គាត់ចង់ប្រាប់យើងជាកូននាគថា រឿងអាថ៌កំបាំងរបស់គាត់អាចដឹង អាចផ្សព្វផ្សាយមកខាងលើបានលុះត្រាតែមានរូបទេវតានៅខាងលើ (ពេលមាតាពុំអាចចេញពីឃុំរួច) ទើបកូននាគសម័យខាងក្រោយអង្គរ អាចដឹងពីទុក្ខសោកវេទនារបស់គាត់ក្នុងសមុទ្រទឹកដោះបាន។ ព្រោះពេលកើតឡើងនូវនិមិត្តសញ្ញាទេវតា តំណាងឲ្យ**គណបក្សប្រជាជន**នេះ ពេលនោះរូបកូរសមុទ្រទឹកដោះក៏កើត ឡើងព្រមគ្នា នេះជាសញ្ញាប្រាប់ពេលវេលាឲ្យកូននាគបានដឹងថា **សាសនព្រះម៉ែ** ជិតដល់ពេលរស់ និងអណ្ដែតមកស្ថិតក្នុងក្រសែដួងចិត្តរបស់កូននាគប្រុសស្រីឡើងវិញហើយ។ ដូចមានសម្អាងក្នុងចម្លាក់នេះជាដើម ពីមុនបរទេសបានពន្យល់ក្នុងគម្ពីរភាសារូបរបស់គេ ថាជារឿងរបស់សាសនាដោយគេបានលាក់បំពួនកុំឲ្យកូននាគយល់ដឹងពីភាសារូបពិត តែខ្ញុំពុំយល់ដូចជនបរទេសថា ឬសសេរឡើយ ខ្ញុំជាកូននាគដាច់ខាត់ត្រូវតែដឹងរឿងក្នុងបេះដូងរបស់ម៉ែនាគ និងនៅក្នុងក្បាំងនាគ ឬក្បាល របស់គាត់ ព្រោះខ្ញុំពុំជឿថាម៉ែឪរាល់រូបដែលខំរកស៊ីមួយជីវិត ដើម្បីប្រមូលទ្រព្យសម្បត្តិយកមកទុកឲ្យកូនហើយបែរជាទុកឲ្យអ្នកដទៃនោះ គឺវាពុំមែនជាហេតុត្រឹមត្រូវឡើយ។

សរុបសេចក្ដីមក រូបភាពនេះគាត់ចង់បើកបង្ហាញពីការបាត់បង់សិទ្ធិអំណាចរបស់ខ្លួនពីអតីតកាល ហើយរឿងរបស់គាត់ទាំងនោះលុះត្រាតែដល់បាបកម្មចាស់ឲ្យផលអស់ទើបអាចមានកូននាគណាមួយមកជួយស្រង់ ជួយលើកជួយរើកសាសនប្រស្នាគាត់មកផ្សព្វផ្សាយ ដើម្បីតវង្សត្រកូលនាគឲ្យរស់រវើកឡើងវិញក្នុងសន្តានចិត្តកូនខ្មែរ។

## ៣០/. រូបភាពទី៣០ស្ត្រីគ្រប់លក្ខណ៍ ឬលាក់(ជញ្ជាំងប្រាសាទបន្ទាយស្រី

រូបភាពនេះ បង្ហាញពីស្ត្រីម្នាក់ ឈរឱនមុខ ដៃឆ្វេងកាន់ផ្កាឈូកមួយទងសំយ៉ុងចុះ ដៃស្ដាំកាន់ផ្កាឈូកព័ទ្ធពីខាងក្រោយក សំយ៉ុងទងផ្កាចុះមកក្រោម បម្រុងនឹងរីក តែរីកពុំរួច ហើយរូបគាត់ឈរនៅលើទម្រ ដែលមានក្បាច់ត្របកឈូកបំបែក។ នៅពីខាងក្រោមទម្រដែលគាត់ឈរ មានសត្វករវិក

កំពុងត្រដាងស្លាបទ្វេ ចំណែកឯនៅពីខាងលើរូបគាត់ មានគំរបខ្លោងទ្វាររាងដូចក្បាំងក្លែង ដែលមាននិមិត្តរូបនាគសង្វាង គ្របឬក្រុងពីលើ។ ហើយនៅពីលើក្បាលគាត់ មានផ្កាឈូកដ៏ធំមួយសំយ៉ុងចុះក្រោម នៅពីលើក្បាច់ស៊ុមក្បាំងក្លែង មានរូបទេពតាហោះសង្វាង ហាក់បីដូចជាកំពុងចាប់បើកគម្របស៊ុមនេះឡើង។ ចំណែកនៅសង្វាងមានក្បាច់ចង្វាយអង្គរអមរូប ដែលក្បាច់ចង្វាយអង្គរទាំងនោះនៅដើមក្បាច់ មានរូបខ្លួនសត្វរាជសី ឬតោ ដៃឥតមានក្បាល ក្អែចេញជាក្បាច់ដុះបន្តគ្នា ទីបំផុត



ក្បាលរាជសី ឬតោ អាចកើតមានឡើង នៅចុងក្បាំងក្លែងខាងលើឯនោះ នេះជាប្រស្នាកំបាំងក្នុងរូប។ តើរូបទាំងអស់ ដែលខ្ញុំបានរៀបរាប់នេះ គាត់ចង់និយាយពីអ្វី ក្នុងរឿងរបស់គាត់?

យើងបានដឹងហើយថា ឈ្មោះប្រាសាទនេះ គឺបន្ទាយស្រី គឺមានន័យថា ជាទីតាំងលាក់ទុក នៅមរតករឿងរបស់ស្ត្រី តែក៏មិនដឹងថា ទុកនៅរបស់អ្វីឡើយ លុះត្រាតែយើងមើលរូបរួចត្រិះរិះពិចារណា ហើយពិចារណាទៀត ឆ្ងល់ហើយ ឆ្ងល់ទៀត ទីបំផុតយើងនឹងដឹងរឿងក្នុងបេះដូង ប្រាសាទបន្ទាយស្រីនេះជាពុំខាន។ ព្រោះឈ្មោះរបស់សត្វ បុគ្គល សម្ភារៈ ទីកន្លែង...អាចកើតឡើងបាន ក៏ត្រូវមានហេតុបច្ច័យគ្រប់គ្រាន់ ទើបនាមបញ្ញត្តិ ឬឈ្មោះនោះ អាចឧប្បត្តិកឡើងនឹងឋិតថេរគង់វង្ស រហូតមកដល់សព្វថ្ងៃនេះ។ ដូចជាយើង ចង់ដាក់ឈ្មោះឲ្យបុត្រា បុត្រី ឬសត្វចិញ្ចឹមទី១យើងត្រូវមើលពេលវេលាថ្ងៃខែឆ្នាំដែលកើត រួមផ្សំ នឹងពេលសុបិន្តឃើញគេមកចាប់កំណើតផងឪពុកម្ដាយត្រូវរិះរកឈ្មោះណាមួយ ដែលមានន័យស័ក្តិសមទៅតាមកម្លាំងថ្ងៃកំណើត (ចំពោះឪពុកម្ដាយដែលចេះដឹង)។ យ៉ាងណាមិញ ឈ្មោះសត្វ បុគ្គល ទីកន្លែង សម្ភារៈ.....ផ្សេងៗ ក្នុងសម័យមុន ក៏

ឈ្មោះទាំងនោះ ប្រកបទៅដោយអាថ៌កំបាំងន័យប្រស្នា ទៅតាមកំរិតបញ្ញារបស់អ្នកដាក់ ព្រោះឈ្មោះទាំងនេះ (នាម និងគោត្រ) មានអាយុកាលវែង លុះត្រាតែអស់ពូជនៃជនជាតិដើម ជាអ្នកកកើត ទើបឈ្មោះនេះរលុបបាត់ទៅតាមកាលវេលានោះ (ឧ.ខេត្តក្មែរពីអតីតនគរស្រីល្វោ សព្វថ្ងៃលពបូរី ក្រុងព្រៃនគរ សព្វថ្ងៃហូជីមិញ....)។

ស្ត្រីគ្រប់លក្ខណ៍ ឬគ្រប់លាក់ ⇒ ក្រាក់លុប ពាក្យក្រាក់ គឺជាគល់ឈើដែលចាស់ របកសំបកដោយខ្លួនឯង ហើយមានអាយុយូរ (គល់ក្រាក់) ដូចជាពាក្យថា បុកលក្តធ្វើធ្មេញ បន្សាបពិសនាគ តើអ្នកណាជានាគ? ពាក្យបុកល័ក្តម្យ៉ាងទៀត បើយើងសរសេរតាមសូរសព្ទនិយាយ បុកហើយលាក់ គឺមានន័យថា បុកឲ្យចុះទៅក្រោម រួចលាក់ទុកកុំឲ្យគេដឹង។ ស្ត្រីគ្រប់លក្ខណ៍ នៅក្នុងរូបនេះ គេឆ្លាក់ឲ្យគាត់ឈរនៅក្នុងស៊ុមទ្វារមួយដ៏ចង្អៀត មើលទៅហាក់បីដូចជាពុំមែននៅមាត់ទ្វារផ្ទះឡើយ ធម្មតាមាត់ទ្វារផ្ទះ ទោះបីជាតូចយ៉ាងណា ក៏ម្ចាស់ផ្ទះអាចចេញចូលដោយមិនចង្អៀតដែរ ដូច្នេះប្រស្នាក្នុងទីខ្លោងដ៏ចង្អៀតនេះ គាត់ទុកឲ្យយើងមើលរួចឆ្ងល់។ ហេតុអ្វីបានជារូបស្ត្រី សម័យមុនអង្គរ ឬសម័យអង្គរ គេឆ្លាក់រូបពួកគាត់លែងខ្លួនទទេខាងលើ មិនដូចជាជនជាតិឥណ្ឌា ចិន .....បរទេសដែលនៅជិតខាង? ក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរ អ្នកប្រាជ្ញសម័យមុន ក្មែរ និងបរទេស បានទាញពីកំណើតជនជាតិនេះ ថាមកពីឥណ្ឌា ឬបរទេសផ្សេងៗ ចុះហេតុអ្វីក៏រូបចម្លាក់យើង មិនឆ្លាក់ឲ្យមានសម្លៀកបំពាក់ដូចបរទេសទាំងនោះ? នេះជាហេតុដែលយើងត្រូវ រកអាថ៌កំបាំងឬសកែវ របស់ដូនតាយើងក្នុងនាមជាពូជអ្នកកសាងប្រាសាទថ្ម ថាតើគាត់បានលាក់អាថ៌កំបាំងរបស់គាត់នៅឯណា? ដូចជាស្ត្រីដែលគាត់ឆ្លាក់ភាគច្រើនពុំមានស្លៀកដណ្ដប់ល្វែងខាងលើ គាត់ចង់ប្រាប់យើងទាំងអស់គ្នាថា គាត់គឺជាប្រមុខនៃពូជកេរមេ (ក្នុងភាគ១) ហើយក្មេរនេះ ក្រោយមកបានក្លាយជាក្មែរ ដែលបានបន្សល់ទុកពាក្យមាតុភូមិមកដល់សព្វថ្ងៃ បើភូមិប្រទេសនេះ ជារបស់ម៉ែៗត្រូវតែបំបៅកូនបន្តគ្នា ទឹកដោះរបស់ពួកគាត់បានផ្សុំបន្តគ្នា រហូតក្លាយបានជាសមុទ្រ (សមុទ្រទឹកដោះ) ហេតុនេះ ទើបគាត់ឲ្យកូនសម័យនោះ ឆ្លាក់គាត់មិនឲ្យមានពាក់អាវ ព្រោះគាត់ចង់បង្ហាញប្រាប់យើងថា ពូជគាត់ពុំបានកើតចេញពីបរទេសឡើយ (ប្រស្នារូប ដែលពុំពាក់អាវ)។ គាត់ចង់ប្រាប់កូននាគសម័យខាងក្រោយ ឲ្យយល់ពីអាថ៌កំបាំងរបស់ពូជនាគ ព្រោះគាត់ជាមេនាគ ពុំមែនដូចបរទេសមួយចំនួន បានថានគរក្មែរសម័យនោះ ពុំស៊ីវិល័យ ពុំមានអារ្យធម៌ ពុំមានពូជពង្សច្បាស់លាស់ នោះគឺពុំត្រឹមត្រូវទេ ប្រទេសមួយអាចពង្វាតទឹកដីឲ្យទៅជាចក្រភពបាន អាចកសាងប្រាសាទថ្មរាប់ពាន់បាន បើពួកគាត់ពុំមានវប្បធម៌អារ្យ

ចម៌ទៅដល់កំពូល ធ្វើដូចម្ដេចសមិទ្ធិផលទាំងនេះអាចកើតមាន និងស្ថិតស្ថេរមកដល់សព្វថ្ងៃបាន? ពេលដែលយើងពុំបានស្រាវជ្រាវពីអាថ៌កំបាំងរបស់ខ្លួន ទើបធ្វើឲ្យប្រវត្តិរបស់ជនជាតិនេះ ម្ដងថាកើតពីជាតិនេះ ម្ដងថាកើតពីប្រទេសនោះ (ប្រវត្តិសាស្ត្រខ្មែរ) ហាក់បីដូចជាជនជាតិនេះ កំពុងឈរលើក្បូន ម្ដងផ្អៀងទៅខាងនេះ ម្ដងផ្អៀងទៅខាងនោះ រកកំណត់លំនឹងខ្លួនគ្មាន។ តាមពិត ពូជនាគនៅតែជាពូជនាគ ព្រោះយើងមានមេនាគជាដើមហេតុ ព្រះមាតានាគនេះហើយ ដែលបានបន្សល់ទុកពូជនាគរាប់ពាន់ជំនាន់ រហូតមកដល់សព្វថ្ងៃ គ្រាន់តែយើងពុំបានមើល និងពិចារណាតែប៉ុណ្ណោះ ដោយរឿងរបស់ពួកគាត់ បានបាត់ដាន ហើយលិចចុះទៅក្នុងសមុទ្រទឹកដោះ រួមទាំងបរទេសចូលមកក្លែងបំភ័ន្ត (លុបដាន សាដាន លក់ដាន) ទៀតនោះ ធ្វើឲ្យកូននាគសម័យខាងក្រោយ ដែលប្រសូត្រចេញពីផ្ទៃមាតាទាំង១២ ដែលយក្សបានខ្វេះកែវភ្នែកយកទៅនោះ ត្រូវងងឹតមិនដឹងរឿងបន្តគ្នា (មើលភាគ១ និងភាគ២)។ ដូចមានរូបស្រីគ្រប់លក្ខណ៍នេះ ជាភ័ស្តុតាងស្រាប់ ដែលរូបនេះ គាត់ប្រតិស្ឋានទុក ក្នុងប្រាសាទបន្ទាយស្រី ព្រោះវាជារឿងរបស់ស្ត្រីដែលជាមេជាម៉ែ ហើយគាត់បានប្រាប់ដំណើររឿង គ្រប់ផ្ទៃរ ក្បាំងក្លែង ជញ្ជាំង ទុកឲ្យយើងមើលពីដំណើរកម្មរបស់គាត់ ក្នុងពេលជាប់ទោស ក្នុងពេលមានកូនចុះទៅជួយគាត់ និងពេលដែលគាត់រួចពីទោស។ តែបរទេសដែលធ្លាប់ធ្វើអាណានិគម គេមានសិទ្ធិមានអំណាច ប្រែភាសារូបបង្វែងឲ្យទៅជារឿងរបស់សាសនា រួចឲ្យយើងទាំងអស់គ្នាជាកូននាគ រៀនសូត្រតាមគម្ពីររបស់ពួកគេ (បទសារិកាកែវ) ទីបំផុត យើងពុំអាចដឹងរឿងពិតក្នុងភាសារូបទាំងនោះឡើយ។ ហេតុអ្វីក៏តោមានតែជើង អត់ក្បាល? ព្រោះភាសាគំនិតក្នុងរូបនេះ គាត់ចង់ប្រាប់យើងថាទៅថ្ងៃអនាគតខាងមុខ នឹងកើតមានទីក្រុងមួយឈ្មោះថា ទីក្រុងព្រះសីហនុ (ទីក្រុងតោ) ព្រោះចង្វាយក្បាច់ដែលដុះបន្តគ្នាទៅលើនោះ គឺបញ្ជាក់ប្រាប់ពេលវេលាទៅថ្ងៃខាងមុខ ពេលដែលកើតមានទីក្រុងនេះហើយ លុះត្រាតែកើតមានរូបនិមិត្តសញ្ញាទេវតាថែមទៀត ទើបមានកូននាគអាចដឹងរឿងអាថ៌កំបាំងរបស់គាត់ ហើយរឿងប្រស្នាបណ្ដាំព្រះម៉ែនេះ គឺបានលេចចេញពីទីក្រុងតោនោះឯង ដូចនេះទើបអ្នកសរសេរទំនាយថ្ងៃសុក្រ ថ្ងៃសៅរ៍ គាត់បានប្រើពាក្យឱះឱអាសូររាជសីសត្វ ព្រោះប្រារព្ធទៅលើរឿងអាថ៌កំបាំងនេះ បានផុសចេញពីទីក្រុងតោពីរនេះ។ ដូច្នេះស្ទើរតែគ្រប់ប្រាសាទនានា តែងតែមានតោនៅពីក្រោយនាគ ព្រោះតោជានិមិត្តរូបជួយជ្រោងនាគ ឬស្រង់នាគ (ស្រះស្រង់)។

# ៣១/.រូបភាពទី៣១រូបតោនៅចុងក្បាំងភ្លែង(ប្រាសាទបន្ទាយស្រី



រូបភាព ក្នុងចុងក្បាំងភ្លែងនេះ មានតោ កំពុងចេញពីមាត់យក្ស ដែលខ្ញុំបានពន្យល់ ពីភាសារូបភាព មុនៗរួចហើយ ព្រោះជើងតោនៅខាងក្រោម ទម្រាំតែអាចកើតចេញជារូបរាងតោពិតប្រាកដបាននោះ គឺមានរយពេល រាប់រយពាន់ឆ្នាំទៅខាងក្រោយ។ តោនេះ ទោះបីកើតមានរូបរាងពិតប្រាកដ ក្នុងសម័យខាងក្រោយក៏ដោយ ក៏តោនេះ នៅជាប់ឃុំក្នុងអំណាចយក្សដដែល (គឺក្នុងមាត់យក្ស) ទោះបីឡើងទៅដល់ទីខ្ពស់ក៏មិនទាន់រួចពីទោសដែរ តែវាគ្រាន់ជាងពីមិនទាន់ មានរូបរាងតោពិតប្រាកដ នោះបានន័យថា បាបទាំងឡាយរបស់គាត់ ជិតអស់ហើយ (មើលស្រីគ្រប់លក្ខណ៍ខាងក្រោម)។ ដូច្នេះរឿងរ៉ាវតោនេះ ខ្ញុំបានពន្យល់តាំងពីភាគមុនមកម្ល៉េះ ចំណែកភាគនេះ ខ្ញុំគ្រាន់តែយករូបភាពមកជាសម្អាង ដើម្បីឲ្យកូននាគប្រុសស្រីមើលរួចពិចារណា ព្រោះ**យើងជាកូននាគជាពូជនាគ ត្រូវតែដឹងរឿងពិតនៅក្នុងប្រាសាទថ្មរបស់ខ្លួន**។

## ៣២/.រូបភាពទី៣២រូបក្បាំងក្លែងបន្ទាយស្រីសព្វថ្ងៃនៅសារមន្ទីជាតិភ្នំពេញ



*រូបភាពក្នុងក្បាំងក្លែងនេះ បានរៀបរាប់ពីសកម្មភាពរបស់ស្ត្រីម្នាក់នៅចំកណ្ដាល នៅសងខាងរូបស្ត្រីនោះ មានបុរសកំពុងលើកអាវុធគំរាម ទាញដៃដណ្ដើមស្ត្រីនៅកណ្ដាលម្នាក់មួយចំហៀងហាក់បីដូចជាបង្ហំដោយអំណាចហឹង្សា ដើម្បីហែកស្ត្រីនេះ ឲ្យរយះជាពីរចំហៀង។ នៅសងខាងបុរស មានមនុស្សអង្គុយ រូបទីមួយមានដើមឈើរាងផ្លិតនៅពីក្រោយ កំពុងលើកដៃសំពះ ឯម្នាក់ទៀតនៅពីក្រោយ ពុំលើកដៃសំពះទេ រូបម្ខាងទៀតក៏មានសកម្មភាពដូចគ្នា។ នៅខាងក្រោយស្ត្រីមានដើមឈើជារាងផ្លិត ហើយនៅលើផ្លិតមានទេវតាពីរហោះពីលើ តើរូបភាពចម្លាក់គំនិតនេះ គាត់ចង់និយាយប្រាប់យើងពីអ្វី?*

***ក*/.រូបស្ត្រីមានសម្លៀកបំពាក់ដូចជា ស្រីគ្រប់លក្ខណ៍នោះ គឺតំណាងឲ្យព្រះម៉ៃមហានគរ ឯផ្លិតជាដើមឈើនៅពីក្រោយគាត់ គឺតំណាងឲ្យអំណាច យសសក្តិ កេរ្តិ៍ឈ្មោះ របស់គាត់ ពីអតីតកាល ព្រោះរាងផ្លិតនេះ ដូចជារាងផ្លិតតំណាងឲ្យយសសក្តិមន្ត្រីសង្ឃក្នុងរាជាគណៈ តាំងពីថ្នាក់សម្ដេចសង្ឃរាជរហូតដល់រាជាគណៈថ្នាក់កិត្តិយស។*

***ខ/***.ក្រោយពីស្ត្រីនេះអស់អំណាចយសសក្តិ គាត់ត្រូវយក្សចាប់យកទៅឃុំ បុរសសង្វាងបានឆ្លៀតឱកាសលុកលុយឈ្លានពានមាតុភូមិនេះ ហែកគាត់ជាបីចំណែក (ដំរីក្បាលបី ឬស្ត្រីហែកខ្លួនជាបី) ព្រោះសកម្មភាពរូប បានបង្ហាញពីការហែកស្ត្រីនេះ ដោយអំណាចសង្គ្រាម គឺអាវុធ។

***គ/***.ចំណែកអ្នកអង្គុយសង្វាង ម្នាក់មានផ្លិតពីខាងក្រោយ តែតូចជាងផ្លិតរបស់មាតាមហានគរនោះ កំពុងសំពះអង្វរ តំណាងឲ្យកូននាគកំពុងដឹកនាំប្រទេសសម័យក្រោយៗសំពះអង្វរបុរស កំពុងដណ្តើមគ្នាហែកស្ត្រី (មាតុភូមិ) នោះ ឲ្យឈប់ប្រព្រឹត្តទៀតទៅ តែមើលទៅគេពុំព្រមឈប់ឡើយ ព្រោះសេចក្តីលោភរបស់បុគ្គលមួយ គ្រួសារមួយ សមាគមមួយ ប្រទេសមួយ ពុំចេះស្កប់ស្កល់ឡើយ ដូចជាព្រះម៉ែមហានគរ ពីអតីតកាលយ៉ាងដូច្នោះ។ ឯម្នាក់ខាងក្រោយអង្គុយដាក់ដៃធម្មតា គឺតំណាងឲ្យកូននាគ ដែលពុំខ្វល់ ឬរើបម្រះ ពុំឈឺក្បាលវិលមុខពីរឿងអ្វីឡើយ គឺបានត្រឹមតែហៃអើៗអាជ័យធ្លាក់ទឹក គឺមានន័យថា ធនធានរបស់ជ័យគ្រប់ជំនាន់ពីអតីត តាំងពីជ័យដំបូង រហូតដល់ជ័យចុងក្រោយ បានធ្លាក់លិចទៅក្នុងទឹកទៅហើយ (មើលការពន្យល់ពាក្យក្រពើ នៅក្នុងភាគ១)។

***ឃ/***.ទេវតាខាងលើ តំណាងឲ្យនិមិត្តសញ្ញារបស់គណបក្សមួយដែលមានរូបទេវតា ពេលមានរូបនេះកើតឡើង ទើបដឹងរឿងរ៉ាវព្រះមាតាខាងក្រោម (អតីតកាល) បើរូបទេវតានេះពុំកើតឡើងទេ អាថ៌កំបាំងនេះ ត្រូវកប់ក្នុងអតីតកាលក្នុងសមុទ្រទឹកដោះដដែល។

សរុបសេចក្តីមក ភាសាថ្មក្នុងរូបនេះ បានបើកបង្ហាញប្រាប់យើងជាមុនរួចទៅហើយ នៅក្នុងការដណ្តើមហែកនគរ ឬហែកក្បាលដំរីឲ្យទៅជាបី ក្រោយពេលដែលគាត់ត្រូវទទួលទណ្ឌកម្មពីយក្សពេលនោះ អ្នកជិតខាងបានឆ្លៀតឱកាស ដណ្តើមហែកយកមាតុភូមិនេះ។

## ៣៣/.រូបភាពទី៣៣រូបផ្ដែរទ្វារ និងក្បាំងភ្លែងខាងលើ(ប្រាសាទបន្ទាយស្រី






ក្នុងរូបភាពផ្ដែរនេះ បានបង្ហាញពីបុគ្គលិកលក្ខណៈ របស់បុរសម្នាក់មានពាក់ក្រវិលដូចរូបចម្លាក់ស្រីគ្រប់លក្ខណ៍ (ក្បាលរូបតំណាងព្រះម៉ែ) ចាប់ហែកក្បាលស្ត្រីម្ខាងមួយ រយះរហូតដល់ផ្ចិត ដែលក្បាលត្រូវហែកសង្ខាងនោះ ពុំមានពាក់ក្រវិលត្រចៀកឡើយ។ រូបដែលហែកនេះ បានឈរលើផ្កាឈូកមួយ ហើយមានក្បាំងគ្របពីលើជិត ដែលក្បាំងនោះ កើតចេញពីរាជ្យបញ្ញាពីក្នុងមាត់យក្ស ដែលខាំក្បាច់និមិត្តរូបខ្លួននាគយក្សខាំទាំងសង្ខាងនោះ។ តើក្នុងផ្ដែរនេះ គាត់ផ្ដាំឲ្យយើងមើលឃើញពីរឿងអ្វី?

**ក**/.ក្នុងរូបភាពទី៣២មុន គឺមានបុរសពីរនាក់ ដៃកាន់អាវុធកំពុងចាប់ហែកដណ្ដើមស្ត្រីម្នាក់ ឥឡូវកម្លាំងហែកដណ្ដើម បានធ្វើឲ្យកាយស្ត្រីនោះ ត្រូវរយះជាបី ក្បាលកណ្ដាលតំណាងឲ្យនគរខ្មែរ

ព្រោះត្រចៀករូបកណ្តាលមានក្រវិល ដែលជាមរតកម៉ែ (មាតុភូមិ) រូបសង្ខាងមានទម្លាក់សក់វែងជាស្រីដែរ តែត្រចៀកពួកគេពុំមានពាក់ក្រវិលទេ មានន័យថា គេពុំមែនជាពូជអ្នកទទួលកេរម៉ែឡើយ (ខ្មែរ)។ សកម្មភាពរូបមុន បង្ហាញពីពេលដែលកំពុងហែក ចំណែកសកម្មភាពរូបនេះ គឺបានហែកជាបីរហូតដល់ផ្ចិត មានន័យថា បេះដូងក្នុងចំណែករូបទាំងបី មានពណ៌សម្បុរភាសាខុសគ្នាហើយឯក្បាលកណ្តាលអ្នកហែក មានរាងដូចជាបុរសពាក់ក្រវិលត្រចៀកនោះ មានន័យថា អ្នកដឹកនាំប្រទេសជំនួសគាត់សម័យក្រោយៗ គឺជាបុរសដែលជាពូជពង្សនាគ បានទទួលនូវមរកតព្រះម៉ែ ព្រោះពួកគេបានកើត កំពុងរស់នៅ និងទីបំផុតត្រូវកប់សាកសពនៅក្នុងមាតុភូមិនេះ។

ខ/.ក្បាំងក្លែងខាងលើ មានបុរសម្នាក់អង្គុយបញ្ឈរជង្គង់ លើទម្រផ្កាឈូកមួយ ដែលមានរូបតោបីកំពុងចំអើតឡើង ជ្រែងលើរូបខាងលើ ឯនៅខាងលើបុរសនោះ មានរូបបុរសពីរនាក់សង្ខាងបង្កប់ក្នុងក្បាច់ត្រឹមផ្ចិត ហើយនៅលើរូបបុរសទាំងពីរ មានក្បាលយក្សមួយខាំក្បាច់ខាងក្រោមជាប់ហើយនៅពីលើក្បាលយក្សនោះ មានទេវតាពីរទៀតស្ថិតនៅសង្ខាង។ តើសកម្មភាពរូបទាំងអស់នេះមានបង្កប់អត្ថន័យយ៉ាងណា?

១/.រូបដែលអង្គុយលើបល្ល័ង្ក តំណាងកូននាគដែលចុះមកក្នុងសមុទ្រទឹកដោះ ដើម្បីស្រាវជ្រាវនិងជួយម្តាយ តែរូបតំណាងឲ្យគាត់នៅចំកណ្តាល ភាគច្រើនត្រូវបានដាប់បំផ្លាញចោលស្ទើរគ្រប់ប្រាសាទ ព្រោះគេយល់ដឹងភាសារូប គេត្រូវឧបកិច្ចកាត់កឲ្យកូននាគនោះស្លាប់ (មើលពិធីឧបកិច្ចរបស់ស្តេចជ័យវរ្ម័នទី២ កាត់កស្តេចផ្វា)។

២/.តោតំណាងឲ្យទីក្រុងតោ តែក្នុងរូបនេះមានតោបី គឺតោទីមួយតំណាងអតីត តោទីពីបច្ចុប្បន្ន តោទីបីអនាគត និងតំណាងឲ្យសោឃុំអច្ឆរមាតាទាំងបីជាន់។

៣/.រូបបុរសពាក់កណ្តាលខ្លួនសង្ខាង តំណាងឲ្យកូននាគមុននឹងចុះមកអង្គុយលើបល្ល័ង្កខាងក្រោម។

៤/.ក្បាលយក្ស តំណាងឲ្យអ្នកចាប់មាតាបិតា យកទៅដាក់ឃុំពីអតីត ហេតុនេះទើបក្បាលយក្ស ស្ថិតនៅខាងលើផង ខាងក្រោមផង ហើយរូបដែលស្ថិតនៅក្នុងអំណាចយក្សទាំងអស់ តំណាងឲ្យអ្នកដឹងរឿងរបស់ព្រះមាតាមហានគរ។

៥/.រូបទេវតាខាងលើ គឺតំណាងឲ្យនិមិត្តសញ្ញាគណបក្សនយោបាយ (គណបក្សប្រជាជន) ពេលមាននិមិត្តសញ្ញាទេវតា គឺជាសញ្ញាបង្ហាញថា រឿងមាតានាគបានត្រូវកូននាគបានដឹងហើយ។

សរុបសេចក្តីមក រូបទាំង**៣៣**ផ្ទាំងនេះ បានបើកបង្ហាញពីការទទួលទុក្ខទារុណកម្ម របស់មាតាបិតាមហានគរពីអតីតកាល ដែលពួកគាត់ស៊ូទ្រាំនៅរង់ចាំកូនរាប់ពាន់ឆ្នាំ ទ្រនៅទម្ងន់ទុក្ខជាពិសេស គឺមាតាមហានគរ។ ពួកគាត់ក៏មានក្តីសង្ឃឹមយ៉ាងមុតមាំថា ទៅថ្ងៃក្រោយនឹងមានកូននាគណាម្នាក់ចុះមកស្រាវជ្រាវរាវរករឿងពិតរបស់គាត់ រួចជួយស្រង់ពួកគាត់ឲ្យរួចផុតពីបាបកម្មនេះ។ ការពន្យល់បកស្រាយរបស់ខ្ញុំក្នុងរូបទាំង**៣៣**នេះ ហាក់បីដូចជារបស់ដែលធ្លាប់តែផ្កាប់ជារឿងក្នុងសាសនា ឥឡូវត្រូវផ្ងារមកជារបស់ព្រះម៉ែវិញ វាហាក់បីដូចពុំគួរឲ្យជឿឡើយ តែវាជារឿងពិត ព្រោះថ្មពុំចេះកុហកយើងឡើយ។ បើយើងពិតជាអ្នកទទួលមរតកព្រះម៉ែមែន ជាកូននាគមែន យើងត្រូវតែស្គាល់រឿងពិតរបស់ព្រះមេនាគ ព្រោះរឿងទាំងអស់ស្ថិតក្នុងក្បាំង (ក្បាំងក្លែង) ដែលពាក់នៅលើក្បាល ហើយក្បាំងនោះ គឺជាក្បាំងរបស់ព្រះមាតានាគ ព្រោះជាតួខ្លួននាគពីរ បង្កើតបានជាក្បាំងរាប់ពាន់ម៉ឺនសែនក្បាំងនៅគ្រប់ប្រាសាទទូទាំងមាតុភូមិនេះ ទាំងអតីត និងបច្ចុប្បន្ន។ សូម្បីតែក្បាំងអប្សរកំពុងពាក់រាំរាល់ថ្ងៃក៏មាននាគពីរនៅជិតត្រចៀកដែរ គាត់ចង់ខ្សិបប្រាប់កូនឲ្យមើលរឿងម៉ែ ទីបំផុតអច្ឆរាទាំងអស់ត្រូវគថ្លង់ពុំអាចស្តាប់ឮ និងនិយាយបាន (អាចិកំបាំងអច្ឆរារាប់ពាន់ម៉ឺនមានតែពីរ គឺមួយលៀនអណ្តាត និងមួយទៀតញញឹមចេញធ្មេញ) ព្រោះហេតុតែបាបកម្មចាស់ ឲ្យផលបន្តគ្នារហូតមកដល់សព្វថ្ងៃពុំទាន់អស់។ ដូច្នេះចូលកូននាគប្រុសស្រី ភ្ញាក់ឡើងជួយជ្រោងលើកពួកគាត់ រួមសាមគ្គីជានាគព័ន្ធរួមខ្លួនតែមួយ ក្នុងក្បាំង ដែលនៅលើក្បាលតែមួយ ដើម្បីចាកចេញពីអំណាចយក្ស ដោយហេតុតែកែវភ្នែកមាតាទាំង**១២** បានត្រូវភ្លឺឡើងវិញ កូននាគនឹង**មើលឃើញនូវសាសនពិតទាំងឡាយរបស់ព្រះមាតានាគ** ដែលធ្លាប់តែងងឹតពីអតីតកាលនោះ។

## II.រូបភាពបង្ហាញពីសកម្មភាពកូននាគ ច្បានទៅជួយមាតាឲ្យរួចពីអំណាចយក្ស

### ៣៤/.រូបភាពទី៣៤រូបកូនចាប់មាតាផ្គុំខ្លួនដែលហែក(ប្រាសាទបន្ទាយស្រី)



ក្នុងរូបភាពទី**៣២** គេកំពុងចាប់ដណ្ដើមហែកស្ត្រីជាមាតា តែមិនទាន់រហែក មកដល់រូបទី**៣៣** រូបស្ត្រីនោះត្រូវចាប់ហែកជាបី ចំណែកឯរូបទី**៣៤**នេះ ភាសារូបបានបង្ហាញប្រាប់យើងដូចម្ដេច? បើយើងពិនិត្យមើលសកម្មភាពរូបនេះ យើងឃើញបុរសម្នាក់មានមាឌមាំធំ ឈរអង្គុញជើងម្ខាងលើផ្កាឈូកមួយទង ជើងម្ខាងទៀត លើកអង្គុញផុតពីទម្រផ្កាឈូក ហើយគាបលើភ្លៅស្ត្រី ដែលដងខ្លួន និងក្បាលស្ត្រីនោះ ផ្ដេកទៅលើភ្លៅដែលកំពុងឈរ ដោយរូបស្ត្រីនោះទម្លាក់សក់ និងក្រវិលត្រចៀកចុះមកក្រោម។ ចំណែកដៃទាំងពីររបស់បុរសនេះ កំពុងចាប់ស្នាមដែលគេហែកនោះ (មើលរូបទី៣៣) ចេញចាប់ស្នាមហែកឲ្យជាប់គ្នាវិញ នៅក្នុងកាយវិការមួយដ៏លំបាក ព្រោះគាត់បានឈរជើងបានតែមួយចំហៀង ហើយអង្គុញទៀត។ តើរូបបុរសតំណាងឲ្យអ្វី? ហើយរូបស្ត្រីតំណាងឲ្យអ្វី?

**ក**/.ក្នុងរូបភាពនេះ រូបបុរសដែលគេបានដាប់ក្បាលគាត់ចោលនោះ តំណាងឲ្យកូននាគត្រូវចុះមកជួយស្រង់ និងប្រស់មាតាដែលដេកស្លាប់រាប់ពាន់ឆ្នាំនោះ ព្រោះរាងកាយគាត់ត្រូវហែកជាបី កូននេះត្រូវមានភារកិច្ចផ្គុំផ្សាររូបគាត់ឲ្យទៅជាមួយឡើងវិញ។ ប៉ុន្តែគួរឲ្យអនិច្ចានិមិត្តរូបគាត់ណាស់ ពួក

ទុច្ចរិត ព្រោះហេតុតែប្រាក់ បានត្រូវគេជួលឲ្យដាប់បំផ្លាញ ដើម្បីឧបកិច្ចឲ្យកូននាគនេះស្លាប់ បើកូននាគនេះស្លាប់ ព្រះមាតាមហារនគរក៏នៅដេកស្លាប់ដដែល ព្រោះពុំមានអ្នកណាមកប្រស់មកស្រង់ឲ្យគាត់រស់ក្នុងបេះដូងកូនខ្មែរឡើងវិញបានឡើយ។ ហើយកូននាគនេះទៀតសោត មានជើងតែម្ខាងសម្រាប់ឈរ ឯជើងម្ខាងទៀតត្រូវលើកមកគាបទប់ខ្លួនម្ដាយឲ្យមានលំនឹង ដើម្បីផ្សារស្នាមរបែកឲ្យទៅជាមួយវិញ ដូច្នេះគាត់ត្រូវមានការលំបាកណាស់ ទប់ខ្លួនឯងផង ទប់ខ្លួនព្រះម៉ែផង ព្រោះជើងមួយចំហៀងដែលឈរនេះ បានបង្ហាញពីការលំបាកឲ្យយើងដឹង។ រូបគាត់ត្រូវពួនសំងំម្នាក់ឯងនៅក្នុងព្រៃក្បាច់ គឺព្រៃមនុស្សនោះឯង (ប្រាសាទបាពួន) ដើម្បីបំពេញកិច្ចជាកូន ទោះបីមានជើងឈរតែម្ខាង ក៏សុខចិត្តស៊ូទ្រាំគ្រប់កាលលំបាក ដើម្បីប្រស់ម្ដាយឲ្យរស់ឡើងវិញ ក្នុងសន្ដានចិត្ត បេះដូងកូនខ្មែរ។

**ខ/.**រូបស្ត្រីដែលដេកទន់ខ្លួនរងាកនោះ គឺតំណាងឲ្យព្រះមាតានាគ ឬមាតាមហានគរ ដែលគាត់បានដេកស្លាប់ចេញពីបេះដូងកូនខ្មែររាប់រយឆ្នាំហើយ គឺក្រោយពេលដែលខ្មែរបោះបង់ចោលក្រុងអង្គរ ឬយសោធបុរៈ ព្រោះគាត់ពុំអាចចេញពីទីឃុំបានទៀតឡើយ។ ហើយក្នុងរូបនេះ បានប្រាប់ថា មានកូននាគម្នាក់ កំពុងតែចុះស្រង់ និងប្រស់គាត់ឲ្យរស់ឡើងវិញ ក្នុងដួងចិត្តកូនខ្មែរប្រុសស្រី **ចង់ឲ្យមាតុភូមិនេះ ក្លាយជារាជាណាចក្រអច្ឆរិយពិតប្រាកដ** យើងត្រូវតែស្វែងរកអាទិទេពដែលជាអ្នកបង្កើតដែនដីអច្ឆរិយនេះឲ្យឃើញ បើពុំនោះទេ ពាក្យអច្ឆរិយនេះ គឺមានតែស្រមោលនៃពាក្យតែប៉ុណ្ណោះ។

សរុបសេចក្ដីមក អត្ថន័យភាសារូបក្នុងប្រាសាទបន្ទាយស្រី គឺបានបង្ហាញប្រាប់រឿងបន្តគ្នា ពីខ្លោងទ្វារមួយទៅខ្លោងទ្វារមួយ ពីផ្ទែរមួយទៅផ្ទែរមួយ ពីក្បាំងក្លែងមួយទៅក្បាំងក្លែងមួយ បន្តរហូតគ្រប់ប្រាសាទថ្ម ដែលមានក្នុងដែនដីព្រះម៉ែនេះ។ ព្រោះគាត់បានដឹងថា ទៅថ្ងៃអនាគត ពួកបរទេស និងកូននាគដែលពុំយល់ពុំដឹង ច្បាស់ជាបំផ្លាញប្រវត្តិសាវតាពិតរបស់គាត់ជាពុំខាន ព្រោះគាត់បានបង្កប់គំនិតចារឹកទុកក្នុងថ្មធ្វើឲ្យថ្មទាំងនោះ ចេះនិយាយប្រាប់នៅរឿងរ៉ាវពីអតីត បច្ចុប្បន្ន អនាគត សំរាប់ជាមរតកគំនិតទុកឲ្យកូននាគជំនាន់ក្រោយ មើលរួចពិចារណា។ បើប្រាសាទថ្មរបស់ខ្មែរ ត្រូវបានដាប់គាស់បំផ្លាញអស់ទៅហើយនោះ មិនខុសណាពីពាក្យនិយាយរបស់កូននាគ ដែលពុំយល់ដឹង គាត់តែងពោលតគ្នាថា ទៅមើល**ប្រាសាទទាំងនោះ ពុំដឹងទៅមើលអ្វីទេ គឺទៅមើលតែដុំថ្មតែប៉ុណ្ណោះ** នេះជាសំដីពិត ដែលខ្ញុំធ្លាប់បានឮកូនខ្មែរគេនិយាយ។

## ៣៥/.រូបភាពទី៣៥រូបក្បាំងខ្លែង(ប្រាសាទបន្ទាយស្រី

រូបភាពក្នុងក្បាំងខ្លែងនេះ ត្រូវបែងចែកជាពីជាន់ ជាន់ក្រោមមានរូបគ្រុឌមួយនៅកណ្ដាល ចំណែកនៅចុងសង្ខាង មានគោកំពុងផុសលេចចេញពីព្រៃក្បាច់ ដែលព្រៃក្បាច់នោះ មានរាងនិមិត្តរូបជាខ្លួននាគ។ ចំណែកជាន់ខាងលើ មានស្ត្រីម្នាក់ពាក់មកុដទ្រង់គ្រឿងជាស្តេច គង់លើផ្កាឈូក ចំកណ្ដាលពីលើក្បាលគ្រុឌ បង្អែកបល្ល័ង្កខាងក្រោយ មានរាងជានិមិត្តរូបនាគក្បាល៩ ហើយនៅសង្ខាងស្ត្រីនោះ មានដំរីពីរកំពុងបួងរបស់អ្វីមួយរាងដូចជាត្រាផែនដី។ នៅខាងចុងក្បាំងខ្លែង មានរូប



គោ កំពុងចេញពីមាត់យក្សសង្ខាង ដោយនៅក្នុងមាត់គោទាំងពីនោះ មានពាំគប់ភ្លើង ដែលចុងរបស់គប់ភ្លើងនោះ សំយ៉ុងចុះក្រោម តើរូបភាពទាំងអស់ក្នុងក្បាំងខ្លែងនេះ គាត់ចង់និយាយប្រាប់យើងពីអ្វី?

**ក**/.រូបគ្រុឌតំណាងឲ្យសេនាយក្ស និមិត្តរូបសៀម ដែលដៃគ្រុឌទាំងពីរកំពុងចាប់ក្បាច់ និមិត្តរូបនាគសង្ខាង (មាតុភូមិ ឬភូមិនាគ) ហាក់បីដូចជាមិនចង់ឲ្យគោដែលនៅខាងចុងខ្លួននាគនិមិត្តរូបនោះចេញពីក្នុងព្រៃក្បាច់នោះរួច ដើម្បីស្រែកប្រាប់រឿងស្ត្រីខាងលើ។ តែគ្រុឌមិនអាចចាប់ជាប់រហូតបានឡើយ ព្រះអង្គទ្រង់ត្រាស់សម្តែងថា **នត្ថកម្មំ សមំពលំ** កម្លាំងអ្វីស្មើដោយកម្លាំងកម្ម គឺពុំមានឡើយ បាបកម្មក្តី បុញ្ញកម្មក្តី តែដល់ពេលត្រូវឲ្យនៅកម្មវិបាកហើយ ទោះបីកម្លាំងឫទ្ធិរបស់បុគ្គលណាមួយ

ចង់ទប់ ឬឃាត់ គឺពុំបានឡើយ ដូចមានបង្ហាញក្នុងរូបភាពរបស់គ្រុឌនេះស្រាប់ ទោះបីជាខំប្រើកម្លាំងឫទ្ធិទាញទប់កុំឲ្យតោចេញមកខាងក្រៅ ដើម្បីស្រែកប្រាប់រឿង ក៏ពុំអាចឃាត់ឃាំងបានឡើយ។

**ខ/.**រូបតោពីរ តំណាងឲ្យទីក្រុងដែលមានតោពីរ (ក្រុងព្រះសីហនុ) តោនៅពីខាងឆ្វេងដៃគ្រុឌ ខំរើខ្លួនចេញ ខំស្រែក តែពុំទាន់អាចស្រែកប្រាប់រឿងខាងលើបានឡើយ ព្រោះក្បាច់ដែលចេញពីមាត់តោ តំណាងឲ្យសម្លេងនោះ មិនទាន់អាចតភ្ជាប់ទៅខាងលើបាន។ រីឯតោនៅខាងស្ដាំដៃគ្រុឌវិញ ខំរើថែមទៀត ទើបឃើញលេចចេញជើងមួយចំហៀងទៀត ចំណែកសម្លេងដែលចេញពីមាត់តោ គឺអាចស្រែកប្រាប់ពីរឿងអាថ៌កំបាំងស្ត្រីខាងលើបានហើយ ព្រោះក្បាច់ដែលចេញពីមាត់តោ មានសំណុំក្បាច់ធំ ហើយតភ្ជាប់គ្នារហូត។

**គ/.**រូបស្ត្រីដែលពាក់មកុដរាជ និងពាក់គ្រឿងអលង្ការ អង្គុយលើបល្ល័ង្កផ្កាឈូក ពីខាងលើក្បាលគ្រុឌនោះ តំណាងឲ្យមាតាមហានគរ ឬព្រះមាតានាគ ពេលដែលកូននាគទូទាំងនគរបានដឹងពីរឿងអាថ៌កំបាំងរបស់ខ្លួនហើយ អំណាចគាត់អាចអង្គុយ ឬសង្កត់ពីលើគ្រុឌបាន។ ឫទ្ធានុភាពរបស់គាត់អាចផ្សាយទូទៅក្នុងលោកបាន ព្រោះបង្អែកនៅពីខាងក្រោយគាត់នោះ បង្ហាញពីមហិទ្ធិឫទ្ធិដែលផ្សាយចេញពីខ្លួនគាត់ (និមិត្តរូបនាគក្បាល៥)។

**ឃ/.**ដំរីដែលនៅសង្ខាង តំណាងឲ្យក្បាលដំរី ដែលហែកចេញជាបី ឬស្ត្រីដែលត្រូវហែកជាបីនោះ ត្រូវបានបង្រួមឲ្យទៅជាមួយឡើងវិញ ព្រោះដំរីសង្ខាងបានបួងនៅត្រាផែនដី មកប្រគល់ឲ្យម្ចាស់ដើម ដែលជាអ្នកបង្កើតដែនដីនាគពីអតីត។ បើយើងមើលបង្អែកបល្ល័ង្កក្បាលនាគនិមិត្តរូបនៅពីខាងក្រោយ យើងច្បាស់ជាយល់ថា អនាគតកាលរបស់មាតានាគរបស់យើងគាត់មានមហិទ្ធិឫទ្ធិខ្លាំងណាស់ ព្រោះតែឫទ្ធិនេះ ទើបពួកបរទេសគេដឹង គេបិទសន្ធប់ មិនចង់ឲ្យគាត់ចេញមកខាងក្រៅរួចសូម្បីតែរូបគ្រុឌនៅខាងក្រោម ក៏ខំទប់ទាញកុំឲ្យតោរើខ្លួនចេញពីព្រៃរួច ដើម្បីស្រែកប្រាប់ពីអាថ៌កំបាំងរបស់គាត់។ ខ្ញុំធ្លាប់ឮចាស់ៗនិយាយតៗគ្នាថា "**នឹងមានស្ដេចសតូចស្ដើង សោយរាជ្យនគរបី**" ប្រហែលជាគាត់មើលរូបចម្លាក់នេះយល់ ហើយគាត់តាក់តែងទំនាយទុក សម្រាប់ជាមរតកកូនខ្មែរតទៅថ្ងៃអនាគតទេដឹង? ព្រោះបើមើលតាមអត្ថន័យរូប ដែលខ្ញុំបានពន្យល់ដោយសង្ខេបនេះ យើងអាចនឹងយល់បានថាក្នុងអនាគតខាងមុខ គាត់នឹងបង្រួមដែនដីនាគនេះ ដែលត្រូវហែកជាបីចំណែកនោះ ឲ្យរួមមកតែមួយវិញ (ដំរីក្បាលមួយ)។

**ង**/.រូបតោសង្ខាងនៅខាងចុងក្បាំងក្លែង ដែលកំពុងរើខ្លួនចេញពីមាត់យក្ស គឺតំណាងឲ្យទីក្រុង តោពីរនេះដដែល ខាងក្នុងក្បាំងក្លែងខំរើខ្លួនចេញពីអំណាចគ្រុឌជាសេនា តោពីរខាងក្រៅខំរើខ្លួនចេញពីអំណាចយក្ស ដែលជាម្ចាស់ពៀរ ហើយជាសោចាក់ឃុំម៉ែឪកូនពីដើមដំបូង (មើលការពន្យល់រូបភាពមុនៗ)។ ភាគច្រើននៅចុងក្បាំងក្លែងគ្រប់ប្រាសាទខ្មែរ គាត់តែងឆ្លាក់ក្បាលនាគត្រូវយក្សលេប មានភាគតិចណាស់ដែលគាត់ឆ្លាក់តោ គ្រុឌ រាជសី.....ចេញពីមាត់យក្ស ហើយប្រស្នារូបទាំងនេះ គាត់ទុកឲ្យយើងជាកូននាគ មើលរួចឆ្ងល់ៗរួចគិត ដើម្បីស្រាវជ្រាវរករឿងពិតរបស់រូប ព្រោះសិល្បព្រះម៉ែ ពុំមែនសិល្បដើម្បីសិល្ប គឺជាសិល្បអច្ឆរិយ ឬសិល្បអរូបីយ។ ចំណែកឯមាត់តោពាំគប់ភ្លើងសំយ៉ុងចុះ គាត់ចង់ប្រាប់យើងថា តោពុំទាន់មានកម្លាំងគ្រប់គ្រាន់ អាចលើកគប់ភ្លើងបញ្ឈរដើម្បីបំភ្លឺរឿងពិត ពីអតីតរបស់គាត់ដែលត្រូវបានលុបក្នុងពិភពងងឹតឲ្យភ្លឺឡើងវិញ គប់ភ្លើងនោះ តំណាងឲ្យកែវភ្នែកមាតាទាំង**១២** ដែលយក្សបានខ្វេះយកទៅ។ សរុបសេចក្ដីមក ភាសាគំនិតដែលបានបង្កប់ក្នុងចម្លាក់ក្បាំងនេះ គឺបានបង្ហាញនឹងបញ្ជាក់ប្រាប់យើង ពីពេលវេលាដែលព្រះម៉ែ និងតោអាចចេញពីមាត់យក្សរួច ហើយយើងក៏មានសេចក្ដីសង្ឃឹមថា តោទាំងពីររួមទាំងព្រះម៉ែនាគនឹងអាចរួចផុតពីអំណាចបាបកម្មនេះជាពុំខាន។

## ៣៦/.រូបភាពទី៣៦រូបយក្សនិងក្មេងតូច(ប្រាសាទបាគង ឬបាគង់)



ក្នុងរូបភាពនេះបានបង្ហាញ ពីតួអង្គយក្សជាច្រើន ហើយក្នុងចំណោមយក្សដ៏ច្រើននោះ មានក្មេងតូចម្នាក់ កំពុងហោះកាត់ពីខាងមុខយក្ស តើក្នុងរូបភាពនេះ ព្រឹទ្ធដូនតាគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

*ក*/.យក្សតំណាងឲ្យ អ្នកដាក់ទោសមាតាបិតារួមទាំងញាតិវង្សាគាត់ពីអតីតកាល (មើលការពន្យល់រូបមុន)។

*ខ*/.រូបក្មេងតូចតំណាងកូននាគ ដែលត្រូវទៅស្រាវជ្រាវរឿងអាថ៌កំបាំង ដែលលាក់ម្ដាយទុកក្នុងទីឃុំដ៏ជ្រៅនៅឯឋានយក្ស សកម្មភាពរបស់ក្មេងតូចនេះ ហាក់បីដូចជាមានឫទ្ធិណាស់ ព្រោះគាត់អាច កាច់បំបាក់អាវុធរបស់យក្សបាន មិនតែប៉ុណ្ណោះ គាត់ហ៊ានទៅរុកឡុកក្នុងដែនដីយក្ស ដោយគ្មានខ្លាចញញើតចំពោះយក្សឡើយ។ តែគួឲ្យអនិច្ចាចំពោះក្មេងនេះណាស់ បរទេសដឹងរឿង គេបានជួលជនទុច្ចរិតឲ្យដាប់បំបាក់ដៃស្ដាំរបស់គាត់បាត់ទៅហើយ ពេលដែលដៃនោះកំពុងឈោងយករបស់ម្យ៉ាងខាងក្រោយឆ្អកក្បៀនយក្ស ព្រោះគេឧបកិច្ចឲ្យកូននាគនោះ ពិកា ឬស្លាប់ដើម្បីកុំឲ្យសម្រេចបំណងបាន។ ហេតុអ្វីបានជាបរទេសចូលចិត្តជួលពួកទុច្ចរិតឲ្យដាប់រូបចម្លាក់តាមប្រាសាទ? (ដែលភាសាអ្នកប្រកបរបរនោះ គេហៅថាអ្នកជួញដូរក្បាលអ្នកតា) ព្រោះបរទេសគេសិក្សាស្រាវជ្រាវទៅដឹងថា ប្រវត្តិពិតរបស់បុព្វជនជាតិនេះ បានចារឹករឿងរបស់ខ្លួនទុកនៅក្នុងថ្ម (សិលាចារឹក) ដែលនិយាយប្រាប់ពីរឿងក្នុងអតីតកាល បច្ចុប្បន្នកាល អនាគតកាល ពុំមែនសរសេររឿងទុកក្នុងស្លឹកក្នុងស្បែក ឬក៏ក្នុងវត្ថុផ្សេងៗឡើយ គឺពួកគាត់យកទៅទុកក្នុងថ្ម ចំណែកឯរឿងដែលកើតក្នុងស្លឹក ស្បែក ក្រដាស គឺចម្លងចេញពីក្នុងថ្មទាំងនោះ។ ហើយភាសារូបនៅក្នុងថ្មទាំងនោះ គាត់បានឆ្លាក់លាយឡំបង្កប់ជាមួយនឹងក្បាច់លម្អ លាយឡំបំភាន់ជាមួយរឿងក្នុងសាសនា ដោយកូននាគជាអ្នកឆ្លាក់ទាំងនោះ ពុំបានបញ្ចេញឈ្មោះ ឬនាម នៅក្នុងថ្មចារឹកទាំងនោះឡើយ គឺអ្នកឆ្លាក់ទាំងនោះ ជាកំពូលជន**អនាមិក**។ ក្នុងវិជ្ជាមន្តរបស់ព្រហ្មញ្ញសាសនា មានវិជ្ជាមួយនៅក្នុងគម្ពីរអថវេទ វិជ្ជានេះ គេសូនរូបបុគ្គលដែលគេចង់ធ្វើបាបនោះ រួចសរសេរឈ្មោះថ្ងៃខែឆ្នាំកំណើត រួចគេប្រើមន្តសូត្រឧបកិច្ចកាត់ដៃកាត់ជើង ឬកាត់ក ដើម្បីឲ្យបុគ្គលដែលគេព្យាបាទនោះ វិនាស ដូចជាស្ដេចជ័យវរ្ម័នទី២ ធ្លាប់ឲ្យព្រាហ្មណ៍ជារាជគ្រូសម័យនោះ ធ្វើពិធីឧបកិច្ចកាត់កស្ដេចជ្វា ក្នុងពេលដែលព្រះអង្គធ្វើពិធីទេវរាជ តែងតាំងខ្លួនជាស្ដេចចក្រវាល (ឥសូរ)។ ហើយវិជ្ជានេះ បានបន្សល់ទុករហូតមកដល់សព្វថ្ងៃ ក្នុងដែនសុវណ្ណភូមិ ដែលខ្មែរយើងនិយមហៅថា វិជ្ជាធ្មប់ (អ្នកចេះធ្វើអំពើធ្មប់) ហើយអ្នកដែលនៅចេះប្រើ

វិជ្ជាធ្មប់នេះ ពេលដែលគេចង់ព្យាបាទនរណាម្នាក់ គេតែងធ្វើដូចវិធីខាងលើ។ ដូច្នេះពួកបរទេសដែលបានដឹងអាថ៌កំបាំងក្នុងថ្ម គេដឹងថារូបចម្លាក់គ្រប់ប្រាសាទនៅតាមជញ្ជាំង ផ្ដែរ ក្បាំងក្លែង.....តែងមានមនុស្សម្នាក់មកជិះគ្រុឌ និងជាន់ ឬអង្គុយលើក្បាលយក្ស ដើម្បីឲ្យព្រមដោះលែងមាតា ដែលពួកគេបានចាប់ឃុំ ហើយរូបបុរសនោះ គេតាងនាមឲ្យគាត់តាមសម័យកាល ម្ដងព្រះវិស្ណុ ឥសូរ ព្រះព្រហ្មលោកេស្វរ:.... ក្នុងរឿងព្រេង គាត់តាងនាមឲ្យផ្សេង ឧ.បក្សីចាំក្រុង ព្រហ្មកិល ពុទ្ធសែន...។ល។ ហើយបុរសនោះ គេតាមរកគាត់ពុំឃើញឡើយ ព្រោះគាត់ស្ថិតក្នុងព្រៃមនុស្ស ចំណែកសំណាករបស់គាត់ដែលដូនតាបានឆ្លាក់ឡើង គឺមាននៅក្នុងថ្ម ដើម្បីសម្លាប់គាត់មានតែប្រើវិធីឧបកិច្ច កាត់ករូបក្នុងថ្មនោះម្យ៉ាងៗទៀត បើកាត់ករូបចម្លាក់នោះ ពុំបានជោគជ័យ ក៏គេបានប្រយោជន៍ពីរដែរ គឺបានបំផ្លាញឯកសារពិតក្នុងថ្ម។ បើមិត្តអ្នកអានបានទៅទស្សនា រូបតាមប្រាសាទនានាទើបដឹងថា ជារឿងគួរឲ្យសង្វេគ ព្រោះរូបចម្លាក់ក្នុងផ្ដែរខ្លះ មានទំហំប៉ុនមេដៃមេជើង ក៏គេដាប់បំផ្លាញចោលដែរ ឲ្យតែគេសង្ស័យថា ជារូបបុរសនោះ ទីបំផុតគ្រប់ប្រាសាទខ្មែរ រូបចម្លាក់ភាគច្រើនគឺពុំមានក្បាល ពុំមានដៃ....។ល។ ដោយគេមិនចង់ឲ្យបុរសនោះមានជីវិតនៅរស់ ដើម្បីមកជួយស្រង់ប្រស់មាតាឲ្យលោករស់ក្នុងសន្ដានចិត្តកូននាគប្រុសស្រីឡើយ ព្រោះមាតានាគគាត់បានដេកស្លាប់ រាប់រយឆ្នាំទៅហើយ សព្វថ្ងៃគឺនៅសល់តែកេរមរតកគាត់តែប៉ុណ្ណោះ ចំណែកឯអ្នកទទួលកេរមរតកនេះ គេពុំបានស្គាល់គាត់ឡើយ។ យ៉ាងណាមិញ រូបក្មេងតូចក្នុងប្រាសាទបាគងនេះ វាសនារបស់រូបក៏មិនសូវខុសពីរូបនៅប្រាសាទផ្សេងៗទៀតដែរ បើដៃ ឬក្បាលរបស់គាត់ ត្រូវគេដាប់បាត់ទៅហើយ តើគាត់មានកម្លាំង និងជីវិតអ្វីអាចមកជួយមាតាបិតាមហានគរបាន ឬគាត់ជាមនុស្សពិការ តើអាចធ្វើអ្វីកើត សូម្បីតែជួយខ្លួនឯង ក៏ជួយសឹងពុំបានផង។ នេះជាការពន្យល់ប្រៀបធៀបរូបចម្លាក់នៅតាមប្រាសាទនានា ដែលធ្លាក់ខ្លួនពិការបាក់បែក ព្រោះមានហេតុខាងដើមដូចដែលខ្ញុំបានពន្យល់ រៀបរាប់ដោយត្រួសៗមកនេះ ទុកជាទុនសម្រាប់កូននាគពិចារណា ពីហេតុដែលនាំឲ្យគេដាប់រឿងក្នុងបេះដូង មេនាគរបស់យើងដែលទុកក្នុងថ្ម។

# ៣៧/.រូបភាពទី៣៧រូបផ្ដែរប្រាសាទបន្ទាយស្រី(សារមន្ទីរជាតិភ្នំពេញ)



តើក្នុងរូបភាពផ្ដែរនេះ ព្រះមាតានាគលោកចង់ប្រាប់កូននាគពីរឿងអ្វី?

**ក**/.ចំកណ្ដាលផ្ដែរមានរូបព្រះវិស្ណុបែងភាគដៃបួន កំពុងជាន់ពីលើសត្វគ្រុឌ ដៃលដៃគ្រុឌមួយចំហៀងលើកផ្ទារឡើង គាបជើងស្ដាំជាប់ ដៃគ្រុឌមួយចំហៀងទៀតចាប់ជង្គង់ជើងឆ្វេង ដៃលបត់ហាក់បីដូចជាមិនចង់ឲ្យព្រះវិស្ណុងើបឈរបានឡើយ។ ហើយនៅខាងលើក្បាលរបស់ព្រះវិស្ណុ មានគម្របមួយគ្របពីលើជិត ហើយគម្របនោះរាងដូចក្បាំង ឬខ្លោងទ្វារ ប្រៀបបីដូចជាអង្រុតក្រុងពីលើដៃទាំងបួនរបស់រូប ដៃស្ដាំពីរ ដៃមួយកាន់ដុំមូល មួយទៀតមានសោផ្កាចន្ទន៍នៅពីលើបាតដៃ ដៃឆ្វេងម្ខាងកាន់ខ្យងស័ង្ខ ដៃមួយទៀតកាន់រាជសារ។

ព្រះវិស្ណុតំណាងឲ្យកូននាគ ដៃលត្រូវចុះមកជួយស្រង់ប្រស់ព្រះមាតាមហានគរ ដៃលគ្រុឌជាសេនាយក្ស កំពុងក្រុងគ្របលាក់ទុករូបគាត់កុំឲ្យកូននាគដឹង តៃពេលនេះព្រះវិស្ណុគាត់ពុំទាន់មានកម្លាំងឡើងឈរជាន់លើគ្រុឌបានទេ តៃគ្រុឌគេក៏ពុំព្រមចុះចាញ់ឡើយ ព្រោះអាងអំណាចរបស់យក្សដៃលបានចាប់ព្រះម៉ែកនាគឃុំ ជាយូរយាណាស់មកហើយ រឿងអ្វីគេត្រូវដោះលៃង។ ចំណែកសត្វគ្រុឌវិញ តំណាងឲ្យសៀម ព្រោះរាជវង្សសៀមនិមិត្តសញ្ញារបស់គេ គឺគ្រុឌ គ្រុឌនេះហើយដៃលបានក្រុងគ្របរឿងពិតក្នុងនគរ (ពន្យល់ក្នុងរូបភាពទី១៦ ១៧ ១៨ និងក្នុងរឿងបក្សីចាំក្រុង)។ ដៃព្រះវិស្ណុទាំងបួន ដៃកាន់ដុំមូល តំណាងឲ្យរឿងរបស់មាតាមហានគរ ដៃកាន់ផ្កាចន្ទន៍ តំណាងឲ្យកូនសោផ្កាចន្ទន៍

សម្រាប់បើកមេសោផ្កាចន្ទន៍ទាំងប្រាំ នៅលើទ្វារថ្មបញ្ឆោតដែលមានគ្រប់ប្រាសាទ ឯដៃកាន់ខ្សែសង្វា តំណាងឲ្យឧបករណ៍ សម្រាប់ផ្ដុំដាស់កូននាគកំពុងដេកលក់ ដៃកាន់រាជសារ តំណាងឲ្យសាសន ព្រះម៉ែមហានគរ។

**ខ**/.រូបក្បាលនាគតូចៗចំនួនប្រាំ ដែលផុសចេញពីខ្លួននាគនិមិត្តរូបយក្សលេប តំណាងឲ្យមាតាមហានាគលោករួចចេញម្ដងបន្តិចៗ រហូតមកដល់ចុងផ្ដែរ ទើបគ្រុឌព្រមលើកដៃឡើង ក្អែនាគចេញមកក្រៅទាំងស្រុង (ព្រមចុះចាញ់ដោះលែងនាគ)។ ក្បាលនាគដែលក្អែចេញពីមាត់គ្រុឌនោះ មានទំហំធំខុសពីក្បាលនាគតូចៗប្រាំខាងដើម គ្រុឌទាំងសង្ខាងព្រមលើកដៃចុះចាញ់អំណាចកូននាគ គឺព្រះវិស្ណុ ដែលគាត់អាចមានឫទ្ធិ គឺគុណធម៌អាចជាន់គ្រុឌ និងយក្សឲ្យដោះលែងព្រះមាតានាគបាន។ សាច់រឿងនៅក្នុងផ្ដែរនេះ មានតួអង្គតែបីប៉ុណ្ណោះ តួអង្គទីមួយគឺព្រះវិស្ណុ តួអង្គទីពីរគឺគ្រុឌ រីឯតួអង្គទីបីគឺព្រះមាតាមហានាគ ដូច្នេះទើបរឿងនេះ ពុំអាចមាននរណាដឹងឡើយ ក្រៅពីតួអង្គទាំងបីក្នុងផ្ដែរនេះ រួមទាំងយក្ស ដែលបានលេបនាគ (ខ្លួននាគក្នុងផ្ដែរនេះ និមិត្តរូបគឺយក្សលេប)។

**គ**/.ឯជាន់ខាងលើ គឺនិយាយពីតួអង្គព្រះវិស្ណុ ដែលនៅតូចមិនទាន់មានកម្លាំងគ្រប់គ្រាន់ (គុណធម៌) ដើម្បីចុះក្នុងសមុទ្រទឹកដោះ ជាន់យក្ស និងគ្រុឌ ដែលបានចាប់ព្រះមាតាឃុំនោះ ហើយរូបតូចៗទាំងនេះ ចំណុចកណ្ដាល គឺកំពូលក្បាំងខាងក្រោម។ សកម្មភាព និងកាយវិការរូបខាងលើគឺជាអ្នកសិល្ប ព្រោះគេឆ្លាក់គាត់លើកដៃរាំ តែយើងមិនដឹងថា ជាសិល្បអ្វីឡើយ ព្រោះវាជាប្រស្នាគំនិតក្នុងភាសារូប ការពន្យល់ពីរូបភាពនេះ ខ្ញុំចង់ឲ្យកូននាគ ចេះពិនិត្យមើលអាថ៌កំបាំងក្នុងភាសារូប យើងជាកូននាគត្រូវតែដឹងរឿងក្នុងបេះដូងនាគ ដូចរឿងក្នុងផ្ដែរនេះ ជាតឹកតាងស្រាប់។ បើយើងមើលពុំបានពិនិត្យ និងល្បែងយល់ទេ យើងច្បាស់ជាមើលពុំឃើញក្បាលនាគតូចទាំងប្រាំ ដែលគាត់ឆ្លាក់បង្កប់ក្នុងក្បាច់ និងក្បាលទីប្រាំមួយ ដែលគ្រុឌក្អែចេញមកខាងក្រៅនោះឡើយ។ ហើយបើយើងពុំបានដឹងបុព្វហេតុពីខាងដើមទេ ហេតុខាងចុងក៏ពុំអាចរកសុខពិតបានដែរ ដូចជាអាថ៌កំបាំងព្យញ្ជនៈក្មេរយ៉ាងដូច្នោះ តួអក្សរ**ក**ជាអ្នកផ្ដើម **កកើត**នៅមរតកគ្រប់បែបយ៉ាងក្នុងទឹកដីនេះ ហើយចុងបញ្ចប់យើងអាចសប្បាយសុខស្រួលបាន ដោយព្យញ្ជនៈបញ្ចប់ គឺ**អ** ពាក្យថា**អអ**មានន័យថា **អ**មួយសែងស្ពានទៅភ្ជាប់**អ**ពីរ (អ អ) ទើបកើតជា**អអ**បាន។ **អ**ទីមួយគឺរឿងក្នុងអតីតកាល **អ**ទីពីរគឺរក្នុងបច្ចុប្បន្នកាល **អ**ទីបីគឺកូនដែលត្រូវសែងស្ពានទៅតភ្ជាប់**អ**ទីមួយ និង**អ**ទីពីរឲ្យរួមគ្នា ទើបអាចរកសេចក្ដីសុខត្រេក**អរ**

បាន។ ហើយតួរអង្គកូន ដែលត្រូវជួយស្រង់មាតាបិតាមហានគរ គឺមានឈ្មោះនៅគ្រប់តួព្យញ្ជនៈទាំង ៣៣តួនោះឯង ហើយយើងកុំច្រឡំគំនូសកណ្ដាលព្យញ្ជនៈ**ម** និង**អ** ថាវះពោះឲ្យសោះ ពាក្យថាវះពោះ គឺកាត់ផ្ដាច់ចេញពីគ្នា វាផ្ទុយពីដាក់ស្ពាន គឺតភ្ជាប់គ្នាពីម្ខាងទៅម្ខាង។ យើងកាន់តែស្រាវជ្រាវ ទើបយើងដឹងថា យើងជាពូជព្រះនាងនាគ យើងជាកូននាគពិត តែពូជនាគត្រូវបានគេបន្សាបពិសអស់ទៅហើយ សព្វថ្ងៃយើងជាកូននាគបានក្លាយទៅជានាគត្រូវគេបន្សាបពិសអស់ទៅហើយ ព្រោះពិសរបស់នាគ បានបន្សាបតៗមករាប់ពាន់ឆ្នាំហើយ (អាចិកំបាំងក្នុងមង្គលការ បុកល័ក្ខ ធ្វើធ្មេញ បន្សាបពិសនាគ គឺពិសព្រះនាងនាគ) ហើយកូននាគ និងព្រះនាងនាគ ដែលនៅមានសព្វថ្ងៃ សល់តែឈ្មោះប៉ុណ្ណោះ ហើយឈ្មោះនេះ និងត្រូវលុបបន្តិចម្ដងៗ ចេញពីសន្ដានកូនខ្មែរទៀត ព្រោះសព្វថ្ងៃវប្បធម៌បរទេស បានកំពុងលុកលុយចូលទៅក្នុងបេះដូងកូននាគស្រករក្រោយ។

## ៣៨/.រូបភាពទី៣៨រូបផ្ដែរ(ប្រាសាទព្រះគោ)



ក្នុងរូបភាព ចម្លាក់ប្រាសាទព្រះគោនេះ តើគំនិតដូនតាគាត់បាននិយាយប្រាប់យើង ពីរឿងអ្វី?

**ក**/.មនុស្សលើកដៃរាំ នៅលើក្បាលយក្ស គឺតំណាងឲ្យកូននាគ ដែលចុះមកបង្ក្រាបយក្ស ឲ្យលែង ព្រះមាតានាគហើយបុគ្គលនេះ ខ្ញុំបានពន្យល់ក្នុងរូបមុនៗរួចហើយ។

**ខ**/.យក្ស ដែលត្រូវកូននាគជាន់ក្បាលពីលើនោះ គឺតំណាងអ្នកចាប់ព្រះមាតានាគពីអតីតកាល កំពុងចាប់ហែកមាត់ខ្លួនឯង ដោយដៃទាំងពីរ។ ក្បាច់ដែលយក្សចាប់ទាញនោះ តំណាងឲ្យរាជបញ្ជាខ្លួន ដែលបានចាប់

ឃុំព្រះម៉ែនាគ ព្រោះនៅដៃខាងឆ្វេង មានខ្លួននាគពាក់នៅលើកំភួនដៃ រីឯកនាគស្ថិតនៅក្នុងដៃគ្រុឌ។

**គ**/.គ្រុឌ ដែលកំពុងចាប់ខ្លួននាគបន្តពីយក្ស (សេនាយក្ស) ឈរជ្រែងចាប់នាគទាំងសង្ខាង ព្រោះរូបភាពនេះ មានក្បាលយក្សសង្ខាង ហើយនាគសង្ខាងនេះ គឺតំណាងឲ្យអតីតកាល និងបច្ចុប្បន្ន ព្រោះនៅពីខាងស្ដាំមុន ខាងឆ្វេងគឺក្រោយ។

**ឃ**/.ព្រះវិស្ណុ ដែលជាន់យក្ស ឥឡូវគាត់មកជាន់គ្រុឌហើយ រូបគាត់រីកធំជាងមុន មានបែងភាគ ដៃបួនរួចជិះពីលើគ្រុឌ កំពុងប្រឹងក្រោកឈរឡើង សង្កត់ឲ្យគ្រុឌលែងមាតានាគ ព្រោះក្បាលនាគ និមិត្តរូបឲ្យមាតានាគ ត្រូវគ្រុឌថ្ពក់ដៃទាញកជាប់។ រូបព្រះវិស្ណុ គឺតំណាងឲ្យកូននាគ ដែលត្រូវចុះទៅ ជួយដោះបាបកម្មចាស់ឲ្យដូននាគ ព្រោះពាក្យដូនក្លាយមកពីពាក្យសណ្ដូន ពាក្យជីដូន គឺមានន័យថា ជីទៅសណ្ដូនស្រង់ប្រស់យាយនាគ ពីក្នុងសមុទ្រទឹកដោះ (សមុទ្រទុក្ខ) ព្រោះពាក្យជីខ្ញុំបានពន្យល់នៅក្នុងភាគមុនរួចហើយ (ជីសូរ ជីក្រែង ជីលា ជីហែ...)។

សរុបសេចក្ដីមក រូបចម្លាក់ប្រាសាទព្រះគោនេះ (ឈ្មោះព្រះគោបានពន្យល់ហើយក្នុងភាគពីរ) អត្ថន័យក្នុង រូបក៏មិនខុសពីប្រាសាទផ្សេងៗទៀតឡើយ គ្រាន់តែការឆ្លាក់របស់ពួកគាត់ គឺជាសិល្ប បំភាន់រូបទៅក្នុងក្បាច់ ដើម្បីកុំឲ្យគេចាប់អារម្មណ៍ បើយើងមើលពុំបានពិនិត្យឲ្យច្បាស់លាស់ទេ ពិត ជាពុំឃើញសាច់រឿងក្នុងចិត្តរបស់គាត់ឡើយ។

## ៣៩/.រូបភាពទី៣៩រូបផ្តែរ(ពុំដឹងប្រភព)



រូបភាពផ្ទៃរនេះ មានរូបភាពស្រដៀង និងផ្ទៃរមុន គ្រាន់តែក្នុងផ្ទៃរនេះ ពុំមានរូបយក្សតែប៉ុណ្ណោះ តើម៉ែគាត់ផ្ដាំឲ្យយើងមើលរឿងអ្វី នៅក្នុងប្រស្នាចម្លាក់នេះ?

**ក**/.នៅចំកណ្ដាលផ្ទៃរជាន់ទីមួយមានរូបព្រះវិស្ណុ រូបគាត់បានបែងភាគដៃបួន ដៃលកំពុងប្រឹងក្រោកឈរឡើងជាន់គ្រុឌ ឲ្យលែងនាគទាំងពីរជាន់ នាគមួយគូនៅក្នុងអន្ទាក់ដៃគ្រុឌ នាគមួយគូទៀតនៅក្រោមក្រញ៉ាំជើងគ្រុឌ ដើម្បីឲ្យគ្រុឌព្រមចុះចាញ់ ដោះលែងនាគទាំងពីរជាន់នោះ។

**ខ**/.រូបគ្រុឌនៅជាន់ទីពីរ ក្នុងដៃគ្រុឌទាំងសង្ខាង មានចាប់ត្រកងកនាគក្បាលបី ហើយចំណែកនៅក្រោមក្រញ៉ាំជើងគ្រុឌ មាននាគក្បាលមួយ រាងដូចជាពស់ ត្រូវជើងគ្រុឌជាន់ជាប់ត្រឹមក (មើលការពន្យល់រូបមុន)។

**គ**/.តើនាគក្បាលបី នៅពីលើដៃគ្រុឌសង្ខាង និងនាគក្បាលមួយ នៅក្រោមជើងគ្រុឌសង្ខាងតំណាងឲ្យអ្វី? នាគក្បាលបីនៅពីខាងលើ តំណាងឲ្យដូននាគ យាយនាគ ព្រះមាតានាគ ពីអតីតព្រោះសម័យមុនគាត់មានឫទ្ធិអាចបែងភាគខ្លួនបានជាបី ប្រាំ ប្រាំពីរ....។ល។ ឯនាគក្បាលមួយ នៅពីខាងក្រោមជើងគ្រុឌ គឺតំណាងឲ្យកូននាគសម័យខាងក្រោយ ព្រោះកន្ទុយនាគក្បាលមួយនេះ បានពាក់តពីខ្លួននាគខាងលើ មានន័យថា កូននាគខាងក្រោម ជាតំណពូជពង្សមេនាគខាងលើ។ តែគួរឲ្យអនិច្ចានឹងសង្វេគខ្លួនណាស់ នាគទាំងខាងលើ និងខាងក្រោម សុទ្ធតែជាប់ឃុំក្រុងក្នុងអំណាចគ្រុឌដែលជាសេនារបស់យក្សដូចគ្នា (មើលការពន្យល់អត្ថន័យរូបមុន)។ ដូច្នេះរូបផ្ទៃរនេះ គាត់គ្រាន់តែចង់ពន្យល់ប្រាប់យើងពីរឿងពិត ពីពូជនាគតំណាខាងក្រោយ (កូននាគ) ត្រូវគេបន្សាបពិសបន្តគ្នាបានក្លាយខ្លួនទៅជានាគក្បាលមួយ ដូចជាពស់ធម្មតា ដោយពុំបានដឹងពីពូជ និងសារជាតិពិតរបស់ខ្លួន ដូចជាសុភាសិតអ្នកប្រាជ្ញភ្នំជីសូរ បានពោលទុកថា **ស្ដេចខ្លៅនាម៉ឺនខ្លៅ ដូចពស់ឆាងត្រៅវពេននៅមាត់ជណ្ដើរ ស្ដេចប្រាជ្ញ នាម៉ឺនមហិទ្ធិយក្ស ដូចពស់ពញាក់ពេននៅមាត់ជណ្ដើរស្ដេចប្រាជ្ញ នាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាក់រមនោរា។**

## ៤០/.រូបភាពទី៤០រូបទ្វារបញ្ឆោតផ្តែរ ក្បាំងក្លែង(ប្រាសាទបន្ទាយស្រី



រូបទ្វារថ្មបញ្ឆោតនេះ តើមាតានាគគាត់ចង់ប្រាប់យើងពីប្រស្នាអ្វី ទាក់ទងនឹងរឿងអាថ៌កំបាំងរបស់ពួកគាត់?

**ក**/.ទ្វារថ្មបញ្ឆោតនេះ បើយើងពិនិត្យមើលទៅតាមរូបភាពជាក់ស្តែង ក្នុងសិល្បបំភ័ន្ត មើលទៅហាក់បីដូចជា ក្របទ្វារ និងបន្ទះទ្វារ ដែលអាចបើកបិទបាន តែតាមពិត គឺពុំអាចបើកបិទបានឡើយ ព្រោះវាគ្រាន់តែជាទ្វារបញ្ឆោតភ្នែកតែប៉ុណ្ណោះ។ ហើយនៅលើទីប្រជុំនៃមាត់ទ្វារទាំងសង្ខាង មានក្បាច់ផ្កាចន្ទន៍ប្រាំគ្រាប់ ឬប្រាំបន្ទះនៅពីលើ និមិត្តរូប គឺតំណាងឲ្យមេសោដែលចាក់ទ្វារថ្មនេះ កុំឲ្យបើករួច ហើយអ្នកដែលអាចបើកទ្វារថ្មនេះរួច ទាល់តែមានកូនសោជារាងផ្កាចន្ទន៍នេះ ទើបអាចបើកបាន ហើយទ្វារបញ្ឆោតថ្មទាំងនេះ មានស្ទើរគ្រប់ប្រាសាទនៅទូទាំងនគរនេះ។ នៅខាងមុខទ្វារបញ្ឆោត មានសសរម្មូលពីរដើម ដែលយើងតែងហៅថាសសរពេជ្រ ពាក្យសសរពេជ្រ គឺជាឈ្មោះរបស់មានតម្លៃ ស្មើនឹងពេជ្រ ហើយសសរពេជ្រនេះ បានទ្រនៅរឿងក្នុងផ្តែរ និងក្នុងក្បាំងក្លែងខាងលើ ដែលជារឿងមានតម្លៃស្មើនឹងពេជ្រ ឬលើសពីពេជ្រ ដែលសសរនេះ នៅឈរទ្រឿងក្នុងផ្តែរ និងក្បាំងរាប់រយពាន់ឆ្នាំហើយ (អាថ៌កំបាំងសសរពេជ្រ)។ រឿងរ៉ាវដែលនៅពីលើទ្វារបញ្ឆោតនោះ (ផ្តែរ និង

ក្បាំង) គឺសុទ្ធតែជារឿងដែលលំបាក នឹងនាំចេញមកផ្សព្វផ្សាយខាងក្រៅ ហេតុនេះដូនតាគាត់ចង់ប្រាប់យើងថា រឿងចម្លាក់នៅលើទ្វារបញ្ឆោត មិនងាយនឹងមើលយល់ មើលយល់ហើយមិនងាយ និងនាំយកចេញមកខាងក្រៅ ដើម្បីផ្សព្វផ្សាយ ព្រោះហេតុអ្វី? ព្រោះទ្វារទាំងនោះ បានចាក់សោផ្កាចន្ទន៍ការពារដល់ទៅប្រាំជាន់ឯនោះ ហើយទ្វារនេះក៏មិនងាយនឹងបើកទៀត (ប្រស្នាជានិមិត្តរូបសោ) លុះត្រាតែមានកូនសោផ្កាចន្ទន៍ ទើបអាចបើកទ្វារទាំងនោះរួច ពេលដែលបើករួច ទើបអាចនាំបណ្តាំដូនតាគឬបណ្តាំព្រះមាតានាគ មកប្រាប់កូននាគខាងក្រៅឲ្យដឹងរឿងបាន (ប្រស្នាអាថ៌កំបាំងទ្វារថ្មបញ្ឆោត)។ ពេលយើងមើលរូប ហើយយើងពិចារណាត្រិះរិះ ទើបមើលឃើញគតិបណ្ឌិតក្នុងបេះដូងដូននាគ ដែលលោកខំលួចចេញពីគុកបាន ក្នុងសម័យមហានគរ គឺលោកមានបំណងឲ្យកូននាគទាំងនោះ ទុកបណ្តាំប្រស្នាទាំងនេះ នៅលើផ្ទាំងថ្ម ព្រោះមានតែថ្មទេ ដែលអាចរក្សាឯកសារអាថ៌កំបាំងបណ្តាំនេះទុកបានយូរ។ ហើយលោកក៏មានសេចក្តីសង្ឃឹមថា នឹងមានកូននាគណាមួយ អាចបើកមេសោផ្កាចន្ទន៍នោះរួច មេសោរអាចបើករួច លុះត្រាតែមានកូនសោនាគ កូននាគណា ព្រមធ្វើជាសោចូលទៅក្នុងទ្រូងម៉ែ ទើបអាចជួយស្រង់ ជួយប្រស់ ជួយបើកបាន (អាថ៌កំបាំងពាក្យកូនសោ និងមេសោ។

## ៤១/.រូបភាពទី៤១រូបភាពបាតដៃផ្កាចន្ទន៍(នៅសារមន្ទីរជាតិភ្នំពេញ)

ក្នុងចម្លាក់បាតដៃនេះ សព្វថ្ងៃក្នុងសៀវភៅបរទេស គេបានពន្យល់ថា ជាបាតព្រះហស្តរបស់ព្រះសម្មាសម្ពុទ្ធ តែបើយើងមើលស្តាប់សិក្សា ពីបុរិសលក្ខណៈ៣២ប្រការរបស់ព្រះសម្មាសម្ពុទ្ធនោះក្នុងបាតព្រះហស្តរបស់ព្រះអង្គ គឺមានរូបចក្រដែលមានកាំមួយពាន់ឯនោះ។ ចំណែកបាតដៃក្នុងរូបនេះ មានកាំខាងក្រៅ១២ កាំខាងក្នុង៨ បានន័យថា គេបង្វែងការពិតរបស់យើង ទៅជារឿងមួយផ្សេងទៀត ព្រោះរូបស្រដៀងអាចឲ្យគេបំភាន់យើងបាន តើកាំទាំង១២ និងកាំ៨ តំណាងឲ្យអ្វី?

១/.កាំរស្មីទាំង១២ តំណាងឲ្យកែវភ្នែកមាតាទាំង១២ ឬតំណាង១២ខែ ព្រោះមួយឆ្នាំស្មើ១២ខែ ក្នុងខែថ្ងៃណាមួយ ក៏កូននាគរស់ក្នុងភូមិព្រះម៉ែ មានឈ្មោះថាអ្នកបានទទួលនៅមរតកព្រះម៉ែ ដូច្នេះបើកែវភ្នែកទាំង១២ងងឹត អ្នកទទួលមរតកពីគាត់ក៏ងងឹត បើកែវភ្នែកម៉ែភ្លឺឡើងវិញ អ្នកទទួលមរតកពីគាត់ក៏ភ្លឺដូចគាត់ដែរ នេះជាពន្លឺចក្រ ដែលផ្សាយចេញពីកាំទាំង១២ ន័យមួយទៀត គឺតំណាងឲ្យកូនសោដែលត្រូវយកមកបើក កាំផ្កាចន្ទន៍ដែលជា មេសោទាំងប្រាំ។



២/.ឯកាំទាំង៨ខាងក្នុង តំណាងឲ្យទិសតូច៤ ទិសធំ៤ ដូនកែវគាត់ចង់ប្រាប់យើងថា បើកូនចង់ប្រមូលពន្លឺ ដួងកែវរបស់ម៉ែទាំង ១២ ឲ្យមកជុំគ្នាវិញ លុះត្រាតែកូនដើរប្រមូល ដួងកែវនេះ ដែលស្ថិតនៅគ្រប់ទិសទាំង៨ក្នុង នគរ ព្រោះដួងកែវទាំង១២នេះ ម៉ែបានយក ទៅពង្រាយ តាំងពីម៉ែជាប់ឃុំដំបូង រហូតដល់ ម៉ែលែងចេញពីឃុំរួច (អាថ៌កំបាំងប្រាសាទ ហាន់ជ័យ)។ ដូននាគបានប្រាប់យើងទៀតថា ពេលណាដែលកូននាគរកកែវភ្នែក គ្រប់ ចំនួនក្នុងបាតដៃហើយ កូនអាចទៅបើកសោ លើទ្វារថ្មបញ្ឆោតទាំងអស់បាន ព្រោះមេសោ ផ្កាចន្ទន៍ទាំងនោះ ទាល់តែមានកូនសោ គឺ បាតដៃផ្កាចន្ទន៍ ដែលមានកាំ១២ + ៨ + ១ = ២១ ⇔ ១២ នេះហើយទើបអាចធ្វើឲ្យសោថ្ម ដែលយក្សចាក់ពីអតីតកាលនោះ ឲ្យរបើក បាន (នេះជាប្រស្នាថ្ម)។ ចំណែកម្រាមដៃទាំង ៥តំណាងឲ្យអ្វីដែរ?

១/.ម្រាមតូចជាងគេ មានឈ្មោះថាម្រាមកូនដៃ កូននេះហើយ ដែលគាត់បានសន្មត់ឈ្មោះទុក ឲ្យយើងពិចារណា (កូនសោនាគ ចូលក្នុងទ្រូងមេសោដើម្បីបើកទ្វារបេះដូងមេសោនាគ)។

២/.ម្រាមបន្ទាប់ មានឈ្មោះថា ម្រាមនាងដៃ ម្រាមនេះតំណាងឲ្យនាង ឬមេ មានន័យថា ព្រះនាងនាគ ឬព្រះមាតានាគ ដែលកូនត្រូវមកជួយនាងនោះ។

៣/.ម្រាមកណ្ដាល គឺម្រាមចង្អុលខ្មោច ឬម្រាមចង្អុលកណ្ដាល មានន័យថា សម្រាប់ចង្អុល ខ្មោចព្រះមាតានាគ ដែលលោកបានដេកស្លាប់ទៅហើយនោះ ចង្អុលឲ្យបានរស់ឡើងវិញ ក្នុងសន្ដាន ចិត្តកូននាគប្រុសស្រី។

៤/.ម្រាមចង្អុលដៃ

៥/.ម្រាមមេដៃ

ក្នុងរូបភាពបាតដៃនេះ គាត់បានប្រាប់យើងថា ព្រោះហេតុតែ**ចង្អុល** និង**មេ**នេះហើយ ធ្វើឲ្យពួកគាត់ជាប់ទោសរាប់ពាន់ឆ្នាំ ព្រោះហេតុអ្វី? ពេលអ្នកដែលមានឫទ្ធិអំណាច ចង់បានរបស់អ្វីមួយដោយរំលោភបំពាន តែងលើកដៃចង្អុលបង្ហាញទិស និងទីតាំង ពេលដែលលើកដៃចង្អុលនោះ មេដៃ និងចង្អុលដៃទៅព្រមគ្នា ឯម្រាមបីទៀត ត្រូវក្ដោបជាប់ពុំអាចរើខ្លួនរួចឡើយ។ ប្រស្នាក្នុងម្រាមដៃនេះ គាត់បានប្រាប់យើងថា ហេតុតែចង់ឲ្យកូននាគសម័យក្រោយ សោយសុខក្នុងគំនរកេរមរតកម៉ែឪ ទីបំផុតពួកគាត់បានត្រឹមតែក្លាយជាអ្នកទោសក្នុងអបាយភូមិតែប៉ុណ្ណោះ (កម្មវដ្ដ) ហើយបាបកម្មនេះបានអូសបន្លាយរហូតមកដល់សព្វថ្ងៃ។ ចំណែកឯម្រាមបីដែលបត់ជាប់មកខាងក្រោយនោះ គាត់ចង់ប្រាប់យើងថា តទៅអនាគតខាងមុខ និងមានកូននាគណាមួយ (កូនដៃ) មកជួយដោះទុក្ខនាង (នាងដៃ ឬនាងនាគ) ដែលដេកស្លាប់គេឈប់ស្គាល់ឈប់ដឹងនោះ កូននាគនឹងប្រើចង្អុលខ្មោច (ចង្អុលកណ្ដាល) ចង្អុលប្រស់គាត់ឲ្យរស់ឡើងវិញ នៅក្នុងសន្ដានចិត្តកូននាគប្រុសស្រី ដែលពីមុនបានភ្លេចគាត់ទៅហើយនោះ ឲ្យបានស្គាល់ការពិតរបស់គាត់ នឹងគោរពគាត់ឡើងវិញ (នេះជាអាថ៌កំបាំងប្រស្នាឈ្មោះម្រាមដៃទាំងប្រាំ)។ ប្លង់ប្រាសាទអង្គរតូចកំពូលប្រាំ ដែលប្រាំនេះ តំណាងឲ្យម្រាមដៃទាំងប្រាំ និងន័យមួយទៀត គឺតំណាងឲ្យបញ្ចក្ខន្ធ (ខន្ធប្រាំ) ដែលមានរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលខន្ធទាំងប្រាំនេះ បានចងពួកគាត់ជាប់ក្នុងទីទុក្ខ រាប់ពាន់ឆ្នាំ (មើលអាថ៌កំបាំងស្ករតាំងម៉ៃភាគមុន)។ ដូច្នេះបាតដៃដែលមានរូបចក្រជារាងផ្កាចន្ទន៍ និងឈ្មោះម្រាមដៃទាំងប្រាំ ដែលខ្ញុំបានពន្យល់ដោយសង្ខេបនេះ ទុកគ្រាន់ជាគំនិតតូចមួយសម្រាប់ឲ្យកូននាគត្រិះរិះពិចារណា ពីឈ្មោះម្រាមដៃ ដែលដូនតាយើងប្រសិទ្ធិនាមឲ្យឈ្មោះផ្សេងៗគ្នា (អ្នកមានក្រាំងផ្កាចន្ទន៍ទើបអាចបើកមេសោផ្កាចន្ទន៍បាន)។

# ៤២/.រូបភាពទី៤២រូបចម្លាក់លោត(សារមន្ទីជាតិភ្នំពេញ



តើរូបក្នុងផ្ទាំងនេះ គាត់ចង់និយាយប្រាប់ ពីដំណើររឿងអ្វី?

**ក**/.រូបព្រះ ដែលគង់លើសត្វនាគបើកពពារ ហើយគ្រងសំពត់ស្បង់ចីវរជាអ្នកបួសនោះ គឺតំណាងឲ្យព្រះសម្មាសម្ពុទ្ធ សមណគោតមបរមគ្រូនៃយើង ព្រោះព្រះអង្គជាមេនាគទីបី (មើលការពន្យល់ក្នុងមង្គលបីភាគពីរ) ដូច្នេះទើបដូនតាយើង ឆ្លាក់ព្រះអង្គគង់ពីខាងលើនាគ។ ក្នុងបឋមត្រាស់ពេលដែលព្រះសម្មាសម្ពុទ្ធ គង់នៅក្នុងឈានសមាបត្តិ សោយនូវវិមុត្តសុខ នាមាត់ស្រះមុជ្ជលិន ចំនួនប្រាំពីរថ្ងៃ ដោយមាន ភ្លៀងធ្លាក់យ៉ាងខ្លាំង ពេលនោះ នាគនៅក្នុងស្រះមុជ្ជលិន បានលូនចេញពីក្នុងស្រះមកព័ទ្ធព័ន្ធជុំវិញ ព្រះសម្មាសម្ពុទ្ធ រហូតដល់ពីខាងលើ រួចនាគបើកពពារគ្របបាំង ដើម្បីកុំឲ្យព្រះអង្គទទឹកភ្លៀង។ ក្នុងពេលនោះបើគេមើលពីចំងាយ គេពុំបានឃើញរូបរាងព្រះសម្មាសម្ពុទ្ធឡើយ គឺឃើញដូចជារាងផ្ទះកំពូលមួយ ដោយនាគមុជ្ជលិនបានយកខ្លួនធ្វើជាជញ្ជាំងបាំង យកក្បាលធ្វើជាដំបូលប្រក់ ដូចនេះទើបគេមើលឃើញដូចជារាងផ្ទះកំពូលមួយ។ ចុះហេតុអ្វីបានជាសិល្បខ្មែរ ឆ្លាក់រូបព្រះសម្មាសម្ពុទ្ធ គង់ពីលើនាគទៅវិញ? សិល្បខ្មែរ គឺជាសិល្បអរូប សិល្បបង្កប់ទៅដោយគំនិតអច្ឆរិយសិល្បបំភាន់ បើសិនជាអ្នកមើលពុំបានឆ្ងល់រួចពិចារណា គឺពុំអាចមើលឃើញអាថ៌កំបាំងអរូបនេះឡើយ ព្រោះសំបកពីខាងក្រៅ ជារឿងមួយផ្សេង បេះដូងរូបខាងក្នុងជារឿងមួយផ្សេងទៀត។ ដូចក្នុង

រូបភាពនេះ គាត់ចង់បំភាន់អ្នកមើលថា ព្រះគង់លើនាគប្រក់ ពេលយើងស្រាវជ្រាវរូបភាពដើម ក្នុងបឋមត្រាស់ គឺរូបភាពខុសគ្នា ព្រោះបឋមត្រាស់ គឺខ្លួននាគព័ទ្ធជុំវិញធ្វើជញ្ជាំង ឯក្បាលធ្វើជាដំបូល ពុំមែនគង់ពីលើនាគឡើយ ឯរូបក្នុងសិល្បខ្មែរ ព្រះពុទ្ធគង់ពីខាងលើនាគ មានន័យថា ព្រះអង្គជានាគ (មើលរឿងដំបូកហុយផ្សែង)។ ហេតុអ្វីបានជាគាត់ឆ្លាក់ព្រះអង្គគង់លើនាគដូច្នេះ? ព្រោះមាតានាគចង់បញ្ជាក់ប្រាប់កូននាគថា រូបគាត់ក៏អង្គុយលើនាគដែរ (មើលរូបក្របមុខភាគមួយ) គឺគាត់ជាព្រះនាងនាគ ហើយនឹងមានរូបកូននាគ ជាអ្នកមកជួយស្រង់ប្រស់ពួកគាត់ ក៏គេឆ្លាក់រូបអង្គុយលើនាគដែរ ដែលសព្វថ្ងៃ យើងហៅថាព្រះទ្រង់គ្រឿង តាមពិតគឺពុំមែនព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងឡើយ ព្រោះព្រះអង្គជាអ្នកបួស ពុំពាក់គ្រឿងអលង្ការទេ រូបនោះ គឺជាកូននាគដែលត្រូវមកជួយមាតានាគ ដែលក្នុងទំនាយគេហៅថា តួអង្គព្រះសិអារ្យមេត្រី (ចូរមើលការពន្យល់ពីពាក្យនាគក្នុងភាគមួយ)។

ខ/.បុរសដែលអង្គុយពែនភ្នែន ក្នុងឥរិយាបថសមាធិ ដៃលើកសំពះកាន់ផ្កាឈូក ដែលលែងខ្លួនខាងលើទទេនោះ តំណាងឲ្យអ្វី? បើយើងពិនិត្យមើលគន្លងផ្លូវរូបទាំងពីរ ព្រះសម្មាសម្ពុទ្ធ និងរូបបុរសខាងក្រោម គឺគន្លងផ្លូវតែមួយ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានត្រាស់ដឹង និងបរិនិព្វានទៅហើយ រីឯបុរសដែលនៅពីខាងក្រោម លោកនៅបំពេញបារមីជាពោធិសត្វនៅឡើយ ព្រោះហេតុអ្វី? ព្រោះទីមួយលោកបានស្ថិតនៅក្នុងគន្លងផ្លូវ ជាមួយនឹងព្រះសម្មាសម្ពុទ្ធ ទីពីរលោកពុំមានគ្រងសំពត់ចីវរ ជាអ្នកបួស ហើយដៃលោកទាំងពីមានកាន់ផ្កាឈូកក្រពុំ មានន័យថានៅសន្សំគុណធម៌ គឺបារមីនៅឡើយ ហើយបុគ្គលក្នុងរូបនេះទៀងតែនឹងបានត្រាស់ បន្ទាប់ពីព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ក្នុងចុងភទ្ទកប្បនេះ ព្រោះរូបនៅជាប់គ្នា។ ដូច្នេះហើយ ទើបយើងតែងឮចាស់ៗនិយាយទំនាយតៗគ្នាថា នឹងមានអ្នកមានបុណ្យជាតួអង្គព្រះសេរអារ្យមេត្រី មកលើកសាសនាព្រះសមណគោតមបរមគ្រូនៃយើង ប្រហែលជាអ្នកប្រាជ្ញបណ្ឌិតយើងពីមុន លោកមើលរូបភាពនេះយល់ រួចលោកតាក់តែងទំនាយទុកទេដឹង? ព្រោះរូបនេះ បានបង្ហាញពីអត្ថន័យដូចខ្ញុំបានបកស្រាយពន្យល់ខាងលើនេះ។

គ/.រូបនៅពីខាងស្ដាំដៃ ត្រូវបានដាប់បំផ្លាញប៉ុន្តែរូបដែលគេដាប់ចោលនេះ គឺតំណាងឲ្យឪពុក ឬបិតាឈរនៅលើផ្កាឈូក ដែលបែកចេញពីដៃព្រះពោធិសត្វជាកូននាគ ព្រោះទងផ្កាដែលទ្រនោះ បែកចេញពីកែងដៃ បុរសដែលអង្គុយនៅខាងក្រោម។ ចំណែកឯរូបតំណាងឲ្យឪពុកដែលត្រូវបំផ្លាញនោះ គេមិនចង់ឲ្យកូននាគមើលយល់រូបនៅក្នុងផ្ទាំងនេះ ទើបគេបំផ្លាញដើម្បីបំភាន់ ហើយរូបនេះគាត់សន្សំបារមីឲ្យបានជាពុទ្ធបិតាទៅអនាគតជាតិ។

***ឃ/.***រូបខាងឆ្វេងដៃ គឺរូបស្ត្រីឈរកាន់ផ្កាឈូកក្រពុំតូចមួយនៅក្នុងដៃស្តាំ ហើយឈរនៅលើផ្កាឈូក ដែលទងផ្កាបានផុសចេញពីកែងដៃខាងឆ្វេងរូបខាងក្រោម ហើយស្ត្រីនេះ គឺតំណាងឲ្យព្រះមាតាមហានគរ ដែលគាត់សន្សំបារមីឲ្យបានជាពុទ្ធមាតាទៅអនាគតជាតិ។ អត្ថន័យរូបទាំងមូល គឺបានបង្ហាញពីសកម្មភាពកូននាគ ដែលត្រូវបែងភាគជ្រោងឪពុកម្តាយឲ្យរួចពីទីទុក្ខ ដើម្បីបំពេញបារមីដូចជាព្រះពោធិសត្វសុវណ្ណសាម (កតញ្ញូ កតវេទី) គឺជួយជ្រោមជ្រែងម៉ែឪដែលរងទុក្ខក្នុងអបាយភូមិរាប់ពាន់ឆ្នាំនោះ ឲ្យលោកទាំងពីររួចផុតពីទម្ងន់ទុក្ខនេះ ហើយនឹងឲ្យខ្លួនបានបំពេញនូវបារមីដើម្បីឲ្យបានត្រាស់ដឹងជាព្រះពុទ្ធមួយអង្គទៅអនាគតជាតិ។ រូបនេះទៀតសោត ក៏បានបង្ហាញនៅអាថ៌កំបាំងឈ្មោះភ្នំដងរែក ដែលខ្ញុំបានពន្យល់រួចហើយនៅក្នុងភាគពីរ អាថ៌កំបាំងឈ្មោះប្រាសាទព្រះវិហារ និងឈ្មោះប្រាសាទដទៃៗទៀត រួមទាំងឈ្មោះភ្នំ ភូមិ ស្រុក.....ដែលខ្ញុំបានបកស្រាយក្នុងភាគមុនរួចហើយ។

## ៤៣/.រូបភាពទី៤៣រូបអង្គវិស្ណុតូចៗ(ព្រះខ័នកំពង់ស្វាយ)



ក្នុងឯកសារស្រាវជ្រាវភាគពីរ ខ្ញុំបានពន្យល់រួចហើយពីឈ្មោះអង្គរតូចឬអង្គរវត្ត ពេលនេះខ្ញុំយករូបចម្លាក់អង្គតូចៗក្នុងរូប មកបកស្រាយពន្យល់ជាបន្ថែម ដើម្បីឲ្យកាន់តែច្បាស់ នឹងងាយយល់ពីឈ្មោះអង្គរតូច ឬអង្គរវត្តនោះ។ ក្នុងរូបដុំសីមានេះ មានរូបវិស្ណុតូចៗ ដូចរូបវិស្ណុតូចនៅទ្វស្ពានខាងក្រោម ផ្លូវចូលទៅប្រាសាទអង្គរវត្តដែរ រូបទាំងនេះ មាន១៥ជាន់ក្នុងមួយជ្រុង មួយជាន់មានរូបវិស្ណុ១៧អង្គ ហើយដុំសីមានេះមាន៤ជ្រុង សរុបរូបទាំង៤ជ្រុង ស្មើនឹង១០២០រូប គឺ ១៧ x ១៥ x ៤ = ១០២០រូប។ នៅខាងលើដុំសីមាមានក្បាំងនាគ៤ទិស នៅខាងក្នុងក្បាំងមួយទិសមានរូបរឿងមួយ ហើយឈ្មោះរូបទាំងនោះ គឺផ្សេងៗគ្នា តើអត្ថន័យដុំសីមានេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? រូបតូចៗគ្រប់ជ្រុងទាំងបួននេះ គាត់ចង់

និយាយពីការសន្សំគុណធម៌ គឺបារមីរបស់ព្រះវិស្ណុ ទម្រាំអាចក្លាយជារូបធំខាងលើបាន ហើយគាត់អាចទៅតតាំងនឹងយក្ស រួមទាំងបក្សពួកឲ្យព្រមចុះចាញ់ រួចទៅជួយរ៉ែក ទៅស្រង់ (មើលភ្នំដងរ៉ែក និងភ្នំស្រង់ភាគពីរ) មាតាបិតាដែលយក្សចាប់ឃុំពីអតីតកាល ឲ្យលោកបានរួចផុតពីទុក្ខ។ បើយើងមើលតាមសកម្មភាពក្នុងដុំសីមានេះ គាត់សន្សំបារមីបន្តិចម្ដងៗ ដោយស្ងៀមស្ងាត់ គ្មាននរណាដឹងរឿងក្រៅពីខ្លួនគាត់ឡើយ ពេលដែលគុណធម៌ធំបានជារូបធំ គាត់ហ៊ានឡើងទៅជិះលើក្បាលយក្ស និងគ្រុឌនៅខាងលើ គឺមានតែយក្ស និងគ្រុឌទេ ដែលដឹងរឿងគាត់។ រូបខាងលើទាំងបួនទិសមានឈ្មោះព្រះវិស្ណុជិះគ្រុឌ ព្រះពោធិសត្វលោកេស្វរៈ ព្រះឥសូរ និងព្រះព្រហ្ម ហើយរូបធំខាងលើដែលអាចកើតឡើងបាន ដោយសារការផ្គុំរូបតូចៗខាងក្រោម ប្រៀបបីដូចព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ អាចត្រាស់ដឹងបាន ត្រូវសន្សំបារមីទាំង៣០ គឺបារមី១០ ឧបបារមី១០ បរមត្ថបារមី១០ រាប់អសង្ខេយ្យផែនដី ទើបធ្វើឲ្យបញ្ញាអាចត្រាស់ដឹងនៅសច្ចធម៌ដោយខ្លួនឯងបាន។ យ៉ាងណាមិញរអាចិកំបាំងភាសារូបក្នុងថ្មនេះ ក៏មិនខុសពីការសន្សំបារមីរបស់ព្រះពោធិសត្វអង្គមុនៗឡើយ ព្រោះដូនតាបានសរសេរទំនាយទុកនោះ ពួកគាត់បានបំបែកប្រស្នាក្នុងរូបភាពថ្មទាំងនេះ ម្យ៉ាងទៀត អ្នកឆ្លាក់បណ្ដាំគំនិតមាតាមហានគរ (បិសាចពស់) លោកចារឹករឿងទុកលើថ្មផង លោកនិយាយ និងសរសេរទំនាយផង ទុកជាមរតកសម្រាប់កូននាគសម័យក្រោយ យកទៅផ្សំផ្គុំបូកបញ្ចូលគ្នា ទើបអាចក្លាយជាសាសនមាតា (បណ្ដាំមាតា) មួយដែលមានរូបរាងពិតប្រាកដបាន។

## ៤៤/.រូបភាពទី៤៤រូបក្នុងក្បាំងក្លែង(មិនដឹងប្រភព នៅសារមន្ទីរជាតិ)

តើសកម្មភាព ក្នុងរូបភាពចម្លាក់នេះ ព្រឹទ្ធដូនតាលោកចង់និយាយពីអ្វី?

**ក**/.ទីមួយ រូបចំកណ្ដាលពីខាងលើ គឺតំណាងឲ្យព្រះពោធិសត្វលោកេស្វរៈ ព្រោះសំពត់រូបពីខាងមុខមានផ្នត់បត់ជាបន្ទះជាន់គ្នា ខុសពីសំពត់ចីវររបស់ព្រះសម្មាសម្ពុទ្ធ។

ទីពីរបល្ល័ង្ក ដែលទ្រូរូបពុំទាន់មានផ្កាឈូកនៅឡើយ ព្រោះព្រះពោធិសត្វនៅបំពេញបារមីនៅឡើយ ហើយរូបនេះ ពេលដែលតោមិនទាន់ជ្រែងបើកវាំងនន ឬទ្វារនេះឡើង គឺពុំមាននរណាដឹង រឿងពួកគាត់ទាំងបី នៅខាងក្នុងទ្វារនោះឡើយ។ ហើយព្រះពោធិសត្វអង្គនេះហើយ ដែលហ៊ានឡើងជាន់លើក្បាលយក្ស (មើលការពន្យល់រូបមុន)



ឲ្យយក្សនៅខាងក្រោមខ្សោយកម្លាំង ពុំអាចចាប់ទាញជើងតោឲ្យចុះមកក្រោមទៀតបាន។

**ខ**/.រូបឥសីដែលអង្គុយលុតជង្គង់លើផ្កាឈូក នៅពីខាងស្ដាំដៃ កំពុងលើកបង្ហាញរបស់មួយនៅក្នុងដៃនោះ តំណាងឲ្យឥសីកម្ពុ ព្រះថោង កៅណ្ឌិន ...ដែលជាឪពុក ឬព្រះបិតា។

**គ**/.រូបស្ត្រីនៅខាងឆ្វេងដៃគឺតំណាងឲ្យដូននាគ ព្រះម៉ែនាគ ព្រះនាងនាគ លិវយី សោមា ព្រះម៉ែសក់ក្រអូប ព្រះនាងគង្ហីង ទិព្វសេដាច័ន្ទ វិមានច័ន្ទ ក្រពុំឈូក រំសាយសក់ ឧមាវតី ខេមា.... កំពុងអង្គុយបត់ជើងលើកដៃសំពះលើផ្កាឈូកមួយទង ដែលដុះចេញពីចំហៀងក្បាលយក្ស រូបគាត់មានពាក់មកុដរាជខុសពីឥសីដែលពុំមានពាក់មកុដ។

**ឃ**/.រូបយក្សដែលនៅពីខាងក្រោមមានមុខធំសម្បើម បើប្រៀបធៀបទៅនឹងរូបបីខាងលើ មិនស្មើនឹងក្បាលយក្សមួយផង ហើយយក្សនេះកំពុងលានអណ្ដាតជានិមិត្តរូបក្បាច់ ដោយធ្មេញយក្សខាំអណ្ដាតខ្លួនឯងជាប់ មានន័យថាបញ្ញាដាក់ទោសព្រះមាតាបិតាពីអតីតកាលត្រូវអស់សុពលភាពហើយ ព្រោះហេតុអ្វី? ដោយកូននាគនៅពីខាងលើកំពុងតែជាន់ផ្ចាញ់ឲ្យយក្សព្រមខាំអណ្ដាត គឺរាជបញ្ញារបស់គាត់ដែលដាក់ទោសពីអតីត ត្រូវបានបញ្ឈប់ (អាចិកំប៉ាំងរាហ៍កន្លង និងរូបយក្សក្ដៃ ប្រាសាទបន្ទាយឆ្មារ) ព្រោះយក្សមិនអាចមានអំណាចចាប់ព្រះមាតាបិតាលេបបានទៀតឡើយ។ ដៃទាំងពីរបស់យក្ស កំពុងចាប់ទាញជើងតោទាំងសង្ខាង កុំឲ្យតោនេះជ្រោងបើកទ្វារខាងលើបាន តែកំឡាំងយក្សបានចុះខ្សោយទៅហើយ ព្រោះត្រូវកូននាគខាងលើជាន់ក្បាលជាប់ ធ្វើឲ្យអស់ឫទ្ធិអំណាច។

**ង**/.រូបគោពីរខាងក្រោម ដែលយក្សកំពុងចាប់ទាញជើងទាំងសង្ខាងនោះ នៅតែប្រឹងចំអើត ជ្រោងបើកទ្វារ ដែលកាន់ទ្រផ្កាឈូកពីទង ឲ្យរបើកឡើង។ គោពីនេះ មានពាក់គ្រឿងអលង្ការដូចមនុស្ស ហើយច្រមុះគោមានដុះចុងប្រមោយដូចកូនដំរី គឺសត្វគុជសី (ពាក់កណ្ដាលដំរី ពាក់កណ្ដាលរាជសីហ្គោ)។ គោពីរនេះតំណាងឲ្យទីក្រុងគោពីរគឺក្រុងព្រះសីហនុ ព្រោះទីក្រុងនេះមានរូបសំណាកគោពីរធំៗ ហើយទីក្រុងគោនេះកំពុងបើកនូវអាថ៌កំបាំងដែលយក្សបានលេបលាក់រឿងទុកខាងលើគឺអាថ៌កំបាំងបណ្ដាំមាតាមហានគរខ្មែរ។ គោពីមុនមិនទាន់មានពាក់គ្រឿងអលង្ការឡើយពេលដែលគោបានក្លាយខ្លួនជាគុជសីទើបមានគ្រឿងអលង្ការ តើព្រោះហេតុអ្វី? ទីក្រុងសៀមរាបដែលជាទីក្រុងអច្ឆរិយនោះពីមុនឈ្មោះថាទីក្រុងដំរី (ទីក្រុងយសោធបុរៈ) ទីក្រុងគោពីរមានឈ្មោះថាទីក្រុងព្រះសីហនុ ទីក្រុងពីររលាយចូលគ្នាកើតបានសត្វមួយផ្សេងទៀតគឺ**សត្វគុជសី** ដែលមានខ្លួនពាក់កណ្ដាលដំរីពាក់កណ្ដាលរាជសី។ អាថ៌កំបាំងមាតាមហានគរបានបំបែកនិងផ្សព្វផ្សាយនៅក្នុងទីក្រុងរាជសី មានតែសត្វគុជសីនេះទេដែលអាចយកគ្រឿងអលង្ការព្រះមាតាពីអតីតកាលមកពាក់បង្ហាញប្រាប់ពិភពលោកឲ្យគេបានដឹង និងយល់ពីប្រស្នាបណ្ដាំពិតក្នុងភាសាថ្ម ដែលជាសិល្បអរូបីមានក្នុងទឹកដីនេះពីអតីតកាលនិងបច្ចុប្បន្នកាលគឺបានកើតចេញពីក្នុងបេះដូងអច្ឆរា (អប្សរា) ដែលជាប្រមុខខ្មែរ (មេ) ពីអតីតកាលនោះឯង (ពុំមែនជារឿងក្នុងសាសនាទេ)។

សរុបសេចក្ដីមកការពន្យល់រឿងរ៉ាវក្នុងរូបនេះ ពីមុនដែលគោមិនទាន់បើកក្បាំងទ្វារនេះរួចយើងពុំអាចដឹងរឿងអាថ៌កំបាំងក្នុងទ្វារនេះឡើយ តែឥឡូវនេះទ្វារត្រូវបានរបើក ដោយកម្លាំងគុជសីទាំងពីរ ទើបយើងដឹងរឿងមនុស្សបីនាក់ក្នុងរបាំងទ្វារនេះ ដែលដំណើររឿងរបស់អ្នកទាំងបីខ្ញុំបានរៀបរាប់ពន្យល់ដោយសង្ខេបពីខាងលើរួចហើយ។

## ៤៥/. រូបភាពទី៤៥រូបផ្តែរ(នៅប្រាសាទភ្នំជីសូរ)




តើរូបក្នុងផ្តែរនេះគាត់ចង់ពន្យល់ប្រាប់យើងពីរឿងអ្វី? ហើយរូបទាំងអស់តំណាងឲ្យអ្វី?

១/.រូបមនុស្សប្រុសដែលពាក់មកុដនៅចំកណ្តាល កំពុងឈរជ្រែងលើកដៃម្ខាងបើកគម្របដែលគ្របពីលើ ហើយដៃម្ខាងទៀតច្រត់ជង្គង់ឈរលើក្បាលយក្ស គឺតំណាងឲ្យកូននាគ ដែលត្រូវមកជួយម្តាយឪពុកដែលនៅសងខាង ( មើលការពន្យល់ក្នុងរូបមុន )។

២/.រូបបុរសខាងស្តាំពាក់មកុដ ដែលលើកដៃសំពះបន្ទូលដាក់លើក្បាលនោះ តំណាងឲ្យឪពុក ឬឥសីកម្ម.....(មើលការពន្យល់ក្នុងរូបមុន)។

៣/.រូបស្ត្រីខាងឆ្វេងកំពុងអង្គុយលើកដៃសំពះទៅលើក្បាល មានពាក់មកុដដូចជាស្តេចតំណាងឲ្យម្តាយ ឬមាតានាគ...... ( មើលការពន្យល់ក្នុងរូបមុន )។

៤/.រូបយក្សចាប់កាន់ខ្លួននាគនិមិត្តរូបដោយដៃសង្ខាង តំណាងឲ្យអ្នកមានឫទ្ធិអំណាចដែលចាប់មាតាបិតាឃុំពីរអតីត គឺម្ចាស់ពៀរ (មើលការពន្យល់ក្នុងរូបមុន)។

៥/.រូបសត្វករវិកកំពុងទទះស្លាបរងាវនៅពីខាងលើមួយជួរ តំណាងឲ្យមនោគមវិជ្ជាបរទេស (មើលការពន្យល់ពីសត្វករវិកនៅរូបមុន)។ ក្នុងសកម្មភាពរូបក្នុងផ្តែរនេះ រូបសំខាន់ជាងគេគឺ រូបកូននៅកណ្តាល ទោះបីខ្លួនមានដៃតែម្ខាងក៏ដោយ ក៏គាត់នៅតែព្យាយាមបើកគម្របដែលគេបិទពីខាងលើនោះដែរ ព្រោះមាតាបិតា ដែលលោកនៅអង្គុយខាងក្រោមកំពុងសំពះលើកដៃបន្ទូលដាក់នៅលើក្បាល គឺអង្វរឲ្យកូននោះព្យាយាមជួយពួកគាត់បន្តទៅទៀត ដូច្នោះកូននោះមានតែតស៊ូព្យាយាមបើកគម្របនេះតទៅទៀត ទោះបីជាខ្លួនមានដៃតែម្ខាងក៏ដោយ។

## ៤៦/.រូបភាពទី៤៦រូបក្បាំងក្លែង(ប្រាសាទភ្នំជីសូរ)



តើរូបក្នុងប្ចាំងក្លែងនេះ ដូនតាចង់និយាយពីរឿងអ្វី?

១/.រូបមនុស្សពីរនាក់ជិះគោ ដែលមានឆ្វេតឆ័ត្របាំងពីខាងលើ ដូចរាងដើមឈើ តើតំណាងអ្វី?

ក/.មនុស្សទីមួយ តំណាងឲ្យកូននាគដែលមកជួយព្រះមាតា (ក្នុងរូបគេហៅថាព្រះឥសូរជិះគោនន្ទិន) ដឹកនាំគាត់ចេញពីទីទុក្ខ (មើលការពន្យល់ពីឈ្មោះប្រាសាទភ្នំជីសូរភាគ២)។

ខ/.រូបទីពីរដែលនៅពីខាងក្រោយ គឺតំណាងឲ្យមាតាមហានគរ ដែលកូននាំចេញពីក្នុងសមុទ្ទទឹកដោះ (មាតានាគ)។

គ/.គោតំណាងឲ្យសេចក្ដីព្យាយាម ខ្ញុំបានពន្យល់ក្នុងភាគមុនរួចហើយ ពីការធ្វើស្រែរបស់ព្រះសម្មាសម្ពុទ្ធ (កសិសូត្រ)។

ឃ/.ឆ្វេតឆ័ត្រ តំណាងឲ្យឫទ្ធិបារមីរបស់ព្រះមាតា និងតំណាងឲ្យពោធិញាណរបស់ព្រះពោធិសត្វលោកេស្វរៈ របស់កូននាគកំពុងសន្សំបារមី ជួយព្រះមាតាឲ្យបានរួចពីឃុំរបស់យក្ស។

២/.អ្នកអង្គុយសង្វាងពីខាងមុខ និងពីខាងក្រោយ គឺតំណាងឲ្យកូននាគប្រុសស្រី ដែលបានដឹងរឿងពិតរបស់មាតានាគ ហើយអបអរសាទរ នឹងហែហមអមដំណើរគាត់ចេញពីទីឃុំឃាំង។ ក៏ប៉ុន្តែរូបភាពនេះ នៅជាប់ក្នុងក្បាំងក្លែង ដែលក្បាលនាគសង្វាងនូវមានយក្សលេប គឺមានន័យថា មិនទាន់មានសេរីភាពពេញលេញនៅឡើយទេ ដូច្នេះទើបដូនតា គាត់ឆ្លាក់សកម្មភាពគោកំពុងដើរទៅមុខ។

## ៤៧/.រូបភាពទី៤៧រូបផ្តែរនិងក្បាំងក្លែង(ប្រាសាទភ្នំជីសូរ)



ក្នុងរូបភាពក្បាំងក្លែងនេះ អត្ថន័យរូប ក៏ដូចរូបទី៤៦ខាងលើ ដែលខ្ញុំបានពន្យល់បកស្រាយរួច គ្រាន់តែរូបភាពនេះ ពុំទាន់នរណាបានដឹងរឿងគាត់នៅឡើយ។ រូបគោនៅក្នុងក្បាំងក្លែងខាងលើ នៅខាងក្រោមពោះគោមានមនុស្សម្នាក់នៅអង្គុយពីក្រោម កំពុងអង្គុយលត់ជង្គង់ឱនចុះ រូបនេះតំណាងឲ្យ មនុស្សមានឈ្មោះដូចសត្វគោ ដែលកំពុងជួយជ្រោមជ្រែងអ្នកនៅខាងលើ ពេលដែលខ្លួនបានដឹងពីសាវតាពិត របស់ព្រះម៉ែ។ ចំណែកឯផ្តែរខាងក្រោមវិញ មានអត្ថន័យដូចការពន្យល់ក្នុងរូបទី៤៤ និង៤៥ ព្រោះអត្ថន័យរបស់រូបស្រដៀងគ្នា ដោយកូននាគសម័យមុនត្រូវយករឿងពិតរបស់ព្រះម៉ែ ទៅពង្រាយទុកគ្រប់ទីកន្លែងក្នុងទិសទាំង៨ សម្រាប់ឲ្យកូននាគសម័យក្រោយ ជួយព្រះមាតា ពេលដែលដល់ឆ្នាំកំណត់ទោសដែលត្រូវចប់ និងមានកូននាគណាមួយអាចមើលយល់ភាសាគំនិតក្នុងបេះដូង របស់ព្រះមាតាដែលបានចារឹកទុកក្នុងថ្មទាំងនេះ គេនឹងព្យាយាមជួយគាត់ជាពុំខាន។

## ៤៨/.រូបភាពទី៤៨រូបផ្តែរ(ប្រាសាទនាងខ្មៅខេត្តតាកែវ)



ក្នុងរូបភាពផ្តែរនេះ មានរូបមនុស្សតូចៗបង្កប់នៅក្នុងក្បាច់ជាច្រើន តើរូបតូចៗទាំងនេះ មានបង្កប់អត្ថន័យរឿងដូចម្តេច? ផ្ទាំងរូបភាពនេះ ចែកចេញជាបីជាន់ ជាន់លើ កណ្តាល និងក្រោម តើក្នុងជាន់នីមួយៗសកម្មភាពរូបគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

**ក**/.ជាន់ទី១ មានរូបមនុស្សមួយជួរត្រឹមពាក់កណ្តាលខ្លួន មានពាក់មកុដ និងគ្រឿងអលង្ការដូចជាស្តេច កំពុងលើកដៃសំពះត្រឹមទ្រូង អង្វរបួងសួងសុំឲ្យយក្សដែលនៅខាងក្រោមឲ្យព្រម ដោះលែង

ព្រះម៉ែ ចេញពីអំណាចឃុំគ្រងរបស់ខ្លួន ហើយខ្លួនឯងដែលជាអ្នករអង្វរបួងសួងសុំនោះ ក៏ជាប់ឃុំក្នុងចន្លោះខ្លោងទ្វារមួយដែរ។

*ខ*/.ជាន់ទី២នៅចំកណ្ដាល មានរូបមនុស្សតូចមួយអង្គុយនៅលើក្បាលយក្ស និងនៅសង្ខាងមានរូបលើកដៃសំពះបន្ទូលដាក់លើក្បាល នៅក្នុងទ្រនុងខ្នងនាគ និងមានរូបក្បាលយក្សកំពុងខាំលេបនាគ។

១/.រូបអង្គុយលើក្បាលយក្សចំកណ្ដាល តំណាងឲ្យកូននាគដែលត្រូវមកជាន់យក្ស ឲ្យសុខចិត្តលើករាជបញ្ញា ដែលបានដាក់ទោសព្រះមាតាបិតាពីអតីតកាល ហើយរូបគាត់លើកដៃសំពះត្រឹមដើមទ្រូង គឺមានន័យថា រឿងទុក្ខវេទនារបស់ព្រះម៉ែមហានគរគាត់បានយកមកទុកក្នុងដើមទ្រូងរបស់គាត់ (ក្នុងបេះដូង) រូបកូននោះទៀតសោត ក៏នៅក្នុងឃុំដែរ ព្រោះមានក្បាំងមួយគ្របពីលើគាត់ជាប់ (បក្សីចាំក្រុង) មានន័យថា គាត់មិនទាន់មានកម្លាំងគ្រប់គ្រាន់អាចបញ្ចប់នៅទោសទាំងអស់ ពីអតីតឲ្យបានរួចស្រឡះនៅឡើយ។

២/.យក្សកំពុងលើកដៃទ្រចាប់ខ្លួននាគនិមិត្តរូបពីក្រោម ទាំងសង្ខាង គឺមានន័យថា ទោសដែលគេបានដាក់ទៅលើព្រះម៉ែនាគ ទាំងក្នុងអតីត និងបច្ចុប្បន្ន គេពុំទាន់ព្រមលើកលែងទោសឲ្យពួកគាត់ឡើយ លុះត្រាតែព្រះវិស្ណុតូចដែលនៅខាងលើ សន្សំគុណធម៌ឲ្យបានគ្រប់គ្រាន់ ទើបធ្វើឲ្យទម្ងន់នៃគុណធម៌នោះ អាចធ្វើឲ្យយក្សព្រមលើករាជបញ្ញា (លើកលែងទោស)។

៣/.រូបនៅពីខាងស្ដាំ គឺតំណាងឲ្យអតីតកាល ហើយគ្រប់រូបទាំងបួនដែលនៅក្នុងទ្រនុងខ្នងនាគ គឺតំណាងឲ្យព្រះម៉ែមហានគរ ឬព្រះមាតានាគ ដែលជាប់ឃុំក្នុងសោទាំងបួនជាន់ (មើលការពន្យល់រូបទី១)។ ឯគាត់លើកដៃបន្ទូលបួងសួង គឺគាត់ចង់ឲ្យកូននាគដែលកំពុងទទួលមរតកគាត់សព្វថ្ងៃ ជួយស្រង់គាត់ផង ព្រោះគាត់រងទុក្ខវេទនាខ្លោចផ្សាណាស់ នៅក្នុងអបាយភូមិគឺសមុទ្រទឹកដោះព្រោះហេតុតែប្រមូលកេរមរតកទុកឲ្យកូន (កេរម៉ែ = ក្មែរ)។

៤/.រូបនៅពីខាងឆ្វេង គឺតំណាងឲ្យបច្ចុប្បន្ន គឺរូបគាត់នៅជាប់ទោសដដែល (មើលការពន្យល់ទី៣ខាងលើ)។

*គ*/.ជាន់ទី៣ រូបនៅខាងក្រោមមាត់យក្ស មានរាងជាក្បាច់ធ្លាក់ចុះមកក្រោម ដូចជាអណ្ដាតយក្ស ហើយក្នុងអណ្ដាតនិមិត្តរូបនោះ មានរូបស្ត្រីម្នាក់ពាក់មកុដ និងគ្រឿងអលង្ការ ជាប់នៅក្នុង

រង្វង់ក្បាំងបញ្ច្រាស់ នោះគឺតំណាងឲ្យព្រះមាតានាគ។ រូបនេះបានបង្ហាញពីការជាប់ឃុំរបស់ព្រះម៉ែនាគ ក្នុងរាជបញ្ជាដែលយក្សបានបញ្ចេញសំដីនិយាយដាក់ទោស ព្រោះរាជបញ្ជាកើតចេញពីសំដីនិយាយៗកើតចេញពីអណ្ដាតជាអ្នករលាស់ ដូច្នេះទើបគេឆ្លាក់គាត់ឃុំក្នុងអណ្ដាតយក្ស។ ពេលយើងមើលរូបរួច ពិចារណាត្រិះរិះតាមការពន្យល់ដោយសង្ខេបខាងលើនោះ ទើបយើងដឹងថា ការយករឿងក្នុងចិត្តបំឡែងជាសិល្បគំនិត រួចបញ្ចូលទុកក្នុងថ្ម ជាសាសនបណ្ដាំព្រះមាតានាគ ដ៏មានអត្ថន័យជ្រៅលំបាកនឹងគិតយល់បាន។ ព្រោះការបំភាន់នេះ គាត់បានយករូបទៅបំប្លែងលាយជាមួយនឹងក្បាច់ធ្វើឲ្យអ្នកមើលពុំបានចាប់អារម្មណ៍ ដូច្នេះបើយើងមើលនឹងភ្នែក គឺឃើញត្រឹមតែរូបលុះត្រាតែមើល នឹងថ្វាសទើបឃើញរឿងពិតក្នុងបេះដូងរបស់គាត់។ ហើយរឿងនេះទៀតសោត គឺមានតែកូននាគដែលហ៊ានចុះទៅអង្គុយនៅលើក្បាលយក្ស ទើបអាចដឹងរឿងនៅខាងក្នុងពោះយក្សបាន ហេតុនេះ ទើបនៅស្ទើរគ្រប់ប្រាសាទតែងមានរូបមនុស្ស អង្គុយលើក្បាលយក្សផង អង្គុយ នឹងឈរជាន់លើត្រុឌផង ព្រោះមានតែបុគ្គលនេះទេ ដែលអាចធ្វើឲ្យយក្ស និងបក្សពួកចុះចាញ់ ហើយអាចជួយមាតាមហានគរបាន។

## ៤៩/.រូបភាពទី៤៩រូបអប្សរាឬអច្ឆរា(ជញ្ជាំងប្រាសាទបាណន់)



រូបភាពចម្លាក់នេះ ត្រូវបានជនទុច្ចរិតជាប់បំផ្លាញ មុខគាត់អស់ទៅហើយ តើរូបនេះតំណាងឲ្យអ្វី? អត្ថន័យនៅក្នុងរូបនេះ ក៏មិនសូវខុសពីក្នុងរូបមុនៗទេ ដែលខ្ញុំយកមកបង្ហាញនេះ គ្រាន់តែចង់ឆ្លុះបញ្ចាំងប្រៀបធៀប ពីប្រាសាទមួយ ទៅប្រាសាទមួយ ពីរជ្ជកាលមួយ ទៅរជ្ជកាលមួយ។ ព្រោះចង់ឲ្យកូននាគ យល់ពីប្រស្នាកំបាំងក្នុងរូប កុំឲ្យចេះតែជឿទៅតាមការបកពន្យល់ របស់អ្នកប្រាជ្ញបរទេស ដែលមានឯកទេស ខាងបកភាសារូប ដែលបានបំភាន់សតិបញ្ញាយើង ឲ្យ

យល់ឃើញស៊ប់ តែទៅក្នុងរឿងសាសនា ដូច្នេះពលិកម្មដូនតាពូជនាគអ្នកកសាងប្រាសាទថ្មពីអតីតលោកច្បាស់ជាអស់សង្ឃឹម និងយើងជាកូននាគស្រករក្រោយជាពុំខាន ហើយយើងស្លាប់ទៅ ក៏គ្មានមុខឯណាទៅជួបមុខដូនតាទាំងនោះទេ។ រូបស្ត្រីដែលគេដាប់ក្បាលនោះ គឺជាអច្ឆរាតំណាងឲ្យព្រះម៉ែមហានគរ ដែលនៅខាងលើក្បាំងគ្របនោះ មានរូបក្បាលយក្សកំពុងចាប់ខាំ គឺតំណាងឲ្យសោដែលចាក់ឃុំគាត់។ នៅសង្ខាងពីក្រោមមានតោពីរ កំពុងជ្រែងបើកក្បាច់ក្បាំង ដែលខ្ញុំពន្យល់រួចហើយក្នុងរូបទី៤៤ រូបចម្លាក់នេះទោះបីជាគាត់ធ្លាក់ពុំបានផ្ចិតផ្ចង់ ឲ្យមានសោភ័ណភាពក៏ដោយ អត្ថន័យរូបបានបង្ហាញប្រាប់យើង ល្មមគ្រប់គ្រាន់អាចឲ្យយើងមើលយល់បាន ហើយអាចឲ្យជនបរទេសជួលជនខិលខូច ដាប់បំផ្លាញចោលឯកសារថ្មនេះបាន។

## ៥០/.រូបភាពទី៥០រូបអប្សរា ឬអច្ឆរា(ប្រាសាទបាណន់)

តើរូបនេះ គាត់ចង់បង្ហាញយើងពីរឿងអ្វី?

១/.នៅពីខាងលើក្បាលយក្ស មានបល្ល័ង្កមានរាងដូចជាក្បាលនាគ មានរូបមនុស្សម្នាក់អង្គុយនៅលើបល្ល័ង្កនោះ ដែលក្នុងរូបនេះ យើងមើលឃើញនៅសល់តែជង្គង់ភ្នែនតែប៉ុណ្ណោះ ឯរូបដងខ្លួនត្រូវបានបំផ្លាញរលុបអស់ហើយ ហើយមនុស្សនោះតំណាងឲ្យកូននាគដែលខំសន្សំបារមី ដើម្បីអាចឡើងទៅបង្ក្រាបយក្សឲ្យព្រមចុះចាញ់បាន។



២/.ខាងក្រោមបល្ល័ង្ក គឺមានក្បាលយក្សដ៏ធំមួយ ដែលដៃយក្សទាំងពីរកំពុងចាប់ជើងកូននាគទាំងសង្ខាង មិនឲ្យឡើងទៅដាន់ពីលើក្បាលខ្លួនបាន ហើយយក្សនេះទីមួយ គឺតំណាងឲ្យមហាអំណាចដែលដឹងរឿងគាត់តាមបិទសន្ធប់គាត់ ទីពីរគឺយក្សដែលកំពុងសោយនូវផលបុណ្យសព្វថ្ងៃ គឺរាហ៊ុអសុរិន្ទ ព្រោះខ្មែរយើងមានពាក្យទំនៀមមួយឃ្លាថា កូនរាហ៍កន្លង (មើលការពន្យល់ក្នុងភាគពីរ)។

៣/.មនុស្សទាំងពីរនាក់សង្ខាង តំណាងឲ្យកូន

នាគ ក្នុងអតីតកាល និងបច្ចុប្បន្ន កំពុងតែរើខ្លួនចេញពីអំណាចដៃយក្ស ដៃលចាប់ជើងគាត់ជាប់នោះដើម្បីឲ្យបាន រួចហើយឡើងទៅអង្គុយនៅបល្ល័ង្កខាងលើ ដើម្បីឲ្យយក្សព្រមដោះលែងទោសព្រះមាតា ដែលនៅខាងក្រោម តែក្នុងរូបនេះគុណាធម៌គាត់មិនទាន់គ្រប់គ្រាន់ ព្រោះឋិតនៅក្នុងអំណាចយក្ស។

៤/. រូបស្ត្រីដែលគេដាប់ក្បាលគាត់ចោលនៅខាងក្រោមផ្តែរនោះ គឺតំណាងឲ្យព្រះមាតាមហានគរ គាត់ជាប់ក្រុងក្រោមអំណាចយក្ស ព្រោះក្បាំងនាគដែលគ្របពីលើកគាត់នោះ គឺនាគដែលត្រូវយក្សលេបដល់ក ហើយដែលគេដាប់ក្បាលគាត់ចោលនេះ គេឧបកិច្ចឲ្យគាត់ស្លាប់ ដោយគេមិនចង់ឲ្យគាត់មានជីវិតរស់ ក្នុងបេះដូងកូនខ្មែរសព្វថ្ងៃឡើយ។ រូបភាពប្រាសាទនេះ ទោះបីការឆ្លាក់មិនសូវមានសោភ័ណភាព តែអត្ថន័យក្នុងបេះដូងថ្មអាចឲ្យយើងមើលយល់បាន បូកផ្សំនឹងឈ្មោះប្រាសាទផង (មើលការពន្យល់ក្នុងភាគ២) ទើបយើងអាចបំបែកប្រស្នាបំភាន់របស់គាត់ ក្នុងភាសារូបនេះបាន។

សកម្មភាពរូបទី៤៩ ពុំទាន់មានកូននាគចុះមកជួយគាត់ឡើយ ឯរូបទី៥០នេះ មានកូននាគម្នាក់បានចុះមកប្រយុទ្ធតតាំងជាមួយនឹងយក្ស ឲ្យព្រមដោះលែងម្តាយដែលជាប់ឃុំ ក្នុងអំណាចរបស់ខ្លួនរាប់ពាន់ឆ្នាំមកហើយនោះ។ ដូច្នេះក្នុងប្រាសាទនីមួយៗ ព្រះមាតានាគគាត់បានបើកបង្ហាញរឿងក្នុងបេះដូងរបស់គាត់ ដែលបានប្រតិស្ឋានទុកក្នុងថ្ម គាត់ប្រាប់ពីពេលដែលកំពុងជាប់ទោស ពីពេលកំពុងរួចពីទោស និងពីពេលដែលបានរួចផុតចាកទោស។ តែសកម្មភាពរូបភាគច្រើន ដែលខ្ញុំបានប្រទះឃើញ គឺគាត់កំពុងចាកចេញពីទោស ដូចនេះទើបអ្នកប្រាជ្ញករី បណ្ឌិតខ្មែរ ពីសម័យដើម ដែលលោកបានដឹងពីអាថ៌កំបាំងក្នុងបេះដូងថ្មទាំងនេះ លោកបានចងក្រងជាប្រស្នា ទំនាយផ្សេងៗ ដែលប្រស្នាទំនាយទាំងនេះ គឺមានតែនៅក្នុងនគរនេះ តែប៉ុណ្ណោះ ព្រោះវាជាអាថ៌កំបាំងភាសាថ្ម ដែលបង្កប់រឿងក្នុងបេះដូងព្រះម៉ែ។

## ៥១/.រូបភាពទី៥១រូបផ្តែរ(ប្រាសាទបាណន់)

អាថ៌កំបាំងភាសារូបក្នុងផ្តែរប្រាសាទនេះ ក៏មិនខុសពីអត្ថន័យក្នុងផ្តែរមុនៗឡើយ ដែលខ្ញុំយករូបមកដាក់បង្ហាញ គ្រាន់តែចង់ឲ្យកូននាគចេះមើលរូប រួចប្រៀបធៀបពីប្រាសាទមួយ ទៅប្រាសាទមួយថារឿងក្នុងបេះដូងរបស់គាត់ទោះបីជាស្ថិតក្នុងប្រាសាទ នៅក្នុងមាតុភូមិបច្ចុប្បន្ននេះក៏ដោយ ឬប្រាសាទ



ដែលជាអតីតមាតុភូមិខ្មែរក៏ដោយ រឿងនៅក្នុងបេះដូងថ្មទាំងនោះ ត្រូវបានបរិយាយប្រាប់ពីអត្ថន័យក្នុងរូបចម្លាក់ដូចៗ គ្នា។

## ៥២/.រូបភាពទី៥២រូបអប្សរាឬអច្ឆរានៅជញ្ជាំង(ប្រាសាទអង្គរវត្ត)



តើអត្ថន័យរូបអច្ឆរាក្នុងជញ្ជាំងនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

១/.នៅខាងលើចំកណ្តាល មានបុរសម្នាក់ពាក់មកុដ និងគ្រឿងអលង្ការកំពុងអង្គុយបញ្ឈរជង្គង់ នៅពីលើក្បាលយក្ស ដែលនៅក្នុងដៃស្តាំមានកាន់អាវុធ រូបនោះគឺតំណាងឲ្យព្រះវិស្ណុ ឬព្រះនារាយណ៍ ដែលជាកូននាគ ត្រូវមកជួយព្រះមាតានាគ។ ហើយព្រះវិស្ណុនេះទៀតសោត គាត់ខ្លាចយើងមានការភ័ន្តច្រឡំថាជាអាទិទេពនៅបរទេស ទើបគាត់កសាងប្រាសាទអង្គរវត្តនេះឡើង ដើម្បីឧទ្ទិសដល់ព្រះវិស្ណុ ដែលប្លង់ប្រាសាទនេះ មើលពីខាងលើ គឺជារាងយោនី (តំណាងមាតុភូមិ) ព្រោះផ្លូវចូលប្រាសាទ មាន

ចង្អុរផ្លូវយោនីជីវែង គឺមានន័យថា ព្រះវិស្ណុកើតចេញពីមាតុភូមិនេះ ហើយគាត់ត្រូវសន្សំគុណធម៌ ប្រើពេលដ៏យូរដើម្បីនាំអច្ឆរាឬព្រះមាតានាគចេញពីក្នុងសមុទ្រទឹកដោះខាងក្នុង។

២/.អប្សរាកំពុងហោះសង្ហាង គឺតំណាងឲ្យទេវតាស្រី ដែលជានិមិត្តសញ្ញា តំណាងឲ្យគណបក្ស ប្រជាជន ដែលមានរូបទេវតាជាសញ្ញា ព្រោះគាត់ចង់ប្រាប់យើងថា ពេលណានិមិត្តសញ្ញាទេវតា និង និមិត្តសញ្ញាកូរសមុទ្រទឹកដោះ កើតមានឡើងព្រមគ្នានៅក្នុងនគរនេះ ពេលនោះ និងមានកូននាគដឹង រឿង លាក់ទុកក្នុងផ្ទះរបស់គាត់ ដែលត្រូវយក្សចាប់យកទៅឃុំកាលពីអតីត ហើយកូននាគដែលបាន ដឹងរឿងរបស់គាត់នោះ និងព្យាយាមជួយគាត់ (មើលការពន្យល់រូបមុនៗ)។

៣/.យក្សតំណាងឲ្យ ម្ចាស់ពៀរ ឬអ្នកចាប់មាតាបិតាមហានគរយកទៅឃុំ ហើយក្នុងសកម្ម ភាពរបស់យក្សក្នុងរូបនេះ គាត់នៅអាចបញ្ចេញឫទ្ធិចាប់ខាំពាំ រាជបញ្ចាដែលបានដាក់ទោសពីអតីត កាលនៅជាប់មាំដដែល។

៤/.រូបសង្ហាង ដែលនៅជាប់ក្នុងរង្វង់ក្រោមអំណាចដៃ និងមាត់របស់យក្សនោះ តើតំណាង ឲ្យអ្វី?

ក/.រូបខាងឆ្វេងដៃ ជាប់ក្នុងរង្វង់ ដែលក្បាលរង្វង់មានរាងដូចជាសត្វហង្ស ឬមាន់ (រកា) គឺ តំណាងឲ្យឆ្នាំរកា ដែលកូនត្រូវនាំរឿងរបស់ព្រះមាតាត្រូវជាប់ឃុំ យកមកផ្សព្វផ្សាយខាងក្រៅនោះ តែពុំអាចផ្សាយរួចឡើយ ព្រោះពាក្យរកាសាដានចាស់ តែសាពុំរួច ព្រោះដល់ឆ្នាំរកាត្រូវកោង (រកា កោង) គឺត្រូវថែមរយពេលពាក់កណ្ដាលទៀត។

ខ/.រូបជាប់នៅក្នុងរង្វង់ខាងស្ដាំដៃយក្ស ដែលក្បាលរង្វង់មានរូបរាងជាសត្វគុជសី (ពាក់ កណ្ដាលដំរី ពាក់កណ្ដាលរាជសី) នោះ គឺតំណាងឲ្យទីក្រុងពីរបូកបញ្ចូលគ្នា (មើលការពន្យល់រូបមុន) ពេលណាដែលរូបគុជសីនេះ កាន់តែមានរូបរាងច្បាស់ (មានគ្រប់អវយវៈ) ពេលនោះ រឿងក្នុងបេះដូង របស់ព្រះមាតាកាន់តែមានពន្លឺច្បាស់ឡើង។ ចំណែកឯរូបតូចទាំងពីរ ដែលជាប់ក្នុងរង្វង់ឃុំនោះ គឺ តំណាងឲ្យព្រះវិស្ណុ កំពុងសន្សំនៅគុណធម៌ ដើម្បីចេញពីរង្វង់ឃុំ រួចឡើងទៅខាងលើអង្គុយលើក្បាល យក្ស (មើលរូបខាងលើ)។

៥/.រូបអច្ឆរាដែលជាប់ក្នុងក្បាំងនាគ មានយក្សលេប តំណាងឲ្យមាតានាគ នៅខាងក្រោយរូប គាត់ មានក្បាច់ឋាន ដែលមានរូបក្បាលយក្សខាំក្បាច់ គឺមានន័យថា នៅខាងក្នុងបន្ទប់ទៅហើយ ក៏

មានយក្សនៅចាំយាម ដូច្នេះគាត់មិនអាចចេញមកក្រៅទៀតបានឡើយ។ នាគក្បាំងទាំងសង្ខាង មានពាំផ្កាកម្រង គឺមានន័យថា មានកូននាគដឹងរឿងរបស់គាត់ហើយៗគេបានបូជានូវផ្កាកំរង គឺឧទ្ទិសបុណ្យជូនទៅគាត់ ដែលគាត់ស៊ូទ្រាំនៅរងទុក្ខរាប់ពាន់ឆ្នាំមកនោះ គឺមិនអស់សង្ឃឹមឡើយ ព្រោះពេលនេះ មានកូននាគសុខចិត្តយកបេះដូងឲ្យទៅយក្ស ដើម្បីជួយគាត់។ រូបភាពចម្លាក់គ្រប់ប្រាសាទទាំងអស់ គាត់តែងឆ្លាក់បន្លំជាមួយនឹងក្បាច់ ព្រោះក្បាច់ គឺតំណាងឲ្យព្រៃក្នុងអតីត បច្ចុប្បន្ន និងអនាគត ដែលពុំមានអ្នកណាដឹង ហើយអ្នកដែលដឹង គឺមានតែតួអង្គដែលបង្កប់នៅក្នុងក្បាច់នោះ។

សរុបសេចក្ដីមកការពន្យល់បកស្រាយរូបដោយសង្ខេបខាងលើនេះ អត្ថន័យរបស់រឿង គឺមិនសូវខុសគ្នាពីរូបមុនៗឡើយ គ្រាន់តែរូបខាងក្នុងប្រាសាទ គាត់និយាយផ្សេង ចំណែករូបខាងក្រៅគាត់និយាយប្រាប់មានការធូរស្រាលជាង ព្រោះបាបកម្មរបស់គាត់ជិតអស់ហើយ។

## ៥៣/.រូបភាពទី៥៣រូបព្រះវិស្ណុអង្គធំ(ប្រាសាទអង្គវត្ត)



ពាក្យថាអង្គរតូច ឬអង្គរវត្ត ខ្ញុំបានពន្យល់រួចហើយ នៅក្នុងឯកសារភាគពីរ ហើយរូបវិស្ណុអង្គធំនេះ កើតឡើងបានក៏ដោយសារការផ្តុំរូបវិស្ណុតូចៗ ដែលនៅទ្រពីខាងក្រោមផ្លូវដើរចូលតែប៉ុណ្ណោះ យើងអ្នកទស្សនាពុំបានចាប់អារម្មណ៍ឡើយ ព្រោះនៅខាងក្រោមផ្ទាល់ដី។ ព្រះមាតាចង់ប្រាប់យើងថា តួអង្គព្រះវិស្ណុនេះ សុខចិត្តលំបាកវេទនាទ្រស្ថាន ឲ្យគេដើរឆ្លងកាត់រាល់ថ្ងៃ រូបសំណាកតូចៗ តំណាងឲ្យគាត់ ត្រូវគេនោមដាក់ ដើរជាន់ដូចសំរាម (ព្រោះទីនោះងាយបន្ទោបង់ទឹកមូត្រ) តែគាត់សុខចិត្តតស៊ូទ្រនូវទម្ងន់ស្ពាននេះ ដើម្បីបំពេញគុណធម៌គឺបារមី ស្រង់ព្រះម៉ែចេញពីសមុទ្រទុក្ខ (សមុទ្រទឹកដោះ)។ ប្រស្នារូបនេះ ក៏បានប្រាប់យើងទៀតថា ផ្លូវ

កណ្តាលគាត់ពុំអាចនាំរឿងព្រះមាតាចេញមកខាងក្រៅបានឡើយ មានន័យថាអាថ៌កំបាំងមាតាពុំអាចដឹងជាចំហបានឡើយ គឺត្រូវគេដឹងតាមច្រកតូច ដែលមានរូបនេះជាភស្តុតាងស្រាប់ ព្រោះព្រះវិស្ណុនេះបើគាត់ចេញមកក្រៅ ត្រូវដើរលើផ្លូវដី ពុំមែនដើរលើផ្លូវថ្មឬផ្លូវដែលក្រាលកៅស៊ូឡើយ។ ហើយម្យ៉ាងទៀត មាតាដែលនៅខាងឆ្វេងដៃគាត់ ត្រូវដាក់ឲ្យឈរបញ្ច្រាសទិសចង្អូរយោនី គឺខ្ចប់មុខទៅជញ្ជាំង ឯក្បាលម្តាយនិងដៃត្រូវមនុស្សទុច្ចរិត ដែលមានពៀរនឹងគាត់ បានវាយបំបាក់អស់ទាំងស្រុងទៅហើយ តើងាយអ្វីដែលកូនជាព្រះវិស្ណុអាចនាំគាត់ចេញមកខាងក្រៅបានដោយងាយនោះ។ ហើយរូបព្រះវិស្ណុធំនេះទៀតសោត ទម្រាំអាចផ្គុំបានជារូបធំនេះត្រូវគ្រុឌស្ទាក់គ្រប់ជំហាន (មើលរូបក្រោមស្ពាន) តែគាត់ស៊ូទ្រាំព្យាយាម ដើម្បីជួយស្រង់ប្រស់ម៉ែឪមហានគរឲ្យលោកបានរួចពីបាបកម្មចាស់ ទោះបីខ្លួនត្រូវទ្រស្ពានដ៏វែងឆ្ងាយយ៉ាងណាក៏ដោយគាត់សុខចិត្តស៊ូទ្រាំ ព្រោះនេះជាក្តីសង្ឃឹមរបស់ព្រះមាតាបិតានាគ មកលើរូបគាត់ជាកូនតែមួយគត់ (ព្រះវិស្ណុ)។

## ៥៤/.រូបភាពទី៥៥រូបមាតាមហានគរ(អង្គរវត្ត)



រូបមាតាមហានគរនេះ ស្ថិតនៅពីខាងឆ្វេងព្រះវិស្ណុអង្គធំ ដែលខ្ញុំលើកយកមកដាក់បង្ហាញនេះ គ្រាន់តែចង់ឲ្យកូននាគមើលរូបរួចពិចារណាថា បើអាទិទេពរបស់យើងស្ថិតក្នុងសភាពបែបនេះ ពេលដែលយើងជាកូននាគទាំងអស់គ្នាមានភ័យអាសន្នកើតឡើង ហើយយើងនាំគ្នាបន់ស្រន់បួងសួង ឲ្យព្រះមាតាមហានគរ ឬអាទិទេពផ្សេងៗទៀតមកជួយ តើឲ្យពួកគាត់មកជួយយើងយ៉ាងដូចម្តេច? បើរូបតំណាងអ្នកដែលត្រូវមកជួយយើងជាកូន ត្រូវបានដាប់បំផ្លាញអស់យ៉ាងនេះ តើយើងសង្ឃឹមលើអាទិទេពរបស់យើង យ៉ាងដូចម្តេច? ទោះបីអ្នកយកសំពត់ទៅស្លៀក យកអាវទៅពាក់ តើមានប្រយោជន៍អ្វី? បើពួកគាត់បាត់ក្បាល និងអវយវៈអស់ទៅហើយនោះ។

# ៥៥/.រូបភាពទី៥៥នាគ៣រួមខ្លួនតែមួយ(ប្រាសាទអង្គរវត្ត)



នាគបីរួមខ្លួនមួយនេះ នៅជិតផ្លូវចូលខ្លោងទ្វារ (គោបុរៈ) ហើយប្រស្នានាគបីរួមខ្លួនមួយនេះ មាននៅក្នុងរឿងធនជ័យ ដោះប្រស្នាអ្នកប្រាជ្ញចិន ដែលគាត់បានឆ្លើយប្រាប់លោកគ្រូសង្ក្រាជផ្សេង ប្រាប់សម្ដេចចៅពញាវាំងផ្សេង និងប្រាប់ស្ដេចផែនដីផ្សេង គឺអត្ថន័យពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងសាសនមាតាមហានគរបូកបញ្ចូលគ្នា។ អាថ៌កំបាំងបេះដូងនាគក្នុងថ្មទាំងនេះ លុះត្រាតែកូននាគសម័យក្រោយ ព្រមហែក និងព្រមចុះទៅក្នុងទ្រូងមេនាគ ទើបដឹងរឿងក្នុងបេះដូងថ្មគ្រប់ប្រាសាទរាប់ពាន់ ដែលមាននៅក្នុងទឹកដីព្រះម៉ែនេះ។ ដូច្នេះហើយ ទើបនៅប្រាសាទព្រះវិហារក្នុងផ្ទៃរ និងក្បាំងក្លែងមួយ ដែលខ្ញុំធ្លាប់មើលប៉ះក្នុងទូរទស្សន៍ គឺគាត់បានឆ្លាក់រូបបុរសម្នាក់ ចាប់ហែកនាគជាពីរ ន័យរបស់រូប គឺមើលអាថ៌កំបាំងក្នុងបេះដូងនាគ (មើលការបកស្រាយប្រស្នាចាក់ទឹកដូងភាគ១ និងមង្គល៣ភាគ២)។ ដូនតាយើងជាពូជនាគ ជាអ្នកប្រាជ្ញ ជាបណ្ឌិត រាល់ការបន្សល់ទុកកេរមរតកគំនិតរបស់ពួកគាត់សុទ្ធតែមានបង្កប់ន័យនៅក្នុងស្នាដៃ មិនឆ្លាក់រឿងដោយពុំមានហេតុផលនោះទេ។ ដូចជារូបនាគរួមខ្លួនមួយ ជាភស្តុតាងស្រាប់ ន័យរបស់រូបគឺ អតីត បច្ចុប្បន្ន អនាគត នាគម៉ែ នាគឪ នាគកូនត្រូវរួមគ្នាជាខ្លួនតែមួយ (នាគព័ន្ធ) ទើបអាចរំដោះខ្លួនរួចផុតពីអំណាចយក្ស ដែលលេបពីអតីតបាន បើពុំរួមខ្លួនទេ គឺដូចសុភាសិតខ្មែរបានប្រាប់ថា **ចង្កឹះមួយឬទាច់កាច់ពុំបាក់ តែបើចង្កឹះតែមួយគេអាចកាច់បំបាក់បាន។**

ន័យមួយទៀតគាត់បានប្រាប់ថា បេះដូងពិតរបស់ព្រះម៉ែនាគ គឺបានលាក់ទុកនៅក្នុងព្រហ្មញ្ញសាសនា និងពុទ្ធសាសនាទាំងពីរនិកាយ គឺយើងត្រូវច្របាច់បញ្ចូលបីឲ្យក្លាយជាមួយ ដូចប្រស្នាធនជ័យប្រាប់ចម្លើយដល់យើងថា ក្នុងចម្លើយបីនេះ កើតឡើងពីបីរួមគ្នា គឺបានចម្លើយមួយពិត ហើយចម្លើយមួយនោះអាចកើតឡើងបាន លុះត្រាតែត្រិះរិះពិចារណាដោយខ្លួនឯង ពុំមែនទៅសួររកចម្លើយពីអ្នកដទៃឡើយ(បរទេស) ព្រោះ**ពុំមាននរណាស្រឡាញ់ខ្មែរជាងខ្មែរស្រលាញ់ខ្មែរឡើយ។**

## ៥៦/.រូបភាពទី៥៦រូបផ្តែរខាងក្នុងប្រាសាទ(មិនស្គាល់ប្រភព)



រូបផ្តែរដែលនៅខាងក្នុងប្រាង្គប្រាសាទ ប្រៀបបីដូចជានៅក្នុងទ្រូង ឬក្នុងបេះដូង ព្រោះទ្វារបន្ទប់នីមួយៗ បានលាក់ទុកនៅរឿងមួយ ដូចក្នុងចិត្តរបស់បុគ្គលម្នាក់ៗតែងលាក់រឿងទុកក្នុងចិត្តរបស់ខ្លួនដូច្នោះ ដែលរឿងនោះទៀតសោត មានច្រើនពុំអាចនឹងរាប់ចំនួនបាន។ ក្នុងបណ្តារឿងក្នុងចិត្តទាំងអស់ គឺមានតែរឿងទុក្ខសោកស្តាយក្រោយ ដែលខ្លួនបានប្រព្រឹត្តខុសតែប៉ុណ្ណោះ វាតាមដេរស្តីថាបន្ទោសឲ្យខ្លួនរហូត ដែលនាំឲ្យមានការក្តៅក្រហាយចិត្ត (កក្កុច្ចៈចេតសិត) ហើយអកុសលចិត្តនេះតែងឲ្យផលជាទុក្ខក្នុងអបាយភូមិ (ភូមិទុក្ខ)។ ព្រោះបុគ្គលដែលបរិបូណ៌ដោយញាតិ ដោយយសសក្តិ ដោយទ្រព្យសម្បត្តិ ពុំអាចជួយបុគ្គលនោះកុំឲ្យធ្លាក់អបាយភូមិបានឡើយ លុះត្រាតែបុគ្គលដែលបរិបូណ៌ដោយបុណ្យគឺទាន សីល ភាវនា បរិបូណ៌ដោយសម្មាទិដ្ឋិ (ការយល់ត្រូវ).....ទើបអាចជួយបុគ្គលនោះ ឲ្យបានសោយផលក្នុងសុគតិភពបាន ហើយទីបំផុតអាចត្រាស់ដឹងនូវសច្ចៈធម៌ (បើកទ្វារព្រះនិព្វាន្ត) ទៅតាមថ្នាក់មគ្គ និងផលរហូតដល់ទីបំផុតនៃមគ្គ និងផល។

រូបផ្ដែរនៅខាងក្នុងប្រាង្គប្រាសាទនេះ និយាយពីបុរសម្នាក់ ដែលអង្គុយលើក្បាលយក្ស ហើយនឹងរូបនៅពីសង្ខាងរូបកណ្ដាល យើងពុំអាចមើលយល់ឡើយ ព្រោះជនទុច្ចរិតបានដាប់បំផ្លាញក្បាលចោលអស់ហើយ គំនិតរបស់ពួកគេគឺមិនចង់ឲ្យអ្នកទាំងបី រស់រានមានជីវិតឡើយ។ អត្ថន័យក្នុងផ្ដែរនេះ ក៏មិនខុសពីផ្ដែរដែលនៅខាងក្រៅឡើយ គាត់គ្រាន់តែចង់ពន្យល់ពីអាថ៌កំបាំងប្រាប់យើងថា រឿងនៅផ្ដែរខាងក្នុងប្រាង្គ គឺរឿងក្នុងចិត្ត (ក្នុងទ្រូងក្នុងបេះដូង) រឿងនៅផ្ដែរ ឬក្បាំងក្លែងនៅខាងក្រៅ គឺរឿងដែលបាននាំចេញមកផ្សព្វផ្សាយហើយ (លែងលាក់ទុក) គឺរឿងនៅលើមុខ។

សរុបសេចក្ដីមករូបផ្ដែរក្នុងប្រាង្គដែលខ្ញុំបានយកមកបង្ហាញនេះ គ្រាន់តែចង់ឲ្យកូននាគមើលពីកម្លាំងបំផ្លាញរបស់សត្រូវ គឺទាំងខាងក្នុងទាំងខាងក្រៅ ព្រោះពួកគេមិនចង់ឲ្យរឿងដែលគេបានលុបបំបាត់ដាន់រាប់ពាន់ឆ្នាំមកហើយនោះ អាចរស់ឡើងវិញឡើយ។

## ៥៧/.រូបភាពទី៥៧រូបអច្ឆរាញញឹមចេញធ្មេញ(ប្រាសាទអង្គរវត្ត)



ក្នុងចំណោមរូបអច្ឆរារាប់ពាន់ ដែលមាននៅលើប្រាសាទអង្គរវត្ត ភាគច្រើនគឺបិទមាត់ ហើយក្នុងចំណោមរូបទាំងនោះ មានតែអច្ឆរាពីរប៉ុណ្ណោះបើតាមខ្ញុំដឹង គឺរូបមួយលានអណ្ដាត និងរូបមួយទៀតញញឹមចេញធ្មេញ។ ហើយរូបអច្ឆរាញញឹមចេញធ្មេញនេះ ក៏នៅក្នុងអំណាចក្រុងរបស់យក្សនៅឡើយ ព្រោះសុទ្ធតែក្បាច់ឋាន ដែលនៅបង្កប់ពីខាងក្រោយរូប តែមានរូបក្បាលយក្សដៃចាប់កាន់ និងមាត់ខាំពាំរាជបញ្ជារបស់ខ្លួន (មិនទាន់ព្រមលើកលែងទោស ឬលើករាជបញ្ជាឡើង) ដូចអត្ថន័យរូបមុន ដែលខ្ញុំបានពន្យល់ហើយ។ ធ្មេញគឺមានន័យថា គាត់អាចបង្ហាញនៅអាថ៌កំបាំងក្នុងមាត់ ដែលពីមុនពុំអាចហាមាត់

រួចនោះ ឥឡូវនេះគាត់ចាប់ផ្ដើមអាចបញ្ចេញរឿងអាថ៌កំបាំងក្នុងចិត្ត ចេញមកខាងក្រៅបានខ្លះហើយ តាមរយសូរសព្ទវាចា នឹងតាមរយអត្ថបទ។ ហើយរូបអប្សរានេះ ព្រឹទ្ធដូនតាគាត់បានឆ្លាក់នៅលើជញ្ជាំងជិតផ្លូវចេញមកខាងក្រៅ ច្រកចំហៀងវិស្ណុអង្គធំ (តារាជ) ព្រោះគាត់ដឹងថា រឿងរបស់អច្ឆរាពុំអាចនាំចេញដោយបើកចំហបានឡើយ គឺអច្ឆរមាតាលោកចេញមកដោយលួចលាក់ និងស្ងៀមស្ងាត់ ព្រោះកូននាគដែលនាំរឿងរបស់លោកចេញ ពុំមានឫទ្ធិអំណាច និងកំឡាំងគ្រប់គ្រាន់ អាចធ្វើការផ្សព្វផ្សាយរឿងបានដោយងាយស្រួលនោះឡើយ។

នៅជាន់ខាងលើអច្ឆរា មានរូបមនុស្សកំពុងជិះសត្វក្ដាន់ឬរមាំង ហើយសត្វរមាំងនោះ ងើបឈរជើងពីរឡើងទៅលើ (កញ្ច្រោល) ពុំព្រមដាក់ជើងមុខចុះទៅក្រោមឡើយ ដើម្បីដើរចេញតាមច្រកផ្លូវដែលតោកំពុងជ្រោងបើក។ ដូច្នេះទើបអ្នកជិះរមាំងនោះ យកជើងគាត់មួយចំហៀងទៅជាន់ជើងមុខរបស់សត្វរមាំងនោះ ឲ្យព្រមទំលាក់ខ្លួនឱនចុះ ទើបអាចចេញតាមទ្វារដ៏ទាប ដែលតោកំពុងប្រឹងជ្រោងបើកនោះរួច។ បុរសជិះរមាំងពីខាងលើនោះ តំណាងឲ្យព្រះវិស្ណុឬកូននាគមានភារកិច្ចត្រូវនាំរឿងរបស់អច្ឆរា ដែលបានលាក់កប់ទុករាប់ពាន់ឆ្នាំក្នុងសមុទ្រទឹកដោះនោះ ដើម្បីយកចេញមកផ្សព្វផ្សាយខាងក្រៅ។ ឯសត្វរមាំង តំណាងឲ្យយានជំនិះ ឬមនុស្សដែលមានកិច្ចក្នុងការជួយដល់អ្នកជិះខាងលើ ដើម្បីនាំរឿងចេញតាមច្រកទ្វារតោ គឺតាមច្រកទ្វារសត្វសីហៈ (មើលការពន្យល់ពីសត្វតោក្នុងរូបមុន) ព្រោះរឿងសាសនបណ្ដាំអច្ឆរមាតានេះ ត្រូវបានផ្សព្វផ្សាយចេញតាមច្រកទ្វារតោនេះ។ អច្ឆរមាតាអាចបង្ហាញពីធ្មេញ ដែលធ្លាប់តែលាក់បិទនោះ (បុកលាក់ ធ្វើធ្មេញ បន្សាបពិសនាគ) ត្រូវពឹងផ្អែកទៅលើកូននាគខាងលើ និងច្រកទ្វាររាជសីជ្រោងបើកខាងលើនោះឯង ព្រោះអាថ៌កំបាំងដែលគាត់រងទុក្ខ នៅក្នុងសមុទ្រទឹកដោះ គឺលោកសង្ឃឹមទៅលើកូននាគណាដែលព្រមចុះទៅក្នុងសមុទ្រទឹកដោះ ស្វែងរកដំណក់ទឹកអម្រឹតរបស់គាត់តែប៉ុណ្ណោះ (នេះជានិមិត្តរូបផ្លូវ ដែលកូននាគចេញ)។

សរុបសេចក្ដីមកមាតាមហានគរឬអច្ឆរមាតាលោកមានសង្ឃឹមថា រឿងដែលលោកទទួលទុក្ខរាប់ពាន់ឆ្នាំ ក្នុងសមុទ្រទឹកដោះនៅខាងក្នុងប្រាសាទនោះ ជិតចេញផុតពីទ្វារទុក្ខហើយ ព្រោះបេះដូងថ្មបាននិយាយប្រាប់យើងជាកូននាគប្រុសស្រី ឲ្យដឹងពីរឿងពិតក្នុងជីវិតថ្ម ដែលខំទ្រាំឈរហាលភ្លៀងហាលថ្ងៃ និងក្រោមគំនាបដាប់បំផ្លាញរបស់ជនទុច្ចរិត ពីគ្រប់ទិសទី ក្នុងពេលនេះ **អច្ឆរមាតាបានបង្ហាញធ្មេញ បញ្ចេញសូរសព្ទរបស់ខ្លួនហើយ។**

## ៥៨/.រូបភាពទី៥៨រូបផ្ដែរ(ប្រាសាទប្រែរូប)



ប្រាសាទនេះ អ្នកប្រាជ្ញបរទេសស្រាវជ្រាវភាសារូប បានពន្យល់ថាជាកន្លែងសម្រាប់បូជាសពព្រះរាជា ព្រោះអាចារ្យយោគីពេលដែលបូជាសពតែងប្រើពាក្យថា ប្រែរូបចាស់ផ្លាស់រូបថ្មី (រូបចាស់ត្រូវដុតឆេះអស់ រូបថ្មីសល់តែធាតុ) រូបចាស់គឺទឹក ដី ភ្លើង ខ្យល់ដែលមានពីមុន ឯរូបថ្មីគឺធាតុដែលនៅសល់ពីការបូជានោះ។ បើយើងមើលរូបក្នុងផ្ដែរដែលនៅសេសសល់នេះ បេះដូងរូបបានប្រាប់យើងថាមានបុរសម្នាក់មុខតោ ឬរាជសី កំពុងបីព្រះមាតាដាក់លើភ្លៅទាំងសង្ខាង ហើយកូននាគនោះផ្សះផ្សារប្រស់ឲ្យគាត់រស់ឡើងវិញ (មើលការពន្យល់រូបទី៣៤) គឺប្រែរូបពីស្លាប់ឲ្យរស់ ប្រែពីផ្កាប់មកផ្ងារ ប្រែរូបរឿងដែលនៅខាងក្នុងថ្មពីមុនកូននាគមិនដឹង ឲ្យមកដឹងរឿងពិតន័យរបស់រូបថ្មទាំងនោះ....។ល។ នៅក្នុងទ្រនុងខ្នងនាគនិមិត្តរូបទាំងសង្ខាង មានរូបមនុស្សកំពុងលើកដៃរាំ (មើលការពន្យល់រូបទី៣៧) ហើយចុងក្រោយរូបតូចៗទាំងនេះ បានរីកធំនៅក្នុងក្បាលនាគនិមិត្តរូបខាងចុង រូបនេះតំណាងឲ្យព្រះវិស្ណុ ឥសូរ លោកេស្វរៈ......ដែលជាកូននាគត្រូវមកជួយមាតានាគ (មើលការពន្យល់រូបមុនៗ)។ នៅក្រោមក្បាច់តំណាងឲ្យខ្លួននាគនិមិត្តរូបនោះ មានរូបមនុស្សពាក់កណ្ដាលខ្លួនតូចៗបីសង្ខាង គឺតំណាងឲ្យព្រះមាតានាគ ដែលសកម្មភាពរូបកំពុងលើកដៃសំពះអង្វរ ចំពោះកូននាគប្រុសស្រីមានក្ដីអាណិតមេត្តាជួយដល់គាត់ផង (ទំនួញប្រែត) តើឲ្យកូននាគទាំងអស់ជួយដូចម្ដេចទៅ? កុំថាឡើយជួយ គ្រាន់តែដឹងរឿងរបស់ព្រះម៉ែមហានគរ ក៏ពុំមាននរណាដឹងផង ព្រោះដានស្នាមរបស់គាត់ត្រូវគេបិទ គេលុប គេចុក គេសន្ធប់ជិតអស់ទៅហើយ។ ក្នុងរូបនេះ រឿងរបស់គាត់បានលាក់ទុកក្នុងព្រៃ

ក្បាច់ជ័ញ្ជីកស្ពែកស្ពះ សូម្បីតែចាប់អារម្មណ៍ក៏មិនចាប់ផង ព្រោះឯកសារក្នុងថ្មទាំងនេះ បរទេសបាន ពន្យល់ថា ជាផ្ទូរ ប៉ាឆា ហើយពាក្យនេះបានជិតក្នុងសន្ដានកូនខ្មែររាប់រយឆ្នាំកន្លងមកហើយ។

សរុបសេចក្ដីមករអត្ថន័យរឿងក្នុងផ្ទៃរប្រាសាទនេះ ក៏មិនខុសពីផ្ទៃរក្នុងប្រាសាទដទៃទៀតដែរ ដែលខ្ញុំលើកយកមកបង្ហាញនេះ គ្រាន់តែចង់ឲ្យកូននាគឆ្លុះបញ្ចាំងជាមួយរូបទី៣៤ ដែលគេបានដាប់ ក្បាលរូបចោល យើងអាចមើលរូបក្នុងផ្ទៃរនេះ ទៅប្រៀបធៀបនឹងផ្ទៃរនោះ យើងនឹងដឹងថា បុគ្គល ដែលគេដាប់ក្បាលចោលក្នុងរូបទី៣៤ គឺមានក្បាលជាតោឬរាជសី ព្រោះសកម្មភាពរូប គឺស្រដៀង គ្នា។

## ៥៩/.រូបភាពទី៥៩រូបនៅជញ្ជាំង(ប្រាសាទអង្គរវត្ត)



រូបភាពក្នុងជញ្ជាំងនេះ បានបង្ហាញពីសកម្មភាពអច្ឆរមាតា កំពុងអង្គុយបញ្ឈរជង្គង់នៅលើ អង្រឹងស្នែង ដែលមុខមាត់គាត់ពុំមានភ្នែកច្រមុះពិតប្រាកដឡើយ គឺមានតែរាងមុខប៉ុណ្ណោះ (បិស្នា កំបាំងដែលកូននាគសព្វថ្ងៃពុំស្គាល់មុខមាត់ពិតរបស់គាត់)។ ហើយអ្នកដែលកំពុងសែងអង្រឹងស្នែង

ដងស្នែងទាំងសង្ខាងមានសុទ្ធតែក្បាលនាគ អ្នកសែងទាំងនោះមានដំណើរឈានទៅមុខយ៉ាងស្វាហាប់ តើក្នុងរូបនេះគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

១/.អច្ឆរាដែលអង្គុយក្នុងអង្រឹងស្នែង ដែលមានដំបូលគ្របខាងលើវិចិត្រទៅដោយក្បូរក្បាច់មានរាងដូចជាដំបូលប្រាសាទនោះ ស្ត្រីនេះតំណាងឲ្យ អច្ឆរមាតា ឬព្រះម៉ែមហានគរ ព្រោះគេបានឆ្លាក់មុខគាត់ពុំមានច្រមុះមាត់ឡើយ គឺមានតែទម្រង់មុខដែលមានពាក់ក្បាំងតំណាងឲ្យអច្ឆរាតែប៉ុណ្ណោះ។ ក្នុងរូបនេះគាត់ចង់ប្រាប់យើងថា សព្វថ្ងៃនេះមានកូននាគតិចណាស់បានស្គាល់អច្ឆរាដែលជាអ្នកបង្កើតភាពអច្ឆរិយៈនេះឡើង ព្រោះរឿងពិតរបស់គាត់គេបានលុបបំបាត់ដានអស់ទៅហើយ ប្រៀបដូចជាមុខរបស់គាត់ក្នុងរូបនេះ នៅសល់តែមកុដតែប៉ុណ្ណោះ រីឯមុខមាត់ពិតប្រាកដត្រូវបានរលុបអស់ហើយ។ ដៃគាត់ខាងស្ដាំ កំពុងហុចរបស់ម្យ៉ាងឲ្យកូនក្មេងដែលនៅឈរខាងក្រោម ព្រោះគាត់មានសង្ឃឹមថា ថ្ងៃក្រោយកូននោះនឹងស្គាល់មុខមាត់ពិតរបស់គាត់ តាមរយៈសសៃរខ្សែមានបន្ដោងដែលគាត់បានហុចឲ្យ គេនឹងធ្វើការស្រាវជ្រាវរកប្រភពដើមកំណើតពិតពីរបស់នោះ។ តែគួរឲ្យសង្វេគណាស់ កំភួនដៃគាត់ត្រូវបានជនទុច្ចរិតដាប់បំផ្លាញអស់ហើយ ព្រោះគំនិតអ្នកដាប់ គេមិនចង់ឲ្យអច្ឆរានេះ ហុចវត្ថុដែលនៅក្នុងដៃមកឲ្យក្មេងដែលឈរពីខាងក្រោមបាន។

២/.ក្មេងខាងក្រោមដែលកំពុងឈរនៅលើចិញ្ចើមផ្លូវខាងស្ដាំ ហើយដៃលើកទទួលនូវវត្ថុ ដែលស្ត្រីក្នុងអង្រឹងស្នែងខាងលើហុចឲ្យនោះ គឺតំណាងឲ្យកូននាគដែលបានទទួលប្រស្នាកំបាំង មរតករបស់ស្ត្រីអច្ឆរាខាងលើ ក្មេងនេះទៀតសោត ពូជពង្សឋានៈរបស់គាត់ស្មើនឹងអ្នកលក់ដូរតាមចិញ្ចើមថ្នល់ ព្រោះក្មេងនោះគឺជាកូនស្ត្រីម្នាក់ កំពុងអង្គុយលុតជង្គង់ដាក់កញ្ជើលក់នោះឯង។ ដូច្នេះអាចកំបាំងមរតកស្ត្រីជាអច្ឆរា គ្មានមុខនៅក្នុងអង្រឹងស្នែងខាងលើនោះ រឿងរបស់គាត់ថ្ងៃក្រោយគឺមានតែក្មេងម្នាក់ ដែលជាពូជពង្សអ្នកលក់ដូរតាមចិញ្ចើមថ្នល់នេះទេ ដែលដឹងរឿងរបស់គាត់ ហើយក្មេងនេះអាចនឹងបើកមុខមាត់ពិត របស់ស្ត្រីដែលនៅក្នុងអង្រឹងស្នែងខាងលើបាន។ ចំណែកឯម្ដាយរបស់ក្មេងនោះវិញ គាត់ពុំបានដឹងរឿងដែលកូននេះ បានទទួលមរតកពីស្ត្រីដែលនៅក្នុងអង្រឹងស្នែងខាងលើឡើយ ព្រោះគាត់រវល់តែលក់ដូរងាកមើលទៅខាងក្រោយ (មើលរូប) សម្លៀកបំពាក់ដែលក្មេងនោះបានស្លៀក ស្រដៀងនឹងសំពត់ដែលអច្ឆរមាតាខាងលើបានស្លៀក គ្រាន់តែសំពត់របស់ក្មេងមានទំហំតូចជាងតែប៉ុណ្ណោះ។

ដំបូលដែលអ្នកប្រៀងទូដើរសង្ហាងតាមអង្រឹងស្នែងខាងលើនោះ គឺមានរូបរាងដូចជាគម្រប ម្ឈូសសព្វថ្ងៃនេះ មានន័យថា គេកំពុងសែងគាត់យកទៅឃុំ ទៅគ្របលាក់ទុក ប្រៀបបីដូចមនុស្សរស់ ក៏ប៉ុន្តែឈ្មោះថាដេកស្លាប់ ព្រោះរឿងពិតរបស់អច្ឆរមាតា (បិសាចពស់ ឬបិសាចនាគ) បានស្លាប់ពី ក្នុងសន្តានចិត្តកូននាគប្រុសស្រីអស់ទៅហើយ (ព្រោះខ្មែរពុំបានដឹងពីសាសនអច្ឆរមាតា) មនុស្សរស់ តែដេកក្នុងម្ឈូស។

## ៦០/.រូបភាពទី៦០រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី

តើអត្ថន័យក្នុងក្បាំងក្លែងនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?



១/.ជាប់ខាងលើក្នុងក្បាំងក្លែង គឺរូបមនុស្សម្នាក់កំពុងរៀបងើបឈរ ដៃម្ខាងលើករាំ ដៃម្ខាង ទៀតកាន់រាជសាររឿងក្នុងដៃ រូបនេះត្រូវគ្របជាប់ក្នុងក្បាំងតូចមួយផ្សេងទៀត ហើយគាត់ជិះលើដំរី ក្បាលបី ដែលរូបដំរីត្រូវរលកទឹកបិទបាំងជើងខាងក្រោម។ ដៃកាន់រាជសារ តំណាងឲ្យរឿងមាតាលាក់ ទុកក្នុងបេះដូងថ្ម ដែលគាត់ត្រូវយកមកផ្សព្វផ្សាយប្រាប់ ដៃលើករាំតំណាងឲ្យ វិជ្ជាជីវៈរបស់គាត់ (ពន្យល់រួចហើយក្នុងរូបមុន) ហើយគាត់ជិះលើដំរីក្បាលបី គឺគាត់អាចដឹងពីអាថិកំបាំងក្នុងបេះដូងដំរី ទាំងនេះ ថាក្នុងអតីតកាលកន្លងទៅដំរីនេះ មានក្បាលតែមួយទេ (ពន្យល់រួចហើយ)។

២/.មនុស្សលើកដៃសំពះបន្ទួលទៅលើនៅពីសង្ខាង ដែលកំពុងងើបក្បាលរួចពីក្នុងទឹកត្រឹមចង្កេះនោះ គឺពួកគាត់តំណាងឲ្យមាតាទាំង១២ ឬឆ្នាំ និងខែទាំង១២ ក្នុងមាតុភូមិនេះ មានន័យថាកែវភ្នែកដែលធ្លាប់តែងងឹតដោយអំណាចយក្សខ្វេះជាយូរយារណាស់មកហើយនោះ ឥឡូវនេះពួកគាត់អាចមើលឃើញរឿងពិតរបស់ខ្លួនបន្តិចម្ដងៗហើយ។ ស្ត្រីទាំងនោះ មានចំនួនម្ខាង៥នាក់ៗ សរុបទៅគឺមានចំនួន១០នាក់ ចំណែកឯពីរនាក់ទៀត នៅមិនទាន់ដឹងសាវតាពិតរបស់ខ្លួនឡើយ ហើយពួកគាត់ទាំង១០នាក់នេះ កំពុងលើកដៃបន្ទួលងើយក្បាល ទៅមើលបុរសដែលជិះនៅលើដំរីក្បាលបីខាងលើ ហាក់បីដូចជាចង់ប្រាប់ថា ឲ្យកូននោះខំប្រឹងប្រែងព្យាយាមតស៊ូបន្តទៅទៀត ដើម្បីរើខ្លួនឲ្យរួចពីក្បាំង ឬអង្រៀតដែលក្រុងគ្របពីខាងលើ តាំងពីក្បាំងតូចរហូតទៅដល់ក្បាំងធំទាំងបីជាន់ខាងលើ កុំឲ្យកូនដាក់ធុរៈធ្ងន់នេះចុះ ព្រោះពួកគាត់មានក្ដីសង្ឃឹមទៅលើកូននាគនោះទាំងស្រុង។

៣/.ខាងក្រោមបន្ទាប់ គឺមានរលកទឹកត្រួតគ្នាជាន់ៗ ខាងក្រោមរលកទឹកជាន់ៗនោះ គឺមានបន្ទាត់ឆូតៗពីរជាន់ មើលទៅហាក់បីដូចជាសសៃរទឹកភ្លៀង ដែលត្រូវហូរធ្លាក់ពីរលកទឹកខាងលើ តើទឹកនេះតំណាងឲ្យអ្វី? ទឹកនេះគឺតំណាងឲ្យ រលកទឹកចិត្ត មនោគមវិជ្ជាបរទេស ដែលធ្លាប់បានមកគ្របសង្កត់បិទបាំង និងធ្វើអាណានិគម មកលើទឹកចិត្តកូនខ្មែរបំភាន់នៅការពិត តាំងពីអតីតកាលមកនោះ ដូច្នេះទើបមនុស្សសត្វដែលនៅខាងក្រោមទឹកនោះ មិនលង់ទឹកស្លាប់ ហើយមិនត្រឹមតែមិនលង់ទឹកនោះស្លាប់ទេ រូបទាំងនោះកំពុងមានសកម្មភាពបររថប្រឈមមុខដាក់គ្នាថែមទៀត។

៤/.នៅខាងក្រោមរលកទឹកនោះ ចំកណ្ដាលមានក្បាលនាគពីរកំពុងបន្តឡើងត្រួតគ្នា តើតំណាងឲ្យអ្វី? នាគទាំងពីនោះ គឺតំណាងឲ្យព្រះមាតានាគ ដែលខំប្រឹងប្រែងងើបចេញពីខាងក្រោម ដើម្បីឲ្យរួចពីការឃុំគ្រងរបស់យក្ស និងបក្សពួក ដោយអំណាចកូនខាងលើបានជួយបើកទ្វារឃុំទាំង៣ ហើយការប្រឹងងើបរបស់គាត់ជាលើកទីពីរនោះ គឺអព្ភូតហេតុដែលកើតមានឡើង កាលពីឆ្នាំកន្លងទៅនៅក្នុងទន្លេបួនមុខ។ អព្ភូតហេតុក្នុងពេលនោះ គឺដូចជាខ្យល់កួចទឹកទៅលើ ដើម្បីទំលុះពពកនៅខាងលើ ដែលខ្យល់អព្ភូតហេតុធម្មជាតិនោះ មានរាងដូចជាខ្លួននាគ ប៉ុន្តែគាត់ពុំទាន់មានកម្លាំងឡើងទៅខាងលើរួចឡើយ គឺមានរូបក្នុងក្បាំងភ្លែងនេះ តំណាងឲ្យគាត់ជាភស្តុតាងស្រាប់។ អព្ភូតហេតុនេះទៀតសោត កើតឡើងក្នុងថ្ងៃ១៤រោច ខែភទ្របទ គឺមុនភ្ជុំបិណ្ឌមួយថ្ងៃ ដែលគាត់ខំស្ទុះឡើងមុខព្រះបរមរាជវាំងកណ្ដាលក្រុងភ្នំពេញ ហើយក្នុងរដូវបិណ្ឌភ្ជុំទៀត ព្រោះគាត់ចង់ឲ្យកូននាគទាំងអស់ឧទ្ទិសបុណ្យជូនទៅឲ្យគាត់ (ពេលដែលត្រូវឧទ្ទិសបុណ្យជូនប្រេត) តែជាការឥតប្រយោជន៍

សោះ ព្រោះគ្មានកូននាគណាម្នាក់បានដឹង ពីអាថ៌កំបាំងក្នុងបេះដូងរបស់គាត់ឡើយ បានត្រឹមតែទៅឈរមើលតែប៉ុណ្ណោះ។

៥/.សត្វករវិកមួយជួរកំពុងហើរបញ្ច្រាសទិសគ្នា តើតំណាងអ្វី? អាថ៌កំបាំងមហិទ្ធិឫទ្ធិសម្លេងសត្វករវិកនេះ ខ្ញុំបានពន្យល់ក្នុងរូបទី១ និងទី២រួចហើយ។ សត្វនេះតំណាងឲ្យសកម្មជនដែលជាអ្នកផ្សព្វផ្សាយ រលកមនោគមវិជ្ជាបរទេសខាងលើ ដែលបិទគ្របពីខាងលើនោះ ដើម្បីកុំឲ្យអ្នកដែលនៅខាងក្រោម ដឹងរឿងនៅពីខាងលើទឹក។

៦/.ឯជាន់ខាងក្រោម ដូចជានៅលើដី ឬលើភក់ មានរូបសត្វជាច្រើនដូចជា ដំរី គោ ក្ដាន់ រមាំង ឈ្លូស ស្វា...... និងមានមនុស្សជិះរថសង្វាង ដែលរថនោះទឹមដោយសេះដែលមានដុះស្នែងមួយ ហើយអ្នកដែលជិះរថនោះ មានកាន់អាវុធនៅក្នុងដៃ តើរូបទាំងនេះ តំណាងឲ្យអ្វី? រូបសត្វទាំងអស់ តំណាងឲ្យឈ្មោះខេត្តក្រុងពីអតីត ហើយសត្វដែលតំណាងឲ្យខេត្តក្រុងទាំងនេះ កំពុងតែផ្អើលរត់ជាន់គ្នាដោយភ័យខ្លាចនឹងការប្រយុទ្ធរបស់អ្នកទាំងសង្វាង ចំណែករូបមនុស្សដែលជិះរថទាំងសង្វាងនោះ តំណាងឲ្យកូននាគ។

៧/.ចុងនៃក្បាំងក្លែងនេះ មានគោពីរ ឬគុជសីនៅសង្វាង កំពុងរើខ្លួនចេញពីមាត់យក្ស ដែលនៅក្នុងមាត់មានពាំចង្វាយផ្កាជារាងប្រទីប បានបាក់បែកខាងគល់អស់ទៅហើយ នៅសល់តែខាងចុងអាចឲ្យយើងមើលដឹងថាជាប្រទីប ដែលប្រទីបនេះមិនទាន់អាចលើកបំភ្លឺរួចនៅឡើយ។ ដៃគោកំពុងជ្រែងដូច្នេះគោនេះ មិនទាន់មានដៃអាចចាប់លើកគប់ភ្លើងឡើងរួចឡើយ នៅពីក្រោយគោមាននិមិត្តរូបក្បាលនាគគ្របពីខាងលើ មានន័យថាគោនេះ កើតចេញពីក្នុងភូមិនាគ ឬមាតុភូមិ។

៨/.ក្បាំងជាន់ទី២មានគ្រុឌសង្វាង កំពុងក្អែនាគចេញពីមាត់របស់ខ្លួន ហើយនឹងកំពុងចេញពីមាត់យក្ស (សូមមើលការពន្យល់ក្នុងរូបទី៨) ឯក្បាំងជាន់ទីបីពុំមានរូប ខ្ញុំពុំអាចពន្យល់បានឡើយ។

សរុបសេចក្ដីមកអត្ថន័យរូបនៅក្នុងក្បាំងក្លែងនេះ បើយើងមើលមួយភ្លែតហាក់ដូចជាធម្មតា តែបើយើងមើលរួចគិតត្រិះរិះពិចារណា ទើបយើងស្ងើចសសើរបញ្ញាអច្ឆរមាតា គឺពិតជាអ្នកបង្កើតមាតុភូមិអច្ឆរយ:នេះមែន ព្រោះសូម្បីតែរូបក្នុងថ្ម ក៏បង្កប់ទៅដោយគតិបណ្ឌិតដ៏ជ្រាលជ្រៅ ដែលយើងជាកូននាគសម័យនេះ កំពុងបានទទួលនៅមរតករបស់គាត់ ក៏លំបាកនឹងទម្លុះបំបែកគំនិតប្រស្នាអាថ៌កំបាំងក្នុងថ្មទាំងនោះណាស់។ សិល្បអច្ឆរិយ:ទាំងអស់ មានតែនៅក្នុងក្បាំងដែលពាក់លើ

ក្បាលព្រះម៉ែអច្ឆរនាគទេ ឯបរទេសដែលគេថាសិល្បយើងចម្លងពីខាងក្រៅនោះ គឺពួកគេនិយាយបំផ្លើស បំភាន់ កុហកយើងតែប៉ុណ្ណោះ **វាមិនដែលក្នុងក្បាំងអច្ឆរា (មាតានាគ) ដល់ពេលចារឹករឿងរូបបែរទៅជាជាប់ឆ្លាក់រឿងខាងក្រៅក្បាលខ្លួនទៅវិញ** (នេះជាប្រស្នានៅក្នុងរឿងឥសីមាត់ទិព្វ ដែលព្រះថៅទិព្វវង្សបានជិះសត្វមាស ទៅប្រស់អ្នកនគរដែលបានក្លាយជាថ្ម ឲ្យរូបថ្មទាំង នោះបានរស់ឡើងវិញ ពន្យល់នៅក្នុងភាគ២ពីប្រាសាទគុករមាស)។

## ៦១/.រូបភាពទី៦១រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី



រូបរឿងក្នុងក្បាំងក្លែងនេះ នៅចំកណ្ដាលមានរូបយក្សមួយកំពុងច្រានបុរសម្នាក់ មានពាក់មកុដឲ្យធ្លាក់ទៅក្រោម បើយើងមើលតាមសកម្មភាពរូប តើអត្ថន័យក្នុងក្បាំងនេះ អច្ឆរមាតាគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

១/.យក្សតំណាងឲ្យអ្នកដែលចាប់មាតាបិតាយកទៅឃុំពីអតីតកាល ហើយពេលនេះគាត់កំពុងច្រានទម្លាក់មនុស្សម្នាក់ឲ្យធ្លាក់ចុះមកក្រោម ព្រោះមិនចង់ឲ្យបុរសនេះ នៅរស់រានមានជីវិតឡើយ។

២/.មនុស្សប្រុសម្នាក់មានដុះពុកមាត់ ពាក់មកុដ ទងត្រចៀកមានពាក់ក្រវិលធ្លាក់យាចុះមកក្រោមតាមក្បាលនោះ គឺតំណាងឲ្យកូននាគ ដែលត្រូវមកជួយព្រះមាតាបិតាឲ្យរួចពីអំណាចឃុំរបស់យក្ស។ ទោះបីជាគាត់បានអធិដ្ឋានជីវិតរបស់គាត់ឲ្យទៅយក្សនេះក៏ដោយ ក៏គាត់នៅនៅតែព្យាយាមចាប់ទាញដៃយក្ស ព្រោះគាត់ពុំទាន់បានបញ្ចប់រឿងក្ដីយក្ស និងមាតាបិតាមហានគរនៅឡើយ។ គាត់

ត្រូវធ្លាក់មកក្រោម ដោយអំណាចអណ្ដាតយក្ស ដែលយារធ្លាក់មកលើខ្លួនគាត់ តែគាត់មិនទាន់អាចស្លាប់បានទេ ព្រោះព្រះមាតានាគកំពុងសំពះអង្វរកូននៅពីសង្ខាង ឲ្យកូននោះជួយគាត់ផង។

៣/.នៅខាងក្នុងរង្វង់សីមាក្បាច់ខាងឆ្វេង មានរូបស្ត្រីពាក់មកុដចេញពីក្នុងក្បាច់ បានពាក់កណ្ដាលខ្លួនចំនួនពីររូប ដែលដៃគាត់លើកបន្ទូលទៅលើ និងរូបមួយទៀត បានឡើងមកជិតស្មើនឹងកយក្ស។ រូបលើកដៃសំពះសំបូងសង្រ្គង គឺអង្វរដល់កូនដែលយក្សកំពុងរុញទម្លាក់នោះ ឲ្យប្រឹងប្រែងព្យាយាមតស៊ូបន្តទៅមុខទៀត ព្រោះគាត់បានចេញពីសោទាំងបីរួចហើយ ឯរូបទីបីគាត់បានប្រឹងឡើងមកខាងលើ ដៃរបស់គាត់ទាំងសង្ខាងកំពុងជ្រោងបើករង្វង់សីមាយក្ស។ ឯខាងស្ដាំដៃវិញ ក៏មានរូបដូចខាងឆ្វេងដែរ ហើយអត្ថន័យរូបគឺមានន័យដូចគ្នា គ្រាន់តែរូបមួយចំហៀង តំណាងឲ្យអតីតកាល និងមួយចំហៀងទៀតគឺបច្ចុប្បន្នកាល។ រូបស្ត្រីតូចទាំងបីសង្ខាងនេះ តំណាងឲ្យមាតាមហានគរឬអច្ឆរមាតា ដែលលោកកំពុងព្យាយាមចេញពីទ្វារគុកទាំងបួនជាន់ ដែលកូនត្រូវយក្សច្រានខាងលើជាអ្នកមកបើកទ្វារឃុំនេះ។

៤/.ចុងសង្ខាងក្បាំងក្លែងនេះមានរូបសត្វគុជសី កំពុងរើខ្លួនចេញពីមាត់យក្ស បានជិតពាក់កណ្ដាលខ្លួនហើយ ឯប្រមោយសត្វគុជសីកំពុងចាប់បួងគប់ភ្លើង (អាថ៌កំបាំងមាតា) តែពុំទាន់អាចលើករួច ព្រោះខ្លួនទើបតែចេញមកខាងក្រៅបានពាក់កណ្ដាល តើរូបនេះ តំណាងឲ្យអ្វី? គុជសីតំណាងឲ្យទីក្រុងពីររលាយចូលគ្នា (ពន្យល់រួចហើយ) គប់ភ្លើងតំណាងឲ្យកែវភ្នែកទាំង១២ ដែលត្រូវយកមកដាក់ឲ្យភ្លឺឡើងវិញ តែពុំទាន់អាចលើកបញ្ឈរគប់រួចឡើយ ដោយសារខ្លួនទើបតែរួចផុតពីអំណាចយក្សបានត្រឹមតែពាក់កណ្ដាល។

សរុបសេចក្ដីមកអច្ឆរមាតាក្ដី គុជសីក្ដី ជាពិសេសកូននាគដែលយក្សរុញច្រានទម្លាក់ពីខាងលើនោះក្ដី បានធ្លាក់ខ្លួនពិការ ត្រូវដេកវាលូន ដឹកនាំអច្ឆរមាតាចេញពីឃុំ ដែលនៅសល់ពាក់កណ្ដាលខ្លួនទៀត (មើលពាក្យល្វាទេ ឬវិស្ណុដេកក្នុងភាគ២) ទើបអាចលើកគប់ភ្លើងដែលជាកែវភ្នែកអច្ឆរមាតាមហានគរនេះ ឲ្យឈរឡើងបំភ្លឺរឿងពិតបាន ព្រោះក្រោយពេលដែលយក្សបានរុញច្រានទំលាក់ហើយនោះ គាត់ត្រូវធ្លាក់ខ្លួពិការ (នេះជាប្រស្នារូប)។

# ៦២/.រូបភាពទី៦២រូបនៅ(ប្រាសាទបន្ទាយស្រី



តើសកម្មភាពក្នុងរូបនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

ក/.រូបខាងលើបល្ល័ង្ក មានបុរសម្នាក់ស្ត្រីម្នាក់ ហើយបុរស គឺតំណាងឲ្យកូននាគ ដែលនាំមាតាតាំងពីទ្វារគុកទីមួយ រហូតដល់ទ្វារគុកចុងក្រោយ។ សកម្មភាពរបស់កូនប្រុសនោះ ដៃម្ខាងគ្រាកចង្កេះម្ដាយអូសចេញ ដៃម្ខាងទៀតច្រានរុញខ្លោងទ្វារ ដើម្បីនាំព្រះម៉ែចេញ។ ឯព្រះម៉ែវិញ ដៃម្ខាងរុញចង្កេះកូនចេញ និងដៃម្ខាងទៀតតោងចាប់ខ្លោងទ្វារ ហាក់បីដូចពុំចង់ចេញពីមាត់ទ្វារឃុំឃាំងឡើយ តើមកពីមូលហេតុអ្វី?

នៅត្រចៀកស្ត្រីនេះ មានពាក់ក្រវិលដូចរូបស្ត្រីគ្រប់លក្ខណ គឺគាត់តំណាងឲ្យមាតាមហានគរ ដែលគេក្រុងបិទសន្ធប់គ្របលាក់ទុករឿងរបស់គាត់ រាប់ពាន់ឆ្នាំមកហើយ។ ហេតុដែលគាត់ពុំព្រមចង់ចេញ ព្រោះគាត់មានសេចក្ដីប្រកាន់មាំថា កាលគាត់ទៅទទួលទោស គែហែហាមគាត់ទៅដោយមានត្រែស្នែងដ៏វិចិត្រ (មើលរូបទី៥៩) ហើយមានកូននាគមួយនគរ ហែហាមគាត់ ព្រោះគេបានដឹងពីឧបការគុណរបស់គាត់។ តែឥឡូវមានតែកូននាគម្នាក់មកយាងអញ្ជើញ មកទទួលគាត់ចេញ ដូចនេះ

គាត់គិតត្រិះរិះក្នុងចិត្តថា កូនគាត់មានរាប់លាននាក់កំពុងទទួលមរតករបស់គាត់ (ខ្មែរ) តែគ្មាននរណាមកហែហមអបអរសាទរ ទទួលដំណើរដែលគាត់ចេញពីទីទុក្ខសោះ ហេតុនេះទើបវាចាគំនិតក្នុងរូបនេះ បានបញ្ជាក់ពីសកម្មភាពរបស់គាត់ក្រាញពុំព្រមចេញ។

ខ/.នៅពីខាងក្រោមបល្ល័ង្កចំកណ្ដាល មានរូបសេះចង់ក្រាបមួយ តើតំណាងឲ្យអ្វី? ហេតុអ្វីសេះនេះមានដុះចៃដូចជាជ្រូក? សេះតំណាងឲ្យឆ្នាំមមី តែសេះនេះបើមើលតាមភិនភាគ ដែលមានដុះចៃនោះ គាត់ចង់ប្រាប់យើងថា សេះនោះមានវ័យចាស់ទៅហើយ តាមពិតសេះគ្មានដុះចៃទេ គឺមានតែជ្រូក ហេតុអ្វីបានជាគាត់ឆ្លាក់សេះយ៉ាងដូច្នេះ? ព្រោះដូនតាយើងគាត់ចង់ប្រៀបធៀប បុគ្គលដែលកើតឆ្នាំនេះ គាត់ស៊ូទ្រាំនៅទ្របល្ល័ង្កដ៏ធ្ងន់ ដែលមានមនុស្សនៅឈរខាងលើ បុគ្គលនោះឈរយូរពេកទៅគាត់ពុំអាចព្រំបានក៏ទ្រោមចុះ ម្យ៉ាងទៀតគាត់ចង់ប្រាប់ពីអាយុរបស់បុគ្គលនោះ មានវ័យចម្រើនហើយ (ដុះចៃ) តែគាត់នៅតែជួយស៊ូទ្រាំហែហមលើកជ្រោងព្រះម៉ែចេញ។

គ/.រូបតោដែលជួយលើកដៃទ្របល្ល័ង្ក លើខ្នងសេះទាំងសង្ខាងកំពុងងើយក្បាល ហើយអណ្ដាតក្បាច់ចេញពីមាត់នោះ តំណាងឲ្យខេត្តក្រុង ដែលមានរូបសំណាករបស់ខ្លួន កំពុងងើយស្រែកប្រាប់កូននាគដែលបានទទួលមរតកអច្ឆរមាតា (ខ្មែរ) ឲ្យបានដឹងដំណឹងពីសាវតាពិតរបស់ខ្លួន និងតំណាងឲ្យច្រកទ្វារ។

សង្ខេបសេចក្ដីមកអត្ថន័យភាសាគំនិតក្នុងបេះដូងថ្មនេះ គឺបានបញ្ជាក់ប្រាប់យើង ពីការតស៊ូព្យាយាមអត់ធ្មត់ទ្រាំទ្រនៅការលំបាកគ្រប់បែបយ៉ាង ទាំងអ្នកនៅពីខាងលើ ទាំងអ្នកនៅពីខាងក្រោម ដើម្បីនាំរឿងអច្ឆរមាតាចេញ ទោះបីគេជួយគាំទ្រក្ដី ឬក៏រារាំងក្ដី ដាច់ខាតកូននាគនោះ ត្រូវតែជួយស្រង់ និងប្រស់អច្ឆរមាតា និងនាំរឿងពិតរបស់គាត់ ដែលបានរួចពីបាបកម្ម (ទុក្ខក្នុងសមុទ្រទឹកដោះ) មកប្រាប់ដល់កូននាគ ដែលកំពុងរស់នៅ និងបានទទួលមរតករបស់គាត់ឲ្យបានដឹង។

## ៦៣/.រូបភាពទី៦៣រូបនៅជញ្ជាំង(ប្រាសាទតាព្រហ្ម)

រូបភាពក្នុងជញ្ជាំងនេះ មើលទៅហាក់បីដូចជាមានសកម្មភាពរស់រវើក ទោះបីជាការដាប់ឆ្លាក់ពុំសូវមានសោភ័ណភាពក៏ដោយ ក៏រូបក្នុងផ្ទាំងនេះ មានបង្កប់អាថិកំបាំងមួយដ៏ជ្រាលជ្រៅ តើអាថិកំបាំងក្នុងសិលាចារឹករូបនេះ គាត់ចង់ប្រាប់យើងពីរឿងអ្វី?



*ក/.រូបនៅចំកណ្ដាល គឺតំណាងឲ្យអប្សរមាតា (ព្រះមាតាមហានគរ) ដែលលោកកំពុងចាកចេញពីភក់ខាងក្រោម (ថ្មភក់) ព្រោះដោយរូបលោកឈរនៅលើផ្កាឈូក ដែលកំពុងដុះចេញពីភក់ ផ្កាឈូកនោះបានរុញច្រានលោក ឲ្យបានឡើងទៅបល្ល័ង្កធំខាងលើវិញ (មាតុភូមិ)។ បល្ល័ង្កធំខាងលើនេះពីមុននៅទទេ (មើលការពន្យល់ប្រាសាទបាយ័ន្តកោរភាគ១ និងភាគ២) ដោយម្ចាស់បល្ល័ង្ក (មាតានាគ) បានចុះទៅកប់ក្នុងភក់ (អបាយភូមិ) ហើយភក់ដែលកប់ម្ចាស់បល្ល័ង្កនោះ បានរឹងក្លាយទៅជាថ្មគឺ**ថ្មភក់** ដែលកូនគាត់បានយកមកកសាងប្រាសាទថ្មរាប់ពាន់ ហើយឆ្លាក់រឿងក្នុងបេះដូងរបស់អច្ឆរមាតា ដូច្នេះទើបគាត់យកឈ្មោះថ្មនេះ មកធ្វើជានិមិត្តរូប តំណាងឲ្យបាបកម្មរបស់គាត់ (មើលរឿងឥសីមាត់ទិព្វ)។ ផ្កាឈូកតំណាងឲ្យការបំពេញបុណ្យ សន្សំកុសល អ្នកដែលគោរព និងជឿតាមឱវាទព្រះសម្មាសម្ពុទ្ធ (អ្នកកាន់ព្រះពុទ្ធសាសនា) ឯដៃដែលគាត់លើកបញ្ឈរទល់គ្នា តំណាងឲ្យការអង្វរកសូមអភ័យ ចំពោះអ្នកដែលកំពុងចងពៀរនឹងគាត់ ដែលអ្នកចងពៀរនឹងគាត់នោះ គាត់ធ្លាប់បានរំលោភបំពានគេ កាលពីអតីតកន្លងមក។*

*ខ/.នៅពីខាងឆ្វេងដៃរូបអច្ឆរមាតា មានមនុស្សពីរជាន់ (ជាន់ក្រោម និងជាន់លើ) ដែលនៅក្នុងដៃអ្នកទាំងនោះ មានកាន់អាវុធ សកម្មភាពរបស់រូប ជើងមួយបញ្ឈរ ជើងមួយទៀតបត់ទៅក្រោយ ដូចកាយវិការកំពុងហោះ ដៃរុកដំបង ឬលំពែង ចាក់សំដៅទៅរកអច្ឆរមាតា មានន័យថា គេមិនចង់ឲ្យគាត់រួចពីទុក្ខទោស ទៅអង្គុយលើបល្ល័ង្កធំខាងលើវិញឡើយ។ ឯអ្នកជិះដំរីខាងក្រោមបន្ទាប់ គឺ*

តំណាងឲ្យអ្នកដែលបំបែកយកនគរដំរី (យសោធបុរៈ) ន័យក្នុងសកម្មភាពរបស់បក្សពួកគេ គឺដូចគ្នា (មើលរូបទី៣៣) ព្រោះគេមិនចង់ឲ្យម្ចាស់ទ្រព្យ (ម្ចាស់ដើម) រួចពីទុក្ខទោស ឬពីឃុំឡើយ។

**គ**/.នៅពីខាងស្តាំដៃវិញ ក៏មានមនុស្សមករារាំងគាត់ដែរ មនុស្សម្នាក់នៅពីខាងលើ ជើងម្ខាងរបស់គេជាន់លើក្បាលដំរី ជើងម្ខាងទៀតកំពុងលូកទៅជាន់ផ្កាឈូក ដែលអច្ឆរមាតាកំពុងឈរ កុំឲ្យដុះឡើងទៅលើរួច ចំណែកឯអ្នកនៅខាងក្រោមវិញ ជួយដោលទ្រជើងជាកម្លាំង ដើម្បីឲ្យអ្នកដែលមានពៀរខាងលើនោះ អាចក្រោកទៅឈរលើផ្កាឈូកនោះបាន។

**ឃ**/.នៅពីលើខាងស្តាំ មានរូបមនុស្សជិះសេះ គឺតំណាងឲ្យកូនដែលត្រូវមកជួយអច្ឆរមាតា ដែលរូបនេះមានបកស្រាយក្នុងរឿងព្រេងខ្មែរ **ព្រហ្មកិល** (មើលប្រាសាទតាព្រហ្មកិលភាគ២) ព្រហ្មកិលនេះហើយ បានដេញស្តេចដំបងក្រញូង ដែលជាមនុស្សព្រៃគ្មាននគរពីអតីតកាលនោះ។ ស្តេចដំបងក្រញូងនេះ រើសបានដំបងមួយក្នុងស្រុកមោង (ពីមុនខេត្តមោងឬស្សី គឺមោងឬស្សី (មោងសក្តិយក្ស) ដែលជាដំបងមានឫទ្ធិអស្ចារ្យ ជាអំណោយរបស់យក្ស (ត្រុឧបក្សពួកយក្ស) បានដេញវាយកូននាគ (ស្តេច) ឲ្យរត់ខ្ចាត់ខ្ចាយសម័យក្រោយអង្គរ រួចដណ្តើមហែកយករាជបល្ល័ង្ក (ដំរីក្បាលបី) បង្កើតបានជានគរវាយកូនខ្មែរ ឲ្យស៊ីថ្លៃដំបងតៗគ្នា (មើលបទសារិកាភាគ១)។ ក្រោយមកមានស្តេចមួយអង្គ ជាពូជពង្សកូននាគជំនាន់មុន ប៉ុន្តែពិការដើរពុំរួច បានត្រឹមវារ និងលូន (មើលពាក្យល្ខោទេរកាកោង ភាគ២) តែដោយអំណាចបុណ្យរបស់គាត់ ក្នុងរឿងព្រេងខ្មែរបានប្រាប់ថា ព្រះឥន្ទ្រាធិរាជ្យបានប្រែភេទជាតាចាស់ម្នាក់ស្លៀកសពាក់ស យកសេះមួយ និងសម្លៀកបំពាក់សម្រាប់គ្រងរាជមួយបង្វេច មកចងដៃផ្ញើរនឹងបុរសពិការនោះ។ គ្រាន់តែតាចាស់ (ព្រះឥន្ទ្រ) ចេញផុត សេះក៏កញ្ច្រោលទាញដៃបុរសពិការនោះឲ្យលាត្រង់ ព្រហ្មកិលឃើញយ៉ាងដូច្នេះ ក៏យកខ្សែសេះទៅចងដៃ និងជើងទាំង២ឲ្យសេះទាញលាត្រង់បាត់ភាពពិការ ទើបគាត់យកសម្លៀកបំពាក់ដែលមានក្នុងបង្វេចនោះ មកស្លៀកពាក់ រួចឡើងជិះសេះសនោះទៅ។ ពេលដែលសេះបោលរត់ សេះនោះបានហោះឡើងក្រវែលជុំវិញក្រុងអង្គរធំ (បាយ័ន) ធ្វើឲ្យស្តេចដំបងក្រញូងជាស្តេចជ្រែករាជខឹងក្រោធ រួចក៏ចាប់ទាញដំបងឫទ្ធិចោលសំដៅទៅរកអ្នកជិះសេះសនោះ តែពុំត្រូវគាត់ឡើយ ហើយដំបងនេះបានជ្រុះបាត់ក្នុងដែនដីខេត្តបាត់ដំបងសព្វថ្ងៃ។ ទើបខេត្តនេះសន្មត់ឈ្មោះទៅតាម រឿងព្រេងព្រហ្មកិល (ពាក្យព្រេងក្លាយមកពីពាក្យព្រេងព្រិទ្ធអ្នកតាក់តែងទុក) ហើយដំបងក្រញូងវិញ គឺតំណាងឲ្យកុក (សៀម) ព្រោះខ្មែរយើងមានឈ្មោះសត្វកុកមួយប្រភេទដែលមានមាឌធំចង្រៃ្លងឈ្មោះថា កុកដំបងក្រញូង (មើលក្នុងចាក់ទឹក

ដូងទីពីរត្រង់កន្ទុយត្រីប្រាក្បាលនាងកុក) ដូច្នេះហើយទើបរឿងពិតរបស់អច្ឆរមាតាបានបាត់ដាន ជាបន្តបន្ទាប់មកសម័យខាងក្រោយ ព្រោះដំបងគ្រញូងបានវាយឲ្យយើងស៊ីផ្លែដំបងបន្តគ្នា (មើលបទសារិការកែវភាគ១)។

បង្រួមសេចក្ដីមកបើយើងមើលទៅតាមអត្ថន័យក្នុងរូប រួចយកមកប្រៀបធៀបនឹងរឿងផ្សេងៗ (រឿងព្រេង ទំនាយ ប្រស្នា ទំនៀមទម្លាប់ឈ្មោះរបស់ភូមិស្រុក ប្រាសាទ....) យើងអាចយល់បានថា ក្នុងរឿងទាំងនោះ បានទាក់ទងនឹងរឿងដែលនៅក្នុងថ្ម ព្រោះរូបរឿងនៅក្នុងថ្មវាពុំចេះប្រែក្លាយ ដូចជារឿងព្រេង ទំនាយ ឈ្មោះ...ឡើយ ដោយរឿងនៅក្នុងថ្មទាំងនោះ បានបង្ហាញពីរឿងក្នុងចិត្តរបស់បុគ្គលណាម្នាក់ ដែលបានយករឿងពិតក្នុងចិត្តទៅទុកក្នុងថ្មទាំងនេះ ឲ្យជួយរក្សានៅរឿងអាថ៌កំបាំងរបស់ខ្លួន។

## ៦៤/.រូបភាពទី៦៤រូបអង្គរវត្ត(ប្លង់មើលពីខាងលើ)



រូបប្លង់អង្គរមើលពីលើនេះ ដែលខ្ញុំយកមកដាក់បង្ហាញ ព្រោះខ្ញុំចង់ប្រាប់កូននាគឲ្យយល់ថា ភាគច្រើននៃប្លង់ប្រាសាទរបស់ខ្មែរ គឺមានរាងតំណាងឲ្យយោនីអច្ឆរមាតាមហានគរ (មាតុភូមិ) ហើយប្លង់រាងយោនីនេះទៀតសោត គឺមានតែប្លង់អង្គរតូច និងប្រាសាទព្រះវិហារទេ ដែលទរចង្អូរយោនិ គឺផ្លូវចូលវែងជាងគេ ហេតុអ្វីក៏ប្រាសាទខ្មែរ ព្រឹទ្ធដូនតារៀបចំប្លង់ជារាងយោនីដូច្នេះ? ហេតុ

ដូចម្ដេចបានជាគ្រប់ប្រាង្គប្រាសាទ សុទ្ធតែមានតម្កល់យោនី ដែលមានលិង្គនៅចុកបិទពីខាងលើយ៉ាងនេះ?

ខ្ញុំពុំថាតាមឯកសារភាសារូបរបស់បរទេស ដែលបានធ្លាប់បកស្រាយហើយនោះទេ ខ្ញុំចង់ឲ្យកូននាគទាំងអស់មើលថ្មទាំងនោះ មកជាមរតករឿងរបស់អច្ឆរព្រះម៉ែមហានគរវិញ ព្រោះការពន្យល់ក្នុងភាគ១ ភាគ២ និងភាគ៣នេះ គឺខ្ញុំបានបើកបង្ហាញពីបេះដូងថ្មដែលព្រះមេ និងព្រះម៉ែ (ក្មេរ និងខ្មែរ) ត្រូវគេឃុំក្រោមយោនីរបស់ខ្លួនឯង ព្រោះយោនីតំណាងភេទស្ត្រី (មាតុភូមិ)។ ភូមិម៉ែនេះហើយ ដែលបានបង្កើតនូវកុលបុត្រខ្មែរប្រុសស្រី រាប់រយពាន់ជំនាន់មក ហើយក្នុងបណ្ដាកេរមរតកព្រះម៉ែដែលទុកឲ្យកូនប្រុសស្រីនោះ កេរដែលនៅរឹងមាំជាងគេ គឺប្រាង្គប្រាសាទថ្មរាប់ពាន់ ដែលប្រាសាទទាំងនេះ បានផ្ទុករឿងក្នុងបេះដូងម៉ែគ្រប់ផ្ទៃរ ក្បាំង ជញ្ជាំង។ មរតកផ្សេងៗត្រូវវិនាស ត្រូវក្លាយ ត្រូវល្បេរង តែមរតកថ្មនៅរក្សាភាពបរិសុទ្ធដដែល រឿងក្នុងចិត្តរបស់គាត់បានចារឹកទុកពីមុនយ៉ាងណា សព្វថ្ងៃក៏នៅតែយ៉ាងនោះ គ្រាន់តែត្រូវបំផ្លាញដោយជនទុច្ចរិតល្ងានពាន នឹងដោយសារធម្មជាតិខ្លះប៉ុណ្ណោះ។ បល្ល័ង្កប្រាសាទមានរាងជាយោនីទាំងអស់ គឺមានតែបល្ល័ង្កប្រាសាទនាគព័ន្ធមួយទេ ដែលមានផ្លូវបែកជា៤ ជាសញ្ញាលេខបូក ឬលេខគុណ ហើយក្នុងចុងនៃសញ្ញាលេខបូក ឬលេខគុណនេះ គឺមានទឹកហូរចេញតាមមាត់គ្រប់ទិស។ ក្នុងបណ្ដាបង្ហូរទឹកទិសទាំង៤ គឺមានតែទិសខាងកើតទេ ដែលមានរូបសេះ**ពលាហក** និងមានមុខអច្ឆរមាតាមហានគរកប់ត្រឹមក រួចទូលទ្រយោនីខ្លួនឯង (មើលការពន្យល់ក្នុងរូបទី៦)។ ដូនតាយើងកសាងប្រាសាទភាគច្រើនក្នុងបល្ល័ង្កជារាងយោនី ខ្លះមានចង្អូរផ្លូវចូលវែង ខ្លះមានចង្អូរខ្លី ខ្លះមានមួយទិស ខ្លះទៀតមានចង្អូរបួនទិស ដោយគាត់ចង់ប្រាប់យើងថា អាទិទេពទាំងអស់ (ឥសូរ លោកេស្វរៈ វិស្ណុ ព្រះព្រហ្ម.....)ដែលប្រតិស្ឋានទុកគ្រប់ប្រាសាទនោះ គឺសុទ្ធតែប្រសូតចេញពីផ្ទៃរបស់គាត់ទាំងអស់ (មាតុភូមិ) ហើយបានទទួលកេរមរតកពីគាត់គ្រប់ៗគ្នា។ គ្រប់សំណាកយោនីដែលតម្កល់ទុកក្នុងប្រាសាទ សុទ្ធតែមានលិង្គចុកបិទសង្កត់ពីខាងលើ ឯប្រាសាទបាណន់មានរូបផ្ចាំឈរសង្កត់ពីលើ ដោយដូនតាគាត់ឆ្លាក់ទម្រជារាងស្នឹងស៊កបញ្ចូលទៅក្នុងរន្ធយោនី ហើយនៅពីខាងលើក្បាលស្នឹង គាត់ឆ្លាក់រូបផ្ចាំ តំណាងឲ្យបក្សពួកយក្សឈរសង្កត់ពីលើ រូបឈរពីលើនេះ សព្វថ្ងៃគេដាប់យកទៅបាត់ហើយ (អត្ថន័យរូបនេះ ចូរមើលការពន្យល់ភាគមុន និងរូបទី១)។ ចំណែកបល្ល័ង្កអង្គរវត្តនេះ មានរបាំងព័ទ្ធបីជាន់ (មើលទោសទាំងបីជាន់រូបទី១) ហើយបង្ហូរទរយោនី គឺផ្លូវចូលទៅសព្វថ្ងៃដ៏វែងនោះ គាត់ចង់ប្រាប់ពីការនាំអច្ឆរព្រះមាតាចេញពីសមុទ្រទឹកដោះ ត្រូវឆ្លងកាត់

ទ្វារទាំងបីជាន់ក្នុងចង្អូរផ្លូវដ៏វែងឆ្ងាយ ហើយចង្អូរផ្លូវចូល ឬចេញនោះទៀតសោត មានអង្គព្រះវិស្ណុតូចៗនៅឈរទ្រស្ពាននេះពីខាងក្រោម (មើលការពន្យល់រូបទី៤៣) ទម្រាំគាត់ផ្គុំរូបឲ្យធំបាន ទើបអាចមានកម្លាំងរែកព្រះមាតាបិតា ទៅដាក់លើកំពូលភ្នំប្រាសាទព្រះវិហារវិញ។ ផ្លូវចូលប្រាសាទព្រះវិហារក៏ចង្អូរយោនីវែង ហើយចោតខ្ពស់ ព្រោះគាត់ត្រូវសន្សំបារមីរែកព្រះមាតាបិតាឡើងទៅដាក់លើកំពូលភ្នំប្រាសាទព្រះវិហារ គឺមានន័យថា ពីពាក់កណ្ដាលផ្ចិតទៅចុងជើង ត្រូវស្មើនឹងពាក់កណ្ដាលបីដង់ផ្លូវចូលអង្គរតូចនេះ (មើលការពន្យល់ឈ្មោះប្រាសាទព្រះវិហារ និងរកាកោងភាគ២)។

បង្រួមសេចក្ដីមកអច្ឆរមាតាមហានគរលោកចង់ប្រាប់កូននាគប្រុសស្រី សម័យខាងក្រោយកុំឲ្យយល់ច្រឡំថា **អាទិទេពខ្មែរទាំងនោះ ប្រសូតនៅបរទេស គឺអាទិទេពខ្មែរ កើតឡើងក្នុងភូមិព្រះម៉ែរក្សានិងជួយស្រង់ប្រស់ព្រះម៉ែ** (អាទិទេពអ្នកបង្កើតខ្មែរ និងខ្មែរក្នុងភាគ១) ដែលដេកស្លាប់ចេញពីសន្ដានចិត្តកូននាគប្រុសស្រីនោះ ឲ្យមានជីវិតរស់ឡើងវិញ ក្នុងមាតុភូមិដ៏សែនកំសត់នេះ។ រឿងរបស់អច្ឆរព្រះមាតា បានចារឹកទុកក្នុងក្បាំងតាំងពីខាងក្រោម រហូតទៅដល់កំពូលខាងលើ ព្រោះទៅដល់ទីណា ក៏ព្រះម៉ែនាគនៅទៅតាមបាំងរក្សាថែរហូតដល់ទីនោះ ដោយមរតកទាំងនេះ គឺជារឿងក្នុងបេះដូងរបស់គាត់(ក្បាំងនាគរួមខ្លួនតែមួយ)។

## ៦៥/.រូបភាពទី៦៥រូបយោនីនៅខាងក្រោមទឹក(ក្បាលស្ពាន)



តើរូបយោនីដែលនៅក្នុងទឹកនេះ ដូននាគគាត់និយាយប្រាប់យើងពីរឿងអ្វី? យើងដឹងថាតាំងពីប្រភពទឹកដំបូង ចេញពីកំពូលភ្នំគូលែន ដូនតាយើងគាត់បានឆ្លាក់រូបបន្តគ្នាលាក់ទុកក្នុងទឹក នៅលិង្គ

មួយពាន់ មានរូបវិស្ណុធំតូចៗ និងវិស្ណុធំៗនៅក្រោមខ្សែទឹកលិង្គមួយពាន់....។ល។ ហេតុអ្វីបានគាត់ឆ្លាក់រូបទាំងនេះ នៅក្នុងទឹក? បើរូបទាំងនោះ ជារូបមនុស្សមានជីវិតវិញ មិនលង់ស្លាប់ទេឬ?

រូបចម្លាក់យោនីដ៏ធំនេះ នៅខាងក្នុងមានដុំមូលរាងជាកងចំនួនប្រាំគ្រាប់ នៅខាងចុងទ្វារយោនីមានដុំកងមួយរុញបិទមាត់ទរឲ្យរួមតូច និងមានកងជាច្រើនគ្រាប់ទៀត នៅព័ទ្ធជុំវិញពីខាងក្រៅ តើប្រស្នាក្នុងគំនិតថ្មនេះ គាត់ចង់និយាយប្រាប់ពីរឿងអ្វី?

**ក/.**យោនីដ៏ធំនេះ តំណាងឲ្យផ្ទៃរបស់អច្ឆរមាតានាគ (មាតុភូមិ) ដែលផ្ទៃនេះ បានងបង្កើតពូជពង្សនាគរាប់ពាន់ជំនាន់មកហើយ តែជាអកុសលយោនីដែលជានិមិត្តរូបតំណាងឲ្យអប្សរមាតានេះ ត្រូវឃុំជាប់នៅពីខាងក្រោមទឹក (មើលការពន្យល់រូបទី៦០) ដែលទឹកនេះ តំណាងឲ្យមនោគមវិជ្ជាបរទេស (បិទបាំងលាក់សន្ធប់)។

**ខ/.ន័យទី១** កងទាំងប្រាំដែលនៅក្នុងយោនី តំណាងឲ្យការបង្អាក់កំណើតពូជពង្សនាគ ព្រោះសព្វថ្ងៃម្ដាយដែលចង់ពន្យាកំណើត គាត់ដាក់កងតែមួយទេ គឺស្ត្រីជាមាតានោះ ពុំអាចមានបុត្រឡើយ ចុះហេតុអ្វីក្នុងរូបយោនីនោះ មានកងដល់ទៅប្រាំគ្រាប់យ៉ាងនេះ? ហើយនៅខាងចុងទរ មានកងមួយមកបិទបង្រួមទរយោនីឲ្យរួមតូច ដើម្បីកុំឲ្យកងប្រាំខាងក្នុងចេញមកក្រៅរួច។ អច្ឆរមាតាគាត់ចង់ប្រាប់កូនខ្មែរថា បើកូនដោះប្រស្នាកងទាំងប្រាំ រួមទាំងកងទីប្រាំមួយ ដែលរុញបិទទ្វារខាងក្រៅឲ្យរួមតូចនោះពុំរួចទេ អនាគតភូមិម៉ែ លែងអាចប្រសូតកូននាគប្រុសស្រីបានទៀតហើយ ព្រោះភាសាថ្មក្នុងទឹក បាននិយាយប្រាប់យើងយ៉ាងនេះ។

**ន័យទី២** នៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញចិនបានយកប្រស្នាមកដាក់ភ្នាល់យកនគរ ដែលក្នុងប្រស្នានោះ ធនជ័យបានលើកដៃជាសញ្ញា ដើម្បីឆ្លើយបញ្ហាដែលអ្នកប្រាជ្ញចិនយកមកសាកសួរនោះ ទីបំផុតប្រស្នាជាសញ្ញានេះ គាត់អាចបំបែកបាន (ចិនលើកម្រាមប្រាំ ធនជ័យលើកម្រាមមួយ)។

**ន័យទី៣** នៅក្នុងភាសាបរមត្ថធម៌ អច្ឆរមាតាគាត់ចង់ប្រាប់យើងថា កងទាំងប្រាំនោះ តំណាងឲ្យឧបាទានក្ខន្ធ (សេចក្ដីប្រកាន់មាំ) ការប្រកាន់មាំនេះហើយ ដែលបានទម្លាក់គាត់ទៅក្នុងអបាយភូមិ ត្រូវគេបិទសន្ធប់លាក់រឿងពិតរបស់គាត់ទុកមកដល់សព្វថ្ងៃ។ ដូចមានប្រស្នាក្បាលនាគទាំង១៤នៅលានព្រះគម្លង និងនៅក្បាលស្ពានកំពុងក្ដី ក្នុងលានព្រះគម្លង់ក្បាល៥នៅលើក្បាល៧ និងក្បាល៩ (មើលរូបទី១៣ ១៤ ១៥) នៅក្បាលស្ពានកំពុងក្ដីនាគក្បាល៩នៅពីលើក្បាល៥ ដែលមានខ្លួនរួមតែ

មួយចម្លើយនៃប្រស្នាក្បាលនាគនេះ មាននៅក្នុងគម្ពីរព្រះអភិធម្មឯណោះ ព្រោះហេតុអ្វី? ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតានៅឋានតាវត្តិង្ស ព្រះអង្គបានយកព្រះអភិធម្មទាំង៧គម្ពីរទៅសម្ដែងប្រោស ព្រោះមានតែគុណរបស់បរមត្ថអភិធម្មទេ ដែលអាចយកទៅថ្លឹង ឬតបគុណរបស់ព្រះមាតាបាន។ ក្នុងការសម្ដែងប្រោសនោះទៀតសោត លើកទីមួយព្រះពុទ្ធមាតាពុំអាចសំរេចនូវមគ្គផលអ្វីឡើយ ដោយលោករវល់តែជាប់ជំពាក់ក្នុងសេចក្ដីប្រកាន់មាំ ថាបានធ្វើជាព្រះមាតាព្រះសម្មាសម្ពុទ្ធ នឹងជាប់ជំពាក់ក្នុងមហាបុរិសលក្ខណ៣២ប្រការ របស់ព្រះអង្គ ទើបព្រះអង្គប្រោសសម្ដែងជាលើកទីពីរ ពេលនោះព្រះមាតាបានសម្រេចមគ្គផល ជាលោកានាមិស្សសោតា លែងវិលត្រឡប់មកកាន់មនុស្សលោកទៀតហើយ លោកទៀងតែនឹងបរិនិព្វាននៅស្ថានព្រហ្មលោក។ យ៉ាងណាមិញប្រស្នាក្នុងថ្មនេះ ក៏មានន័យយ៉ាងនោះដែរ ព្រោះយោនីតំណាងព្រះមាតាដូចគ្នា គ្រាន់តែអច្ឆរព្រះមាតាមហានគរលោកនៅជាបុថុជ្ជន តែអត្ថន័យដោះស្រាយនៅប្រស្នានេះគឺដូចគ្នា ព្រោះអច្ឆរមាតាមហានគរ លោកបាននាំយកព្រះពុទ្ធសាសនា មកទុកជាមរតកឲ្យកូននាគ(ខ្មែរ) ព្រោះលោកសង្ឃឹមថា នឹងមានកូននាគណាមួយជួយបំបែកប្រស្នាកងនេះជួយគាត់ជាពុំខាន។

សរុបសេចក្ដីមកការពន្យល់ដោយត្រួសៗពីអត្ថន័យរបស់រូបនេះ គឺមានន័យបង្កប់បីយ៉ាងដូចបានបកស្រាយហើយ សូមកូននាគកុំយល់ច្រឡំថា ដូនតាយើងទៅរៀនឆ្លាក់ ឬទៅឆ្លាក់លេងឲ្យសោះបើយើងយល់ខុសនោះ អច្ឆរមាតាលោកពិតជាអស់សង្ឃឹមចំពោះយើងជាកូននាគ ដែលកំពុងទទួលមរតករបស់គាត់សព្វថ្ងៃនេះជាពុំខាន។

## ៦៦/.រូបភាពទី៦៦រូបព្រះវិស្ណុធំ(នៅក្បាលស្ពាន)

តើរូបព្រះវិស្ណុធំនៅក្បាលស្ពាននេះ មានបង្កប់អត្ថន័យយ៉ាងដូចម្ដេច?

**ក**/.យើងដឹងហើយថា រូបព្រះវិស្ណុនៅក្នុងបាតស្ទឹងភ្នំគូលែន មានរូបព្រះវិស្ណុនេះតាំងពីលិង្គមួយពាន់មកម្លេះ ដំបូងរូបគាត់តូចៗក្រោយមកទើបបានរីកធំ នៅទន្ទឹមប្រាសាទរោងចិន វិស្ណុអង្គតូចៗន័យរបស់រូប ដូចព្រះវិស្ណុតូចៗនៅទ្រក្រោមស្ពានផ្លូវចូលអង្គរវត្តដែរ។ ហើយរូបព្រះវិស្ណុតូចៗនោះ គឺជាការសន្សំនៅគុណធម៌គឺបារមីរបស់គាត់ ទោះបីជារូបទាំងនោះនៅក្នុងទឹកក៏ដោយ ក៏គាត់សន្សំគុណធម៌រហូតក្លាយជាព្រះវិស្ណុដែលមានរូបរាងធំ ដែលអាចនាំរូបព្រះមាតានៅពីខាងចុងជើង (មើលការ



ពន្យល់ក្នុងរូបមុន) តែគាត់នៅលិចក្រោមអំណាចទឹកដដែល (មនោគមវិជ្ជា) ហើយរូបរឿងរបស់គាត់ក៏ត្រូវដាច់ត្រឹមជ្រោះទឹកធ្លាក់ទៅក្រោម (បាត់ដានស្នាម)។

**ខ**/.ផ្លូវទឹកដ៏សែនវែងឆ្ងាយបានហូរធ្លាក់មកដល់ក្បាលស្ពាន ទើបកើតមានឡើងរូបព្រះវិស្ណុនោះវិញ ព្រោះតែតំណរូបគាត់បានលាក់កំបាំងក្នុងទឹក និងក្នុងព្រៃ ធ្វើឲ្យរឿងនាំព្រះមាតាចេញពីទីទុក្ខ ត្រូវបាត់ដានដោយខ្លួនគាត់បានធ្លាក់ខ្លួនពិការដោយយក្សច្រានទម្លាក់ (មើលរូបទី៦១)។ តែទោះបីជាគាត់ផ្ទុំ ឬដេកក៏ដោយ គាត់នៅតែព្យាយាមតស៊ូ នាំអច្ឆរមាតាចេញពីទីទុក្ខ រហូតមកដល់ក្បាលស្ពាន រូបគាត់ចាប់ផ្ដើមអណ្ដែតផុតពីទឹក មានន័យថា គាត់ឈប់នៅក្រោមការបំភាន់បន្លំ របស់បរទេសទៀតហើយ ដោយគាត់បានដឹងពីសាវតាពិតរបស់អច្ឆរមាតា។ តើពាក្យក្បាលស្ពានមានន័យដូចម្ដេច? ក្បាលគឺអវយវៈប៉ែកខាងលើរបស់មនុស្ស សត្វ ចំណែកពាក្យថា ក្បាលស្ពានវិញមានន័យថា ក្បាលខាងនាយ និងក្បាលខាងអាយ ព្រោះស្ពានពុំមានជើង ឬកន្ទុយឡើយ គឺមានក្បាលទាំងសង្ខាង។ អាថ៌កំបាំងប្រស្នារបស់ពាក្យនេះ គាត់ចង់ប្រាប់យើងជាកូននាគថា រឿងរបស់គាត់បានមកជិតដល់ទីបញ្ចប់ហើយ **ទីមួយ**រូបព្រះវិស្ណុដែលបាននាំព្រះម៉ែចេញពីសមុទ្រទឹកដោះនោះ បានងើបផុតពីអំណាចទឹកហើយ **ទីពីរ**ដល់ពេលដែលកូនរបស់គាត់ព្រះវិស្ណុ ចាប់ផ្ដើមភ្ជាប់ស្ពានពីក្បាលម្ខាងឲ្យជាប់ទៅក្បាលម្ខាងទៀត មានន័យថា រឿងពិតរបស់គាត់ក្នុងអតីតកាលភ្ជាប់ និងបច្ចុប្បន្នកាល (មើលការ

ពន្យល់ប្រស្នាព្យញ្ជនៈទាំង៣៣តួក្នុងរូបទី៣៧) ឲ្យជាប់គ្នាទើបសេចក្តីសុខ និងត្រេកអរអាចកើតមាន ឡើងបាន (មើលរូបនាគសង្វាងក្បាលស្ពានកំពុងក្តី)។

**គ**/.ការភ្ជាប់ស្ពាននាគបច្ចុប្បន្ន ឲ្យជាប់នឹងស្ពាននាគពីអតីត (រឿងពីអតីតផ្សព្វផ្សាយក្នុង បច្ចុប្បន្ន) គឺត្រូវប្រើពេលវេលាដ៏យូរ ព្រោះគេធ្លាក់រូបគាត់ដេកមិនទាន់អាចក្រោកឡើងបាន ម្យ៉ាង ទៀតគាត់ត្រូវអូសរឿងអច្ឆរមាតាដ៏ធំមួយពីអតីត និងបច្ចុប្បន្នឲ្យជាប់គ្នានោះ កម្លាំងមនុស្សម្នាក់ ដែលដេក (ជានិមិត្តរូប) ដូចមនុស្សពិការឬឈឺ គឺត្រូវប្រើសេចក្តីអត់ធ្មត់ព្យាយាមប្រឹងប្រែងអស់កាល ដ៏យូរ ទើបអាចដើរទៅដល់ទីបញ្ចប់បាន។ ដូចជាព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ហេតុតែព្រះអង្គចង់ សាងស្ពានមួយ ដើម្បីចម្លងសត្វលោកឲ្យចាកចេញពីភពបី (កាមភព រូបភព អរូបភព) ព្រះអង្គត្រូវ ហែលឆ្លងសមុទ្រវដ្តសង្សារ អស់រយពេលបួនអសង្ខេយ្យ និងមួយសែនមហាកប្ប ដើម្បីសន្សំគុណ ធម៌គឺបារមីទាំង៣០ឲ្យពេញបរិបូណ៌ទើបអាចលើកស្ពាន (ភ្ជាប់ត្រើយនាយ និងត្រើយអាយ) គឺការ ត្រាស់ដឹងនូវសច្ចធម៌ដោយខ្លួនឯងបាន ដើម្បីចម្លងសត្វលោកទៅដាក់ត្រើយនាយ គឺព្រះនិព្វាន ដែល ជាទីស្ពានរួចផុតចាកទុក្ខទាំងពួង។

**ឃ**/.រូបភាពព្រះវិស្ណុផ្ទុំនេះ គឺគាត់ផ្ទុំលើនាគហើយនៅចុងជើងគាត់មានរូបអច្ឆរមាតាមហានគរ នៅពីខាងក្រោយចំកណ្តាលផ្ចិតមានដុះទងឈូកមួយ ហើយនៅលើផ្កាឈូកនោះ មានរូបព្រះព្រហ្ម អង្គុយពីលើ។ ព្រះវិស្ណុ តំណាងឲ្យកូននាគ ដែលដេកនាំព្រះម៉ែចេញពីសមុទ្រទឹកដោះ ស្ត្រីដែលនៅ ខាងចុងជើង តំណាងឲ្យអច្ឆរមាតានាគ ដែលជាម្ចាស់មាតុភូមិនេះពីអតីតកាល ព្រះព្រហ្មតំណាងឲ្យ រឿងព្រះវិស្ណុពេលនាំរឿងព្រះមាតាមកដល់ពាក់កកណ្តាល (ចំណុចផ្ចិត) គាត់ត្រូវប្រែរូបទៅជាព្រះ ព្រហ្មគង់លើផ្កាឈូក ដែលព្រហ្មនេះ តំណាងឲ្យពោធិសត្វលោកេស្វរៈនូវបំពេញបារមី សត្វនាគ តំណាងឆ្នាំដែលគាត់ចេញពីគុក តំណាងឲ្យពូជពង្សកូន ជាពូជនាគ (ខ្មែរ) ផ្កាឈូកតំណាងឲ្យការ សន្សំបញ្ញារបស់អ្នកកាន់ព្រះពុទ្ធសាសនា និងតំណាងឲ្យការរួចផុតពីការឃុំគ្រង របស់បរទេសពី អតីតកាល។

បង្រួមសេចក្តីមកការបកស្រាយដោយសង្ខេបនេះ គឺបញ្ជាក់ពីន័យរបស់ថ្ម ទីតាំងដែលយើង ត្រូវតែរែកញែក រករឿងពិតក្នុងបេះដូងថ្ម ថាតើហេតុអ្វីបានជាពួកគាត់ត្រូវធ្លាក់រូបនៅក្នុងទឹក នៅ ក្បាលស្ពាន......?

# ៦៧/.រូបភាពទី៦៧រូបព្រះវិស្ណុផ្ទុំនៅលើក្បាំងក្លែង(ប្រាសាទព្រះខាន់ឬជ័យស្រី)



តើភាសារូបក្នុងក្បាំងក្លែងនេះ អច្ឆរមាតាលោកចង់ប្រាប់យើងពីអ្វី?

១/.ព្រះវិស្ណុតំណាងឲ្យកូននាគ កំពុងនាំមាតានាគចេញពីទីទុក្ខ (មើលការពន្យល់រូបមុន) ដៃបែកជាបួន ដៃពីរខាងក្រោម ដៃមួយទប់ក្បាល តំណាងឲ្យការត្រិះរិះពិចារណា និងទប់លំនឹង ដៃមួយទៀតច្រត់កែង នឹងមានរាជសារក្នុងដៃ តំណាងឲ្យការបំបែកប្រស្នាអាថ៌កំបាំងក្នុងសារបណ្ដាំ (ក្នុងថ្ម) ដៃពីរខាងលើ ដៃមួយកាន់ដុំមូល តំណាងឲ្យរឿងដែលគាត់ប្រមូលបាន ដៃមួយទៀតកាន់ផ្កាឈូកហុចទៅឲ្យព្រះមាតានៅចុងជើង តំណាងឲ្យបញ្ញាក្នុងព្រះពុទ្ធសាសនា (ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និង សីលសមាធិ បញ្ញា) គាត់ចង់ឲ្យព្រះមាតាសមាទានសីលសមាធិបញ្ញាឡើងវិញ។ ឥរិយាបថដេកតំណាងឲ្យភាពពិការ ឬការងើបឈរនាំព្រះមាតាចេញមិនទាន់បាន (មើលការពន្យល់រូបមុន)។

២/.រូបស្ត្រីនៅចុងជើងមានពាក់ក្បាំងមកុដដូចអច្ឆរា តំណាងឲ្យអប្សរមាតាមហានគរ ដែលជាអ្នកបង្កើតពូជខ្មែរ និងពូជខ្មែរ ដៃឱបជើង គឺគាត់ប្រឹងប្រែងចាកចេញពីទុក្ខ ដៃម្ខាងទៀតពុំទាន់ព្រមទទួលផ្កាឈូកពីកូនគាត់ហុចឲ្យ គឺមានន័យថា គាត់នូវមានចិត្តចង់សងសឹកអ្នកធ្វើបាបគាត់ និងអ្នកដែលមិនដឹងគុណគាត់ (គាត់ពុំទាន់ព្រមរក្សាសីល)ឥរិយាបថនៅអង្គុយ ហើយព្រះវិស្ណុគងពីលើ មានន័យថា គាត់ពុំទាន់មានគុណធម៌គ្រប់អាចងើបឈរបាន (គឺបុណ្យឧទ្ទិសជូនគាត់ពុំទាន់គ្រប់)។

៣/.រូបសត្វគុជសី គឺតំណាងឲ្យទីក្រុងពីររលាយចូលគ្នា (ខ្ញុំបានពន្យល់រួចហើយ) ហើយឥរិយាបថកំពុងដើរទៅមុខ គឺមានន័យថា កំពុងនាំរឿងនៅខាងលើខ្លួនព្រះវិស្ណុ និងព្រះមាតាចេញទៅខាងក្រៅ ឲ្យកូននាគទាំងអស់បានដឹង។

៤/.រូបភាពខាងលើមើលទៅ ហាក់ដូចធ្លាក់ពុំទាន់ហើយ គឺតំណាងឲ្យរលកទឹកចិត្តមនោគមវិជ្ជា (មើលរូបទី៦០ពីទឹក) បរទេស ដែលគ្របពីលើគាត់ ទើបគាត់ពុំទាន់អាចផ្សាយរឿងទៅខាងលើបាន។

៥/.នៅខាងក្រោមពោះសត្វគុជសី មានសត្វត្រី និងអណ្ដើក

ក/.សត្វត្រីតំណាងឲ្យលាភសក្ការៈ មានន័យថា ត្រី ឬលាភសក្ការៈ មិនអាចឡើងទៅរំខានគាត់ខាងលើទៀតឡើយ។

ខ/.សត្វអណ្ដើក គឺតំណាងឲ្យឧបាទានក្ខន្ធ គឺអណ្ដើកឈប់ឡើងទៅរំខានគាត់ទៀតហើយ។ នៅក្នុងពិធីមង្គលការតែងមានមេអណ្ដើក និងកូនអណ្ដើត មេអណ្ដើកតំណាងឲ្យស្ត្រីម្នាក់ ដែលដឹកនាំបុរសឲ្យទៅជួបស្ត្រី គឺមានន័យថា ដឹកខន្ធមួយ ទៅជួបនឹងខន្ធមួយទៀត ឯខ្លួនឯងអ្នកដឹកក៏ជាខន្ធមួយដែរ។ ប្រស្នានេះ មាននៅក្នុងព្រះពុទ្ធសាសនា ដែលយើងសព្វថ្ងៃ តែងយល់ច្រឡំថា អណ្ដើកតំណាងឲ្យភេទស្ត្រីទៅវិញ ព្រោះភេទគ្រាន់តែជានាមបញ្ញត្តិមួយ ក្នុងបរមត្ថធម៌តែប៉ុណ្ណោះ។ ន័យម៉្យាងទៀតអណ្ដើក និងត្រី គឺបង្ហាញពីឋាន គឺគុជសីបានងើបផុតពីទឹកហើយ ព្រោះសត្វទាំងនេះ តែងរស់នៅក្នុងទឹក តែយើងត្រូវមើលរឿងទាំងនេះ គាត់ប្រតិស្ឋានទុកនៅលើក្បាល គឺក្នុងក្បាំងមកុដនាគ ពុំមែនស្ថិតនៅក្នុងទឹកដូចរូបនៅភ្នំគូលែនឡើយ។ ដូចនេះកូននាគប្រុសស្រី ត្រូវចេះពិចារណារាវរកហេតុផលពិតដោយខ្លួនឯងតាមរយៈការបកស្រាយពន្យល់ដោយសង្ខេបនេះថា តើវាជារឿងសាសនា ឬរឿងរបស់យើង?

៦/.រូបឥសីសង្ខាង គឺតំណាងឲ្យអ្នកបួស តែនៅជឿមង្គលភ្ញាក់ផ្អើលនៅឡើយ មានន័យថា អ្នកបួសក្នុងព្រះពុទ្ធសាសនាក្តី អ្នកបួសក្រៅព្រះពុទ្ធសាសនាក្តី ឲ្យតែអ្នកដែលមានជំនឿទៅលើមង្គលភ្ញាក់ផ្អើល ឬសីលវត្តខាងក្រៅ គឺសុទ្ធតែក្រុមឥសីទាំងអស់។ ម៉្យាងទៀតបើអ្នកបួសទាំងនោះ គ្មានពោធិបក្ខិយធម៌ទាំង៣៧ ដែលមានសតិបដ្ឋាន៤ជាខាងដើម និងមគ្គដែលមានអង្គ៨ជាខាងចុង សម្រាប់ប្រតិបត្តិនោះទេ គឺពុំមែនជាសមណពិតឡើយ ហើយផ្លូវទាំង៨ដែលត្រូវដើរនោះ គឺមានសម្មាទិដ្ឋិជាខាងដើម (ការយល់ត្រូវ) និងសម្មាសមាធិ (តំកល់ចិត្តត្រូវ) ជាខាងចុង សម្រាប់ឲ្យចិត្តធ្វើ

ដំណើរ បើពួកគេពុំមានផ្លូវ (មគ្គ) ទាំង៨នេះទេ គឺសុទ្ធតែជាតសីទាំងអស់។ ហើយរូបទាំងនោះអង្គុយបញ្ឈរជង្គង់ រួចលើកដៃសំពះ ដែលមានទឹកមុខញញឹម មានន័យថា ពួកគាត់ចាប់ផ្ដើមបានដឹងរឿងរបស់ខ្លួន ហើយៗអបអរសាទរទទួលស្គាល់នូវរឿងពិត របស់អច្ឆរមាតា ដែលពីមុនពួកខ្លួនស្ថិតនៅក្រោមអំណាចទឹកចិត្តយក្សគ្របសង្កត់បិទបាំង ឥឡូវបានព្រះវិស្ណុមកជួយបើក ជួយស្រង់ឲ្យរួចផុតពីភាពងងឹត ដែលពុំបានដឹងនៅការពិតនេះ។

សរុបសេចក្ដីមកការបកស្រាយដោយសង្ខេបពីអត្ថន័យក្នុងរូបនេះ គ្រាន់តែចង់ពញ្ញាក់បញ្ញាស្មារតីកូននាគ ឲ្យចេះមើលឃើញរឿងពិតរបស់មេនាគ ចេះប្រៀបធៀបពីការវិវឌ្ឍន៍របស់រូបចម្លាក់ពីប្រាសាទមួយទៅប្រាសាទមួយ ដើម្បីស្វែងរករឿងពិតក្នុងបេះដូងថ្ម ដែលជាមរតកគំនិតមិនអាចកាត់ថ្លៃបាន ដែលជនទុច្ចរិតតែងដាប់បំផ្លាញចោលនោះ ឲ្យក្លាយមកជារតនទ្រព្យដ៏មានតម្លៃកាត់ថ្លៃពុំបាន ដែលយើងគួរនាំគ្នាការពារ និងថែរក្សា ដូចជាថែរក្សាកេរ្ដិ៍ភ្នែកទាំងគូ។

## ៦៨/.រូបភាពទី៦៨រូបព្រះវិស្ណុដេកនៅក្បាំងក្លែង(ប្រាសាទបន្ទាយសំរែ)



តើភាសារូបក្នុងក្បាំងក្លែងនេះ មានអត្ថន័យយ៉ាងណាចំពោះសាសនអច្ឆរមាតា? ពាក្យថា បន្ទាយសំរែ ឬបន្ទាយអ្នកស្រែ ខ្ញុំបានពន្យល់រួចហើយនៅក្នុងភាគពីរ ពេលនេះខ្ញុំគ្រាន់តែយករូបភាពដែលបានលាក់បំប្លែង ដែលបានលាក់ក្នុងក្បាំងដែលពាក់លើក្បាលអច្ឆរមាតា មកបកស្រាយពន្យល់នៅការពិតតែប៉ុណ្ណោះ។ រូបព្រះវិស្ណុដេកនេះ បើយើងមើលទៅតាមភាពជាក់ស្ដែង គាត់បានឆ្លាក់ពង្រាយស្ទើរគ្រប់ទីកន្លែង គ្រាន់តែកន្លែងខ្លះរូបតូច កន្លែងខ្លះរូបធំ កន្លែងខ្លះមានរូបវិស្ណុផ្ទុំលើនាគ រួចគងលើព្រះម៉ែ កន្លែងខ្លះផ្ទុំលើសត្វគុជសី ចំណែករូបព្រះវិស្ណុផ្ទុំនៅប្រាសាទបន្ទាយសំរែនេះ គាត់ផ្ទុំលើសត្វនាគផង គាត់ផ្ទុំលើសត្វគុជសីផង ហេតុអ្វីក៏រូបនេះ គាត់ឆ្លាក់ខុសពីរូបមុនៗ?

ក/.ព្រះវិស្ណុក្នុងរូបនេះ មានអត្ថន័យដូចរូបមុន ខុសត្រង់ដៃខាងលើមានទប់ទងផ្កាដែលដុះចេញពីផ្ចិតរបស់គាត់ ឯដៃខាងលើមួយទៀត ដែលហុចផ្កាឈូកឲ្យព្រះមាតានោះ ផ្កានេះមានទំហំធំហើយមានស្រទាប់ផ្កាច្រើន។

ខ/.ស្ត្រីដែលនៅខាងចុងជើង តំណាងឲ្យអច្ឆរមាតា ក្នុងរូបនេះ គាត់ប្រឹងក្រោកឈរ ហើយដៃឆ្វេងរបស់គាត់ ព្រមទទួលទផ្កាឈូកដែលកូនបានហុចឲ្យ គឺខុសពីរូបមុន ដែលគាត់ពុំព្រមទទួលឡើយ ឯដៃស្ដាំវិញ ប្រឹងច្រត់ជើងកូនដើម្បីងើបឈរ ខុសពីរូបមុន ដែលគាត់ប្រឹងឱបជើងកូន។

គ/.ដោយការខំប្រឹងប្រែងងើបឈររបស់គាត់ ទីបំផុតគាត់បានឡើងទៅឈរលើខ្នែងផ្កាឈូកដែលដុះចេញពីផ្ចិតរបស់ព្រះវិស្ណុ ដែលរូបនៅលើផ្កាឈូកខ្នែងម្ខាង តំណាងឲ្យអច្ឆរមាតា និងរូបម្ខាងទៀត តំណាងឲ្យបិតា ចំណែករូបកណ្ដាល តំណាងឲ្យរូបព្រះវិស្ណុ ដែលបំបែកខ្លួនត្រឹមផ្ចិត ត្រូវផ្លាស់នាមថ្មី ជាព្រះព្រហ្ម ឬព្រះពោធិសត្វលោកេស្វរៈ ហេតុអ្វីបានជាទៅដល់ពាក់កណ្ដាលផ្ចិត គាត់ត្រូវបំបែកខ្លួនយ៉ាងដូច្នេះ? ព្រោះផ្ចិតជាចំណុចកណ្ដាល បានន័យថា ពាក់កណ្ដាលខាងលើ និងពាក់កណ្ដាលខាងក្រោម គឺស្មើគ្នា (មើលការពន្យល់ក្នុងមង្គលបីភាគ២)។ ទៅដល់ចំណុចកណ្ដាលនោះ គុណធម៌របស់គាត់ ត្រូវរុញច្រានឲ្យគាត់ផ្លាស់ប្ដូររូប ជាព្រះព្រហ្ម ឬព្រះពោធិសត្វលោកេស្វរៈ ព្រោះបញ្ញារបស់គាត់បានយល់ច្បាស់ពីបរមត្ថសច្ចៈ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា (នត្ថិកម្មំ សមំពលំ) **កម្លាំងអ្វីស្មើដោយកម្លាំងកម្ម គឺពុំមានឡើយ** ដោយគាត់បានយល់ពាក្យភាសិតនេះ ថាគាត់ពុំអាចប្រើនៅកម្លាំងចិត្ត បង្ខំឲ្យព្រះមាតាព្រះបិតាឆាប់រួចពីឃុំតាមចិត្តចង់ របស់គាត់បានឡើយ សូម្បីតែព្រះសម្មាសម្ពុទ្ធ ក៏ព្រះអង្គមិនអាចគេចផុតពីកម្លាំងកម្ម ដែលត្រូវឲ្យផលនោះបានទេ។ ផ្លូវកណ្ដាលមួយបានកើតឡើង ពេលដែលទៅដល់ចំណុចផ្ចិត ដែលទងផ្កាទាំងបីត្រូវកើតឡើង គាត់លូនវារ

ទៅមុខផង បណ្ដុះទងផ្កាគឺគុណធម៌ឡើងទៅលើផង តែគួរឲ្យអនិច្ចាបរទេសគេបានដឹងពីអាថ៌កំបាំងថ្ម ទាំងនេះ គេបានជួលពួកទុច្ចរិតឲ្យដាប់បំផ្លាញក្បាលរបស់គាត់ ព្រោះគេមិនចង់ឲ្យគាត់នៅរស់ ជួយស្រង់អ្នកទាំងពីរ លើកទៅដាក់លើបល្ល័ង្កឈូក ដែលនៅទំនេរពីខាងលើនោះ (មើលការពន្យល់រូបទី៤២)។ ក្នុងអត្ថន័យរូបនេះ និងរូបទី៤២ដែលបានពន្យល់ហើយ បានបញ្ជាក់ប្រាប់យើងពីឈ្មោះភ្នំដងរែក ដែលគាត់ត្រូវរែកម៉ែឪទៅដាក់លើកំពូលភ្នំព្រះវិហារវិញ ដែលអ្នករែកនោះជាពូជសំរែ ឬអ្នកស្រែ ព្រោះរូបវិស្ណុផ្ទុំបន្ទាយសំរែនេះ បានបញ្ជាក់ពីសាវតាពិតរបស់បុគ្គលនេះ ទៅតាមឈ្មោះរបស់ប្រាសាទ ដែលគេបានឆ្លាក់រូបនិមិត្តទុកនេះ (មើលការពន្យល់ពីឈ្មោះប្រាសាទបន្ទាយសំរែភាគ២)។

**ឃ**/.គាត់ផ្ទុំលើសត្វនាគផង លើសត្វគុជសីផង (មើលការពន្យល់រូបទី៦៦និងរូបទី៦៧) អត្ថន័យគឺរឿងអាថ៌កំបាំងមេនាគ ដែលបានហាន់ជាចំណិតៗ (ហាន់ជ័យ) ពីអតីតនោះ ត្រូវបានផ្គុំបញ្ចូលគ្នាវិញ គឺប្រែស្នាក្នុងព្យញ្ជនៈខ្មែរទាំង៣៣តួ និងអាថ៌កំបាំងក្នុងមរតកព្រះម៉ែ ដែលមានសល់មកដល់សព្វថ្ងៃ។

សង្ខេបសេចក្ដីមកអត្ថន័យរូបនេះ ខុសពីរូបមុន ត្រង់គាត់ព្រមក្រោកឈរ ហើយខំប្រឹងប្រែងឡើងទៅកាន់ទីខ្ពស់វិញ ដោយពួកគាត់ព្រមរួមគ្នាមិនបែកគ្នាដូចរូបមុន គឺមានតែមាតា និងកូន ឯក្នុងរូបនេះ កូនបានស្រង់រែកមាតា និងបិតា ដូចជាព្រះពោធិសត្វសុវណ្ណសាម បានរែកមាតាបិតាយ៉ាងដូច្នោះ (បំពេញនូវកតញ្ញូកតវេទី)។

## ៦៩/.រូបភាពទី៦៩រូបក្រពើសាមពាន់(នៅក្បាលស្ពាន)



តើសត្វក្រពើនេះ តំណាងឲ្យអ្វី? ពាក្យក្រពើនេះ ខ្ញុំបានពន្យល់រួចហើយ ក្នុងភាគមួយ និងភាគពីរ ពេលនេះខ្ញុំយករូបភាពចម្លាក់មកដាក់បង្ហាញ ព្រោះចង់ឲ្យបានដឹងថា រឿងហេតុភាគច្រើន គឺកើតចេញពីថ្ម ព្រោះព្រឹទ្ធដូនតាយើងលោកចងក្រងរឿងព្រេង ទំនាយ និងពាក្យទូន្មានផ្សេងៗ ភាគច្រើនគាត់បានដកយកចេញពីក្នុងថ្ម។ រូបចម្លាក់ក្រពើនេះ មានឈ្មោះថា ក្រពើសាមពាន់ ព្រោះពាក្យថាសាមពាន់ គឺគុណបន្តគ្នា បានន័យថា ក្រពើបានបែងភាគចូលគ្រប់កូននាគ ដូច្នេះទើបពេលស្លាប់ទៅ គេតែងលើកទង់ក្រពើស ឲ្យម្នាក់មួយៗ ហើយដែលគាត់យករូបនេះ ទៅឆ្លាក់នៅក្នុងទីតាំងក្បាលស្ពាន អច្ឆរមាតាគាត់ចង់ប្រាប់យើងថា អាថ៌កំបាំងនៃពាក្យក្រពើ និងទង់ក្រពើ បានបើកបង្ហាញហើយ ព្រោះបានទៅដល់ទីបញ្ចប់ ព្រោះក្បាលស្ពានពីអតីត និងក្បាលស្ពានបច្ចុប្បន្ន បានភ្ជាប់ ធ្វើឲ្យយើងអាចដើរឆ្លងទៅមើលអាថ៌កំបាំងក្នុងថ្ម ពីអតីតកាលបាន។

## ៧០/.រូបភាពទី៧០រូបបុរសជ្រោងក្រពើឡើង(មិនដឹងប្រភព)



តើក្នុងរូបភាពនេះ អត្ថន័យរបស់រូបគាត់ចង់និយាយប្រាប់ពីអ្វី? រូបនេះ បានបង្ហាញពីបុរសម្នាក់ជ្រោងក្រពើដៃម្ខាងឡើងទៅលើ ដោយបុរសនោះឈរលើកជើងមួយចំហៀង។ ក្រពើនៅខាងលើឈរនៅលើទំរមួយ នៅពីខាងលើក្រពើមានសន្លឹកក្បាច់មួយ ដូចជារាងបេះដូង ឯរាងសង្ខាងក្បាច់ទាំងមូលព័ទ្ធជុំវិញ មានរាងជាត្រីកោណ រាងខ្លែង និងរាងដូចទង់។ នៅសង្ខាងបុរសកំពុងជ្រោងក្រពើ មានស្ត្រីពីរនាក់មានពាក់មកុដ និងមានស្លៀកសំពត់ដូចជាអច្ឆរា ឈរនៅលើបល្ល័ង្ក ទាបជាងបុរសនោះ។ បុរសដែលមានពាក់ខ្សែអង្កាំ ឈ្វៀងស្មាម្ខាងនោះ (ធនជ័យមើលប្រស្នាចាក់ទឹកដូងភាគ១) តំណាងឲ្យអ្នកដឹងពីអាថ៌កំបាំងទង់ក្រពើនេះ ដៃម្ខាងកាន់ដងធ្នូ ច្រត់លើចង្កេះ ដៃម្ខាងទៀតគាត់ជ្រោងទ្រនាប់ដែលទ្រសត្វក្រពើ មិនឲ្យក្រពើ

នោះ មកប៉ះនឹងដៃគាត់ឡើយ ហាក់ដូចជាចង់បង្ហាញប្រាប់ ពីអត្ថន័យកំបាំងរបស់សត្វក្រពើនេះ ឲ្យអ្នកផងទាំងពួងបានដឹង។ ឯក្បាច់ដែលមានរាងដូចជាបេះដូងនោះ គឺជានិមិត្តរូបនៅក្នុងប្រស្នាចាក់ទឹកដូងលើកទី១ ដែលចាក់ទឹកក្នុងបេះដូងម៉ែដំបូង ពុំបានឃើញរឿងក្នុងចិត្តគាត់ឡើយ គឺឃើញតែក្បាលក្រពើ ហើយក្រពើនោះក៏ដេញតាមខាំបុរសនោះ (មើលចាក់ទឹកដូងក្នុងភាគមួយ) ព្រោះក្នុងរូបនេះនិមិត្តរូបបេះដូង និងសត្វក្រពើ គឺនៅក្នុងរង្វង់ជាមួយគ្នា។ ឯរូបស្ត្រីពីរនាក់ ដែលឈរនៅសង្ខាងនោះតំណាងឲ្យអច្ឆរមាតា ដែលកូនជ័យបានចាក់ទឹកក្នុងបេះដូងរបស់គាត់ទាំង២លើក ចាក់លើកទី១ គឺក្នុងអតីត ចាក់លើកទី២ គឺក្នុងបច្ចុប្បន្ន មានន័យថាយករឿងពិតក្នុងអតីត មកភ្ជាប់ស្ពានជាមួយបច្ចុប្បន្ន (ប្រស្នាក្នុងព្យញ្ជនៈ)។

បង្រួមសេចក្ដីមករូបក្រពើនៅក្បាលស្ពាន និងរូបក្រពើនេះ ដែលបង្កើតឲ្យមានភ្នំក្រពើ ទង់ក្រពើ ផ្កាយក្រពើ.....ឈ្មោះភូមិស្រុក និងក្នុងពាក្យទូន្មានអប់រំ ដែលគាត់យកសត្វក្រពើមកប្រៀបធៀប គឺអត្ថន័យពាក្យទាំងនោះ សុទ្ធតែចេញពីក្នុងបេះដូងថ្ម ក្នុងរូបចម្លាក់ដែលមាននៅសល់ទាំងអស់។

## ៧១/.រូបភាពទី៧១រូបផ្ដែរនៅប្រាសាទវត្តភូ(ប្រទេសលាវ)



តើអត្ថន័យភាសាថ្មក្នុងរូបនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? អត្ថន័យក្នុងរូបនេះ ខ្ញុំបានពន្យល់ម្ដងហើយ នៅក្នុងភាគ២ រឿងមង្គលបីប្រការ តែដែលខ្ញុំយកមកបញ្ចូលក្នុងភាគ៣ជាបន្តនេះ ខ្ញុំចង់ពន្យល់ប្រៀបធៀបរូបហែកជាបីក្នុងរូបភាពទី៣៣ តើវាមានអត្ថន័យខុសគ្នាដូចម្ដេច? រូប

នេះ ក្បាលដែលត្រូវហែកចេញទាំងសង្ខាង គឺមានពាក់មកុដ ក្រវិល គ្រឿងអលង្ការ ដែលខុសពីរូបស្រ្តីទី៣៣ ដែលហែកសង្ខាងដូចគ្នា តែគ្មានពាក់មកុដ ក្រវិល គ្រឿងអលង្ការឡើយ ហើយការហែកក្នុងរូបនេះ ផុតពីបេះដូងតែបន្តិច ឯរូបភាពទី៣៣ គឺហែករហូតដល់ផ្ចិត ដែលជាចំណុចកណ្ដាលនៃដងខ្លួនមនុស្ស។ ដោយការប្រៀបធៀបរូបចម្លាក់ទាំងពីរនេះ អត្ថន័យក្នុងការហែកគឺផ្សេងគ្នា ហែកទីមួយ គឺហែកដណ្ដើមកេរមរតកព្រះម៉ែ ហែកទីពីរ គឺហែកមើលរឿងក្នុងបេះដូងព្រះម៉ែ បើគ្រាន់តែមើលពុំបានយកមកពិចារណាប្រៀបធៀប និងឈ្វេងយល់ ច្បាស់ជាយល់ថា មានអត្ថន័យដូចគ្នាពុំខាន ឧ. ដូចជានៅក្នុងភាសាខ្មែរ ពាក្យសរសេរ "ក ក៏ ករ" សម្លេងអានមានសូរដូចគ្នា តែន័យខុសគ្នា។

សង្ខេបសេចក្ដីមកសិល្បបំភាន់របស់ដូនតា ក៏យ៉ាងដូច្នោះដែរ បើយើងពុំបានយកឈ្មោះប្រាសាទមកវែកញែក រួមទាំងរឿងផ្សេងៗ ដែលជាប់ទាក់ទងនឹងរូប មកបូកបញ្ចូលជាមួយគ្នានោះទេ យើងច្បាស់ជារកចម្លើយឲ្យសមហេតុ និងផល ពុំបានឡើយ ព្រោះកែវភ្នែករបស់មាតាយើង ត្រូវយក្សដកយកទៅលាក់ទុករអស់ហើយ (ប្រស្នានៅក្នុងរឿង)។

## ៧២/.រូបភាពទី៧២រូបក្បាច់ចង្វាយក្នុងសសរ(ប្រាសាទទន្លេបាត់ទី)



តើនៅក្នុងក្បាច់ចង្វាយទាំងនេះ មានបង្កប់រឿងក្នុងបេះដូងរបស់គាត់ យ៉ាងដូចម្ដេច? ហើយគាត់ចង់ប្រាប់យើងពីរឿងអ្វី?

១/.កងក្បាច់ខាងក្រោម នៅក្នុងកងនោះ មានរូបគ្រុឌកំពុងចាប់សន្លឹកក្បាច់សង្ខាង ដែលនិមិត្តរូបសន្លឹកក្បាច់នោះ គឺជាសត្វដំរី ព្រោះក្បាលដំរីធ្លាក់ទៅក្រោម ដោយដៃគ្រុឌចាប់ជើងក្រោយដំរីលើកឡើង។ រូបនេះ បើយើងមើលហើយ មិនបានពិនិត្យឲ្យដិតដល់ទេ ច្បាស់ជាពុំឃើញរូបដំរីឡើយ គឺឃើញតែសន្លឹកក្បាច់តែប៉ុណ្ណោះ ព្រោះការឆ្លាក់បំភាន់នេះ គឺពួកគាត់មានទេពកោសល្យ

ខ្ពស់។ តើគ្រុឌនៅកណ្ដាល ដំរី ក្បាច់ព័ទ្ធជុំវិញ តំណាងឲ្យអ្វី?

ក/.គ្រុឌតំណាងឲ្យសៀម (ពន្យល់រួចហើយ)

ខ/.ដំរីតំណាងឲ្យឈ្មោះនគរ យសោធបុរៈ (នគរដំរី) ដែលពីមុននគរនេះ ងើបឈរត្រដែត ក្រោយមកត្រូវគ្រុឌចាប់លើកជើងឡើង ឲ្យសំយ៉ុងក្បាលចុះ (មើលការពន្យល់រូបទី៦៣ពីដំបង ក្រញូង)។

គ/.ក្បាច់កងដែលព័ទ្ធជុំវិញ តំណាងឲ្យសីមា ឬគុករបស់យក្ស ត្បិតថាក្នុងរូបនេះគ្មានយក្ស តែ សត្វគ្រុឌគឺជាសេនារបស់យក្ស ដែលតំណាងឲ្យយក្ស។

ឃ/.ហេតុអ្វីបានជាគ្រុឌនៅចំកណ្ដាលទៅវិញ ក្នុងរូបនេះ? ក្នុងការដណ្ដើមឈ្លានពានហែក យកនគរដំរីនេះ ដំបូងពួកគ្រុឌឬដំបងក្រញូងនេះ ដែលជាមនុស្សព្រៃគ្មានប្រទេសគ្មាននគរ បានលុក លុយឈ្លានពាន វាតទីដណ្ដើមយកកេរមរតកព្រះម៉ែមុនគេ នេះជាហេតុទី១។ យើងបានដឹងហើយថា បេះដូងនគរមេ ឬនគរស្រីល្វោពីអតីតនោះ សព្វថ្ងៃគឺនៅក្នុងខេត្តល្វោ ឬលពបុរី (បុរីដែលត្រូវគ្រុឌ លុបដាន) ជាបេះដូងមេដំបូង ដែលខ្ញុំបានពន្យល់ក្នុងភាគ១ ពីការបង្កើតពូជនាគ ឬពូជក្មេរ (កេរមេ) ដែលក្រោយមកក្លាយជាពូជខ្មែរ (កេរម៉ែ)។ ចំណុចកណ្ដាលនេះ សព្វថ្ងៃត្រូវគ្រុឌហែកដណ្ដើមយក ទៅ ហេតុនេះ ទើបដូនតាឆ្លាក់ក្នុងក្បាច់រង្វង់ដាក់គ្រុឌនៅចំកណ្ដាលនេះ ហើយនៅក្នុងទីតាំងសសរ ប្រាសាទទន្លេបាត់ទី (មើលការពន្យល់ក្នុងភាគ២ ឈ្មោះទន្លេបាត់ទី) ដែលជាឈ្មោះបង្ហាញ ពីកាបាត់ ប្រភពមេ (ទឹកតំណាងឲ្យព្រះម៉ែ មេគង្គ ឬមេកុង)។

២/.តើរូបស្ត្រីដែលនៅក្នុងឃុំ រង្វង់ជាបន្ទាប់នោះ តើគាត់ជានរណា? រូបស្ត្រីដែលមានពាក់ មកុដ គ្រឿងអលង្ការ ដែលកំពុងលើកដៃរាំច្រៀងទៅលើ ដៃម្ខាងដាក់ត្រឹមដើមទ្រូង ជើងម្ខាងលើក ឡើង និងជើងម្ខាងទៀត ឈរនៅលើផ្កាឈូកមួយទងនោះ គឺតំណាងឲ្យអច្ឆរមាតាមហានគរ (មើល ការពន្យល់រូបទី៥៣) ដែលគាត់កំពុងជាប់ទោសក្នុងរង្វង់សីមាយក្ស។ ព្រោះកាំក្បាច់ដែលនៅជុំវិញ គាត់នោះ គឺជាធ្មេញយក្សដែមាននៅខាងក្នុង និងខាងក្រៅជុំវិញ ហើយរង្វង់នេះ បានវិលជុះជាបន្ត ទៅខាងលើទៀត សម្រាប់ភ្ជាប់រឿងទៅខាងលើ។

៣/.តើរូបមនុស្សអង្គុយក្នុងកងរង្វង់ទី៣ តំណាងឲ្យអ្វី?

រូបដែលអង្គុយឈ្ងោកចុះក្រោម នៅលើផ្កាឈូកនោះ គឺតំណាងឲ្យពោធិសត្វលោកេស្វរៈ ឬព្រះវិស្ណុ ដែលជាកូននាគត្រូវចុះទៅខាងក្រោម (សមុទ្រទឹកដោះ) ដើម្បីរាវរករឿងព្រះម៉ែ (មើលការពន្យល់ក្នុងរូបមុនៗ)។

៤/.រូបទី៤ ដែលស្ថិតនៅក្នុងរង្វង់សីមានេះ ក៏តំណាងឲ្យកូននាគដែរ តែគាត់ចាប់ផ្ដើមដឹងរឿងអច្ឆរមាតារួចងើបមុខឡើង គឺមានន័យថា ចាប់ផ្ដើមនាំព្រះមាតាឡើងទៅខាងលើវិញ ហើយអ្នកទាំងពីរសុទ្ធតែនៅជាប់ក្នុងរង្វង់សីមា ដែលមានកាំក្បាច់ធ្មេញយក្សដូចគ្នា។

៥/.រូបក្នុងរង្វង់ទី៥ គឺគាត់ចាប់ផ្ដើមដេកលើបល្ល័ង្កផ្កាឈូក ដឹកព្រះមាតាចេញមានន័យថា គាត់នាំព្រះមាតាចេញពីទីឃុំរបស់យក្សទៅដល់ចំណុចផ្ចិតហើយ (មើលការពន្យល់វិស្ណុដេក ឬផ្ទុំ)។

៦/.ក្នុងរង្វង់សីមាទី៦ គឺបានដាច់រូបគាត់បាត់ទៅហើយ គឺមានន័យថា ទៅដល់ចំណុចផ្ចិតភ្លាមគាត់ត្រូវបាត់ដំណឹង លែងមាននរណាបានដឹងពីរឿងគាត់ទៀតហើយ។ ព្រោះពាក្យថាដេក គឺនៅក្នុងផ្ទះ ក្នុងបន្ទប់ នៅលើគ្រែ បើអ្នកណាចង់ជួបគាត់ ទាល់តែចូលទៅក្នុងផ្ទះ ក្នុងបន្ទប់ ទើបឃើញគាត់ នេះជាអត្ថន័យថ្មបាននិយាយប្រាប់យើង ពីឥរិយាបថបុគ្គលដែលកំពុងដេក។

សរុបសេចក្ដីមកការបកពន្យល់ដោយសង្ខេប ក្នុងរូបចង្វាយឃុំទាំង៦នេះ គឺបានបញ្ជាក់ប្រាប់ពីការខំប្រឹងប្រែង វារងើបឡើងរបស់កូន ដែលចុះស្រង់ព្រះមាតានៅបាតខាងក្រោម។ ហើយដែលការខិតខំនេះ ធ្វើឲ្យរូបគាត់បានរីកធំនៅខាងលើ ពេលដែលគាត់បានលើករែកព្រះមាតានិងបិតា ទៅដាក់ដល់កំពូលរបស់ពួកគាត់វិញ នៅចុងបញ្ចប់នៃគ្គី។



## ៧៣/.រូបភាពទី៧៣រូបវិស្ណុនៅក្បាំងក្លែងខាងលើ(ប្រាសាទទន្លេបាត់ទី)

នៅក្នុងរូបភាពចម្លាក់នេះ ត្រូវបានចែកចេញជា៦ជាន់ ហើយក្នុងជាន់នីមួយៗ បានបង្ហាញសកម្មភាពរូបផ្សេងៗពីគ្នា តើអត្ថន័យក្នុងរូបទាំងនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? រូបនៅផ្ដែរខាងក្រោម ចែកចេញជា៣ជាន់ ហើយក្នុងជាន់ទាំង៣ នេះ កើតមានរូបឡើងបន្តគ្នារហូតដល់ចុងក្បាំងខាងលើ ក៏ដោយសារការព្យាយាមសន្សំគុណធម៌ តាំងពីរូបតូចៗក្នុងរង្វង់សីមា នៅឯសសរខាងក្រោមឯណោះ។ ដោយការព្យាយាមវាឡើងរបស់គាត់ ទីបំផុតរូបរបស់ពួកគាត់ ត្រូវបានស្រង់រែកយកទៅដាក់ ដល់កំពូលក្បាំងខាងលើមែន (មើលរូបភាព)។

១/.រូបជាន់ទី១ មានមនុស្សមួយជួរ មានពាក់មកុដ កំពុងអង្គុយចំអើត បញ្ឈរជង្គង់លើកដៃសំពះ ពុំមានពាក់អាវឡើយ តើរូបនេះ តំណាងឲ្យអ្វី? រូបកំពុងលើកដៃសំពះនេះ តំណាងឲ្យព្រះវិស្ណុសន្សំនៅគុណធម៌ គឺបារមី ឲ្យក្លាយខ្លួនជាពោធិសត្វលោកេស្វរៈ (មើលការពន្យល់រូបមុនៗ)។ ក្នុងចន្លោះរូបមួយ មានសន្លឹកក្បាច់ខណ្ឌមួយ សន្លឹកក្បាច់នោះ គឺក្បាច់ត្របកឈូកបំបែកផ្កាប់ចុះ មានន័យថា ផ្កាឈូកគឺបញ្ញារបស់គាត់ ពុំទាន់អាចត្រាស់ដឹងនៅសច្ចធម៌បានទេ គឺនៅបំបែកសន្សំបារមីនៅឡើយ។ សភាវៈពិតរបស់ផ្កាឈូក ទងផ្កាត្រូវដុះឡើងទៅលើ ពុំមែនដុះសំយ៉ុងផ្កាប់ចុះក្រោមឡើយ បើផ្កាប់ចុះ គឺពុំអាចធ្វើឲ្យផ្កានោះរីករួច បើរីករួចគឺត្រូវរលួយជាពុំខាន។

២/.រូបជាន់ទី២ ក៏បង្ហាញពីមនុស្សមួយជួរអង្គុយបញ្ឈរជង្គង់ ពុំមានពាក់មកុដ តែមានពាក់អាវ កំពុងលើកដៃទ្រផ្កាឈូកតូចមួយ នៅចន្លោះមនុស្សម្នាក់ៗមានរូបដាវសំយ៉ុងចុងផ្លែចុះក្រោម តើរូបទាំងនេះ តំណាងឲ្យអ្វី? រូបដែលមានពាក់អាវ គឺពួកគេពុំមែនជាពូជនាគ ឬពូជខ្មែរទេ ព្រោះពូជម៉ែ

ជាពូជលែងខ្លួនទទេល្វែងខាងលើ ទាំងបុរសទាំងស្ត្រី (រូបចម្លាក់ពីអតីត) មានន័យថា ពួកគេតំណាងឲ្យជនជាតិខាងក្រៅ គឺបរទេស។ ដៃដែលពួកគេទ្រផ្កាឈូកគ្រប់គ្នានោះ ន័យទីមួយ គឺពួកគេកំពុងសន្សំគុណធម៌ គឺបញ្ញាតាមការគោរពព្រះពុទ្ធសាសនាទាំងពីរនិកាយ (ហិនយាន មហាយាន) ន័យទីពីរ គឺពួកគេព្រមទទួលចុះចាញ់ឫទ្ធិបារមីរបស់ព្រះវិស្ណុខាងលើ ពេលដែលគាត់សន្សំបុណ្យ គុណធម៌បានគ្រប់គ្រាន់អាចលើកព្រះមាតាបិតាមហានគរ យកទៅដាក់ក្នុងទីខ្ពស់វិញបាន គឺពួកគេកំពុងចុះចាញ់រួចបូជាផ្កាភ្ញីចំពោះអ្នកនៅខាងលើ។ ហើយអាវដែលពួកគេពាក់ បង្ហាញពីសារជាតិជនជាតិមួយ បានផ្តាច់ចេញពីជនជាតិខ្មែរ ដែលមានទម្លាប់លែងខ្លួនទទេ រូបភាពមនុស្សមានពាក់អាវនេះ យើងច្រើនឃើញដូនតាឆ្លាក់លើជញ្ជាំងប្រាសាទ ដោយពួកគាត់ចង់ញែកលក្ខណខាងក្រៅឲ្យដាច់ពីគ្នា។ ដាវដែលសំយុងចុងចុះខណ្ឌរូបនីមួយៗឲ្យដាច់ពីគ្នានោះ តំណាងឲ្យការចុះចាញ់របស់ពួកគេនៅទីបញ្ចប់ ព្រោះការតាមព្យាបាទ ឈ្នានីស ដែលពួកគេខំបិទ លាក់ សន្ធប់ ដោយប្រើរូបភាពគ្រប់បែបយ៉ាង គឺពុំអាចឃាត់ឃាំង ការព្យាយាមរបស់កូនក្នុងការស្រង់ប្រស់ និងនាំមាតាបិតា ចេញពីទីឃុំបានទេ។ ដូចកាលក្នុងបឋមត្រាស់ មារាធិរាជបាននាំពលសេនាដ៏ច្រើន ទៅផ្ចាញ់ដើម្បីដណ្តើមយករតនបល្ល័ង្កក្រោមដើមពោធិព្រឹក្សពីព្រះសម្មាសម្ពុទ្ធនោះ ការចុះចាញ់របស់មារាធិរាជ និងបក្សពួក គឺមានន័យដូចការចុះចាញ់ក្នុងរូបចម្លាក់នេះ ដោយព្រះវិស្ណុ ឬព្រះពោធិសត្វលោកេស្វរៈ លោកបានផ្ចាញ់ដោយការមិនតបត (ពៀររម្ងាប់ដោយការមិនចងពៀរ) ដូចមានសុភាសិតខ្មែរបុរាណបានពោលទុកថា **"អ្នកផ្ចាញ់គឺព្រះ ឈ្នះលើពួកមា"**។

៣/.រូបជាន់ទី៣ គឺចែកចេញជាបី មានរូបកណ្ដាល រូបខាងឆ្វេង និងរូបខាងស្ដាំ ក្នុងរូបទាំងនេះមានឥរិយាបថផ្សេងៗគ្នា។

**ក**/.រូបកណ្ដាលតំណាងឲ្យព្រះវិស្ណុ ឬព្រះនរាយណ៍ កំពុងអង្គុយក្នុងឥរិយាបថសមាធិ ដែលមានរាងដូចជាក្បាំងតូចមួយ គ្របពីលើគាត់ជាប់ (មើលការពន្យល់ក្បាំងគ្របក្នុងរូបមុន)។

**ខ**/.ខាងឆ្វេងដៃគាត់ មានរូបមនុស្សតូចពីរនាក់ មួយឈរកាន់ច្រត់ ដែលមានសម្លៀកបំពាក់ដូចអច្ឆរា និងមួយទៀតលើកដៃសំពះ គឺតំណាងឲ្យអច្ឆរមាតាកំពុងងើបឈរឡើងកាន់ច្រត់ ហើយនៅក្រោយរូបតូចទាំងពីរ មានមនុស្សអង្គុយបត់ជើងបញ្ឈរជង្គង់ លើកដៃសំពះមានពាក់អាវ អត្ថន័យរូបដូចរូបខាងក្រោម។

គ/.ខាងស្ដាំក៏មានរូបកំពុងក្រោកឈរ និងអង្គុយបញ្ឈរជង្គង់ ក្នុងឥរិយាបថដូចរូបខាងឆ្វេង ចំណែកន័យរូបក៏ដូចរូបខាងឆ្វេងដែរ ព្រោះរូបក្នុងជាន់ទីបីនេះរលុបៗ មើលពុំសូវច្បាស់ឡើយ ដូចនេះការបកស្រាយពន្យល់ គឺទៅតាមលក្ខណរូបរាងដែលនៅសល់ ហើយច្បាស់តែប៉ុណ្ណោះ។

៤/.ក្នុងរូបជាន់ទីបួននេះ មានរូបមនុស្សស្រី និងរូបមនុស្សប្រុស នៅសង្ខាងបល្ល័ង្កកណ្ដាល ដែលរូបទាំងពីរ មានឥរិយាបថអង្គុយបត់ជើងបញ្ឈរជង្គង់ បម្រុងងើបឈរដូចគ្នា រូបនេះបានមកស្ថិតក្នុងក្បាំងក្លែងហើយ ដោយបានឆ្លងផុតសោជាន់ទីពីរ គឺផ្ដែរ។

ក/.រូបស្ត្រីដែលស្ថិតនៅពីខាងឆ្វេងបល្ល័ង្ក មានពាក់មកុដក្បាំងដូចអច្ឆរា ដៃឆ្វេងប្រឹងច្រត់ទប់ខ្លួនឡើង ដៃស្ដាំមានកាន់វត្ថុមួយក្នុងដៃ គឺតំណាងឲ្យអច្ឆរមាតាមហានគរ ដែលលោកត្រូវប្រឹងប្រែងងើបឈរឡើងទៅខាងលើជាបន្តទៅទៀត។ នៅខាងក្រោយរូបអច្ឆរមាតា មានសញ្ញាឆ្លាក់ជារូបផ្លែព្រូញមួយ ចង្អុលចុងព្រូញទៅខាងលើ គឺមានន័យថា គាត់ត្រូវប្រឹងឡើងទៅខាងលើបន្តទៅទៀត ដើម្បីចេញពីអំណាចក្រុងឃុំរបស់យក្ស។

ខ/.រូបនៅពីខាងស្ដាំបល្ល័ង្កវិញ មានរូបមនុស្សប្រុសម្នាក់មានពាក់មកុដ បែងភាគដៃជាបួន កំពុងអង្គុយបត់ជើងបញ្ឈរជង្គង់ ដៃឆ្វេងដែលបែងនោះ ខាងលើកាន់ខ្យងស័ង្ខ ខាងក្រោមដាក់លើដើមទ្វង ឯដៃស្ដាំខាងលើកាន់ដុំមូល ខាងក្រោមឱបទ្វងពីលើដៃឆ្វេង តើរូបទាំងនេះ តំណាងឲ្យអ្វី? ខ្យងស័ង្ខ តំណាងឲ្យសម្លេងផ្សព្វផ្សាយរឿងពិតរបស់អច្ឆរមាតា ដុំមូលតំណាងឲ្យ ការប្រមូលរឿងដែលហាន់ជាចំណែកៗ (ប្រាសាទហាន់ជ័យ) ឲ្យមូលជុំឡើងវិញ ដៃឱបវត្ថុមួយលើទ្វងតំណាងឲ្យ រឿងនេះតម្លៃស្មើនឹងជីវិត ឬបេះដូងរបស់គាត់ (មើលការពន្យល់ពាក្យទ្វងក្នុងភាគ២)។

គ/.រូបព្រះវិស្ណុធំឈរលើបល្ល័ង្កកណ្ដាល លើកជើងបញ្ឈរមួយចំហៀង ហាក់ដូចទើបក្រោកឈររួច មានដៃបែកជាបួន ដៃឆ្វេងខាងលើកាន់ខ្យងស័ង្ខ ដៃឆ្វេងខាងក្រោមដាក់ស្មើដើមទ្វង រួចផ្ទារបាតដៃ ឯដៃស្ដាំខាងលើវិញ កាន់ដុំមូល ដៃស្ដាំខាងក្រោមដាក់ត្រឹមទ្វង ផ្ទារបាតចេញមកខាងក្រោម ដូចដៃឆ្វេងដែរ ហើយរូបវិស្ណុធំនេះ មានពាក់គ្រឿងអលង្ការ កងដៃ កងជើង និងក្បាលមានពាក់មកុដ។ រូបនេះបើយើងមើលមួយភ្លែត ហាក់បីដូចរូបស្ត្រី រួមទាំងមានកាយវិការលើកដៃផ្ទារ មួយលើកទៅលើ មួយលើកទៅក្រោម និងលើកជើងម្ខាងទៀត ដូចជាកាយវិការអប្សរារាំលើកជើងយ៉ាងដូច្នោះ តើរូបនេះ តំណាងឲ្យអ្នកណា? រូបនេះតំណាងឲ្យព្រះវិស្ណុ ព្រោះដៃលាបាតដៃរាំនៅលើដើមទ្វងនោះ គឺបាន

បង្ហាញប្រាប់រឿងក្នុងបាតដៃ ចង្អុលបាតដៃចុះក្រោម តំណាងឲ្យរឿងក្នុងអតីតកាល របស់អច្ឆរមាតា ដែលនៅកប់ក្រោមដី គឺក្នុងភក់ក្នុងទឹក ដែលពុំមាននរណាដឹងរឿងគាត់ រីឯបាតដៃផ្ងារចង្អុលទៅលើ តំណាងឲ្យ រឿងរបស់គាត់ទៅអនាគត នឹងបានរួចផុតពីអំណាចឃុំរបស់យក្ស គឺមានន័យថា រឿងពិតរបស់គាត់ ដែលធ្លាប់តែផ្កាប់ចុះពុំមាននរណាដឹង ឥឡូវនេះ ត្រូវបានផ្ងារឡើងបើកបង្ហាញក្នុងលោកទាំង៦ ឲ្យបានដឹងពីរឿងពិតនេះ។ ដៃពីរទៀត ដៃមួយកាន់ស័ង្ខ ដៃមួយទៀតកាន់ដុំមូល អត្ថន័យដូចការពន្យល់ខាងលើ ខាងឆ្វេងដៃគាត់មានអប្សរាតូចមួយកំពុងហោះ មានន័យថា អច្ឆរមាតាត្បិតតែរឿងគាត់ពុំមាននរណាដឹង (រូបតូច) គាត់អាចអណ្តែតទៅខាងលើបានហើយ តែមិនទាន់រួចផុតពីក្បាំង ដែលមានយក្សលេបខ្លួននាគទាំងសង្ខាង មានន័យថា រូបដែលស្ថិតក្នុងក្បាំងទាំងនេះ គឺនៅក្នុងអំណាចឃុំរបស់យក្សនៅឡើយ។

៥/.រូបនៅក្នុងជាន់ទីប្រាំនេះ តើគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

**ក**/.រូបកណ្ដាល ដែលនៅក្នុងទ្រនុងខ្នងនាគក្បាំង តំណាងឲ្យព្រះពោធិសត្វលោកេស្វរៈ ឬព្រះវិស្ណុ ដែលការប្រឹងប្រែង តស៊ូ ព្យាយាម តាំងតែពីរូបតូចជាប់នៅក្នុងសីមាសសរខាងក្រោមនោះនៅទីបំផុត ការព្យាយាមរបស់គាត់ អាចឲ្យគាត់លើកអ្នកទាំងពីរ ដែលជាប់ក្នុងអំណាចឃុំរបស់យក្សឲ្យបានឡើងផុតពីអំណាចឃុំនេះ។ នៅខាងក្រោយបល្ល័ង្ក មាននិមិត្តរូបជារាងក្បាលនាគ ន័យទីមួយ គឺគាត់ជាពូជពង្សរបស់ព្រះនាងនាគ ន័យទីពីរ ព្រះពោធិសត្វអង្គនេះ ទៀងតែនឹងបានត្រាស់ដឹងជាព្រះពុទ្ធមួយអង្គ ទៅអនាគតជាតិ (មើលរូបទី៤២)។

**ខ**/.រូបក្នុងទ្រនុងខ្នងនាគពីខាងឆ្វេងខាងលើ តំណាងឲ្យព្រះថោង ឥសីកម្ពុ កៅណ្ឌិន ហ៊ុនទៀន....(ការពន្យល់រូបទី១២ និងរូបទី៤៤) ព្រោះគាត់ត្រូវបានព្យួរទោស តាំងពីអតីតកាលមកហើយៗក្នុងពេលនេះ គាត់ត្រូវរួចពីការព្យួរទោសនេះ។

**គ**/.រូបខាងឆ្វេងដៃខាងក្រោមក្នុងទ្រនុងខ្នងនាគ តំណាងឲ្យអច្ឆរមាតាមហានគរ ដែលលោកបានរួចចេញពីឃុំ តាំងពីសោទ្វារដំបូងក្នុងសមុទ្រទឹកដោះ រហូតមកទល់នឹងក្នុងរូបនេះ បានរួចផុតពីការឃុំរបស់យក្សហើយ តែពួកគាត់ពុំទាន់អាចរីកធំនៅឡើយ បើមើលតាមរូបភាពនេះ ព្រោះហេតុអ្វី? ព្រោះកូននាគទូទាំងនគរដំរី ដែលបែកជាបី ពុំទាន់មាននរណាទទួលស្គាល់រឿងពិតរបស់ពួកគាត់នៅឡើយ ហើយភាគច្រើនពុំទាន់មាននរណាហៅគាត់ថា ម៉ែឡើយ ឋាន:ម៉ែឪអាចឡើងរួច លុះត្រា

តែកូនដឹងគុណ ព្រមទទួលស្គាល់ការពិតរួចហៅ តែបើមានកូនរាប់សិបលាននាក់ ហើយកូនពុំព្រមហៅថាម៉ែឪឋានៈនោះ ពុំអាចឡើងរួចឡើយ។

**ឃ**/.រូបពីខាងស្ដាំ រូបកណ្ដាល បើយើងមើលតាមឥរិយាបថរូប គឺមិនខុសពីរូបខាងឆ្វេងឡើយ ឯអត្ថន័យរូបវិញ ក៏ប្រហាក់ប្រហែលគ្នា គ្រាន់តែមួយនៅខាងឆ្វេង មួយនៅខាងស្ដាំតែប៉ុណ្ណោះ មួយតំណាងអតីត មួយទៀតតំណាងឲ្យបច្ចុប្បន្ន មានន័យថា **ក**នៅខាងដើម និង**អ**នៅខាងចុង (មើលការពន្យល់ព្យញ្ជនៈ)។

បង្រួមសេចក្ដីមកការបកពន្យល់ពីរូបទី៧២នេះ ទោះបីមានការខ្វះចន្លោះពុំបានគ្រប់គ្រាន់ ក៏ចាត់ទុកដូចកូនសោមួយ អាចចាក់បើកមេដែលមានច្រែះនិងស្និមជាយូរមកហើយនោះឲ្យរបើកឡើងបាន ហើយវាជាការងាយស្រួលក្នុងការទៅទស្សនាប្រាសាទដើម្បីធ្វើការសិក្សាស្រាវជ្រាវ។

## ៧៤/.រូបភាពទី៧៤រូបផ្ដែរកូរសមុទ្រទឹកដោះនៅផ្ដែរ(ប្រាសាទទន្លេបាត់ទី



រូបផ្ដែរនេះសព្វថ្ងៃបានធ្លាក់ជ្រុះមកខាងក្រោម ហើយបានទុកនៅពីខាងមុខផ្លូវចូលប្រាសាទ មើលទៅគួរឲ្យសង្វេគណាស់ ដែលពីមុនផ្ទាំងផ្ដែរនេះបានទ្រដោយសសរពេជ្រមួយគូ ហើយផ្ដែរនេះជាកែវមរតកដ៏មានតម្លៃដែលពុំអាចកាត់ថ្លៃបាន ព្រោះវាជារឿងនៅក្នុងចិត្តរបស់អច្ឆរមាតាឥឡូវត្រូវធ្លាក់មកដីដោយរងការបំផ្លាញពីធម្មជាតិនិងសង្គ្រាម។ តើផ្ដែររឿងកូរសមុទ្រទឹកដោះនេះ ខុសគ្នាពីរឿងកូរសមុទ្រទឹកដោះនៅប្រាសាទដទៃឬ? ក្នុងរូបផ្ដែរនេះចែករូបជាបួនថ្នាក់ហើយចែកជាបីចំណែក ចំណែកខាងក្បាល ចំណែកកណ្ដាលនិងចំណែកខាងកន្ទុយ។

ក/.ថ្នាក់ជាន់ទីមួយខាងក្រោមត្រង់កណ្តាល មានរូបអណ្តើកមួយនៅស្មើនឹងជើងអ្នកឈរ ហើយនៅពីក្រោយអណ្តើកនោះមានរូបមនុស្សពាក់កណ្តាលខ្លួន តើអណ្តើកតំណាងឲ្យអ្វី? មនុស្សពាក់កណ្តាលខ្លួននោះតំណាងឲ្យអ្វី? អណ្តើកតំណាងឲ្យឧបាទានក្ខន្ធប្រាំ (មើលការពន្យល់ក្នុងភាគមួយ) មនុស្សនៅពីក្រោយអណ្តើកតំណាងឲ្យកូននាគគឺព្រះវិស្ណុ ដែលត្រូវចុះមកក្នុងសមុទ្រទឹកដោះ ស្វែងរកដំណក់ទឹកដោះដំបូងដែលជាទឹកអម្រិត (មិនចេះស្លាប់) គឺមានអាយុរាប់ពាន់ឆ្នាំហើយដែលដំណក់ទឹកដោះនេះបានបង្កើតពូជពង្សខ្មែរបន្តគ្នា។

ខ/.ថ្នាក់ជាន់ទីពីរត្រង់រូបកណ្តាល មានរូបខ្លួននាគព័ទ្ធជុំវិញដងស្នូលសម្រាប់បង្វិលកូរ មានមនុស្សខាងឆ្វេងឈរទាញខាងកន្ទុយ ឯខាងស្តាំឈរទាញខាងក្បាល នៅខាងក្រោមក្បាលនាគមានមនុស្សតូចម្នាក់អង្គុយបញ្ឈរជង្គង់នៅលើផ្កាឈូក កំពុងទប់ក្បាលនាគកុំឲ្យអ្នកទាំងសង្ខាងទាញកូររួច។ តើរូបទាំងអស់នេះតំណាងឲ្យអ្វី? ហេតុអ្វីក្នុងរូបនេះឥតមានយក្សក្បាល១០ចាប់ខាងក្បាលនាគ ហានុមានចាប់ខាងកន្ទុយដូចរូបកូរសមុទ្រទឹកដោះនៅថែវអង្គរវត្ត?

១/.ស្នូលកណ្តាលនិមិត្តរូបតំណាងឲ្យការបញ្ចប់នៅពៀរវេរា រវាងអ្នកទាំងសង្ខាងព្រោះរូបកំពុងទាញខាងក្បាលតំណាងឲ្យអ្នកចាប់មាតានាគយកទៅដាក់ឃុំ អ្នកទាញខាងចុងកន្ទុយតំណាងឲ្យអ្នកចង់ជួយព្រះមាតានាគឲ្យរួចពីឃុំ តែការប្រទាញនេះត្រូវប្រើរយពេលអស់ជាង ពីរពាន់ឆ្នាំកន្លងមកហើយ។

២/.ក្រោយមកមានជីក្រែង ដែលត្រូវឡើងចេញពីភក់ ពីទឹកដើម្បីបញ្ចប់នូវពៀរនេះ (មើលការពន្យល់ពាក្យជីស្វរ និងជីក្រែងស្ពានកំពុងក្តីភាគ២)។ ហើយជីក្រែងនេះ (ជីក្រែង ជីស្វរ ព្រះវិស្ណុ...) គឺរូបដែលអង្គុយលើផ្កាឈូក ដែលកំពុងយកដៃទៅទប់ក្បាលនាគ (មើលរូប) ឈប់ឲ្យអ្នកទាំងសង្ខាងទាញកូររួចទៀត ព្រោះបើពុំមានព្រះវិស្ណុ ឬជីក្រែងទៅធ្វើអាជ្ញាកណ្តាលទេ រឿងកំពុងក្តីក្តាំនេះ (ស្ពានកំពុងក្តី) មិនអាចចប់ដោយគ្មានហេតុបានឡើយ។ ពេលនេះទុក្ខវេទនារបស់អច្ឆរមាតាមហានគរ ចាប់ផ្តើមធូរស្រាលបន្តិចម្តងៗ ព្រោះនិមិត្តរូបនាគដែលតំណាងឲ្យគាត់នោះ គេឈប់ចាប់ទាញគាត់យកទៅដាក់ឃុំក្នុងសមុទ្រទឹកដោះទៀតហើយ (មើលការពន្យល់ក្នុងភាគ១)។

**គ**.ថ្នាក់ជាន់ទីបីត្រង់ចំណុចកណ្ដាល មានរូបព្រះវិស្ណុឱបបង្គោលស្នូលមានដៃបួន និងមានរូបមួយទៀត កំពុងសំយ៉ុងក្បាលចុះមកខាងក្រោម នៅពីសង្ខាងព្រះវិស្ណុគឺមានសត្វករវិកជាជួរ តើរូបទាំងអស់នេះ តំណាងឲ្យអ្វី?

១/.រូបដៃបួនកំពុងឱបបង្គោលតំណាងឲ្យព្រះវិស្ណុ ដែលចុះមកស្រង់រឿងអច្ឆរមាតាមហានគរ នៅក្នុងសមុទ្រទឹកដោះ ក្នុងការស្រង់នោះទៀតសោត ពេលដែលបានដឹងរឿងហើយ គឺលំបាកនឹងយកមកផ្សព្វផ្សាយឲ្យគេជឿណាស់ នេះបើយើងមើលតាមឥរិយាបថ ដែលគាត់ប្រឹងឱបរឿងឡើងតាមបង្គោលស្នូលនេះ។ ពីមុនយើងធ្លាប់តែឃើញគាត់ក្នុងឥរិយាបថដេក ដឹកនាំអច្ឆរមាតាចេញពីគុក (វិស្ណុដេក) មើលទៅហាក់ដូចជាធម្មតា បើមើលដោយពុំបានគិតពិចារណា ឥឡូវដូនតាគាត់ឆ្លាក់ឲ្យយើងមើលសកម្មភាពតោងបង្គោលនាំរឿងឡើងមកខាងលើ ទើបយើងឃើញថាមានការលំបាក។ ព្រោះបើមើលក្នុងរូបនេះ គាត់ឱបរឿងមាតាផងយឹតយោងខ្លួនឯងផង ដោយមានតែជើងមួយចំហៀងគាប នឹងដៃមួយចំហៀងឱបបង្គោលតោងឡើង ចំណែកឯដៃទាំងពីរទៀត ជាប់កាន់វត្ថុផ្សេងៗពុំអាចជួយតោងបានឡើយ។ ហើយជាន់ទីបីនេះ ក៏ជាចំណុចផ្ចិតគឺជាចំណុចកណ្ដាលក្នុងមង្គលទី៣ ដែលខ្លួនត្រូវដេក ឬឱបរឿងឡើង ហើយក៏ជាចំណុចបំបែកខ្នែងដើម្បីរែកម៉ែឪ យកទៅដាក់លើកំពូលព្រះវិហារវិញ (មើលការពន្យល់វិស្ណុដេក ឬផ្ទុំរូបមុន)។

២/.រូបសំយុងក្បាលចុះនៅខាងឆ្វេងដៃនោះ ក៏តំណាងឲ្យព្រះវិស្ណុដែរ តែរូបនេះមានន័យបង្កប់ពីរយ៉ាង។

**អត្ថន័យទី១**គាត់ត្រូវទម្លាក់ខ្លួនចុះមកក្នុងសមុទ្រទឹកដោះ ដើម្បីជ្រាវរករឿងពិតរបស់អច្ឆរមាតាដែលកំពុងរងទុក្ខ ព្រោះរឿងនេះបានលុបបាត់ដានស្នាមអស់ទៅហើយ (មើលប្រស្នាលុបដានសាដាន លក់ដានក្នុងមង្គល៣ភាគ២)។

**អត្ថន័យទី២**តំណាងឲ្យរូបព្រះវិស្ណុងនេះ ពេលដែលបាននាំរឿងមកដល់ចំណុចផ្ចិត ឬចំណុចកណ្ដាលនេះ ត្រូវយក្សរុញច្រានគាត់ទម្លាក់ពីលើ (មើលការពន្យល់រូបទី១) តែដោយអំណាចបុណ្យរបស់គាត់នៅមាន ជីវិតនេះមិនទាន់បែកធ្លាយទេ គាត់អាចនៅជួយស្រង់ប្រស់ព្រះម៉ែឪជាបន្តទៅទៀត ព្រោះភារកិច្ចនាំរឿងចេញនេះនៅមិនទាន់ចប់នៅឡើយ។

៣/.សត្វករវិកសង្ខាង តំណាងឲ្យការផ្សព្វផ្សាយមនោគមវិជ្ជាសណ្ដំរបស់បរទេស សង្កត់អ្នកខាងក្រោមមិនឲ្យដឹងការពិត (មើលការពន្យល់សត្វករវិករូបទី១ និងរូបទី២)។

ឃ/.ថ្នាក់ជាន់ទីបួនចំណុចកណ្ដាលមានរូបនៅកណ្ដាល នៅខាងឆ្វេងដៃនិងខាងស្ដាំដៃមានរូបមនុស្សពីរនាក់នៅជាប់ក្នុងរង្វង់សីមា ហើយបន្ទាប់ពីខាងឆ្វេងដៃរូបក្នុងសីមា មានរូបអង្គុយលើបន្ទាត់កំពុងលើកដៃសំពះ និងរូបឈរជ្រៀងបែងភាគដៃបួន។ នៅខាងស្ដាំដៃរូបជាប់ក្នុងសីមាក៏មានរូបអង្គុយលើបន្ទាត់ កំពុងលើកដៃសំពះដូចខាងឆ្វេងដៃរ ហើយនៅខាងចុងមានរូបមួយស្ថិតក្នុងឥរិយាបថហោះ កំពុងទម្លាក់ខ្លួនចុះមកខាងក្រោម ដោយនៅក្នុងដៃរបស់រូបមានកាន់ផ្កាឈូកមួយទងផង។ តើរូបទាំងអស់នេះ មានអត្ថន័យដូចម្ដេច?

១/.រូបកណ្ដាលអង្គុយលើដងស្នូលដែលមានរាងបល្ល័ង្កជាផ្កាឈូកនោះ គឺការខំប្រឹងឡើងរបស់ព្រះវិស្ណុពីខាងក្រោមមកខាងលើ ពេលមកដល់ចំណុចនេះគាត់បានក្លាយជាព្រះព្រហ្ម ដោយគុណធម៌របស់គាត់គ្រប់គ្រាន់ អាចបំឡែងរូបគាត់ឲ្យទៅជាព្រហ្មបាន ហើយព្រហ្មនោះទៀតសោតគឺជាកូននាគ ដែលចុះទៅស្រង់អច្ឆរមាតា កប់នៅខាងក្រោមភក់ (អាថ៌កំបាំងឈ្មោះថ្មភក់)។ ទីបំផុតនៃសេចក្ដីព្យាយាមបានមកដល់ចំណុចទ្វារទីបួននេះ បានស្ដាបនាឲ្យគាត់ក្លាយជាព្រះព្រហ្ម (និមិត្តរូប) ហើយរូបព្រហ្មបានបែងភាគដៃបួន ដៃពីរខាងក្រោមបិតនៅក្នុងឥរិយាបថសមាធិ ឯដៃពីខាងលើកំពុងព្យាយាមបើកគម្រប នៅសល់ចុងក្រោយដែលគ្របពីលើ (មើលការពន្យល់រូបទី៧២) ឯរូបអង្គុយលើបល្ល័ង្កផ្កាឈូក តំណាងឲ្យពោធិសត្វកំពុងសន្សំបារមី។

២/.រូបសង្ខាងស្ថិតក្នុងរង្វង់សីមា មួយតំណាងឲ្យអច្ឆរមាតាមហានគរមួយទៀតតំណាងឲ្យបិតាមហានគរ ដែលអ្នកទាំងពីសុទ្ធតែជាប់ក្នុងឃុំដូចគ្នា គ្រាន់តែបិតានៅក្រៅឃុំគឺព្យួរទោស ឯមាតាវិញសុខចិត្តទទួលទោសទាំងពីររបស់ស្វាមីនិងកូន (មើលការពន្យល់ក្នុងរូបទី១២)។

៣/.រូបអង្គុយសង្ខាងកំពុងលើកដៃសំពះ គឺតំណាងឲ្យមាតាទាំង១២ ដែលរង់ចាំកូនយកកែវភ្នែកមកឲ្យខ្លួនវិញ ព្រោះពួកខ្លួនត្រូវបាត់បង់កែវភ្នែក ដោយហេតុបាបកម្មចាស់តាមឲ្យផល (មើលរឿងពុទ្ធិសែននាងកង្រី) ឥឡូវពួកគាត់មានក្ដីសង្ឃឹមថានឹងមានកូននាគណាមួយ ដែលសល់ពីពួកគាត់បែកស៊ី គេនឹងយកកែវភ្នែកមកឲ្យពួកគាត់វិញជាពុំខាន។ ចំណែកឯរូបឈរជ្រៀងមានដៃបែកជា

ប្អូន មិនដឹងជារូបយក្ស ឬព្រះវិស្ណុឡើយ ព្រោះមើលពុំច្បាស់ដោយសភាពមុខរបស់រូប បានបាក់បែកអស់ហើយ។

៤/.រូបទេវតាដែលកំពុងហោះចុះមកក្រោម កាន់ផ្កាឈូកក្រពុំដ៏ធំមួយទងនៅក្នុងដៃនោះ។

**ទី១តំណាងឲ្យ**គណបក្សដែលមាននិមិត្តរូបដែលមានសញ្ញាសំគាល់រូបទេវតា (គណបក្សប្រជាជន)។

**ទី២តំណាងឲ្យ**អ្នកនាំយកផ្កាឈូក (និមិត្តរូប) មកឲ្យព្រះវិស្ណុដែលនៅជាប់ខាងក្នុងសមុទ្រទឹកដោះ ឲ្យលោកបានដឹងថា រូបលោកគឺជាពោធិសត្វលោកេស្វរៈ ដែលក្នុងជាតិនេះលោកត្រូវបំពេញបារមីគឺអធិដ្ឋានបរមត្ថបារមី គឺអធិដ្ឋានជីវិតឲ្យទៅយក្ស ដើម្បីឲ្យយក្សដោះលែងអច្ឆរមាតាឈប់យកគាត់ធ្វើជាខ្សែទាញបន្តទៅទៀត។ បើគ្មានទេវតាមកដាស់តឿនពន្យល់ដល់គាត់ទេនោះ (សុបិន្ត) គាត់ពុំអាចបំពេញនៅគុណធម៌គឺបរមត្ថបារមីនេះបានឡើយ ព្រោះធម៌ទាំងឡាយអាចកើតមានឡើងដោយមានហេតុនឹងបច្ច័យនៃធម៌ បើពុំមានហេតុនឹងបច្ច័យទេ ចក្រគឺវដ្តសង្សារនេះពុំអាចវិលទៅមុខបានឡើយ បើវដ្តសង្សារពុំមានការសន្សំនៅគុណធម៌ គឺបារមីក៏ពុំមានដែរ (មើលការបរិនិព្វានរបស់ព្រះអរហន្តទាំងឡាយគឺវដ្តសង្សារ ឈប់វិលទៅមុខទៀតហើយ)។

សរុបសេចក្ដីមកការបកពន្យល់ក្នុងរូបភាពនេះ គ្រាន់តែជាការប្រៀបធៀបរូបកូរសមុទ្រទឹកដោះក្នុងប្រាសាទមួយ ទៅប្រាសាទមួយទៀត ដែលមានសកម្មភាពរូបផ្សេងៗគ្នានោះ ព្រោះដូនតាគាត់ចង់ឲ្យកូននាគឆ្ងល់ថា ឈ្មោះរូបកូរសមុទ្រទឹកដោះដូចគ្នា ហេតុអ្វីបានជាសកម្មភាពរូបផ្សេងៗគ្នាទៅវិញ?

## ៧៥/.រូបភាពទី៧៦រូបក្នុងរង្វង់បេះដូង(មិនដឹងប្រភព)



តើរូបក្នុងរង្វង់ជារាងស្លឹកពោធិ ឬស្លឹកម្លូនេះ តើដូនតាយើងគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

**ក**/.រង្វង់ព័ទ្ធពីខាងក្រៅដែលមានរាងជាបេះដូង ស្លឹកពោធិ ស្លឹកម្លូ....តំណាងឲ្យអ្វី? បើចង់វែកញែករូបរង្វង់នេះ យើងត្រូវមើលការបកពន្យល់ពីល្បែងចាក់ទឹកដូងទាំង២បែប ព្រោះរាងរូបរង្វង់នេះព័ទ្ធពីខាងក្រៅ ចំណែកឯរូបរឿងនៅពីខាងក្នុងរង្វង់នេះ ដូចជារឿងក្នុងចិត្ត ឬក្នុងបេះដូង ដែលបានប្រព្រឹត្តនូវកម្មទាំងកម្មខ្មៅ ទាំកម្មស(កម្ម = អំពើ) អំពើទាំងនេះ តែយកទៅលាក់ទុកក្នុងចិត្ត (ហទយ:) គឺក្នុងបេះដូងនេះឯង។ ក្នុងបេះដូងដ៏ធំនេះ គឺមានរូបទាំងអស់៥ រូបពីរជាសត្វឯរូបបីទៀតជាមនុស្ស តើរូបទាំងនេះ ព្រឹទ្ធដូនតាយើងគាត់ចង់និយាយប្រាប់យើងជាកូននាគពីអ្វីខ្លះ? ចង់ដឹងពីរឿងម៉ែ ទាល់តែចាក់ទឹកក្នុងបេះដូង (ទឹកចិត្ត) ចេញពីទ្រូងម៉ែ ទើបដឹងរឿងរបស់ពួកគាត់ ព្រោះរឿងរបស់ពួកគាត់បានលាក់ទុកនៅក្នុងចិត្ត ក្នុងបេះដូង ក្នុងទ្រូង (មើលការពន្យល់ក្នុងចាក់ទឹកដូងភាគ១)។

**ខ**/.រូបកណ្ដាលតំណាងឲ្យព្រះវិស្ណុ ព្រះឥសូរ ព្រះពោធិសត្វលោកេស្វរៈ....ដៃស្ដាំខាងក្រោមរបស់គាត់កាន់ច្រត់ទប់ខ្លួន ដៃស្ដាំខាងលើកាន់ខ្សែផ្ដាំសម្រាប់ភាវនារម្ងាប់ចិត្ត ដៃឆ្វេងខាងក្រោមឱបដុំមូលផ្ទិបទ្រូង ដៃឆ្វេងខាងលើលើកឡើងទៅលើជាប់នឹងរង្វង់។ ចំណែកជើងខាងឆ្វេង ជាន់ស៊ប់នៅលើខ្នងគោ ឯជើងខាងស្ដាំវិញ ដាក់បន្ដើរពីលើ គឺជាន់មិនទាន់ស៊ប់ឡើយ ក្នុងសកម្មភាពរបស់រូបនេះ បានបង្ហាញប្រាប់ថា គាត់បានងើបឈរហើយ ទោះបីជើងទាំងពីររបស់គាន់ មិនទាន់ឈរស៊ប់ក៏ដោយ ក៏គាត់ប្រឹងទប់ច្រត់ឈរឡើង នាំរឿងក្នុងបេះដូងនេះយកចេញទៅខាងក្រៅ ដើម្បីឲ្យកូននាគអ្នកទទួលមរតកម៉ែបានដឹងរឿងក្នុងបេះដូងព្រះម៉ែ (មើលចាក់ទឹកដូងភាគ១)។

**គ**/.រូបសត្វគោខាងក្រោមតំណាងឲ្យសេចក្ដីព្យាយាម តែក្នុងរូបនេះគោដេកផងងើយមើលអ្នកឈរនៅពីខាងលើផង មានន័យថាព្រះវិស្ណុខាងលើទោះបីជាក្រោកឈរបាន តែសេចក្ដីព្យាយាមរបស់គាត់ពុំទាន់អាចងើបឈរបានឡើយ (ក្នុងសីល សមាធិ បញ្ញា)។ ដូចនេះក្នុងការដឹកនាំរឿងអច្ឆរមាតាពីខាងក្នុងបេះដូងព្រះម៉ែគឺពុំអាចមានកម្លាំងគ្រប់គ្រាន់នាំរឿងចេញ ទៅផ្សព្វផ្សាយខាងក្រៅបានឡើយ ព្រោះកម្លាំងព្យាយាមរបស់គាត់មិនទាន់គ្រប់គ្រាន់។

**ឃ**/.រូបស្ត្រីដែលនៅពីខាងក្រោយ តំណាងឲ្យអ្នកដែលជួយជាកម្លាំងដល់គាត់ គឺភរិយា ដៃរបស់ស្ត្រីនោះម្ខាងឱបកូនឯដៃម្ខាងទៀត កាន់ដំបងគោះគោឲ្យក្រោកឡើង។ មានន័យថាស្ត្រីនេះមានកូនម្នាក់ក្នុងបន្ទុក ហើយភារៈកិច្ចរបស់គាត់ គឺជួយដាស់សេចក្ដីព្យាយាមរបស់ព្រះវិស្ណុ(គោ) ឲ្យប្រឹងក្រោកឡើង ជួយនាំរឿងព្រះម៉ែចេញ។ ឯកូនដែលឱបក្នុងដៃ ពុំបានបង្ហាញពីសកម្មភាពអ្វីឲ្យដឹងបានឡើយ ប្រហែលជាគេនៅក្មេង ឬតូចពេកមិនទាន់អាចជួយបាន។

**ង**/.ស្វាក៏តំណាងឲ្យកូននាគដែលត្រូវជួយនាំរឿងដែរ តែស្វាក្នុងរូនេះគឺកំពុងរវល់ហូបអាហារ គឺមានន័យថាគេកំពុងជាប់រវល់ក្នុងកិច្ចការងារចិញ្ចឹមជីវិត។ ដោយការស្វះស្វែងរកទ្រព្យចិញ្ចឹមគ្រួសារ ក្នុងរូបនេះ ស្វាមិនទាន់ក្រោកឡើងឡើយ គឺនៅអង្គុយហើយស្វានេះទៀតសោត គ្មានគ្រឿងអលង្ការទេតំណាងឲ្យអ្នកពុំសម្បូរយសសក្តិ និងទ្រព្យសម្បត្តិឡើយ។

សរុបសេចក្ដីមកការពន្យល់ដោយសង្ខេបនេះ ទោះបីក្នុងផ្ទាំរង្វង់បេះដូងនេះមានរូបភាពតិចក៏ដោយ ប៉ុន្តែសកម្មភាពបានពន្យល់ពីអត្ថន័យគ្រប់គ្រាន់ អាចឲ្យយើងពិនិត្យមើលអត្ថន័យក្នុងរូប

ដែលប្រាប់ពីហេតុនៅក្នុងបេះដូងទាំងមូលនេះបាន ហើយអាចឲ្យយើងដឹងពីការឃើតឃូរក្នុងការនាំរឿងអច្ឆរមាតាចេញមកខាងក្រៅ ប្រាប់ដល់កូននាគប្រុសស្រី។

## ៧៦/.រូបភាពទី៧៦រូបយោនីមានស្នឹងចុកបិទ(នៅប្រាសាទបាណន់)



តើរូបយោនីដែលនៅសេសសល់នេះ គាត់ចង់ប្រាប់យើងពីរឿអ្វី? រូបយោនីតំណាងឲ្យមាតុភូមិ (ទ្វារមាសរបស់ស្ត្រី) នៅប្រាសាទបាណន់នេះ បើយើងមើលសំណល់ ដែលនៅសេសសល់ពីការដាប់បំផ្លាញ យើងអាចយល់ពីអត្ថន័យរូប ដែលព្រឹទ្ធដូនតាលោកបានទុកប្រស្នារូបឲ្យយើងឆ្ងល់ថា ហេតុអ្វីបានជារូបយោនីនេះ មានស្នឹងមួយចុកពីខាងលើជាប់? ដែលនៅពីខាងលើក្បាលស្នឹងមានរូបមនុស្សម្នាក់ ឈរសង្កត់ពីលើថែមទៀត តើឲ្យអច្ឆរមាតាដែលនៅទ្រពីខាងក្រោមយោនីនោះ លោកចេញមកម្ដេចរួច (មើលរូបទី៦)? ប្រស្នាក្នុងរូបនេះ បើយើងមើលរួចពិចារណាត្រិះរិះគិត យើងកាន់តែមានក្ដីអាណិតអាសូរដល់លោកអ្នកមានគុណ គឺមាតាបិតាបច្ចុប្បន្ន និងអច្ឆរមាតាពីអតីត ដែលលោកខិតខំបង្កើតនគរម៉ែនេះទុក ទីបំផុតបានត្រឹមតែទូលភេទរបស់ខ្លួន គឺចាត់ទុកថានៅគ្រាន់បើ។ តែក្នុងរូបនេះ ទោសរបស់គាត់ពុំមែនតែប៉ុណ្ណឹងទេ គឺគេបោះស្នឹង (ប្រាសាទស្នឹង) ចុកបិទរន្ធយោនីនោះថែម

ទៀត ដោយខ្លាចគាត់លួចចេញមកខាងក្រៅ គេថែមមនុស្សម្នាក់ទៀត (បក្សពួកយក្ស) ឲ្យជាន់សង្កត់ពីលើក្បាលស្នឹង។ នៅលើម្រាមជើងរូបដែលឈរនៅលើក្បាលស្នឹង រូបខ្លះមានកងសោចាក់ជាប់គ្រប់ម្រាមទាំងប្រាំ មានន័យថាមិនឲ្យរូបឈរនៅលើក្បាលស្នឹងដែលចុកបិទនេះ ដើរទៅណារួចឡើយ នេះជាហេតុដែលអច្ឆរមាតាឬបិសាចពស់ លោកលែងចេញមកខាងក្រៅ ដើម្បីជួបនឹងកូនបានទៀត។ ចំណែកមាតាបិតាបច្ចុប្បន្នវិញ លោកមើលការបកពន្យល់នេះហើយ លោកគួរតែតក់ស្លុតរួចភ្ញាក់ស្មារតីឡើង កុំភ្លេចធ្វើទីពឹងឲ្យខ្លួនឯង ហើយរវល់តែធ្វើទីពឹងឲ្យអ្នកដទៃ បើមិនដូច្នោះទេដំណើរផ្លូវគឺមិនខុសពីបុព្វដូនតាយើងឡើយ ត្រូវរងទុក្ខទោសក្នុងអបាយភូមិតែឯង រងចាំកូនឲ្យគេជួយគឺមានសង្ឃឹមតិចតួចណាស់ បើនិយាយពីកូនសព្វថ្ងៃនេះវិញ ភាគច្រើនគឺពួកគេលែងជឿកម្មឲ្យផលទៀតហើយ ព្រោះមនោគមវិបបថ្មី (សំភារៈនិយម បច្ចេកវិជ្ជាសម័យថ្មី និងគ្រឿងញៀន) កំពុងលុកលុយពង្វក់ស្មារតីពួកគេ។

សរុបសេចក្តីមករូបនេះត្បិតតែនៅសល់រាងហេតុតិចតួចអាចមើលយល់តែវាមានសារសំខាន់ណាស់ សម្រាប់ឲ្យយើងជាកូននាគងាយមើលយល់ពីទម្ងន់ទុក្ខវេនា ដែលអច្ឆរមាតាកំពុងទទួលនូវបាបពីអតីតរបស់លោក ហើយក៏ជាប្រយោជន៍មួយជួយដាស់ស្មារតីកូននាគ ដែលកំពុងទទួលមរតកព្រះម៉ែឲ្យជួយថែទាំសំណល់កេរដែលនៅសល់ និងជួយឧទ្ទិសមហាកុសល (ឧទ្ទិសបុណ្យ) ជូនទៅឲ្យពួកគាត់។ ព្រះពុទ្ធសាសនាជាចំណែកកេរមរតកម៉ែមួយដ៏សំខាន់ ដែលព្រះមាតាមហានគរលោកបាននាំមកប្រតិស្ថានទុកសម្រាប់គោរពបូជានិងសិក្សារៀនសូត្ររហូតមកដល់សព្វថ្ងៃ ដើម្បីទុកជាប្រយោជន៍ដល់កូននាគទាំងពីរភេទ (ឧត្តមភេទ ហីនភេទ) ហើយលោកសង្ឃឹមថា ពួកគេនឹងនឹកឃើញនៅឧបការគុណរបស់ពួកគាត់ហើយគេនឹងព្យាយាមជួយគាត់ (នេះជាហេតុដែលព្រះពុទ្ធសាសនាមកប្រតិស្ថានក្នុងមាតុភូមិ) ។

## ៣៧/.រូបភាពទី៣៧រូបលើជញ្ជាំង(ពុំដឹងប្រភព)

រូបភាពចម្លាក់នេះ បើយើងមើលមួយភ្លែតហាក់បីដូចជាធម្មតា តែបើយើងមើលឲ្យយូរបន្តិចទើបគួរឲ្យអាណិតសង្វេគគាត់ណាស់ ព្រោះហេតុអ្វី? មនុស្សម្នាក់ដែលត្រូវផ្លែព្រួញដោតពីលើខ្លួនច្រើនម្លឹងៗ តើគាត់មានការឈឺចាប់យ៉ាងណាទៅ? តើនៅក្នុងរូបនេះ តំណាងឲ្យអ្វីខ្លះ? ក្នុងរូបដែលមាននេះ ចែកចេញជាបួនជាន់ ជាន់ទីមួយ ទីពីរ ទីបី និងជាន់ទីបួន។

***ក***/.រូបខាងក្រោមបង្ហាញពីរូបស្ត្រីមួយជួរកំពុងអង្គុយកាន់ដងក្លស់ និងដងថ្នោលដោលទៅលើ គឺតំណាងឲ្យ (មេនឹងម៉ែ) អ្នកបាំងក្លស់ និងជួយជ្រោងមនុស្សនៅខាងលើ។



***ខ***/.មនុស្សកំពុងអង្គុយបញ្ឈរជង្គង់លើកដៃសំពះ តំណាងឲ្យអ្នកអង្វរចំពោះអ្នកដែលដេកនោះ ឲ្យប្រឹងក្រោកឈរតស៊ូព្យាយាមបន្តទៅទៀត ដើម្បីស្រង់រឿងព្រះមេនិងព្រះម៉ែខាងក្រោម យកទៅបង្ហាញកូននាគខាងលើ ឲ្យពួកគេបានដឹង។

***គ***/.រូបដេកដែលត្រូវដោលទ្រពីខាងក្រោមនោះ តំណាងឲ្យព្រះវិស្ណុដេក តែព្រះវិស្ណុដេកនេះខុសពីព្រះវិស្ណុមុនៗ ព្រោះហេតុអ្វី? រូបព្រះវិស្ណុមុនៗ បើយើងមើលដោយពុំបានគិតពិចារណា យើងនឹងពុំបាននឹកឃើញទុក្ខវេនារបស់គាត់ក្នុងការនាំរឿងអច្ឆរមាតាចេញពីទីឃុំឡើយ។ ព្រោះខ្លួនត្រូវដេកផងវារលូនផង នាំព្រះមាតាចេញផង តើមានការលំបាកយ៉ាងណា? យើងគ្រាន់តែវារលូនម្នាក់ឯងលំបាកណាស់ទៅហើយ ចុះទម្រាំមានអូសស្ត្រីម្នាក់ចេញពីទីទាប យកទៅដាក់ទីខ្ពស់នោះ (ភ្នំព្រះវិហារ) តើមានការលំបាកយ៉ាងណា? នេះជាន័យដែលបង្កប់នៅក្នុងប្រស្នារូប។ ចុះចំណែកព្រះវិស្ណុផ្ទុំនៅក្នុងរូបនេះវិញ ដូនតាគាត់បានប្រាប់បង្ហាញយើងពីសកម្មភាព ដែលដេកនៅលើទម្រថ្នោលដែលស្ត្រីខាងក្រោមដោលឡើង វាងាយនឹងធ្លាក់ចុះមកខាងក្រោមណាស់ តែដើម្បីបុព្វហេតុព្រះមេ និងព្រះម៉ែ គាត់សុខចិត្តដេកស៊ូទ្រាំលំបាក នៅលើទ្រនើរឈើដោលដែលយោលចុះយោលឡើង ទៅតាមកម្លាំងទប់របស់ស្ត្រីដែលកាន់នៅខាងក្រោម។ ហេតុតែរឿងព្រះម៉ែដែលបានកប់លុបអស់រយពេលរាប់ពាន់ឆ្នាំ

នេះ ធ្វើឲ្យគាត់លំបាកនឹងរកលំនឹងឬតឹកតាំង ដើម្បីពន្យល់កូននាគក្នុងសម័យនេះ ឲ្យគេជឿបាន ណាស់ ព្រោះរឿងរបស់អច្ឆរមាតាបានត្រូវគេលុបដាន សាដាន និងលក់ដានអស់ហើយ (មើលលុប ដាន សានដាន លក់ដានមង្គល៣ភាគ២)។ នៅលើដងខ្លួនគាត់ពីខាងលើ មានផ្លែព្រួញដ៏ច្រើនបាន ដោតចាក់លើខ្លួនគាត់ តើផ្លែព្រួញទាំងនោះ តំណាងឲ្យអ្វី? ផ្លែព្រួញតំណាងឲ្យការឈឺចុកចាប់ ពេល ដែលត្រូវផ្លែព្រួញនោះដោតនៅលើសាច់ ផ្លែព្រួញមួយគឺឈឺចាប់មួយ បើផ្លែព្រួញដ៏ច្រើនយ៉ាងនេះ ដោតនៅលើខ្លួន តើគាត់ឈឺចាប់ពើតដូចម្តេចទៅ? (មើលការពន្យល់ពីប្រាសាទគក់ទ្រូងនៅអង្គរវត្ត ភាគ២)។ ព្រោះតែបុព្វហេតុមេ និងម៉ែ គាត់សុខចិត្តដេកទ្រាំក្នុងការឈឺចុកចាប់គ្រប់បែបយ៉ាង ដើម្បី នាំរឿងទុក្ខវេទនារបស់អច្ឆរមាតា នាំយកចេញមកបង្ហាញឲ្យកូននាគទាំងពីភេទ បានដឹងពីសាវតា ពិតរបស់ខ្លួន ព្រោះព្រះម៉ែមហានគរ លោកឈឺចុកចាប់រងទុក្ខវេទនាជាងរាប់ពាន់ម៉ឺនសែនដង លើស គាត់ទៅទៀត ក្នុងសមុទ្រទឹកដោះខ្លួនឯង ដែលជាសមុទ្រគម្រង់ (មើលការពន្យល់ក្នុងភាគ២) ព្រោះ ហេតុតែតាំងខ្លួនជាម៉ែគេ (ស្តរតាំងម៉ែ មើលរូបពន្យល់មុនៗ)។

**ឃ**/.ចំណែកឯរូបមនុស្សដែលនៅខាងចុងជើងគាត់ ដៃម្ខាងកាន់ខែលនិងដៃម្ខាងទៀតកាន់ អាវុធ បើមើលតាមសកម្មភាពរូបនេះ ហាក់ដូចជាកំពុងលើអាវុធដែលនៅក្នុងដៃ យកមកចាក់ពីលើ ខ្លួនរបស់ព្រះវិស្ណុដេកនេះបន្ថែមទៀត ព្រោះរូបនេះត្រូវដាច់ត្រឹមនេះ ដូច្នេះរូបព្រះវិស្ណុដេកនេះគាត់ត្រូវ រងនូវការឈឺចាប់មួយថ្មីថែមទៀត។

សង្ខេបសេចក្តីមកយើងអាចយល់បានថា រូបនេះពុំមែនជាសាកសពមនុស្សដេកស្លាប់ឡើយ ព្រោះមនុស្សស្លាប់គេតែងដាក់ក្នុងម្ឈូស ឬដំកល់នៅលើជើងថ្ករសម្រាប់បូជា គឺពុំមែនដាក់នៅលើ ឈើមនុស្សដោលពីខាងក្រោមដូច្នេះឡើយ។ សកម្មភាពរូបនេះ អាចអណ្តែតនៅពីខាងលើផ្ទោល ដែលដោលដោយព្រះមេ និងព្រះម៉ែបាននោះ ក៏ដោយសារគាត់បានបំពេញកាតព្វកិច្ចជាកូននាគ មាននូវកតញ្ញូ និងកតវេទីចំពោះអច្ឆរមាតាមហានគរ តែឥរិយាបថរបស់គាត់ហាក់ដូចជាមនុស្ស ស្លាប់ (មើលការពន្យល់ពីវិស្ណុដេក) គាត់សុខចិត្តដេកស្លាប់ឲ្យតែអាចប្រស់មាតាមហានគរឲ្យរស់ ឡើងវិញ ក្នុងសន្តានចិត្ត (បេះដូង) កូននាគប្រុសស្រី ដែលកំពុងទទួលមរតកព្រះម៉ែក្នុងបច្ចុប្បន្ននេះ។

## ៧៨/.រូបភាពទីពីរ៨រូបយក្សនិងទេវតានៅលើជើងទម្រ(សព្វថ្ងៃនៅសារមន្ទីរ)



នៅក្នុងរូបភាពនេះ មានរូបចម្លាក់ពីរផ្ទាំង។

១/. នៅលើបល្ល័ង្កមួយ មានយក្សក្បាល ១០បែងភាគដៃម្ខាង៨ ជាន់នៅលើរូបមនុស្ស មានក្បាល៤ (ព្រហ្ម) ហើយនៅជុំវិញយក្ស នោះ មានស្ត្រីនៅសល់ចំនួន៦នាក់ កំពុងឈរ នៅលើផ្កាឈូកជុំវិញ។

ក/.រូបភាពទីមួយ រូបយក្សនៅ ចំកណ្តាលកំពុងឈរជើងឆ្វេងម្ខាង និងជើង ស្តាំលើកជាន់រូបព្រហ្មខាងក្រោមនោះ គឺ តំណាងឲ្យយក្ស ដែលបានចាប់មាតាយកទៅ ឃុំ (មើលការពន្យល់រូបទី១៩និងទី២០) គ្រាន់ តែក្នុងរូបនេះ គំនិតគាត់ក្នុងការឆ្លាក់ជារូប ក្បាលព្រហ្ម សម្រាប់ឲ្យយើងចេះឆ្ងល់។ រីឯដៃ ម្ខាង៨ គឺតាងឲ្យទិសតូច៤ និងធំ៤ ព្រោះរឿង អាថិកំបាំងនគរ បានលាក់ទុកនៅគ្រប់ទិស ទាំង៨ក្នុងមាតុភូមិនេះ ទាំងនៅក្នុងអតីតកន្លងមក ទាំងនៅក្នុងបច្ចុប្បន្ន ដែលជាតំណពីអតីត។ តាម ពិតទិសមានរហូតដល់ទៅ១០ឯណោះ គឺ២ទៀតទិសខាងលើ និងទិសខាងក្រោម ហើយអាថិកំបាំង ដែលលាក់ទុកក្នុងទិសលើ និងទិសក្រោមនេះ ទាល់តែបុគ្គលមានឧបនិស្ស័យខ្ពស់ ទើបអាចដឹងនូវ អាថិកំបាំងរបស់គាត់បាន។ នៅក្នុងដៃរបស់យក្ស មានកូនក្មេងតូច១នៅគ្រប់បាតដៃ (ចូលមើលការ ពន្យល់ក្នុងរូបទី១៩ ទី២១ នឹងរូបនៅជញ្ជាំងប្រាសាទបន្ទាយឆ្មារ រូបភាពទី២៥ និងទី២៦)។ រូបយក្សដ៏ធំនេះ គឺមានពាក់គ្រឿងអលង្ការ ហើយមានស្លៀកខោខើចខ្លីស្ទើរជិតដល់ក្រលៀន ទៅហើយ ដែលឥទ្ធិពលខោខើចខ្លីនេះ បានជះឥទ្ធិពលមកដល់ស្ត្រីខាងក្រោមឲ្យស្លៀកតាម។

ខ/.រូបភាពទីពីរ ក្នុងរូបភាពនេះ មានរូបស្ត្រីឈរលើផ្កាឈូកចំនួន៦នាក់ តែតាមពិតគឺមាន ៧នាក់ ហើយស្ត្រីជាអច្ឆរាទាំង៧នាក់នេះ គឺតំណាងឲ្យទេពធីតាគ្រប់ថ្ងៃទាំង៧ ក្នុងមួយសប្តាហ៍ ដែលបានបែរក្បាលកបិលមហាព្រហ្មរាល់ៗឆ្នាំនោះឯង។ ទេពធីតាជាកូននោះ មានរហូតដល់១២នាក់ឯណោះ (មាតាទាំង១២) តែ១២នាក់នេះ មានតែ៧នាក់ទេ ហើយ៧នាក់នេះតែងបញ្ចាំគ្នាទៀត (មើលការពន្យល់ពីដូងខែស៊ីក្នុងភាគ២) គឺមានតែម្នាក់ប៉ុណ្ណោះក្នុងមួយឆ្នាំ ដែលមកដង្ហែ និងថែរក្សារំលឹកដល់គុណម៉ែឪរបស់ខ្លួនពីអតីត។ ស្ត្រីដែលឈរលើកជើងស្តាំជាន់លើផ្កាឈូក ជើងខាងឆ្វេងស្លៀកខោខើចខ្លី ដៃមានកាន់ឧបករណ៍តំណាងឲ្យសំភារៈសម្រាប់ចិញ្ចឹមជីវិត ដៃម្ខាងទៀតលើកចុះទៅលើ គឺតំណាងឲ្យស្ត្រីជាកូននាគដែលកំពុងទទួលឥទ្ធិពល ស្លៀកខោខើចខ្លីពីយក្ស ព្រោះយក្សមានសេនាគឺគ្រុឌៗនេះតំណាងឲ្យសៀម ដែលកំពុងនាំវប្បធម៌ស្លៀកខោខើចខ្លី ចូលមកលុបវប្បធម៌ស្លៀកសំពត់ ក្បិន ស្លៀកហូល (ក្មេងស្រីសព្វថ្ងៃ)។ ព្រោះគ្រុឌនេះនៅគៀក ងាយនឹងផ្សព្វផ្សាយវប្បធម៌ស្លៀកពាក់នេះណាស់ តើក្នុងនាមយើងជាកូនព្រះនាងនាគបានដឹងពីការលុបដាន របស់អ្នកខាងក្រៅដែរឬទេ? ឯស្ត្រីដែលស្លៀកសំពត់នៅសល់ម្នាក់ នោះគឺតំណាងឲ្យស្ត្រីខ្មែរដែលនៅរក្សាប្រពៃណី កេរមរតកព្រះម៉ែ គឺនៅស្លៀកសំពត់ហូល ផាមួង....ជាសរសៃដែលបានកើតឡើងពីសំបុកនាង ដែលដង្កូវនាង (ព្រះនាងនាគ) សុខចិត្តដេកស្លាប់ក្នុងសំបុក (ឃុំក្នុងសីមា) ឲ្យគេស្ងោរក្នុងទឹកក្តៅ (អបាយភូមិ) ដើម្បីឲ្យគេហូតយកសរសៃសូត្រទុកសម្រាប់រុំព័ទ្ធព័ន្ធនគរខ្លួន ដែលសរសៃសូត្រនេះ តំណាងឲ្យមហាពលិកម្មរបស់អច្ឆរមាតាមហានគរ ហេតុតែដើម្បីកូននាគប្រុសស្រី (គោមសំពត់ហូល តំណាងឲ្យស្រកានាគៗ ⇨ និមិត្តរូបអច្ឆរមាតា)។ សព្វថ្ងៃអាចារ្យតែងនាំគ្នាធ្វើតៗគ្នា ពិធីក្រុងពលីនៅក្នុងបុណ្យប្រពៃណីទំនៀមទម្លាប់ និងក្នុងមង្គលផ្សេងៗ គឺធ្វើដោយពុំដឹងពីសារតាពិតរបស់ពិធីនេះឡើយ ពាក្យក្រុងពលីមានន័យថា កូននាគប្រុសស្រីត្រូវតែឧទ្ទិសនៅបុណ្យ គឺមហាកុសលជូនទៅអច្ឆរមាតានិងបិតា ដែលយក្សនិងគ្រុឌជាសេនា កំពុង**ក្រុង**ឃុំពួកគាត់ជាប់ (មើលការពន្យល់រូបពីទី១រហូតមក) ហើយពួកគាត់សង្ឃឹមថា នឹងមានកូននាគឧទ្ទិសបុណ្យឲ្យគាត់។ ដូច្នេះហើយទើបនៅក្នុងពិធីនេះ គេតែងរៀបដង្វាយ គឺគេយកពូជធញ្ញជាតិដូចជាស្រូវ សណ្តែក ល្ង ដំឡូង អំពៅ ចេក និងគ្រឿងសក្ការៈ....យកមកដាក់បូជា ព្រោះភោគផលទាំងនេះ ត្រូវយកទៅដាំដុះនៅលើដីមេ ឬម៉ែ ហើយម៉ែដែលជាម្ចាស់មាតុភូមិនេះ បានបំពេញពលិកម្មដ៏ធំ ដើម្បីប្រមូលកេរមរតកមកទុកឲ្យកូននាគប្រុសស្រី ទីបំផុតបានត្រឹមតែជាប់ក្នុងក្រុងរបស់យក្ស និងគ្រុឌ ព្រោះហេតុតែពលិកម្មនេះ (ក្រុងពលី)។ ក្នុងវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជជួន ណាត ភាគ១ និងភាគ២ ន័យក្នុងព្រះពុទ្ធសាសនា ពលីមាន

៥យ៉ាង ទី១ញាតិពលី(ការសង្គ្រោះញាតិ) ទី២អតិថិពលី(ការទទួលភ្ញៀវពន្លឺ) ទី៣បុព្វបេតពលី(ការធ្វើទានរួចឧទ្ទិសផ្សាយចំណែកបុណ្យចំពោះអ្នក ដែលចែកឋានទៅកាន់បរលោក) ទី៤រាជពលី(កិច្ចការបង់ពន្ធដារសួយសារអាករ) ទី៥ទេវតាពលី(ការចែកនូវចំណែកបុណ្យចំពោះពួកទេវតា តាមបែបព្រះពុទ្ធសាសនា ការសែនព្រេនផ្សេងៗ តាមលិទ្ធិក្រៅពុទ្ធសាសនា) បើយើងមើលពលីទាំង៥យ៉ាងនេះគ្មានពាក្យក្រុងពីខាងដើមឡើយ ដូចនេះក្រុងពលីគឺមានន័យដូចដែលខ្ញុំពន្យល់ខាងលើ គឺមានន័យថាឧទ្ទិសបុណ្យទៅឲ្យបុគ្គលដែលគាត់បានបំពេញ**ពលិកម្ម** ហើយត្រូវគេ**ក្រុង**ជាប់។ ពាក្យថាសរសៃសូត្រសំរាប់យកមកត្បាញសំពត់ហូល ផាមួង អន្លូញ....គឺតំណាងឲ្យការទន្ទេញឲ្យចាំ (សូត្រទន្ទេញ) តែពុំដូច្នោះឡើយ កូននាគប្រុសស្រីបែរជាភ្លេចបណ្ដាំព្រះម៉ែ (មើលឈ្មោះភូមិតាប្រាប់ បាត់ដឹងភាគ២)។

សរុបសេចក្ដីមករូបចម្លាក់នេះត្បិតតែមានទំហំតូច តែបានបង្កប់នៅអត្ថន័យរឿងរបស់អច្ឆរមាតានិងកូន ដែលត្រូវទទួលមរតកពីគាត់បន្តគ្នា ហើយចុងក្រោយយើងបែរជាធ្វើតាមឥរិយាបថរបស់យក្សនិងគ្រុឌ ដែលជាអ្នកឃុំក្រុងអច្ឆរមាតានិងបិតា ហើយពួកគាត់ក៏មានសង្ឃឹមថា ពេលណាដែលកូនបានដឹងបណ្ដាំគាត់ហើយ ពួកគេនឹងនាំគ្នាសូត្រទន្ទេញឡើងវិញពីអាថ៌កំបាំងសំពត់ ដែលនៅសល់តិចតួចនេះ។ ហើយរូបនេះទៀតសោត ក៏បានបង្ហាញពីការអស់សង្ឃឹមទៅលើកូននាគក្នុងថ្ងៃទាំងប្រាំពីរ ដែលគ្រាន់តែលើកដៃចោល ពុំបានជ្រោងលើកយក្ស ដែលជាន់គាត់នោះចេញឡើយ ដូច្នេះគាត់មានតែដេកចាំមើលកូននាគណា ដែលហ៊ានចូលទៅក្នុងទ្រូងម៉ែ (មើលល្បែងចាក់ទឹកដូងនិងរូបទី៤២ ៤៤)។

## ៣៩/.រូបភាពទី៣៩ រូបពពិលពីសម័យដើម(នៅសារមន្ទីរ)

ពពិល = មាតាគង់លើនាគបើកពពារ មានក្បាល៧ (ប្រាំពីរ ឬប្រាំពិលពាក្យនិយាយ)

ពពិល = ប្រដាប់សំរាប់ឆ្លុះស្រមោល (វ៉ែនតា) សិល្បចម្លាក់ខ្មែរ ជាសិល្បនិមិត្តរូប ជាសិល្បស្រមោល ឬអរូបី ដែលសិល្បៈនេះបានក្លាយជាតំណាតគ្នារហូតមកដល់សព្វថ្ងៃ ហើយសព្វថ្ងៃរូបភាពចម្លាក់ទាំងនេះ គ្រាន់តែជាស្រមោលបង្ហាញពីភាពអច្ឆរិយ ក្នុងអតីតកាលតែប៉ុណ្ណោះ។ ហើយស្រមោលអច្ឆរិយទាំងនេះ សព្វថ្ងៃយើងតែងយល់ច្រឡំថា ជារឿងនៅក្នុងសាសនាទៅទៀត តែតាមពិត ពុំមែនដូច្នោះឡើយ អ្នកដែលបង្កើតភាពអច្ឆរិយនេះ គឺអច្ឆរមាតា ឬអប្សរមាតាដែលគេបានហៅគាត់ថា បិសាចពស់ ឬបិសាចនាគនោះឯង។



នៅក្នុងរូបនេះមានស្ត្រីម្នាក់ គង់ក្នុងឥរិយាបថសមាធិ នៅពីខាងលើនាគបើកពពារ (ពាក្យនិយាយបើកពពៃរ) ដែលមានពាក់មកុដ និងគ្រឿងអលង្ការផ្សេងៗនៅលើដងខ្លួន តើស្ត្រីនោះគាត់ជានរណា? ឈ្មោះក្នុងអតីតកាលរបស់គាត់គឺព្រះនាងនាគ មកដល់បច្ចុប្បន្នព្រះមាតានាគ ព្រោះគាត់បានបង្កើតពូជពង្សនាគតជាប់គ្នា ជាងពីរពាន់ជំនាន់មកហើយ ដែលយើងជាកូននាគប្រុសស្រី បានទទួលកេរមរតកគាត់គ្រប់ៗគ្នានោះគឺជនជាតិខ្មែរ (សូមមើលការពន្យល់ក្នុងអាថ៌កំបាំងបណ្ដាំមាតាមហានគរភាគ១ និងភាគ២)។ រូបភាពដែលគេឆ្លាក់គាត់នៅពីលើដងមួយ បន្តពីខ្លួននាគ គឺតោបីឈរជ្រោងបន្ទាប់ពីតោទាំងបី គឺចន្លោះដងទទេ បន្ទាប់ពីចន្លោះទទេមានក្បាលយក្សនៅពីខាងក្រោម វត្ថុនេះយើងហៅថាពពិល។ ពពិលគឺជាឧបករណ៍មួយសំខាន់ណាស់ ក្នុងពិធីមង្គលផ្សេងៗ ដូចជាពិធីកោរជុកបំបួសនាគ ចូលម្លប់អាពាហ៍ពិពាហ៍..... (មើលក្នុងមង្គលបិភាគ២) គេតែងយកទៀនធ្វើពីក្រមួនសុទ្ធទៅបិទភ្ជាប់នឹងពពិល រួចដុតបង្វិលព័ទ្ធសីមាជុំវិញចំនួនបីជុំ (មើលការពន្យល់ពីសរសៃសូត្រ) រួចចុងក្រោយអាចារ្យបានយកស្លឹកម្លូទៅពន្លត់ (ប្រស្នាយកស្លឹកម្លូទៅពន្លត់នេះ មើលរូបទី៦)។ អាចារ្យក្ដី អ្នកដែលជួយបង្វិលព័ទ្ធជុំវិញក្ដី បានត្រឹមតែបក់ផ្សែងឲ្យអ្នកនៅខាងក្នុងសីមា ហិតស្រូបតែប៉ុណ្ណោះ ព្រោះអ្នកបក់ និងអ្នកហិតសុទ្ធតែពុំបានដឹងពីអាថ៌កំបាំងក្នុងប្រស្នានេះដូចគ្នា ដោយហេតុអ្វី?

ព្រោះសព្វថ្ងៃរឿងដែលទាក់ទងនឹងពពិលនេះ គេបានទម្លាក់ទៅក្នុងរឿងព្រហ្មញ្ញសាសនាបាត់ទៅហើយ ដោយគេចាត់ទុកថាទៀនតំណាងឲ្យលិង្គព្រះឥសូរ រីឯពពិលវិញតំណាងឲ្យយោនីព្រះនាងឧមាវតី ឬឧមាភគវតី ដោយហេតុកែវភ្នែកមាតាទាំង១២ ដែលជាអ្នកទទួលមរតកអច្ឆរមាតានោះ

ត្រូវបានយក្សដកខ្នេះយកទៅបាត់ហើយ។ ដូចនេះពន្លឺទៀន ដែលឆេះបំភ្លឺលើក្បាលនាគបើកពពារទាំងប្រាំពីរនោះ គ្មាននរណាអាចមើលឃើញនៅពន្លឺទាំងនោះឡើយ បានត្រឹមតែស្រូបក្លិនក្រមួនទៀនដែលឆេះនៅសល់តែប៉ុណ្ណោះ (មើលប្រវត្តិសាស្ត្រខ្មែរ ដែលទាក់ទងនឹងពាក្យខេត្តក្រមួនស ឬក្រមួនសុទ្ធពីអតីតកាល)។ នេះជាប្រស្នាអរូបីទាក់ទងនឹងវត្ថុនេះ (ពពិល) ដែលយើងជាកូននាគខាងក្រោយ បានធ្វើតៗគ្នាដោយពុំបានធ្វើការស្រាវជ្រាវរកការពិតរបស់ខ្លួន បានត្រឹមតែនាំគ្នាហិតក្លិនដែលនៅសេសសល់តែប៉ុណ្ណោះ ហើយក្លិនដែលនៅសល់នេះពុំបរិសុទ្ធទៅទៀត ព្រោះក្រមួនដែលយកមកលញ់ធ្វើទៀនសព្វថ្ងៃ សុទ្ធតែជាក្រមួនសិប្បនិមិត្ត។ សូម្បីតែពន្លឺទៀនដែលបំភ្លឺខាងលើ យើងមើលប្រស្នានេះពុំយល់ផង ធ្វើដូចម្តេចអាចមើលឃើញអច្ឆរមាតា គង់នៅពីលើនាគខាងក្រោមបាន តើនាគក្បាលពកក្នុងរូបតំណាងអ្វី? តោទាំងបីតំណាងអ្វី? ក្បាលយក្សខាងក្រោមតំណាងអ្វី?

**ក**/.នាគក្បាលពតំណាងឲ្យនិមិត្តរូបព្រះមាតានាគ ក្នុងមួយសប្តាហ៍ត្រូវភ្លឺឡើងវិញគ្រប់ថ្ងៃ ព្រោះពីខាងលើក្បាលនាគមានចំណិតកាំរស្មីពន្លឺ ផ្សាយជះចេញទៅខាងក្រៅ ដោយអំណាចមហិទ្ធិឫទ្ធិព្រះមាតាមហានគរដែលគង់លើនាគ។ ពីមុនយើងពឹងទៅលើពន្លឺរបស់ទៀន ដែលតំណាងឲ្យលិង្គព្រះឥសូរ (ឆ្នុកចុករន្ធយោនីរូបទី៧៥) ឥឡូវនេះកូននាគបានដឹងពីសាវតាពិត របស់អច្ឆរមាតាខ្លួនវិញហើយ។ ដូច្នេះពន្លឺរបស់ព្រះមាតានាគ (មើលពីភាពរុងរឿងរបស់ព្រះនាងនាគក្នុងភាគ១) ត្រូវបានផ្សាយចេញជាថ្មីឡើងវិញហើយ ក្រោយពីកូននាគទាំងប្រុសស្រីបានដឹងពីអាថ៌កំបាំងមនោគមវិជ្ជាបរទេស (ប្រស្នាលិង្គចុកបិទ) ដែលបានគ្របសង្កត់មកលើខ្លួនពីមុននោះ ពេលឥឡូវនេះអំណាចព្រះមាតានាគ ត្រូវផ្សាយទៅគ្រប់ទិសទីដូចពីមុន (ព្រះមាតាសក់ក្រអូប)។

**ខ**/.តោបីគឺតំណាងឲ្យទីក្រុងតោ ឬទីក្រុងសីហ ដែលប្រឹងប្រែងបើកប្រស្នាសោទាំងបី ក្នុងមង្គលបី (មើលមង្គលបីក្នុងភាគ២) ឲ្យបានភ្លឺឡើងវិញ ពេលបានដឹងពីអាថ៌កំបាំងក្នុងមង្គលទាំងបីហើយ ពេលនោះមហិទ្ធិឫទ្ធិព្រះមាតានាគ ចាប់ផ្តើមរះចែងចាំងជះពន្លឺឫទ្ធិបារមីរបស់លោក ផ្សព្វផ្សាយទៅគ្រប់ទិស។ ក្នុងរូបពពិលជាប្រស្នានេះ មានរូបតោដល់ទៅបីខុសពីរូបផ្សេង ព្រោះហេតុអ្វី? ព្រោះមង្គលរបស់កូននាគពីដើម ឪពុកម្តាយធ្វើឲ្យកូនធំៗតែបីដងប៉ុណ្ណោះ ឯពិធីផ្សេងទៀតគ្រាន់តែជាពិធីបន្ទាប់បន្សំ ម្យ៉ាងទៀតពពិលនេះ សម្រាប់ប្រើក្នុងមង្គលទាំងបីនេះជាសំខាន់ ដូច្នេះទើបប្រស្នារូបពពិលនេះ មានរូបសត្វតោបី ឬរាជសីបី (តំណាងឲ្យរឿងព្រះមាតាគង់លើកពពិលនេះ ត្រូវបើកសោទាំងបី ក្នុងទីក្រុងតោ)។

គ/.ក្បាលយក្សនៅខាងក្រោមតំណាងឲ្យម្ចាស់ពៀរ ដែលធ្លាប់ចាប់យកគាត់ទៅឃុំក្នុងសមុទ្ទទឹកដោះពីអតីតកាល ក្នុងរូបនេះយក្សឈប់មានអំណាចចាប់គាត់បានទៀតហើយ ព្រោះដើមឈូករបស់គាត់ បានដុះផុតពីក្បាលយក្សខាងក្រោម គាត់កំពុងគង់លើនាគផ្សាយឫទ្ធិរស្មីឡើងវិញ (មើលការពន្យល់រូបទី៦៣)។

ឃ/.ដងវែងខាងក្រោមនាគ និងក្រោមគោ តំណាងឲ្យពេលវេលាលូតលាស់របស់ដើមឈូក ដែលដើមឈូកទ្រូបល្ល័ង្កនាគនេះ អាចដុះផុតចេញពីអំណាចរបស់យក្ស (មើលរូប៦៣) ហើយទងផ្កាឈូកនេះតំណាងឲ្យបញ្ញាអ្នកគោរពព្រះពុទ្ធសាសនា ព្រោះព្រះសម្មាសម្ពុទ្ធ បានចាត់ទុកបញ្ញារបស់សត្វលោក ដូចជាផ្កាឈូកបួនពួកនៅក្នុងជលសា។

១/.ពួកផ្កាដែលកំពុងដុះចេញពីភក់

២/.ពួកផ្កាដែលដុះចេញពីភក់តែនៅក្នុងទឹក

៣/.ពួកផ្កាដែលដុះចេញពីភក់ហើយតែផុតពីទឹក

៤/.ពួកផ្កាដែលដុះចេញពីភក់ពីទឹកហើយរងចាំព្រះសូរ្យសែងចាំងមករអាលនឹងរីក

ដូច្នេះក្នុងរយៈពេល៤៥ព្រះវស្សា ព្រះអង្គមានពុទ្ធកិច្ចប្រាំយ៉ាងក្នុងមួយថ្ងៃ ក្នុងពុទ្ធកិច្ចទាំងប្រាំនោះ ពុទ្ធកិច្ចចុងក្រោយគឺព្រះអង្គប្រមើលមើលនិស្ស័យសត្វមានភ័ព្វ ឬឥតភ័ព្វ រួចព្រះអង្គយាងទៅប្រោសទេសនា ដើម្បីឲ្យផ្កាឈូកគឺបញ្ញា រីកទទួលព្រះសូរ្យសែង គឺព្រះធម៌នេះឯង។ ហេតុនេះសិល្បខ្មែរគ្រប់ៗប្រាសាទ ពុំចោលក្បាច់ត្របកឈូកឡើយ ប៉ុន្តែក្បាច់ត្របកឈូកទាំងនោះ ត្រូវពួកគាត់បំបែកក្នុងត្របកមួយសន្លឹកៗនោះ ឲ្យមានក្បាច់ល្អិតៗនៅខាងក្នុងបន្តទៅទៀត ដើម្បីទុកជាប្រស្នាកំបាំងក្នុងនិមិត្តរូបត្របកឈូកនេះ (ក្បាច់ត្របកឈូបបំបែក)។

សរុបសេចក្ដីមកការពន្យល់ពីរូបពពិលដោយសង្ខេបនេះ គ្រាន់តែជាការស្រាយនៅអាថ៌ប្រស្នាជាស្រមោល របស់អច្ឆរមាតាពីអតីត ដែលពីមុនយើងបានត្រឹមតែស្រូបហិតក្លិន ចំហេះទៀនដែលនៅសល់ពុំបរិសុទ្ធនោះ ឲ្យមកមើលឃើញដោយភ្នែកគឺបញ្ញា។ ក្នុងរឿងពិតដែលលាក់កប់ក្នុងពពិលនេះ តាមការបកស្រាយពីខាងលើ កូននាគប្រុសស្រីច្បាស់ជាឈប់យល់ច្រឡំដោយធ្វើការពិចារណាសាជាថ្មីឡើងវិញ ថាឧបករណ៍ពពិលនេះ ពុំមែនជាសំណល់សល់ពីព្រហ្មញ្ញសាសនានោះឡើយ

ព្រោះពពិលពិតប្រាកដគឺព្រះមាតានាគគង់លើនាគបើកពពារ រួចមកព័ទ្ធសីមាថែរក្សាកូនប្រុសស្រីក្នុងមង្គលទាំងបី ចំណែកព្រហ្មញ្ញសាសនានៅបរទេស គឺពុំមានពពិលនេះឡើយ (ខ្លួនជាប់ទោសទៅហើយ នៅតែគិតពីកូនទៀត)។

## ៨០/.រូបភាពទី៨០រូបអច្ឆរមាតាឬបិសាចពស់(មិនដឹងប្រភព)



តើរូបភាពចម្លាក់នេះព្រឹទ្ធដូនតា គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី នៅក្នុងថ្មនេះ? នៅក្នុងភាគទីមួយខ្ញុំបានពន្យល់ពីបិសាចពស់ ដែលអ្នកការទូតចិនជិវតាក្វាន់ គាត់បានឮអ្នកស្រុកខ្មែរសម័យនោះ និយាយពីរឿងបិសាចពស់នេះ តែងតែឡើងមកជួបនឹងស្តេចក្នុងវេលារាត្រី។ ក្នុងរូបនេះមានស្ត្រីម្នាក់ពាក់មកុដដូចអច្ឆរា កំពុងហែកនាគក្បាល៦ចេញមកក្រៅ ហើយខ្លួនគាត់គឺជាក្បាលទី៧ (មើលការពន្យល់ក្នុងរូបទីមួយ) ដោយគាត់ចង់ប្រាប់យើងតាមរយរូបចម្លាក់នេះថា នាគគឺជានិមិត្តរូបរបស់គាត់។ តើគាត់ចេញពីខ្លួននាគមកខាងក្រៅធ្វើអ្វី? គាត់ចេញដើម្បីមកប្រាប់កូននាគប្រុសស្រីក្នុងសម័យនោះ ចង្អុលប្រាប់ពីរបៀបដឹកនាំនគរ ដើម្បីពង្រីកអំណាច និងប្រាប់ពីការកសាងប្រាសាទឆ្លាក់រឿងរបស់គាត់ទុក រួមទាំងកិច្ចពិធីផ្សេងៗទៀតទុកជាប្រស្នា ទំនៀមទម្លាប់ ព្រោះគាត់ដឹងថាតទៅថ្ងៃក្រោយ គាត់មិនអាចចេញមកខាងក្រៅទៀតបានឡើយ (មើលការពន្យល់ក្នុងរូបមុន និងក្នុងភាគមុន)។ ហើយរូបនេះទៀតសោតខ្ញុំពុំបានដឹងថា ដូនតាឆ្លាក់ក្នុងប្រាសាទណាឡើយ ព្រោះខ្ញុំបានដករូបភាពនេះ ចេញពីសៀវភៅរបស់ជប៉ុន ដែលបានបោះពុម្ពកាលពីទសវត្ស៦០ ដែលរូបនេះកាលសម័យ

នោះ មិនទាន់រងនៅការបំផ្លាញនៅឡើយ ដោយក្នុងពេលនោះពួកបរទេសជិតខាង ពុំទាន់ចាប់អារម្មណ៍យល់ពីអាថ៌កំបាំងក្នុងភាសារូបទាំងនោះ។ ឯរូបសង្ខាងកំពុងចុះតាមកាំជណ្ដើរ ដែលមានបួនថ្នាក់ (មើលការពន្យល់រូបទី១ ពីសោចាក់ទាំងបួនជាន់) ម្ខាងរូបស្ត្រី ម្ខាងទៀតរូបបុរស ដែលតំណាងឲ្យកូននាគអ្នកទទួលមរតកផ្ទាល់ក្នុងសម័យនោះ (អ្នកដឹកនាំ) ចុះទៅក្រោមដើម្បីជួបអច្ឆរមាតា (បិសាចនាគ ឬពស់) ទទួលនូវឱវាទយកមកប្រតិបត្តិតាម ដោយកូននាគសម័យនោះបេះដូងរបស់ពួកគាត់ គឺជាបេះដូងទេវតា (បេះដូងកូននាគពោរពេញដោយការដឹងគុណ មើលរាជបំណងរបស់ស្ដេចជ័យវរ្ម័នទី៧ ដែលគាត់ចង់ឲ្យប្រជារាស្ត្រក្លាយជាទេវតា និងដែនដីគាត់ក្លាយជាឋានសួគ៌)។ កាំជណ្ដើរទាំងសង្ខាងមានក្រៅមានក្នុង គឺតំណាងឲ្យអតីតកាល និងបច្ចុប្បន្ន ដែលតទៅខាងមុខនឹងមានកូននាគណាមួយ ដឹងរឿងក្នុងបេះដូងថ្មទាំងនេះ គេនឹងចុះទៅជួយគាត់ក្នុងទីឃុំឃាំងនោះ។ សេះនៅខាងលើ និងសេះនៅខាងក្រោម តំណាងឲ្យឆ្នាំមមីក្នុងអតីត និងឆ្នាំមមីក្នុងបច្ចុប្បន្នកាល ដែលឆ្នាំនេះតាងឲ្យបុគ្គលជាស្ត្រីឈរនោះឯង ដែលគាត់ត្រូវចុះមកជួយស្រង់អច្ឆរមាតា ឯដើមឈើតំណាងឲ្យការបិទបាំងលាក់រឿងក្នុងអតីតកាល (មើលរូបមុនៗ បង្កប់លាក់ក្នុងព្រៃក្បាច់) ផ្កាឈូកក្រពុំមួយទងនៅជិតអច្ឆរមាតា តំណាងឲ្យបញ្ញាក្នុងព្រះពុទ្ធសាសនា និងតំណាងឲ្យឈ្មោះរបស់គាត់ គឺព្រះមាតាក្រពុំឈូក ឬឈូកក្រពុំ។ ឯខាងបុរសវិញយើងពុំឃើញមានរូបតំណាងឲ្យឆ្នាំឡើយ ព្រោះផ្ទាំងថ្មនេះត្រូវប្រេះរយះធ្វើឲ្យបាត់សភាពដើម តែយើងអាចយល់បានថា អច្ឆរមាតាលោកសង្ឃឹមបុរសនោះជាងព្រោះហេតុអ្វី? ទីមួយអច្ឆរមាតាបានងាកបែរមុខ ទៅរកបុរសដែលជាកូននាគនោះ ទីពីរមានតែបុរសទេដែលអាចបំពេញបារមី ជាព្រះពោធិសត្វលោកេស្វរៈបាន ព្រោះគ្រប់ពោធិសត្វទាំងអស់ដែលបំពេញបារមីដើម្បីឲ្យបានត្រាស់ដឹងជាព្រះពុទ្ធ គឺពុំមានស្ត្រីឡើយ នេះជាក្រិតក្រមរបស់ធម្មជាតិ។

សង្ខេបសេចក្ដីមករូបភាពដែលខ្ញុំបានយកមកបកពន្យល់ដោយត្រួសៗនេះ គ្រាន់តែចង់ឲ្យកូននាគប្រុសស្រី បានស្គាល់ពីបិសាចពស់ឬនាគ ក្នុងឯសារអ្នកការទូតចិនជាវតាក្វាន់ ថាតើបិសាចនោះជានរណា? កុំឲ្យយើងជាអ្នកទទួលមរតកមេនាគហើយ មិនដឹងសាវតាររបស់គាត់វាជារឿងមួយគួរឲ្យខ្មាស់អៀនណាស់ ព្រោះភាសាគំនិតដែលគាត់ឆ្លាក់ទុកក្នុងថ្ម វាគឺជាត្រីវិស័យនិងភស្តុតាងមួយដ៏សំខាន់ សម្រាប់ឆ្លុះបញ្ចាំងមើលរឿងអតីតកាលកន្លងមក នឹងការវិឌ្ឍន៍ទៅរកអនាគតកាលខាងមុខ។ ហើយរូបនេះទៀតសោត បានបើកបង្ហាញពីការពិតរបស់បិសាចពស់ (ចិនអ្នកថា) ដែលជាប្រមុខអ្នកបង្កើតនគរខ្មែរ នឹងជាអ្នកបង្កើតនូវអរិយធម៌អច្ឆរិយ គឺគាត់ជាអច្ឆរមាតាមហានគរ។ ភស្តុតាង

នេះកូននាគប្រុសស្រីក្នុងសម័យបច្ចុប្បន្ន ត្រូវតែទទួលស្គាល់ថា បិសាចពស់ដែលគួរឲ្យខ្លាចពីអតីតកាលនោះ ការពិតគឺជាអ្នកខំប្រមូលទ្រព្យសម្បត្តិកេរមរតកទុក ហើយនឹងបានបន្សល់ទុកឲ្យយើងជាកូនខ្មែរទទួលមរតករបស់គាត់គ្រប់ៗគ្នា ក្នុងបច្ចុប្បន្ននេះ។

## ៨១/.រូបភាពទី៨១រូបចម្លាក់នៅលើបល្ល័ង្កតែមួយ(មិនដឹងប្រភព)



តើរូបទាំងបីនេះតំណាងឲ្យអ្វី? ហេតុអ្វីបានជារូបអង្គុយលើបល្ល័ង្កនាគ និងរូបស្ត្រីឈរបិទភ្នែក ហើយបើកភ្នែកតែរូបបុរសដែលមានដៃច្រើន?

ក/.រូបចំកណ្ដាលកំពុងអង្គុយពែនភ្នែន លើនាគពែនបើកពពារ រូចមានពាក់មកុដនឹងគ្រឿងអលង្ការ ស្ថិតក្នុងឥរិយាបថសមាធិ ដែលនៅលើបាតដៃត្រួតគ្នានោះ មានផ្កាឈូកក្រពុំមួយទង ហើយនៅទងត្រចៀកមានពាក់ក្រវិល តើរូបនេះតំណាងឲ្យអ្វី? រូបនេះតំណាងឲ្យកូននាគដែលជាព្រះពោធិសត្វលោកេស្វរៈ ដែលត្រូវមកបំពេញបារមីជួយស្រង់ប្រស់អច្ឆរមាតាមហានគរ (មើលការពន្យល់រូបទី៤២ និង៤៤) ហេតុអ្វីបានជារូបនេះពុំអាចបើកភ្នែកបាន? ព្រោះរឿងអាថ៌កំបាំងរបស់

ព្រះម៉ែមហានគរ ពុំទាន់មានកូននាគណាព្រមទទួលយកនូវកែវភ្នែកនេះ ទៅដាក់មើលរឿងពិតរបស់ខ្លួនឡើយ គឺនៅបិទភ្នែកដដែល បុគ្គលបិទភ្នែកមិនអាចមើលអ្វីឃើញឡើយ។

ខ/.រូបខាងឆ្វេងដៃរូបកណ្តាល គឺស្ត្រីឈរលើទម្រពាក់មកុដនិងគ្រឿងអលង្ការ ដៃគាត់ម្ខាងកាន់ផ្កាឈូកក្រពុំនិងដៃម្ខាងទៀតកាន់គម្ពីរ ហើយបិទភ្នែកដូចរូបនៅកណ្តាលដែរ តំណាងឲ្យអច្ឆរមាតាមហានគរ គាត់កំពុងចាកចេញពីការដាក់ទណ្ឌកម្មរបស់យក្ស។ រូបគាត់គេបានឆ្លាក់បិទភ្នែកដដែល មានន័យថាពីឆ្នាំ១៩៩៨មកទល់នឹងឆ្នាំពី២០១០នេះ (មើលអារម្ភបទភាគ១) អាថិកំបាំងរឿងរបស់គាត់នូវលាក់បិទដដែល ព្រោះកែវភ្នែកមាតាទាំង១១កន្លះ ពុំទាន់បានយកទៅដាក់បញ្ចូលឲ្យពួកគាត់ទាំង១២ឡើយ។ ដូច្នេះហើយទើបរូបកូនដែលអង្គុយលើបល្ល័ង្កនាគក៏បិទភ្នែក មាតាឈរក៏បិទភ្នែក ព្រោះអ្នកនាំរឿងមាតាយកមកផ្សព្វផ្សាយ ពុំទាន់អាចបញ្ជ្រាបរឿងចូលទៅក្នុងបេះដូងកូនខ្មែរបាននៅឡើយ។ នេះជាប្រស្នាថ្មដែលគាត់ឆ្លាក់មនុស្សពីរនាក់បិទភ្នែក ព្រោះធម្មតាបុគ្គលដែលបិទភ្នែក គឺមើលអ្វីពុំឃើញឡើយ ទោះបីជាបើកភ្នែកមើលឃើញរូប តែពុំបានគិតពិចារណា ក៏ទុកដូចជាបិទភ្នែកដដែល ដូច្នេះទើបមានពាក្យជេរទូន្មានរបស់ចាស់បុរាណថា "**កុំមើលនឹងភ្នែក ត្រូវចេះមើលនឹងថ្វាស**"។

គ/.ហេតុអ្វីដែលរូបបុរសដែលកំពុងឈរ បែងភាគដៃបួន នៅលើទម្រតែមួយហើយបើកភ្នែក?

**ន័យទី១** ក្រោយពេលដែលមាតាចុះទៅទទួលទោស នៅក្នុងសមុទ្រទឹកដោះនោះ រឿងរបស់អច្ឆរមាតាត្រូវបានគេលុបដានចោលអស់ទៅហើយ (មើលមង្គលពាភាគ២) ហេតុនេះបុរស (ប្រា) ត្រូវដណ្តើមសិទ្ធិធ្វើជាមេ ព្រោះមនោគមវិជ្ជាបរទេសដែលយកមកសង្កត់នគរនេះ គឺយកបុរសជាធំ (កុងម៉ា ≠ មេប្រា)។ ហេតុតែតាំងខ្លួនជាមេ បុរសគាត់ត្រូវធ្វើកិច្ចការជាច្រើន នៅក្នុងផ្ទះក្រៅផ្ទះ គ្រប់គ្រងគ្រួសារ គ្រប់គ្រងនៅសិទ្ធិគ្រប់បែបយ៉ាងជំនួសមេ ឯមេគឺមាននៅសល់តែឈ្មោះប៉ុណ្ណោះ។

**ន័យទី២** តំណាងឲ្យកូននាគដែលត្រូវមកជួយម្តាយ ពេលដែលគាត់នៅជាព្រះវិស្ណុ ឬព្រះឥសូរ គាត់ត្រូវបែងភាគដើម្បីប្រមូលផ្តុំរឿងរបស់អច្ឆរមាតា ដែលត្រូវបានហាន់ជាចំណិតៗ (ប្រាសាទហាន់ជ័យ) ដើម្បីយកមកផ្គុំឲ្យក្លាយបានជារូបរាងមួយ អាចធ្វើឲ្យកូននាគមើលយល់ពីការពិត នូវរឿងរបស់អច្ឆរមាតានេះបាន។ ឯភ្នែកបីតំណាងឲ្យគាត់ត្រូវមើលនឹងភ្នែកផង ត្រូវយកមកគិតត្រិះរិះពិចារណាក្នុងភ្នែកទីបី នៅកណ្តាលថ្ងាសផង មានន័យថាត្រិះរិះដោយបញ្ញាដោយយកគោលក្នុងព្រះពុទ្ធ

សាសនា និងក្នុងព្រហ្មញ្ញសាសនា មកវែកញែករាវរកការពិត ក្នុងមរតកម៉ែទាំងអស់ តើមួយណាជារបស់ក្នុងសាសនា មួយណាជារបស់ព្រះម៉ែ? ហេតុនេះហើយទើបព្រឹទ្ធដូនតា គាត់ផ្ដាក់ប្រស្នាគំនិតទុកក្នុងរូបទាំងបីនេះ ដែលឈរនិងអង្គុយលើជើងទម្រតែមួយរួមគ្នា ពីរនាក់បិទភ្នែកម្នាក់បើកភ្នែក ព្រោះកុំឲ្យអ្នកមើលយល់ច្រឡំថា គាត់ភ្លេចផ្ដាក់ឲ្យបើកភ្នែក។ នៅមានរឿងមួយទៀត ក្នុងទំនៀមទំលាប់ខ្មែរទាក់ទងនឹងព្រះពុទ្ធសាសនា គឺពិធីបុណ្យអភិសេកព្រះពុទ្ធបដិមា ក្នុងបុណ្យនេះមានកិច្ចមួយគេហៅថា ពិធីបើកព្រះនេត្រព្រះ ហេតុអ្វីចាំបាច់បើកព្រះនេត្រព្រះ បើជាងអ្នកឆ្លាក់គេបានបើករួចទៅហើយនោះ? ដែលបញ្ញារបស់ព្រះសម្មាសម្ពុទ្ធ បានសន្សំបារមីទាំង៣០ អស់រយៈពេលបួនអសង្ខៃយ និងមួយសែនផែនដី ព្រះអង្គមានបារមីគ្រប់គ្រាន់ អាចត្រាស់ដឹងដោយខ្លួនឯងបាន ចុះហេតុអ្វីក៏ចម្លែកម្លេះ យើងមានពិធីបើកព្រះនេត្រព្រះអង្គ បើយើងគ្រាន់តែជាអ្នកទទួលនូវឱវាទ ដែលជាមរតករបស់ព្រះអង្គសោះ តើយើងមានឫទ្ធិបារមីអ្វីទៅបើកព្រះនេត្រព្រះអង្គបាន? នេះហើយដែលជាប្រស្នាសម្រាប់កូននាគប្រុសស្រី ដែលជាអ្នកគោរពកាន់ព្រះពុទ្ធសាសនា គួរពិចារណាថា តើកិច្ចដែលត្រូវបើកព្រះនេត្រនោះ គឺបើកព្រះនេត្ររបស់ព្រះណាឲ្យពិតប្រាកដ? ចម្លើយគឺសូមមើលការពន្យល់គ្រប់ភាគទាំងបីថា តើព្រះនេត្រព្រះណាដែលកូនខ្មែរប្រុសស្រី ត្រូវបើកដោយពិតពុំមែនបើកដោយព្រាវនោះ? ព្រោះព្រះនេត្រ ឬចក្ខុរបស់ព្រះសម្មាសម្ពុទ្ធមានប្រាំគឺ៖

១/.មំសចក្ខុ (ចក្ខុ គឺសាច់ដួងភ្នែក)

២/.ទិព្វចក្ខុ (ចក្ខុដូចជាទិព្វ)

៣/.បញ្ញាចក្ខុ (ចក្ខុ គឺបញ្ញា)

៤/.ពុទ្ធចក្ខុ (ចក្ខុ គឺប្រាជ្ញាត្រាស់ដឹង)

៥/.សមន្តចក្ខុ (ចក្ខុឃើញដោយជុំវិញ)

សរុបសេចក្ដីមកព្រឹទ្ធដូនតាយើង គាត់ពូកែយកគំនិតទៅលាក់ទុកក្នុងថ្មណាស់ តែដោយយើងទុកសិទ្ធិឲ្យបរទេសជាអ្នកស្រាវជ្រាវបកស្រាយភាសារូបនេះ យើងត្រូវបានគេខ្ទប់បិទរឿងពិតរបស់ព្រះម៉ែនាគ ដែលលោកខំព្យាយាមទុករឿងខ្លួនក្នុងថ្ម ពួកគេបានបកប្រែភាសារូបឲ្យក្លាយជារឿងរបស់សាសនាទៅវិញ។ ពេលនេះកូននាគប្រុសស្រីត្រូវចេះមើលប្រវត្តិពិតរបស់ខ្លួន ដែលលោកបាន

ចារឹក និងប្រតិស្ថានទុកក្នុងថ្ម ទំនៀមទម្លាប់ រឿងព្រេង ទំនាយ ឈ្មោះភូមិស្រុក....ដើម្បីស្វែងរកការពិតរបស់អាទិទេពខ្មែរ ដែលបានបង្កើតភាពអច្ឆរិយនេះ។

## ៨២/.រូបភាពទី៨២រូបនៅជញ្ជាំគ្រលុកនៅខាងឆ្វេង(លានជល់ដំរី)

## ៨៣/.រូបភាពទី៨៣រូបនៅជញ្ជាំគ្រលុកនៅខាងឆ្វេង(លានជល់ដំរី)







រូបនេះបានចែកចេញជាពីរផ្ទាក់ តើរូបទាំងអស់នេះ ព្រឹទ្ធដូនតាយើងគាត់ចង់និយាយប្រាប់ពីរឿងអ្វី? ពាក្យថាលានជល់ដំរី គឺមានន័យថាទីលានសម្រាប់យកដំរីទៅប្រជល់គ្នា ក៏ប៉ុន្តែក្នុងន័យភាសារូបក្នុងលាននេះ គឺពុំនិយាយដូច្នេះឡើយ បែរជានិយាយពីហ្មដែលជិះនៅលើក្បាលដំរីទាំងបីចុះមកប្រយុទ្ធដណ្តើមរារាំង សម្លាប់ក្មេងម្នាក់ដែលនៅជាប់ឃុំក្នុងទីនោះ កុំឲ្យឡើងមកខាងលើរួច។ ហ្មលើដំរីទាំងបីនោះ (មើលរូបហ្មនៅក្បាលដំរីខ្លោងទ្វារចូលទីក្រុងអង្គរធំ) តាមពិតនៅឯជាន់ទីបីខាងលើឯណោះ ហេតុតែដើម្បីតាមរកក្មេងម្នាក់នេះ ពួកគេបាននាំគ្នាចុះមកក្នុងអន្លង់គុកដ៏ជ្រៅ តាមរារាំងចាប់សម្លាប់បុគ្គលនោះ។ ក្នុងរូបទាំងពីរផ្ទាំងខាងលើនេះ តាមពិតរូបស្ថិតក្នុងជញ្ជាំងតែមួយ ដោយរូបមុនថតយកពុំបានអស់ ទើបខ្ញុំចាប់ផ្តើមយករូបទី២មកដាក់បន្តឲ្យជាប់គ្នា ដើម្បីងាយស្រួលក្នុងការពន្យល់ ដូច្នេះទើបក្នុងរូបនេះមានរូបពីរសន្លឹកជាប់គ្នា។ ក្នុងរូបទី៨២យើងឃើញមានមនុស្សបី

នាក់មានពាក់មកុដ ដូចជាមកុដស្ដេចក្នុងល្ខោនបាសាក់ អ្នកទាំងបីនោះដៃខាងស្ដាំមានកាន់អាវុធលើកគំរាមឡើងលើ ចំណែកជើងទាំងពីររបស់មនុស្សទាំងបីនាក់នោះ ជាន់នៅលើផ្កាឈូកកំពុងរីក។ នៅពីក្រោយអ្នកទាំងបី មានរូបមនុស្សម្នាក់តូចដូចជាកូនក្មេង ដែលគាត់នៅឈរពីខាងក្រោយអ្នកលើកអាវុធ ឬហ្មដំរីទាំងបី (មើលការពន្យល់បន្ថែមរូបទី៣៣) គាត់កំពុងរកផ្លូវគេចដើរចេញ ពីការរារាំងរបស់អ្នកទាំងបី ដើម្បីឡើងទៅខាងលើ។ ពេលដែលក្មេងនោះដើរមកដល់ទន្ទឹម ជើងឆ្វេងសេះក្បាលប្រាំ គាត់បានឈរជាន់លើផ្កាឈូកមួយទង ដែលរំលងពីផ្កាឈូកគាត់ជាន់ មានផ្កាឈូកទំនេរមួយ បន្ទាប់ពីផ្កាឈូកទំនេរ ទើបដល់ផ្កាឈូកដែលហ្មដំរីជាន់ (ពីជើងគាត់រំលងផ្កាឈូកមួយ) តែក្បាលក្មេងនោះពួកជនទុច្ចរិតបានដាច់ចោលអស់មួយចំនួនទៅហើយ ព្រោះគេឧបកិច្ចឲ្យក្មេងនោះស្លាប់ (មើលការឧបកិច្ចរបស់ស្ដេចជ័យវរ្ម័នទី២ពេលប្រកាសតែងតាំងខ្លួនជាស្ដេចចក្រវាលលើភ្នំគូលែន)។ បន្ទាប់មកក្មេងនោះបានឡើងទៅលើជាន់ទីពីរ គាត់បានលុតជង្គង់សំពះអង្វរហ្មទាំងបី តែអ្នកទាំងបីដែលឡើងតាមគាត់មកខាងលើនោះ គឺពុំព្រមអត់ឱនលើកលែងឲ្យគាត់ឡើងទៅលើទៀតឡើយ សកម្មភាពរបស់ពួកគេគឺ លើកអាវុធឡើងគំរាមរារាំងគាត់ដដែល (មើលរូបភាព)។ ក្នុងរូបបន្តទី៨៣ ដោយគាត់ពុំអាចឡើងទៅលើរួច គាត់ចុះមកជ្រកខាងក្រោមសេះក្បាលប្រាំ សកម្មភាពរូបគាត់លុតជង្គង់លើបល្ល័ង្កផ្កាឈូក ដៃកាន់ទំពក់ស្ថិតនៅខាងក្រោមពោះសេះ កំពុងរកផ្លូវដើម្បីចាកចេញ។ ទើបរូបគាត់បានមកស្ថិតឈរពីខាងស្ដាំជើងសេះ នៅលើផ្កាឈូកមួយទង ដែលក្នុងរូបនេះជើងហ្មដំរីបានលើករំលងផ្កាឈូកពីរ មកជាន់ពីលើជើងផ្កាឈូករបស់ក្មេង ដើម្បីកុំឲ្យគាត់ឡើងទៅលើរួច កាលនៅពីខាងឆ្វេងជើងសេះ ហ្មដំរីជាន់នៅសល់ផ្កាឈូកមួយទំនេរ តែមកដល់ខាងស្ដាំជើងសេះវិញ ហ្មបានជាន់រំលងមកដល់ផ្កាឈូកដែលក្មេងនោះឈរ មានន័យថាគេតាមឈ្នានីស ព្យាបាទ រុកគួន ព្រោះគេមិនចង់ឲ្យគាត់នាំរឿងអច្ឆរមាតាដែលជាប់ក្នុងគុកនេះ មកផ្សព្វផ្សាយនៅខាងលើឡើយ។ ក្នុងសកម្មភាពរូបបានពន្យល់ប្រាប់យើងថា គាត់ព្យាយាមដកជើងចេញពីការជាន់របស់ហ្ម រួចប្រឹងឡើងទៅខាងលើ រូបខាងលើជាបន្តគាត់អង្គុយបញ្ឈរជង្គង់ងើយក្បាលមើលទៅលើ ប្រុងប្រៀបខ្លួននឹងឡើងទៅទៀត តែត្រូវមានរូបស្ត្រីធំមួយឡើងទៅតាមស្ទាក់លើកជើងដាក់ពីខាងលើក្បាលគាត់ ដើម្បីរារាំងដំណើរផ្លូវរបស់គាត់។ បើយើងមើលតាមសកម្មភាពរូបទី៨២ និង៨៣នេះ គួរឲ្យសង្វេគ នឹងអាណិតគាត់ណាស់ ព្រោះដើម្បីនាំរឿងអាថ៌កំបាំងអច្ឆរមាតាឡើងទៅខាងលើ គាត់ត្រូវមានសត្រូវធំៗមកស្ទាក់រារាំង តាំងពីដើមទីមកម៉្លេះ ព្រោះហ្មទាំងបីដែលខំចុះមកក្នុងគ្រលុកនេះ ពួកគេមិនចង់ឲ្យក្មេងនេះនាំរឿងអាថ៌កំបាំងមាតាមហានគរឡើងទៅខាងលើឡើយ ពួកគេបានប្រើគ្រប់រូបភាព រារាំង

ឈ្មានីស ព្យាបាទ គ្រប់ជំហានដំណើររបស់គាត់ (មើលសកម្មភាពរូប)។ ហេតុតែពូជនាគដែលជាពូជអច្ឆរា បានដេកលក់រាប់រយជំនាន់មកហើយ (លុបដាន សាដាន លក់ដាន) ដូច្នេះពួកហ្មទាំងបីគេមិនអាចឲ្យពូជអច្ឆរិយនេះ ដឹងពីសាវតាពិតក្នុងអតីតរបស់ខ្លួនឡើយ នេះជាគំនិតបង្កប់ក្នុងភាសារូប ដែលបានប្រាប់យើងពីសកម្មភាពរារាំង ព្យាបាទ ឈ្មានីសរបស់ពួកគេ។

## ៨៤/.រូបភាពទី៨៤រូបនៅជញ្ជាំងគ្រលុកខាងស្តាំផ្លូវចុះ(លានជល់ដំរី)



នៅក្នុងរូបភាពលានជល់ដំរី លើជញ្ជាំងពីខាងស្តាំដៃផ្លូវចុះនេះ សកម្មភាពរូបអត្ថន័យមិនសូវខុស ពីរូបនៅខាងឆ្វេងដៃឡើយ គ្រាន់តែក្នុងរូបនេះបានបង្ហាញពីអត្ថសញ្ញា ដែលយើងជាកូននាគ គួរដឹងថា តើគាត់ព្យាយាមគេចវេះចេញ ពីការតាមព្យាបាទ របស់ពួកហ្មទាំងបីព្រោះរឿងអ្វី? ក្នុងរូបនេះនៅខាងឆ្វេងជើងសេះក្បាលប្រាំ ពីខាងក្រោម មានរូបបុរសម្នាក់ឈរអង្គុញលើកជើង ម្ខាងខ្ចប់មុខទៅជញ្ជាំង កំពុងរុញនិមិត្តរូបក្បាលនាគ យ៉ាងធំមួយទៅលើ។ ក្នុងការព្យាយាមរបស់គាត់ត្រូវពួកហ្មដំរី ដែលនៅបន្ទាប់គាត់ កំពុងលើកយារអាវុធឡើងវាយប្រហាគាត់ រារាំងគាត់មិនឲ្យរុញនិមិត្តរូបកូននាគនេះឡើង ទៅខាងលើបាន។ អត្ថន័យរបស់រូបដែលខ្ចប់មុខទៅជញ្ជាំង បានពន្យល់ប្រាប់យើងថា គាត់ពុំមាននរណាស្គាល់ដឹងពីសកម្មភាពនឹងមុខមាត់ពិតរបស់គាត់ឡើយ ទោះបីជាគាត់នៅក្នុងទីទាបក៏ដោយ ក៏ពុំបានបង្ហាញមុខឲ្យគេបានដឹងឡើយ។ ចំណែកឯក្បាលនាគដែលគាត់កំពុងប្រឹងរុញច្រានទៅខាងលើនោះ គឺតំណាងឲ្យអាថ៌កំបាំងបណ្តាំរឿងរបស់ព្រះមាតានាគ ដែលបានលិចកប់ទៅក្នុងមហាសមុទ្រទឹកដោះពីអតីតកាលកន្លងផុតទៅ សកម្មភាពរូបបានបង្ហាញប្រាប់យើងថា អ្នកដែលព្យាបាទគេ និងអ្នកដែលត្រូវគេព្យាបាទ សុទ្ធតែឈរលើទម្រង់ផ្កាឈូកដូចគ្នា។ រូបភាពនេះបើលោកអ្នកអានចង់ដឹងការពិតឲ្យ

កាន់តែច្បាស់ សូមអញ្ជើញទៅមើលរូបជាក់ស្ដែង រួចពិចារណាតាមសាច់រឿង ដែលខ្ញុំបានពន្យល់ដោយសង្ខេបនេះ ព្រោះការពន្យល់បកភាសារូប យើងពុំអាចនិយាយអ្វីឲ្យហួសពីការ ដែលយើងបានមើលឃើញនោះឡើយ ខ្ញុំក៏សូមអភ័យទោសដោយខ្វះលទ្ធភាពក្នុងការប្រមូលឯកសារឲ្យបានគ្រប់គ្រាន់។ ក្នុងឯកសារថ្មដែលបានលាក់ទុកក្នុងលានជល់ដំរីនេះ បើយើងមើលរួចហើយ ពិចារណាអត្ថន័យរូប ទើបយើងដឹងថាព្រឹទ្ធដូនតាលោកបានដឹងជាមុនរួចទៅហើយ នៅការតាមព្យាបាទឈ្នានីសចំពោះកូននាគ ដែលត្រូវចុះទៅជួយប្រស់រុញច្រានស្រង់គាត់ឡើង ហើយពួកគាត់ទុកប្រស្នានេះជាហេតុសំរាប់ចង្អុលប្រាប់កូននាគ ឲ្យខិតខំព្យាយាមអត់ធ្មត់គ្រប់ការលំបាកវេទនា ដែលខ្លួនត្រូវទទួល ទើបអាចឲ្យសម្រេចកិច្ចការដ៏ធំនេះទៅដល់ទីបញ្ចប់បាន។

## ៨៥/.រូបភាពទី៨៥រូបជញ្ជាំងខាងលើ(លានជល់ដំរី)



ទីតាំងលានដំរីក្បាលបីខាងលើ បើយើងមើលរូបភាពពីចម្ងាយ យើងឃើញគ្រលុកគុកសេះក្បាលប្រាំ នៅពីខាងក្រោម (មើលរូប៨២ ៨៣ និង៨៤) ចំណែកឯផ្ទាំងរូបដំរីក្បាលបី គឺនៅពីខាងលើយើងអាចមើលឃើញ គ្រលុកសេះក្បាលប្រាំនេះតាមរយរូបថតដែលមើលពីចម្ងាយ។ ក្នុងរូបនេះយើងមើលឃើញក្បាលដំរី មានប្រាំមួយគឺម្ខាងបីៗ តែក្នុងប្រស្នារូបនេះ បើយើងមើលដោយពុំបានគិតពិចារណាឈ្វេងយល់ ច្បាស់ជាយល់ច្រឡំតាមសិល្បបំភាន់នេះជាពុំខាន ព្រោះព្រឹទ្ធដូនតាយើងគាត់ចង់ប្រាប់កូននាគថា បើចង់ដឹងរឿងពិតក្នុងនគរដំរី (យសោធបុរៈ) ត្រូវមើលក្នុងទ្រូង ឬក្នុងបេះដូងដំរី ទើបអាចដឹងរឿងក្នុងចិត្តរបស់នគរដំរី។ បើសិនជាគាត់ឆ្លាក់ដំរីក្បាលបី គាត់ពិបាកចែកញែកក្បាលសម្រាប់សរសេររឿងណាស់ ដូច្នេះគាត់ត្រូវតែឆ្លាក់ក្បាលដំរីម្ខាងបីៗ ចំណែកឯរឿងកណ្ដាលទុកដូចជារឿង នៅក្នុងទ្រូងដំរី ន័យម្យ៉ាងទៀតក្បាលបីម្ខាង ចាត់ទុកដូចជាម្ដាយម្ខាងទៀតដូចឪពុក ព្រោះធាតុទឹក**១២** = **៣** ធាតុដី**២១** = **៣** ឬក៏ព្យញ្ជនៈទាំង**៣៣តួ** ក៏មានន័យដូចក្នុងរូបផ្ទាំងនេះដែរ។ នៅលើខ្នងដំរីមានបល្ល័ង្កផ្កាឈូកដ៏ធំមួយយើងហៅថារយាងដំរី ចំណុចកណ្ដាលនៃរយាងនេះហើយ ទើបយើងយល់ពីសិល្បបំភាន់របស់ពួកគាត់ តាមពិតដំរីមានក្បាលតែបីប៉ុណ្ណោះ

ព្រោះយើងមើលរូបដំរីក្បាលបីខាងក្រោម នៅជញ្ជាំងខាងមុខជាប់ផ្ទាល់ និងមើលរូបដែលគេដណ្ដើមហែកនគរជាបី (រូបទី៣២ ៣៣ និង៣៤)។ ក្នុងដំណាក់កាលទីមួយ មនុស្សប្រុសតូចនោះត្រូវប្រើពេលវេលា ដើម្បីចុះទៅក្នុងគ្រលុកគុកសេះក្បាលប្រាំរាវរកអាថ៌កំបាំងអច្ឆរមាតានាគ ដំណាក់កាលទីពីរ ពេលដែលបានដឹងអាថ៌កំបាំងអច្ឆរមាតាហើយ គាត់ត្រូវរុញច្រានរឿងដ៏ធំនេះ ចេញពីគ្រលុកគុកខាងក្រោមឲ្យមកឋិតនៅខាងលើ ដំណាក់កាលទីបី គាត់ត្រូវព្យាយាមវារលូនអូសរឿងអច្ឆរមាតានាគ យកទៅដាក់នៅលើបល្ល័ង្កផ្កាឈូក ដែលជារយាងដំរីវិញ។ ហេតុនេះហើយ ទើបហ្មដំរីទាំងបីសុខចិត្តនាំគ្នាចុះពីលើក្បាលដំរី មករារាំងក្មេងនេះ ក្នុងគ្រលុកគុកសេះក្បាលប្រាំខាងក្រោម តាមព្យាបាទរហូតទៅដល់ជាន់ខាងលើ ព្រោះមិនចង់ឲ្យក្មេងនេះ នាំរឿងអាថ៌កំបាំងក្នុងបេះដូងដំរីចេញមកខាងក្រៅឡើយ ដូច្នេះទើបនៅលើកំពូលភ្នំគូលែន មានទីកន្លែងមួយគេហៅថា អន្លង់ដំរី ព្រោះគាត់ចង់ប្រាប់យើងឲ្យមើលរឿងក្នុងអន្លង់លានជល់ដំរីនេះ។

## ៨៦/.រូបភាពទី៨៦រូបក្នុងជញ្ជាំងកណ្ដាលទ្រូងដំរី(លានជល់ដំរី)



រូបនៅជញ្ជាំងកណ្ដាលក្បាលដំរីសង្ខាងនេះ ដូននាគយើងបានលាក់រឿងរបស់គាត់ទុកក្នុងទ្រូងដំរី ដែលជាដំណាក់កាលចុងក្រោយរបស់គាត់ គាត់ដឹងថា នឹងមានកូននាគណាម្នាក់ត្រូវស្រង់យកគាត់ទៅដាក់លើបល្ល័ង្កឈូកធំនោះវិញ ហេតុតែក្មេងម្នាក់នេះ ដំរីទាំងបីត្រូវជល់គ្នាយ៉ាងដូចម្ដេចដើម្បីដណ្ដើមគ្នាបោចឲ្យដោយផ្កាឈូកមួយទងនេះ? (មើលរូបដំរីបោចដើម និងផ្កាឈូកចោល)

នៅចំកណ្ដាលមានរូបក្បាលយក្សមួយដ៏ធំ បានចាប់ខាំក្បាលនាគម្ខាងបីៗ ឯក្បាលនាគនោះគឺតំណាងឲ្យអច្ឆរមាតានាគ (មើលការពន្យល់រូបទី១ និងរូបទី៨០) ដែលមកដល់ដំណាក់ចុងក្រោយនេះទើបព្រឹទ្ធដូនតាយើង បានបង្ហាញពីអ្នកចាប់គាត់យកទៅឃុំ។ នៅខាងឆ្វេងក្បាលយក្សមានហ្មដំរីពីរនាក់ អ្នកទាំងពីរនេះ បានតាមរាវាំងតាំងពីក្នុងអន្លង់សេះក្បាលប្រាំខាងក្រោមឯណោះ មកដល់ខាងលើនេះ ពួគេប្រឹងលើកដៃទ្រផ្កាឈូក ដើម្បីបន្ដថ្នាល ឬរន្ទារបស់ខ្លួន តាមរាវាំងកូននាគដែលកំពុងនាំអច្ឆរមាតាឡើងទៅខាងលើ។ នៅខាងឆ្វេងដៃហ្មឈរទាំងពីរ មានមនុស្សម្នាក់អង្គុយលុតជង្គង់ ដោយលើកដៃស្ដាំចង្អុលប្រាប់ហ្មដំរីទាំងពីរនាក់ មានន័យថាចង្អុលប្រាប់ទិសអ្នកនាំអច្ឆរមាតាចេញ ឲ្យហ្មទាំងពីរបានដឹង ដើម្បីឡើងទៅស្ទាក់ផ្លូវ។ ឯថ្នាក់ជាន់ទីពីរពីខាងឆ្វេងក្បាលយក្ស ហ្មទាំងពីរនៅសល់តែហ្មមួយ បានឡើងជាន់លើផ្កាឈូក ដែលខ្លួនបានបណ្ដុះទ្រពីក្រោមទៅ ដែលហ្មនោះខំប្រឹងឡើងជាន់រន្ទាផ្កាឈូកឲ្យទាន់ក្មេងនោះ ដើម្បីទប់ស្កាត់កុំឲ្យក្មេងនោះឡើងទៅលើផ្កាឈូកធំបាន។ ឯអប្សរាតូចដែលឈរពីលើផ្កាឈូក ពីខាងលើក្បាលមនុស្សអង្គុយលុតជង្គង់នោះ ឡើងមកដល់ថ្នាក់ទីពីរអប្សរានេះបានរីកខ្លួនធំ ដោយជើងម្ខាងជាន់លើផ្កាឈូកខ្លួនឯង និងជើងម្ខាងទៀតជាន់ប្របេះលើផ្កាឈូករបស់ហ្ម ដែលជាសេនាយក្ស ហេតុនេះទើបអប្សរានេះអាចរីកធំបាន ដោយអំណាចចំហាយពីផ្កាឈូកសេនាយក្ស។ រូបនៅចំពីលើក្បាលយក្សកណ្ដាល គឺតំណាងឲ្យហ្មទីពីរដែលឡើងពីក្រោមទៅតែមិនទាន់រីកធំ ទៅដល់ជាន់ទីបីទើបហ្មនេះរីកខ្លួនធំ ដោយជាន់លើផ្កាឈូកដែលខ្លួនទ្រនៅជាន់ទីពីរ ព្រោះរូបជាន់ទីបីនេះ ខ្លួនមានផ្កាឈូកពីរសម្រាប់ជាន់ ខុសពីជាន់ទីពីរដែលមានតែមួយ។ នៅខាងស្ដាំហ្មទីពីរ គឺហ្មទីបី ដែលកំពុងលើកដៃទ្ររន្ទាផ្កាឈូកបន្ដទៅលើទៀត នៅជាន់ទីពីរខាងលើហ្មទីបីនេះបានរីកខ្លួនធំ ព្រោះជើងមានទម្រជាន់ទាំងសង្ខាង ហើយហ្មទីបីនេះពុំមានរូបក្នុងជាន់ទីមួយឡើយ។ នៅពីខាងស្ដាំក្បាលយក្សវិញ រូបភាពទីមួយកូននាគនោះអង្គុយបញ្ឈរជង្គង់ ជ្រោងរុញក្បាលនាគទៅលើ ដែលក្បាលនាគនេះ គាត់ជ្រោងរុញឡើងតាំងពីអន្លង់ខាងក្រោមមក។ ជាបន្ទាប់រូបភាពទីពីរគាត់ចាប់ផ្ដើមក្រោកឈរជើងម្ខាងជាន់លើផ្កាឈូក ឱបរឿងអច្ឆរមាតាជាប់នឹងទ្រូង ហើយគាត់ព្យាយាមនាំរឿងអច្ឆរមាតា ឡើងទៅខាងលើទៀត ដោយមុខគាត់បានបែរចេញមកក្រៅ ខុសពីរូបមុនដែលគាត់បែរមុខខ្ទប់ទៅជញ្ជាំង។ ឡើងទៅដល់ជាន់ទីពីរ គាត់បានអង្គុយលុតជង្គង់លើផ្កាឈូកដោយយកដៃឆ្វេងដាក់លើដើមទ្រូង តែរូបនេះបានដាប់ក្បាលបាត់ទៅហើយ ដោយអត្ថន័យក្នុងរូបនេះ បើយើងមើលសកម្មភាពរូបដែលនៅសល់ គាត់ចង់ប្រាប់យើងថារឿងអច្ឆរមាតា គឺជារឿងក្នុងបេះដូងរបស់គាត់ ព្រោះដៃឱបលើទ្រូងជានិមិត្តសញ្ញាបង្ហាញប្រាប់ ពីអត្ថន័យរូប។ ឡើងទៅ

ដល់ថ្នាក់ទីបី រូបគាត់បានត្រូវផ្តោបខ្ចប់ទៅជញ្ជាំង ដើម្បីរុំព្រួចច្រានអច្ឆរមាតានាគជាចុងក្រោយ ឲ្យដល់រយាងផ្កាឈូកដ៏ធំខាងលើនោះ តែគួរឲ្យអនិច្ចារូបគាត់បានបាត់ក្បាលទៅហើយក្នុងវគ្គបញ្ចប់ ព្រោះថ្មមួយដុំមានរូបក្បាលគាត់ និងក្បាលហ្មពីខាងស្តាំនោះ ត្រូវគេយកចេញបាត់ទៅហើយ ដូច្នេះយើងពុំដឹងថាទីបញ្ចប់នៃរឿង តើមានន័យយ៉ាងណាឡើយ?

បើនិយាយពីដំរីក្បាលប្រាំមួយឬក្បាលបីវិញ ប្រមោយរបស់វាប្រឹងបោចដើមឈូកនិងផ្កាឈូកចោល ព្រោះយើងដឹងហើយថាផ្កា និងដើមនេះ ពេលណាដែលគេបោចដាច់ចេញពីគល់វា គឺត្រូវតែងាប់ពុំអាចរីករួចឡើយ តើផ្កាឈូកតំណាងឲ្យអ្វី? ផ្កាឈូកតំណាងឲ្យប្រជារាស្ត្រអ្នកកាន់ និងគោរពព្រះពុទ្ធសាសនា (មើលការពន្យល់មុនៗ) បើបុគ្គលនោះត្រូវបោចដាច់ចេញពីគល់ទៅហើយ តើផ្កានោះរស់ ឬស្លាប់? ក្នុងប្រស្នានេះ កូននាគប្រុសស្រីត្រូវពិចារណាឈ្វេងយល់ថា បើហ្មបញ្ជាដំរីឲ្យបោចផ្កាឈូកចោលច្រើនម្លឹងៗ ហេតុតែដើម្បីរកផ្កាឈូកមួយទងនៅអន្លង់ខាងក្រោមនោះ តើព្រឹទ្ធដូនតាយើងគាត់ចង់ប្រាប់យើងពីអ្វី? សូមពិចារណាភាសាថ្ម រួចស្វែងរកចម្លើយពិតប្រាកដមួយដោយខ្លួនឯង នោះ**កូននាគនឹងដឹងពីភាពប្រែប្រួលពីរបបដឹកនាំរបស់នគរខ្មែរពុំចេះចប់ក្នុងអតីតកាលសាងតារឿងទាំងអស់ដែលមានក្នុងបេះដូងថ្ម លានជល់ដំរីនេះបានប្រាប់យើងពីហេតុគេទុកជាមុន ដែលត្រូវកើតមាននៅក្នុងនគរនេះ។**

បង្រួមសេចក្តីមកការយករឿងក្នុងថ្មលានជល់ដំរី មកបកស្រាយដោយសង្ខេបនេះ គ្រាន់តែចង់ឲ្យកូននាគចេះមើលរឿងរបស់ខ្លួន ដែលដូនតាលោកព្យាយាមចារឹកថ្មទុក ព្រោះលោកបានដឹងមុនរួចទៅហើយ នៅដំណើរផ្លូវរបស់អ្នកនគរនេះ ពេលដែលអច្ឆរមាតាជិតរស់បាបកម្ម នគរនេះនឹងត្រូវគេតាមចង់ពៀរជាមួយនឹងគាត់ ជាមួយនឹងកូននាគ និងអ្នកដែលត្រូវចុះទៅជួយស្រង់គាត់។ ហើយប្រស្នាក្នុងថ្មនេះ គឺត្រូវយកថ្លុកទៅលុបត្រពាំង មានន័យថាកូនដែលត្រូវចុះទៅក្នុងអន្លង់ដំរីក៏ជាប់ឃុំ (តិចជាង) ឯអច្ឆរមាតាដែលកូនត្រូវទៅជួយក៏ជាប់ឃុំនៅក្នុងទឹកដូចគ្នា គ្រាន់តែទឹកថ្លុកវារាក់ និងតូចជាងទឹកត្រពាំងតែប៉ុណ្ណោះ។ ដូច្នេះហើយទើបលានទាំងពីរគាត់កសាងឡើងទន្ទឹមគ្នា គឺលានព្រះគម្លង់ និងលានជល់ដំរី កូនជាប់ឃុំក្នុងអន្លង់លានជល់ដំរី ឯអច្ឆរមាតាជាប់ឃុំក្នុងលានព្រះគម្លង់ ព្រោះជញ្ជាំងបាំងគុកលានព្រះគម្លង់ជ្រៅជាង និងផ្លូវវែងឆ្ងាយជាង។ ហេតុនេះទើបប្រស្នាក្នុងថ្មចង់ពន្យល់ប្រាប់ថា ពុំងាយមានអ្នកណាអាចទៅដឹងរឿងពិតនៅក្នុងថ្ម ទីលានទាំងពីរនោះឡើយ ភាគច្រើនបានត្រឹមតែដើរ ឬបើកបរកាត់ពីខាងមុខលានតែប៉ុណ្ណោះ។ ក្នុងលានព្រះគម្លង់រូបចុងក្រោយជិត

នឹងរួចពីទោស គាត់បានឆ្លាក់ប្រាប់យើងពីស្នាមអេះចូលជ្រៅទៅក្នុងសាច់ថ្ម **"កូនហ្មើយយក្សបានចាប់លេបម៉ែ អស់ជាង៨ពីរពាន់ឆ្នាំហើយ ខ្លួនម៉ែពុំដែលស្គាល់ការផ្ងួតទឹក ឬអេះនៅរមាស់ឲ្យបានដល់សាច់ឡើយ"** ដូចនេះរូបស្នាមដែលអេះចូលជ្រៅទៅក្នុងសាច់ថ្មនោះហើយ ជាឈ្មោះរបស់ទីលាននេះ ហើយក៏ជាឈ្មោះរបស់បាបកម្ម ដែលព្រះម៉ែទទួលទោសកន្លងមក ព្រោះហេតុតែស្វែងរកមរតកទុកឲ្យកូនខ្មែរ។ ភាសាថ្មក្នុងទីតាំងលាននេះ ទោះបីជាខ្ញុំបានបកពន្យល់ត្រួសៗក៏ដោយ ខ្ញុំជឿជាក់នូវបញ្ញារបស់ពូជនាគច្បាស់ជាយល់ ហើយនឹងជួយផ្ដុំ ជួយស្រាវបន្តនូវបុព្វហេតុទាំងឡាយ ដែលខ្វះចន្លោះនោះឲ្យកាន់តែច្បាស់ ឈប់ស្រពិចស្រពិល ឬភាន់ច្រឡំដូចពីមុនទៀត ដើម្បីឲ្យរឿងទាំងនោះក្លាយជាការពិតរបស់យើងទាំងអស់គ្នា។ កូននាគទាំងឡាយអ្នកគួរសង្កេត នៅការតាមចងពៀររវៀនឹងគ្នា (មើលការពន្យល់រូប) ហេតុនេះទើបព្រះសម្មាសម្ពុទ្ធ បានសម្ដែងនូវគាថាប្រារព្ធពួកភិក្ខុក្នុងដែនកោសម្ពី ដែលបានឈ្លោះទាស់ទែងគ្នាព្រោះតែហេតុបន្តិចបន្តួច ដោយព្រះអង្គប្រារព្ធរឿងព្រះបាទទីឃាតិទូន្មានកូនទីឃាវុថា **"ទីឃាវុកូនចូរកូនកុំឃើញកាលវែង កុំឃើញកាលខ្លី នៃទីឃាវុកូនធម្មតាពៀររមែងរម្ងាប់ដោយការមិនចងពៀរ"** ក្នុងគាថានេះ ព្រះអង្គចង់ឲ្យយើងទម្លាក់ចោលនូវភារៈដ៏ធ្ងន់ ដែលយើងបានរែកទូលអស់មួយសង្សារវដ្តមកហើយ។

## ៨៧/.រូបភាពទី៨៧ រូបព្រះមាតាមហានគរ(នៅប្រាសាទរលស់)



រូបអច្ឆរមាតាឈរក្នុងខ្លោងទ្វារនេះ ខុសពីរូបនៅប្រាសាទនានា ព្រោះហេតុអ្វី? ដោយរូបភាគច្រើននៅក្នុងខ្លោងទ្វារតាមប្រាសាទនានា គេច្រើនឆ្លាក់បុរស ឬស្ត្រីនៅក្នុងស៊ុមខ្លោងទ្វារដែលមានក្បាលនាគត្រូវយក្សលេប (ម្ករ) ហើយទ្រនុងខ្នងនាគនិមិត្ត ច្រើនឆ្លាក់ជាសន្លឹកក្បាច់ពេញ។ ចំណែកក្នុងរូបនេះខុសពីរូបដែលរៀបរាប់ខាងលើ ព្រោះចុងក្បាំងស៊ុមទ្វារជាក្បាលសត្វគុជសី (ពន្យល់រួចហើយ) រីឯទ្រនុងដែលជាក្បាច់ពីមុន ត្រឡប់បែរជាមានប្រាសាទផុសបន្តគ្នាបន្តិចម្ដងៗ រហូតដល់កំពូលខាងលើ។ ប្រស្នាថ្មនេះបើគ្រាន់តែមើលគឺឃើញត្រឹមរូប តែបើមើលរួចគិតទើបឃើញ

រឿងក្នុងបេះដូងម៉ែ ដែលអច្ឆរមាតាលោកបានបំប្លែងបំភាន់ លាក់ទុកក្នុងប្រាសាទរាប់ពាន់ ដែលកើតចេញពីគំនិតព្រឹទ្ធដូនតា បន្សល់ទុកនូវមរតកនេះ គឺគំនិតរបស់ "**អច្ឆរា ឬអច្ឆរិយ**"។ តើរូបនេះមាតាគាត់ចង់ប្រាប់យើងពីរឿងអ្វី តទៅអនាគត?

**ក**/.ស្រ្តីម្នាក់ពាក់មកុដ ពាក់ក្រវិល និងគ្រឿងអលង្ការ ដៃសង្វាងមានពាក់កងជារង្វង់ៗបន្តគ្នា ដៃស្តាំកាន់ដំបងរំពាត់រោមកន្ទុយចាមរី ដៃឆ្វេងចង្អុលចុះក្រោម ស្លៀកសំពត់មានក្បាច់លម្អ រំយោលឈរពីលើកាំជណ្តើរទាំងបួនកាំ តើស្រ្តីនេះតំណាងឲ្យអ្វី?

១/.រូបស្រ្តីនេះតំណាងឲ្យព្រះមាតាមហានគរ ឬអច្ឆរមាតាមហានគរខ្មែរ

២/.ពាក់មកុដតំណាងឲ្យគាត់ជាប្រមុខ ជាស្តេច ក្នុងអតីតនិងបច្ចុប្បន្នដៃលត្រូវមករអភិបាលគ្រប់គ្រងថែរក្សាកេរមរតកចាស់គាត់វិញ (មើលការពន្យល់រូបទី៣៥)។

៣/.ពាក់កងដែលមានរង្វង់ជាន់ៗគ្នា តំណាងឲ្យគាត់ជាអ្នកបង្កើតពូជខ្មែរមន ព្រោះកងពាក់នៅលើដៃគាត់ និងកងដែលពាក់នៅកស្រ្តីជនជាតិមន (មើលរូបទី២១) គឺដូចគ្នា ឯរូបស្រ្តីពាក់កងជាន់ៗដូចរូបនេះខ្ញុំឃើញមានរូបគាត់នៅប្រាសាទភ្នំបូក។

៤/.ដៃស្តាំកាន់ដំបងមានរោមកន្ទុយចាមរី តំណាងឲ្យអាវុធរបស់គាត់ឈ្មោះ កន្សែងបក់ប្រោយ

៥/.ដៃឆ្វេងចង្អុលចុះក្រោម ដែលម្រាមចង្អុលដៃគាត់ធំជាងមេដៃនោះ គាត់ចង់បង្ហាញប្រាប់យើងឲ្យមើលទៅខាងក្រោម តាមសញ្ញាចង្អុលប្រាប់នេះ។ **សញ្ញាចង្អុលដៃនេះ ពេលដែលខ្ញុំថ្វានឆ្លាក់រូបនេះហើយ ខ្ញុំឆ្ងល់រួចគតពិចារណាអស់រយៈពេលពីរឆ្នាំ** ទើបអាចរកឃើញចម្លើយដោយសមស្របមួយ ក្នុងពេលដែលមានក្មួយម្នាក់បានយកសំណួរល្បែងចាក់ទឹកដូង (មើលការពន្យល់ល្បែងចាក់ទឹកដូងក្នុងភាគ១) មកសួរខ្ញុំថា តើល្បែងនេះមានអត្ថន័យយ៉ាងដូចម្តេច? ប្រស្នាក្នុងដៃចង្អុលចុះក្រោមនេះគាត់ចង់ប្រាប់យើងថា "កូនឲ្យម៉ែចេញមកក្រៅម្តេចរួច បើម៉ែនៅទូលយោនីខ្លួនឯងយ៉ាងនេះ កូនត្រូវតែវែកបំពង់ស្រីនេះសិន ទើបអាចចាប់ស្រង់ម៉ែចេញពីក្នុងបំពង់យោនីនេះបាន ហើយម៉ែអាចឡើងមកខាងលើរួច" (មើលមាតាប្រសូតកូន) ដែលក្នុងល្បែងចាក់ទឹកដូងលើកទីពីរបានប្រាប់យើងថា៖

ចាក់ទឹកដូងពីទ្រូងមាតា  កន្ទុយត្រីប្រាក្បាលនាងកុក

អកកំប្រោរចាំកូនស្រង់  បំពង់ស្រី (យោនី) ចាំកូនវែក

ក្បាលម៉ែព្រែក ក្អែកនាំគ្នាជុះអាចម៍ដាក់ក្បាលម៉ែប៉ក់។

អាថ៌កំបាំងរឿងចង្អុលដៃរបស់គាត់ចង្អុលទៅខាងក្រោមនេះ ខ្ញុំបានពន្យល់ក្នុងរូបទី៧៥នៅភ្នំបាណន់ ដែលព្រឹទ្ធដូនតាបានធ្វើជារាងស្នឹងយកទៅបោះដោតសង្កត់ សន្ធប់រន្ធយោនីនោះជាប់ ដើម្បីកុំឲ្យគាត់ចេញមកខាងលើរួច (មើលន័យពាក្យប្រាសាទស្នឹង) ដូចនេះទើបគាត់ចង្អុលដៃទៅក្រោមទុកជាសញ្ញា សម្រាប់ឲ្យយើងពិចារណាឈ្វេងយល់ ហើយជួយស្រង់គាត់។

៦/.កាំជណ្ដើរទាំងបួនកាំ តំណាងឲ្យការឡើងពីទីទុក្ខខាងក្រោមចំនួនបួនលើក (មើលការពន្យល់រូបទីមួយ) ពេលដែលគាត់មកឈរលើកាំទីបួនហើយ គាត់នៅតែចង្អុលទៅក្រោមដដែល នេះគឺជាហេតុដែលយើងត្រូវស្រាវជ្រាវរកប្រស្នាកំបាំងចង្អុលដៃនេះ។

៥/.ខ្លោងទ្វារឬក្បាំងដែលគ្របពីលើគាត់ ក៏បានបង្ហាញភាសាគំនិតបង្កប់ទុក ក្នុងពេលដែលគាត់ចាកចេញពីទោស ព្រោះថាក្បាំងគឺនៅលើក្បាល មានន័យថាក្បាំងបាំងក្បាល ឬបាំងរឿងក្នុងក្បាលកុំឲ្យគេដឹង ឬមើលឃើញ។

១/.ក្បាលគុជសីទាំងសង្ខាងកំពុងបួងកម្រងផ្កា តំណាងឲ្យការបង្រួមទីតាំងទាំងពីរ ឲ្យទៅជាទីតាំងមួយថ្មី (មើលការពន្យល់រូបមុន) ពេលនោះការអបអរសាទរ បានត្រូវពាំកម្រងផ្កាបំពាក់លើកឡើង ដែលជានិមិត្តរូបបញ្ជាក់ប្រាប់ថា រឿងអាថ៌កំបាំងគាត់ចាប់ផ្ដើមមានគេឆ្លល់ហើយគេដឹងរួចជ្រាវរកប្រភពសរសៃសូត្រ ដែលហូតចេញពីនាងដែលជាប់ក្នុងសំបុកសីមា ដោយគាត់បានបំពេញពលិកម្មដេកស្ងោរក្នុងទឹកក្ដៅ ហេតុតែសរសៃសូត្រដើម្បីត្បាញជាសំពត់ហូល....(និមិត្តរូបស្រកានាគ) និងមួយទៀតតំណាងគប់ភ្លើង។

២/.ទ្រនុងរាងប្រាសាទទីមួយ តំណាងឲ្យការរួចចាកទោសរបស់គាត់ ជាលើកដំបូង ឬលើកទីមួយ។

៣/.ទ្រនុងរាងប្រាសាទទីពីរ តំណាងឲ្យការរួចចាកទោសលើកទីពីរ

៤/.ទ្រនុងរាងប្រាសាទទីបី តំណាងឲ្យការរួចចាកទោសលើកទីបី ហើយគ្រប់ទ្រនុងនាគនិម្មិតរូបប្រាសាទ តែងមានក្បាច់បាំងពីក្រោមប្រាសាទ ក្បាច់តំណាងឲ្យការលាក់បាំងរឿងអាថ៌កំបាំងរបស់

គាត់ ក្នុងពេលដែលគាត់កំពុងចាកចេញពីទោស ដែលកូននាគភាគច្រើនពុំបានដឹងពីរឿងនេះ (ពុំទាន់បានដឹងការផ្សព្វផ្សាយ)។

៥/.ទ្រនុងកណ្តាលជាទ្រនុងចុងក្រោយ ឬច្រកទ្វារចុងក្រោយ គាត់បានឆ្លាក់ប្រាប់យើងឲ្យមើលរូបហើយពិចារណាថា ទ្វារចុងក្រោយនេះត្រូវបំបែកជាបីតំណាក់កាលទៀត

* ក្បាំងថ្នាក់ទីមួយ មានទំហំតូច
* ក្បាំងថ្នាក់ទីពីរ មានទំហំធំ
* ក្បាំងថ្នាក់ទីបី មានទំហំកណ្តាល

ឆ្លងកាត់ទ្វារមួយបែកខ្នែងបី (មើលមង្គលទីបីក្នុងភាគពី២) នេះទៀត ទើបអច្ឆរមាតាអាចរួចផុតពីអំណាចឃុំរបស់យក្ស បើយើងមើលរួចពិចារណាតាមប្រស្នារូប អត្ថន័យរូបបានប្រាប់យើងថា សោទីមួយ ទីពីរ ទីបី គឺងាយនឹងបើក ព្រោះពុំមានថ្នាក់បិទបាំងសាំញ៉ាំច្រើន ពេលចូលទៅដល់ទ្វារទីបួន ឬសោទីបួន គឺមានទ្វារមួយតែបែកជាទ្វារបី។ ទ្វារមួយបំបែកជាបីនេះ យើងច្បាស់ជាយល់ថាគាត់លំបាកនឹងចេញឲ្យរួចទៅដល់កំពូលវិញណាស់ ព្រោះទ្វារខាងលើមួយ ស្មើទ្វារខាងក្រោមពីរ ដូច្នេះកូននាគដែលទៅជួយគាត់ ត្រូវប្រើពេលវេលាកាន់តែវែងឆ្ងាយ។ ហេតុនេះហើយទើបគេឆ្លាក់រូបព្រះវិស្ណុដេកលើកថ្មោល ហើយនៅលើខ្លួនត្រូវជាប់ផ្លែព្រួញដ៏ច្រើន (មើលរូបទី៧៦) ការឈឺចាប់ទុក្ខវេទនារបស់អ្នកទាំងពីរ កាន់តែអូសបន្លាយគួរឲ្យអាណិត និងសង្វេគ។

បង្រួមសេចក្តីមក ការបកពន្យល់ភាសាគំនិតដោយសង្ខេបពីរូបនៅប្រាសាទរលស់នេះ (អស់ម្តងបន្តិចៗ) បើយើងមើលនឹងភ្នែកគឺឃើញត្រឹមតែរូប បើយើងមើលហើយពិចារណាក្នុងថ្វាស គឺឃើញរឿងនៅក្នុងបេះដូងមួយ ដែលពោរពេញទៅដោយភាពស្មុកស្មាញ លំបាកវេទនាទុក្ខសោករបស់អ្នកជំនាន់មុន និងអ្នកជំនាន់ក្រោយ។ ទោះបីរូបតូចតែមានអត្ថន័យជ្រៅ ព្រោះបញ្ញារបស់បុគ្គលអច្ឆរិយមិនងាយនឹងចាក់ទម្លុះឲ្យយល់បានឡើយ ដូចជាគាថារបស់ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាសសម្តែងថា "**បុគ្គលណាបានឃើញនូវសច្ចធម៌ ទើបឃើញតថាគត បើបុគ្គលនោះពុំបានឃើញនៅសច្ចធម៌ទេ ក៏ពុំបានឃើញតថាគតឡើយ**" គឺបានឃើញត្រឹមតែសំបករូបតថាគតតែប៉ុណ្ណោះ។

# ៨៨/.រូបភាពទី៨៨រូបផ្ដែរ(មិនដឹងប្រភព)



រូបផ្ដែរនេះគឺជារូបចុងក្រោយនៅក្នុងបណ្ដាំព្រះមាតាមហានគរភាគទីបី ហើយក៏ជារូបមួយដែលមានសារៈសំខាន់ណាស់ចំពោះខ្ញុំ ដែលធ្វើឲ្យខ្ញុំមានជំនឿលើគតិបណ្ឌិតរបស់អច្ឆរមាតា វាក៏ជាត្រីវិស័យមួយសម្រាប់ចង្អុលផ្លូវ ធ្វើឲ្យកើតមានកម្លាំងព្យាយាមឡើងវិញ ពេលដែលជួបឧបសគ្គមករារាំង ដើម្បីអាចឈានទៅបំបែកអាថ៌កំបាំងជាបន្ត ពេលដែលខ្ញុំមើលយល់ពីអត្ថន័យក្នុងប្រស្នាថ្មនេះ។ ព្រោះភាសាថ្មក្នុងផ្ដែរបានផ្ដាំឲ្យខំប្រឹងប្រែងនាំបណ្ដាំព្រះម៉ែ ឲ្យបានដល់ទីបញ្ចប់ ដោយរូបចម្លាក់ក្នុងផ្ដែរនេះ គឺជាប្លង់មួយសម្រាប់ឲ្យដឹងកាលពេលវេលា ក្នុងការបើកសោទ្វារម្ដងៗ ហើយនឹងសម្រាប់ទប់ស្កាត់ឧបសគ្គផ្សេងៗ ពេលកំពុងស្រាវជ្រាវរឿងនៅក្នុងបណ្ដាំព្រះមាតាមហានគរនេះ។ ក្នុងរូបភាពផ្ដែរនេះត្រូវបានចែកចេញជាបីថ្នាក់ គឺថ្នាក់ខាងលើ ថ្នាក់កណ្ដាល និងថ្នាក់ខាងក្រោម ហើយនៅក្នុងថ្នាក់នីមួយៗ បានបង្ហាញពីសកម្មភាពផ្សេងៗគ្នា ហើយក្នុងរូបផ្ដែរនេះទៀតសោតត្រូវបានបំផ្លាញស្ទើរតែអស់ទៅហើយ តែយើងអាចផ្គុំផ្គុំមើលនូវយល់បាន។ ការមើលអត្ថន័យបង្កប់ក្នុងភាសាថ្មរូបផ្ដែរនេះ យើងត្រូវចាប់ផ្ដើមមើលពីចំណុចកណ្ដាលមុន ឯរូបនៅខាងឆ្វេង និងខាងស្ដាំគឺអត្ថន័យប្រហាក់ប្រហែលនឹងគ្នា ទោះបីត្រូវបំផ្លាញមួយចំហៀង ក៏យើងនៅអាចស្វែងយល់មួយចំហៀងទៀតបាន ហើយក្នុងផ្ដែរនេះ រូបរឿងបានមូលមិនខ្វះដូចផ្ដែរប្រាសាទដទៃទៀតឡើយ។

១/.រូបចំកណ្ដាលផ្ដែរ

ក/.ខាងលើមានក្បាលយក្សដ៏ធំមួយ ដែលក្នុងមាត់យក្សគឺជាតួខ្លួននាគ ដែលយក្សបានលេប តាំងពីអតីតកាលមក (មើលការពន្យល់រូបមុនៗ)។ នៅខាងក្រោមខ្លួននាគដែលជាប់ទោស មានដៃយក្សកំពុងលើទ្រខ្លួននាគឡើងបញ្ចូលទៅក្នុងមាត់វិញ មានន័យថាយក្សព្រមលើករាជបញ្ចាខ្លួនឡើង ដែលរាជបញ្ចានេះបានដាក់ទោស អស់រយៈកាលជាងពីរពាន់ឆ្នាំកន្លងមកហើយ ចំពោះបុព្វដូនតា ដែលបានប្រព្រឹត្តខុសជាមួយនឹងយក្សនេះ។ និមិត្តរូបដៃទ្រខ្លួននាគបញ្ចូលទៅក្នុងមាត់វិញនេះ បានបង្ហាញពីការចុះចាញ់ ព្រមទទួលលើករាជបញ្ចាឡើង តើដោយសារហេតុអ្វី បានជាយក្សព្រមលើករាជបញ្ចាឡើង? បើខ្លួនមានឫទ្ធិអំណាចខ្លាំងៗ (មើលភាពសម្បើមរបស់យក្សក្នុងរូប) ហេតុអ្វីក៏យក្សត្រូវចុះចាញ់?

ខ/.រូបក្បាលព្រះវិស្ណុនៅចំចន្លោះកណ្ដាលក្បាលយក្ស និងនាគក្បាលបីនេះហើយ ដែលគាត់បានមកបញ្ចប់នូវពៀរវេរារបស់អ្នកទាំងពីរ តើព្រះវិស្ណុនេះគាត់បញ្ចប់ពៀររបស់យក្ស និងមាតានាគខាងក្រោម ដោយកម្លាំងឫទ្ធិអ្វី ទើបធ្វើឲ្យយក្សព្រមចុះចាញ់? នេះជាចម្លើយមួយដែលលំបាកនឹងឆ្លើយពន្យល់ ក៏ប៉ុន្ដែបើយើងក្រឡេកមើលទៅក្នុងបារមី ពីអតីតកាលរបស់ព្រះពោធិសត្វគ្រប់ៗព្រះអង្គ ដែលអាចស្ដាបនាឲ្យព្រះពោធិសត្វត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធបាន គឺត្រូវបំពេញបារមីទាំង១០ ដែលបារមីទាំង១០នោះ ត្រូវបែកជាបីថែមទៀតត្រូវជា៣០ គឺមានបារមី១០ ឧបបារមី១០ បរមត្ថបារមី១០។ បារមីគឺគុណជាតិដែលត្រូវសន្សំឲ្យគ្រប់ទាំង៣០នេះ ទើបធ្វើឲ្យព្រះពោធិសត្វគ្រប់ៗព្រះអង្គ អាចត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធបាន ហើយក្នុងបារមីទាំង១០នេះ គឺមានបារមីមួយឈ្មោះថាអធិដ្ឋានបារមី។ ព្រះវិស្ណុដែលលោកអាចឲ្យយក្សព្រមចុះចាញ់ ព្រមលើករាជបញ្ចាឡើងបាន ព្រោះលោកបានបំពេញក្នុងអធិដ្ឋានបរមត្ថបារមី មានន័យថាគាត់អធិដ្ឋានឧទ្ទិស (ការតាំងចិត្ត) ជីវិតរបស់គាត់ ឲ្យទៅយក្ស ដើម្បីឲ្យយក្សឈប់ចងពៀរ ហើយព្រមដោះលែងអច្ឆរមាតាខាងក្រោម នេះជាហេតុដែលយក្សព្រមចុះចាញ់ រួចលើករាជបញ្ចាចូលទៅក្នុងមាត់វិញ។ ដូច្នេះគ្រប់ផ្ដែរ ឬរឿងលើជញ្ជាំងគ្រប់ប្រាសាទនានាទូទាំងមាតុភូមិនេះ តែងមានរូបព្រះវិស្ណុនៅត្រង់ចំណុចកណ្ដាលជានិច្ច ព្រោះព្រះវិស្ណុ ឬពោធិសត្វលោកេស្វរ:... ត្រូវមកបញ្ចប់ពៀររបស់អ្នកទាំងពីរ។

គ/.រូបនាគក្បាលបីខាងក្រោម ដែលមានដៃព្រះវិស្ណុខាងលើចាប់ខ្សែសង្វាង ដែលចុងខ្សែម្ខាងនៅជាប់នឹងក្បាលនាគ និងចុងខ្សែម្ខាងទៀតនៅជាប់នឹងដៃយក្ស ខ្សែនេះតំណាងឲ្យចំណងពៀរវេរា

ដែលអ្នកទាំងពីរចងគ្នា ឥឡូវដល់ពេលព្រះវិស្ណុចុះមកស្រាយចំណងចងនេះ ដោយការបំពេញបរមត្ថបារមីខាងលើ។ ហើយនៅសង្ខាងរូបក្បាលនាគ មានផ្កាវំយោលធ្លាក់ចេញពីចន្លោះដៃយក្សខាងលើ ដែលផ្កានេះក្លាយជានិមិត្តរូបសោខណ្ឌរូបមួយៗ ឲ្យដាច់ចេញពីគ្នា ងាយឲ្យយើងអ្នកសិក្សាស្រាវជ្រាវភាសារូប ឆាប់មើលយល់ពីសិល្បបំភាន់នេះ។

២/.រូបពីចំហៀងក្បាលគុជសីខាងស្តាំដៃយក្ស (បើកសោទ្វារទី១)

ក/.រូបថ្នាក់ជាន់កណ្តាលពីខាងស្តាំដៃយក្ស មាននិមិត្តរូបក្បាលគុជសី (ពន្យល់រួចហើយ) និងនិមិត្តរូបកន្ទុយនាគត្រូវយក្សលេប នៅជាប់នឹងមាត់សត្វគុជសី ដែលតួខ្លួននាគនៅជាប់ក្នុងអំណាចឃុំរបស់យក្សនៅឡើយ ព្រោះនេះជាលើកទីមួយដែលគាត់ត្រូវចាកចេញ ពីសោទ្វារជាន់ទីមួយ (មើលការពន្យល់រូបសោទាំងបួនជាន់រូបទី១)។ ហើយការបើកទ្វារលើកទីមួយនេះ បានរបើកឡើងនៅថ្ងៃ៥ ១៥ ១០ ឆ្នាំរោង ថ្ងៃទី២៨ ខែកញ្ញា ព.ស២៥៤៤ គ.ស២០០០ ដែលនៅក្នុងថ្ងៃនោះវេលាព្រឹក សេនាជននៅការពារសន្តិសុខ រមណីដ្ឋានភ្នំអង្គរស្សកន្លែងសន្ធប់រូងនាគ(ទ្វារឃុំអច្ឆរមាតាចុះក្រោយ) គាត់បាននិយាយប្រាប់ថា កាលវេលាថ្ងៃខាងលើចិនហុងស៊ុយបានមកដុតធូប កន្លែងព្រះអង្គធំបាក់បែកនេះ ស្រាប់តែមានកើតរឿងចម្លែកមួយ គឺវិញ្ញាណនាគពីរឈ្មោលមួយ ញីមួយ (សំដីនិយាយរបស់សេនាជន) ចូលក្នុងខ្លួនចិនពីរនាក់ ហើយចិនទាំងពីរនាក់នោះ ដើរដូចដំណើរនាគហើយនិយាយថាគាត់បានរួចពីទុក្ខទោសហើយ (ហេតុភេទលើកទីមួយ កិច្ចធ្វើនៅខេត្តព្រះសីហនុរួចនៅអង្គរស្ស) ។

ខ/.រូបក្បាលនាគខាងក្រោម ដែលចេញពីមាត់ទ្វារលើកទីមួយ បានបែរមុខចូលមកខាងក្នុង ហើយមានរូបព្រះវិស្ណុតូចមួយ នៅអង្គុយពីខាងក្រោយនាគក្បាលបីនោះ ដែលនៅសង្ខាងមានទងផ្កាខណ្ឌជាប់។ កាលគាត់ចេញពីទ្វារគឺរួមតូច ពេលចេញផុតមកដល់ក្រោមទើបរីកធំ ដែលគាត់ចេញពីទ្វារទីមួយមក រួចបែរក្បាលចូលមកខាងក្នុង គឺមានន័យថាគាត់ចេញមកក្នុងប្រទេសខ្មែរនេះ មើលគ្រោះធម្មជាតិក្នុងឆ្នាំនោះ ដែលគាត់បានសម្តែងពីមហិទ្ធិឫទ្ធិឲ្យកូននាគប្រុសស្រីដឹងថា បណ្តាសានេះគាត់ចង់ព្រមានកូននាគប្រុសស្រី ដែលពុំដឹងគុណគាត់ (ទំនួញប្រេត បណ្តាសាប្រេត)។ ចំណែកឯរូបព្រះវិស្ណុដែលរួមតូច បានបង្ហាញប្រាប់យើងឲ្យដឹងថា គាត់ពុំអាចយករឿងនេះទៅប្រាប់ឲ្យអ្នកណាឲ្យគេជឿ និងជួយគាត់បានឡើយ ព្រោះរឿងអច្ឆរមាតាវាធំហួសពីឋានៈរបស់គាត់ នេះម្យ៉ាងៗទៀតថ្នាក់ខាងក្រោម ដែលអច្ឆរមាតាចេញមកខាងក្រៅនេះ មានន័យថាអ្នកដឹងនឹងនាំអច្ឆរមាតាចេញ ឋានៈគាត់ស្មើនឹងប្រជារាស្ត្រសាមញ្ញ (មើលការពន្យល់ពាក្យបន្ទាយសំរែ)។ ហើយក្នុងឆ្នាំដដែលនោះ មាន

ភូតហេតុនាគផុះច្រើនកន្លែង ធ្វើឲ្យកូននាគមានការងឿងឆ្ងល់រហូតមកដល់សព្វថ្ងៃពីរឿងនាគផុស ដោយពុំដឹងថាកើតចេញពីហេតុអ្វី? ពេលចេញពីទ្វារទីមួយរួចហើយ គាត់ត្រូវត្រឡប់ចូលទៅក្នុងឃុំ ដើម្បីបើកសោទ្វារទីពីរជាបន្តទៀត។

៣/.រូបក្បាលគុជសីខាងស្តាំដៃយក្សបន្ទាប់ទី២(បើកទ្វារទី២)

ក/.រូបក្បាលគុជសីទីពីរនេះក៏ដូចរូបទីមួយដែរ រូបនេះតំណាងឲ្យទ្វារជាន់ទីពីរ ដែលព្រះវិស្ណុជា កូននាគត្រូវនាំមាតាចេញជាលើកទីពីរ (មើលប្លង់ប្រាសាទបន្ទាយសំរែផ្លូវចូលសព្វថ្ងៃ)។ សោទ្វារទីពីរ នេះ ត្រូវបានរបើកឡើងនៅថ្ងៃ៤ ១ ២ ឆ្នាំមមី ទី២៩ ខែមករា ព.ស២៥៤៦ គ.ស២០០៣ សូមកូន នាគស្រាវជ្រាវមើលហេតុភេទក្នុងថ្ងៃនោះដែលកើតមានក្នុងនគរ ។

ខ/.និមិត្តរូបនាគដែលព្រះវិស្ណុជិះចេញមកខាងក្រៅ ក្នុងទ្វារទីពីរនេះ ក៏ដូចជានិមិត្តរូបក្នុងទ្វារទី មួយដែរ ព្រោះរូបព្រះវិស្ណុនៅតូច ហើយក្បាលនាគបែរចូលមកខាងក្នុងនគរដដែល ក្នុងចន្លោះទ្វារ ទីមួយ និងទ្វារទីពីរនេះ មានរយៈពេលជិត៣ឆ្នាំ។ រួចគាត់ត្រូវត្រឡប់ចូលទៅក្នុងឃុំវិញ ព្រោះគាត់ត្រូវ សន្សំបុណ្យគឺបារមីព្យាយាមបើកសោទ្វារទីបីជាបន្តទៀត ដោយអំណាចរំយោលផ្កាខណ្ឌរបស់យក្ស គឺត្រូវតែធ្វើដូច្នេះ។

៤/.រូបក្បាលគុជសីខាងស្តាំដៃយក្សបន្ទាប់ទី៣(បើកទ្វារទី៣)

ក/.ក្នុងសោទ្វារមាត់គុជសីលើកទីបីនេះ ត្រូវបំបែកខ្នែងជាពីរទៀតបើតាមមើលរូប ព្រោះ និមិត្តរូបក្បាច់ដែលនៅក្នុងខណ្ឌរំយោលផ្កា មានរាងដូចជាក្បាលនាគបែរចេញទៅខាងក្រៅ មាន ន័យថាជាសោទ្វារមួយដែរ ព្រោះមានរំយោលខណ្ឌសង្ខាង។ សោទ្វារនេះបានបើកឡើងនៅថ្ងៃទី ១១៥១ ឆ្នាំរក ទី២៦ ខែធ្នូ ព.ស២៥៤៨ គ.ស២០០៤ គឺថ្ងៃដែលមានកើតគ្រោះធម្មជាតិរលកយក្ស ស៊ូណាមិ ព្រោះនិមិត្តសញ្ញាក្បាច់បានប្រាប់យើងថា គាត់ឈប់បែរចូលមកខាងក្នុងទៀតហើយ គឺ សញ្ញាក្បាច់បែរចេញទៅខាងក្រៅ (គាត់ចេញពីឃុំទៅខាងក្រៅនគរ ឬប្រទេស)។

ខ/.ក្បាលនាគនិមិត្តសោទីបីនេះ គឺគ្មានរូបព្រះវិស្ណុជិះទៀតទេ ដោយព្រះវិស្ណុបានដេកបាត់ទៅហើយ (មើលការពន្យល់រូបទី៧២) ក្បាលនាគនិមិត្តនេះ ដូចជាការសម្ដែងឫទ្ធិឲ្យពិភពលោកស្គាល់



ពីអំណាចគាត់ បើមើលរូបរលកយក្សស៊ូណាមីពីលើ យើងឃើញដូចជារូបនាគមួយកំពុងពត់ពេនខ្លួនបង្ហាញពីឫទ្ធានុភាព ហើយគាត់ត្រូវត្រឡប់ចូលទៅក្នុងទីឃុំវិញ ដើម្បីបើកទ្វារជាលើកចុងក្រោយ។

៥/.សោទ្វារជាន់ទីបីក្នុងទ្វារលើកទីពីរ ក្នុងទ្វារចុងក្រោយនេះ ក្បាច់រំយោលដែលធ្លាក់ចុះមកខណ្ឌ ឲ្យកើតជាវគ្គៗនោះ ឥឡូវនេះបើយើងមើលតាមរូបភាព គឺក្បាច់រំយោលនោះ ធ្លាក់ចេញពីមាត់គុជសីក្នុងទ្វារទីបីនេះបានតែបន្តិច រំលងចុះមកខណ្ឌបានទៀតហើយ។ ចុងក្រោយនេះ នាគដែលជានិមិត្តរូបអច្ឆរមាតា បានចេញតាមច្រកទ្វារនេះដោយរលូន តាមទំហំរូបរាងពិតប្រាកដ មិនដូចជាចេញទាំងបីលើកពីខាងដើមឡើយ គឺចេញមកដោយពេញលក្ខណៈ (មានសេរីភាពពេញលេញ)។ ឯរូបព្រះវិស្ណុដែលធ្លាប់តែតូចពីមុននោះ ក្នុងរូបចុងក្រោយនេះគាត់បានរីកធំទៅតាមគុណធម៌ ក្បាលនាគក៏ធំទៅតាមសភាពដើម ហើយបែរចេញទៅក្រៅ ប៉ុន្តែចេញចុះមកខាងក្រោមដដែល មានន័យថាកូននាគប្រុសស្រី ពុំទាន់មាននរណាព្រមទទួលស្គាល់គាត់ឡើយ។ នៅទ្វារចុងក្រោយនេះគាត់ចេញមកស្ថិតនៅលើបល្ល័ង្កមួយ ដែលនៅខាងក្រោមបល្ល័ង្កគឺមានកូនស្វាតូចមួយ កំពុងទ្រសែងបល្ល័ង្កនោះចេញ សកម្មភាពរបស់កូនស្វានេះ ខ្លួនតូចទេតែអាចលើកទ្របល្ល័ង្ក និងរូបដ៏ធំខាងលើរួច (មើលរូបខាងឆ្វេងដៃយក្ស)។ កូនស្វានេះក៏តំណាងឲ្យកូននាគម្នាក់ដែលបានដឹង និងយល់ពីរឿងពិតរបស់អច្ឆរមាតាមហានគរ ហើយខ្លួនជួយគាំទ្រហែហមគាត់ ចេញពីទីឃុំឃាំង ទោះបីជាខ្លួនស្ថិតក្នុងស្រទាប់ឋានៈខាងក្រោមក៏ដោយ ( **មើលការពន្យល់ពីស្វារូបទី៧៥**) ។

៦/.រូបផ្ដែរជាន់ខាងលើ បង្ហាញពីមនុស្សបីនាក់ស្ថិតនៅទាំងសង្ខាងក្បាលយក្ស ហើយរូបមនុស្សទាំងបីសង្ខាងនោះ នៅពីលើក្បាលគុជសី ដែលពុំដឹងមានកាន់អ្វីក្នុងដៃឡើយ ព្រោះរូបបានបាក់បែកអស់ទៅហើយ លំបាកនឹងមើលឲ្យយល់បានណាស់ ដោយលក្ខណៈរូបបាត់បង់ស្ទើរតែទាំងអស់ទៅហើយ ដូច្នេះខ្ញុំមិនអាចបកពន្យល់បានឡើយ ព្រោះឯកសារពុំគ្រប់គ្រាន់។

សរុបសេចក្ដីមកអត្ថន័យភាសាគំនិតបង្កប់ក្នុងរូប ផ្ដែរដែលនៅសេសសល់នេះ ព្រឹទ្ធដូនតាយើងគាត់បានលួចឡើង មកចង្អុលបង្ហាញកូននាគក្នុងសម័យនោះ ឲ្យដាប់ឆ្លាក់រឿងទាំងនេះទុកដើម្បីជាប្រយោជន៍ដល់កូននាគសម័យក្រោយ អាចយកមកធ្វើជាត្រីវិស័យសម្រាប់ចង្អុលបង្ហាញផ្លូវកុំឲ្យវង្វេងភាន់ច្រឡំ អស់សេចក្ដីព្យាយាម ព្រោះតែការរារាំងពីអ្នកដទៃ ដែលពួកគេទាំងនោះពុំបានយល់រឿង។ អច្ឆរមាតាលោកបានដឹងជាមុនថា ក្នុងការបើកសោទ្វារទាំងបីជាន់នេះ បុគ្គលដែលជាកូននាគនោះ ត្រូវក្រាញននៀលរងគ្រប់សម្ពាធទុក្ខ ដែលសង្កត់ប្រៀបបីដូចបុគ្គលទ្រភ្នំ ឬឱបភ្នំ ព្រោះការលើកស្ពាន និងរកស្ពានទៅភ្ជាប់រឿងពីអតីត និងបច្ចុប្បន្នឲ្យជាប់គ្នា គឺពុំងាយស្រួលឡើយ (មើលការពន្យល់រូបវិស្ណុដេកក្បាលស្ពាន)។

## III.អត្ថន័យសាសនមាតាបង្កប់ក្នុងថ្មពាក្យប្រៀនប្រដៅរបស់អច្ឆរមាតាឲ្យមើលថ្ម)

ក/.យើងដឹងហើយថា ការចូលទៅទស្សនាគ្រប់ប្រាសាទថ្ម ដែលអច្ឆរមាតាបានបន្សល់បណ្ដាំទុក ជាដំបូងគឺនៅខ្លោងទ្វារចូល ដែលនៅលើខ្លោងទ្វារនោះមានផ្ដែរ (ពន្យល់រួចហើយ) ហើយផ្ដែរនោះមានខាងក្រៅ និងខាងក្នុង ដែលគ្រប់ផ្ដែរទាំងអស់ភាគច្រើន គឺមានសសរដែលទ្រនៅបណ្ដាំម៉ែនោះ ឈ្មោះថាសសរពេជ្រ។ ហើយពីផ្ដែរឡើងទៅក្បាំងក្លែង ឬបាំងក្លែង (ពន្យល់រួចហើយ) តែងមានល្បាក់ថ្មលយចេញ ដែលគាត់ចង់ឲ្យយើងដឹងថា ការឡើងតាមផ្ដែរទៅលើ ត្រូវឆ្លងកាត់ល្បាក់លយចេញមួយ ហើយល្បាក់នេះបើយើងពុំមានដៃស្អិតដូចជីងចក់ ឬតុកកែទេ ពុំអាចឆ្លងទៅតំណាក់ក្បាំងបានឡើយ (នេះជាប្រស្នារបស់គាត់)។ ដូច្នេះការដឹងរឿងក្នុងផ្ដែរគឺមិនទាន់ចប់នូវឡើយ ត្រូវឡើងទៅមើលរឿងជាបន្តនៅលើក្បាលគាត់ថែមទៀត ដែលក្បាលនោះមានក្បាំងពាក់បំភាន់ ដើម្បីការពារការរុករកស្រាវជ្រាវ របស់អ្នកមកពីខាងក្រៅ (បរទេស)។ បើយើងឡើងតាមសភាពធម្មតា គឺបានត្រឹមថ្នាក់ផ្ដែរតែប៉ុណ្ណោះ យើងលំបាកឆ្លងទៅល្បាក់ខាងលើទៀតបានណាស់ (មើលឯកសារឡើងជញ្ជាំងភ្នំដែលមានល្បាក់លយចេញ) ដូចនេះទើបរូបនៅសសរទ្វារទន្លេបាត់ទី (រូបទី៧២ និង៧៣) ចុង

ក្រោយត្រូវបាត់រូបព្រះវិស្ណុ ព្រោះតំណាក់កាលឆ្លងកាត់ល្បាក់លយចេញនេះ ជាតំណាក់កាលលំបាក។ អច្ឆរមាតាគាត់ចង់ប្រាប់យើងថា បណ្ដាំអាថ៌កំបាំងរបស់គាត់ គឺលំបាកនឹងយល់បានណាស់ ប្រៀបបីដូចជាបុគ្គលដែលសិក្សាបរមត្ថធម៌អភិធម្មយ៉ាងដូច្នោះ សិក្សាបានចេះចាំហើយធ្វើឲ្យការត្រាស់ដឹងនៅសច្ចធម៌ រិតតែលំបាកជាងការសិក្សាទន្ទេញនោះទៅទៀត ព្រោះគោត្រភូញាណពីបុថុជ្ជនឆ្លងទៅកាន់លោកុត្តរបាន ត្រូវសន្សំបុណ្យយ៉ាងតិចក៏មួយសែនមហាកប្បដែរ កុំថាឡើយគោត្រភូលោកុត្តរសូម្បីតែកាមាវចរចិត្តឆ្លងទៅរូបាវចរចិត្ត និងអរូបាវចរចិត្តនោះ មនុស្សយើងសព្វថ្ងៃនេះ គឺឆ្លងបានដោយលំបាកណាស់។

ខ/.អច្ឆរមាតាគាត់ផ្ដាំជាបន្តទៀតថា បើកូនឆ្លងផុតតំណាក់ផ្ដែរនេះហើយ កូនត្រូវឆ្លងចូលតំណាក់ក្បាំង ហើយក្បាំងនេះបើយើងក្រឡេកមើលក្បាំងប្រាសាទអង្គរវត្ត យើងច្បាស់ជាអស់កម្លាំងនឹងឡើងជាពុំខាន ព្រោះក្បាំងមានច្រើនជាន់ថ្នាក់ ហើយគ្រប់ជាន់ថ្នាក់ក្នុងក្បាំងទាំងនោះ មានរឿងរបស់គាត់និងកូននាគ រួមទាំងអ្នកដែលមានពៀរវេរានឹងគាត់ផង តាមឈ្មោនីសដាក់ទោសគ្រប់ជាន់ថ្នាក់។ ដូចរូបទី៨៨ដែលបានពន្យល់រួចមកហើយនេះ បានបង្ហាញប្រាប់យើងថា និមិត្តរូបអច្ឆរមាតាទំរាំតែអាចចេញមកបង្ហាញស្រមោល ពីអតីតកាលរបស់គាត់បានម្ដងៗ ត្រូវប្រើរយៈពេលវែងយូរ ទើបអាចចេញរួច បង្ហាញរួចហើយត្រូវចូលក្នុងបន្ទប់ឃុំមួយថ្មីផ្សេងទៀត ដើម្បីរកនៅគន្លិះបើកទ្វារឃុំឃាំងជាបន្តទៀត។

ឃ/.យើងមានគ្រឿងសក្ការមួយបែបហៅថា "**បាយសី**" ហើយយើងតែងតែយល់ថា បាយសីគឺជាឥទ្ធិពលរបស់ព្រហ្មញ្ញសាសនាទៀតផង តែតាមពិតគឺពុំមែនដូច្នោះឡើយ។ បាយសីពាក្យពិតពីមុនគឺមានឈ្មោះថា "**បាចសី**" តែពាក្យនិយាយបានយារក្លាយជាបាយសី ពាក្យថាបាចសី ⇨ បិសាច តើអ្នកណាជាបិសាច ដែលយើងនាំគ្នារៀបគ្រឿងសក្ការនេះថ្វាយបូជា? បិសាចគឺអច្ឆរមាតាមហានគរដែលអ្នកការទូតចិនជិវតាក្វាន់ បានស្គាល់តាមរយការហៅ របស់អ្នកស្រុកចេនឡាក្នុងសម័យនោះព្រោះបិសាចពស់ ឬនាគនេះ (មើលការពន្យល់រូបទី៧៩) គឺជាទេវតា ឬព្រះភូមិ ដែលជាអ្នកថែរក្សាព្រះនគរនេះទាំងមូល។ ដូច្នេះហើយទើបព្រឹទ្ធដូនតាបានបន្សល់ទុកនូវ វត្ថុជាគ្រឿងសក្ការបូជានេះ ជានិមិត្តរូបសម្រាប់បង្ហាញជាតំណាងជំនួសរូបគាត់ បើយើងមើលតាមលក្ខណៈរូបរបស់បាចសី គឺដូចជាក្រចកម្រាមដៃទាំងប្រាំ (កូនបាយសីដែលគេកាច់ទាំងប្រាំ) របស់ស្ត្រីដែលពុំធ្លាប់បានកាត់ ដូចនេះក្រចកត្រូវតែតូចវែង ហើយស្រួច (មើលក្រចកដៃមហាក្សត្រីចិន ក្នុងរឿងភាគ ឬក្រចកព្រាយ

បិសាច)។ ក្រចកទាំងប្រាំតំណាងឲ្យកូនរបស់បាយសី បានឡើងបន្តគ្នាជាថ្នាក់ៗមានន័យថា អច្ឆរមាតាលោកប្រឹងប្រវាឡើង លួចចេញពីទីឃុំក្នុងសមុទ្រទឹកដោះ ដើម្បីឡើងមកជួបនឹងកូនសម័យនោះ ផ្ដល់ឱវាទឲ្យកូន នឹងទុកនូវប្រស្នាបាចសីនេះ។ បើយើងមើលថ្នាក់ក្បាំងភ្លែងរបស់ប្រាង្គប្រាសាទនីមួយៗ និងមើលទម្រង់ថ្នាក់របស់បាយសី អត្ថន័យខាងក្នុងបង្កប់គឺដូចគ្នា គ្រាន់តែមួយជាក្បាំងពាក់នៅលើក្បាល និងមួយទៀតនៅចុងក្រចក ហើយបាចសីនេះគឺមានតែនៅក្នុងស្រុកខ្មែរយើងតែប៉ុណ្ណោះ ព្រោះវាជារឿងប្រស្នាអាថ៌កំបាំងរបស់បិសាចពស់ ឬនាគ (អច្ឆរមាតាមហានគរ)។

ដូច្នេះទើបប្រាសាទបន្ទាយស្រី មានឈ្មោះហៅក្រៅមួយទៀត គឺ "**ប្រាសាទកាច់បាយសី ឬកាច់បាចសី**" ព្រោះអត្ថន័យសាច់រឿងក្នុងថ្មរបស់ប្រាសាទនេះ បាននិយាយរៀបរាប់ពីការកាច់បំបាក់ ភាពរុងរឿងរបស់ស្ត្រីជាអច្ឆរមាតា គឺព្រះមាតានាគ (បិសាចពស់) ហើយចាប់គាត់យកទៅឃុំ និងចុងក្រោយមានកូននាគមានឈ្មោះថា ព្រះវិស្ណុ ឥសូរ លោកេស្វរ:....បានជិះគោដឹកព្រះម៉ែចេញ (មើលការពន្យល់ពីសត្វគោភាគ២)។ គ្រប់គ្រូមន្តអាគម (ជាអ្នកមានជំនឿលើព្រហ្មញ្ញសាសនា) តែងរៀបគ្រឿងសក្ការមានបាយសី ដូងស្លាធម៌ជាតំណាងឲ្យគ្រូតូចធំ ដែលជាគ្រូដើមទៅតាមថ្នាក់បាយសី តែពួកគាត់ទាំងនោះ ពុំដែលបានគិតរកប្រស្នាអាថ៌កំបាំង ក្នុងវត្ថុសម្រាប់បូជាទាំងនេះឡើយ គឺគ្រាន់តែដឹងថាបូជាឲ្យគ្រូដើមតៗគ្នាតែប៉ុណ្ណោះ មិនដឹងថាគ្រូដើមដំបូងរបស់ខ្លួនជាអ្នកណាឡើយ ហើយតែងទម្លាក់គ្រឿងសក្ការទាំងនេះ ថាជាកេរតំណែលបន្សល់ពីឥទ្ធិពលព្រហ្មញ្ញសាសនា។

២/.គ្រឿងសក្ការដែលអមជាមួយបាយសី គឺដូងស្លាធម៌ តើដូងស្លាធម៌មានអត្ថន័យដូចម្ដេចទាក់ទងនឹងរឿងអច្ឆរមាតា? ដូងស្លាធម៌គេតែងតែយកដូងខ្ចី និងទុំមកធ្វើ ប្រស្នារបស់ឈ្មោះផ្លែដូងនេះខ្ញុំបានបកពន្យល់រួចហើយ ពីល្បែងចាក់ទឹកដូង ក្នុងអាថ៌កំបាំងបណ្ដាំមាតាមហារនគរខ្មែរភាគ១។ ឥឡូវនេះខ្ញុំគ្រាន់តែលើកយកពីប្រស្នាម្លូស្លាកំបោរ មកបកពន្យល់ថា ហេតុអ្វីបានជាវត្ថុទាំងបីនេះយើងតែងនាំគ្នាហូបបន្តគ្នា ហើយជាពិសេសទៅទៀតនោះ គឺបូជាព្រះធម៌ (ដូងស្លាធម៌)។ ស្លឹកម្លូតំណាងឲ្យភេទរបស់ស្ត្រី ព្រោះរាងរបស់ស្លឹកនេះ ដូចភេទរបស់ស្ត្រី ស្លាតំណាងឲ្យសាច់របស់បេះដូង (បេះដូងព្រះមាតាពោរពេញដោយភាពចត់) ព្រោះបេះដូងសត្វ ឬមនុស្ស ពេលដែលយើងហាន់បេះដូងសត្វ មានសាច់ជាន់ៗ ដូចជាសាច់ផ្លែស្លា រីឯកំបោរវិញ គឺតំណាងឲ្យថ្ម អាចបំបែកថ្មឲ្យទៅជាកំបោរបានលុះត្រាតែដុត (ធ្វើតប:ធម៌) ទើបអាចដឹងរឿងក្នុងថ្ម។ វត្ថុទាំងបីនេះ ពេលដែលបានទំពារចូលគ្នាគឺក្លាយដូចជាឈាម ហេតុអ្វីបានជាភាគច្រើនស្ត្រីដែលចាស់ៗ គេឲ្យហូបម្លូស្លា? ព្រោះស្ត្រី

ដែលចាស់ គាត់ឈប់មានឈាមរដូវ ហេតុនេះគាត់ពុំអាចបង្កើតបុត្របានទៀតឡើយ ប្រស្នាហូបម្លូស្លានេះ គាត់ចង់ប្រាប់យើងជាកូននាគថា កូនខ្មែរដែលកំពុងយកភេទ (យោនី) ម៉ែមកជេរ អ្នកត្រូវសម្លឹងមើលទឹកមាត់ស្លា ដែលស្ដោះចេញពីមាត់ស្ត្រីហូបម្លូ ន័យរបស់គាត់ចង់ប្រាប់យើងថា អនាគតជាតិរបស់អ្នកនោះ នឹងកើតជាប្រេតស៊ីខ្ទុះឈាម លាមក....ព្រោះភេទរបស់ម៉ែសម្រាប់បង្ហូរចេញនូវឈាម ទឹកមូត្រ និងកាកសំណល់ផ្សេងៗពេលប្រសូតបុត្រ ហើយបើអ្នកនោះយកភេទម៉ែមកដាក់ក្នុងមាត់ (ជេរម៉ែ) តើឲ្យពួកគេមានកំណើតក្នុងសុគតិភពម្ដេចបាន? ដូច្នេះហើយទើបស្ត្រីដែលចាស់ ត្រូវហូបម្លូស្លាបន្តគ្នា ដើម្បីទុកជាប្រស្នាឲ្យកូននាគសម័យក្រោយពិចារណា ទើបនៅក្នុងច្បាប់ប្រុសស្រីដូនតាបានផ្ដាំទុកថា "**ស្លាម្លូស៊ីឲ្យច្រៀកកុំបីបៀកទាំងមូលមិញតូចធំឲ្យច្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ**" ក្នុងន័យនេះហើយ ដែលយើងពុំដឹងអត្ថន័យក្នុងប្រស្នានេះ ព្រោះយើងពុំបានច្រៀកគិតពិចារណា រកហេតុផលពិតពីវត្ថុទាំងបីនេះ។ ហើយម្លូស្លាកំប្បោរនេះ មានឋានៈនៅលើអាសនៈសម្រាប់គោរពបូជា ដែលខុសពីរុក្ខជាតិផ្សេងៗ នឹងនៅក្នុងពិធីមង្គលដទៃផ្សេងៗ ដូចជាក្នុងមង្គលការគេបានរៀបម្លូពាន់ស្លាពាន់ (ម្លូព័ន្ធស្លាព័ន្ធ) តើន័យរបស់**ពាន់** និង**ព័ន្ធ**នេះ ន័យមួយណាជាន័យពិតដែលបានបង្កប់ក្នុងពាក្យនិយាយនេះ?

**គ**/.ហេតុអ្វីបានជាអច្ឆរមាតាយកបណ្ដាំទៅទុកក្នុងថ្ម?

គ្រប់ប្រាង្គប្រាសាទទាំងអស់របស់ខ្មែរ ពុំដែលបានសរសេររៀបរាប់សាវតារឿង ទុកនៅលើប្រាសាទឡើយ បើសរសេរគឺគ្រាន់តែកំណត់កាលបរិច្ឆេទ ក្នុងការកសាងរបស់ស្ដេចអង្គមួយៗ និងឧទ្ទិសដល់បុគ្គល ដែលមានឧបការៈតែប៉ុណ្ណោះ ចំណែកឯរឿងពិតរបស់គាត់ គេពុំបានសរសេរអក្សរជាសាច់រឿងឡើយ គឺគេដាប់ឆ្លាក់ចារឹករូបជារឿងសុទ្ធតែម្ដង ដូចជាយើងទស្សនាខ្សែភាពយន្ត។ ហេតុតែអច្ឆរមាតាយករឿងទៅទុកក្នុងថ្ម ព្រោះបណ្ដាវត្ថុក្នុងលោក វត្ថុដែលអាចទុកឯកសារបានយូរជាងគេ គឺមានតែថ្ម ឯវត្ថុដទៃដូចជា ស្បែក ក្រដាស ឈើ ស្លឹក ស្ពាន់ ប្រាក់....ពុំអាចរក្សាទុកឯកសារបានយូរឡើយ ម្យ៉ាងទៀតបើចង់សរសេរភាសារូប ក៏លំបាកនឹងសរសេរទៀតផងព្រោះត្រូវការទីវែង។ ចំណែកឯថ្មវិញមានសភាពរឹងមាំ នឹងអាចទុកឯកសារសាវតាបានយូរ (ចំពោះគ្មានការបំផ្លាញ) ហើយលោកដឹងថា កសាងតិចតួចគឺពុំបានទៀត ដោយកម្លាំងនៃការបំផ្លាញទៅថ្ងៃក្រោយមានទំហំធំព្រោះពូជជ័យដែលទទួលមរតកគាត់ ក្លាយជាពូជចាញ់ (មើលរឿងអាជ័យមេរត ឬមេត្រត) ដូច្នេះបើពួកគេបំផ្លាញអស់មួយ គឺនៅសល់មួយ បំផ្លាញលើគោកអស់នៅសល់ក្នុងទឹក និងក្នុងដី...។ល។

ទម្រាំតែដល់គម្រប់ឆ្នាំដែលគាត់ត្រូវរួចពីទោស ឯកសារថ្មទាំងនេះក៏នៅសេសសល់ អាចឲ្យកូននាគដែលមានឧបនិស្ស័យ ជាមួយនឹងគាត់គេមើលយល់ គេអាចនឹងជួយគាត់បាន នេះជាហេតុដែលកូនជ័យសម័យអង្គរ កសាងប្រាសាទថ្មបន្តគ្នា រហូតដល់តំណាក់កាលចុងក្រោយ គឺស្ដេចជ័យវរ្ម័នទីពដែលកូនគាត់នេះហើយ បានតែងនិទានរឿងជ័យទុកសម្រាប់ទៅថ្ងៃអនាគត នឹងកើតមានកូនជ័យពីរជ័យទីមួយគឺជ័យសួស្ដី ឬធនជ័យ ឯជ័យទីពីរគឺជ័យមេរត ឬមេត្រត គឺកូនជ័យក៏ល្ងង់ហើយចាញ់ ឯមេដែលធ្លាប់តែនៅពីលើគេ **(មេដំបូល)** ឥឡូវមេមកធ្វើជាមេរត ឲ្យគេក្រាលរនាបរួចគេដើរ គេដេកគេអង្គុយ គេជាន់ពីលើ (ប្រស្នានៅក្នុងរឿង)។ សាច់រឿងទាំងពីរបានប្រាប់ពីឈ្មោះអ្នកនិពន្ធ ឬម្ចាស់រឿងរួចទៅហើយ នៅក្នុងតួឯកប្រុសស្រីនោះ ហើយគាត់បានដឹងទៀតថា តទៅថ្ងៃមុខធនធានជ័យពីអតីត ត្រូវធ្លាក់ទៅក្នុងទឹកអស់ហើយ មើលពាក្យបន្ទរក្នុងរឿងធនជ័យៗបានស្រែកប្រាប់ថា **"អាជ័យធ្លាក់ទឹកហែអើៗ"** ដែលធ្លាក់ទឹកពិតប្រាកដនោះ គឺសមិទ្ធិផលកេរមរតករបស់ដូនតា ជ័យជំនាន់មុនទេតើ ដែលត្រូវធ្លាក់ទឹកនោះ តើយើងជាពូជកូនជ័យ ពូជកូននាគគួរនាំគ្នាស្រង់កេរមរតកជ័យយ៉ាងដូចម្ដេចហ្ន៎? ដូចក្នុងប្រស្នានំមួយដែលយើងបានស្គាល់ នឹងធ្លាប់ហូបនោះ គឺនំបញ្ចុកប្អូនប៉ែនចុក តើឈ្មោះរបស់នំនេះ កើតចេញពីអ្នកណាជាអ្នកដាក់? ឈ្មោះរបស់នំនេះ កើតចេញពីធនជ័យជាអ្នកដាក់ ហើយឈ្មោះនំនេះកើតមានរឿងអ្វីខ្លះ ចំពោះធនជ័យ? បើយើងមើលតាមសាច់រឿងរបស់ធនជ័យ គាត់គឺជាព្រះពោធិសត្វលោកេស្វរៈ ដោយហេតុអ្វី? ត្រង់វគ្គដែលគាត់ស្វែងរកភរិយានោះ គាត់បានស្វែងរកស្ត្រីដែលមានប្រាជ្ញា គឺស្រីសួស្ដី ឯក្នុងទសជាតកព្រះមហោសថ ព្រះអង្គគឺព្រះពោធិសត្វ ដែលជាអតីតជាតិរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង អត្ថន័យរឿងក៏ដូចជារឿងរបស់ធនជ័យដែរ ពេលដែលព្រះមហោសថស្វែងរកភរិយា ព្រះអង្គបានស្វែងរកស្ត្រីដែលមានប្រាជ្ញាទីបំផុតបានជួបនឹងនាងអមរា ដែលជាស្ត្រីមានរូបសម្បត្តិនិងបញ្ញាសម្បត្តិ ចំណុចត្រង់នេះហើយដែលយើងអាចយល់បានថាធនជ័យគឺជាព្រះពោធិសត្វលោកេស្វរៈ ព្រោះព្រះបាទជ័យវរ្ម័នទីពលោកបានដកយកអត្ថន័យ ចេញពីរឿងព្រះមហោសថ សម្រាប់ឲ្យយើងជា កូននាគពិចារណាពីតួអង្គធនជ័យ។ ហើយពាក្យជ័យនិងសួស្ដីនេះ គេតែនាំគ្នាស្រែកសួគ្នាក្នុងពិធីមង្គលការថា ជ័យហាង សួហាង គឺមានន័យថា ជ័យផងសួស្ដីផង ហើយមានអ្វីជាបន្ទាល់ (សម្គាល់) គេក៏នាំគ្នាគោះគង ដែលសម្លេងគងនេះ ជាសញ្ញាប្រាប់ថា ពេលទ័ពចូលសមរភូមិសម័យដើម តែងគោះសម្លេងគងស្គរ ដែលអ្នកសែងស្គរនិងគងដើមទន្ទឹមអ្នកកាន់ទង់ជ័យ (សម្លេងគង គឺជាសម្លេងឈ្នះក្នុងសមរភូមិ)។ សព្វថ្ងៃគេយល់ថាពាក្យជ័យនិងសួនេះ ដកចេញពីរឿងព្រះបាទត្រសក់ផ្អែមនិងសួសជាប្អូន នឹងដកចេញ

ពីតួអង្គសួសក្នុងរឿង អនណើយស្រីអន ចំណុចត្រង់នេះសូមមិត្តអ្នកអានស្វែងរកចម្លើយពិតដោយខ្លួនឯងចុះ ព្រោះក្នុងមង្គលការគេត្រូវយកលំនាំបុគ្គលដែលឈ្មោះមានពីរនាក់ គឺស្ត្រីម្នាក់បុរសម្នាក់ ដើម្បីធ្វើជាតំណាងឲ្យសិរីមង្គល ដល់កូនប្រុសស្រីរបស់ពួកគេ។

រីឯឈ្មោះនំប៉ែនចុកវិញគឺកើតមានក្នុងពេល ដែលគាត់ត្រូវស្ដេចបំបរបង់ទៅស្រុកចិន ព្រោះហេតុតែខ្លាចញញើតបញ្ញារបស់គាត់ ហើយនំនេះឈ្មោះរបស់វាបានកើតឡើង ក្នុងពេលដែលស្ដេចចិនចង់បរិភោគ។ ធនជ័យគាត់បានបញ្ជាឲ្យស្ដេចចិន តាមងើយមើលសរសៃនំ រួចគាត់បានពោលតិះដៀលថា "**មើលមុខស្ដេចចិនដូចជាមុខឆ្កែមើលមុខស្ដេចខ្មែរដូចខែពេញបូណ៌មី** មានន័យថាចិនបានតាមព្យាបាទដល់ពូជជ័យរបស់គាត់ ទីបំផុតអំពើបាបកម្មនេះធ្វើឲ្យបុគ្គលអ្នកប្រព្រឹត្ត នឹងធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិបួន មាននរក ប្រេត តិរិច្ឆាន អសុរកាយ ហើយតិរិច្ឆាននេះជានិមិត្តរូបតំណាងឲ្យសត្វឆ្កែ។ ចំណែកពាក្យថាមើលមុខស្ដេចខ្មែរដូចខែពេញបូណ៌មី គាត់ចង់ឲ្យស្ដេចចិនមើលមុខរបស់គាត់ពេលដែលងើយមុខឡើង ព្រោះគាត់មានកំណើតកើតចេញពីមហាសុបិន្តរបស់ម្ដាយគាត់ "**យល់សប្តិយល់សូង យល់សប្តិឃើញដូង បេះបានទាំងផ្លែ យល់សប្តិឃើញខែៗពេញបូណ៌មី** ព្រោះគាត់គឺជាស្ដេចបញ្ញា ដែលមានពន្លឺភ្លឺស្រទន់មិនបៀតបៀនគេ សុខចិត្តស៊ូទ្រាំលំបាកគ្រប់បែបយ៉ាងដើម្បីខ្មែរ។ កំណើតខ្លែងឯក ក៏កើតមានពេលដែលគាត់ជាប់គុក (មើលរឿង) ព្រោះគាត់ចង់ប្រាប់ស្ដេចចិនថា អ្នកមិនអាចយកនគរនេះបានឡើយ ឲ្យតែពូជជ័យនៅរស់ ឯកខ្មែរនៅតែស្រែកខ្ទរពេញផ្ទៃអាកាសដដែល គ្រាន់តែបច្ចុប្បន្នយើងយកក្បាលក្រពើ មកពាក់ពីមុខឯកឲ្យឈប់ស្រែកជាបណ្ដោះអាសន្នតែប៉ុណ្ណោះ (មើលល្បែងចាក់ទឹកដូង) ពេលដែលយើងនាំគ្នា ដោះក្បាលក្រពើចេញវិញ ឯកនៅតែស្រែកបង្ហាញពីមោទនភាពអច្ឆរិយ (អច្ឆរា) ដដែល។ ឈ្មោះនំបញ្ចុកនេះ ធនជ័យគាត់ហៅពេលផ្ចាញ់ស្ដេចចិន តាមឈ្មោះនឹងន័យពិតគឺនំប៉ែនចុក ដោយអ្នកធ្វើនំត្រូវយកអង្ករទៅត្រាំទឹកឲ្យរីក រួចយកទៅកិនៗរួចត្រងចងពាតៗរួចយកទៅបុកៗរួច យកទៅផ្ដុំស្ងោរៗរួចយកទៅបុកទៀតទើបយកមកលុញផ្ដុំឲ្យប៉ុននឹងរន្ធប៉ែន រួចច្រកដុំម្សៅចូលទៅក្នុងប៉ែន ទើបយកដុំឈើប៉ុនមាត់ប៉ែនមកចុកពីលើដើម្បីរោយម្សៅ ឲ្យធ្លាក់ទៅក្នុងខ្ទះទឹកក្ដៅ ដែលកំពុងពុះឯក្រោម។ ពេលសរសៃនំឆ្អិនហើយ គេដួសយកមកត្រាំក្នុងផ្ទាំងទឹកត្រជាក់ ទើបគេចាប់ឆ្វាយជាចង្វាយ តម្រៀបក្នុងកញ្ច្រែងល្អី ឬកញ្ជើ....បើមិត្តអ្នកអានបានមើលអាថ៌កំបាំងបណ្ដាំមាតាមហានគរភាគ១ ត្រង់វគ្គដែលខ្ញុំបានពន្យល់ពីបាយនោះ ទើបយើងដឹងពីទុក្ខវេទនា ជាប្រស្នានៃនំប៉ែនចុកនេះ។ គេត្រូវយកអង្ករទៅកិនជាម្សៅ

រួចបុកស្មោរចុងក្រោយត្រូវយកម្សៅនេះទៅចុកបិទ រន្ធបង្ហើយរបស់គាត់ (មើលអត្ថន័យវត្ថុភាគ១) ព្រោះអង្ករ ម្សៅ ឬបាយ និមិត្តរូបតំណាងឲ្យព្រះមេ តែម្សៅតំណាងព្រះមេនេះ ត្រូវគេយកទៅញាត់ក្នុងរន្ធប៉ែន រួចយកឈើឆ្នុកទៅចុកបិទសង្កត់ កុំឲ្យម្សៅនេះចេញមកលើរួច តែម្សៅតំណាងឲ្យសរសៃរបស់មេនោះ ត្រូវរុះរោយធ្លាក់ទៅដេកត្រាំក្នុងទឹកក្ដៅ (មើលការពន្យល់ពីសរសៃសូត្រ)។ រន្ធប៉ែនតំណាងឲ្យយោនីរបស់គាត់ ឆ្នុកដែលចុកពីលើរន្ធប៉ែន តំណាងឲ្យការបិទសន្ធប់ ព្រះមេកុំឲ្យចេញមកក្រៅរួច កិន បុក ស្មោរ....តំណាងឲ្យការព្យាបាទឈ្នានីស មិនចង់ឲ្យគាត់ចេញមកខាងក្រៅរួច នេះជាប្រស្នារបស់នំប៉ែនចុកនេះ ដែលព្រឹទ្ធដូនតាជ័យបានបន្សល់ទុកជាកេរមរតក។ ចង់ដឹងរឿងរបស់សរសៃនំប៉ែនចុកនេះ ត្រូវយកទឹកទៅលាចង្វាយ ដែលបានឆ្វាយទុកក្នុងកញ្ច្រែង...នោះ ទឹកដែលត្រូវយកមកលាចង្វាយទីមួយឈ្មោះថា ទឹកសម្លខ្ទាយ ឬសម្លប្រហើរ ទឹកទីពីរគឺសម្លការី (ពាក្យនិយាយគិរី = ភ្នំ)។ ឈ្មោះសម្លប្រហើរមានន័យថា យើងខ្វះខ្ទាយដោយសម្លនេះត្រូវបង់មើមខ្ទាយ ជាគ្រឿងផ្សំមួយ ហើយពាក្យខ្ទាយនេះ ក្លាយមកពីពាក្យខ្វះខ្ទាយ ហេតុតែយើងប្រហែសធ្វេសខ្វះខ្ទាយគំនិត ទើបយើងពុំអាចដឹងពីអាថ៌កំបាំងអច្ឆរមាតាយើង (មើលបន្ថែមក្នុងចាក់ទឹកដូងលើកទី១) ហើយពាក្យថាប្រហើរនេះ ពីដើមដែលម្ដាយឪពុកធ្លាប់ស្ដីឲ្យកូនថៅថា **"មើលវាធ្វើឲ្យប្រហើរ ឥតខ្វល់ខ្វាយជួយដោះទុក្ខធុរៈម៉ែឪសោះ"** ព្រោះពាក្យប្រហើរគឺមានតែក្លិន។ ចំណែកទឹកទីពីរគឺសម្លការី ដែលសម្លនេះប្រភពគ្រឿងផ្សំ ចេញមកពីជនជាតិក្លិង្គ (ឥណ្ឌា) សម្លនេះ អាចស្រាយប្រស្នាកំបាំងចង្វាយ ដែលគេឆ្វាយរឿងរបស់ព្រះមេទុកពីអតីតបាន អាចឲ្យរលាមើលឃើញរឿងពិតរបស់នំនេះ (មើលចាក់ទឹកដូងបែបទីពីរភាគ១)។ ធនជ័យគាត់បានប្រាប់យើងនៅក្នុងប្រស្នាចាក់ទឹកដូងទាំងពីរបែប ចាក់លើកទីមួយគឺពុំឃើញរឿងអ្វីឡើយ ព្រោះរវល់តែក្រពើតាមដេញខាំគាត់ ទាល់តែចាក់លើកទីពីរ ទើបឃើញរឿងម៉ែបង្កប់នៅក្នុងនោះ ដោយការចាក់លើកទីពីរ មានពាក្យ**មាតា**នាំមុខ មាតាគឺជាភាសាអ្នកដែនមគធៈ (បាលី) សព្វថ្ងៃស្ថិតក្នុងប្រទេសឥណ្ឌា។ រឿងនិទានតន្ត្រារបស់ធនជ័យ គឺជារឿងដែលបង្កប់ទៅដោយប្រស្នាដ៏មានជម្រៅ សម្រាប់បំបែកការរំលោភបំពានមកលើពូជពង្សជ័យឬនាគ ព្រោះយើងជាកូនខ្មែរសព្វថ្ងៃ គឺជាអ្នកទទួលមរតកជ័យពីអតីត ហេតុដែលខ្ញុំលើកយករឿងនេះមកពន្យល់ គ្រាន់តែចង់ដកយកនូវចំណែកមួយ របស់អ្នកប្រាជ្ញាជំនាន់មុន មកធ្វើការពិចារណាតែប៉ុណ្ណោះ។ ដូចពាក្យដែលគាត់បានផ្ដាំនឹងស្ដេច មុនពេលស្លាប់ថា **"បើព្រះអង្គសោយត្រីព្រួលកុំចោលស្រកា សោយត្រីប្រាកុំចោលស្រកី ស្មោរក្បាលត្រីប្រាកុំចោលម្ជូរសណ្ដាន់ ឬសន្តាន"** ហើយពាក្យនេះទៀតសោត គាត់ផ្ដាំទុក

សម្រាប់អ្នកដឹកនាំ ដែលទទួលមរតកជ័យគ្រប់ជំនាន់ ត្រូវមានគោលធម៌សម្រាប់ដឹកនាំប្រទេសឲ្យបាន សុខសាន្ត និងរីកចម្រើន។

១/.ពាក្យថាសោយត្រីព្រួលកុំចោលស្រកា ន័យត្រង់ត្រីព្រួលអាចរស់បាន ដោយសារស្រកា ព្រោះស្រកាជាគ្រឿងបិទបាំងរាងកាយត្រី ន័យបង្កប់ស្រកាប្រៀបដូចជាប្រជារាស្ត្រ ដែលនៅជុំវិញអ្នកដឹកនាំដែលមានគុណធម៌ ន័យបង្កប់មួយទៀត បើសិនជាមិនចង់ឲ្យអំណាចដឹកនាំរបស់ខ្លួនប្រែប្រួល ឬប្រួលប្រែទេ (ព្រួលមាន សូរដូចប្រួល) គ្រប់អ្នកដឹកនាំត្រូវគិតប្រយោជន៍ស្រកាគឺប្រជារាស្ត្រ ព្រោះរាស្ត្រអាចលើកបុគ្គលម្នាក់ធ្វើជាអ្នកដឹកនាំបាន ហើយក៏អាចរុះរើទម្លាយនូវអំណាចដឹកនាំបុគ្គលនោះ ឲ្យប្រែប្រួលក្រឡាប់ចាក់បាន នេះជាន័យក្នុងប្រស្នាទីមួយ ដែលធនជ័យបានផ្តាំអ្នកដឹកនាំ (ស្តេច)។

២/.ប្រស្នាទីពីរព្រះអង្គសោយត្រីប្រាកុំចោលស្រកី (ពន្យល់រួចហើយភាគ១) ន័យត្រង់ស្រកីគឺនៅនឹងក្បាល ស្រកីជាច្រមុះដកដង្ហើមរបស់ត្រី ត្រីប្រាអាចរស់បាន គឺដោយសារច្រមុះសម្រាប់ដកដង្ហើមនេះ បើគ្មានស្រកីទុកដូចជាស្លាប់។ ន័យបង្កប់ទីមួយ នគរមួយអាចរស់បានដោយឯករាជ្យ ត្រូវពឹងផ្អែកលើសេដ្ឋកិច្ច ព្រោះសេដ្ឋកិច្ចជាភាពខ្លាំងរបស់នគរមួយៗ ឬដូចជាគ្រួសារមួយអាចមានភាពសុខដុមរមនាបាន គឺស្ត្រីជាអ្នក**កា**ផ្គុំទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យគង់វង្ស ទើបអាចក្លាយជាអ្នកបរិបូរណ៍ដោយទ្រព្យ ពាក្យ**ស្រកី**ក្លាយមកពីពាក្យត្រឡប់ថា **ស្រីក**មានន័យថា បើស្រី**កា**ទុក្ខគឺបានទុក្ខ បើស្រី**កា**សុខគឺបានសុខ និងសុភមង្គល។ ន័យបង្កប់ទីពីរ គឺប្រាស្រ័យទាក់ទង សង្គមជាតិមួយអាចរីកចម្រើនបាន អ្នកដឹកនាំត្រូវចេះប្រាស្រ័យទាក់ទង (ឲ្យដឹងសួរសុខទុក្ខ) ពីក្រោមទៅលើ ពីតូចទៅធំ ពីទាបទៅខ្ពស់ ពីក្នុងប្រទេសទៅក្រៅប្រទេស ដើម្បីចម្រាញ់នឹងនាំយកនូវអ្វីដែលថ្មី និងជឿនលឿន សម្រាប់យកមកកសាងមាតុភូមិរបស់ខ្លួនឲ្យបានរីកចម្រើន ដូចន័យប្រស្នាថា សោយត្រីប្រាកុំចោលស្រកី គឺក្បាលត្រូវចេះគិតពីដង្ហើមរស់ សម្រាប់ចិញ្ចឹមខ្លួនត្រីទាំងមូល (**ស្តេចប្រាជ្ញនាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាំកែវមនោរា**)។

៣/.ប្រស្នាទីបីគឺ ស្ងោរក្បាលត្រីប្រាកុំចោលម្ជូរសណ្តាន់ ន័យត្រង់បើយើងស្ងោរក្បាលត្រី ត្រូវប្រើម្ជូរសម្រាប់កាត់នូវចម្អាប ហេតុអ្វីបានជាគាត់មិនយកម្ជូរដទៃ បែរជាយកម្ជូរសណ្តាន់មកដាក់ជាប្រស្នា? ព្រោះពាក្យសណ្តាន់ និងសន្តានដែលតំណាងឲ្យញាតិ មានសូរសព្ទស្រដៀងគ្នា សម្រាប់ចង

ជាប្រស្នាបំភាន់។ ន័យបង្កប់គាត់ចង់ប្រាប់អ្នកដឹកនាំគ្រប់ជំនាន់ថា បើយើងគ្រប់គ្រងនគរត្រូវសម្លឹងមើលញាតិរបស់ខ្លួន ព្រោះភាគច្រើននៃញាតិ តែងយកអំណាចរបស់អ្នកដឹកនាំ ទៅប្រើគំរាមកំហែងអ្នកនៅខាងក្រោមផ្ដេសផ្ដាស ទៅតាមចិត្តលោភលន់របស់ខ្លួន ដែលធ្វើឲ្យអ្នកដឹកនាំមានញាតិដូចនេះ នឹងមានកេរ្តិ៍ឈ្មោះមិនល្អ។ គ្រប់អ្នកដឹកនាំទាំងឡាយ ត្រូវតែប្រើច្បាប់គឺម្ទូរសម្រាប់កាត់នូវចម្អាបគឺក្លិនឆ្អាបមិនល្អ ដែលញាតិរបស់ខ្លួនបានធ្វើឲ្យខូចសណ្ដាប់ធ្នាប់សង្គមព្រោះបានយកឈ្មោះអ្នកដឹកនាំទៅបាំង ជាពិសេសធ្វើឲ្យកើតនៅគំនុំគំគួន ចំពោះអ្នកដឹកនាំដែលមានញាតិមិនល្អ ធ្វើឲ្យកម្លាំងរាស្ត្រដែលរងគ្រោះត្រូវរកវិធីសាស្ត្រ រម្លាយអំណាចបុគ្គលនោះចោល នេះជាហេតុដែលធនជ័យយកឈ្មោះម្ទូរសណ្ដាន់ **មកបញ្ចប់ប្រស្នាចុងក្រោយមុនពេលគាត់ស្លាប់**។ បើយើងគ្រាន់តែស្ដាប់រឿងពុំបានពិចារណា គឺបានត្រឹមតែស្ដាប់រួចសើចសប្បាយ បើយើងពិចារណារឿងធនជ័យ លោកគឺជាពោធិសត្វលោកេស្វរៈ ដែលខ្ញុំបានពន្យល់ប្រៀបធៀបខាងលើ ដែលឈ្មោះពោធិសត្វនេះ យើងធ្លាប់បានស្គាល់ឈ្មោះគាត់ក្នុងសម័យអង្គរធំនោះឯង (ស្ដេចជ័យវរ្ម័នទី៧) ។

ប្រស្នាកំបាំងរបស់ឈ្មោះនំប៉ែនចុកនេះ យើងអាចយល់ឃើញទៅដល់ឈ្មោះខេត្តស្វាយរៀងសព្វថ្ងៃ ព្រោះខេត្តនេះនៅជាប់នឹងខេត្តព្រៃវែង ហើយខេត្តព្រៃវែងនេះជារាជធានីបាភ្នំពីអតីតកាល ហើយក៏ជាទីក្រុងបាត់បង់នូវក្បាលពីអតីត ដោយអំណាចស្ដេចថ្វាបានមកកាត់ក្បាលស្ដេចខ្មែរក្នុងកាលនោះ (មើលប្រវត្តិសាស្ត្រខ្មែរ)។ ពាក្យហៅពីមុនគឺឆ្វាយរឿង ព្រោះរឿងត្រូវបាត់បង់ក្បាលនៅទីនោះ ទម្រាំអាចប្រមូលរឿងយកទៅកសាងឯភ្នំគូលែនបាន ត្រូវឆ្វាយយករឿងពីទីនោះ យកទៅលានៅភ្នំគូលែន ដែលក្រោយមកបានហៀរហូរ មកដល់ទីក្រុងយសោធបុរៈ គឺខេត្តសៀមរាបសព្វថ្ងៃ។ នេះគ្រាន់តែជាការឆ្កឹះឲ្យមិត្តអ្នកអាននាំគ្នាស្រាវជ្រាវតែប៉ុណ្ណោះ ព្រោះអ្នកប្រាជ្ញាដែលជាអ្នកដឹកនាំពីមុន លោកបានដឹងពីរឿងរ៉ាវអនាគត របស់នគរនេះរួចជាស្រេចទៅហើយ ដោយភាសាគំនិតបានបង្កប់ទុកនៅក្នុងថ្ម ដែលខ្ញុំបានពន្យល់ដោយសង្ខេបខាងលើ បានចង្អុលបង្ហាញប្រាប់យើងរួចទៅហើយ។ ផ្ដែរក្នុងរូបទី១គឺនៅប្រាសាទប៉ែនជុន ហើយខ្ញុំមិនដឹងថាប្រាសាទនេះ ស្ថិតនៅក្នុងខេត្តណាឡើយ ឈ្មោះប្រាសាទ និងអត្ថន័យរូបដែលខ្ញុំបានពន្យល់ហើយ គឺមានន័យស្រដៀងនឹងនំប៉ែនចុកនេះ ខ្ញុំពុំបាច់ពន្យល់ទៀតឡើយ ព្រោះការបកស្រាយភាសារូប និងការបកស្រាយនំប៉ែនចុកនេះ អាចធ្វើឲ្យយើងស្វែងយល់ពីឈ្មោះប្រាសាទនេះបាន ដោយពាក្យនេះបានបង្ហាញន័យគ្រប់ គ្រាន់តែជ្រលិះគ្នាបន្តិចបន្តួចប៉ុណ្ណោះ គឺ **ប៉ែនជុន** និង**ប៉ែនចុក**។

បង្រួមសេចក្តីមកការបកស្រាយពន្យល់ក្នុងភាគទីបីនេះ ដោយខ្ញុំបាទខំប្រមែលប្រមូលឯកសារថ្មមកបកពន្យល់ រួមទាំងគំនិតផ្សេងៗ ដែលបានបកស្រាយហើយនេះ ទុកដូចជាកូនប្រទីបមួយ ឬសោមួយ សម្រាប់បើកមើលអាថ៌កំបាំងរបស់ពូជពង្សនាគ ដែលបានរលុបបាត់ដានអស់ទៅហើយនោះ ឲ្យមកស្ថិតក្នុងសន្តានចិត្តកូននាគប្រុសស្រីឡើងវិញ។ ការខិតខំស្រាវជ្រាវរាវរកការពិតរបស់រូបចម្លាក់ ដែលធ្វើឲ្យខ្ញុំឆ្ងល់អស់ជាង២០ឆ្នាំនេះ ពីរូបក្បាលនាគខ្មែរដែលមានតែក្បាលនោះ ទីបំផុតចម្លើយគឺមាននៅក្នុងឯកសារស្រាវជ្រាវ អាថ៌កំបាំងបណ្តាំមាតាមហានគរភាគ១ភាគ២ ហើយភាសារូបនេះបានបកពន្យល់ក្នុងភាគ៣ ដើម្បីឲ្យកូននាគព្រមទទួលស្គាល់ការពិត ដែលព្រះម៉ែបានយកសាវតាររបស់ខ្លួនទៅប្រតិស្ឋានទុកក្នុងថ្ម។ ហើយក្នុងរយៈពេលខ្ញុំបានជួបស្ត្រីម្នាក់ក្នុងសុបិន្ត ដែលកាលនោះគាត់មានអាយុ១៩៩៨ឆ្នាំ (មើលអារម្ភបទភាគ១) តែជាអ្នកទោស ពីពេលដែលបានជួបគាត់ មកទល់នឹងបច្ចុប្បន្ននេះ មានរយៈពេល១២ឆ្នាំកន្លងផុតទៅហើយ ក្នុងរយៈពេល១២ឆ្នាំនេះ ខ្ញុំបានស្វែងរកអាថ៌កំបាំងរបស់ស្ត្រីនេះ ថាតើគាត់ជានរណា? ពេលនេះឯកសារស្រាវជ្រាវទាំង៣ភាគ បានបើកបង្ហាញពីរូបរាងពិតរបស់គាត់ហើយ។ គ្រាន់តែថាកូនខ្មែរប្រុសស្រី ព្រមទទួលស្គាល់គាត់ដែរឬអត់ នោះគឺអាស្រ័យការពិចារណាឈ្វេងយល់ របស់កូននាគដែលជាអ្នកបានទទួលមរតកគាត់សព្វថ្ងៃនេះ ឯខ្ញុំបានត្រឹមតែនាំរឿងទុក្ខវេទនារបស់គាត់ មកបើកបង្ហាញតែប៉ុណ្ណោះ។ ឯកសារសាវតានេះប្រៀបបីដូចស្រះទឹក កូននាគប្រុសស្រីដូចជាអ្នកស្រេកទឹក ចំណែកឯខ្ញុំបាទជាអ្នកស្គាល់ និងចង្អុលបង្ហាញផ្លូវទៅស្រះទឹក ដូច្នេះកូននាគអ្នកអាចបាត់ស្រេកបាន លុះត្រាតែព្រមក្រេបផឹកទឹកក្នុងស្រះនោះ ឯភារធ្ងន់របស់ខ្ញុំត្រូវបានបញ្ចប់ ក្នុងការប្រមូលឯកសារសាវតាព្រះម៉ែមហានគរទាំងបីភាគនេះ។

ខ្ញុំនៅតែមានសង្ឃឹមក្នុងចិត្តថា បញ្ហារបស់កូននាគដែលជាបុត្របានទទួលមរកតព្រះម៉ែគឺព្រះពុទ្ធសាសនា ដែលព្រះអង្គជាមេនាគធំជាងគេក្នុងភពបីនេះ កូននាគប្រុសស្រីច្បាស់ជាយល់ នូវហេតុបច្ច័យគ្រប់យ៉ាង ដែលកម្មបានតាក់តែងនឹងវិចិត្ររួចហើយ ឲ្យវដ្តសង្សារនេះវិលគ្មានទីបញ្ចប់ សោយផលសុខ និងទុក្ខ នៅពេលណាដែលអមតធម៌ពុំទាន់កើតឡើង ដោយឯកសារសាវតាព្រះម៉ែទាំង៣ភាគនេះ គ្រាន់តែបើកបង្ហាញពីការសោយផលបាបពីអតីតកាលរបស់ពួកគាត់តែប៉ុណ្ណោះ។ អាទិទេពខ្មែរអាចរស់ឡើងវិញបាន គឺដោយសារកូនខ្មែរព្រមជ្រោងគាត់ឡើង ហើយភាពអច្ឆរិយអាចឋិតថេរបាន ទាល់តែយើងព្រមលើកព្រមទទួលស្គាល់ អ្នកបង្កើតភាពអច្ឆរិយគឺអច្ឆរមាតា

មហានគរ ខ្ញុំមិនចង់ឲ្យ គ្រោះមហន្តរាយមួយថ្មីទៀតកើតឡើងក្នុងនគរនេះ ព្រោះតែត្រូវបណ្ដាសារបស់ពួកគាត់ ដោយហេតុតែយើងជាកូននាគពុំដឹងគុណគាត់នោះទេ (**ទំនួញប្រេត បណ្ដាសាប្រេត**)។

ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមអភ័យទោសគ្រប់សំណាក់មិត្តអាន ទាំងគ្រហស្ថនិងបព្វជិត នូវរាល់កំហុសឆ្គងទាំងឡាយ ដែលកើតឡើងដោយអចេតនា ព្រោះខ្ញុំបាទពុំមែនជាអ្នកនិពន្ធ ដូចនេះកង្វះខាតក្នុងអក្ខរាវិរុទ្ធនិងឃ្លាល្បះ ច្បាស់ជាកើតមាននូវកំហុសដោយអចេតនា ម្យ៉ាងទៀតសាវតាររឿងបានលាក់បាំងទុកយូរឆ្នាំហើយ ដូច្នេះពេលលើកឡើងរមែងមានប្រែៈស្និម អាចឲ្យការបកស្រាយមានការភាន់ច្រឡំខ្លះជាពុំខាន ហើយអ្នកដែលជួយវាយអត្ថបទនិងបញ្ចូលរូបភាព គឺកូនប្រុសរបស់ខ្ញុំឈ្មោះ គៀត វង្សច័ន្ទភូមាន។

ជាទីបញ្ចប់ខ្ញុំព្រះករុណាខ្ញុំបាទសូមប្រគេនបុណ្យ ជូនបុណ្យ និងឧទ្ទិសបុណ្យ ដែលបានខិតខំស្រាវជ្រាវសាវតារអាថ៌កំបាំងមាតាមហានគរទាំង៣ភាគនេះ សូមផលនៃបុណ្យនេះជួយឧបត្ថម្ភគាំទ្រដល់លោកអ្នកដ៏មានគុណ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ និងញាតិធម៌របស់ខ្ញុំគ្រប់កាលទាំងបី ដែលពួកលោកសុទ្ធតែជាអ្នកមានឧបការគុណ សូមឲ្យជួបតែសេចក្ដីសុខក្នុងសម្បត្តិមនុស្ស សុខក្នុងសម្បត្តិទេវតា និងសុខក្នុងសម្បត្តិព្រះនិព្វាន ដែលជាសុខរួចផុតចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ។

ខេត្តព្រះសីហនុថ្ងៃ **៥១៥១០** ឆ្នាំខាលទោស័ក ថ្ងៃទី**២៣** ខែកញ្ញា ព.ស**២៥៥៤** / គ.ស**២០១០**

ឯកសារសាវតាព្រះម៉ែនេះ ខ្ញុំសូមរក្សាសិទ្ធិទាំងស្រុង

ពីខ្ញុំព្រះករុណាខ្ញុំបាទអ្នកទទួលមរតកព្រះម៉ែ

**គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្ប

## ចំណាទដៃឆ្នាំថ្មី (ទំនួញព្រះម៉ែមហាគុណ)

១.ក្កកើតទុកកេរក្នុងដែនដី ប្រាប់រឿងស្ត្រីអ្នកប្រសូត

ខ្ខខុសខខះរឿងរឹងស្ងួត គ្គគាំងរឹបរួតស៊ីមិនរួចៗ

២.ឃ្ឃឃុំអ្នកកកើតហេតុកម្ម ក្សត្រីដេកចាំចិត្តព្រឺព្រួច

ង្ងងោកទៅក្រោមព្រោះកម្មលួច ច្ចចាប់ចងគួចព្រោះអទិន្នាៗ

៣.ឆ្ឆឆេះឈើចាប់តសន្ដាន ជ្ជជាប់លំអានទុក្ខពុំជា

ឈ្ឈឈឺងជាថ្នូតជាប់គ្នា ញ្ញញាតិអ្នកងារតមកក្រោយៗ

៤.ដ្ដដេកពើតចុកតែម្នាក់ឯង ឋ្ឋឋានសំដែងទីបង្ហើយ

ឌ្ឌឌួតតរឿងជាប់កៀកកើយ ឍ្ឍឍាលចម្លើយក្នុងប្រស្នាៗ

៥.ណ្ណណែនាំប្រាប់រឿងកំប្លាំង ត្តតែងចំណាំងក្នុងតម្រា

ថ្ថថែតម្រុយរឿងមាតា ទ្ទទៅមូរខារសរសៃសូត្រៗ

៦.ធ្ធធៀបស្វែងរកអ្នកប្រមូល ន្ននាំត្រកូលអ្នកប្រសូត

ប្បប្ងាខំបីត្រកងពូត ផ្ផផ្សៀផ្សុំពួតបានជាភ្លើងៗ

៧.ព្ពពឺតខិតខំផ្គុំក្រៀកចង ភ្ភភ្នែករៀបក្រងបង្ហោះឡើង

ម្មមិនទំនេរទាញឲ្យថ្មើង យ្យយកមេឡើងកាន់វេហាៗ

៨.រ្ររឿតរះរួចរិះគិត ល្លលើកគំនិតព្រះមាតា

វ្វវេនវ៉ាលួនដោះប្រស្នា ស្សសូត្រសាសនាបណ្ដាំម៉ែៗ

៩.ហ្ហហាមិនរួចតែនៅខំ ឡ្ឡឡើងទៅផ្គុំរឿងព្រះមេ

អ្អឱនទទួលមរតកម៉ែ ស្គាល់កាលបុព្វទើបបានសុខៗ

កំណាព្យប្រស្នានេះចងក្រងរួចនៅថ្ងៃសុក្រ ១២កើត ខែចេត្រព.ស២៥៥៤ ត្រូវនឹងថ្ងៃ១៥ខែមេសាគ.ស២០១១

ដោយឧបាសក **គៀត ចាន់ថុន**

## បណ្ដាំម៉ែ

១.កេរមេ កេរម៉ែ(ក្មេរក្មែរ)ខ្មែរតែមួយ    ពូជអ្នកលើកស្ទួយមរតកថ្ម
កម្មកាចកម្ទេចខ្សែតំណា    ពូជពង្សដែលល្អត្រាំគំរង់ៗ
២.ហេតុអ្វីក៏កូនមាសពន្លក    មិនត្រិះរិះរកមើលទម្រង់
រូបរាងម៉ែពិតល្អផូរផង់    អ្នក**ៗ**ពូជពង្សកាលអតីៗ
៣.ហេតុអ្វីកូនម៉ែបែរមិនជឿ    មិនមានជំនឿលើសិរី(សិរី៣ប្រការ ឬស្រី៣ប្រការ)
ដែលជាអ្នក**ៗ**កើតទឹកដី    រូបម៉ែសព្វថ្ងៃត្រូវខ្ទេចកាយ(ឈ្មោះនិម៉ែនចុកឬនិបញ្ចុក)ៗ
៤.ព្រះមេត្រូវខ្ទេចទៅជាម្សៅ    តំណវង្សផៅជ្រុះមិនស្ដាយ
មិនដឹងព្រះមេតាងឲ្យម្ដាយ    ព្រោះកាយម៉ែក្លាយខ្ទេចសាកសពៗ
៥.ឫាយក្លាយជាម្សៅម៉ែត្រូវស្លាប់    ចិត្តម៉ែរងរ៉ាប់រួមប្រសព្វ
ជាមួយនឹងបុត្រមិនកំសត់    ទោះមានឬអត់ក៏តាមថៃៗ
៦.នេះជាសារជាតិនៃស្ត្រីពិត    ទឹកដក់ក្នុងចិត្តឈ្មោះថាម៉ែ
មិនបោះបង់កូនតជាខ្សែ    កេរមេ កេរម៉ែ(ក្មេរក្មែរ)ទ្រព្យព្រះរស់(មាតុភូមិ)ៗ

រៀបរៀងដោយឧបាសក **គៀត ចាន់ថុន**

ថ្ងៃអង្គារ ទី១៥កើត ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស ២៥៥៥
គ.ស ២០១១

## ទំនួញ ដ្ត ត្ត

**១.ដ្ត**ដើរដេកដួលឈើចាប់ពើត    ព្រោះហេតុកកើតទ្រព្យទុកកេរ
ភ្លេចការឈើចាប់តាំងជាម៉ែ    **ត្ត** ថែតំណមរតកទុក។
**២.**ចែកឲ្យកូនក្មែរជំនាន់ក្រោយ    សេពសោយមរតកម៉ែគ្រប់មុខ
ម៉ែរងឈឺចាប់ត្រាំក្នុងទុក្ខ    **ដ្ត**ឈឺពើតចុក **ត្ត**មកក្រោយ។
**៣.**បើកូនម៉ែស្គាល់ពាក្យថា**អរ**(ររ)    **ដ្តត្ត** ត្រាច់ចរចេញបង្ហើយ
កូននិងជួបសុខព្រោះដល់ត្រើយ    ម៉ែបានចម្លើយក្នុងសុគតិ។

រៀបរៀងដោយឧបាសក **គៀត ចាន់ថុន**

# <u>បណ្តាំធនជ័យ</u>

១.បណ្តាំធនជ័យ ប្រាប់កូនប្រុសស្រី ឲ្យប្រឹងលើកស្ទួយ មរតកព្រះម៉ែ
ដែលមានតែមួយ បណ្ឌិតលោកព្រួយ ខ្លាចកូនហៃអើ(ហៃអើៗធនធានជ័យធ្លាក់ទឹក)ៗ

២.បើកូនបែរដឹង រូតរះខំប្រឹង គិតឆ្ងល់សើរើ នូវមរតកចាស់
ដូនតាបានធ្វើ ចារចាំងទុកលើ ផ្ទាំងថ្មប្រាសាទៗ

៣.មានរាប់រយពាន់ គាត់បានបំតីន លាក់ទុកតាមខ្នាត ខ្លាចអ្នកខាងក្រៅ(បរទេស)
មកដាប់សម្អាត ឲ្យរៀបដល់ឫាត ទ្រព្យកេរព្រះម៉ែៗ

៤.ទោះខ្លួនជាប់គុក កាយចិត្តពុំសុខ ខំប្រវាំថៃ លួចបង្ហោះខ្លែង
តាងឲ្យកេរម៉ែ បន្តវង្សខ្មែរ ពូជពង្សសិលាៗ

៥.ដង្ហើមចុងក្រោយ គាត់ពុំបណ្តោយ មុននឹងមរណា ហៅស្តេចមកផ្តាំ
ប្រាប់ក្បួនតម្រា ក្នុងការរក្សា កេរតំណែលម៉ែៗ

ថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥

រៀបរៀងដោយឧបាសក **គៀត ចាន់ថុន**

# <u>គុកដាក់ធនជ័យ</u>

១.គុកមួយគុកពីរគុកបី គុកមួយក្រុងស្ត្រី (សត្វត្រី) ក្នុងអង្រុត
ឃុំឃាំងឲ្យជាប់យាមគត់មុត បំបែររឿងពិតតែន័យផ្សេងៗ

២.គុកពីរឃុំក្រុងព្រះនគរ ប្រជាវីកវរព្រោះ ម៉េងឆេង
មនោគមសណ្តំរួចបំប្លែង ឲ្យសត្វវង្វេងភ្លេចកំណើតៗ

៣.គុកបីដាក់ស្ត្រីដែលជាន្ទំ ដាក់ឃុំក្នុងរូងព្រោះខ្លាចកើត
ពូជពង្សអ្នក**ត**ដែនល្អឆើត កុំឲ្យកកើតជាថ្មីវិញៗ

(នេះជាប្រស្នាអ្នកប្រាជ្ញចិនមកយកនគរ) គុកនេះធនជ័យអាចចេញមកបង្ហោះខ្លែងបានៗ

ខ្លែងឯក => **ខ**លែងឯក => ឯក = ឯនិងក <=> អរនិងកែ បើយើងព្រមកែនិងជួបអរៗ (ប្រស្នាខ្លែងឯក)

អង្គាម => អ ង កាម => អ ងចុះទៅរកកាមគុណាគឺរូប សម្លេង ក្លិន រស ផោដ្ឋព្វៗ

អង្គរ => អរ ឯក ពូជជ័យខាងក្រោយមិនព្រមអរទៅរកកឡើយ គឺអរតែសិបក (ប្រស្នាសាបអង្គាម)ៗ

រៀបរៀងដោយឧបាសក **គៀត ចាន់ថុន**

**<u>បណ្តាំព្រះមេ ព្រះម៉ែមហានគរ</u>** (ទុជង្គលីលា = ព្រះនាងនាគធ្វើដំណើរ)

| | | |
|---|---|---|
| ១.នេះបទកំណាត់ចងជា | ទុជង្គលីលា | និទានរឿងស្រីៗ |
| ២.អ្នកឆកំណើតបុរី | នគរស្ត្រី | ឈ្មោះថាទូមីម៉ែៗ |
| ៣.ដំណែលឆកើតហូរហែរ | កាលដែលរូបម៉ែ | នៅជាព្រះមេៗ |
| ៤.មានឈ្មោះបរិសុទ្ធឋិតថេរ | នាងនាគអ្នកថៃ | រក្សាទឹកដីៗ |
| ៥.នគរល្បៅសុទ្ធតែស្រី | សុវណ្ណបុរី | មេស្រីដឹកនាំៗ |
| ៦.រក្សាការពារថែទាំ | លំបាកស៊ូទ្រាំ | ព្រោះហេតុទឹកដីៗ |
| ៧.ហេតុតែកម្មពីអតី | ធ្វើឲ្យនាគស្រី | ជាប់ក្នុងធ្លាក់ស្នេហ៏ៗ |
| ៨.បង្កើតជាពូជកេរម៉ែ(ខ្មែរ) | តំណហូរហែរ | តមកខាងក្រោយៗ |
| ៩.ម៉ែពុកហេតុតែបណ្តោយ | កម្មនាំឲ្យធ្លោយ | ក្លាយជាអ្នកទោសៗ |
| ១០.ចិត្តលោភបង្ខំជ្រុលហួស | ចិត្តលោភនាំខុស | ព្រោះហេតុតែល្មួចៗ |
| ១១.លួចនោះមិនយកតិចតួច | នាំចិត្តមុតស្រួច | លួចស្ថានយក្សាៗ |
| ១២.ចង់បានវត្ថុអស្ចារ្យ | យកមករក្សា | វង្សត្រីក្របុរីៗ |
| ១៣.ទុកកេរឲ្យខ្មែរប្រុសស្រី | ម៉ែខ្ញីជួបភ័យ | ធ្លាក់ក្នុងអបាយៗ |
| ១៤.ចិត្តម៉ែហេតុតែនឹកស្តាយ | រូបម៉ែតាំងកាយ | ព្រមទទួលជួសៗ |
| ១៥.សុខចិត្តរែកទម្ងន់ទោស | ពុកកូនទាំងអស់ | ឲ្យគេសជាតិៗ |
| ១៦.ជាប់ទោសព្រាត់ប្រាសពីញាតិ | តែចិត្តម៉ែឆ្លៀត | ថៃខ្ទិបរក្សាៗ |
| ១៧.ក្មេរខ្មែរមរតកអស្ចារ្យ | វង្សព្រះមាតា | មហានាគអតីៗ |
| ១៨.វង្សក្សត្រគ្រប់គ្រងទឹកដី | ព្រះម៉ែក្សត្រថ្លៃ | វិសេសអស្ចារ្យៗ |
| ១៩.ទ្រាំទុក្ខបង្ហូរនេត្រា | រងចាំបុត្រធ្វា | ពេលណាទើបយល់ៗ |
| ២០.ចុងមែកកើតចេញពីគល់ | ឬមួយនិមល | មិនយល់សាសនាៗ |
| ២១.ហួបឬាយដឹងគុណអ្នកណា | ឬមួយកូនទ្វេ | ដឹងគុណគ្រាប់ឬាយៗ |
| ២២.ព្រះមេពិតគឺជាម្តាយ | សព្វថ្ងៃម៉ែក្លាយ | ជាបីសាចពស់ (ឯកសារចិនជីវតាក្វាន់)ៗ |
| ២៣.ខ្លួនស្លាប់តែបុរីរស់ | ម៉ែបានសាបព្រោះ | កេរមរតកទុកៗ |
| ២៤.រងចាំមើលទៅថ្ងៃមុខ | ពេលកូនសោយសុខ | មាននឹកឃើញទេៗ |
| ២៥.អ្នកណាទុកមរកតកេរ | កេរម៉ែកេរមេ (ខ្មែរខ្មេរ) | ឲ្យកូនសព្វថ្ងៃៗ |
| ២៦.ចិត្តម៉ែរងចាំបុត្រថ្លៃ | ឈើចាប់ពើតក្រៃ | ព្រោះកូនពុំធ្លាក់ៗ |

២៧.ពួកកូនជាប់ជុំងអន្ទាក់ មនោគមវិស្រាក់ ព័ន្ធជុំគល់ធ្លក។

២៨.ពេលណាទើបកូនពន្លក កើតន្នែកចេញមក មើលឃើញសាសនា។

២៩.បណ្តាំម៉ែក្នុងសិលា កូនពិចារណា មានសុទ្ធតែនាគ។

៣០.ក្នុងក្រៅស្ថិតគ្រប់ទួមិទាត ដែនដីមេនាគ ពីអតីតា។

៣១.នាមប្រាង្គតួអង្គសាសនា ទួមិស្រុកប្រពៃណី សុទ្ធតែរឿងម៉ែ។

៣២.កូនគិតតាមគំណាខ្មែរ កូននឹងឃើញម៉ែ រងទុក្ខម្នាក់ឯង។

៣៣.ម៉ែខំសាបព្រោះរួចបែង ព្រោះម៉ែខ្លាចក្រែង កូនម៉ែពុំដឹង។

៣៤.អកុសលធ្វើឲ្យស្លាក់ដឹង កូនម៉ែឈប់ទ្រឹង គ្មានដឹងអ្វីសោះ។

៣៥.ម៉ែនឹកឃើញស្តាយស្រណោះ ទួមិម៉ែនៅរស់ តែរឿងម៉ែស្លាប់។

៣៦.កូនហ្មើយចូរកូនសណ្តាប់ ម៉ែនឹងរ៉ាយរាប់ ពីសាសនាម៉ែ។

៣៧.ឲ្យកូនឃើញគំណាខ្មែរ ពូជពង្សព្រះម៉ែ ព្រះនាងនាគក្សត្រ។

៣៨.រឿងម៉ែត្រូវសាត់ប្បាត់ បរទេសកំចាត់ បំផ្លាញបណ្តាំ។

៣៩.មរតកខ្ចាំខ្មេចប្រេះស្រាំ ព្រោះហេតុតែកម្ម ផ្តល់ពីបុព្វេ។

៤០.ធ្លាក់ឡើងបុត្រពូជព្រះមេ នាំគ្នាខំថែ មរតកព្រះរស់។

៤១.ម៉ែកូនអាចឆ្លងផុតគ្រោះ ម៉ែបីសាចពស់ ក្លាយជានាគពិត។

៤២.រក្សាដែនដីពិសិដ្ឋ ថ្លៃថ្លាស្នេស្ថិត អនាគតយូរលង់។

៤៣.នេះបទលីលាទុជង្គ ម៉ែប្រាប់ទម្រង់ សាវតាម៉ែក្សត្រ។

៤៤.កុំឲ្យបទឃ្លាតឆ្ងាយប្បាត់ ៖ខ្មែរវង្សក្សត្រ អ្នកកើតទឹកដី។

៤៥.រឿងពិតគឺម្ចាស់ក្សត្រី នាមនាគថ្លាថ្លៃ ដំណើរទៅមុខ។

៤៦.វាលូននាំរឿងក្នុងទុក្ខ ដើម្បីកូនសុខ សោយក្នុងសុខា។

៤៧.បេះដូងកូនមានទេវតា ដែនដីសួគ៌ា ប្រស្នាជ័យហោង។

៤៨.កតញ្ញូនាំសុខចម្បង ប្បារមីចម្លង ដល់ដែនអមតៈ។

រៀបរៀងនិងចងក្រងដោយឧបាសក **គៀត ចាន់ថុន**

ថ្ងៃពុធ ១៥ រោច ខែពិសាខ ឆ្នាំថោះត្រីស័ក ព.ស ២៥៥៥ ថ្ងៃទី១ ខែមិថុនា គ.ស ២០១១

# **គំនិតព្រហ្មឬការគិតរបស់ព្រហ្ម** = (បទព្រហ្មគិត)

១.អនិច្ចាឱរាព្រហ្ម ខំពូតផ្គុំផ្គុំគំនិត ទុកបទព្រហ្មគិត ជាប្រស្នាឲ្យកូនស្រាយៗ

២.ព្រហ្មពិតជាអ្នកណា ព្រះមាតាបីតាថ្លៃ គិតកូនគ្មាននឿយណាយ ហេតុតាំងខ្លួនជាព្រះរស់ៗ

៣.វិហារធម៌ទាំងបួន ក្រុងគ្រប់កូនការពារគ្រោះ ម៉ែឪរងជំនួស ហេតុតែកូនសុខចិត្តបាបៗ

៤.ធម៌មួយគឺ**មេត្តា** ថែរក្សាឲ្យឱវ៉ាទ លំបាកលុតលូនក្រាប ទុក្ខលំបាកគិតចម្បែងៗ

៥.ធម៌ពីរគឺ**ករុណា** គិតបុត្រាអាណិតក្រែង ខ្លាចកូនពុំប្រឹងប្រែង សន្សំបុណ្យរៀនដឹងចេះៗ

៦.ធម៌បីគឺ**មុទុតា** ចិត្តជ្រះថ្លាគិតរិះត្រិះ សប្បាយនិងកូនចេះ មិនធ្លាក់ខ្លួនដើរផ្លូវខុសៗ

៧.ធម៌បួនគឺ**ឧបេក្ខា** ចិត្តល្អថ្លាមានសន្ដោស កណ្ដាលមិនជ្រុលហួស កូនសុខទុក្ខគិតតាមកម្មៗ

៨.ព្រហ្មគិតពិតមានមែន ព្រហ្មជាក់ស្ដែងគង់រងចាំ ឲ្យក្មេងស្រាយបណ្ដាំ ការគិតទុករបស់ព្រហ្មៗ

៩.ឆ្លាក់មុខទុកលើថ្ម ពួជអ្នក**ទា**បែរជាឃំ ព្រោះកូនពុំស្គាល់ព្រហ្ម ម៉ែឪឱបទុក្ខព្រោះបុត្រៗ

១០.ពេលណាទើបកូនដឹង ចេះសញ្ជឹងងើបពីច្បុត កើតឡែកទើបរួចផុត ព្រោះការគិតឡែកក្នុងថ្ងាសៗ

១១.កូនក្រោកទើបស្វាងថ្លា ឡែកបញ្ញាភ្លឺឱកាស ស្គាល់ព្រហ្មពិតល្អណាស់ ពុំមែនព្រហ្មនៅឯនាយ[១]ៗ

១២.ព្រហ្មពិតលោកបានសុខ រួចផុតទុក្ខកម្មពីឆ្ងាយ ម៉ែពុកអរសប្បាយ គំនិត[២]ព្រហ្មកូនបានយល់ៗ

១៣ព្រហ្មចរិយធម៌ ថ្លៃថ្លាល្អផ្ដាច់ឫសគល់ អវិជ្ជាអស់គ្មានសល់ ដល់មណ្ឌលឋានអមតៈៗ

ពន្យល់ន័យ ១.ព្រហ្មញ្ញសាសនា ២.អ្នកបង្កើតប្រាសាទមុខព្រហ្ម

ថ្ងៃព្រហស្បតិ៍ ១កើត ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី២ មិថុនា ២០១១

រៀបរៀងចងក្រងដោយ ឧបាសក **គៀត ចាន់ថុន**

# ទំនួញព្រហ្មលិខិត ឬលិខិតព្រហ្ម

១.ចំណារគតិព្រហ្ម    ខំពូតផ្ដុំចារលិខិត    ប្រស្នាកាព្យគំនិត    ចារលើថ្ងៃឲ្យកូនស្រាយ។

២.ពាក្យថាព្រហ្មលិខិត  ន័យខ្មែរពិតតស្រទ្បាយ  ពុំមែនព្រហ្មញ្ញនាយ  គឺគំនិតព្រះព្រហ្មខ្មែរ។

៣.លិខិតចារលើថ្ង    ពេញនគរជាប់ហូរហែ    តំណាងឲ្យកេរម៉ែ(ខ្មែរ)  ញញឹមទុកបង្កប់ន័យ។

៤.ហេតុម្ដេចលោកមិនទុក  លិខិតពុទ្ធសាស្ដាស្រី  ពុទ្ធសាសចូលដែនដី    សុវណ្ណភូមិស្រុករគ្នា។

៥.ទុកតែលិខិតព្រហ្ម    យើងទួញយំស្រែកតគ្នា    ព្រហ្មលិខិតតាមចងព្យេរ    តើព្រហ្មាមានសិទ្ធិអ្វី។

៦.មកដាក់បណ្ដាសារ    យើងគ្រប់គ្នាទាំងប្រុសស្រី    តាមពិតកម្មអតី    បុត្រប្រុសស្រីបានសាងមក។

៧.ពុំមែនលិខិតព្រហ្ម  ចាប់បង្ខំឲ្យកូនយក  គ្រោះឬាបកម្មទុក្ខសោក  តាមអំណាចព្រះព្រហ្មឡើយ។

៨.ឬាបកូនគឺទង្វើ  ដែលកូនធ្វើទុកមកហើយ  ពុំមែនសារព្រហ្មឡើយ  ព្រះសាស្ដាព្រះអង្គផ្ដាំ។

៩.ថាសត្វលោកទាំងអស់  ប្រព្រឹត្តិឆ្ពោះតាមផលកម្ម  ចក្រវិលតាមលំនាំ  ដានស្នាមកម្មមានហើយពិត។

១០.ហេតុអ្វីបានជាបែរ    នាំគ្នាថៃព្រហ្មលិខិត    ពាក្យចេញពីគំនិត    លិខិតព្រហ្មកប់ក្នុងថ្ង។

១១.លិខិតគឺសិរី(សិរីថ)  ចូលឆ្នាំថ្មីថ្ងៃបវរ    សង្ក្រាន្តនាំតំណរ    លិខិតព្រហ្មចាញ់ប្រស្នា។

១២.ហេតុតែមានអំនួត    មានៈអួតថាអស្ចារ្យ  តាំងខ្លួនជាមាតា    បិតាពិតបង្កើតព្យេរ។

១៣.នាំគ្នាប្រព្រឹត្តខុស    មានកំហុសនឹងព្រហ្មមារ  លោកត្រូវបណ្ដាសារ  កម្មនាំទុក្ខព្រោះតែកេរ។

១៤.តើកូនម៉ែមានឆ្ងល់    កើតចម្ងល់នឹងព្រហ្មទេ    ព្រហ្មខ្មែរពីបុព្វេ    មានតែក្បាលពុំមានខ្លួន។

១៥.តើខ្លួនបាត់ទៅណា    មានសិរសាប្រាណបំពួន  បុត្រទ្វាថ្ងៃនឹមនួន    ដោះប្រស្នាលិខិតព្រហ្ម។

១៦.ធម្មបាលមានវាសនា  ស្ដាប់ចរចាឥន្ទ្រីធំ    មេកូនក្នុងទ្រនំ  និយាយប្រាប់រឿងធម្មបាល។

១៧.ឥន្ទ្រីគឺជាអ្វី        បុត្រប្រុសស្រីស្ដាប់តំណាល  រឿងកើតមានក្នុងកាល  កន្លងទៅស្ទើរលុបដាន។

១៨.ឥន្ទ្រីយមួយសទ្ធា  ពីរវិរិយាតាមលំអាន  បីសតិប្បដ្ឋាន  បួនសមាធិនាំចិត្តស្ងប់។

១៩.ឥន្ទ្រីយប្រាំមាំក្លា    គឺបញ្ញាហ៊ានគាស់កាប់  មោហៈឲ្យដេកស្លាប់    កុំប្រទ្បឹសត្វឥន្ទ្រី។

២០.ឥន្ទ្រីយក្នុងបស្សនា  តាមតម្រាមានម្ភៃពីរ    ដើមគេចក្ខុន្ទ្រីយ  ចុងអញ្ញាតាវិន្ទ្រីយ។

២១.កបិលមហាព្រហ្ម  នៅក្នុងយុំរូងគីរី    បុត្រីមានប្រាំពីរ  ចរលើលានាំគ្នាថៃ។

២២.បុត្រពិតពីរដណ្ដប់  កូនសំណប់តាងម្ដាយខ្មែរ  តាមពិតអ្នកមកថៃ  មានប្រាំពីរដែលចេះនឹក។

២៣.ទឹកក្នុងបេះដូងគេ  ត្រូវថ្ងៃខែស៊ីសាច់ទឹក(ដួងខែស៊ី)  ធ្វើឲ្យគេភ្លេចភ្លឹក  ឈប់រំលឹកពីព្រហ្មថ្លៃ។

២៤.ឯកូនទាំងប្រាំពីរ    ដែលសល់ពីកូនឥតន័យ  ប្រចាំគ្នាពេកក្រៃ    វេនអ្នកណាហ្នឹងទៅហែ។

២៥.ចំណែកអ្នកឯទៀត    គ្មានពេលឆ្លៀតមកជួបម៉ែ  ដោះសារកិច្ចបង្វែរ  ថារវល់ព្រោះអត្តា។

២៦.អស់ឱ្យព្រហ្មលិខិត    កម្មព្រហ្មពិតតាមយថា    កម្មសាងជាចំណារ   ទុក្ខណែនទ្រូងស្រែកដង្ហោយ។

២៧.ព្រហ្មថ្មកើតមានមុន  ក្បិលមហាព្រហ្មកើតមានក្រោយ ប្រស្នាទុកកូនស្រាយ ពីសិរីបីប្រការ(ស្រីថ)។

២៨.ធម្មបាលអ្នកឃាមធមិ៍   បើកទ្វារគតិ៍ដោះប្រស្នា លិខិតដែលព្រហ្មចារ  ម៉ែឳ្យសុខដល់ត្រើយនាយ។

២៩.សាស្តាត្រាស់ដឹងឯង  ទ្រង់សម្តែងសព្វបរិយាយ  ឲ្យសាវកត្រួសត្រាយ  ដោយបញ្ញាគិតសឹមជឿ។

៣០.កុំជឿព្វគេថា   តាមតម្រាឬជំនឿ  ឈ្វេងយល់ផុតទាបតឿ   សច្ចៈមានកូនត្រូវយល់។

៣១មែកស្លឹកផ្លែផ្កាបាន  មានលំអានឬសនិងគល់  លិខិតព្រហ្មបន្សល់  ព្រោះព្រហ្មពិតគឺឪម៉ែ។

៣២.បើកូនបានសោយកេរ   ត្រូវរិះរករគល់ខ្សែ  រាវរកពូជពង្សខែ  ដែលមានកម្មពីអតី។

៣៣.ហួបបាយនឹកឃើញព្រះ  ខ្ពស់ល្អណាស់ព្រះមេស្រី  អ្នកឥកើតទឹកដី  ព្រះម៉ែក្សត្រពូជពង្សព្រហ្ម។

៣៤.បើព្រហ្មលោកបានសុខ  ចាកផុតទុក្ខពៀរគំនុំ   ចំណាររបស់ព្រហ្ម  កូនបានដោះប្រស្នាហើយ។

៣៥.កូនម៉ែអើយទ្លាក់ឡើង  លើកតម្កើងកុំព្រងើយ ព្រហ្មពិតផុតទុក្ខហើយ  ព្រហ្មមុនក្រោយបានសុខា។

ថ្ងៃច័ន្ទ ៥កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី៦ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ថុន**

# ស្រណោះមេបួន(បទមេបួន)

| | | | |
|---|---|---|---|
| ១.នឹកឃើញអាឡោះ | ស្រណោះមេបួន | ឈ្មោះកាព្យបាត់ខ្លួន | នៅសល់តែមេៗ |
| ២.បាត់នាមត្រកូល | ពូជពង្សម្ចាស់កេរ | តើឈ្មោះព្រះមេ | លិចបាត់ទៅណាៗ |
| ៣.កាបកាបកាបកាព្យ | កាបញើរកប្បា | កាបខ្សែឃុផ្កា | កាបគាបរនេះៗ |
| ៤.កាព្យពាក្យចុងជួន | កាព្យជាចំណោះ | ឃ្លាកាព្យមិនធ្វេស | ប្រហែសបាត់ឃ្លោងៗ |
| ៥.ឱឈ្មោះកាព្យអើយ | នឹកឡើងរលោង | កាព្យសល់តែគ្រោង | មេបួនជាឃ្លាៗ |
| ៦.ជាបទកំណាព្យ | រណ្ដំជាប់គ្នា | ហេតុតែវេរា | ម្ចាស់បទបាត់ឈ្មោះៗ |
| ៧.លិចបាត់ទៅក្រោម | ស្រោបរុំដោយគ្រោះ | កាព្យមិនមានឈ្មោះ | មានត្រឹមមេបួនៗ |
| ៨.មេបួនជាអ្វី | មេតាងមាសសួន | ម៉ែឪមុខបួន | តែកូនពុំស្គាល់ៗ |
| ៩.ព្រោះហេតុអំនួត | ហ៊ានលោតហ៊ានឆ្វាល់ | បញ្ចប់ត្រូវទ័ល | មានមុខបាត់ខ្លួនៗ |
| ១០.តើកូនដឹងទេ | ម៉ែទុក្ខផ្ទួនៗ | ទុក្ខព្រោះតាំងខ្លួន | ជាស្តុរតាំងម៉ែៗ |
| ១១.ផ្អែមហើយល្វីងស្វិត | បាបកម្មព្រោះតែ | តាំងខ្លួនជាម៉ែ | ធ្លាក់ក្នុងអបាយៗ |
| ១២.ជាព្រាយជាប្រែត | កម្មតាំងជាម្ដាយ | នឹកឡើងសែនស្ដាយ | ត្រូវកូនបំភ្លេចៗ |
| ១៣.នៅសល់តែមេ | ពាក្យបួនរំលេច | កុំឲ្យតែភ្លេច | ឧបកិច្ចនឹកមេៗ |
| ១៤.អ្នកក្រោយចូរចាំ | រិះគិតគ្នាន់គ្នេ | កុំស្គាល់ព្រះមេ | នៅត្រឹមតែបាយៗ |
| ១៥.បញ្ញាភ្លឺឡើង | ខំដោះខំស្រាយ | ខំត្រួសខំត្រាយ | ទើបឃើញការពិតៗ |
| ១៦.ពូជវង្សសម្ភា | ពូជត្រិះរិះគិត | ពូជវង្សបណ្ឌិត | ពូជចេញចាកទុក្ខៗ |
| ១៧.បើកូនយល់ហើយ | ទើបមេបានសុខ | ចរចាកចោលគុក | សោយផលសួគ៌ាៗ |
| ១៨.ចម្លើយឈ្មោះមេ | តាមវង្សព្រហ្មា | ពង្សព្រះចន្ទ្រា | ទិព្វសេដាច័ន្ទៗ |
| ១៩.ជាមេអ្នកសាង | ពូជសោមព្រះឥន្ទ | ទាវវង្សអ្នកកាន់ | មរតកស្ណុកាៗ |
| ២០.សង្ខេបដោយខ្លី | ស្រដីតាមការ | ស្វែងរកនាមា | កាព្យបួនប្រពៃៗ |
| ២១.បើសមមិនសម | សូមជួយអត្ថ័យ | មេបួនមានន័យ | បង្កប់ប្រស្នាៗ។ |

ថ្ងៃច័ន្ទ ៦កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី៧ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ថុន**

# ស្រណោះមេបុណ្យខាងលិច (បទបន្ទោលកាកគតិ/បទបថ្យាវត្ត)

១.មេបុណ្យខាងកើតមេបុណ្យខាងលិច　　កាព្យលើករំលេចតាមកិច្ច[1]ថ្យាវត្ត
　មេបួនផ្ទួនពីរនាំឲ្យវិវឌ្ឍន៍　　កើតបថ្យាវត្តបានពាក្យប្រាំបីៗ
២.បទបថ្យាវត្តប្រាប់បេះដូងស្រី　　រូបរាងកប់នីយក្សត្រីជាមេ
　បង្កើតតក្រៃព្រហ្មត្រួតផ្តុំឡើងទ្វេ　　ព្រហ្មមួយជាម៉ែព្រហ្មមួយជាក្សត្រៗ
៣.ដំណើរនៃព្រហ្មអណ្តែតរសាត់　　លិចចុះកប់បាត់ស្ងប់ស្ងាត់ដំណឹង
　[2]ទក់ក្លាយជាថ្មអ្នក**ឥ**បាត់ដឹង　　**ឥ**គាំងស្មៀមឈឹងគ្មានចេញវាចាៗ
៤.[3]ព្រហ្មត្រួតរំពឹងអ្នក**ឥ**វាសនា　　ពេលណាសិលាចរចារចេញមក
　មេបុណ្យខាងលិចជាម្លប់ឈប់ជ្រក　　ខ្ញុំកែវពន្លកអ្នក[4]ដេកដល់ណាៗ
៥.ឬក្រពើលេបឲ្យក្ស័យមរណា　　មិនឃើញជីវ៉ាវាចាស្រដី
　ឬក្រពើដេញត្របាក់ពិសី　　កោះមេបុណ្យជ័យរាងក្បាលក្រពើៗ
៦.សំណាកគាស់បានរូបរាងស្ទាក់ស្ទើរ　　មានតែខាងលើនៅទើខាងជើង
　[5]បរទេសរុះរើគាស់កាយរំលើង　　ចិត្តថ្មើងទំនើងអាងខ្លួនអ្នកដឹកៗ
៧.មេបុណ្យខាងលិចនៅលិចក្នុងទឹក　　ទំនាយរំលឹកឲ្យនឹកតគ្នា
　កម្មពីអតីតបន្តវេរា　　រងទុក្ខវេទនាកប់ក្នុងព្រៃមនុស្សៗ
៨.ទំនាយសុក្រសៅរ៍ចង្អុលគំនូស　　ព្រៃហោមពាន្តនោះលាក់សត្វរាជសីហ៍
　អាណិតអាសូរដល់ពូជអ្នកថ្លៃ　　ទម្រង់ចរណៃត្រឹមតែព្រៃៗ
៩.នេះជាស្រមោលចំណាំងពន្លឺ　　ឈ្មោះអ្នកធ្លាប់ឮចាស់ៗនិយាយ
　មានបុណ្យខាងលិចលេចក្នុងទំនាយ　　ស្ទូរស័ព្ទបរិយាយតគ្នាមកៗ
១០.ឬកែវថ្មើមថ្លៃគ្មានម្លប់ឈប់ជ្រក　　ទើបកែវពន្លកមិនមកហាស្តី
　ឬនៅបន្ទំសន្សំបារមី　　គុណធម៌ប្រពៃព្រះពោធិសត្វៗ
១១.ឬកម្មវេរាអតីតមកកាត់　　ឲ្យលិចចុះបាត់កប់ស្ងាត់ក្នុងព្រៃ
　បាត់ដឹងបាត់ដាន[6]ពូជពង្សធនជ័យ　　អ្នកប្រាជ្ញឈ្លាសវៃដោះប្រស្នាចិនៗ
១២.ស្រណោះមេបុណ្យសូមស្លេះទុកសិន　　ពូជពង្សស្មៀកក្បិនស្លេះសិនប៉ុណ្ណោះ
　បញ្ចប់ការគិតឈ្វេងយល់រិះត្រិះ　　ទុកឲ្យប្រាជ្ញចេះលោក**ឥ**ប្រស្នាៗ៕

១.បទបថ្យាវត្ត ២.ថ្មទក់ ៣.ព្រហ្មមុខ៤ ៤.រូបព្រះវិស្ណុដេក ៥.បរទេសធ្លាប់ធ្វើអាណានិគមពីមុន ៦.ពូជជ័យវរ្ម័ន

ថ្ងៃសុក្រ ៩កើត ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃ១០ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ថុន**

**<u>កំណើតធនជ័យ</u>** (បទកាកគតិ)

១.នេះបទកាកគតិ តំណែលបិតិ មរតកដូនតា ជាកាកគំនិត ទុកក្នុងសិលា
រឿងរ៉ាវអច្ឆរា មរតកព្រះម៉ែ។

២.កំណើតធនជ័យ កើតដោយប្រពៃ មានរឿងហូរហែ ម្តាយយល់សុបិន្ត ដូងបេះទាំងផ្លែ
ឃើញវង់ព្រះខែ រះពេញបូណ៌មី។

៣.ធ្លាក់ស្វាងពេលណា ម៉ែពិចារណា សុបិន្តរាត្រី ឃើញហេតុចម្លែក សែនល្អពេកក្រៃ
ចង់ដឹងអត្ថន័យ ទៅរកគ្រូទាយ។

៤.ទៅផ្ទះហោរា មិនជួបនឹងតា បានជួបតែយាយ ស្តាប់ពាក្យបរិយាយ អ្នកមករកទាយ
យាយបែរទំនាយ ប្រាប់ន័យបង្ខុស។

៥.ហេតុតែច្រណែន សប្តិល្អមែនទែន កើតចិត្តប្រទុស្ត ព្រោះកើតមោហ: និយាយបង្ខុស
យាយទស្សន៍ទាយនោះ ចិត្តបាបពេកក្រៃ។

៦.ម្តាយចាប់មានគភ៌ គ្រប់ថ្ងៃទ្វារទេរ ប្រសូត្របុត្រថ្លៃ តាំងនាមឲ្យឈ្មោះ កុលបុត្រធនជ័យ
កុំឲ្យបុត្រថ្លៃ ធំឡើងខ្ញុំគេ។

៧.ធនជ័យធំឡើង ម៉ែខ្វិតំកើង មិននៅផ្ទះទេ ទៅលេងឯផ្ទះ សេដ្ឋីជាមេ
អ្នកមានលើសគេ ក្នុងទឹកដីនោះ។

៨.រឿងហេតុកើតឡើង សេដ្ឋីនីយើង ត្បាញហូលគ្រលំជ្រុះ ប្រើជ័យឲ្យរើស ឈ្នួលអំបុកដូស
រឿងកើតពេលនោះ ស្ទូត្រនិងអំបុក។

៩.ស្ទូត្រតាងឲ្យនាង និមិត្តរូបរាង ជាប់ក្នុងសំបុក គេយកទៅស្ងោរ នាងនាគរងទុក្ខ
ចិត្តកាយជាប់គុក ព្រោះហេតុតែគេ។

១០.ចំណែកអំបុក ប្រស្នាចារទុក តាងឲ្យព្រះមេ ស្រូវលីងឲ្យឆ្អិន ទុក្ខកើនឡើងទ្វេរ
រួចបុកព្រះមេ បាត់រូបរាងដើម។

១១.នេះគឺជាហេតុ ដែលនាំកើតនេទ រឿងជ័យចាប់ផ្តើម កើតពីព្រះមេ តាងឲ្យម្តាយដើម
ដែលជាសំណើម ប្រាជ្ញចាប់កំណើត។

១២.ជ័យពិចារណា សេដ្ឋីយាយតា ដែលបានរស់កើត សោយកេរព្រះមេ មរតកល្អឆើត
ម្តេចឡេចកំណើត ចិត្តលោភប្រវ័ញ្ច។

១៣.ស្ទូម្បីតែក្មេង នៅតូចរត់លេង សេដ្ឋីតាមផ្ចាញ់ មិនសង្វេគសោះ វិត្ថបចម្រាញ់
ប្រឹងកេងប្រវ័ញ្ច ក្នុងដែនព្រះម៉ែ។

១៤.ធនជ័យតស៊ូ ធ្វើជាគំរូ ក្នុងនាមកូនខ្មែរ ចិត្តងើបប្រឆាំង គគ្នាហូរហែ

តាងឲ្យវង្សខែ រះពេញបូណ៌មីៗ

១៥.ជ័យផ្ដាញ់ទាំងអស់ មិនឲ្យសល់សោះ តាំងពីសេដ្ឋី ពីតូចទៅធំ នាម៉ឺនមន្ត្រី

ក្សត្រស្ដេចផែនដី ដែលពុំដឹងគុណាៗ

១៦.ឲ្យកូនម៉ែឡាក់ មើលឃើញវង្សត៍ក្រ ព្រហ្មរងទុក្ខធ្ងន់ ព្រោះហេតុតែកេរ ម៉ែឪលោតលន់

ទទួលទុក្ខធ្ងន់ កប់ទឹកតក់ដីៗ

១៧.ជ័យស៊ូនឹងចិន នាំប្រាជ្ញអ៊ែប៊ុន មកយកបុរី ស្លាប់ខ្លួនជាតិរស់ ដោះប្រស្នាបី

រក្សាទឹកដី មរតកព្រះរស់ៗ

១៨.ហេតុតែប្រទេស ត្រូវគេនិទេស ជ័យជួបនឹងគ្រោះ ដើម្បីកេរម៉ែ ជ័យហានប្រទូស្ត

ថាស្ដេចចិននោះ មុខដូចសត្វឆ្កែៗ

១៩.ចិនចាប់ដាក់គុក កាយចិត្តពុំសុខ រិះគិតហូរហែ លួចបង្ហោះខ្លែង តាងឲ្យកេរម៉ែ

ឥពូជពង្សខែ សោមខ្មែរអច្ឆរាៗ

២០.ចុងក្រោយចិនចាញ់ បណ្ឌិតលោកផ្ដាំញ់ ដោយចោទប្រស្នា ទុកឈ្មោះខ្លែងឯក មរតកដូនតា

ទុកជាប្រស្នា ន័យកាកគំនិតៗ

២១.ចំណែកខ្លែងឯក មានអ្វីគួរប្លែក ក្រដាសមួយសន្លឹក ចិនបែរចុះចាញ់ ជ័យប្រាជ្ញបណ្ឌិត

ប្រស្នាគំនិត ជ័យទុកឲ្យកូនៗ

២២.ចុងក្រោយជ័យផ្ដាំ ឲ្យកូនម៉ែចាំ កុំឲ្យសាបសូន្យ សំណាល់គំនិត ជ័យទុកឲ្យកូន

ធ្វើជាទូកក្បូន ដោះប្រស្នាបីៗ

២៣.កូនកុំបណ្ដោយ បើកូនបានសោយ កូនត្រូវដឹងន័យ ដឹកនាំនគរ ឲ្យខ្ពស់ថ្លាថ្លៃ

ត្រូវស្គាល់អត្ថន័យ សត្វត្រី(ស្ត្រី)ប្រស្នាៗ

២៤.ប្រស្នាជ័យហោង តាមដោយគន្លង នៃក្បួនប្រស្នា បណ្ឌិតទុកពាក្យ បេះដូងទេវតា

ដែនដីសួគ៌ា កត្តញ្ញូនាំសុខៗ

២៥.សូមបញ្ចប់ស្លេះ សង្ខេបប៉ុណ្ណោះ សូត្រនឹងអំបុក បង្កើតប្រាជ្ញជ័យ រៀបរាប់ទំនុក

ជ័យជួបតែទុក្ខ ឲ្យតែជាតិរស់ៗ

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស ២៥៥៥ ត្រូវនឹងថ្ងៃទី១៦ មិថុនា គ.ស ២០១១

រៀបរៀងចងក្រងដោយឧបាសក **គៀត ចាន់ថុន**

# **ពំនោលមាតាមហានគរ** (បទពំនោល)

១.សូសៀងសំនៀងពំនោល ដូនតាបានពោល ពំនោលទុកជាមេកាព្យៗ

២.ជាពូជទុកឲ្យកូនសាប ជានាមកំណាព្យ មេកាព្យមានតែល្បះបីៗ

៣.ឲ្យកូនយល់ដឹងអត្ថន័យ ប្រស្នាសិរី ឆ្នាំថ្មីមានបីប្រការៗ

៤.សង្ក្រានតំណែលដូនតា ទុកន័យប្រស្នា ចំណារជាលិខិតព្រហ្មៗ

៥.ពំនោលពោលប្រាប់ទុក្ខធំ ព្រហ្មជាប់ក្នុងឃុំ រូងត្និគិរី[១]សុមេរុៗ

៦.ព្រហ្មតាងតំណាងព្រះម៉ែ ម្ចាស់មរតកខ្មែរ ព្រះម៉ែជាម្ចាស់[២]សិរីៗ

៧.កប់ខ្លួនទៅក្នុង[៣]ទក់ដី ព្រះម៉ែនាគថ្លៃ ខ្លួនស្រីត្រូវរាហូលេបៗ

៨.លោភទោនាំចិត្តឲ្យសេព នាំឲ្យពង្សទេព យក្សលេបក្លាយជា[៤]បិសាចៗ

៩.អកុសលគួរឲ្យខ្លាច ព្រោះហេតុអំណាច កម្មកាចកើតពីចិត្តលោភៗ

១០.កម្មនាំសោយផលស្មោកគ្រោក សោយទុក្ខវិយោគ សោយសោកពុំមានកូនដឹងៗ

១១.កាលមនុស្ស[៥]ព្រហ្មខ្វេរខំប្រឹង ឱបលោភច្រើនម្ល៉ឹង ស្រវឹងនឹងទ្រព្យទុកកេរៗ

១២.ទុកឲ្យអ្នកសោយកេរម៉ែ រស់សុខល្ហើយល្ហៃ កូនខ្មែរពុំស្គាល់ពំនោលៗ

១៣.ដូនតាចងកាព្យរួចពោល កាព្យបំភ្លឺទ្រោល ពាក្យពោលបង្កប់ទុកន័យៗ

១៤.កូនកើតឈ្មោះថាប្រាជ្ញជ័យ ដោះប្រស្នាបី ចិន[៦]តែមកយកនគរៗ

១៥.ប្រាជ្ញជ័យលោកបើកទ្វារគតិ ដោះតាសាឝ ប្រាជ្ញទ្រជួយជ័យជួបជោគៗ

១៦.ពំនោលពោលប្រាប់ពីសោក ជ័យមានក្នុងលោក ជួបសោកច្រើនជាងជួបសុខៗ

១៧.ជាតិរស់ចិត្តបានស្រណុក ខ្លួនមានក្តីសុខ ជាតិទុក្ខចិត្តខ្លោចផ្សាក្រៃៗ

១៨.ជិតស្លាប់ចិត្តនៅរំពៃ ពោលប្រស្នាបី ឲ្យស្តេចចងចាំរិះគិតៗ

១៩.ពំនោលពោលពីគំនិត ពង្ស[៧]ជ័យប្រាជ្ញពិត ពូជពិតសាងប្រាសាទថ្មៗ

២០.តំណែលហូរហែបន្ត រៀបរាប់ដំណា វង្សថ្មត្រូវដាច់ដំណឹងៗ

២១.[៨]ចោលក្រុងព្រៃដុះជិតឈឹង កូនម៉ែលែងដឹង ឈប់ទ្រឹងឝគាំងដូចថ្មៗ

២២.ពំនោលលែងពោលបន្ត ការត្រិះរិះល្អ កើតមានគ្រប់ញាតិសន្តានៗ

២៣.ពំនោលពោលត្រូវសុខសាន្ត ចិត្តសុខក្សេមក្សាន្ត ស្គាល់ធម៌ដល់អមតៈសុខៗ

១.ត្និព្រះសុមេរ ២.ស្រីបីប្រការ ឬសិរីបីប្រការ ៣.ថ្មទក់ ៤.បិសាចពស់(ឯកសារចិនជីវតាក្វាន់ ៥.ព្រះម៉ែខ្មៅ ៦.តៃបន្លិ ៧.ពូជជ័យវរ្ម័ន ៨.ការបោះបង់ចោលក្រុងអង្គរជាង៤០០ឆ្នាំ

ថ្ងៃ១២រោច ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១១

ដោយខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ថុន**

## **<u>សំណល់មរតកកេរ</u>** (បន្ទោលកាក)

១.បទបន្ទោលកាក សល់ជាសំណាកឈ្មោះកាព្យ ដូនតាបានសាប មកកាព្យជាកេរព្រះរស់ៗ
២.បន្ទោរសំណល់ ផ្លែផ្កាជាផលប្រាប់ឈ្មោះ អត្ថន័យកាព្យនោះ រង្គោះជ្រុះបាត់ន័យពិតៗ
៣.ដំណើរដើមទង ថ្លែងតាមទំនងការគិត បន្ទោរគំនិត ន័យពិតទុកឲ្យកូនស្រាយៗ
៤.គំនិតជាកេរ ក្នុងដែនព្រះមេសុះសាយ ដំណាំវែងឆ្ងាយ បានក្លាយជាកេរព្រះម៉ែៗ
៥.តែខ្មែរគំនិត បានបាត់រឿងពិតវង្សខែ គំនិតព្រះម៉ែ ដាច់ខ្មែរជាង[១]បួនរយឆ្នាំៗ
៦.សំណល់គំនិត សាសនមានពិតត្រូវកម្ម ឲ្យភ្លេចបណ្ដាំ ភ្លេចចាំយល់ខុសព្រោះបាបៗ
៧.បរទេសឈ្លានពាន ចូលមករុករានបង្ក្រាប នាំចិត្តសេពបាប ព្រោះសាបមនោគមថ្មីៗ
៨.បំភ្លេចការពិត រាល់កាកគំនិតរឿងស្រ្តី ព្រះម៉ែម្ចាស់ថ្លៃ បំភ្លៃថារឿងសាសនាៗ
៩.កូនម៉ែភ្លេចដឹង ឆគាំងស្ងៀមឈឹងវាចា ពោលតាមតម្រា [២]រិចារបរទេសគិតឲ្យៗ
១០.បើកូនកើតសុខ ម៉ែសាងកេរទុកឲ្យសោយ ត្រូវរកមកោយ កុំធ្លោយគំនិតជឿងាយៗ
១១.តាំងជាម៉ែខ្មី នាំចិត្តខុសផ្លូវព្រោះស្ពាយ មរតកពង្រាយ អោយរាយពាសពេញនគរៗ
១២.ក្រែងលោកូនដឹង ត្រិះរិះសញ្ជឹងរុករ លើកម៉ែខ្មីទ្រ បញ្ឈរដាក់លើសិរសាៗ
១៣.បើយល់[៣]ទំនៀម បេះដូងកូនមានទេវតា ដែនដីសួគ៌ា ប្រស្នាបន្ទោរកាកគិតៗ
១៤.សូមបញ្ចប់ស្លេះ សង្ខេបរិះត្រិះការគិត បញ្ចប់គំនិត ម៉ែពិតប៉ុណ្ណោះឯងហោងៗ

១.ការបោះបង់ចោលក្រុងអង្គរ ២.ការពិចារណា ៣.ទំនៀមទំលាប់ប្រពៃណី ៤.រាជបំណាងជ័យវរ្ម័នទី៧

ថ្ងៃ១២រោច ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១១

ដោយខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ថុន**

# លោកអ្នកមានឧបការៈគុណ

១.លោកឪពុក ឧបាសក គៀត គុណា

២.អ្នកម្តាយឧបាសិកា ជុំ ហ៊ីន

៣. លោកស្រី ប្រាក់ ច័ន្ទសុខា

៤.ព្រះភិក្ខុ គៀត ចាន់ធុច

៥.លោក ឌី បូរីម៉ា

៦.លោក កុយ គមលាង (ហៅ ឈាង)

៧.លោក ឈួ សុខម៉េង

៨.លោក អេង ឡុង

៩.លោក ហួត ខួនថៃ(ហៅគោ)

១០.លោក មាស ចាន់ស៊ី

១១.លោក អ៊ុក សីលា

១២.សេន  រ៉ែន(ហៅម៉ាំង)

១៣.គៀត វង្សច័ន្ទកូមាន

១៤.ពៅ សាវឿន (ហៅទុត)

១៥.សុខ គមហេង

**១៦. KENJI KENMOCHI** 剣持研治

# បណ្តាំព្រះមាតាព្រហ្ម



ព្រះមាតាព្រហ្មរួចពីទោស

ប្រវត្តិសាវតាព្រះមាតាព្រហ្ម

ស្រាវជ្រាវនឹងចងក្រងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ

**គៀត ចាន់ធុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ

**ភាគទី៤**

# <u>**អារម្ភបទ**</u>

ក្រោយពេលខ្ញុំព្រះករុណាខ្ញុំបាទ សរសេរចងក្រងភាគទី៣ចប់ជាងមួយឆ្នាំហើយ ខ្ញុំបាទមិនបាន សរសេរភាគ៤បន្តទៀតឡើយ គ្រាន់តែសរសេរបណ្តាំព្រះម៉ែមហានគរជាពាក្យកាព្យ ស្រាយនូវ ប្រស្នាបង្កប់ក្នុងឈ្មោះកំណាព្យទាំង៧មេ មុនសម័យអង្គរនិងក្នុងសម័យអង្គរ។ ចំណែកការស្រាវជ្រាវឃើញថ្មីខាងក្រោយ ដែលបានលាក់ទុកក្នុងមរតកអច្ឆរិយនេះ ខ្ញុំពឹងឲ្យក្មួយ២នាក់ ម្នាក់នៅខេត្តព្រះសីហនុ និងម្នាក់ទៀតនៅភ្នំពេញ ឲ្យជួយយកការរកឃើញថ្មីនេះទៅផ្សព្វផ្សាយ។

ខ្ញុំព្រះករុណាបាទពុំអស់ចិត្ត ដោយក្នុងបណ្តាំព្រះម៉ែភាគ៣ ខ្ញុំបាទពុំទាន់ដឹងការរួចពីទុក្ខទោសជាស្ថាពរ របស់មាតាបិតានិងញាតិវង្សាមហានគរឡើយ។ ដូច្នេះខ្ញុំព្រះករុណាខ្ញុំបាទ ក៏ចាប់សរសេរភាគ៤នេះឡើង ក្រោយពីមាតាបិតាមហានគរបានរួចផុតពីទោសជាងមួយឆ្នាំ ដោយខ្ញុំបាទចង់ប្រាប់ពេលវេលា រួចពីទោសរបស់ពួកគាត់ក្នុងទីបញ្ចប់ ហើយនឹងបកស្រាយនូវអ្វីដែលខ្ញុំបាទពុំបានបកស្រាយនូវក្នុងភាគមុន។ ម្យ៉ាងទៀតឯកសារបណ្តាំព្រះម៉ែទាំង៣ភាគមុន មិនទាន់អាចបង្កើតបានជាមុខព្រហ្មឡើយ ហើយភាគទី៤នេះទើបអាចបង្កើតបានជាមុខព្រហ្ម ក្នុងអតីតផងនិងសម្រាប់បច្ចុប្បន្នផង ដើម្បីឲ្យកូននាគបាន ឃើញនៅដំបូលព្រហ្មវិហារធម៌ពិត របស់អ្នកកកើតមរតកអច្ឆរិយនេះ។ ឯកសារស្រាវជ្រាវនេះទុកជាមរតកគំនិតថ្មីមួយ ដើម្បីភ្ជាប់តំណថ្មដែលបានដាច់រាប់ពាន់ឆ្នាំមកហើយនេះឲ្យជាប់គ្នាវិញ ទុកសម្រាប់ឲ្យកូននាគយកទៅពិចារណាទៅតាមផ្លូវលោក ផ្លូវធម៌ និងបានបើកបង្ហាញនៅរឿងពិត ម្ចាស់មរតកពីអតីតរបស់យើង។

ឯកសារនេះស្រាវជ្រាវនិងចងក្រងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ**គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ

គេហទំព័រ:

http://kietchanthon.blogspot.com

http://kietchanthon.info

អ៊ីម៉ែល:kietchanthon@gmail.com

info@kietchanthon.info

ក្នុងអាថ៌កំបាំងបណ្ដាំមហានគរភាគ ១ ២ ៣ ខ្ញុំបាទជាអ្នកស្រាវជ្រាវរៀបរៀងចងក្រង ពុំបានបកស្រាយឲ្យស៊ីជម្រៅ ទៅក្នុងគំនិតប្រស្នាបង្កប់ក្នុងមេកាព្យ ព្យញ្ជនៈ ស្រៈ លេខ ទិស ផ្កាយ..... គឺពន្យល់បានត្រួសៗតែប៉ុណ្ណោះ។ បើយើងពុំបានទាញយកមកពិចារណាត្រិះរិះគិតទេនោះ យើងពិតជាយល់ថាវាជារឿងធម្មតា របស់បុរាណបណ្ឌិតជូនតាយើង។ ពួកគាត់បានទុកមរតកដ៏ច្រើន តែបើយើងយកសូរសម្ដីនិយាយនោះមកពិចារណាវែកញែក នៅក្នុងពាក្យសូរស័ព្ទ សញ្ញា យើងនឹងមើលឃើញនូវរឿងផ្សេងមួយទៀត ដែលនឹកគិតស្មានពុំដល់។ ដូចពាក្យសុភាសិតបុរាណខ្មែរមួយបានពោលទុកថា"**សម្ដីជាឯក លេខជាទោ អក្សរជាត្រី**" បើយើងសួរខ្លួនឯងថា ហេតុអ្វីបានជាពាក្យសម្ដីនៅក្នុងលំដាប់លេខ**១** ចំណែកលេខនៅក្នុងលំដាប់លេខ**២** រីឯអក្សរកត់ត្រាបែរជានៅលំដាប់លេខ**៣**ទៅវិញ។ ចម្ងល់នេះយើងត្រូវតែត្រិះរិះរកន័យពិត ដើម្បីស្រាយនូវរាល់បញ្ហា ដែលមានបង្កប់ន័យនៅក្នុងសុភាសិតនេះ ព្រោះអ្វីក៏ដោយដែលកើតមានក្នុងលោក សុទ្ធតែមានហេតុនិងបច្ច័យរបស់វា។ យ៉ាងណាមិញសុភាសិតរបស់ជូនតាយើងក៏ដូច្នោះដែរ ពួកគាត់តាក់តែងឡើងហើយ សុទ្ធតែបង្កប់នូវន័យខ្លឹមសារដ៏មានជម្រៅ ដែលយើងត្រូវត្រិះរិះពិចារណារុករកនៅអត្ថន័យនេះ បើពុំនោះទេយើងបានត្រឹមតែស្ទាបអង្អែល ត្រឹមសំបកខាងក្រៅតែប៉ុណ្ណោះ មិនអាចដឹងន័យខាងក្នុង របស់ពួកគាត់ឡើយ។ សព្វថ្ងៃប្រជាជនខ្មែរភាគច្រើន កំពុងកាន់និងគោរពព្រះពុទ្ធសាសនា តើមានប្រជាជនខ្មែរប៉ុន្មាននាក់ ដែលបានយល់ពីខ្លឹមសាក្នុងសាសនៈបណ្ដាំ ឬពាក្យប្រៀនប្រដៅនេះ? ដែលនៅក្នុងឪវាទទាំងនោះ ព្រះអង្គបានសម្ដែងដោយសង្ខេបថា"**កិរិយាមិនធ្វើនូវអំពើបាបទាំងពួងមួយ កិរិយាបំពេញនូវកុសលឲ្យខ្លួនមួយ កិរិយាធ្វើចិត្តរបស់ខ្លួនឲ្យបានផូរផង់មួយ**" ពាក្យទាំងនេះជាពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ បើបង្រួញសេចក្ដីមកគឺ សីល សមាធិ បញ្ញា ជាលោកិយ នឹងឈានទៅរកសីល សមាធិ បញ្ញា ជាលោកុត្តរៈ ដើម្បីចេញចាក់ពីវដ្ដសង្សារនេះ។ ចំណែកយើងអ្នកកាន់នឹងគោរពភាគច្រើន តែងទៅបួងសួងបន់ស្រន់ឲ្យព្រះសម្មាសម្ពុទ្ធ ឬអាទិទេពផ្សេងៗទៀតមកជួយ តើមានអាទិទេពណាមកជួយយើង ក្រៅពីយើងចេះជួយខ្លួនឯងនោះ? ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា"**សត្វទាំងឡាយមានខ្លួនឯងជាទីពឹង គឺពុំមានអ្នកដ៏ទៃណាជាទីពឹងឡើយ បុគ្គលដែលបានអប់រំខ្លួន(ចិត្ត)បានល្អហើយ នឹងបាននូវទីពឹងដែលគេបានដោយក្រ**"។ តើយើងបានធ្វើទីពឹងឲ្យខ្លួនឯងហើយឬនៅ បើពុំបានធ្វើទីពឹងឲ្យខ្លួនឯងទេ យើងពិតជាធ្វើដំណើរតាមផ្លូវមាតាមហានគរពីអតីតជាពុំខាន ព្រោះពួកគាត់សុខចិត្តតាំងខ្លួនជាម៉ែជាឪ ជាអ្នកគ្រប់គ្រងថែរក្សា

ទឹកដី ដោយពុំបានធ្វើទីពឹងឲ្យខ្លួនឯង ទីបំផុតបានត្រឹមតែរងទុក្ខតែម្នាក់ឯង ក្នុងអបាយភូមិតែប៉ុណ្ណោះ។ ក្នុងសុភាសិតខ្មែរដែល មានសុភាសិតជាច្រើនបានពោល ទាក់ទងជាមួយនឹងពាក្យសម្តីដូចជា៖

- **សំដីសជាតិ មាយាទសពូជ**
- **មនុស្សគេយកសម្តី ដំរីគេយកភ្លុក**
- **រនាបបាក់យករនាបជួស សម្តីពោលហួសមានតែតាមកែឬបង់ប្រាក់**
- **បណ្ឌិតនិយាយពីគំនិត អ្នកប្រាជ្ញនិយាយពីហេតុការណ៍ មនុស្សធម្មតានិយាយពីរឿងផឹកស៊ី**

ដែលខ្ញុំលើកយកមកនេះ គ្រាន់តែចង់ពញ្ញាក់ដាស់ស្មារតីកូននាគ ដែលពុំបានពិចារណានូវកាកគំនិតរបស់បណ្ឌិតដូនតាយើង ដែលពួកគាត់បានខំបន្សល់ទុកនេះ ដើម្បីយកមកពិចារណារាវរកសេចក្តីពិតពីកាកគំនិត ដែលមានបង្កប់ន័យទុកក្នុងមរតកអច្ឆរិយនេះ។

មួយឆ្នាំកន្លងទៅហើយ ដែលខ្ញុំបានស្រាយប្រស្នាមេកាព្យទាំងប្រាំពីរមេ ដែលកើតមានមុនសម័យអង្គរនិងក្នុងសម័យអង្គរ ព្រោះវាជាភស្តុតាងមួយបានប្រាប់បង្ហាញយើងថា ជាមេកាព្យដែលកើតនឹងស្ថិតក្នុងវង្សថ្ម។ ចំណែកឯមេកាព្យ ដែលកើតមានក្រោយសម័យ បោះបង់ចោលក្រុងអង្គរ ឬក្រោយសម័យថ្ម ខ្ញុំបាទពុំបានយកមកបកន័យរបស់វាឡើយ។ ព្រោះតំណនៃភាពអច្ឆរិយ បានដាច់អស់ជាង១០០ឆ្នាំ ដែលពួកបរទេសឈ្លានពាន បានវាយឲ្យខ្មែររត់ចោលក្រុងអង្គរ រហូតដល់ខ្មែរខ្លួនឯង ពុំដឹងថាខ្លួនមានរាជធានីអច្ឆរិយនៅទីនោះផង។ លុះមកដល់សម័យខាងក្រោយ មានស្តេចមួយអង្គព្រះនាមច័ន្ទរាជា បានចេញទៅប្រពាតព្រៃ ជាមួយនឹងជនជាតិព័រទុយហ្គាល់ ហើយបានរុករកឃើញទីក្រុងចាស់ ដែលមានប្រាសាទដ៏ធំស្កឹមស្កៃ បានលាក់កប់ទុកក្នុងព្រៃដ៏ក្រាស់ ទើបភ្ញាក់ដឹងថាខ្លួនជាពូជពង្សថ្ម។

ក្នុងសម័យព្រះបាទអង្គឌួង មានព្រះសង្ឃមួយអង្គ លោកបាននិមន្តមកពីស្រុកសៀម លោកមានព្រះនាមថាប៉ាងឬប៉ាន ព្រះអង្គជាកវីនិពន្ធ នៅក្នុងរាជព្រះបាទអង្គឌួង និងនរោត្តម លោកបានសរសេរនូវអត្ថបទកំណាព្យមួយឡើង គឺរឿងល្បើកអង្គរវត្ត។ យើងគួរពិចារណាថា ក្នុងសម័យក្រោយបោះបង់ចោលក្រុងអង្គរ អ្នកប្រាជ្ញរាជបណ្ឌិតខ្មែរភាគច្រើន តែងតែទៅសិក្សាបួសរៀននៅស្រុក

សៀម ចុះបើគ្រូសៀមគេកុហក យើងមិនត្រូវវង្វេងហើយឬ? ឧទាហរណ៍ដូចជាល្បើកនគរវត្ត(អង្គរវត្ត)នេះ បើអ្នកសរសេរបើកអាថ៌កំបាំងអង្គរខុស ក្មេរជំនាន់ក្រោយនឹងត្រូវសិក្សាខុសបន្តគ្នា តែបើបើកអាថ៌កំបាំងជាតិត្រូវ នោះវាជាភ័ពសំណាងរបស់ជាតិនេះ ដែលបានដឹងពីប្រវត្តិសាវតាពិតរបស់ខ្លួន។

## ពន្យល់ពាក្យ

***ល្បើកអង្គរ = ល + បើក + អង្គរ*** មានន័យថា សាកល្បងបើកអាថ៌កំបាំងអង្គរ ឬអាថ៌កំបាំងថ្មបើបើកត្រូវភាពរុងរឿងនឹងកើតឡើង តែបើបែរជាបើកពន្យល់ខុសវិញ នោះនឹងធ្វើឲ្យអ្នកស្នងមរតកថ្មជំនាន់ក្រោយៗ នឹងភ្លេចនូវសាវតារបស់ខ្លួនទេឬ? ដូចមាននៅក្នុងរឿងល្បើកអង្គរនេះស្រាប់ ព្រះអង្គបានពន្យល់ថា មានទេវតានិងអាទិទេពផ្សេងៗ ចុះមកកសាងប្រាសាទ និងមកជួយរៀបចំនគរនេះឲ្យជាតិក្មេរ ចុះអាទិទេពទាំងអស់នោះមានពេលទំនេរអ្វីម្លេះ ដែលចុះមកកសាងប្រាសាទឲ្យតែប្រទេសក្មេរនោះ? ចំណែកប្រទេសដ៏ទៃជាច្រើនទៀត ដែលនៅជុំវិញយើង និងនៅលើពិភពលោកទាំងមូល ម្ដេចអាទិទេពទាំងនោះ មិនទៅជួយប្រាប់ជួយកសាងឲ្យផង? នៅក្នុងសម័យពុទ្ធកាល ពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែងនូវព្រះធម៌ ព្រះព្រហ្ម ព្រះឥន្ទ្រ ទេវតាម៉ឺនសែនលាន កោដិចក្រវាល បានមកស្ដាប់ព្រះធម៌ ដែលព្រះអង្គបានសម្ដែងប្រោស អាទិទេពទាំងនោះបានស្ដាប់ព្រះធម៌ហើយ ក៏បានសម្រេចមគ្គផល ទៅតាមកម្លាំងបញ្ញារបស់ខ្លួន ហើយក៏ថ្វាយបង្គំលារួចជៀសចេញទៅ។ សម័យនោះមិនបានឃើញ អាទិទេពអង្គណាមួយ មកកសាងប្រាសាទថ្វាយព្រះអង្គឡើយ គឺមានតែឧបាសក ឧបាសិកា ដែលបានដល់នូវព្រះរតនៈត្រៃ ជាទីពឹងទីរលឹកដោយមិនញាប់ញ័រ ស្មើដោយជីវិតតែប៉ុណ្ណោះ ដែលបានស្ម័គ្រកសាង ប្រាសាទ ព្រះវិហារ គន្ធកុដិ......ថ្វាយចំពោះព្រះសង្ឃដែលមានព្រះសម្មាសម្ពុទ្ធជាប្រធាន។ ក្នុងសម័យពុទ្ធកាលនោះដដែល ព្រះសម្មាសម្ពុទ្ធព្រះអង្គពុំបានខ្វល់ខ្វាយ ក្នុងការកសាងវត្តអារាមទុកឡើយ រួមទាំងអគ្គសាវក អគ្គសាវិកា និងសង្ឃសាវកទាំងឡាយលោកពុំបានជាប់ជំពាក់ក្នុង កិច្ចកសាងវត្តអារាមនេះឡើយ ព្រោះភារៈកសាងសេនាសនសង្ឃ គឺជាកិច្ចរបស់គ្រហស្ថ ដែលជាពុទ្ធបរិសទ្ធអ្នកមានសទ្ធាជ្រះថ្លា ជាអ្នកគ្រប់គ្រងផ្ទះ បានលះនូវទ្រព្យដើម្បីការកសាងនេះ ដើម្បីសន្សំនូវកុសលទុកក្នុងសន្ដានចិត្ត ដើម្បីទុកជាឧបនិស្ស័យតទៅខាងមុខ។

ដោយការលើកជាឧទាហរណ៍មកបង្ហាញនេះ ខ្ញុំបាទចង់ឲ្យកូននាគពិចារណាឡើងវិញ តើប្រាសាទថ្ម ដែលកើតបន្តគ្នាក្នុងសម័យនោះ កើតឡើងដោយសារអាទិទេពអ្នកសាង ឬក៏កើតឡើងដោយកម្លាំងកូននាគមានកតញ្ញូ និងកតវេទី? បើយើងមើលរឿងល្បើករង្គរ យើងជឿថាមានអាទិទេពមកកសាង តែបើកូនខ្មែរមើលរឿងភាសា**គ**ដែលមានក្នុងថ្ម បានឆ្លាក់ពន្យល់ប្រាប់ពីដំណើរនៃរឿងទុក្ខវេទនា របស់មាតាបិតាមហានគរ គឺកើតចេញពីទឹកចិត្តកតញ្ញូនិងកតវេទី របស់កូននាគក្នុងសម័យនោះ បានរួមគ្នាកសាងប្រាសាទថ្មទាំងនេះ។ ហើយរឿងដែលមាននៅក្នុងប្រាសាទទាំងនេះ កើតចេញពីមហិទ្ធិឫទ្ធិព្រះមាតានាគ(ចិនហៅថាបីសាចពស់) ដែលលោកលួចចេញពីទីឃុំ មកប្រាប់កូននាគក្នុងកាលនោះ ឲ្យសាងប្រាសាទឆ្លាក់រៀបរាប់ ប្រវត្តិរឿងទុក្ខវេទនារបស់ខ្លួន ទុកក្នុងគុហារប្រាសាទទាំងនោះ។

ការបកស្រាយពន្យល់ឡើងវិញនេះ គ្រាន់តែជាការពញ្ញាក់សតិស្មារតីកូនខ្មែរ ឲ្យចេះពិចារណាឡើងវិញ នូវន័យប្រស្នាកំបាំង ដែលបានលាក់កប់ទុកក្នុងមរតកម៉ែ ដោយពីមុនយើងពុំបានចាប់អារម្មណ៍នោះ។ នៅក្នុងពិធីបុណ្យទានសែនព្រេន និងពិធីផ្សេងៗទៀត ដែលកើតមានក្នុងនគរនេះពុំចេះដាច់ បន្តពីជំនាន់មួយទៅជំនាន់មួយ កាលបើមានអ្នកឆ្ងល់ណាមួយ សួរអំពីកិច្ចទាំងនោះពួកគាត់ឆ្លើយពុំរួច យើងតែងឮគាត់ឆ្លើយថាជា ទំនៀមទម្លាប់ប្រពៃណី ឧទាហរណ៍ការរៀបចំធ្វើបាយសីស្លាធម៌ដូង ពិធីក្រុងពកលី មង្គលការ ....។ល។ ខ្លះឆ្លើយថាជាពិធីក្នុងព្រហ្មញ្ញសាសនា តែព្រហ្មញ្ញនៅឥណ្ឌាពុំស្គាល់បាយសី ដូងស្លាធម៌ ម្លូព័ន្ធ ស្លាពាន់ នឹងពិធីផ្សេងៗទៀត ដែលមាននៅក្នុងស្រុកខ្មែរយើងឡើយ ខ្លះទៀតឆ្លើយដាក់ថាជាទំនៀម ទម្លាប់ប្រពៃណី។ ដូចជាការហែកបិលមហាព្រហ្មក្នុងរដូវចូលឆ្នាំថ្មី យើងពុំបាននឹកឆ្ងល់ថា បើមាតាព្រហ្មបិតាព្រហ្ម ព្រមទាំងប្រាសាទមុខព្រហ្មដែលមាននៅលើទឹកដីនេះទាំងអស់ មានតែសិរសា(ក្បាល) ពុំមានដងខ្លួនយ៉ាងនេះ បើយើងចង់ឲ្យពួកគាត់ជួយការពារ ឬរកសិរីសួស្ដីឲ្យ ដែលក្នុងនាមពួកគាត់ជាមាតាបិតា ឬជាអាទិទេពរបស់យើង តើពួកគាត់ជួយម្ដេចបាន បើគាត់គ្មានដៃគ្មានជើង គ្មានដងខ្លួនយ៉ាងនេះ? ហើយយើងសួរទៀតថា ហេតុអ្វីបានមានរឿងយ៉ាងនេះ អ្នកឆ្លើយច្បាស់ជាឆ្លើយថា វាជារឿងទំនៀមទម្លាប់ប្រពៃណី...។ល។ ដូច្នេះយើងត្រូវសាកល្បងយកពាក្យបីម៉ាត់នេះមក ពិចារណាវែក ញែករកការពិត តើវាមានបង្កប់ន័យអ្វីនូវក្នុងពាក្យទាំងបីម៉ាត់នេះ?

## ពន្យល់ពាក្យ

*ទំនៀម = ទាមសូរដូចទៀម = ធ្វើឲ្យជាប់ ឧ.ឈ្លើងទាម ខ្សែទាម(ទៀម)*

*ទម្លាប់ = ធ្លាប់ .អ្វីដែលធ្វើញយៗវាតែងតែធ្លាប់ៗដដែលៗវាក្លាយជាទម្លាប់*

*ប្រពៃ = ប្រពៃ(ភាសាខ្មែរ) = សាធុ(ភាសាបាលី)*

*ណី = ពាក្យសម្គាល់ឥត្ថីភាវរូបគឺភេទស្ត្រី . រាជនី . ភិក្ខុនី . ពិធីការនី . កម្មការនី...*

*ប្រពៃណី = រឿងប្រពៃរបស់ស្ត្រីឬរបស់រាជនី ដែលជាបឋមក្សត្រ អ្នកបង្កើតពូជខ្មែរ ខ្មែរ*

*ទំនៀមទម្លាប់ប្រពៃណី = ទាមឲ្យជាប់ ក្លាយជាទម្លាប់ រឿងប្រពៃរបស់ស្ត្រី ដែលជាអ្នកកកើតទឹកដីអច្ឆរិយនេះ ដែលប្រព្រឹត្តបន្តគ្នាពុំដាច់ សម្រាប់មនុស្សជំនាន់ក្រោយ ស្រាយនូវប្រស្នានេះ។*

*ពាក្យប្រពៃណី ក្នុងវចនានុក្រមសម្ដេចព្រះសង្ឃរាជជួនណាតមានន័យថា:*

*ទំនៀម; ពូជពង្ស, តំណវង្សត្រកូល : រក្សាបវេណី, ធ្វើបុណ្យទានតាមប្រពៃណី។បវេណីទេវតាដែលគេរាប់អានតាមតំណវង្សត្រកូល តៗមក។ រួមបវេណីរួមសុខទុក្ខរបស់ស្វាមីភរិយា។*

*តើប្រពៃណីវាជាតំណពូជពង្សវង្សត្រកូលអ្នកណា? គឺជាតំណពូជពង្សវង្សត្រកូលព្រះនាងនាគក្រោយមកបានយាក្លាយជាព្រះមាតានាគ (សូមអានអាថ៌កំបាំងបណ្ដាំមាតាមហានគរខ្មែរ ភាគទី១ . ២. ៣)។ ដូចពាក្យរាជធានី គឺមានន័យថា រាជ្យ = ភាវៈជាព្រះរាជា... ធា = ធារស្រូវឬទឹក(សូរធា = ធារ) នី = ភេទស្ត្រី ដូច្នេះពាក្យរាជធានី គឺអ្នកគ្រប់គ្រងទីក្រុងទឹកដីគឺស្ត្រី ព្រោះម្ដាយតំណាងធាតុទឹក ១២ រាជធានីភ្នំពេញ គឺម៉ែពេញ ឬយាយពេញជាអ្នកបង្កើតទីក្រុងនេះ។*

*មេកាព្យខ្មែរយើងដែលមានមុនសម័យអង្គរ និងក្នុងសម័យអង្គរ តើមេកាព្យទាំងនេះមានបង្កប់នូវប្រស្នាអ្វីខ្លះ? មេកាព្យទាំងប្រាំពីរមេនេះ គឺមានមេបទ:*

1. *បទមេបួន(៤)*
2. *បទបឋ្យាវត្ត*
3. *បទកាកតិ*
4. *ព្រហ្មគីតិ ឬព្រហ្មគិត*
5. *បទពំនោល*
6. *បទបន្ទោកាក*

7. បទកុជង្គលីលា

ចំណែកឯមេបទដែលកើតមានក្រោយសម័យអង្គរ ខ្ញុំបាទពុំបានយកមកវែកញែកបកស្រាយឡើយ ព្រោះមេបទទាំងនោះកើតឡើង ក្នុងសម័យដាច់តំណាថ្មជាង១០០ឆ្នាំ ដូច្នេះអត្ថន័យកំបាំងប្រស្នាក្នុងមរតកអច្ឆរិយ យើងមិនអាចរកឲ្យឃើញឡើយ។ ម្យ៉ាងទៀតអ្នកប្រាជ្ញកវីនិពន្ធ ក្រោយសម័យ អង្គរ សុទ្ធតែត្រូវបានបរទេសឈ្លានពាន កៀរ ប្រមូល បញ្ជូនឲ្យទៅរៀនបែបបទមនោគម ពីស្រុកគេ(សៀម..) ដូច្នេះចំណេះដឹងខាងក្រោយ ត្រូវវិប្រែពណ៌ថ្មី លែងមានភាពបរិសុទ្ធ ដូចមុនទៀតហើយ។

# I.អំពីកំណាព្យនិងអត្ថន័យបង្កប់ក្នុងមេកាព្យទាំងប្រាំពីរមេ

ពន្យល់ពាក្យដែលមានសូរសម្លេងដូចកាព្យ:

**កាប** ( ន. ) ឈ្មោះសម្រាប់រឹតគាប : កាបរទេះ(ដកចេញពីវចនានុក្រមសម្ដេច)

**កាបៗ** ( ឧ. ) សូរសម្រែកសត្វទាស្រែកយំផ្លូនៗបន្តគ្នា: ទាស្រែកព្កាបៗ។(ដកចេញពីវចនានុក្រមសម្ដេច)

**កាប** ( ន. ) ខ្សែ.កាប

**កាព្យ** កាបបា.; សំ. ( ន. ) (កាវ្យ) របៀបពាក្យចួនមានឃ្លោងឃ្លា (កំណាព្យ) : ពាក្យកាព្យ, តែងកាព្យ.... កម្រងពាក្យសម្ដីដែលមានពាក្យចាប់ចុងជួន ផ្ទួនៗគ្នារណ្ដំណែង ណងគួឲ្យចង់ ស្ដាប់។ (ដកចេញពីវចនានុក្រមសម្ដេច)

**<u>១.បទមេបួន</u>**

ហេតុអ្វីបានជាដូនតាដាក់ឈ្មោះកាព្យនេះថាមេបួន? ដោយហេតុតែសម័យខាងក្រោយកូននាគលែងស្គាល់គាត់ គឺស្គាល់ត្រឹមតែគ្រាប់បាយ(ហូបបាយកុំឲ្យកំពុបត្រូវដឹងគុណព្រះមេ សូមមើលការ បកស្រាយអាថ៌កំបាំងភាគមុន)។ បួនតំណាងឲ្យមុខព្រហ្មដែលមាននៅលើថ្ម មុខព្រហ្មក្នុងមហាសង្ក្រាន្តឆ្នាំថ្មី និងបួនតំណាងឲ្យព្រហ្មវិហារធម៌របស់មេនាគទាំងបី ដែលមកគ្រប់គ្រងកូននាគគ្រប់ជំនាន់។ មេនាគទី១គឺមាតាបិតាបង្កើតរបស់កូនប្រុសស្រី មេនាគទី២គឺមាតាបិតាបង្កើតមហានគរនេះ មេនាគទី៣គឺព្រះអរហន្តសម្មាសម្ពុទ្ធ ដែលមេនាគទាំងបីនេះ បានគ្រប់គ្រងថែរក្សាកូនក្មេរទាំងប្រុសស្រី គ្រប់ៗកាលទាំងបី។ មេបួនមុខបួនមានតែសិរសា(ក្បាល) បាត់ខ្លួនព្រោះហេតុតែមានមាន: អំនួត .លោភ: .ទោស:. មោហ: ប្រកាន់មាំទីបំផុតបានត្រឹមក្លាយខ្លួនជាប្រែត ជាព្រាយបិសាចតែប៉ុណ្ណោះ(ក្នុងឯកសារចិនជាវតាក្វាន់)។ ក្នុងមួយឆ្នាំសង្ក្រាន្តវិលជុំម្ដង មានកូនរលឹកឃើញឧបការគុណ៧នាក់ ហើយកូនទាំង៧នាក់នេះ សង្ក្រាន្តវិលត្រូវថ្ងៃរបស់អ្នកណា អ្នកនោះត្រូវមកហែហមព្រះសិរសាម្ដាយឪពុក ចំណែកឯកូនដែលសង្ក្រាន្តវិលមិនត្រូវ រវល់ប្រចាំគ្នាពុំបានមកជួបជុំរួមគ្នាឡើយ។

កូនកបិលមហាព្រហ្ម ពិតប្រាកដគឺមាន១២នាក់ឯណោះ តែកូនអាចមកហែហមរំលឹកគុណម៉ែឪមានតែ៧នាក់ ហើយប្រចាំគ្នាទៀត។ រឿងព្រេងទាក់ទងនឹងកបិលមហាព្រហ្មនេះ ក្នុងគម្ពីរព្រហ្មញ្ញក៏គ្មាន ហើយក្នុងគម្ពីរព្រះត្រៃបិដកក៏គ្មាន តើរឿងនេះកើតចេញពីណា? រឿងនេះបានបដិសន្ធិចេញពីថ្ម គឺថ្មកើតមានមុន រឿងប្រសូតតាមក្រោយ ហើយសង្ក្រាន្តពីសម័យមុន ត្រូវចូលក្នុងខែមិគសិរ ដែលជាខែទីមួយក្នុងច័ន្ទគតិ។ ដោយសាខែនោះប្រជាកសិករ នៅជាប់រវល់ការងារ ច្រូតកាត់ប្រមូលផលស្រូវ ដូច្នេះត្រូវផ្លាស់សង្ក្រាន្ត ឬចូលឆ្នាំថ្មីត្រូវប្តូរមកខែចេត្រវិញ។ បើយើងពិចារណាមកលើសង្ក្រាន្តទើបយើងដឹងថា ទេវតាផ្លាស់ឆ្នាំចាស់ចូលឆ្នាំថ្មី គឺពុំមែនអាទិទេព ជាអ្នកកំណត់សម្រេចឡើយ គឺដូនតាខ្មែរជាអ្នកកំណត់។ ត្រង់នេះវាជាប្រស្នា ដែលយើងត្រូវតែរែកញែក រកចម្លើយឲ្យឃើញនូវការពិត គឺមិនចេះតែជឿតៗគ្នា ដោយពុំបានពិចារណារាវរក ហេតុផលនោះឡើយ។ ចុះកំណាព្យមេបួនមានន័យអ្វី ទាក់ទងទៅនឹងឫសកែវរបស់អ្នកនគរនេះ? គឺវាមានទាក់ទង នឹងអាថ៌ប្រស្នាប្រវត្តិរឿងរាជនីពីអតីតនោះ ដែលឫសកែវម្ចាស់ក្សត្រីនេះ បានត្រូវអតីតកាលរួមផ្សំ និងបរទេសចូលមកកប់លាក់ធ្វើឲ្យវង្សត្រកូលនាគ ត្រូវបាត់ឈ្មោះចេញពីសន្តានកូនខ្មែរ ហើយកប់ទៅក្នុងដីនៃអតីតកាលធ្វើឲ្យកូននាគសម័យក្រោយ ពុំស្គាល់គាត់ឡើយ។ យើងមើលអ្នករាំរបាំអប្សរាឬអច្ឆរា ដែលបានឡើងសម្តែងនៅលើឆាកសព្វថ្ងៃ ក្បាច់រាំចុងក្រោយនៃរបាំនេះ ពួកគាត់បានទាញយកមែកផ្កាស្លឹកមាសចេញពីចង្កេះ មកបង្ហួតបង្ហាញប្រាប់គ្រប់ទស្សនិកជន។ តើពួកគាត់អ្នករាំនិងអ្នកមើល មានដឹងថា ដើមឫសកែវនៃស្លឹក ផ្កាមាសនេះនៅឯណា? ហេតុអ្វីបានជាមានតែមែកស្លឹកផ្កា? ចម្លើយគឺឆ្លើយដាក់ទៅលើ ទំនៀមទម្លាប់ប្រពៃណីដែលមានក្នុងថ្ម អ្វីដែលខ្ញុំបាទបានឆ្ងល់សួរនិងបកស្រាយនេះ គឺខ្ញុំចង់រកយុត្តិធម៌ឲ្យឫសកែវ ដែលលោកសុខចិត្តរងទុក្ខតែម្នាក់ឯង នៅក្នុងអបាយភូមិ ព្រោះហេតុតែមរតកអច្ឆរិយនេះ ដើម្បីសម្រាប់ទុកជាកេរ ឲ្យកូនខ្មែរជំនាន់ក្រោយបានសេពសោយ។ ម៉ែឪសព្វថ្ងៃទុកដូចជា ឫសកែវនៃដើមឈើ ខ្លួនសុខចិត្តធ្វើពលិកម្ម ចាក់រុលចូលទៅក្នុងដី ដើម្បីជញ្ជក់ប្រមូលយកនូវជីវជាតិ មិនថាមូត្រលាមកឬគំរង់ដ៏គួឲ្យខ្ពើមដែលកប់នៅក្នុងដី.... ហេតុតែដើម្បីយកមកចិញ្ចឹមដើម មែក ស្លឹក ផ្លែ ផ្កា និងចិញ្ចឹមខ្លួន រួមទាំងញាតិដែលនៅជុំវិញ។ ទីបំផុតអ្នកដែលត្រូវគេសសើរ មិនមែនសសើរឫសកែវ ឬដើមឡើយ គេស្ញើចសសើរតែស្លឹកផ្លែផ្កាតែប៉ុណ្ណោះ។ ចំណែកឯខ្លួនជាឫសកែវ បានត្រឹមតែកប់ លាក់បំបាំងខ្លួន និងប្រវត្តិខ្លួននៅក្នុងដី។ តើគួរដែរឬទេ ដែលមាតាបិតាហេតុតែកូន សុខចិត្តប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង ដោយពុំទូន្មានចិត្តឲ្យមានសីល សមាធិនិងបញ្ញា ហើយចុងបញ្ចប់បានត្រឹមសោយទុក្ខម្នាក់ឯង នៅក្នុងអបាយភូមិ ដោយពុំមានអ្នកខាងក្រោយណាម្នាក់ដឹង។ ដូចជាមាតាបិតា ញាតិវង្សរាមហានគរ ជាភស្តុតាងស្រាប់ ដែលខ្ញុំបាទបានយកមកបើកបង្ហាញនៅក្នុងភាគ១.២.៣នោះ ក្នុងនាមខ្លួនជាឫសកែវ បរទេសបានកាប់ក្តៀង លុបដីលុបដានសន្ធប់ពីលើយ៉ាងជិត មិនឲ្យកូននាគខាងក្រោយដឹង តើគួរឲ្យតក់ស្លុតសង្វេគប៉ុណ្ណា ដែលខ្លួនបាន

*ត្រឹមតែស្រែកដង្ហោយ ហៅអ្នកជំនាន់ក្រោយរបស់ខ្លួនតែម្នាក់ឯងពីក្នុងឃុំ តើមានកូននាគប៉ុន្មាននាក់បានដឹងហើយទទួលស្គាល់នូវការពិតនេះ? បទមេបួននេះមានបួនព្យាង្គ ហើយមានបួនរបះ ដែលអត្ថន័យបង្កប់ក្នុងឈ្មោះបទមេបួន ដូចខ្ញុំបានបកស្រាយពន្យល់ ដោយសង្ខេបខាងលើ(សូមមើលអត្ថបទកំណាព្យមេបួនខាងក្រោម)។*

## ស្រណោះមេបួន( បទមេបួន )

១.នឹកឃើញអាឡោះ ស្រណោះមេបួន ឈ្មោះកាព្យបាត់ខ្លួន នៅសល់តែមេៗ
២.បាត់នាមត្រកូល ពូជពង្សម្ចាស់កេរ តើឈ្មោះព្រះមេ លិចបាត់ទៅណាៗ
៣.កាបកាបកាបកាព្យ កាបញើរកបា កាបខ្សែយុត្តា កាបគាបរទេះៗ
៤.កាព្យពាក្យចុងជួន កាព្យជាចំណោះ ឃ្លាកាព្យមិនធ្វេស ប្រហែសបាត់ឃ្លោងៗ
៥.ឱ្យឈ្មោះកាព្យអើយ នឹកឡើងរលោង កាព្យសល់តែគ្រោង មេបួនជាឃ្លាៗ
៦.ជាបទកំណាព្យ រណ្តំជាប់គ្នា ហេតុតែវេរា ម្ចាស់បទបាត់ឈ្មោះៗ
៧.លិចបាត់ទៅក្រោម ស្រោបរុំដោយគ្រោះ កាព្យមិនមានឈ្មោះ មានត្រឹមមេបួនៗ
៨.មេបួនជាអ្វី មេតាងមាសសួន ម៉ែឪមុខបួន តែកូនពុំស្គាល់ៗ
៩.ព្រោះហេតុអំនួត ហ៊ានលោតហ៊ានឆ្មាល់ បញ្ចប់ត្រូវខ័ល មានមុខបាត់ខ្លួនៗ
១០.តើកូនដឹងទេ ម៉ែទុក្ខផ្ទួនៗ ទុក្ខព្រោះតាំងខ្លួន ជាស្តូរតាំងម៉ែៗ
១១.ផ្តេមហើយល្វឹងស្វិត បាបកម្មព្រោះតែ តាំងខ្លួនជាម៉ែ ធ្លាក់ក្នុងអបាយៗ
១២.ជាព្រាយជាប្រែត កម្មតាំងជាម្តាយ នឹកឡើងសែនស្តាយ ត្រូវកូនបំភ្លេចៗ
១៣.នៅសល់តែមេ ពាក្យបួនរំលេច កុំឲ្យតែភ្លេច ខួបកិច្ចនឹកមេៗ
១៤.អ្នកក្រោយចូរចាំ រិះគិតគ្នាន់គ្នេ កុំស្គាល់ព្រះមេ នៅត្រឹមតែបាយៗ
១៥.បញ្ញាភ្លឺឡើង ខំដោះខំស្រាយ ខំត្រួសខំត្រាយ ទើបឃើញការពិតៗ
១៦.ពូជវង្សសម្មា ពូជត្រិះរិះគិត ពូជវង្សបណ្ឌិត ពូជចេញចាកទុក្ខៗ
១៧.បើកូនយល់ហើយ ទើបមេបានសុខ ចរចាកចោលគុក សោយផលសួគ៌ាៗ
១៨.ចម្លើយឈ្មោះមេ តាមវង្សព្រហ្មា ពង្សព្រះចន្ទ្រា ទិព្វសេដាច័ន្ទៗ
១៩.ជាមេអ្នកសាង ពូជសោមព្រះឥន្ទ ទាវវង្សអ្នកកាន់ មរតកស្ពុកាៗ
២០.សង្ខេបដោយខ្លី ស្រដីតាមការ ស្វែងរកនាមា កាព្យបួនប្រពៃៗ
២១.បើសមមិនសម សូមជួយអត្ថ័យ មេបួនមានន័យ បង្កប់ប្រស្នាៗ៚

**ថ្ងៃច័ន្ទ ៦កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី៧ មិថុនា គ.ស២០១១**

**រៀបរៀងដោយឧបាសក គៀត ចាន់ផុន**

**២.បទបថ្យាវត្ត**

ពាក្យថាបទបថ្យាវត្តនេះ នៅក្នុងវចនានុក្រមសម្ដេច ព្រះអង្គពុំបានពន្យល់ន័យ នៃពាក្យនេះឡើយ ខ្ញុំបាទសូមសាកល្បង ពន្យល់អត្ថន័យដែលបានបង្កប់នៅក្នុងពាក្យនេះ។

**បថ្យាវត្ត** បើយើងបំបែកជាពាក្យរាយ គឺមានតួអក្សរ(**ប . ថ . យា . វត្ត**) មានន័យបង្កប់ក្នុងពាក្យនេះថា ការប្រព្រឹត្តបដិបត្តិ បរទៅមុខផង បរថយក្រោយផង គឺស្វែងយល់អតីតកាលកន្លងទៅ បដិបត្តិក្នុងបច្ចុប្បន្ន និងទទួលផលផ្លែផ្កាក្នុងពេលអនាគត។ ពាក្យ"**បរ**"មានសូរដូចព្យញ្ជនៈ"**ប**"នេះចំពោះសូរស័ព្ទនិយាយ។ ចំណែក"**ថ្យា**"បើយកជើង"**យ**"ចេញពី"**ថ**"នឹងឃើញពាក្យ**ថយា = ថយយា** គឺមានន័យថា យាទៅមុខផងយាថយក្រោយផង អស់កាលជ័យូរយា។ វត្តគឺការប្រព្រឹត្ត, សេចក្ដីប្រតិបត្តិ,,កិច្ចការដែលគួរធ្វើ; នាទី; ការកាន់សីលធម៌; សេចក្ដីគោរព; ទំនៀម, សណ្ដាប់ធ្នាប់ : មនុស្សមានវត្តល្អមនុស្សមានសេចក្ដីប្រតិបត្តិល្អ; សិស្សធ្វើវត្តឬយកវត្តគ្រូ សិស្សធ្វើសេចក្ដីគោរពចំពោះគ្រូ។ សរុបន័យរបស់ឈ្មោះមេកាព្យនេះ គឺឈ្វេងយល់ពីន័យ ក្នុងអតីតកាលបច្ចុប្បន្ននិងអនាគត បើពុំប្រតិបត្តិគ្រប់កាលទាំងបីទេ គឺពុំអាចដឹងអាថ៌កំបាំងរបស់មេកាព្យ ឬពុំដឹងពីម្ចាស់គំនិត ដែលបង្កើតឈ្មោះមេកាព្យនេះ។

បទបថ្យាវត្តនេះ ក្នុង១របះមាន៤ឃ្លា ក្នុងមួយឃ្លាមាន៨ព្យាង្គ តាមការស្រាវជ្រាវ ដោយភ្ជាប់ទៅនឹងអាថ៌កំបាំងមាតាមហានគរ គាត់ចង់ប្រាប់យើងថា កាលនៅជាបទ**មេបួន** គាត់មានមុខតែបួនប៉ុណ្ណោះ(ព្រហ្មមុខបួន)។ ពេលវិវឌ្ឍន៍មកដល់បទ**បថ្យាវត្ត** គឺមានពាក្យ៨ ព្រហ្មត្រូវមានមុខប្រាំបី គឺមុខបួនត្រួតលើមុខបួន(សូមមើលរូបព្រហ្មក្របភាគ២)នេះជានិមិត្តរូប។ អត្ថន័យមុខព្រហ្មទីមួយ តំណាងឲ្យមាតាបិតាបង្កើត ដែលមានព្រហ្មវិហារធម៌ទៅលើកូនប្រុសស្រី ផ្សាយទៅមិនចេះដាច់ មិនថាពេលយប់ឬពេលថ្ងៃក្រឬមាន ឈឺឬជា....។ល។ អត្ថន័យព្រហ្មត្រួតទីពីរ តំណាងឲ្យអ្នកអភិបាលដឹកនាំនគរ ដែលត្រូវតែមានព្រហ្មវិហារធម៌ ផ្សាយទៅលើប្រជារាស្ត្រប្រុសស្រី ក្មេងចាស់ គ្រប់ស្រទាប់វណ្ណៈ គឺគ្រប់គ្រងថែរក្សាជនជាតិខ្លួន ទុកដូចជាកូនបង្កើត។ ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានពោលសុភាសិតទុកថា **ពេលណារាស្ត្ររបស់ខ្ញុំឈឺ គឺខ្លួនខ្ញុំក៏ឈឺ ពេះដូចរបស់ស្ដេចនិងរាស្ត្រផ្សាភ្ជាប់គ្នា ភាពឈឺចាប់របស់រាស្ត្រ វាឈឺចាប់ជាងអាពាធរបស់ខ្ញុំទៅទៀត**។ អ្នកដឹកនាំដែលមានព្រហ្មត្រួតលើព្រហ្ម ទើបនគរបានសន្តិភាព ប្រជារាស្ត្ររស់នៅមានសេចក្ដីសុខក្សេម ពុំបានរងទុក្ខដោយការបៀតបៀន របស់អ្នកអភិបាលរក្សា ព្រោះអ្នកដឹកនាំគ្រប់គ្រងថែរក្សា ជាព្រហ្មរបស់ខ្លួន ដោយអ្នកដឹងនាំនោះ ទ្រទ្រង់នូវទសពិធរាជធម៌(ទសពិធរាជធម៌នោះគឺ **១-ទាន:** ការធ្វើអំណោយ; **២-សីល:** ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល៨ តាមកាល; **៣-បរិច្ចាគ:** ការចំណាយព្រះរាជទ្រព្យ ទំនុកបម្រុងប្រទេសជាតិ; **៤-អាជ្ជវ:** មានសេចក្ដីទៀងត្រង់; **៥-មទ្ទវ:** មានសេចក្ដីទន់ភ្លន់ស្លូតបូតសុភាពរាបសា; **៦-តប:** ការកាន់ឧបោសថសីលតាមកាលកំណត់ម្ដងៗ (ម. ព. តបៈ ឬ តបះ ផង); **៧-អក្កោធន:** មិនធ្វើឲ្យ

*អ្នកដទៃក្ដៅក្រហាយ;* ***៨-អវិហឹសា*** *មិនបៀតបៀនអ្នកដទៃ;* ***៩-ខន្តិ*** *មានសេចក្ដីអត់ធន់;* ***១0-អវិរោធន:*** *មិនបំពានលើធម៌លើច្បាប់ ។)។*

*អត្ថន័យដែលខ្ញុំបាទបានបកស្រាយ ដោយសង្ខេបក្នុងន័យរបស់ឈ្មោះមេកាព្យទី២នេះ ន័យបង្កប់នៅក្នុងមេបទ ដូនតាមហានគរលោកចង់ឲ្យយើងឈ្វេងយល់ រឿងក្នុងអតីតបច្ចុប្បន្ននិងអនាគត របស់ពួកគាត់។ សូមមើលអត្ថបទកំណាព្យខាងក្រោម:*

## <u>ស្រណោះមេបុណ្យខាងលិច</u> (បទបថ្យាវត្ត)

១.មេបុណ្យខាងកើតមេបុណ្យខាងលិច     កាព្យលើករំលេចតាមកិច្ច[១]ថ្យាវត្ត
មេប្អូនផ្អូនពីរនាំឲ្យវិវឌ្ឍន៍     កើតបថ្យាវត្តបានពាក្យប្រាំបីៗ
២.បទបថ្យាវត្តប្រាប់បេះដូងស្រី     រូបរាងកប់ន័យក្សត្រីជាមេ
បង្កើតទ័ក្រព្រហ្មត្រួតផ្ដុំឡើងទ្វេរ     ព្រហ្មមួយជាម៉ែព្រហ្មមួយជាក្សត្រៗ
៣.ដំណើរនៃព្រហ្មអណ្ដែតរសាត់     លិចចុះកប់បាត់ស្ងប់ស្ងាត់ដំណឹង
[២]ទក់ក្លាយជាថ្មអ្នក**ភ**បាត់ដឹង     **ភ**គាំងស្ញៀមឈឹងគ្មានចេញវាចាៗ
៤.[៣]ព្រហ្មត្រួតរំពឹងអ្នក**ភ**វាសនា     ពេលណាសិលាចរចារចេញមក
មេបុណ្យខាងលិចជាម្លប់ឈប់ជ្រក     ខ្ញីកែវពន្លកអ្នក[៤]ដេកដល់ណាៗ
៥.ឬក្រពើលេបឲ្យក្ស័យមរណា     មិនឃើញជីវាវាចាស្រដី
ឬក្រពើដេញត្របាក់ពិសី     កោះមេបុណ្យជ័យរាងក្បាលក្រពើៗ
៦.សំណាកគាស់បានរូបរាងស្ទាក់ស្ទើរ     មានតែខាងលើនៅទើខាងជើង
[៥]បរទេសរុះរើគាស់កាយរំលើង     ចិត្តថ្មើងទំនើងអាងខ្លួនអ្នកដឹកៗ
៧.មេបុណ្យខាងលិចនៅលិចក្នុងទឹក     ទំនាយរំលឹកឲ្យនឹកតគ្នា
កម្មពីអតីបន្តវេរា     រងទុក្ខវេទនាកប់ក្នុងព្រៃមនុស្សៗ
៨.ទំនាយសុក្រសៅរ៍ចង្អុលគំនូស     ព្រៃហោមពាន្តនោះលាក់សត្វរាជសីហ៍
អាណិតអាសូរដល់ពូជអ្នកថ្លៃ     ទម្រង់ចរណៃត្រឹមតែព្មៗ
៩.នេះជាស្រមោលចំណាំងពន្លឺ     ឈ្មោះអ្នកធ្លាប់ឮចាស់ៗនិយាយ
មានបុណ្យខាងលិចលេចក្នុងទំនាយ     សូរស័ព្ទបរិយាយតគ្នាមកៗ
១០.ឬកែវថ្លើមថ្លៃគ្មានម្លប់ឈប់ជ្រក     ទើបកែវពន្លកមិនមកហាស្ដី
ឬនៅបន្ទំសន្សំបារមី     គុណធម៌ប្រពៃព្រះពោធិសត្វៗ
១១.ឬកម្មវេរាអតីមកកាត់     ឲ្យលិចចុះបាត់កប់ស្ងាត់ក្នុងព្រៃ

ប្បាត់ដឹងបាត់ដាន⁶ពូជពង្សធនជ័យ អ្នកប្រាជ្ញឈ្លាសវៃដោះប្រស្នាចិនៗ
១២.ស្រណោះមេបុណ្យសូមស្លេះទុកសិន ពូជពង្សស្បៀកក្បិនស្លេះសិនប៉ុណ្ណោះ
បញ្ចប់ការគិតឈ្វេងយល់វិះត្រិះ ទុកឲ្យប្រាជ្ញចេះលោកតប្រស្នាៗ៕

១.បទបថ្យាវត្ត ២.ថ្នក់ ៣.ព្រហ្មមុខ៤ ៤.រូបព្រះវិស្ណុដេក ៥.បរទេសធ្លាប់ធ្វើអាណានិគមពីមុន ៦.ពូជជ័យវរ្ម័ន

ថ្ងៃសុក្រ ៩កើត ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃ១០ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ផុន**

## ៣.បទកាកគតិ

*តើពាក្យកាកគតិមានន័យដូចម្ដេច?*

## ពន្យល់ពាក្យ

**កាក** (ន.) *អ្វីៗដែលសោះ; ដែលអស់រសជាតិដោយច្របាច់ឬដោយទំពា, ដោយស្ងោរជាដើម : កាកអំពៅ, កាកដូង។សម្លដែលស្រង់យកតែសាច់និងបន្លែមក ឬដួសយកតែទឹកចេញ ក៏ហៅថាកាកដែរ : កាកសម្ល។ កាកសំបុត្រ គឺសំបុត្រដែលគេលែងត្រូវការ។ កាកមនុស្ស គឺមនុស្សដែលប្រើធ្វើការអ្វីមិនកើត....។(ដកចេញពីវចនានុក្រមសម្ដេច)*

**គតិ**បា. សំ. (ន.) *ការទៅ, ការដើរទៅ, ដំណើរ; ផ្លូវគន្លង; ទីកើតផ្សេងៗ; និស្ស័យ; អធ្យាស្រ័យ; ប្រាជ្ញាញាណ; ទីនៅ; បរិសុទ្ធ។(ដកចេញពីវចនានុក្រមសម្ដេច)*

**កាកគតិ**កាក-គៈ-តិបា. (ន.) *ឈ្មោះបទកាព្យពាក្យ៤ (បទដំណើរក្អែកលោត) : នេះគឺច្បាប់ក្រម ប្រសើរឧត្ដមទូន្មានអ្នកផង ប្រើឱនលំទោនកុំបីមានឆ្គង ប្រាជ្ញាបុណ្យផងកើតដោយប្រណិប័តន៍..។ (ដកចេញពីក្នុងវចនានុក្រមសម្ដេច)*

**កាក + គតិ =** *សំណល់គំនិតដែលដូនតា បានបន្សល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយ តែវាបានអស់រសជាតិ នឹងទឹកដមពិតរបស់វាទៅហើយ ភាពរុងរឿងរបស់ពួកគាត់ វាគ្រាន់តែជាស្រមោលនៃអតីតកាល របស់កូនខ្មែរ ដែលកំពុងរស់នៅបច្ចុប្បន្ននេះតែប៉ុណ្ណោះ ព្រោះហេតុអ្វី? ការដាច់តំណថ្មអស់ជាង១០០ឆ្នាំ បានធ្វើឲ្យកាកគំនិតថ្ម ធ្វើដំណើរតមកខាងក្រោយ តាមគន្លងផ្លូវដែលត្រូវបានបរទេសលុបដាន សារដាន លក់ដាន(មើលក្នុងពិធីមង្គលការក្នុងភាគ២)។ កូននាគជំនាន់ខាងក្រោយលែងយល់នូវខ្លឹមសារពិត អត្ថន័យពិត រឿងរ៉ាវពិតបានប្រែក្លាយទៅជារឿងសាសនា រឿងអាទិទេពផុតពីបណ្ដាំពិតរបស់ដូនតាមហានគរ ដែលលោកបានយកប្រវត្តិរឿងពិតរបស់ខ្លួន ទៅសរសេរជាភាសាគ ទុកនៅលើថ្មប្រាសាទរាប់ពាន់ ទុកក្នុងទំនៀមទម្លាប់ប្រពៃណី..... ដែលរសជាតិពិតរបស់វាបានបាត់រសអស់ទៅហើយ គឺនៅសល់តែកាកគំនិតតែប៉ុណ្ណោះ។ កាកគំនិតដែលសល់ កំពុងតែឈានទៅរកភាពបាត់បង់ជាបណ្ដើរៗ ដោយកាកគំនិតថ្មីរបស់បរទេស(បច្ចេកវិទ្យាឬមនោគមវិទ្យា*

សម័យថ្មី) កំពុងតែលុកលុយហូរចូលមក ក្នុងនគរនេះដោយគំហុក ឧទាហរណ៍ពីដើមកូនក្មេងខ្មែរ ចេះលេងចាក់ទឹកដូង បាយខុំ វាយហ៊ីង និងល្បែងប្រជាប្រិយផ្សេងៗទៀតជាច្រើន ដែលល្បែងទាំងនោះ បានបង្កប់នូវរឿងដូចត់របស់ពួកគាត់ តើសព្វថ្ងៃមានកូនក្មេងខ្មែរប៉ុន្មាននាក់ ដែលចេះលេងល្បែងទាំងនោះ? របស់ថ្មីនេះ ពួកគេបានចាប់យកកាកសំណាលគំនិតបរទេស ដែលកំពុងបង្ហូរចូលមកក្នុងប្រទេសនេះ គឺល្បែងបច្ចេកវិទ្យាថ្មី លេងហ្គេម....។ល។

អត្ថន័យក្នុងឈ្មោះមេបទកាកគតិនេះ ពុំមែនមានន័យថា ដំណើរក្អែកលោតតែម្យ៉ាងប៉ុណ្ណោះទេ គឺមានបង្កប់នូវកាកគំនិតរបស់ដូនតា ដែលជាសំណល់អច្ឆរិយៈ សព្វថ្ងៃនេះពិភពលោកគេកំពុងស្ញើចសសើរ នៅកាកសំណល់គំនិតទាំងនេះ។ ពិសេសពួកអ្នកស្រាវជ្រាវ រុករកអាថ៌កំបាំងប្រាសាទបុរាណ(discovery) គេឆ្ងល់ថាមនុស្សរាប់ពាន់ឆ្នាំមុន ធ្វើសំណង់ប្រាសាទនៅលើដី តែប្លង់ប្រាសាទទាំងនោះ បានឆ្លុះជាមួយនឹងផ្កាយនៅលើមេឃ ចម្លើយធ្វើឲ្យពួកគេមិនអាចបកស្រាយបានឡើយ គឺមានតែពូជនាគតែមួយគត់ ដែលអាចយល់ប្រស្នានេះបាន។ ដូចជារឿងព្រះអាទិត្យមួយដួង អាចបង្កើតភាពអច្ឆរិយនៅលើពិភពលោក ក្នុងថ្ងៃតែមួយ គឺទី២១ ខែមីនា(ផ្កាយរូបសត្វត្រី = ស្ត្រី) និងថ្ងៃទី២១ ខែកញ្ញា(ផ្កាយរូបស្ត្រីក្រមុំ)។ ព្រះអាទិត្យមួយដួងក្នុងថ្ងៃតែមួយនេះ ទី១រះចំកណ្ដាលកំពូលប្រាសាទអង្គរតូច ទី២រះចំកំពូលកណ្ដាលប្រាសាទពីរាមីត នៅប្រទេសអេហ្ស៊ីប ទី៣រះបង្កើតស្រមោលខ្លួននាគ នៅប្រាសាទម៉ាយ៉ាប្រទេសម៉ិចស៊ិក និងទី៤រះចំកណ្ដាលថ្ម លើកបន្ទុបជារាងខ្លោងទ្វារ នៅប្រទេសពែរូ....។ ហេតុអ្វីបានជាមានភាពអស្ចារ្យអ្វីម្លេះ ដែលសំណង់ប្រាសាទថ្មក្នុងប្រទេសទាំងនេះ បានឆ្លុះទៅនឹងព្រះអាទិត្យ តែមួយដួងក្នុងថ្ងៃតែមួយ តើអ្នកប្រាជ្ញណាអាចរកចម្លើយនេះឃើញ? គឺមានតែធនជ័យតែម្នាក់គត់ ដែលអាចយល់ប្រស្នានេះបាន ព្រោះក្នុងរឿងគាត់បានប្រាប់យើងថា ពេលដែលអ្នកប្រាជ្ញចិន មកភ្នាល់យកនគរខ្មែរជាលើកទី២ ភាសារបស់គេគឺ ចិនលើកដៃចង្អុលទៅលើមេឃ ធនជ័យលើកដៃចង្អុលទៅរកព្រះអាទិត្យ ចិនចង្អុលទៅក្រៅលាបាតដៃ ធនជ័យលើកម្រាមប្រាំបញ្ឈរឡើងទៅលើ ចិនចង្អុលចុះក្រោម ធនជ័យចង្អុលមកខ្លួនឯង(ចង់ដឹងពិស្ដាសូមមើលរឿងធនជ័យ)។ ដែលខ្ញុំបាទចង់ប្រាប់កូននាគឲ្យដឹងនោះ គឺដូនតានាគលោកបានដឹង ពីភាពអច្ឆរិយនេះ តាំងពីរាប់ពាន់ឆ្នាំមុនម្លេះ ព្រោះធនជ័យចង្អុលទៅព្រះអាទិត្យមានន័យថា ព្រះអាទិត្យបំភ្លឺលោកនេះទាំងមូល ហើយក្នុងថ្ងៃដែលអ្នកប្រាជ្ញធនជ័យចង្អុលនោះ បានបកស្រាយបំភ្លឺនូវភាពអច្ឆរិយ របស់ប្រាសាទរាងពីរាមីត នៅក្នុងលោកនេះទាំងអស់ ដែលប្រាសាទរាងសាជីទាំងនោះ បានឆ្លុះទៅនឹងព្រះអាទិត្យមួយដួងនោះ។ សូមកូននាគប្រុសស្រី ពិចារណាបន្ថែមថា ទោះបីជាព្រះអាទិត្យមួយដួង ក្នុងថ្ងៃ ២១មីនានិងថ្ងៃ២១កញ្ញា រះចំកណ្ដាលកំពូលពីរាមីតដ៏ច្រើន ក៏ពន្លឺព្រះអាទិត្យមួយដួងនោះ ពុំអាចជះពន្លឺចូលទៅក្នុង ប្រាសាទរាងសាជីទាំងនេះបានដែរ(និមិត្តរូប)។ លុះត្រាតែមានបុគ្គលណា អាចផ្ចារប្រាសាទរាងសាជី ឬក៏បើកគំរបកំពូលសាជីទាំងនោះ ឲ្យមានប្រហោងឡើង ទើបពន្លឺព្រះអាទិត្យអាច

*ចាំងបភ្លឺ ឲ្យយល់ពីរឿងរ៉ាវក្នុងប្រាសាទ រាងសាជីទាំងអស់នេះបាន។ ប្រស្នាកំបាំងទាំងនេះ ជាកាក គំនិតរបស់មនុស្សផ្កាយ កាលពីរាប់ពាន់ឆ្នាំមុន។ ពន្លឺក្នុងន័យប្រស្នានេះ ពុំមែនពន្លឺចំណាំងរបស់ព្រះ អាទិត្យឡើយ វាគឺជាពន្លឺបញ្ញាញាណ ដែលផុះចេញពីគំនិតមនុស្សពូជផ្កាយ ពូជនាគ ពូជអច្ឆរិយ ដែលកើតចេញពីភ្នែកទីបី នៅចំកណ្ដាលថ្ងាស។ ដូចរូបចម្លាក់អាទិទេពក្មេរ ដែលមាននៅតាម ប្រាសាទ ដូនតាក្មេរបានឆ្លាក់ភ្នែកនៅចំកណ្ដាលថ្ងាស ទាំងអាទិទេពស្រី និងអាទិទេពប្រុស។ ដូច្នេះ ហើយទើបដូនតា បានទុកប្រស្នាជាពាក្យប្រដៅកូនចៅពីអតីតថា* ***ល្ងីល្ងើមិនពកថ្ងាស*** *បើគ្រាន់តែពក ថ្ងាសបាត់ល្ងើនោះ យើងមិនចាំបាច់ទៅរៀន តាំងពីថ្នាក់បឋម រហូតដល់សកលវិទ្យាល័យនោះឡើយ យើងគ្រាន់តែយករបស់រឹង មកវាយឲ្យចំកណ្ដាលថ្ងាស នោះថ្ងាសនឹងពកឡើង យើងបាត់ល្ងីល្ងើទៅ ហើយ។ តែន័យបង្កប់ក្នុងពាក្យនេះ ពុំដូច្នេះឡើយ គឺវាមានន័យផ្សេងរបស់វាទៅវិញ បើកូនក្មេរមិន កើតភ្នែកទីបីចំកណ្ដាលថ្ងាសទេ មិនអាចដឹងពីន័យកាកគំនិត ប្រាសាទរាងសាជីទាំងក្នុងប្រទេស និង នៅក្នុងលោកទាំងមូលនេះបានឡើយ។*

*បទកាកគតិនេះ ក្នុងមួយរបះមាន៧ឃ្លា ក្នុងមួយឃ្លាមាន៤ព្យាង្គ មានន័យបង្កប់ថា សំណល់ គំនិតពួកព្រហ្មពីអតីតកាល(ព្រហ្មមុខ៤) ត្រូវរស់នៅដោយឈឺចាប់ ជាមួយនឹងអ្នកទទួលមរតកទាំង ប្រុសស្រី គ្រប់ៗថ្ងៃទាំង៧(ស្មើមួយសប្ដាហ៍) តាំងពីអតីតរហូតដល់បច្ចុប្បន្ន នេះជាន័យពិតដែលបង្កប់ ទុកក្នុងឈ្មោះបទកាកគតិ។ សូមមើលអត្ថបទកំណាព្យខាងក្រោម:*

**<u>កំណើតធនជ័យ</u>** (បទកាកគតិ)

១.បទកាកគតិ តំណែលបិតិ
ជាកេរដូនតា ជាកាកគំនិត
ទុកក្នុងសិលា រឿងរ៉ាវអច្ឆរា
មរតកម៉ែៗ

២.កំណើតធនជ័យ កើតដោយប្រពៃ
មានរឿងហូរហៃ ម្ដាយយល់សុបិន្ត
ដូងបេះទាំងផ្លែ ឃើញវង់ព្រះខែ
ពេញបូណ៌មីៗ

៣.ធ្លាក់ស្វាងពេលណា ម៉ែពិចារណា
សុបិន្តរាត្រី ឃើញហេតុចម្លែក
សែនល្អពេកក្រៃ ចង់ដឹងពីន័យ

ទៅរកគ្រូទាយៗ

៤.ទៅផ្ទះហោរា មិនជួបនិងតា
បានជួបតែយាយ ស្ដាប់ពាក្យរ៉ាយរ៉ាប់
អ្នកមករកទាយ យាយបែរទំនាយ
ប្រាប់ន័យបង្កុសៗ

៥.ហេតុតែច្រណែន សប្តិល្អមែនទែន
កើតចិត្តប្រទុស្ត ព្រោះកើតមោហ:
និយាយបង្កុស យាយទស្សន៍ទាយនោះ
ចិត្តបាបពោកក្រៃៗ

៦.ម្តាយចាប់មានគភ៌ គ្រប់ថ្ងៃខ្វាទទរ
ប្រសូត្រកុត្រថ្លៃ តាំងនាមឲ្យឈ្មោះ
កុលបុត្រធនជ័យ កុំឲ្យបុត្រថ្លៃ
ធំឡើងខ្ញុំគេៗ

៧.ធនជ័យធំឡើង ម៉ែខ្ញុំតំកើង
មិននៅផ្ទះទេ ទៅលេងឯផ្ទះ
សេដ្ឋីជាមេ អ្នកមានលើសគេ
ក្នុងទឹកដីនោះៗ

៨.រឿងហេតុកើតឡើង សេដ្ឋីនីយើង
ក្បាញហ្វូលគ្រល់ជ្រុះ ប្រើជ័យឲ្យរើស
ឈ្នួលអំបុកជួស រឿងកើតពេលនោះ
សូត្រនិងអំបុកៗ

៩.សូត្រតាងឲ្យនាង និមិត្តរូបរាង
ជាប់ក្នុងសំបុក គេយកទៅស្ងោរ
នាងនាគវងទុក្ខ ចិត្តកាយជាប់គុក
ព្រោះហេតុតែគេរៗ

១០.ចំណែកអំបុក ប្រស្នាចារទុក

តាងឲ្យព្រះមេ ស្រូវលើងឲ្យឆ្អិន
ទុក្ខកើនឡើងទ្វេរ រួចបុកព្រះមេ
ប្លាត់រូបរាងដើមៗ
១១.នេះគឺជាហេតុ ដែលនាំកើតវេទ
រឿងជ័យចាប់ផ្ដើម កើតពីព្រះមេ
តាងឲ្យម្ដាយដើម ដែលជាសំណើម
ប្រាជ្ញចាប់កំណើតៗ
១២.ជ័យពិចារណា សេដ្ឋីយាយតា
ដែលបានរស់កើត សោយកេរព្រះមេ
មរតកល្អឆើត ម្ដេចភ្លេចកំណើត
ចិត្តលោភប្រវ័ញ្ចៗ
១៣.សូម្បីតែក្មេង នៅតូចរត់លេង
សេដ្ឋីតាមផ្ចាញ់ មិនសង្វេគសោះ
វិតរួបចម្រាញ់ ប្រឹងកេងប្រវ័ញ្ច
ក្នុងដែនព្រះម៉ែៗ
១៤.ធនជ័យគស្ទូ ធ្វើជាគ្រូ
ក្នុងនាមកូនខ្មែរ ចិត្តងើបប្រឆាំង
តក្កាហួរហែ តាងឲ្យវង្សខែ
រះពេញបូណ៌មីៗ
១៥.ជ័យផ្ចាញ់ទាំងអស់ មិនឲ្យសល់សោះ
តាំងពីសេដ្ឋី ពីតូចទៅធំ
នាម៉ឺនមន្ត្រី ក្សត្រស្ដេចផែនដី
ដែលពុំដឹងគុណៗ
១៦.ឲ្យកូនម៉ែឆ្លាក់ មើលឃើញវង្សត្រ័ក្រ
ព្រហ្មរងទុក្ខធ្ងន់ ព្រោះហេតុតែកេរ
ម៉ែឪលោភលន់ ទទួលទុក្ខធ្ងន់

កប់ទឹកឆក់ដីៗ

១៧.ជ័យស៊ូនឹងចិន នាំប្រាជ្ញវ៉ៃប៉ិន
មកយកហ៊ុរី ស្លាប់ខ្លួនជាតិរស់
ដោះប្រស្នាបី រក្សាទឹកដី
មរតកព្រះរស់ៗ

១៨.ហោតុតែប្រទេស ស្តេចនិរទេស
ជ័យជួបនឹងគ្រោះ ដើម្បីកេរម៉ែ
ជ័យហានប្រទូស្ត ថាស្តេចចិននោះ
មុខដូចសត្វឆ្កែៗ

១៩.ចិនចាប់ដាក់គុក កាយចិត្តពុំសុខ
រិះគិតហួរហែ លួចបង្ហោះខ្លែង
តាងឲ្យកេរម៉ែ ឥពូជពង្សខែ
សោមខ្មែរអច្ឆរាៗ

២០.ចុងក្រោយចិនចាញ់ បណ្ឌិតលោកផ្ចាញ់
ដោយចោទប្រស្នា ទុកឈ្មោះខ្លែងឯក
មរតកដូនតា ទុកជាប្រស្នា
ន័យកាកគំនិតៗ

២១.ចំណែកខ្លែងឯក មានអ្វីគួរប្លែក
ក្រដាសមួយសន្លឹក ចិនបែរចុះចាញ់
ជ័យប្រាជ្ញបណ្ឌិត ប្រស្នាគំនិត
ជ័យទុកឲ្យកូនៗ

២២.ចុងក្រោយជ័យផ្តាំ ឲ្យកូនម៉ែចាំ
កុំឲ្យសាបសូន្យ សំណាល់គំនិត
ជ័យទុកឲ្យកូន ធ្វើជាទូកក្បួន
ដោះប្រស្នាបីៗ

២៣.កូនកុំបណ្តោយ បើកូនបានសោយ

កូនត្រូវដឹងន័យ ដឹកនាំនគរ

ឲ្យខ្ពស់ថ្លាថ្លៃ ត្រូវស្គាល់អត្ថន័យ

សត្វត្រី(ស្ត្រី)ប្រស្នា។

២៨.ប្រស្នាជ័យហោង តាមដោយគន្លង

នៃក្បួនតម្រា បណ្ឌិតទុកពាក្យ

យេះដូងទេវតា ដែនដីសួគ៌ា

កត្តញ្ញូនាំសុខ។

២៩.សូមបញ្ចប់ស្លេះ សង្ខេបប៉ុណ្ណោះ

សូត្រនិងអំបុក បង្កើតប្រាជ្ញជ័យ

រៀបរាប់ទំនុក ជ័យជួបតែទុក្ខ

ឲ្យតែជាតិរស់។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស ២៥៥៥ ត្រូវនឹងថ្ងៃទី១៦ មិថុនា គ.ស ២០១១

រៀបរៀងចងក្រងដោយឧបាសក **គៀត ចាន់ផុន**

**៤.បទព្រហ្មគីតិឬព្រហ្មគិត**

*កូនក្មេរជំនាន់ក្រោយតែងហៅមេបទនេះថា ព្រហ្មគីតិឬចម្រៀងព្រហ្ម ឈ្មោះរបស់មេបទនេះន័យពិតរបស់វាតើដូចម្ដេច?*

**ពន្យល់ពាក្យ**

*ព្រហ្មគីតិ(ព្រំម:គីតិ, ប្រ--គីត) ន. (បា. ព្រហ្ម "ព្រហ្ម" + គីតិ "ចម្រៀង") ឈ្មោះកាព្យមួយយ៉ាងមានជើង៤គឺក្នុងមួយរបះមាន៤ឃ្លា, ត្រង់ឃ្លាទី១និងទី៣មាន៥ពាក្យ, ឃ្លាទី២និងទី៤មាន៦ពាក្យ : បទព្រហ្មគីតិ (ដកចេញពីវចនានុក្រមសម្ដេច)ព្រហ្មគិត ការគិតទុក របស់ ព្រហ្ម (ភាសានិយាយ)*

*តើន័យរបស់មេកាព្យនេះ មានខ្លឹមសារពិតយ៉ាងណា? បើតាមការស្រាវជ្រាវ ឲ្យដាប់ទៅនឹងឬសកែវរបស់ដូនតាមហានគរ យើងអាចយល់បានថា គឺពុំមែនព្រហ្មជាទេវតាឬអាទិទេពណា មកគិតតែងចម្រៀងឬមេកាព្យ ទុកឲ្យកូនក្មេរយើងឡើយ។ ព្រោះភារ:នេះជាកិច្ចរបស់ព្រហ្មក្មេរ អ្នកដឹកនាំក្មេរ ដែលជាអ្នកបង្កើតមាតុភូមិនេះ ខំប្រមែប្រមូលមរតកកេរគ្រប់បែបយ៉ាង មកទុកឲ្យកូនក្មេរខាងក្រោយ គ្រប់ជំនាន់សោយនូវផលកេរនេះ។ ដូចនេះយើងតែងឮសូរពាក្យពោលត្អូញត្អែ របស់អ្នកមានទុក្ខព្រួយធ្ងន់តែងនិយាយថា នេះជា***ព្រហ្មលិខិត*** *យើងមិនបាននិយាយថាកម្មលិខិតឡើយ ក្នុងនាមយើងជាអ្នកគោរពព្រះពុទ្ធសាសនា យើងពុំបានជឿទៅលើអំពើកម្ម ដែលយើងបានសាងទុកក្នុង*

អតីតកាល បច្ចុប្បន្នកាល ដែលកម្មនេះកំពុងតែឲ្យផល វិបាកជាសុខឬទុក្ខ។ អ្វីទៅជាព្រហ្មលិខិត? តើអាទិទេពព្រហ្មមានអំណាចអ្វី មកដាក់ទុក្ខទោសឲ្យសព្វសត្វ ជាពិសេសគឺកូនខ្មែរនោះ? តាមការស្រាវជ្រាវពាក្យថាព្រហ្មលិខិត យើងអាចយល់បានថា ព្រហ្មដូនតាយើងលោកទុកលិខិតសារបណ្តាំនៅក្នុងថ្មគ្រប់ប្រាសាទ(ពីអតីត) ទំនៀមទម្លាប់ប្រពៃណី..... ដោយកូននាគពុំបានឈ្វេងយល់ យើងបែរជាយល់ច្រឡំថាជាលិខិតព្រហ្ម របស់ព្រហ្មញ្ញសាសនាទៅវិញ។ ដូនតាឲ្យយើងមើលថ្ម ដែលជាភាសាគឬភាសញ្ញា ហេតុអ្វីរូបចម្លាក់ពួកគាត់មានតែក្បាល? តើដងខ្លួនពួកគាត់បាត់ទៅណា? ក្នុងនាមយើងជាអ្នកទទួលមរតកអច្ឆរិយនេះ តើមានឆ្ងល់ដែរឬទេ? សារលិខិតរបស់ព្រហ្ម របស់កបិលមហាព្រហ្មគឺសិរសា(ក្បាល) ដែលជាប្រស្នារបស់ដូនតាយើង ក្នុងមួយឆ្នាំកូននាំគ្នាហែហម រំលឹកគុណគាត់បានម្តង ក្នុងថ្ងៃសង្ក្រាន្តចូលឆ្នាំថ្មី តើរឿងនេះកើតមានមុនថ្ម ឬក៏ថ្មកើតមានមុនរឿង? ហេតុអ្វីសិរសាកបិលមហាព្រហ្ម ដែលដង្ហែរាល់ឆ្នាំ សាកសពនេះម្តេចមិនស្អុយ មិនរលួយមិនស្លាប់ចេញពីសណ្តានចិត្តកូនខ្មែរ? ចូរកូននាគទាំងឡាយ ពិចារណារកព្រហ្មពិតឲ្យឃើញ ទើបយើងអាចស្គាល់បេះដូងព្រហ្ម ដែលជាពូជនាគនិងពូជអច្ឆរិយ ព្រោះវាជានិមិត្តរូបរបស់ដូនតាយើង។

ដូចមេកាព្យព្រហ្មគីតិនេះ បើព្រហ្មចង់ច្រៀងត្រូវតែត្រិះរិះគិត ទើបច្រៀងចេញមកបាន ដូច្នេះចម្រៀងព្រហ្មគ្គី(ព្រហ្មគីតិ) ការគិតទុករបស់ព្រហ្មគ្គី(ព្រហ្មគិត) គឺមានន័យតែមួយដូចគ្នា បើពុំត្រិះរិះគិត គឺពុំអាចច្រៀងចេញបានឡើយ។ ព្រហ្មគីតិឬព្រហ្មគិត គឺជាការស្រែកច្រៀងរៀបរាប់ ប្រាប់ពីទុក្ខវេទនា ដែលខ្លួនបានក្លាយជាព្រាយ ប្រែត.... នៅក្នុងអបាយភូមិ ដោយគាត់មានសង្ឃឹមថា នឹងមានកូននាគណាម្នាក់ បានយល់ពីអាថ៌កំបាំងប្រវត្តិសាវតារបស់ពួកគាត់ ហើយគេនឹងជួយដោះទុក្ខ។ សូមមើលអត្ថបទកំណាព្យខាងក្រោម:

## <u>**គំនិតព្រហ្មឬការគិតរបស់ព្រហ្ម**</u> = (បទព្រហ្មគិត)

១.អនិច្ចាឱ្យាព្រហ្ម ខំពូតផ្តុំផ្គុំគំនិត
ទុកបទព្រហ្មគិត ជាប្រស្នាឲ្យកូនស្រាយៗ

២.ព្រហ្មពិតជាអ្នកណា ព្រះមាតាបិតាថ្លៃ
គិតកូនគ្មានន្ធើយណាយ ហោតុតាំងខ្លួនជាព្រះរស់ៗ

៣.វិហារធម៌ទាំងបួន ក្រុងគ្រប់កូនការពារគ្រោះ

| | |
|---|---|
| ម៉ែឪរងជំនួស | ហេតុតែកូនសុខចិត្តប្លាប់ៗ |
| ៤.ធម៌មួយគឺ**មេត្តា** | ថែរក្សាឲ្យឪវ៉ាទ |
| លំបាកលុតលួនក្រាប | ទុក្ខលំបាកគិតចម្បែងៗ |
| ៥.ធម៌ពីរគឺ**ករុណា** | គិតបុត្រត្វាអាណិតក្រែង |
| ខ្លាចកូនពុំប្រឹងប្រែង | សន្សំបុណ្យរៀនដឹងចេះៗ |
| ៦.ធម៌បីគឺ**មុទិតា** | ចិត្តជ្រះថ្លាគិតរិះត្រិះ |
| សប្បាយនិងកូនចេះ | មិនធ្លាក់ខ្លួនដើរផ្លូវខុសៗ |
| ៧.ធម៌បួនគឺ**ឧបេក្ខា** | ចិត្តល្អថ្លាមានសន្តោស |
| កណ្តាលមិនជ្រុលហួស | កូនសុខទុក្ខគិតតាមកម្មៗ |
| ៨.ព្រហ្មគិតពិតមានមែន | ព្រហ្មជាក់ស្តែងគង់រងចាំ |
| ឲ្យក្មេរស្រាយបណ្តាំ | ការគិតទុករបស់ព្រហ្មៗ |
| ៩.ធ្លាក់មុខទុកលើថ្ម | ពូជអ្នក**ករ**បែរជាឃំ |
| ព្រោះកូនពុំស្គាល់ព្រហ្ម | ម៉ែឪឱបទុក្ខព្រោះបុត្រៗ |
| ១០.ពេលណាទើបកូនដឹង | ចេះសញ្ជឹងងើបពីច្បុត |
| កើតខ្មែរទើបរួចផុត | ព្រោះការគិតខ្មែរក្នុងថ្ងៃសៗ |
| ១១.កូនក្រោកទើបស្វាងថ្លា | ខ្មែរបញ្ញាភ្លឺឱកាស |
| ស្គាល់ព្រហ្មពិតល្អណាស់ | ពុំមែនព្រហ្មនៅឯនាយ¹ៗ |

១២.ព្រហ្មពិតនឹងបានសុខ រួចផុតទុក្ខកម្មពីឆ្ងាយ
ម៉ែពុកអរសប្បាយ គំនិត[២]ព្រហ្មកូនបានយល់ៗ

១៣.ព្រហ្មចរិយធម៌ ថ្លៃថ្លាល្អផ្ដាច់ឫសគល់
អវិជ្ជាអស់គ្មានសល់ ដល់មណ្ឌលឋានអមតៈ[៣]ៗ

ពន្យល់ន័យ ១.ព្រហ្មញ្ញសាសនា ២.អ្នកបង្កើតប្រាសាទមុខព្រហ្ម ៣.ឋាននិព្វាន

ថ្ងៃព្រហស្បតិ៍ ១កើត ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី២ មិថុនា ២០១១

រៀបរៀងចងក្រងដោយ ឧបាសក **គៀត ចាន់ផុន**

## <u>ទំនួញព្រហ្មលិខិត ឬលិខិតព្រហ្ម</u>

១.ចំណារគតិព្រហ្ម ខំពូតផ្ដុំចារលិខិត
ប្រស្នាកាព្យគំនិត ចារលើថ្មឲ្យកូនស្រាយៗ

២.ពាក្យថាព្រហ្មលិខិត ន័យក្មេរពិត**ត**ស្រឡាយ
ពុំមែនព្រហ្មញ្ញនាយ គឺគំនិតព្រះព្រហ្មក្មេរៗ

៣.លិខិតចារលើថ្ម ពេញនគរជាប់ហូរហែ
គំណរាងឲ្យគេរម៉ែ(ក្មេរ) ញញឹមទុកបង្កប់ន័យៗ

៤.ហេតុម្ដេចលោកមិនទុក លិខិតពុទ្ធសាស្ត្រាស្រី
ពុទ្ធសាសចូលដែនដី សុវណ្ណភូមិស្រុករគ្នាៗ

៥.ទុកតែលិខិតព្រហ្ម យើងទួញយំស្រែកគគ្នា

ព្រហ្មលិខិតតាមចងពៀរ តើព្រហ្មាមានសិទ្ធិអ្វីៗ

៦.មកដាក់បណ្តាសារ យើងគ្រប់គ្នាទាំងប្រុសស្រី

តាមពិតកម្មអតីត ឬត្រប្រុសស្រីបានសាងមកៗ

៧.ពុំមែនលិខិតព្រហ្ម ចាប់បង្ខំឲ្យកូនយក

គ្រោះឬាបកម្មទុក្ខសោក តាមអំណាចព្រះព្រហ្មឡើយៗ

៨.ឬាបកូនគឺទង្វើ ដែលកូនធ្វើទុកមកហើយ

ពុំមែនសារព្រហ្មឡើយ ព្រះសាស្តាព្រះអង្គផ្តាំៗ

៩.ថាសត្វលោកទាំងអស់ ប្រព្រឹត្តិឆ្ពោះតាមផលកម្ម

ចក្រវិលតាមលំនាំ ដានស្នាមកម្មមានហើយពិតៗ

១០.ហេតុអ្វីបានជាបែរ នាំគ្នាថៃព្រហ្មលិខិត

ពាក្យចេញពីគំនិត លិខិតព្រហ្មកប់ក្នុងថ្មៗ

១១.លិខិតគឺសិរី(សិរីបី) ចូលឆ្នាំថ្មីថ្ងៃបវរ

សង្ក្រាន្តនាំតំណរ លិខិតព្រហ្មចាញ់ប្រស្នាៗ

១២.ហេតុតែមានអំនួត មានះអួតថាអស្ចារ្យ

តាំងខ្លួនជាមាតា បិតាពិតបង្កើតពៀរៗ

១៣.នាំគ្នាប្រព្រឹត្តខុស មានកំហុសនឹងព្រហ្មមារ

លោកត្រូវបណ្តាសារ កម្មនាំទុក្ខព្រោះតែគេរៗ

១៤.តើកូនម៉ែមានឆ្ងល់ កើតចម្ងល់នឹងព្រហ្មទេ

ព្រហ្មក្មេរពីបុព្វេ មានតែក្បាលពុំមានខ្លួន។

១៥.តើខ្លួនបាត់ទៅណា មានសិរសាប្រាណបំពួន

បុត្រត្វាថ្លៃនឹមនួន ដោះប្រស្នាលិខិតព្រហ្ម។

១៦.ធម្មបាលមានវាសនា ស្តាប់ចរចាឥន្ទ្រីធំ

មេកូនក្នុងទ្រនំ និយាយប្រាប់រឿងធម្មបាល។

១៧.ឥន្ទ្រីគឺជាអ្វី បុត្រប្រុសស្រីស្តាប់គំណាល

រឿងកើតមានក្នុងកាល កន្លងទៅស្ទើរលុបដាន។

១៨.ឥន្ទ្រីយ**មួយ**សទ្ធា **ពីរ**វិរិយាតាមលំអាន

**បី**សតិប្បដ្ឋាន **បួន**សមាធិនាំចិត្តស្ងប់។

១៩.ឥន្ទ្រីយ**ប្រាំ**មាំក្លា គឺបញ្ញាហ៊ានគាស់កាប់

មោហៈឲ្យដេកស្លាប់ កុំច្រឡំសត្វឥន្ទ្រី។

២០.ឥន្ទ្រីយក្នុងបស្សនា តាមតម្រាមាន**ម្ភៃពីរ**

ដើមគេចក្ខុន្ទ្រីយ ចុងអញ្ញាតាវិន្ទ្រីយ។

២១.កបិលមហាព្រហ្ម នៅក្នុងឃុំរូងគីរី

បុត្រីមាន**ប្រាំពីរ** ចរលើលានាំគ្នាថៃ។

២២.បុត្រពិត**ពីរដណ្តាប់** កូនសំណប់តាងម្តាយក្មេរ

តាមពិតអ្នកមកថៃ មាន**ប្រាំពីរ**ដែលចេះនឹកៗ

២៣.ទឹកក្នុងបេះដូងគេ ត្រូវថ្ងៃខែស៊ីសាច់ទឹក(ដួងខែស៊ី)

ធ្វើឲ្យគេភ្លេចភ្លឹក ឈប់រំលឹកពីព្រហ្មថ្លៃៗ

២៤.ឯកូនទាំងប្រាំពីរ ដែលសល់ពីកូនឥតន័យ

ប្រចាំគ្នាពេកក្រៃ វេនអ្នកណាហ្នឹងទៅហៃៗ

២៥.ចំណែកអ្នកឯទៀត គ្មានពេលឆ្លៀតមកជួបម៉ែ

ដោះសារកិច្ចបង្វែរ ថារវល់ព្រោះអត្តាៗ

២៦.អស់ខ្ញុំព្រហ្មលិខិត កម្មព្រហ្មពិតតាមយថា

កម្មសាងជាចំណារ ទុក្ខំណៃនទ្រូងស្រែកដង្ហោយៗ

២៧.ព្រហ្មថ្មកើតមានមុន ក្បិលមហាព្រហ្មកើតមានក្រោយ

ប្រស្នាទុកកូនស្រាយ ពីសិរីបីប្រការ(ស្រីបី)ៗ

២៨.ធម្មបាលអ្នកឃាមធម៌ បើកទ្វារគតិដោះប្រស្នា

លិខិតដែលព្រហ្មចារ ម៉ែខ្ញុំសុខដល់ត្រើយនាយៗ

២៩.សាស្ដាត្រាស់ដឹងឯង ទ្រង់សម្ដែងសព្វបរិយាយ

ឲ្យសាវកគ្រួសត្រាយ ដោយបញ្ញាគិតសឹមជឿៗ

៣០.កុំជឿឮគេថា តាមតម្រាឬជំនឿ

ឈ្វេងយល់ផុតទាបតឿ សច្ចៈមានកូនត្រូវយល់ៗ

| | |
|---|---|
| ៣១.មែកស្លឹកផ្លែផ្កាប្បាន | មានលំអានឫសនិងគល់ |
| លិខិតព្រហ្មបន្សល់ | ព្រោះព្រហ្មពិតគឺឪម៉ែៗ |
| ៣២.បើកូនបានសោយកេរ | ត្រូវរិះរករកគល់ខ្មែរ |
| រាវរកពូជពង្សខែ | ដែលមានកម្មពីអតីតៗ |
| ៣៣.ហូបបាយនឹកឃើញព្រះ | ខ្ពស់ល្អណាស់ព្រះមេស្រី |
| អ្នក**ភ**កើតទឹកដី | ព្រះម៉ែក្សត្រពូជពង្សព្រហ្មៗ |
| ៣៤.បើព្រហ្មលោកបានសុខ | ចាកផុតទុក្ខពៀរគំនុំ |
| ចំណាររបស់ព្រហ្ម | កូនបានដោះប្រស្នាហើយៗ |
| ៣៥.កូនម៉ែអើយធ្លាក់ឡើង | លើកតម្កើងកុំព្រងើយ |
| ព្រហ្មពិតផុតទុក្ខហើយ | ព្រហ្មមុនក្រោយបានសុខាៗ |

ថ្ងៃច័ន្ទ ៥កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី៦ មិថុនា គ.ស២០១១

រៀបរៀងដោយឧបាសក **គៀត ចាន់ផុនន**

**5.បទពំនោល**

**ពន្យល់ពាក្យ**

***ពំនោល*** ( ន. ) *ដំណើរដែលពោល, ពាក្យពោល; បទពោលល្ខោន។ឈ្មោះកាព្យមួយយ៉ាង មានជើងបី គឺក្នុងមួយរបះមានឃ្លាបី, មានចួនបី, ឃ្លាទី១, និងទី៣មាន៦ពាក្យ, ឃ្លាទី២មាន៤ពាក្យ : បទពំនោល, ដូចជា : យក្សក្រោធច្រឡោតខ្លាំងក្រៃ ស្ទុះហោះច្រៀវច្រៃ ពួតដៃកំញើញគួរស្ញែង។ ស្រែកហ៊ោសន្ធាប់ឥតក្រែង ថាវ៉ីយប្រស្តែងម្តេចឯង ពុំកោតចេស្តា។(ដកចេញពីវចនានុក្រមសម្តេច)*

*តើបទពំនោលនេះ ដូនតាយើងគាត់បន្សល់អត្ថន័យ ពោលទុកពីរឿងអ្វី? ឈ្មោះមេកាព្យបួនបទខាងដើម ខ្ញុំបាទបានពន្យល់រួចហើយ ពីន័យរបស់ឈ្មោះ បង្កប់ទុកក្នុងមេកាព្យទាំងនោះ ចំណែកមេបទពំនោលនេះ ក៏មិនខុសអ្វីពីន័យមេកាព្យ ទាំងបួនខាងលើឡើយ។ ដូនតាយើងជាម្ចាស់មរតក*

*អច្ឆរិយ លោកបានពោលជាបទពំនោលត្អូញត្អែ រៀបរាប់ទុក្ខសោករបស់ខ្លួន ដែលបានតាំងខ្លួនជាម៉ែ (ស្ករតាំងម៉ែ)តាំងខ្លួនជាឪជាព្រហ្មជាអាទិទេព ត្រួតត្រាទឹកដីពង្វាតទឹកដី តាំងខ្លួនជាមេជាធំលើគេ ទីបំផុតនៃសេចក្តីលោភ បានត្រឹមតែពោលរៀបរាប់ ពីការខកខ្លួនស្តាយក្រោយ ក្នុងនាមជាអ្នកទោស ជាព្រាយ ជាប្រេត បិសាច.... តើមានកូនណាយល់ន័យក្នុងពំនោលរបស់មេ(ម៉ែ) ដែលបានពោលរៀបរាប់នេះ? កូននាគជំនាន់ក្រោយ បានត្រឹមតែយកមេបទ មកតែងបន្តទៅតាមគំនិតរបស់ខ្លួន ធ្វើដូចម្តេចអាចជួយស្រាយប្រស្នា បង្កប់នូវរឿងទុក្ខព្រួយរបស់ម្ចាស់មេបទនេះបាន? នេះជាផលកម្ម ដែលពួកគាត់ត្រូវទទួល ដោយពួកគាត់បានសាង សាបព្រោះនៅពូជនេះទុកឲ្យខ្លួនឯង ដូច្នេះផលនៃទុក្ខរមែងកើតឡើង។ នៅក្នុងគម្ពីព្រះត្រៃបិដក ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានត្រាស់សម្តែងរៀបរាប់ប្រាប់ រឿងរបស់អានន្ទសេដ្ឋី ដែលជាបុគ្គលមច្ឆរិយកំណាញ់ មាននូវមច្ឆាទិដ្ឋិគឺការយល់ខុស ពុំជឿទៅលើកម្មនិងផល ទីបំផុតក្រោយពីច្យុតិចិត្តគឺស្លាប់ កម្មបានរៀបចំឲ្យគាត់ឲ្យកើតជាមនុស្ស ក្នុងត្រកូលចណ្ឌាល ដែលជាមនុស្សត្រកូលថោកទាប ក្ររហេមរហាម សូម្បីតែរូបរាងកាយគាត់ ក៏ខុសប្រក្រតីពីមនុស្សធម្មតា។ ឪពុកម្តាយដែលគាត់ទៅបដិសន្ធិគឺកើតជាមួយ ត្រូវវេទនាក្ររហេមរហាម រកអាហារបរិភោគស្ទើរពុំបាន ដោយអំណាចបាបកម្មរបស់សេដ្ឋីនោះ ចំហាយនៃបាបរបស់គាត់នេះ បានជះផ្សាយទៅឲ្យញាតិដែលនៅជុំវិញ។ ពេលក្រោយមកទើបព្រះសម្មាសម្ពុទ្ធ បានជួបនឹងត្រាស់សម្តែងគាថា ប្រារព្ធទៅលើរឿងអានន្ទសេដ្ឋី*

***១.បុគ្គលពាលល្ងង់ខ្លៅតែងសម្លាប់ប្រយោជន៍ខ្លួនឯងផង និងសម្លាប់ប្រយោជន៍អ្នកដទៃដែលនៅជុំវិញខ្លួនផង***

***២.បុគ្គលពាលល្ងង់ខ្លៅ តែងប្រកាន់យល់ថាខ្លួនមានទ្រព្យ យសសក្តិ បុត្រ ភរិយា ញាតិ.. ទីបំផុត សូម្បីតែខ្លួនឯង ក៏មិនមានផង តើមានទ្រព្យ យសសក្តិ បុត្រ ភរិយា ញាតិ... មកពីណា?***

*ពំនោលពោលរៀបរាប់ នៅរឿងទុក្ខវេទនាសព្វបែបយ៉ាង ដែលពួកគាត់បានយក ទៅលាក់បង្កប់ទុក ក្នុងទំនៀមទម្លាប់ប្រពៃណី សាសនា សំណង់ប្រាសាទ សិល្បៈ ចម្លាក់...... ជាពិសេសនោះគឺន័យរបស់ឈ្មោះមេកាព្យទាំងអស់នេះ។ ពំនោលពោលរឿងពិត របស់ម្ចាស់មរតក ឬសគល់អ្នកបង្កើតជាតិទាំងមូល ដោយសង្ឃឹមថាថ្ងៃណាមួយ កូននាគនឹងយល់ នូវអាថ៌កំបាំងប្រស្នាទាំងអស់នេះ ហើយគេនឹងជួយដោះទុក្ខខ្លួនជាពុំខាន។ សូមមើលកំណាព្យខាងក្រោម:*

**<u>ពំនោលមាតាមហានគរ</u>** (បទពំនោល)

| | | |
|---|---|---|
| ១.សូសៀងសំនៀងពំនោល | ដូនតាបានពោល | ពំនោលទុកជាមេកាព្យៗ |
| ២.ជាពូជទុកឲ្យកូនសាប | ជានាមកំណាព្យ | មេកាព្យមានតែឈ្មោះបីៗ |

៣.ឲ្យកូនយល់ដឹងអត្ថន័យ ប្រស្នាសិរី ឆ្នាំថ្មីមានបីប្រការ។

៤.សង្គ្រានតំណែលដូនតា ទុកន័យប្រស្នា ចំណារជាលិខិតព្រហ្ម។

៥.ពំនោលពោលប្រាប់ទុក្ខធំ ព្រហ្មជាប់ក្នុងឃុំ រូងត្នុគីរី[១]សុមេរុ។

៦.ព្រហ្មតាងតំណាងព្រះម៉ែ ម្ចាស់មរតកខ្មែរ ព្រះម៉ែជាម្ចាស់[២]សិរី។

៧.កប់ខ្លួនទៅក្នុង[៣]តក់ដី ព្រះម៉ែនាគថ្លៃ ខ្លួនស្រីត្រូវរាហូលេប។

៨.លោភលោភនាំចិត្តឲ្យសេព នាំឲ្យពង្សទេព យក្សលេបក្លាយជា[៤]បីសាច។

៩.អកុសលគួរឲ្យខ្លាច ព្រោះហេតុអំណាច កម្មកាចកើតពីចិត្តលោភ។

១០.កម្មនាំសោយផលស្មោកគ្រោក សោយទុក្ខវិយោគ សោយសោកពុំមានកូនដឹង។

១១.កាលមនុស្ស[៥]ព្រហ្មទ្វេរខំប្រឹង ឱបលោភច្រើនម្លឹង ស្រវឹងនឹងទ្រព្យទុកករ។

១២.ទុកឲ្យអ្នកសោយកេរម៉ែ រស់សុខល្ងើយល្ងែ កូនខ្មែរពុំស្គាល់ពំនោល។

១៣.ដូនតាចងកាព្យរួចពោល កាព្យបំភ្លឺទ្រោល ពាក្យពោលបង្កប់ទុកន័យ។

១៤.កូនកើតឈ្មោះថាប្រាជ្ញជ័យ ដោះប្រស្នាបី ចិន[៦]តែមកយកនគរ។

១៥.ប្រាជ្ញជ័យលោកបើកទ្វារគតិ ដោះគាថាសារ៖ រក៏ប្រាជ្ញជួយជ័យជួបជោគ។

១៦.ពំនោលពោលប្រាប់ពីសោក ជ័យមានក្នុងលោក ជួបសោកច្រើនជាងជួបសុខ។

១៧.ជាតិរស់ចិត្តបានស្រណុក ខ្លួនមានក្តីសុខ ជាតិទុក្ខចិត្តខ្លោចផ្សាក្រៃ។

១៨.ជិតស្លាប់ចិត្តនៅវិវែ ពោលប្រស្នាបី ឲ្យស្តេចចងចាំរិះគិត។

១៩.ពំនោលពោលពីគំនិត ពង្ស[៧]ជ័យប្រាជ្ញពិត ពូជពិតសាងប្រាសាទថ្ម។

២០.តំណែលហូរហែបន្ត រៀបរាប់ដំណា វង្សថ្មត្រូវដាច់ដំណឹង។

២១.⁸ចោលក្រុងព្រៃដុះជិតឈើង កូនម៉ែលែងដឹង ឈប់ទ្រឹងឥតាំងដូចថ្ម។

២២.ពំនោលលែងពោលបន្ត ការត្រិះរិះល្អ កើតមានគ្រប់ញាតិសន្តាន។

២៣.ពំនោលពោលត្រូវសុខសាន្ត ចិត្តសុខក្សេមក្សាន្ត ស្គាល់ធម៌ដល់អមតៈសុខ។

១.ន្ទីព្រះសុមេរ ២.ស្រីបីប្រការ ឬសិរីបីប្រការ ៣.ថ្មតក់ ៤.បីសាចពស់(ឯកសារចិនជីវតាក្វាន់ ៥.ព្រះម៉ែខ្មី ៦.តែបន្លិ៧.ពូជជ័យវ៉ែន ៨.ការបោះបង់ចោលក្រុងអង្គរជាង១០០ឆ្នាំ

ថ្ងៃ១២រោច ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១១

ដោយខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ផុន**

## ៦.បទបន្ទោលកាកឬបន្ទោកាក

### ពន្យល់ពាក្យ

**បន្ទោល** = *ពាក្យនេះក្នុងវចនានុក្រមសម្តេច ពុំមានការពន្យល់ឡើយ*

**បន្ទោ** ( *កិ.* ) *បញ្ចេញ, បន្ថយ, នាំចេញ : បន្ទោឧច្ចារៈ, បន្ទោបស្សាវៈ, បន្ទោសេចក្តីក្រោធ។ (ដកចេញពីវចនានុក្រមសម្តេច)*

*តើន័យពិតរបស់ឈ្មោះមេកាព្យនេះ បន្ទោលកាកឬបន្ទោកាក? ខ្ញុំបាទពន្យល់រួចហើយពីមេបទកាកគតិ ពេលនេះយើងបានមកស្គាល់មេបទទី៦ គឺបន្ទោកាក មានន័យថានាំចេញឬបន្ទោចេញកាកសំណល់គំនិត ដែលបានគិតទុកក្នុងចិត្ត មកដាក់ជាឈ្មោះមេកាព្យ ប្រាសាទ ភូមិស្រុក ភ្នំ...... ដោយលោកសង្ឃឹមថា នឹងមានកូននាគណាមួយគេឆ្ងល់ រួចពិចារណាគេនឹងអាចដឹងពីអាថ៌កំបាំងដែលបង្កប់ក្នុងឈ្មោះមេកាព្យនេះ។ ក្តីសង្ឃឹមនេះទីបំផុត ក៏បានមកដល់គោលដៅ ដែលពួកគាត់បានរង់ចាំ យើងមានសេចក្តីរំភើបត្រេកអរណាស់ ដោយដូនតាយើងពួកគាត់សុទ្ធតែជាបុគ្គល ទ្រទ្រង់ដោយគុណធម៌ ស្ម័គ្រចិត្តរងទុក្ខ ព្រោះហេតុតែប្រមូលមរតកកេរ មកទុកឲ្យជាតិនេះទាំងមូល។ មេកាព្យនេះក្នុងមួយរបះមាន៤ឃ្លា ឃ្លាទី១និងទី៣មាន៤ព្យាង្គ ឃ្លាទី២និងទី៤ មាន ៦ព្យាង្គ ហើយអត្ថន័យរបស់មេកាព្យនេះ ដូចខ្ញុំបាទបានបកស្រាយពន្យល់ដោយសង្ខេបខាងលើ។ សូមមើលកំណាព្យខាងក្រោម:*

## សំណល់មរតកកេរ(បន្ទោលកាក)

១.បទបន្ទោលកាក សល់ជាសំណាកឈ្មោះកាព្យ

ជូនតាបានសាប មកាព្យជាកេរព្រះរស់ៗ

២.បន្ទោសំណល់ ផ្លែផ្កាជាផលប្រាប់ឈ្មោះ

អត្ថន័យកាព្យនោះ រង្គោះជ្រុះបាត់ន័យពិតៗ

៣.ដំណើរដើមទង ថ្លែងតាមទំនងការគិត

បន្ទោគំនិត ន័យពិតទុកឲ្យកូនស្រាយៗ

៤.គំនិតជាកេរ ក្នុងដែនព្រះមេសុះសាយ

ដំណាំវែងឆ្ងាយ បានក្លាយជាកេរព្រះម៉ែៗ

៥.តែខ្សែគំនិត បានបាត់រឿងពិតវង្សខែ

គំនិតព្រះម៉ែ ដាច់ខ្សែជាង១មួយរយឆ្នាំៗ

៦.សំណល់គំនិត សាសនមានពិតត្រូវកម្ម

ឲ្យភ្លេចបណ្តាំ ភ្លេចចាំយល់ខុសព្រោះបាបៗ

៧.បរទេសឈ្លានពាន ចូលមករុករានបង្ក្រាប

នាំចិត្តសេពបាប ព្រោះសាបមនោគមថ្មីៗ

៨.បំភ្លេចការពិត រាល់កាកគំនិតរឿងស្ត្រី

ព្រះម៉ែម្ចាស់ថ្លៃ បំភ្លៃថារឿងសាសនាៗ

៩.កូនម៉ែភ្លេចដឹង គគាំងស្មៀមឈឹងវាចា

ពោលតាមតម្រា ២វិចារបរទេសគិតឲ្យៗ

| | |
|---|---|
| ១០.បើកូនកើតសុខ | ម៉ែសាងកេរទុកឲ្យសោយ |
| ត្រូវរកមកោយ | កុំឆ្លោយគំនិតជឿងាយៗ |
| ១១.តាំងជាម៉ែឪ | នាំចិត្តខុសផ្លូវព្រោះស្ដាយ |
| មរតកពង្រាយ | រោយរាយពាសពេញនគរៗ |
| ១២.ក្រែងលោកូនដឹង | ត្រិះរិះសញ្ជឹងរុក**ទក៏**(រក) |
| លើកម៉ែឪទ្រ | បញ្ជូរដាក់លើសិរសាៗ |
| ១៣.បើយល់[៣]ទំនៀម | បេះដូងកូនមានទេវតា |
| ដែនដីសួគ៌ា | ប្រស្នាបន្ទោកាកពិតៗ |
| ១៤.សូមបញ្ចប់ស្លេះ | សង្ខេបរិះត្រិះការគិត |
| បញ្ចប់គំនិត | ម៉ែពិតប៉ុណ្ណេះឯងហោងៗ |

១.ការបោះបង់ចោលក្រុងអង្គរជាង១០០ឆ្នាំ ២.ការពិចារណា ៣.ទំនៀមទំលាប់ប្រពៃណី ៤.រាជបំណាងជ័យវរ្ម័នទី៧

ថ្ងៃ១២រោច ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១១

ដោយខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ធុន**

## ៧.ភុជង្គលីលា( នាគដើរឬដំណើរនាគ )

### ពន្យល់ពាក្យ

***ភុជង្គ***ភុជង់សំ. បា. ( ន. ) (ភុជគ, ភុជង្គ, ភុជង្គម "សត្វទៅដោយល្បាត់") ពស់, នាគ។ភុជង្គនាគ ខ្មែរប្រើសំដៅសេចក្ដីថាពិភពនាគ) (ម. ព. ពិភពផង) ។(ដកចេញពីវចនានុក្រមសម្ដេច)

***លីលា***សំ. បា. ( ន. ) *ដំណើរឬលំនាំកែក្រាយ, ដំណើរល្វតល្វៃ, ការយាងយាស; បែបភាពឬទ្រង់ទ្រាយល្អ, សមរម្យ; ការលេងសប្បាយ, ការរាំច្រៀងលោតលេងសប្បាយ : លីលាល្ខោន។ខ្មែរប្រើជាកិ. ឬកិ. វិ. ឬគុ. ក៏មាន : ចរលីលា, ដើរលីលា, លីលាយាត្រា, ដំណើរលីលា។លីលាកមលឬ --បទុម (--ក:ម៉ល់ឬ--ប៉:ទុម) ផ្កាឈូកដែលគេកាន់ដើរលេងឬកាន់រាំ។លីលាគ្រឹះឬ--មន្ទីរផ្ទះសម្រាប់លេងសប្បាយ; រោងរាំ, រោងល្ខោន។ (ដកចេញពីវចនានុក្រមសម្ដេច)*

***ភុជង្គលីលា***ភុជង់-- ( ន. ) ឈ្មោះកាព្យមួយប្រភេទក្នុងមួយឃ្លាមានសង្កាត់បី, ត្រង់សង្កាត់ទី១ មាន៦ពាក្យ, សង្កាត់ទី២និងទី៣មាន៤ពាក្យហៅថាបទភុជង្គលីលា, ដូចជា : ព្រឹងព្រូសជន្លួសភ្លូភ្លង ក្រូចព្រៃអង្គ្រង ដុះដាសលាយគ្នា។(ដកចេញពីវចនានុក្រមសម្តេច)

តើឈ្មោះរបស់មេកាព្យនេះ មានបង្កប់ន័យប្រស្នាអ្វីខ្លះ? កូននាគបានដឹងហើយថា អ្នកបង្កើតទឹកដីសុវណ្ណភូមិនេះដំបូង គឺព្រះនាងនាគឬរាជនីនាគ ដែលយាមកដល់សម័យខាងក្រោយ ក្លាយជាមាតានាគឬដូននាគ (មើលបន្ថែមអាថ៌កំបាំងបណ្តាំមាតាមហានគរភាគ១)។ លោកបានបំពេញពលិកម្មគ្រប់បែបយ៉ាង ដើម្បីប្រមូលកេរមរតក មកទុកឲ្យកូននាគជំនាន់ក្រោយ។ ការតស៊ូក្នុងដំណើរវារលូន ខំប្រមូលកេរមរតកមកទុកនេះ បានបន្សល់ទុកនៅស្នាមដានព្រះបាទគ្រប់ទីកន្លែង ឈ្មោះថា ព្រះបាទជាន់ទុក នៅតាមភ្នំប្រាសាទ និងទីដទៃផ្សេងៗ...។ល។ ហេតុអ្វីបានជាព្រះបាទជាន់ទុករបស់ខ្មែរ ខុសពីព្រះបាទជាន់ទុករបស់ព្រះសម្មាសម្ពុទ្ធ? នេះជាការឆ្ងល់ និងជាកាស្រាយបំភ្លឺនៅប្រស្នាឈ្មោះមេកាព្យភុជង្គលីលានេះ។ មាតាបិតានាគ លោកចង់ប្រាប់ឲ្យកូននាគប្រុសស្រី ចេះគិតពិចារណាឈ្វេងយល់ បើគាត់ជាអ្នកវារលូន(និមិត្តរូប) តើស្នាមដែលដឹតជាមក្នុងឈ្មោះកាព្យ លើថ្ម ដីដែលមានគ្រប់ទីកន្លែង ជាដានស្នាមរបស់អ្នកណា? នេះជាហេតុឬចម្លើយតែមួយគត់ ដែលយើងស្រាយនូវចម្ងល់ប្រស្នានេះ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងថា"**កម្លាំងអ្វីស្មើដោយកម្លាំងកម្ម គឺពុំមានឡើយ**" សូម្បីតែព្រះអង្គក៏ទទួលនូវវិបាករបស់កម្មដែរ ទោះបីជាព្រះអង្គជាព្រះសម្មាសម្ពុទ្ធក៏ដោយ ដូចជាអកុសលកម្មរបស់ព្រះអង្គ ត្រូវធ្វើទុក្ករកិរិយា ទេវទត្តទំលាក់ថ្ម ឲ្យត្រូវព្រះបាទពុះពងព្រះលោហិត ព្រះអង្គបរិនិព្វានក្នុងព្រះជន្ម៨០វស្សា....។ល។ ឯបុញ្ញកម្មឬកុសលកម្ម ដែលព្រះអង្គត្រូវទទួលវិបាកគឺត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណ ហើយចុងក្រោយគឺព្រះអង្គបរិនិព្វាន ដោយឧបាទិសេសនិព្វាន និងអនុបាទិសេសនិព្វាន....។

ការបកស្រាយពីន័យក្នុងមេកាព្យ យើងបានស្គាល់ពីម្ចាស់គំនិត ដែលបានបង្កើតមរតកមុនគេ ហើយលោកជាឬសគល់របស់ជាតិទាំងមូល។ ពេលនោះសំណេរថ្មី ដែលកើតបន្តខាងក្រោយត្រូវតែមានភាពរុងរោចន៍ ពេលយើងបានដឹងពីប្រវត្តិម្ចាស់មរតកនេះ បានបាត់ដានអស់រាប់ពាន់ឆ្នាំ ពេលនេះយើងជាកូននាគ ត្រូវសើរើឡើងវិញ ដើម្បីរកឲ្យឃើញនូវបេះដូង ខ្លឹម ប្រមាត់របស់ម្ចាស់មរតកអច្ឆរិយនេះ នោះទើបពន្លឺនៃពូជផ្កាយ អាចបញ្ចេញរស្មីជាថ្មីវិញបាន។ សូមមើលកំណាព្យខាងក្រោម:

<u>**បណ្តាំព្រះមេ ព្រះម៉ែមហានគរ**</u>(ភុជង្គលីលា = ព្រះនាងនាគធ្វើដំណើរ)

**១.នេះបទកំណាត់ចងជា ភុជង្គលីលា និទានរឿងស្រីៗ**

២.អ្នកឆកំណើតបុរី នគរស្ត្រី ឈ្មោះថាតូចមីម៉ែ។

៣.ដំណែលឆកើតហូរហែរ កាលដែលរូបម៉ែ នៅជាព្រះមេ។

៤.មានឈ្មោះបរិសុទ្ធបិតថេរ នាងនាគអ្នកថែ រក្សាទឹកដី។

៥.នគរឈ្មោសុទ្ធតែស្រី សុវណ្ណបុរី មេស្រីដឹកនាំ។

៦.រក្សាការពារថែទាំ លំបាកស៊ូទ្រាំ ព្រោះហេតុទឹកដី។

៧.ហេតុតែកម្មពីអតី ធ្វើឲ្យនាគស្រី ជាប់ក្នុងធ្លាក់ស្នេហ៏។

៨.បង្កើតជាពូជកេរម៉ែ(ក្មេរ)តំណាហូរហែរ តមកខាងក្រោយ។

៩.ម៉ែពុកហេតុតែបណ្ដោយ កម្មនាំឲ្យធ្លោយ ក្លាយជាអ្នកទោស។

១០.ចិត្តលោតបង្ខំជ្រុលហួស ចិត្តលោតនាំខុស ព្រោះហេតុតែលួច។

១១.លួចនោះមិនយកតិចតួច នាំចិត្តមុតស្រួច លួចស្ថានយក្សា។

១២.ចង់បានវត្ថុអស្ចារ្យ យកមករក្សា វង្សត្រៃបុរី។

១៣.ទុកកេរឲ្យក្មែរប្រុសស្រី ម៉ែឳជួបភ័យ ធ្លាក់ក្នុងអបាយ។

១៤.ចិត្តម៉ែហេតុតែនឹកស្ដាយ រូបម៉ែតាំងកាយ ព្រមទទួលជួស។

១៥.សុខចិត្តរែកទម្ងន់ទោស ពុកកូនទាំងអស់ ឲ្យគេសជាតិ។

១៦.ជាប់ទោសព្រាត់ប្រាសពីញាតិ តែចិត្តម៉ែឆ្លៀត ថែឱបរក្សា។

១៧.ក្មេរក្មែរមរតកអស្ចារ្យ វង្សព្រះមាតា មហានាគអតី។

១៨.វង្សក្សត្រគ្រប់គ្រងទឹកដី ព្រះម៉ែក្សត្រថ្លៃ វិសេសអស្ចារ្យ។

១៩.ទ្រាំទុក្ខបង្ហូរនេត្រា រងចាំបុត្រា ពេលណាទើបយល់។

២០.ចុងម៉ែកកើតចេញពីគល់ ឬមួយនិមល មិនយល់សាសនា។

២១.ហួបប្វាយដឹងគុណអ្នកណា ឬមួយកូនទ្វេ ដឹងគុណគ្រាប់ប្វាយ។

២២.ព្រះមេពិតគឺជាម្ដាយ សព្វថ្ងៃម៉ែក្លាយ ជាបីសាចពស់ (ឯកសារចិនជីវតាក្វាន់)។

២៣.ខ្លួនស្លាប់តែបុរីស់ ម៉ែបានសាបព្រោះ កេរមរតកទុក។

២៤.រងចាំមើលទៅថ្ងៃមុខ ពេលកូនសោយសុខ មាននឹកឃើញទេ។

២៥.អ្នកណាទុកមរកតកេរ កេរម៉ែកេរមេ (ក្មេរក្មេរ) ឲ្យកូនសព្វថ្ងៃ។

២៦.ចិត្តម៉ែរងចាំបុត្រថ្លៃ ឈឺចាប់ពើតក្រៃ ព្រោះកូនពុំឆ្លាក់។

២៧.ពួកកូនជាប់ជុងអន្ទាក់ មនោគមរ៉ុស្រាក់ ព័ន្ធជុំគល់ធ្លក។

២៨.ពេលណាទើបកូនពន្លកកើតឆ្នែកចេញមក មើលឃើញសាសនា។

២៩.បណ្ដាំម៉ែក្នុងសិលា កូនពិចារណា មានសុទ្ធតែនាគ។

៣០.ក្នុងក្រៅស្ថិតគ្រប់ឆ្មមិតាគ ដែនដីមេនាគ ពីអតីតា។

៣១.នាមប្រាង្គតួអង្គសាសនា ឆ្មមិស្រុកប្រពៃណី សុទ្ធតែរឿងម៉ែ។

៣២.កូនគិតតាមគំណាខ្សែ កូននឹងឃើញម៉ែ រងទុក្ខម្នាក់ឯង។

៣៣.ម៉ែខំសាបព្រោះរួចបែង ព្រោះម៉ែខ្លាចក្រែង កូនម៉ែពុំដឹង។

៣៤.អកុសលធ្វើឲ្យស្លាក់ដឹង កូនម៉ែឈប់ទ្រឹង គ្មានដឹងអ្វីសោះ។

៣៥.ម៉ែនឹកឃើញស្ដាយស្រណោះ ឆ្មមិម៉ែនៅរស់ តែរឿងម៉ែស្លាប់។

៣៦.កូនហ្នើយចូរកូនសណ្ដាប់ ម៉ែនឹងរ៉ាយរាប់ ពីសាសនាម៉ែ។

៣៧.ឲ្យកូនឃើញគំណាខ្សែ ពូជពង្សព្រះម៉ែ ព្រះនាងនាគក្សត្រ។

៣៨.រឿងម៉ែត្រូវសាត់ឃ្លាត់ បរទេសកិចាត់ បំផ្លាញបណ្តាំៗ

៣៩.មរតកខ្មាំខ្មេចប្រេះស្រាំ ព្រោះហេតុតែកម្ម ផ្តល់ពីបុព្វេៗ

៤០.ធ្លាក់ឡើងបុត្រពូជព្រះមេ នាំគ្នាខំថែ មរតកព្រះរស់ៗ

៤១.ម៉ែកូនអាចឆ្លងផុតគ្រោះ ម៉ែបីសាចពស់ ក្លាយជានាគពិតៗ

៤២.រក្សាដែនដីពិសិដ្ឋ ថ្លៃថ្លាស្មេរស្និត អនាគតយូរលង់ៗ

៤៣.នេះបទលើលាតុជង្គ ម៉ែប្រាប់ទម្រង់ សាវតាម៉ែក្សត្រៗ

៤៤.កុំឲ្យបទឃ្លាតឆ្ងាយឃ្លាត់ ៖ខ្សែវង្សក្សត្រ អ្នកកើតទឹកដីៗ

៤៥.រឿងពិតគឺម្ចាស់ក្សត្រី នាមនាគថ្លាថ្លៃ ដំណើរទៅមុខៗ

៤៦.វាលូននាំរឿងក្នុងទុក្ខ ដើម្បីកូនសុខ សោយក្នុងសុខាៗ

៤៧.បេះដូងកូនមានទេវតា ដែនដីសួគ៌ា ប្រស្នាជ័យហោងៗ

៤៨.កតញ្ញូនាំសុខចម្បង ប្បារមីចម្លង ដល់ដែនអមតៈៗ

ថ្ងៃពុធ ១៥ រោច ខែពិសាខ ឆ្នាំថោះត្រីស័ក ព.ស ២៥៥៥ ថ្ងៃទី១ ខែមិថុនា គ.ស ២០១១

រៀបរៀងនិងចងក្រងដោយឧបាសក **គៀត ចាន់ធុន**

## <u>ចំណងដៃឆ្នាំថ្មី</u> (ទំនួញព្រះម៉ែមហានគរ)

១.ភ្នកើតទុកកេរក្នុងដែនដី ប្រាប់រឿងស្ត្រីអ្នកប្រសូត

ខ្ចខុសខខះរឿងវីងស្ងួត ភ្គគាំងវីប្បូតស្ដីមិនរួចៗ

២.ឃ្ស្យឃុំអ្នកកកើតហេតុកម្ម ក្សត្រីដេកចាំចិត្តព្រឺព្រួច

ខ្វងោកទៅក្រោមព្រោះកម្មល្បួច ច្ឆចាប់ចងគួចព្រោះអទិន្នា ៗ

៣.ឆ្លួឆេះឈើចាប់តសន្តាន ជ្វជាប់លិអានទុក្ខពុំជា

ឈ្ល្យឈឹងជាថ្នូតជាប់គ្នា ញ្ញញាតិអ្នកងារតមកក្រោយ ៗ

៤.ដ្ឋដេកពើតចុកតែម្នាក់ឯង ឋ្ឋឋានសំដែងទីបង្ហើយ

ឌ្ឍឌូតតរឿងជាប់កៀកកើយ ឍ្ល្យឍរាលចម្លើយក្នុងប្រស្នា ៗ

៥.ណ្ឋណែនាំប្រាប់រឿងកំបាំង ត្តតែងចំណាំងក្នុងតម្រា

ថ្លថែតម្រុយរឿងមាតា ទ្ធទៅមូរខារសរសៃសូត្រ ៗ

៦.ធ្ឆធៀបស្វែងរកអ្នកប្រមូល ន្ឋនាំត្រកូលអ្នកប្រសូត

ប្សបាខំបីត្រកងពូត ផ្ឋផ្សែផ្សំពួតបានជាភ្លើង ៗ

៧.ព្ឋពឹតខិតខំផ្គុំក្រៀកចង ភ្នភ្នែករៀបក្រងបង្ហោះឡើង

ម្ហមិនទំនេរទាញឲ្យថ្កើង យ្សយកមេឡើងកាន់វេហា ៗ

៨.រ្វរើរូតរះរួចរិះគិត ល្លលើកគំនិតព្រះមាតា

វ្វវេនវាល្បួនដោះប្រស្នា ស្សសូត្រសាសនាបណ្ដាំម៉ែ ៗ

៩.ហ្ហហាមិនរួចតែនៅខំ ឡ្សឡើងទៅផ្គុំរឿងព្រះមេ

អ្នឱនទទួលមរតកម៉ែ ស្គាល់កាលបុព្វេទើបបានសុខ

កំណាព្យប្រស្នានេះចងក្រងរួចនៅថ្ងៃសុក្រ ១២កើត ខែចេត្រព.ស២៥៥៤ ត្រូវនឹងថ្ងៃ១៥ខែមេសាគ.ស២០១១

ដោយខុបាសក **គៀត ចាន់ថុន**

## <u>**បណ្តាំព្រះម៉ែមហានគរ**</u>

១.**ក្ន**កើតកេរទុកក្នុងដែនដី ព្រះម៉ែពូជជ័យអ្នកប្រសូត

**ខ្វ**ម៉ែម្ចាស់ជាតិឲ្យរឹងស្អូត **ក្ត**គាំងរឹបត្រូតស្តីមិនរួចៗ

២.**ឃ្យ**ឃុំអ្នកកកើតព្រោះកម្ម ក្សត្រីដេកចាំចិត្តឈឺព្រួច

**ខ្វ**ដោកចងខ្លួនព្រោះកម្មល្អួច **ច្ច**ចាប់ព្រោះល្អួចរួមគ្និគ្នាៗ

៣.**ន្ធ**នាំឲ្យឆេះតសន្តាន **ជ្វ**ជាប់លំអានជាអ្នកងារ

**ឈ្ល្យ**ក្លាយជាថ្នតជាប់គ្នា **ញ្ញ**ញាតិមានពៀរតមកក្រោយៗ

៤.**ដ្ត**ដេកឈឺចាប់តែម្នាក់ឯង **ឋ្ឋ**ប្រាប់កន្លែងទីបង្ហើយ

**ខ្ឋ**ខ្ទូតពូតរឿងជាប់កៀកខ្នើយ **ឍ្ល្យ**ឈាលចម្លើយដោះប្រស្នាៗ

៥.**ណ្ឌ**និយាយប្រាប់រឿងកំបាំង **ត្ត**ខ្សែចំណាំងក្នុងតម្រា

**ថ្ល**ធ្លាប់ប្រវត្តិរឿងមាតា **ទ្ធ**រកសាវតាសរសៃស្នូត្រៗ

៦.**ធ្ធ**ផ្តើមស្វែងរកអ្នកប្រមូល **ន្ត**នាំត្រកូលអ្នកប្រសូត

**ឬ**ខំបីពត្រកងត្រួត **ផ្ទ**ស្រាយពាក្យត្រួតបានជារឿងៗ

៧.**ព្ក**គិតខិតខំផ្ដុំក្រៀកចង **ភ្ន**រែករៀបក្រងបង្ហាះឡើង

**ម្វ**ខំទាញម៉ែឲ្យបានថ្លើង **យ្យ**នាំមេឡើងកាន់វេហាៗ

៨.**ទ្រ**ប្រឹងរូតរះផ្ដុំគំនិត **ល្អ**បើករឿងពិតព្រះមាតា

**ឡ**វាលូននាំព្រះសាសនា **សូ**ដោះប្រស្នាបណ្ដាំម៉ែៗ

៩.**ហ្ន**ស្ដីមិនរួចតែនៅខំ **ឡ**ប្រឹងពូតផ្ដុំរឿងព្រះមេ

**អ្ន**អស់កម្មចាស់របស់ម៉ែ ស្គាល់គុណាបុព្វេទើបបានសុខៗ

កំណាព្យប្រស្នានេះចងក្រងរួចនៅថ្ងៃច័ន្ទ ១២កើត ខែទុតិយសាឍពុ.ស២៥៥៦ ត្រូវនឹងថ្ងៃ៣០ខែកក្កដា គ.ស២០១២

ដោយខុបាសក **គៀត ចាន់ផុន**

**<u>បណ្ដាំម៉ែ</u>**

១.កេរមេ កេរម៉ែ(ក្មេរក្មែរ)ខ្មែរតែមួយ ពូជអ្នកលើកស្ទួយមរតកថ្ម

កម្មកាចកម្មេចខ្សែតំណា ពូជពង្សដែលល្អត្រាំគំរង់ៗ

២.ហេតុអ្វីក៏កូនមាសពន្លក មិនត្រិះរិះរកមើលទម្រង់

រូបរាងម៉ែពិតល្អផូរផង់ អ្នក**ឆ**ពូជពង្សវង្សអច្ឆរិៗ

៣.ហេតុអ្វីកូនម៉ែបែរមិនជឿ មិនមានជំនឿលើសិរី(សិរី៣ប្រការ ឬស្រី៣ប្រការ)

ដែលជាអ្នក**ឆ**កើតទឹកដី រូបម៉ែសព្វថ្ងៃត្រូវខ្ទេចកាយ(ឈ្មោះនំប៉ែនចុកឬនំបញ្ចុក)ៗ

៤.ព្រះមេត្រូវខ្ទេចទៅជាម្សៅ តំណវង្សផៅជ្រុះមិនស្ដាយ

មិនដឹងព្រះមេតាងឲ្យម្ដាយ ព្រោះកាយម៉ែក្លាយខ្ទេចសាកសពៗ

៥.ឬាយក្លាយជាម្សៅរឿងត្រូវស្លាប់ ចិត្តម៉ែក្រសោបឬមប្រសព្វ

ជាមួយនឹងបុត្រមិនកំសត់ ទោះមានឬអត់ក៏តាមថែៗ

៦.នេះជាសារជាតិនៃស្ត្រីពិត ទឹកដក់ក្នុងចិត្តឈ្មោះថាម៉ែ

មិនបោះបង់កូនតជាខ្សែ កេរមេ កេរម៉ែ(ក្មេរក្មែរ)ទ្រព្យព្រះរស់(មាតុទ្ធមិ)។

រៀបរៀងដោយខុបាសក **គៀត ចាន់ថុន**

ថ្ងៃអង្គារ ទី១៨កើត ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស ២៥៥៥
គ.ស ២០១១

## ទំនួញ ដ្គ ត្គ

**១.ដ្គ**ដើរដេកដួលឈើចាប់ពើត ព្រោះហេតុកកើតទ្រពទុកកេរ

ភ្លេចការឈើចាប់តាំងជាម៉ែ **ត្គ**ថែតំណមរតកទុក។

**២.**ចែកឲ្យកូនក្មែរជំនាន់ក្រោយ សេពសោយមរតកម៉ែគ្រប់មុខ

ម៉ែរងឈឺចាប់ត្រាំក្នុងទុក្ខ **ដ្គ**ឈើពើតចុក**ត្គ**មកក្រោយ។

**៣.**បើកូនម៉ែស្គាល់ពាក្យថា**អរ**(ររ) **ដ្គត្គ**ត្រាច់ចរចេញបង្ហើយ

កូននិងជួបសុខព្រោះដល់ត្រើយ ម៉ែបានចម្លើយក្នុងសុគតិ។

រៀបរៀងដោយខុបាសក **គៀត ចាន់ថុន**

## បណ្តាំធនជ័យ

១.បណ្តាំធនជ័យ ប្រាប់កូនប្រុសស្រី ឲ្យប្រឹងលើកស្ទួយ

មរតកព្រះម៉ែ ដែលមានតែមួយ បណ្ឌិតលោកព្រួយ

ខ្លាចកូនហៃអើ(ហៃអើៗធនធានជ័យធ្លាក់ទឹក)។

២.បើកូនបែរដឹង វត្តរះខំប្រឹង គិតឆ្ងល់សើរើ

នូវមរតកចាស់ ដូនតាបានធ្វើ ចារចាំងទុកលើ

ផ្ទាំងថ្មប្រាសាទៗ

៣.ប្រាង្គរាប់រយពាន់ គាត់បានបំផ្លិន លាក់ទុកតាមខ្នាត

ខ្លាចអ្នកខាងក្រៅ(បរទេស) មកដាប់សម្អាត ឲ្យរៀបដល់បាត

ទ្រព្យកេរព្រះម៉ែៗ

៤.ទោះខ្លួនជាប់គុក កាយចិត្តពុំសុខ ខំប្រវាំថៃ

លួចបង្ហោះខ្លែង តាងឲ្យកេរម៉ែ បន្តវង្សក្មែរ

ពូជពង្សសិលាៗ

៥.ដង្ហើមចុងក្រោយ ពុំបានព្រងើយ មុននឹងមរណា

ហៅស្ដេចមកផ្ដាំ ប្រាប់ក្បួនតម្រា ក្នុងការរក្សា

កេរតំណែលម៉ែៗ

ថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥

រៀបរៀងដោយឧបាសក **គៀត ចាន់ធុន**

## <u>គុកដាក់ធនជ័យ</u>

១.គុកមួយគុកពីរគុកបី គុកមួយក្រុងស្រី (សត្វត្រី) ក្នុងអង្រុត

ឃុំឃាំងឲ្យជាប់ឃាមគត់មត់ បំបែររឿងពិតតែន័យផ្សេងៗ

២.គុកពីរឃុំក្រុងព្រះនគរ ប្រជារីករាវព្រោះ ម៉េងឆេង

មនោគមសណ្ដាំរួចបំប្លែង ឲ្យសត្វវង្វេងភ្លេចកំណើតៗ

៣.គុកបីដាក់ស្ត្រីដែលជាន្ទិ ដាក់ឃុំក្នុងរូងព្រោះខ្លាចកើត

ពូជពង្សអ្នក**ភ**ដែនល្អឆើត កុំឲ្យកកើតជាថ្មីវិញ ។

(នេះជាប្រស្នាអ្នកប្រាជ្ញចិនមកយកនគរ) គុកនេះធនជ័យអាចចេញមកបង្ហោះខ្លែងបាន ។

ខ្លែងឯក =>**ខ**លែងឯក =>ឯក = ឯនិងក <=>អរនិងកែ បើយើងព្រមកែនិងជួបអរ ។(ប្រស្នាខ្លែងឯក)

អង្កាម =>អ ង កាម =>អ ងចុះទៅរកកាមគុណាគឺរូប សម្លេង ក្លិន រស ផោដ្ឋព្វ ។

អង្ករ =>អរ ឯក ពូជជ័យខាងក្រោយមិនព្រមអរទៅរកកឡើយ គឺអរតែសំបក (ប្រស្នាសាបអង្កាម) ។

រៀបរៀងដោយខូបាសក **គៀត ចាន់ផុន**

## <u>II.អំពីព្យញ្ជនៈខ្មែរទាំង៣៣តួបង្កប់ក្នុងន័យបណ្ដាំមាតាមហានគរ</u>

*ព្យញ្ជនៈខ្មែរមាន៣៣តួ ដែលផ្ដើមដោយព្យញ្ជនៈ**ក** និងបញ្ចប់ទៅវិញដោយព្យញ្ជនៈ**អ** មានន័យថា បើយើងមិនស្គាល់**ក** គឺយើងមិនអាចស្គាល់**អ**បានឡើយ។ ព្យញ្ជនៈបើចែកជាវគ្គឬសង្កាត់មាន៦វគ្គ ៥វគ្គខាងដើមក្នុង១វគ្គ មានអក្សរ៥តួ ចំណែកឯវគ្គទី៦ មានអក្សរ៨តួ រួមសរុបទាំងអស់ត្រូវជា ៣៣តួ។*

### <u>ពន្យល់ពាក្យ</u>

***ព្យញ្ជនៈ****ព្យញ្ជ-ជៈនៈបា.; សំ. ( ន. ) (ព្យញ្ជន; វ្យញ្ជន) តួអក្សរដែលសម្រាប់ផ្សំជាមួយនឹងស្រៈ, លុះតែមានស្រៈផ្សំផង ទើបកើតច្បាស់ប្រាកដជាពាក្យសម្ដីឡើងបាន។ ព្យញ្ជនៈសម្រាប់ប្រើក្នុងភាសាខ្មែរ ក្នុងសម័យសព្វថ្ងៃនេះមាន៣៣តួ (ស្មើគ្នានឹងព្យញ្ជនៈខាងភាសាបាលីដែរ) គឺកខគឃង, ចឆជឈញ, ដឋឌឍណ, តថទធន, បផពភម; យរលវសហឡអ; កាលពីក្នុងសម័យបុរាណខ្មែរប្រើព្យញ្ជនៈ៣៥តួព្រោះមានគមពីរតួនេះផងសម្រាប់ប្រើខាងភាសាសំស្ក្រឹត, រៀងរបៀបត្រង់ចន្លោះវនិងស (វឝឞស), ប៉ុន្តែលើកលែងប្រើយូរហើយ, ត្រង់ពាក្យណាដែលត្រូវប្រើឝបដូចជាបឝ្ចិម, បឞ្ឞជាដើមនោះប្រើតែសមួយនេះជាជំនួសជាបស្ចិម, ព្រះឱស្ឋដូច្នេះវិញ (សរសេរជាព្យញ្ជនក៏បាន) ។(ដកចេញពីវចនានុក្រមសម្ដេច)*

***ព្យញ្ជនៈ***( ន. ) (ព្យញ្ជន; វ្យញ្ជន) ម្ហូបក្រៅពីសម្លទឹកគឺម្ហូបក្រៀម, ម្ហូបគោក, ម្ហូបខាប់, ឬទឹកត្រី, ទឹកគ្រឿង, អន្លក់ជាដើមហៅព្យញ្ជនាហារ (ព្យ័ញ្ជ-ជៈនាហា) ក៏បាន។ម. ព. សូបៈ និង សម្ល ផង។(ដកចេញពីវចនានុក្រមសម្តេច)

***ព្យញ្ជនៈ***បា. ឧត្តរិភង្គឈ្មោះម្ហូបគោកមួយប្រភេទក្នុងវិ. ពុ. ថាជាព្យញ្ជនៈដែរប្រហែលជាប្រហិត ? (ដកចេញពីវចនានុក្រមសម្តេច)

បើតាមការបកស្រាយពន្យល់ខាងលើ ន័យទីមួយគឺតួអក្សរ ចំណែកឯន័យទីពីរគឺឈ្មោះម្ហូបអាហារ តើព្យញ្ជនៈក្មែរមានន័យបង្កប់ខាងក្នុងអ្វីខ្លះ? ខ្ញុំបាទសុំធ្វើការស្រាយបំភ្លឺ តាមការយល់ដឹងពីន័យ ដែលមានបង្កប់ក្នុងព្យញ្ជនៈទាំង៣៣តួនេះ ក្នុងបណ្តាំដូនតាមហានគរក្មែរ។

**<u>ក.វគ្គទី១</u>**( មានតួអក្សរ៥តួគឺ **ក ខ គ ឃ ង**)

**<u>១.អំពីតួអក្សរ( ក )</u>** (ព្យញ្ជនៈទី១ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**ក** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**<u>ពន្យល់ពាក្យ</u>**

**ក**( ន. ) អវយវៈដែលតពីក្បាលទៅស្មា ឬទៅខ្លួននៃមនុស្សសត្វ។ ដៃជើងមនុស្សក៏មានកដែរៈ កដៃ, កជើង។ ទងខាងដើមក្បួរស្រូវក៏ហៅកដែរ : កស្រូវ។កន្លែងដែលតជាប់ពីមាត់ដប ជាដើមចុះទៅទល់នឹងក្អេងក៏ហៅកដែរ : កដប, កក្អម។(ដកចេញពីវចនានុក្រមសម្តេច)

**ក** ( កិ. ) តាំងផ្តើម, តាំងធ្វើ : កសាង, កកើត, កចេតិយ, កភូមិ។(ដកចេញពីវចនានុក្រមសម្តេច)

**ក៏**( និ. ) ពាក្យជាសន្ធានមានសំឡេងកញ្ជាក់ខ្លី សម្រាប់និយាយតប្រយោគដោយឡែក : អ្នកក៏ទៅ,ខ្ញុំក៏ទៅ, ធ្វើដូច្នេះក៏បាន, របស់នេះរូបក៏ល្អ តម្លៃក៏ថោក។ (ដកចេញពីវចនានុក្រមសម្តេច)

**ករ**បា. ( ន. ) ដៃ : លើកករប្រណម្យ។ (ដកចេញពីវចនានុក្រមសម្តេច)

សូរដូចក្នុងន័យបង្កប់ព្យញ្ជនៈ**ក**ខាងលើ បានពន្យល់បង្ហាញប្រាប់យើងថា តួអក្សរ**ក**នេះបង្កើតខ្លួនឯងផង បង្កើតព្យញ្ជនៈទាំង៣២ពីក្រោយខ្លួនទៀតផង មានន័យថាបើគ្មានព្យញ្ជនៈ**ក** ក៏គ្មានព្យញ្ជនៈ**អ**ខាងចុងឡើយ។ នេះជាហេតុដែលដូនតាក្មែរ បានយកព្យញ្ជនៈដំបូងនេះ បង្កើតជាពាក្យសម្គាល់ជាតិមួយ មានឈ្មោះថា ពូជក្មេរ(កេរមេ) ឬក្មែរ(កេរម៉ែ) ដែលមានព្យញ្ជនៈ**ក**ជាបេះដូង ជាពាក្យសម្រាប់សម្គាល់ជាតិនេះ។ តើន័យពិតរបស់ពាក្យក្មែរ កើតឡើងដោយសារហេតុអ្វី? ពីដំបូងយើងហៅម៉ែថា**មាតា** ភាសានិយាយបានក្លាយជា**ម្តា ម្តា**គាត់បានចាស់យាត្រូវថែម**យ** ក៏ក្លាយជា**ម្តាយ ម្តាយ**កាន់តែចាស់យា បានក្លាយជា**យាយ** ព្រោះហេតុតែយាឆ្ងាយដោយចាស់យូរ យាយកាន់តែយា

យូរគាត់មានចៅបន្តគ្នា យើងហៅថា**យាយតួត**មកពីពាក្យត្រួតលើគ្នា **យាយត្រួត**លើគ្នាច្រើនដង បានយាក្លាយជា**យាយលួត** មានន័យថាចៅលែងចង់ទទួលស្គាល់គ្នា ចុងបញ្ចប់គឺ**យាយលា** មានន័យថាឈាមជ័រពូជពង្សត្រកូល តគ្នាលែងជាប់ហើយ គឺកូនចៅជំនាន់ក្រោយ លែងទទួលស្គាល់នឹងរាប់អានគ្នា។ នេះជាហេតុដែលម្ចាស់មរតកអច្ឆរិយ លោកត្រូវបង្កើតពាក្យសម្រាប់សម្គាល់ជាតិមួយ ដែលកូននាគជំនាន់ក្រោយ ទទួលមរតកគាត់រួមគ្នា គឺជាតិ**ខ្មែរ**(កេរម៉ែ)។ ទោះបីជាតំណាខាងក្រោយ ត្រូវផ្លាស់ប្ដូរត្រកូល ផ្សេងៗគ្នាយ៉ាងណាក៏ដោយ កូននាគទាំងនោះត្រូវប្រសូត ចេញពីទ្វារមាសគឺមាតុភូមិនេះ អ្នកនឹងបានទ្រព្យសម្បត្តិពីម៉ែគ្រប់ៗគ្នា គឺកេរមរតកម៉ែ(ខ្មែរ)។ បើអ្នកពុំបានប្រសូតចេញពីទ្វារមាសគឺមាតុភូមិនេះទេ តើអ្នកបានមរតកអច្ឆរិយនេះ មកពីណា? ក្នុងបណ្ដាមរតកអច្ឆរិយទាំងនេះ មានមរតកដ៏អស្ចារ្យមួយ គឺព្រះពុទ្ធសាសនា ជាសារបណ្ដាំរបស់មេនាគទីបី ដែលអាចដឹកនាំ អ្នកទទួលមរតកម៉ែទាំងឡាយ ឲ្យចេញចាកបានពីសេចក្ដីទុក្ខ ឆ្លងដល់ត្រើយអមតសុខ គឺព្រះនិព្វាន្ត។ ព្រះពុទ្ធសាសនាអាចមក ប្រតិស្ឋានក្នុងមាតុភូមិនេះបាន បើមេនាគទីពីរ ពុំអនុញ្ញាតិទទួលយកមកទុកជាមរតកទេ ធ្វើដូចម្ដេចប្រជាជនខ្មែរ អាចមានព្រះពុទ្ធសាសនា សម្រាប់គោរពប្រតិបត្តិបូជា រហូតមកដល់សព្វថ្ងៃ? នេះជាអត្ថន័យពិតដែលបានបង្កប់ ក្នុងព្យញ្ជនៈ**ក**ជាព្យញ្ជនៈទី១ ដែលមានន័យដ៏អស្ចារ្យ ដោយដូនតាបានបង្កប់ក្នុងបេះដូងពាក្យ សម្រាប់សម្គាល់ជាតិខ្មែរនេះ បើកូនខ្មែរពុំស្គាល់អ្នក**ក**គឺម៉ែទេ កូននាគមិនអាចស្គាល់ពាក្យឬព្យញ្ជនៈ**អ**បានឡើយ។ នេះជាអត្ថន័យពិត ដែលបានបង្កប់លាក់ទុកក្នុងព្យញ្ជនៈ**ក** ដោយពុំទាន់លាយពណ៌នៅក្នុងភាសាបាលី ឬសំស្ក្រិត ព្រោះវាជាន័យត្រង់របស់ភាសាខ្មែរ ដែលកើតចេញពីព្យញ្ជនៈដំបូងគឺ**ក។**

**២.អំពីតួអក្សរ(ខ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**ខ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ខ**)

**ខ** ( កិ. ) ចម្អិនម្ហូបដែលហៅខ : ខត្រី, ខសាច់។(ដកចេញពីវចនានុក្រមសម្ដេច)

**ខ** ( ន. ) ត្រីឬសាច់ដែលចម្អិនដោយមានគ្រឿងផ្សេងៗលាយផ្សំផង, ជាម្ហូបមានទឹកទីទៃពីសម្លនិងត្រីស្ងោរ : ត្រីខ, ជ្រូកខ។(ដកចេញពីវចនានុក្រមសម្ដេច)

**ខ**( ន. ) ឈ្មោះដាវដងវែងមានង្វៀងនៅខ្នង : ដាវខ។(ដកចេញពីវចនានុក្រមសម្ដេច)

**ខ** ( ន. ) ប្រការ, ចំពូក, មាត្រា, បទ, ន័យ, សេចក្ដីស្រង់រួមចំនួនខ្លីៗ : ខ១, ខ២, ខ៣។(ដកចេញពីវចនានុក្រមសម្ដេច)

**ខរ**សំ. បា. (ន.) ("សត្វលា; រណារ"; គុ. កាច, រឹងរូស) ឈ្មោះយក្សមួយក្នុងរឿងរាមកេរ្តិ៍។(ដកចេញពីវចនានុក្រមសម្ដេច)

ហេតុអ្វីបានជាព្យញ្ជនៈ**ខ**ត្រូវនៅក្នុងលំដាប់ទីពីរ? សព្វថ្ងៃពាក្យសម្រាប់សម្គាល់ជាតិសាសន៍នេះ យើងសរសេរជាទូទៅ គឺ**ខ្មែរ** = **ខេមរៈ**

**ពន្យល់ពាក្យ**

**ខេមរៈ**ខេម៉ៈរ៉ៈ (ន.) **ខ្មែរ**; (ពាក្យនេះ**មានទំនង**ជាបាលីភាសាដែលប្រែថា "មនុស្សមានសេចក្ដីក្សេម" មកអំពីវិគ្គហៈថា "ខេមំយស្សអត្ថីតិខេមរោ" ឬជាពហុវចនៈថា "ខេមំយេសមត្ថីតិខេមរា"; **ប៉ុន្តែនឹងពោលឲ្យប្រាកដ**ថាបានជាហៅ "ខេមរៈៗ" នោះពីព្រោះប្រែថាមានសេចក្ដីក្សេមដូច្នេះក៏**អាចដឹងប្រាកដពុំបាន** ព្រោះក្នុងសិលាចារឹកបុរាណសរសេរ "**ក្មែរ**" ក៏មាន។ (ដកចេញពីវចនានុក្រមសម្ដេច)

បើយើងមើលការពន្យល់ពាក្យខ្មែរ របស់អ្នកប្រាជ្ញខាងលើ គឺព្រះអង្គពុំទាន់ហ៊ានអះអាងថាពាក្យខ្មែរនេះត្រឹមត្រូវដាច់ខាតនូវឡើយទេ ព្រោះព្រះអង្គប្រើពាក្យថា**ទំនង**ក្នុងឃ្លាទី១ ឃ្លាទី២ព្រះអង្គបានប្រាប់ថា**ដឹងប្រាកដពុំបាន** ព្រោះក្នុងសិលាចារឹកគេសរសេរពាក្យក្មែរ ម្យ៉ាងទៀតអ្នកប្រាជ្ញជំនាន់ព្រះអង្គ សុទ្ធតែប្រសូតក្រោយសិលាចារឹក។ ដោយសម្អាងទៅលើការពន្យល់ពាក្យខ្មែរ = ខេមរៈខាងលើ អ្នកប្រាជ្ញរាជបណ្ឌិតសម័យមុន លោកពុំបានបិទច្រកទ្វារគំនិតត្រិះរិះពិចារណា សម្រាប់អ្នកជំនាន់ក្រោយឡើយ គឺលោកទុកឲ្យកូនក្មែរខាងក្រោយ រាវរកស្រាវជ្រាវស្វែងរកន័យពិត របស់ពាក្យសម្គាល់ឈ្មោះជនជាតិនេះ។ ពាក្យសម្រាប់សម្គាល់ឲ្យជនជាតិមួយ បើយើងបែរជាយកភាសាបាលី គឺជាភាសាអ្នកដែនមគធៈពីបុរាណ សព្វថ្ងៃគឺប្រទេសឥណ្ឌា មកសម្គាល់ឲ្យជាតិយ៉ាងនេះ តើត្រឹមត្រូវដែរឬទេ? បើយើងខ្ចីពាក្យគេយកមកប្រើសម្គាល់ជាតិ តើជាតិយើងជាឥណ្ឌាទីពីរឬ? ឬមួយក៏ខ្មែរយើងជាជនជាតិភាគតិច របស់ឥណ្ឌាពីបុរាណ? តើពាក្យខ្មែរនេះ បើបកតាមន័យរបស់ពាក្យ ជាភាសាខ្មែរ ដោយកុំឲ្យលាយឡំ ជាមួយភាសាបាលី តើមានន័យដូចម្ដេច?

**ខ្មែរ** = **ខ** + **ម៉ែ** + **រ** មានន័យថាម៉ែ ដែលជាអ្នកបង្កើតនគរអច្ឆរិយនេះ ត្រូវគេ**ខ**ជាប់បាត់ទៅហើយ ព្រោះហេតុអ្វី? **ខ**គឺឈ្មោះម្ហូបម្យ៉ាង ដែលគេត្រូវយកស្ករ ទៅធ្វើឲ្យជាតាំងម៉ៃសិន ទើបគេបង់គ្រឿងផ្សំផ្សេងៗ នឹងសាច់ចូលទៅ។ នៅក្នុងមុខម្ហូបនេះ មានឈ្មោះស្ករតាំងម៉ៃ ដែលខ្ញុំបាទពន្យល់រួចហើយ(ភាគ១) គឺមានន័យថាតាំងខ្លួនជាម៉ែគេ ត្រូវផ្អែមល្វីងស្អិត តែពណ៌ខាងក្រៅត្រូវក្រម៉ៅ ពណ៌ក្រម៉ៅនេះហើយជានិមិត្តរូប ដែលត្រូវរារាំងពួកគាត់ ឲ្យជាប់ក្នុងអបាយភូមិ ព្រោះហេតុតែកូនពួកគាត់គ្មាន គុណធម៌ថ្នាក់ទីមួយគឺសីល។ ចុះចំណែកព្យញ្ជនៈ**រ** ដែលនៅពីខាងក្រោយ ន័យរបស់វាបាន និយាយប្រាប់ឲ្យកូន**រ** ព្រោះភាសានិយាយ**រក៏** = **រក** អ្នកចាប់ម៉ែ**ខ**រម្ងាស់ឲ្យរលួយ បាត់រូបរាងម្ចាស់ដើម (សូមមើលអត្ថន័យប្រាសាទហាន់ជ័យ នំប៉ែនចុក សរសៃសូត្រ.... ភាគមុន)។ ន័យត្រង់ព្យញ្ជនៈ**ខ**រម្ងាស់ឲ្យរលួយអ្នក**ក** គឺមិនអាចឲ្យស្គាល់អ្នក**ក**បានឡើយ បើក្មែរស្គាល់ពាក្យសម្គាល់ជាតិ

ត្រឹម**ខ** ធ្វើដូចម្ដេចអាចស្គាល់**អ**(**អរ**)បាន? នៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញលោកបានទុកប្រស្នាប្រាប់យើងថា គាត់ជាប់នៅក្នុងគុក គាត់អាចលួចបង្ហោះខ្លែងឯកបាន ទីបំផុតត្រូវចិនចុះចាញ់គាត់ជាលើកទីបី ដោយយល់ព្រមដោះលែងគាត់ ហើយឈប់មានមហិច្ឆតាមកឈ្លានពាននគរខ្មែរទៀត។ គុកដែលអាចចេញមក បង្ហោះខ្លែងបានជាគុកអ្វី? តើក្រដាសតែមួយសន្លឹក យកមកធ្វើខ្លែង ហេតុអ្វីបានជាចិនចុះចាញ់? តើពាក្យខ្លែងឯកមានន័យពិតដូចម្ដេច ទើបធ្វើឲ្យចិនចុះចាញ់គាត់នោះ?

គុកដែលធនជ័យអាចចេញមកបង្ហោះខ្លែងបាន គឺជាគុកមនោគមវិជ្ជា ព្រោះវាជាគុកឥតជញ្ជាំង ទើបគាត់អាចចេញមកបង្ហោះខ្លែងបាន។ ខ្លែងឯកបើយើងសម្រាយពាក្យនេះ យើងនឹងឃើញអត្ថន័យពិតរបស់វា គឺប្រាប់ពីឈ្មោះព្យញ្ជនៈ**ខ** លែងដើរតួជាទីមួយជំនួសព្យញ្ជនៈ**ក**។

**<u>ពន្យល់ពាក្យ</u>**

**ខ្លែងឯក** = **ខ** + **លែង** + **ឯក**បើយើងដកព្យញ្ជនៈ**ល** ចេញពីក្រោម**ខ**កុំឲ្យត្រួតគ្នា យើងឃើញពាក្យពន្យល់ប្រាប់ន័យថា **ខលែងឯក** បើ**ខ**លែងដើរជាតួឯក គឺមានតែ**ក**ជាតួឯក។ ឯពាក្យឯក គឺ**ឯនិងក** ទើបក្លាយជាពាក្យ**ឯក** បើយើងត្រឡប់ពាក្យ**ឯនិងក = អនិងកែ** មានន័យថា បើបើកូននាគព្រមកែ យើងនឹងស្គាល់**អ** បើពាក្យសម្គាល់ជាតិលែងប្រើព្យញ្ជនៈ**ខ** រួចកែមកប្រើព្យញ្ជនៈ**ក** ទើបយើងស្គាល់ព្យញ្ជនៈ**អ**។ នេះជាន័យពិតរបស់ពាក្យខ្លែងឯក ដែលធនជ័យលួចបង្ហោះធ្វើឲ្យចិនចុះចាញ់ ពុំមែនគ្រាន់តែក្រដាសមួយសន្លឹក ធ្វើឲ្យចិនចុះចាញ់នោះឡើយ បើងាយស្រួលដូច្នេះមែន កូនខ្មែរបង្ហោះខ្លែងឯករាល់ឆ្នាំ ចិនព្រមចាញ់ខ្មែរទៅហើយ។ ខ្លែងឯកដែលបង្ហោះនោះ វាជារឿងអាថ៌កំបាំងរបស់ពាក្យសម្រាប់សម្គាល់ជាតិមួយ ដែលត្រូវបានគាស់សើរើ យកមកគិតពិចារណាឡើងវិញតែប៉ុណ្ណោះ ព្រោះពាក្យ**ខ្មែរ**នេះ ត្រូវដេកលក់អស់**៣៤ឆ្នាំ** គឺពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ២០០៩។ ពួកកាន់អំណាចផ្ដាច់ការខ្មែរក្រហម បានកៀរប្រជាជនខ្មែររាប់លានអ្នក យកទៅធ្វើទារុណកម្មហើយសម្លាប់ នៅក្នុងបណ្ដាប្រជាជន ដែលត្រូវយកទៅសម្លាប់ទាំងនោះ មាននិស្សិតបញ្ញវន្តអ្នកប្រាជ្ញរាជ្យបណ្ឌិត ទាំងគ្រហស្ថនិងបព្វជិត ត្រូវពួកគេធ្វើបាបរួចសម្លាប់ចោល ស្ទើរតែទាំងអស់។ ក្រោយថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ អ្នកចេះដឹងដែលនូវសេសសល់ពីស្លាប់ អ្នកខ្លះត្រូវរត់គេចខ្លួនទៅនៅប្រទេសក្រៅ ចំណែកអ្នកនៅក្នុងស្រុក ត្រូវភ័យបាក់ស្បាតផ្លូវចិត្តពីរបបផ្ដាច់ការ លែងហ៊ានយកពាក្យខ្មែរនេះ មកបញ្ចេញមតិជជែកវែកញែក ដូចសម័យមុនទៀត។ មកដល់ឆ្នាំ២០០៩ខ្ញុំបាទបានគាស់ ពាក្យសម្គាល់ជាតិមួយម៉ាត់នេះ ដែលមាននៅក្នុងសិលាចារឹក ហើយបានត្រូវដេកលក់អស់ជាង៣០ឆ្នាំ មកគិតពិចារណាសើរើវែកញែកឡើងវិញ ដើម្បីរកឲ្យឃើញនូវន័យពិត របស់ពាក្យសម្គាល់ជាតិនេះ ដោយសង្ឃឹមថានឹងអាចរកឫសកែវពិត របស់ពាក្យសម្គាល់ជាតិអច្ឆរិយនេះ។

**<u>៣.អំពីតួអក្សរ(គ)</u>** (ព្យញ្ជនៈទី៣ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**គ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**គ**)

**គ**( គុ. ) ឥតសំដី : មនុស្សគ។បើលោហជាតិវិញថាឥតសូរ : ប្រាក់គ។(ដកចេញពីវចនានុក្រមសម្តេច)

**គ**( ន. ) ឈ្មោះឈើជាដំណាំផ្លែមានសរសៃជាប៉ុយសំឡីសម្រាប់ច្រកញាត់ខ្នើយ, កែប, ពូកជាដើម : ព្រះសម្ពុទ្ធទ្រង់បញ្ញត្តហាមមិនឲ្យភិក្ខុសាមណេរប្រើប្រាស់ពូកញាត់សំឡីគ, ទ្រង់អនុញ្ញាតឲ្យប្រើពូកញាត់ស្មៅ, ញាត់ជក់ដូងជាដើមបាន, ឯកែប, ខ្នើយឲ្យញាត់សំឡីគបាន ។ (ដកចេញពីវចនានុក្រមសម្តេច)

**គរ** ( កិ. ) ធ្វើឲ្យជាគំនរ។(ដកចេញពីវចនានុក្រមសម្តេច)

ហេតុអ្វីព្យញ្ជនៈ**គ**ទីពនេះ នៅក្រោយលំដាប់ព្យញ្ជនៈ**ខ**? ក្រោយពី**ខ**មែឲ្យបាត់រូបរាងដើម ហើយ រឿងរ៉ាវទាំងអស់ត្រូវភ្លេចភ្លាំង គគាំងនិយាយលែងចេញ ហេតុនេះគាត់ត្រូវប្រើភាសាសញ្ញា គឺភាសា**គ** តើភាសាសញ្ញា**គ**របស់ជាតិយើង សព្វថ្ងៃនៅឯណា?

– ទីមួយភាសា**គ**បង្កប់ទុកនៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញលោកបានប្រាប់ឲ្យយើងរៀនភាសាសញ្ញាគឺភាសាគ ដើម្បីទប់ទល់នឹងបរទេស(ចិន...) ដែលមានមហិច្ឆតាចង់មកដណ្តើមយកនគរខ្មែរ (មើលភាសាសញ្ញានៅក្នុងរឿងធនជ័យ)។

– ទីពីរភាសា**គ**បានបង្កប់លាក់ទុក ក្នុងរូបរឿងនិងក្បាច់ចម្លាក់ ដែលមាននៅលើជញ្ជាំងប្រាសាទរាប់ពាន់ ក្នុងទឹកដីនេះពីបុរាណ ដែលភាសា**គ**ទាំងនេះ បានបង្កប់នូវប្រវត្តិរឿង តាមរូបភាពចម្លាក់នៅលើជញ្ជាំង ផ្តែរ ក្បាំងក្លែង.....។ល។ នៅក្នុងខេត្តពោធិសាត់បច្ចុប្បន្ន មានស្រុកមួយឈ្មោះថាស្រុកក្រគ តើក្រគនេះក្រគសំឡីសម្រាប់ច្រកពូក ខ្នើយ ឬមួយក្រលែងនិយាយបាន? ដំបងគ្រញូងបានជ្រែករាជ្យ ដណ្តើមយករាជ្យបានក្នុងសម័យអង្គរ ក្រោយពីបានគ្រប់គ្រងទឹកដីមហានគរទាំងមូល ពួកគេបានវាយធ្វើបាបកូនខ្មែរ ឲ្យស៊ីផ្លែដំបងបន្តគ្នា (មើលបទសារិកាកែវភាគ១) វាយរហូតដល់កូនខ្មែររត់ចោលទីក្រុងអង្គរ ឲ្យភ្លេចដើមកំណើតខ្លួន ថាជាពូជថ្មពូជនាគពូជផ្កាយពូជអច្ឆរាអស់ជាង១០០ ឆ្នាំ តើគួរឲ្យអាសូរដែរឬទេ? ដែលជាតិមួយធ្លាប់ថ្កុំថ្កើងរុងរឿង លេចធ្លោឡើងពីអតីតកាលនោះ។ ចុងក្រោយក្រុមខ្មែរក្រហម អនុវត្តលិទ្ធិផ្តាច់ការជ្រុលនិយម បានទទួលយកមនោគមវិជ្ជាកុម្មុយនិស្ត បានមកវាយធ្វើបាបកាប់សម្លាប់កូនខ្មែរ ដោយគ្មានក្តីអាណិអាសូរជាតិសាសន៍ឯង បាត់បង់អស់នូវ

គុណធម៌អ្នកកាន់នឹងគោរពព្រះពុទ្ធសាសនា។ អ្នកដែលនៅរស់សេសសល់ពីស្លាប់ ក្នុងសម័យនោះ ត្រូវតែចេះធ្វើគល្លង់ ទើបអាចមានជីវិតរស់រានឆ្លងផុត ពីសម័យផ្ដាច់ការ ប្រល័យពូជសាសន៍នោះបាន។ នេះជាន័យបង្កប់ក្នុងព្យញ្ជនៈ**គ** ដែលត្រូវ**ខ**ម៉ៃឲ្យរលួយ រួចវាយកូននាគខាងក្រោយឲ្យ**គ** ភ្លេចភ្លាំងភាន់ភាំងច្រឡំវង្វេង នៅពេលណាដែលយើងមិនគាស់កកាយ រុករកឬសកែវដែលត្រូវគេកប់លាក់ទុក អស់រាប់ពាន់ឆ្នាំទេនោះ យើងច្បាស់ជាមិនអាច ដឹងពីប្រវត្តិជាតិពិតបានឡើយ។

នៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញលោកបានប្រាប់យើងឲ្យដឹងថា អ្នកប្រាជ្ញចិនចាញ់លោក ដោយសារភាសាក្ដាម តើភាសាក្ដាម មានបង្កប់អត្ថន័យអ្វី? ក្ដាមជាសត្វដែលដើរនៅលើភក់ តាមវាលស្រែ នឹងកាយរន្ធនៅក្នុងដីភក់ទន់ ពេលដែលវាដើរស្នាមក្រចកជើងរបស់វា បានទុំតដាមជាប់ទៅលើដីភក់ទន់នោះ។ ពាក្យក្ដាមបើយើងសម្រាយពាក្យតម្រួតនេះ **ក្ដាម** = **ក** + **ដាម** អ្នកកកើតទឹកដីបានយករឿងរបស់ខ្លួន ទៅដាមនៅលើភក់ ក្រោយមកភក់នោះបានរឹងក្លាយជាថ្ម ឈ្មោះថាថ្មភក់។ ហេតុនេះហើយ គ្រប់ប្រាសាទថ្មទាំងឡាយពីបុរាណ ដូនតាយើងបានយកថ្មភក់ជានិមិត្តរូប មកកសាងប្រាសាទ រួចដាមភាសាគឬភាសាក្ដាម ទុកនៅគ្រប់ប្រាសាទទាំងនោះ។ ដែលចិនចុះចាញ់ភាសាក្ដាមក្នុងពេលនោះ ព្រោះពួកគេមើលភាសាទាំងនេះពុំទាន់យល់ ទើបគេយកភាសាក្ដាម ដែលក្មេងៗបានស្រែកអាននោះ យកទៅសិក្សានៅប្រទេសគេ ទីបំផុតគេបានយល់ពីភាសាគឬភាសាក្ដាមនេះ។ ចំណែកឯក្មេងៗ បានអានភាសាក្ដាមរបស់អ្នកប្រាជ្ញជ័យ ពុំមាននឹកឆ្ងល់ឬក៏សួរកចម្លើយ ថាហេតុអ្វីបានជាអ៊ុំជ័យ ឲ្យពួកយើងចេះតែអាន ថាតាមតែនឹកឃើញយ៉ាងនេះ ដូចជារឿងដែលស្ដេចទៅស្ដាប់បណ្ដាំចុងក្រោយ ពីការបរិភោគត្រី ស្ដេចក៏ពុំចេះឆ្ងល់ឡើយ ដោយគិតថាធនជ័យនិយាយពីរឿង សោយត្រីធម្មតាទៅវិញ ដោយភ្លេចគិតពិចារណាថា អ្នកប្រាជ្ញក្បែរទាំងមូលរៀបនឹងស្លាប់ តើមានពេលឯណានៅនិយាយពាក្យលេងសើចធម្មតាទៀត? នេះជាប្រស្នាដែលបានបង្កប់លាក់ទុកក្នុងព្យញ្ជនៈ**គ** គឺភាសាក្ដាមឬភាសាអ្នកប្រាជ្ញធនជ័យ។

**<u>៤.អំពីព្យញ្ជនៈ(ឃ)</u>** (ព្យញ្ជនៈទី៤ក្នុងវគ្គទី១)

ព្យញ្ជនៈ**ឃ**នេះពុំមានន័យគ្រប់គ្រាន់ បង្កើតជាពាក្យបានឡើយ នៅពេលដែលពុំបានផ្សំជាមួយនឹងស្រៈឬព្យញ្ជនៈ។ ព្រោះតំណាអ្នក**ក** ត្រូវផ្ដាច់ត្រឹម**ខ** នឹងត្រូវវាយឲ្យ**គ**គាំងទៅហើយ ដូច្នេះប្រវត្តិរបស់អ្នកកកើតទឹកដី ត្រូវលុបដានសាដានលក់ដាន ស្នាមដានដែលសេសសល់ ត្រូវលាយចំរុះពណ៌លែងមានភាពបរិសុទ្ធ។

**<u>៥.អំពីព្យញ្ជនៈ(ខ)</u>**(ព្យញ្ជនៈទី៥ក្នុងវគ្គទី១)

សូរសម្លេងរបស់ព្យញ្ជនៈ**ខ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ខ**)

**ង**( គុ. ) ដែលមានរំពត់ខាងគល់ឬខាងចុងងើយស្ទើតឡើង : ស្នែងគោងស្ទើត, ទូកង, (ប្រើឲ្យងាយមើលងាយអានគួរសរសេរស្នែងគោ-ងស្ទើត, ទូក-ង) ។(ដកចេញពីវចនានុក្រមសម្ដេច)

**ងរ** ( កិ. ) សំដែងអាការមាយានាំឲ្យងរ : ងរចុះ, ងរឡើង។(ដកចេញពីវចនានុក្រមសម្ដេច)

បើយើងពិនិត្យមើលព្យញ្ជនៈក្នុងវគ្គទី១ ដែលមានប្រាំតួអក្សរនេះ គឺត្រូវបញ្ចប់ត្រឹមព្យញ្ជនៈ**ខ** ហើយព្យញ្ជនៈ**ង**នេះ សក់ត្រូវចង់ក្អួចខ្លួនឯងដូចលេខ៥ដែរ អក្សរ**ង**ចង់គួចចង្អុលបែរទៅក្រោយ (អតីត) ឯលេខ**៥**ចង់គួចខ្លួនឯង ចង្អុលបែរទៅមុខ(អនាគត)។ បើយើងពុំបានយករូបភាពព្យញ្ជនៈទាំង៣៣តួ មកវិភាគរូបរាងសណ្ឋាននោះទេ គឺយើងពុំបានចាប់អារម្មណ៍ពីរាងរបស់វាឡើយ ហើយក្នុងបណ្ដាព្យញ្ជនៈទាំង៣៣តួ មានតែតួអក្សរងតែមួយប៉ុណ្ណោះ ដែលចងខ្លួនឯងឲ្យជាប់ក្នុងវគ្គទីមួយនេះ ដែលជាតួអក្សរទី៥ក្នុងវគ្គទី១។ ចំណែកសូរសព្ទនិយាយ និងន័យដែលបង្កប់ក្នុងព្យញ្ជនៈនេះ គឺមានន័យថា ងរចុះឬធ្លាក់ចុះ មិនថាមនុស្សឬសត្វ ចាស់ក្មេង បុរសស្ត្រី គ្រហស្ថបព្វជិត ពេលដែលសេចក្ដីងរថ្នាំងថ្នាក់ចិត្តកើតឡើង(ទោមនស្ស) ធ្វើឲ្យចិត្តធ្លាក់ចុះទៅរកទោសៈមូល ហេតុដោយសេចក្ដីវង្វេងដោយមោហៈនិងលោភៈ។ ទោមនស្សចិត្តនេះ បើកើតឡើងនៅពេលជិតស្លាប់ អាចឲ្យច្យុតិចិត្តចុងក្រោយរបស់បុគ្គលនោះ ទៅបដិសន្ធិនៅក្នុងអបាយភូមិបាន ព្រោះហេតុអកុសលចិត្តនេះ(ងរ)។ យ៉ាងណាមិញ អត្ថន័យក្នុងប្រស្នាព្យញ្ជនៈក្នុងវគ្គទី១ ដែលមានតួអក្សរង ជាតួអក្សរបញ្ចប់ក្នុងវគ្គនេះ ន័យជារួមក្នុងវគ្គគឺ អ្នក**ក**ត្រូវ**ខ**ឲ្យល្អួយ បាត់សភាពទ្រង់ទ្រាយដើមរបស់ខ្លួន ហើយត្រូវវាយឲ្យ**គ** និយាយលែងចេញ បាត់ដានស្នាមត្រឹម**ឃ** រួចក៏ងធ្លាក់ចុះទៅក្នុងអបាយភូមិ។ (សូមអានបន្ថែមបណ្ដាំមាតាមហាគរភាគ១ ២ ៣)

**ខ.វគ្គទី២**( មានតួអក្សរ៥តួគឺ **ចឆជឈញ**)

**៦.អំពីព្យញ្ជនៈ( ច )**(ព្យញ្ជនៈទី១ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ច** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ច**)

**ច**( កិ. ) ពុះឈើបំបែកជាពីរដោយដឹងភ្លុក : មនុស្សក្នុងជាន់បុរាណច្រើនចឈើធ្វើជាក្ដារក្រាល ព្រោះក្នុងសម័យនោះមានតែដឹង មិនទាន់មានរណារ។(ដកចេញពីវចនានុក្រមសម្ដេច)

**ច**ស. ( ន. ) (ចូអ. ថ. ច) ស្បៃហ្នាំងគឺស្បៃសដែលគេត្រដាង បញ្ចាំងស្រមោលរូបស្បែកដាប់រំហោក : ចហ្នាំងឬចណាំងសំពត់ស ដែលសម្រាប់បញ្ចាំងភាពយន្តសម័យបច្ចុប្បន្ន ក៏គឺចនុះឯង (ម. ព. ណាំង, ហ្នាំងផង)។(ដកចេញពីវចនានុក្រមសម្ដេច)

**ច**យ ( ន. ) (ឆ្កែ) ឈ្មោះឆ្នាំទី១១ (សុនខ) : ឆ្នាំច។(ដកចេញពីវចនានុក្រមសម្តេច)

**ចរ**ចសំ. បា. ( កិ. ) ត្រាច់, ដើរ, ទៅ; ប្រព្រឹត្ត។(ដកចេញពីវចនានុក្រមសម្តេច)

បើតាមសូរព្យញ្ជនៈក្នុងតួអក្សរ**ច** ន័យត្រង់ចង់ប្រាប់យើងថា សម័យខាងក្រោយតំណាថ្ម ការ**ចរ**នាំប្រវត្តិរឿងអ្នក**ក**(កកើត)ចេញ គឺគ្រាន់តែជាស្រមោល**ច**ណាំង លើក្រណាត់សម្លូយផ្ទាំង ដែលឆ្លុះទៅតាមរូបជាស្រមោល បានមកចាំងប៉ះឲ្យឃើញ ជាស្រមោលខ្មៅតែប៉ុណ្ណោះ មិនអាចឲ្យយល់រូបភាព ពិតប្រាកដច្បាស់លាស់បានឡើយ។ ភាពជាស្រមោលនេះហើយ ដែលសម្តេចប៉ានលោកបានចងក្រង សរសេរឿងល្បើកអង្គរវត្ត ត្រូវរកភាពពិតរបស់អច្ឆរាលែងឃើញ គឺគ្រាន់តែជាការស្មានតាមស្រមោល របស់ភាសា**គ** ដែលចាំងមកលើផ្ទាំងសំពត់សតែប៉ុណ្ណោះ។ រយកាលជាង១០០ឆ្នាំ ដែលខ្មែរបានបោះបង់រាជធានីអច្ឆរិយរបស់ខ្លួន បូករួមទាំងពួកបរទេសគេមានបំណង ចង់លាក់នឹងបំផ្លាញប្រវត្តិដានស្នាមរបស់ជាតិ ពួកគេបានលាយពណ៌ជាតិបញ្ចូលជាមួយនឹងសាសនា... តើធ្វើដូចម្តេច យើងអាចទទួលបាននៅភាពបរិសុទ្ធ នៃប្រវត្តិជាតិខ្មែរនេះបាន? កូនខ្មែរបានត្រឹមតែមើលប្រវត្តិរឿងខ្លួន ក្នុងស្រមោលចណាំង រួចចរនាំប្រវត្តិជាតិជាស្រមោលនេះបន្តគ្នា។ ឧទាហរណ៍ដូចជា សិល្បៈឆៃយ៉ាំ ពាក្យពិតរបស់ពាក្យ ឆៃយ៉ាំ គឺឆាយ៉ាំ(ភាសានិយាយ) ដែលក្លាយមកពីពាក្យឆាយាមានន័យថាស្រមោលនៃការរីករាយសប្បាយ ពីអតីតកាល ក្នុងស្រមោលរឿងរបស់អ្នកនគរនេះ។ ព្រោះអ្នករាំទាំងនោះ ពុំបានប្រើមុខពិតរបស់ខ្លួនឡើយ គឺប្រើមុខត្លុកពាក់ក្លែងក្លាយ បង្អួតបង្ហាញប្រាប់អ្នកមើល ថាដូចជាខ្លួនសប្បាយតាមមុខដែលពាក់នេះ។ ចំណែករូបពិតមុខពិត កំពុងតែហត់ហើយព្រួយបារម្ភ ពីការចិញ្ចឹមជីវិតដោយត្រូវការប្រាក់ ដើម្បីយកទៅចិញ្ចឹមក្រុមគ្រួសារ រីឯមុខពាក់ជាស្រមោលចេះតែញញឹម សើចចេញធ្មេញតែឯងទៅ។ ម្យ៉ាងទៀតសិល្បៈឆៃយ៉ាំក្តី ល្ខោនបាសាក់ក្តី ពេលលេងបើកឆាកក្តី អ្នកលេងតែងស្រែកពោលថា **យក្សអរឆ្មើមមុន**រហូត ម្តេចបានជាយក្សអរសប្បាយម្លេះ! ហើយម្តេចបានជាលេងមិនស្រែកថា**ខ្មែរអរ**? ន័យបង្កប់នេះ គ្រាន់តែជាការឆ្លល់នឹងពន្យល់ពីអត្ថន័យ ដែលបង្កប់ក្នុងព្យញ្ជនៈ**ច** និងសិល្បៈល្ខោនបាសាក់ឆៃយ៉ាំតែប៉ុណ្ណោះ(សូមមើលបណ្តាំមាតាមហានគរភាគ១ ២ ៣)។

**<u>៧.អំពីព្យញ្ជនៈ( ឆ )</u>** (ព្យញ្ជនៈទី២ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ឆ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**<u>ពន្យល់ពាក្យ</u>** (មានសូរដូច**ឆ**)

**ឆ**( កិ. ) បំភាន់ដោយសំដីដើម្បីនឹងយកទ្រព្យរបស់គេ : ឆយកទ្រព្យគេ, ឆបោកប្រាក់គេចងកសត្វពាហនៈរូបព័ទ្ធឃ្លុំមាត់ ជួសកន្ទុះជួសបង្ក្បៀរឆច្រមុះកូនគោ បង្ខានមិនឲ្យបៅដោះ។ (ដកចេញពីវចនានុក្រមសម្ដេច)

**ឆ** ឆឬឆៈបា.; សំ. ( ប. សំ. ) (ឆសិ) ប្រាំមួយ (៦) ។ឆមាស (ឆ-មាស) "ប្រាំមួយខែ" ។តាមសំយោគវិធានត្រូវតម្រួតមជាឆម្មាស, ព្រោះឆ "៦" នេះកាលបើផ្សំនៅពីខាងដើមសព្ទដទៃត្រូវតែតម្រួតព្យញ្ជនៈខាងចុងនោះជាដរាប, ដូចជាឆ + ទន្ត>ឆទ្ទន្ត "ដំរីមានភ្លុក៦ព័ណ៌"; ឆ + វិធ>ឆព្វិធ "៦ប្រការ, ៦យ៉ាង" ជាដើម។ បើមានស្រៈនៅខាងចុងត្រូវចុះអាគមមកផ្សំ, ដូចជាឆ + អង្គ>ឆឡង្គ "អង្គ៦" ។ល។ (ដកចេញពីវចនានុក្រមសម្ដេច)

**ឆ**( ឱ. )ស្ងួរពុះដោយទឹកហូរ ឬចាក់គ្រាប់អ្វីនីមួយតូចៗ មានស្រូវអង្ករជាដើម។ (ដកចេញពីវចនានុក្រមសម្ដេច)

**ឆរ** ( ប. ) ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យឈូ: មនុស្សផ្អើលឈូឆរ។ (ដកចេញពីវចនានុក្រមសម្ដេច)

ពាក្យដែលបានបង្កប់ន័យសូរដូច ទុកក្នុងព្យញ្ជនៈ**ឆ** គឺមានន័យថាបញ្ឆោតយើង កុហកឲ្យយើងផ្អើលឈូឆរឡើង។ **ចរ**នាំរឿងចេញបែរជាត្រូវ**ឆ**បញ្ឆោតកុហក ប្រវត្តិពិតរបស់អ្នក**ឝ** ព្រោះចង់បំបែកបំបាក់ ដើម្បីប្រមូលយកទ្រព្យសម្បត្តិ មរកតរបស់ដូនតា ធ្វើឲ្យសតិបញ្ញាកូននាគខាងក្រោយវង្វេងរកប្រវត្តិពិតពុំបាន ដោយឬសកែវរបស់ជាតិ បានត្រូវគេកប់លាក់ទុកទៅក្នុងអតីតកាល។ អ្វីដែលបានយកមកបង្ហាញនេះ គ្រាន់តែជាស្រមោលចណាំង**ឆ**បោកកុហក រឿងពិតរបស់អ្នក**ឝ** គឺមាតាមហានគរ គេឆកុហកថាជារឿងរបស់សាសនាទៅវិញ ធ្វើឲ្យពូជនាគលែងដឹងពីសាវតាពិតរបស់ខ្លួន ដោយចាញ់កលល្បិចអ្នកប្រាជ្ញបរទេស មកបំភាន់បិទទ្វារបញ្ញាក្នុងទិសធំទាំង៦ លែងឲ្យដឹងរឿងពិត នេះជាន័យត្រង់ក្នុងភាសាខ្មែរ ដែលបង្កប់ទុកក្នុងសូរព្យញ្ជនៈ**ឆ**។

**<u>៨.អំពីព្យញ្ជនៈ(ជ)</u>** (ព្យញ្ជនៈទី៣ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ជ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ**ជ** = **ជរ**។

**<u>ពន្យល់ពាក្យ</u>** (មានសូរដូច**ជ**)

**ជរ** ( ន. ) ក្បាច់រំលេចសម្រាប់ដាក់ប្រកបត្រង់ជាយ, ត្រង់រឹម, ត្រង់ហាម : សំពត់មានជរ (គុ.) ដែលមានជរ : ហូលជរ, អាវជរ។ (ដកចេញពីវចនានុក្រមសម្ដេច)

តួអក្សរ**ជ**ក៏មានន័យជាពាក្យអាចស្ដាប់បាន ទោះបីផ្សំជាមួយព្យញ្ជនៈដូចគ្នា ក៏សម្លេងនូវមានសូរ**ជរ**ដដែល ចំពោះភាសានិយាយ។ តើព្យញ្ជនៈនេះមានបង្កប់ន័យអ្វី សម្រាប់ឲ្យយើង

ពិចារណា? ពាក្យ**ជ** = **ជរ** បើពុំបានកាត់ផ្ដាច់ គឺនៅតែបន្តគ្នារហូត ឲ្យតែយើងព្យាយាមថែរក្សា កុំឲ្យបាត់បង់(ជរសំពត់)។ _ឧទាហរណ៍:_ទេវតាដែលថែរក្សាក្នុងផ្ទះ ភាសានិយាយ ខ្លះហៅថា**ជីនាង**ផ្ទះ ខ្លះទៀតហៅថា**ជរនាង**ផ្ទះ និង**ជំនាង**ផ្ទះ តើពាក្យទាំងបីម៉ាត់នេះ ពាក្យមួយណាត្រឹមត្រូវ បើពាក្យផ្ដើមសុទ្ធតែប្រើព្យញ្ជនៈ**ជ**?

**១.ជីនាង**

នៅក្នុងពាក្យសម្គាល់ទេវតាថែរក្សាផ្ទះ មានពាក្យ**ជី** + **នាង** ជីគឺអ្នកបានបួសជាសាមណេរ ហើយសឹកមកវិញ ពីសម័យមុនហៅថាជី តែសម័យសព្វថ្ងៃ ហៅថាបណ្ឌិតឬអន្ទិត។ ជីមួយទៀតគឺសំដៅសម្គាល់ ទៅលើបុរសស្ត្រីនៅជាគ្រហ្ថ តែបានប្រព្រឹត្តិព្រហ្មចរិយធម៌ ថ្នាក់សីល៥, ៨, ១០ក៏ហៅថាជីដែរ ដូចជាយើងហៅអ្នកដែលស្លៀកសពាក់សថា តាជី ដូនជី យាយជី...។ល។ ដូច្នេះពាក្យជីនាង គឺនាងដែលថែរក្សាផ្ទះសម្បែង នោះជាស្ត្រីដែលបានកាន់និងគោរពព្រះពុទ្ធសាសនា មានគុណធម៌ថ្នាក់សីល ដូចបានរៀបរាប់ខាងលើ ហើយចិត្តគាត់បានជាប់ជំពាក់នឹងមរតក ធ្វើឲ្យកម្មត្រូវរៀបចំឲ្យគាត់ មកថែរក្សាទឹកដីក្នុងផ្ទះទាំងនេះ។

**២.ជរនាង**

ជរនាងគឺជាតំណរវង្សត្រកូល តគ្នាមិនដាច់របស់ព្រះមេ ដែលជាអ្នកបង្កើតទឹកដីពីដំបូង ហើយក្រោយមកបានក្លាយជាព្រះម៉ែ(មើលឯកសារជីវតាក្វាន់និយាយពីរឿងបិសាចពស់) ដែលព្រះម៉ែជាព្រះភូមិរក្សាមាតុភូមិនេះទាំងមូល ព្រោះទឹកដីនេះវាជាមរតកតែមួយគត់ ដែលកើតចេញពីញើសឈាមរបស់គាត់។

**៣.ជំនាងឬជុំនាង**

ជំនាងគឺនាងដែលជាអ្នកធ្វើឲ្យជុំញាតិ ជុំទ្រព្យសម្បត្តិ.... ទាំងខាងប្ដីទាំងខាងខ្លួន និងធ្វើឲ្យជុំរឿងសុខទុក្ខគ្រប់បែបយ៉ាង អ្នកធ្វើឲ្យជុំគឺនាង។ ក្នុងពិធីលើកផ្ទះថ្មី(ផ្ទះឈើ) មុននឹងលើកបញ្ឈរសសរកន្លោង គេតែងយកសំពត់ជាតិ ព្រៃពណ៌ក្រហម (ពណ៌តំណាងឲ្យជនជាតិចិន)ប្រមាណកន្លះម៉ែត្រ មានគូរយ័ន្ត៨ទិស រួចយកមកវាយភ្ជាប់នឹងមេដំបូល ត្រង់សសរកណ្ដាលគឺសសរកន្លោង។ រួចគេមានរៀបទ្រនឹបជាង មានបង្អែមចម្អាប ទៀនធូប ភ្ញីផ្កាជាដើម ទៅតាមសមគួរនឹងកម្លាំងទ្រព្យ ដើម្បីសែនព្រែនរំលឹកដល់ទេវតាមួយអង្គ ដែលពួកជាងពីបុរាណ តែងប្រកាន់ជឿថាជាគ្រូធំបំផុតរបស់ពួកខ្លួន។

បើយើងពិនិត្យតាមបណ្ដាំភាសា**គ** របស់ព្រះម៉ែមហានគរដែលផ្ដាំទុក រឿងរបស់មេឬនាងបានបន្តគ្នាមកមិនដាច់ រហូតមកដល់សព្វថ្ងៃនេះ(ជរនាង)។ ហេតុអ្វីបានជាជាងត្រូវវាយយ័ន្តសីមា៨ទិស ព័ទ្ធមេដំបូលចំកណ្ដាលសសរកន្លោង?

**ពន្យល់ពាក្យ**

**កន្លោង** ( ន. ឬគុ. ) ម្តាយ; ដែលជាធំ, ដែលជាមេខ្លោង, ជាចំបងលើគេ : ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះអភិធម្ម ប្រោសព្រះកន្លោង (ព្រះមាតា) សសរកន្លោងគឺសសរទ្រូង។

កន្លោងគឺតំណាងឲ្យព្រះមេឬព្រះម៉ែ គាត់ជាមេខ្លោងគ្រប់គ្រងនគរនេះទាំងមូល បើមេខ្លោងត្រូវចាក់សោដោយយ័ន្តក្រហម មានព័ទ្ធសីមា៨ទិស មកចាក់បោះបិទលើមេដំបូលនោះទៅហើយ តើឲ្យគាត់ចេញមកជួយថែរក្សាកូនចៅម្តេចបាន? នេះមិនទាន់លើកផ្ទះបញ្ឈរឲ្យត្រង់ផង កូនក្មេរវាយចាក់សោបិទឃុំគាត់ ដែលជាទេវតាថែរក្សាផ្ទះដោយពុំដឹងខ្លួន។ ព្រះម៉ែលោកមិនអាចនៅពីខាងលើបានក៏ចុះមកនៅត្រឹមកណ្តាលផ្ទះ ដែលជាកន្លែងតម្កល់**ជីនាង ជរនាង ជំនាង**សព្វថ្ងៃ តែត្រូវកូនយកយ័ន្តក្រហមមានសសេរអក្សរចិន មកបិទចាក់សោឃុំគាត់បន្ថែមទៀត។ សព្វថ្ងៃនេះមិនត្រឹមតែយ័ន្តទេគឺមានរូបអ្នកតាកុងដៀវឬអុងដៀ មកអង្គុយជំនួសកន្លែងគាត់ តើឲ្យគាត់ទៅនៅឯណា? ក្នុងនាមខ្លួនជាម្ចាស់មរតក? បើយើងសាកសួរខ្លួនឯងដោយឆ្លល់ថា ពេលមានគ្រោះភ័យកើតឡើង យើងបន់ស្រន់រូបអ្នកតានោះ តើអ្នកតានោះគាត់សុខចិត្ត ជិះយន្តហោះពីស្រុកគាត់(ស្រុកឆ្ងាយ)មកជួយយើង ឬក៏គាត់ជួយកូនចៅគាត់សិន? ចុះអ្នកណា? ដែលទុកមរតកកេរនេះឲ្យយើងគ្រប់គ្នា ហើយថែមទាំងជួយថែរក្សាយើងសព្វថ្ងៃ? ធម្មតាកូនកើតចេញពីផ្ទៃ ឬទ្វារមាសរបស់គាត់ តើគាត់សុខចិត្ត ឱបដៃមើលកូនដែលកំពុងរងគ្រោះកើតដែរឬទេ? ពូជនាគជាពូជដឹងគុណ ជាពូជប្រសើរ ជាពូជព្រហ្ម ហេតុអ្វីបានជាពូជនាគពេលស្លាប់ គេលើទង់ក្រពើឲ្យម្នាក់មួយៗ? ប្រស្នាទាំងនេះហើយ ដែលយើងត្រូវតែចេះឆ្ងល់ ហើយត្រូវចេះស្វែងរកចម្លើយ ដោយសមតាមហេតុផល ទោះបីមានឧបសគ្គមករារាំង រហូតដល់ជីវិតក៏ដោយ ក៏ត្រូវតែរកយុត្តិធម៌ឲ្យមេដំបូល ដែលជាព្រះកន្លោង ព្រោះលោកសុខចិត្តបំពេញពលិកម្មរងទុក្ខរាប់ពាន់ឆ្នាំ ធ្វើជាព្រាយបិសាច ជាប្រែត ព្រោះហេតុតែថែរក្សា កេរមរតកអច្ឆរិយទាំងនេះទុកឲ្យយើង។

ពេលដែលកូននាគចាក់សោកន្លែង**ជរនាង ជីនាង ជំនាង**ជាប់ តើឲ្យគាត់ទៅនៅឯណា? គាត់ទៅនៅពីខាងក្រោមរនាប គឺ**មេរត** ព្រោះហេតុនេះ បានជាយើងមានរឿងនិទានអាជ័យ មេរត មេរតគរបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ បានក្លាយជាមេគ្រត ពាក្យគ្រតក្លាយមកពីពាក្យ**គរត=គ្រត** លើគ្នា(មើលរូបព្រះមាតាទូលយោនីនៅពីលើក្បាល រួចកប់ត្រឹម**ក**នៅគ្របក្នុងគុហារប្រាសាទនាគព័ន្ធ)។ នេះជាន័យប្រស្នាដែលបានបង្កប់ លាក់ទុកក្នុងព្យញ្ជនៈ**ឋ** បង្កើតបានជារឿង**ចរ**ចេញនាំរឿង**ឆ**បោកបញ្ឆោត**ឋ**រនាង អ្នក**ត**ទ្រព្យឲ្យទៅធ្វើជាមេរត ទ្ររនាបបាត់ឈ្មោះព្រះកន្លោងចេញពីក្នុងសន្តានកូននាគប្រុសស្រី។

**៩.អំពីព្យញ្ជនៈ(ឈ)** (ព្យញ្ជនៈទី៤ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ឈ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ សូរឈ = ឈរ។

**ពន្យល់ពាក្យ**(មានសូរដូចឈ)

**ឈរ** ( កិ. ) ឋិតពេញជំហរជើងជាន់ត្រង់, ជាឈ្មោះឥរិយាបថមួយ ក្នុងឥរិយាបថទាំង៤គឺ ដើរ, ឈរ, អង្គុយ, ដេក។ស្ថិតនៅ, នៅស្តីទីរាជការ : រាជការត្រូវចាត់លោក... ឲ្យទៅឈរខេត្រស្វាយរៀង; ខ្ញុំបានឈរធ្វើរាជការទីអភិបាលខេត្រ នៅខេត្រកំពតអស់៥ឆ្នាំ។ នៅទ្រឹងមិនឡើងមិនចុះ, មិនគ្រាន់បើ មិនរីតឡើង(ជំងឺ) : ជំងឺឈរឲ្យមើលយូរណាស់ មិនគិតរកគ្រូមើលគ្នា។ (គុ. ឬន.) អក្សរដែលមានតួរាងត្រង់ : អក្សរឈរ។ (ដកចេញពីវចនានុក្រមសម្តេច)

រឿងព្រះកន្លោងដែល**ច**បំបែក រួច**ច**រនាំចេញមក ត្រូវ**ឆ**បោកកុហកទៅហើយ តើរឿងរបស់**ជ**រនាង អាច**ឈរ**បង្ហាញពីភាពពិតរបស់ខ្លួន ឬក៏ក្លែងក្លាយ? នេះជាហេតុពិត ដែលប្រវត្តិរឿងសម្គាល់ជាតិមួយ នៅតែជាស្រមោល មិនទាន់អាចក្លាយជាការពិតបាន ព្រោះអ្នកលើកប្រវត្តិជាតិឲ្យឈរពីសម័យមុន ភាគច្រើនសុទ្ធតែអ្នកប្រាជ្ញបរទេស។

**១០.អំពីព្យញ្ជនៈ( ញ )** (ព្យញ្ជនៈទី៥ក្នុងវគ្គទី២)

សូរសម្លេងរបស់ព្យញ្ជនៈ**ញ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ញ**)

**ញ**( ន. ) ឈ្មោះឈើមានផ្លែប្រើជាថ្នាំឬជាអាហារ ស្លឹកក៏ប្រើជាអាហារបាន; ញមានពីរប្រភេទគឺញស្រុកមួយ,ញព្រៃមួយ;ញព្រៃនឹងប្រើផ្លែឬស្លឹកជាអាហារពុំបានទេ។ (ដកចេញពីវចនានុក្រមសម្តេច)

**ញ** ( គុ. ) ដែលមានសណ្ឋានដូចផ្លែញ ដោះញ, ស្ត្រីដោះញ (ប្រើចំពោះតែដោះស្ត្រី)។ (ដកចេញពីវចនានុក្រមសម្តេច)

ព្យញ្ជនៈទី៥ក្នុងវគ្គទី២នេះ ត្រូវបញ្ចប់ដោយតួអក្សរ**ញ** ព្រោះហេតុអ្វី? កូននាគអាចស្គាល់ម្តាយបាន លុះត្រាតែបៅដោះម៉ែ ចុះបើក្បាលដោះម៉ែ ជាស្ត្រីដោះញទៅហើយ តើឲ្យកូនបៅម្តេចបាន? ហើយបើកូនបៅពុំបាន ធ្វើដូចម្តេច អាចទៅឋិតក្នុងទ្រូងម្តាយកើត? ប្រស្នាជានិមិត្តរូបនេះហើយ បានជាមានស្រុកមួយនៅក្នុងខេត្តព្រៃវែង ឈ្មោះហៅថាស្រុកក្របៅ។ ប្រស្នាព្យញ្ជនៈ**ញ**នេះ បានបើកបង្ហាញបញ្ជាក់ ឲ្យកូននាគដឹងថា យើងពុំបានស្ថិតនៅក្នុងដើមទ្រូងគាត់ ពុំបានបៅដោះ

គាត់ ដូច្នេះទើបយើងមិនដឹងថា ម្ចាស់អ្នកបង្កើតមាតុភូមិនេះជានរណា? ម្ចាស់សមុទ្រទឹកដោះជានរណា? អ្នកណាជាម្ចាស់ទឹកអម្រឹត នៅក្នុងសមុទ្រទឹកដោះ?

**គ.វគ្គទី៣** (មានតួអក្សរ៥តួគឺ ដ ឋ ឌ ឍ ណ)

**១១.អំពីព្យញ្ជនៈ(ដ)** (ព្យញ្ជនៈទី១ក្នុងវគ្គទី៣)

សូរសម្លេងរបស់ព្យញ្ជនៈ**ដ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ដ**)

**ដ** យ. ទីចម្លង, កំពង់ចម្លង : កំពង់ដ។ ទូកសម្រាប់ចម្លងនៅកំពង់នោះក៏ហៅដដែរ : ទូកដ។ ល។ (ដកចេញពីវចនានុក្រមសម្ដេច)

**ដរ** ( គុ. ) អំពីរោគដែលរើឡើងដោយប៉ះទង្គិច : ដំបៅដរ, បូសដរ, ជាដើម។ (ដកចេញពីវចនានុក្រមសម្ដេច)

**ដ៏** និ. ដែល, ដែលជា; ពាក្យជាវិសេសនៈ, មានសំឡេងខ្លីកំបុត សម្រាប់និយាយផ្សំនឹងគុណនាម ប្រើរៀងរបៀបត្រង់ខាងដើមគុណនាម ដែលគួរប្រកបជាមួយផងបាន: ធម៌ដ៏បវរ, ទ្រព្យដ៏ប្រសើរ។ មិនប្រើជាវិសេសនៈចំពោះមនុស្សសត្វផងទេ កុំប្រើជាមនុស្សដ៏ស្រែ, ដ៏ចម្ការ; ត្រូវប្រើពាក្យថា : មនុស្សអ្នកស្រែ, អ្នកចម្ការ។ល។ (ដកចេញពីវចនានុក្រមសម្ដេច)

ក្នុងនាមជាព្រះព្រហ្មជាបុព្វទេវតា គាត់សុខចិត្តធ្វើបាបគ្រប់បែបយ៉ាងដើម្បីកូន ចុងក្រោយបានទទួលផលតបស្នង គឺត្រឹមឈឺចាប់**ដរ**ពើតផ្សាតែម្នាក់ឯង។ ទោះបីជាខំស្រែកហៅអ្នកខាងក្រោយឲ្យជួយ ក៏គេមិនដឹងមិនឮមិនស្គាល់ខ្លួន ក្នុងនាមជាអ្នកធ្វើទូកក្បូន ធ្វើទីចម្លងឲ្យគេ បានត្រឹមតែប្រមូលមរតកមកទុក ហើយទៅសោយទុក្ខ។ ព្យញ្ជនៈ**ដ**នេះបានបង្ហាញ ប្រាប់ន័យរបស់ខ្លួនថា មានទុក្ខធ្ងន់ឈឺចាប់**ដរ**ពើតខ្លោចផ្សាដ៏ក្រៃលែង ហើយតែម្នាក់ឯងទៀត ព្រោះគ្មានអ្នកដឹងក្រៅពីខ្លួនអ្នកប្រព្រឹត្តសាង ព្រោះហេតុតែធ្វើទីចម្លងដល់ពពួកញាតិ មានកូននិងក្រុមគ្រួសារ...។ល។

**១២.អំពីព្យញ្ជនៈ(ឋ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី៣)

**១៣.អំពីព្យញ្ជនៈ(ឌ)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៣)

**១៤.អំពីព្យញ្ជនៈ(ឍ)** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៣)

**១៥.អំពីព្យញ្ជនៈ(ណ)** (ព្យញ្ជនៈទី៥ក្នុងវគ្គទី៣)

ក្នុងព្យញ្ជនៈវគ្គទី៣នេះ ត្រូវបាត់ដានរឿងក្នុងបួនតួអក្សរ **ឋ ឌ ឍ ណ** ព្យញ្ជនៈទាំងបួននេះ មិនអាចបង្កើតជាពាក្យ ឲ្យមានន័យគ្រប់គ្រាន់ស្ដាប់បាន គឺរឿងរបស់ពួកគាត់ស្ថិតក្នុងភាពងងឹត ដោយពុំបានបង្ហាញ ឲ្យកូននាគខាងក្រោយបានឃើញ ពីការ**ដរពើត**ឈឺចាប់តែម្នាក់ឯង របស់អ្នក**ក**ទ្រព្យមរតក គឺមាតាមហានគរ ព្រោះរឿងពិតរបស់លោក បានបាត់ដំណឹងសូន្យឈឹង ក្រោយពេល

ដែលបោះបង់ចោលក្រុងអង្គរ។ ព្រះមាតាមហានគរ លោកលែងមានកម្លាំងឬទ្ធិ អាចលួចចេញពីទីឃុំបានទៀតហើយ សេចក្ដីសង្ឃឹមតែមួយគត់ គឺពឹងទៅលើកូននាគណា មាននិស្ស័យចេះដោះនូវប្រស្នាភាសា**ត** ដែលបានបង្កប់ក្នុងមរតករបស់លោក។

**ឃ.វគ្គទី៤**( មានតួអក្សរ៥តួគឺ **ត ថ ទ ធ ន**)

**១៦.អំពីព្យញ្ជនៈ( ត )** (ព្យញ្ជនៈទី១ក្នុងវគ្គទី៤)

សូរសម្លេងរបស់ព្យញ្ជនៈ**ត** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ត**)

**ត** ( កិ. ) ភ្ជាប់, ភ្ជាប់គ្នាឲ្យវែងតទៅទៀត : តដៃដែលបាក់, តខ្សែដែលដាច់, តខ្សែឲ្យវែង, តហប់ផ្ទះ...។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**កិ. វិ. ឬគុ. ដែលជាលំដាប់ៗគ្នា, ដែលមានពីមួយទៅមួយ, ពីនេះទៅនោះ : ឮតពីគេមក, ឮតៗគ្នា, នាំតៗគ្នាមក; ផ្លូវតគ្នា...។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**ដៃកិ. ប្រយុទ្ធតវិញ, តស៊ូមកវិញដោយដៃឬដោយគ្រឿងប្រហារ។តតបកិ. ឆ្លើយឆ្លងសងសម្ដី, ជជែកសងពាក្យសម្ដីរកខុសត្រូវ។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**តាំងកិ. ប្រណាំងប្រជែងសម្ដីដោយអាងភស្តុតាង, តពាក្យសម្ដីឬតដំណើរសេចក្ដីដោយមានក្រិយាតំណាំង។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**តួកិ. វិ. ដែលតស៊ូគ្នាតែមួយនិងមួយ : វាយតតួ, ចំបាប់តតួ; តែមួយនិងមួយឥតមានថែម : ដូរគោតតួ។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**ទល់កិ. និយាយសើរើរកខុសរកត្រូវទល់មុខគ្នា, លើកទ័ពឬពួកកងទៅមកប្រឈមទល់គ្នា។(ដកចេញពីវចនានុក្រមសម្ដេច)

**ត**ទៅនិ. រៀងទៅ, ដរាបទៅ (ដកចេញពីវចនានុក្រមសម្ដេច)

ព្យញ្ជនៈ**ត**នេះ បានផ្ដើមប្រាប់ន័យរបស់វាឲ្យយើងដឹងថា រឿងរ៉ាវអ្នក**ក**ដែលបាត់ដំណឹងរាប់ពាន់ឆ្នាំនោះ ត្រូវសើរើ**ត**ភ្ជាប់សារជាថ្មីឡើងវិញ។ អ្នកកកើតមរតកទុក ចាប់ផ្ដើមមានក្ដីសង្ឃឹម ព្រោះមានកូននាគចាប់ដឹងរឿងរួច**ត**តំណ ដែលដាច់ឲ្យជាប់គ្នាវិញ គឺអតីតកាល ភ្ជាប់ជាមួយនឹងបច្ចុប្បន្នកាល។

**១៧.អំពីព្យញ្ជនៈ( ថ )** (ព្យញ្ជនៈទី២ក្នុងវគ្គទី៤)

តួអក្សរ**ថ**នេះពុំមានន័យបង្កើតជាពាក្យ អាចមានន័យគ្រប់គ្រាន់ស្ដាប់យល់បានឡើយ តែវាជានិមិត្តរូបតាងឲ្យអ្នក**ត**អ្នកវែក។ ព្យញ្ជនៈទាំង៣៣តួ បើយើងយកមកចែកនឹង២ គឺមិនអាចចែក

ដាច់ឡើយ ត្រូវនៅសល់តួអក្សរមួយនៅចំកណ្តាល គឺតួអក្សរ**ថ**ជាអ្នករែកតួអក្សរទាំង១៦សងខាង។ ហេតុអ្វីបានជាជនជាតិសៀម ផ្លាស់ឈ្មោះទៅជាថៃ? តាមការយល់នឹងស្រាវជ្រាវ រកឃើញនៅក្នុងព្យញ្ជនៈនិងស្រៈ យើងអាចឈ្វេងយល់បានថា ការផ្លាស់ប្តូរឈ្មោះពីសៀមមកថៃ អ្នកប្រាជ្ញគេបានគិតទុករួចជាមុនទៅហើយ នូវន័យប្រស្នាបង្កប់ ក្នុងព្យញ្ជនៈខ្មែរទាំង៣៣តួនេះ។ សៀមមកពីពាក្យពីរម៉ាត់ សៀ + ម (សសៀវម៍) គឺព្យញ្ជនៈ**ស**ផ្សំនឹងស្រៈ**ៀ**បូកនឹង**ម** ភាសានិយាយ**ម៏** ភាសាសរសេរ**មក** ។ ថៃគឺព្យញ្ជនៈ**ថ**+ស្រៈ**ៃ** ដែលព្យញ្ជនៈ**ថ**ជាតួរែក ដូចខ្ញុំបានពន្យល់ខាងលើរួចហើយ គឺ**ថ**រែកតួអក្សរ១៦ខាងដើម និងព្យញ្ជនៈ១៦ខាងចុង។ ចំណែកស្រៈ**ៀ**(សៀម) និងស្រៈ**ៃ**(ថៃ)នៅអមសងខាងបិទស្រៈ**េ** និងស្រៈ**ៃ**ជាប់ ដោយយើងសរសេរពាក្យសម្គាល់ ជាតិយើងក្មេរ ឬក្មែរ។ ស្រៈ**ៀ**និងស្រៈ**ៃ**បាននៅសងខាងឃុំស្រៈ**េ**និងស្រៈ**ៃ**ជាប់ ព្រោះវាជានិស្ស័យរបស់ជាតិក្មែរនេះ ត្រូវតែប្រើប្រាស់ស្រៈ**េ**និងស្រៈ**ៃ**។ ជានិមិត្តរូប ពួកគេចង់ប្រកាសឈ្មោះ ដែលដូរនេះឲ្យយើងដឹងថា ភ្នំដងរែកដ៏ធំវែង សម្រាប់រែកម៉ែនិងឪ យកទៅដាក់នៅលើកំពូលប្រាសាទភ្នំព្រះវិហារវិញ គឺមានតែជនជាតិ ដែលមានតួអក្សរ**ថ**ជាឈ្មោះសម្គាល់ទេ ដែលមានចំនួនមនុស្សជាង៨០លាននាក់ ទើបអាចលើកភ្នំដងរែកនេះរួច នេះជាមហិច្ឆតាដែលសព្វថ្ងៃ ពួកគេចង់បានប្រាសាទព្រះវិហារ។ តួអក្សរ**ថ**ត្បិតថាពុំមានន័យគ្រប់គ្រាន់ បង្កើតជាពាក្យបាន ក៏ប៉ុន្តែគុណធម៌បង្កប់របស់វាគឺជាតួរែក ព្យញ្ជនៈខាងដើម១៦ និងព្យញ្ជនៈខាងចុង១៦ បើប្រៀបធៀបមកមនុស្ស គឺតំណាងឲ្យកូនកតញ្ញូ។ តើអ្នករែកព្រះមាតាព្រះបិតា ទៅដាក់លើកំពូលភ្នំប្រាសាទព្រះវិហារធម៌វិញ **ថ**តំណាងថៃ ឬ**ថ**តំណាងក្មែរ?

**<u>១៨.អំពីព្យញ្ជនៈ( ទ )</u>** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៤)

សូរសម្លេងរបស់ព្យញ្ជនៈ**ទ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**<u>ពន្យល់ពាក្យ</u>**(មានសូរដូច**ទ**)

**ទ**( ន. ) ប្រដាប់ធ្វើដោយឈើ, ឬស្សីឬដោយស័ង្កសីជាដើមសម្រាប់រង, សម្រាប់បង្ហូរទឹក : ទឹកហូរតាមទ; ផ្ទះភ្លោះ៥ខ្នងមានទ៤កន្លែង។ធ្លារទឹកភ្លៀងដែលធ្លាក់ពីអាកាស : ទនៃទឹកភ្លៀង (ប្រា. ហៅឧទកធារ, ជលធារ "ធារទឹក, ទនៃទឹក") ។ទនេះជាសព្ទកំព្រា, ត្រូវសរសេរទ-ទឹក (ទនៃទឹក), កុំឲ្យច្រឡំនឹងភ្លៀងទទឹក, សំពត់ទទឹក។ឧទាហរណ៍សម្រាប់ប្រើពាក្យទនិងទរ : ទស័ង្កសីនៅផ្ទះបាយវាធ្លុះលេចទឹក, ខ្ញុំអាល័យតែផ្សារ-ទឲ្យជិតឡើងវិញ, ស្រាប់តែឆ្មាមួយចូលទៅក្នុងផ្ទះបាយទរត្រីអាំងម៉ែអស់មួយតម្បុត, ម៉ែមិនទរឆ្មា, បែរជាទរខ្ញុំកំពុងផ្សារ-ទធ្លុះឯណោះទៅវិញថាខ្ញុំមិនជួយមើលត្រីអាំងឲ្យផងបណ្តាលឲ្យឆ្មាទរអស់ (ម. ព. ទរទៀតផង) ។(ដកចេញពីវចនានុក្រមសម្តេច)

***ទរ*** ( កិ. ) កិន. គឺជេរ, ស្ដីឲ្យ, បន្ទោស; វាយ, ទះ, តប់... (ជាពាក្យសាមញ្ញសម្រាប់និយាយបញ្ឆៀងមិនចំពោះដំណើរជេរ, បន្ទោសជាដើមនោះទេ) : ខ្ញុំឥតដឹងរឿងហ្នឹងសោះស្រាប់តែគាត់មកដល់ភ្លាមតាំងទរខ្ញុំតែម្ដង។ស៊ី (ព. សា.) ឆ្កែទរនំអស់។ល។(ដកចេញពីវចនានុក្រមសម្ដេច)

ទឹកចិត្តព្រះម៉ែហូរតាមទចេញពីទរូង(ទ្រូង) ពេលណាដែលកូននាគព្រមចាក់ទឹកចិត្ត ម៉ែចេញពីក្នុងបេះដូង (មើលល្បែងចាក់ទឹកដូងក្នុងភាគ១) នោះយើងនឹងស្គាល់ព្រហ្ម។ គាត់តែងបន្ទោសជេរស្ដីទរឲ្យកូននាគថា អ្នកទាំងអស់មិនដឹងគុណគាត់ បំភ្លេចគាត់ ស្គាល់គាត់បានត្រឹមគ្រាប់បាយ(ព្រះមេ) បើបានជារំលឹកឃើញឈ្មោះគាត់ កូននាគ ភាគច្រើន គឺយកគាត់មកជេរ(ជេរម៉ែឬជេរម្ដាយ)។ នេះជាហេតុអកុសលកម្មឲ្យផល ពេលនឹករលឹកឃើញឈ្មោះគាត់ ពុំបានបញ្ជូនបុណ្យឧទ្ទិសបុណ្យ ចែកបុណ្យទៅដល់ពួកគាត់ ដែលជាអ្នកនាំមរតកទាំងអស់ មកទុកឲ្យកូនប្រុសស្រី ជាពិសេសគឺមរតកព្រះពុទ្ធសាសនា គឺជាសាសនាដែលអាចនាំអ្នកប្រព្រឹត្តប្រតិបត្តិ ជួយឲ្យអ្នកមានទុក្ខ ដែលជាញាតិបានរួចផុតពីទុក្ខ និងជួយខ្លួនឯងឲ្យបានចាកចេញ ពីវដ្ដសង្សារនេះផង។

**<u>១៩.អំពីព្យញ្ជនៈ(ឆ)</u>** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៤)

**<u>២០.អំពីព្យញ្ជនៈ(ន)</u>** (ព្យញ្ជនៈទី៥ក្នុងវគ្គទី៤)

ព្យញ្ជនៈទាំងពីរតួនេះ មិនទាន់ផ្សំជាមួយស្រៈឬព្យញ្ជនៈ ពុំអាចបង្កើតជាពាក្យមានន័យគ្រប់គ្រាន់បានឡើយ បានត្រឹមតំណាងឲ្យតួព្យញ្ជនៈខ្លួនឯងតែប៉ុណ្ណោះ ប៉ុន្តែតួអក្សរទាំងពីរនេះ មានប្រស្នាកំបាំងមួយ ដែលលាក់ទុកនៅជិតគ្នា។ បើព្យញ្ជនៈទាំងពីរបញ្ចូលគ្នា បង្កើតបានជាពាក្យ**ធន** = **ទ្រព្យសម្បត្តិ**ហេតុអ្វីព្យញ្ជនៈទាំងពីរនេះ នៅជិតគ្នាបែរជាមិនអាចបង្កើតជាពាក្យបាន? បើយើងងាកទៅអតីតកាល យើងនឹងធ្លាប់ឮចាស់ៗនិយាយសួរគ្នាថា តើអ្នកចេះអក្សរឬទេ? ចាស់ដែលមិនបានបួសរៀនគាត់តែងឆ្លើយថា ខ្ញុំមិនចេះ**ន**ខ្វាក់មួយទេ ហេតុអ្វីបានជាព្យញ្ជនៈ**ន**បែរជាខ្វាក់? ហើយព្យញ្ជនៈ៣២ទៀតមិនខ្វាក់? ប្រស្នានេះហើយ ដែលបានបញ្ជាក់ប្រាប់ថា ព្យញ្ជនៈ**ន** មើលព្យញ្ជនៈ**ធ**មិនឃើញ ទើបមិនអាចបង្កើតជាពាក្យធនបាន ព្រោះ**ន**បានខ្វាក់ទៅហើយ។

**<u>ពន្យល់ពាក្យ</u>**(**ន**ខ្វាក់)

***នខ្វាក់***ន-ខ្វាក់ព. បុ. ( ន. ) អក្សរនដែលមានរាងសណ្ឋានក្ងួចខ្វែងជាត្រីកោណ (បីជ្រុង)  នេះសម្រាប់សរសេរចុះក្នុងផ្ទៃកន្សែងយ័ន្ត ក្នុងសម័យបុរាណ ដោយគេសន្មតថាជាតួអក្សរពិសេស មានអានុភាពពូកែស័ក្តិសិទ្ធិសម្រាប់ជួតក្បាលចូលកាន់សង្គ្រាម...។ អ្នកដែលមិនចេះអក្សរច្រើននិយាយប្រាប់គ្នីគ្នាថា ខ្ញុំឥតចេះអក្សរមួយតួទេសូម្បីតែនខ្វាក់ក៏ឥតចេះដែរ។ (ដកចេញពីវចនានុក្រមសម្ដេច)

ធនជ័យបានផ្ដាំថា ពេលកូននាគស្គាល់ធនធានរបស់ជ័យ គ្រប់ជំនាន់ប្រាសាទថ្ម ពេលនោះតួអក្សរ**ន**ឈប់ខ្វាក់ទៀតហើយ នឹងមានភ្នែកទីបីក្រឡេកមើលក្រោយ ឃើញ**ឆ**ដែលជាអ្នកជំនាន់មុនរបស់ខ្លួន រួមជាមួយនឹងខ្លួនជាតួអក្សរ**ន** បង្កើតបានជាទ្រព្យធនអច្ឆរិយ។

**ខ.វគ្គទី៥**( មានតួអក្សរ៥តួគឺ **ប ផ ព ភ ម**)

**២១.អំពីព្យញ្ជនៈ(ប)** (ព្យញ្ជនៈទី១ក្នុងវគ្គទី៥)

សូរសម្លេងរបស់ព្យញ្ជនៈ**ប** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ប**)

**បរ** ( កិ. ) ដឹក, នាំ, បញ្ជូន, បណ្ដោញឲ្យទៅមុខដោយជិះ, ដោយដើរកាល់, ដើរអម, ដើរតាម, តម្រង់ឲ្យត្រង់តាមលំអានតាមផ្លូវដែលត្រូវការ : បររទេះ, បររថ, បរសេះ, បរដំរី។បរពល (--ពល់) លើកកងទ័ពត្រួតពលបណ្ដើរ។ល។ លលកបរគឺសត្វលលកដើរបណ្ដើរបញ្ចេញសំឡេងញាប់រន្ថាន់រនេ។ បណ្ដើរ។(ដកចេញពីវចនានុក្រមសម្ដេច)

បើតាមន័យពាក្យមានសូរដូច**ប** គឺដល់ពេលវេលាត្រូវដឹកនាំបញ្ជូនចេញមកក្រៅ ក្រោយពីបានដឹងរួចតក្អាប់ នៅរឿងរបស់អ្នក**ត**មរតកអច្ឆរិយពីអតីតកាល ហើយបរនាំយករឿងចេញ មកផ្សព្វផ្សាយប្រាប់ឲ្យកូននាគទាំងអស់ បានដឹងរួចឈ្វេងយល់ នៅសាវតានាគពីអតីត។ នេះជាអត្ថន័យបង្កប់ក្នុងព្យញ្ជនៈ**ប**ក្នុងវគ្គទី៥ ក្នុងតួអក្សរទី១ ដែលបង្ហាញពីន័យពិត និងភារកិច្ចតួនាទីរបស់ខ្លួន។

**២២.អំពីព្យញ្ជនៈ(ផ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី៥)

ព្យញ្ជនៈ**ផ**នេះ មិនទាន់ផ្សំជាមួយស្រៈឬព្យញ្ជនៈ ពុំអាចបង្កើតបានជាពាក្យមានន័យគ្រប់គ្រាន់ឡើយ បានត្រឹមតំណាងឲ្យតួព្យញ្ជនៈខ្លួនឯងតែប៉ុណ្ណោះ។ នៅក្នុងវគ្គទី៤ ព្យញ្ជនៈ**ត**រួចព្យញ្ជនៈ**ថ** ចំណែកវគ្គទី៥ ព្យញ្ជនៈ**ប**រួចព្យញ្ជនៈ**ផ** ហេតុអ្វីបានជាអ្នកដែល**ត**រឿងគឺ**ថ** ចំណែកអ្នក**ប**រនាំរឿងចេញផ្លាស់ទៅជា**ផ**?

**២៣.អំពីព្យញ្ជនៈ(ព)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៥)

សូរសម្លេងរបស់ព្យញ្ជនៈ**ព** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្តាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូចព)

**ព**( កិ. ) លើកដាក់ចង្កេះកៀកនឹងដៃឈរឬដើរ : ពកូន។ព. ប្រ. ពផែនដីរក្សាផែនដីគឺគ្រប់គ្រងរក្សាអាណាចក្រនីមួយៗ។ពពោះមានផ្ទៃពោះ (ផើម) ។ទទួលរងធ្វើកិច្ចការរបស់អ្នកដទៃឲ្យនៅលើខ្លួនទាំងអស់; ទទួលរ៉ាប់រងទុក្ខលំបាកជាងគេឬជាជំនួសអ្នកដទៃ : ពកិច្ចការ, ពគំនរទុក្ខ, ពការនឿយហត់ , ពរវល់។(ដកចេញពីវចនានុក្រមសម្តេច)

**ពរ**សំ. បា. ( ន. ) (វរ) គុណជាតិដ៏ប្រសើរ; គុណជាតឬអ្វីៗដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសរើសយកតាមគាប់ចិត្ត : សូមពរ, ឲ្យពរ, ទទួលពរ។ឲ្យពរសព្ទសាធុការបញ្ចេញសូរសព្ទថាសាធុសូមឲ្យ... បានប្រកបតាមបំណង!... ។ស្រែកឲ្យពរឲ្យជ័យស្រែកឲ្យពរថាសូមឲ្យ... មានជ័យជម្នះ ! ដូចយ៉ាងស្រែកថាជយោ ! ឬជយោ ! ជយោ ! ជាដើម (ម. ព. នោះផង) ។ពាក្យនេះសំ. បា. ប្រើជាគុ. ក៏បានប្រែថា "ប្រសើរ; ដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសរើសយកតាមគាប់ចិត្ត"; ខ្មែរប្រើក្លាយមកជាព្រះក៏មាន, នៅជាវរឬវរៈតាមរូបដើមក៏មាន (ម. ព. ព្រះនិងវរឬវរៈទៀតផង) ។(ដកចេញពីវចនានុក្រមសម្តេច)

**ពរ** ( ន. ) លាបបូកព្រលាំងដោយជ័រឲ្យក្រាស់ជិតសាច់ពុំឲ្យជ្រាបទឹកបាន : ពរទូក, បិទពរ។(ដកចេញពីវចនានុក្រមសម្តេច)

នៅក្នុងព្យញ្ជនៈ**ព**នេះ ន័យបង្កប់ក្នុងតួអក្សរ គឺមានកូននាគចាប់ផ្តើម**ព**នាំគាត់ចេញមកក្រៅ ហើយ ដោយបរនាំចេញផង **ព**បីលើកគាត់ចេញពីសមុទ្រទឹកដោះផង។ **ពរ**ដែលជាគុណធម៌ដ៏ប្រសើរ តែងកើតមានដល់កុលបុត្រណា ដែលបានបំពេញនូវកតញ្ញូកតវេទី។ ការប្រតិបត្តិដ៏ប្រសើរនេះ សម្លេង**ពរ**ជ័យសិរីសួស្តីទាំងឡាយ តែងកើតមានចំពោះកុលបុត្រនោះ ព្រោះបានបិទពរ (បិទបាប) មាតាបិតា និងពពួកញាតិ មិនឲ្យទឹកលិចចូលក្នុងចិត្ត នាំឲ្យធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិទៀត។

**២៤.អំពីព្យញ្ជនៈ( ភ )** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៥)

*សូរសម្លេងរបស់ព្យញ្ជនៈ**ភ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។*

**<u>ពន្យល់ពាក្យ</u>**(មានសូរដូច**ភ**)

***ភរ*** *( កិ. ) ពោលពាក្យមិនពិត, កុហក។គុ. ឬកិ. វិ. ដែលមិនពិត, កុហក : មនុស្សភរ, សម្ដីភរ; និយាយភរ។ភរភាយភររហាចរហតាមតែរួចពីមាត់។ ភរភូតឬភូតភរភរទាំងស្រុង; ដែលសុទ្ធតែភរ។ (ព. កា.) : មនុស្សមេភរ ចេះតែកម្ទរភរឲ្យគេស្ដាប់ ភរទៅភរទៅត្រូវលង់ចំណាប់ អ្នកផងគេចាប់-ថ្នាក់ ព្រោះតែភរ។(ដកចេញពីវចនានុក្រមសម្ដេច)*

*ព្យញ្ជនៈ**ភ**នេះ តាមសូរសព្ទនិយាយយើងអាចស្ដាប់ន័យបាន ថាកុហក ឬពាក្យមិនពិត(ភរ) មានន័យថា ពីមុនបរទេសគេ**ភរ**ឆបោកយើង ឲ្យយល់ច្រឡំថា មរតកអច្ឆរាទាំងអស់ជាមរតករបស់សាសនា។ ពេលនេះយើងឈប់ជឿ ដោយមិនទាន់បានពិចារណាឈ្វេងយល់ ព្រោះមានអ្នក**ភ**រឿង មានអ្នក**ប**រនាំរឿង ចេញមកខាងក្រៅហើយ បើបរទេសចង់**ភរ**តទៅទៀត ត្រូវទុកឲ្យកូននាគពិចារណាសិន បើសមតាមហេតុសឹមជឿតាមក្រោយ ក៏មិនយឺតពេលដែរ។ ខ្លួនជាប្រមុខ ជាប្រភពដើមនៃព្រហ្មញ្ញសាសនា ទីបំផុតបានត្រឹមសុំចម្លងសំណង់ប្រាសាទអង្គរ ចេញពីគំនិតកូនសិស្សទៅវិញ តើវាសមហេតុផលដែរឬទេ?*

**<u>២៥.អំពីព្យញ្ជនៈ( ម )</u>** *(ព្យញ្ជនៈទី៥ក្នុងវគ្គទី៥)*

*សូរសម្លេងរបស់ព្យញ្ជនៈ**ម** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។*

**<u>ពន្យល់ពាក្យ</u>**(មានសូរដូច**ម**)

**ម៏**ម ( កិ. ) *ពាក្យសាមញ្ញ ឬជាគ្រាមភាសាមានសូរបញ្ចោក់ខ្លី ឬសូរបង្ហួសជាជំនួសសម្ដីថា មក ដូចជានិយាយថា : ម៏ទៅផ្ទះ ! ឬថាមក៏, មក៏អង្គុយឯណេះម៏ !; ឬថា : ម៉ុះ ! តុះ ! ដូចជាថា:ម៉ុះ, ទៅផ្ទះ !, តុះ, ប៉ុណ្ណឹងចុះ ! (ហៅថាសម្ដីម៉ុះតុះ សម្រាប់និយាយចំពោះមនុស្សអ្នកមានសភាពស្មើគ្នា) ។មក៏ (ដកចេញពីវចនានុក្រមសម្ដេច)*

**មរ**មបា. ; សំ. ( កិ. ) (មរ៍, ម្រ, ម្ទ) ស្លាប់ (សម្រាប់ប្រើចំពោះតែក្នុងកាព្យដែលកវីត្រូវការប្រើខ្លះ កុំឲ្យខ្វះដូចជា) : *ព្រឹកមិញគាត់ត្រាច់ចរ ល្ងាចគាត់មរឥតដឹងខ្លួន នេះគឺការគាប់ជួន នាំឲ្យខ្លួនមានគ្រោះកាច។(ដកចេញពីវចនានុក្រមសម្ដេច)*

**មរ**( ន. ) *ភក់ដែលកើតអំពីទឹកត្រាំដើមត្រុំ ព្រមទាំងស្លឹកត្រុំស្រស់ផងឲ្យរលួយ ហើយកូរឲ្យខះកក មានសម្បុរខ្មៅខ្សៀវទៅជាធ្លះ សម្រាប់ប្រើជាគ្រឿងជ្រលក់ : គាត់ភ័យស្លុតឡើងមុខខ្មៅប៉េះដូចជាមរ។ (ម. ព. ធ្លះទៀតផង) ។(ដកចេញពីវចនានុក្រមសម្ដេច)*

*តាមន័យបង្កប់ក្នុងពាក្យ ដែលមានសូរសម្លេង***ម***ខាងលើ បានបញ្ជាក់ប្រាប់យើងថា ប្រវត្តិរឿងអច្ឆរាមាតាមហានគរ ត្រូវដេកស្លាប់(***មរ***) ចេញពីសន្ដានកូននាគប្រុសស្រី រាប់ពាន់ឆ្នាំមកហើយ ដែលរូបគាត់ត្រូវទៅកប់លាក់ក្នុងភក់ខ្មៅ( សមុទ្រទឹកដោះ ឬសមុទ្រគំរង់ ) តែម្នាក់ឯង។ តើធ្វើដូចម្ដេចអាចឲ្យកូននាគជំនាន់ក្រោយ ទទួលស្គាល់គាត់ បើបាបកម្មរបស់គាត់ ឲ្យផលមិនទាន់អស់នោះ ដូច្នេះទើបម្រាមដៃយើងក្នុងន័យខ្មែរ មានឈ្មោះកូនដៃ នាងដៃ ចង្អុលកណ្ដាលឬចង្អុលខ្មោច ចង្អុលដៃមេដៃ។ កូនម៍(មក) ជួយនាងដៃៗបានមរ(ស្លាប់)ទៅហើយ ដូច្នេះត្រូវប្រើចង្អុលកណ្ដាលឬចង្អុលខ្មោច ចង្អុលប្រោះគាត់ឲ្យរស់ ហើយបានរួចពីឃុំ ដែលយក្ស(ម្ករ)បានចាប់គាត់ ឃុំអស់រាប់ពាន់ឆ្នាំនោះ (មើលរូបចម្លាក់នៅក្នុងភាគ៣)។ ការរៀបរាប់នេះ ហាក់ដូចជារឿងនិទាន តែនេះជាការពិតរបស់កម្លាំងកម្ម ដែលគាត់បានសាងទុកមក ដូច្នេះកូននាគជាអ្នកកាន់ព្រះពុទ្ធសាសនា គង់នឹងយល់ពីកម្លាំងវិបាករបស់កម្មឲ្យផល។ ដូចអ្នកត្រូវគេសម្លាប់ក្នុងរបបប៉ុលពត ប្រជាជនដែលត្រូវគេសម្លាប់ទាំងនោះ មុននឹងស្លាប់សុទ្ធតែបានអង្វរករ ឲ្យពេជ្ឈឃាតទាំងនោះ ដោះលែងនិងទុកជីវិតឲ្យ ហេតុអ្វីបានជាពួកឃាតករទាំងនោះ គ្មានចិត្តមេត្តាករុណាយ៉ាងនេះ? នេះមិនគឺជាកម្លាំងកម្មទេឬ? ដែលមិនអាចឲ្យមនុស្សមានឈាមជ័រជាតិដូចគ្នា ប្រៀបដូចជាបងប្អូន មិនអាចអនុគ្រោះអធ្យាស្រ័យឲ្យបានបែរជាមានភ្នែក(បញ្ញា) តែងងឹតមិនដឹងបាបបុណ្យគុណទោស សម្លាប់ជាតិឯងយ៉ាងព្រៃផ្សៃដូចនេះ។ ដូចជាអ្នកសម្លាប់សត្វលក់រាល់ថ្ងៃ សត្វទាំងនោះមុននឹងត្រូវគេសម្លាប់ តែងតែស្រែកអង្វរករចំពោះពេជ្ឈឃាតទាំងនោះ មិនថាជ្រូក មាន់ ទា គោ ក្របី.... តើដែលឃើញអ្នកសម្លាប់ទាំងនោះ ធ្លាប់ឲ្យអភ័យដល់សត្វទាំងនោះទេ? នេះជាការសាងកម្មទុក ដែលកម្មនេះត្រូវរៀបចំ ឲ្យសមទៅតាមពូជ (អំពើ) ដែលខ្លួនបានសាបព្រោះទុក យ៉ាងណាមិញមាតាបិតាមហានគរនិងញាតិវង្សា ក៏លោកត្រូវទទួលផលវិបាករបស់កម្ម ដែលខ្លួនបានសាងសន្សំទុកមកហើយនោះ គឺពុំអាចកែប្រែនឹងគេចឲ្យរួចបានឡើយ (សូមមើលកម្លាំងកម្ម ដែលបានសម្ដែងទុកក្នុងគម្ពីរព្រះពុទ្ធសាសនា)។*

**<u>ច.វគ្គទី៦</u>**( មានតួអក្សរ៨តួគឺ ***យ រ ល វ ស ហ ឡ អ***)

**<u>២៦.អំពីព្យញ្ជនៈ( យ )</u>** *(ព្យញ្ជនៈទី១ក្នុងវគ្គទី៦)*

*សូរសម្លេងរបស់ព្យញ្ជនៈ***យ** *មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។*

**<u>ពន្យល់ពាក្យ</u>**(មានសូរដូច**យ**)

**យក៍**ព. សា. ( កិ. ) (អ. ថ. យ) យក : ហ៍យក៍ចុះ ! (ហ៍យកចុះ); អាវំបល់យក៍ ! (ពាក្យជេរទ្រគោះច្រឡោះបោះ); ចុះឯងយក៍អីវ៉ាន់អស់ហ្នឹងពីណាមក៍ ? (និយាយចំពោះឥស្សរជនពុំបានឡើយ) ។ (ដកចេញពីវចនានុក្រមសម្ដេច)

បើតាមន័យរបស់ព្យញ្ជនៈ**យ** ភាសានិយាយគឺ**យក៍ = យក** ដល់ពេលវេលា ដែលត្រូវយករឿងសាសនៈបណ្ដាំព្រះម៉ែ មកបើកបង្ហាញឲ្យកូននាគទាំងអស់បានដឹង ពីសាវតាពិតរបស់អ្នកកកើតទឹកដីមាតុភូមិនេះ ដែលលោកគឺជាឬសកែវរបស់យើងទាំងអស់គ្នា។

**២៧.អំពីព្យញ្ជនៈ(រ)** (ព្យញ្ជនៈទី២ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**រ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**រ**)

**រ** ស. ( ន. ) បង្កោល, ឃ្នង, របងបោះរាំងក្នុងទឹកជាគ្រឿងការពារសត្វទឹកដែលសាហាវមិនឲ្យចូលមកបាន : បោះររាំងបាំងកន្លែងចុះងូតទឹកទន្លេ។ (ដកចេញពីវចនានុក្រមសម្ដេច)

**រក៍** ( កិ. ) រក។ពាក្យសាមញ្ញសម្រាប់និយាយរហ័ស : មក៍រក៍អី ? ដើររក៍សព្វអន្លើហើយមិនឃើញទេ។ (ដកចេញពីវចនានុក្រមសម្ដេច)

សូររបស់ព្យញ្ជនៈ**រ** បានបញ្ជាក់ប្រាប់ន័យដល់យើងថា ត្រូវ**រក៍ = រក** អ្វីមកបញ្ជាក់ជាភស្តុតាងសំអាង ដើម្បីការពារនៅឧបសគ្គ ដែលត្រូវមករារាំងជាថ្មី បង្កើតជាគ្រោះភ័យទៀត។ **យក៍ចេញម៍**ហើយ រួចបើកបង្ហាញ**រក៍**អ្នកយល់ចិត្ត ជួយរំកពុនគាំទ្រ អ្នក**ក**ឲ្យចាកចេញពីទុក្ខធ្ងន់ ហើយតបគុណអនន្តដល់ព្រះទាំងពីរ។

**២៨.អំពីព្យញ្ជនៈ(ល)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**ល** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ល**)

**ល**( កិ. ) ល្បង, លង : លឲ្យដឹង; កុំអាលចាំលមើលសិន ! ។ជន្លល្បងមើល : លកាប់។លលើកាប់ក្រោមកិ. វិ. ឬគុ. (ព. ប្រ.) ដែលនិយាយលូកលរាវរកផ្លូវរកទំនងហាក់ដូចគេលើកគ្រឿងសស្ត្រាជន្លខាងលើឲ្យភ័ន្តហើយលូកកាប់ខាងក្រោម : និយាយលលើកាប់ក្រោម;សម្ដី-- ។លលេងល្បងលេង, ជន្ល

លេង : និយាយលលេង; សម្ដី- ។លលែងៗលហើយលែងៗហើយលរឿយៗ។ល។ព. ទ. បុ. យកកទៅលអន្ទាក់ហុចទំនងឲ្យជាប់កុនជាប់ដំណើរ... ។(ដកចេញពីវចនានុក្រមសម្ដេច)

បើតាមសូរព្យញ្ជនៈ**ល**នេះ បានប្រាប់ន័យឲ្យយើងដឹងថា ល្បង**ល**សាកមើលថា តើកូននាគទាំងអស់ សុខចិត្តបែរក្រោយ សាកល្បងពិចារណារឿងគំនិត បង្កប់ទុកក្នុងភាសាថ្ម(គ) ភាសានិយាយ សរសេរ ទំនៀមទម្លាប់ប្រពៃណី សាសនា ឈ្មោះភូមិស្រុក ល្បែងប្រជាប្រិយ ពិធីបុណ្យផ្សេងៗ.... ឬទេ? បើយើងមិនសាកល្បងឆ្ងល់នោះ អ្វីៗដែលជាកេរមរតករបស់អច្ឆរា នឹងក្លាយជារឿងក្នុងសាសនាទាំងអស់ ដែលបរទេសធ្លាប់**ឆ**កុហកយើង។

**២៩.អំពីព្យញ្ជនៈ(វ)** (ព្យញ្ជនៈទី៤ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**វ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**វ**)

**វ** ស. (ន.) យានមួយប្រភេទមានកែ្រ, ដងស្នែង, ដំបូលសម្រាប់ឥស្សរជនថ្នាក់ខ្ពស់ជិះមានមនុស្សសែង : គង់លើ-វ, ជិះវ (មានប្រើច្រើនតែក្នុងសម័យពីដើម); វ. ស. ព្រះវរចម្មតា; (ព្រះសិវិកា ឬព្រះទីន័ងសិវិការមានក្បាច់រចនាវិចិត្រ) ។(ដកចេញពីវចនានុក្រមសម្ដេច)

**វរ** (កិ.) ទាស់ការ, ទាស់ទំនង; នាំឲ្យមានរវល់ឥតប្រយោជន៍; នាំឲ្យទាស់ដំណើរ។វរហើយ ! ទាស់ហើយ ! ។កុំវរ ! កុំរវល់ !; នាំវរនាំរវល់; វររឹកឬរឹកវរច្របូកច្របល់; ធ្វើឲ្យច្រឡំបល់, ឲ្យទាស់ការ។វររឹកទទឹកស្ងួត (ព. ប្រ.) ច្របូកច្របល់ដូចគេយករបស់ទទឹក ដាក់លាយនឹងរបស់ស្ងួត (ព. សា.) : វររឹកទទឹកស្ងួតអស់ទៅហើយ ! (ដកចេញពីវចនានុក្រមសម្ដេច)

**វរ** សំ. បា. (គុ.) (វរ) ប្រសើរ, ខ្ពស់ខ្ពស់, លើសលន់, ថ្លៃថ្លា; ជាចម្បង; ដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសយក; ដែលគួរសូម,... ។ន. ពរ (ម. ព. ព្រះផង) ។ប្រើផ្សំនឹងសព្ទដទៃបានតាមគួរដល់ការប្រកប, ដូចជា : វរគុណគុណដ៏ប្រសើរ, គុណគាប់។វរចក្រចក្រដ៏ប្រសើរ។វរជនជនប្រសើរ។វរជ័យជម្នះដ៏ប្រសើរ។វរញ្ញូអ្នកដឹងធម៌ដ៏ប្រសើរ (ព្រះពុទ្ធ) : ព្រះវរញ្ញូ។វរតនូឬវរនារីស្ត្រីល្អឆ្នើម។វរទានការឲ្យពរ; ការឲ្យរង្វាន់។វរនាថពំនាក់ដ៏ប្រសើរ។ វរបិតាបិតាប្រសើរ (បិតាក្សត្រិយ៍) : ព្រះវរបិតា។វរបុរសបុរសប្រសើរ, ប្រុសថ្លៃ។វរមន្ត្រីមន្ត្រីប្រសើរ; ខ្មែរប្រើជាថ្នាក់ឋានន្តរនៃមន្ត្រីជាន់ខ្ពស់ផ្នែករដ្ឋបាល, នៅត្រង់ចន្លោះថ្នាក់អនុមន្ត្រីនិងឧត្ដមមន្ត្រី។វរមាតាមាតាប្រសើរ (មាតាក្សត្រិយ៍) : ព្រះវរមាតា។វរមិត្តឬ--មិត្រមិត្រប្រសើរ។វរយោសិតស្ត្រីមានរូបល្អ, នាងឆើតឆោម, ស្រីថ្លៃ។វររាជស្ដេចប្រសើរ។វរលញ្ឆករ

ត្រាដ៏ប្រសើរ (ព្រះរាជមុទ្រា) : ព្រះវរលញ្ឆករ។វរលក្ខណ៍លក្ខណៈដ៏ប្រសើរ; ដែលមានលក្ខណៈដ៏ប្រសើរ។ វរវង្សវង្សដ៏ប្រសើរ; ដែលមានវង្សខ្ពង់ខ្ពស់។វរវណ្ណិនី ស្ត្រីមានសម្បុរល្អ, នាងឆើតឆោមឬនាងឆោមឆាយ។វរវៀងជ័យ (ម. ព. វៀងជ័យ) ។វរសេនិយឬវរសេនីយ៍ (វ:វរ:សេនី) : វរសេនីយ៍ត្រីឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់បន្ទាប់ពីវរសេនីយ៍ទោ។វរសេនីយ៍ទោឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់នៅត្រង់ចន្លោះវរសេនីយ៍ត្រីនិងវរសេនីយ៍ឯក។វរសេនីយ៍ឯកឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់, ខ្ពស់ផុតក្នុងថ្នាក់វរសេនីយ៍។វរោកាស (<វរ + ឱកាស) ឱកាសប្រសើរ។វរោត្តម (វ:រោត-ដំ; <វរ + ឧត្តម) ឧត្តមថ្លៃថ្លា, ប្រសើរខ្ពង់ខ្ពស់។ល។(ដកចេញពីវចនានុក្រមសម្ដេច)

សូរស័ព្ទរបស់ព្យញ្ជនៈ**ឝ** ន័យរបស់វាគឺត្រែស្នែងដ៏វិចិត្រ សែងអ្នក**ឝ**មរតកគឺអច្ឆរាយកទៅឃុំ (មើលរូបនៅក្នុងភាគ៣ រូបភាពទី៥៩រូបនៅជញ្ជាំង) នឹងសែងអ្នក**ឝ**មរតកចេញពីទីឃុំវិញ។ ទោះបីមានសត្រូវជិតឆ្ងាយ មករារាំងបង្កភាព**ខ**វរីក អ្នកត្រូវតាំងចិត្តឲ្យខ្ពស់ ដើម្បីបំពេញកិច្ចកតញ្ញូនេះព្រោះកតញ្ញូនិងកតវេទី ជាគុណធម៌ខ្ពង់ខ្ពស់ថ្លៃថ្លាចម្បង។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង កាលព្រះអង្គនៅបំពេញបារមី ជាព្រះពោធិសត្វនៅឡើយ មិនថាព្រះអង្គនៅក្នុងកំណើតមនុស្សទេ សូម្បីតែមានកំណើតជាសត្វតិរិច្ឆាន ក៏ព្រះអង្គបំពេញនូវកតញ្ញូនិងកតវេទីនេះដែរ ចុះទំរាំកូននាគប្រុសស្រីជាមនុស្ស ហើយគោរពបដិបត្តិតាមឱវាទ ដែលជាពាក្យបណ្ដាំ(សាសនៈ) របស់ព្រះសម្មាសម្ពុទ្ធទៀតនោះ តើគួរលើកតំកើងខ្លួន ឲ្យមានគុណធម៌នេះដែរឬទេ?

**៣០.អំពីព្យញ្ជនៈ( ស )** (ព្យញ្ជនៈទី៥ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**ស** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ស**)

**ស**( គុ. ) ដែលមានសម្បុរដូចសំឡីកប្បាស : ព៌ណ៌ស, សំពត់ស។សក្បុសសណាស់។សត្រសុសសម៉ដ្ឋប៉ផូរ, សផូរផង់។សភ្លឺសស្អាត។សស្គុសសត្រសោល, សបរិសុទ្ធ។សស្វាច សភ្លឺមើលទៅឃើញស្វាច។ល។(ដកចេញពីវចនានុក្រមសម្ដេច)

**ស** ( កិ. ) ចាក់បុះព្រាវដោយស្នូ : សត្រី។ព. ប្រ. សរកឲ្យឃើញសង្កេតរកព្រាវៗដោយស្មានៗឲ្យឃើញ។(ដកចេញពីវចនានុក្រមសម្ដេច)

***ស*** ( កិ. ) សម្ដែងអាការឲ្យឃើញច្បាស់, បញ្ចេញបែបឲ្យឃើញជាក់ : សសេចក្ដី, សហេតុ។ ហែកកេរ្ដិ៍ : សកេរ្ដិ៍ឬសកេរ្ដិ៍សគល់។ព. ទ. បុ. សម្ដីសជាតិមារយាទសត្រកូលសំនៀងភាសាសប្រាប់ឲ្យគេស្គាល់ជាតិឬកពាមារយាទសម្រាប់ឲ្យគេស្គាល់ពូជត្រកូល។(ដកចេញពីវចនានុក្រមសម្ដេច)

***សរ***សបា.; សំ. ( ន. ) (គរ) ព្រួញ, កាំ, កាំផ្លូ, កាំស្នា : ស្ដេចថ្លែងសរ ; ត្រូវសរ។សរជ័យសរមានជ័យ។កូនសរព្រួញ; គ្រាប់កាំភ្លើង។ល។(ដកចេញពីវចនានុក្រមសម្ដេច)

***សរ*** បា. ( កិ. ) រឭក, រឭកឃើញ, នឹកឃើញ, សាដឹងឡើងវិញ។សរជាតិដឹងជាតិ។សរញ្ញាណពិចារណាឬរំពឹងដឹងហេតុច្បាស់ ទៅខាងអតីតកាលឬខាងអនាគតកាល : ព្រះពុទ្ធទ្រង់សរញ្ញាណ... (បា. សរញ្ញាណន. ញាណឬប្រាជ្ញាជាគ្រឿងរឭកឃើញ) ។(ដកចេញពីវចនានុក្រមសម្ដេច)

បើតាមន័យបង្កប់នៅក្នុងសូរព្យញ្ជនៈ**ស** មានន័យថាភាពបរិសុទ្ធមិនប្រែពណ៌ យើងត្រូវរុករក**ស**ឲ្យឃើញ នោះនឹង**ស**បើកបង្ហាញ**ស**សេចក្ដី បើកទ្វារកេរ**អ៊ំ**ឬសកែរ**យក់ម៉**មើល តើអ្នកណាជាឬសកែវរបស់ជាតិ? បញ្ញាតាំងឡើងឲ្យខ្ពស់ បាញ់**សរ**ឲ្យឆ្ងាយ **សរ**ជាតិទៅនាយខាងក្រោយពិត នឹងឃើញសាវតារឿងអតីត អ្នកកកើតជីវិតជាតិមិនខាន។ បើគ្រាន់តែជឿអ្នកប្រាជ្ញក្រៅ ភាពល្ងិតល្ងង់ខ្លៅជិតជាប់ប្រាណ កូនដោះប្រស្នាក្នុងសង្គ្រាន្ត ឃើញព្រហ្មមានខ្លួន ពេញបរិបូរណ៍។

**៣១.អំពីព្យញ្ជនៈ( ហ )** (ព្យញ្ជនៈទី៦ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**ហ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

## **ពន្យល់ពាក្យ**(មានសូរដូច**ហ**)

***ហ*** !ឬហ៍!( និ. ) ពាក្យសម្រាប់ប្រើក្នុងការហុច, ក្នុងការប្រគល់អ្វីៗឲ្យគ្នា ឬប្រើក្នុងការតឿនជាសញ្ញាឲ្យស្រុះគ្នា; ប្រើបានចំពោះតែទៅរកបុគ្គល អ្នកតូចជាងឬស្មើគ្នា។ ហជាពាក្យបង្អួសវែងសម្រាប់តឿនឲ្យស្រុះគ្នា ឬឲ្យអ្វីៗយ៉ាងយឺតមិនប្រញាប់មិនបង្ខំ : ហលើក ! ។ហ៍ជាពាក្យរស្សៈមានសំឡេងខ្លីសម្រាប់ប្រើការប្រញាប់ : ហ៍យកចុះ ! ។ម. ព. ហោះហ៍ឬហែះហ៍ផង។ហ៍ ! (ដកចេញ ពី វចនានុក្រមសម្ដេច)

សូរបង្កប់ក្នុងព្យញ្ជនៈ**ហ**(ហ៍) ន័យរបស់ពាក្យគឺហុចឲ្យគ្រប់គ្នា ទទួលយកនៅបណ្ដាំព្រះម៉ែមហានគរ ទៅគិតពិចារណាឈ្វេងយល់ ថាតើរឿងនេះត្រឹមត្រូវ សមតាមហេតុនិងផលដែរឬទេ? បើត្រឹមត្រូវកូននាគទាំងអស់ ត្រូវលើកតំកើងមាតានាគបិតានាគ ដោយស្រុះគ្នាឈប់មើលបំណាំគ្នាទៀតហើយ។ មនុស្សអាចទៅបដិសន្ធិក្នុងពិភពផ្កាយបាន(សុគតិភព) ទាល់តែបុគ្គលនោះមានបេះដូងផ្កាយ (**គឺកតញ្ញូនិងកតវេទី**)។

**៣២.អំពីព្យញ្ជនៈ(ឡ)** (ព្យញ្ជនៈទី៣ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**ឡ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**ឡ**)

**ឡ** (ន.) គុកឬជើងក្រាន គុកធំទូលាយបិទជិត ទុកឲ្យមានប្រហោងតែត្រង់កន្លែង ដែលត្រូវទុកសម្រាប់ដុតឥដ្ឋ ជាដើមបង្កប់កម្ដៅឲ្យឆ្អិន : ឡឥដ្ឋ, ឡក្បឿង, ឡធ្យូង។ (ដកចេញពី វចនា នុក្រមសម្ដេច)

**ឡ** (ឧ.) សូរស្រែកឬយំឮខ្លាំង : ស្រែកឡ, យំឡ។(ដកចេញពីវចនានុក្រមសម្ដេច)

សូរសម្លេងរបស់ព្យញ្ជនៈ**ឡ** ន័យរបស់វាគឺសូរសម្រែកស្រែកយំ(ឡ) ជាប់ឃុំក្នុងគុហារ(ឡ) ដូចជាធនជ័យគាត់ជាប់នៅក្នុងឃុំ ហើយអាចលួចចេញមកបង្ហោះខ្លែងឯក ឲ្យស្រែកប្រាប់សត្រូវនិងកូននាគ ដែលជាអ្នកទទួលមរតកម៉ែ(ក្មេរ)ថា បើពូជជ័យនៅរស់ គឺពុំមាននរណាអាចយកដែនដីនាគនេះបានឡើយ។ នៅក្នុងព្យញ្ជនៈ**ឡ**នេះ គឺជាព្យញ្ជនៈដែលខុសពីព្យញ្ជនៈទាំង៣២តួ គេមានជើងសម្រាប់ឈរគ្រប់គ្នា ចំណែកព្យញ្ជនៈឡ ពុំមានជើងនឹងគេឡើយ។

**៣៣.អំពីព្យញ្ជនៈ(អ)** (ព្យញ្ជនៈទី៨ក្នុងវគ្គទី៦)

សូរសម្លេងរបស់ព្យញ្ជនៈ**អ** មិនទាន់ផ្សំជាមួយស្រៈនិងព្យញ្ជនៈ ឬផ្សំជាមួយស្រៈនិងព្យញ្ជនៈ ហើយនៅរក្សាសូរសម្លេងដើម ជាពាក្យមានន័យគ្រប់គ្រាន់អាចស្ដាប់យល់បាន ចំពោះភាសានិយាយ។

**ពន្យល់ពាក្យ**(មានសូរដូច**អ**)

**អ** ស. (ន.) ឈ្មោះប៉ីមួយប្រភេទធ្វើដោយដើមបបុស ទាំងតួទាំងអណ្ដាត ឬយកដើមបបុសធ្វើតែអណ្ដាត ឯតួធ្វើដោយដើមពកជាដើម : ផ្លុំប៉ីអ។ តាមដោយធ្លាប់បានសង្កេតរូបគំនូរ នៅជញ្ជាំងឧបោសថាគារ គឺវិហារនៅខេត្រក្រៅក្នុងប្រទេសសៀម ដែលជាងសៀមគូរក្នុងសម័យបុរាណព្រេងនាយឃើញមានរូបអ្នកភ្លេង លេងភ្លេងខ្មែរមានអ្នកផ្លុំប៉ីបបុស, ប្រហែលជាសៀមហៅថាប៉ីអខ្មែរក៏ហៅតាមសៀមដែរទៅទេដឹង ? (គួរហៅប៉ីបបុសតាមខ្មែរវិញ) ។(ដកចេញពីវចនានុក្រមសម្ដេច)

***អ*** ! ( ឧ. ) *សូរលាន់មាត់ដោយបញ្ជាក់សេចក្ដី ឬដោយបាត់ងឿងឆ្ងល់ជាដើម : អ ! ដូច្នោះទេឬ ?; អ៎ ! ឯណោះទេហ: ? អ៎ ! អញ្ជើញមក !  អ៎ !(ដកចេញពីវចនានុក្រមសម្ដេច)*

***អរ*** *អ  ( កិ. )  មានអំណរ, មានសោមនស្ស, រីករាយចិត្ត, មានចិត្តរីករាយ : អរព្រោះបានទ្រព្យគាប់ចិត្ត; បានឮថាកូនប្រឡងជាប់ខ្ញុំអរណាស់ ! ។អរគុណអរចំពោះគុណគេ, មានអំណរគុណគេ : ដោយគេបានជួយសង្គ្រោះខ្ញុំបន្តិចប៉ុណ្ណឹង  ខ្ញុំនឹងអរគុណគេមិនភ្លេច។អរគុណ  !  ពាក្យសម្រាប់ទទួលអំណរចំពោះគុណគេ ក្នុងទីចំពោះមុខ។ តាមធម្មតារបស់អ្នកសុភាពឬអ្នកមានច្បាប់, សូម្បីគ្រាន់តែគេហុចអ្វីបន្តិចបន្តួច  ឲ្យមកខ្លួនឬគេគូសឈើគូសកាន់ឲ្យខ្លួនអុជបារីប៉ុណ្ណោះ ក៏ត្រូវបញ្ចេញវាចាអរគុណគេថាអរគុណ ! ឬថាអរគុណលោក !, អរគុណអ្នក ! ... ។អរភិតអរភ័យអរៗភ័យៗគឺអរខ្លះភ័យខ្លះម្ដងៗ។ អរសាទរអររីករាយដោយសាទរ។ អរអេកអរខ្លាំងស្ទើរភ្លេចខ្លួន,អរឆ្អែឆ្អា។ល។ (ដកចេញពីវចនានុក្រមសម្ដេច)*

*សូរសម្លេងក្នុងព្យញ្ជនៈ***អ**  *ន័យបង្កប់ក្នុងពាក្យគឺសម្លេងភ្លេង(ប៉ី) ដែលស្រែកប្រកាសប្រាប់  ពីសោមនស្សចិត្តកើតឡើង  ដោយហេតុអ្វី?  ពេលដែលកូននាគដឹងន័យ  បង្កប់ក្នុងព្យញ្ជនៈតួទីមួយដាច់ខាតត្រូវតែស្គាល់ន័យក្នុងព្យញ្ជនៈតួបញ្ចប់គឺ***អ***នេះ។   បើខ្មែរស្គាល់ជាតិ   ត្រឹមព្យញ្ជនៈ***២** *គឺមានតែយក្សនឹងបក្សពួកទេ   ដែលស្គាល់***អ***(យក្សអរ)។   ការបកស្រាយក្នុងព្យញ្ជនៈទាំង៣៣តួនេះ  សម្រាប់ឲ្យកូនខ្មែរ  យកមកគិតពិចារណាឈ្វេងយល់សើរើឡើងវិញ  តើយើងគួស្គាល់ប្រវត្តិសាវតាបេះដូងអច្ឆរា ជាម្ចាស់មរតកអច្ឆរិយនេះដែរឬទេ? សូម្បីតែតួរអក្សរក្នុងព្យញ្ជនៈខ្មែរទាំង៣៣តួនេះ ក៏បង្កប់នូវភាពអស្ចារ្យដែរ  ពេលដែលយើងឆ្ងល់ រួចយកមកវែកញែករកន័យពិត ក្នុងតួព្យញ្ជនៈមួយៗ។  ទោះបីមិនទាន់ផ្សំជាមួយនឹងស្រៈ  ឬព្យញ្ជនៈឲ្យផ្លាស់ប្ដូរសម្លេងថ្មីផង  វាក៏មានន័យគ្រប់គ្រាន់អាចឲ្យយើងយកមកប្រើ  ជាពាក្យនិយាយឬសរសេរបាន។  បណ្ឌិតជំនាន់បុរាណ  លោកបានយកព្យញ្ជនៈទាំង៣៣តួ   ទៅបកពន្យល់ន័យលាយបញ្ចូលទៅក្នុងសាសនា  ដើម្បីទុកប្រស្នាឲ្យយើងចេះឆ្ងល់  ហេតុអ្វីបណ្ដាំរបស់ព្រះសម្មាសម្ពុទ្ធ  មកទើនៅក្នុងព្យញ្ជនៈទាំង៣៣តួនេះ?   ចំណែកការឈ្វេងយល់របស់ខ្ញុំ  ន័យពិតរបស់ព្យញ្ជនៈទាំង៣៣តួ  គំនិតក្នុងបណ្ដាំមាតាមហានគរ  លោកភ្ជាប់ន័យរបស់ព្យញ្ជនៈទៅនឹងភាសាគឬភាសារូប   ដែលមាននៅក្នុងប្រាសាទរាប់ពាន់  រួមទាំងមរតកម៉ែដទៃទៀត  ចំណែកការភ្ជាប់ព្យញ្ជនៈ ជាមួយនឹងសាសនា វាគ្រាន់តែជាសំបកសម្រាប់បិទបាំងសាវតាពិត របស់មាតាបិតាមហានគរតែប៉ុណ្ណោះ។ នៅក្នុងពាក្យភាសាខ្មែរ ជាភាសាដែលមានន័យក្នុងន័យនៅពេលណាដែលបណ្ដូលពាក្យ  កើតចេញពីព្យញ្ជនៈណា  ពាក្យនោះបានប្រាប់ន័យយើងជាមុនរួចស្រេចហើយ។ ឧ.  ទ្វារ = ទ + វា + រ មានន័យថា* ***ទ****របស់****វា*** *តើច្រកសម្រាប់ចេញចូលនោះ ជា****ទ****របស់អ្នកណា? គឺជា****ទ****របស់ម្ចាស់ផ្ទះ  ព្រោះ****ទ****នោះតែងនាំទឹកចិត្តម្ចាស់ផ្ទះ ចេញចូលតាមច្រកនោះ។ ក៏ប៉ុន្តែគាត់សរសេរមានថែម****រ***  *មានន័យថាគាត់ឲ្យយើង   រក៍(រក)អ្វីមកបិទបាំងច្រកនោះ   ការពារមនុស្ស*

*អាក្រក់ ដែលមានឈ្មោះថាចោរ។ ព្រោះពាក្យចោរ ក៏សរសេរដាក់**រ**ដែរ គឺរក៏លួច ដូច្នេះច្រកទ្វារនោះត្រូវរក៏អ្វីមកបិទបាំងការពារ នេះគ្រាន់តែជាការបកស្រាយក្នុងពាក្យមួយ ក្នុងចំណោមរាប់ម៉ឺនពាក្យ។*

## III.ព្យញ្ជនៈខ្មែរទាំង៣៣តួ នៅក្នុងន័យអក្សរបុរាណ បានបញ្ចូលក្នុងព្រះពុទ្ធសាសនា

**ធាតុទឹកគុណម្តាយ១២**

*ន ប ផ ព ភ ម យ រ ល វ ស ហ នៅក្នុងខ្លួនគឺ៖*

- *ន ជាទឹកប្រមាត់*
- *ប ជាទឹកកស្លេស្ម*
- *ផ ជាទឹកខ្ទុះ*
- *ព ជាទឹកឈាម*
- *ភ ជាទឹកញើស*
- *ម ជាខ្លាញ់ខាប់*
- *យ ជាទឹកភ្នែក*
- *រ ជាខ្លាញ់រាវ*
- *ល ជាទឹកមាត់*
- *វ ជាទឹកសម្បោរ*
- *ស ជាទឹករំអិល*
- *ហ ជាទឹកមូត្រ*

*ចប់គុណម្តាយធាតុទឹក១២។*

**ធាតុដីគុណឪពុក២១**

***ក ខ គ ឃ ង ច ឆ ឃ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ឡ អ***៊ូនៅក្នុងខ្លួន៖

- *ក បង្កើតជាសក់*
- *ខ បង្កើតជារោម*
- *គ បង្កើតជាក្រចក*
- *ឃ បង្កើតជាធ្មេញ*
- *ង បង្កើតជាស្បែក*
- *ច បង្កើតជាសាច់*
- *ឆ បង្កើតជាសរសៃ*
- *ជ បង្កើតជាឆ្អឹង*

- *ឈ បង្កើតជាខួរក្នុងឆ្អឹង*
- *ញ បង្កើតជាទាច*
- *ដ បង្កើតជាបេះដូង*
- *ឋ បង្កើតជាថ្លើម*
- *ឌ បង្កើតជាវាវ(សន្ទះខ្យល់)*
- *ឍ បង្កើតជាក្រពះ*
- *ណ បង្កើតជាសួត*
- *ត បង្កើតជាពោះវៀនធំ*
- *ថ បង្កើតជាពោះវៀនតូច*
- *ទ បង្កើតជាអាហារថ្មី*
- *ធ បង្កើតជាអាហារចាស់*
- *ឡ បង្កើតជាអំបែងក្បាល(លលាដ៍ក្បាល)*
- *អ បង្កើតជាខួរក្បាល*

*ចប់គុណឪពុកធាតុដី២១។*

*ហេតុអ្វីបានជាអ្នកប្រាជ្ញពីបុរាណ លោកយកព្យញ្ជនៈទាំង៣៣តួ ទៅបញ្ចូលលាយជាមួយសាសនា? ការសន្សំបារមីទាំង៣០ ឲ្យពេញបរិបូរណ៍ ព្រះអង្គត្រូវប្រើរយៈពេលសន្សំ អស់បួនអសង្ខេយ្យនិងមួយសែនផែនដី ទើបអាចត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធបាន ហេតុអ្វីបានជាគុណធម៌របស់ព្រះអង្គ មកទើត្រឹមព្យញ្ជនៈទាំង៣៣ និង ស្រៈ....? តើប្រស្នានេះ គាត់ចង់ឲ្យយើងស្វែងយល់ពីអ្វី? គឺការបកស្រាយន័យ ក្នុងព្យញ្ជនៈទាំង៣៣តួនិងស្រៈ។*

## IV.អំពីស្រៈនិស្ស័យនិងស្រៈពេញតួ

**ក.ស្រៈនិស្ស័យឬនិស្ស័យស្រៈ** (*ស្រាក់*)

**ពន្យល់ពាក្យ**(*មានសូរដូចស្រៈ*)

***ស្រៈ****បា.; សំ. ( ន. ) (សរ; ស្វរ) អក្សរដែលអាច បញ្ចេញសំឡេងខ្លួនឯងបានផង អាចនាំព្យញ្ជនៈឲ្យចេញសំឡេងបាន មានសូរព្មតាមរំពងរបស់ព្យញ្ជនៈផង។ ། ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ། ះ, (ដកចេញពីវចនានុក្រមសម្ដេច)*

**ស្រាក់** ( កិ. ) ដាក់តម្រួតៗលើគ្នាចង់រុំឬចងរួតរឹត : ស្រាក់ស្ករផែន, ស្រាក់ចាន។ចង់រុំប្រទាក់ឆ្វាក់ឲ្យណែន : ស្រាក់ដៃនឹងចូលដាល់។(ដកចេញពីវចនានុក្រមសម្ដេច)

**ស្រាក់**( ន. ) អ្វីៗដែលដាក់តម្រួតៗលើគ្នាចងរុំឬចងរួតរឹត : ស្ករមួយស្រាក់, ចានពីរស្រាក់។ ឈ្មោះចានមួយប្រភេទ មានត្រចៀកទាំងពីរខាង សម្រាប់ស៊កដាក់តម្រួតលើគ្នាក្នុងដៃយួរ : ម្ហូបមួយចានស្រាក់។គុ. ដែលចងជាស្រាក់ : ស្ករស្រាក់ស្ករផែនដែលដាក់តម្រួតៗគ្នា ខ្ចប់ដោយស្លឹកត្នោតចងរុំ។(ដកចេញពីវចនានុក្រមសម្ដេច)

ហេតុអ្វីតួអក្សរនេះមានឈ្មោះថាស្រៈ? ហេតុអ្វីស្រៈនេះ មានឈ្មោះថាស្រៈនិស្ស័យ? បើយើងមើលតាមន័យមកជាខ្មែរ ដូនតាយើងបានប្រាប់យើងថា ការច្របាច់ចូលគ្នាចងប្រមូលចូលគ្នា ការតម្រួតគ្នាចងជាបាច់ បានមានឈ្មោះថាស្រៈ សម្លេងសូរនិយាយស្មើនឹងស្រាក់។ ស្រៈមិនពេញតួ ឬស្រៈនិស្ស័យនេះមាន២១តួ គឺការប្រមូលផ្ដុំស្រាក់បញ្ចូលគ្នា បង្កើតបានជាមរតកភាសាមួយ ដែលមានន័យអាចឲ្យយើងយល់បាន។ ចំពោះពាក្យនិយាយថាស្រៈនិស្ស័យ ដូនតាគាត់បានប្រាប់យើងថា បុគ្គលណាមាននិស្ស័យ ទើបយល់ពីការស្រាក់សាមគ្គីគ្នានេះ ដើម្បីរួមប្រមូលផ្ដុំគ្នាបង្កើតជាកម្លាំង អាចគាស់កកាយនូវអាថ៌កំបាំងរបស់ជាតិ។ ក្នុងស្រៈនិស្ស័យនេះ ស្រៈ**អ**(l)ជាអ្នកនាំមុខ តើយើងមានឆ្ងល់ទេ? ហេតុអ្វីបានជាដូនតាយើង មិនយកសូរសម្លេងស្រៈ **ក ខ ច ឆ**.... ដែលស្រៈទាំងនេះមានសម្លេងតូចដូច**អ**ដែរ គាត់បែរជាយកព្យញ្ជនៈ**អ** ធ្វើជាបណ្ដូលសម្លេងស្រៈនិស្ស័យនេះ? ព្រោះគាត់ចង់ឲ្យកូននាគ ជំនាន់ក្រោយបានយល់ថា ពេលកូននាគមាននិស្ស័យបុណ្យ(កតញ្ញូ)កើតឡើង គឺយើងនឹងស្រាក់គ្នា ព័ន្ធគ្នា សាមគ្គីគ្នា នោះសូរសម្លេង**អ**(អរ) នឹងកើតឡើងក្នុងសន្ដានចិត្តកូននាគ។ ស្រៈ**អ**(l) នេះមានរាងជាបន្ទាត់ ឬបង្គោលបញ្ឈរមួយ បង្គោលនេះបើយើងយកទៅភ្ជាប់ព្យញ្ជនៈ**រ**ពីរ(ររ)ឲ្យជាប់គ្នា នឹងកើតបានព្យញ្ជនៈ**អ**នេះ។ ពាក្យ**អរ**មាន**រ**បី(ររ) រទីបីសែងស្ពានឬបង្គោលទៅភ្ជាប់ រទីពីរនិងទីមួយភ្ជាប់គ្នា ទើបកើតបានជាពាក្យ**អរ** មានន័យថាភ្ជាប់រឿងអតីតនិងបច្ចុប្បន្ន ធ្វើឲ្យយើងដឹងសាវតាពិត សេចក្ដីត្រេកអរនឹងកើតឡើង។ យើងតែងនាំគ្នាហៅសញ្ញាស្ពាននេះ ថាជាសញ្ញាវះពោះទៅវិញ វះពោះមានន័យថាកាត់ផ្ដាច់ចេញពីគ្នា បើភ្ជាប់គ្នាពី**រ**ម្ខាងទៅ**រ**ម្ខាងទៀត ពុំមែនវះពោះឡើយ តែវាគឺជាស្ពាន។ ការបកស្រាយពន្យល់ពីពាក្យ ស្រៈឬស្រាក់នេះ ខ្ញុំបាទ

គ្រាន់តែចង់ ឲ្យកូននាគបែរមកពិចារណា រាវរកហេតុផលពិត នៅក្នុងមរតកបណ្ដាំមាតាមហានគរ ដែលបានបង្កប់លាក់បញ្ចូលទុក ទៅក្នុងស្រៈនិស្ស័យនេះ។

**ខ.ស្រៈពេញតួ**

ស្រៈពេញតួមាន១៣តួគឺ**អអា**, **ឥឦ**, **ឧឩ**, **ឬ**, **ឫ**, **ឭ**, **ឯឰ**, **ឱឳ**;ថែមស្រៈឮមួយដោយឡែកមកទៀតជា១៤តួ។ ហេតុអ្វីបានជាដូនតាយើង ហៅស្រៈនេះថាជាស្រៈពេញតួ? កាលនៅជាស្រៈនិស្ស័យ គ្រាន់តែជាសញ្ញាបង្កប់នៅ បន្ទាត់មួយតែប៉ុណ្ណោះ ដែលយើងហៅថាស្រៈ**អ**។ លុះមកដល់ស្រៈពេញតួ តួអក្សរស្រៈ**អ** បានបង្ហាញរូបរាងច្បាស់ឲ្យយើងស្គាល់ គឺព្យញ្ជនៈ**អ** ពុំមែនគ្រាន់តែជាបន្ទាត់ត្រង់ ឬបង្គោលឈរដូចមុនឡើយ។ កាលបើយើងស្រាក់គ្នា(ស្រៈ) សូរសម្លេង**អ**នាំមុខ ពេលដែលយើងស្វែងរកអ្នក**ឥ អ**ទៅនៅពីខាងក្រោយវិញ ប្រស្នាគាត់ចង់ប្រាប់យើងថា កាលនៅជាស្រៈ **អ** ជាអ្នកនាំមុខ ពេលក្លាយជាព្យញ្ជនៈ**អ**ទៅនៅពីក្រោយ (សូមមើលការពន្យល់ព្យញ្ជនៈទាំង៣៣តួទំព័រមុន)។ នេះជាប្រស្នាបង្កប់ ដែលដូនតាយើងបានបញ្ចូលទៅលាក់ទុក ក្នុងស្រៈទាំងពីរបែបនេះ គឺស្រៈនិស្ស័យនិងស្រៈពេញតួ ហេតុដែលមានឈ្មោះយ៉ាងនេះ ដូចបានពន្យល់រៀបរាប់ខាងលើ។ ឈាមជ័ររបស់អ្នក**ឥ**មរតកនេះទុក មិនអាចផ្ដាច់ចិត្តចេញពីកេរ ដែលខ្លួនបានហួងហែងឡើយ សេចក្ដីប្រកាន់ខ្ជាប់នៅសណ្ឋិតជាប់ជានិច្ច ឲ្យតែកូននាគចេះយកមក រែករៀកររូចពិចារណា នោះនឹងឃើញរឿង របស់ម្ចាស់មរតកនេះជាពុំខាន។

## V.អំពីអត្ថន័យបង្កប់ក្នុងលេខខ្មែរ (សម្ដីជាឯក លេខជាទោ អក្សរជាត្រី)

ហេតុអ្វីនៅក្នុងសុភាសិតខ្មែរនេះ បណ្ឌិតលោកទុកលេខ ក្នុងលំដាប់លេខ២ដូច្នេះ? តើក្នុងលេខខ្មែរ មានបង្កប់ប្រស្នាអាថ៌កំបាំងអ្វីខ្លះ ទៅនឹងរឿងបណ្ដាំមាតាមហានគរ? លេខខ្មែរបើយើងរាប់ គឺមានចំនួនត្រឹមប្រាំ(៥ចំពោះខ្ទង់រាយ) ផុតពីប្រាំទៅត្រូវបូក ប្រាំបូកមួយស្មើប្រាំមួយ(៦) ប្រាំបូកពីរស្មើប្រាំពីរ(៧) ប្រាំបូកបីស្មើប្រាំបី(៨) ប្រាំបូកបួនស្មើប្រាំបួន(៩) លេខដប់គឺប្រាំដណ្ដប់លើប្រាំ(ដប់ស្មើនឹងប្រាំដណ្ដប់ប្រាំ)។ ផុតពីដប់ទៅគឺមួយដណ្ដប់(មួយដណ្ដប់លើដប់) ពីរដណ្ដប់(ពីរដណ្ដប់លើដប់)..... ចំពោះភាសានិយាយ ចំណែកភាសារអាន គឺដប់មួយដប់ពីរ...។ល។ ហេតុអ្វីលេខខ្មែរមានត្រឹម**ប្រាំ** ផុតពីប្រាំត្រូវបូកយ៉ាងនេះ? ពាក្យប្រាំបើដកជើង**រ**មកដាក់ខាងមុខ ក្លាយជាពាក្យ**របាំ** យក**រ**ទៅត្រួត**បាំ**ឃើញពាក្យ**ប្រាំ** យក**រ**មកដាក់ពីក្រោយ**ប**ឃើញពាក្យ**បរាំ**។ ហើយលេខ៥នេះ បើយើងតាំ

រៀបលេខដូចម្រាមដៃ ជាកញ្ចុំរង្វង់មូល រួចយើងផ្គុំចំណុចពីម្រាមមួយទៅម្រាមមួយ នោះសញ្ញាគំនូសបានបង្ហាញប្រាប់យើងថា ក្មេរពូជប្រាំគឺជាពូជផ្កាយ ពូជផ្កាយនេះហើយ ដែលបានបន្សល់ទុក នៅសំណាង់ប្រាសាទថ្មរាប់ពាន់ ដែលប្រាសាទទាំងនោះ បានឆ្លុះទៅនឹងផ្កាយលើមេឃ។

**ក.អត្ថន័យបង្កប់ក្នុងលេខមួយ(១)**

មួយពាក្យសរសេរជាអក្សរ មួយប្រកបចេញពីព្យញ្ជនៈ**ម** ហើយពាក្យមនេះខ្ញុំបានពន្យល់ ក្នុងព្យញ្ជនៈខាងលើហើយ ម៍(ទៅ) មរ(ស្លាប់) មរ(ភក់ខ្មៅ)។ លេខមួយគឺមុនគេមុខគេ ដូច្នេះន័យឬឋានៈរបស់វា ស្មើនឹងព្យញ្ជនៈ**ក** ព្រោះអ្នក**ក**ត្រូវដេកស្លាប់(មរ) ក្នុងភក់ខ្មៅ(មរ) រងចាំកូននាគទៅជួយស្រង់គាត់ ចេញពីទីទុក្ខនោះ។ នៅក្នុងរឿងព្រះធម្មសេនាបតីសារីបុត្រ ព្រះអង្គជាអគ្គសាវកស្តាំ លោកបានជួយស្រង់មាតាលោក ដែលមានកំណើតក្នុងអបាយភូមិ កាលពីប៉ុន្មានជាតិកន្លងទៅ។ ព្រោះមាតាលោក បានមកឲ្យនិមិត្តដល់លោក ដើម្បីឲ្យលោកជួយ ពេលព្រះសារីបុត្រលោកបានជ្រាបដឹង លោកក៏បានថ្វាយទានចំពោះសង្ឃ ដែលបដិគ្គាហកអ្នកទទួល គឺសុទ្ធតែជាព្រះអរហន្តអស់អាសវៈកិលេស ទីបំផុតមាតាលោក ដែលមានកំណើតជាប្រេតនោះ បានរួចចាកផុតពីទុក្ខហើយទៅសោយសម្បត្តិសុខក្នុងទេវលោក។

យ៉ាងណាមិញ រឿងមាតាមហានគរក្មេរ ប្រវត្តិសាវតារបស់លោក ក៏ដូចជារឿងមាតាព្រះសារីបុត្រដែរ ពាក្យត្រឡប់ មួយចាំកូនជ = មរចាំកូនជួយ ព្រោះភក់ខ្មៅនិងមរណៈ គឺតំណាងឲ្យទីទុក្ខនិងស្លាប់ មានតែរងចាំកូននាគ ជំនាន់ក្រោយរបស់គាត់តែប៉ុណ្ណោះ ទើបមានសង្ឃឹមរួចពីមរភក់ និងមរណៈ នេះជាអត្ថន័យបង្កប់ក្នុងពាក្យ សរសេរជាអក្សរលេខមួយ(១)។

**ខ.អត្ថន័យបង្កប់ក្នុងលេខពីរ(២)**

ហេតុអ្វីអក្សរសរសេរ ពាក្យលេខ២មាន**រ**? ព្រោះដូនតាគាត់ចង់ឲ្យយើងរក៏មួយ មកគួបបូកនិងមួយកើតបានជាពីរ គ្រប់ពាក្យក្មេរពេលដែលសរសេរ មានដាក់**រ**ពីខាងក្រោយ គឺប្រស្នារបស់ពាក្យឲ្យយើង**រ**(រក៍)។ លេខ២សរសេរជាអក្សរគឺ**ពីរ** ដែលមានព្យញ្ជនៈ**ព**ជាបណ្តូលពាក្យ ហើយសួរព្យញ្ជនៈ**ព**នេះ ន័យទីមួយគឺលើកឡើង ន័យទីពីររក្សាផែនដី ន័យទីបីគុណជាតិប្រសើរគួប្រាថ្នា ន័យទីបួនគឺបិទរន្ធទឹកកុំឲ្យលិចចូល (សូមមើលការបកស្រាយពិស្តារនៅក្នុងព្យញ្ជនៈព)។ ពាក្យត្រឡប់របស់លេខពីរគឺ ពីរាជន = ពរាជនី លើកឡើងចេញពីទីទុក្ខ ដែលគាត់បានដេកស្លាប់ចេញពីសន្តាន

ចិត្តកូននាគសម័យក្រោយ ក្នុងភក់ខ្មៅ ឬអបាយភូមិ(មរ)តែម្នាក់ឯង យើងគួរនាំគ្នាជួយលោក ឲ្យបានរួចពីទុក្ខ ហើយទៅសោយសុខក្នុងសុគតិភព ដោយអំណាចការដឹងគុណ និងតបគុណ។

**គ.អត្ថន័យបង្កប់ក្នុងលេខបី(៣)**

អត្ថន័យបង្កប់នៅក្នុងពាក្យសរសេរលេខបី ទោះពុំទាន់បកស្រាយ ក៏អាចងាយយល់ជាងពាក្យពីរ ព្រោះពាក្យបីគឺបីត្រកងឡើង យកមកផ្គោបជាប់នឹងដើមទ្រូង ន័យគឺពផងបីផង លើកគាត់ឡើងចេញពីទីទុក្ខ នាំទៅដាក់ក្នុងទីសុខ ដោយកម្លាំងកតញ្ញូនិងកតវេទី។ ពាក្យសរសេរសម្គាល់លេខ៣នេះ មានព្យញ្ជនៈ**ប**ជាបណ្តូលរបស់ពាក្យ ហើយព្យញ្ជនៈ**ប**នេះ សូមមើលការបកស្រាយក្នុងព្យញ្ជនៈ៣៣តួខាងលើ។ ពាក្យត្រឡប់លេខបីគឺ បីស្រៈអ = បស្រៈី គឺបីផងស្រាក់ដៃសាមគ្គីគ្នាផង ទើបជួបអរ ឬបរនាំចេញរឿងសិរី(ស្រី)បីប្រការ។

**ឃ.អត្ថន័យបង្កប់ក្នុងលេខបួន(៤)**

អត្ថន័យនៅក្នុងពាក្យសរសេរលេខបួន អក្សរសរសេរក៏មានព្យញ្ជនៈ**ប** ជាបណ្តូលពាក្យដែរ ពាក្យត្រឡប់លេខបួន គឺបួនទាំងខ្លី = បីទាំងខ្លួន។ ហេតុអ្វីបានត្រូវបីទាំងខ្លួន? ព្រោះទេពធីតាទាំង៧រាល់ឆ្នាំ ក្នុងថ្ងៃមហាសង្ក្រាន្ត ទេពធីតាដែលត្រូវវេន គឺពបីដង្ហែតែសិរសា(ក្បាល) កបិលមហាព្រហ្មតែប៉ុណ្ណោះ។ នៅក្នុងឆ្នាំរោង ចត្វាស័ក ពុទ្ធសករាជ ២៥៥៦នេះ ព្រហ្មម៉ែ ព្រហ្មឪមាន ដងខ្លួនពេញលេញវិញហើយ ដូច្នេះឆ្នាំនេះគឺជាឆ្នាំព្រហ្មម៉ែឪ លោកមានរូបរាងកាយគ្រប់គ្រាន់ មិនដូចពីមុន ព្រហ្ម នាគ និងរូបតំណាងឲ្យមាតាផ្សេងៗទៀត មានតែសិរសា(ក្បាល) ពុំមានដងខ្លួននិងអវយវគ្រប់គ្រាន់។

**ង.អត្ថន័យបង្កប់ក្នុងលេខប្រាំ(៥)**

នៅក្នុងអត្ថន័យបង្កប់ពាក្យសរសេរលេខ**ប្រាំ** = **បរាំ** = **របាំ** ពាក្យនេះមានព្យញ្ជនៈ**ប**ជាបណ្ដាល និងថែមជើងព្យញ្ជនៈ**រ**មួយអមខាងក្រៅទៀត។ ក្នុងលេខទាំងបីខាងចុងនេះ មានព្យញ្ជនៈ**ប** ទាំងបីលេខ គឺលេខបី លេខបួន លេខប្រាំ ព្រោះបរនាំគាត់ចេញពីទ្វារឃុំទាំងបី (មើលការពន្យល់រូបក្នុងភាគ២ និង៣)។






*លក្ខណៈរូបភាពរបស់លេខ**៥** និងព្យញ្ជនៈ**ង** សុទ្ធតែចងគួចខ្លួនឯងដូចគ្នា គ្រាន់តែព្យញ្ជនៈ**ង** ចង្អុលប្រាប់ទិសពីអតីតកាល គឺគួចបែរទៅក្រោយ រីឯលេខ**៥**ចង្អុលគួចប្រាប់ទិសទៅខាងមុខ ប្រស្នាចងគួចព្យញ្ជនៈនិងលេខនេះ ពេលដែលយើងផ្គុំគ្នារួចស្រាយលា នោះនឹងឃើញចម្លើយសាវតារបស់ជាតិ។ បើតាមការបកស្រាយលេខ**៥**នេះ ឲ្យភ្ជាប់ទៅនឹងន័យរបស់ព្យញ្ជនៈ និងភ្ជាប់ទៅក្នុងរឿងបណ្តាំមាតាមហានគរ ទើបយើងដឹងថា លោកយករឿងរបស់ខ្លួន ទៅលាយបញ្ចូលក្នុងមរតកអច្ឆរិយទាំងអស់ ដែលមាននៅក្នុងមាតុភូមិនេះ។ ហើយប្រស្នាលេខខ្ទង់រាយក្មេរ មានត្រឹម**៥**នេះ ត្រូវផ្សាភ្ជាប់ទៅនឹងប្រស្នា ប្រាសាទពីរាមីតលើពិភពលោក គឺមានតែពូជ**៥** ដែលជាពូជផ្កាយ ពូជនាគទេ ដែលអាចយល់ពីអាថ៌កំបាំង រូបភាព គំនូរចម្លាក់ ក្នុងប្រាសាទពីរាមីតនៅពិភពលោកនេះបាន ទាំងក្នុងអតីតនិងបច្ចុប្បន្ន។*



**<u>ច.អត្ថន័យបង្កប់ក្នុងលេខដប់</u>**(**១០**)

*អត្ថន័យបង្កប់ពាក្យសរសេរនៅក្នុងលេខដប់(១០) គឺមានព្យញ្ជនៈ**ដ** ជាបណ្តូលរបស់ពាក្យ (មើលការពន្យល់ ព្យញ្ជនៈដខាងលើ) ពាក្យដប់នេះគឺ ចេញមកពីពាក្យ**ប្រាំដណ្តប់លើប្រាំ** = **១០**។ ប្រាំតំណាងឲ្យបរទេស មកបិទដណ្តប់លើពូជប្រាំ ពូជនាគ ពូជផ្កាយ ពូជអ្នកទទួលកេរមរតកម៉ែ (ក្មេរ) ពូជអច្ឆរិយ(អច្ឆរា) ឲ្យលិចចុះក្នុងទីងងឹត មិនអាចបញ្ចេញពន្លឺរស្មីរបស់ខ្លួនបាន (មើលការពន្យល់រូប នេះក្នុង ភាគបី)។ ទាល់តែមានកូននាគណា ស្ម័គ្រចិត្តចុះទៅញែកការដណ្តប់នេះ ឲ្យឃ្លាតចេញពីគ្នា ទើបអាចបើកអាថ៌កំបាំងរាប់ពាន់ឆ្នាំមុន របស់អ្នកបង្កើតពូជនាគ និងទឹកដី (មើលប្រស្នាភាសាគចិនមកយកនគរ ដែលអ្នកប្រាជ្ញចិនលើកម្រាមប្រាំ ធនជ័យលើកម្រាមមួយ)។ ហើយផុតពី*

ដប់ទៅ គឺគេរួមគ្នាដណ្ដប់ពីលើយើង ធ្វើឲ្យយើងលែងមើលស្គាល់ សារតាពិតរបស់ខ្លួន ចង់ស្គាល់ពូជខ្មែរ ប្រវត្តិខ្មែរ ត្រូវតែសិក្សាពីបរទេស (និមិត្តរូបវត្ថុដែលដណ្ដប់ពីលើប្រាំ)។

## ឆ.អត្ថន័យបង្កប់ក្នុងលេខម្ភៃ(២០)

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខម្ភៃ(២០) បើយើងសម្រាយន័យរបស់ពាក្យ យើងឃើញពាក្យពីម៉ាត់គឺ **ម** + **ភៃ** ភាសានិយាយស្មើ **ភ័យ**ហេតុអ្វីមងើបឡើងវិញបែរជាភ័យ? ព្រោះមាតាមហានគរ (ឯកសារចិនគេ ហៅគាត់ ថាបិសាចពស់) ដែលជាមេ ជាម៉ែ ជាយាយ ត្រូវបានបាបកម្មឃុំគាត់ទុក រាប់ពាន់ឆ្នាំហើយ។ បើស្ត្រីនេះបានរួចពីឃុំឃាំងវិញ គ្រោះភ័យទាំងឡាយនឹងកើតមាន ដោយការតាមចងពៀរ បិទសន្ធប់ពីសំណាក់បរទេស ខាងក្រៅមកលើរូបគាត់។ តើព្រោះហេតុអ្វី? ពីព្រោះពួកគេមិនចង់ឲ្យមាតានាគ ដែលគេបានឃុំគាត់ជាប់រាប់ពាន់ឆ្នាំនោះ រួចចេញមកសារជាថ្មីវិញឡើយ តែកម្លាំងឫទ្ធិរបស់មនុស្ស ពុំអាចឈ្នះកម្លាំងកម្មបានឡើយ ទោសរបស់គាត់បានត្រូវបញ្ចប់ជាស្ថាពរក្នុងថ្ងៃទី២ មិថុនា ឆ្នាំ២០១១។ ទោសរបស់គាត់ ដែលយក្សបានចាប់គាត់ឃុំទុកនោះ គឺម្ដាយឪពុកកូន ព្រោះពួកគាត់បានរួមគ្នា ទៅលួចយកកែវមណីរបស់យក្ស ព្រោះកែវមណីនេះ អាចឲ្យពួកគាត់សម្រេចប្រយោជន៍បានគ្រប់យ៉ាង ហេតុនេះការលួចគឺជាចោរ គេចាប់បានត្រូវដាក់ឃុំឃាំង នេះជាច្បាប់កម្ម។ ការរៀបរាប់នេះ កូននាគច្បាស់ជាយល់ថា ជារឿងហួសនិស្ស័យយល់ មិនអាចទទួលយកបាន។ ក៏ប៉ុន្តែបើកូននាគបានសិក្សា ឲ្យស៊ីជំរៅទៅក្នុងព្រះពុទ្ធសាសនា នោះគឺគ្មានអ្វីជាការលាក់កំបាំងឡើយ ព្រោះព្រះអង្គបានសម្ដែង រឿងកម្មនិងផលនេះទុកក្នុងត្រៃបិដក ដែលមានរយៈពេលជាង២០០០ឆ្នាំមកហើយ គឺមុនប្រវត្តិរឿងមាតាមហានគរ។ មិនត្រឹមតែសម្ដែង ក្នុងរឿងកម្មផលប៉ុណ្ណឹងទេ ព្រះអង្គបានសម្ដែងនូវផ្លូវឬមគ្គ លោកកុត្តរធម៌ ដែលជាធម៌ដឹកនាំសត្វលោក ឲ្យចេញចាកពីបញ្ចក្ខ័ន្ធ ឈប់ឲ្យសត្វវិលកើត វិលស្លាប់បានទៀតផង ព្រះអង្គបានចង្អុលប្រាប់យើងនៅត្រើយសុខ គឺអមតមហានិព្វាន។

## ជ.អត្ថន័យបង្កប់ក្នុងលេខសាមសិប(៣០)

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខសាមសិប ពាក្យបង្កប់ក្នុងន័យគឺ **សាមសិប** = **សាមខ្សឹប** តើសាមសិប ឬខ្សឹបពីរឿងអ្វី? គឺខ្សឹបពីរឿងកុកទាំងបី មកលេបសត្វត្រី(ស្ត្រី) មើលចាក់ទឹកដូងលើកទី២ គឺចាក់ ទឹកដូងពីទ្រូងមាតា កន្ទុយត្រីប្រាក្បាលនាងកុក អកកំបោរចាំកូនស្រង់ បំពង់ស្រីចាំកូន

រំរែក ក្បាលម៉ែប្រែកក្អែកជុះអាចម៍ដាក់ប៉ក់។ ន័យចាក់ទឹកដូងនេះខ្ញុំបានពន្យល់រួចហើយនៅក្នុងភាគ ១ ដែលខ្ញុំលើកយកមកបង្ហាញនេះ ចង់បញ្ជាក់ពីន័យលេខសាមសិប គឺខ្សឹបប្រាប់ពីរឿងកុកទាំងបីមកលេបត្រីប្រា ដែលត្រីប្រាតំណាងព្រះម៉ែ ឲ្យនៅសល់តែកន្ទុយ។ ដូច្នេះកូននាគសម័យខាងក្រោយ បានយកក្បាលក្រពើមកពាក់ សូមមើលល្បែងចាក់ទឹកដូងលើកទី១ ដែលបានបង្ហាញប្រាប់ថា កន្ទុយខ្លែងក្មេរ(កេរម៉ែ) ពាក់ក្បាលក្រពើ។

## ឈ.អត្ថន័យបង្កប់ក្នុងលេខសែសិប(៤០)

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខសែសិបនេះ គឺខ្សឹបប្រាប់ពីរឿងក្រសែ(សែ) លំអានជំនួរវង្សត្រកូលក្មេរ ដែលដាច់តំណាខ្សែលោហិតរាប់រយពាន់ឆ្នាំ ឲ្យដឹងក្រសែជំនួរឡើងវិញ។ កូននាគទាំងឡាយ ពេលអ្នកទៅទស្សនាប្រាសាទបុរាណ អ្នកនឹងប្រទះឃើញនូវចង្អូររន្ធទឹកតូចមួយ ដែលមានទរល្បៀនចេញមកក្រៅជញ្ជាំង។ ពេលណាដែលអ្នកចាក់ទឹក ក្នុងយោនីពីខាងក្នុងប្រាសាទ ទឹកនឹងហូរធ្លាក់ចេញ តាមរន្ធចង្អូរតូចនេះមកខាងក្រៅ ដែលសព្វថ្ងៃគេពន្យល់ថាជាទឹកមន្ត ឬទឹកអង្គបំពង់ស្រី។ រន្ធចង្អូរនេះ ឃើញមាននៅប្រាសាទអាស្រមឥសី នៅអង្គរបុរី ប្រាសាទបាយង្កោរ ប្រាសាទភ្នំជីសូរ....។ល។ និម្មិតរូបរន្ធចង្អូរនេះ ដូនតាយើងគាត់ចង់ប្រាប់ ឲ្យកូននាគដឹងថា រឿងក្រសែជំនួរក្នុងទឹកចិត្តម៉ែ ឬរឿងរបស់មាតា ពុំអាចស្រែកឲ្យឮខ្ទរខ្ទារបានឡើយ បានត្រឹមតែខ្សឹប(សិប)ប្រាប់ឲ្យកូននាគខាងក្រោយ ដឹងពីក្រសែស្រឡាយរបស់ខ្លួនតែប៉ុណ្ណោះ។ ព្រោះគាត់ត្រូវឃុំក្នុងគុហារ ទូលយោនីនៅពីលើក្បាល ដែលយោនីនោះតំណាងឲ្យទឹកដី(មាតុភូមិ) រួចមាត់ហាបញ្ចេញទឹកចិត្តពីក្នុងទ្រូង (មើលរូបមាតាកប់ត្រឹមកនៅភាគ៣) មកលាតត្រដាង បង្ហាញពីភាសាគ ឬខ្សឹប ដល់កូននាគខាងក្រោយ ឲ្យបានដឹងពីរឿងពិតរបស់ខ្លួន។ ដោយសង្ឃឹមថា ពេលដែលកូននាគខាងក្រោយដឹង ពួកគេនឹងរួមគ្នា លើកត្រកងពបីពួកគាត់ឡើង ទៅដាក់លើប្រាសាទភ្នំព្រះវិហារវិញ ដែលជានិម្មិតរូបព្រហ្ម ដំបូល ឬបល្ល័ង្ក។

## ញ.អត្ថន័យបង្កប់ក្នុងលេខហាសិប(៥០)

អត្ថន័យបង្កប់ពាក្យសរសេរក្នុងលេខ៥០នេះ គឺន័យរបស់ពាក្យ មាត់ហាស្រែកហៅកូន តែសម្លេង ឮត្រឹមតែខ្សឹបខ្សៀវគ្នាតែប៉ុណ្ណោះ មិនអាចឲ្យឮបានពេញទំហឹងជាទូទៅឡើយ។ ព្រោះការស្រែកហៅ របស់គាត់រាប់រយពាន់ឆ្នាំធ្វើឲ្យស្អកក នឹងម្យ៉ាងទៀតផលនៃបាបចាស់របស់គាត់ ឲ្យ

វិបាកកម្មមិនទាន់អស់។ ហាសិបបើយើងត្រឡប់ពាក្យ គឺហិបសា ឬហិបទុកសាសនៈបណ្ដាំ របស់មាតាមហានគរនេះឯង។

**ដ.អត្ថន័យបង្កប់ក្នុងលេខហុកសិប(៦០)**

ពាក្យថាហុកសិប បើត្រឡប់ពាក្យគឺហិបសុកឬសុខ បានសុខព្រោះអ្វី? ព្រោះទ្រព្យមរតកអច្ឆរិយនេះ កូននាគចាប់ផ្ដើមបើកហិបរើកកាយ រកប្រវត្តិម្ចាស់មរតកអច្ឆរិយនេះហើយ ថាតើម្ចាស់មរតក គាត់ជានរណា? បើកូននាគសើរើរកម្ចាស់ដើម អ្នកប្រមូលទ្រព្យមរតកឃើញ នឹងបានសុខ ព្រោះការដឹងគុណនឹងតបគុណ ដល់អ្នកដែលបានបំពេញពលិកម្ម ខិតខំប្រមូលទ្រព្យមរតកមកទុក ឲ្យយើងទាំងអស់គ្នា។ វាគឺជាច្បាប់របស់ធម្មជាតិឬធម្មៈ ព្រោះមាតាបិតាទុកដូចជាអ្នកស្រែកហៅ ចំណែកឯកូនប្រុសស្រី ទុកដូចជាអ្នកឆ្លើយ តើយើងគួរឆ្លើយតបទៅពួកគាត់វិញ ដោយពាក្យកតញ្ញូ ឬអកតញ្ញូ?

**ឋ.អត្ថន័យបង្កប់ក្នុងលេខចិតសិប(៧០)**

អត្ថន័យបង្កប់ទុកក្នុងលេខចិតសិបនេះ សូរសម្លេង **ចិត** = **ចិត្ត** ចំពោះសូរស័ព្ទនិយាយសាសនបណ្ដាំមាតាមហានគរ បាននិយាយខ្សឹបប្រាប់ ហូរចូលទៅដល់ក្នុងចិត្ត កូននាគហើយទោះជាមិនទាន់បានដឹងជាទូទៅ ក៏ដំណឹងនេះបានជ្រាបបន្តិចម្ដងៗ។ ពេលចិត្តកូននាគបានដឹងរឿងសាវតាររបស់ខ្លួន តាមរយៈការនិយាយខ្សឹបនេះ ចិត្តកូននាគបានភ្ញាក់រន្ធត់អារម្មណ៍ ថាគួរឲ្យសង្វេគនិងអស្ចារ្យណាស់ ដែលពីមុនខ្លួនពុំបានដឹងពីប្រវត្តិ របស់ម្ចាស់មរតកអច្ឆរិយនេះ។ ចំណែកបរទេសដែលដឹងរឿងពិតរបស់ខ្មែរ បែរជាមកកុហករួចបំភាន់ ឲ្យកូនខ្មែរនៅក្នុងទីងងឹតមិនអាចយល់ដឹង ពីប្រវត្តិរបស់អ្នកបង្កើតជាតិ ដោយបង្វែរឲ្យដឹង ពីរឿងផ្សេងទៅវិញ។

**ឌ.អត្ថន័យបង្កប់ក្នុងលេខប៉ែតសិប(៨០)**

អត្ថន័យបង្កប់ទុកក្នុងលេខប៉ែតសិបនេះ គឺខ្សឹបប្រាប់ឲ្យបានដឹង ពីរឿងប្រវត្តិកំណើតរបស់ខ្លួន ហើយត្រេកអរព្រឺព្រួចសប្បាយ ពេលដែលកូននាគបានដឹងពីសាវតាពិតរបស់ខ្លួន ព្រោះពាក្យ **ប៉ែត** = **ប៉ែតី** = **បេតី** = **បីតិ** ឬសោមនស្ស ត្រេកអរ។

## ឍ.អត្ថន័យក្នុងលេខកៅសិប(៩0)

នៅក្នុងពាក្យសរសេរលេខ៩០នេះ ន័យរបស់ពាក្យគឺមានពាក្យ **កៅ** = **កៅអី** = **បល្ល័ង្ក** តើខ្សឹបប្រាប់ពីរឿងអ្វី? ខ្សឹបប្រាប់ពីរឿងកៅអីទទេ ឬបល្ល័ង្កទទេ ព្រោះយើងមានឈ្មោះប្រាសាទ បយ័ង្កកោរ ឬបាយ័ង់កោរ ដែលមានន័យថាបល្ល័ង្កទទេឬកៅអីទទេ។ តើម្ចាស់ដែលអង្គុយលើកៅអីឬបល្ល័ង្កនេះទៅណា? ទើបពាក្យសម្គាល់លេខកៅសិបនេះ បានខ្សឹបប្រាប់ពីរឿងម្ចាស់បល្ល័ង្ក ឬកៅអីដែលលោកបានទៅសោយទុក្ខ ក្នុងអបាយភូមិតែម្នាក់ឯង ដោយទុកឈ្មោះបល្ល័ង្កទទេថា មាតុភូមិ ឬភូមិមាតុ = មាតា ដែលម្ចាស់មាតុភូមិនេះ កូននាគពុំបានដឹងប្រវត្តិរឿងជូរចត់គាត់ឡើយ។

## ណ.អត្ថន័យបង្កប់ក្នុងលេខមួយរយ(១00)

នៅក្នុងពាក្យសរសេរសម្គាល់លេខមួយរយនេះ មានពាក្យ **មួយ** + **រយ** ពាក្យសរសេរមួយខ្ញុំបានពន្យល់រួចហើយ ចំណែកពាក្យរយគឺមានន័យថា រៀបចំឲ្យមានសណ្ដាប់ធ្នាប់ របៀបរៀបរយ។ ព្រោះភាសានិយាយ យើងតែងប្រើពាក្យថារៀបនិងរយ គឺរៀបចំឲ្យមានបែបផែន រយរៀបឬរយ អ្នករៀប គឺ**មួយ** = **ម៉ៃ**= **មរ** ឡើងមករៀបចំឲ្យបានរៀបរយឡើងវិញ។

## ត.អត្ថន័យបង្កប់ក្នុងលេខមួយពាន់(១000)

ពាក្យសរសេរសម្គាល់លេខមួយពាន់(១០០០) អត្ថន័យបង្កប់ក្នុងពាក្យសរសេរ ដូនតាគាត់ចង់និយាយប្រាប់កូននាគឲ្យបានដឹងថា សូរក្នុងពាក្យនិយាយ **ពាន់** = **ព័ន្ធ**។ កូននាគក្នុងនគរនេះ ពីអតីតនិងបច្ចុប្បន្នទាំងមូល ពេលណាដែលព័ន្ធចូលគ្នាជាដុំមួយហើយ ពន្លឺនៃភាពអច្ឆរិយរបស់ពូជផ្កាយ នឹងត្រូវចែងចាំងរស្មីសាជាថ្មីឡើងវិញ នឹងត្រូវផ្សព្វផ្សាយ ទូទៅពេញក្នុងលោកទាំងមូល។

## ថ.អត្ថន័យបង្កប់ក្នុងលេខមួយម៉ឺន(១0000)

ពាក្យសរសេរសម្គាល់លេខខ្ទង់ម៉ឺនឬមួយម៉ឺន(១០០០០) អត្ថន័យរបស់ពាក្យម៉ឺន ដូនតាគាត់ចង់ប្រាប់យើងថា ពេលដែលកូននាគព័ន្ធ(ពាន់) គ្នាហើយ ភាពជាជាតិថ្កើង គឺពូជម៉ឺន(នាម៉ឺន) ពូជផ្កាយ ពូជនាគ ពូជអច្ឆរិយ នឹងកើតផុលផុសឡើងជាថ្មី នៅលើទឹកដីចាស់នេះ។

**ឝ.អត្ថន័យបង្កប់ក្នុងលេខមួយសែន(១00000)**

អត្ថន័យបង្កប់នៅក្នុងពាក្យមួយសែន(១00000) ដូនតាមហានគរ លោកចង់ប្រាប់យើងថា ពូជនាគគឺជាពូជខ្ពង់ខ្ពស់ប្រសើរ ដូច្នេះពូជនេះគឺជាពូជដឹងគុណ ពូជអ្នកមានកតញ្ញូនិងកតវេទី។ ពេលដែលកូនខ្មែរ ចាប់ផ្ដើមដឹងប្រវត្តិកំណើតនៃជាតិ នោះយើងនឹងរួមសាមគ្គីគ្នា ធ្វើនូវមហាកុសល ក្នុងបុញ្ញកិរិយា១០យ៉ាង **សែន**បញ្ជូនឧទ្ទិសផ្សាយ ចែកជូនទៅដល់អ្នកមានឧបការគុណទាំងនោះក្នុងទិសទាំង១០ ឲ្យលោកបានត្រេកអរទទួលអនុមោទនា រួចបានទៅសោយសុខក្នុងសុគតិភព។ **ពាក្យសែន** = **ឧទ្ទិសជូន** ផ្សាយជូននូវមហាកុសល ដែលកើតចេញពីការតាំងចេតនាក្នុងកុសល **សែន**បញ្ជូនទៅដល់ញាតិធម៌ ដែលសុទ្ធតែជាអ្នកមានឧបការគុណទាំងនោះ។

**ឆ.អត្ថន័យបង្កប់ក្នុងលេខមួយលាន(១000000)**

អត្ថន័យដែលបង្កប់ នៅក្នុងពាក្យមួយលានឬលាន(១000000) ពេលដែលកូន នាគបានរៀប**រយ**ហើយ ក៏ចាប់ផ្ដើម**ពាន់**សាមគ្គីគ្នា រួចបង្កើតបានជាពូជ**ម៉ឺន** ហើយក៏នាំគ្នា**សែន**បញ្ជូន ឧទ្ទិសមហាកុសល ពេលនោះពូជអច្ឆរិយ ពូជផ្កាយ ពូជនាគ ក៏ចាប់ផ្ដើម**លាន**ចេញ ឲ្យពិភពលោកបានឃើញ ព្រោះភាសានិយាយពាក្យ **លាន** = **លៀន**។

**ជ.អត្ថន័យបង្កប់ក្នុងលេខមួយកោដិ(១0000000)**

សូរសព្ទ័សម្លេងនិយាយពាក្យថា **កោដិ** = **កោដ្ឋ** = **កោត** ន័យបង្កប់ក្នុងពាក្យកោដិនេះ ដូនតាមហានគរលោកចង់ប្រាប់យើងថា ពេលដែលព្រះមាតាមហានគរ លោកបានរួចពីមរ (ស្លាប់ ភក់ខ្មៅ...) ហើយ អ្វីៗនឹងត្រូវប្រែប្រួលក្នុងលោកនេះ។ ព្រោះន័យតាំងពីខ្ទង់រយ ពាន់ ម៉ឺន សែន លាន ទីបញ្ចាប់ពិភពលោកទាំងមូល នឹងត្រូវកោតស្ញប់ស្ញែង ពូជផ្កាយ ពូជនាគ ជាពូជអច្ឆរិយ ដែលត្រូវអកុសល បិទសន្ធប់លាក់ទុករាប់ពាន់ឆ្នាំនោះ ចាប់ផ្ដើមបញ្ចេញប្រវត្តិពន្លឺអច្ឆរិយរបស់ខ្លួនឡើងវិញហើយ។ ដូច្នេះលេខខ្មែរយើង មានត្រឹមចំនួនខ្ទង់កោដិតែប៉ុណ្ណោះ បើកូននាគពុំស្គាល់ អត្ថន័យបង្កប់ទុកក្នុងលេខ**មួយ**ទេ គឺពុំអាចមកស្គាល់អត្ថន័យ**កោដិ**(កោត)ខាងក្រោយបានឡើយ នេះចំពោះលេខ។ ចំណែកឯព្យញ្ជនៈ បើកូនខ្មែរពុំស្គាល់អត្ថន័យ**ក** កូនខ្មែរក៏មិនអាចស្គាល់**អ**បានឡើយ លុះត្រាតែបុគ្គលមាននិស្ស័យស្រាក់ឬបូក ទើបអាចរកឃើញប្រស្នាបង្កប់ របស់ដូនតាទាំងនេះ។

# VI.អំពីអត្ថន័យបទ្មប់ក្នុងទិស

ដូនតាមហានគរយើង បានយករឿងទិសនេះ ទៅបញ្ចូលលាក់ទុកក្នុងទំនាយ នឹងក្នុងមរតក និងពិធីផ្សេងៗទៀត ហើយអត្ថន័យរបស់ទិស បានបង្កប់ក្នុងពាក្យបណ្ដាំមាតាមហានគរ។ យើងតែងឮចាស់ៗពោលដំណាលបន្តគ្នាថា នឹងមានអ្នកមានបុណ្យចេញពីទិសខាងលិច(ភាសានិយាយឡិច) តើទំនាយប្រស្នានេះ ន័យពិតរបស់វាយ៉ាងដូចម្ដេច? បើយើងមិនបានឈ្វេងយល់ពិចារណាទេ គឺបានត្រឹមតែនិយាយបន្តគ្នា រហូតដល់បង្កើតបានជាពាក្យឃោសនា បោកបញ្ឆោតគ្នាទៀតផង។ យើងអាចបកស្រាយ ប្រស្នាទំនាយដូនតានេះបាន លុះត្រាតែយើងទៅស្វែងយល់ អំពីទិសដែលមាននៅក្នុងគម្ពីរព្រះពុទ្ធសាសនា ទើបអាចរកនូវការពិតឃើញ ព្រោះដូនតាយើងលោកបានយករឿង ទុក្ខសោករបស់ខ្លួន ទៅលាក់ទុកក្នុងស្រោមរបស់សាសនា។ ព្រោះមានតែសាសនាទេ ដែលងាយលាក់ទុក នៅបណ្ដាំរបស់គាត់គ្រប់បែបយ៉ាង កុំឲ្យពួកបរទេសគេងាយមើលយល់ តែទីបំផុតបរទេស គេមើលយល់មុនកូននាគ ចំណែកកូនខ្មែរមើលរឿងបណ្ដាំ របស់មាតាមិនយល់ ព្រោះវាជាភាសាគម្ពីរភាសាក្ដាម។ ហេតុអ្វីបានជាអ្នកប្រាជ្ញខ្មែរពីបុរាណ ទាយថានឹងមានអ្នកមានបុណ្យមកពីទិសខាងលិច ហើយជាពោធិសត្វព្រះសិរអារ្យមេត្រីទៀតផង? ហេតុម្ដេចក៏អ្នកមានបុណ្យនេះ មិនទៅបដិសន្ធិ(កើត) នៅប្រទេសដែលកាន់ នឹងគោរពព្រះពុទ្ធសាសនាដូចយើង ដូចជាប្រទេសសៀម ភូមា ស្រីលង្កា លាវ.... ហើយបែរជាគាត់ត្រូវមកកើត នៅក្នុងប្រទេសខ្មែរនេះទៅវិញ? រហូតក្នុងទំនាយបានប្រាប់ថា មានចិនលីគម្ពីរស្វែងរកអ្នកមានបុណ្យឲ្យខ្មែរ ដែលអ្នកមានបុណ្យគឺជាកំណប់ទ្រព្យ ខាងសេចក្ដីល្អ ដែលមនុស្សសាមញ្ញធម្មតាពុំអាចធ្វើបាន គឺមានតែព្រះពោធិសត្វដែលបំពេញបារមី ដើម្បីឲ្យបានត្រាស់ដឹងជាព្រះពុទ្ធទេ ទើបអាចបំពេញបារមីទាំង៣០ នេះ ឲ្យពេញបរិបូរណ៍បាន។ ហើយបុគ្គលនេះ បើបដិសន្ធិក្នុងនគរណាហើយ នគរនោះនឹងមានភាពរុងរឿងលេចធ្លោកើតឡើង ចុះហេតុអ្វីបានជាហោរាចិនចិត្តល្អអ្វីម្ល៉េះ សុខចិត្តលះបង់ពេលវេលារបស់ខ្លួន មកលីគម្ពីរតាមស្វែងរកអ្នកមានបុណ្យឲ្យខ្មែរ? សម័យផ្ដាច់ការ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលដឹកនាំដោយ លោកប៉ុលពតនិងបក្សពួក បានកៀរប្រជាជនខ្មែរចេញពីទីក្រុង ដែលនៅក្នុងនោះ មានអ្នកប្រាជ្ញ បណ្ឌិត និស្សិត បញ្ញវន្ត.... ទាំងប្រជារាស្ត្រស្លូតត្រង់ ទាំងគ្រហស្ថ និងបព្វជិត យកទៅធ្វើទារុណកម្ម ហើយសម្លាប់យ៉ាងព្រៃផ្សៃនូវជាតិសាសន៍ឯង អស់ចំនួនរាប់លានអ្នក។ តើ

ពួកគេចង់រកអ្នកមានបុណ្យដើម្បី សម្លាប់ចោលឬ? ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គជាកំពូលអ្នកមានបុណ្យ លើអ្នកមានបុណ្យទាំង ឡាយក្នុងលោក ដោយការត្រាស់ដឹងនូវបរមត្ថសច្ចៈ គឺសម្មាសម្ពោធិញ្ញាណរបស់ព្រះអង្គ បានធ្វើឲ្យពន្លឺនៃការត្រាស់ដឹង ជះផ្សាយទៅគ្រប់ទិសទាំង១០ និងទៅគ្រប់ភពតូចនិងភពធំ រកបុគ្គលណាមួយឲ្យស្មើនឹងព្រះអង្គគ្មាន។ ចុះអ្នកមានបុណ្យ ក្នុងទំនាយក្មេរយើង មានន័យយ៉ាងណាដែរ? ដូនតាយើងបានប្រាប់ថា អ្នកមានបុណ្យនោះ ជាតួអង្គព្រះសម្មាសម្ពុទ្ធព្រះសិរអារ្យមេត្រី ដែលនឹងបានត្រាស់ដឹងក្នុងចុងនៃភទកប្បនេះ។ បើតាមការពន្យល់ក្នុងគម្ពីរព្រះត្រៃបិដកបានប្រាប់ថា ពោធិសត្វព្រះសិរអារ្យមេត្រី ព្រះអង្គកំពុងតែសោយសម្បត្តិជាសុខ នៅក្នុងស្ថានតុសិតឯណោះ ហេតុអ្វីបានជាក្នុងទំនាយក្មេរ ថាព្រះអង្គបានមកចាប់បដិសន្ធិជា កូនក្មេរទៅវិញ? ចម្លើយគឺមានតែបុគ្គល អាចសម្រេចបាននូវអភិញ្ញាប្រាំមួយ និងវិជ្ជាប្រាំបី ទើបអាចឆ្លើយ នូវសំនួរចម្ងល់ខាងលើនេះបាន។

ទិសធំនៅក្នុងព្រះពុទ្ធសាសនាមានប្រាំមួយ(៦) ហើយទិសទាំង៦គឺតំណាងឲ្យ ឋានៈរបស់សត្វ ឬមនុស្ស ទៅតាមទិសនោះៗ។ រឿងទាក់ទងនឹងទិសនេះ កូននាគអាចអានដោយពិស្តារបាន នៅក្នុងរឿងសិង្គាលកសូត្រ ដែលសិង្គាលកបុត្រនេះ គឺជាបុត្ររបស់គហបតី នៅក្នុងក្រុងរាជគ្រឹះ។ សិង្គាលកបុត្រ ត្រូវបានព្រះសម្មាសម្ពុទ្ធជាម្ចាស់ យាងទៅប្រោសសម្ដែងធម្មទេសនា ឲ្យបានយល់ច្បាស់ពីទិស ដែលខ្លួនបានថ្វាយបង្គំរាល់ថ្ងៃ តាមបណ្ដាំបិតា ផ្ដាំឲ្យខ្លួនប្រព្រឹត្តប្រតិបត្តិ មុនពេលស្លាប់។ ពេលព្រះអង្គសម្ដែងបញ្ចប់ធម្មទេសនា សិង្គាលកបុត្របានដល់នូវព្រះរតនៈត្រៃ ជាទីពឹងទីរលឹកស្មើដោយជីវិត នៅក្នុងថ្ងៃដែលបានស្ដាប់ការបកស្រាយពន្យល់ ដោយពិស្ដារអំពីទិសនោះ។

**<u>ក.អត្ថន័យទិសក្នុងព្រះពុទ្ធសាសនា</u>**

**<u>១.ទិសខាងកើត</u>**

មាតាបិតាទុកជាទិសខាងកើត កូនប្រុសស្រីគប្បីប្រតិបត្តិដោយស្ថាន៥យ៉ាង៖

- កូនត្រូវតាំងចិត្តថាអញនេះ ម៉ែឪបានចិញ្ចឹមបីបាច់ថែរក្សាមកហើយ អញត្រូវ ចិញ្ចឹមបីបាច់ថែរក្សាគាត់វិញ។
- កូនត្រូវតាំងចិត្តថា កាលណាបើមាតាបិតាលោកមានកិច្ចរវល់ នោះអញត្រូវបញ្ឈប់ការងារ របស់ខ្លួនទុកសិន ហើយត្រូវទៅជួយធ្វើកិច្ចការមាតាបិតាវិញ។

- កូនត្រូវតាំងចិត្តថា អញត្រូវតម្កល់វង្សត្រកូលមាតាបិតា ទុកដោយល្អ មិនឲ្យវិនាស និងអាប់កេរ្តិ៍ឈ្មោះ មិនធ្វើឲ្យទ្រព្យមាតាបិតាវិនាស ដោយឥតប្រយោជន៍ និងសង្គ្រោះមាតាបិតាឲ្យផុតពីវង្ស ដែលមិនប្រកបដោយធម៌ ហើយនែនាំឲ្យពួកគាត់សេពគប់នៅវង្ស ដែលប្រកបដោយធម៌។ មិនផ្ដាច់នៅអំពើជាកុសលទាំងឡាយ មានការឲ្យទាន រក្សាសីល ស្ដាប់ធម៌ អប់រំសមាធិ បញ្ញា ដែលមាតាបិតាបានប្រព្រឹត្តធ្វើតាម កន្លងមកហើយនោះទេ។
- កូនត្រូវតាំងចិត្តថា អញនឹងតាំងគំនិតមារយាទឲ្យល្អ ឲ្យជាទីពេញចិត្តរបស់មាតាបិតា ឲ្យជាមនុស្សគួរមាតាបិតា ប្រគល់ទ្រព្យសម្បត្តិកេរមរតកឲ្យ។
- កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាធ្វើកាលកិរិយា(ស្លាប់) អញត្រូវធ្វើទក្ខិណាទាន ឧទ្ទិសកុសល ផលបុណ្យជូនដល់ពួកគាត់ជារឿយៗ ចាប់តាំងពីថ្ងៃគម្រប់៣អំពី ថ្ងៃដែល មាតា បិតា ដល់នៅសេចក្ដីស្លាប់នោះ។

ចំណែកមាតាបិតាវិញ ត្រូវអនុគ្រោះកូនដោយស្ថាន៥យ៉ាងគឺ៖

- ហាមឃាត់កូនមិនឲ្យធ្វើនូវអំពើអាក្រក់ មានហាមកូនមិនឲ្យសម្លាប់សត្វ មិនឲ្យលួចទ្រព្យគេ មិនឲ្យប្រព្រឹត្តខុសក្នុងបុត្រភរិយាគេ មិនឲ្យនិយាយភូតកុហក និងមិនឲ្យផឹកនៅទឹកស្រវឹង ដែលជាហេតុនាំឲ្យបាត់នៅសតិស្មារតី។
- ឲ្យកូនប្រព្រឹត្តនូវអំពើជាកុសលផ្សេងៗ មានការឲ្យទាន និងការរក្សាសីលជាដើម... ។ល។
- ឲ្យកូនរៀនសិក្សាសិល្បៈវិជ្ជា មានលេខនិងអក្សរ និងវិជ្ជាសម្រាប់ចិញ្ចឹមជីវិត ទៅតាមការវេលា។
- រៀបចំឲ្យកូនមានស្វាមីឬភរិយា សមគួរទៅដល់ជាតិត្រកូល និងទ្រព្យសម្បត្តិ។
- ឲ្យទ្រព្យដល់កូនក្នុងសម័យពីរយ៉ាង គឺនិច្ចសម័យមួយ និងកាលសម័យមួយ។ និច្ចសម័យគឺឲ្យទ្រព្យរឿយៗ ឲ្យកូនចាយវាយប្រើប្រាស់តាមសមគួរ ឬឲ្យដើម្បីធ្វើអំពើជាកុសលណាមួយ កាលសម័យគឺឲ្យក្នុងពេលកូនមានភរិយា ឬស្វាមី ឬឲ្យក្នុងកាលដែលខ្លួនជិតដល់មរណភាព។

**២.ទិសខាងត្បូង**

គ្រូអាចារ្យទុកដូចជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថានកិច្ច៥យ៉ាង៖

- ដោយកិរិយាធ្វើនូវការក្រោកឡើងទទួល បើសិស្សកំពុងអង្គុយក្នុងទីណាមួយ ដែលមិនមានបុគ្គលជាធំជាងគ្រូអាចារ្យ ហើយបានឃើញគ្រូអាចារ្យមកកាន់ទីនោះ សិស្សត្រូវក្រោកឡើងទទួល។ បើលោកមានបរិក្ខារអ្វី យើងត្រូវទទួលអំពីដៃលោក ត្រូវរកទឹកលាងជើង រកក្រណាត់ជូតជើង រកទីអាសនៈដើម្បីជូនលោក លុះលោកអង្គុយចុះហើយ ទើបយើងអង្គុយទៅតាមក្រោយ។ បើលោកក្រោកលាទៅវិញ យើងត្រូវក្រោកឈរជូនដំណើរលោក យ៉ាងជិតបំផុតក៏ត្រឹមមាត់ទ្វាររបងដែរ។

- ដោយកិរិយាចូលទៅបំរើគ្រូអាចារ្យ ក្នុងមួយថ្ងៃ៣ដង គឺវេលាព្រឹក ថ្ងៃត្រង់ និងល្ងាច ....។ល។

- ជឿស្ដាប់ពាក្យឱវាទរបស់គ្រូអាចារ្យ ដែលលោកបានពោលទូន្មាន ប្រៀនប្រដៅយើងឲ្យធ្វើនូវអំពើល្អ គ្រប់បែបយ៉ាង។

- ដោយការបំរើផ្សេងៗ មានឲ្យឈើស្ទន់(ឈើសម្រាប់សំអាតធ្មេញ) និងទឹកលុបលាងមុខជាដើម។

- រៀនដោយយកចិត្តទុកដាក់ នូវសិល្បសាស្ត្រ និងចំណេះវិជ្ជាផ្សេងៗ អំពីគ្រូអាចារ្យ ដោយគោរពនឹងយកចិត្តទុកដាក់ គឺរៀនទៅតាមសមគួរ ដល់កម្លាំងប្រាជ្ញារបស់ខ្លួន ហើយខំស្វាធ្យាយទន្ទេញ ដរាបដល់ចាំចូលចិត្ត។

ចំណែកគ្រូអាចារ្យ ត្រូវអនុគ្រោះសិស្សដោយស្ថាន៥យ៉ាងគឺ៖

- អប់រំទូន្មានប្រៀនប្រដៅសិស្សដោយល្អ គឺទូន្មានឲ្យសិស្សចេះរៀបចំឥរិយាបទទាំងបួន រៀនដេក ដើរ ឈរ អង្គុយ នឹងទូន្មានហាមប្រាមមិនឲ្យសិស្ស សេពគប់បាបមិត្ត ណែនាំពន្យល់ឲ្យសិស្សសេពគប់ នូវកល្យាណមិត្តនិងសប្បុរសទាំងឡាយ។

- បង្ហាត់បង្រៀនសិស្សដោយល្អ គឺបង្ហាត់ដោយត្រឹមត្រូវ ទៅតាមអត្ថនិងព្យញ្ជនៈ ទៅតាមរបៀបពាក្យរបៀបសេចក្ដី ដើម្បីឲ្យសិស្សងាយយល់ចាំចូលចិត្ត។

- ពោលពាក្យលើកសសើរ ចំពោះសិស្សដែលរៀនពូកែ មានកិរិយាមារយាទល្អនោះឲ្យបានច្បាស់ពិតប្រាកដ នៅចំពោះមុខមិត្ត អាមាត្យ និងមហាជន។

- ការពាររក្សាសិស្សក្នុងទិសទាំងឡាយ គឺថាឲ្យសិស្សសិក្សារៀនសិល្បសាស្ត្រ ចំណេះវិជ្ជាមិនឲ្យទើសទាល់ ក្នុងវេលាដែលសិស្ស ចេញទៅចញ្ចឹមជីវិតនៅក្នុងទិសនោះៗ(ពុំលាក់ចំណេះ)។

**<u>៣.ទិសខាងលិច</u>**

ទិសខាងលិចទុកដូចជាភរិយានិងបុត្រ ស្វាមីគប្បីអនុគ្រោះដោយស្ថាន៥យ៉ាងគឺ៖

- មានសេចក្តីស្រឡាញ់រាប់អានទៅរកភរិយា ដោយសម្តីទន់ផ្អែម
- ដោយកិរិយាមិនបៀតបៀន មិនមើលងាយភរិយា ដូចទាសកម្មករ
- ដោយកិរិយាមិនប្រព្រឹត្តកន្លងចិត្ត គឺក្បត់ចិត្តភរិយា
- ដោយប្រគល់នូវឥស្សរិយស គឺភារៈជាធំក្នុងការចាត់ចែង បាយទឹកនំចំណីភោជនីយហារ និងកិច្ចផ្សេងៗទៀតផ្តាច់មុខឲ្យទៅភរិយា។
- ផ្គត់ផ្គង់នូវគ្រឿងប្រដាប់តាក់តែងរាងកាយ ដល់ភរិយាតាមសមគួរ ដល់សម្បត្តិរបស់ខ្លួនដែលមាន។

ចំណែកភរិយាវិញ ត្រូវទំនុកបម្រុងស្វាមីដោយស្ថាន៥យ៉ាងគឺ៖

- ចាត់ចែងការងារ មានការចម្អិនម្ហូបអាហារ មានបាយទឹកបបរជាដើម ដោយផ្ចិតផ្ចង់ឲ្យត្រូវទៅតាមកាលវេលា។
- សង្គ្រោះដល់ញាតិខាងប្តី និងញាតិរបស់ខ្លួន ដោយស្មោះស្មើមិនលំអៀង
- មិនប្រព្រឹត្តក្បត់កន្លងចិត្តស្វាមី (កិរិយាផិតក្បត់)។
- ភរិយាជាស្ត្រីឆ្លាតឈ្លាស ប្រសប់ក្នុងកិច្ចការទាំងពួង ក្នុងការងារចាត់ចែងរៀបចំផ្ទះសម្បែង និងភោជនីយអាហារជាដើម ជាអ្នកមិនខ្ជិលច្រអូសក្នុងកិច្ចការទាំងឡាយ ហើយអាចញ៉ាំងកិច្ចការទាំងពួងឲ្យសម្រេចបាន។

**<u>៤.ទិសខាងជើង</u>**

ទិសខាងជើងទុកដូចជាមិត្តសម្លាញ់ កុលបុត្រត្រូវទំនុកបម្រុងដោយស្ថាន៥យ៉ាងគឺ៖

- ឲ្យទ្រព្យដែលគួរឲ្យដល់មិត្តសម្លាញ់
- ពោលពាក្យសម្តីពីរោះ ផ្អែមល្ហែមទៅរកមិត្ត

- ប្រព្រឹត្តធ្វើនូវប្រយោជន៍ ឲ្យកើតដល់មិត្តទាំងផ្លូវលោក ទាំងផ្លូវធម៌
- ដោយភាវៈជាអ្នកមានចិត្តស្មើទៅរកមិត្ត(មិនស៊ីលើស៊ីក្រោម)
- ដោយមិនក្លែងពោលពាក្យ មិនពិតដល់មិត្ត

ចំណែកខាងមិត្តសម្លាញ់ត្រូវអនុគ្រោះ កុលបុត្រវិញដោយស្ថាន៥យ៉ាងគឺ៖

- ជួយថែរក្សាមិត្ត ដែលបានប្រព្រឹត្តភ្លាំងភ្លាត់ ឬធ្វេសប្រហែស
- ជួយថែរក្សាទ្រព្យសម្បត្តិរបស់មិត្ត ដែលមិត្តបានភ្លេចភ្លាំង ធ្វេសប្រហែស
- កាលបើមិត្តមានភ័យកើតឡើង ក៏អាចជាទីពឹងពាក់អាស្រ័យដល់មិត្តបាន
- មិនលះបង់ចោលមិត្ត ពេលដែលមិត្តជួបគ្រោះភ័យ និងការក្រផ្សេងៗ
- ស្រឡាញ់រាប់អាន ពូជពង្សវង្សត្រកូលកូនចៅរបស់មិត្ត ដោយមិនរើសអើង

## ៥.ទិសខាងក្រោម

ទិសខាងក្រោមទុកដូចជាបាវព្រាវឬកម្មករ ដែលជាអ្នកធ្វើការឈ្នួល ចៅហ្វាយនាយគប្បីអនុគ្រោះ ទំនុកបម្រុងដោយស្ថាន៥យ៉ាងគឺ៖

- ចាត់ចែងនូវការងារឲ្យកម្មករធ្វើ ទៅតាមសមគួរដល់កម្លាំងកាយ ឬបញ្ញានៃកម្មករ គឺដាក់ការងារទៅតាមកម្លាំងក្មេង ចាស់ ប្រុស ស្រី។
- ឲ្យនូវបាយទឹកនំចំណី ប្រាក់ឈ្នួលបំណាច់ ទៅតាមសមគួរទំនងសាច់ការដែលត្រូវឲ្យ
- មានការថែរក្សាព្យាបាលរោគ កាលដែលពួកគេមានជំងឺ ហើយមិនបៀតបៀន ឲ្យធ្វើការអ្វីឡើយ នៅក្នុងពេលដែលឈឺនោះ។
- ចែករំលែកនៅម្ហូបចំណី ដែលមានរសឆ្ងាញ់ពិសា ឲ្យដល់កម្មករបានបរិភោគ
- បើកឱកាសឲ្យកម្មករបានឈប់សម្រាក ពីធ្វើការក្នុងនិច្ចសម័យ កាលបើដឹងថា ទាសកម្មករធ្វើការហត់នឿយពេញមួយថ្ងៃ ឲ្យគ្នាបានឈប់សម្រាកកម្លាំង ឬក៏ឲ្យឈប់សម្រាកក្នុងថ្ងៃបុណ្យទានផ្សេងៗ មានបុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំជាដើម...។ល។

ចំណែកខាងបាវព្រាវនិងមនុស្សធ្វើការឈ្នួល ត្រូវយកចិត្តទុកដាក់បំពេញកិច្ចការ តបទៅចៅហ្វាយនាយវិញ ដោយស្ថាន៥យ៉ាងគឺ៖

- ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ
- ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ
- មិនលួចឬកេង យកទ្រព្យសម្បត្តិរបស់ចៅហ្វាយនាយ យកតែទ្រព្យសម្បត្តិណា ដែលចៅហ្វាយនាយឲ្យ ជាគុណបំណាច់ឬប្រាក់ថ្លៃឈ្នួល
- ធ្វើការងារឲ្យចៅហ្វាយនាយ ដោយយកចិត្តទុកដាក់ផ្ចិតផ្ចង់ គឺមិនធ្វេសប្រហែស
- នាំយកសេចក្តីល្អរបស់ចៅហ្វាយនាយ ទៅពោលសសើរក្នុងទីដែលខ្លួនត្រូវនិយាយ។

**៦.ទិសខាងលើ**

ទិសខាងលើទុកដូចជាសមណព្រាហ្មណ៍ កុលបុត្រជាគ្រហស្ថគឺអ្នកគ្រប់គ្រងផ្ទះ ត្រូវផ្គត់ផ្គង់ដោយស្ថាន៥យ៉ាងគឺ៖

- គ្រហស្ថត្រូវប្រព្រឹត្តដោយកាយកម្ម(អំពើធ្វើដោយកាយ) ប្រកបទៅដោយមេត្តា គឺថាធ្វើនៅកិច្ចដោយទៅនិមន្តលោកដល់វត្ត និងទទួលយកធម្មក្រកទៅដងទឹកប្រគេនលោក នឹងជួយគក់ច្របាច់ ជាដើម ដោយសេចក្តីរាប់អាន ដោយស្មោះអស់ពីដួងចិត្ត។
- គ្រហស្ថត្រូវប្រព្រឹត្តដោយវចីកម្ម(អំពើធ្វើដោយវាចា) គឺពោលពាក្យប្រកបដោយមេត្តា មានការពោលពាក្យដាស់តឿនដល់អ្នកដទៃ ឲ្យចេះធ្វើទានដល់សមណព្រាហ្មណ៍ ចេះបន្លឺនូវសព្ទសាធុការ ក្នុងពេលស្តាប់ធម្មទេសនាចប់ និងធ្វើនូវបដិសណ្ឋារកិច្ច ដោយសម្តីរាក់ទាក់ជាដើម ក្នុងការរាប់អាន ដោយស្មោះត្រង់អស់ពីចិត្ត។
- គ្រហស្ថត្រូវប្រព្រឹត្តដោយមនោកម្ម(អំពើធ្វើដោយចិត្ត) ប្រកបដោយមេត្តា គឺការធ្វើនូវកិច្ចដោយចិត្តគិតថា ព្រះថេរៈទាំងឡាយ ដែលលោកនិមន្តមកកាន់ត្រកូលរបស់យើង សូមឲ្យលោកបាននូវសេចក្តីសុខ ដោយសេចក្តីរាប់អានដ៏ស្មោះចេញពីដួងចិត្ត។
- ដោយភាពជាអ្នកមិនបិទទ្វារផ្ទះ គឺមិនកំណាញ់ មិនត្អូញត្អែរ ពេលឃើញសមណព្រាហ្មណ៍មកដល់ ក៏ឲ្យនៅទានតាមសមគួរ ដល់ទ្រព្យធននិងពេលវេលា។
- ដោយកិរិយាឲ្យនូវអាមិសទាន គឺភោជនីយហារ មានបង្អែមនិងចម្អាបជាដើម ដល់សមណព្រាហ្មណ៍ ដែលបាននិមន្តមកដល់នោះ។

ចំណែកសមណព្រាហ្មណ៍ ត្រូវអនុគ្រោះកុលបុត្រ ដោយស្ថាន៦យ៉ាងគឺ៖

- ហាមឃាត់កុលបុត្រ វៀរចាកអំពើអាក្រក់
- ពន្យល់កុលបុត្រ ឲ្យប្រព្រឹត្តតម្កល់ចិត្តក្នុងអំពើល្អ(កុសល)
- អនុគ្រោះដល់កុលបុត្រដោយចិត្តល្អ គឺតាំងចិត្តផ្សាយនូវព្រហ្មវិហារធម៌
- បំភ្លឺអត្ថសេចក្ដីក្នុងធម៌ ដែលកុលបុត្របានស្ដាប់ហើយ ឲ្យកាន់តែយល់ច្បាស់ភ្លឺថ្លូរផង ឡើងថែមទៀត។
- ប្រាប់ផ្លូវដល់កុលបុត្រ ក្នុងការប្រព្រឹត្តបុញ្ញកិរិយាទាំង១០ ដែលជាធម៌នាំទៅកាន់សុគតិភព ដោយអំណាចទាន សីល សមាធិ បញ្ញា...។ល។

ចំណែកឯទិសបង្កប់ទៅដោយប្រស្នា ដែលមានក្នុងព្រះពុទ្ធសាសនាគឺ៖

១.ពេលដែលព្រាហ្មបានថ្វាយស្បូវភ្លាំង ព្រះអង្គបានយកស្បូវនោះទៅក្រាល ពីទិសខាងជើង ពីទិសខាងលិច ពីទិសខាងត្បូងដើមពោធិព្រឹក្ស រតនៈបល្ល័ង្កពុំបានផុសឡើងឡើយ លុះត្រាតែព្រះអង្គយកស្បូវភ្លាំងនោះ ទៅក្រាលពីទិសខាងកើតដើមពោធិព្រឹក្ស ទើបផែនដីរញ្ជួយផុសឡើងនៅរតនៈបល្ល័ង្កនេះ តើហេតុអ្វីបានជាទិសខាងលិច ទិសខាងត្បូង ទិសខាងជើង មិនអាចផុសរតនៈបល្ល័ង្ក ហើយបែរជាផុស ក្នុងទិសខាងកើតទៅវិញ?

២.ពេលដែលព្រះអង្គរៀបនឹងបរិនិព្វាន ព្រះអង្គបានផ្ទំនៅចន្លោះដើមសាលព្រឹក្សទាំងគូ ព្រះអង្គបានដាក់ព្រះសិរិសាទៅទិសខាងជើង ដាក់ព្រះបាទទៅទិសខាងត្បូង និងបែរព្រះភ័ក្ត្រទៅទិសខាងលិច តើហេតុដូចម្ដេចបានជាព្រះអង្គ បន្សល់ទុកនូវឥរិយាបទដូច្នេះ? ហេតុដូចម្ដេចបានជាព្រះអង្គមិនដាក់សិរិសា ព្រះបាទ និងព្រះភ័ក្ត្រទៅទិសផ្សេង?

**<u>ខ.អត្ថន័យទិសក្នុងព្រហ្មញ្ញសាសនា</u>**

**<u>១.ទិសឦសាន្ត</u>**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសឦសាន្តគឺជាលំនៅរបស់ព្រះអាទិត្យ។

**<u>២.ទិសបូព៌</u>**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសបូព៌គឺជាលំនៅរបស់ព្រះច័ន្ទ។

**<u>៣.ទិសអគ្នេយ៍</u>**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសអគ្នេយ៍គឺជាលំនៅរបស់ព្រះអង្គារ។

**៤.ទិសទក្សិណ**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសទក្សិណគឺជាលំនៅរបស់ព្រះពុធ។

**៥.ទិសនិរតី**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសនិរតីគឺជាលំនៅរបស់ព្រះសៅរ៍។

**៦.ទិសបស្ចិម**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសបស្ចិមគឺជាលំនៅរបស់ព្រះព្រហស្បតិ៍។

**៧.ទិសពាយព្យ**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសពាយព្យគឺជាទីលំនៅរបស់ព្រះរាហូ។

**៨.ទិសឧត្តរ**

នៅក្នុងក្បួនព្រហ្មញ្ញសាសនា ទិសឧត្តរគឺជាលំនៅរបស់ព្រះសុក្រ។

**គ.អត្ថន័យទិសបង្កប់ក្នុងពាក្យខ្មែរ**

ទិសនៅក្នុងន័យរបស់ខ្មែរ ដូនតាលោកបានបង្កប់ទុកក្នុងពាក្យតែម្ដង ។

១.ទិសខាងកើតជាភាសាខ្មែរ ភាសាបាលីគឺទិសបូព៌ ពាក្យថាខាងកើតគឺមានន័យថា អ្វីដែលកើតចេញពីភាពងងឹត(យប់) គឺភ្លឺ។ ក្នុងន័យពាក្យកើត គឺស្មើនឹងតាំងឡើង រះឡើង ឧបត្តិកឡើង... មិនថាជាសភាវៈល្អឬអាក្រក់ឡើយ។ នេះជាន័យត្រង់ ដែលបញ្ជាក់ប្រាប់ពីន័យពិតរបស់ទិសនេះ គឺដូនតាយើងគាត់ពុំបានលាក់លៀមឡើយ។

២.ទិសខាងលិចជាភាសាខ្មែរ ភាសាបាលីគឺទិសបស្ចិម ភាសានិយាយយើងច្រើន និយាយ ថាឡិច = លិច។ ពាក្យថាខាងលិច គឺបានន័យថាលិចចុះ រលត់ចុះ បាត់ចេញពីខ្សែភ្នែកឬស្លាប់។ កើតគឺផ្ទុយនិងលិច កើតផ្ទុយនិងស្លាប់ ន័យត្រង់របស់ពាក្យលិចនេះ ដូនតាលោកចង់ប្រាប់យើងថា អ្វីដែលកើតមានហើយ តែងតែរលត់ចុះវិញជាធម្មតា នេះជាធម្មៈ។

៣.ទិសខាងត្បូងជាភាសាខ្មែរ ភាសាបាលីគឺទិសទក្ខិណពាក្យថាខាងត្បូង មានន័យថា ក្បាល។ ព្រោះពាក្យត្បូងស្មើនឹងក្បាល ឬស្មើនឹងកែវវិសេសម្យ៉ាង ដូនតាយើងគាត់ចង់ប្រាប់ថា ទិស នេះគឺជាទិសដំណេក ទើបដូនតាយើងចងក្រងជាសុភាសិតមួយទុកថា **ត្រពាំងពីទិសខាងត្បូង អណ្ដូងពីទិសខាងលិច គោក្របៅក្រឡាច់ ស្ត្រីដោះញ្ញ ត្បាល់ដើមដូង អន្លុងពង្រ ខ្ញុំឆ្ងាសម្បុរបើធ្វើម្ដេចអាចជួយអ្នកបាន**។ ក្នុងន័យសុភាសិតនេះ គាត់បានប្រាប់ន័យប្រស្នា ដែលបង្កប់ក្នុងទិសរបស់ខ្មែរ។

៤.ទិសខាងជើងជាភាសាខ្មែរ ភាសាបាលីគឺទិសឧត្តរ ពាក្យថាខាងជើងគឺផ្ទុយពីក្បាល គឺផ្នែកខាងក្រោមក្បាលគឺជើង នេះជាន័យត្រង់បង្កប់ក្នុងទិសរបស់ខ្មែរ។

តាមការបកស្រាយពន្យល់ដោយសង្ខេប អំពីទិសក្នុងន័យព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងក្នុងន័យខ្មែរ យើងអាចស្វែងយល់ដល់ទំនាយ របស់ដូនតាខ្មែរ ដែលបានព្យាករណ៍ទុកមកថា នឹងមានអ្នកមានបុណ្យមកពីទិសខាងលិច(ឡិច)។ បើយើងមើលតាមការពន្យល់ របស់ព្រះសម្មាសម្ពុទ្ធ ដល់សង្គាលកបុត្រនោះ ទិសខាងលិចទុកដូចជាភរិយា និងបុត្រ ព្រោះពេលក្លាយជាភរិយា និងវិវឌ្ឍន៍ក្លាយជាម្ដាយគេ។ ទិសខាងលិចវាផ្ទុយពីទិសខាងកើតៗគឺរះឡើង ទិសខាងលិចគឺលិចចុះ (មើលការពន្យល់ន័យខ្មែរខាងលើ)។ ប្រស្នាដែលគាត់បានប្រាប់បង្ហាញយើងថា អ្នកដែលកកើតទឹកដីនេះ ទុកដូចមាតាបិតា ឯអ្នកដែលលិចចុះ គឺភរិយា ពុំមែនឪពុកឬស្វាមីទេ តើព្រោះហេតុអ្វី? ក្នុងបណ្ដាទិសទាំង៦ ក្នុងន័យព្រះពុទ្ធសាសនា ឥតមានទិសដែលតំណាងឲ្យស្វាមីទេ គឺមានតែទិស តំណាងឲ្យភរិយា។ ចំណុចនេះយើងគួរឆ្ងល់ថា ទិសខាងកើតទុកដូចមាតាបិតា(ឪពុកម្ដាយ ឬម៉ែឪ) ទិសខាងលិចហេតុអ្វីមានតែភរិយានិងបុត្រ បាត់ប្ដី ឬស្វាមីទៅណា? ក្នុងបណ្ដាំមាតាមហានគរ ទាំង៣ភាគមុន ឪពុកនិងកូនគាត់បានព្យួរទោស នៅខាងក្រៅឃុំ មានតែម៉ែទេដែលសុខចិត្តយកទោស របស់ឪពុកនិងកូនមកទទួលតែម្នាក់ឯង។ ដូច្នេះពាក្យថាអ្នកមានបុណ្យងើបពីទិសខាងលិច ឬចេញពីទិសខាងលិច គឺមាតាអ្នកបង្កើតនគរនេះឯង ដែលតំណាងឲ្យព្រះម៉ែ មហេសីរាជនី ដែលលោកបានបំពេញបុណ្យ សុខចិត្តធ្វើជាប្រេត ជាបិសាច(មើលឯកសារជីវិតាក្ខាន់)។ ដើម្បីធ្វើជាឬសកែវ ឬដួងកែវ រក្សានគរនេះឲ្យនៅគង់វង្ស រហូតទោសនិងបាបកម្ម របស់គាត់ឲ្យផុតអស់ តើសព្វថ្ងៃនេះ មានស្ត្រីតាំងខ្លួនជាម៉ែប៉ុន្មាននាក់ ដែលហ៊ានធ្វើពលិកម្មធ្វើជាប្រេត បិសាចដើម្បីរក្សាទឹកដីមាតុភូមិនេះ? គឺពុំងាយនឹងរកស្ត្រី ដែលមានចិត្តហ៊ានលះបង់ដូច្នេះបានឡើយ គឺមាន

តែព្រះម៉ែទេ ដែលលោកសុខចិត្ត រងទុក្ខវេទនាតែម្នាក់ឯងយ៉ាងនេះ ដូចជាព្រះបរមពោធិសត្វ ដែលខំសន្សំបារមីរាប់អសង្ខេយ្យផែនដី ដែលជាបញ្ញាធិកគឺសន្សំបារមី២០អសង្ខេយ្យ សទ្ធាធិកសន្សំបារមី៤០អសង្ខេយ្យ វីរិយធិកសន្សំបារមី៨០អសង្ខេយ្យផែនដី តើសត្វធម្មតាណាអាចធ្វើបាន គឺមានតែព្រះអង្គទេ ដែលសុខចិត្តហែលកាត់មហាសមុទ្រសង្សារវដ្ដ ព្រោះហេតុតែករុណាដល់សព្វសត្វ។

យ៉ាងណាមិញព្រះម៉ែមហានគរ លោកគ្រាន់តែជាចំណែកមួយនៃព្រះពោធិសត្វ លោកបានបំពេញនូវបុណ្យបារមី ដើម្បីឲ្យបានជាព្រះពុទ្ធមាតា(ម្ដាយព្រះពុទ្ធ) សម្រាប់ព្រះពុទ្ធអង្គណាមួយ ទៅអនាគតជាតិ។ ប្រស្នាទំនាយដែលអ្នកប្រាជ្ញបុរាណខ្មែរ បានទាយលាក់បង្កប់ទុកទៅក្នុងទិស គឺជាប្រស្នាមានជម្រៅដ៏ក្រៃលែង យើងមិនអាចរកឃើញចម្លើយ ដោយពុំបានសិក្សាស្គីពីទិស ក្នុងគម្ពីរព្រះសម្មាសម្ពុទ្ធបានឡើយ ព្រោះដូនតាយើងបានយករឿងខ្លួន ទៅបង្កប់ក្នុងពុទ្ធសាសនា។

## VII.អំពីអត្ថន័យបង្កប់ក្នុងផ្កាយ

ចំពោះផ្កាយដែលរះក្នុងលំហអាកាសឬលើមេឃ បើយើងពុំបានយកមក រែកញែកពិចារណាទេ យើងក៏មិនអាចស្វែងយល់ ក្នុងមរតកអច្ឆរិយនេះបានឡើយ តើព្រោះហេតុអ្វី? ដោយអាថ៌កំបាំងក្នុងលេខខ្មែរ រាប់បានតែត្រឹមលេខ៥(មើលការពន្យល់ពីលេខ) នេះជាតឹកតាងបង្ហាញថា ខ្មែរជាពូជពង្សផ្កាយ។ យើងតែងមើលឃើញ ភាគច្រើននៃប្លង់ប្រាសាទខ្មែរ គឺតែងតែមានប្រាង្គប្រាសាទ៥ ហើយប្រាង្គទី៥តែងនៅចំកណ្ដាល មានប្រាង្គទាំង៤អមជុំវិញ។ ហើយប្លង់រូមទាំងមូលរបស់ប្រាសាទ តែងតែមានដីពូនចាក់ជារាងយោនី(ភេទស្ត្រី) ដោយមានគូទឹកព័ទ្ធជុំវិញ។ ដោយគាត់ខ្លាចកូនខ្មែរ ជំនាន់ក្រោយមើលពុំយល់ ទើបគាត់បានឆ្លាក់យោនីឬទ្វារមាស ដែលមានកង៥គ្រាប់នៅជាប់ពីខាងក្នុង ទុកនៅបាតស្ទឹងភ្នំគូលែន (មើលការពន្យល់រូបក្នុងលេខ១០)។ បណ្ដាំថ្មដែលជាភាសាគនេះ ដូនតាចង់ឲ្យយើងជាកូននាគ ដោះប្រស្នាភាសាគឬភាសាក្ដាមរបស់គាត់ បើកូននាគដោះចេញ នឹងដឹងសាវតាខ្លួនជាពូជផ្កាយ បើដោះមិនចេញទេ គឺមិនអាចដឹងឬសកែវជាពូជផ្កាយបានឡើយ។ បើយើងយកគ្រាប់ទាំង៥មករាយ ឲ្យមានលំនាំដូចម្រាមដៃ កុំឲ្យមានគ្រាប់ណាមួយជាប់ក្នុងឃុំ រួចយើងគូសបន្ទាត់ភ្ជាប់គ្រាប់ពីមួយទៅមួយ យើងនឹងបានឃើញរូបរាងផ្កាយកើតឡើង បង្ហាញពីសាវតាលេខ៥នេះជាពុំខាន។ នេះជាហេតុដែលនាំឲ្យ លេខរាយខ្មែរមានត្រឹមលេខ៥

អប្សរារាំបង្ហាញម្រាម៥ ប្រាសាទភាគច្រើនមានកំពូល៥ រីឯរូបភាពនៅក្នុងរង្វង់មូល តំណាងឲ្យប្រក្រតីទិនរបស់ជនជាតិម៉ាយ៉ាន នៅប្រទេសម៉ិចស៊ិកូ ក៏មានកងចនៅពីខាងក្រោម រូបក្បាលដែលមានលាននអណ្ដាត ហើយជាប់ឃុំក្នុងរង្វង់កងចព័ទ្ធជុំវិញ។ បាននិយថាបុព្វជូនតា នៃជនជាតិម៉ាយ៉ាននេះ ពួកគេសុទ្ធតែជាពូជផ្កាយដូចយើងដែរ ហើយសុទ្ធតែជាអ្នកជាប់ឃុំ ប៉ុន្តែអ្នកស្នងមរតកជំនាន់ខាងក្រោយ នៃក្រុមប្រាសាទដែលទាក់ទងនឹងផ្កាយទាំងនោះ ពុំបានដឹងពីបំណងរបស់អ្នកជំនាន់មុនឡើយ ថាតើពួកគាត់ចង់បានអ្វីពីខ្លួន ដែលពួកគាត់បានសរសេររៀបរាប់ ទុកក្នុងភាសាគ(ភាសារូប)ទាំងនោះ?

**<u>ក.ផ្កាយក្រពើ</u>**

ផ្កាយក្រពើនេះ តែងតែរះឡើងនៅទិសខាងជើង បើមើលការផ្គុំរូបរាងទ្រង់ទ្រាយរបស់វា គឺពុំដូចជាសត្វក្រពើឡើយ វាដូចជាសត្វនាគបើកវែក(ពពារ) ឬដូចជារាងខ្លែងដែលគេបង្ហោះ តើហេតុអ្វីបានជាដូនតាយើង ហៅផ្កាយនេះថាផ្កាយក្រពើ? ពួកអ្នកស្រាវជ្រាវ រុករករអាថ៌កំបាំងប្រាសាទនៅលើពិភពលោក(Discovery) បានផ្គុំពួកប្រាសាទនៅតំបន់អង្គរ ដែលមានប្រាសាទអង្គរតូចជាក្បាល និងប្រាសាទបន្ទាយសំរ៉ែជាកន្ទុយ បង្កើតបានជារាងសត្វនាគមួយ ឬរាងខ្លែងមួយ ដែលរាងនេះ ដូចជាផ្កាយក្រពើសព្វថ្ងៃ។ ពួកគេឆ្ងល់ថា ជនជាតិខ្មែររាប់ពាន់ឆ្នាំមុន ធ្វើប្រាសាទនៅលើដី ហេតុអ្វីឆ្លុះទៅនឹងផ្កាយលើមេឃ? ចម្លើយគឺបានត្រឹមតែឆ្ងល់តែប៉ុណ្ណោះ ព្រោះពួកគេអ្នកស្រាវជ្រាវ ពុំមែនជាខ្មែរ ពុំមែនជាពូជផ្កាយ ពុំមែនជាពូជអច្ឆរិយ...។ល។ ចំពោះការស្រាវជ្រាវរបស់ខ្ញុំបាទវិញ ខ្ញុំឆ្ងល់ថាផ្កាយនេះជាផ្កាយនាគ ឬផ្កាយខ្លែងទិសខាងជើង ហេតុអ្វីបានជាដូនតាហៅថាផ្កាយក្រពើ ព្រោះក្នុងច្បាប់បុរាណខ្មែរ សត្វក្រពើជានិមិត្តរូប តាងឲ្យមនុស្សរមិលគុណ គឺមិនដឹងគុណ។ ក្នុងច្បាប់ធម្មជាតិសត្វដែលរមិលគុណ ចិត្តមិនអាចទៅបដិសន្ធិឬកើត នៅឋានផ្កាយឬទេវលោកបានឡើយ គឺមានតែធ្លាក់ចុះឬច្យុតិ ទៅទីទាបគឺអបាយភូមិ ហេតុអ្វីបានជាសត្វក្រពើ អាចកើតជាផ្កាយបាន? ចម្លើយន័យប្រស្នាផ្កាយក្រពើនេះ យើងទៅមើលការបកស្រាយ នៅក្នុងល្បែងប្រស្នាចាក់ទឹកដូងលើកទី១ ទើបស្រាយនូវចម្ងល់នេះបាន។

ចាក់ទឹកដូងពីទ្រូងម៉ែ **កន្ទុយខ្លែងខ្មែរពាក់ក្បាលក្រពើ**

ក្រពើជិះសេះខ្ញុំជិះដំរី ក្រពើចង់ឆីខ្ញុំឡើងផ្ទះ

ក្រពើត្របាក់ ខ្ញុំប្រឹងរុល

ក្រពើភ្នែកទុល ខ្ញុំញីម្ទេស។

តើឲ្យផ្កាយនេះមានឈ្មោះថាផ្កាយនាគ ឬផ្កាយខ្លែងម៉ែម្តេចបាន? បើកូននាគបានយកក្បាលក្រពើ គឺក្បាលមិនដឹងគុណ ទៅពាក់ពីលើក្បាលនាគទៅហើយនោះ ធ្វើម្តេចផ្កាយនោះអាចមានឈ្មោះជាផ្កាយនាគ ឬផ្កាយខ្លែងទិសខាងជើងបាន? ផ្កាយខ្លែង មានផ្កាយខ្លែងទិសខាងជើង ទិសកណ្តាល និងទិសខាងត្បូង។ ក្រៅពីផ្កាយខ្លែងទិសខាងជើង ផ្កាយខ្លែងដ៏ទៃទៀតពុំមានកន្ទុយឡើយ គឺមានតែផ្កាយខ្លែង ទិសខាងជើងមួយតែប៉ុណ្ណោះ ដែលមានកន្ទុយ។ ដូច្នេះហើយទើបម្ចាស់សំណង់ប្រាសាទ ដែលមានមុនក្មេរ ហើយសំណង់ប្រាសាទទាំងនោះ ឆ្ពុះទៅនឹងផ្កាយលើមេឃ ដែលអ្នកជំនាន់ក្រោយរបស់ពួកគេ ត្រូវដាច់តំណឹងតំណរបស់ដូនតាខ្លួន ព្រោះនិមិត្តរូបផ្កាយខ្លែងគ្មានកន្ទុយ ព្រោះកន្ទុយតំណាងឲ្យ អ្នកជំនាន់ក្រោយរបស់ខ្លួន។ ចំណែកឯក្មេរយើង ផ្កាយខ្លែងទិសខាងជើងមានកន្ទុយ ព្រោះអ្នកទទួលតំណាមរតកអច្ឆរិយ នៅសល់កេរមរតកពូជផ្កាយ គឺព្រះពុទ្ធសាសនាឬពូជនាគ ដែលធ្វើឲ្យកូននាគសម័យក្រោយ អាចបើកនៅគម្របអាថ៌កំបាំងនេះបាន។ ពេលនេះផ្កាយក្រពើ ត្រូវបានបើកអាថ៌កំបាំងហើយ តើកូននាគត្រូវហៅផ្កាយនេះ ថាផ្កាយក្រពើឬក៏ផ្លាស់ឈ្មោះមកជាផ្កាយនាគ ឬផ្កាយខ្លែងទិសខាងជើងវិញ? ពេលដែលកូននាគ ទទួលស្គាល់ខ្លួនឯងជាពូជនាគ ក្បាលក្រពើត្រូវតែជ្រុះចេញពីក្បាលនាគ ហើយពេលនោះពូជនាគ ដែលរស់នៅលើមាតុភូមិនេះ ត្រូវឆ្ពុះទៅរកផ្កាយនៅលើមេឃ ព្រោះហេតុអ្វី? បុគ្គលដែលទ្រទ្រង់នូវធម៌កតញ្ញូនិងកតវេទី ពុំអាចធ្លាក់ចុះទៅកាន់អបាយភូមិឡើយ គឺតែងតែទៅបដិសន្ធិនៅទេវលោក។ ដូចជាព្រះឥន្ទ្រាធិរាជសព្វថ្ងៃ លោកអាចកើតជាព្រះឥន្ទ្របាន កាលលោកនៅជាមឃមាណព លោកបានសម្មាទានធម៌៧យ៉ាងគឺ៖

១.ចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាអស់មួយជីវិត

២.គោរពត្រកូលរៀមច្បងអស់មួយជីវិត

៣.ពោលពាក្យសម្តីផ្អែមល្ហែមទន់ភ្លន់អស់មួយជីវិត

៤.ឲ្យទានដល់បដិគ្គាហកៈ(បុគ្គល) ទាំងសមណៈព្រាហ្មណ៍ ឬស្មូមយាចកអស់មួយជីវិត

៥.លះបង់នូវពាក្យសម្ដីញុះញង់បំបែកបំបាក់អ្នកដទៃអស់មួយជីវិត

៦.ពោលតែពាក្យសច្ចៈទៀងត្រង់អស់មួយជីវិត

៧.គមហាមចិត្តមិនឲ្យក្រោធខឹងអស់មួយជីវិត

ធម៌ទាំង៧យ៉ាងនេះ ដែលមឃមាណពបានសមាទាន និងបានប្រព្រឹត្តធ្វើហើយ នាំឲ្យគាត់បានទទួលសេចក្ដីសុខ ក្នុងបច្ចុប្បន្នផងនិងទៅសោយសុខ ក្នុងបរលោកផង។ យ៉ាងណាមិញពូជនាគ ដែលជាពូជផ្កាយនៅលើមេឃ(ផ្កាយនាគ) តើគួប្រព្រឹត្តខ្លួនជាបុគ្គលអកតញ្ញូ(ក្រពើ) ឬក៏ប្រព្រឹត្តខ្លួនឲ្យមាននូវ កតញ្ញូនិងកតវេទី?

**<u>ខ.ផ្កាយកូនមាន់</u>**

ផ្កាយកូនមាន់នេះ ខ្ញុំបានបកស្រាយរួចម្ដងហើយ នៅក្នុងភាគទី២ ដែលនិយាយអំពីរឿងបុណ្យអុំទូក អកអំបុក សំពះព្រះខែ។ ដែលលើកយកមក បកស្រាយជាបន្ថែមនេះ គ្រាន់តែចង់ឲ្យកូន នាគបានយល់ថា យើងបច្ចុប្បន្ននិមិត្តរូប គឺផ្កាយកូនមាន់ដែលជាពូជផ្កាយ រីឯមេមាន់វិញពីមុន បានធ្លាក់ទៅរងទុក្ខក្នុងអបាយភូមិ ព្រោះហេតុតែតាំងខ្លួនជាម៉ែ(ស្គរតាំងម៉ែ)។ ឥឡូវនេះព្រះម៉ែ ដែលធ្លាក់ទៅជាប់ឃុំក្នុងអបាយភូមិនោះ បានរួចពីទុក្ខ ហើយទៅសោយនៅសម្បត្តិជាសុខ ក្នុងទេវលោកវិញហើយ គឺបដិសន្ធិក្នុងឋានផ្កាយ តើយើងជាកូនក្មេរ ដែលជាកូនពូជពង្សខាងក្រោយរបស់គាត់ គួជេរប្រមាថគាត់(ជេរម៉ែ) មើលងាយគាត់ ឬគួរដឹងគុណគាត់ ហើយធ្វើដំណើរតាមផ្លូវគាត់បច្ចុប្បន្ននេះ។ ដូច្នេះបើយើងដឹងប្រវត្តិសាវតា ថាខ្លួនជាពូជផ្កាយ ដាច់ខាតពេលស្លាប់ទៅវិញ ក៏ជាពូជផ្កាយ បុគ្គលដែលមាននូវកតញ្ញូ ពុំធ្លាក់ទៅកាន់អបាយភូមិឡើយ។

**<u>គ.ផ្កាយយាម</u>**

ផ្កាយយាមនេះ បានឆ្លុះស្រមោលទៅនឹងប្រាសាទពីរ៉ាមីតទាំងបី នៅប្រទេសអេស៊ីប បើតាមមើលការស្រាវជ្រាវ របស់ពួកអ្នករុករកអាថិកំបាំង(Discovery)។ ពាក្យនិយាយថាយាម ន័យទីមួយគឺយាមនង្គ័ល ន័យទីពីរពេលវេលា(យាមទី១យាមទី២) ន័យទីបីគឺការពារកុំឲ្យរត់រួចឬបាត់បង់ ដូចជាពួកឆ្មាំទ្វារឬទ្វារបាល ជាអ្នកយាមទ្វារកុំឲ្យបាត់បង់ របស់ដែលមាននៅខាងក្នុង មិនថាទ្រព្យមានជីវិត ឬឥតជីវិតឡើយ។ បើយើងក្រឡេកមើល ពួកប្រាសាទរាងសាជីទាំងអស់ ដែលមាននៅក្នុងពិភពលោកនេះ ទោះបីព្រះអាទិត្យតែមួយដួង ក្នុងថ្ងៃ២១ខែមីនានិង២១ខែកញ្ញា បានរះចំកណ្ដាល

កំពូលពីរ៉ាមីតដ៏ច្រើន ក៏នៅតែមិនអាចឲ្យពន្លឺនៃព្រះសូរិយា ចាំងជះពន្លឺកម្ដៅចូលទៅក្នុងពីរ៉ាមីតទាំងនោះបានឡើយ នេះជាប្រស្នាសំណង់ប្រាសាទថ្ម ដែលឆ្លុះនឹងផ្កាយ។ ដូចជាសាជីដែលគ្របពីលើបាយស្រី នៅក្នុងពិធីមង្គលការ ទាល់តែមានអ្នករាំបើកគម្របសាជីឬបាយស្រី ទើបដឹងអាថ៌កំបាំងវត្ថុ ដែលនៅក្នុងគម្របសាជីនោះ ថាជាព្រះមេ (មើលការពន្យល់បាយដែលតាងឲ្យព្រះមេក្នុងភាគ ១)។ យ៉ាងណាមិញប្រាសាទ មានរាងជាសាជី(ពីរ៉ាមីត) ដែលមាននៅក្នុងពិភពលោកនេះ ប្រស្នាអាថ៌កំបាំងដែលមាននៅក្នុងគម្រប ប្រាសាទរាងសាជីទាំងនោះ យើងអាចដឹងរឿងខាងក្នុងបាន លុះត្រាតែអ្នកជំនាន់ក្រោយ ព្រមចុះចូលទៅក្នុងទ្រូងម៉ែឪ ទើបអាចដឹងអាថ៌កំបាំងនៅក្នុង ទ្រូងសាជីទាំងនោះបាន។ ប្រស្នាអាថ៌កំបាំងភាសាគ ដែលអ្នកប្រាជ្ញពូជផ្កាយទាំងនោះ បានទុកនៅស្នាដៃគំនិត សម្រាប់ឲ្យអ្នកជំនាន់ក្រោយរបស់ពួកគេ អាចស្រាយបំភ្លឺប្រស្នារូបបាន លុះត្រាតែអ្នកជំនាន់ក្រោយនោះ ព្រមបើកគម្រប ឬក៏ចូលទៅក្នុងទ្រូងរបស់សាជីទាំងនោះ ទើបដឹងរឿងពិតនៃម្ចាស់ប្រាសាទថ្ម។

**<u>ឃ.រូបផ្កាយក្នុងសុរិយគតិ</u>** (ការគិតដំណើររូបផ្កាយ តាមដំណើរព្រះអាទិត្យ)

១.**មករា**(ផ្កាយរូបសត្វម្ករ) ២.**កុម្ភៈ** (ផ្កាយរូបក្អម) ៣.**មីនា** (ផ្កាយរូបសត្វត្រី) ៤.**មេសា** (ផ្កាយរូបសត្វចៀម) ៥.**ឧសភា** (ផ្កាយរូបសត្វគោ ឬក្បាលគោ) ៦.**មិថុនា** (ផ្កាយរូបមនុស្សប្រុសនិងស្រី) ៧.**កក្កដា** (ផ្កាយរូបសត្វក្ដាម) ៨.**សីហា** (ផ្កាយរូបសត្វរាជសីហ៍) ៩.**កញ្ញា** (ផ្កាយរូបស្រីក្រមុំ) ១០.**តុលា** (ផ្កាយរូបជញ្ជីង) ១១.**វិច្ឆិកា** (ផ្កាយរូបសត្វខ្ទួយ) ១២.**ធ្នូ** (ផ្កាយរូបធ្នូ)។

**<u>ខ.រូបផ្កាយក្នុងច័ន្ទគតិ</u>** (ការគិតដំណើរផ្កាយតាមព្រះច័ន្ទ)

១.**មិគសិរ** (ផ្កាយរូបសត្វក្ដាន់) ២.**បុស្ស** (ផ្កាយរូបសត្វក្ដាម) ៣.**មាឃ** (ផ្កាយរូបសត្វស្វាព្រាម) ៤.**ផល្គុន** (ផ្កាយរូបសត្វគោញីឈ្មោល) ៥.**ចេត្រ** (ផ្កាយរូបសត្វខ្លា) ៦.**ពិសាខ** (ផ្កាយរូបសត្វក្របី) ៧.**ជេស្ឋ** (ផ្កាយរូបសត្វពពែ) ៨.**អាសាឍ** (ផ្កាយរូបសត្វរាជសីឈ្មោលញី) ៩.**ស្រាពណ៍** (ផ្កាយរូបផ្កាឈើ) ១០.**ភទ្របទ** (ផ្កាយរូបរមាសញីឈ្មោល) ១១.**អស្សុជ** (ផ្កាយរូបសត្វសេះ) ១២.**កត្តិក** (ផ្កាយរូបសត្វកូនមាន់)។

**<u>ច.ផ្កាយប្រចាំសប្ដាហ៍</u>**

ក្នុងក្បួនបុរាណ អ្នកប្រាជ្ញលោកបាន រកឃើញនៅភពទាំង៧ជាយូរលុងណាស់មកហើយ គឺមុនសម័យព្រះសម្មាសម្ពុទ្ធត្រាស់ដឹងទៅទៀត ការដឹងពីដំណើរផ្កាយទាំងនេះ គឺដោយសាការចំរើន ឈានសមាបត្តិ ជាលោកីយរបស់ពួកព្រាហ្មណ៍ទាំងឡាយសម័យមុន។ អ្នកប្រាជ្ញខាងសាសនាបានដឹងភពទាំងនេះ មុនវិទ្យាសាស្ត្របច្ចុប្បន្នទៅទៀត អ្នកប្រាជ្ញសព្វថ្ងៃគ្រាន់តែ ទៅស្វែងរកតាមលំអាន អ្នកប្រាជ្ញពីបុរាណតែប៉ុណ្ណោះ។ តាមការត្រាស់សំម្តែង របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានពន្យល់ថា ផ្កាយឬភព នៅក្នុងចក្រវាលនេះ មិនមានចំនួនអាចរាប់បានឡើយ (អនន្ត) ដូចជាចំនួនព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានត្រាស់ដឹង នឹងបរិនិព្វានហើយ ច្រើនដូចជាគ្រាប់ខ្សាច់ ដែលមាននៅក្នុងមហាសាគរយ៉ាងណា ចំនួនភពទាំងនោះក៏ដូច្នោះដែរ។ កំណើតផ្កាយ ដែលមាននៅក្នុងក្បួនហោរាសាស្ត្រខ្មែរ ដែលដកចេញពីគម្ពីរព្រហ្មញ្ញសាសនា បង្កប់ចូលក្នុងមរតកអច្ឆរិយខ្មែរ។

**១.ព្រះអាទិត្យ**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះអាទិត្យឡើង ដោយយកសត្វរាជសីហ៍៦មកវាយដោយវេទ(វេទមន្ត) ឲ្យល្អិតជាផង់ ហើយហុំព័ទ្ធដោយសំពត់ ពណ៌ក្រហមចាស់ រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតជាអង្គព្រះសូរិយា(ព្រះអាទិត្យ) ទេពនិករឡើង មានពណ៌កាយក្រហមទ្រង់ទិព្វអាភរណ៍ ឆ្មៀលឆ្លាត់ព្រោងព្រាតទៅដោយកែវបទុមរាគ ឯវិមានប្រាសាទមានពណ៌ក្រហម ទ្រង់រាជសីហ៍ជាពាហនៈ ស្ថិតនៅក្នុងទិសឦសាន្ត(ព្រះអាទិត្យមានកម្លាំង៦)។

**២.ព្រះច័ន្ទ**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះច័ន្ទពីទេពកញ្ញា១៥រូបដោយយកទេពកញ្ញាទាំង១៥ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌លឿងខ្ចី រួច ប្រោះ ព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាព្រះច័ន្ទទេវបុត្រឡើង។មានពណ៌កាយជាពណ៌ស៊ីនួន(សម្បុរស លាយលឿង) ទ្រង់ទិព្វអាភរណ៍ កែវប្រពាលវិចិត្ត វិមានប្រាសាទមានពណ៌កែវមុក្តា ទ្រង់ អស្សរាជ(សេះ) ជាពាហនៈស្ថិតក្នុងទិសបូព៌(ព្រះច័ន្ទមានកម្លាំង១៥)។

## ៣.ព្រះអង្គារ

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះអង្គារពីមហិង្សា(ក្របី) ៨ រូប ដោយក្របីទាំង៨ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌ ក្រហម ស្ទើរ(ស៊ីជំពូ ឬពណ៌ទទឹម) គឺពណ៌របស់កែវពិទាយ រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបាន ជាអង្គព្រះអង្គារទេវបុត្រឡើង។ មានពណ៌កាយជាកែវពិទាយ ទ្រង់វត្ថកោមិនជាអាភរណ៍ មាន វិមានប្រាសាទពណ៌ទទឹមទ្រង់រាជកាសរ (ក្របី) ជាពាហនៈនៅស្ថិតក្នុងទិសអគ្នេយ៍(មានកម្លាំង៨)។

## ៤.ព្រះពុធ

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះពុធ ពីស្ដេចគុជសា(ស្ដេចដំរី)១៧រូប ដោយយកដំរីទាំង១៧ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌បៃតង (ស្លឹកឈើចាស់) រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះពុធទេវបុត្រឡើង។ មានពណ៌ កាយជាពណ៌កែវមរកត ទ្រង់ទិព្វអាភរណ៍មានវិមានពណ៌កែវមណីមានគជេន្ទ្រ (ដំរី) ជាពាហនៈស្ថិតនៅក្នុងទិសទក្សិណ (ព្រះពុធមានកម្លាំង១៧)។

## ៥.ព្រះព្រហស្បតិ៍

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះព្រហស្បតិ៍ ពីឥសី១៩រូប ដោយយកឥសីទាំង១៩ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់ពណ៌លឿងទុំ រួចប្រោះ ព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះព្រហស្បតិ៍ទេវបុត្រឡើង។ មានពណ៌កាយជាកែវពិទូរ្យ (ពេជ្រភ្នែកឆ្មា) ទ្រង់ទិព្វអភរណ៍សុវណ្ណរត្នរូជី សៀតដោយមុក្តាហារ មានវិមានពណ៌ស្រគាំ ឬ បុស្រាខាំ ទ្រង់ម្រិគរាជ(សត្វក្ដាន់ ឬសត្វកង្កែប) ជាពាហនៈស្ថិតនៅក្នុងបស្ចិមទិស (ព្រះព្រហស្បតិ៍ មានកម្លាំង១៩)។

## ៦.ព្រះសុក្រ

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះសុក្រ ពីគាវី(គោ) ២១រូប ដោយយកគោទាំង២១ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅដោយសំពត់

ពណ៌ទឹកប្រាក់ ឬក្រាម រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះសុក្រទេវបុត្រឡើង។ មានពណ៌កាយជាពណ៌ព្រះ ព័ស្ត្រសទ្រង់អភរណ៍ សំឡុយព្រះព័ស្ត្រឱភាស មានវិមានពណ៌មាស គង់លើគោឧសុភរាជជា ពាហនៈ ស្ថិតនៅក្នុងទិសឧត្តរ (ព្រះសុក្រមានកម្លាំង២១)។

**៧.ព្រះសៅរ៍**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះសៅរ៍ ពីព្យគ្ឃ្រៈ(ខ្លា) ១០ រូប ដោយយកខ្លាទាំង១០ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ ហើយរុំព័ទ្ធទៅ ដោយសំពត់ពណ៌ ខ្មៅរួច ប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជាអង្គព្រះសៅរ៍ទេវបុត្រឡើង។ ដែលមានពណ៌កាយខ្មៅស្មើ រតនៈនីលជាទិព្យអភរណ៍ មានវិមានពណ៌មរកត ទ្រង់ព្យគ្ឃ្រៈ (ខ្លា) ជាពាហនៈ ស្ថិតនៅក្នុងនីរតីទិស (ព្រះសៅរ៍មានកម្លាំង១០)។

**៨.ព្រះរាហូ**

តាមតំណាលក្នុងក្បួនហោរាសាស្ត្រ ព្រះឥសូរជាម្ចាស់បានសាងព្រះរាហូ ពីក្បាលខ្មោច១២ រូប ដោយយកក្បាលខ្មោចទាំង១២ មកវាយកាយដោយព្រះវេទ ឲ្យល្អិតទៅជាផង់ រួចប្រោះព្រំដោយទឹកអម្រឹត ក៏បង្កើតបានជា អង្គព្រះអសុរិន្ទរឿងរឹទ្ធិមហាក្លៀវក្លៃឡើង។ មានពណ៌កាយជាពណ៌សំរឹទ្ធ ទ្រង់ទិព្យសុវណ្ណសែង ពណ៌ផ្កាស្អាត មានវិមានជាពណ៌នីល មានមហាសុបណ្ណរាជឬគ្រុឌ ជាពាហនៈ ស្ថិតនៅក្នុងពាយព្យទិស (ព្រះរាហូអសុរិន្ទមានកម្លាំង១២)។ ព្រះរាហូជានាមផ្កាយទី ៨ ដែលផ្កាយរាហូនេះ មានជាប់ទាក់ទងទៅនឹង ប្រវត្តិសាវតាមាតាមហានគរ ព្រោះហេតុអ្វី? ១២ តំណាងឲ្យធាតុទឹក និមិត្តរូបឲ្យមាតា ព្រះម៉ែត្រូវយក្សចាប់យកទៅដាក់ទោស ដូច្នេះយក្សរាហូមានកំណើតកើតឡើងបាន ដោយសារសាកសពទាំង១២របស់ព្រះមាតា ព្រោះ១២ខែ = ១ឆ្នាំ (មើលការពន្យល់រូបក្នុងភាគ៣ រូបភាពទី២៦)។ ពេលដែលមិនទាន់មានកូននាគ ចេញមកច្បាំងនឹងយក្សអាថិកំបាំងនេះ គឺពុំមាននរណាដឹងឡើយ លុះត្រាតែមានកូននាគ ចេញមកច្បាំងនឹងយក្ស ធាក់យក្សឲ្យដួល ទើបយក្សព្រមក្អែរឿងចេញ។ នៅក្នុងពោះយក្សនោះ ពេលដែលក្អែចេញមក គឺមានព្រះមាតាព្រះបិតា បុត្រីបុត្រា រួមទាំងមរតកទ្រព្យទាំងអស់ គឺនគរខ្មែរទាំងមូលជារបស់យក្ស ព្រោះយើងទាំងអស់គ្នា ស្ថិតក្នុងពោះយក្ស ដូច្នេះទើបយក្សតែងតែស្រែកអរ(យក្សអរ)។ ហើយយក្សឬរាហូនេះទៀតសោត មានគ្រុឌជាយានជំនិះ ដែលគ្រុឌនេះជាសេនា ជាយានជំនិះរបស់យក្សឈ្មោះ

រាហូ ឬក្រុងរាពណ៍ និមិត្តរូបគ្រុឌជាសញ្ញារបស់ជនជាតិសៀម។ រាហូគឺជាផ្កាយមួយដួង អាចមានរូបរាងកើតឡើង ដោយសារក្បាលខ្មោចទាំង១២ ដែលតំណាងឲ្យព្រះម៉ែមហានគរ គាត់បានដេកស្លាប់នៅក្នុងពោះយក្សនេះ ដោយត្រូវទណ្ឌកម្មគឺយក្សលេប ហេតុនេះទើបក្នុងតម្រាផ្កាយ មានរឿងរាហូចាប់ច័ន្ទ រាហូតំណាងឲ្យយក្ស ចំណែកឯព្រះច័ន្ទតំណាងឲ្យទិព្វសេតាច័ន្ទ វិមានច័ន្ទសោមាឬសោម.... ដែលជាឈ្មោះរបស់មាតាមហានគរ។ ដូច្នេះចង់ដឹងពីប្រវត្តិសាវតាព្រះម៉ែមហានគរ កូននាគត្រូវតែច្បាំងតតាំងបំបែកបេះដូងយក្ស ទើបដឹងអាថ៌កំបាំងខាងក្នុងពោះយក្សបាន នេះជាប្រស្នាអាថ៌កំបាំងដែលមានលាក់ទុករឿង ក្នុងដួងផ្កាយរាហូនេះ រីឯផ្កាយផ្សេងៗទៀត សូមកូននាគជួយត្រិះរិះឈ្វេងយល់។

## ៩.ព្រះកេតុ

ជានាមផ្កាយដួងទី៩ ក្នុងតំណាលវេទកំណើត មិនបានពោលទុកថាសាងដោយអ្វីឡើយ ហើយក៏មិនបានប្រាប់ថា ជាផ្កាយដែលសោយអាយុមនុស្សផង ហោរាចារ្យប្រើពិធីកាញ់គ្មេរ ក្នុងការចងដួងជតា សម្រាប់ឲ្យគ្រប់ចំនួនផ្កាយ៩ដួង។ ក្នុងក្រាំងជាតម្រាបុរាណ ហោរាសាស្ត្រ និងដួងកាលចក្របានពោលថា ព្រះកេតុនេះសាងឡើង ដោយស្តេចនាគ១០ ជាវិញ្ញាណធាតុ ស្ថិតនៅត្រង់កណ្តាលភ្នែក ជាផ្កាយព្រះគ្រោះទី៨ គឺថាមិននៅក្នុងទិសណាៗ។ ព្រះកេតុទេវរាជ ទ្រង់ទិព្យសុវណ្ណអភរណ៍វិភូសិទ ទ្រង់ម័ង្គរឿងរិទ្ធិជាពាហណៈ ព្រមដោយទេពសុរារិទ្ធិ ចោមរោមជាបរិវា ស្ថិតក្នុងទិសបស្ចិម អាស្រ័យផ្ទះជាមួយនឹងព្រះព្រហស្បតិ៍។

## ១០.ម្រឹត្យូវ

ម្រឹត្យូវនេះជាអាកាសធាតុ ថាមិនមែនផ្កាយក៏មិនបាន ព្រោះមានគោចរក្នុងទំនង ហោរាសាស្ត្របានពោលថា ស្រដៀងគ្នានឹងផ្កាយព្រះគ្រោះ ប៉ុន្តែដើរយូរជាងផ្កាយគ្រប់ដួងទាំងអស់។ (ក្បួនតារាសាស្ត្រនេះ ដកស្រង់ចេញពីក្បួនហោរាសាស្ត្របុរាណ)

បើយើងមើលទៅលើដួងផ្កាយ ដែលបានរៀបរាប់ខាងលើ គឺបានបញ្ជាក់ប្រាប់យើងថា ព្រះឥសូរ បានបង្កើតភពឬផ្កាយ ដោយវេទ(វេទមន្ត) តើកូននាគមានឆ្ងល់ទេ បើព្រះឥសូរជាអ្នកបង្កើតផ្កាយ ភព ធម្មជាតិ សត្វលោកមកហើយ ហេតុអ្វីចាំបង្កើតទុក្ខសោក ព្រាត់ប្រាស់ រោគាព្យាធិមរណៈ លោភៈ ទោសៈ មោហៈ........ មកឲ្យសត្វលោកធ្វើអ្វី? ម្តេចក៏មិនបង្កើតតែសេចក្តីល្អៗ

ទៅ ការឆ្ងល់នេះធ្វើឲ្យយើង ត្រូវតែស្វែងរកនូវសច្ចភាពគឺធម៌ពិត តើភពផ្កាយមនុស្ស សត្វ ធម្មជាតិ .... ទាំងអស់ដែលមានក្នុងចក្រវាល មិនមាន ទីបំផុតនេះ អ្នកណាជាអ្នកបង្កើត? គឺគ្មានអាទិទេព ណា ជាអ្នកបង្កើតឬសាងលោកនេះឡើយ គឺវាកើតឡើងទៅតាមកម្លាំងកម្ម ជាធម្មតា(ធម្ម:)របស់ វា។ ចំណែកឯរឿង អ្នកបង្កើតនគរនិងជាតិ គឺមាតាមហានគរក្តី សំណង់ប្រាសាទក្មេរនិងសំណង់ ប្រាសាទនៅលើពិភពលោក ដែលឆ្លុះទៅនឹងដួងផ្កាយក្តី សុទ្ធតែទាក់ទង នឹងកើតឡើង ដោយកម្លាំង កម្ម។ មនុស្សអាចដឹង កាលអតីតបច្ចុប្បន្នអនាគត ក៏វាទាក់ទងទៅនឹងកម្មដែរ ព្រោះការប្រព្រឹត្ត អំពើ(កម្ម)ដោយកាយវាចាចិត្ត វាបង្កើតបានជាខ្សែច្រវាក់មួយ គឺវដ្តសង្សារដែលទាក់ទងគ្នាមិន ដាច់ ត្រូវនាំចិត្តទៅបដិសន្ធិក្នុងភពតូច និងភពធំ(កាមភព រូបភព និង អរូបភព)។ នៅពេលណា ដែលសត្វទាំងអស់ រស់នៅក្នុងភពទាំងបីនេះ ពុំបានលះបង់ចោលនៅសេចក្តីប្រកាន់មាំ ក្នុង បញ្ចក្ខន្ធគឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណទេនោះ ខ្សែនៃតណ្ហាត្រូវចងភ្ជាប់ឲ្យសត្វ ទាំងអស់ ជាប់នៅក្នុងភពបីនេះ ស្រាយចំណងពុំរួចឡើយ។ ដូចជាបុគ្គលបង្ហោះខ្លែង ខ្លែងតែងហោះទៅកាន់ វេហា ទោះជាបុគ្គលអ្នកបង្ហោះ ខំបន្ធូរខ្សែឲ្យវែង រហូតដល់មើលតួខ្លែងមិនឃើញក៏ដោយ ខ្លែង នោះមិនអាចហោះទៅឲ្យបានផុត ពីខ្សែដែលគេចងនៅដើមទ្រូងបានឡើយ។ យ៉ាងណាមិញបុគ្គល ដែលអាចចម្រើនឈាន មានរិទ្ធិមានអភិញ្ញា បើមិនបានកាត់ផ្តាច់នូវឫសគល់ គឺអវិជ្ជានិងតណ្ហា នោះទេ ក៏មិនអាចចេញរួច ពីវដ្តសង្សារនេះបានឡើយ។ ដូចជាព្រះមាតាបិតា និងបុត្រអ្នកបង្កើត នគរនេះ លោកជាបុគ្គលចម្រើននូវឈានសមាបត្តិ មានរិទ្ធិអភិញ្ញាជាលោកិយ អាចហោះទៅកាន់ ទេវលោកបាន កាលពីជាង២០០០ឆ្នាំមុន។ ដោយចិត្តលោភ អ្នកទាំងបីនោះគឺឪពុកម្តាយកូន ពួក គាត់បានទៅលួចយកកែវមណី ពីឋានយក្សរាហូឬក្រុងរាពណ៍ រួចត្រូវយក្សតាមចាប់យកទៅដាក់ ទោស មិនឲ្យពួកគាត់ងូតទឹកចំនួន២ថ្ងៃ គឺស្មើនឹងរយៈពេលស្ថានមនុស្ស២០០០ឆ្នាំ។ នេះជា ហេតុដែលនាគក្មេរមានតែក្បាល ឯខ្លួនត្រូវយក្សលេប គឺវាជានិមិត្តរូបទោស ដែលមិនឲ្យ ងូតទឹក ពួកគាត់បុណ្យត្រូវ ឲ្យទៅបដិសន្ធិក្នុងព្រហ្មលោក ដោយអំណាចឈានសមាបត្តជា លោកិយ ផ្ទុយទៅវិញពួកគាត់បែរជាទៅសោយបាប ដោយអំណាចតណ្ហាលោភៈ ទោសៈ មោហៈ និងសេចក្តីប្រកាន់មាំ។ ចំណែកនាគនៅម៉ាយ៉ានប្រទេសម៉ិចស៊ីកូ នាគចម្លាក់របស់ពួកគេ ក៏មានតែក្បាលដែរ ក្នុងមួយឆ្នាំស្រមោលព្រះអាទិត្យ ថ្ងៃ២១មីនានិង២១កញ្ញា បង្កើតជាស្រមោល ខ្លួននាគបានពីរថ្ងៃ គឺមានខ្លួននឹងគេដែរ តែខ្លួនជាស្រមោលចណាំងថ្ងៃ គ្មានរូបភាពពិតដូចជានាគ

ក្មេរឡើយ នាគក្មេរមានខ្លួនពិតតែជាខ្លួនយក្ស(និមិត្តរូប)។ នេះជាហេតុដែលអ្នកប្រាជ្ញ ខាងរុករក អាចិកំបាំងប្រាសាទ ពួកគេមានការងឿងឆ្ងល់រកចម្លើយនេះមិនឃើញ ព្រោះចម្លើយវាមានទាក់ទង ទៅនឹងភពផ្កាយខាងលើ ក្នុងភាសាព្រះធម៌ព្រះពុទ្ធសាសនា គឺកម្ម និងវិបាករបស់កម្ម។ បឹងយក្ស ឡោមនៅខេត្តរតនៈគិរី សព្វថ្ងៃយើងនាំគ្នាសន្មត់ថា ជារណ្ដៅបន្ទុះភ្នំភ្លើង ដូនតាយើងបានដាក់ ឈ្មោះទីនោះ ដោយប្រាប់ហេតុថា គឺយក្សឡោមព័ទ្ធដេញចាប់មនុស្សបីនាក់ ដែលទៅលួចយកកែវ មណីរបស់គេ។ ពួកគាត់លួចយកកែវមណីមក ដើម្បីចាក់សោការពារទ្រព្យ ដែលខ្លួនធ្វើសង្គ្រាម ពង្រាតទឹកដី រួចប្រមូលដណ្ដើមយកមក ពីប្រទេសជាចំណុះរាប់រយ ដើម្បីទុកឲ្យបានគង់វង្សមាំមួនកុំ ឲ្យបាត់បង់ សម្រាប់ទុកជាមរតក ឲ្យពូជក្មេរជំនាន់ក្រោយ។ ទីបំផុតអ្នកដែលប្រព្រឹត្ត បានត្រឹមក្លាយ ខ្លួនជាអ្នកទោស មានឈ្មោះជាព្រាយ ជាប្រេត ជាបិសាច ព្រោះហេតុតែមរតកទ្រព្យរបស់ខ្លួន គឺ មាតុភូមិនេះទាំងមូល ដែលគាត់ខំវាយលូនកាប់ឆ្ការប្រមូល ទ្រព្យមរតកទាំងនេះ មកទុកឲ្យកូនក្មេរ ជំនាន់ក្រោយ។ ដោយខ្លាចកូនក្មេរជំនាន់ក្រោយពុំដឹងរឿងខ្លួន គាត់ខំសម្ដែងរឹទ្ធិជាចុងក្រោយ លួច ចេញពីទីឃុំ ប្រមូលយកឯកសារសំណង់ប្រាសាទ ដែលមាននៅក្នុងលោកនេះទាំងមូល យកមកឲ្យ កូននាគសម័យមហានគរ សង់ប្រាសាទថ្មបន្តគ្នា រួចឆ្លាក់រៀបរាប់រឿង ដែលខ្លួនបានប្រព្រឹត្តហើយ ត្រូវជាប់ទោស និងរឿងដែលមានកូននាគ អ្នកមកជួយឲ្យរួចពីទោស។ តំណាក់កាលចុងក្រោយ ពួកបរទេសគេបានស្រាវជ្រាវដឹង ពួកគេ តាមបិទតាមសន្ធប់ តាមលុបដានស្នាមឈប់ឲ្យគាត់ចេញ មកក្រៅឃុំរួច ដើម្បីកុំឲ្យកូនក្មេរជំនាន់ក្រោយដឹង។ ទោះបីពួកគេខំប្រឹងប្រែង បិទសន្ធប់យ៉ាងណាក៏ ដោយ កម្លាំងឫទ្ធិជាលោកិយ ពុំអាចឈ្នះកម្លាំងកម្មបានឡើយ កុំថាឡើយមនុស្សជាបុថុជ្ជន សូម្បី តែព្រះអរហន្តសម្មាសម្ពុទ្ធ អស់អាសវកិលេសមានឫទ្ធិអភិញ្ញា អាចឃាត់ឃាំងនៅដំណើរមារាធិ រាជបាន ក៏នៅតែមិនអាចឃាត់ឃាំង នូវកម្លាំងកម្ម ដែលតាមឲ្យផលនេះបានឡើយ។ ពេលណា បាបកម្មឲ្យផលអស់ បុញ្ញកម្មក៏តាមឲ្យផលជាបន្ត វិលទៅវិលមក ម្ដងបាបឲ្យផលម្ដងបុណ្យ ឲ្យផល បង្កើតបានជាកងចក្រវាក់មួយគឺវដ្តសង្សារ លុះត្រាតែបុគ្គលរួចផុតពីខន្ធ កាត់ផ្ដាច់នៅខ្សែ តណ្ហា ដែលមានអវិជ្ជាជាឫសគល់ ទើបនៅជាសុខលែងវិលកើតវិលស្លាប់ គឺបរិនិព្វាន។

## VIII.អំពីអត្ថន័យបន្ទប់ក្នុងនំអន្សម នំគម ដើមចេក

### ក.នំអន្សម

នំអន្សមគឺជានំមួយ ដែលទាក់ទងទៅនឹងប្រវត្តិនំប្រពៃណីខ្មែរ ព្រោះនំនេះគេច្រើនវេច នៅរដូវបុណ្យចូលព្រះវស្សា បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំ នៅក្នុងពិធីមង្គលផ្សេងៗ មានមង្គលការជាដើម។ល។ តើនំអន្សមនេះ មានន័យប្រស្នាអ្វី បង្កប់ទុកក្នុងរឿងមាតាមហានគ?

**ពន្យល់ពាក្យ** (អន្សម)

អន្សមជាពាក្យតម្រួត ពាក្យរាយឬសម្រាយមានពាក្យ **អន** + **សម** = **អន្សម**

***អន*** ស. ( គុ. ) ទន់, ស្រទន់ : សម្បុរអន សម្បុរស្រទន់, សម្បុរស្រគាំ; ខៀវអន ខៀវខ្ចី ។ ព. កា. សម្រាប់កវីប្រើតាមត្រូវការ, ដូចជាកាព្យថា កញ្ញាឈ្មោះអន និងនាងគូកន ពាក់អាវអនខ្ចី ដំណើរញ៉ែងញ៉ង ញ៉ិកញ៉ាក់ល្វតល្វៃ មុខមាត់ប្រិមប្រិយ៍សម្ដីស្រទន់ ។ ឬមួយបែបទៀតថា ទ្រង់ទ្រាយស្រឡូនឆវីវណ្ណអន មុខមាត់ស្រស់បស់ ពេញទាំងសព៌ាង្គ រូបរាងទាំងអស់ សុទ្ធសឹងតែស្រស់ ឥតទាស់ភ្នែកឡើយ ។ (ដកចេញពីវចនានុក្រមសម្ដេច)

***អន*** ( ន. ) ឈ្មោះបទភ្លេងបុរាណខ្មែរមួយបែប : ភ្លេងអន ។ គេលេងនៅពេលដែលត្រូវសុំឲ្យកូនស្រីចេញពីល្វែងចន្ទន៍ខាងក្នុងមកក្រាបផ្ទឹមជាមួយនឹងកូនប្រុសជាគូគ្នា, ប្រើក្នុងពិធីអាវាហមង្គល; គេច្រៀងថា : អនអើយស្រីអន សុំបើកវាំងនន អញ្ជើញអនមកផ្ទឹម លុះផ្ទឹមរួចហើយ អញ្ជើញសន្សឹម ដើរចូលតែត្រឹម ល្វែងចន្ទន៍ខាងក្នុង ។ល។ វាយទំនុកយ៉ាងណានោះ ស្រេចនឹងការឈ្លាសវៃស្ទាត់ជំនាញរបស់អ្នកច្រៀងដែលច្រៀងវាយទំនុកមិនឲ្យឆ្គង។ (ដកចេញពីវចនានុក្រមសម្ដេច)

***សម*** ស. ( ន. ) នេសាទុបករណ៍មួយប្រភេទ មានផ្លែដែកមូលស្រួចបីទន្ទឹមគ្នាឥតង្វៀង មានដងឈើខ្លីកោងក្ងក់ សម្រាប់ចាក់ត្រី ។ ប្រដាប់មានផ្លែជាប្រាមបួនទន្ទឹមគ្នាជាគូនឹងស្លាបព្រា សម្រាប់កាន់ចាក់ចាប់អាហារបរិភោគ ។ (ដកចេញពីវចនានុក្រមសម្ដេច)

***សម***. ( កិ. ) ហ្វឹកហាត់ឲ្យស្ទាត់, ហាត់ជាមួយគ្នាឲ្យជំនាញ, ល្បងគ្នាមើលឲ្យដឹងដំណើរស្ទាត់រាល់ខ្លួន : អ្នកប្រដាល់សមដៃគ្នា, លោកសង្ឃសមធម៌, អ្នករៀនបាលីសមប្រយោគ ។ (ដកចេញពីវចនានុក្រមសម្ដេច)

***សម***( គុ. ) ដែលរញមស្លឹក ដោយត្រូវកម្ដៅថ្ងៃខ្លាំង ឬជាំទឹកជាដើម : ឈើសមស្លឹក ។ (ដកចេញពីវចនានុក្រមសម្ដេច)

**សម** សំ សំ. បា. ( គុ. ) ដែលស្មើគ្នា, ប៉ុនគ្នា, ប្រហែលគ្នា; ស្រដៀងគ្នា : រូបរាងសមគ្នា, ប្ដីប្រពន្ធសមគ្នា ។ ដែលល្មមល្អមើល, មិនទាស់ភ្នែក, មិនឆ្គង : កាត់សក់សម, ស្លៀកពាក់សម ។ ដែលត្រូវ, ត្រូវដូច; សមដូចពាក្យគេថា; និយាយដូច្នេះមិនសមសោះ ! ។ល។ សមគប់ កិ. គប់រក, ចូលគំនិតគ្នា ។ សមគួរ គុ. ល្មម, យ៉ាងមធ្យម : ល្អសមគួរ ។ ន. ដំណើរសម្ដែងអាការកិរិយាសុភាពរៀបរយ, ការធ្វើបដិសណ្ឋាររកគ្នាត្រូវបែបបទ : មានសមគួរកគ្នា ។ សមគំនិត កិ. រួមគំនិតជាមួយ ។ សមជា និ. គួរជា, ល្មមជា : សមជានឹងបាន ។ សមតែ និ. គួរតែ, ល្មមតែ : សមតែនឹងឲ្យ ។ សមបី និ. គួរបី, គួរគប្បី : សមបីអ្វីនឹងដល់ម្លឹង !; មិនសមបីនឹងទៅជាយ៉ាងហ្នឹងសោះ ! ។ សមបុណ្យ គុ. ដែលគួរដល់បុណ្យ, ដែលល្មមនឹងបុណ្យ ។ សមបើ និ. គួរបើ : មិនសមបើដល់ម្លឹងសោះ ! ។ សមបំណង កិ. ឬ កិ. វិ. បានដូចបំណង; ដែលត្រូវត្រង់តាមបំណង: បានសម្រេចប្រយោជន៍សមបំណង ។ សមប្រកប កិ. ឬ កិ. វិ. បានកបដូចចិត្ត; ដែលត្រូវចួនត្រូវទំនង: រកស៊ីសមប្រកប ។ សមមាឌ កិ. ឬ. គុ. ល្មមដល់មាឌ : ខ្លាំងមិនសមមាឌ ។ សមមាត់ កិ. ឬ គុ. គួរដល់មាត់, គួរស្ដីនិយាយ, គួរហើបមាត់ថា : មិនសមមាត់នឹងនិយាយទៅរក ។ សមរម្យ (--រំ) គុ. ឬ កិ. វិ. ដែលត្រូវបែបត្រូវយ៉ាង, មិនទាស់ភ្នែក : ស្លៀកពាក់សមរម្យ , រូបឆោមសមរម្យ ។ សមសក្តិ ឬ --ស័ក្តិ ន. ឬ គុ. អំណាចដ៏សមរម្យ; អំណាចស្មើ; សមបុណ្យសមអំណាច ។ សមសារ (ម. ព. លំនាំសមសារ ផង) ។ សមសួន គុ. (សំ. បា. សម + ស. ស្វន អ. ថ. សួន "ភាគ, ចំណែក, ប៉ែក") មានភាគដ៏សម, សមតាមភាគ; សមតាមបែប, តាមភាព; ដែលត្រូវតាមខ្នាត: រូបរាងសមសួន; មានកម្ពស់សមសួន ។ល។ (ដកចេញពីវចនានុក្រមសម្ដេច)

**សម** ស:ម៉: សំ. បា. ( គុ. ) ស្មើ, ស្មើគ្នា, ប៉ុនគ្នា, ប្រហែលគ្នា, ដូចគ្នា (ព. ផ្ទ. វិសម) ។ ប្រើរៀងភ្ជាប់ពីខាងដើមសព្ទដទៃបានតាមគួរដល់ការប្រកប : សមគោត្ត ឬ--គោត្រ គោត្រត្រូវគ្នា, សែត្រូវគ្នា; អ្នកដែលមានគោត្រត្រូវគ្នា ។ សមចរិយា (ស:ម៉:ច:រិយ៉ា) ការប្រព្រឹត្តស្មើ, ការកាន់ធម៌ស្មើ គឺមិនលម្អៀង ព្រោះស្រឡាញ់, ព្រោះស្អប់, ព្រោះល្ងង់, ព្រោះខ្លាច (ម. ព. អគតិ ផង) ។ សមចារី អ្នកប្រព្រឹត្តស្មើ, អ្នកកាន់ធម៌ស្មើ (អ្នកមិនលម្អៀងដោយអគតិ ៤ យ៉ាង); បើស្ត្រីជា សមចារិនី ។ សមចិត្ត ចិត្តស្មើ; ចិត្តស្មើគ្នា ។ សមចិន្តា (--ចិន-ដា) គំនិតស្មើគ្នា ។ សមជាតិ ជាតិស្មើគ្នា; ជាតិត្រូវគ្នា ។ សមជាតិក ឬ--ជាតិក: អ្នកដែលមានជាតិស្មើគ្នា (បើស្ត្រីជា សមជាតិកា) ។ សមជីវិតា ការចិញ្ចឹមជីវិតស្មើ គឺចិញ្ចឹមជីវិតត្រូវតាមធម៌ តាមច្បាប់មិនខ្ពស់ៗទាបៗ ។ សមតេជះ តេជះ, អំណាច ស្មើគ្នា; អ្នកដែលមានអំណាចស្មើគ្នា ។ សមទណ្ឌ (--ទ័ន) អាជ្ញា, ពិន័យដែលសមនឹងទោសខុស ។ សមនាម ឬ សមាននាម

(សៈម៉ានៈ--) ឈ្មោះត្រូវគ្នា; អ្នកដែលមានឈ្មោះត្រូវគ្នា ។ សមភាគ ចំណែកស្មើគ្នា ។ សមភាព ភាពស្មើគ្នា, ដំណើរស្មើមុខគ្នា (ម. ព. នេះទៀតផង) ។ សមវ័យ អាយុស្មើគ្នា, ឆ្នាំដំណាលគ្នា ។ សមវិជ្ជា ឬ--វិទ្យា ចំណេះស្មើគ្នា ។ សមវិទ អ្នកដែលមានចំណេះស្មើគ្នា ។ សមវិបាក ដែលមានវិបាកស្មើគ្នា; អំពើដែលមានផលស្មើគ្នា ។ សមានុភាព (សៈម៉ា--; សំ. បា. < សម + អានុភាវ) អនុភាពស្មើគ្នា; អ្នកដែលមានអានុភាពស្មើគ្នា ។ល។(ដកចេញពីវចនានុក្រមសម្តេច)

បើតាមមើលការពន្យល់ពាក្យខាងលើ ន័យរបស់នំអន្សមគឺនំដែលមានសភាពទន់ មានរូបរាងប៉ុនគ្នា កើតឡើងដោយភាពស្ទាត់ជំនាញរបស់អ្នកវេច ត្រូវស្ងោរឲ្យញមស្លឹកចេកដែលវេចខ្ចប់ទើបឆ្អិន។ បើបកតាមន័យអាថ៌កំបាំង បណ្តាំមាតាមហានគរ និមិត្តរូបសោឃុំឃាំងទាំង៤ជាន់ តើដូចម្តេច? ចំណាងចងនំពីខាងក្រៅ ទុកដូចជាសោទ្វារទីមួយ ស្លឹកចេកដែលវេចខ្ចប់ ទុកដូចជាសោទ្វារទីពីរ អង្ករដំណើប ទុកដូចជាសោទ្វារទីបី ចំណែកឯសណ្តែក ដែលប្រឡាក់រុំព័ទ្ធសាច់ជ្រូក គឺជាសោទ្វារទីបួន រីឯសាច់ជ្រូកតំណាងឲ្យបុគ្គលដែលជាប់ឃុំ។ ព្រោះនិមិត្តរូបសត្វជ្រូក គឺជាប់ក្នុងទ្រុងដេកលើភក់ នឹងលាមកទឹកមូត្រខ្លួនឯង ធ្វើជាសម្លៀកបំពាក់ ដូចជាប្រវត្តិរឿងមាតាមហានគរ ត្រូវដេកត្រាំក្នុងសមុទ្រទឹកដោះ ដែលស្អុយរាប់ពាន់ឆ្នាំ នៅក្នុងភក់រហូតភក់ក្លាយជាថ្ម គឺថ្មភក់។ នំអន្សមនេះរាងរៅរបស់វា គេតែងប្រដូចទៅនឹងលិង្គព្រះឥសូរ បើជានិមិត្តរូបលិង្គរបស់ព្រះឥសូរ ហេតុអ្វីបានជាត្រូវយកមកស្ងោរ នៅក្នុងទឹកក្តៅ?

**ខ.នំគម**

នំគមឬនំបត់ គឺជានំដែលជាគូនឹងនំអន្សម ហើយប្រវត្តិរបស់វាក៏ដូចជានំអន្សមដែរ គ្រាន់តែនំគមនេះ អភ័ពជាងនំអន្សម ព្រោះគេត្រូវយកអង្ករដំណើប ទៅកិនបំបែករាងកាយឲ្យទៅជាម្សៅ រួចយកទៅស្ពៀតឲ្យអស់ទឹក ទើបយកមកវេច (និមិត្តរូបទារុណកម្ម)។

**ពន្យល់ពាក្យ** (គម)

**គម** ( គុ. ) ដែលមានខ្នងពកកំពូកស្រដៀងនឹងបូកគោ : មនុស្សគម, ខ្នងគម, គមគាក់ គមនិងគាក់ (ម. ព. គាក់ ផង) ។ (ដកចេញពីវចនានុក្រមសម្តេច)

**គម** ( ន. ) ឈ្មោះនំ ១ យ៉ាង មានសណ្ឋានដូចខ្នងគម ធ្វើពីម្សៅដំណើបមានស្នូលដូង ឬ ស្នូលសណ្ដែកស្បាត់ស្ករ ខ្ចប់ដោយស្លឹក ចម្អិនដោយចំហុយ : នំគម ។ (ដកចេញពីវចនានុក្រមសម្ដេច)

**គម** ( ន. ) បណ្ដូល-កឈើក្នុងពួកត្នោត, ដូង, ស្លា, ជ្រៃ; ប្រើធ្វើជាបន្លែ, អន្លក់ មានរសពីសាប្រើជួសសាឡាត់បាន : គមត្នោត, គមដូង, គមស្លា គមស្លាត្រឌិន ។ល។(ដកចេញពីវចនានុក្រមសម្ដេច)

នំគមបើមើលតាមការពន្យល់ពាក្យខាងលើ គឺជានំដែលមានរាងពកកំពូកឡើង ហើយជាបណ្ដូលនៃរុក្ខជាតិ(ពួកត្នោត ដូង ស្លា ជ្រៃ) បើប្រៀបនឹងរឿងមាតាមហានគរ គឺជាឬសកែវ។ តើនំគមមានអត្ថន័យដូចម្ដេច ទាក់ទងនឹងសាវតាមាតាមហានគរ? នំគមមានស្លឹកចេករុំព័ទ្ធជាទី១ ម្សៅដំណើបរុំព័ទ្ធជាទី២ ចំណែកស្នូលជាទី៣នៅខាងក្នុង គឺយកស្ករទៅធ្វើជាតាំងម៉ៃ ទើបដាក់ដូងឬសណ្ដែកកូរជាមួយស្ករតាំងម៉ៃឲ្យចូលគ្នាសព្វ។ ដូច្នេះន័យក្នុងអាថិកំបាំងមាតាមហានគរ ទី១រូបរាងនំដូចជាភេទរបស់ម្ដាយ ទី២បណ្ដូលឬស្នូលខាងក្នុង មានបង្កប់ឈ្មោះស្ករតាំងម៉ៃ ទី៣អង្ករដំណើបដែលកិនជាម្សៅ តំណាងឲ្យព្រះមេ។ ហេតុអ្វីនំអន្សម និងនំគម ត្រូវយកអង្ករដំណើបមកធ្វើ? យើងតែងឮចាស់ពីបុរាណ គាត់ជេរស្ដីប្រៀបធៀបមនុស្ស ដែលមានស្មារតីពុំគ្រប់គ្រាន់ថាមនុស្សដំណើបលាយខ្សាយ គឺមានន័យថាពុំបរិសុទ្ធគ្រប់គ្រាន់។ ចុះបើដំណើបសុទ្ធវិញ តើមានន័យដូចម្ដេច? គឺវាទន់ជ្រាយស្អិត មិនងាយនឹងមានភាពរឹងប៉ឹង ខ្លួនឯងឡើងវិញបានឡើយ ដូច្នេះត្រូវតែពឹងពាក់ភាពរឹងប៉ឹងពីខាងក្រៅ។

**<u>គ.ដើមចេក</u>**

ហេតុអ្វីក៏ដើមចេកនេះ មានវាសនាខ្ពស់អ្វីម្លេះ អាចឡើងទៅកាន់ទីសក្ការៈផ្សេងៗ? នៅក្នុងពិធីបុណ្យផ្សេងៗ យើងតែងឃើញគេយកកូនចេកឬដើមចេកទៅធ្វើស្លាធម៌ បាយសី យកស្លឹកទៅវេចនំ យកស្រទបទៅធ្វើពៃ....។ល។ ហើយកូនចេកនោះទៀតសោត គេច្រើនយកកូនចេកដែលមានស្លឹក៣ តើអាថិកំបាំងដើមចេកនេះ វាមានន័យអ្វីទៅនឹងសាវតាមាតាមហានគរ? ពាក្យនិយាយថាដាំចេក ត្រឡប់ពាក្យមកវិញគឺដេកចាំ តើអ្នកណាជាអ្នកដេកចាំ? អ្នកដែលដេកចាំអស់រយកាលរាប់ពាន់ឆ្នាំ គឺមាតាមហានគរ ដែលលោកដេកចាំយូរពេកទៅ ក៏ស្លាប់ឈ្មោះចេញពីសន្ដានចិត្តកូននាគ តើលោកដេកចាំអ្វី? គឺលោកដេកចាំកូននាគ ស្វែងរកអាថិកំបាំងរបស់

លោកឲ្យឃើញ ហើយនាំគ្នាជួយស្រង់លោក ឲ្យរួចផុតពីទីឃុំទាំង៣។ ដូច្នេះហើយទើបដើមចេកមានវាសនាខ្ពស់ ក្លាយជារុក្ខជាតិបូជាព្រះធម៌(ចេកស្លាធម៌) ក្លាយជាស្លឹកសម្រាប់វេចនំ និងក្លាយជាពែងដាក់អាហារ សែនឧទ្ទិសទៅឲ្យពពួកបិសាចប្រេត ចំណែកផ្លែក្លាយជាសំណែនរបស់អមនុស្សត្រយ៉ូង ក្លាយជារបោយសម្រាប់លាយ បំភ័ន្តជាមួយនឹងនំបញ្ចុក។ល។

នេះគ្រាន់តែជាការបកស្រាយពន្យល់ ដោយសង្ខេបអំពីនំអន្សម នំគម ដើមចេក ដែលបានបង្កប់ទុកក្នុងប្រវត្តិសាវតា របស់មាតាមហានគរពីអតីតកាល សម្រាប់ឲ្យកូននាគយកទៅពិចារណាឡើងវិញ ហេតុអ្វីបានជារបស់ទាំងនេះ មានតម្លៃជាអមតៈ ស្ថិតក្នុងសន្តានចិត្តកូនក្មេរ។

## IX.អំពីសុភាសិត

សុភាសិតគឺជាកម្រងពាក្យសម្ដី ដែលបង្កប់ន័យគំនិត ទៅតាមបញ្ញាជាលោកិយ និងជាលោកុត្តរៈ ដូច្នេះយើងអាចយល់ភាសិតទាំងនោះបាន លុះត្រាតែបានស្ដាប់ការពន្យល់បកស្រាយ ពីបណ្ឌិតបុរសប្បុរសនោះ។ល។

ឧ. សុភាសិតរបស់ព្រះសម្មាសម្ពុទ្ធ

- កម្លាំងអ្វីស្មើដោយកម្លាំងកម្មគឺពុំមានឡើយ
- ទុក្ខអ្វីស្មើដោយខន្ធនេះគឺពុំមានឡើយ
- ភ្លើងអ្វីស្មើដោយភ្លើងរាគៈគឺពុំមានឡើយ
- កំហុសអ្វីស្មើដោយទោសៈគឺពុំមានឡើយ
- សុខអ្វីស្មើដោយសេចក្ដីស្ងប់គឺពុំមានឡើយ

ឧ.សុភាសិតដូនតាក្មេរ៖

- ទូកទៅកំពង់នៅ
- ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាយកភ្លើងដុតគល់
- នំមិនធំជាងនាឡិ
- អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក

- ពេលឈឺយកដំរីទៅបន់ ពេលជំងឺស្រន់ពងមាន់មួយស្តាយ
- ត្រុកៗអ្នកស្រុកមើលងាយ រលាស់គូថខ្ចាយ មានឪនមានភ័ន្ត

ឱ.<u>នេះជាសុភាសិតខ្ញុំប្បាទះ</u>

- ពេលប្រើប្រាស់ទឹកត្រូវនឹកឃើញម្តាយ ពេលបានហូបបាយនឹកឃើញព្រះមេ
- បេះស្លឹកផ្កាផ្លែនឹកឃើញគល់ឬស ចង់ដឹងន័យទិសនឹកដល់ព្រះសាស្តា
- ហូបអំបុកនំប៉ែនចុក នឹកឃើញទុក្ខវេទនា ប្រើប្រាស់គង់គានឹកឃើញដល់ម៉ែ
- នំគមអន្សមស្លោកស្លឹកព្រោះក្តៅ ម៉ែយាព្រោះចៅ ក្លាយជាជីដូន
- ដូងចេកម្លូស្លាសាវតាម្ចាស់ជាតិ គ្រប់ញាតិក្នុងដែនចោលកេរបាត់ជាតិ
- រឿងកើតលើដីផ្លុះផ្កាលើមេឃ
- ជ័យឈ្នះទីមួយដោះប្រស្នាឪឡឹកបី ជ័យឈ្នះទីពីរប្រើភាសាក្តាម ជ័យឈ្នះទីបីបង្ហោះខ្លែងឯក
- ព្រហ្មពិតស្ថិតនៅលើដី ពូជខ្មែរប្រុសស្រីកើតចេញពីព្រហ្ម
- ទេវបុត្រមានមុខតែមួយ ព្រហ្មមានតែត្រួយមានមុខបួន
- សម្លខ្មែរទឹកខ្ចាយពណ៌បៃតង ការីក្រហមដាំបំបែកប្រស្នាចង្វាយទ្វារមាស
- ក្របីគីបីក្រ ក្រូចពីដេកក្នុងភក់ ក្រូចពីនឹម ក្រូចពីសត្វតិរិច្ឆាន
- ១២តាងម្តាយ ២១តាងឪពុក ស្រាយរឿងតាមទំនុកឃើញព្យញ្ជនៈ៣៣
- បើមើលទៅថ្មឃើញរឿងដំរី មើលប្រាសាទលើដីផ្លុះផ្កាយលើមេឃ
- ទឹកចិត្តហូរចេញពីទ្រូង ទឹកដូងដក់នៅក្នុងផ្លែ ទឹកចិត្តឪម៉ែជាព្រហ្មដណ្តប់លើកូន
- បើស្គាល់ឈ្មោះជាតិត្រឹមខ្មែរ ពូជម៉ែត្រូវខ្ទេចខ្ទីឲ្យរលួយ
- បើស្គាល់ឈ្មោះជាតិក្មេរខ្មែរ ត្រូវស្គាល់ពូជនាគ ពូជព្រហ្ម ពូជផ្កាយពូជអច្ឆរិយ
- ដូនតាប្រតិស្ឋានទុកស្នាមព្រះបាទ កូននាគសង្វាតលាងតែខ្នងជើង
- ១២តាងទឹកឲ្យទូកអណ្តែត ដី២១មួយជាហេតុ ឲ្យមនុស្សសត្វធម្មជាតិអាស្រ័យនៅ
- មានឈ្មោះជាកែវតែកប់ក្នុងដី ផ្លែស្លឹកផ្កាប្រពៃឈ្មោះតាមតម្រា

នេះគ្រាន់តែជាការសាកល្បង តាក់តែងជាសុភាសិត សម្រាប់ទុកជាគតិពិចារណា ទៅលើមរតកដូនតា ដែលពួកគាត់សុទ្ធតែជាអ្នកប្រាជ្ញ បណ្ឌិត ហើយពួកគាត់បានបន្ទោរនៅកាកគំនិតទាំងនេះ ទុកឲ្យយើងស្រាយ ដើម្បីជាក្បួនអប់រំទូន្មានចិត្ត ឲ្យក្លាយជាពូជ នាគ ផ្កាយ ព្រហ្ម អច្ឆរិយ....។

ម្ដាយជាទូទៅប្រសូត្របុត្រយ៉ាងយូរ ឈឺពោះឆ្លងទន្លេរយៈពេល៧ថ្ងៃ ទើបសម្រាលបុត្រ គឺមានតែមាតាព្រះសីវលីទេ ដែលលោកត្រូវរងការឈឺចាប់ ជាប់នៅក្នុងផ្ទៃ ៧ឆ្នាំ ៧ខែ ៧ថ្ងៃទើបប្រសូត្រ។ ចំណែកឯមាតាមហានគរវិញ ខ្ញុំបាទត្រូវប្រសូត្រគាត់ និងប្រវត្តិរឿងរបស់គាត់ចេញពីទ្វារមាស(យោនី) ដែលគាត់ទូលនៅលើក្បាល ត្រូវប្រើរយៈពេលជាង១២ឆ្នាំ ទើបគាត់អាចរួចពីទោសនេះបាន។ ពីឆ្នាំ១៩៩៨មកដល់ឆ្នាំ២០០០ គ្រាន់តែស្រាវជ្រាវ រកប្រវត្តិសាវតាដូនចាស់ម្នាក់ ដែលខ្ញុំបានជួបគាត់ក្នុងសុបិន្តនោះ ព្រោះគាត់ជាអ្នកទោស ត្រូវគេហាមមិនឲ្យងូតទឹកអស់រយពេល១៩៩៨ឆ្នាំ គឺពីឆ្នាំដែលបានជួបគាត់ ប្រើរយពេលស្វែងរក ប្រវត្តិសាវតាដូនចាស់នេះ អស់រយពេលជាង២ឆ្នាំ។ ពេលវេលាដែលត្រូវបើកទ្វារឃុំទាំង៤គឺ **លើកទី១** ថ្ងៃព្រហស្បតិ៍ ១៥រោច ខែភទ្របទ ឆ្នាំរោង ព.ស ២៥៤៤ ត្រូវនឹងថ្ងៃ២៨កញ្ញា ឆ្នាំ២០០០ **លើកទី២** ថ្ងៃពុធ ១២រោច ខែបុស្ស ឆ្នាំមមី ព.ស២៥៤៦ ត្រូវនឹងថ្ងៃទី២៩មករា ឆ្នាំ២០០៣ **លើកទី៣** ថ្ងៃអាទិត្យ ១៥កើត ខែមិគសិរ ឆ្នាំវក ព.ស២៥៤៨ ត្រូវនឹងថ្ងៃទី២៦ធ្នូ ឆ្នាំ២០០៤ **លើកទី៤** ថ្ងៃព្រហស្បតិ៍ ១កើត ខែជេស្ឋ ឆ្នាំថោះ ព.ស២៥៥៥ ត្រូវនឹងថ្ងៃ២ មិថុនា ឆ្នាំ២០១១។ ក្នុងទ្វារចុងក្រោយនេះ ការទន្ទឹងរងចាំ ដែលខ្ញុំបាទបានសន្យាជាមួយនឹងគាត់ កាលពីជួបលើកដំបូង ថានឹងជួយដោះលែងគាត់ឲ្យបានរួចពីទោស ពេលវេលាបានពន្យាជាង១២ឆ្នាំ ចុងក្រោយទើបបានឮសម្លេងដូនចាស់នេះ ពោលប្រាប់ខ្ញុំថា ម៉ែអស់កម្មពៀរហើយកូន ម៉ែត្រូវទៅសោយសម្បត្តិទេវលោកហើយ ពាក្យមួយម៉ាត់នេះ ខ្ញុំត្រូវប្រើរយពេលជាង១២ឆ្នាំ ដើម្បីប្រសូត្រគាត់ឲ្យរួចពីទីទុក្ខ នេះជាកិច្ចដែលខ្ញុំបានបំពេញ ក្នុងនាមជាកូនខ្មែរម្នាក់។

ដូច្នេះភាគទី៤នេះ ខ្ញុំបាទមិនអាចមិនសរសេរគឺមិនបាន ព្រោះខ្ញុំចង់ឲ្យកូននាគទូទាំងមាតុភូមិនេះ ទាំងក្នុងទឹកដីបច្ចុប្បន្ន និងក្នុងអតីតឲ្យបានដឹងថា ម្ចាស់មរតកអច្ឆរិយនេះ លោកបានសោយនៅក្នុងទុក្ខជាង២០០០ឆ្នាំ ព្រោះហេតុតែមាតុភូមិ ដែលជាកេរមរតករបស់លោកនេះ លោកក៏បានរួចផុតពីទោស សព្វថ្ងៃកំពុងសោយផលសុខ រួមទាំងញាតិវង្សរបស់លោក ដែលមាននិស្ស័យត្រេកអរបុណ្យជាមួយនឹងខ្ញុំ។ ខ្ញុំបាទក៏សូមអភ័យទោសដល់ញាតិទាំងអស់ ចំពោះការ

ស្រាវជ្រាវ និងចងក្រងទាំង៤ភាគនេះ ហាមមិនឲ្យយកទៅថតចម្លង បោះពុម្ពធ្វើអាជីកម្ម ឡើយ ព្រោះខ្ញុំបាទខិតខំបំពេញកិច្ចនេះ គឺដើម្បីប្រយោជន៍ពូជនាគទាំងអស់។

ជាទីបញ្ចប់ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមអភ័យទោសគ្រប់សំណាក់ញាតិអ្នកអាន ទាំងបព្វជិត និងគ្រហស្ថនូវរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានក្នុងស្នាដៃ ខ្ញុំបាទបានស្រាវជ្រាវទាំង៤ភាគ នេះ។ ខ្ញុំព្រះករុណាខ្ញុំបាទ សូមប្រគេនបុណ្យ ជូនបុណ្យ ឧទ្ទិសបុណ្យដែលខំប្រឹងប្រែងមួយ ជីវិត ដើម្បីស្វះស្វែងរកនូវយុត្តិធម៌ ជូនដល់ដូនតាម្ចាស់នគរនេះ សូមឲ្យមហាកុសលនេះ កើតមាន ដល់ព្រះគុណម្ចាស់គ្រប់ព្រះអង្គ លោកឪពុកអ្នកម្តាយ ដែលលោកបានបង្កើតរូបខ្ញុំ ឲ្យខ្ញុំបាននូវ បំពេញកិច្ចនេះ និងញាតិធម៌ ដែលសុទ្ធតែជាអ្នកមានឧបការគុណទាំងអស់ និងសព្វសត្វទាំងអស់ ក្នុងទិសទាំង១០ ដែលសុទ្ធតែជាញាតិរបស់ខ្ញុំក្នុងសង្សារវដ្ត គ្រប់កាលទាំងបីឲ្យបានរួចផុតចាក ទុក្ខ សូមឲ្យជួបតែពរទាំងឡាយ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ ហើយនឹងអាច ត្រាស់ដឹងនូវសច្ចៈធម៌ ក្នុងកាលជាអនាគត កុំបីក្លាយជាប្រការដទៃឡើយ។

ខេត្តព្រះសីហនុថ្ងៃអាទិត្យ**៤**កើត ខែទុតិយាសាឍ ឆ្នាំរោង ចត្វាស័ក ព.ស**២៥៥៦**
ត្រូវនឹងថ្ងៃទី**២២** ខែកក្កដា ឆ្នាំ**២០១២**

ការខិតខំស្រាវជ្រាវនេះ សូមរក្សាសិទ្ធិទាំងស្រុង

ពីខ្ញុំករុណាខ្ញុំបាទឧបាសក **គៀត ចាន់ផុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ **គៀត ចាន់ផុន**